# ព្រះត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ៤៩

បាលីប្រែ ៦០

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# ជាតកដ្ឋកថា

## សេចក្ដីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ  ជាតក

## នវមភាគ

# ៤៩

# បាលីប្រែ  ៦០



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៤៣*

# ក្បាលទី ៤៩

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ជាតក

# នវមភាគ

# បកិណ្ណកនិបាត ជាតក

# សាលិកេទារជាតក

[ ១ ] ( បុរសអ្នករក្សាស្រែពោលថា ) បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែបរិបូណ៌ដែរ តែពួកសេកតែងស៊ី បពិត្រព្រហ្ម ខ្ញុំសូមជម្រាបលោក ខ្ញុំមិនអាចហាមឃាត់សេកទាំងនោះបានឡើយ បណ្ដាសេកទាំងនោះ មានសេកមួយដែលល្អដោយចំណែកទាំងពួងជាងសេកទាំងនោះ ស៊ីនូវស្រូវសាលីតាមសេចក្ដីប្រាថ្នារួចហើយ ក៏ពាំស្រូវដោយចំពុះហើរទៅទៀត ។

[ ២ ] ( សាលិទ្ទិយព្រាហ្មណ៍កោសិយគោត្តពោលថា ) ជនទាំងឡាយ ចូរដាក់អន្ទាក់ធ្វើដោយកន្ទុយសត្វ បក្សីនោះនឹងជាប់ ចូរអ្នកចាប់វាទាំងរស់ នាំមកក្នុងសំណាក់នៃអញ ។

[ ៣ ] ( ស្ដេចសេកពោលថា ) បក្សីទាំងនុ៎ះ ស៊ីផងផឹកផង ហើយហើរចេញទៅ អាត្មាអញម្នាក់ឯងជាប់អន្ទាក់ហើយ អាត្មាអញធ្វើហើយនូវអំពើលាមកដូចម្ដេច ។

[ ៤ ] ( ព្រាហ្មណ៍... ) ម្នាលសេក ពោះសេកទាំងឡាយដទៃ ( ជាពោះតូចល្មម ) ដោយពិត ( ចំណែកខាងពោះ ) របស់អ្នក ជាពោះធំជ្រុល

ពេក បានជាអ្នកស៊ីស្រូវសាលីតាមសេចក្ដីប្រាថ្នារួចហើយ ក៏ពាំយកស្រូវដោយចំពុះហើរទៅ ។ ម្នាលសេក អ្នកបំពេញជង្រុកក្នុងព្រៃរកានោះឬ ឬក៏អ្នកចងពៀរនឹងយើង ម្នាលសម្លាញ់ យើងសួរហើយ អ្នកចូរប្រាប់ អ្នកកប់ស្រូវសាលីទុកក្នុងទីណា ។

[ ៥ ] ( ស្ដេចសេក... ) ខ្ញុំមិនចងពៀរជាមួយនឹងអ្នកទេ ជង្រុករបស់ខ្ញុំក៏មិនមានដែរ ខ្ញុំដោះបំណុលផង ឲ្យបុលផង ខ្ញុំហើរទៅដល់ចុងរកា ក៏កប់កំណប់ទុក ក្នុងព្រៃរកានោះ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះចុះ ។

[ ៦ ] ( ព្រាហ្មណ៍... ) ការឲ្យបុលរបស់អ្នកដូចម្ដេច ការដោះបំណុលដូចម្ដេច អ្នកចូរប្រាប់នូវការកប់កំណប់ កាលបើដូច្នោះ អ្នកនឹងរួចចាកអន្ទាក់ ។

[ ៧ ] ( ស្ដេចសេក... ) បពិត្រកោសិយៈ ខ្ញុំមានកូនតូចៗមិនទាន់ដុះស្លាបនៅឡើយ កូនតូចទាំងឡាយនោះ ដែលខ្ញុំចិញ្ចឹមហើយ នឹងចិញ្ចឹមខ្ញុំវិញ ហេតុនោះ ខ្ញុំត្រូវឲ្យបុល ដល់កូនតូចៗទាំងនោះ ។ ម្យ៉ាងទៀត ខ្ញុំមានមាតាបិតាចាស់គ្រាំគ្រា មានវ័យកន្លងហើយ ខ្ញុំពាំ ( នូវស្រូវសាលី ) ដោយចំពុះ យកទៅជូនមាតាបិតាទាំងនោះ ខ្ញុំត្រូវដោះបំណុលដែលគាត់ធ្វើហើយមុន ។ ក្នុងព្រៃរកានោះ មានបក្សីទាំងឡាយដទៃទៀត ដែលជ្រុះស្លាបអស់ហើយ ថមថយកម្លាំង ខ្ញុំត្រូវការដោយបុណ្យ ក៏ឲ្យដល់បក្សីទាំងនោះ បណ្ឌិតទាំងឡាយពោលថា បុញ្ញកម្មនោះ ជាកំណប់ ។ ការឲ្យបុលរបស់ខ្ញុំយ៉ាងនេះ ការដោះបំណុលរបស់ខ្ញុំយ៉ាងនេះ ខ្ញុំប្រាប់នូវការកប់កំណប់ បពិត្រ

កោសិយៈ អ្នកចូរជ្រាបយ៉ាងនេះ ។

[ ៨ ] ( ព្រាហ្មណ៍... ) បក្សីមានកំណើតពីរដងនេះ ប្រសើរណាស់តើ ជាសត្វប្រកបដោយធម៌ដ៏ក្រៃលែង មនុស្សពួកខ្លះ មិនមានធម៌នេះទេ អ្នកចូរបរិភោគនូវស្រូវសាលីជាមួយនឹងពួកញាតិទាំងអស់ តាមប្រាថ្នាចុះ ម្នាលសេក សូមឲ្យយើងឃើញអ្នកទៀត ដ្បិតការបានជួបប្រទះនឹងអ្នក ( នេះ ) ជាទីស្រឡាញ់របស់យើង ។

[ ៩ ] ( ស្តេចសេក... ) បពិត្រកោសិយៈ ខ្ញុំបានបរិភោគផង ផឹកផង ក្នុងលំនៅអ្នករួចហើយ ខ្ញុំមិនអាចនឹងនៅក្នុងសំណាក់នៃអ្នកអស់រាត្រីមួយទេ អ្នកចូរឲ្យទាន ( ចំពោះសមណព្រាហ្មណ៍ដែលមានអាជ្ញាដាក់ចុះហើយផង ) ចូរចិញ្ចឹមមាតាបិតាដែលចាស់គ្រាំគ្រាផង ។

[ ១០ ] ( ព្រាហ្មណ៍... ) លក្ខី ( សិរី បុណ្យ និងប្រាជ្ញា ) បានកើតឡើងហើយដល់យើងក្នុងថ្ងៃនេះ ដ្បិតយើងបានជួបនឹងស្តេចសេកដ៏ប្រសើរជាងពួកបក្សីទាំងឡាយ យើងនឹងធ្វើបុណ្យឲ្យច្រើន ព្រោះបានស្តាប់នូវសុភាសិតរបស់សេក ។

[ ១១ ] ( អភិសម្ពុទ្ធគាថា ) សាលិទ្ទិយព្រាហ្មណ៍ ជាកោសិយគោត្តនោះ មានចិត្តរីករាយ មានចិត្តខ្ពស់ឯក មានចិត្តជ្រះថ្លា បានចាត់ចែងនូវបាយនិងទឹក ហើយញ៉ាំងសមណៈ និងព្រាហ្មណ៍ទាំងឡាយ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។

**ចប់ សាលិកេទារជាតកទី ១ ។**

# បកិណ្ណកនិបាត ជាតក

## អដ្ឋកថា សាលិកេទារជាតក

[ ១-១១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សម្បន្នំ សាលិកេទារំ** ដូច្នេះជាដើម ។

ផ្ទៃរឿងនឹងមានច្បាស់ក្នុងសាមជាតក ( សុវណ្ណសាមជាតក ) ។ ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុនោះមកសួរថា ម្នាលភិក្ខុ បានឮថា អ្នកចិញ្ចឹមគ្រហស្ថឬ កាលភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ ពិតហើយ ព្រះសាស្តាក៏ត្រាស់សួរថា គ្រហស្ថទាំងនោះជាអ្វីរបស់អ្នក កាលភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ ជាញោមស្រី ញោមប្រុសរបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា សាធុភិក្ខុ ទោះបីបណ្ឌិតក្នុងកាលមុន ជាសត្វតិរច្ឆាន កើតក្នុងកំណើតបក្សី ក៏ឲ្យមេនិងបាដែលចាស់ហើយ ដេកក្នុងសម្បុក ហើយពាំអាហារមកដោយចំពុះចិញ្ចឹមបាន ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទមគធរាជ សោយរាជសម្បត្តិក្នុងនគររាជគ្រឹះ ។ កាលនោះ នាទិសឦសានព្រះនគរ មានស្រុកព្រាហ្មណ៍ឈ្មោះថា សាលិន្ទិយៈ ។ ក្នុងទិសឦសាននៃស្រុកនោះ ជាស្រែចម្ការរបស់អ្នកមគធៈ ។ ក្នុងទីនោះ ព្រាហ្មណ៍កោសិយគោត្ត អ្នកសាលិន្ទិយៈ កាប់ស្រែទុកប្រមាណ ១ ពាន់ករីសៈ ហើយព្រោះស្រូវសាលី ។ កាលសន្ទូងដុះឡើងហើយ ព្រាហ្មណ៍ឲ្យ

មនុស្សធ្វើរបងយ៉ាងរឹងប៉ឹង ចែកឲ្យបរិស័ទរបស់ខ្លួននោះឯង មើលថែរក្សា អ្នកខ្លះ ៥០ ករីសៈ អ្នកខ្លះ ៦០ ករីសៈ រហូតអស់ប្រមាណ ៥០០ ករីសៈ ចំណែកដ៏សេស ៥០០ ករីសៈទៀត ព័ទ្ធរបងឲ្យអ្នកស៊ីឈ្នួលម្នាក់ មើលថែរក្សា ។ កូនឈ្នួលសង់ខ្ទមត្រង់នោះ នៅជាប្រចាំ ទាំងពេលយប់និងពេលថ្ងៃ ។ ក្នុងទិសឦសាននៃស្រែនោះ មានព្រៃរកាធំនៅត្រង់ភ្នំដែលមានកំពូលរាបស្មើមួយ ហ្វូងសេកច្រើនរយ នាំគ្នាអាស្រ័យនៅក្នុងព្រៃរកានោះ ។ កាលនោះ ព្រះពោធិសត្វសោយព្រះជាតិជាកូនរបស់ស្ដេចសេក នៅក្នុងហ្វូងសេកទាំងនោះ កាលធំចម្រើនវ័យហើយ មានរូបស្អាតសម្បូរដោយកម្លាំង មានរាងកាយធំប៉ុនដុំរទេះ ។ លុះដល់បិតាចាស់ បិតារបស់សេកបានប្រគល់ភាពជាស្ដេចឲ្យ ដោយពាក្យថា ឥឡូវនេះ យើងមិនអាចហើរទៅឆ្ងាយបាន ចូរបាគ្រប់គ្រងហ្វូងបក្សីទាំងនេះចុះ ។ លុះស្អែកឡើង សេកនោះក៏មិនឲ្យមាតាបិតាហើរទៅរកស៊ី កាលបានគ្រប់គ្រងហ្វូងសេក ក៏ទៅកាន់ព្រៃហិមពាន្ត ចឹកស៊ីស្រូវសាលី ក្នុងព្រៃស្រូវសាលីដែលកើតឯង រហូតដល់ឆ្អែត ក្នុងពេលត្រឡប់មក ក៏ពាំអាហារដែលគ្រប់គ្រាន់ដល់មាតាបិតា ចិញ្ចឹមបក្សីទាំងពីរ ។ ថ្ងៃមួយ ពួកសេកនាំគ្នាប្រាប់ថា កាលមុនក្នុងរយៈកាលនេះ មនុស្សធ្លាប់ព្រោះស្រូវសាលីក្នុងស្រែដែនមគធៈ ឥឡូវនេះ នៅតែធ្វើឬដូចម្ដេចហ្ន៎ ។ ស្ដេចសេកប្រើសេកពីរទៅថា បើដូច្នោះចូរឯងទៅស៊ើបមើល ។ សេកទាំងពីរហើរទៅ កាលចុះក្នុងមគធខេត្ត ទៅចុះក្នុងស្រែដែលកូនឈ្នួលនោះយាម ចឹកស៊ីស្រូវសាលី ហើយពាំកួរស្រូវមួយគួ ហើរត្រឡប់មកកាន់ព្រៃរកា ដាក់

កូរស្រូវសាលីទៀបដើងមហាសត្វពោលថា ក្នុងទីនោះ មានស្រូវសាលីបែប
នេះ ។ ស្អែកឡើងស្តេចសេក ហោមរោមដោយពួកសេកហើរទៅក្នុងទីនោះ
ចុះក្នុងស្រែរបស់កូនឈ្នួលនោះ ។ ចំណែកបុរសនោះ ឃើញសេកទាំងឡាយ
នាំគ្នាចឹកស៊ីស្រូវសាលី ទោះបីរត់ត្រឡប់ទៅត្រឡប់មក ដើម្បីឃាត់ ក៏មិន
អាចឃាត់បាន ។ សត្វសេកដ៏សេសនាំគ្នាចឹកស៊ីកូរស្រូវសាលី មួយចម្អែត
ក៏នាំគ្នាហើរទៅមាត់ទទេទាំងអស់ តែស្តេចសេក ប្រមូលកូរស្រូវបញ្ចូលគ្នា
ពាំដោយចំពុះមកឲ្យដល់មាតាបិតា ។ ហ្វូងសេកចាប់ពីថ្ងៃរះឡើង ក៏នាំគ្នាចឹក
ស៊ីស្រូវសាលីក្នុងទីនោះតែមួយកន្លែង ។ កាលនោះបុរសនោះ ឃើញហ្វូង
សេក កំពុងចុះស៊ីស្រូវសាលី ក៏រត់ទៅរត់មកដើម្បីដេញ តែមិនអាចឃាត់
បាន ទើបគិតថា បើសេកទាំងនេះនាំគ្នាចុះស៊ីយ៉ាងនេះ ២-៣ ថ្ងៃប៉ុណ្ណោះ
ក៏មិនមានស្រូវសាលីនៅសល់តិចតួច ព្រាហ្មណ៍នឹងវាយតម្លៃ ធ្វើឲ្យអញក្លាយ
ជាអ្នកសងបំណុលក៏បាន អញត្រូវទៅប្រាប់ដល់គាត់ ។ កាលកាន់យកបណ្ណា
ការ តាមមានតាមបាន ជាមួយកណ្តាប់ស្រូវសាលី ឆ្ពោះទៅកាន់សាលិន្ទិយ
គាម ជួបព្រាហ្មណ៍សំពះហើយឲ្យបណ្ណាការ ឈរក្នុងចំណែកម្ខាង កាល
ព្រាហ្មណ៍សួរថា នែបា ស្រែស្រូវសាលីសម្បូរល្អឬ ក៏ឆ្លើយថា បពិត្រ
ព្រាហ្មណ៍ ស្រូវសម្បូរល្អ ហើយពោលគាថា ២ ថា

បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែបរិបូណ៌ដែរ តែពួកសេក
តែងស៊ី បពិត្រព្រហ្ម ខ្ញុំសូមជម្រាបលោក ខ្ញុំមិនអាចហាម
ឃាត់សេកទាំងនោះបានឡើយ បណ្តាសេកទាំងនោះ មាន

សេកមួយដែលល្អដោយចំណែកទាំងពួង ជាងសេកទាំងនោះ
ស៊ីនូវស្រូវសាលី តាមសេចក្តីប្រាថ្នារួចហើយក៏ពាំស្រូវដោយ
ចំពុះ ហើរទៅទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្បន្នំ** សេចក្តីថា សម្បូរ គឺមិនខ្វះខាតឡើយ ។ បទថា **សាលិកេទារំ** បានដល់ ស្រែនៃស្រូវសាលី ។ បទថា **សព្វសុន្ទរោ** សេចក្តីថា សេកនោះស្អាតគ្រប់ចំណែក ចំពុះក្រហម ភ្នែកមានពន្លឺ ដូចផ្លែទំពាំងបាយជូរ មានជើងក្រហម មានផ្នត់កពណ៌ក្រហម ព័ទ្ធជុំវិញក ៣ ជាន់ ទំហំប៉ុនក្អែក ស៊ីស្រូវសាលីឆ្អែតហើយ ពាំយកទៅដោយចំពុះទៀត ។

ព្រាហ្មណ៍ស្តាប់ពាក្យរបស់អ្នកចាំស្រែនោះ កើតសេចក្តីស្រឡាញ់ ក្នុងសត្វសេក សួរអ្នកយាមស្រែថា នែបា ឯងចេះដាក់អន្ទាក់ដែរឬទេ បុរសនោះឆ្លើយថា ខ្ញុំចេះ ព្រាហ្មណ៍ពោលគាថាជាមួយបុរសនោះថា

ជនទាំងឡាយ ចូរដាក់អន្ទាក់ធ្វើដោយកន្ទុយសត្វ បក្សីនោះ
នឹងជាប់ ចូរអ្នកចាប់វាទាំងរស់ នាំមកក្នុងសំណាក់នៃអញ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧឌ្ឌេន្តុ** បានដល់ ចូរដាក់ ( អន្ទាក់ ) ។ បទថា **វាលបាសានិ** បានដល់ អន្ទាក់ដែលធ្វើដោយខ្សែ មានរោមកន្ទុយសេះជាដើម ។ បទថា **ជីវញ្ច នំ** សេចក្តីថា ចូរចាប់សេកនោះទាំងរស់ ។ បទថា **អានយេហិ** បានដល់ ចូរនាំមកឲ្យ ( យើង ) ។

អ្នកយាមស្រែស្ដាប់ពាក្យនោះហើយ ត្រេកអរ ព្រោះព្រាហ្មណ៍មិនបាន វាយតម្លៃឲ្យខ្លួនសង ប្រញាប់ទៅធ្វើអន្ទាក់ដោយរោមកន្ទុយសេះ កំណត់មើល ទីចុះរបស់ស្ដេចសេកថា ថ្ងៃនេះត្រូវចុះត្រង់នេះ ស្អែកឡើងមិនធ្វើកង្ហារ ( ឧបករណ៍ដេញបក្សី ) ដាក់ទន្ទាក់អំពីព្រលឹម ទន្ទឹងការមករបស់សេក អង្គុយក្នុងខ្ទម ។ ចំណែកស្ដេចសេក ចោមរោមដោយពួកសេកហើរមក ចុះក្នុងទីរកស៊ីកាលពីម្សិលមិញ ព្រោះមិនឡេះឡោះ ជើងគ្រាន់តែចូលទៅក្នុងរង្វង់អន្ទាក់ ក៏ជាប់អន្ទាក់ ។ ស្ដេចសេកនោះដឹងភាពដែលខ្លួនជាប់អន្ទាក់ ហើយគិតថា បើអញស្រែកក្នុងពេលនេះ ញាតិរបស់អញនឹងត្រូវនាំគ្នាខ្លាចស្លាប់ មិនរកស៊ីហើរគេចទៅ អញត្រូវអត់សង្កត់ ទម្រាំញាតិទាំងនោះ រកស៊ីឆ្អែតស្កប់ស្កល់ កាលដឹងថាសេកទាំងនោះស៊ីស្កប់ស្កល់ហើយ ត្រូវសេចក្ដីខ្លាចស្លាប់គំរាម ទើបស្រែកបីដង ។ កាលនោះ សេកទាំងពួង បានឮហើយ នាំគ្នាហើរទៅអស់ ស្ដេចសេកកាលខ្សឹកខ្សួលថា បណ្ដាញាតិរបស់អញត្រឹមតែម្នាក់ដែលបែរមើល មិនមានឡើយ អញធ្វើបាបកម្មអ្វីហ្ន៎ ក៏ពោលគាថាដូច្នេះថា

> បក្សីទាំងនុ៎ះ ស៊ីផង ផឹកផង ហើយហើរចេញទៅ អាត្មាអញ
> ម្នាក់ឯង ជាប់អន្ទាក់ហើយ អាត្មាអញធ្វើហើយនូវអំពើលាមក
> ដូចម្ដេច ដូច្នេះ ។

អ្នកយាមស្រែ បានឮសំឡេងយំរបស់សេក និងសំឡេងហ្វូងបក្សីដែលហើរទៅក្នុងអាកាសត្រិះរិះថា នេះជាអ្វីហ្ន៎ ទើបចុះអំពីខ្ទមទៅមើលអន្ទាក់ បាន

ឃើញស្តេចសេកត្រេកអរថា អញជាក់អន្ទាក់សេកណា សេកដែលអញត្រូវការនោះ ក៏ជាប់អន្ទាក់ហើយ ដោះសេកអំពីអន្ទាក់ ចងជើងទាំងពីរជាប់គ្នាយ៉ាងណែន នាំទៅកាន់សាលិន្ទិយគាម ឲ្យស្តេចសេកដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍មានសេចក្តីស្រឡាញ់ក្នុងព្រះមហាសត្វ យកដៃទាំងពីរចាប់ទុកយ៉ាងណែន ហើយដាក់លើភ្លៅ កាលសំណេះសំណាលជាមួយស្តេចសេកនោះ ទើបពោលគាថា ២ ថា

ម្នាលសេក ពោះសេកទាំងឡាយដទៃ ( ជាពោះតូចល្មម ) ដោយពិត ( ចំណែកខាងពោះ ) របស់អ្នក ជាពោះធំជ្រុលពេក បានជាអ្នកស៊ីស្រូវសាលីតាមសេចក្តីប្រាថ្នារួចហើយ ក៏ពាំយកស្រូវដោយចំពុះហើរទៅ ។ ម្នាលសេក អ្នកបំពេញជង្រុក ក្នុងព្រៃរកានោះឬ ឬក៏អ្នកចងពៀរនឹងយើង ម្នាលសម្លាញ់ យើងសួរហើយ អ្នកចូរប្រាប់ អ្នកកប់ស្រូវសាលីទុកក្នុងទីណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទរំ នូន** សេចក្តីថា នែបក្សីសេក ពោះរបស់អ្នកប្រហែលជាធំជាងពោះរបស់បក្សីដទៃទេដឹង ។ បទថា **តត្ថ** បានដល់ក្នុងព្រៃរកានោះ ។ បទថា **បូរេសិ** សេចក្តីថា អ្នកបំពេញជង្រុកឲ្យពេញក្នុងរដូវភ្លៀងឬ ។ បទថា **និធីយសិ** សេចក្តីថា អ្នករក្សា គឺកប់ស្រូវសាលីទុក ( ក្នុងទីណា ) ។

ស្តេចសេកបានស្តាប់ដូច្នោះហើយ ទើបពោលគាថាទី ៧ ដ៏ពីរោះដោយ

ភាសាមនុស្សថា

ខ្ញុំមិនចងពៀរជាមួយនឹងអ្នកទេ ជង្រុករបស់ខ្ញុំក៏មិនមានដែរ ខ្ញុំដោះបំណុលផង ឲ្យបុលផង ខ្ញុំហើរទៅដល់ចុងរកា ក៏កប់កំណប់ទុកក្នុងព្រៃរកានោះ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥណំ មុញ្ចាមិណំ ទម្មិ** សេចក្ដីថា ខ្ញុំនាំស្រូវសាលីរបស់អ្នកទៅដោះបំណុលចាស់ផង បុលបំណុលថ្មីផង ។ បទថា **និធឹបិ** សេចក្ដីថា ខ្ញុំកប់កំណប់ទ្រព្យទុកមួយផ្នែកដែលជាគ្រឿងជាប់តាមទៅបាន ក្នុងព្រៃរកានោះ ។ លំដាប់នោះ ព្រាហ្មណ៍ក៏សួរស្ដេចសេកនោះថា

ការឲ្យបុលរបស់អ្នកដូចម្ដេច ការដោះបំណុលដូចម្ដេច អ្នកចូរប្រាប់នូវការកប់កំណប់ កាលបើដូច្នោះ អ្នកនឹងរួចចាកអន្ទាក់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥណទានំ** បានដល់ ការបុលបំណុល ។ បទថា **និធិនិធានំ** សេចក្ដីថា ការកប់កំណប់ទ្រព្យ ។

ស្ដេចសេកត្រូវព្រាហ្មណ៍សួរយ៉ាងនេះហើយ កាលព្យាករណបញ្ហា បានពោលគាថា ៤ ថា

បពិត្រកោសិយៈ ខ្ញុំមានកូនតូចៗ មិនទាន់ដុះស្លាបនៅឡើយ កូនតូចទាំងឡាយនោះ ដែលខ្ញុំចិញ្ចឹមហើយ នឹងចិញ្ចឹមខ្ញុំវិញ ហេតុនោះ ខ្ញុំត្រូវឲ្យបុលដល់កូនតូចៗទាំងនោះ ។ មួយទៀត

*ខ្ញុំមានមាតាបិតាចាស់គ្រាំគ្រា មានវ័យកន្លងហើយ ខ្ញុំពាំ ( នូវស្រូវសាលី ) ដោយចំពុះ យកទៅជូនមាតាបិតាទាំងនោះ ខ្ញុំត្រូវដោះបំណុល ដែលគាត់ធ្វើហើយមុន ៗ ក្នុងព្រៃរកានោះ មានបក្សីទាំងឡាយដទៃទៀត ដែលជ្រុះស្លាបអស់ហើយ ថមថយកម្លាំង ខ្ញុំត្រូវការដោយបុណ្យ ក៏ឲ្យដល់បក្សីទាំងនោះ បណ្ឌិតទាំងឡាយពោលថា បុញ្ញកម្មនោះ ជាកំណប់ ៗ ការឲ្យបុលរបស់ខ្ញុំ យ៉ាងនេះ ការដោះបំណុលរបស់ខ្ញុំ យ៉ាងនេះ ខ្ញុំប្រាប់នូវការកប់កំណប់ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះ ដូច្នេះ ៗ*

*បណ្ដាបទទាំងនោះ បទថា* **ហាតូន** *បានដល់ ពាំទៅហើយ ៗ បទថា* **តំ និធឹ** *សេចក្ដីថា បណ្ឌិតទាំងឡាយពោលបុញ្ញកម្មនោះថា ជាកំណប់ដែលជាប់តាមខ្លួន ៗ បទថា* **និធិនិធានំ** *បានដល់ កប់កំណប់ទ្រព្យទុក បាលីថា* **និធយំ** *ដូច្នេះក៏មាន ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ៗ*

*ព្រាហ្មណ៍ស្ដាប់ធម្មកថារបស់មហាសត្វ មានចិត្តជ្រះថ្លា បានពោលគាថា ២ ថា*

*បក្សីមានកំណើតពីរដងនេះ ប្រសើរណាស់តើ ជាសត្វប្រកបដោយធម៌ដ៏ក្រៃលែង មនុស្សពួកខ្លះ មិនមានធម៌នេះទេ អ្នកចូរបរិភោគនូវស្រូវសាលី ជាមួយនឹងពួកញាតិទាំងអស់តាមប្រាថ្នាចុះ ម្នាលសេក សូមឲ្យយើងឃើញអ្នកទៀត ដ្បិតការ*

បានជួបប្រទះនឹងអ្នក ( នេះ ) ជាទីស្រឡាញ់របស់យើង
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភុញ្ជ សាលឹ** សេចក្ដីថា ព្រាហ្មណ៍កាលប្រគល់ស្រែមួយពាន់ករីសៈឲ្យដល់មហាសត្វនោះឯង ទើបពោលយ៉ាងនេះថា អ្នកចូរបរិភោគនូវស្រូវសាលី ជាមួយនឹងពួកញាតិទាំងអស់ តាមប្រាថ្នាចុះ ដូច្នេះ ។ បទថា **បស្សេមុ** សេចក្ដីថា ពួកយើងគប្បីឃើញអ្នកក្នុងថ្ងៃដទៃតាមគាប់ចិត្តរបស់ខ្លួន ។

ព្រាហ្មណ៍អង្វរព្រះមហាសត្វយ៉ាងនេះហើយ សម្លឹងមើលដោយចិត្តទន់ភ្លន់ ដូចមើលកូនជាទីស្រឡាញ់បណ្ដើរ ស្រាយខ្សែដែលចងត្រង់ជើងបណ្ដើរ លាបជើងទាំងគូដោយប្រេងដែលចម្រាញ់រាប់រយដង ឲ្យទំលើតាំងដ៏ស្អាត ឲ្យបរិភោគលាជលាយដោយទឹកឃ្មុំក្នុងចានមាស ឲ្យផឹកទឹកដែលលាយដោយស្ករក្រាម ។ កាលស្ដេចសេកពោលថា បពិត្រមហាព្រាហ្មណ៍ ចូរអ្នកកុំប្រមាទ កាលឲ្យឱវាទដល់ព្រាហ្មណ៍ ក៏ពោលថា

> បពិត្រកោសិយៈ ខ្ញុំបានបរិភោគផង ផឹកផង ក្នុងលំនៅអ្នករួច
> ហើយ ខ្ញុំមិនអាចនឹងនៅក្នុងសំណាក់នៃអ្នកអស់រាត្រីមួយទេ
> អ្នកចូរឲ្យទាន ( ចំពោះសមណព្រាហ្មណ៍ ដែលមានអាជ្ញា
> ដាក់ចុះហើយផង ) ចូរចិញ្ចឹមមាតាបិតា ដែលចាស់គ្រាំគ្រា
> ផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តវស្សមម្ហិ** បានដល់ ក្នុងនិវេសន៍របស់អ្នក ។

*បទថា **រតិ** បានដល់ ត្រេកអរក្រៃលែង ។ ព្រាហ្មណ៍បានស្តាប់ដូច្នោះហើយ ត្រេកអរ កាលបន្លឺឧទានទើបពោលគាថាថា*

*លក្ខី ( សិរី បុណ្យ និងប្រាជ្ញា ) បានកើតឡើងហើយដល់ យើងក្នុងថ្ងៃនេះ ដ្បិតយើងបានជួបនឹងស្តេចសេកដ៏ប្រសើរជាង ពួកបក្សីទាំងឡាយ យើងនឹងធ្វើបុណ្យឲ្យច្រើន ព្រោះបានស្តាប់ នូវសុភាសិតរបស់សេក ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា **លក្ខី** បានដល់ សិរីក៏មាន បុណ្យក៏មាន បញ្ញាក៏មាន ។ ព្រះមហាសត្វបានសងស្រែប្រមាណ ១ ពាន់ករីសៈ ដែល ព្រាហ្មណ៍បានឲ្យដល់ខ្លួន ទទួលតែ ៨ ករីសៈប៉ុណ្ណោះ ។ ព្រាហ្មណ៍ក៏ចារឹក បង្គោលប្រគល់ស្រែដល់មហាសត្វ ហើយបូជាដោយគ្រឿងក្រអូប ផ្កាកម្រង ជាដើម សូមខមាទោសស្រេចហើយ បញ្ជូនទៅដោយពាក្យថា សូមអ្នក អញ្ជើញទៅចុះ សូមលួងលោមមាតាបិតា ដែលកំពុងយំឲ្យធូរស្បើយចុះ ។ ស្តេចសេកនោះត្រេកអរ ប្រមូលកួរស្រូវសាលីពាំទៅទុកត្រង់មុខមាតាបិតា បណ្តើរ ពោលបណ្តើរថា បពិត្រមេបា សូមលោកក្រោកឡើងចុះ ។ មាតា បិតាទាំងពីររបស់ស្តេចសេកនោះ នាំគ្នាក្រោកឡើងសើចទាំងទឹកភ្នែក ។ វេលា នោះ ពួកសេកមកប្រជុំគ្នាសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់រួចមក បានដូចម្តេច សេកបាននិទានរឿងទាំងអស់ដល់សេកទាំងនោះដោយពិស្តារ ។ កោសិយព្រាហ្មណ៍ស្តាប់ឱវាទសត្វសេកហើយ ចាប់តាំងអំពីនោះ ក៏តម្កល់ មហាទាន ដល់សមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ ។*

ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះទើបត្រាស់គាថាចុងក្រោយថា

សាលិន្ទិយព្រាហ្មណ៍ ជាកោសិយគោត្តនោះ មានចិត្តរីករាយ

មានចិត្តខ្ពស់ឯក មានចិត្តជ្រះថ្លា បានចាត់ចែងនូវបាយនិងទឹក

ហើយញុំាងសមណៈនិងព្រាហ្មណ៍ទាំងឡាយឲ្យឆ្អែតស្កប់ស្កល់

ដោយបាយនិងទឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តប្បយិ** សេចក្តីថា ដាក់ភាជនៈដែលទទួលទៅហើយឲ្យពេញ អន្លាសឲ្យឆ្អែតស្កប់ស្កល់ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការចិញ្ចឹមមាតាបិតា ជាវង្សរបស់បណ្ឌិតទាំងឡាយដោយប្រការដូច្នេះ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ( ក្នុងកាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ) ហើយទ្រង់ប្រជុំជាតកថា ហ្វូងសេកក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ សេកមេបាក្នុងកាលនោះ បានមកជាត្រកូលមហារាជ អ្នកយាមស្រែក្នុងកាលនោះ បានមកជាឆន្នៈ ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទ ចំណែកស្តេចសេកក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សាលិកេទារជាតក ចប់

# ចន្ទកិន្នរជាតក

[ ១២ ] ( ចន្ទកិន្នរពោលថា ) ម្នាលនាងចន្ទា ជីវិតនេះប្រហែលជាជិតដាច់ហើយ ព្រោះក្រពុលដោយឈាម អញនឹងលះបង់នូវជីវិតក្នុងថ្ងៃនេះឯង ម្នាលនាងចន្ទា ជីវិតរបស់អញនឹងរលត់ ។ ជីវិតរបស់អញ ជាទុក្ខពៀបចុះហើយ ហឫទ័យរបស់អញក្តៅណាស់ អញលំបាកក្រៃពេក ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ អញនឹងស្វិតស្រពោន ដូចជាស្មៅ ( ដែលគេដាក់លើថ្មក្តៅ ) ដូចជាដើមឈើ ( ដែលកាត់ផ្តាច់ឫសហើយ ) អញនឹងរីងស្ងួតដូចជាស្ទឹងដែលមានទឹកមិនពេញព្រោះនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ ទឹកភ្នែកទាំងឡាយរបស់អញនេះហូរទៅ ដូចជាភ្លៀងក្បែរជើងភ្នំ ហូរទៅ ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃឡើយ ។

[ ១៣ ] ( នាងចន្ទាកិន្នរីពោលផ្តាសាថា ) រាជបុត្តណាបាញ់នូវប្តីដែលអញជាអ្នកកំព្រាប្រាថ្នាហើយ រាជបុត្ត ( នោះ ) អាក្រក់មែន ប្តីរបស់អញនោះ ដែលត្រូវសរមុតហើយ ដេកលើផែនដី ទៀបគល់ឈើ ។ នៃរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណានៃអញ ដែលកំពុងសម្លឹងមើលនូវកិន្នរ សូមមាតារបស់អ្នក បាននូវសេចក្តីសោកក្នុងហឫទ័យដូចអញនេះដែរ ។ នៃរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណារបស់អញ ដែលកំពុងសម្លឹងមើលនូវកិន្នរ សូមប្រពន្ធរបស់អ្នកបាននូវសេចក្តីសោកក្នុងហឫទ័យដូចអញនេះដែរ ។ នៃរាជបុត្ត បុគ្គលណាបានសម្លាប់កិន្នរដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឲ្យម្តាយរបស់អ្នក ( នោះ ) បានឃើញកូនផង សូមកុំឲ្យ

បានឃើញប្តីផង ។ នែរាជបុត្ត អ្នកណាបានសម្លាប់កិន្នរដែលជា សត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឲ្យប្រពន្ធរបស់អ្នកនោះ បានឃើញកូនផង សូមកុំឲ្យបានឃើញប្តីផង ។

[ ១៤ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) ម្នាលនាងចន្ទា មានភ្នែកដូចជាផ្កានៃតិមិរព្រឹក្សក្នុងព្រៃ នាងកុំយំ កុំសោកឡើយ នាងនឹងបានជាអគ្គមហេសីនៃយើង នឹងមាននាងនារីបូជាក្នុងរាជត្រកូល ។

[ ១៥ ] ( កិន្នរី... ) នែរាជបុត្ត អ្នកណាបានសម្លាប់នូវកិន្នរដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ អញស៊ូតែស្លាប់ អញនឹងមិនធ្វើ ( ជាប្រពន្ធ ) របស់អ្នក ( នោះ ) ទេ ។

[ ១៦ ] ( ព្រះរាជា... ) ម្នាលនាងកិន្នរីដែលជាស្រីមានសេចក្តីខ្លាចផង ចង់រស់នៅផង នាងជាមេម្រឹគ មានស្លឹកកំញាននិងស្លឹកក្រស្នា ជាភោជន ចូរនាងទៅកាន់ព្រៃហិមវន្តចុះ ពួកម្រឹគ ដទៃនឹងត្រេកត្រអាលចំពោះនាង ។

[ ១៧ ] ( កិន្នរី... ) ភ្នំទាំងឡាយនោះផង ជ្រោះភ្នំទាំងឡាយនោះផង គុហាភ្នំទាំងឡាយនោះផង បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ យើងទាំងឡាយរមែងត្រេកត្រអាលជាមួយគ្នា លើភ្នំទាំងឡាយណា បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំទាំងឡាយនោះ តើនឹងធ្វើដូចម្តេច ។ ភ្នំទាំងឡាយនោះដេរដាសដោយស្លឹកឈើ គួរឲ្យរីករាយ ដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុង

ទីនោះ តើនឹងធ្វើដូចម្តេច ។ ភ្នំទាំងឡាយនោះ ដេរដាសដោយផ្កាឈើគួរឲ្យរីករាយ ដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ ស្ទឹងលើភ្នំ និងស្ទឹងក្នុងព្រៃទាំងឡាយ មានទឹកដ៏ថ្លា កាលហូរទៅ មានផ្កាឈើអណ្តែតទៅតាមខ្សែទឹកព្រោងព្រាត បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ខៀវ គួរឲ្យរមិលមើល បពិត្រកិន្នរខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌លឿង គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ក្រហម គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានចុងស្រួច គួរឲ្យរមិលមើល បពិត្រកិន្នរខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត ដែលមានពណ៌ស គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្តដ៏វិចិត្រ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកភុម្មទេវតាសេពហើយ ជាភ្នំដេរដាសដោយឱសថទាំងឡាយ តើនឹងធ្វើដូចម្តេច ។ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកកិន្នរសេពហើយ ជាភ្នំដ៏ដេរដាសដោយឱសថទាំងឡាយ តើនឹងធ្វើដូចម្តេច ។

[ ១៨ ] បពិត្រព្រហ្មជាម្ចាស់ ខ្ញុំសូមថ្វាយបង្គំនូវព្រះបាទទាំងឡាយរបស់លោក ព្រោះលោកបានស្រោចប្តីដែលខ្ញុំជាស្រីកំព្រាប្រាថ្នាហើយ ដោយទឹកអម្រឹតដែលជាទីស្រឡាញ់ ដោយវិសេស ក្នុងទីដែលលោកជួបគ្នា ។

[ ១៩ ] ឥឡូវនេះ យើងទាំងឡាយនឹងត្រាច់ទៅកាន់ស្ទឹងក្បែរភ្នំ និងស្ទឹងក្នុងព្រៃទាំងឡាយ ដែលមានផ្កាឈើអណ្តែតទៅតាមខ្សែទឹកព្រោងព្រាតទាំងមានឈើផ្សេងៗដុះហែរវិញ យើងទាំងឡាយនឹងពោលនូវពាក្យជាទីស្រឡាញ់ទៅវិញទៅមក ។

**ចប់ ចន្ទកិន្នរជាតក ទី ២ ។**

# អដ្ឋកថា
# ចន្ទកិន្នរជាតក

[ ១២-១៩ ] ព្រះសាស្តាកាលទ្រង់អាស្រ័យក្រុងកបិលពស្តុ គង់ក្នុងនិ-គ្រោធារាម ទ្រង់ប្រារព្ធរាហុលមាតា ត្រាស់ព្រះធម្មទេសនានេះ ក្នុងព្រះរាជនិវេសន៍ មានពាក្យផ្តើមថា **ឧបនីយតិទំ មញ្ញេ** ដូច្នេះជាដើម ។

មែនពិត ជាតកនេះគួរពោលតាំងអំពីទូរេនិទាន ។ តែនិទានកថានោះរហូតដល់ព្រះឱវាទលកស្សប្រះបទ្ទឹសីហនាទក្នុងលដ្ឋិវន ពោលទុកក្នុងអបណ្ណកជាតក បន្ទាប់អំពីនោះរហូតដល់ទ្រង់យាងទៅកាន់នគរកបិលពស្តុ នឹងមានជាក់ច្បាស់ក្នុងវេស្សន្តរជាតក ។

កាលព្រះសាស្តា គង់ក្នុងនិវេសន៍របស់ពុទ្ធបិតា ក្នុងពេលកំពុងសោយត្រាស់មហាធម្មបាលជាតក សោយស្រេច ទ្រង់ព្រះតម្រិះថា តថាគតនឹងអង្គុយក្នុងនិវេសន៍របស់រាហុលមាតា ពោលគុណរបស់នាង សម្តែងចន្ទ-កិន្នរីជាតក ដូច្នេះហើយ ទើបឲ្យព្រះរាជាកាន់បាត្រ យាងទៅកាន់ទីប្រថាប់របស់រាហុលមាតាជាមួយអគ្គសាវកទាំងពីរ ។ កាលនោះអ្នករបាំ ៤ ម៉ឺននាក់ របស់ព្រះនាងនាំគ្នាបង្ហាញមុខ ។ បណ្តាស្រីទាំងនោះ ជាខត្តិយកញ្ញាមាន ១០៩០ នាក់ ។ ព្រះនាងជ្រាបថា ព្រះតថាគតយាងមកក៏ត្រាស់ប្រាប់ដល់ស្ត្រីទាំងនោះថា ចូរនាំគ្នាស្លៀកសំពត់ជ្រលក់ទឹកចត់គ្រប់គ្នា ។ ស្រីទាំងនោះនាំគ្នាធ្វើយ៉ាងនោះ ព្រះសាស្តាយាងមកគង់លើព្រះទែនដែលត្រៀមទុក ។ កាលស្រីទាំងនោះ នាំគ្នាយំដោយសំឡេងខ្លាំង សំឡេង ក៏កើតមានហើយចំណែករាហុលមាតា ក៏ទ្រង់ព្រះកន្សែង កាលព្រះនាងបន្ទោបង់សេចក្តីសោក

បាន ក៏ថ្វាយបង្គំព្រះសាស្តា ប្រថាប់គង់ដោយសេចក្តីស្និទ្ធស្នាលច្រើន ប្រព្រឹត្តទៅជាមួយសេចក្តីគោរពដែលមានក្នុងព្រះរាជា ។ កាលនោះ ព្រះរាជាទ្រង់ប្រារព្ធគុណកថារបស់ព្រះនាង បានត្រាស់ពណ៌នាគុណ របស់ព្រះនាងដោយប្រការផ្សេងៗថា បពិត្រព្រះអង្គ កូនប្រសាររបស់ញោម បានឮថាទ្រង់ស្លៀកកាសាវពស្ត្រ នាងក៏ស្លៀកសាកាវពស្ត្រដូចគ្នា បានឮថា ទ្រង់វៀរនូវផ្កាកម្រងជាដើម ព្រះនាងក៏វៀរកម្រងផ្កាជាដើមដែរ បានឮថា ទ្រង់មិនផ្ទំលើសេនាសនៈដ៏ប្រសើរ នាងក៏ផ្ទំលើផែនដីដូចគ្នា ក្នុងរយៈកាលដែលទ្រង់សាងផ្នួស នាងជាស្រីមេម៉ាយ មិនទទួលបណ្ណាការពីព្រះរាជាដទៃៗដែលបញ្ជូនមកឲ្យឡើយ នាងមានចិត្តមិនប្រែប្រួលក្នុងទ្រង់ដល់ម្ល៉េះ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ នេះមិនគួរអស្ចារ្យឡើយ ដែលនាងមានសេចក្តីស្រឡាញ់មិនប្រែប្រួលក្នុងតថាគតក្នុងអត្តភាពចុងក្រោយរបស់តថាគតនេះ នាងមិនត្រេកអរក្នុងអ្នកដទៃនោះ សូម្បីកើតក្នុងកំណើតតិរច្ឆាន ក៏គង់មិនមានចិត្តប្រែប្រួលក្នុងតថាគត មិនត្រេកអរក្នុងអ្នកដទៃ ហើយទ្រង់ត្រូវទូលអារាធនាទើបនាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតកិន្នរ ក្នុងហិមវន្តប្បទេស ។ ភរិយារបស់លោកឈ្មោះថាចន្ទា ។ កិន្នរទាំងគូអាស្រ័យត្រង់ភ្នំប្រាក់ឈ្មោះចន្ទបពិត ។ កាលនោះ ព្រះបាទពារាណសីប្រគល់រាជសម្បត្តិដល់ពួកអាមាត្យ ទ្រទ្រង់នូវសំពត់ជ្រលក់ដោយទឹកម្ចត់ពីរផ្ទាំង ទ្រង់សៀតបញ្ចាវុធ ចូលកាន់ព្រៃហិមពាន្ត តែ

មួយព្រះអង្គឯងប៉ុណ្ណោះ ។ ទ្រង់សោយសាច់ ដែលបាញ់បានជាព្រះក្រយាហារ ទ្រង់យាងទៅដល់ស្ទឹងតូចៗមួយខ្សែដោយលំដាប់ ហើយទ្រង់យាងទៅរហូតដល់ប្រភពទឹក ។ ហ្វូងកិន្នរដែលនៅត្រង់ចន្ទបព៌តក្នុងរដូវវស្សា ក៏មិនចុះមក នាំគ្នានៅលើភ្នំនោះឯង លុះដល់រដូវប្រាំងទើបនាំគ្នាចុះមក ។ កាលនោះ ចន្ទកិន្នរចុះមកជាមួយភរិយារបស់ខ្លួន ដើរបេះគ្រឿងក្រអូបក្នុងទីនោះៗ បរិភោគកេសរផ្កា ដណ្តប់ដោយសារាយ និងផ្កាឈើ ជិះវល្លិ៍ធ្វើជាទោងជាដើម លេងបណ្តើរច្រៀងបណ្តើរ ដោយសំឡេងដ៏ពីរោះ រហូតដល់ស្ទឹងតូចមួយខ្សែនោះ ឈប់ត្រង់ព្រៃមួយកន្លែង បាចផ្កាទៅក្នុងទឹក លេងទឹកហើយស្លៀកដណ្តប់សារាយនិងផ្កា រៀបចំទីដេកដោយផ្កាលើថ្មខ្សាច់ ដែលមានពណ៌ដូចប្រាក់ កាន់ខ្លុយមួយអង្គុយលើទីដេក ។ បន្ទាប់អំពីនោះ ចន្ទកិន្នរក៏ផ្លុំខ្លុយដោយសំឡេងដ៏ពីរោះ ចន្ទកិន្នរី ក៏រាំដោយដៃដ៏ទន់ ឈរក្នុងទីជិតប្តីបណ្តើរច្រៀងបណ្តើរ ព្រះរាជាទ្រង់ស្តាប់សំឡេងរបស់កិន្នរញីឈ្មោលនោះក៏ទ្រង់លបចូលទៅសន្សឹមៗ ឈរក្នុងទីកំបាំង ទតឃើញកិន្នរទាំងនោះ ទ្រង់មានចិត្តប្រតិព័ទ្ធក្នុងកិន្នរី ទ្រង់ព្រះតម្រិះថា នឹងបាញ់កិន្នរនោះ ឲ្យអស់ជីវិតសម្រេចការនៅរួមជាមួយកិន្នរីនេះ ហើយទ្រង់ក៏បាញ់កិន្នរ ។ ចន្ទកិន្នរឈឺចាប់ យំរៀបរាប់ពោលគាថា ៤ ថា

ម្នាលនាងចន្ទា ជីវិតនេះ ប្រហែលជាជិតដាច់ហើយ ព្រោះ
ក្រពុលដោយឈាម អញនឹងលះបង់នូវជីវិត ក្នុងថ្ងៃនេះឯង
ម្នាលនាងចន្ទា ជីវិតរបស់អញនឹងរលត់ ។ ជីវិតរបស់អញ

ជាទុក្ខពៀបចុះហើយ ហឫទ័យរបស់អញក្តៅណាស់ អញលំបាកក្រៃពេក ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ អញនឹងស្ងិតស្រពោនដូចជាស្មៅ ( ដែលគេដាក់លើថ្មក្តៅ ) ដូចជាដើមឈើ ( ដែលកាត់ផ្តាច់ឫសហើយ ) អញនឹងរីងស្ងួត ដូចជាស្ទឹងដែលមានទឹកមិនពេញ ព្រោះនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ ទឹកភ្នែកទាំងឡាយរបស់អញនេះហូរទៅ ដូចជាភ្លៀងក្បែរជើងភ្នំហូរទៅ ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែន ព្រោះការសោកដទៃឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបនីយតិ** សេចក្តីថា ជីវិតរបស់អញជិតដាច់ហើយ ។ បទថា **ឥធំ** បានដល់ ការរស់នៅ ។ បទថា **ចាណា** សេចក្តីថា នៃនាងចន្ទា ខ្យល់ដង្ហើម គឺជីវិតរបស់អញជិតរលត់ ។ បទថា **ឱសធិ មេ** សេចក្តីថា ជីវិតរបស់អញរមែងលិចចុះ ។ បទថា **ធិតម្មាមិ** បានដល់ អញលំបាកក្រៃលែង ។ បទថា **តវ ចន្ទិយា** សេចក្តីថា សេចក្តីទុក្ខរបស់អញនេះ មិនមែនសេចក្តីសោកដទៃ ដោយពិត ព្រោះហេតុនៃសេចក្តីសោករបស់នាងចន្ទាដែលកំពុងសោក គឺព្រោះនាងចន្ទាសោយសោកដោយការព្រាត់ប្រាសអំពីអញ ។ បទថា **តិណាមិវ វនមិវ មិលាយាមិ** សេចក្តីថា ចន្ទកិន្នរពោលថា អញក្រៀមស្ងិតដូចស្មៅដែលចោលលើថ្មក្តៅ ដូចព្រៃឈើដែលត្រូវកាត់ឫសដូច្នោះ ។ បទថា **សរេ ចាធេ** សេចក្តីថា ដូចតំណាក់ភ្លៀង

ដែលធ្លាក់លើជើងភ្នំ ហូរទៅមិនដាច់ខ្សែដូច្នោះ ។

ព្រះមហាសត្វខ្សឹកខ្សួលដោយគាថាទាំង ៤ នេះហើយ ដេកដួលលើដំណេកផ្កានោះឯង បម្រះនទៀលបាត់ស្មារតី ចំណែកព្រះរាជាឈរនៅនោះឯង ។ ចន្ទាកិន្នរី កាលព្រះមហាសត្វកំពុងកន្ទក់កន្ទេញ នាងកំពុងក្លើតក្លើនដោយការត្រេកអររបស់ខ្លួន មិនបានដឹងថាព្រះពោធិសត្វត្រូវព្រួញ តែកាលឃើញព្រះពោធិសត្វបាត់ស្មារតី ដេកលើផែនដី ក៏ខ្សឹកខ្សួលថា ទុក្ខរបស់ប្តីជាទីស្រឡាញ់របស់អញដូចម្តេចហ្ន៎ លុះឃើញឈាមហូរចេញអំពីមុខរបួស ក៏មិនអាចអត់សង្កត់សេចក្តីសោកដ៏មានកម្លាំង ដែលកើតក្នុងស្វាមីជាទីស្រឡាញ់បាន ក៏យំដោយសំឡេងខ្លាំង ព្រះរាជាទ្រង់ព្រះតម្រិះថា កិន្នរមុខតែស្លាប់ហើយ ក៏បង្ហាញខ្លួនចេញមក ។ ចន្ទាកិន្នរីឃើញព្រះរាជា រន្ធត់ចិត្តគិតថាចោរនេះជាអ្នកបាញ់ប្តីជាទីស្រឡាញ់របស់អញ ទើបរត់ឡើងទៅលើកំពូលភ្នំ ជេរបរិភាសព្រះរាជា បានពោលគាថា ៥ ដូច្នេះថា

រាជបុត្តណាបាញ់នូវប្តីដែលអញជាអ្នកកំព្រាប្រាថ្នាហើយ រាជបុត្ត ( នោះ ) អាក្រក់មែន ប្តីរបស់អញនោះ ដែលត្រូវសរមុតហើយ ដេកលើផែនដី ទៀបគល់ឈើ ។ នែរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណានៃអញ ដែលកំពុងសម្លឹងមើលនូវកិន្នរ សូមមាតារបស់អ្នកបាននូវសេចក្តីសោកក្នុងហឫទ័យដូចអញនេះដែរ ។ នែរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណារបស់អញ ដែលកំពុងសម្លឹងមើលនូវកិន្នរ សូមប្រពន្ធរបស់

អ្នក បាននូវសេចក្ដីសោកក្នុងហឫទ័យដូចអញនេះដែរ ។ នែរាជបុត្ត បុគ្គលណា បានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឲ្យម្ដាយរបស់អ្នក ( នោះ ) បានឃើញកូនផង សូមកុំឲ្យបានឃើញប្ដីផង ។ នែរាជបុត្ត អ្នកណាបានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឲ្យប្រពន្ធរបស់អ្នកនោះ បានឃើញកូនផង សូមកុំឲ្យបានឃើញប្ដីផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វរាកិយា** បានដល់ ជាបុគ្គលកំព្រា ។ បទថា **បដិមុញ្ចតុ** បានដល់ ចូរត្រឡប់បាន គឺពាល់ត្រូវ ។ បទថា **មយ្ហំ កាមេហិ** បានដល់ ព្រោះសេចក្ដីស្រឡាញ់ក្នុងអញ ។ ព្រះរាជាកាលត្រាស់លួងលោមនាងដែលកំពុងឈរយំលើកំពូលភ្នំ ទើបពោលគាថាថា

ម្នាលនាងចន្ទា មានភ្នែកដូចជាផ្កានៃតិមិរព្រឹក្សក្នុងព្រៃ នាងកុំយំ កុំសោកឡើយ នាងនឹងបានជាអគ្គមហេសីនៃយើង នឹងមាននាងនារីបូជាក្នុងរាជត្រកូល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចន្ទេ** សេចក្ដីថា ព្រោះបានស្ដាប់ឈ្មោះរបស់ព្រះពោធិសត្វពេលយំសោក ទើបត្រាស់យ៉ាងនោះ ។ បទថា **វនតិមិរមត្តក្ខិ** បានដល់ ជាអ្នកមានភ្នែកដូចផ្កាដែលរីកក្នុងពេលយប់ក្នុងព្រៃធំ ។ បទថា **បូជិតា នារីភិ** សេចក្ដីថា នាងនឹងបានជាអគ្គមហេសី ជាប្រធានក្នុងបណ្ដាស្រី ១ ម៉ឺន ៦ ពាន់នាក់ ។ នាងចន្ទាកិន្នរីស្ដាប់ពាក្យរបស់ព្រះ

រាជាហើយពោលថា ទ្រង់ពោលអ្វី កាលនឹងបន្លឺសីហនាទ ទើបពោលគាថាបន្តថា

នែរាជបុត្ត អ្នកណាបានសម្លាប់នូវកិន្នរដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ អញស៊ូតែស្លាប់ អញនឹងមិនធ្វើ ( ជាប្រពន្ធ ) របស់អ្នក ( នោះ ) ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ ឆ្នាហំ** សេចក្តីថា ទោះបីយើងនឹងត្រូវស្លាប់យ៉ាងពិតប្រាកដនោះឯង ។ ព្រះរាជាស្តាប់ពាក្យរបស់កិន្នរីនោះហើយក៏អស់សេចក្តីស្រឡាញ់ ត្រាស់គាថាបន្តថា

ម្នាលនាងកិន្នរី ដែលជាស្រីមានសេចក្តីខ្លាចផង ចង់រស់នៅផង នាងជាមេម្រឹគ មានស្លឹកកំញានទិងស្លឹកក្រស្នាជាភោជន ចូរនាងទៅកាន់ព្រៃហិមវន្តចុះ ពួកម្រឹគដទៃនឹងត្រេកត្រអាលចំពោះនាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ ភីរុកេ** បានដល់ ជាអ្នកមានជាតិខ្លាចក្រៃលែង ។ បទថា **តាលិសតគ្គរភោជនា** សេចក្តីថា ព្រះរាជាត្រាស់នឹងកិន្នរីថា នាងជាម្រឹគបរិភោគស្លឹកក្លាំពាក់[១]និងស្លឹកក្រស្នា ព្រោះហេតុនោះម្រឹគដទៃៗនឹងត្រេកអរចំពោះនាង នាងមិនសមគួរក្នុងរាជត្រកូល ចូរនាងទៅចុះ ។

កាលត្រាស់យ៉ាងនេះហើយ ក៏ចៀសចេញទៅដោយមិនមានជាប់ចំពាក់

---

១-បិដកខ្មែរជាស្លឹកកំញាន ។

នាងជ្រាបថាព្រះរាជាទៅហើយ ក៏ចុះមកឱបមហាសត្វ បីឡើងទៅកាន់កំពូលភ្នំ ឲ្យដេកលើកំពូលភ្នំ យកក្បាលដាក់លើភ្លៅរបស់ខ្លួន យំរៀបរាប់ឲ្យជាកម្លាំង ទើបពោលគាថា ១២ ថា

ភ្នំទាំងឡាយនោះផង ជ្រោះភ្នំទាំងឡាយនោះផង គុហាភ្នំទាំងឡាយនោះផង បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះតើនឹងធ្វើដូចម្តេច ។ យើងទាំងឡាយរមែងត្រេកត្រអាលជាមួយគ្នាលើភ្នំទាំងឡាយណា បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំទាំងឡាយនោះ តើនឹងធ្វើដូចម្តេច ។ ភ្នំទាំងឡាយនោះ ដេរដាសដោយស្លឹកឈើ គួរឲ្យរីករាយ ដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ ភ្នំទាំងឡាយនោះ ដេរដាសដោយផ្កាឈើគួរឲ្យរីករាយដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នក ក្នុងទីនោះតើនឹងធ្វើដូចម្តេច ។ ស្ទឹងលើភ្នំនិងស្ទឹងក្នុងព្រៃទាំងឡាយ មានទឹកដ៏ថ្លា កាលហូរទៅ មានផ្កាឈើអណ្តែតទៅតាមខ្សែទឹកព្រោងព្រាត បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ខៀវ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មាន

ពណ៌លឿង គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ក្រហម គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានចុងស្រួច គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្ត ដែលមានពណ៌ស គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលទាំងឡាយនៃភ្នំហិមវន្តដ៏វិចិត្រ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកកុម្ភទេវតាសេពហើយ ជាភ្នំដេរដាសដោយឱសធទាំងឡាយ តើនឹងធ្វើដូចម្តេច ។ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកកិន្នរសេពហើយ ជាភ្នំដ៏ដេរដាសដោយឱសធទាំងឡាយ តើនឹងធ្វើដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ បព្វតា** សេចក្តីថា កិន្នរីខ្សឹកខ្សួលថា ភ្នំទាំងនោះ ញកភ្នំទាំងនោះ គុហាទាំងនោះដែលយើងធ្លាប់ឡើង ត្រេកអរនឹងគ្នា តាំងនៅក្នុងទីនោះឯង ឥឡូវនេះ កាលខ្ញុំមិនឃើញអ្នកត្រង់ញកភ្នំនោះ នឹងធ្វើដូចម្តេច កាលខ្ញុំមិនឃើញអ្នកលើផ្ទាំងសំពត់ ដែលក្រាលស្អាតទៅ

ដោយស្លឹកឈើ ផ្កាឈើនិងផ្លែឈើជាដើម ខ្ញុំនឹងអត់ធ្មត់បានដូចម្តេច ។ បទថា **បណ្ណសន្ថតា** សេចក្តីថា ដេរដាសដោយក្លិននិងស្លឹករបស់ស្លឹកក្ដាំពាក់ជាដើម ។ បទថា **អច្ឆា** បានដល់ មានទឹកថ្លាស្អាត ។ បទថា **នីលានិ** បានដល់ សម្រេចដោយកែវមណី ។ បទថា **បីតានិ** បានដល់ សម្រេចដោយមាស ។ បទថា **តម្ពានិ** បានដល់ សម្រេចដោយមនោសិលា ។ បទថា **តុង្គានិ** សេចក្តីថា មានកំពូលស្រួចខ្ពស់ ។ បទថា **សេតានិ** បានដល់សម្រេចដោយប្រាក់ ។ បទថា **ចិត្រានិ** បានដល់ លាយដោយរតនៈ ៧ ប្រការ ។ បទថា **យក្ខគណសេវិតេ** សេចក្តីថា ដែលពួកទេវតាសេពហើយ ។

កិន្នរីយំរៀបរាប់ដោយគាថា ១២ ដោយប្រការដូច្នេះហើយ ដាក់ដៃលើទ្រូងមហាសត្វ ដឹងថានៅក្តៅក៏គិតថា កិន្នរនៅមានជីវិតពិត អញត្រូវធ្វើការសម្លឹងទោសទេវតា ឲ្យជីវិតរបស់កិន្នរមកវិញ ហើយបានធ្វើការសម្លឹងទោសរបស់ទេវតាថា ទេវតាដែលបានឈ្មោះថា ទេវលោកបាល មិនមានឬហ្ន៎ ឬគេចទៅអស់ហើយ ឬក៏ស្លាប់អស់ហើយ បានជាមិនថែរក្សាប្តីជាទីស្រឡាញ់របស់យើង ។ ដោយកម្លាំងសេចក្តីសោករបស់នាង សក្កពិភព ក៏ក្តៅ ។ សក្កទេវរាជទ្រង់ជ្រាបហេតុនោះ កាឡាខ្លួនជាព្រាហ្មណ៍ កាន់កុណ្ឌី ទឹកមកប្រោះលើព្រះមហាសត្វ ។ រំពេចនោះឯងពិសក៏វិនាសទៅ មុខរបួសក៏ពេញសម្បុរគែស្នាមដែលអាចថាព្រួញត្រូវត្រង់នេះ ក៏មិនប្រាកដ ។ ព្រះមហាសត្វជាសះស្បើយក្រោកឡើងបាន ។ ចន្ទាកិន្នរីឃើញប្តីប្រាសចាករោគ ត្រេកអរក្រៃលែង ថ្វាយបង្គំទៀបបាទជើងរបស់សក្កៈ ពោលគាថាជាលំដាប់ថា

បពិត្រព្រហ្មជាម្ចាស់ ខ្ញុំសូមថ្វាយបង្គំ នូវព្រះបាទទាំងឡាយ
របស់លោក ព្រោះលោកបានស្រោចប្ដី ដែលខ្ញុំជាស្រីកំព្រា
ប្រាថ្នាហើយ ដោយទឹកអម្រឹត ដែលជាទីស្រឡាញ់ដោយ
វិសេស ក្នុងទីដែលលោកជួបគ្នា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អមតេន** សេចក្ដីថា នាងចន្ទាកិន្នរីសម្គាល់ជាជាទឹកអម្រឹត ទើបពោលយ៉ាងនោះ ។ បទថា **បិយតមេន** បានដល់ គួរស្រឡាញ់ជាង បាលីក៏យ៉ាងនោះដូចគ្នា ។

សក្កទេវរាជ បានប្រទានឱវាទដល់កិន្នរទាំងគូនោះថា តាំងអំពីនេះទៅ អ្នកទាំងពីរកុំចុះអំពីចន្ទបព៌ត ទៅកាន់ដែនដីមនុស្សឡើយ ចូរនាំគ្នានៅក្នុងទីនេះប៉ុណ្ណោះ ផ្ដាំហើយក៏យាងទៅកាន់លំនៅរបស់ទ្រង់វិញ ។

ចំណែកចន្ទាកិន្នរីក៏ពោលថា នែអ្នក ខ្ញុំនឹងត្រូវការអ្វីដោយទីដែលមានភ័យជុំវិញទាំងនេះ មកចុះ យើងនាំគ្នាទៅកាន់ចន្ទបព៌ត ហើយបានពោលអវសានគាថាថា

ឥឡូវនេះ យើងទាំងឡាយនឹងត្រាច់ទៅកាន់ស្ទឹងក្បែរភ្នំ និង
ស្ទឹង ក្នុងព្រៃទាំងឡាយ ដែលមានផ្កាឈើអណ្ដែតទៅតាមខ្សែ
ទឹកព្រោងព្រាត ទាំងមានឈើផ្សេងៗដុះហែវិញ យើងទាំង
ឡាយនឹងពោលនូវពាក្យជាទីស្រឡាញ់ទៅវិញទៅមក ដូច្នេះ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុង

កាលមុននាងក៏មិនបានដកចិត្តឆ្ងាយអំពីតថាគត មិនមែនស្រីដែលអ្នកដទៃនាំទៅបានដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ ចន្ទាកិន្នរីក្នុងកាលនោះ បានមកជារាហុលមាតា ចំណែកចន្ទកិន្នរក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ចន្ទកិន្នរជាតក ចប់

# មហាឧក្កុសជាតក

[ ២០ ] ( ខ្លែងញីពោលថា ) ម្នាលខ្លែងឈ្មោល ពួកអ្នកជនបទចងគប់ភ្លើងទាំងឡាយក្នុងកោះតូចៗ ប្រាថ្នានឹងស៊ីនូវកូនតូចៗរបស់ខ្ញុំ អ្នកចូរហៅនូវមិត្តផង សម្លាញ់ផង អ្នកចូរក្រាបទូលនូវសេចក្តីវិនាសរបស់ពួកបក្សីជាញាតិ ( នៃយើងដល់ស្តេចអកផង ) ។

[ ២១ ] ( ខ្លែងឈ្មោលក៏ទៅក្រាបទូលស្តេចអកថា ) បពិត្រស្តេចអកព្រះអង្គជាទិជជាតិផង ជាបក្សីប្រសើរជាងពួកទិជជាតិផង ខ្ញុំសូមយកព្រះអង្គជាទីពឹង ដ្បិតពួកអ្នកជនបទអាក្រក់ណាស់ ប្រាថ្នានឹងស៊ីកូនតូចៗរបស់ខ្ញុំ សូមព្រះអង្គ ( មេត្តាស្រោចស្រង់ ) ខ្ញុំឲ្យបានសេចក្តីសុខ ។

[ ២២ ] ( ស្តេចអកពោលថា ) បណ្ឌិតទាំងឡាយ ជាអ្នកស្វែងរកសេចក្តីសុខក្នុងកាលគួរនិងកាលមិនគួរ រមែងចងមិត្តផង សម្លាញ់ផង ម្នាលខ្លែងឈ្មោល យើងនឹងធ្វើនូវប្រយោជន៍នុ៎ះ ដល់អ្នកបាន ដ្បិតអរិយជនតែងធ្វើនូវកិច្ចដល់អរិយជន ( ដូចគ្នា ) ។

[ ២៣ ] ( ខ្លែង... ) អំពើណាដែលអរិយជនជាអ្នកអនុគ្រោះគប្បីធ្វើដល់អរិយជន អំពើនោះ ព្រះអង្គបានធ្វើហើយ សូមទ្រង់រក្សានូវព្រះអង្គចុះ សូមទ្រង់កុំក្តៅក្រហាយឡើយ កាលបើព្រះអង្គរស់នៅ យើងគង់នឹងបាននូវកូនទាំងឡាយ ( ទៀត ) ។

[ ២៤ ] ( ស្តេចអក... ) យើងខ្ញុំធ្វើនូវការរក្សានិងកិរិយាការពារនោះឯង ត្រាតែបែកធ្លាយនូវសរីរៈ ក៏មិនតក់ស្លុតដែរ ដ្បិតសម្លាញ់ទាំងឡាយនេះ តែងលះបង់ជីវិត ជួយធ្វើ ( កិច្ចការ ) ដល់សម្លាញ់ផងគ្នា នេះជា

ធម៌របស់សប្បុរសទាំងឡាយ ។

[ ២៥ ] ( អភិសម្ពុទ្ធគាថា ) ស្ដេចអកនេះ ជាសត្វស្លាប កើតអំពីស៊ុត បានធ្វើនូវអំពើដែលគេធ្វើដោយកម្រក្រៃពេក ដើម្បីប្រយោជន៍ ( នឹងរក្សា ) នូវកូនខ្លែងទាំងឡាយ ដរាបដល់ពាក់កណ្ដាលអធ្រាត្រ ។

[ ២៦ ] ( ខ្លែង... ) បុគ្គលពួកខ្លះ ឃ្លាតចាក ( យសឬទ្រព្យ ) ក៏មាន ភ្លាំងភ្លាត់ដោយកម្មរបស់ខ្លួនក៏មាន ហើយត្រឡប់តាំងខ្លួនបាន ដោយសារសេចក្ដីអនុគ្រោះរបស់ពួកមិត្ត កូនទាំងឡាយរបស់ខ្ញុំ មានសេចក្ដីក្ដៅក្រហាយ ខ្ញុំមក ( យកអ្នក ) ជាគតិ ( ទីពឹង ) បពិត្រសត្វត្រាច់ទៅក្នុងទឹក ចូរអ្នកប្រព្រឹត្តប្រយោជន៍ដល់ខ្ញុំ ។

[ ២៧ ] ( អណ្ដើក... ) បណ្ឌិតទាំងឡាយ តែងចងមិត្តនឹងសម្លាញ់ដោយទ្រព្យផង ដោយស្រូវផង ដោយខ្លួនផង ម្នាលខ្លែង យើងនឹងធ្វើប្រយោជន៍នេះដល់អ្នកបាន ដ្បិតអរិយជន តែងធ្វើកិច្ចដល់អរិយជនដូចគ្នា ។

[ ២៨ ] ( កូនអណ្ដើក... ) បពិត្រឪពុក អ្នកចូរជាបុគ្គលមានសេចក្ដីខ្វល់ខ្វាយតិច អង្គុយស្ងៀមចុះ កូនតែងប្រព្រឹត្តប្រយោជន៍ដល់ឪពុក ខ្ញុំនឹងជួយការពារនូវកូនខ្លែង ហើយប្រព្រឹត្តនូវប្រយោជន៍ជំនួសលោក ។

[ ២៩ ] ( អណ្ដើក... ) ម្នាលកូន នេះជាធម៌របស់សប្បុរសទាំងឡាយ កូនត្រូវតែប្រព្រឹត្តប្រយោជន៍ដើម្បីឪពុក ពិតមែនហើយ តែពួកអ្នកជនបទ មិនគប្បីបៀតបៀននូវកូនរបស់ខ្លែង ព្រោះឃើញនូវអញដែលមានកាយធំ ។

[ ៣០ ] ( ខ្ទែង... ) បពិត្រព្រះអង្គប្រសើរដោយសេចក្តីព្យាយាម ក្នុងពួកម្រឹគ ពួកសត្វចិញ្ចឹមនិងពួកមនុស្ស ត្រូវភ័យគ្របសង្កត់ហើយ រមែង ចូលទៅពឹងបុគ្គលដ៏ប្រសើរ កូនទាំងឡាយរបស់ខ្ញុំ មានសេចក្តីក្តៅក្រហាយ ( ព្រោះហេតុនោះ ) ខ្ញុំមក ( យកព្រះអង្គ ) ជាគតិ ព្រះអង្គជាស្តេចរបស់ យើង សូមព្រះអង្គមេត្តា ( ស្រោចស្រង់ ) ខ្ញុំឲ្យបានសេចក្តីសុខ ។

[ ៣១ ] ( សីហៈ... ) ម្នាលខ្ទែងឈ្មោល យើងនឹងធ្វើនូវប្រយោជន៍ នុ៎ះដល់អ្នក មកយើងនឹងទៅសម្លាប់ពួកសត្រូវនោះរបស់អ្នក ធម្មតាអ្នកប្រាជ្ញ ជាអ្នកអាចនឹងសម្លាប់នូវសត្រូវបាន ដឹងច្បាស់ ( នូវភ័យកើតឡើងដល់មិត្ត ) មិនគប្បីប្រើងប្រែងរក្សានូវជនដែលទុកដូចជាខ្លួនដូចម្តេចកើត ។

[ ៣២ ] ( ខ្ទែងញីនិយាយនឹងខ្ទែងឈ្មោលថា ) បុគ្គលគួរធ្វើ ( នូវ បុគ្គលណាមួយ ) ឲ្យជាមិត្តផង ឲ្យជាសម្លាញ់ផង គួរធ្វើ ( នូវបុគ្គលណា មួយ ) ឲ្យជាម្ចាស់ផង ដើម្បីបាននូវសេចក្តីសុខ យើងទាំងឡាយ ( អាច កម្ចាត់បង់នូវពួកសត្រូវបាន ដោយកម្លាំងនៃមិត្ត ) យើងនឹងបានមូលមិត្តគ្នា រីករាយជាមួយនឹងកូនទាំងឡាយ ដូចជាបុគ្គលដែលមានអាវក្រោះពាក់ហើយ អាចរាំងនូវកូនសរទាំងឡាយបានដូច្នោះ ។

[ ៣៣ ] កូនតូចទាំងឡាយ ( បញ្ចេញសំឡេងដ៏ពីរោះ ) គួរឲ្យ ខ្ទោចចិត្ត ហើយស្រែកហៅ ( ខ្ញុំ ) ដែលកំពុងស្រែកយំ ដោយសារសេចក្តី ព្យាយាមរបស់សីហៈ ជាមិត្តរបស់ខ្លួន ជាសម្លាញ់ ជាសត្វមិនរត់ ។

[ ៣៤ ] បណ្ឌិតនោះប្រើប្រាស់នូវកូន នូវសត្វចិញ្ចឹម ឬក៏នូវទ្រព្យ

ព្រោះអាស្រ័យមិត្តសម្លាញ់ ខ្ញុំក្តី ពួកកូនក្តី ប្តីរបស់ខ្ញុំក្តី បានមូលមិត្តគ្នា ដោយសេចក្តីអនុគ្រោះរបស់ពួកមិត្ត ។ បុគ្គល មានស្តេចផង មានមិត្តដ៏ក្លៀវក្លាផង ( ជាមិត្តហើយ ) អាចសម្រេចប្រយោជន៍បាន ដ្បិតសម្លាញ់ទាំងឡាយនុ៎ះ រមែងមានដល់បុគ្គលដែលបរិបូណ៌ដោយសម្លាញ់ បពិត្រស្វាមីអ្នកប្រាថ្នានូវកាម បុគ្គលអ្នកមានមិត្ត មានយស មានសេចក្តីខ្ពង់ខ្ពស់នោះ រមែង រីករាយក្នុងលោកនេះ ។

[ ៣៥ ] បពិត្រខ្ញែងឈ្មោល បុគ្គលសូម្បីក្រខ្សត់ ក៏គួរធ្វើនូវមិត្តធម៌ អ្នកចូរមើលចុះ យើងទាំងឡាយបានព្រមព្រៀងគ្នាជាមួយនិងញាតិទាំងឡាយ ដោយសេចក្តីអនុគ្រោះរបស់មិត្ត ។ បពិត្រខ្ញែងឈ្មោល បក្សីណាធ្វើនូវមិត្ត ជាមួយនឹងបុគ្គលក្លៀវក្លា ជាមួយនឹងបុគ្គលមានកម្លាំង បក្សីនោះ រមែងបាន សេចក្តីសុខយ៉ាងនេះ ដូចខ្ញុំនិងអ្នក ។

## ចប់ មហាឧក្កុសជាតកទី ៣ ។

# អដ្ឋកថា

# មហាឧក្កុសជាតក

[ ២០-៣៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកដែលចងមិត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧក្កា មិលាចា ពន្ធន្តិ** ដូច្នេះជាដើម ។

បានឮថា ឧបាសកនោះជាបុត្តនៃត្រកូលចាស់ ក្នុងនគរសាវត្ថី បញ្ជូនសម្លាញ់ទៅឲ្យសូមកុលធីតាម្នាក់ ។ កុលធីតានោះសួរថា មិត្តនិងសម្លាញ់ដែលអាចចែករំលែកកិច្ចដែលកើតឡើងរបស់គេមានដែរឬទេ បុរសនោះឆ្លើយថាមិនមាន កាលកុលធីតានោះពោលថា បើដូច្នោះ បុរសនោះត្រូវចងមិត្តទុកជាមុនចុះ ។ បុរសនោះតាំងនៅក្នុងពាក្យជាស់តឿននោះ ផ្តើមធ្វើមេត្រីជាមួយអ្នកយាមទ្វារទាំង ៤ ហើយបានធ្វើមេត្រីជាមួយអ្នករក្សានគរនិងឥស្សរជនមានអាមាត្យជាដើម សូម្បីជាមួយសេនាបតីនិងជាមួយឧបរាជ ក៏ធ្វើមេត្រីទុកដែរ កាលធ្វើជាមិត្តនឹងជនទាំងនោះបាន ក៏ធ្វើមេត្រីជាមួយព្រះរាជាដោយលំដាប់ បន្ទាប់អំពីនោះក៏បានធ្វើមេត្រីជាមួយព្រះមហាថេរ ៨០ អង្គ និងជាមួយព្រះអានន្ទ រហូតដល់ព្រះតថាគត ។ ពេលនោះព្រះសាស្តា ទ្រង់ក៏ឲ្យបុរសនោះតាំងនៅក្នុងសរណៈ និងសីល ។ ព្រះរាជាក៏ប្រោសប្រទានឥស្សរិយយសដល់បុរសនោះ ។ បុរសនោះប្រាកដឈ្មោះថាមិត្តគន្ធកៈនោះឯង ។ កាលនោះ ព្រះរាជាប្រទានឃ្លាំងធំដល់បុរសនោះ ឲ្យធ្វើអាវាហមង្គល ។ មហាជនចាប់តាំងពីព្រះរាជាឡើងទៅ បញ្ជូនបណ្ណាការឲ្យបុរសនោះ កាល

នោះ កិរិយារបស់បុរសនោះ ក៏បញ្ជូនបណ្ណាការដែលព្រះរាជាទ្រង់ប្រទាន ទៅជូនដល់ឧបរាជ បញ្ជូនបណ្ណាការដែលឧបរាជប្រទាន ទៅឲ្យដល់សេនាបតីជាលំដាប់ទៅ ដោយឧបាយនេះឯង ។ បានចងសម្ពន្ធនឹងអ្នកនគរគ្រប់គ្នាបាន ។ ក្នុងថ្ងៃទី ៧ ស្វាមីកិរិយារៀបចំមហាសក្ការៈ យាងព្រះទសពលថ្វាយមហាទានដល់ភិក្ខុសង្ឃប្រមាណ ៥០០ រូប មានព្រះពុទ្ធជាប្រធាន ពេលស្រេចភត្តកិច្ច ស្តាប់ព្រះតម្រាស់អនុមោទនាដែលព្រះសាស្តាត្រាស់ ប្តីប្រពន្ធទាំងពីរ ក៏តាំងនៅក្នុង សោតាបត្តិផល ។ ភិក្ខុទាំងឡាយនាំគ្នាលើករឿងនេះឡើងសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ឧបាសកមិត្តគន្ធកៈ អាស្រ័យកិរិយារបស់ខ្លួន ស្តាប់ពាក្យរបស់នាង ធ្វើមេត្រីជាមួយមនុស្សទាំងពួង បានសម្បត្តិច្រើនអំពីសម្នាក់ព្រះរាជា ធ្វើមេត្រីជាមួយព្រះតថាគត តាំងនៅក្នុងសោតាបត្តិផលទាំងពីរនាក់ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេដែលឧបាសកនេះអាស្រ័យមាតុគ្រាម ដល់នូវយសធំ សូម្បីក្នុងកាលមុន កើតក្នុងកំណើតតិរច្ឆាន ធ្វើមិត្តមេត្រីជាមួយសត្វជាច្រើនតាមពាក្យរបស់នាង ផុតចាកសេចក្តីសោកព្រោះកូនបាន ភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី

អ្នកបច្ចន្តជនបទទាំងនោះ បានសាច់ច្រើនៗ ក្នុងទីណាមួយ ក៏នាំគ្នាសង់ផ្ទះក្នុងទីនោះៗ ហើយនាំគ្នាដើរក្នុងព្រៃសម្លាប់ម្រឹគជាដើម យកសាច់មកចិញ្ចឹមកូនប្រពន្ធ ។ ក្នុងទីមិនឆ្ងាយអំពីស្រុករបស់ជនទាំងនោះ មានស្រះធំកើតឯង ។ ខាងស្តាំនៃស្រះនោះ មានខ្លែងមួយ ខាងក្រោយស្រះ មានខ្លែងញីមួយ ខាងជើងស្រះមានរាជសីហ៍ ខាងត្បូងស្រះមានស្តេចអកអាស្រ័យនៅ ក្នុងទីទឹករាក់នៃស្រះអណ្តើកអាស្រ័យនៅ ។ កាលនោះ ខ្លែងពោលនឹងខ្លែងញីថា នាងជាភរិយារបស់យើងចុះ ។ ខ្លែងញីពោលថា អ្នកមានសម្លាញ់ខ្លះដែរឬទេ ខ្លែងតបថា មិនមានឡើយ ។ ខ្លែងញីពោលថា កាលភ័យ ឬទុក្ខកើតឡើងដល់យើង យើងត្រូវបានមិត្ត ឬសម្លាញ់ជួយជ្រោមជ្រែងទើបគួរ អ្នកត្រូវចងមិត្តជាមុនចុះ ។ ខ្លែងសួរថា នែនាង យើងចងមិត្តជាមួយអ្នកណា ខ្លែងញីឆ្លើយថា ចងមិត្តជាមួយស្តេចអកដែលនៅទិសខាងកើត ស្តេចសីហៈ ដែលនៅទិសខាងជើង អណ្តើកនៅក្នុងស្រះ ខ្លែងស្តាប់ពាក្យរបស់ខ្លែងញីហើយ ទទួលពាក្យហើយធ្វើតាមនោះ ។ កាលនោះខ្លែងទាំងគូ ក៏បានរៀបចំទីលំនៅនាំគ្នាធ្វើសម្បុក អាស្រ័យនៅត្រង់ដើមក្តុម្ព ដែលនៅលើកោះមួយកន្លែងក្នុងស្រះនោះឯង មានទឹកព័ទ្ធជុំវិញ ។ ក្នុងកាលតមក ខ្លែងទាំងគូបានឲ្យកំណើតដល់កូនតូចពីរក្បាល ។ ខណៈកូនខ្លែងទាំងពីរ មិនទាន់មានរោមស្លាបនោះឯង ថ្ងៃមួយ អ្នកជនបទទាំងនោះ នាំគ្នាដើរព្រៃអស់មួយថ្ងៃ មិនបានម្រឹគណាមួយ គិតថា ពួកយើងមិនអាចទៅផ្ទះដោយដៃទទេបាន ត្រូវចាប់ត្រីឬអណ្តើកទៅឲ្យបាន នាំគ្នាចុះស្រះ ទៅដល់កោះនោះ ដេកត្រង់គល់ក្តុម្ពនោះ

កាលត្រូវមូសជាដើមខាំ ក៏នាំគ្នាក្លួតភ្លើង ធ្វើផ្សែងបណ្តេញមូសទាំងនោះ ។ ផ្សែងក៏ហើរឡើងទៅ ប៉ះបក្សីទាំងឡាយ កូនបក្សីក៏នាំគ្នាយំ អ្នកជនបទបានឮសំឡេង នាំគ្នាពោលថា អ្នកដ៏ចម្រើន សំឡេងកូនបក្សី អ្នកទាំងឡាយចូរឡើងទៅចាប់យកកូនបក្សី ពួកយើងឃ្លានរហូតទ្រាំមិនបាន ស៊ីសាច់បក្សីហើយសឹមដេក នាំគ្នាបង្កាត់ភ្លើងឲ្យឆេះ ហើយចងគប់ភ្លើង ។ មេបក្សីបានឮសំឡេងជនទាំងនោះគិតថា ជនទាំងនេះត្រូវការស៊ីកូនរបស់អញ អញចងមិត្តទុកដើម្បីការពារភ័យ ដែលមានសភាពបែបនេះ អញត្រូវបញ្ជូនប្តីទៅរកស្តេចអក ហើយពោលថា សូមអ្នកទៅចុះ ភ័យកើតឡើងដល់កូនរបស់យើងហើយ ចូរប្រាប់ដល់ស្តេចបក្សីអកចុះ ហើយពោលគាថាជាបឋមថា

ម្នាលខ្លែងឈ្មោល ពួកអ្នកជនបទ ចងគប់ភ្លើងទាំងឡាយក្នុង
កោះតូចៗ ប្រាថ្នានឹងស៊ីនូវកូនតូចៗរបស់ខ្ញុំ អ្នកចូរហៅនូវមិត្ត
ផង សម្លាញ់ផង អ្នកចូរក្រាបទូលនូវសេចក្តីវិនាសរបស់ពួក
បក្សីជាញាតិ ( នៃយើងដល់ស្តេចអកផង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គិលាចា** បានដល់ អ្នកជនបទ ។ បទថា **ទីបេ** បានដល់ លើកោះតូច ។ បទថា **បជា មម** បានដល់ កូនរបស់ខ្ញុំ ។ មេបក្សីហៅសត្វខ្លែងដោយឈ្មោះថា **សេនក** ។ បទថា **ញាតិព្យសនំ ទិជានំ** សេចក្តីថា មេបក្សីពោលថា អ្នកចូរទៅប្រាប់ការវិកវររបស់បក្សីដែលជាញាតិរបស់យើងនេះដល់ស្តេចអក លុះខ្លែងនោះហើរទៅកាន់លំនៅរបស់ស្តេចអកដោយរហ័ស ហើយរោវឲ្យដឹងការដែលខ្លួនមក បានទទួលឱកាស ក៏ចូល

ទៅថ្វាយបង្គំ ត្រូវសួរថា អ្នកមកធ្វើអ្វី កាលសម្តែងហេតុដែលខ្លួនត្រូវមក ទើបពោលគាថាទី ២ ថា

បពិត្រស្តេចអក ព្រះអង្គជាទិជជាតិផង ជាបក្សីប្រសើរជាង
ពួកទិជជាតិផង ខ្ញុំសូមយកព្រះអង្គជាទីពឹង ដ្បិតពួកអ្នកជន
បទអាក្រក់ណាស់ ប្រាថ្នានឹងស៊ីកូនតូចៗរបស់ខ្ញុំ សូមព្រះអង្គ
(មេត្តាស្រោចស្រង់) ខ្ញុំឲ្យបានសេចក្តីសុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិជោ** សេចក្តីថា លោកជាបក្សីដែលប្រសើរជាងបក្សីទាំងឡាយ ។

ស្តេចអកលួងលោមខ្លែងថា កុំភ័យឡើយ ហើយពោលគាថាទី ៣ ថា

បណ្ឌិតទាំងឡាយ ជាអ្នកស្វែងរកសេចក្តីសុខ ក្នុងកាលគួរ
និងកាលមិនគួរ រមែងចងមិត្តផង សម្លាញ់ផង ម្នាលខ្លែង
ឈ្មោល យើងនឹងធ្វើនូវប្រយោជន៍នុ៎ះដល់អ្នកបាន ដ្បិតអរិយ
ជនតែងធ្វើនូវកិច្ចដល់អរិយជន ( ដូចគ្នា ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាលេ អកាលេ** បានដល់ ក្នុងពេលថ្ងៃនិងពេលយប់ ។ បទថា **អរិយោ** នេះ អាចារៈ លោកបំណងយកថាជាអរិយជន ស្តេចអកពោលថា ក្នុងទីនេះអ្វីហៅថាអរិយៈ មែនពិត បុគ្គលដែលសម្បូរដោយអាចារៈ រមែងធ្វើកិច្ចរបស់បុគ្គលដែលសម្បូរដោយអាចារៈប៉ុណ្ណោះ ។

លំដាប់នោះ ស្តេចអកសួរខ្លែងថា ពួកមនុស្សនាំគ្នាឡើងដើមឈើហើយ

ឬសម្លាញ់ ខ្លែងក៏ឆ្លើយថា ពេលនេះមិនទាន់ឡើងនៅឡើយទេ កំពុងនាំគ្នាចងគប់ភ្លើងប៉ុណ្ណោះ ។ ក៏ប្រាប់ថា បើដូច្នោះ ចូរប្រញាប់ទៅលួងលោមសម្លាញ់ស្រីរបស់យើង ប្រាប់ដល់ការមករបស់យើងចុះ ខ្លែងធ្វើយ៉ាងនោះ ។ ចំណែកស្តេចអក ក៏ហើរមកទំត្រង់ចុងឈើមួយដើម មិនឆ្ងាយអំពីដើមក្តម្ពសម្លឹងមើលផ្លូវឡើងរបស់ពួកមនុស្ស ពេលដែលអ្នកស្រុកម្នាក់ឡើងដើមក្តម្ពជិតនឹងដល់សម្បុក អកក៏មុជក្នុងស្រះ នាំយកទឹកមកដោយស្លាបនិងដោយចំពុះ ស្រោចពន្លត់គប់ភ្លើង គប់ភ្លើងនោះក៏រលត់ ។ ពួកអ្នកស្រុកពោលថាពួកយើងត្រូវស៊ីខ្លែងនេះផង ស៊ីកូនរបស់វាផង ហើយក៏សម្រូតចុះ ដុតគប់ភ្លើងឲ្យឆេះហើយឡើងជាថ្មី ។ ស្តេចអកក៏យកទឹកមកពន្លត់ទៀត ។ កាលស្តេចអកប្រើឧបាយនេះ ពន្លត់គប់ភ្លើងដែលចងហើយ ពេលវេលា ក៏កន្លងទៅដល់កណ្តាលយប់ ស្តេចអកនឿយហត់ពន់ពេក ។ ស្ងួតក៏ស្ងួត ពោះក៏ធូរ ភ្នែកទាំងពីរក៏រកាំ មេខ្លែងឃើញហើយពោលនឹងខ្លែងថា នែអ្នកស្តេចអកលំបាកណាស់ហើយ ចូរអ្នកទៅប្រាប់ស្តេចអណ្តើកចុះ ដើម្បីឲ្យស្តេចអកបានសម្រាកខ្លះ លុះខ្លែងស្តាប់ពាក្យនោះ ក៏ចូលទៅរកស្តេចអកបណ្តើរពោលគាថាបណ្តើរថា

> អំពើណា ដែលអរិយជនជាអ្នកអនុគ្រោះគប្បី ធ្វើដល់អរិយជន អំពើនោះព្រះអង្គបានធ្វើហើយ សូមទ្រង់រក្សានូវព្រះអង្គចុះ សូមទ្រង់កុំក្តៅក្រហាយឡើយ កាលបើព្រះអង្គរស់នៅយើងគង់នឹងបាននូវកូនទាំងឡាយ ( ទៀត ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តយិទំ** កាត់បទជា **តយា ឥទំ** បាលីក៏យ៉ាងនោះដូចគ្នា ។

ស្ដេចអកស្ដាប់ពាក្យខ្លែងនោះហើយ កាលទឹងបន្លឺសីហនាទ ក៏ពោលគាថាទី ៥ ថា

យើងខ្ញុំធ្វើនូវការរក្សា និងកិរិយាការពារនោះឯង ត្រាតែបែកធ្លាយនូវសរីរៈ ក៏មិនតក់ស្លុតដែរ ដ្បិតសម្លាញ់ទាំងឡាយនេះតែងលះបង់ជីវិត ជួយធ្វើ ( កិច្ចការ ) ដល់សម្លាញ់ផងគ្នា នេះជាធម៌របស់សប្បុរសទាំងឡាយ ដូច្នេះ ។

ព្រះសាស្ដាជាអភិសម្ពុទ្ធ កាលទ្រង់ពណ៌នាគុណរបស់ស្ដេចអក ទើបត្រាស់គាថាទី ៦ ថា

ស្ដេចអកនេះជាសត្វស្លាប កើតអំពីស៊ុត បានធ្វើនូវអំពើដែលគេធ្វើដោយកម្រក្រៃពេក ដើម្បីប្រយោជន៍ ( នឹងរក្សា ) នូវកូនខ្លែងទាំងឡាយ ដរាបដល់ពាក់កណ្ដាលអធ្រាត្រ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុររោ** បានដល់ ស្ដេចអក ។ បទថា **បុត្តេ** សេចក្ដីថា រក្សាកូនរបស់ខ្លែង ដើម្បីប្រយោជន៍ដល់កូនរបស់ខ្លែងទាំងនោះ ។ បទថា **អឌ្ឍរត្តេ អនាគតេ** សេចក្ដីថា ធ្វើនូវការព្យាយាមរហូតដល់យាមទី ២ ឈ្មោះថា ធ្វើបានលំបាក ចំណែកខ្លែងឈ្មោលពោលថា បពិត្រស្ដេចអកសម្លាញ់ អញ្ជើញអ្នកសម្រាកបន្តិចចុះ ហើយទៅរកអណ្ដើក ដាស់អណ្ដើកឲ្យក្រោកឡើង កាលអណ្ដើកពោលថា មកធ្វើអ្វីសម្លាញ់ ក៏ប្រាប់ថា ភ័យបែប

នេះកើតហើយ ស្តេចបក្សីព្យាយាមមកតាំងអំពីព្រឹក ហត់នឿយ ហេតុនោះ ទើបខ្ញុំមករកអ្នក ហើយពោលគាថាទី ៧ ថា

បុគ្គលពួកខ្លះ ឃ្លាតចាក ( យសឬទ្រព្យ ) ក៏មាន ភ្លាំងភ្លាត់ ដោយកម្មរបស់ខ្លួនក៏មាន ហើយត្រឡប់តាំងខ្លួនបាន ដោយ សារសេចក្តីអនុគ្រោះរបស់ពួកមិត្ត កូនទាំងឡាយរបស់ខ្ញុំ មាន សេចក្តីក្តៅក្រហាយ ខ្ញុំមក ( យកអ្នក ) ជាគតិ ( ទីពឹង ) បពិត្រសត្វត្រាច់ទៅក្នុងទឹក ចូរអ្នកប្រព្រឹត្តប្រយោជន៍ ដល់ខ្ញុំ ដូច្នេះ ។

អត្ថនៃគាថានោះដូច្នេះថា មែនពិត បុគ្គលពួកខ្លះទោះបីឃ្លៀងឃ្លាតចាក យស ឬចាកទ្រព្យ ដល់នូវការភ្លាំងភ្លាត់ចាកការងាររបស់ខ្លួន រមែងតម្កល់ខ្លួន ទុកបាន ដោយការអនុគ្រោះរបស់សម្លាញ់ ឯកូនរបស់ខ្ញុំត្រូវគេចង់បរិភោគ ក្តៅក្រហាយ ហេតុនោះ ទើបខ្ញុំមក ធ្វើលោកឲ្យជាគតិ ឲ្យជាទីពំនាក់ សូម លោកជួយឲ្យជីវិតដល់កូនរបស់ខ្ញុំ បំពេញប្រយោជន៍ដល់ខ្ញុំចុះ ។

អណ្តើកស្តាប់ពាក្យនោះហើយ ពោលគាថាបន្តថា

បណ្ឌិតទាំងឡាយ តែងចងមិត្តនឹងសម្លាញ់ ដោយទ្រព្យផង ដោយស្រូវផង ដោយខ្លួនផង ម្នាលខ្លែង យើងនឹងធ្វើប្រ- យោជន៍នេះដល់អ្នកបាន ដ្បិតអរិយជនតែងធ្វើកិច្ចដល់អរិយ ជនដូចគ្នា ដូច្នេះ ។

កាលនោះ កូនរបស់អណ្តើកដេកនៅមិនឆ្ងាយ ស្តាប់ពាក្យបិតា គិតថា

បិតារបស់អញកុំលំបាកឡើយ អញនឹងធ្វើកិច្ចឯង ទើបពោលគាថាទី ៩ ថា

បពិត្រឪពុក អ្នកចូរជាបុគ្គលមានសេចក្តីខ្វល់ខ្វាយតិច អង្គុយស្ងៀមចុះ កូនតែងប្រព្រឹត្តប្រយោជន៍ដល់ឪពុក ខ្ញុំនឹងជួយការពារនូវកូនខ្វែងហើយប្រព្រឹត្តនូវប្រយោជន៍ជំនួសលោក ដូច្នេះ ។

កាលនោះ បិតាបានពោលគាថាថា

ម្នាលកូន នេះជាធម៌របស់សប្បុរសទាំងឡាយ កូនត្រូវតែប្រព្រឹត្តប្រយោជន៍ដើម្បីឪពុក ពិតមែនហើយ តែពួកអ្នកជនបទមិនគប្បីបៀតបៀននូវកូនរបស់ខ្វែង ព្រោះឃើញនូវអញដែលមានកាយធំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតមេស ធម្មោ** សេចក្តីថា នេះជាធម៌របស់បណ្ឌិតទាំងឡាយ ។ បទថា **បុត្តា** សេចក្តីថា ពួកព្រានជនបទ មិនគប្បីបៀតបៀនពួកកូនៗរបស់ខ្វែងឡើយ ។

អណ្តើកធំកាលពោលយ៉ាងនេះហើយ ក៏បញ្ជូនខ្វែងឲ្យទៅមុនដោយពាក្យថា នែសម្លាញ់កុំខ្លាចឡើយ សូមអ្នកទៅមុនចុះ អញនឹងទៅឥឡូវនេះ ពោលបណ្តើរ ក៏លោតចុះទឹកបណ្តើរ វែកភក់និងចកមកដល់កោះហើយ ក៏ពន្លត់ភ្លើងឲ្យរលត់អស់ ។ ពួកអ្នកស្រុកនិយាយគ្នាថា ពួកយើងរវល់ត្រូវការកូនបក្សីធ្វើអ្វី ត្រឡប់មកសម្លាប់អណ្តើកក្អែកខ្វាក់នេះចុះ វាគ្រប់គ្រាន់ដល់យើងគ្រប់គ្នា ថាបណ្តើរបោចវល្លិ៍បណ្តើរចង ហើយស្រាយសំពត់ចាស់ៗចងទុកក្នុងទីនោះៗ មិនអាចប្រមៀលអណ្តើកបាន អណ្តើកក៏នាំជនទាំងនោះចុះទៅ

កាន់ទឹកជ្រៅ ជនទាំងនោះក៏ហែលតាមទៅ ព្រោះចង់បានអណ្តើក ជនទាំងនោះមានពោះពេញដោយទឹក លំបាកគ្រប់គ្នា កាលឡើងមកវិញបានហើយក៏ពោលថា អ្នកដ៏ចម្រើន សត្វអកមួយចាំពន្ធត់គប់ភ្លើងរបស់យើង រហូតដល់កណ្តាលយប់ ឥឡូវនេះ អណ្តើកនេះឲ្យយើងធ្លាក់ទឹក ផឹកទឹកពេញពោះគ្រប់គ្នា យើងនឹងបង្កាត់ភ្លើងជាថ្មីចុះ សូម្បីអរុណរះឡើង ក៏ត្រូវស៊ីកូនខ្ទែងនេះឲ្យបាន ហើយក៏ផ្តើមបង្កាត់ភ្លើង ។ មេបក្សីបានស្តាប់ពាក្យជនទាំងនោះក៏ពោលថា នែអ្នក ជនទាំងនេះត្រូវការស៊ីកូនរបស់យើងឲ្យបាន ក្នុងពេលណាមួយ ហើយទើបនាំគ្នាទៅ អ្នកត្រូវទៅរកពជសីហ៍ជាសម្លាញ់របស់យើងចុះ ។ ខ្ទែងនោះទៅដល់សម្នាក់រាជសីហ៍រំពេចនោះឯង កាលរាជសីហ៍ពោលថា មានរឿងអ្វី ទើបមកក្នុងពេលដែលមិនគួរ ក៏ប្រាប់រឿងនោះតាំងអំពីដើមដល់ចប់ ហើយពោលគាថាទី ១១ ថា

> បពិត្រព្រះអង្គប្រសើរដោយសេចក្តីព្យាយាម ក្នុងពួកម្រឹគ ពួកសត្វចិញ្ចឹម និងពួកមនុស្ស ត្រូវភ័យគ្របសង្កត់ហើយ រមែងចូលទៅពឹងបុគ្គលដ៏ប្រសើរ កូនទាំងឡាយរបស់ខ្ញុំមានសេចក្តីក្តៅក្រហាយ ( ព្រោះហេតុនោះ ) ខ្ញុំមក ( យកព្រះអង្គ ) ជាគតិ ព្រះអង្គជាស្តេចរបស់យើង សូមព្រះអង្គមេត្តា ( ស្រោចស្រង់ ) ខ្ញុំឲ្យបានសេចក្តីសុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បសូ** សេចក្តីថា ខ្ទែងនោះពោលសំដៅយកសត្វតិរច្ឆានទាំងអស់ លោកពោលអធិប្បាយពាក្យនេះថា នែសម្លាញ់ ក្នុង

ពួកម្រឹគ លោកជាសត្វប្រសើរជាងគេ ដោយសេចក្ដីព្យាយាម ទាំងសត្វតិរច្ឆាននិងមនុស្សទាំងអស់ក្នុងលោក កាលជួបនូវភ័យ រមែងនាំគ្នាចូលមករកបុគ្គលប្រសើរ ឯកូនទាំងឡាយរបស់ខ្ញុំកំពុងក្ដៅក្រហាយ ទើបខ្ញុំមកពឹងលោក លោកជាស្ដេចនៃពួកខ្ញុំ សូមលោកឲ្យនូវសេចក្ដីសុខដល់ខ្ញុំចុះ ។

រាជសីហ៍ស្ដាប់ដូច្នោះ ក៏ពោលគាថាដូច្នេះថា

ម្នាលខ្លែងឈ្មោល យើងនឹងធ្វើនូវប្រយោជន៍នុ៎ះដល់អ្នក មកយើងនឹងទៅសម្លាប់ពួកសត្រូវនោះរបស់អ្នក ធម្មតាអ្នកប្រាជ្ញជាអ្នកអាចនឹងសម្លាប់នូវសត្រូវបាន ដឹងច្បាស់ ( នូវភ័យកើតឡើងដល់មិត្ត ) មិនគប្បីប្រឹងប្រែងរក្សានូវជន ដែលទុកដូចជាខ្លួន ដូចម្ដេចកើត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តំ ធិសតំ** បានដល់ ពួកនៃសត្រូវនោះ អធិប្បាយថា ពួកនៃសត្រូវរបស់អ្នកនោះ ។ បទថា **បហុ** សេចក្ដីថា អាចកម្ចាត់ពួកសត្រូវ ។ បទថា **សម្បជានោ** សេចក្ដីថា ដឹងថាភ័យកើតឡើងដល់មិត្ត ។ បទថា **អត្តជនស្ស** បានដល់ ជនដែលជាមិត្តស្មើដោយខ្លួន គឺអ្នកស្មើដោយអវយវៈ ។

កាលពោលយ៉ាងនេះហើយ រាជសីហ៍ក៏បញ្ជូនខ្លែងនោះទៅថា សូមអ្នកទៅចុះ ចូរលួងលោមកូន ហើយដើរលុយទឹកដែលមានពណ៌ដូចកែវមណីទៅ ពួកអ្នកស្រុក ឃើញរាជសីហ៍នោះកំពុងដើរមក នាំគ្នាពោលថា ដំបូងអកចាំពន្លត់ភ្លើងរបស់ពួកយើង បន្ទាប់មក អណ្ដើកមកធ្វើឲ្យពួកយើងអស់សំពត់

ស្មៀក ឥឡូវនេះ រាជសីហ៍នឹងធ្វើពួកយើងឲ្យអស់ជីវិត មានការខ្លាចស្លាប់ជាកម្លាំង នាំគ្នារត់ខ្ចាត់ខ្ចាយទៅ ។ រាជសីហ៍មកដល់គល់កុម្ពនោះ មិនឃើញនូវបុគ្គលណាមួយត្រង់គល់ឈើឡើយ ។ កាលនោះ អក អណ្តើកនិងខ្លែងក៏នាំគ្នាចូលទៅរក ធ្វើការវកិច្ចដល់រាជសីហ៍នោះ រាជសីហ៍ក៏ពោលអានិសង្សនៃមិត្តដល់សត្វទាំងនោះដោយជាស់តៀនថា តាំងអំពីនេះទៅ អ្នកទាំងឡាយចូរកុំទម្លាយមិត្តធម៌ កុំប្រមាទចុះ ហើយចៀសចេញទៅ ។ សត្វទាំងនោះក៏នាំគ្នាទៅកាន់លំនៅរបស់ខ្លួន មេខ្លែងសម្លឹងមើលកូនរបស់ខ្លួនហើយ គិតថា ព្រោះអាស្រ័យពួកមិត្ត ទើបយើងរក្សាកូនទុកបាន ។ កាលដល់សម័យដែលអង្គុយ ក៏នាំគ្នានៅយ៉ាងសប្បាយ កាលចរចាជាមួយខ្លែងឈ្មោលទើបពោលគាថា ៦ ឈ្មោះថា មិត្តធម្មគាថា ដូច្នេះថា

បុគ្គលគួរធ្វើ ( នូវបុគ្គលណាមួយ ) ឲ្យជាមិត្តផង ឲ្យជាសម្លាញ់ផង គួរធ្វើ ( នូវបុគ្គលណាមួយ ) ឲ្យជាម្ចាស់ផង ដើម្បីបាននូវសេចក្តីសុខ យើងទាំងឡាយ ( អាចកម្ចាត់បង់នូវពួកសត្រូវបាន ដោយកម្លាំងនៃមិត្ត ) យើងនឹងបានមូលមិត្តគ្នា រីករាយជាមួយនឹងកូនទាំងឡាយ ដូចជាបុគ្គលដែលមានអាវក្រោះពាក់ហើយ អាចរាំង នូវកូនសរទាំងឡាយបាន ដូច្នោះ ។

កូនតូចទាំងឡាយ ( បញ្ចេញសំឡេងដ៏ពីរោះ ) គួរឲ្យខ្លាចចិត្ត ហើយស្រែកហៅ ( ខ្ញុំ ) ដែលកំពុងស្រែកយំ

ដោយសារសេចក្តីព្យាយាមរបស់សីហៈ ជាមិត្តរបស់ខ្លួន ជាសម្លាញ់ ជាសត្វមិនរត់ ។

បណ្ឌិតនោះប្រើប្រាស់នូវកូន នូវសត្វចិញ្ចឹម ឬក៏នូវទ្រព្យ ព្រោះអាស្រ័យមិត្តសម្លាញ់ ខ្ញុំក្តី ពួកកូនក្តី ប្តីរបស់ខ្ញុំក្តី បានមូលមិត្តគ្នាដោយសេចក្តីអនុគ្រោះរបស់ពួកមិត្ត ។ បុគ្គលមានស្តេចផង មានមិត្តដ៏ក្លៀវក្លាផង ( ជាមិត្តហើយ ) អាចសម្រេចប្រយោជន៍បាន ដ្បិតសម្លាញ់ទាំងឡាយនុ៎ះ រមែងមានដល់បុគ្គលដែលបរិបូណ៌ដោយសម្លាញ់ បពិត្រស្វាមីអ្នកប្រាថ្នានូវកាម បុគ្គលអ្នកមានមិត្ត មានយស មានសេចក្តីខ្ពង់ខ្ពស់នោះ រមែងរីករាយក្នុងលោកនេះ ។

បពិត្រខ្លែងឈ្មោល បុគ្គលសូម្បីក្រខ្សត់ ក៏គួរធ្វើនូវមិត្តធម៌ អ្នកចូរមើលចុះ យើងទាំងឡាយ បានព្រមព្រៀងគ្នាជាមួយនឹងញាតិទាំងឡាយ ដោយសេចក្តីអនុគ្រោះរបស់មិត្ត ។ បពិត្រខ្លែងឈ្មោល បក្សីណា ធ្វើនូវមិត្តជាមួយនឹងបុគ្គលក្លៀវក្លា ជាមួយនឹងបុគ្គលមានកម្លាំង បក្សីនោះ រមែងបានសេចក្តីសុខយ៉ាងនេះ ដូចខ្ញុំនិងអ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិត្តញ្ច** បានដល់ មិត្តរបស់ខ្លួនឯណានីមួយ ។ បទថា **សុហាទយញ្ច** សេចក្តីថា ចូរធ្វើនូវការសេពគប់មិត្តដែលមានចិត្តល្អ និងបុគ្គលដែលមានតំណែងជាចៅហ្វាយ ។ បទថា **ឆិវត្ថកោដោវ សបេតិ–**

**ហន្ត្វា** នេះ ពាក្យថា **កោដោ** បានដល់ អាវក្រោះ ។ ខ្វែងពោលថា ក្រោះ ដែលបុគ្គលពាក់ហើយ រមែងកម្ចាត់ គឺរមែងហាមនូវព្រួញទាំងឡាយបាន យ៉ាងណា សូម្បីយើងទាំងឡាយ ក៏យ៉ាងនោះ រមែងកម្ចាត់សត្រូវទាំងឡាយ បាន ដោយកម្លាំងនៃមិត្ត ត្រេកអរនឹងកូនទាំងឡាយ ។ បទថា **សកមិត្តស្ស កម្មេន** សេចក្តីថា ព្រោះការប្រើប្រែងនៃមិត្តរបស់ខ្លួន ។ បទថា **សហា-យស្សា បលាយិនោ** បានដល់ ស្តេចម្រឹគ ដែលជាសម្លាញ់ មិនគេចមុខ ។ បទថា **លោមហំសា** សេចក្តីថា បក្សីទាំងឡាយដែលជាកូនតូចរបស់យើង បន្លឺសំឡេងយំពីរោះជាប់ចិត្តជាមួយយើងដែលរងាវហៅបាន ។ បទថា **សមង្គិ-ភូតា** គឺតាំងនៅក្នុងឋានៈដូចគ្នា ។ បទថា **រាជវតា សុវតា ច អត្ថោ** សេចក្តីថា បុគ្គលដែលអាចសម្រេចនូវប្រយោជន៍បានដោយគុណ មានព្រះ រាជា ដូចរាជសីហ៍ និងគុណគឺភាពជាអ្នកក្លៀវក្លា ដូចបក្សីអកនិងអណ្តើក ។ បទថា **ភវន្តិ ហោតេ** សេចក្តីថា ព្រោះសំឡាញ់ទាំងនោះ រមែងមានដល់ បុគ្គលដែលដល់ព្រមដោយសំឡាញ់ ដែលដល់ព្រមដោយមិត្តធម៌ ។ បទថា **ឧគ្គតត្តោ** បានដល់ ភាពជាអ្នកមានមិត្ត មានយសដោយសិរីដ៏ល្អ ។ បទថា **អស្មិញ្ច លោកេ** សេចក្តីថា រមែងត្រេកអរក្នុងលោកនេះ ពោលគឺឥធលោក ។ បក្សីញីហៅបក្សីឈ្មោលថា **កាមកាមិ** គឺជាអ្នកប្រាថ្នាក្នុងកាម មែនពិត ប្តី នោះប្រាថ្នាក្នុងកាម ឈ្មោះថា **កាមកាមិ** ។ បទថា **សមគ្គម្ហា** សេចក្តីថា យើងជាបុគ្គលព្រមព្រៀងគ្នា ។ បទថា **សញាតកេ** សេចក្តីថា មួយអន្លើ ដោយញាតិនិងកូនទាំងឡាយ ។

ខ្វែងញីសម្តែងគុណរបស់មិត្តធម៌ដោយគាថាទាំង ៦ ដោយប្រការដូច្នេះ សូម្បីសត្វទាំងអស់ ក៏នៅជាសម្លាញ់នឹងគ្នា មិនទម្លាយនូវមិត្តធម៌ តាំងនៅដរាបដល់អស់អាយុ ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលឧបាសកនេះអាស្រ័យភរិយា មានសេចក្តីសុខ សូម្បីក្នុងកាលមុន ក៏មានសេចក្តីសុខព្រោះអាស្រ័យភរិយាដូចគ្នា ដូច្នេះហើយទ្រង់ប្រជុំជាតកថា ខ្វែងឈ្មោលនិងខ្វែងញីក្នុងកាលនោះ បានមកជាគូស្វាមីភរិយាក្នុងកាលឥឡូវនេះ កូនអណ្តើកក្នុងកាលនោះ បានមកជារាហុល បាអណ្តើកក្នុងកាលនោះ បានមកជាមហាមោគ្គល្លាន សត្វអកក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែករាជសីហ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មហាឧក្កុសជាតក ចប់

# ឧទ្ទាលកជាតក

[ ៣៦ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) ពួកជដិលណា ជណ្តប់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រឡាក់ដោយមន្ទិល មានភ្នែកមិនបន្តក់ មានរូបអាក្រក់ កំពុងរាយនូវមន្ត ជដិលទាំងនោះ បានដឹងនូវការប្រព្រឹត្តនូវតបៈ និងការស្វាធ្យាយនូវមន្តនេះ ក្នុងសេចក្តីព្យាយាមជារបស់មនុស្ស នឹងបានរួចចាកអបាយដែរឬ ។

[ ៣៧ ] ( បុរោហិតក្រាបទូលថា ) បពិត្រមហារាជ បើបុគ្គលជាពហុស្សូត មិនប្រព្រឹត្តធម៌ ធ្វើតែអំពើលាមកទាំងឡាយ បុគ្គលនោះ សូម្បីចេះនូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់បានសម្រេចនូវចរណៈ ( សមាបត្តិប្រាំបី ) ទេ ក៏មិនគប្បីរួចចាកទុក្ខឡើយ ។

[ ៣៨ ] ( ឧទ្ទាលកតាបសពោលថា ) បុគ្គលសូម្បីចេះនូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់បានសម្រេចនូវចរណៈ ( សមាបត្តិប្រាំបី ) ទេ ក៏មិនគប្បីរួចចាកទុក្ខឡើយ ខ្ញុំសំគាល់ថា វេទទាំងឡាយជាសភាពឥតផល មានតែចរណៈដែលប្រកបដោយការសង្រួម ទើបជាការពិតប្រាកដ ។

[ ៣៩ ] ( បុរោហិត... ) ខ្ញុំមិនមែនពោលថា វេទទាំងឡាយជាសភាពឥតផលទេ តែចរណៈដែលប្រកបដោយការសង្រួម ជារបស់ពិតមែន ឯបុគ្គលរៀននូវវេទទាំងឡាយ គ្រាន់តែបាននូវកិត្តិសព្ទ បុគ្គលអ្នកទូន្មានដោយចរណៈហើយ ទើបបានដល់នូវការស្ងប់រម្ងាប់ ( និព្វាន ) ។

[ ៤០ ] ( ឧទ្ទាលកៈ... ) មាតាបិតា និងផៅពង្សត្រូវតែកូនចិញ្ចឹម

អាត្មាកើតអំពីបុគ្គលណា បុគ្គលនោះឯងនៅជាបុគ្គលនោះដដែល អាត្មាឈ្មោះឧទ្ទាលកៈ ជាអ្នកតវង្សត្រកូលនៃសោត្ថិយគោត្តដ៏ចម្រើន ។

[ ៤១ ] ( បុរោហិត... ) ម្នាលអ្នកដ៏ចម្រើន បុគ្គលឈ្មោះថាព្រាហ្មណ៍ តើដោយប្រការដូចម្តេច បុគ្គលមានគុណធម៌បរិបូណ៌ តើដោយប្រការដូចម្តេច មួយទៀត ការរលត់កិលេស តើដោយប្រការដូចម្តេច បុគ្គលដែលគេហៅថា អ្នកតាំងនៅក្នុងធម៌ តើដោយប្រការដូចម្តេច ។

[ ៤២ ] ( ឧទ្ទាលកៈ... ) បុគ្គលកាន់យកនូវភ្លើងហើយ ធ្វើនូវការបម្រើមិនឲ្យមានចន្លោះ ឈ្មោះថាព្រាហ្មណ៍ ព្រាហ្មណ៍កាលស្រោចទឹក ( អភិសេក ) បូជា ( នូវយញ្ញ ) ហើយលើកនូវសសរយញ្ញ ព្រាហ្មណ៍ធ្វើយ៉ាងនេះ ឈ្មោះថា ជាអ្នកមានសេចក្តីក្សេម ( ជនទាំងឡាយ ) ហៅ ( ព្រាហ្មណ៍នោះ ) ថា ជាអ្នកឋិតនៅក្នុងធម៌ ដោយហេតុនោះ ។

[ ៤៣ ] ( បុរោហិត... ) សេចក្តីបរិសុទ្ធ ពុំមែនមានដោយការស្រោចទឹកទេ បុគ្គលដែលឈ្មោះថាព្រាហ្មណ៍អ្នកបរិបូណ៌ដោយគុណធម៌ ខន្តិសោរច្ចៈ និងបុគ្គលអ្នករំលត់ទុក្ខបាននោះ មិនមាន ( ដោយការស្រោចទឹកជាដើមទេ ) ។

[ ៤៤ ] ( ឧទ្ទាលកៈ... ) នែអ្នកដ៏ចម្រើន បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ តើដោយប្រការដូចម្តេច បុគ្គលដែលជាអ្នកមានគុណធម៌ដ៏បរិបូណ៌ តើដោយប្រការដូចម្តេច ម្យ៉ាងទៀត ការរំលត់កិលេស តើដោយប្រការដូចម្តេច បុគ្គលដែលគេហៅថាជាអ្នកឋិតនៅក្នុងធម៌ តើដូចម្តេច ។

[ ៤៥ ] ( បុរោហិត... ) បុគ្គលមិនមានស្រែចម្ការ មិនមានផៅពង្ស មិនមានសេចក្តីប្រកាន់ មិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីលោភដ៏លាមក អស់សេចក្តីជាប់ចំពាក់ក្នុងភព ព្រាហ្មណ៍ធ្វើយ៉ាងនេះ ទើបឈ្មោះថា ជាអ្នកដល់នូវសេចក្តីក្សេម ( ជនទាំងឡាយ ) ហៅ ( ព្រាហ្មណ៍នោះ ) ថាជាអ្នកឋិតនៅក្នុងធម៌ ដោយហេតុនោះ ។

[ ៤៦ ] ( ឧទ្ទាលកៈ... ) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកចណ្ឌាល និងជនអ្នកកើបសំរាម ពួកជនទាំងអស់ ឈ្មោះថាជាអ្នកស្ងួតបូត ជាអ្នកទូន្មានឥន្ទ្រិយបានហើយ ពួកជនទាំងអស់ឈ្មោះថាមានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមក មានដល់ជនទាំងអស់ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំ ( ដែរឬ ) ។

[ ៤៧ ] ( បុរោហិត... ) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាល និងជនអ្នកកើបសំរាម ពួកជនទាំងអស់ដែលជាអ្នកស្ងួតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់ឈ្មោះថា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរនិងទោសដ៏លាមកមិនមាន ដល់ពួកជនទាំងអស់ ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំឡើយ ។

[ ៤៨ ] ( ឧទ្ទាលកៈ... ) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាល និងជនអ្នកកើបសំរាម ពួកជនទាំងអស់ ដែលជាអ្នកស្ងួតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់ឈ្មោះថា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរនិងទោសដ៏លាមក មិនមានដល់ជនទាំងអស់

ដែលមានសេចក្តីត្រជាក់ត្រជុំឡើយ ( កាលបើយ៉ាងនេះ ) អ្នកប្រព្រឹត្តនូវភាពនៃខ្លួនជាព្រហ្ម គួរឲ្យគេសរសើរ ហើយញ៉ាំងវង្សត្រកូលនៃសោត្ថិយគោត្ត ( ឲ្យវិនាស ) ។

[ ៤៩ ] ( បុរោហិត... ) វិមានដែលគេប្រក់ដោយសំពត់ទាំងឡាយ មានពណ៌ក្រហមផ្សេងៗ ស្រមោលរបស់សំពត់ទាំងនោះ មិនផ្សេងគ្នាឡើយ ( មានសម្បុរតែមួយបែប ) ការជ្រលក់នោះ ក៏មិនផ្សេងគ្នាដែរ ( យ៉ាងណាមិញ ) សូម្បីមនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ ពួកមាណពបរិសុទ្ធ ( ដោយអរិយមគ្គ ) ក្នុងកាលណា ពួកជនមានវត្តល្អ បានដឹងនូវនិព្វានធម៌ ក៏មិនសាកសួរ នូវជាតិរបស់មាណពទាំងនោះ ( ក្នុងកាលនោះ ) ឡើយ ។

## ចប់ ឧទ្ទាលកជាតក ទី ៤ ។

# អដ្ឋកថា

## ឧទ្ទាលកជាតក

[ ៣៦-៤៩ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ កុហកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ខរាជិនា ជដិលា បង្កទន្តា** ដូច្នេះជាដើម ។

រឿងសង្ខេបមានដូច្នេះថា ភិក្ខុនោះ បួសក្នុងសាសនា ដែលមានធម៌ជា គ្រឿងនាំចេញចាកទុក្ខបានហើយ ក៏គង់ពេញចិត្តប្រព្រឹត្តនូវរឿងកុហក ៣ ស្ថាន ដើម្បីត្រូវការបច្ច័យទាំង ៤ ។ កាលនោះពួកភិក្ខុ កាលប្រកាសទោសរបស់ លោក តាំងរឿងសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុឈ្មោះនោះ បួសក្នុងសាសនា ដែលប្រកបដោយធម៌ជាគ្រឿងនាំចេញចាកទុក្ខបែប នេះ ហើយ គង់អាស្រ័យការកុហកដើម្បីចិញ្ចឹមជីវិត ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនា គ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុង កាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អ្នកក៏ធ្លាប់កុហកដូចគ្នា ទើប ទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាបុរោហិត ជាបណ្ឌិតឈ្លាសវៃ ។ ថ្ងៃមួយ ព្រះពោធិសត្វនោះទៅលេងឧទ្យាន ឃើញស្រីផ្កាមាសរូបស្អាតម្នាក់ជាប់ចិត្ត

សម្រេចការនៅរួមជាមួយនាង នាងអាស្រ័យបុរោហិតនោះ ក៏មានគភ៌ កាលដឹងថាខ្លួនមានគភ៌ ក៏ប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំមានទម្ងន់ហើយ ក្នុងពេលកុមារកើត កាលខ្ញុំនឹងដាក់ឈ្មោះ តើដាក់ឈ្មោះគេដូចម្ដេច បុរោហិតគិតថា ក្មេងកើតក្នុងផ្ទៃរបស់នាងវណ្ណទាសី មិនអាចដាក់ឈ្មោះតាមត្រកូលបាន ក៏ពោលថា នែនាង ដើមឈើដែលការពារខ្យល់បានមួយដើមនេះ ឈ្មោះថា ដើមឧទ្ទាលកៈ ព្រោះយើងបានកុមារក្នុងទីនេះ នាងគួរដាក់ឈ្មោះគេថាឧទ្ទាលកៈចុះ ហើយបានឲ្យចិញ្ចៀនពាក់ម្រាមដៃដោយប្រាប់ថា បើជាកូនស្រីគប្បីចិញ្ចឹមក្មេងនោះ ដោយចិញ្ចៀននេះ បើជាកូនប្រុស គប្បីបញ្ជូនខ្លួនគេ ដែលគេធំហើយដល់ខ្ញុំ ។ បន្ទាប់មក នាងក៏ប្រសូតកូនប្រុស បានដាក់ឈ្មោះថា ឧទ្ទាលកៈ ។

កុមារនោះលុះចម្រើនវ័យហើយសួរមាតាថា បពិត្រអ្នកម៉ែ អ្នកណាជាឪពុករបស់ខ្ញុំ នាងឆ្លើយថា គឺបុរោហិត ។ កុមារពោលថា បើដូច្នោះ ខ្ញុំត្រូវរៀនទូវវេទ ហើយទទួលចិញ្ចៀននិងតម្លៃទ្រនិបអាចារ្យអំពីដៃមាតាធ្វើដំណើរទៅកាន់នគរតក្កសិលា រៀនទូវសិល្បសាស្ត្រក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ឃើញគណៈតាបសមួយគណៈគិតថា ក្នុងសម្នាក់របស់ពួកនេះគង់មានសិប្បៈដ៏ប្រសើរ អញនឹងរៀនសិប្បៈនោះ ព្រោះការលោភក្នុងសិប្បៈទើបបួស ធ្វើវត្ត បដិបត្តិ ដល់តាបសទាំងនោះ ហើយពោលថា បពិត្រលោកអាចារ្យ សូមលោកឲ្យខ្ញុំសិក្សាក្នុងសិប្បៈដែលលោកចេះចុះ ។ តាបសទាំងនោះ ក៏ឲ្យសិក្សាតាមទំនងដែលខ្លួនដឹង ។ បណ្ដាតាបស ៥០០ មិនមានសូម្បីតែ

តាបសមួយរូបដែលឈ្មោះថាឧទ្ទាលកៈនោះ ។ ឧទ្ទាលកៈតែម្នាក់ ជាកំពូលជាងតាបសទាំងនោះខាងបញ្ញា ។ កាលនោះ ពួកតាបសទាំងនោះទើបប្រជុំគ្នាលើកតំណែងអាចារ្យឲ្យដល់ឧទ្ទាលកៈនោះហើយ ឧទ្ទាលកតាបស ពោលនឹងតាបសទាំងនោះថា អ្នកនិរទុក្ខ ពួកអ្នកនាំគ្នាបរិភោគត្រាវដំឡូង និងផ្លែឈើក្នុងព្រៃជាអាហារនៅក្នុងព្រៃ ហេតុអ្វីមិននាំគ្នាទៅកាន់ដែនដីមនុស្ស ពួកតាបសឆ្លើយថា លោកនិរទុក្ខ ធម្មតាពួកមនុស្ស ឲ្យទានច្រើនៗហើយក៏នឹងអារាធនាឲ្យធ្វើអនុមោទនា សូមឲ្យពោលធម្មកថា នាំគ្នាសួរបញ្ហា ពួកខ្ញុំមិនទៅកាន់ទីកដីមនុស្សព្រោះខ្លាចភ័យនោះ ។ តាបសនោះពោលថា ទោះបីជាស្តេចចក្រពត្តិការពោលឲ្យចាប់ចិត្តជាភារៈរបស់ខ្ញុំ ពួកលោកកុំខ្លាចឡើយ ទើបត្រាច់ទៅជាមួយពួកតាបសទាំងនោះ ដល់នគរពារាណសីជាលំដាប់ ស្នាក់នៅក្នុងព្រះរាជឧទ្យាន លុះស្អែកឡើង ក៏ត្រាច់ភិក្ខាទៅតាមទ្វារស្រុក ជាមួយពួកតាបសទាំងពួង ។ ពួកមនុស្សនាំគ្នាឲ្យមហាទាន ស្អែកឡើងពួកតាបសក៏នាំគ្នាចូលកាន់ព្រះនគរ ។ ពួកមនុស្ស បាននាំគ្នាឲ្យមហាទាន ឧទ្ទាលកតាបសធ្វើអនុមោទនា ពោលនូវមង្គល វិសជ្ជនានូវបញ្ហា ពួកមនុស្សនាំគ្នាជ្រះថ្លា បានប្រគេនបច្ច័យសន្និកសន្ទាប់ ។ អ្នកនគរដែលជាប្រធាន នាំគ្នាក្រាបទូលដល់ព្រះរាជាថា តាបសទ្រទ្រង់ធម៌ ជាបណ្ឌិត ជាសាស្តានៃគណៈ មកដល់ហើយ ។ ព្រះរាជាត្រាស់សួរថា តាបសទាំងនោះនៅឯណា ទ្រង់បានដឹងថានៅក្នុងឧទ្យាន ក៏ត្រាស់ថា សាធុ ថ្ងៃនេះយើងនឹងទៅជួបតាបសទាំងនោះ ។ មានបុរសម្នាក់ បានទៅប្រាប់ដល់ឧទ្ទា-

លកតាបសថា បានឮថា ព្រះរាជានឹងយាងមកសួរសុខទុក្ខលោកម្ចាស់ទាំងឡាយ ។ តាបសហៅគណៈឥសីមកប្រាប់ថា អ្នកនិរទុក្ខទាំងឡាយ បានឮថាព្រះរាជាយាងមក ធម្មតាទ្រង់ជាអ្នកធំ ធ្វើឲ្យពេញចិត្តបានមួយថ្ងៃហើយ ក៏ពេញចិត្តទៅមួយជីវិត ។ ពួកតាបសនាំគ្នាសួរថា បពិត្រលោកអាចារ្យ ពួកខ្ញុំត្រូវធ្វើដូចម្ដេច ។ ឧទ្ទាលកតាបសពោលយ៉ាងនេះថា បណ្ដាពួកលោក ពួកខ្លះចូរប្រព្រឹត្តវគ្គុលិវត្ត គឺប្រតិបត្តិដូចសត្វប្រចៀវ ( យកជើងពាក់លើមែកឈើសំយុងក្បាលចុះមកក្រោម ) ពួកខ្លះចូរអង្គុយប្រហោង ពួកខ្លះចូរនាំគ្នាដេកលើបន្លា ពួកខ្លះចូរអាំងភ្លើង ៥ គំនរ ពួកខ្លះចូរនាំគ្នាត្រាំទឹក ពួកខ្លះចូរនាំគ្នាស្វាធ្យាយមន្តក្នុងទីនោះ ៗ ពួកតាបសក៏ធ្វើតាមនោះ ចំណែកខ្លួនឯងបបួលតាបសដែលឆ្លាតវ័យ មានវាទៈពូកែ ៨ ឬ ១០ អង្គ ដាក់គម្ពីរដែលស្អាតលើជើងអាធារ ចោមរោមដោយអន្តេវាសិក អង្គុយលើអាសនៈ ដែលរៀបចំទុកយ៉ាងល្អ ។ ខណៈនោះ ព្រះរាជាត្រាស់បបួលបុរោហិត យាងទៅកាន់ព្រះរាជឧទ្យាន ជាមួយបរិវារធំ ទតឃើញតាបសទាំងនោះ នាំគ្នាប្រព្រឹត្តតបៈខុសៗគ្នា ទ្រង់ជ្រះថ្លាថា ជនទាំងនេះផុតហើយចាកភ័យក្នុងអបាយ យាងដល់សម្នាក់ឧទ្ទាលកតាបស ទ្រង់ធ្វើបដិសណ្ឋារៈ អង្គុយក្នុងចំណែកម្ខាង មានព្រះហឫទ័យសោមនស្ស កាលនឹងត្រាស់សន្ទនាជាមួយបុរោហិត បានត្រាស់គាថាដំបូងថា

> ពួកជដិលណា ដណ្ដប់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រឡាក់ដោយមន្ទិល មានក្អែកមិនបន្តក់ មានរូបអាក្រក់ កំពុង

*រាយនូវមន្ត ជដិលទាំងនោះ បានដឹងនូវការប្រព្រឹត្តនូវតបៈ*
*និងការស្វាធ្យាយនូវមន្តនេះ ក្នុងសេចក្ដីព្យាយាម ជារបស់*
*មនុស្ស នឹងបានរួចចាកអបាយដែរឬ ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **ខរាជិនា** *សេចក្ដីថា ប្រកបដោយស្បែកខ្លា ទាំងក្រចក ។ បទថា* **បង្កទន្តា** *សេចក្ដីថា មានធ្មេញដែលមន្ទិលប្រឡាក់ ហើយ ព្រោះមិនទំពាឈើស្ទន់ ។ បទថា* **ទុម្មក្ខរូបា** *សេចក្ដីថា ភ្នែកមិន បន្តក់ រាងកាយមិនប្រដាប់តាក់តែង មានសំពត់ពាក់ចៀងស្មោកគ្រោក ។ បទថា* **មានុសកេ បយោគេ** *សេចក្ដីថា ក្នុងសេចក្ដីព្យាយាមដែលពួកមនុស្ស គប្បីធ្វើ ។ បទថា* **ឥទំ វិទូ** *សេចក្ដីថា ដឹងនូវការប្រព្រឹត្តតបៈនិងការទន្ទេញ មន្តនេះ ។ បទថា* **អបាយា** *សេចក្ដីថា ព្រះរាជាត្រាស់សួរថា ពួកអាចារ្យ ផុតចាកអបាយ ៤ ទាំងនេះបានហើយឬ ។*

*បុរោហិត បានស្ដាប់ពាក្យនោះហើយត្រិះរិះថា ព្រះរាជាអង្គនេះ ទ្រង់ ជ្រះថ្លាក្នុងឋានៈដែលមិនគួរ អញនៅស្ងៀមមិនបាន ទើបពោលគាថាទី ២ ថា*

*បពិត្រមហារាជ បើបុគ្គលជាពហុស្សូត មិនប្រព្រឹត្តធម៌ ធ្វើតែ*
*អំពើលាមកទាំងឡាយ បុគ្គលនោះ សូម្បីចេះនូវវេទ មួយ-*
*ពាន់ ហើយអាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់*
*បានសម្រេចនូវចរណៈ ( សមាបត្តិប្រាំបី ) ទេ ក៏មិនគប្បី*
*រួចចាកទុក្ខឡើយ ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **ពហុស្សុតោ** *សេចក្ដីថា បពិត្រមហារាជ*

បើបុគ្គលតម្កើងខ្លួនថាអញជាពហុស្សូតដូច្នេះ សូម្បីមានវេទជំនាញ ក៏មិនបាន ប្រព្រឹត្តកុសលធម៌ទាំង ១០ ប្រការ គប្បីធ្វើបាបដោយទ្វារទាំង ៣ បានដូច គ្នា វេទទាំង ៣ ចូរលើកទុកចុះ សូម្បីមានវេទមួយពាន់ អាស្រ័យភាពជា ពហុស្សូតនោះ តែមិនបានសម្រេចនូវចរណធម៌ គឺសមាបត្តិ ៨ ហើយ ក៏ ផុតចាកអបាយទុក្ខមិនបានឡើយ ។

ឧទ្ទាលកតាបសបានស្តាប់ពាក្យដូច្នេះហើយគិតថា ព្រះរាជាទ្រង់ជ្រះថ្លា ក្នុងគណៈឥសីតាមអធ្យាស្រ័យហើយ តែព្រាហ្មណ៍នេះមកស្ទាក់គោដែលកំពុង ទៅ ដូចបោលសំរាមលើកត្ត ដែលគេរៀបចំទុកហើយ អញត្រូវពោល ជាមួយព្រាហ្មណ៍ កាលនឹងពោលទើបពោលគាថាទី ៣ ថា

បុគ្គលសូម្បីចេះនូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជា
ពហុស្សូតនោះ តែមិនទាន់បានសម្រេចនូវចរណៈ ( សមា
បត្តិប្រាំបី ) ទេ ក៏មិនគប្បីរួចចាកទុក្ខឡើយ ខ្ញុំសំគាល់ថា
វេទទាំងឡាយ ជាសភាពឥតផល មានតែចរណៈដែលប្រកប
ដោយការសង្រួម ទើបជាការពិតប្រាកដ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អផលា** សេចក្តីថា ក្នុងវាទៈរបស់លោក វេទទាំងឡាយនិងសិប្បៈដ៏សេស រមែងដល់នូវការមិនមានផល ព្រោះហេតុ នោះនឹងរៀនវេទនិងសិប្បៈទាំងនោះធ្វើអ្វី ចរណៈនិងការសង្រួមដោយសីល ប៉ុណ្ណោះ ទើបសម្រេចជាសច្ចៈឯណានីមួយ ។

លំដាប់នោះ បុរោហិតពោលគាថាថា

ខ្ញុំមិនមែនពោលថា វេទទាំងឡាយ ជាសភាពឥតផលទេ តែចរណៈដែលប្រកបដោយការសង្រួម ជារបស់ពិតមែន ឯបុគ្គលរៀននូវវេទទាំងឡាយ គ្រាន់តែបាននូវកិត្តិសព្ទ បុគ្គលអ្នកទូន្មានដោយចរណៈហើយ ទើបបានដល់នូវការស្ងប់រម្ងាប់ ( និព្វាន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆហោវ** សេចក្តីថា យើងមិនបានពោលថា វេទទាំងឡាយមិនមានផល តែចរណធម៌មួយអន្លើដោយការសង្រួមជាសេចក្តីពិត គឺជាភាវៈដ៏ឧត្តម ព្រោះហេតុនោះឯង ទើបអាចផុតចាកទុក្ខបាន ។ បទថា **សន្តឹ បុណាតិ** សេចក្តីថា កាលបុគ្គលទូន្មានខ្លួនដោយចរណធម៌ ពោលគឺសមាបត្តិ រមែងដល់នូវព្រះនិព្វាន ដែលធ្វើសេចក្តីនូវស្ងប់នៃហទយៈ ។

ឧទ្ទាលកតាបសបានស្តាប់ដូច្នោះហើយ គិតថា យើងមិនអាចឆ្លើយឆ្លងនឹងបុរោហិតនេះ ដោយអំណាចការប្រកែកប្រណាំងបាន ធម្មតាបុគ្គលដែលមិនធ្វើនូវការត្រេកអរក្នុងពាក្យដែលត្រូវពោលមិនមានឡើយ អញត្រូវប្រាប់ភាពជាកូនដល់បុរោហិត ទើបពោលគាថាទី ៥ ថា

មាតាបិតា និងផៅពង្សត្រូវតែកូនចិញ្ចឹម អាត្មាកើតអំពីបុគ្គលណា បុគ្គលនោះឯងនៅជាបុគ្គលនោះដដែល អាត្មាឈ្មោះឧទ្ទាលកៈ ជាអ្នកតវង្សត្រកូលនៃសោត្ថិយគោត្តដ៏ចម្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភច្ចា** សេចក្តីថា មាតាបិតានិងញាតិមិត្តដ៏សេស ជាបុគ្គលបានឈ្មោះថា ជាអ្នកដែលបុត្តត្រូវចិញ្ចឹម អាត្មាជាកូនអ្នក

នោះឯង មែនពិត ខ្ញុំនោះឯងរមែងកើតដើម្បីបុគ្គលណា សូម្បីអាត្មាក៏កើតហើយត្រង់គល់ឧទ្ទាលកៈ ព្រោះលោកដាក់ឈ្មោះទុកហើយនោះឯង ទើបអាត្មាឈ្មោះឧទ្ទាលកៈ ។

កាលបុរោហិតសួរថា ពិតឬលោកម្ចាស់ឧទ្ទាលកៈ ឧទ្ទាលកតាបសឆ្លើយថា ពិត ក៏សួរបន្តថា ខ្ញុំឲ្យគ្រឿងសម្គាល់ទុកដល់មាតារបស់លោក គ្រឿងសម្គាល់នោះនៅឯណា ទើបឧទ្ទាលកតាបសឆ្លើយថា នេះនែព្រាហ្មណ៍ ពោលបណ្តើរដាក់ចិញ្ចៀនលើដៃបុរោហិតបណ្តើរ ព្រាហ្មណ៍នៅចាំចិញ្ចៀនបាន តែនៅតែពោលថា លោកជាព្រាហ្មណ៍ព្រោះទន្ទឹងការមានបាន តែចេះ ព្រាហ្មណធម៌ឬ កាលសួរដល់ព្រាហ្មណធម៌ ទើបពោលគាថាទី ៦ ថា

ម្នាលអ្នកដ៏ចម្រើន បុគ្គលឈ្មោះថាព្រាហ្មណ៍ តើដោយប្រការដូចម្តេច បុគ្គលមានគុណធម៌បរិបូណ៌ តើដោយប្រការដូចម្តេច មួយទៀត ការរលត់កិលេស តើដោយប្រការដូចម្តេច បុគ្គលដែលគេហៅថា អ្នកតាំងនៅក្នុងធម៌ តើដោយប្រការដូចម្តេច ដូច្នេះ ។

ឧទ្ទាលកតាបស កាលប្រាប់ដល់បុរោហិត ទើបពោលគាថាទី ៧ ថា

បុគ្គលកាន់យកនូវភ្លើងហើយ ធ្វើនូវការបម្រើមិនឲ្យមានចន្លោះ ឈ្មោះថា ព្រាហ្មណ៍ ព្រាហ្មណ៍កាលស្រោចទឹក ( អភិសេក ) បូជា ( នូវយញ្ញ ) ហើយលើកនូវសសរយញ្ញ ព្រាហ្មណ៍ធ្វើយ៉ាងនេះ ឈ្មោះថា ជាអ្នកមានសេចក្តីក្សេម ( ជនទាំង

ឡាយ ) ហៅ ( ព្រាហ្មណ៍នោះ ) ថា ជាអ្នកឋិតនៅក្នុងធម៌ ដោយហេតុនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆិរំ កត្វា អគ្គិមាធាយ** សេចក្ដីថា បុគ្គលជាព្រាហ្មណ៍ត្រូវបង្កាត់ភ្លើងបម្រើភ្លើងកុំឲ្យដាច់ ។ បទថា **អាធោសិញ្ចំ យជំ ឧស្សេតិ យូបំ** សេចក្ដីថា កាលធ្វើនូវការស្រោចទឹកដើម្បីនឹងបូជាសម្មាបាស-យញ្ញក្ដី វាជបេយ្យយញ្ញក្ដី និរគ្គឡយញ្ញក្ដី ត្រូវឲ្យលើកឈើប្រត់មាសឡើងធ្វើ ។ នេះទើបជាព្រាហ្មណ៍ ដែលចូលដល់នូវការក្សេម ។ បទថា **ខេមី** បានដល់ ដែលដល់នូវសភាពក្សេម ។ បទថា **អមាបយឹសុ** សេចក្ដីថា ដោយហេតុនោះឯង ជនទាំងឡាយរមែងនាំគ្នាហៅថា បុគ្គលតាំងនៅក្នុងធម៌ ។

បុរោហិតបានស្ដាប់ដូច្នោះហើយ កាលតិះដៀលព្រាហ្មណ៍តាមដែលពោលទើបពោលគាថាទី ៨ ថា

សេចក្ដីបរិសុទ្ធ ពុំមែនមានដោយការស្រោចទឹកទេ បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ អ្នកបរិបូណ៌ដោយគុណធម៌ ខន្តិ សោរច្ចៈ និងបុគ្គលអ្នករំលត់ទុក្ខបាននោះ មិនមាន ( ដោយការស្រោចទឹកជាដើមទេ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សេចនេន** សេចក្ដីថា ក្នុងព្រាហ្មណធម៌ទាំងឡាយ ដែលតាបសនោះពោល បុរោហិតបដិសេធទាំងអស់ ដោយសម្ដែងត្រឹមតែមួយប្រការ គឺដោយការស្រោចទឹក សេចក្ដីនេះមានអធិប្បាយថា ការបរិសុទ្ធ មានមិនបានឡើយ ដោយការបម្រើភ្លើង ដោយការស្រោចទឹក ឬ

ដោយការសម្លាប់សត្វបូជាយញ្ញ ដោយហេតុត្រឹមប៉ុណ្ណេះ នឹងក្លាយជាព្រា-ហ្មណ៍បរិបូណ៌គ្រប់គ្រាន់ក៏មិនបាន ការអត់ធន់ គឺការអត់ធ្មត់ក៏មានមិនបាន ការស្ងប់ស្ងៀមគឺសីលនឹងមានមិនបាន និងឈ្មោះថាជាព្រាហ្មណ៍រំលត់ដោយជុំវិញ ព្រោះការរំលត់ជុំវិញនូវកិលេសក៏មិនបាន ។

លំដាប់នោះ ឧទ្ទាលកតាបសកាលនឹងសួរថា បើមិនជាព្រាហ្មណ៍ដោយហេតុយ៉ាងនេះ តើជាព្រាហ្មណ៍ដោយហេតុដូចម្តេច ក៏ពោលគាថាទី ៩ ថា

នែអ្នកដ៏ចម្រើន បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ តើដោយ
ប្រការដូចម្តេច បុគ្គលដែលជាអ្នកមានគុណធម៌ដ៏បរិបូណ៌ តើ
ដោយប្រការដូចម្តេច ម្យ៉ាងទៀត ការរំលត់កិលេសតើដោយ
ប្រការដូចម្តេច បុគ្គលដែលគេហៅថាជាអ្នកឋិតនៅក្នុងធម៌ តើ
ដូចម្តេច ដូច្នេះ ។

ចំណែកបុរោហិត កាលពោលដល់តាបស ក៏ពោលគាថាបន្តទៅថា

បុគ្គលមិនមានស្រែចម្ការ មិនមានផៅពង្ស មិនមានសេចក្តី
ប្រកាន់ មិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីលោភ ដ៏លា-
មក អស់សេចក្តីជាប់ចំពាក់ក្នុងភព ព្រាហ្មណ៍ធ្វើយ៉ាងនេះទើប
ឈ្មោះថា ជាអ្នកដល់នូវសេចក្តីក្សេម ( ជនទាំងឡាយ )
ហៅ ( ព្រាហ្មណ៍នោះ ) ថាជាអ្នកឋិតនៅក្នុងធម៌ ដោយ
ហេតុនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អក្ខេត្តពន្ធុ** បានដល់ ដែលមិនមានស្រែ មិន

មានគ្នីគ្នា អធិប្បាយថា លោកជាបុគ្គលវៀរហើយចាកការគ្រប់គ្រងស្រែចម្ការ ស្រុក តំបន់ ឈ្មោះថាជាអ្នកមិនមានស្រែចម្ការ វៀរផ្តាច់ហើយចាកការគ្រប់គ្រងពួកគណៈ ខ្សែស្រឡាយ ញាតិមិត្ត គ្នីគ្នា សម្លាញ់ និងគ្នីគ្នាខាងសិប្បៈ ឈ្មោះថាជាអ្នកមិនមានគ្នា ។ បទថា **អមមោ** បានដល់ ដែលវៀរចាកការប្រកាន់ថា ជារបស់អញ ដោយអំណាចតណ្ហា និងទិដ្ឋិក្នុងសត្វនិងសង្ខារទាំងឡាយ ។ បទថា **និរាសោ** បានដល់ ដែលវៀរហើយ ចាកការសង្ឃឹមក្នុងញាតិក្នុងទ្រព្យក្នុងបុត្តនិងក្នុងជីវិត ។ បទថា **និល្លោភបាបោ** បានដល់ វៀរចាកសេចក្តីលោភដែលជាបាប បានដល់ សេចក្តីលោភក្នុងឋានៈដែលមិនស្មើ ។ បទថា **ភវលោភខីណោ** បានដល់ អស់នូវការត្រេកអរក្នុងភពហើយ ។

លំដាប់នោះ ឧទ្ទាលកៈពោលគាថាថា

ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកចណ្ឌាល និងជនអ្នកកើបសំរាម ពួកជនទាំងអស់ ឈ្មោះថាជាអ្នកស្ងួតបូត ជាអ្នកទូន្មានឥន្ទ្រិយបានហើយ ពួកជនទាំងអស់ ឈ្មោះថាមានទុក្ខរលត់ហើយ គុណដ៏ប្រសើរនិងទោសដ៏លាមក មានដល់ជនទាំងអស់ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជុំ ( ដែរឬ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថិ សេយ្យោវ បាបិយោ** សេចក្តីថា ឧទ្ទាលកៈសួរថា ក្សត្រជាដើមទាំងនេះ គ្រប់គ្នារមែងមានគុណសម្បត្តិ គឺកាព

ជាបុគ្គលត្រេកអរបានទាំងអស់ កាលបើយ៉ាងនោះហើយ ការទាប ការខ្ពស់ យ៉ាងនេះថា បុគ្គលនោះល្អជាង បុគ្គលនេះអាក្រក់ជាង មានឬមិនមាន ។

លំដាប់នោះ ដើម្បីចង្អុលបង្ហាញថា ចាប់តាំងពីសម្រេចអរហត្តទៅ ឈ្មោះថាការទាប ការខ្ពស់ រមែងមិនមានដល់បុគ្គលនោះ ទើបព្រាហ្មណ៍ពោលគាថានេះថា

ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាលនិងជនអ្នកកើបសំរាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់ឈ្មោះថា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមកមិនមាន ដល់ពួកជនទាំងអស់ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំឡើយ ដូច្នេះ ។

លំដាប់នោះ ឧទ្ទាលកៈកាលតិះដៀលបុរោហិតនោះ ទើបពោលគាថា ២ ថា

ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាល និងជនអ្នកកើបសំរាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់ឈ្មោះថា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមក មិនមានដល់ជនទាំងអស់ដែលមានសេចក្តីត្រជាក់ត្រជំឡើយ ( កាលបើយ៉ាងនេះ ) អ្នកប្រព្រឹត្តនូវភាពនៃខ្លួនជាព្រហ្ម គួរឲ្យគេសរសើរ ហើយញុំាងវង្សត្រកូលនៃសោត្ថិយ

គោត្ត ( ឲ្យវិនាស ) ដូច្នេះ ។

គាថានោះមានអធិប្បាយថា សូម្បីសេចក្ដីពិសេសរបស់បុគ្គលមានគុណទាំងនោះមិនមានឡើយ នឹងរមែងជាវណ្ណៈតែមួយបាន កាលបើយ៉ាងនោះ លោកក៏កំពុងទម្លាយភាពជាឧកតោសុជាតិ ឈ្មោះថា កំពុងប្រព្រឹត្តទម្លាយនូវភាពជាព្រាហ្មណ៍ ឲ្យស្មើគ្នានឹងចណ្ឌាល ទម្លាយនូវភាពជាពូជពង្សនៃសោត្ថិយត្រកូលចោល ។ កាលនោះ បុរោហិតកាលប្រៀបធៀបឲ្យយល់ ទើបពោលគាថា ២ ថា

វិមានដែលគេប្រក់ដោយសំពត់ទាំងឡាយ មានពណ៌ក្រហមផ្សេងៗ ស្រមោលរបស់សំពត់ទាំងនោះ មិនផ្សេងគ្នាឡើយ ( មានសម្បុរតែមួយបែប ) ការជ្រលក់នោះក៏មិនផ្សេងគ្នាដែរ ( យ៉ាងណាមិញ ) សូម្បីមនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ ពួកមាណពបរិសុទ្ធ ( ដោយអរិយមគ្គ ) ក្នុងកាលណា ពួកជនមានវត្តល្អ បានដឹងនូវនិព្វានធម៌ ក៏មិនសាកសួរនូវជាតិរបស់មាណពទាំងនោះ ( ក្នុងកាលនោះ ) ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិមានំ** បានដល់ ផ្ទះ ឬមណ្ឌប ។ បទថា **ឆាយា** បានដល់ ស្រមោលរបស់សំពត់ទាំងនោះ ពណ៌ជ្រលក់ដែលមានច្រើនពណ៌ជារបស់វិចិត្រ ពណ៌ជ្រលក់នោះ មិនមាន ( ក្នុងស្រមោល ) ស្រមោលទាំងអស់ រមែងមានពណ៌តែមួយដូចគ្នាទាំងអស់ ។ បទថា **ឯវមេវ**

សេចក្តីថា ក្នុងពួកមនុស្សក៏ដូច្នោះដូចគ្នា ពួកព្រាហ្មណ៍ដែលមិនមានការដឹង ពួកខ្លះ រួមគ្នាបញ្ញត្តវណ្ណៈ ៤ ទុក ដោយមិនមានហេតុ អ្នកកុំប្រកាន់ថា សេចក្តីនេះមានឡើយ កាលណាបុគ្គលដែលជាបណ្ឌិតក្នុងលោកនេះ ផូរផង់ ដោយអរិយមគ្គ កាលនោះបណ្ឌិតបុរសដែលមានវត្តល្អ គឺមានសីល ព្រោះ ជ្រាបនិព្វានធម៌ តាមដែលលោកទាំងនោះសម្រេចហើយ លោកទាំងនោះ រមែងដោះនូវជាតិរបស់ខ្លួន ព្រោះថា តាំងអំពីសម្រេចព្រះនិព្វានទៅ ឈ្មោះ ជាជាតិ រមែងមិនមានប្រយោជន៍ឡើយ ។

ឧទ្ទាលកៈមិនអាចនាំបញ្ហាមកសួរទៀតបាន ក៏អង្គុយស្ងៀម ពេលនោះ ព្រាហ្មណ៍នោះក្រាបទូលដល់ព្រះរាជាថា បពិត្រមហារាជ ជនទាំងអស់ជាអ្នក កុហក នាំគ្នាទម្លាយនូវជម្ពូទ្វីបទាំងមូល នេះជាការកុហកពិត សូមទ្រង់ឲ្យ ឧទ្ទាលកៈសឹក តាំងឲ្យធ្វើជាបុរោហិត ឥសីទាំងអស់ ក៏ឲ្យសឹកចេញ ព្រះ រាជទានខែលនិងអាវុធ ឲ្យធ្វើជាសេវកៈចុះ ព្រះរាជាត្រាស់ថា សាធុលោក អាចារ្យ ទ្រង់ឲ្យធ្វើយ៉ាងនោះហើយ ។ ឧទ្ទាលកៈក៏ក្លាយជាខ្ញុំរាជការ ហើយ ទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុង

កាលមុន ភិក្ខុនេះក៏ធ្លាប់កុហកដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ឧទ្ទាលកៈតាបសក្នុងកាលនោះ បានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ចំណែកបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឧទ្ទាលកជាតក ចប់

# ភិសជាតក

[ ៥០ ] ( ឧបកាញ្ចនតាបសស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបាននូវសេះផង គោផង ប្រាក់ផង មាសផង ប្រពន្ធជាទីគាប់ចិត្តក្នុងលោកនេះផង ចូរនៅមូលមិត្តគ្នាដោយកូននិងប្រពន្ធទាំងឡាយចុះ ។

[ ៥១ ] ( តាបសទី ២ ស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរទ្រទ្រង់នូវផ្កាកម្រងផង នូវសំពត់ដែលគេនាំមកអំពីដែនកាសីនិងខ្លឹមចន្ទន៍ផង ចូរឲ្យបុគ្គលនោះមានកូនច្រើនផង ចូរឲ្យ ( បុគ្គលនោះ ) ធ្វើនូវសេចក្ដីអាឡោះអាល័យដ៏ក្លៀវក្លាក្នុងកាមទាំងឡាយផង ។

[ ៥២ ] ( តាបសទី ៣ ស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក ( បុគ្គលនោះ ) ចូរមានស្រូវច្រើន មានកសិកម្ម មានយស ( បាន ) នូវកូនទាំងឡាយ ជាគ្រហស្ថ មានទ្រព្យ ចូរ ( បាន ) នូវកាមគ្រប់យ៉ាង ចូរកុំឲ្យឃើញនូវវ័យ ( របស់ខ្លួន ) នៅគ្រប់គ្រងផ្ទះចុះ ។

[ ៥៣ ] ( តាបសទី ៤ ស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបានជាក្សត្រ អ្នកធ្វើនូវការរឹបជាន់ ជារាជាធិរាជ មានពល មានយស ចូរបានគ្រប់គ្រងផែនដីដែលមានសមុទ្ទទាំង ៤ ជាទីបំផុតចុះ ។

[ ៥៤ ] ( តាបសទី ៥ ស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណា

លួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរជាព្រាហ្មណ៍មិនប្រាស ចាករាគៈ ចូរប្រកបក្នុងគន្ធក្បួនយាមនិងនក្ខត្តឫក្ស បុគ្គលជាម្ចាស់នៃដែន ( ស្តេច ) ដែលមានយស ចូរបូជាព្រាហ្មណ៍នោះចុះ ។

[ ៥៥ ] ( តាបសទី ៦ ស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយរបស់លោក លោកទាំងអស់ ចូរសំគាល់ ( នូវបុគ្គលនោះ ) ថាជាអ្នកស្វាធ្យាយនូវវេទ ព្រមទាំងមន្តគ្រប់យ៉ាង ថាជាអ្នកមានតបៈ ពួកអ្នកជនបទចូរឃើញហើយបូជានូវបុគ្គលនោះចុះ ។

[ ៥៦ ] ( តាបសជាសម្លាញ់ស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបរិភោគនូវស្រុកសួយដ៏ស្តុកស្តម្ភដែលកុះករដោយវត្ថុ ៤ យ៉ាង ហាក់ដូចស្តេចវាសវៈប្រទានឲ្យ ចូរដល់នូវមរណៈ ទាំងមិនទាន់បានប្រាសចាករាគៈចុះ ។

[ ៥៧ ] ( តាបសជាខ្ញុំប្រុសស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបានជាធំក្នុងស្រុក ចូររីករាយដោយការរាំនិងច្រៀងទាំងឡាយក្នុងកណ្តាលនៃសម្លាញ់ កុំឲ្យបាននូវសេចក្តីវិនាសតិចតួចអំពីស្តេចឡើយ ។

[ ៥៨ ] ( នាងកាញ្ចនទេវីស្បថថា ) បពិត្រព្រាហ្មណ៍ ស្រីណា លួចក្រអៅឈូកទាំងឡាយរបស់លោក សូមឲ្យស្តេចឯករាជដែលទ្រង់ឈ្នះនូវផែនដីលើកតម្កើង ( ស្រីនោះ ) ឲ្យប្រសើរលើសជាងស្រីទាំងមួយពាន់ សូមឲ្យ ( ស្រីនោះ ) បានជាស្រីប្រសើរលើសជាងស្រីទាំងឡាយចុះ ។

[ ៥៩ ] ( នាងទាសីស្បថថា ) បពិត្រព្រាហ្មណ៍ ទាសីណាលួចក្រអៅឈូកទាំងឡាយរបស់លោក ក៏បណ្តាទាសីទាំងឡាយ ទាសីនោះចូរកុំញាប់ញ័រ ( ក្នុងកណ្តាល ) នៃម្ចាស់ទាំងឡាយដែលជួបជុំគ្នាទាំងអស់ ចូរបរិភោគនូវវត្ថុមានរសឆ្ងាញ់ ( ទាសីនោះ ) ចូរប្រព្រឹត្តនិយាយកុហក ព្រោះហេតុតែលាភចុះ ។

[ ៦០ ] ( ទេវតាស្បថថា ) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក ( បុគ្គលនោះ ) ចូរបានជាចៅអាវាសក្នុងមហាវិហារចុះ ចូរធ្វើនូវនវកម្មក្នុងនគរឈ្មោះកជង្គលៈចុះ ចូរធ្វើនូវបង្អួចឲ្យហើយតែមួយថ្ងៃចុះ ។

[ ៦១ ] ( ដំរីស្បថថា ) បពិត្រព្រាហ្មណ៍ ដំរីណាលួចក្រអៅឈូកទាំងឡាយរបស់លោក ដំរីនោះ ចូរជាប់ដោយអន្ទាក់ច្រើន ត្រង់កន្លែងទាំង ៦ ( គឺជើងទាំង ៤ កនិងចង្កេះ ) ចូរឲ្យគេនាំអំពីព្រៃ ជាទីរីករាយទៅកាន់រាជធានីចុះ ដំរីនោះ ចូរឲ្យគេចាក់ដោយកង្វេរទាំងឡាយ ដែលមានដងវែង មានបន្ទាពីរចុះ ។

[ ៦២ ] ( ស្វាស្បថថា ) បពិត្រព្រាហ្មណ៍ ស្វាណាលួចក្រអៅឈូកទាំងឡាយរបស់លោក ( ស្វានោះ ) ចូរមានប្រឡៀក ហើយគេបោះត្រចៀកបំពាក់សំណចុះ ឲ្យហ្មពស់ វាយដោយរំពាត់ ហើយចូរទៅរកមាត់ពស់ចុះ ឲ្យគេចងយ៉ាងមាំ ហើយដើរទៅកាន់ប្រកល្អកចុះ ។

[ ៦៣ ] ( ព្រះមហាសត្វស្បថថា ) នៃអ្នកដ៏ចម្រើនទាំងឡាយ

បុគ្គលណា ពោលនូវចំណែកដែលមិនបាត់ថាបាត់ ម្យ៉ាងទៀត បុគ្គលណា វង្វៀសបន្តិចបន្តួច ( ចំពោះអ្នកទាំងឡាយ ) បុគ្គលនោះ ចូរបាន និងចូរបរិភោគ នូវកាមទាំងឡាយចុះ ចូរស្លាប់ក្នុងកណ្តាលនៃផ្ទះចុះ ។

[ ៦៤ ] ( សក្កទេវរាជពោលថា ) ( សត្វទាំងឡាយ ) រមែងស្វែងរកនូវវត្ថុកាមនិងកិលេសកាមណា ហើយត្រាច់ទៅក្នុងលោក វត្ថុកាមនិងកិលេសកាមនុ៎ះ ជាទីប្រាថ្នាផង ជាទីរីករាយផង ជាទីស្រឡាញ់ផង ជាទីពេញចិត្តរបស់ទេវតា និងមនុស្សច្រើនគ្នាក្នុងជីវលោកនេះ ចុះហេតុអ្វីក៏ពួកឥសីមិនសរសើរនូវកាមទាំងឡាយ ។

[ ៦៥ ] ( មហាសត្វពោលថា ) ជនទាំងឡាយ ត្រូវគេវាយ ត្រូវគេចង ព្រោះតែកាមទាំងឡាយ សេចក្តីទុក្ខផង ភ័យផង ដែលកើតឡើង ក៏ព្រោះតែកាមទាំងឡាយ បពិត្រព្រះភូតាធិបតី សត្វទាំងឡាយស្រវឹងព្រោះកាមទាំងឡាយ ធ្វើនូវអំពើទាំងឡាយដ៏លាមក ព្រោះវង្វេង ។ ជនមានធម៌ដ៏លាមកទាំងឡាយនោះ ទទួលនូវបាប លុះបែកធ្លាយរាងកាយរមែងទៅកើតក្នុងនរក ព្រោះហេតុនោះ បានជាពួកឥសីមិនសរសើរនូវកាមទាំងឡាយព្រោះឃើញទោសក្នុងកាមគុណទាំងឡាយ ។

[ ៦៦ ] ( សក្ក... ) ខ្ញុំល្បងមើលទេ ខ្ញុំយកក្រអៅឈូកទាំងឡាយរបស់ឥសី ក្បែរឆ្នេរទៅកប់ទុកលើគោក ( ឥឡូវនេះខ្ញុំដឹងហើយថា ) ឥសីទាំងឡាយ ជាអ្នកបរិសុទ្ធ មិនមានបាប បពិត្រលោកជាព្រហ្មចារី នុ៎ះក្រអៅឈូកទាំងឡាយរបស់លោក ។

[ ៦៧ ] ( មហាសត្វ... ) ម្នាលទេវរាជ ជាសហស្សនេត្រ ( ពួកយើង ) មិនមែនជាអ្នករបាំរបស់អ្នកទេ ទាំងមិនមែនជាបុគ្គល គួរអ្នកលេងទេ មិនមែនជាផៅពង្ស ទាំងមិនមែនជាសម្លាញ់របស់អ្នកទេ ហេតុអ្វីក៏អ្នក (ធ្វើ) នូវសេចក្តីមើលងាយចំពោះបុគ្គលដទៃ ហើយលេងជាមួយនឹងពួកឥសី ។

[ ៦៨ ] ( សក្ក... ) បពិត្រតាបសដ៏ប្រសើរ លោកម្ចាស់ ជាអាចារ្យរបស់ខ្ញុំផង ជាបិតារបស់ខ្ញុំផង ម្លប់ព្រះបាទរបស់លោកម្ចាស់នេះ សូមជាទីពឹង ( របស់ខ្ញុំ ) ដែលមានសេចក្តីភ្លាំងភ្លាត់ហើយ បពិត្រតាបស មានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់នូវកំហុសម្តង បណ្ឌិតទាំងឡាយ មិនមានសេចក្តីក្រោធជាកម្លាំងទេ ។

[ ៦៩ ] ( មហាសត្វ... ) កាលដែលពួកឥសី ( នៅក្នុងព្រៃ ) សូម្បីតែមួយយប់ ក៏ឈ្មោះថាបាននៅល្អហើយ ព្រោះថាយើងទាំងឡាយ បានចួបនឹងព្រះវាសវៈជាម្ចាស់នៃទេវតា ពួកអ្នកដ៏ចម្រើនទាំងអស់គ្នា ចូរតាំងចិត្តឲ្យល្អចុះ ដ្បិតព្រាហ្មណ៍ ( ជាអាចារ្យរបស់អ្នកទាំងឡាយ ) បាននូវក្រអៅឈូកវិញហើយ។

[ ៧០ ] ( អភិសម្ពុទ្ធគាថា ) បងប្អូនប្រាំពីរនាក់ក្នុងកាលនោះ គឺ តថាគត ១ សារីបុត្ត ១ មោគ្គល្លាន ១ កស្សប ១ អនុរុទ្ធ ១ បុណ្ណ ១ អានន្ទ

១ ។ ក្នុងកាលនោះ ប្អូនស្រី គឺនាងឧប្បលវណ្ណា ទាសី គឺនាងខុជ្ជុត្តរា ក្នុងកាលនោះ ខ្ញុំប្រុស គឺគហបតិ ឈ្មោះចិត្តៈ ទេវតា គឺសាតាគិរយក្ខ ។ ក្នុងកាលនោះ ដំរីដ៏ប្រសើរ គឺដំរីឈ្មោះបាលិលេយ្យ ស្វាដ៏ប្រសើរ គឺមធុទៈ ក្នុងកាលនោះ ទេវរាជឈ្មោះសក្កៈ គឺកាឡុទាយី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

## ចប់ កិសជាតក ទី ៥ ។

# អដ្ឋកថា
# ភិសជាតក

[ ៥០-៧០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អស្សំ គវំ រជតំ ជាតរូបំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នជាក់ច្បាស់ក្នុងកុសជាតក តែក្នុងកាលនោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថាអ្នកអផ្សុកពិតឬ កាលភិក្ខុនោះទទួលថា ករុណាព្រះអង្គ ព្រះសាស្តាក៏ត្រាស់ថា ព្រោះហេតុអ្វី កាលភិក្ខុនោះទូលថា ព្រោះកិលេស ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលមានធម៌ជាគ្រឿងនាំចេញចាកទុក្ខបែបនេះ ហេតុអ្វីអាស្រ័យកិលេសធ្វើនូវការអផ្សុក បណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើងក្នុងលោក បួសក្នុងលទ្ធិពាហិរៈ ក៏គង់នាំគ្នាប្រារព្ធដល់វត្ថុកាម និងកិលេសកាម ធ្វើនូវពាក្យសម្បថ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាកូនរបស់ព្រាហ្មណមហាសាល មានសម្បត្តិ ៨០ កោដិ ពួកញាតិដាក់ឈ្មោះថា មហាកញ្ចនកុមារ ។ កាលលោកដើរបាន មាតាក៏បានបុត្តដទៃមួយទៀត ពួកញាតិក៏ដាក់ឈ្មោះកុមារនោះថា ឧបកញ្ចនកុមារ ដោយលំដាប់យ៉ាងនេះ ក៏មានកូនដល់ ៧ នាក់ តែកូនពៅជាកូនស្រី ពួកញាតិបានដាក់ឈ្មោះថា កញ្ចនទេវី ។ មហាកញ្ចនកុមារ ធំចម្រើនវ័យហើយ រៀន

សិប្បៈទាំងពួង មកអំពីតក្កសិលានគរ ។ កាលនោះ មាតាបិតាប្រាថ្នានឹងចង លោកទុកដោយឃរាវាសក៏ពោលថា យើងនឹងដណ្តឹងទារិកាអំពីត្រកូលដែល មានជាតិស្មើគ្នាមកឲ្យឯង ចូរឯងតាំងនៅក្នុងឃរាវាសចុះ ។ ព្រះពោធិសត្វ ប្រាប់ថា លោកឪពុកអ្នកម្តាយ ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះឡើយ ព្រោះភពទាំង បីប្រាកដដល់ខ្ញុំថាមានភ័យគួរខ្លាចដូចភ្លើងឆេះ ដូចជាគ្រឿងចង ឬគុក ជារបស់ គួរស្អប់ខ្ពើមក្រៃលែង ដូចគ្នានឹងផែនដីដែលជាទីស្មោកគ្រោក ខ្ញុំមិនធ្លាប់ឃើញ មេថុនធម្ម សូម្បីតែយល់សប្តិ កូនដទៃៗរបស់លោកមាន សូមលោកឲ្យគេ គ្រប់គ្រងផ្ទះបន្តចុះ សូម្បីត្រូវអង្វរឿយៗ សូម្បីត្រូវមាតាបិតាបញ្ជូនពួកសម្លាញ់ ទៅអង្វរ ក៏មិនប្រាថ្នាឡើយ ។

កាលពួកសម្លាញ់នាំគ្នាសួរថា នែសម្លាញ់ ឯងប្រាថ្នាអ្វី ទើបមិនចង់ បរិភោគកាមគុណ ។ ព្រះពោធិសត្វប្រាប់អធ្យាស្រ័យ ក្នុងការចេញចាកកាម ដល់ជនទាំងនោះ ។ មាតាបិតាស្តាប់រឿងនោះហើយ ក៏សំណូមពរកូនដ៏ សេស កូនទាំងនោះក៏មិនត្រូវការ ។ កញ្ចនទេវី ក៏មិនត្រូវការដូចគ្នា ។ តមកមិនយូរប៉ុន្មាន មាតាបិតាក៏អនិច្ចកម្មទៅ មហាកញ្ចនបណ្ឌិត កាលធ្វើ កិច្ចដែលត្រូវធ្វើដល់មាតាបិតាហើយ ក៏ឲ្យមហាទានដល់មនុស្សកំព្រា និង មនុស្សក្រីក្រដោយទ្រព្យ ៨០ កោដិ ហើយបបួលប្អូនប្រុស ៦ នាក់ និង ប្អូនស្រី ទាសៈម្នាក់ ទាសីម្នាក់ និងសម្លាញ់ម្នាក់ ចេញមហាភិនេស្រ្កមណ៍ ចូលកាន់ព្រៃហិមពាន្ត លោកទាំងនោះ អាស្រ័យស្រះឈូកក្នុងព្រៃហិមពាន្ត នោះ សាងអាស្រមក្នុងភូមិភាគដែលគួររីករាយ ហើយនាំគ្នាបួស ចិញ្ចឹម

ជីវិតដោយមើមឈើ និងផ្លែឈើក្នុងព្រៃ ។ លោកទាំងនោះទៅព្រៃក៏រួមគ្នា បុគ្គលណាមួយជួបដើមឈើ ឬស្លឹកឈើក្នុងទីណា ក៏ហៅអ្នកដទៃទៅក្នុងទីនោះ និយាយដល់រឿងដែលឃើញ ដែលបានឮជាដើមបណ្តើរ បេះផ្លែឈើបណ្តើរ ស្អានទីនោះ ដូចទីធ្វើការរបស់អ្នកស្រុក ។ តាបសមហាកញ្ចនៈជាអាចារ្យ ត្រិះរិះថា ការត្រាច់ស្វែងរកផលាផល ដោយអំណាចការគ្គាំគ្គងនេះ មិនសម គួរដល់ពួកជនដែលលះទ្រព្យ ៨០ កោដិមកបួសឡើយ តាំងអំពីនេះទៅ អញម្នាក់ឯងនឹងរកផលាផលមក ។ លុះដល់អាស្រមហើយ ព្រះពោធិសត្វ ក៏ហៅតាបសទាំងនោះមកប្រជុំគ្នា ក្នុងពេលល្ងាច ប្រាប់រឿងនោះឲ្យជ្រាប ហើយពោលថា ពួកអ្នកចូរធ្វើសមណធម៌ក្នុងទីនេះឯង ខ្ញុំនឹងទៅរកផ្លែឈើ មក ។ កាលតាបស មានឧបកញ្ចនជាដើមនាំគ្នាពោលថា បពិត្រលោក អាចារ្យ ពួកខ្ញុំនាំគ្នាអាស្រ័យលោកបួសហើយ ចូរលោកធ្វើនូវសមណធម៌ ក្នុងទីនេះឯង ប្អូនស្រីរបស់ពួកយើង ក៏ត្រូវនៅទីនេះដូចគ្នា ទាសីក៏ត្រូវនៅក្នុង សម្នាក់របស់ប្អូនស្រីនោះ ពួកខ្ញុំទាំង ៨ នាក់ នឹងប្តូរវេនគ្នាទៅនាំផលាផល មក លោកទាំង ៣ នាក់ ជាអ្នកផុតភារៈ ហើយទទួលបេ្ចជា ។ តាំងអំពី ពេលនោះជនទាំង ៨ ក៏ប្តូរភារៈម្តងម្នាក់នាំផលាផលមក ជនដ៏សេស នៅក្នុង សាលារបស់ខ្លួននោះឯង មិនចាំបាច់ទៅរួមគ្នា ។ ជនដែលត្រូវភារៈរកផ្លែឈើ មកហើយក៏ចែកជា ១១ ចំណែកលើផ្ទាំងថ្មមួយផ្ទាំង ហើយវាយជួង កាន់ យកចំណែកដែលចែករបស់ខ្លួនទៅកាន់លំនៅ ។ តាបសដ៏សេស នាំគ្នា ចេញមកដោយសំឡេងជួងជាសញ្ញា មិនធ្វើសំឡេងឲ្យឮ ដើរទៅដោយអាកប្ប

កិរិយាសម្តែងសេចក្តីគោរព កាន់យកចំណែកដែលរៀបចំទុកដើម្បីខ្លួន ហើយទៅកាន់លំនៅឆាន់ហើយ ធ្វើសមណធម៌តទៅ ។ ក្នុងកាលតមក តាបសទាំងឡាយ នាំគ្រាអៅឈូកមកឆាន់ នាំគ្នាមានតបៈរុងរឿង មានតបៈក្លៀវក្លា ឈ្នះនូវឥន្ទ្រិយបានយ៉ាងក្រៃលែង នាំគ្នាធ្វើកសិណបរិកម្ម ។

កាលណោះ ភពរបស់សក្កៈញាប់ញ័រដោយតេជះនៃសីលរបស់តាបសទាំងនោះ ។ សក្កទេវរាជក៏ទ្រង់រង្កៀសថា ឥសីទាំងនេះ នៅបង្អោនចិត្តទៅក្នុងកាម ឬមិនបង្អោនចិត្តទៅហ្ន៎ ។ កាលទ្រង់ព្រះតម្រិះថា អញនឹងចាំចាប់ទោសឥសីទាំងនេះ ហើយសម្តែងអានុភាពបន្ទំយកចំណែករបស់ព្រះមហាសត្វអស់ ៣ ថ្ងៃ ។ ថ្ងៃដំបូងព្រះមហាសត្វមិនឃើញចំណែកក៏គិតថា ឥសីទាំងនោះភ្លេចចំណែករបស់ខ្លួន ក្នុងថ្ងៃទី ២ គិតថា អញគង់មានទោស ប្រហែលជាមិនដាក់ចំណែកទុកដើម្បីអញ ព្រោះត្រូវការបណាម ( ព្រមាន ) ក្នុងថ្ងៃទី ៣ គិតថា ហេតុការណ៍អ្វីហ្ន៎ ទើបមិនបែងចែកចំណែកដល់អញ បើទោសរបស់អញមាន អញត្រូវសូមឲ្យអត់ទោស ហើយក៏វាយជួងជាសញ្ញាក្នុងពេលល្ងាច ។

តាបសទាំងអស់ប្រជុំគ្នាពោលថា អ្នកណាវាយជួង ព្រះមហាសត្វឆ្លើយថា ខ្ញុំ តាបសទាំងឡាយនាំគ្នាសួរថា ព្រោះហេតុអ្វីលោកអាចារ្យ ព្រះមហាសត្វពោលថា បាទាំងឡាយក្នុងថ្ងៃទី ៣ អ្នកណាជាអ្នករកផ្លែឈើ តាបសមួយរូបក្រោកឡើងប្រាប់ថា ខ្ញុំ លោកអាចារ្យ ព្រះមហាសត្វសួរថា កាលអ្នកចែកចំណែកដ៏សេស អ្នកចែកចំណែកដើម្បីខ្ញុំដែរឬទេ តាបសម្នាក់ឆ្លើយថា

ចែកលោកអាចារ្យ ខ្ញុំទុកចំណែកឲ្យលោកអាចារ្យជាពិសេស ព្រះមហាសត្វសួរថា ម្សិលមិញជាវេនអ្នកណា ឥសីមួយរូបក៏ក្រោកឈរប្រាប់ថា ជាវេនរបស់ខ្ញុំ ព្រះមហាសត្វសួរថា កាលអ្នកចែកមានទឹកដល់ខ្ញុំដែរឬ ក៏ឆ្លើយថា ខ្ញុំទុកចំណែកដើម្បីលោកម្ចាស់ជាពិសេសដែរ ។ ព្រះមហាសត្វសួរថា ថ្ងៃនេះជាវេនរបស់អ្នកណា ឥសីមួយរូបក្រោកឈរប្រាប់ថា ជាវេនខ្ញុំ ព្រះមហាសត្វសួរថា កាលអ្នកចែក បានទឹកដល់ខ្ញុំដែរឬទេ ក៏ឆ្លើយថា ខ្ញុំតម្កល់ចំណែកលោកម្ចាស់ទុកជាពិសេស ។ ព្រះមហាសត្វពោលថា នែបាទាំងឡាយ ខ្ញុំមិនបានទទួលចំណែកក្នុង ៣ ថ្ងៃ ទាំងថ្ងៃនេះ ថ្ងៃទី ១ ខ្ញុំមិនឃើញចំណែក គិតថា អ្នកចែកគង់នឹងភ្លេចខ្ញុំ ក្នុងថ្ងៃទី ២ គិតថា ខ្ញុំគង់មានទោសណាមួយ ចំណែកថ្ងៃនេះគិតថា បើទោសរបស់ខ្ញុំមាន ខ្ញុំនឹងសូមខមាទោស ទើបហៅអ្នកទាំងឡាយមកប្រជុំ ដោយវាយជួងជាសញ្ញា អ្នកទាំងឡាយប្រាប់ថា ពួកខ្ញុំនាំគ្នាចែកក្រអៅឈូកទាំងនេះ តែខ្ញុំមិនបាន ប្រហែលជាមានចោរលួចស៊ីក្រអៅឈូកទាំងនោះ ឈ្មោះថាការលួចត្រឹមតែក្រអៅឈូកមិនសមគួរដល់អ្នកដែលលះកាមហើយបួស ។ តាបសទាំងនោះ ស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ នាំគ្នាមានចិត្តស្រយុតស្រយង់គ្រប់គ្នាថា ឱកម្មនេះធ្ងន់ពិតហ្ន៎ ។

ទេវតាដែលអាស្រ័យដើមឈើធំក្នុងព្រៃនាអាស្រមបទនោះ ចុះមកអំពីប្រគាបឈើអង្គុយក្នុងសម្នាក់របស់តាបសទាំងនោះដូចគ្នា ។ ដំរីមួយត្រូវគេចងដោយទន្ទឹង មិនអាចទ្រាំបាន ទម្លាយទន្ទឹងរត់គេចចូលព្រៃ ធ្លាប់មកថ្វាយ

បន្តុំ គណៈឥសីតាមកាលសមគួរ ។ ដំរីនោះក៏មកឈរក្នុងចំណែកម្ខាង ។ មានស្វាមួយធ្លាប់ម្ចាស់ឲ្យលេងជាមួយពស់ រត់មកផុតអំពីកណ្ដាប់ដៃគ្រូពស់ចូលព្រៃអាស្រ័យនៅក្បែរអាស្រមនោះឯង ។ ថ្ងៃនោះ ស្វានោះក៏មកថ្វាយបន្តុំគណៈឥសី ហើយអង្គុយក្នុងចំណែកម្ខាង ។ ទេវរាជត្រិះរិះថា អញចាំចាប់ទោសរបស់គណៈឥសី ដូច្នេះហើយ ទើបមិនបានបង្ហាញកាយឲ្យប្រាកដឈរក្នុងសម្នាក់របស់តាបសទាំងនោះ ។ ខណៈនោះឧបកញ្ចនៈ តាបសប្អូនប្រុសរបស់ព្រះពោធិសត្វ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះពោធិសត្វហើយសម្ដែងការឱនលំទោនដល់តាបសដ៏សេសសួរថា លោកអាចារ្យ ខ្ញុំមិនប្រាថ្នាវត្ថុដទៃដើម្បីនឹងបានលាងជម្រះខ្លួនទេឬ ព្រះមហាសត្វឆ្លើយថា បាន ។ ឧបកញ្ចន តាបសនោះ ឈរនៅក្នុងកណ្ដាលគណឥសីធ្វើនូវការស្បថថា បើខ្ញុំធាន់ក្រអៅឈូករបស់លោក សូមឲ្យយ៉ាងនេះចុះ ហើយពោលគាថាទី ១ ថា

> បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់
> លោក បុគ្គលនោះ ចូរបាននូវសេះផង គោផង ប្រាក់ផង
> មាសផង ប្រពន្ធជាទីគាប់ចិត្តក្នុងលោកនេះផង ចូរនៅមូល
> មិត្តគ្នាជោយកូននិងប្រពន្ធទាំងឡាយចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អស្សំ គវំ** នេះ គប្បីជ្រាបថា ឥសីនោះពោលតិះដៀលវត្ថុកាមទាំងឡាយថា បិយវត្ថុមានប្រមាណប៉ុណ្ណា សេចក្ដីសោកនិងសេចក្ដីទុក្ខ មានប្រមាណប៉ុណ្ណោះ រមែងកើតឡើងព្រោះការវិប្បយោគ

( ព្រាត់ប្រាស ) ទាំងនេះ ។

គណៈឥសីស្តាប់ដូច្នោះទើបពោលថា លោកនិរទុក្ខ លោកកុំពោលយ៉ាងនេះ សម្បថរបស់លោកធ្ងន់ក្រៃលែងណាស់ នាំគ្នាបិទត្រចៀក ។ ចំណែកព្រះពោធិសត្វពោលថា នែបា ពាក្យសម្បថរបស់លោកធ្ងន់ក្រៃពេក លោកមិនបានធាន់ ចូរអង្គុយក្នុងអាសនៈសម្រាប់លោកចុះ ។ កាលឧបកញ្ចនៈធ្វើនូវសម្បថ អង្គុយចុះហើយ ប្អូនប្រុសទី ២ ក្រោកឡើងថ្វាយបង្គំព្រះមហាសត្វ កាលនឹងជម្រះខ្លួនដោយពាក្យសម្បថ ទើបពោលគាថាទី ២ ថា

បពិត្រព្រាហ្មណ៍ បុគ្គលណា លួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរទ្រទ្រង់នូវផ្កាកម្រងផង នូវសំពត់ដែលគេនាំមកអំពីដែនកាសីនិងខ្លឹមចន្ទន៍ផង ចូរឲ្យបុគ្គលនោះមានកូនច្រើនផង ចូរឲ្យ ( បុគ្គលនោះ ) ធ្វើនូវសេចក្តីអាឡោះអាល័យដ៏ក្លៀវក្លាក្នុងកាមទាំងឡាយផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តិព្វំ** សេចក្តីថា ធ្វើនូវការសម្លឹងយ៉ាងខ្លាំងក្លាក្នុងវត្ថុកាមនិងកិលេសកាម ។ ពាក្យនេះ ឥសីពោលដោយអំណាចការបដិសេធសេចក្តីទុក្ខប៉ុណ្ណោះថា បុគ្គលមានការសម្លឹងខ្លាំងក្លាក្នុងវត្ថុកាម និងកិលេសកាមទាំងនោះ បុគ្គលនោះ រមែងបានទទួលសេចក្តីទុក្ខដ៏ខ្លាំងក្លាព្រោះការព្រាត់ប្រាសអំពីរបស់ទាំងនោះ ។

កាលប្អូនប្រុសទី ២ អង្គុយហើយ តាបសដ៏សេស ក៏នាំគ្នាពោលគាថា

មួយម្នាក់តាមគួរដល់អធ្យាស្រ័យរបស់ខ្លួនថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក ( បុគ្គលនោះ ) ចូរមានស្រូវច្រើន មានកសិកម្ម មានយស ( បាន ) នូវកូនទាំងឡាយ ជាគ្រហស្ថ មានទ្រព្យ ចូរ ( បាន ) នូវកាមគ្រប់យ៉ាង ចូរកុំឲ្យឃើញនូវវ័យ ( របស់ខ្លួន ) នៅគ្រប់គ្រងផ្ទះចុះ ។

តាបសទី ៤ ស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបានជាក្សត្រ អ្នកធ្វើនូវការរឹបជាន់ ជារាជាធិរាជ មានពល មានយស ចូរបានគ្រប់គ្រងផែនដី ដែលមានសមុទ្ទទាំង ៤ ជាទីបំផុតចុះ ។

តាបសទី ៥ ស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរជាព្រាហ្មណ៍ មិនប្រាសចាករាគៈ ចូរប្រកបក្នុងគន្ធងក្ស័នយាមនិងនក្ខត្តឫក្ស បុគ្គលជាម្ចាស់នៃដែន ( ស្តេច ) ដែលមានយស ចូរបូជាព្រាហ្មណ៍នោះចុះ ។

តាបសទី ៦ ស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក លោកទាំងអស់ចូរសំគាល់ ( នូវបុគ្គលនោះ ) ថាជា

អ្នកសា្វធ្យាយនូវវេទ ព្រមទាំងមន្តគ្រប់យ៉ាង ថាជាអ្នកមាន តបៈ ពួកអ្នកជនបទចូរឃើញ ហើយបូជានូវបុគ្គលនោះចុះ ។

តាបសជាសម្លាញ់ស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរបរិភោគនូវស្រុកសួយដ៏ស្តុកស្តម្ភ ដែលកុះករដោយវត្ថុ ៤ យ៉ាង ហាក់ដូចស្តេចវាសវៈប្រទានឲ្យ ចូរដល់នូវមរណៈទាំងមិនទាន់បានប្រាសចាករាគៈចុះ ។

តាបសជាខ្ញុំប្រុសស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបានជាធំក្នុងស្រុក ចូររីករាយដោយការរាំនិងច្រៀងទាំងឡាយក្នុងកណ្តាលនៃសម្លាញ់ កុំឲ្យបាននូវសេចក្តីវិនាសតិចតួចអំពីស្តេចឡើយ ។

នាងកញ្ញទេវីស្បថថា

បពិត្រព្រាហ្មណ៍ ស្រីណា លួចក្រអៅឈូកទាំងឡាយរបស់លោក សូមឲ្យស្តេចឯករាជ ដែលទ្រង់ឈ្នះនូវផែនដី លើកតម្កើង ( ស្រីនោះ ) ឲ្យប្រសើរ លើសជាងស្រីទាំងមួយ-ពាន់ សូមឲ្យ ( ស្រីនោះ ) បានជាស្រីប្រសើរលើសជាងស្រីទាំងឡាយចុះ ។

នាងទាសីស្បថថា

បពិត្រព្រាហ្មណ៍ ទាសីណា លួចក្រអៅឈូកទាំងឡាយរបស់លោក ក៏បណ្ដាទាសីទាំងឡាយ ទាសីនោះចូរកុំញាប់ញ័រ ( ក្នុងកណ្ដាល ) នៃម្ចាស់ទាំងឡាយដែលជួបជុំគ្នាទាំងអស់ ចូរបរិភោគនូវវត្ថុមានរសឆ្ងាញ់ ( ទាសីនោះ ) ចូរប្រព្រឹត្តនិយាយកុហក ព្រោះហេតុតែលាភចុះ ។

ទេវតាស្បថថា

បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក ( បុគ្គលនោះ ) ចូរបានជាចៅអាវាសក្នុងមហាវិហារចុះ ចូរធ្វើនូវនវកម្មក្នុងនគរឈ្មោះកជង្គលៈចុះ ចូរធ្វើនូវបង្អួចឲ្យហើយតែមួយថ្ងៃចុះ ។

ដំរីស្បថថា

បពិត្រព្រាហ្មណ៍ ដំរីណា លួចក្រអៅឈូកទាំងឡាយរបស់លោក ដំរីនោះ ចូរជាប់ដោយអន្ទាក់ច្រើន ត្រង់កន្លែងទាំង ៦ ( គឺជើងទាំង ៤ កនិងចង្កេះ ) ចូរឲ្យគេនាំអំពីព្រៃ ជាទីរីករាយទៅកាន់រាជធានីចុះ ដំរីនោះ ចូរឲ្យគេចាក់ដោយកង្វេរទាំងឡាយដែលមានជង់វែង មានបន្ទាពីរចុះ ។

ស្វាស្បថថា

បពិត្រព្រាហ្មណ៍ ស្វាណា លួចក្រអៅឈូកទាំងឡាយរបស់លោក ( ស្វានោះ ) ចូរមានប្រឡៀក ហើយគេចោះត្រចៀក

បំពាក់សំណាចុះ ឲ្យហ្លួតស់វាយដោយរំពាត់ ហើយចូរទៅរក
មាត់ពស់ចុះ ឲ្យគេចងយ៉ាងមាំ ហើយដើរទៅកាន់ច្រកល្ហក
ចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ៣ ដែលប្អូនប្រុសទី ៣ របស់ព្រះមហាសត្វ ពោលជាពាក្យសម្បថ ។ បទថា **កសិមា** បានដល់ កសិកម្មដែលសម្បូរ ។ បទថា **បុត្តេ គិហី ធនិមា សព្វកាមេ** សេចក្ដីថា ឲ្យបុគ្គលនោះ បានជាអ្នកស្រែ មានកសិកម្មដ៏សម្បូរ ចូរមានបុត្រច្រើន ចូរជាគ្រហស្ថ ចូរមានទ្រព្យ ៧ ប្រការ បាននូវវត្ថុដែលគួរប្រាថ្នា មានរូបជាដើមគ្រប់ប្រភេទ ។ បទថា **វយំ អបស្សំ** សេចក្ដីថា ចូរកុំបីឃើញនូវការអស់ទៅសូន្យទៅរបស់ខ្លួន ទោះបីសមគួរដល់បព្វជ្ជាក្នុងពេលចាស់ ចូរគ្រប់គ្រងផ្ទះដែលដល់ព្រមដោយកាមគុណ ៥ រហូតទៅយ៉ាងនេះ ។ លោកពោលដើម្បីសម្ដែងថា បុគ្គលដែលដល់ព្រមដោយបញ្ចកាមគុណនោះ រមែងដល់នូវការវិនាសធំ ដោយសេចក្ដីព្រាត់ប្រាសចាកកាមគុណ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដែលប្អូនប្រុសទី ៤ ពោល បទថា **រាជា-ធិរាជា** បានដល់ ព្រះរាជាដែលធំក្នុងរវាងនៃព្រះរាជាទាំងឡាយ នេះលោកសម្ដែងទោសក្នុងរាជសម្បត្តិថា ធម្មតាបុគ្គលដែលជាធំ កាលភាពជាធំព្រាត់ប្រាសទៅ ក៏រមែងកើតទុក្ខក្រៃលែង ។

ក្នុងគាថាដែលប្អូនប្រុសទី ៥ ពោល បទថា **អវីតរាគោ** បានដល់ ជាអ្នកមានតណ្ហាដោយតណ្ហាក្នុងតំណែងបុរោហិត ទាំងនេះលោកពោលដើម្បី

សម្ដែងថា ភាពជាបុរោហិត របស់ព្រាហ្មណ៍បុរោហិត ត្រូវមច្ចុលេបត្របាក់ប៉ុណ្ណោះ ទោមនស្សធំរមែងកើតឡើង ។

ក្នុងគាថាដែលប្អូនប្រុសទី ៦ ពោល បទថា **តបស្សិនំ** សេចក្ដីថា សត្វលោកទាំងពួង ចូរសម្គាល់បុគ្គលនោះថា ជាអ្នកមានតបៈ សម្បូរដោយសីល លោកពោលពាក្យទាំងនេះ ដោយអំណាចការតិះដៀលលាភសក្ការៈថា ទោមនស្សធំ រមែងកើត ព្រោះលាភសក្ការៈប្រាសទៅហើយ ។

ក្នុងគាថាដែលតាបសជាសម្លាញ់ពោល បទថា **ចតុស្សទំ** សេចក្ដីថា បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោកទៅ បុគ្គលនោះ ចូរគ្រប់គ្រងស្រុកសួយដ៏ឧត្ដម ដោយហេតុ ៤ កន្លែង គឺដោយពួកមនុស្ស ព្រោះជាស្រុកដែលស្កុកស្កម្ភដោយស្រូវ ព្រោះស្រូវច្រើន ដោយឧសរកបានងាយនិងដោយទឹក ព្រោះមានទឹកបរិបូរ ។

បទថា **វាសវេន** សេចក្ដីថា ដែលមិនញាប់ញ័រដូចវាសវៈទ្រង់ប្រទាន គឺដែលព្រះរាជានោះប្រទានហើយ ព្រោះឲ្យព្រះរាជាអង្គនោះទ្រង់ប្រោសប្រាណ ដោយអានុភាពនៃពរដែលបានអំពីស្ដេចវាសវៈ ។ បទថា **អវីតរាគោ** សេចក្ដីថា ចូរនៅក្នុងភក់ គឺកាមដូចជ្រូកជាដើម ដែលលិចចុះក្នុងភក់ដូច្នោះ ។ តាបសជាសម្លាញ់នោះ កាលថ្លាថ្លែងនូវទោសរបស់កាមទាំងឡាយ ទើបពោលគាថានេះ ដោយប្រការដូច្នេះ ។

ក្នុងគាថាដែលទាសៈពោល បទថា **គាមណី** សេចក្ដីថា ជាអ្នកធំ ក្នុងស្រុក ទាសៈនេះ ក៏តិះដៀលនូវកាមទាំងឡាយដូចគ្នា ទើបពោលយ៉ាងនេះ ។

ក្នុងគាថាដែលនាងកញ្ញទេវីពោល បទថា **យំ** បានដល់ ស្រីណា ។ បទថា **ឯកការជា** គឺអគ្គភរិជា ។ បទថា **ឥត្ថីសហស្សាន** លោកពោលដោយការរណ្តំនៃពាក្យ អធិប្បាយថា តាំងទុកក្នុងតំណែងដ៏ប្រសើរជាងស្រី ១ ម៉ឺន ៦ ពាន់នាក់ ។ បទថា **សីមន្តិនីនំ** សេចក្តីថា ( ធំ ) ជាងស្រីទាំងឡាយដែលនៅក្នុងព្រះរាជវាំង ។ កញ្ញទេវីនោះ តាំងនៅក្នុងភាពជាស្រី ក៏តិះដៀលកាមទាំងឡាយដូចគំនរលាមកដែលមានក្លិនស្អុយដូច្នោះ ទើបបានពោលយ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងគាថាដែលទាសីពោល បទថា **សព្វសមាគតានំ** សេចក្តីថា ឲ្យទាសីនោះ អង្គុយមិនញាប់ញ័រ មិនតក់ស្លុត បរិភោគរបស់មានរសល្អកណ្តាលមនុស្សទាំងពួងដែលប្រជុំគ្នា បានឮថា ឈ្មោះថា ការដែលទាសីនោះ អង្គុយបរិភោគក្នុងសម្នាក់របស់ចៅហ្វាយទាំងឡាយ ជាកិរិយាមិនល្អ ព្រោះហេតុនោះ ទើបទាសីនោះពោលយ៉ាងនេះ ព្រោះជារឿងមិនគាប់ចិត្តរបស់ខ្លួន ។ បទថា **ចរាតុ** បានដល់ ចូរប្រព្រឹត្ត ។ បទថា **លាភេន វិកត្ថមានា** សេចក្តីថា ធ្វើនូវកម្មនៃបុគ្គលកុហកព្រោះហេតុនៃលាភ ចូរញ៉ាំងលាភសក្ការៈឲ្យកើតឡើងត្រាច់ទៅចុះ ។ ស្រីនោះ សូម្បីតាំងនៅក្នុងភាពជាទាសីក៏គង់តិះដៀលកិលេសកាមនិងវត្ថុកាមដូចគ្នា ដោយគាថានេះ ។

ក្នុងគាថាដែលទេវតាពោល បទថា **អាវាសិកោ** សេចក្តីថា ជាអ្នកគ្រប់គ្រងអាវាស ។ បទថា **កជង្គលាយំ** សេចក្តីថា ក្នុងនគរដែលមានឈ្មោះយ៉ាងនោះ ( ពារាណសី ) បានឮថា ក្នុងនគរនោះ មានទព្វសម្ភារៈរក

បានឆាយ ។ បទថា **អាលោកសន្ធិំ ទិវសា** សេចក្តីថា ចូរធ្វើនូវសន្ទុះបង្អួចពេញមួយថ្ងៃចុះ បានឮថា ទេវបុត្តនោះ ក្នុងសាសនានៃព្រះពុទ្ធកស្សបៈ បានជាព្រះសង្ឃត្ថេរ ក្នុងមហាវិហារចាស់ មានប្រមាណ ១ យោជន៍ ជាប់នឹងគនរកជង្គលៈ កាលធ្វើនវកម្មក្នុងវិហារចាស់នោះឯង ត្រូវសោយទុក្ខយ៉ាងធំ ព្រោះហេតុនោះ ប្រារព្ធដល់ទុក្ខនោះឯង ទើបពោលយ៉ាងនេះ ។

ក្នុងគាថាដែលដំរីពោល បទថា **ទាសសតេហិ** សេចក្តីថា ដោយអន្ទាក់ជាច្រើន ។ បទថា **ឆព្ភិ** សេចក្តីថា ក្នុងឋានៈ ៦ គឺជើង ៤ ក ១ និងចង្កេះ ១ ។ បទថា **គុត្តេហិ** សេចក្តីថា ដោយកង្វេរដែកវែង ដែលមានមុខពីរ ។ បទថា **ទាចនេភិ** បានដល់ ដោយជន្ទញ គឺកង្វេរ ។ បានឮថា ដំរីនោះប្រារព្ធដល់ទុក្ខដែលខ្លួនធ្លាប់ទទួលមកហើយនោះឯង ទើបពោលយ៉ាងនេះ ។

ក្នុងគាថាដែលស្វាពោល បទថា **អលក្កមាលី** សេចក្តីថា ប្រកបដោយមាលាពាក់ក ដែលគ្រូពស់បំពាក់ទុកត្រង់ក ។ បទថា **តិបុកណ្ណាវិទ្ធោ** សេចក្តីថា ប្រដាប់ត្រចៀកដោយគ្រឿងប្រដាប់គឺសំណរ ។ បទថា **លដ្ឋិហតោ** សេចក្តីថា គ្រូពស់ឲ្យសិក្សាកីឡាពស់ ត្រូវវាយដោយចំរៀកឫស្សី ។ កាលពានរនោះពោលយ៉ាងនេះ សំដៅដល់សេចក្តីទុក្ខដែលខ្លួនបានសោយ ក្នុងកណ្តាប់ដៃរបស់គ្រូពស់ ។ កាលជនទាំង ១៣ ស្បថយ៉ាងនេះហើយ ព្រះមហាសត្វត្រិះរិះថា ជួនកាលជនទាំងនេះ ស៊ីចិត្តក្នុងអញថា ឥសីនេះពោលដល់វត្ថុដែលមិនបាត់ថាបាត់ដូច្នេះ អញក៏ត្រូវស្បថដែរ កាលនឹងធ្វើសម្បថ ទើបពោលគាថានេះថា

នៃអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលណា ពោលនូវចំណែកដែល
មិនបាត់ថាបាត់ ម្យ៉ាងទៀត បុគ្គលណា វង្វៀសបន្តិចបន្តួច
( ចំពោះអ្នកទាំងឡាយ ) បុគ្គលនោះ ចូរបានទិងចូរបរិភោគ
នូវកាមទាំងឡាយចុះ ចូរស្លាប់ក្នុងកណ្តាលនៃផ្ទះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភោណ្ដោ** ជាអបលនៈ លោកអធិប្បាយទុកថា លោកដ៏ចម្រើនទាំងឡាយ បុគ្គលណាពោលដល់ចំណែកដែលមិនបាត់ថាបាត់ទៅអស់ហើយ ឬបុគ្គលណាសង្ស័យក្នុងពួកអ្នកណាមួយ បុគ្គលនោះចូរបានបរិភោគបញ្ចកាមគុណ កុំបានបព្វជ្ជាដែលគួរត្រេកអរឡើយ ចូរស្លាប់កណ្តាលផ្ទះនោះឯង ។ កាលឥសីទាំងឡាយនាំគ្នាស្បថហើយ សក្កទេវរាជទ្រង់កិតភ័យគិតថា អញបំណាងមកពិសោធជនទាំងនេះមើល ទើបធ្វើឲ្យក្រអៅឈូកបាត់ទៅ ជនទាំងនេះនាំគ្នាតិះដៀលកាមទាំងឡាយ ដូចដុំទឹកមាត់ដែលស្តោះចោល ធ្វើនូវសម្បថដល់គ្នានឹងគ្នា អញត្រូវសួរជនទាំងនោះដល់ហេតុដែលតិះដៀលកាមគុណ ហើយទ្រង់សម្តែងកាយឲ្យប្រាកដ ទ្រង់ថ្វាយបង្គំព្រះពោធិសត្វ កាលនឹងសួរ ទើបត្រាស់គាថាបន្តថា

( សត្វទាំងឡាយ ) រមែងស្វែងរកនូវវត្ថុកាមនិងកិលេសកាម
ណាហើយ ត្រាច់ទៅក្នុងលោក វត្ថុកាមនិងកិលេសកាមទុំះ
ជាទីប្រាថ្នាផង ជាទីរីករាយផង ជាទីស្រឡាញ់ផង ជាទីពេញ
ចិត្តរបស់ទេវតានិងមនុស្សច្រើនគ្នាក្នុងជីវលោកនេះ ចុះហេតុ
អ្វីក៏ពួកឥសី មិនសរសើរនូវកាមទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេសមានា** មានអធិប្បាយថា ពួកសត្វតែងស្វែងរកវត្ថុកាមនិងកិលេសកាមណាដោយកម្មទាំងសមគួរ និងមិនសមគួរ មានកសិកម្មនិងគោរក្ខកម្មជាដើម នាំគ្នាត្រាច់ទៅក្នុងលោក កាមនោះជាវត្ថុគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្តនិងគួរត្រេកអរ របស់សត្វជាច្រើន គឺរបស់ពួកទេវតានិងមនុស្ស ហេតុអ្វីទើបពួកឥសីមិនសរសើរកាមទាំងឡាយ ។ ដោយបទថា **កាមេ** នេះ សក្កទេវរាជសម្ដែងវត្ថុកាមនោះ ដោយសរុប ។

កាលណោះ កាលព្រះមហាសត្វឆ្លើយបញ្ហារបស់សក្កទេវរាជ បានពោលគាថា ២ ដោយសេចក្ដីថា

> ជនទាំងឡាយ ត្រូវគេវាយ ត្រូវគេចង ព្រោះតែកាមទាំង-ឡាយ សេចក្ដីទុក្ខផង ភ័យផង ដែលកើតឡើង ក៏ព្រោះតែកាមទាំងឡាយ បពិត្រព្រះភូតាធិបតី សត្វទាំងឡាយស្រវឹងព្រោះកាមទាំងឡាយ ធ្វើនូវអំពើទាំងឡាយដ៏លាមក ព្រោះវង្វេង ។ ជនមានធម៌ដ៏លាមកទាំងឡាយនោះ ទទួលនូវបាបលុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ព្រោះហេតុនោះ បានជាពួកឥសីមិនសរសើរនូវកាមទាំងឡាយ ព្រោះឃើញទោសក្នុងកាមគុណទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាមេសុ** សេចក្ដីថា មនុស្សទាំងឡាយរមែងធ្វើទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើមព្រោះហេតុនៃកាម គឺព្រោះអាស្រ័យកាមទាំងឡាយ ។ បទថា **ហញ្ញរេ** សេចក្ដីថា រមែងក្ដៅក្រហាយ

ព្រោះអាជ្ញាជាដើម ។ បទថា **ពន្ធរេ** សេចក្ដីថា រមែងត្រូវចងដោយចំណង គឺខ្សែជាដើម ។ បទថា **ទុក្ខំ** បានដល់ ទុក្ខមិនមែនសេចក្ដីសុខដែលប្រព្រឹត្ត ទៅតាមផ្លូវកាយនិងប្រព្រឹត្តទៅតាមផ្លូវចិត្ត ។ បទថា **ភយំ** បានដល់ ភ័យ ទាំងពួង មានការតិះដៀលខ្លួនជាដើម ។ ព្រះមហាសត្វ ហៅសក្កទេវរាជ ថា **ភូតាធិបតី** ។ បទថា **អាទីនវំ កាមគុណេសុ ទិស្វា** សេចក្ដីថា ព្រោះ ឃើញទោសបែបនេះ ឯទោសនេះ គប្បីសម្ដែងដោយសូត្រទាំងឡាយ មាន ទុក្ខក្ខន្ធសូត្រ ជាដើម ។

សក្កទេវរាជទ្រង់ស្ដាប់ពាក្យព្រះមហាសត្វ មានព្រះទ័យតក់ស្លុត ត្រាស់ គាថាបន្ដថា

ខ្ញុំល្បងមើលទេ ខ្ញុំយកក្រអៅឈូកទាំងឡាយរបស់ឥសី ក្បែរ ឆ្នេរទៅកប់ទុកលើគោក ( ឥឡូវនេះខ្ញុំដឹងហើយថា ) ឥសី ទាំងឡាយជាអ្នកបរិសុទ្ធ មិនមានបាប បពិត្រលោកជាព្រហ្ម- ចារី នុ៎ះក្រអៅឈូកទាំងឡាយរបស់លោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វីមំសមានោ** សេចក្ដីថា បពិត្រលោក ម្ចាស់ ខ្ញុំសាកល្បងថា ឥសីទាំងនេះ បង្អោនចិត្តទៅក្នុងកាមដែរឬទេ ។ បទ ថា **ឥសិនោ** សេចក្ដីថា កាន់យកក្រអៅឈូកដែលជារបស់លោកអ្នកស្វែង រកគុណធំ ។ បទថា **តីរេ គហេត្វាន** សេចក្ដីថា កាន់យកក្រអៅឈូកដែល លោកកប់ទុកត្រង់ច្រាំងស្ទឹង ហើយកប់ទុកក្នុងចំណែកមួយ លើគោក ។ បទ ថា **សុទ្ធា** សេចក្ដីថា ឥឡូវនេះ ខ្ញុំដឹងដល់ការធ្វើសម្បថរបស់លោក ឥសី

ទាំងនេះជាអ្នកបរិសុទ្ធ មិនមានបាប ។ ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ ពោលថា

ម្នាលទេវរាជ ជាសហស្សនេត្រ ( ពួកយើង ) មិនមែនជា អ្នករបាំរបស់អ្នកទេ ទាំងមិនមែនជាបុគ្គលគួរអ្នកលេងទេ មិន មែនជាផៅពង្ស ទាំងមិនមែនជាសម្លាញ់របស់អ្នកទេ ហេតុអ្វី ក៏អ្នក ( ធ្វើ ) នូវសេចក្តីមើលងាយចំពោះបុគ្គលដទៃ ហើយ លេងជាមួយនឹងពួកឥសី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន តេ នដា** សេចក្តីថា នែសក្កទេវរាជ ពួក អាត្មាមិនមែនជាអ្នករបាំរបស់លោក និងជាអ្នកមិនគួរបុគ្គលណាមួយ គប្បី លេងសើច មិនមែនជាញាតិ មិនមែនជាសម្លាញ់របស់លោក កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបទ្រង់ធ្វើនូវការមើលងាយ ព្រោះអាស្រ័យអ្វី ទើបទ្រង់លេងនឹងឥសីទាំងឡាយ ។

កាលនោះសក្កទេវរាជកាលសូមខមាទោស ទើបពោលគាថាទី ២០ ថា

បពិត្រតាបសដ៏ប្រសើរ លោកម្ចាស់ ជាអាចារ្យរបស់ខ្ញុំផង ជា បិតារបស់ខ្ញុំផង ម្ចប់ព្រះបាទរបស់លោកម្ចាស់នេះ សូមជាទី ពឹង ( របស់ខ្ញុំ ) ដែលមានសេចក្តីភ្លាំងភ្លាត់ហើយ បពិត្រ តាបសមានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់នូវកំហុស ម្តង បណ្ឌិតទាំងឡាយមិនមានសេចក្តីក្រោធជាកម្លាំងទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯសា បតិដ្ឋា** សេចក្តីថា ម្ចប់ជើងរបស់

លោកម្ចាស់ ចូរជាទីពឹងរបស់ខ្ញុំដែលភ្លាំងភ្លាត់ក្នុងថ្ងៃនេះ ។ បទថា **កោធ ពលា** សេចក្តីថា ឈ្មោះថាបណ្ឌិតទាំងឡាយ រមែងមានខន្តិជាកម្លាំង មិនមែនជាអ្នកមានសេចក្តីក្រោធជាកម្លាំងឡើយ ។

ព្រះមហាសត្វ អត់ទោសដល់សក្កទេវរាជហើយ កាលឲ្យគណៈឥសីអត់ទោសដល់ខ្លួនឯង ទើបពោលគាថាបន្តថា

កាលដែលពួកឥសី ( នៅក្នុងព្រៃ ) សូម្បីតែមួយយប់ ក៏ឈ្មោះថាបាននៅល្អហើយ ព្រោះថា យើងទាំងឡាយ បានចួបនឹងព្រះវាសវៈ ជាម្ចាស់នៃទេវតា ពួកអ្នកដ៏ចម្រើនទាំងអស់គ្នា ចូរតាំងចិត្តឲ្យល្អចុះ ដ្បិតព្រាហ្មណ៍ ( ជាអាចារ្យរបស់អ្នកទាំងឡាយ ) បាននូវក្រអៅឈូកវិញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុវាសិតំ ឥសិនំ ឯករត្តំ** មានអធិប្បាយថា ជារាត្រីឯក ដែលអ្នកមានអាយុទាំងឡាយនាំគ្នានៅក្នុងព្រៃនេះ ជាការនៅល្អទាំងអស់ ព្រោះហេតុអ្វី ព្រោះថាពួកយើងនាំគ្នាឃើញស្តេចវាសវៈ ដែលជាម្ចាស់នៃភូត បើពួកយើងនៅក្នុងនគរក៏គង់មិនបានឃើញ ។ បទថា **ភោន្តោ** សេចក្តីថា នៃអ្នកនិរទុក្ខទាំងឡាយ អ្នកទាំងអស់គ្នាចូរសប្បាយចិត្តចុះ ចូរត្រេកអរចុះ ចូរអត់ទោសដល់សក្កទេវរាជចុះ ព្រោះហេតុអ្វី ព្រោះព្រាហ្មណ៍បានក្រអៅឈូកមកវិញហើយ គឺព្រោះអាចារ្យរបស់ពួកអ្នក បានក្រអៅឈូកមកវិញ ។

សក្កទេវរាជថ្វាយបង្គំគណៈឥសីហើយ ក៏ទៅកាន់ទេវលោក ។ ចំណែក

គណៈឥសី នាំគ្នាញុំាងឈាននិងអភិញ្ញាឲ្យកើតហើយ ក៏បានទៅកាន់ព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បោរាណកបណ្ឌិត នាំគ្នាស្បថលះកិលេសយ៉ាងនេះ ហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈទាំងឡាយ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ។ កាលព្រះសាស្តាទ្រង់ប្រជុំជាតក បានត្រាស់គាថាចុងក្រោយ ៣ គាថាដូច្នេះថា

បងប្អូនប្រាំពីរនាក់ក្នុងកាលនោះ គឺ តថាគត ១ សារីបុត្ត ១ មោគ្គល្លាន ១ កស្សប ១ អនុរុទ្ធ ១ បុណ្ណ ១ អានន្ទ ១ ។ ក្នុងកាលនោះ ប្អូនស្រីគឺនាងឧប្បលវណ្ណា ទាសីគឺនាងខុជ្ជុត្តរា ក្នុងកាលនោះ ខ្ញុំប្រុសគឺគហបតិឈ្មោះចិត្តៈ ទេវតាគឺសាតាគិរយក្ខ ។ ក្នុងកាលនោះ ដំរីដ៏ប្រសើរគឺដំរីឈ្មោះបាលិលេយ្យ ស្វាដ៏ប្រសើរគឺមធុទៈ ក្នុងកាលនោះទេវរាជឈ្មោះសក្កៈគឺកាឡុទាយី អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ដូច្នេះ ។

**អដ្ឋកថា ភិសជាតក ចប់**

# សុរុចិជាតក

[ ៧១ ] ( នាងសុមេធាទេវីពោលថា ) ខ្ញុំជាមហេសីកនិយារបស់ព្រះបាទសុរុចិ ដែលព្រះអង្គទ្រង់នាំមកមុនដំបូង ព្រះបាទសុរុចិនាំខ្ញុំមកអស់មួយហ្មឺនឆ្នាំហើយ ។ បពិត្រព្រាហ្មណ៍ ខ្ញុំនោះមិនដែលដឹងថា ខ្ញុំបានមើលងាយព្រះរាជា សុរុចិ ជាធំក្នុងដែនវិទេហៈ ព្រះអង្គគ្រប់គ្រងនូវក្រុងមិថិលា ដោយកាយ ដោយវាចា ឬដោយចិត្ត ក្នុងទីវាលឬក្នុងទីកំបាំងមុខឡើយ ។ បពិត្រឥសី សូមឲ្យបុត្តកើត ( ក្នុងផ្ទៃរបស់ខ្ញុំ ) ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

[ ៧២ ] ព្រះភស្តាផង ព្រះមាតាក្មេកផង ព្រះបិតាក្មេកផង ព្រះមាតាបង្កើតនិងបិតាបង្កើតផង ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ( របស់ខ្ញុំ ) បពិត្រព្រហ្ម ព្រះបិតាក្មេកនិងព្រះមាតាក្មេកទាំងពីរនោះ រស់នៅដរាបណា ក៏ទូន្មានខ្ញុំដរាបនោះ ។ ខ្ញុំនោះជាស្រីប្រកបដោយសេចក្តីមិនត្រេកអរ គឺការមិនបៀតបៀន ជាអ្នកប្រព្រឹត្តធម៌ដោយពិតប្រាកដ មិនខ្ជិលច្រអូស បានបម្រើព្រះមាតាក្មេកនិងព្រះបិតាក្មេកនោះ ដោយសេចក្តីគោរព ទាំងយប់ទាំងថ្ងៃ ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

[ ៧៣ ] បពិត្រព្រាហ្មណ៍ ខ្ញុំមិនមានសេចក្តីប្រច័ណ្ឌ ឬសេចក្តីក្រោធចំពោះពួកស្ត្រីទាំងមួយហ្មឺនប្រាំមួយពាន់ ដែលជាកិរិយាជាមួយគ្នា ក្នុងកាល

ណាម្តងឡើយ ។ ខ្ញុំត្រេកអរចំពោះស្ត្រីទាំងនោះ ដោយប្រយោជន៍ ស្រីណាមួយ មិនជាទីស្រឡាញ់របស់ខ្ញុំ ឥតមានឡើយ ខ្ញុំអនុគ្រោះពួកស្ត្រីរមប្តីទាំងអស់សព្វៗកាល ដូចជាខ្លួនឯង ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

[ ៧៤ ] ខ្ញុំមានឥន្ទ្រិយស្រស់ស្រាយ សព្វៗកាល បានចិញ្ចឹមនូវទាសៈទាំងឡាយផង កម្មករទាំងឡាយផង បុគ្គលដែលត្រូវចិញ្ចឹមទាំងឡាយផង ពួកជនដទៃដែលរស់នៅដោយសារផង តាមសមគួរដល់ហេតុ ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

[ ៧៥ ] ខ្ញុំមានដៃលាងហើយ បានផ្គត់ផ្គង់នូវពួកសមណៈផង នូវពួកព្រាហ្មណ៍ផង នូវពួកវណិព្វកៈដទៃផង ដោយបាយនិងទឹកសព្វៗកាល ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

[ ៧៦ ] ខ្ញុំជាស្ត្រីសង្រួមក្នុងសីលទាំងឡាយសព្វៗកាល បានរក្សានូវឧបោសថ ប្រកបដោយអង្គទាំង ៨ អស់ថ្ងៃទី ១៤ ផង អស់ថ្ងៃទី ១៥ ផង អស់ថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

[ ៧៧ ] ( សក្កទេវរាជពោលថា ) ម្នាលនាងរាជបុត្រី មានយស ដ៏ចម្រើន នាងបានថ្លែងនូវធម្មគុណទាំងឡាយណា ( ដែលមាន ) ក្នុងខ្លួន ធម្មគុណនោះទាំងអស់ មានបរិបូណ៌ ចំពោះនាងមែនហើយ ។ ព្រះរាជ បុត្តជាក្សត្របរិបូណ៌ដោយជាតិ កើតបរិសុទ្ធអំពីចំណែកទាំងពីរ មានយស ជាស្តេចប្រកបដោយធម៌របស់ជនទាំងឡាយ អ្នកនៅក្នុងដែនវិទេហៈនឹងកើត ដល់នាង ។

[ ៧៨ ] ( នាងសុមេធាទេវី... ) អ្នកមានក្អែកក្លិថ្ងា ទ្រទ្រង់នូវលំអង ឋិតនៅលើអាកាសទទេ ពោលវាចាជាទីពេញចិត្ត ដែលជាវាចាចូលទៅក្នុង ហឫទ័យរបស់ខ្ញុំ ។ ចុះអ្នកជាទេវតា ទើបនឹងមកអំពីឋានសួគ៌ ឬជាឥសីអ្នក មានឫទ្ធិច្រើន ម្យ៉ាងទៀត អ្នកជាអ្វី បានមកដល់ ( ក្នុងទីនេះ ) ចូរអ្នក ប្រកាសខ្លួនឲ្យជាក់ដល់ខ្ញុំ ។

[ ៧៩ ] ( សក្កទេវរាជ... ) ពួកទេវតា ប្រជុំគ្នាក្នុងរោងឈ្មោះសុធម្មា ហើយថ្វាយបង្គំនូវខ្ញុំណា ខ្ញុំនោះ ឈ្មោះសក្កៈ ជាអ្នកឃើញនូវហេតុមួយពាន់ ( ដោយមួយរំពេច ) បានមកក្នុងសំណាក់នាង ។ ស្ត្រីទាំងឡាយណា ក្នុង ជីវលោក ដែលជាអ្នកប្រព្រឹត្តស្មើ មានប្រាជ្ញា មានសីល ទុកម្តាយក្មេក ដូចជាទេវតា មានវត្តចំពោះប្តី ។ ទេវតាទាំងឡាយ មិនមែនជាមនុស្ស មក ជួបនឹងនាងនារី ជាមនុស្សដែលមានបញ្ញាល្អ មានការងារដ៏ស្អាត ប្រាកដស្មើ ដោយស្ត្រីទាំងនោះ ។ ម្នាលនាងដ៏ចម្រើន នាងបានមកកើតក្នុងរាជត្រកូល នេះ ជាស្ត្រីអាចសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដោយសារអំពើសុចរិត

ដែលនាងបានសាងសន្សំមកក្នុងកាលមុន ។ ម្នាលនាងរាជបុត្រី នេះឯងជាកិរិយាកាន់យកនូវជ័យនៃនាង ក្នុងលោកទាំងពីរ គឺកិរិយាកើតក្នុងទេវលោក ១ កេរ្តិ៍ឈ្មោះក្នុងជីវិតនេះ ១ ។ ម្នាលនាងសុមេធា សូមឲ្យនាងមានសេចក្តីសុខអស់កាលយូរ នាងចូររក្សានូវធម៌ក្នុងខ្លួនចុះ យើងនឹងទៅកាន់ឋានត្រៃត្រិង្សវិញ ការបានជួបនឹងនាងរាប់ថាជាទីស្រឡាញ់ពេញចិត្តរបស់យើង ។

## ចប់ សុរុចិជាតកទី ៦ ។

# អដ្ឋកថា

# សុរុចិជាតក

[ ៧១-៧៩ ] ព្រះសាស្ដា កាលអាស្រ័យនៅក្នុងនគរសាវត្ថី ទ្រង់គង់ក្នុងបុព្វារាម ក្នុងប្រាសាទរបស់មិគារមាតា ទ្រង់ប្រារព្ធពរ ៨ ប្រការ ដែលមហាឧបាសិកាវិសាខាបានទទួល ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **មហេសី រុចិនោ ភរិយា** ដូច្នេះជាដើម ។

រឿងពិស្ដារដូច្នេះថា ថ្ងៃមួយនាងវិសាខា ស្ដាប់ធម្មកថាក្នុងវត្តជេតពនមហាវិហារ ហើយក្រាបទូលនិមន្តព្រះដ៏មានព្រះភាគនិងភិក្ខុសង្ឃឆាន់ក្នុងវេលាព្រឹក ហើយត្រឡប់មកផ្ទះ ។ លុះរាត្រីកន្លងទៅ មហាមេឃក៏ញុំាងភ្លៀងឲ្យធ្លាក់ចុះក្នុងទ្វីបទាំង ៤ ។ ព្រះសាស្ដាទ្រង់ហៅពួកភិក្ខុមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភ្លៀងធ្លាក់ក្នុងវត្តជេតពនយ៉ាងណា ក្នុងទ្វីបទាំង ៤ ក៏យ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ មហាមេឃចុងក្រោយ គប្បីសើមកាយរបស់តថាគតបាន ខណៈដែលភ្លៀងកំពុងធ្លាក់ ព្រះសាស្ដាក៏បាត់អំពីវត្តជេតពន ជាមួយពួកភិក្ខុដែលមានឫទ្ធិ ប្រាកដត្រង់ខ្លោងទ្វារផ្ទះរបស់នាងវិសាខា ។ ឧបាសិកាត្រេកអរពោលថា អស្ចារ្យហ្ន៎ គួរចម្លែកពន់ពេកអ្នកទាំងឡាយអើយ ព្រោះព្រះតថាគត ទ្រង់មានឫទ្ធិច្រើន ទ្រទ្រង់នូវអានុភាពច្រើន ក្នុងកាលភ្លៀងមានប្រមាណស្មើក្បាលជង្គង់ក៏មាន ត្រឹមចង្កេះក៏មាន កំពុងហូរទៅ ជើងឬចីវររបស់ភិក្ខុមួយរូប ឈ្មោះថាសើមមិនមានឡើយ ហើយអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានក្រាបទូលសេចក្ដីនេះជាមួយព្រះសាស្ដា ដែលទ្រង់ធ្វើ

កត្តកិច្ចស្រេចហើយថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់សូមពរ ៨ ប្រការ ជាមួយព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា ព្រះតថាគតទាំងឡាយមានពរកន្លងផុតទៅហើយ នាងក្រាបទូលថា បពិត្រព្រះអង្គ ពរណាគួរដល់ខ្ញុំម្ចាស់ ហើយពរណាមិនមានទោស ខ្ញុំម្ចាស់ទូលសូមពរនោះៗ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា ចូរនាងពោលមកចុះ ។ នាងក៏ក្រាបទូលថាបពិត្រព្រះអង្គ ខ្ញុំម្ចាស់សូមប្រាថ្នាដើម្បីថ្វាយសំពត់ងូតទឹកភ្លៀងដល់ភិក្ខុសង្ឃដរាបដល់អស់ជីវិត ដើម្បីថ្វាយភត្តដល់ភិក្ខុដែលនិមន្តមកថ្មី ដើម្បីថ្វាយភត្តដល់ភិក្ខុដែលត្រៀមធ្វើដំណើរ ដើម្បីថ្វាយភត្តដល់ភិក្ខុដែលមានជំងឺ ដើម្បីថ្វាយភត្តដល់ភិក្ខុអ្នកថែជំងឺ ដើម្បីថ្វាយថ្នាំដល់ភិក្ខុមានជំងឺ ដើម្បីថ្វាយយាគូប្រចាំ ដើម្បីថ្វាយសំពត់ងូតទឹកដល់ភិក្ខុនីសង្ឃ ។ ព្រះសាស្តាត្រាស់សួរថាម្នាលនាងវិសាខា នាងឃើញអំណាចប្រយោជន៍អ្វីដល់ពរ ៨ ប្រការជាមួយនឹងតថាគត កាលនាងក្រាបទូលអានិសង្សរបស់ពរ ៨ ប្រការហើយ ព្រះសាស្តាក៏ត្រាស់ថា សាធុ សាធុ វិសាខា នាងឃើញអានិសង្សយ៉ាងនេះសូមពរ ៨ ប្រការ ហើយប្រទានពរ ៨ ប្រការដោយព្រះតម្រាស់ថា ម្នាលនាងវិសាខា តថាគតអនុញ្ញាតពរ ៨ ប្រការដល់នាង ហើយទ្រង់អនុមោទនាស្រេចហើយទ្រង់ចៀសចេញទៅ ។ ថ្ងៃមួយកាលព្រះសាស្តា គង់នៅក្នុងបុព្វារាម ពួកភិក្ខុនាំគ្នាលើករឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយមហាឧបាសិកាវិសាខា សូម្បីតាំងនៅក្នុងអត្តភាពជាមាតុគ្រាម ក៏គង់បានពរ ៨ ប្រការអំពីសម្នាក់ព្រះទសពល ឱ នាងមានគុណច្រើន ។ ព្រះសាស្តា

យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលនាងវិសាខាបានទទួលពរក្នុងសម្នាក់របស់តថាគត សូម្បីក្នុងកាលមុន ក៏បានទទួលពរហើយដូចគ្នា ហើយទ្រង់នាំអតីតនិទាន មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាទ្រង់ព្រះនាមថាសុរុចិ សោយរាជសម្បត្តិក្នុងនគរមិថិលា ទ្រង់មានព្រះរាជឱរស ទ្រង់បានថ្វាយព្រះនាមព្រះរាជឱរសនោះថា សុរុចិកុមារ ។ ព្រះរាជកុមារចម្រើនវ័យ ទ្រង់ព្រះតម្រិះថា អញនឹងរៀនសិប្បៈក្នុងនគរតក្កសិលា យាងទៅប្រថាប់គង់សម្រាក ត្រង់សាលាក្បែរទ្វារព្រះនគរ ចំណែកព្រះរាជឱរសរបស់ព្រះបាទពារាណសី ទ្រង់ព្រះនាមថា ព្រហ្មទត្តកុមារ ក៏យាងទៅក្នុងទីនោះដូចគ្នា ប្រថាប់គង់សម្រាក លើបន្ទះក្តារដែលព្រះសុរុចិកុមារប្រថាប់គង់នោះឯង ។ ព្រះរាជកុមារទាំងពីរទ្រង់សាកសួរគ្នាទៅវិញទៅមកហើយ មានភាពស្និទ្ធស្នាលគ្នា ទៅកាន់សម្នាក់អាចារ្យជាមួយគ្នានោះឯង ទ្រង់បានឲ្យថ្លៃទ្រនិបអាចារ្យហើយផ្តើមរៀនសិប្បៈមិនយូរប៉ុន្មានក៏សម្រេចសិប្បៈ នាំគ្នាលាអាចារ្យ យាងមករួមគ្នាបន្តិច ប្រថាប់ត្រង់ផ្លូវបែកជាពីរ ទ្រង់ឱបក្រសោបគ្នា ហើយធ្វើកតិកាគ្នាដើម្បីរក្សាមិត្តភាពឲ្យបានយឺនយូរថា បើខ្ញុំមានព្រះរាជឱរសទ្រង់មានព្រះរាជធីតា ឬទ្រង់មានព្រះរាជឱរសខ្ញុំមានព្រះរាជធីតា យើងនឹងធ្វើអាវាហមង្គល និងវិវាហមង្គល

ដល់ឱរសនិងធីតារបស់យើងនោះ ។ លុះកុមារទាំងពីរ សោយរាជសម្បត្តិ ព្រះបាទសុរុចិមហារាជ មានព្រះរាជឱរស ព្រះញាតិបានថ្វាយព្រះនាម ព្រះរាជឱរសនោះថា សុរុចិកុមារ ។ ព្រះបាទព្រហ្មទត្ត មានព្រះរាជធីតា ពួកព្រះញាតិបានថ្វាយព្រះនាមព្រះរាជធីតានោះថា សុមេធា ។ ព្រះរាជកុមារសុរុចិទ្រង់ចម្រើនវ័យ យាងទៅកាន់នគរតក្កសិលា ទ្រង់រៀនសិប្បៈសម្រេចហើយក៏យាងមក ។

គ្រានោះ ព្រះរាជបិតា មានបំណងនឹងអភិសេកព្រះរាជកុមារ ក្នុងរាជសម្បត្តិ ទ្រង់ព្រះតម្រិះថា ព្រះបាទពារាណសីសម្លាញ់របស់យើង មានព្រះរាជធីតា យើងនឹងស្តាបនានាងឲ្យជាអគ្គមហេសីរបស់កូនយើង ទ្រង់ប្រទានបណ្ណាការដ៏ច្រើន ទ្រង់បញ្ជូនពួកអាមាត្យទៅ ដើម្បីស្តីដណ្តឹង ព្រះនាងនោះ ។ ខណៈដែលពួកអាមាត្យទាំងនោះមិនទាន់មកដល់ ព្រះបាទពារាណសីសួរព្រះទេវីថា នែនាង អ្វីជាទុក្ខក្រៃលែងរបស់មាតុគ្រាម ព្រះទេវីទូលថា បពិត្រព្រះអង្គ ការមានស្រីរួមប្តីជាទុក្ខរបស់មាតុគ្រាម ព្រះរាជាត្រាស់ថា នែនាងបើដូច្នោះយើងត្រូវជួយគ្នា ដោះសុមេធាទេវីកូនស្រីយើង ឲ្យផុតអំពីទុក្ខនោះ យើងនឹងឲ្យដល់បុគ្គលដែលស្រឡាញ់តែនាងមួយប៉ុណ្ណោះ ។ កាលអាមាត្យទាំងនោះ នាំគ្នាមកដល់ប្រារព្ធព្រះនាមរបស់ព្រះនាងហើយ ទើបទ្រង់ត្រាស់ថា នែបាទាំងឡាយ សេចក្តីពិត កាលមុនយើងធ្វើបដិញ្ញាទុកជាមួយសម្លាញ់របស់យើង តែទោះជាយ៉ាងនោះ ខ្ញុំមិនបានបំណងបញ្ជូននាងទៅក្នុងចំណោមស្ត្រី យើងបំណងឲ្យនាងដល់បុគ្គលដែលស្រឡាញ់នាងតែម្នាក់ប៉ុណ្ណោះ ។

អាមាត្យទាំងនោះ នាំគ្នាបញ្ជូនដំណឹងមកកាន់សម្នាក់ព្រះរាជា ព្រះរាជាត្រាស់ថា រាជសម្បត្តិរបស់យើងធំធេងកន្លង មិថិលានគរមានអាណាខេត្ត ៧ យោជន៍ កំណត់នៃរាជអាណាចក្រដល់ ៣០០ យោជន៍ យ៉ាងតិច គួរមានស្ត្រី ១ ម៉ឺន ៦ ពាន់នាក់ ហើយទ្រង់មិនបានពេញព្រះហឫទ័យ ។

តែសុរុចិកុមារទ្រង់ស្តាប់រូបសម្បត្តិរបស់ព្រះនាងសុមេធាហើយ ក៏ជាប់ព្រះរាជហឫទ័យដោយលំជាប់ ទើបបញ្ជូនព្រះតម្រាស់ដល់ព្រះរាជមាតាបិតាថា ខ្ញុំនឹងលើកនាងជាអគ្គមហេសីតែមួយប៉ុណ្ណោះ ខ្ញុំមិនត្រូវការស្រីដទៃ សូមយាងនាងមកចុះ ព្រះរាជបិតាទ្រង់មិនជំទាស់ព្រះហឫទ័យរបស់ព្រះរាជកុមារ ទ្រង់បញ្ជូនទ្រព្យជាច្រើន យាងព្រះនាងមកដោយបរិវារធំហើយទ្រង់អភិសេកធ្វើព្រះនាងឲ្យជាមហេសីរបស់ព្រះរាជកុមារ ។ ព្រះរាជកុមារនោះទ្រង់ ព្រះនាមថាសុរុចិមហារាជ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ ទ្រង់នៅរួមជាមួយព្រះនាងដោយសេចក្តីស្រឡាញ់ ឯព្រះនាងប្រថាប់នៅក្នុងព្រះរាជវាំង របស់ព្រះរាជាអស់ ១ ម៉ឺនឆ្នាំ ព្រះនាងមិនបានព្រះរាជឱរសឬព្រះរាជធីតាឡើយ ។

កាលនោះ អ្នកនគរប្រជុំគ្នាស្រែកឡើងក្នុងលានព្រះរាជវាំង កាលព្រះរាជាត្រាស់សួរថា តើមានរឿងអ្វី ក៏ក្រាបទូលថា ទោសរបស់ព្រះរាជាមិនមាន តែឱរសអ្នកបន្តវង្សរបស់ទ្រង់មិនមានឡើយ ទ្រង់មានព្រះទេវីមួយអង្គ ធម្មតារាជត្រកូល ត្រូវមានស្រី ១ ម៉ឺន ៦ ពាន់នាក់យ៉ាងតិច សូមទ្រង់ទទួលស្រីទាំងឡាយចុះ បណ្តាស្រីទាំងនោះ ស្រីម្នាក់ គង់មានបុណ្យនឹងបានព្រះរាជឱរស ត្រូវព្រះរាជាទ្រង់ត្រាស់ហាមថា នែបាទាំងឡាយ អ្នក

នាំគ្នានិយាយអ្វី យើងបានប្តេជ្ញាទុកហើយថា នឹងមិនគ្រប់គ្រងស្រីដទៃឡើយ ទើបយាងស្រីនេះមកបាន យើងមិនអាចធ្វើមុសាវាទបាន យើងមិនត្រូវការក្រុមនៃស្ត្រី ចូរនាំគ្នាទៅចុះ ។ ព្រះនាងសុមេធាស្តាប់ ព្រះតម្រាស់នោះ ត្រិះរិះថា ព្រះរាជាមិនបាននាំស្រីដទៃមកឡើយ ព្រោះទ្រង់មានព្រះតម្រាស់ពិតប្រាកដ តែអញនឹងរកមកថ្វាយដល់ទ្រង់ ព្រះនាងតាំងនៅក្នុងតំណែងអគ្គមហេសី ដូចព្រះមាតារបស់ព្រះរាជា ទើបព្រះនាង នាំស្ត្រី ៤ ពាន់នាក់ គឺស្រីដែលជាត្រកូលក្សត្រ ១ ពាន់ កូនសេនាបតី ១ ពាន់ កូនសេដ្ឋី ១ ពាន់ កូនអ្នករបាំ ១ ពាន់ ដែលពេញព្រះហឫទ័យរបស់ព្រះនាង សូម្បីស្រីទាំងនោះនៅក្នុងរាជត្រកូលអស់ ១ ម៉ឺនឆ្នាំ ក៏មិនបានព្រះរាជឱរស ឬព្រះរាជធីតាដូចគ្នា ។ ព្រះនាងទ្រង់រកស្រីដទៃៗមកថ្វាយម្តង ៤ ពាន់ រហូតអស់វារៈ ៣ ដង ស្រីទាំងនោះក៏មិនបានព្រះរាជឱរស ឬព្រះរាជធីតាឡើយ ។ រួមជាស្រីដែលព្រះនាងនាំមកថ្វាយ ១ ម៉ឺន ៦ ពាន់នាក់ ។ ក្នុងកាលកន្លងទៅ ៤ ម៉ឺនឆ្នាំ រួមនឹងពេលដែលទ្រង់នៅជាមួយព្រះនាងតែមួយអង្គឯង ១ ម៉ឺនឆ្នាំផង រួមជា ៥ ម៉ឺនឆ្នាំ ។ កាលណោះ អ្នកនគរប្រជុំគ្នាស្រែកទៀត កាលព្រះរាជាត្រាស់ថា តើមានរឿងអ្វី ទើបនាំគ្នាក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់បង្គាប់ព្រះទេវីទាំងឡាយដើម្បីប្រាថ្នាព្រះរាជឱរសចុះ ។ ព្រះរាជាទទួលថា សាធុ ហើយ ត្រាស់នឹងព្រះទេវីថា ពួកនាងចូរប្រាថ្នាបុត្តចុះ ។ កាលនោះព្រះទេវីទាំងនោះ កាលប្រាថ្នាព្រះរាជឱរស ក៏នាំគ្នាបន់ស្រន់ទេវតាផ្សេងៗ នាំគ្នាបំពេញវត្តផ្សេងៗ ព្រះរាជឱរសក៏នៅតែមិនកើតឡើង ។

កាលណោះ ព្រះរាជាត្រាស់នឹងព្រះនាងសុមេធាថា នែនាង សូមនាងប្រាថ្នាព្រះរាជឱរសចុះ ។ ព្រះនាងទទួលព្រះតម្រាស់ថា សាធុ លុះដល់តិថី ១៥ ព្រះនាងសមាទានឧបោសថ ប្រថាប់គង់លើព្រះទែនដ៏សមគួរ ព្រះនាងរឭកដល់សីលទាំងឡាយក្នុងព្រះដំណាក់ដ៏មានសិរី ។ ព្រះទេវីដ៏សេស នាំគ្នាប្រព្រឹត្តវត្តមានវត្តពពែនិងវត្តគោជាដើម ទៅកាន់ព្រះរាជឧទ្យាន ។ ដោយតេជះនៃសីលរបស់ព្រះនាងសុមេធា ពិភពរបស់សក្កៈញាប់ញ័រ សក្កទេវរាជ ទ្រង់ពិចារណាថា នាងសុមេធាប្រាថ្នាព្រះរាជឱរស អញត្រូវឲ្យព្រះរាជឱរសដល់នាង តែអញមិនអាចឲ្យតាមមានតាមបាន ត្រូវជ្រើសរើសឱរសដែលសមគួរដល់នាង កាលទ្រង់ជ្រើសរើស ក៏ទ្រង់ឃើញទេវបុត្ត នឡការៈ ។ មែនពិត នឡការទេវបុត្តនោះ ជាសត្វដល់ព្រមដោយបុណ្យ កាលនៅក្នុងនគរពារាណសី ក្នុងអត្តភាពមុន ដល់ពេលសាបព្រោះស្រូវឃើញព្រះបច្ចេកពុទ្ធមួយអង្គ បញ្ជូនពួកទាសៈនិងកម្មករទៅសាបព្រោះ ខ្លួនឯងនាំព្រះបច្ចេកពុទ្ធមកកាន់ផ្ទះ ឲ្យឆាន់ហើយនិមន្តមកត្រង់ឆ្នេរស្ទឹងគង្គា រួមដៃជាមួយកូនប្រុសសាងបណ្ណសាលា យកដើមល្ហុធ្វើជាមេជញ្ជាំង យកដើមបបុសធ្វើជាជញ្ជាំង ចងទ្វារធ្វើទីចង្រ្កម ហើយនិមន្តព្រះបច្ចេកពុទ្ធឲ្យគង់នៅក្នុងបណ្ណសាលានោះឯងអស់ត្រៃមាស លោកចាំវស្សាហើយ ឪពុកនិងកូនក៏និមន្តឲ្យគ្រង់ត្រៃចីវរ ហើយបញ្ជូនទៅ ។ ដោយទំនងនេះឯង បាននិមន្តព្រះបច្ចេកពុទ្ធរហូត ៧ អង្គ ឲ្យគង់នៅក្នុងបណ្ណសាលានោះ ហើយឲ្យគ្រង់ត្រៃចីវរ ។ អាចារ្យខ្លះពោលថា ជនទាំងពីរឪពុកនិងកូនជាជាងផែង កំពុងជញ្ជូនឫស្សី

ត្រង់ឆ្នេរស្ទឹងគង្គា ឃើញព្រះបច្ចេកពុទ្ធ ទើបនាំគ្នាធ្វើយ៉ាងនោះ ដូច្នេះក៏មាន ។ ឪពុកកូនទាំងពីរនោះ ធ្វើកាលកិរិយា ទៅកើតក្នុងតាវត្តិង្សពិភព សោយឥស្សរិយយសនៃទេវតាជាធំ វិលវល់ទៅមកក្នុងកាមភពទាំង ៦ ជាន់ ។ ទេវបុត្តទាំងនោះ ប្រាថ្នាចុតិអំពីជាន់នោះ ទៅកើតក្នុងទេវលោកជាន់ខ្ពស់ ។

សក្កទេវរាជទ្រង់ជ្រាបដូច្នោះ យាងទៅដល់ទ្វារវិមានរបស់ទេវបុត្ត មួយអង្គក្នុងទេវបុត្តពីរអង្គនោះ ត្រាស់នឹងទេវបុត្តនោះដែលមកថ្វាយបង្គំ ហើយឈរថា នែអ្នកនិរទុក្ខ លោកគួរទៅកាន់មនុស្សលោក ទេវបុត្តទូលថា បពិត្រមហារាជ មនុស្សលោកគួរខ្ពើមផង ស្មោកគ្រោកផង ពួកជនដែលតាំងនៅក្នុងមនុស្សលោកនោះត្រូវធ្វើបុណ្យមានទានជាដើម ប្រាថ្នាទេវលោក ទូលព្រះបង្គំទៅមនុស្សលោកនោះធ្វើអ្វី ។ ព្រះឥន្ទត្រាស់ថា អ្នកនិរទុក្ខ អ្នកបានបរិភោគទិព្វសម្បត្តិ ដែលធ្លាប់បរិភោគក្នុងទេវលោក ក្នុងមនុស្សលោកក៏នឹងបាននៅក្នុងប្រាសាទរតនៈកម្ពស់ ២៥ យោជន៍ បណ្តោយ ៩ យោជន៍ ទទឹង ៨ យោជន៍ សូមអ្នកទទួលពាក្យចុះ ។ ទេវបុត្តនោះក៏ទទួលពាក្យ ។ សក្កទេវរាជទ្រង់កាន់យកបដិញ្ញារបស់ទេវបុត្តហើយ យាងទៅកាន់ឧទ្យានដោយភេទជាឥសី ចង្ក្រមក្នុងអាកាស អំពីខាងលើស្ត្រីទាំងនោះ ទ្រង់បង្ហាញខ្លួនឲ្យប្រាកដត្រាស់ថា អាត្មានឹងឲ្យឱរសដ៏ប្រសើរដល់ស្រីណា ស្រីណានឹងបានឱរសដ៏ប្រសើរ ។ ស្រីទាំង ១ ពាន់នាក់ លើកដៃអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យដល់ខ្ញុំ បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យដល់ខ្ញុំ ។ ពេលនោះសក្កៈត្រាស់ថា អាត្មានឹងឲ្យឱរសដល់ស្ត្រីដែលមានសីល

ពួកនាងមានសីលដូចម្ដេច មានអាចារៈដូចម្ដេច ។ ស្ត្រីទាំងនោះនាំគ្នាដាក់ដៃដែលលើកឡើងទាំងអស់ ពោលថា បើលោកម្ចាស់ប្រាថ្នាឲ្យដល់ស្ត្រីដែលមានសីល សូមទៅកាន់សម្នាក់របស់ព្រះនាងសុមេធាចុះ សក្កទេវរាជហោះទៅតាមអាកាសនោះឯង ប្រថាប់ឈរត្រង់មាត់បង្អួច ក្បែរទ្វារប្រាសាទរបស់ព្រះនាង ។ កាលនោះស្ត្រីទាំងនោះ នាំគ្នាក្រាបទូលដល់ព្រះនាងថា បពិត្រព្រះទេវី សូមព្រះនាងយាងមកចុះ ទេវរាជមួយអង្គ បំណងនឹងថ្វាយព្រះរាជឱរសដ៏ប្រសើរដល់ព្រះនាង ហោះមកតាមអាកាស កំពុងស្ថិតនៅត្រង់មាត់បង្អួច ។ ព្រះនាងយាងទៅដោយអាកប្បកិរិយារួសរាន់ បើកបង្អួចត្រាស់ថា បពិត្រលោកម្ចាស់ បានឮថា លោកម្ចាស់ឲ្យឱរសដ៏ប្រសើរដល់ស្រីអ្នកមានសីលជាការពិតឬ ។ សក្កទេវរាជត្រាស់ថា បពិត្រព្រះទេវី នេះជាការពិត ព្រះនាងត្រាស់ថា បើដូច្នោះ សូមលោកម្ចាស់ ឲ្យដល់ខ្ញុំចុះ ។ សក្កទេវរាជត្រាស់ថា សីលរបស់នាងដូចម្ដេច សូមត្រាស់មកចុះ បើគាប់ចិត្តអាត្មាភាព អាត្មាភាពនឹងថ្វាយព្រះរាជឱរសដ៏ប្រសើរ ។ ព្រះនាងស្ដាប់ព្រះតម្រាស់របស់សក្កទេវរាជ ត្រាស់ថា បើដូច្នោះសូមលោកម្ចាស់ស្ដាប់ចុះ កាលព្រះនាងពោលដល់សីលគុណរបស់ខ្លួន បានភាសិតព្រះគាថា ១៥ គាថាថា

ខ្ញុំជាមហេសីកិរិយារបស់ព្រះបាទសុរុចិ ដែលព្រះអង្គទ្រង់នាំ
មកមុនដំបូង ព្រះបាទសុរុចិ នាំខ្ញុំមកអស់មួយហ្មឺនឆ្នាំហើយ ។
បពិត្រព្រាហ្មណ៍ ខ្ញុំនោះមិនដែលដឹងថា ខ្ញុំបានមើលងាយព្រះ
រាជាសុរុចិ ជាធំក្នុងដែនវិទេហៈ ព្រះអង្គគ្រប់គ្រងនូវក្រុងមិថិ

លាដោយកាយដោយវាចា ឬដោយចិត្ត ក្នុងទីវាល ឬក្នុងទីកំបាំងមុខឡើយ ។ បពិត្រឥសី សូមឲ្យបុត្តកើត ( ក្នុងផ្ទៃរបស់ខ្ញុំ ) ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

ព្រះភស្តាផង ព្រះមាតាក្មេកផង ព្រះបិតាក្មេកផង ព្រះមាតាបង្កើតនិងបិតាបង្កើតផង ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ( របស់ខ្ញុំ ) បពិត្រព្រហ្ម ព្រះបិតាក្មេក និងព្រះមាតាក្មេក ទាំងពីរនោះ រស់នៅដរាបណា ក៏ទូន្មានខ្ញុំដរាបនោះ ។ ខ្ញុំនោះជាស្រីប្រកបដោយសេចក្តីមិនត្រេកអរ គឺការមិនបៀតបៀន ជាអ្នកប្រព្រឹត្តធម៌ដោយពិតប្រាកដ មិនខ្ជិលច្រអូស បានបម្រើព្រះមាតាក្មេកនិងព្រះបិតាក្មេកនោះ ដោយសេចក្តីគោរព ទាំងយប់ទាំងថ្ងៃ ។ បពិត្រឥសី សូមឲ្យបុត្តកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

បពិត្រព្រាហ្មណ៍ ខ្ញុំមិនមានសេចក្តីប្រច័ណ្ឌ ឬសេចក្តីក្រោធចំពោះពួកស្ត្រីទាំងមួយម៉ឺនប្រាំមួយពាន់ ដែលជាភរិយាជាមួយគ្នាក្នុងកាលណាមួយឡើយ ។ ខ្ញុំត្រេកអរ ចំពោះស្ត្រីទាំងនោះដោយប្រយោជន៍ ស្រីណាមួយមិនជាទីស្រឡាញ់របស់ខ្ញុំ ឥត

មានឡើយ ខ្ញុំអនុគ្រោះពួកស្រ្តីរួមប្តីទាំងអស់សព្វៗកាល ដូចជាខ្លួនឯង ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះកាលបើខ្ញុំនិយាយកុហកសូមឲ្យក្បាល (របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

ខ្ញុំមានឥន្ទ្រិយស្រស់ស្រាយសព្វ ៗ កាល បានចិញ្ចឹមនូវទាសៈទាំងឡាយផង កម្មករទាំងឡាយផង បុគ្គលដែលត្រូវចិញ្ចឹមទាំងឡាយផង ពួកជនដទៃដែលរស់នៅដោយសារផង តាមសមគួរដល់ហេតុ ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហកសូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

ខ្ញុំមានដៃលាងហើយ បានផ្គត់ផ្គង់នូវពួកសមណៈផង នូវពួកព្រាហ្មណ៍ផង នូវពួកវណិព្វកៈដទៃផងដោយបាយនិងទឹកសព្វៗកាល ។ បពិត្រឥសី សូមឲ្យបុត្តកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះកាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល ( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ។

ខ្ញុំជាស្រ្តីសង្រួមក្នុងសីលទាំងឡាយសព្វៗកាល បានរក្សានូវឧបោសថ ប្រកបដោយអង្គទាំង ៨ អស់ថ្ងៃទី ១៤ ផង អស់ថ្ងៃទី ១៥ ផង អស់ថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ។ បពិត្រឥសី សូមឲ្យបុត្ត កើតដោយកិរិយាពោល

នូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល

( របស់ខ្ញុំ ) បែកជាប្រាំពីរភាគចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មហេសី** បានដល់ អគ្គមហេសី ។ បទថា **រុចិនោ** បានដល់ ព្រះរាជាទ្រង់ព្រះនាមថាសុរុចិ ។ បទថា **បឋមំ** សេចក្ដីថា ខ្ញុំបានមកជាអគ្គមហេសីទីមួយ មុនស្រីទាំងពួងបណ្ដាស្រី ១ ម៉ឺន ៦ ពាន់នាក់ ។ បទថា **យំ មំ** សេចក្ដីថា ចាប់តាំងអំពីព្រះបាទសុរុចិ ទ្រង់នាំខ្ញុំមកដើម្បីការនៅរួមគ្នាយ៉ាងមានសេចក្ដីសុខ ខ្ញុំបានជាស្រីម្នាក់ប៉ុណ្ណោះ ដែលបាននៅក្នុងដំណាក់នេះអស់ ១ ម៉ឺនឆ្នាំ ។ បទថា **អតិមញ្ញិត្ថ** សេចក្ដីថា ខ្ញុំមិនធ្លាប់ជ្រាប មិនធ្លាប់រឭកសោះថា ខ្ញុំប្រព្រឹត្តកន្លងព្រះរាជាសុរុចិ ទាំងក្នុងទីចំពោះមុខ ឬទីកំបាំងមុខ សូម្បីត្រឹមតែមួយភ្លែត ។ ព្រះនាងហៅឥសីនោះថា **ឥសេ** ។

បទថា **តេ មំ** សេចក្ដីថា ព្រះជនកនិងព្រះជននីរបស់ព្រះកស្ដា ទាំងពីរអង្គនោះទ្រង់ប្រោសប្រណី ទ្រង់នាំខ្ញុំមក ។ បទថា **វិនេតារោ** សេចក្ដីថា ខ្ញុំបានទទួលការដឹកនាំអំពីទ្រង់ទាំងពីរហើយ ទ្រង់ទាំងពីរនោះ គង់ព្រះជន្មដរាបណា ក៏គង់ប្រទានឱវាទដល់ខ្ញុំដរាបនោះ ។ បទថា **អហឹសារតិនី** សេចក្ដីថា ខ្ញុំប្រកបដោយចេតនាដែលជាហេតុវៀរ ពោលគឺការមិនបៀតបៀនដោយអត្ថថា ខ្ញុំមិនធ្លាប់បៀតបៀនសត្វណាមួយ ចាប់ពីស្រមោចខ្មៅ ស្រមោចក្រហមឡើងទៅ ។ បទថា **កាមសា** បានដល់ ដោយចំណែកមួយនោះឯង ។ បទថា **ធម្មចារិនី** សេចក្ដីថា ខ្ញុំបំពេញក្នុងកុសលកម្ម ១០ ប្រការ ។

បទថា **ឧបដ្ឋាសឹ** សេចក្តីថា ខ្ញុំធ្វើកិច្ចផ្សេងៗ មានការបរិកម្មព្រះបាទជាដើម ប្រ-ណិប័តន៍ទ្រង់ទាំងពីរនោះឯង ។ បទថា **សហភរិយាតិ** សេចក្តីថា ជាភរិយារួមប្តីជាមួយខ្ញុំ ។ បទថា **ធាមា** សេចក្តីថា ធម៌គឺសេចក្តីប្រណែន ឬធម៌គឺសេចក្តីក្រោធព្រោះអាស្រ័យកិលេសមិនធ្លាប់មានដល់ខ្ញុំឡើយ ។ បទថា **ហិ-តេន** សេចក្តីថា កិច្ចណាជាកិច្ចឧបការៈដល់ស្រីទាំងនោះ ខ្ញុំរមែងត្រេកអរដោយប្រយោជន៍របស់ស្រីទាំងនោះពិតៗ ខ្ញុំឃើញស្រីទាំងនោះហើយ រមែងត្រេកអរ ដូចជាបុត្តធីតាដែលកើតអំពីទ្រូងដូច្នោះ ។ បទថា **កាចិ** សេចក្តីថា បណ្តាស្រីទាំងនោះ ស្រីត្រឹមតែម្នាក់ឈ្មោះថាខ្ញុំមិនស្រឡាញ់ មិនមានឡើយ ខ្ញុំស្រឡាញ់គ្រប់គ្នានោះឯង ។ បទថា **អនុកម្បាមិ** សេចក្តីថា ខ្ញុំអាណិតអាសូស្រីទាំង ១ ម៉ឺន ៦ ពាន់នាក់នោះគ្រប់គ្នា ដោយចិត្តទន់ភ្លន់ ដូចស្រឡាញ់ខ្លួនឯងដូច្នោះ ។ បទថា **សហធម្មេន** សេចក្តីថា ខ្ញុំចិញ្ចឹមតាមកិច្ចដែលប្រគល់ឲ្យគេធ្វើបាន ដោយអត្ថថា បុគ្គលណាអាចធ្វើកម្មណា ខ្ញុំក៏ប្រើបុគ្គលនោះក្នុងកម្មនោះ ។ បទថា **បមុទិតិន្ទ្រិយា** សេចក្តីថា កាលប្រើសោតក៏ញញឹមញញែមជានិច្ចនោះឯង ខ្ញុំមិនធ្លាប់ប្រើអ្នកណាមួយ ដោយសេចក្តីក្រេវក្រោធថា ហងទាសីអាក្រក់ អាចូរធ្វើការនេះចុះ ដូច្នេះក្នុងកាលណាឡើយ ។ បទថា **បយតបាណិនី** សេចក្តីថា ជាអ្នកមានបាតដៃលាងហើយលាដៃចេញហើយនោះឯង ។ បទថា **បាដិហារិយបក្ខញ្ច** សេចក្តីថា ៤ ថ្ងៃដោយអំណាចថ្ងៃទទួលនិងថ្ងៃអម គឺថ្ងៃ ៥ ថ្ងៃ ៨ ថ្ងៃ ១៤ ថ្ងៃ ១៥ ។ បទថា **សទា** សេចក្តីថា ជាអ្នកសង្រួមក្នុងសីល ៥ សព្វកាលជានិច្ច គឺ

ជាអ្នកមានអត្តភាពដែលសីលទាំងនោះគ្រប់គ្រងទុកហើយ ។

ធម្មតាការប្រមាណគុណរបស់ព្រះនាង សូម្បីពណ៌នាមួយរយគាថា មួយពាន់គាថា ក៏មិនគ្រប់គ្រាន់ឡើយដោយប្រការដូច្នេះ ។ ក្នុងកាលដែលព្រះនាងពណ៌នាគុណរបស់ខ្លួនដោយគាថា ១៥ ប៉ុណ្ណោះ សក្កទេវរាជ ក៏កាត់ព្រះតម្រាស់របស់ព្រះនាង ព្រោះទ្រង់មានកិច្ចដែលត្រូវធ្វើច្រើន កាលទ្រង់សរសើរព្រះនាងថា គុណរបស់ព្រះនាងអស្ចារ្យនោះឯង ទើបត្រាស់គាថា ២ ថា

ម្នាលនាងរាជបុត្រី មានយសដ៏ចម្រើន នាងបានថ្លែងនូវធម្មគុណទាំងឡាយណា ( ដែលមាន ) ក្នុងខ្លួន ធម្មគុណនោះទាំងអស់មានបរិបូណ៌ចំពោះនាងមែនហើយ ។ ព្រះរាជបុត្តជាក្សត្រ បរិបូណ៌ដោយជាតិ កើតបរិសុទ្ធអំពីចំណែកទាំងពីរ មានយស ជាស្តេចប្រកបដោយធម៌របស់ជនទាំងឡាយ អ្នកនៅក្នុងដែនវិទេហៈ នឹងកើតដល់នាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មគុណា** បានដល់ មានគុណតាមសេចក្តីពិត គឺមានគុណពិត ។ បទថា **សំវិជ្ជន្តិ** សេចក្តីថា គុណទាំងឡាយណាដែលព្រះនាងត្រាស់ហើយ គុណទាំងអស់នោះឯង សម្បូរដល់ព្រមក្នុងព្រះនាង ។ បទថា **អភិជាតោ** សេចក្តីថា ព្រះឱរសទ្រទ្រង់នូវកំណើតបរិសុទ្ធទាំងពីរចំណែក ។ បទថា **យសស្សិមា** សេចក្តីថា ទ្រង់ដល់ព្រមដោយសម្បត្តិគឺយសនិងសម្បត្តិគឺបរិវារ ។ បទថា **ឧប្បជ្ជតេ** សេចក្តីថា កូនបែបនេះ នឹងកើតដល់ព្រះនាង សូមព្រះនាងកុំវិតក្កៈឡើយ ។

ព្រះនាងស្តាប់ព្រះតម្រាស់របស់សក្កៈហើយ សោមនស្ស កាលត្រាស់សួរសក្កទេវរាជ ទើបពោលគាថា ២ ថា

អ្នកមានភ្នែកភ្លឺថ្លា ទ្រទ្រង់នូវលំអង ឋិតនៅលើអាកាសទទេ
ពោលវាចាជាទីពេញចិត្ត ដែលជាវាចាចូលទៅក្នុងហឫទ័យ
របស់ខ្ញុំ ។ ចុះអ្នកជាទេវតាទើបនឹងមកអំពីឋានសួគ៌ ឬជាឥសី
អ្នកមានឫទ្ធិច្រើន ម្យ៉ាងទៀត អ្នកជាអ្វី បានមកដល់ ( ក្នុង
ទីនេះ ) ចូរអ្នកប្រកាសខ្លួនឲ្យជាក់ដល់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧម្មិ** សេចក្តីថា សក្កទេវរាជមានព្រះនេត្រមិនប៉ប្រិច កាលយាងមកក៏យាងមកដោយភេទជាតាបស ដែលគួរគេត្រកអរព្រះនាងត្រាស់យ៉ាងនេះ ព្រោះសក្កទេវរាជយាងមកដោយភេទជាបព្វជិត ។ បទថា **អាយេ** បានដល់ ក្នុងទីដែលមិនមានវត្ថុណាបាំង ។ បទថា **យំ មយ្ហំ** សេចក្តីថា លោកកំពុងពោលពាក្យដែលគួរពេញចិត្តរបស់ខ្ញុំនោះឯង ជាទេវ-តាមកអំពីឋានសួគ៌មកក្នុងទីនេះ ឬបើមិនដូច្នោះ ក៏ជាឥសីមានឫទ្ធិច្រើន ឬបណ្តាទេវតាមានសក្កៈជាដើម លោកជាទេវតាអង្គណាហ្ន៎ មកប្រាកដហើយក្នុងទីនេះ ។ បទថា **អត្តានំ មេ បវេទយ** សេចក្តីថា ព្រះនាងត្រាស់ថា សូមលោកប្រាប់សេចក្តីពិតដល់ខ្ញុំឲ្យជ្រាបផង ។

សក្កទេវរាជ កាលត្រាស់ប្រាប់ដល់ព្រះនាង ក៏ពោលគាថា ៦ ថា

ពួកទេវតាប្រជុំគ្នាក្នុងរោងឈ្មោះសុធម្មា ហើយថ្វាយបង្គំនូវខ្ញុំ
ណា ខ្ញុំនោះ ឈ្មោះសក្កៈ ជាអ្នកឃើញនូវហេតុមួយពាន់

( ដោយមួយរំពេច ) បានមកក្នុងសំណាក់នាង ។ ស្ត្រីទាំងឡាយណា ក្នុងជីវលោកដែលជាអ្នកប្រព្រឹត្តស្មើ មានប្រាជ្ញា មានសីល ទុកម្ដាយក្មេកដូចជាទេវតា មានវត្តចំពោះប្ដី ។ ទេវតាទាំងឡាយ មិនមែនជាមនុស្ស មកជួបនឹងនាងនារី ជាមនុស្សដែលមានបញ្ញាល្អ មានការងារដ៏ស្អាត ប្រាកដស្មើដោយស្ត្រីទាំងនោះ ។ ម្នាលនាងដ៏ចម្រើន នាងបានមកកើតក្នុងរាជត្រកូលនេះ ជាស្ត្រីអាចសម្រេចនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាងដោយសារអំពើសុចរិត ដែលនាងបានសាងសន្សំមកក្នុងកាលមុន ។ ម្នាលនាងរាជបុត្រី នេះឯងជាកិរិយាកាន់យកនូវជ័យនៃនាងក្នុងលោកទាំងពីរ គឺកិរិយាកើតក្នុងទេវលោក ១ កេរ្តិ៍ឈ្មោះក្នុងជីវិតនេះ ១ ។ ម្នាលនាងសុមេធា សូមឲ្យនាងមានសេចក្ដីសុខអស់កាលយូរ នាងចូររក្សានូវធម៌ក្នុងខ្លួនចុះ យើងនឹងទៅកាន់ឋានត្រៃត្រិង្សវិញ ការបានជួបនឹងនាងរាប់ថា ជាទីស្រឡាញ់ពេញចិត្តរបស់យើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សហស្សនេត្តោ** សេចក្ដីថា ឈ្មោះថាជាអ្នកមានភ្នែកមួយពាន់ ដោយអាចឃើញរឿងដែលមនុស្សមួយពាន់នាក់គិត ត្រឹមតែមួយរំពេច ។ បទថា **ឥត្ថិយោ** បានដល់ ស្រីទាំងឡាយ ។ បទថា **សមចារិនី** បានដល់ ដែលប្រកបដោយការប្រព្រឹត្តស្មើ ដោយទ្វារទាំង ៣ ។ បទថា **តាទិសាយ** បានដល់ បែបនោះ ។ បទថា **សុមេធាយ** បានដល់

ជាអ្នកមានបញ្ញាល្អ ។ បទថា **ឧភយត្ថ កដគ្គហោ** សេចក្ដីថា សេចក្ដីនេះ ជាការកាន់យកជ័យជម្នះទុកបានរបស់នាង ទាំងក្នុងអត្តភាពនេះនិងក្នុងអនាគត គឺបណ្ដាលោកនេះ និងលោកខាងមុខទាំងនោះ ក្នុងអនាគត បានដល់ការចូលដល់ទេវលោកក្នុងជីវិត ដែលកំពុងប្រព្រឹត្តទៅ ក៏បានទូវកិត្តិយស ហេតុនោះទើបសេចក្ដីនេះ ឈ្មោះថាជាការកាន់យកនូវជ័យជម្នះ ទុកបានក្នុងលោកទាំងពីរ ។ បទថា **ធម្មំ** បានដល់ ចូររក្សាធម៌ គឺគុណ ដែលមានពិតយ៉ាងនោះ ទុកក្នុងខ្លួនឲ្យឋិតថេរចុះ ។ បទថា **ឃសាហំ** កាត់បទជា **ឃសោ អហំ** ។ បទថា **បិយំ មេ** បានដល់ ការឃើញនាង ជាការឃើញដែលល្អដល់ខ្ញុំ ។

សក្កទេវរាជប្រទានឱវាទដល់នាងថា កិច្ចដែលត្រូវធ្វើរបស់ខ្ញុំ មានក្នុងទេវលោក ហេតុនោះខ្ញុំត្រូវទៅ ចូរនាងកុំប្រមាទចុះ ហើយយាងចៀសចេញទៅ ។ លុះដល់ពេលទៀបភ្លឺ នឡការៈទេវបុត្តក៏ចុតិមកបដិសន្ធិក្នុងព្រះឧទររបស់ព្រះនាង ។ ព្រះនាងទ្រង់ជ្រាបភាពដែលព្រះនាងទ្រង់គភ៌ ក៏ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ប្រទានគ្រឿងរក្សាគភ៌ លុះគ្រប់ទសមាស ព្រះនាងក៏ប្រសូតព្រះរាជឱរស ។ ព្រះញាតិបានថ្វាយព្រះនាមព្រះរាជឱរសថា មហាបនាទៈ ។ អ្នកដែនទាំងពីរ កាលចោលនូវកហាបណៈលើលានព្រះរាជវាំងមួយកហាបណៈ ដើម្បីឲ្យព្រះរាជាទ្រង់ជ្រាបថា ជាថ្លៃទឹកដោះរបស់អយ្យបុត្តរបស់យើងហើយ កហាបណៈក៏ក្លាយជាគំនរធំ ។ សូម្បីព្រះរាជាទ្រង់ត្រាស់ហាម ក៏នាំគ្នាក្រាបទូលថា នឹងបានជាថ្លៃចាយវាយ ក្នុងកាលដែលព្រះអយ្យ

បុត្តរបស់ពួកខ្ញុំទ្រង់ធំចម្រើនឡើង មិនទារនូវសំណាងហើយចៀសចេញទៅ ។ ព្រះរាជកុមារទ្រង់ចម្រើនដោយបរិវារច្រើន កាលទ្រង់មានព្រះជន្ម ១៦ វស្សា ទ្រង់ក៏សម្រេចសិប្បៈគ្រប់ប្រការ ។ ព្រះរាជាទ្រង់ពិនិត្យមើលព្រះជន្មរបស់ព្រះរាជឱរសហើយ ទ្រង់ត្រាស់នឹងព្រះទេវីថា នែនាង ក្នុងពេលអភិសេកកូនរបស់យើងក្នុងរាជសម្បត្តិ នឹងសាងប្រាសាទដែលគួរជាទីត្រេកអរ ហើយធ្វើនូវការអភិសេក ព្រះនាងទទួលព្រះរាជឱង្ការថា សាធុ ។ ព្រះរាជាត្រាស់ឲ្យអាចារ្យដែលចេះមើលទីដីជយភូមិមកត្រាស់ថា នែបាទាំងឡាយ ចូរប្រាប់ជាងឲ្យសាងប្រាសាទ ដើម្បីកូនរបស់យើង ក្នុងទីមិនឆ្ងាយអំពីដំណាក់របស់យើង យើងនឹងអភិសេកកូនរបស់យើងក្នុងរាជសម្បត្តិ ។ ពួកអាចារ្យដែលចេះវិជ្ជាមើលទឹកដីទាំងនោះ ទទួលព្រះរាជឱង្ការថា បពិត្រព្រះអង្គ ទូលព្រះបង្គំ សូមទទួលព្រះរាជបញ្ជា ហើយនាំគ្នាមើលទឹកដីជយភូមិ ។

ខណៈនោះសក្កៈពិភពក៏សម្តែងអាការៈក្តៅ សក្កទេវរាជជ្រាបហេតុនោះ ហៅវិស្សកម្មទេវបុត្តមកត្រាស់ថា នែបាចូរបាទៅសាងប្រាសាទរតនៈបណ្តោយ ៩ យោជន៍ ទទឹង ៨ យោជន៍ កម្ពស់ ២៥ យោជន៍ ឲ្យដល់មហាបនាទរាជកុមារចុះ ។ វិស្សកម្មទេវបុត្ត កាឡាខ្លួនជាជាងឈើទៅកាន់សម្នាក់របស់ពួកជាង ហើយបញ្ជូនជាងទាំងនោះទៅដោយពាក្យថា ពួកលោកបរិភោគបាយព្រឹកហើយសឹមមកចុះ ហើយក៏យកដំបងវាយផែនដី រំពេចនោះឯងប្រាសាទ ៧ ជាន់ មានទំហំដូចពោលហើយក៏ផុសឡើង ។ មង្គល ៣ ប្រការ គឺការឆ្លងប្រាសាទ ការអភិសេកលើកស្វេតច្ឆត្រ និងអាវាហមង្គលរបស់ព្រះរាជ

កុមារមហាបនាទៈ មានក្នុងកាលតែមួយនោះឯង ។ អ្នកដែនទាំងពីរនាំគ្នាប្រជុំក្នុងទីមន្តល ឲ្យកាលវេលាកន្លងទៅអស់ ៧ ឆ្នាំ ដោយមហោស្រពធ្វើមន្តល ព្រះរាជាទ្រង់មិនបានប្រាប់ឲ្យជនទាំងនោះលះបង់ការងារឡើយ ។ វត្ថុទាំងអស់មានគ្រឿងប្រដាប់ គ្រឿងបរិភោគរបស់ជនទាំងនោះ ជាវត្ថុរបស់រាជត្រកូលទាំងអស់ ។ លុះកន្លងទៅបាន ៧ ឆ្នាំ ជនទាំងនោះក៏នាំគ្នាស្រែកកាលព្រះបាទសុរុចិមហារាជត្រាស់សួរថា តើមានរឿងអ្វី ក៏នាំគ្នាក្រាបទូលថា បពិត្រមហារាជ កាលពួកទូលបង្គំនាំគ្នាលេងមន្តល ៧ ឆ្នាំកន្លងទៅហើយទីបំផុតរបស់មន្តលនឹងមានក្នុងកាលណា ។ លំដាប់នោះ ព្រះរាជាត្រាស់ថាអស់កាលមានប្រមាណប៉ុណ្ណេះ កូនរបស់យើងមិនសើចសោះ កាលណាកូនរបស់យើងសើច កាលនោះពួកអ្នកចូរនាំគ្នាទៅចុះ ។ កាលនោះមហាជនក៏ដើរវាយស្គរអញ្ជើញអ្នករបាំរបស់ព្រះបាទមហាបនាទៈនោះមកប្រជុំគ្នា ។ អ្នករបាំ ៦ ពាន់នាក់ នាំគ្នាមកប្រជុំ បែកគ្នាជា ៧ ចំណែក នាំគ្នារាំមិនអាចឲ្យព្រះរាជាសើចបាន ។ ក្នុងពេលនោះ ព្រោះភាពដែលព្រះរាជាធ្លាប់ទតរបាំដែលជាទិព្វមកអស់កាលយូរទើបការរាំរបស់អ្នករបាំទាំងនោះមិនជាទីពេញព្រះហឫទ័យ ។

កាលណោះ កំពូលអ្នករបាំពីរនាក់ គឺភណ្ឌុកណ្ណៈ និងបណ្ឌុកណ្ណគិតថា ពួកយើងនឹងឲ្យព្រះរាជាទ្រង់ព្រះសំណើចឲ្យបាន នាំគ្នាចូលទៅកាន់លានព្រះរាជវាំង បណ្តាកំពូលអ្នករបាំទាំងពីរនោះភណ្ឌុកណ្ណៈ ឲ្យដាំដើមស្វាយជំណ្មោះអតុលៈត្រង់ទ្វារ ហើយចោលដុំអំបោះឡើង ឲ្យពាក់ត្រង់មែកស្វាយនោះ ហើយតោងឡើងតាមសរសៃអំបោះ ។ បានឮថា ដើមស្វាយឈ្មោះ

អតុលៈជាដើមស្វាយរបស់ព្រះបាទវេស្សវ័ណ កាលនោះពួកទាសៈរបស់ព្រះបាទវេស្សវ័ណ ក៏នាំគ្នាកាប់មែកតូចធំរបស់ស្វាយនោះ មែកស្វាយនោះ ក៏ធ្លាក់ចុះមក ។ អ្នករបាំដ៏សេស រើសមែកស្វាយនោះគរជាគំនរ ហើយស្រោចដោយទឹក ។ ភណ្ឌុកណ្ឋៈនោះស្លៀកសំពត់ក្រងដោយផ្កា ក្រោកឡើងចាក់ក្បាច់រាំពត់ពែន ។ ព្រះបាទមហាបនាទៈទតឃើញបុរសនោះហើយ ក៏មិនសើចឡើយ ។ បណ្ឌុកណ្ឋបានធ្វើជើងថ្ករឈើ ត្រង់ផ្ទៃលានព្រះរាជវាំង ហើយដើរចូលកាន់គំនរភ្លើងជាមួយបរិស័ទរបស់ខ្លួន កាលភ្លើងរលត់ហើយ អ្នករបាំទាំងឡាយក៏យកទឹកស្រោចជើងថ្ករ បណ្ឌុកណ្ឋៈនោះ មួយអន្ទើដោយបរិស័ទ ស្លៀកសំពត់ក្រងដោយផ្កា ក្រោកឡើងរាំពត់ពែន ។ ព្រះរាជាទតហើយក៏នៅតែមិនសើចនោះឯង លុះអស់តម្រិះដែលអាចឲ្យព្រះរាជាអង្គនោះសើចបាន ក៏នាំគ្នារំសាយដោយប្រការដូច្នេះ ។ សក្កទេវរាជជ្រាបហេតុនោះទ្រង់បញ្ជូនអ្នករបាំដែលជាទេវតា ទៅដោយព្រះតម្រាស់ថា នែបា ចូរបាទៅចុះ ចូធ្វើឲ្យព្រះបាទមហាបនាទៈទ្រង់សើចចុះ ។ ទេវតាអ្នករបាំនោះ មកឈរលើអាកាស ត្រង់លានព្រះរាជវាំង សម្ដែងក្បាច់រាំដែលមានឈ្មោះថាឧបឌ្ឍង្គៈ ។ ដៃតែម្ខាងប៉ុណ្ណោះ ជើងក៏ម្ខាង ភ្នែកក៏ម្ខាង ចិញ្ចើមក៏ម្ខាង រាំទៅរាំមក កម្រើករំពើកទៅ ឯចំណែកដ៏សេសនៅស្ងៀមមិនកម្រើកឡើយ ព្រះបាទមហាបនាទៈ ទ្រង់ទតឃើញអាការៈនោះទ្រង់ញញឹមបន្តិច ។ តែមហាជនកាលសើច ក៏សើចលាន់រំពងរហូតដល់តម្កល់សតិមិនបាន ក៏បណ្ដោយអវយវៈទាំងអស់បម្រះនទៀលក្នុងលានព្រះរាជវាំង មង្គលក៏បញ្ឈប់ក្នុងពេលនោះ ។

*អត្ថដ៏សេសក្នុងរឿងនេះ ពណ៌នាទុកក្នុងមហាបនាទជាតក ដែលមានពាក្យថា* **បនាទោ នាមសោ រាជា យស្ស យូបោ សុវណ្ណមយោ** *ជាដើម ។*

*ព្រះរាជាមហាបនាទៈ ទ្រង់ធ្វើបុណ្យមានថ្វាយទានជាដើម កាលអស់ព្រះជន្ម ក៏ទៅកាន់ទេវលោកនោះឯង ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា មហាបនាទៈក្នុងកាលនោះ បានមកជាភទ្ទជិភិក្ខុក្នុងកាលឥឡូវនេះ សុមេធាទេវីក្នុងកាលនោះ បានមកជានាងវិសាខា វិស្សកម្មទេវបុត្តក្នុងកាលនោះ បានមកជាអានន្ទ ចំណែកសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។*

## *អដ្ឋកថា សុរុចិជាតក ចប់*

# បញ្ចុបោសថិកជាតក

[ ៨០ ] ( តាបសពោលថា ) ម្នាលព្រាប ឥឡូវនេះ អ្នកមានសេចក្តីខ្វល់ខ្វាយតិច ម្នាលបក្សី អ្នកមិនមានសេចក្តីត្រូវការដោយចំណីសោះ ម្នាលព្រាប អ្នកខំអត់ទ្រាំនូវគម្លាននិងសម្រេក ជាសត្វរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

[ ៨១ ] ( ព្រាបពោលថា ) ក្នុងកាលមុន ខ្ញុំមានចិត្តជាប់នឹងមេព្រាប យើងខ្ញុំទាំងពីរនាក់ កំពុងតែរីករាយ ( ក្នុងកាម ) ក្នុងប្រទេសនោះ ស្រាប់តែសត្វខ្លែងមកចាបយកមេព្រាបទៅ ខ្ញុំក៏អស់សេចក្តីប្រាថ្នា ព្រោះប្រាសចាកមេព្រាបនោះ ។ ខ្ញុំវេទនាទូវវេទនាធំក្នុងចិត្ត ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យរាគៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ។

[ ៨២ ] ( តាបស... ) ម្នាលពស់ ជាឧរគជាតិ លូនទៅមិនត្រង់ មានអណ្តាតពីរ អ្នកមានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក ម្នាលសត្វមានខ្លួនវែង អ្នកអត់ទ្រាំនូវគម្លាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

[ ៨៣ ] ( ពស់... ) គោឈ្មោលឡើងករបស់អ្នកស្រុក ជាគោមានកម្លាំង មានបូកដ៏យុរយារ បរិបូណ៌ដោយសម្បុរនិងកម្លាំង គោនោះដើរជាន់ខ្ញុំ ខ្ញុំខឹងបានចឹកវាៗ ត្រូវសេចក្តីទុក្ខគ្របសង្កត់ ហើយក៏ស្លាប់ទៅ ។ លំដាប់នោះ ពួកជនចេញអំពីស្រុកកន្ទក់កន្ទេញយំទួញ ហើយដើរចៀសចេញទៅ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្តីក្រោធគ្រប

សង្កត់ខ្ញុំបានទៀតឡើយ ។

[ ៨៤ ] ( តាបស... ) ក្នុងព្រៃស្មសាន មានសាច់របស់សត្វស្លាប់ដ៏ច្រើន សាច់ទាំងនោះជាភោជនជាទីគាប់ចិត្តរបស់អ្នក ម្នាលចចក អ្នកខំអត់ទ្រាំនូវគម្មាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

[ ៨៥ ] ( ចចក... ) ខ្ញុំជាសត្វត្រេកអរក្នុងសាកសព ញ៉ាមក្នុងសាច់ដំរីទាំងឡាយ បានចូលទៅក្នុងពោះនៃដំរីធំ ខ្យល់ដ៏ក្តៅផង រស្មីព្រះអាទិត្យ ដ៏ក្លៀវក្លាផង របស់ទាំងនោះ ញុំាងទ្វារអាហារចាស់នៃដំរីនោះ ឲ្យស្ងួតក្រៀម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំស្គមល្មើង ( ក្នុងពោះនៃដំរីនោះ ) ខ្ញុំរកផ្លូវចេញមកវិញមិនរួច ស្រាប់តែភ្លៀងធំបង្អុរចុះភ្លាម ( ក្នុងពេលនោះ ) ភ្លៀងនោះ ធ្វើទ្វារអាហារចាស់នៃដំរីនោះ ឲ្យទទឹកសើម ។ បពិត្រលោក ម្ចាស់ដ៏ចម្រើន លំដាប់នោះ ទើបខ្ញុំចេញមកដូចជាព្រះចន្ទ្រដែលរួចអំពីមាត់នៃរាហុ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យលោភៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ។

[ ៨៦ ] ( តាបស... ) កាលពីដើម អ្នកធ្លាប់ស៊ីនូវកណ្តៀរទាំងឡាយលើក្បាលដំបូក ម្នាលខ្លាឃ្មុំ អ្នកខំអត់ទ្រាំនូវគម្មាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

[ ៨៧ ] ( ខ្លាឃ្មុំ... ) ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុកនៃមល្លជន ព្រោះតែសេចក្តីប្រាថ្នាលើសលុប គ្រានោះ ពួកជនចេញមកពីស្រុក ហើយក៏វាយខ្ញុំដោយធ្នូ ។ ខ្ញុំនោះបែកក្បាលប្រឡាក់ឈាមអស់

ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ព្រោះហេតុនោះ បានជាខ្ញុំរក្សាឧបោសថ កុំឲ្យសេចក្ដីប្រាថ្នាលើសលុប គ្របសង្កត់បានទៀតឡើយ ។

[ ៨៨ ] ( សត្វទាំង ៤ ... ) បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានសាកសួរនូវសេចក្ដីណាចំពោះយើងទាំងឡាយ យើងទាំងអស់គ្នាក៏បានឆ្លើយនូវសេចក្ដីនោះតាមទំនងដែលខ្លួនបានដឹងរួចហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើងសូមសួរលោកម្ចាស់វិញ បពិត្រព្រហ្ម លោកម្ចាស់បានរក្សាឧបោសថ តើព្រោះហេតុអ្វី ។

[ ៨៩ ] ( តាបស... ) ព្រះបច្ចេកពុទ្ធមិនប្រឡាក់ ( ដោយកិលេស ) គង់ក្នុងអាស្រមរបស់យើង មួយរំពេច ព្រះអង្គបានញ៉ាំងយើងឲ្យដឹងនូវទីដែលត្រូវទៅ និងទីដែលត្រូវមកផង នូវនាមផង នូវគោត្តផង នូវសេចក្ដីប្រព្រឹត្តទាំងអស់ផង ។ បើទុកជាយ៉ាងនេះ ក៏យើងនៅតែមិនថ្វាយបង្គំព្រះបាទានៃព្រះបច្ចេកពុទ្ធនោះ ម្យ៉ាងទៀត យើងមិនបានសាកសួរ ព្រោះលុះក្នុងអំណាចមានះ ហេតុនោះ បានជាយើងរក្សាឧបោសថ កុំឲ្យមានះគ្របសង្កត់យើងបានទៀតឡើយ ។

## ចប់ បញ្ចុបោសថិកជាតកទី ៧ ។

# អដ្ឋកថា

# បញ្ចុបោសថិកជាតក

[ ៨០-៨៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសក ៥០០ ដែលរក្សាឧបោសថ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អប្បោស្សុក្កោទានិ តុវំ កបោត** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា កាលណោះព្រះដ៏មានព្រះភាគ គង់លើពុទ្ធាសនៈដែលប្រដាប់តាក់តែងហើយ ក្នុងកណ្តាលបរិស័ទ ៤ ក្នុងធម្មសភា ទតបរិស័ទដោយព្រះហឫទ័យដ៏ស្រទន់ ទ្រង់ជ្រាបថា ថ្ងៃនេះទេសនានឹងកើតឡើង ព្រោះអាស្រ័យពាក្យឧបាសកពិត ទើបហៅពួកឧបាសកមក ត្រាស់សួរថា នែឧបាសកទាំងឡាយ ពួកអ្នកនាំគ្នាបំពេញវត្តនៃអ្នករក្សាឧបោសថឬ កាលឧបាសកទាំងនោះក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ពួកអ្នកធ្វើល្អហើយ ឧបោសថនេះ ជាវង្សនៃពួកបណ្ឌិតអំពីកាលមុន មែនពិតបណ្ឌិតក្នុងកាលមុននាំគ្នារក្សាឧបោសថដើម្បីសង្កត់កិលេស មានរាគៈជាដើម ឧបាសកទាំងនោះនាំគ្នាក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល មានបទេស គឺព្រៃគួរជាទីរីករាយ នៅក្នុងរវាងព្រំដែននៃនគរទាំង ៣ មាននគរមគធៈជាដើម ។ ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងដែនមគធៈ ចម្រើនវ័យហើយលះកាមទាំងឡាយ ដោះខ្លួនចូលទៅកាន់ព្រៃនោះ សាងអាស្រមបទបួសជាឥសីអាស្រ័យនៅ ។

ក្នុងទីមិនឆ្ងាយអំពីអាស្រមរបស់លោក ព្រាបឈ្មោលនិងព្រាបញី អាស្រ័យនៅត្រង់គុម្ពឫស្សីមួយកន្លែង ពស់អាស្រ័យនៅក្នុងជំបូកមួយកន្លែង ចចកអាស្រ័យនៅត្រង់គុម្ពឈើក្នុងព្រៃមួយកន្លែង ខ្លាឃ្មុំអាស្រ័យនៅត្រង់គុម្ពឈើក្នុងព្រៃមួយកន្លែង ( ដូចគ្នា ) ។ សត្វទាំង ៤ នោះ តែងនាំគ្នាទៅរកមហាឥសី ស្តាប់ធម៌តាមកាលដែលជាឱកាស ។

ថ្ងៃមួយ ព្រាបឈ្មោលនិងព្រាបញីចេញអំពីសម្បុកទៅរកស៊ី ខ្លែងមួយឆាបយកព្រាបញី ដែលហើរទៅតាមក្រោយព្រាបឈ្មោលហើយគេចទៅ ។ ព្រាបឈ្មោលបានឮសំឡេងស្រែករបស់ព្រាបញីនោះ បែរមើលឃើញព្រាបញីនោះត្រូវខ្លែងនោះឆាបទៅ ។ ចំណែកខ្លែងក៏សម្លាប់ព្រាបញីនោះ ទាំងកំពុងស្រែកនោះឯងឲ្យស្លាប់ហើយចឹកស៊ី ។ ព្រាបទោមនស្សក្នុងចិត្ត ព្រោះព្រាត់ចាកព្រាបញីនោះ ត្រិះរិះថា សេចក្តីស្រឡាញ់នេះធ្វើអញឲ្យលំបាកក្រៃលែង ពេលនេះបើអញមិនសង្កត់សង្កិនសេចក្តីស្រឡាញ់បានទេ អញមិនចេញទៅរកស៊ីឡើយ ។ ព្រាបឈ្មោលកាត់នូវផ្លូវគោចរ ហើយទៅកាន់សម្នាក់របស់តាបស សមាទានឧបោសថដើម្បីសង្កត់សង្កិននូវរាគៈហើយដេកក្នុងចំណែកម្ខាង ។

ចំណែកពស់គិតថា អញនឹងស្វែងរកចំណី ចេញអំពីលំនៅ ស្វែងរកចំណីក្នុងទីដែលជាទីត្រាច់ទៅនៃមេគោក្នុងស្រុកជាយដែន ។ កាលនោះ គោឈ្មោលដែលជាមង្គល មានពណ៌សសុទ្ធរបស់មេស្រុក ស៊ីស្មៅហើយក៏ដេកត្រង់ជំបូកមួយកន្លែង យកស្នែងវែជដីលេង ។ ពស់ខ្លាចសំឡេងសន្ធឹក

ជើងរបស់មេគោទាំងឡាយ លូនទៅដើម្បីចូលជំបូកនោះ ពេលនោះ គោឈ្មោលក៏ជាន់ដោយជើង ពស់ខឹងនឹងគោនោះក៏ចឹកគោនោះអស់ជីវិត ក្នុងទីនោះឯង ។ ពួកអ្នកស្រុកបានឮដំណឹងថា គោនោះស្លាប់ហើយ ក៏នាំគ្នាមកប្រជុំស្រែកយំ បូជាគោនោះដោយគ្រឿងក្រអូបនិងផ្កាជាដើម នាំគ្នាជីករណ្តៅកប់ហើយចៀសចេញទៅ ក្នុងពេលដែលជនទាំងនោះនាំគ្នាត្រឡប់ ពស់ក៏លូនចេញមកគិតថា អញអាស្រ័យសេចក្តីក្រោធ សម្លាប់នូវគោឈ្មោលនេះ ធ្វើឲ្យមហាជននាំគ្នាសោកស្តាយ ពេលនេះ បើអញសង្កត់នូវសេចក្តីក្រោធនេះមិនបាន អញនឹងមិនទៅរកស៊ី ហើយត្រឡប់ទៅកាន់អាស្រមនោះ ដេកសមាទានឧបោសថ ដើម្បីសង្កត់សេចក្តីក្រោធ ។

ចំណែកចចក កាលស្វែងរកអាហារ ឃើញដំរីងាប់មួយត្រេកអរថាអញបានចំណីធំ ហើយរត់ទៅខាំត្រង់ប្រមោយ ហាក់ដូចជាខាំសសរ មិនបាននូវសេចក្តីត្រេកអរត្រង់ប្រមោយនោះ លុះមកខាំភ្លុក ហាក់ដូចជាខាំដុំថ្ម មកកកេរត្រង់ពោះ ដូចជាខាំចង្អេរ មកខាំកន្ទុយ ដូចជាខាំអង្រែ លុះមកខាំត្រង់ទ្វារធំ ដូចជាខាំនំផ្អែម ។ ចចកក៏ស៊ីដោយអំណាចសេចក្តីលោភ ក៏លុងចូលទៅខាងក្នុងពោះ លុះពេលឃ្លានក៏ស៊ីសាច់ខាងក្នុងពោះនោះ លុះពេលស្រេក ក៏ផឹកនូវឈាម ពេលដេកក៏ដេកលើពោះវៀននិងសួត ។ ចចកគិតថា បាយក្តីទឹកក្តី មានស្រាប់ក្នុងទីនេះឯង អញនឹងធ្វើអ្វីក្នុងទីដទៃ ត្រេកអរក្រៃលែងក្នុងពោះដំរីនោះឯង មិនចេញមកខាងក្រៅឡើយ នៅក្នុងពោះដំរីប៉ុណ្ណោះ ។ ចំណេរកាលតមក សាកសពដំរីក៏ស្ងួតដោយខ្យល់និងកម្តៅថ្ងៃ ប្រហោងទ្វារ

ធំក៏បិទ ។ ចចកដេកខាងក្នុងពោះ ក៏ប្រែជាមានសាច់និងឈាមតិច រាងកាយស្គាំងស្គម មិនឃើញផ្លូវចេញបាន ។ ថ្ងៃមួយមេឃពុំជួកាល បណ្ដាលឲ្យភ្លៀងធ្លាក់ ប្រហោងទ្វារធំក៏សើមហើយទន់ ប្រាកដប្រហោងឲ្យឃើញ ។ ចចកឃើញប្រហោងគិតថា អញលំបាកពេក ត្រូវគេចចេញ តាមប្រហោងនេះឲ្យបាន ហើយយកក្បាលរុញចេញមកត្រង់ទ្វារធំ ។ ចចកមានសរីរៈស្គមចេញអំពីទីចង្អៀតដោយរហ័ស រោមក៏ជាប់ត្រង់ទ្វារធំនោះទាំងអស់ ចចកមានខ្លួនរលីងដូចកំពីងត្នោត ចេញមកបានគិតថា ព្រោះអាស្រ័យសេចក្ដីលោភ អញត្រូវសោយនូវទុក្ខនេះ បើអញសង្កត់នូវសេចក្ដីលោភមិនបាន អញមិនទៅរកស៊ីឡើយ ទៅកាន់អាស្រមនោះ សមាទានឧបោសថ ដើម្បីសង្កត់នូវសេចក្ដីលោភ ហើយដេកក្នុងចំណែកម្ខាង ។

ខ្លាឃ្មុំចេញអំពីព្រៃហើយ ត្រូវចំណង់ក្រៃលែងគ្របសង្កត់ ទើបចូលទៅកាន់ស្រុកជាយដែន ក្នុងដែនមល្លៈ ។ ពួកអ្នកស្រុកបានឮថាខ្លាឃ្មុំមកហើយក៏កាន់ធ្នូនិងដំបង នាំគ្នាចេញទៅព័ទ្ធព្រៃល្បោះនោះ ខ្លាឃ្មុំដឹងថាមហាជនព័ទ្ធទុក ទើបគេចចេញ កាលខ្លាឃ្មុំកំពុងគេចនោះឯង មហាជននាំគ្នាបាញ់ដោយធ្នូ វាយដោយដំបង ។ ខ្លាឃ្មុំបែកក្បាលហូរឈាមទៅកាន់លំនៅរបស់ខ្លួន បានគិតថា ទុក្ខនេះកើតព្រោះអំណាចសេចក្ដីលោភ គឺចំណង់ក្រៃលែងរបស់អញបើអញសង្កត់ចំណង់នេះមិនបាន អញនឹងមិនទៅរកស៊ីឡើយ ទៅកាន់អាស្រមនោះ សមាទានឧបោសថដើម្បីសង្កត់នូវចំណង់ដ៏ក្រៃលែង ហើយដេកក្នុងចំណែកសមគួរម្ខាង ។ ចំណែកតាបសអាស្រ័យជាតិរបស់ខ្លួន ធ្លាក់ក្នុងអំ-

ណាចមានះមិនអាចញ៉ាំងឈានឲ្យកើតបាន ។ កាលណោះ ព្រះបច្ចេកពុទ្ធមួយអង្គ ជ្រាបភាពដែលតាបសនោះមានមានះត្រិះរិះថា សត្វនេះមិនមែនអ្នកដទៃឡើយ គឺជាពន្លកសពេជ្ជនៃព្រះពុទ្ធ នឹងត្រាស់ដឹងជាសព្វញ្ញូក្នុងកប្បនេះឯង អញត្រូវធ្វើការសង្កត់សង្កិននូវមានះរបស់សត្វនេះ ហើយនឹងធ្វើនូវសមាបត្តិ ឲ្យកើតឡើងបាន ទើបហោះមកអំពីព្រៃហិមពាន្ត គឺមកអំពីទិសខាងជើង ខណៈដែលតាបសនោះកំពុងដេកក្នុងបណ្ណសាលានោះឯង ក៏អង្គុយលើបន្ទះក្តារដែលធ្វើអំពីថ្មរបស់តាបសនោះ ។ តាបសចេញមកឃើញព្រះបច្ចេកពុទ្ធនោះអង្គុយលើអាសនៈរបស់ខ្លួន អាក់អន់ព្រោះភាពជាអ្នកមានមានះស៊ុះចូលទៅរកលោកហើយទះដៃសម្តុតថា អន្តរធានចុះអ្នកថោកទាប អ្នកកាឡកណ្ណី សមណៈត្រងោល ឯងមកអង្គុយលើក្តាររបស់យើងធ្វើអ្វី ។ កាលនោះ ព្រះបច្ចេកពុទ្ធពោលថា សប្បុរស ហេតុអ្វីទើបអ្នកមាននូវមានះ អាត្មាសម្រេចនូវបច្ចេកពោធិញាណហើយក្នុងកប្បនេះឯង ឯអ្នកនឹងបានត្រាស់ជាសព្វញ្ញុពុទ្ធ អ្នកជាសពេជ្ជ អ្នកបំពេញបារមីមកហើយ អស់កាលមានប្រមាណប៉ុណ្ណេះ ក្នុងអនាគតកាល អ្នកនឹងបានត្រាស់ជាព្រះពុទ្ធមានឈ្មោះថាសិទ្ធត្ថៈ ។ ព្រះបច្ចេកពុទ្ធប្រាប់នាមត្រកូល គោត្ត និងអគ្គសាវកជាដើមហើយឲ្យឱវាទថា អ្នកនៅតែស្រើងដោយមានះ ជាបុគ្គលគ្រោតគ្រាត ដើម្បីអ្វី នេះមិនសមគួរដល់អ្នកឡើយ ។ តាបសនោះ កាលព្រះបច្ចេកពុទ្ធពោលយ៉ាងនេះហើយ ក៏នៅតែមិនថ្វាយបង្គំនោះឯង មិនសាកសួរថា ខ្ញុំនឹងបានជាព្រះពុទ្ធក្នុងកាលណា ។ កាលព្រះបច្ចេកពុទ្ធពោលថា អ្នកមិនដឹងនូវភាពជា

ធំនៃជាតិ និងភាពជាធំនៃគុណរបស់អាត្មា បើអ្នកអាច ក៏ចូរទៅក្នុងអាកាស ដូចអាត្មា ហើយហោះទៅក្នុងអាកាស ជម្រុះនូវធូលីដែលជាប់ត្រង់ជើង លើមណ្ឌលជដារបស់តាបសនោះ ទៅកាន់ព្រៃហិមពាន្តវិញ ។ លុះលោកនិមន្តទៅហើយ តាបសសង្វេគគិតថា បុរសនេះជាសមណៈដូចគ្នា មានសរីរៈធ្ងន់ទៅក្នុងអាកាសបាន ដូចប៉ុយគអណ្តែតទៅក្នុងអាកាស ព្រោះប្រកាន់ជាតិអញមិនបានក្រាបថ្វាយបង្គំបាទជើង ទាំងគូរបស់ព្រះបច្ចេកពុទ្ធ ដែលមានសភាពបែបនេះ មិនសាកសួរដោយពាក្យថា ខ្ញុំបានត្រាស់ជាព្រះពុទ្ធក្នុងកាលណា ឈ្មោះថាជាតិនឹងធ្វើអ្វីបាន សីលនិងចរណៈប៉ុណ្ណោះជាធំក្នុងលោកនេះ តែបើមានះរបស់អញចម្រើន នឹងនាំទៅកាន់នរកបាន បើអញសង្កត់នូវមានះនេះមិនបាន អញនឹងមិនទៅរកផ្លែឈើឡើយ ចូលទៅកាន់បណ្ណសាលាសមាទានឧបោសថដើម្បីសង្កត់នូវមានះ អង្គុយលើក្តារសម្រាប់អង្គុយ ជាកុលបុត្តមានញាណធំ សង្កត់មានះបាន ចម្រើនកសិណញុំាងអភិញ្ញានិងសមាបត្តិ ៨ ឲ្យកើតបានហើយ ទើបចេញទៅអង្គុយលើផ្ទាំងថ្មខាងចុងទីចង្ក្រម ។ ក្នុងកាលណោះ សត្វមានព្រាបជាដើម នាំគ្នាចូលមករកលោក ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ព្រះមហាសត្វសួរព្រាបថា ក្នុងថ្ងៃដទៃៗអ្នកមិនបានមក ពេលនេះអ្នកគង់មិនបានអាហារ ថ្ងៃនេះអ្នករក្សាឧបោសថដែរឬទេ ព្រាបពោលថា ខ្ញុំរក្សា កាលនោះ ព្រះមហាសត្វសួរថា ព្រោះហេតុអ្វី ក៏ពោលបឋមគាថាថា

ម្នាលព្រាប ឥឡូវនេះ អ្នកមានសេចក្តីខ្វល់ខ្វាយតិច ម្នាល

បក្សី អ្នកមិនមានសេចក្តីត្រូវការដោយចំណីសោះ ម្នាលព្រាប អ្នកខំអត់ទ្រាំនូវតម្ងាន និងសម្រេក ជាសត្វរក្សានូវឧបោសថ តើព្រោះហេតុអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អប្បោស្សុក្កោ** បានដល់ ដែលប្រាសចាកសេចក្តីអាល័យ ។ បទថា **ឆ តវ** សេចក្តីថា ថ្ងៃនេះអ្នកមិនមានសេចក្តីត្រូវការដោយភោជន ។

ព្រាបបានស្តាប់ដូច្នោះហើយ បានពោលគាថា ២ ថា

ក្នុងកាលមុន ខ្ញុំមានចិត្តជាប់នឹងមេព្រាប យើងខ្ញុំទាំងពីរនាក់កំពុងតែរីករាយ ( ក្នុងកាម ) ក្នុងប្រទេសនោះ ស្រាប់តែសត្វខ្លែងមកឆាបយកមេព្រាបទៅ ខ្ញុំក៏អស់សេចក្តីប្រាថ្នា ព្រោះប្រាសចាកមេព្រាបនោះ ។ ខ្ញុំរងនូវវេទនាធំក្នុងចិត្ត ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ហេតុនោះបានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យរាគៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រមាម** សេចក្តីថា ពួកយើងរមែងត្រេកអរដោយសេចក្តីត្រេកអរក្នុងកាម ក្នុងភូមិភាគនេះ ។ បទថា **សាកុណគោ** បានដល់សត្វខ្លែង ។

កាលព្រាបរៀបរាប់ឧបោសថកម្មរបស់ខ្លួនហើយ ព្រះមហាសត្វ ក៏សួរពស់ជាដើមម្តងមួយៗ ។ សត្វទាំងនោះនាំគ្នារៀបរាប់សេចក្តីពិត កាលនឹងសួរពស់ទើបពោលថា

ម្នាលពស់ ជាឧរគជាតិ លូនទៅមិនត្រង់ មានអណ្តាតពីរ អ្នកមានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក ម្នាលសត្វមានខ្លួនវែង អ្នកអត់ទ្រាំនូវតម្មាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

ពស់ពោលថា

គោឈ្មោលឡើងករបស់អ្នកស្រុក ជាគោមានកម្លាំង មានបូកដ៏យុរយារ បរិបូណ៌ដោយសម្បុរនិងកម្លាំង គោនោះដើរជាន់ខ្ញុំ ខ្ញុំខឹងបានចឹកវាៗត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏ស្លាប់ទៅ ។ លំដាប់នោះ ពួកជនចេញអំពីស្រុកកន្ទក់កន្ទេញយំទួញ ហើយដើរចៀសចេញទៅ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្តីក្រោធគ្របសង្កត់ ខ្ញុំបានទៀតឡើយ ។

ព្រះមហាសត្វកាលសួរចចកទើបពោលថា

ក្នុងព្រៃស្មសាន មានសាច់របស់សត្វស្លាប់ដ៏ច្រើន សាច់ទាំងនោះ ជាភោជនជាទីគាប់ចិត្តរបស់អ្នក ម្នាលចចក អ្នកខំអត់ទ្រាំនូវតម្មាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

ចចកពោលថា

ខ្ញុំជាសត្វត្រេកអរក្នុងសាកសព ញ៉ាំមក្នុងសាច់ដំរីទាំងឡាយ

បានចូលទៅក្នុងពោះនៃដំរីធំ ខ្យល់ដ៏ក្តៅផង រស្មីព្រះអាទិត្យដ៏ក្តៅក្លាផង របស់ទាំងនោះញុំាងទ្វារអាហារចាស់នៃដំរីនោះឲ្យស្ងួតក្រៀម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំស្គមលឿង ( ក្នុងពោះនៃដំរីនោះ ) ខ្ញុំរកផ្លូវចេញមកវិញមិនរួច ស្រាប់តែភ្លៀងធំបង្អុរចុះភ្លាម ( ក្នុងពេលនោះ ) ភ្លៀងនោះ ធ្វើទ្វារអាហារចាស់នៃដំរីនោះឲ្យទទឹកសើម ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ទើបខ្ញុំចេញមកដូចជាព្រះចន្ទ្រដែលរួចអំពីមាត់នៃរាហុ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យលោភៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ។

ព្រះមហាសត្វកាលសួរខ្លាឃ្មុំ ទើបពោលថា

កាលពីដើម អ្នកធ្លាប់ស៊ីនូវកណ្តៀរទាំងឡាយលើក្បាលដំបូក ម្នាលខ្លាឃ្មុំ អ្នកខំអត់ទ្រាំនូវគម្ពាននិងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

ខ្លាឃ្មុំពោលថា

ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុកនៃមល្លជន ព្រោះតែសេចក្តីប្រាថ្នាលើសលុប គ្រានោះ ពួកជនចេញមកពីស្រុក ហើយក៏វាយខ្ញុំដោយធ្នូ ។ ខ្ញុំនោះបែកក្បាលប្រឡាក់ឈាមអស់ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅ របស់ខ្លួនវិញ ព្រោះហេតុនោះ បានជាខ្ញុំរក្សាឧបោសថ កុំឲ្យសេច

ក្តីប្រាថ្នាលើសលុប គ្របសង្កត់បានទៀតឡើយ ដូច្នេះ ។

ក្នុងគាថានោះ ព្រះមហាសត្វហៅពស់នោះដោយពាក្យថា **អនុជ្ជុគាមិ** អ្នកលូនមិនត្រង់ ជាដើម ។ បទថា **ចលក្កកុ** សេចក្តីថា គោនោះ មានបូកខ្ពស់ ។ បទថា **ឧក្ខាភិតុន្នោ** សេចក្តីថា គោនោះត្រូវទុក្ខបៀតបៀនក្រៃលែងជាសត្វក្រហល់ក្រហាយ ។ បទថា **ពហូ** កែជា **ពហូនិ** ប្រែថា ជាច្រើន ។ បទថា **បាវិសិ** បានដល់ ចូលទៅហើយ ។ បទថា **រស្មិយោ** បានដល់ ពន្លឺនៃព្រះអាទិត្យ ។ បទថា **និក្ខមិសំ** បានដល់ ចេញទៅហើយ ។ បទថា **កិបិល្លិកានិ** បានដល់ កណ្តៀរទាំងឡាយ ។ បទថា **និប្បោថយន្តោ** បានដល់ ទំពាស៊ី ។ បទថា **អតិហោឡ្យយានោ** បានដល់ មើលងាយ និន្ទា តិះដៀល ។ បទថា **កោឧណ្ណកោឧ** បានដល់ ដោយជង្គង់និងជំបង ។

កាលសត្វទាំង ៤ នោះ ពណ៌នាឧបោសថកម្មរបស់ខ្លួនយ៉ាងនេះហើយ ក៏បបួលគ្នាក្រោកឡើងថ្វាយបង្គំព្រះមហាសត្វ កាលនឹងសួរថា បពិត្រលោកម្ចាស់ ថ្ងៃដទៃៗក្នុងពេលនេះ លោកម្ចាស់ធ្លាប់ទៅរកផលាផល ថ្ងៃនេះហេតុអ្វីទើបលោកម្ចាស់មិនទៅ ហើយធ្វើឧបោសថកម្ម ទើបពោលគាថានេះថា

បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បានសាកសួរនូវសេចក្តីណា ចំពោះយើងទាំងឡាយ យើងទាំងអស់គ្នាក៏បានឆ្លើយនូវសេចក្តីនោះ តាមទំនងដែលខ្លួនបានដឹងរួចហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើង សូមសួរលោកម្ចាស់វិញ បពិត្រព្រហ្ម លោកម្ចាស់បានរក្សាឧបោសថ តើព្រោះហេតុអ្វី

*ដូច្នេះ ។*

*ចំណែកព្រះពោធិសត្វក៏ថ្លែងដល់ជនទាំងនោះថា*

*ព្រះបច្ចេកពុទ្ធមិនប្រឡាក់ ( ដោយកិលេស ) គង់ក្នុងអាស្រម របស់យើងមួយរំពេច ព្រះអង្គបានញុំាងយើងឲ្យដឹងនូវទីដែល ត្រូវទៅ និងទីដែលត្រូវមកផង នូវនាមផង នូវគោត្តផង នូវ សេចក្តីប្រព្រឹត្តិទាំងអស់ផង ។ បើទុកជាយ៉ាងនេះ ក៏យើងនៅ តែមិនថ្វាយបង្គំព្រះបាទា នៃព្រះបច្ចេកពុទ្ធនោះ ម្យ៉ាងទៀត យើងមិនបានសាកសួរ ព្រោះលុះក្នុងអំណាចមានះ ហេតុនោះ បានជាយើងរក្សាឧបោសថ កុំឲ្យមានះ គ្របសង្កត់យើងបាន ទៀតឡើយ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **យំ ឆោ** *សេចក្តីថា លោកបានសួរដល់ សេចក្តី ណានឹងពួកខ្ញុំ ។ បទថា* **យថាបជានំ** *សេចក្តីថា ពួកខ្ញុំបានថ្លែង រឿងនោះ តាមដែលខ្លួនបានដឹងមក ។ បទថា* **អន្វុបលិត្តោ** *សេចក្តីថាដែល កិលេសគ្រប់យ៉ាងមិនចូលទៅប្រឡាក់បានឡើយ ។ បទថា* **សោ មំ អវេទិ** *សេចក្តីថា លោកបានប្រាប់ឲ្យជ្រាប ឲ្យខ្ញុំដឹង សម្តែងដល់ខ្ញុំគ្រប់យ៉ាងដល់ ឋានៈដែលខ្ញុំគួរប្រព្រឹត្ត ឋានៈដែលខ្ញុំប្រព្រឹត្តទៅហើយក្នុងឥឡូវនេះ និងនាម គោត្ត ចរណៈ របស់ខ្ញុំក្នុងអនាគតដូច្នេះថា ខ្ញុំនឹងបានជាព្រះពុទ្ធមាននាមយ៉ាង នេះ នឹងមានគោត្តយ៉ាងនេះ នឹងមានសីលនិងចរណៈយ៉ាងនេះ ។ បទថា* **ឯវម្បិហំ ន វន្ទិំ** *សេចក្តីថា កាលលោកសម្តែងដល់យ៉ាងនេះខ្ញុំមិនបានក្រាប*

ថ្វាយបង្គំ យុគលបាទរបស់លោក ព្រោះអាស្រ័យមានះរបស់ខ្លួន ។

ព្រះមហាសត្វ ថ្លែងនូវការធ្វើឧបោសថរបស់ខ្លួនយ៉ាងនេះហើយ ដាស់តឿនសត្វទាំងនោះបញ្ជូនទៅ ហើយត្រឡប់ចូលបណ្ណសាលា ។ សត្វទាំងនោះនាំគ្នាទៅលំនៅរបស់ខ្លួន ។ ព្រះមហាសត្វមានឈានមិនវិនាស មានព្រហ្មលោកជាទីទៅខាងមុខ សត្វទាំងនោះតាំងនៅក្នុងឱវាទរបស់លោក បានទៅកាន់ឋានសួគ៌រៀងៗខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយទ្រង់បញ្ជាក់ថា ម្នាលឧបាសកទាំងឡាយ ឧបោសថនេះជាបវេណីនៃពួកបណ្ឌិតអំពីបុរាណដោយប្រការដូច្នេះ ឧបោសថជាកម្មគួរបំពេញ ហើយទ្រង់ប្រជុំជាតកថា ព្រាបក្នុងកាលនោះ បានមកជាអនុរុទ្ធក្នុងកាលឥឡូវនេះ ខ្លាឃ្មុំក្នុងកាលនោះ បានមកជាកស្សបៈ ចចកក្នុងកាលនោះ បានមកជាមហាមោគ្គល្លាន ពស់ក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បញ្ចុបោសថិកជាតក ចប់

# មហាមោរជាតក

[ ៩០ ] ( ស្តេចក្ងោកពោធិសត្វពោលថា ) ម្នាលសម្លាញ់ ប្រសិនបើអ្នកចាប់ខ្ញុំព្រោះហេតុនៃទ្រព្យ អ្នកកុំសម្លាប់ខ្ញុំឡើយ សូមចាប់ខ្ញុំទាំងរស់ ហើយនាំខ្ញុំទៅកាន់សំណាក់ព្រះរាជាចុះ អ្នកទំនងជានឹងបានទ្រព្យដ៏ច្រើន ។

[ ៩១ ] ( កូនព្រានព្រៃពោលថា ) ធ្នូដ៏ប្រសើរនិងព្រួញនេះ ខ្ញុំមិនមែនយឹតប្រុងប្រៀបដើម្បីនឹងបាញ់អ្នកក្នុងថ្ងៃនេះទេ ខ្ញុំនឹងបាញ់ផ្តាច់អន្ទាក់របស់អ្នកទេតើ ( ដោយគិតថា ) ស្តេចក្ងោកចូរទៅតាមសប្បាយចុះ ។

[ ៩២ ] ( ស្តេចក្ងោក... ) អ្នកខំអត់ទ្រាំនូវសេចក្តីស្រេកឃ្លានទាំងយប់ទាំងថ្ងៃ ដើរជាប់តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាងនេះ ព្រោះហេតុអ្វី ក៏អ្នកចង់ដោះខ្ញុំដែលកំពុងជាប់អន្ទាក់ឲ្យរួចអំពីអន្ទាក់វិញ ។ អ្នកទើបនឹងវៀរចាកបាណាតិបាតក្នុងថ្ងៃនេះឬ ឬក៏អ្នកឲ្យអភ័យដល់សត្វទាំងពួង បានជាអ្នកចង់ដោះខ្ញុំដែលកំពុងជាប់អន្ទាក់ ឲ្យរួចចាកអន្ទាក់វិញ ។

[ ៩៣ ] ( កូនព្រានព្រៃ... ) ម្នាលស្តេចក្ងោក អ្នកចូរប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួងផង ខ្ញុំសូមសួរអ្នក ត្រង់សេចក្តីនុ៎ះ បុគ្គលនោះច្យុតអំពីលោកនេះទៅ នឹងបាននូវសេចក្តីសុខដូចម្តេចខ្លះ ។

[ ៩៤ ] ( ស្តេចក្ងោក... ) ខ្ញុំនឹងប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួង បុគ្គលនោះរមែងបាននូវសេចក្តីសរសើរក្នុងបច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹងបានទៅកើតនៅឋានសួគ៌ផង ។

[ ៩៥ ] ( កូនព្រាន... ) សមណព្រាហ្មណ៍ពួកខ្លះបានពោលថា ទេវតាទាំងឡាយមិនមានទេ ជីវៈក្នុងលោកនេះរមែងដល់នូវសេចក្តីដាច់សូន្យ ផលនៃអំពើដែលសត្វធ្វើល្អធ្វើអាក្រក់ រមែងដល់នូវសេចក្តីដាច់សូន្យដូចគ្នា ទាំងពោលថា ទានជាគុណជាត គឺមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះ បានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ ។

[ ៩៦ ] ( ស្តេចក្ងោក... ) ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញឆ្ងាយ ភ្លឺរុងរឿង ទៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ ( ជារបស់ ) លោកនេះឬលោកដទៃ ( ពួកជន ) ក្នុងមនុស្សលោក ហៅព្រះចន្ទនិងព្រះអាទិត្យទាំងនោះថាជាអ្វី ។

[ ៩៧ ] ( កូនព្រាន... ) ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញឆ្ងាយ ភ្លឺរុងរឿង ទៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ ( ជារបស់ ) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជនក្នុងមនុស្សលោកហៅព្រះចន្ទនិងព្រះអាទិត្យទាំងនោះថាជាទេវតា ។

[ ៩៨ ] ( ស្តេចក្ងោក... ) សមណព្រាហ្មណ៍ណាមិនពោលអាងកម្មមិនពោលអាងផលនៃកម្ម ដែលសត្វធ្វើល្អធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណាពោលថា ទានជាគុណជាត ដែលមនុស្សល្ងង់បញ្ញត្តហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកហីនវាទ ជាអ្នកអហេតុកវាទ ត្រូវគេដេញជើងទាល់ក្នុងព្យាករណ៍នេះមិនខាន ។

[ ៩៩ ] ( កូនព្រានព្រៃ... ) ពាក្យរបស់អ្នកនុ៎ះទៀងពិត ព្រោះទាន ជាគុណជាតឥតផលដូចម្ដេចកើត ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ក៏ ដូចគ្នា ម្យ៉ាងទៀត ( ទាន ) ជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ ដូច ម្ដេចកើត ។ ខ្ញុំធ្វើអំពើដូចម្ដេច ធ្វើដោយហេតុដូចម្ដេច ប្រព្រឹត្តដូចម្ដេច សេព នូវអ្វី ដោយគុណនៃតបៈដូចម្ដេច មិនគប្បីធ្លាក់ទៅក្នុងនរកយ៉ាងណា ម្នាល ស្ដេចក្ងោក អ្នកសូមប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ ដោយឧបាយយ៉ាងនោះ ។

[ ១០០ ] ( ស្ដេចក្ងោក... ) ពួកសមណៈណាមួយនៅលើផែនដី ជា អ្នកស្លៀកសំពត់កាសាវៈ ប្រព្រឹត្តក្នុងភេទនៃបុគ្គលគ្មានផ្ទះត្រាច់ទៅបិណ្ឌបាត អំពីព្រឹកក្នុងកាលគួរ វៀរចាកកិរិយាត្រាច់ទៅក្នុងកាលខុស ជាអ្នកស្ងប់រម្ងាប់ ។ អ្នកចូរចូលទៅរកសមណៈទាំងនោះ តាមកាលគួរក្នុងទីនោះហើយ ចូរសាកសួរ ចុះ ប្រយោជន៍ណា ដែលជាទីពេញចិត្តរបស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍ នោះ ជាប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកខាងមុខ ( ដល់អ្នក ) តាម ទំនងនៃការចេះដឹង ( របស់លោក ) ។

[ ១០១ ] ( កូនព្រានព្រៃបានត្រាស់ជាព្រះបច្ចេកពុទ្ធហើយក៏សំដែងថា ) ភាពជាព្រានព្រៃនុ៎ះ អាត្មាអញបានលះបង់ហើយ អាត្មាអញបានលះបង់នូវ ភាពនៃខ្លួនជាព្រានព្រៃក្នុងថ្ងៃនេះ ដូចពស់សកនូវសំណកចាស់ជាន់មុន ឬក៏ ដូចដើមឈើមានស្លឹកខៀវ ( ជម្រុះចោល ) នូវស្លឹកលឿង ។

[ ១០២ ] ( បច្ចេកពុទ្ធធ្វើសច្ចកិរិយាថា ) ពួកបក្សីណាច្រើនរយ ដែល អាត្មាអញបានចងទុកក្នុងលំនៅ ( របស់ខ្លួន ) អាត្មាអញ នឹងឲ្យនូវជីវិត

ដល់សត្វទាំងឡាយនោះ ក្នុងថ្ងៃនេះ អាត្មាអញបានរួចចាកកិលេសហើយ សត្វទាំងនោះចូរទៅកាន់លំនៅរបស់ខ្លួនចុះ ។

[ ១០៣ ] ( អភិសម្ពុទ្ធគាថា ) ព្រានព្រៃមានអន្ទាក់ក្នុងដៃ ត្រាច់ទៅក្នុងព្រៃ ដើម្បីទាក់នូវស្ដេចក្ងោកដែលមានយស លុះទាក់នូវស្ដេចក្ងោកដែលមានយសបានហើយ ក៏បានរួចចាកសេចក្ដីទុក្ខ ដូចតថាគតដែលបានរួច ( ចាកទុក្ខដោយសយម្ភូញាណ ) ដូច្នោះដែរ ។

## ចប់មហាមោរជាតកទី ៨ ។

## អដ្ឋកថា

## មហាមោរជាតក

[ ៩០-១០៣ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **សចេ ហិ ត្យាហំ ធនហេតុ គហិតោ** *ដូច្នេះជាដើម ។*

*រឿងមានសេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះទទួលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ តម្រេកដែលជាគ្រឿងត្រេកអរក្នុងចិត្តនេះ រឿងអ្វីដែលមិនឲ្យបុគ្គលបែបអ្នករីករាយបាននោះ ព្រោះថា ខ្យល់ដែលកួចបំបើងភ្នំសិនេរុបាន រឿងអ្វីដែលមិនឲ្យស្លឹកឈើចាស់ៗ ដែលនៅជុំវិញបរិវេណ ខ្ចាត់ខ្ចាយទៅបាន ក្នុងកាលមុននោះឯង សត្វដែលបរិសុទ្ធ ធ្លាប់ហាមឃាត់នូវសេចក្តីរាយមាយរបស់កិលេសអស់ ៧ រយឆ្នាំ ក៏គង់រាគៈនេះធ្វើឲ្យរីករាយបាន ចាំបាច់និយាយថ្វីដល់អ្នកនោះ ហើយទ្រង់នាំអតីតនិទានមក សាធកៈដូចតទៅនេះថា*

*ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងផ្ទៃមេក្ងោក ក្នុងប្រទេសជាយដែន ។ កាលគភ៌ចាស់ហើយ ក្ងោកជាមាតាក៏ពងក្នុងទីរកស៊ីហើយហើរទៅ ធម្មតាស៊ុត បើមេមិនមានរោគ និងមិនមានអន្តរាយដទៃៗ ដូចជាទឹយជាតិបៀតបៀន រមែងមិនខូចឡើយ ហេតុនោះស៊ុតនោះទើបដូចជាផ្កាកណិការក្រពុំ មានពណ៌ដូចមាសលុះដល់គ្រប់កំណត់ ក៏ញាស់ដោយធម្មតារបស់ខ្លួន ។ កូនក្ងោកមានពណ៌*

ដូចមាស ចេញមកហើយ ។ កូនក្ងោកនោះមានភ្នែកទាំងគូ ដូចគ្នានឹងផ្លែទំពាំងបាយជូរ មានចំពុះដូចកែវប្រពាល មានផ្នួតក ៣ ជាន់រហូតដល់កណ្ដាលខ្នង កាលក្ងោកមាសចម្រើនវ័យ មានរាងកាយធំប៉ុនដុំរទេះ រូបល្អក្រៃពេក ។ ក្ងោកដែលមានពណ៌ខៀវទាំងអស់មកប្រជុំគ្នា លើកក្ងោកនោះឲ្យជាប្រធាន នាំគ្នាចោមរោមជាបរិវារ ។

ថ្ងៃមួយក្ងោកមាសផឹកទឹកក្នុងត្រពាំងទឹក ឃើញរូបសម្បត្តិរបស់ខ្លួន គិតថា អញមានរូបស្អាតជាងក្ងោកទាំងអស់ បើអញនៅក្នុងដែនដីមនុស្ស ជាមួយក្ងោកទាំងនេះ អន្តរាយនឹងកើតដល់អញ អញត្រូវទៅកាន់ព្រៃហិមពាន្តអាស្រ័យនៅជាសុខតែម្នាក់ឯងល្អជាង ។ កាលហ្វូងក្ងោកនាំគ្នាចូលទ្រនំដេកក្នុងរាត្រីកាល ក្ងោកមាសនោះមិនបានប្រាប់ឲ្យក្ងោកណាមួយដឹងឡើយ ក៏ហើរទៅកាន់ព្រៃហិមពាន្តឆ្លងជួរភ្នំ ៣ ដល់ជួរភ្នំទី ៤ មានជាតិស្រះធំ ដេរដាសដោយផ្កាឈូកក្នុងព្រៃមិនឆ្ងាយអំពីស្រះនោះ មានដើមជ្រៃធំកើតអាស្រ័យភ្នំមួយក៏ចុះសម្រាកកាយត្រង់មែកជ្រៃនោះ ។ ម្យ៉ាងទៀត ត្រង់កណ្ដាលភ្នំនោះមានគុហាដែលគួរជាទីត្រេកអរ ។ ស្ដេចក្ងោក បំណងនៅក្នុងគុហានោះទើបទំត្រង់មុខគុហានោះ ។ ក្នុងទីនោះ បុគ្គលដែលនៅខាងក្រោម មិនអាចឡើងទៅបានឡើយ បុគ្គលដែលនៅខាងលើសោត ក៏មិនអាចចុះបាន ជាទីផុតភ័យអំពីឆ្មា ពស់និងមនុស្ស ។ ស្ដេចក្ងោកមាសត្រិះរិះថា ត្រង់នេះជាទីក្សេមក្សាន្តរបស់អញ អញនឹងសម្រាកនៅក្នុងទីនេះឯងអស់ថ្ងៃនេះ លុះព្រឹកឡើង ក៏ក្រោកចាកគុហា ទំត្រង់ញកភ្នំ បែរមុខទៅទិសខាងកើត ឃើញសុរិយ

មណ្ឌលកំពុងរះឡើង ក៏សូត្រព្រះបរិត្តដើម្បីការពារក្នុងពេលថ្ងៃថា **ឧទេត-យញ្ចក្ខុមា ឯករាជា** ដូច្នេះជាដើម ហើយបន្ទាប់ខ្លួនចុះក្នុងទីរកស៊ី ត្រាច់រកស៊ីពេលល្ងាច ទើបមកទំត្រង់កំពូលភ្នំ បែរមុខទៅកាន់ទិសខាងលិច សម្លឹងមើលសុរិយមណ្ឌលដែលអស្តង្គត សូត្រព្រះបរិត្តដើម្បីការពារក្នុងពេលយប់ថា **អបេតយញ្ចក្ខុមា ឯករាជា** ដូច្នេះជាដើម ហើយសម្រាកដោយឧបាយនេះ ។

ថ្ងៃមួយព្រានព្រៃម្នាក់ ត្រាច់ទៅក្នុងព្រៃ ឃើញស្តេចក្ងោកនោះទំលើកំពូលភ្នំ លុះមកដល់លំនៅរបស់ខ្លួន កាលខ្លួនជិតស្លាប់ក៏និយាយប្រាប់កូនថា នែបា ក្នុងព្រៃត្រង់ជួរភ្នំទី ៤ មានក្ងោកមាស បើព្រះរាជាត្រាស់សួរ សូមក្រាបទូលឲ្យទ្រង់ជ្រាប ។ ថ្ងៃមួយអគ្គមហេសីរបស់ព្រះបាទពារាណសី ព្រះនាមថាខេមា ទ្រង់សុបិននិមិត្តក្នុងពេលទៀបភ្លឺថា ក្ងោកមានពណ៌ដូចមាសកំពុងសម្តែងធម៌ ព្រះនាងឲ្យសាធុការហើយស្តាប់ធម៌ ក្ងោកនោះសម្តែងធម៌ហើយ ក៏ហើរគេចទៅ ។ ព្រះនាងទតឃើញស្តេចក្ងោកកំពុងហើរទៅ ក៏ត្រាស់ឲ្យមនុស្សទាំងឡាយ នាំគ្នាចាប់ស្តេចក្ងោកនោះឲ្យបាន ខណៈដែលកំពុងត្រាស់នោះឯងព្រះនាងក៏តើនឡើង កាលព្រះនាងជ្រាបថាជាយល់សប្តិ ទើបត្រិះរិះថា បើអញក្រាបទូលថាយល់សប្តិ ព្រះរាជាទ្រង់មិនយកព្រះហឫទ័យអើពើ បើអញក្រាបទូលថា ខ្ញុំម្ចាស់ចាញ់គភ៌ ព្រះរាជានឹងយកព្រះហឫទ័យអើពើ ដូច្នេះហើយព្រះនាងក៏ធ្វើដូចជាចាញ់ព្រះគភ៌ ។ កាលនោះព្រះរាជាចូលមកជិតត្រាស់សួរថា នែនាង នាងមិនសប្បាយរឿងអ្វី ព្រះទេវីក្រាបទូលថា ការចាញ់គភ៌

កើតឡើងដល់ខ្ញុំម្ចាស់ ព្រះរាជាត្រាស់សួរថា នាងត្រូវការវត្ថុណា ក៏ក្រាបទូលថា ខ្ញុំម្ចាស់ប្រាថ្នានឹងស្តាប់ធម៌របស់ស្តេចក្ងោកមាស ព្រះរាជាត្រាស់ថា នែនាង អញនឹងរកស្តេចក្ងោកមាសបែបនេះឯណាបាន ព្រះនាងក៏ក្រាបទូលថា បពិត្រព្រះអង្គ បើមិនបាន ជីវិតរបស់ខ្ញុំម្ចាស់ក៏មិនមាន ព្រះរាជាក៏ត្រាស់លួងលោមថា នែនាង នាងកុំទោមនស្សឡើយ បើសត្វនោះមានក្នុងទីណានាងនឹងបានពិត ហើយទ្រង់ប្រថាប់ គង់លើអាសនៈត្រាស់សួរពួកអាមាត្យថា នែបាទាំងឡាយ ព្រះទេវីប្រាថ្នានឹងស្តាប់ធម៌របស់ក្ងោកមាស ក្ងោកដែលមានពណ៌ដូចមាសមានដែរឬទេ ។ ពួកអាមាត្យក្រាបទូលថា បពិត្រព្រះអង្គ ពួកព្រាហ្មណ៍ គង់ជ្រាប ព្រះរាជាត្រាស់ឲ្យហៅពួកព្រាហ្មណ៍មកគាល់ ហើយត្រាស់សួរ ។ ពួកព្រាហ្មណ៍នាំគ្នាក្រាបទូលយ៉ាងនេះថា បពិត្រមហារាជសត្វតិរច្ឆានទាំងនេះ ក្នុងពួកសត្វទឹក គឺត្រី អណ្តើក ក្តាម ក្នុងពួកសត្វគោកមានម្រឹគ ហង្ស ក្ងោក ទទា ដែលមានពណ៌ដូចមាសមាន សូម្បីមនុស្សទាំងឡាយដែលមានពណ៌សម្បុរដូចមាស ក៏មាន ទាំងនេះមានមកក្នុងគម្ពីរលក្ខណមន្តរបស់ទូលបង្គំទាំងឡាយ ។

ព្រះរាជាទ្រង់ហៅកូនព្រានព្រៃ ក្នុងដែនរបស់ព្រះអង្គមកប្រជុំគ្នាត្រាស់ថា ពួកអ្នកធ្លាប់ឃើញក្ងោកមាសដែរឬទេ កូនព្រានដែលបិតាធ្លាប់ប្រាប់ឲ្យជ្រាបក្រាបទូលថា ទូលព្រះបង្គំក៏មិនធ្លាប់ឃើញ តែឪពុករបស់ទូលព្រះបង្គំបានប្រាប់ថា ក្ងោកមាសមានក្នុងទីឈ្មោះនោះ ។ កាលនោះព្រះរាជាត្រាស់នឹងកូនព្រាននោះថា នែសម្លាញ់ អ្នកជាមនុស្សឲ្យជីវិតដល់ខ្ញុំ និងព្រះទេវីបាន

ព្រោះដូច្នោះ ចូរអ្នកទៅទីនោះ ចាប់ក្ងោកមាសនោះនាំមកចុះ ហើយទ្រង់ប្រទានទ្រព្យជាច្រើនបញ្ជូនទៅ ។ ព្រានព្រៃឲ្យទ្រព្យដល់កូនប្រពន្ធ ហើយទៅក្នុងទីនោះ ឃើញព្រះមហាសត្វ ក៏ធ្វើអន្ទាក់ដាក់បង្កាត់ថា ថ្ងៃនេះគង់ជាប់ ថ្ងៃនេះគង់ជាប់ ក៏ក្ងោកនោះមិនជាប់អន្ទាក់សោះ រហូតដល់ព្រានអស់អាយុទៅ ព្រះទេវីកាលមិនបានតាមប្រាថ្នា ក៏អស់ព្រះជន្ម ព្រះរាជាទ្រង់ពិរោធថា ព្រោះអាស្រ័យក្ងោកមាសនេះជាហេតុ កិរិយាជាទីស្រឡាញ់របស់អញត្រូវអស់ព្រះជន្ម ទ្រង់មានព្រះហឫទ័យប្រព្រឹត្តទៅក្នុងអំណាចពៀរវេរា ទ្រង់ឲ្យគេចារឹកអក្សរក្នុងក្រាំងមាសថា ត្រង់ជួរភ្នំទី ៤ ក្នុងព្រៃហិមពាន្ត មានក្ងោកមាសអាស្រ័យនៅ បុគ្គលណាបានស៊ីសាច់របស់ក្ងោកមាសនោះហើយ នឹងមិនចាស់ មិនស្លាប់ ហើយទ្រង់ដាក់ក្រាំងមាសនោះទុកក្នុងហិបដែលធ្វើអំពីឈើខ្លឹម ហើយសោយទិវង្គតទៅ ។ កាលក្សត្រដទៃបានជាព្រះរាជាហើយ ទ្រង់ទតឃើញអក្ខរាក្នុងក្រាំងមាស ទ្រង់ត្រិះរិះថា អញនឹងមិនចាស់មិនស្លាប់ ហើយទ្រង់បញ្ជូនព្រានម្នាក់ទៅចាប់ក្ងោកមាសនោះ សូម្បីព្រាននោះ ក៏ស្លាប់ក្នុងទីនោះដូចគ្នា ។ ដោយទំនងនេះ កន្លងទៅ ៦ រជ្ជកាលហើយ កូនព្រានទាំង ៦ ស្លាប់ក្នុងព្រៃហិមពាន្តនោះឯង ។ លុះដល់ព្រានទី ៧ ដែលព្រះរាជាអង្គទី ៧ ទ្រង់បញ្ជូនទៅគិតថា អញនឹងចាប់ក្ងោក មាសនោះបានក្នុងថ្ងៃនេះពិតប្រាកដ កន្លងទៅ ៧ ឆ្នាំ ក៏មិនអាចចាប់ក្ងោកមាសនោះបាន ក៏គិតថា ហេតុអ្វីហ្ន៎អន្ទាក់ក៏មិនភ្លាត់ជាប់ជើងស្តេចក្ងោកមាសនេះ ក៏ចាំសង្កេតមើលក្ងោកមាសនោះ ឃើញក្ងោកចម្រើនព្រះបរិត្តរាល់ព្រឹកល្ងាច ក៏កំណត់បាន

ដោយន័យថា ក្នុងទីនេះក្ងោកដទៃមិនមានឡើយ ក្ងោកមាសនេះ គង់ប្រព្រឹត្ត ព្រហ្មចរិយៈ ដោយអានុភាពនៃព្រហ្មចរិយៈ និងដោយអានុភាពនៃព្រះបរិត្ត ទើបអន្ទាក់មិនរួតជើងស្ដេចក្ងោក ហើយទើបទៅកាន់ បច្ចន្តជនបទ ចាប់ក្ងោកញីបានមួយ បង្ហាត់ឲ្យរងាវក្នុងពេលដែលផ្ទាត់ម្រាមដៃ ឲ្យពែនពង់ក្នុងពេលដែលទះដៃ ហើយនាំទៅ ។ មុនពេលដែលព្រះពោធិសត្វចម្រើនព្រះបរិត្តនោះឯង ក៏វាយអន្ទាក់ផ្ទាត់ម្រាមដៃឲ្យក្ងោកញីរងាវ កាលស្ដេចក្ងោកមាសបានស្ដាប់សំឡេងរបស់ក្ងោកញី កិលេសដែលស្ងប់អស់ ៧០០ ឆ្នាំ ក៏ផ្សាយឡើងមួយរំពេច ដូចអាសិរពិសដែលត្រូវវាយដោយដំបង បើកនូវពពារដូច្នោះ ។ ស្ដេចក្ងោកសោប់សល់ដោយអំណាចកិលេស រហូតមិនអាចចម្រើនព្រះបរិត្តបាន ហើរទៅកាន់សម្នាក់ក្ងោកញីដោយរហ័ស គ្រាន់តែចុះពីអាកាស ស៊កជើងចូលទៅក្នុងអន្ទាក់នោះឯង ។ អន្ទាក់មិនធ្លាប់រួតអស់ ៧០០ ឆ្នាំ ក៏រួតជើងក្នុងខណៈនោះឯង ពេលនោះព្រានព្រៃឃើញស្ដេចក្ងោកសំយុងខ្ជួនត្រង់ដងអន្ទាក់ហើយគិតថា កូនព្រាន ៦ នាក់ មិនអាចចាប់ស្ដេចក្ងោកមាសនេះបាន ឯខ្លួនអញក៏មិនអាចចាប់បានអស់ ៧ ឆ្នាំ ថ្ងៃនេះក្នុងពេលអាហារព្រឹក ស្ដេចក្ងោកអាស្រ័យក្ងោកញី ជាសត្វសោប់សល់ដោយអំណាចកិលេស មិនអាចចម្រើនព្រះបរិត្ត មកជាប់អន្ទាក់សំយុងក្បាលចុះ ជាសត្វមានសីលបែបនេះ ត្រូវអញធ្វើឲ្យលំបាកហើយ ការនាំសត្វបែបនេះទៅដើម្បីជាបណ្ណាការដល់ព្រះរាជា មិនសមគួរឡើយ អញត្រូវការអ្វីដោយសក្ការៈដែលព្រះរាជាទ្រង់ព្រះរាជទាន នឹងលែងក្ងោកនេះទៅចុះ ហើយគិតថា ស្ដេចក្ងោក

នេះមានកម្លាំងដូចដំរីសារ សម្បូរដោយសន្ទុះ បើអញចូលទៅជិតគង់គិតថា បុរសនេះនឹងមកសម្លាប់អញ ហើយខាចស្លាប់ពន់ពេក នឹងរើបម្រះ ជើង ឬស្លាបនឹងខូចឬបាក់ បើអញមិនចូលទៅជិត អញនឹងបាញ់ផ្តាច់អន្ទាក់ដោយព្រួញ ពេលនោះ ក្ងោកនឹងទៅតាមគាប់ចិត្តដោយទំនើងខ្លួនឯង ។ ហើយឈរក្នុងទីកំបាំង លើកធ្នូឡើងផ្ទាប់កាំសរ ស្តេចក្ងោកត្រិះរិះថា ព្រាននេះជ្រាបភាពដែលអញលំបាកដោយអំណាចកិលេសហើយ ទើបដាក់អន្ទាក់បាន ឆាយ តែមិនត្រេកអរ គេពួនធ្វើអ្វីហ្ន៎ សម្លឹងមើលដោយជុំវិញ ឃើញកូនព្រានកំពុងកាន់ធ្នូសម្គាល់ថា ប្រហែលជាប្រាថ្នានឹងបាញ់អញឲ្យស្លាប់ ហើយក៏តក់ស្លុតចំពោះមរណភ័យ កាលអង្វរសូមជីវិត ទើបពោលគាថាទី ១ ថា

ម្នាលសម្លាញ់ ប្រសិនបើអ្នកចាប់ខ្ញុំ ព្រោះហេតុនៃទ្រព្យ អ្នក
កុំសម្លាប់ខ្ញុំឡើយ សូមចាប់ខ្ញុំទាំងរស់ហើយនាំខ្ញុំទៅកាន់សំ-
ណាក់ព្រះរាជាចុះ អ្នកទំនងជានឹងបាននូវទ្រព្យដ៏ច្រើនដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សចេ ហិ តាតហំ** កាត់បទជា **សចេ ហិ តេ អហំ** ។ បទថា **ឧបន្តិ នេហិ** បានដល់ នាំទៅកាន់សម្នាក់ ។ បទថា **លច្ឆ-សិធនប្បរូបំ** កាត់បទជា **លច្ឆសិ អធនប្បរូបំ** សេចក្តីថា អ្នកនឹងបានទ្រព្យមិនមែនតិចពិត ។

ព្រានព្រៃបានឮពាក្យនោះហើយត្រិះរិះថា ស្តេចក្ងោកយល់ថា ព្រាននេះផ្ទាប់ព្រួញដើម្បីត្រូវការបាញ់ អញត្រូវលួងលោមក្ងោកនេះចុះ កាលនឹងលួងលោម ទើបពោលគាថាទី ២ ថា

ធ្នូដ៏ប្រសើរនិងព្រួញនេះ ខ្ញុំមិនមែនយឹតប្រុងប្រៀបដើម្បី នឹង
បាញ់អ្នក ក្នុងថ្ងៃនេះទេ ខ្ញុំនឹងបាញ់ផ្តាច់អន្ទាក់របស់អ្នកទេតើ
( ដោយគិតថា ) ស្តេចក្ងោកចូរទៅតាមសប្បាយចុះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អធិចាតយិស្សំ** បានដល់ ខ្ញុំនឹងផ្តាច់ ។

លំដាប់នោះ ស្តេចក្ងោកបានពោលគាថា ២ ថា

អ្នកខំអត់ទ្រាំនូវសេចក្តីស្រេកឃ្លានទាំងយប់ទាំងថ្ងៃ ដើរជាប់
តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាងនេះ ព្រោះហេតុអ្វី
ក៏អ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចអំពីអន្ទាក់វិញ ។
អ្នកទើបនឹងវៀរចាកបាណាតិបាតក្នុងថ្ងៃនេះឬ ឬក៏អ្នកឲ្យអភ័យ
ដល់សត្វទាំងពួង បានជាអ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់
ឲ្យរួចចាកអន្ទាក់វិញ ដូច្នេះ ។

ក្នុងគាថា ២ នោះ បទថា **យំ** មានអធិប្បាយថា អ្នកព្យាយាមដាក់អន្ទាក់ខ្ញុំមក អស់កាលមានប្រមាណប៉ុណ្ណេះ ព្រោះហេតុណា ហេតុនោះ ខ្ញុំសូមសួរអ្នក កាលបើយ៉ាងនេះ អ្នកប្រាថ្នានឹងដោះលែងខ្ញុំ ដែលជាប់ក្នុងអំណាចអន្ទាក់អំពីអន្ទាក់ដើម្បីអ្វី ។

បទថា **វិរតោ នុសជ្ជ** កាត់បទជា **វិរតោ នុសិ អជ្ជ** សេចក្តីថា ក្នុងថ្ងៃនេះ អ្នកវៀរចាកបាណាតិបាតទេដឹង ។

បទថា **សព្វភូតេសុ** បានដល់ ក្នុងពួកសត្វទាំងពួង ។

បន្ទាប់អំពីនេះ គប្បីជ្រាបការសម្ពន្ធនៃការឆ្លើយឆ្លងរវាងនាយព្រាន និង

ក្ងោកដូច្នេះថា

ម្នាលស្តេចក្ងោក អ្នកចូរប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួងផង ខ្ញុំសូមសួរអ្នក ត្រង់សេចក្តីនុ៎ះ បុគ្គលនោះច្យុតអំពីលោកនេះទៅនឹងបាននូវសេចក្តីសុខដូចម្តេចខ្លះ ។

ស្តេចក្ងោកពោលថា

ខ្ញុំនឹងប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួង បុគ្គលនោះ រមែងបាននូវសេចក្តីសរសើរក្នុងបច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹងបានទៅកើតនៅឋានសួគ៌ផង ។

កូនព្រានពោលថា

សមណព្រាហ្មណ៍ពួកខ្លះ បានពោលថា ទេវតាទាំងឡាយមិនមានទេ ជីវៈក្នុងលោកនេះរមែងដល់នូវសេចក្តីដាច់សូន្យផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវសេចក្តីដាច់សូន្យដូចគ្នា ទាំងពោលថាទាន ជាគុណជាត គឺមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះ បានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ ដូច្នេះ ។

គាថាទាំងនេះមានអត្ថងាយយល់ហើយ គប្បីជ្រាបតាមន័យរបស់ព្រះបា

លីនោះឯង ។ បណ្តាបទទាំងនោះ បទថា **ឥតិ អាហុ ឯកេ** សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះ បានពោលយ៉ាងនេះ ។ បទថា **តេសំ វចោ អរហតំ សទ្ទហានោ** សេចក្តីថា បានឮថា ពួកអ្នកបួសអាក្រាត មានវាទៈថាដាច់សូន្យ ជាអ្នកនៅជិតខាងត្រកូលនាយព្រាននោះ ជនទាំងនោះ នាំគ្នាដឹកនាំព្រានដែលជាសត្វដល់ព្រមដោយឧបនិស្ស័យនៃបច្ចេកពោធិញ្ញាណ ឲ្យកាន់យកនូវឧច្ឆេទវាទបាន ព្រោះការសេពគប់នឹងអ្នកបួសអាក្រាតនោះ ទើបនាយព្រាននោះយល់ថា ផលនៃកុសលនិងអកុសលមិនមាន ទើបសម្លាប់ហ្វូងបក្សីជាច្រើន ការគប់រកបុគ្គលអសប្បុរសនេះ មានទោសដល់ម្ល៉េះ ហើយព្រានសម្គាល់ជនទាំងនោះថាជាព្រះអរហន្ត ទើបពោលយ៉ាងនេះ ។

ព្រះមហាសត្វស្តាប់ពាក្យនោះហើយត្រិះរិះថា អញត្រូវពោលដល់ភាពដែលបរលោកមានដល់បុរសនេះ ទាំងក្បាលកំពុងសំយុងចុះត្រង់ចុងអន្ទាក់នោះឯង ហើយពោលគាថាថា

ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿង
ទៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ ( ជារបស់ )
លោកនេះឬលោកដទៃ ( ពួកជន ) ក្នុងមនុស្សលោកហៅ
ព្រះចន្ទនិងព្រះអាទិត្យទាំងនោះថាជាអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥមស្ស** សេចក្តីថា ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់មានក្នុងលោកនេះឬ ឬជារបស់មានក្នុងលោកដទៃ ។ ពាក្យថា លោកដទៃនេះ ជាធត្តមីវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។ បទថា **កថន្នុ**

**តេ** សេចក្តីថា ព្រះអរហន្តនោះពោលទុកដូចម្តេចក្នុងវិមានទាំងនេះ គឺចន្ទិមទេវបុត្តនិងសុរិយទេវបុត្ត ពោលថា មានឬមិនមាន ជាទេវតាឬជាមនុស្ស ។

កូនព្រានពោលគាថាថា

ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ក្នុំរុងរឿងទៅឰដ៏អាកាស ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ ( ជារបស់ ) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជនក្នុងមនុស្សលោកហៅព្រះចន្ទនិងព្រះអាទិត្យទាំងនោះថាជាទេវតាដូច្នេះ ។

កាលនោះព្រះមហាសត្វពោលគាថាថា

សមណព្រាហ្មណ៍ណាមិនពោលអាងកម្ម មិនពោលអាងផលនៃកម្មដែលសត្វធ្វើល្អធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណាពោលថា ទានជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកហីនវាទ ជាអ្នកអហេតុកវាទ ត្រូវគេដេញដើងទាល់ក្នុងព្យាករណ៍នេះមិនខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃគ្គេវ តេ ធីហាតា** សេចក្តីថា បើព្រះចន្ទព្រះអាទិត្យស្ថិតនៅក្នុងទេវលោក មិនមែនស្ថិតនៅក្នុងមនុស្សលោក បើព្រះចន្ទ ព្រះអាទិត្យទាំងនោះជាទេវតា មិនមែនជាមនុស្សសោត ពេលនេះឯងគឺក្នុងការព្យាករណមានប្រមាណប៉ុណ្ណេះ សមណព្រាហ្មណ៍ទាំងនោះ ដែលនៅជិតត្រកូលរបស់អ្នក ជាបុគ្គលដែលមានវាទៈអាក្រក់ ត្រូវអ្នកកម្ចាត់ហើយ ។ បទថា **អហេតុកា** សេចក្តីថា សមណព្រាហ្មណ៍ពួកណា មានវាទៈយ៉ាង

នេះថា កម្មដែលជាតួហេតុនៃសេចក្តីផូរផង់ និងសេចក្តីសៅហ្មង មិនមាន ឈ្មោះថា ពួកអហេតុកៈ ។ បទថា **ឧត្តុបញ្ញត្តំ** សេចក្តីថា និងពួកជនដែល ពោលដល់ទានថា បុគ្គលល្ងង់ខ្លៅនាំគ្នាបញ្ញត្តទុក ។

កាលព្រះមហាសត្វពោលរឿយៗ កូនព្រានទោះក៏កំណត់បាន ហើយ ពោលគាថា ២ ថា

ពាក្យរបស់អ្នកនុ៎ះទៀងពិត ព្រោះទាន ជាគុណជាតឥតផល
ដូចម្តេចកើត ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ក៏ដូចគ្នា
ម្យ៉ាងទៀត ( ទាន ) ជាគុណជាតដែល មនុស្សល្ងង់បញ្ញត្ត
ហើយ ដូចម្តេចកើត ។ ខ្ញុំធ្វើអំពើដូចម្តេច ធ្វើដោយហេតុ
ដូចម្តេច ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ដោយគុណនៃតបៈដូច
ម្តេច មិនគប្បីធ្លាក់ទៅក្នុងនរកយ៉ាងណា ម្នាលស្តេចក្មេក អ្នក
សូមប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ដោយឧបាយយ៉ាងនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្តុបញ្ញត្តញ្ច** សេចក្តីថា ទានឈ្មោះថា បុគ្គលល្ងង់ខ្លៅបញ្ញត្តហើយដូចម្តេចកើត ។ បទថា **កថង្ករោ** សេចក្តីថា ធ្វើ នូវកម្មណា ។ បទថា **កិន្តិករោ** សេចក្តីថា ខ្ញុំធ្វើកម្មដោយហេតុអ្វី ទើបមិន ទៅកាន់នរក ។ ពាក្យក្រៅអំពីនេះ ជាវេវចនៈរបស់ពាក្យនោះឯង ។

ព្រះមហាសត្វស្តាប់ពាក្យនោះហើយ ត្រិះរិះថា បើអញមិនអាចពោល ឆ្លើយបញ្ហានេះ មនុស្សលោកហាក់ដូចជាទទេ អញនឹងពោលភាពដែលសមណ ព្រាហ្មណ៍ ទ្រទ្រង់នូវធម៌មាននៅក្នុងមនុស្សលោកនេះឯងដល់បុរសនេះ ក៏បាន

ភាសិតគាថា ២ ថា

ពួកសមណៈណាមួយនៅលើផែនដី ជាអ្នកស្លៀកសំពត់កា-
សាវៈ ប្រព្រឹត្តក្នុងភេទនៃបុគ្គលគ្មានផ្ទះ ត្រាច់ទៅបិណ្ឌបាត
អំពីព្រឹកក្នុងកាលគួរ វៀរចាកកិរិយាត្រាច់ទៅក្នុងកាលខុស ជា
អ្នកស្ងប់រម្ងាប់ ។ អ្នកចូរចូលទៅរកសមណៈទាំងនោះតាមកាល
គួរ ក្នុងទីនោះហើយ ចូរសាកសួរចុះ ប្រយោជន៍ណាដែលជា
ទីពេញចិត្តរបស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍នោះ ជា
ប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកខាងមុខ ( ដល់អ្នក )
តាមទំនងនៃការចេះដឹង ( របស់លោក ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តោ** គឺបណ្ឌិតដែលមានបាបរម្ងាប់ហើយ បានដល់ព្រះបច្ចេកពុទ្ធ ។ បទថា **យថាបជានំ** សេចក្តីថា សមណៈទាំងនោះ នឹងប្រាប់ដល់លោកតាមទំនងដែលខ្លួនជ្រាប គឺនឹងពោលពាក្យកម្ចាត់នូវសេចក្តីសង្ស័យរបស់លោកចេញបាន ។ បទថា **បរស្ស ចត្ថំ** សេចក្តីថា សមណៈទាំងនោះ នឹងចង្អុលប្រយោជន៍ក្នុងលោកនេះ និងក្នុងបរលោកយ៉ាងនេះថា ដោយកម្មឈ្មោះនេះ នឹងកើតក្នុងមនុស្សលោក ដោយកម្មនេះ នឹងកើតក្នុងទេវលោក ដោយកម្មនេះ នឹងកើតក្នុងនរកជាដើម អញ្ជើញសួរសមណៈទាំងនោះចុះ ។

កាលស្តេចក្មេកពោលយ៉ាងនោះហើយ ឲ្យខ្លាចភ័យក្នុងនរក បុរសនោះជាបច្ចេកពោធិសត្វ មានបារមីពេញហើយ មានញាណចាស់ក្លាហើយ ដូចផ្កា

បទុមដែលចាស់ហើយ ត្រូវពន្លឺព្រះអាទិត្យដូច្នោះ កាលស្តាប់ធម្មកថារបស់ស្តេចក្មេក ឈរដោយឥរិយាបថនោះឯង កំណត់សង្ខារទាំងឡាយ ពិចារណាត្រៃលក្ខណ៍ សម្រេចបច្ចេកពោធិញ្ញាណហើយ ការសម្រេចរបស់លោក និងការរួចផុតចាកអន្ទាក់របស់ព្រះមហាសត្វ មានជំណាលគ្នានោះឯង ព្រះបច្ចេកពុទ្ធទម្លាយកិលេសទាំងឡាយហើយ តាំងនៅក្នុងទីបំផុតនៃភព កាលទ្រង់បន្លឺនូវឧទាន ទើបពោលគាថាដូច្នេះថា

*កាពជាព្រានព្រៃនុ៎ះ អាត្មាអញបានលះបង់ហើយ អាត្មាអញ*
*បានលះបង់នូវភាពនៃខ្លួនជាព្រានព្រៃ ក្នុងថ្ងៃនេះ ដូចពស់*
*សកនូវសំណាកចាស់ជាន់មុន ឬក៏ដូចដើមឈើមានស្លឹកខៀវ*
*( ជម្រុះចោល ) នូវស្លឹកលឿង ដូច្នេះ ។*

អត្ថនៃគាថានោះ មានអធិប្បាយថា ពស់សកសំណាកចាស់ ដែលចាស់គ្រាំគ្រាយ៉ាងណា ដើមឈើដែលមានស្លឹកពណ៌ខៀវ ជម្រុះនូវស្លឹកពណ៌លឿងដែលជាប់ក្នុងទីណាមួយចោលបានយ៉ាងណា អាត្មាក៏យ៉ាងនោះ លះបង់បាននូវភាពជាព្រានក្នុងថ្ងៃនេះ ក្នុងទីនេះ ភាពជាព្រានអាត្មាលះចោលបានហើយល្ហុ៎ អាត្មាលះភាពជាព្រានបានក្នុងថ្ងៃនេះ ។ បទថា **ជហាមហំ** សេចក្តីថា អាត្មាលះហើយ ។

កាលព្រះបច្ចេកពុទ្ធបន្លឺឧទាននេះហើយត្រិះរិះថា អញផុតចាកគ្រឿងជាប់ជំពាក់ គឺកិលេសទាំងពួងបានពិតប្រាកដ តែក្នុងលំនៅរបស់អញមានបក្សីដែលប្រស់ទុកច្រើន អញនឹងដោះលែងបក្សីទាំងនោះបានដូចម្តេច ទើបសួរ

មហាសត្វថា នៃស្តេចក្ងោក ក្នុងលំនៅរបស់អាត្មា មានបក្សីដែលប្រស់ទុកច្រើន អាត្មានឹងដោះលែងបក្សីទាំងនោះបានដូចម្តេច ។ សេចក្តីពិត ញាណក្នុងការកំណត់ឧបាយរបស់ព្រះសព្វញ្ញុពោធិសត្វទាំងឡាយ រមែងធំជាងព្រះបច្ចេកពុទ្ធ ។ ហេតុនោះ ទើបស្តេចក្ងោកពោលថា បច្ចេកពោធិញ្ញាណដែលលោកម្ចាស់ទម្លាយកិលេសទាំងពួងហើយ សម្រេចដោយពោធិមគ្គណា សូមប្រារព្ធពោធិមគ្គនោះ ធ្វើនូវសច្ចកិរិយាចុះ ឈ្មោះថា សត្វដែលត្រូវចងក្នុងជម្ពូទ្វីបទាំងមូល ក៏នឹងមិនមាន ។ ព្រះបច្ចេកពុទ្ធតាំងនៅក្នុងឋានៈដែលព្រះពោធិសត្វពោលហើយ កាលធ្វើសច្ចកិរិយា ទើបពោលគាថាដូច្នេះថា

ពួកបក្សីណាច្រើនរយ ដែលអាត្មាអញបានចងទុកក្បែរលំនៅ
( របស់ខ្លួន ) អាត្មាអញ នឹងឲ្យនូវជីវិតដល់សត្វទាំងឡាយ
នោះ ក្នុងថ្ងៃនេះ អាត្មាអញបានរួចចាកកិលេសហើយ សត្វ
ទាំងនោះ ចូរទៅកាន់លំនៅរបស់ខ្លួនចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មោក្ខញ្ចេ តេ បត្តា** សេចក្តីថា បើអាត្មាសម្រេចមោក្ខធម៌ហើយ គឺសម្រេចបច្ចេកពោធិញ្ញាណហើយ ដោយសច្ចៈនេះ អាត្មារមែងអនុគ្រោះសត្វទាំងនោះដោយការឲ្យជីវិតជាទាន ។ បទថា **សកំ និកេតំ** សេចក្តីថា ព្រះបច្ចេកពុទ្ធពោលថា សូមសត្វទាំងពួងនាំគ្នាទៅកាន់លំនៅរបស់ខ្លួនចុះ ។

លំដាប់នោះ បក្សីទាំងពួងក៏រួចចាកទីឃុំឃាំង ដំណាលគ្នានឹងព្រះបច្ចេកពុទ្ធធ្វើសច្ចកិរិយានោះឯង ក៏នាំគ្នាត្រេកអរ ហើរទៅកាន់លំនៅរបស់ខ្លួន ។

ខណៈនោះ បណ្តាសត្វក្នុងផ្ទះទាំងអស់ មានឆ្មាជាដើម ក្នុងជម្ពូទ្វីបទាំងមូល ឈ្មោះថាជាសត្វដែលត្រូវចងឬឃុំឃាំងមិនមានឡើយ ។ ព្រះបច្ចេកពុទ្ធលើកដៃស្ទាបសីសៈ រំពេចនោះឯងយាវាសក៏អន្តរធានទៅ បព្វជិតភេទក៏ប្រាកដឡើង លោកដូចជាព្រះថេរៈមានវស្សា ៦០ សម្បូរដោយមារយាទ ទ្រទ្រង់នូវបរិក្ខារ ៨ ពោលថា លោកទុំះបានជាទីពឹងរបស់ខ្ញុំ ផ្គងអញ្ជលីដល់ស្តេចក្ងោកធ្វើប្រទក្សិណ ហោះទៅក្នុងអាកាស ទៅកាន់ញកភ្នំឈ្មោះនន្ទមូលក ។ ចំណែកស្តេចក្ងោក ផុតអំពីដងអន្ទាក់ហើយ ស្វែងរកអាហារ ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ឥឡូវនេះ ព្រះសាស្តា កាលទ្រង់ប្រកាសភាពដែលនាយព្រានកាន់យកអន្ទាក់ទៅអស់ ៧ ឆ្នាំ អាស្រ័យស្តេចក្ងោកផុតចាកទុក្ខបាន ទើបត្រាស់គាថាចុងក្រោយថា

ព្រានព្រៃមានអន្ទាក់ក្នុងដៃ ត្រាច់ទៅក្នុងព្រៃដើម្បីទាក់នូវស្តេចក្ងោកដែលមានយស លុះទាក់នូវស្តេចក្ងោកដែលមានយសបានហើយ ក៏បានរួចចាកសេចក្តីទុក្ខ ដូចតថាគតដែលបានរួច ( ចាកទុក្ខដោយសយម្ភូញាណ ) ដូច្នោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពាធេតុ** កែជា **ពាធេតុំ** ប្រែថា ដើម្បីដាក់ ( អន្ទាក់ ) បាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **ពន្ធិត្វា** អធិប្បាយថា កាលដាក់ស្តេចក្ងោកបានហើយ ឈរស្តាប់ធម្មកថារបស់ស្តេចក្ងោកនោះ ក៏បាននូវការសង្វេគ ។ បទថា **យថាហំ** សេចក្តីថា ព្រាននោះរួចផុតចាកទុក្ខ

បាន ដូចតថាគតរួចផុតដោយសយម្ភូញាណដូច្នោះឯង ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងកាលចប់សច្ចធម៌ ភិក្ខុអ្នកអផ្សុកតាំងនៅក្នុងព្រះអរហត្ត ហើយទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បរិនិព្វានហើយ ចំណែកស្តេចក្ងោកក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មហាមោរជាតក ចប់

# តច្ឆសូករជាតក

[ ១០៤ ] ( ជ្រូកឈ្មោះតច្ឆកៈពោលថា ) យើងកាលស្វែងរកពួកញាតិណា ដើរទៅកាន់ភ្នំនិងព្រៃទាំងឡាយ យើងតាមស្វែងរកពួកញាតិដ៏ច្រើន ឯពួកញាតិទាំងនោះយើងបានចួបហើយ ។ មើមឈើ និងផ្លែឈើនេះដ៏ច្រើនផង ភក្សាហារនេះច្រើនផង ភ្នំនិងស្ទឹងទាំងនេះជាទីរីករាយផង ជាលំនៅដ៏សប្បាយ ។ យើងនឹងមិនមានសេចក្ដីខ្វល់ខ្វាយ មិនមានសេចក្ដីរង្កៀសមិនមានសេចក្ដីសោក មិនមានភ័យអំពីទីណា នឹងនៅក្នុងទីនេះឯង ជាមួយនឹងពួកញាតិទាំងអស់ ។

[ ១០៥ ] ( ពួកជ្រូកឯទៀតពោលថា ) ម្នាលតច្ឆកៈ អ្នកចូរស្វែងរកទីជ្រកកោនឯទៀតវិញចុះ ( ដ្បិត ) ក្នុងទីនេះមានសត្រូវចំពោះពួកយើង សត្រូវនោះ តែងមកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយ ( សំដៅតែជ្រូកណា ) ដែលធាត់ៗ ។

[ ១០៦ ] ( តច្ឆកៈ... ) សត្វណា ជាសត្រូវនឹងពួកយើងក្នុងទីនេះ សត្វណាកម្ចាត់បង់នូវញាតិកំពុងនៅចួបជុំគ្នា ដែលសត្រូវកម្ចាត់បង់បានដោយក្រ អ្នកខ្ញុំសួរហើយ ចូរប្រាប់នូវហេតុនោះ ។

[ ១០៧ ] ( ពួកជ្រូក... ) ម្រឹគ ( មួយ ) ជាស្ដេចនៃម្រឹគ មានក្រឡានៃសរីរៈខាងលើ មានកម្លាំងកាយ មានចង្កូមជាអាវុធ ម្នាលតច្ឆកៈម្រឹគនោះ មកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយដែលធាត់ៗ ។

[ ១០៨ ] ( តច្ឆកៈ... ) ខ្នាយទាំងឡាយរបស់ពួកយើង មិនមែនជាមិនមានទេ កម្លាំងក៏ប្រជុំចុះក្នុងកាយ បើពួកយើងទាំងអស់ជាអ្នកព្រមព្រៀងគ្នា

នឹងធ្វើខ្លាតែម្នាក់ឯងនោះ ឲ្យលុះអំណាចបាន ។

[ ១០៩ ] ( ពួកជ្រូក... ) ម្នាលតច្ឆកៈ អ្នកពោលនូវពាក្យជាទីគាប់ចិត្ត គាប់ត្រចៀកណាស់ ដូច្នេះ ប្រសិនបើជ្រូកណា បោលចោលគ្នាក្នុងចម្បាំង យើងនឹងសម្លាប់ជ្រូកនោះក្នុងកាលជាខាងក្រោយ ។

[ ១១០ ] ( កូដជដិល... ) ម្នាលអ្នកមានព្យាយាម ជាងពួកម្រឹគក្នុងថ្ងៃនេះ អ្នកវៀរចាកបាណាតិបាតឬ ឬក៏អ្នកឲ្យអភ័យដល់ ពួកសត្វទាំងអស់ ឬមួយអ្នកមិនមានចង្កូម បានជាអ្នកទៅចូបនឹងហ្វូង ( ជ្រូក ) ហើយសញ្ជប់សញ្ជឹង ដូចជាសត្វកំព្រា ។

[ ១១១ ] ( ខ្លា... ) ខ្ញុំមិនមែនជាមិនមានចង្កូមទេ កម្លាំងក៏ប្រជុំចុះក្នុងកាយ ខ្ញុំម្នាក់ឯងបានឃើញពួកញាតិរបស់ជ្រូកព្រមព្រៀងគ្នាក្នុងទីតែមួយ ហេតុនោះ បានជាសញ្ជប់សញ្ជឹងក្នុងព្រៃ ។

បានឮថា ក្នុងកាលមុន ជ្រូកទាំងឡាយនេះ តែងទៅកាន់ទិសតូចធំ លុះភ័យគ្របសង្កត់ហើយ ក៏ស្វែងរកទីជ្រកកោនផ្សេងៗគ្នា ឥឡូវនេះ ជ្រូកទាំងនោះឋិតនៅក្នុងទីណាដែល ខ្ញុំគ្របសង្កត់បានដោយលំបាក ជ្រូកទាំងនោះក៏មកនៅចូបជុំ ជាមួយគ្នា ( ក្នុងទីនោះ ) ។

ជ្រូកទាំងឡាយនោះ បរិបូណ៌ដោយនាយក ប្រុងប្រៀបខ្លួន មូលមាត់គ្នា ព្រមព្រៀងគ្នា គប្បីបៀតបៀននូវខ្ញុំ ព្រោះហេតុនោះ ខ្ញុំមិនប្រាថ្នានូវជ្រូកទាំងនោះទេ ។

[ ១១២ ] ( កូដជដិល... ) ព្រះឥន្ទ្រតែមួយអង្គ ឈ្នះនូវពួកអសុរ ខ្វែងតែមួយ សង្គ្រុបឆាបយកនូវពួកបក្សីបាន ខ្លាតែមួយ ចូបប្រទះនឹងម្រឹគក៏សម្លាប់នូវម្រឹគដែលធាត់ៗបាន ដ្បិតថាកម្លាំង ( នៃខ្លានោះ ) ប្រាកដដូច្នោះ ។

[ ១១៣ ] ( ខ្លា... ) មិនថាព្រះឥន្ទ្រ មិនថាខ្វែង មិនថាខ្លា ជាស្តេចនៃម្រឹគទេ ខ្លាមិនធ្វើ ( នូវពួកជ្រូក ) ដែលមានញាតិព្រមព្រៀងគ្នា ប្រុងប្រៀបខ្លួនទុក ឲ្យលុះក្នុងអំណាចបានឡើយ ។

[ ១១៤ ] ( កូដជដិល... ) ពួកបក្សីតូចៗ ឈ្មោះកុម្ភិលិកា មានហ្វូងហើរទៅទាំងហ្វូង រីករាយរកគ្នា ហើរទៅរកចំណីក៏ជាមួយគ្នា បានចំណីហើយហើរទៅ ( តាមអាកាស ) ក៏ជាមួយគ្នា ។ កាលបក្សីទាំងនោះ កំពុងមូលមិត្រគ្នា បណ្តាបក្សីទាំងនោះ គង់មានបក្សីមួយហើរឃ្លាតពីគេមិនខាន ខ្វែង ឆាបយកនូវបក្សីដែលហើរឃ្លាតពីគេនោះបាន នោះជាគតិរបស់ខ្លា ។

[ ១១៥ ] ( អភិសម្ពុទ្ធគាថា ) ( ខ្លានោះ ) ត្រូវជដិលអាក្រក់ដែលមានក្អែកសម្លឹងតែអាមិសបញ្ឆោរហើយ អាងខ្លួនមានចង្កូម ស្មានថាដូចមុនក៏ស្ទុះទៅរកពួកជ្រូកដែលមានខ្នាយដែរ ។

[ ១១៦ ] ( រុក្ខទេវតា... ) គួរឲ្យសរសើរដែរ ពួកញាតិច្រើនរូបសូម្បីតែឈើដែលដុះក្នុងព្រៃ ( ក៏គួរឲ្យសរសើរ ) ខ្លា ( ម្នាក់ឯង ) ត្រូវពួកជ្រូកព្រមគ្នាសម្លាប់បានក្នុងផ្លូវតែមួយ ។

[ ១១៧ ] ( អភិសម្ពុទ្ធគាថា ) ជ្រូកទាំងឡាយ បានសម្លាប់នូវព្រាហ្មណ៍និងខ្លាធំទាំងពីរនាក់បានហើយ ក៏ត្រេកអររីករាយស្រែកនូវសម្រែក

ដ៏ខ្លាំង ។

[ ១១៨ ] ជ្រូកទាំងឡាយនោះ ប្រជុំគ្នាទៀបគល់នៃល្វា អភិសេកជ្រូកឈ្មោះតច្ឆកៈថា សូមព្រះអង្គជាស្តេច ជាឥស្សរៈរបស់ពួកយើង ។

**ចប់តច្ឆសូករជាតកទី ៩ ។**

# អដ្ឋកថា

## តច្ឆសូករ ជាតក

[ ១០៤-១១៨ ] ព្រះសាស្តា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធព្រះថេរៈចាស់ពីររូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យ-ទេសមានា វិចរម្ហា** ដូច្នេះជាដើម ។

បានឮមកថា ព្រះបាទមហាកោសល[១] ប្រទានធីតាដល់ព្រះបាទពិម្ពិសារ បានប្រទានកាសិកគាមដល់ព្រះរាជធីតា ដើម្បីជាថ្លៃគ្រឿងងូត ។ កាលព្រះបាទអជាតសត្តុ ផ្ដាច់ព្រះជន្មព្រះរាជបិតាហើយ ព្រះបាទបសេនទិទ្រង់រឹបអូសយកវិញ ។ កាលព្រះរាជាទាំងពីរអង្គ ទ្រង់ច្បាំងដណ្ដើមស្រុកនោះ ជំបូងព្រះបាទអជាតសត្តុ ទ្រង់ឈ្នះ ព្រះបាទបសេនទិកោសល ទ្រង់ចាញ់ ក៏ត្រាស់សួរពួកអាមាត្យថា យើងនឹងប្រើឧបាយដូចម្ដេចហ្ន៎ ទើបចាប់អជាតសត្តុបាន ពួកអាមាត្យនាំគ្នាក្រាបទូលថា បពិត្រមហារាជ ធម្មតាភិក្ខុទាំងឡាយរមែងជាអ្នកឈ្លាសក្នុងការគិត គួរទ្រង់បញ្ជូនឈ្លបទៅ រង់ចាំកំណត់ពាក្យរបស់ពួកភិក្ខុមើល ។ ព្រះរាជាទទួលថាសាធុ ហើយត្រាស់ប្រើរាជបុរសទៅដោយព្រះតម្រាស់ថា មកអ្នកទាំងឡាយ ពួកអ្នកចូរនាំគ្នាទៅកាន់វិហារ លាក់ខ្លួនឃ្លាំចាំស្ដាប់ពាក្យរបស់លោកម្ចាស់ទាំងឡាយឲ្យបាន ។ ក្នុងវត្តជេតពន មានពួករាជបុរសបួសជាច្រើន បណ្ដាភិក្ខុទាំងនោះ ព្រះថេរៈពីររូបដែលនៅ ត្រង់បណ្ណសាលាខាងចុងវិហារ មួយរូបឈ្មោះថា ធនុគ្គហ

---

១-ព្រះរាជបិតារបស់ព្រះបាទ បសេនទិកោសល ។

តិស្សត្ថេរ មួយរូបឈ្មោះថា មន្តិទត្តត្ថេរ ព្រះថេរៈទាំងពីរសិងលក់អស់រាត្រី ភ្ញាក់ពេលទៀបភ្លឺ ព្រះធនុគ្គហតិស្សត្ថេរបង្កាត់ភ្លើងឲ្យឆេះពោលថា លោកម្ចាស់មន្តិទត្តត្ថេរ ព្រះថេរៈសួរថា មានការអ្វីលោកម្ចាស់ ព្រះធនុគ្គហតិស្សត្ថេរសួរថា លោកម្ចាស់កំពុងសិងឬ ក៏ឆ្លើយថា ខ្ញុំមិនសិងទេ តើលោកម្ចាស់មានការអ្វី ។ ព្រះធនុគ្គហតិស្សត្ថេរពោលថា បពិត្រលោកម្ចាស់ ព្រះបាទបសេនទិកោសលនេះល្ងង់ពេកណាស់ ចេះតែសោយអាហារម្តងមួយថាសប៉ុណ្ណោះឯង ព្រះមន្តិទត្តត្ថេរសួរថា តើរឿងនោះដូចម្តេច ។ ព្រះធនុគ្គហតិស្សត្ថេរពោលថា ព្រះរាជាចាញ់សត្រូវ ដែលត្រឹមតែជាដង្កូវក្នុងព្រះឧទររបស់ព្រះអង្គក៏ថាបាន ព្រះមន្តិទត្តត្ថេរសួរថា ចុះយើងគួរធ្វើដូចម្តេច ព្រះធនុគ្គហតិស្សត្ថេរឆ្លើយថា នែអាវុសោមន្តិទត្តត្ថេរ ជម្មតាចម្បាំងមាន ៣ របៀប គឺសកដព្យូហៈ ១ ចក្កព្យូហៈ ១ បទុមព្យូហៈ ១ ក្នុងក្បួនច្បាំងទាំង ៣ នោះ ត្រូវរៀបជាក្បួនសកដព្យូហៈ ទើបចាប់ព្រះបាទអជាតសត្តុជាក្មួយបាន ហើយព្រះថេរៈបន្តទៀតថា ក្នុងទីនោះមានញកភ្នំល្មមបង្កប់ទ័ពទុកពីរចំណែកបាន បញ្ឆោតឲ្យគេដេញមក លុះដឹងថាចូលមកខាងក្នុងហើយ ក៏ស្រែកហ៊ោកញ្ជ្រៀវ ព័ទ្ធទុក ធ្វើឲ្យធ្លាក់ក្នុងកណ្តាប់ដៃដូចចាប់ត្រី ដែលចូលក្នុងលបដូច្នោះ ។ ក្នាក់ងាររបស់ព្រះរាជាដែលទ្រង់បញ្ជូនទៅស៊ើបការ ស្តាប់ពាក្យនោះហើយ នាំគ្នាក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទៅដោយកងទ័ពធំទ្រង់ធ្វើយ៉ាងនោះ ចាប់ព្រះបាទអជាតសត្តុបាន ទ្រង់ចងដោយឃ្នាង ធ្វើឲ្យអស់ស្រវឹងក្នុងអំណាច ២-៣ ថ្ងៃ ហើយលួងលោមថា តទៅសូមទ្រង់កុំធ្វើយ៉ាង

នេះឡើយ ទ្រង់ស្រាយចំណងហើយ ព្រះរាជទានរាជធីតាព្រះនាមថា វជិរកុមារី ដល់ព្រះរាជកុមារ ហើយលែងទៅដោយបរិវារច្រើន ។ រឿងដែលព្រះបាទកោសល ចាប់ព្រះបាទអជាតសត្តុបាន ដោយការចាត់ចែងរបស់ព្រះធនុគ្គហតិស្សត្ថេរ ក៏ល្បីទៅពេញក្នុងចំណោមភិក្ខុ ពួកភិក្ខុនាំគ្នាលើករឿងនោះឯងឡើង សន្ទនាក្នុងធម្មសភា ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាល ឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ធនុគ្គហតិស្សត្ថេរ ក៏ជាអ្នកឈ្លាសក្នុងការរៀបក្បួនច្បាំង ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ជាងឈើម្នាក់ក្នុងស្រុកជិតនគរពារាណសី ចូលទៅកាន់ព្រៃដើម្បីរកឈើរបស់ខ្លួន ជួបកូនជ្រូកមួយធ្លាក់ក្នុងរណ្តៅ ទើបបាននាំមកចិញ្ចឹម ដាក់ឈ្មោះថា តច្ឆសូករៈ ។ ជ្រូកនោះជាអ្នកមានឧបការៈដល់ជាងឈើនោះ ជ្រូកយកច្រមុះប្រមៀលឈើឲ្យក៏បាន យកខ្សែរុំច្រមុះអូសទៅ ឲ្យក៏បាន យកមាត់ពាំពន្លាកនិងញញួរមកឲ្យក៏បាន ជាសត្វធំធាត់មានកម្លាំងច្រើន មានរាងកាយធំ ។ ចំណែកជាងឈើស្រឡាញ់ជ្រូកនោះដូចកូន គិតថា បើជ្រូកនៅក្នុងទីនេះ គង់មានគេធ្វើបាបដោយពិត ទើបយកទៅលែងក្នុងព្រៃ ។ ជ្រូកគិតថា ក្នុងព្រៃនេះអញមិនអាចនៅឯកឯងបាន ត្រូវដើររកពួកញាតិ ហើយនៅកណ្តាលពួកញាតិដែលចោមរោម ដើររកហ្វូងជ្រូកក្នុងព្រៃ ជួបពួកជ្រូក

ជាច្រើនហើយត្រេកអរពោលគាថា ៣ ថា

យើងកាលស្វែងរកពួកញាតិណា ដើរទៅកាន់ក្នុងព្រៃ ទាំងឡាយ យើងតាមស្វែងរកពួកញាតិដ៏ច្រើន ឯពួកញាតិទាំងនោះយើងបានចួបហើយ ។ មើមឈើនិងផ្លែឈើនេះដ៏ច្រើនផង ភក្សាហារនេះច្រើនផង ភ្នំនិងស្ទឹងទាំងនេះ ជាទីរីករាយផង ជាលំនៅដ៏សប្បាយ ។ យើងនឹងមិនមាន សេចក្តីខ្វល់ខ្វាយមិនមានសេចក្តីរង្កៀស មិនមានសេចក្តីសោក មិនមានភ័យអំពីទីណា នឹងនៅក្នុងទីនេះឯង ជាមួយនឹងពួក ញាតិទាំងអស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យមេសមានា** សេចក្តីថា ខ្ញុំស្វែងរកពួកញាតិណា ។ បទថា **អន្វេសំ** សេចក្តីថា ត្រាច់រកអស់កាលយូរហ្ន៎ ។ បទថា **តេមេ** កាត់បទជា **តេ ឥមេ** សេចក្តីថា ពួកញាតិទាំងនោះខ្ញុំជួបហើយ ។ បទថា **ភក្ខោ** សេចក្តីថា ម្យ៉ាងទៀត ភិក្ខា ពោលគឺមើមឈើនិងផ្លែឈើ នោះឯង ។ បទថា **អប្បោស្សុក្កោ** សេចក្តីថា ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ។ ពួកជ្រូកបានស្តាប់ពាក្យរបស់ជ្រូកនោះហើយ នាំគ្នាពោលគាថាទី ៤ ថា

ម្នាលតច្ឆកៈ អ្នកចូរស្វែងរកទីជ្រកកោនឯទៀតវិញចុះ ( ដ្បិត ) ក្នុងទីនេះមានសត្រូវចំពោះពួកយើង សត្រូវនោះ តែងមកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយ ( សំដៅតែជ្រូកណា ) ដែលធាត់ៗ ដូច្នេះ ។

បណ្ដាបទទាំងនោះ ពួកជ្រូកហៅជ្រូកនោះដោយឈ្មោះថា **តច្ឆ** ។ បទថា **វរំ វរំ** សេចក្ដីថា សត្រូវនោះសម្លាប់តែជ្រូកដែលមានរាងកាយធាត់ ។

បន្ទាប់អំពីនេះ គប្បីជ្រាបគាថាដែលរចនាទុកដោយងាយៗ តាមន័យព្រះបាលីនោះឯង ។ តច្ឆសូករៈសួរថា

សត្វណា ជាសត្រូវនឹងពួកយើងក្នុងទីនេះ សត្វណាកម្ចាត់បង់នូវញាតិកំពុងនៅចួបជុំគ្នា ដែលសត្រូវកម្ចាត់បង់បានដោយក្រអ្នក ខ្ញុំសួរហើយ ចូរប្រាប់នូវហេតុនោះ ។

ពួកជ្រូកពោលថា

ម្រឹគ ( មួយ ) ជាស្ដេចនៃម្រឹគ មានក្រឡានៃសរីរៈខាងលើមានកម្លាំងកាយ មានចង្កូមជាអាវុធ ម្នាលតច្ឆកៈ ម្រឹគនោះមកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយដែលធាត់ៗ ។

ពួកជ្រូកតច្ឆៈពោលថា

ខ្នាយទាំងឡាយរបស់ពួកយើង មិនមែនជាមិនមានទេ កម្លាំងក៏ប្រជុំចុះក្នុងកាយ បើពួកយើងទាំងអស់ជាអ្នកព្រមព្រៀងគ្នានឹងធ្វើឱ្យតែម្នាក់ឯងនោះ ឲ្យលុះអំណាចបាន ។

ពួកជ្រូកពោលថា

ម្នាលតច្ឆកៈ អ្នកពោលនូវពាក្យជាទីគាប់ចិត្ត គាប់ត្រចៀកណាស់ ដូច្នេះ ប្រសិនបើជ្រូកណា បោលចោលគ្នាក្នុងចម្បាំងយើងនឹងសម្លាប់ជ្រូកនោះក្នុងកាលជាខាងក្រោយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោ ឆម្ភាកំ** សេចក្ដីថា ខ្ញុំឃើញពួក អ្នកក៏គិតថា ពួកជ្រូកទាំងនេះ មានសាច់និងឈាមតិច ប្រហែលជាមានភ័យចំពោះជ្រូកទាំងនេះ ព្រោះដូច្នោះ ពួកអ្នកចូរប្រាប់យើង អ្នកណាហ្ន៎ជាសត្រូវរបស់ពួកយើងក្នុងទីនេះ ។ បទថា **ឧទ្ធគ្គរាជី** សេចក្ដីថា ប្រកបដោយក្រឡានៃសរីរៈ ពួកជ្រូកពោលសំដៅយកខ្លាធំនោះឯង ។ បទថា **យោបិ** សេចក្ដីថា បណ្ដាពួកយើង ជ្រូកណាមួយគេចទៅ ពួកយើងនឹងសម្លាប់ជ្រូកនោះក្នុងកាលជាក្រោយ ។

តច្ឆសូករៈធ្វើពួកជ្រូកទាំងអស់ ឲ្យមានចិត្តតែមួយ ហើយសួរថា ខ្លានឹងមកក្នុងពេលណា ពួកជ្រូកឆ្លើយថា ថ្ងៃនេះពេលព្រឹក វានឹងមកចាប់ជ្រូកមួយ ហើយគង់មកថ្ងៃស្អែកនេះអំពីព្រលឹមពិត ។ តច្ឆសូករៈនោះ ឈ្លាសក្នុងជយភូមិដឹងថា ក្នុងទីកន្លែងនេះមិនអាចឈ្នះបាន ហេតុនោះទើបរកមើលកន្លែងមួយឲ្យពួកជ្រូករកស៊ី លុះកណ្ដាលយប់ក៏ពោលថា ក្បួនចម្បាំងមាន ៣ យ៉ាង មានសកដព្យូហៈជាដើម ហើយចាត់ចែងក្បួនចម្បាំងតាមបែបបទុមព្យូហៈ ឲ្យពួកកូនជ្រូកដែលកំពុងបៅដោះនៅត្រង់កណ្ដាល ដាក់មេជ្រូកទាំងនោះនៅជុំវិញ បន្ទាប់មកដាក់ជ្រូកញីជំទង់ជុំវិញមេជ្រូកទាំងនោះ ចន្លោះជ្រូកញីជំទង់ទាំងនោះ ដាក់កូនជ្រូកដែលដាច់ដោះព័ទ្ធជុំវិញ ក្នុងរវាងកូនជ្រូកទាំងនោះ ដាក់ជ្រូកជំទង់ៗដែលមានខ្នាយតិចៗ ក្នុងរវាងជ្រូកដែលមានខ្នាយធំ រវាងនោះដាក់ជ្រូកចាស់ៗដែលពេញកម្លាំង ចែកជាពួកៗ មួយពួក ១០ ខ្លះ ២០ ខ្លះ ៣០ ខ្លះ ក្នុងទីនោះៗ ឲ្យជីករណ្ដៅម្នាក់មួយសម្រាប់ខ្លួន ហើយជីកមួយ

ទៀតសម្រាប់ដាក់ខ្លា ធ្វើឲ្យជាទីលានដែលមានសណ្ឋានដូចចង្អេរ រវាងរណ្ដៅទាំងពីរឲ្យធ្វើទីខ្ពស់សម្រាប់ខ្លួន ។ តច្ឆកសូករៈនោះ គ្រប់គ្រងពួកជ្រូកសម្រាប់ច្បាំង ដែលមានកម្លាំងខ្លាំង ត្រាច់ឲ្យកម្លាំងចិត្តក្នុងទីនោះ ៗ ។ លុះតច្ឆសូករៈរៀបចំស្រេចបាច់ ព្រះអាទិត្យក៏រះឡើង ។ ពេលនោះស្ដេចខ្លាធំចេញអំពីអាស្រមបទរបស់ជដិលកោង ឈររលាស់កាយលើកំពូលភ្នំ ។ ពួកជ្រូកឃើញខ្លាហើយនាំគ្នាប្រាប់ថា ម្នាលគ្នាយើង សត្រូវរបស់យើងមកហើយ តច្ឆសូករៈប្រាប់ថា ពួកអ្នកកុំខ្លាច ខ្លាធ្វើអាការៈណា ពួកអ្នកចូរធ្វើអាការៈនោះ ជាបដិបក្ខគ្រប់យ៉ាង ខ្លាធំរលាស់កាយបន្ទន់ខ្លួនបន្តិច បន្ទោបង់បស្សាវៈ ពួកជ្រូកក៏ធ្វើយ៉ាងនោះដែរ ខ្លាសម្លឹងមើលជ្រូកគំរាមដោយសំឡេងខ្លាំង ពួកជ្រូកក៏នាំគ្នាធ្វើយ៉ាងនោះដូចគ្នា ។ ខ្លាឃើញកិរិយា របស់ពួកជ្រូកនោះគិតថា ជ្រូកទាំងនេះមិនដូចជ្រូកមុនៗ ថ្ងៃនេះនាំគ្នានៅជាពួកៗ ជាសត្រូវចំពោះអញ ។ សេនាដែលជាធំរបស់ពួកវាគង់មាន ថ្ងៃនេះ អញមិនគួរទៅជិតពួកវាឡើយ ខ្លាចនូវសេចក្ដីស្លាប់ ក៏ត្រឡប់ទៅរកជដិលកោង ជដិលកោងឃើញខ្លាមកដៃទទេ ក៏ពោលគាថាទី ៩ ថា

ម្នាលអ្នកមានព្យាយាមជាងពួកម្រឹគ ក្នុងថ្ងៃនេះ អ្នកវៀរចាក
បាណាតិបាតឬ ឬក៏អ្នកឲ្យអភ័យដល់ពួកសត្វទាំងអស់ ឬ
មួយអ្នកមិនមានចង្កូម បានជាអ្នកទៅចូលទីងហ្វូង ( ជ្រូក )
ហើយសញ្ជប់សញ្ជឹង ដូចជាសត្វកំព្រា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សជ្ជប្បត្តោ** សេចក្ដីថា ចៅបាននៅក្នុង

ពួកនៃជ្រូក មិនបានបរិភោគអាហារណាមួយរមែងសុបសៅ ដូចមនុស្សកំព្រា ដូច្នោះ ។

កាលនោះ ខ្លាពោលគាថាដូច្នេះថា

ខ្ញុំមិនមែនជាមិនមានចង្កូមទេ កម្លាំងក៏ប្រជុំចុះក្នុងកាយ ខ្ញុំម្នាក់ឯង បានឃើញពួកញាតិរបស់ជ្រូកព្រមព្រៀងគ្នា ក្នុងទីតែមួយ ហេតុនោះ បានជាសញ្ជប់សញ្ជឹងក្នុងព្រៃ ។

បានឮថា ក្នុងកាលមុន ជ្រូកទាំងឡាយនេះ តែងទៅកាន់ទិសតូចធំ លុះភ័យគ្របសង្កត់ហើយ ក៏ស្វែងរកទីជ្រកកោនផ្សេងៗគ្នា ឥឡូវនេះ ជ្រូកទាំងនោះឋិតនៅក្នុងទីណាដែលខ្ញុំគ្របសង្កត់បានដោយលំបាក ជ្រូកទាំងនោះ ក៏មកនៅចួបជុំជាមួយគ្នា ( ក្នុងទីនោះ ) ។

ជ្រូកទាំងឡាយនោះ បរិបូណ៌ដោយនាយក ប្រុងប្រៀបខ្លួនមូលមាត់គ្នា ព្រមព្រៀងគ្នា គប្បីបៀតបៀននូវខ្ញុំ ព្រោះហេតុនោះ ខ្ញុំមិនប្រាថ្នានូវជ្រូកទាំងនោះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សមគ្គា ឯកតោ** សេចក្ដីថា ជាអ្នករួមចិត្តគ្នាតែមួយ ។ បទថា **ឥមស្សុធំ** សេចក្ដីថា ក្នុងកាលមុនពួកជ្រូកទាំងនេះគ្រាន់តែខ្ញុំបើកភ្នែកមើលប៉ុណ្ណោះ ក៏រត់ខ្ចាត់ខ្ចាយទៅកាន់ទិសតូចទិសធំ ។ បទថា **បុថុ** បានដល់ បែកគ្នាទៅកាន់ទិសផ្សេងៗ ។ បទថា **យត្ថដ្ឋិតា** សេចក្ដីថា មកប្រជុំគ្នាក្នុងភូមិភាគណា ។ បទថា **បរិណាយកសម្បន្នា** សេចក្ដីថា ពួក

ជ្រូកទាំងនោះសម្បូរដោយមេទ័ព ។ បទថា **តស្មា តេសំ ន បត្ថយេ** សេចក្ដីថា ព្រោះហេតុនោះ ទើបខ្ញុំមិនប្រាថ្នាជ្រូកទាំងនោះ ។

ជដិលកោងស្ដាប់ពាក្យនោះហើយ កាលពន្យុះឲ្យខ្លាកើតឧស្សាហៈ ទើបពោលគាថាដូច្នេះថា

ព្រះឥន្ទ្រតែមួយអង្គ ឈ្នះនូវពួកអសុរ ខ្លែងតែមួយសង្គ្រុបធាបយកនូវពួកបក្សីបាន ខ្លាតែមួយចូបប្រទះនឹងម្រឹគក៏សម្លាប់នូវម្រឹគដែលជាត់ៗបាន ដ្បិតថាកម្លាំង ( នៃខ្លានោះ ) ប្រាកដដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **មិគសង្ឃប្បត្តោ** សេចក្ដីថា ខ្លាធំទៅដល់ហ្វូងម្រឹគហើយ រមែងសម្លាប់ជ្រូកជាត់ៗបាន ។ បទថា **ពលញ្ហិ តាទិសំ** សេចក្ដីថា ព្រោះកម្លាំងរបស់ខ្លាធំនោះដូច្នេះ ។

លំដាប់នោះ ទើបខ្លាពោលគាថានឹងតាបសថា

មិនថាព្រះឥន្ទ្រ មិនថាខ្លែង មិនថាខ្លា ជាស្ដេចនៃម្រឹគទេ ខ្លាមិនធ្វើ ( នូវពួកជ្រូក ) ដែលមានញាតិព្រមព្រៀងគ្នា ប្រុងប្រៀបខ្លួនទុក ឲ្យលុះក្នុងអំណាចបានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្យគ្ឃា ន** សេចក្ដីថា ខ្លាធំមិនធ្វើជ្រូកដែលធ្វើអាការៈជាដើម មានរលាស់កាយដូចគ្នានឹងខ្លាទុកក្នុងអំណាចបានឡើយ គឺមិនអាចឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបាន ។

ជដិលកោងកាលពន្យុះឲ្យខ្លាអង់អាច ទើបពោលគាថា ២ ថា

ពួកបក្សីតូច ៗ ឈ្មោះកុម្ភិលិកា មានហ្វូងហើរទៅទាំងហ្វូង
រីករាយរកគ្នា ហើរទៅរកចំណីក៏ជាមួយគ្នា បានចំណីហើយ
ហើរទៅ ( តាមអាកាស ) ក៏ជាមួយគ្នា ។ កាលបក្សីទាំង
នោះកំពុងមូលមិត្តគ្នា បណ្តាបក្សីទាំងនោះ គង់មានបក្សីមួយ
ហើរឃ្លាតពីគេមិនខាន ខ្លែងចាបយកនូវបក្សីដែលហើរឃ្លាត
ពីគេនោះបាន នោះជាគតិរបស់ខ្លា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុម្ភិលកា** បានដល់ ហ្វូងបក្សីខ្លួនតូចៗដែល មានឈ្មោះយ៉ាងនោះ ។ បទថា **ឧប្បតន្តិ** បានដល់ ហើរទៅត្រាច់រកស៊ី ។ បទថា **ឧយ្យន្តិ ច** សេចក្តីថា ហើរទៅរកស៊ីតាមអាកាស ។ បទថា **ឯកោតត្ថ អបសក្កតិ** សេចក្តីថា ក្នុងបណ្តាហ្វូងបក្សីទាំងនោះ គង់មានបក្សីមួយយឺត យូរ ឬហើរបែកទៅផ្លូវមួយ ។ បទថា **ឆិតាលេតិ** សេចក្តីថា ខ្លែង រមែងចាបយកទៅបាន ។ បទថា **វេយ្យគ្ឃិយេវ សា គតិ** សេចក្តីថា គតិ នោះ ជាទំនងតែមួយដូចគ្នានឹងខ្លា ព្រោះជាគតិរបស់ខ្លានោះឯង គឺកាលពួក ខ្លានឹងទៅរកហ្វូងសត្វដែលនៅរួមគ្នា ក៏មានគតិទំនងនេះ ទើបបានឈ្មោះថា ជាគតិរបស់ខ្លាពិតៗ ដែលពិតបក្សីទាំងអស់មិនអាចហើរទៅដោយក្រុម តែ មួយបានទេ ហេតុនោះ ក្នុងហ្វូងនោះ គង់មានសត្វណាមួយហើរទៅតែឯង យ៉ាងនេះ ក៏ចាប់យកសត្វនោះទៅ ។

ជដិលកោង កាលពោលយ៉ាងនេះហើយក៏ពន្យុះចិត្តខ្លាធំថា នៃស្តេចខ្លា ចៅមិនបានដឹងកម្លាំងរបស់ខ្លួន កុំខ្លាចឡើយ ចៅស្រែកគំរាមហើយរត់ចូល

ទៅតែម្តងប៉ុណ្ណោះ ពួកជ្រូកដែលនៅផ្ទុំគ្នា មិនអាចនៅបានឡើយ ខ្លាក៏បាន ធ្វើតាមនោះ ។

ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

( ខ្លានោះ ) ត្រូវជជិលអាក្រក់ដែលមានភ្នែកសម្លឹងតែអាមិស

បញ្ឆោរហើយ អាងខ្លួនមានចង្កូម ស្មានថាដូចមុន ក៏ស្ទុះទៅ

រកពួកជ្រូក ដែលមានខ្នាយដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទាឋី** សេចក្តីថា ខ្លាធំមានចង្កូមជាអាវុធស្ទុះ ចូលទៅរកហ្វូងជ្រូកដែលមានខ្នាយជាអាវុធដូចគ្នា ។ បទថា **យថា បុរេ** សេចក្តីថា ព្រោះសម្គាល់ថា ដូចគ្នាក្នុងកាលមុនៗ ។

បានឮថា ខ្លានោះទៅឈរលើភ្នំ ពួកជ្រូកប្រាប់តច្ឆសូករៈថា នែលោក ចោរមកទៀតហើយ តច្ឆសូករៈលួងលោមជ្រូកទាំងនោះថា ពួកអ្នកកុំខ្លាច ឡើយ ជ្រូកឡើងឈរលើទីទួលរវាងរណ្តៅទាំងពីរ ។ ខ្លាក៏លោតមករក តច្ឆសូករៈ ។ តច្ឆសូករៈបែរមុខជាខ្នង ប្រមៀលចូលក្នុងរណ្តៅទីមួយ ខ្លា ធំមិនអាចទប់សន្ទុះបាន ក៏ធ្លាក់ក្នុងរណ្តៅដែលមានរាងដូចចង្អេរ ក៏ជាប់ណែន រើខ្លួនមិនរួច តច្ឆសូករៈស្ទុះឡើងដោយរហ័សចេញអំពីរណ្តៅ យកខ្នាយ វែធត្រង់ពោះរបស់ខ្លា មុតរហូតដល់បេះដូង ស៊ីសាច់ហើយ យកមាត់ពាំ គ្រវាត់ចេញពីរណ្តៅប្រាប់ថា ពួកអ្នកចូរនាំគ្នាស៊ីសាច់ខ្លាចុះ ពួកជ្រូកដែល មកមុន បានឱកាសត្រឹមតែមួយមាត់ប៉ុណ្ណោះ ជ្រូកដែលមកឯក្រោយ មិន បានឡើយ នាំគ្នាពោលថា សាច់ខ្លាមានរសជាតិដូចម្តេចហ្ន៎ ។ តច្ឆសូករៈ

លោតឡើងពីរណ្ដៅហើយ សម្លឹងមើលពួកជ្រូកទាំងឡាយពោលថា ហេតុអ្វីហ្ន៎ ទើបពួកអ្នកមិនសប្បាយចិត្ត ពួកជ្រូកឆ្លើយថា បពិត្រលោកម្ចាស់ ពួកយើងចាប់ខ្លាបានមួយប៉ុណ្ណោះ តែខ្លាក្រៅពីនេះ ដែលបញ្ជូនខ្លាមក នៅមាន ។ តច្ឆសូករៈសួរថា ខ្លានោះឈ្មោះអ្វី ពួកជ្រូកឆ្លើយថា គឺជដិលកោងជាអ្នកស៊ីសាច់ បញ្ជូនខ្លាមកហើយ ។ តច្ឆសូករៈពោលថា បើដូច្នោះ ពួកយើងនាំគ្នាមកចុះ ពួកយើងត្រូវចាប់ជដិលកោងនោះឲ្យបាន ហើយរត់ទៅជាជួរជាមួយជ្រូកទាំងនោះ ។ ជដិលគិតស្មានថា ខ្លាមកយឺត ទន្ទឹងរង់ចាំការមករបស់ខ្លា ឃើញពួកជ្រូកជាច្រើនរត់មកគិតថា ប្រហែលជាជ្រូកទាំងនេះសម្លាប់ខ្លាបានហើយ នាំគ្នារត់មកដើម្បីសម្លាប់អញ ក៏រត់ឡើងដើមល្វាមួយដើម ពួកជ្រូកនាំគ្នាស្រែកថា ជដិលកោងឡើងដើមឈើទៅហើយ តច្ឆសូករៈសួរថា តើដើមឈើអ្វី ពួកជ្រូកក៏ឆ្លើយថា ដើមល្វា តច្ឆសូករៈពោលថា បើយ៉ាងនោះ អ្នកកុំទោមនស្សឡើយ ពួកយើងនឹងចាប់ជដិលកោងបាន ក្នុងកាលឥឡូវនេះឯង ហើយហៅជ្រូកជំទង់ៗ ឲ្យមកនាំគ្នាឈូសដីចេញអំពីគល់ឈើ ឲ្យមេជ្រូកទាំងឡាយទៅបៀមទឹកមក ឲ្យជ្រូកដែលមានខ្នាយធំៗ វែធឫស ដោយជុំវិញ រហូតសល់តែឫសកែវ ដែលចាក់ទៅត្រង់ប៉ុណ្ណោះ បន្ទាប់អំពីនោះក៏ស្រែកប្រាប់ជ្រូកដ៏សេសថា ពួកអ្នកគេចចេញចុះ ហើយលុតជង្គង់យកខ្នាយវែធត្រង់ឫសកែវ ដើមឈើនោះដាច់ទៅដូចកាប់ដោយពូថៅ ដើមឈើនោះក៏រលំ គ្រាន់តែជដិលកោងធ្លាក់មកប៉ុណ្ណោះ ពួកជ្រូកក៏នាំគ្នាចោមរោមស៊ីសាច់ ។ រុក្ខទេវតា ឃើញហេតុអស្ចារ្យនោះ ទើបពោលគាថាដូច្នេះ

ថា

គួរឲ្យសរសើរដែរ ពួកញាតិច្រើនរូប សូម្បីតែឈើដែលដុះក្នុង
ព្រៃ ( ក៏គួរឲ្យសរសើរ ) ខ្លា ( ម្នាក់ឯង ) ត្រូវពួកជ្រូក
ព្រមគ្នា សម្លាប់បានក្នុងផ្លូវតែមួយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកាយនេ ហតោ** សេចក្ដីថា សម្លាប់ខ្លា បាន ព្រោះមានការព្រមព្រៀងគ្នាតែមួយ ។

ព្រះសាស្ដាកាលទ្រង់ប្រកាសភាពដែលជ្រូកទាំងនោះ កម្ចាត់សត្រូវទាំង ពីរបាន ទើបត្រាស់ព្រះគាថាដូច្នេះថា

ជ្រូកទាំងឡាយ បានសម្លាប់នូវព្រាហ្មណ៍និងខ្លាធំទាំងពីរនាក់
បានហើយក៏ត្រេកអររីករាយ ស្រែកនូវសម្រែកដ៏ខ្លាំង ដូច្នេះ ។

តច្ឆសូករៈសួរទៀតថា សត្រូវរបស់ពួកអ្នកដទៃៗនៅមានទៀតឬ ពួក ជ្រូកឆ្លើយថា មិនមានទេលោកម្ចាស់ ក៏សម្រេចថា ពួកយើងត្រូវអភិសេក លោកឲ្យជាព្រះរាជា នាំគ្នាត្រាច់រកទឹក ឃើញស័ង្ខសម្រាប់ដងទឹកផឹករបស់ ជដិល ស័ង្ខនោះជាស័ង្ខទក្ខិណាវដ្ដ គឺវិលទៅស្ដាំ ជាស័ង្ខរតនៈ ទើបដងទឹក មកពេញស័ង្ខ អភិសេកតច្ឆសូករៈត្រង់គល់ល្វានោះឯង ហើយនាំគ្នាឲ្យជ្រូក ញីស្រង់ទឹកអភិសេកជាមហេសី របស់ស្ដេចតច្ឆសូករៈនោះ ចាប់តាំងអំពី កាលនោះ ការអង្គុយលើតាំងធ្វើអំពីដើមល្វា ស្រោចទឹកដោយស័ង្ខទក្ខិណា វដ្ដក៏បានប្រព្រឹត្តបន្តមក ។

ព្រះសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះ ត្រាស់ព្រះគាថាចុងក្រោយថា

ជ្រូកទាំងឡាយនោះ ប្រជុំគ្នាទៀបគល់នៃល្វា អភិសេកជ្រូក ឈ្មោះតច្ឆកៈថា សូមព្រះអង្គជាស្តេច ជាឥស្សរៈរបស់ពួក យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេសុទុម្ពរមូលស្មឹ** បានដល់ ជ្រូកទាំងនោះ ។ **សុ** អក្ខរៈ ត្រឹមតែជានិបាត ។ បទថា **ឧទុម្ពរមូលស្មឹ** បានដល់ ក្បែរគល់ល្វា ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ធនុគ្គហតិស្សត្ថេរ ក៏ឈ្លាសក្នុងការរៀបចំក្បួនចម្បាំង ដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ជដិលកោងក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ តច្ឆសូករៈក្នុងកាលនោះ បានមកជាធនុគ្គហតិស្សត្ថេរ ចំណែករុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តច្ឆសូករជាតក ចប់

# មហាវាណិជជាតក

[ ១១៩ ] ( ព្រះសាស្ដាទ្រង់ត្រាស់ថា ) ពាណិជទាំងឡាយ ជាអ្នកស្វែងរកទ្រព្យមកអំពីដែនផ្សេងៗ ធ្វើនូវការប្រជុំ ( ក្នុងក្រុងពារាណសី ) ធ្វើបុគ្គលម្នាក់ឲ្យជាធំ ហើយចៀសចេញទៅ ។ ពាណិជទាំងឡាយនោះ មកដល់ផ្លូវឆ្ងាយដាច់ស្រយាលនោះ ជាផ្លូវមិនមានស្បៀងអាហារ មិនមានទឹក បានឃើញនូវដើមជ្រៃធំ មានម្លប់ត្រជាក់ ជាទីរីករាយនៃចិត្ត ។ ឯពាណិជទាំងនោះ ជាបុគ្គលល្ងង់ត្រូវមោហៈបិទបាំង ក៏អង្គុយក្រោមម្លប់ឈើនោះ ក្នុងទីនោះ ហើយប្រឹក្សាគ្នាថា យីអើ ឈើនេះ ហាក់ដូចជាសើមដោយទឹក ហាក់ដូចជាមានទឹកហូរទៅ បើដូច្នោះ យើងជាពួកឈ្មួញនឹងកាប់នូវមែកឈើខាងកើត ។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាប់ដាច់ភ្លាម ក៏ស្រក់ទឹកចេញ ឯទឹកក៏ថ្លាមិនល្អក់ ពាណិជទាំងនោះបានងូតផឹក ក្នុងទីនោះ ដរាបដល់អស់ចំណង់ ។ ពួកឈ្មួញពាល ត្រូវមោហៈបិទបាំង ប្រឹក្សានូវហេតុ ទី ២ ថា បើដូច្នោះ ពួកយើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើ ខាងត្បូងនោះទៀត ។ សោតឯមែកឈើនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវបាយនៃស្រូវសាលី ដ៏លាយដោយសាច់ដ៏ច្រើន នូវនំកុម្មាស ហាក់ដូចជាបាយាសមានទឹកតិច នូវសម្លកកូរ និងសម្លសណ្ដែកបាយ ពាណិជទាំងនោះ បានបរិភោគទំពាស៊ីក្នុងទីនោះ ដរាបទាល់អស់ចំណង់ ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សាគ្នានូវហេតុទី ៣ ថា បើដូច្នោះយើងជាពួកឈ្មួញនឹងកាត់មែកឈើខាងលិចនោះទៀត ។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ចេញនូវពួកនាងនារី មានខ្លួនតាក់តែងហើយ

មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមណីនិងកុណ្ឌល ។ គួរសរសើរ ដែរ ពាណិជទាំងឡាយមាននាងនារីម្នាក់ៗ ចំណែកខាងនាងនារី ២៥ នាក់ ចោមរោម ( នូវនាយឈ្មួញជាធំ ) ខាងក្រោមម្លប់ឈើនោះដោយជុំវិញ ពាណិជទាំងនោះ ត្រូវនាងនារីទាំងនោះចោមរោមហើយ ដរាបអស់ចំណាំ ។ ពួកពាណិជល្ងង់ ត្រូវមោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៤ ថា បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងជើងនោះទៀត ។ សោតឯមែក នោះគ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវកែវមុក្តា និងកែវពៃ ទូរ្យដ៏ច្រើនផង នូវប្រាក់ផង នូវមាសផង នូវកម្រាលសម្រាប់ក្រាលលើខ្នង ដំរីជាដើមផង នូវកម្រាលរោមសត្វជាដើមផង នូវសំពត់ដែលគេធ្វើក្នុងដែន កាសីផង នូវសំពត់កម្ពលឈ្មោះឧទ្ទិយានៈផង ពាណិជទាំងនោះ ក៏វេចយក នូវភារៈ ដរាបទាល់អស់ចំណាំក្នុងទីនោះ ។ ពួកពាណិជល្ងង់ដែលត្រូវ មោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៥ ថា បើដូច្នោះ ពួកយើងនឹងកាត់ ត្រង់គល់ឈើនោះ មុខជានឹងបានច្រើនជាងនេះទៅទៀត គ្រានោះឈ្មួញជាធំ ក្រោកឡើងផ្គងអញ្ជលីអង្វរថា ដើមជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពា-ណិជទាំងឡាយ សេចក្តីចម្រើនចូរមានដល់អ្នកចុះ ។ មែកខាងកើត បានឲ្យ ទឹកផ្លូតផង មែកខាងត្បូងបានឲ្យបាយនិងទឹកផង មែកខាងលិចបានឲ្យនាង នារីទាំងឡាយផង មែកខាងជើងបានឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងផង ដើម ជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចម្រើនចូរមាន ដល់អ្នកចុះ ។

បុគ្គលអង្គុយ ឬដេកក្រោមម្លប់នៃឈើណា មិនត្រូវកាច់បំបាក់មែកឈើនោះឡើយ ព្រោះថាបុគ្គលអ្នកប្រទូស្តមិត្ត ជាមនុស្សអាក្រក់ ។ ឯឈ្មួញទាំងនោះច្រើនគ្នា មិនអើពើនូវពាក្យនៃឈ្មួញជាធំម្នាក់ឯងនោះ ក៏ចូលទៅដើម្បីនឹងកាត់នូវដើមជ្រៃនោះត្រង់គល់ដោយប៉ូវថៅទាំងឡាយដែលខ្លួនសំលៀងហើយ។

[ ១២០ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ នាគទាំងឡាយ ២៥ សៀតគ្រឿងក្រោះហើយផង ពួកនាគខ្មាន់ធ្នូ ៣០០ ផង ពួកទាហានកាន់ខែលប្រាំមួយពាន់ផង ក៏ចេញមក ។

[ ១២១ ] ( នាគរាជ... ) អ្នកទាំងឡាយ ចូរសម្លាប់ ចូរចងនូវពាណិជទាំងនុ៎ះ អ្នកទាំងឡាយកុំលែងនូវជីវិតឡើយ អ្នកទាំងឡាយចូរធ្វើនូវពួកពាណិជទាំងអស់នោះឲ្យទៅជាផេះ ទុកតែពាណិជជាធំម្នាក់ប៉ុណ្ណោះ ។

[ ១២២ ] ( អភិសម្ពុទ្ធគាថា ) ព្រោះហេតុនោះ បណ្ឌិតបុរស កាលបើបានឃើញច្បាស់នូវប្រយោជន៍ របស់ខ្លួន មិនគប្បីលុះអំណាច នៃលោភៈឡើយ ត្រូវតែកម្ចាត់បង់នូវចិត្ត ដែលប្រកបដោយលោភៈប្រាកដដូច្នោះ ភិក្ខុបើបានដឹងនូវទោស ( ក្នុងលោភៈ ) យ៉ាងនេះ ដឹងនូវការកើតឡើងនៃទុក្ខព្រោះតណ្ហាយ៉ាងនេះហើយ គប្បីប្រព្រឹត្តជាអ្នកមានតណ្ហាទៅប្រាសហើយ មិនមានសេចក្តីប្រកាន់មាំ មានស្មារតី ។

**ចប់ មហាវាណិជជាតកទី ១០**

# អដ្ឋកថា
# មហាវាណិជជាតក

[ ១១៩-១២២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកឈ្មួញអ្នកនគរសាវត្ថី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វាណិជា សមិតឹ កត្វា** ដូច្នេះជាដើម ។

រឿងមានសេចក្តីថា ឈ្មួញទាំងនោះមានការទៅជួញដូរ ថ្វាយមហាទានដល់ព្រះសាស្តា តាំងមាំក្នុងសរណៈនិងសីល ក្រាបទូលថា បពិត្រព្រះអង្គ បើពួកខ្ញុំព្រះអង្គមិនមានរោគ ត្រឡប់មកបាន នឹងសូមថ្វាយបង្គំយុគលបាទរបស់ព្រះអង្គម្តងទៀត ចេញដំណើរទៅជាមួយរទេះ ៥០០ ដល់ផ្លូវកន្តារកំណត់ផ្លូវមិនបាន ហួសផ្លូវកន្តារចូលដល់ក្នុងព្រៃ ដាច់ទឹកដាច់អាហារ ឃើញដើមជ្រៃដែលនាគគ្រប់គ្រងមួយដើម ក៏នាំគ្នាដាក់រទេះ អង្គុយត្រង់គល់ឈើនោះ ។ ជនទាំងនោះឃើញដើមជ្រៃខៀវស្រងាត់ដូចដើមរំទឹក មែកជ្រៃសោតក៏ដូចឆ្អែតដោយទឹក គិតគ្នាថា ក្នុងដើមឈើនេះប្រាកដជាមានទឹក ពួកយើងកាត់មែកទិសខាងកើត របស់ដើមឈើនេះ ដើម្បីបានទឹកផឹក ពោលហើយបុរសម្នាក់ក៏ឡើងកាត់មែក ។ ធារទឹកប៉ុនដើមត្នោតក៏បានហូរចុះមក ជនទាំងនោះនាំគ្នាងូតនិងផឹកក្នុងទីនោះ ហើយនាំគ្នាកាប់មែកខាងត្បូង ភោជនមានរសផ្សេងៗក៏ធ្លាក់ចុះមកអំពីមែកនោះ ។ ឈ្មួញទាំងនោះនាំគ្នាបរិភោគ ហើយកាប់មែកទិសខាងលិច ពួកស្ត្រីដែលតាក់តែងកាយហើយ នាំគ្នាចេញមកអំពីមែកនោះ ។ ឈ្មួញទាំងនោះនាំគ្នាអភិរម្យជាមួយស្រីនោះ ហើយកាប់

មែកទិសខាងជើង កែវ ៧ ប្រការក៏ហូរចុះមកអំពីមែកនោះ ។ ឈ្មួញទាំងនោះនាំគ្នារើសកែវទាំងនោះ ដាក់ពេញរទេះទាំង ៥០០ ត្រឡប់មកគនរសាវត្ថី ទុកដាក់ទ្រព្យហើយ នាំគ្នាកាន់យកគ្រឿងក្រអូបនិងមាលាជាដើមទៅកាន់វិហារជេតពន ថ្វាយបង្គំព្រះសាស្តាបូជាហើយ អង្គុយក្នុងចំណែកម្ខាងស្តាប់ធម្មកថាហើយ ទូលនិមន្តថ្វាយមហាទានក្នុងថ្ងៃស្អែក នាំគ្នាឲ្យចំណែកបុណ្យថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គសូមឲ្យចំណែកបុណ្យក្នុងទាននេះដល់រុក្ខទេវតាដែលឲ្យទ្រព្យដល់ពួកខ្ញុំ ។ ព្រះសាស្តាទ្រង់ឆាន់ស្រេចហើយត្រាស់សួរថា ពួកអ្នកឲ្យចំណែកបុណ្យដល់រុក្ខទេវតាអង្គណា ពួកឈ្មួញនាំគ្នាក្រាបទូលហេតុដែលពួកខ្លួនបានទ្រព្យក្នុងដើមជ្រៃដល់ព្រះតថាគត ។ ព្រះសាស្តាត្រាស់ថា ពួកអ្នកមិនបានលុះអំណាចតណ្ហា ព្រោះជាអ្នកស្គាល់ប្រមាណទើបបានទ្រព្យ តែក្នុងកាលមុន ពួកជនដែលលុះអំណាចតណ្ហា ព្រោះមិនស្គាល់ប្រមាណ នាំគ្នាលះបង់ទាំងទ្រព្យនិងជីវិត ឈ្មួញទាំងនោះ នាំគ្នាក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ផ្លូវកន្តារនោះឯង ដើមជ្រៃនោះឯង តែនគរឈ្មោះថាពារាណសី ឈ្មួញវង្វេងផ្លូវជួបដើមជ្រៃនោះដូចគ្នា ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទ្រង់សម្តែងសេចក្តីនោះទើបត្រាស់ព្រះគាថាទាំងឡាយថា

ពាណិជទាំងឡាយ ជាអ្នកស្វែងរកទ្រព្យមកអំពីដែនផ្សេងៗ

ធ្វើនូវការប្រជុំ ( ក្នុងក្រុងពារាណសី ) ធ្វើបុគ្គលម្នាក់ឲ្យជាធំ

ហើយចៀសចេញទៅ ។ ពាណិជទាំងឡាយនោះ មកដល់ផ្លូវឆ្ងាយដាច់ស្រយាលនោះ ជាផ្លូវមិនមានស្បៀងអាហារ មិនមានទឹក បានឃើញនូវដើមជ្រៃធំ មានម្លប់ត្រជាក់ ជាទីរីករាយនៃចិត្ត ។ ឯពាណិជទាំងនោះជាបុគ្គលល្ងង់ត្រូវមោហៈបិទបាំង ក៏អង្គុយក្រោមម្លប់ឈើ នោះក្នុងទីនោះ ហើយប្រឹក្សាគ្នាថា យីអើ ឈើនេះហាក់ដូចជាសើមដោយទឹក ហាក់ដូចជាមានទឹកហូរទៅ បើដូច្នោះ យើងជាពួកឈ្មួញនឹងកាប់នូវមែកឈើខាងកើត ។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាប់ដាច់ភ្លាម ក៏ស្រក់ទឹកចេញ ឯទឹកក៏ថ្លាមិនល្អក់ ពាណិជទាំងនោះបានងូតផឹកក្នុងទីនោះ ដរាបដល់អស់ចំណង់ ។ ពួកឈ្មួញពាល ត្រូវមោហៈបិទបាំង ប្រឹក្សានូវហេតុទី ២ ថា បើដូច្នោះ ពួកយើងជាពួកឈ្មួញនឹងកាត់នូវមែកឈើ ខាងត្បូងនោះទៀត ។ សោតឯមែកឈើនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវបាយនៃស្រូវសាលីដ៏លាយដោយសាច់ដ៏ច្រើន នូវនំកុម្មាស ហាក់ដូចជាបាយាសមានទឹកតិចនូវសម្លកក្កូរនិងសម្លសណ្តែកបាយ ពាណិជទាំងនោះ បានបរិភោគទំពាស៊ីក្នុងទីនោះ ដរាបទាល់អស់ចំណង់ ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សាគ្នានូវហេតុទី ៣ ថា បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាត់មែកឈើខាងលិច

នោះទៀត ។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ចេញនូវពួកនាងនារី មានខ្លួនតាក់តែងហើយ មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមណីនិងកុណ្ឌល ។ គួរសរសើរដែរ ពាណិជទាំងឡាយមាននាងនារីម្នាក់ៗ ចំណែកខាងនាងនារី ២៥ នាក់ ចោមរោម ( នូវនាយឈ្មួញជាធំ ) ខាងក្រោមម្លប់ឈើនោះដោយជុំវិញ ពាណិជទាំងនោះ ត្រូវនាងនារីទាំងនោះ ចោមរោមហើយ ដរាបអស់ចំណាំ ។ ពួកពាណិជល្ងង់ត្រូវ មោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៤ ថា បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងជើងនោះទៀត ។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវកែវមុក្តា និងកែវពៃទូរ្យដ៏ច្រើនផងនូវប្រាក់ផង នូវមាសផង នូវកម្រាលសម្រាប់ក្រាលលើខ្នងដំរីជាដើមផង នូវកម្រាលរោមសត្វជាដើមផង នូវសំពត់ដែលគេធ្វើក្នុងដែនកាសីផង នូវសំពត់កម្ពលឈ្មោះឧទ្ទិយានៈផង ពាណិជទាំងនោះក៏វេចយកនូវភារៈដរាបទាល់អស់ចំណាំក្នុងទីនោះ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៥ ថា បើដូច្នោះ ពួកយើងនឹងកាត់ត្រង់គល់ឈើនោះ មុខជានឹងបានច្រើនជាងនេះទៅទៀត គ្រានោះឈ្មួញជាធំ ក្រោកឡើងផ្គងអញ្ជលីអង្វរថា ដើមជ្រៃ ប្រទូស្តពួកអ្នកដូចម្តេច

ម្នាលពាណិជទាំងឡាយ សេចក្តីចម្រើនចូរមានដល់អ្នកចុះ ។ មែកខាងកើត បានឲ្យទឹកផ្លូតផង មែកខាងត្បូង បានឲ្យបាយនិងទឹកផង មែកខាងលិច បានឲ្យនាងនារីទាំងឡាយផង មែកខាងជើង បានឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងផង ដើមជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចម្រើន ចូរមានដល់អ្នកចុះ ។

បុគ្គលអង្គុយ ឬដេកក្រោមម្លប់នៃឈើណា មិនត្រូវកាច់បំបាក់ មែកឈើនោះឡើយ ព្រោះថាបុគ្គលអ្នកប្រទូស្តមិត្តជាមនុស្សអាក្រក់ ។ ឯឈ្មួញទាំងនោះច្រើនគ្នា មិនអើពើនូវពាក្យនៃឈ្មួញជាធំម្នាក់ឯងនោះក៏ចូលទៅដើម្បីនឹងកាត់នូវដើមជ្រៃនោះ ត្រង់គល់ ដោយប៉ូវថៅទាំងឡាយដែលខ្លួនសំលៀងហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមិតិ កត្វា** សេចក្តីថា ចាត់ជាសមាគមគឺច្រើននាក់រួមគ្នាតែមួយ ក្នុងនគរពារាណសី ។ បទថា **បណ្ណមឹសុ** សេចក្តីថា ផ្ទុកទ្រព្យដែលមានក្នុងនគរពារាណសី ដោយរទេះ ៥០០ ធ្វើដំណើរទៅ ។ បទថា **គាមណឹ** សេចក្តីថា តាំងបុគ្គលអ្នកមានបញ្ញាម្នាក់ឲ្យជាធំក្នុងក្រុមរទេះ ។ បទថា **ជាតិយា** បានដល់ ត្រង់ម្លប់ ។ បទថា **អល្លាយតេ** បានដល់ ប្រាកដដូចពេញដោយទឹក ។ បទថា **ជិន្នាវ បតស្សិ** ព្រះសាស្តាទ្រង់សម្តែងថា អ្នកឈ្លាសក្នុងការឡើងដើមឈើម្នាក់ ឡើងទៅកាប់មែកនោះគ្រាន់

តែមែកនោះដាច់ ទឹកថ្លាក៏ហូរចុះមក សូម្បីខាងមុខក៏មានន័យដូចគ្នា ។ បទថា **អប្បោទវណ្ណា កុម្មាសេ** បានដល់ នំកុម្មាសដែលដូចគ្នានឹងបាយាសដែលមានទឹកតិច ។ បទថា **សិង្គិ** បានដល់ សម្លខ្ញីដែលដាក់ខ្ញីជាដើម ។ បទថា **វិធលសូបិយោ** បានដល់ សម្លសណ្ដែកបាយជាដើម ។ បទថា **វាណិជា ឯកកា** គឺដល់ឈ្មួញម្នាក់ៗ ឈ្មួញមានចំនួនប៉ុណ្ណា ក្នុងចំនួននោះ ម្នាក់បានស្រីមួយ តែនាយរទេះ បាន ២៥ នាក់ ។ បទថា **បរិការីសុ** សេចក្ដីថា បោមរោមដោយស្រីទាំងនោះ មានពិដានទិនទីដេកជាដើមហូរមកដោយអានុភាពស្ដេចនាគ ។ បទថា **កុត្តិយោ** បានដល់ ស្រោមដៃជាដើម ។ បទថា **បដិយានិ ច** បានដល់ កម្រាលមានកម្រាលដែលសម្រេចដោយរោមកែះជាដើម ។ អាចារ្យពួកខ្លះពោលថា សំពត់កម្ពលពណ៌សក៏មាន ។ បទថា **ឧទ្ទិយានិ ច កម្ពលា** បានដល់ សំពត់កម្ពលដែលឈ្មោះថាឧទ្ទិយានៈ ក៏មាន ។ បទថា **តេ តត្ថ ភារេ ពន្ធិត្វា** សេចក្ដីថា ត្រូវការប៉ុណ្ណា ក៏ដព្វនយកក្នុងទីនោះប៉ុណ្ណោះ ដាក់ពេញរទេះទាំង ៥០០ ។ បទថា **វាណិជា ភទ្ទមត្ថុ តេ** សេចក្ដីថា នាយឈ្មួញរទេះ ហៅឈ្មួញតែម្នាក់ ទើបពោលថា សេចក្ដីចម្រើនចូរមានដល់អ្នកចុះ ។ បទថា **អន្នបានញ្ច** សេចក្ដីថា បានឲ្យនូវបាយនិងទឹក ។ បទថា **សព្វកាមេ ច** សេចក្ដីថា បានឲ្យវត្ថុដែលគួរប្រាថ្នាទាំងពួង ។ បទថា **មិត្តទុព្ភោ** សេចក្ដីថា ព្រោះថា បុគ្គលទម្លាយមិត្តទាំងឡាយ គឺបុរសប្រទូស្តចំពោះមិត្តទាំងឡាយ ឈ្មោះថាជាបុគ្គលអាក្រក់ក្រៃលែង ។ បទថា **អនាទិត្វា** សេចក្ដីថា មិនកាន់យក គឺមិនជឿ

ពាក្យរបស់នាយឈ្មួញរទេះនោះ ។ បទថា **ឧបក្ខម្ភំ** សេចក្ដីថា ត្រៀមនឹងរម្ងំ គឺផ្ដើមនឹងកាប់ព្រោះសេចក្ដីវង្វេង ។

កាលនោះស្ដេចនាគ ឃើញឈ្មួញទាំងនោះនាំគ្នាចូលទៅក្បែរដើមឈើ ដើម្បីកាប់ក៏ត្រិះរិះថា អញបណ្ដាលទឹកដល់ជនទាំងនេះកំពុងស្រេក បន្ទាប់មកឲ្យភោជនដែលជាទិព្វ មិនស្កប់ស្កល់ ថែមទាំងឲ្យនូវទីដេកនិងស្រីបម្រើដល់ជនទាំងនេះ បន្ទាប់អំពីនោះ ក៏ឲ្យនូវរតនៈពេញរទេះ ៥០០ តែឥឡូវនេះ ជនទាំងនេះនិយាយគ្នាថា នឹងកាប់ដើមឈើត្រង់គល់ ជាមនុស្សលោភលន់ក្រៃពេក អញគួរសម្លាប់ជនទាំងនេះឲ្យអស់ វៀរលែងតែនាយរទេះម្នាក់ ។ ស្ដេចនាគនោះ ទើបត្រៀមសេនាបញ្ជាថា ពួកទាហានដែលពាក់ដោយក្រោះចំនួនប៉ុណ្ណេះចូរចេញទៅ ទាហានធ្នូចំនួនប៉ុណ្ណេះចូរចេញទៅ ទាហានខែលចំនួនប៉ុណ្ណេះ ចូរចេញទៅ ។

ព្រះសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ព្រះគាថានេះថា

លំដាប់នោះ នាគទាំងឡាយ ២៥ សៀតគ្រឿងក្រោះហើយ
ផង ពួកនាគខ្មាន់ធ្នូ ៣០០ ផង ពួកទាហានកាន់ខែលប្រាំមួយ
ពាន់ផង ក៏ចេញមក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សន្នទ្ធា** បានដល់ ពួកជនដែលស្រោបខ្លួនដោយក្រោះស្បែក ប្រដាប់ដោយមាសនិងកែវជាដើម ។ បទថា **ធនុគ្គហា-ធំ តិសតា** សេចក្ដីថា ពួកទាហានកាន់ធ្នូ ដែលធ្វើដោយស្នែងកែះ មានប្រមាណ ៣០០ នាក់ ។ បទថា **ចម្មិនោ** គឺពួកទាហានដែលកាន់ខែលធ្វើ

ដោយស្បែក មានប្រមាណ ៦ ពាន់នាក់ ។

ស្តេចនាគពោលបញ្ជាថា

អ្នកទាំងឡាយ ចូរសម្លាប់ ចូរចងនូវពាណិជទាំងនុ៎ះ អ្នកទាំងឡាយ កុំលែងនូវជីវិតឡើយ អ្នកទាំងឡាយ ចូរធ្វើនូវពួកពាណិជទាំងអស់នោះឲ្យទៅជាផេះ ទុកតែពាណិជជាធំ ម្នាក់ប៉ុណ្ណោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា វោ មុញ្ចិត្ថ ជីវិតំ** សេចក្តីថា អ្នកទាំងឡាយ កុំលែងជីវិតដល់អ្នកណា សូម្បីតែម្នាក់ឡើយ ។

នាគទាំងឡាយធ្វើតាមនោះ ហើយជញ្ជូនយកទ្រព្យ មានកម្រាលដែលល្អៗ ជាដើមដាក់រទេះ ៥០០ នាំឈ្នួញរទេះជាធំបររទេះទាំងនោះ មកកាន់ក្រុងពារាណសី ទុកទ្រព្យទាំងពួងក្នុងរទេះរបស់ព្រះពោធិសត្វហើយ នាំគ្នាលាទៅកាន់នាគពិភពវិញ ។

ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីនោះ ទើបត្រាស់អភិសម្ពុទ្ធគាថាថា

ព្រោះហេតុនោះ បណ្ឌិតបុរស កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន មិនគប្បីលុះអំណាចនៃលោភៈឡើយត្រូវតែកម្ចាត់បង់នូវចិត្ត ដែលប្រកបដោយលោភៈ ប្រាកដដូច្នោះ ភិក្ខុបើបានដឹងនូវទោស ( ក្នុងលោភៈ ) យ៉ាងនេះ ដឹងនូវការកើតឡើងនៃទុក្ខ ព្រោះតណ្ហា យ៉ាងនេះហើយគប្បីប្រព្រឹត្តជា អ្នកមានតណ្ហាទៅប្រាសហើយ មិនមានសេចក្តីប្រកាន់មាំ

មានស្មារតី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តស្មា** សេចក្ដីថា ព្រោះហេតុដែលឈ្លួញលុះក្នុងអំណាចលោភ នាំគ្នាដល់នូវការវិករវរធំ អធិប្បាយថា នាយឈ្មួញរទេះសម្រេចសម្បត្តិដ៏ឧត្ដម ។ បទថា **ហានេយ្យ ឥសកំ មនំ** សេចក្ដីថា បណ្ឌិតគប្បីកម្ចាត់ចិត្តដែលមានសត្រូវគឺលោភៈ ដែលមានប្រការផ្សេងៗ ដែលកើតឡើងដល់ខ្លួន គឺគប្បីកម្ចាត់ចិត្តដែលប្រកបដោយលោភៈ ។ បទថា **ឯវមាទីនវំ** សេចក្ដីថា ជ្រាបនូវទោសក្នុងសេចក្ដីលោភយ៉ាងនេះហើយ ។ បទថា **តណ្ហា ទុក្ខស្ស សម្ភវំ** សេចក្ដីថា ជ្រាបថា តណ្ហានោះជាហេតុ កើតព្រមនៃទុក្ខ មានជាតិជាដើម គឺទុក្ខនោះកើតហើយយ៉ាងនេះ ព្រោះតណ្ហានោះ តណ្ហានោះជាហេតុកើតនៃទុក្ខយ៉ាងនេះ បុគ្គលឃើញភ័យដឹងហើយ គប្បីវៀកដោយសតិ ដែលមកហើយដោយមគ្គ ជាបុគ្គលប្រាសចាកតណ្ហា មិនមានការប្រកាន់មាំ ។ បទថា **បរិព្វជេ** សេចក្ដីថា គប្បីប្រព្រឹត្ត ។ ព្រះសាស្ដាទ្រង់កាន់យកកំពូលនៃទេសនា ដោយអរហត្ត ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយត្រាស់ថា ម្នាលឧ-បាសកទាំងឡាយ ពួកឈ្មួញដែលលុះអំណាចសេចក្ដីលោភ នាំគ្នាដល់នូវសេចក្ដីវិនាសធំក្រៃលែង ក្នុងកាលមុនយ៉ាងនេះ ព្រោះហេតុនោះ អ្នកទាំង

ឡាយ កុំជាបុគ្គលលុះក្នុងអំណាចលោភៈឡើយ ហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ( កាលចប់សច្ចៈ ឈ្មួញទាំងនោះតាំងនៅក្នុងសោតាបត្តិផល ) ហើយទ្រង់ប្រជុំជាតកថា ស្តេចនាគក្នុងកាលនោះបានមកជាសារីបុត្តក្នុងកាលឥឡូវនេះ ចំណែកនាយឈ្មួញរទេះក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មហាវាណិជជាតក ចប់

# សាធិនរាជជាតក

[ ១២៣ ] ( ពួកអ្នកនគរពោលថាស្តេចរបស់យើង ) ចម្លែកណាស់តើ គួរឲ្យព្រឺរោមកើតឡើងក្នុងលោក រថជាទិព្វបានកើតប្រាកដដល់ស្តេចវិទេហៈ ព្រះអង្គមានយស ។

[ ១២៤ ] ( អភិសម្ពុទ្ធគាថា ) ទេវបុត្តឈ្មោះមាតលី ជាទេវសារថី មានឫទ្ធិច្រើន បានអញ្ជើញព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលាថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងឡើងកាន់រថនេះ ទេវតាទាំងឡាយ ជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្រ្ទ ចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយ រឭកព្រះអង្គ នៅរង់ចាំក្នុងរោងឈ្មោះសុធម្មា ។ លំដាប់នោះឯង ព្រះបាទវិទេហៈ ព្រះនាមសាធិន ព្រះអង្គគ្រប់គ្រងក្រុងមិថិលាទ្រង់យាងឡើងកាន់រថ ទឹមដោយសេះច្រើន ហើយបានយាងទៅក្នុងសំណាក់នៃទេវតាទាំងឡាយ ( ព្រះរាជាជាធំទ្រង់ប្រថាប់លើទិព្វយានឈ្មោះហយវាហីដែលទឹមដោយសេះច្រើនកំពុងយាងទៅក៏បានទតឃើញទេវសភានេះ ) ពួកទេវតាបានឃើញព្រះរាជានោះមកដល់ហើយក៏ត្រេកអរស្មោះចំពោះថា បពិត្រមហារាជ ព្រះអង្គយាងមកស្រួលហើយ មិនមែនយាងមកដោយមិនស្រួលទេ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គទ្រង់គង់ក្នុងសំណាក់នៃទេវរាជចុះ ។

ឯព្រះឥន្រ្ទក៏ទទួលរាក់ទាក់ចំពោះព្រះបាទវិទេហៈ ព្រះអង្គគ្រប់
គ្រងក្រុងមិថិលា ព្រះឥន្រ្ទបានអញ្ជើញដោយកាមទាំងឡាយ
ផង ដោយអាសនៈផងថា ប្រពៃណាស់ហើយ ព្រះអង្គបាន

ដល់អាវាសរបស់ទេវតាទាំងឡាយ ដែលញ៉ាំងគេឲ្យប្រព្រឹត្ត ក្នុងអំណាចខ្លួន បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរសូម ព្រះអង្គគង់នៅក្នុងពួកទេវតា ដែលសម្រេចនូវកាមគ្រប់យ៉ាង បាន សូមព្រះអង្គសោយនូវកាមទាំងឡាយ ដែលមិនមែនជា របស់មនុស្សក្នុងពួកទេវតាជាន់តាវត្តិង្សចុះ ។

[ ១២៥ ] ( ព្រះបាទសាធិនរាជ... ) កាលពីដើម ខ្ញុំមកនៅក្នុងឋាន សួគ៌រីករាយដោយរបាំចម្រៀងនិងប្រគំទាំងឡាយ ឥឡូវនេះ ក្នុងថ្ងៃនេះ ខ្ញុំមិន ត្រេកអរក្នុងឋានសួគ៌ទេ បពិត្រព្រះជនិន្ទដ៏ប្រសើរ អាយុ ( របស់ខ្ញុំ ) នឹង អស់ឬ ឬសេចក្ដីស្លាប់ ( ឋិតនៅ ) ក្នុងទីជិត ឬក៏ខ្ញុំជាបុគ្គលវង្វេង ។

[ ១២៦ ] ( សក្ក... ) បពិត្រព្រះអង្គដ៏ប្រសើរ មានព្យាយាមជាងជន អាយុរបស់ព្រះអង្គមិនទាន់អស់ទេ ទាំងសេចក្ដីស្លាប់របស់ព្រះអង្គ ( ក៏ឋិត នៅ ) ក្នុងទីឆ្ងាយ មួយវិញទៀត ព្រះអង្គមិនមែនជាមនុស្សវង្វេងទេ តែជា ព្រះអង្គ សោយនូវផលនៃបុណ្យណា ក្នុងទេវលោកនេះ បុណ្យរបស់ព្រះ អង្គនោះតិច បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គគង់នៅ ដោយទេវានុភាពចុះ សូមព្រះអង្គសោយនូវកាមទាំងឡាយមិនមែនជារបស់ មនុស្សក្នុងទេវលោកជាន់តាវត្តិង្សចុះ ។

[ ១២៧ ] ( ព្រះរាជា... ) យានដែលខ្ចីគេ និងទ្រព្យដែលខ្ចីគេ មាន ឧបមាយ៉ាងណាមិញ ទ្រព្យណាដែលគេបានព្រោះបុគ្គលដទៃឲ្យជាបច្ច័យទ្រព្យ នុ៎ះឯង ក៏មានឧបមេយ្យយ៉ាងនោះដែរ ទ្រព្យណាដែលគេបាន ព្រោះបុគ្គល

ដទៃឲ្យជាបច្ច័យ ខ្ញុំមិនចង់បានទ្រព្យនុ៎ះឡើយ បុណ្យទាំងឡាយដែលខ្ញុំបានធ្វើហើយ ដោយខ្លួនឯង បុណ្យនោះទុកជាទ្រព្យរបស់ខ្ញុំជាប់តាមខ្លួន ខ្ញុំនោះនឹងទៅធ្វើកុសលឲ្យច្រើនក្នុងពួកមនុស្ស ដោយឲ្យទានផង កិរិយាប្រព្រឹត្តិធម៌ស្មើផង កិរិយាសង្រួមដោយសីលផង កិរិយាទូន្មានទូវឥន្ទ្រិយផង ព្រោះថាបុគ្គលធ្វើកុសលហើយ រមែងដល់នូវសេចក្តីសុខ ទាំងមិនក្តៅក្រហាយរឿយៗក្នុងកាលជាខាងក្រោយ ។

[ ១២៨ ] ( សាធិនរាជពោលនឹងស្តេចនារទៈថា ) ស្រែទាំងឡាយនេះផង ទទឹកប្រកបដោយកុណ្ឌលដ៏ល្អនេះផង ផែនដីដ៏ដេរដាសដោយស្មៅពណ៌ខៀវនេះផង ស្ទឹងទាំងឡាយដែលកំពុងហូរនេះផង ស្រះបោក្ខរណីទាំងឡាយជាទីរីករាយ មានសត្វចាកក្រពាកយំហើយ ដ៏ដេរដាសដោយចន្ទលណីដោយផ្កាឈូកនិងផ្កាឧប្បលនេះផង ពួកជនណា រាប់អានទូវទីទាំងឡាយនេះថាជារបស់អញ ជនទាំងនោះ ទៅកាន់ទិសណាហ្ន៎ ។

ម្នាលនារទៈ ស្រែទាំងឡាយ នៅជាស្រែទាំងនោះដដែល ភូមិ
ភាគនៅជាភូមិភាគនោះដដែល ឧបចារៈនៃសួនច្បារទាំងឡាយ
ក៏នៅជាឧបចារៈនោះដដែល តែថាកាលយើងមិនឃើញនូវជន
ទាំងនោះ ទិសប្រាកដដល់យើងហាក់ដូចជាសូន្យឈឹង ។

[ ១២៩ ] ( ព្រះរាជា... ) វិមានទាំងឡាយ ញ៉ាំងទិសទាំង ៤ ឲ្យភ្លឺចិញ្ចែងចំពោះមុខទេវរាជផង ចំពោះមុខពួកទេវតាជាន់ត្រៃត្រិង្សផង យើងបានឃើញហើយ ។ ភពជាទិព្វយើងបាននៅរួចហើយ កាមទាំងឡាយ មិនមែន

ជារបស់មនុស្ស យើងបានបរិភោគរួចហើយក្នុងពួកទេវតាជាន់តាវត្តិង្ស អាច សម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន ។ យើងនោះបានលះបង់សម្បត្តិទិព្វ ប្រាកដដូច្នោះ ហើយមកក្នុងទីនេះ ដើម្បីធ្វើបុណ្យ យើងនឹងប្រព្រឹត្តធម៌តែ ម្យ៉ាង យើងមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិទេ ។ ព្រះពុទ្ធទាំងឡាយ ដែលមានវត្តល្អ ស្តេចយាងទៅតាមផ្លូវណា យើងនឹងដើរទៅតាមផ្លូវនោះ ដែលព្រះសម្មាសម្ពុទ្ធសំដែងហើយ ជាផ្លូវដែលបុគ្គលមិនមានអាជ្ញាគប្បីត្រាច់ ទៅ ។

## ចប់សាធិនរាជជាតកទី ១១ ។

# អដ្ឋកថា

# សាធិនជាតក

[ ១២៣-១២៩ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកឧបាសករក្សាឧបោសថ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អព្ភុតោ វត លោកស្មិំ** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ក្នុងកាលនោះព្រះសាស្តាត្រាស់ថា ម្នាលឧបាសកទាំងឡាយ បណ្ឌិតក្នុងកាលមុនអាស្រ័យឧបោសថកម្មរបស់ខ្លួន ទៅកាន់ទេវលោកអស់កាលយូរដោយសរីរៈនៃមនុស្សនោះឯង ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាទ្រង់ព្រះនាមថាសាធិនៈ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ក្នុងនគរមិថិលា ទ្រង់បានសាងរោងទាន ៦ កន្លែងគឺត្រង់ទ្វារនគរទាំង ៤ ត្រង់កណ្តាលព្រះនគរ ១ ត្រង់ទ្វារព្រះរាជនិវេសន៍ ១ ទ្រង់បំពេញមហាទានធ្វើជម្ពូទ្វីបឲ្យមាននន្ទុលលើកឡើងហើយ ព្រះរាជទានទ្រព្យប្រមាណ ៦ សែន កហាបណៈ ជារាជទ្រព្យដែលទ្រង់ចំណាយរាល់ៗថ្ងៃ ទ្រង់រក្សាសីល ៥ និងឧបោសថសីល ។ ពួកអ្នកដែន ក៏នាំគ្នាតាំងនៅក្នុងឱវាទរបស់ទ្រង់ ធ្វើបុណ្យមានឲ្យទានជាដើម ស្លាប់ហើយទៅកើតក្នុងទេវលោកទាំងអស់ពួកទេវតានាំគ្នាពេញណែនទេវសភាឈ្មោះសុធម្មា នាំគ្នាពណ៌នាគុណ មានសីលជាដើម របស់ព្រះរាជាប៉ុណ្ណោះ ទេវតាដ៏សេស ស្តាប់រឿងនោះហើយប្រាថ្នានឹងឃើញព្រះរាជាដូចៗគ្នា ។ សក្កទេវរាជ ទ្រង់ជ្រាបវារចិត្តរបស់ទេវតាទាំងនោះត្រាស់ថា ពួកអ្នកប្រាថ្នានឹងឃើញព្រះបាទសាធិនរាជឬ ពួកទេវតា

ក្រាបទូលថា ករុណាថ្ងៃវិសេស ។ សក្កៈក៏ត្រាស់នឹងមាតលីទេវបុត្តថា ចូរអ្នកត្រៀមវេជយន្តរថទទួលព្រះបាទសាធិនរាជមក មាតលិទេវបុត្តទទួលទេវបញ្ជាថា សាធុ ហើយរៀបចំរថទៅកាន់ដែនវិទេហៈ ។ កាលនោះជាថ្ងៃ ១៥ កើត ពេលដែលពួកមនុស្សកំពុងបរិភោគអាហារល្ងាច ហើយអង្គុយសន្ទនាគ្នាដោយសុខកថាត្រង់ទ្វារផ្ទះ មាតលិទេវបុត្ត ក៏បររថ មួយអន្ទើដោយចន្ទមណ្ឌល ។ ពួកជននាំគ្នាពោលថា ព្រះចន្ទរះឡើងពីរ តែកាលឃើញរថ និងចន្ទមណ្ឌលហោះមក នាំគ្នាគ្រេកអរថា នេះមិនមែនព្រះចន្ទនេះជារថ ទាំងទេវបុត្តក៏ប្រាកដ រថទិព្វដែលទឹមដោយសេះសិន្ធព្វ មនោម័យនេះ មកទទួលអ្នកណា មិនមានអ្នកដទៃឡើយ ពិតជាព្រះរាជារបស់ពួកយើង ព្រោះថា ព្រះរាជារបស់ពួកយើងទ្រទ្រង់នូវធម៌ ជាធម្មរាជា ហើយក៏ឈរផ្គងអញ្ជលីពោលគាថាជាបឋមថា

> ( ស្តេចរបស់យើង ) ចម្លែកណាស់តើ គួរឲ្យព្រឺរោម កើតឡើងក្នុងលោក រថជាទិព្វបានកើតប្រាកដដល់ស្តេចវិទេហៈព្រះអង្គមានយស ដូច្នេះ ។

គាថានោះ មានអធិប្បាយថា ព្រះបាទវិទេហៈរុងរឿងដោយយស ព្រះរាជារបស់ពួកយើងគួរអស្ចារ្យហ្ន៎ ការព្រឺរោមព្រឺស្បែកកើតហើយក្នុងលោក ដ្បិតរថទិព្វប្រាកដដើម្បីទ្រង់ ។

មាតលិទេវបុត្តនាំរថមកដល់ កាលពួកជននាំគ្នាបូជាដោយផ្កាជាដើម ធ្វើប្រទក្សិណនូវព្រះនគរ ៣ ជុំ ហើយទៅកាន់ទ្វារព្រះរាជវាំងរបស់ព្រះរាជា

បញ្ឈប់រថទុកជិតជរណីបង្អួចខាងក្រោយ ឈរចាំទទួលព្រះរាជា ។ ថ្ងៃនោះ ព្រះរាជាទ្រង់ត្រួតមើលរោងទាន ត្រាស់ថា អ្នកទាំងឡាយចូរឲ្យទានដោយទំនងនេះឯង ទ្រង់សមាទានឧបោសថ ឲ្យថ្ងៃកន្លងទៅ មានពួកអាមាត្យចោមរោម ប្រថាប់គង់បែរព្រះភក្ត្រទៅកាន់បង្អួចទិសខាងកើត ត្រាស់នូវកថាដែលប្រកបដោយធម៌ ក្នុងល្វែងប្រាសាទដែលប្រដាប់ហើយ ។ កាលនោះ មាតលិទេវបុត្ត ទូលអារាធនាព្រះរាជាឡើងរថនាំទៅ ។ ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាទាំងនេះថា

ទេវបុត្តឈ្មោះមាតលីជាទេវសារថីមានឫទ្ធិច្រើន បានអញ្ជើញព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលាថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងឡើងកាន់រថនេះ ទេវតាទាំងឡាយជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយ រឭកព្រះអង្គ នៅរង់ចាំក្នុងរោងឈ្មោះសុធម្មា ។ លំដាប់នោះឯង ព្រះបាទវិទេហៈ ព្រះនាមសាធិន ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ទ្រង់យាងឡើងកាន់រថ ទឹមដោយសេះច្រើន ហើយបានយាងទៅក្នុងសម្នាក់នៃទេវតាទាំងឡាយ ( ព្រះរាជាជាធំទ្រង់ប្រថាប់លើទិព្វយានឈ្មោះហយវាហី ដែលទឹមដោយសេះច្រើនកំពុងយាងទៅក៏បាន ទតឃើញទេវសភានេះ ) ពួកទេវតាបានឃើញព្រះរាជានោះមកដល់ហើយ ក៏ត្រេកអរស្មោះចំពោះថា បពិត្រមហា

រាជ ព្រះអង្គយាងមកស្រួលហើយ មិនមែនយាងមកដោយមិនស្រួលទេ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គទ្រង់គង់ក្នុងសំណាក់នៃទេវរាជចុះ ៗ

ឯព្រះឥន្ទ្រក៏ទទួលរាក់ទាក់ចំពោះព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ព្រះឥន្ទ្របានអញ្ជើញដោយកាមទាំងឡាយផង ដោយអាសនៈផងថា ប្រពៃណាស់ហើយព្រះអង្គបានដល់ អាវាសរបស់ទេវតាទាំងឡាយ ដែលញ៉ាំងគេឲ្យប្រព្រឹត្តក្នុងអំណាចខ្លួន បពិត្រព្រះរាជា អ្នកស្វែងរកគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងពួកទេវតាដែលសម្រេចនូវកាមគ្រប់យ៉ាងបាន សូមព្រះអង្គសោយនូវកាមទាំងឡាយដែលមិនមែនជារបស់មនុស្សក្នុងពួកទេវតាជាន់តាវត្តិង្សចុះ ដូច្នេះ ៗ

បណ្ដាបទទាំងនោះ បទថា **សមប្បរេ** សេចក្ដីថា រមែងប្រាថ្នា ៗ បទថា **អគា ទេវាន សន្តិកេ** សេចក្ដីថា បានយាងទៅក្នុងសម្នាក់នៃពួកទេវតាមែនពិត កាលព្រះបាទសាធិនរាជ ទ្រង់រថប្រថាប់រៀបរយហើយ រថក៏ចេញទៅកាន់អាកាស ហើយទៅទាំងដែលមហាជនកំពុងឃើញនោះឯង មាតលីទេវបុត្ត នាំព្រះរាជាទៅកាន់ទេវលោក ពួកទេវតានិងសក្កៈឃើញព្រះរាជា ក៏ត្រេកអរ ក្រោកឡើងទទួលធ្វើបដិសណ្ឋារៈ ដើម្បីសម្ដែងសេចក្ដីនោះ ព្រះសាស្ដាត្រាស់ព្រះគាថា មានពាក្យថា **តំ ទេវា** ជាដើម ៗ ក្នុងគាថានោះ បទថា **បដិនន្ទឹសុ** សេចក្ដីថា ត្រេកអររឿយៗ ៗ បទថា **អាសនេន ច**

សេចក្តីថា សក្កទេវរាជទ្រង់ឱបព្រះរាជាទ្រង់អញ្ជើញដោយបណ្ឌុកម្ពលសិលាអាសនៈរបស់សក្កៈថា សូមទ្រង់ប្រថាប់ត្រង់នេះ ហើយទ្រង់អញ្ជើញដោយវត្ថុដែលគួរប្រាថ្នាទាំងឡាយ បែងចែកទេវលោកឲ្យពាក់កណ្តាល ប្រថាប់រួមអាសនៈគ្នា ។

កាលព្រះបាទសាធិនរាជអង្គនោះ ទ្រង់សោយរាជសម្បត្តិដែលសក្កៈទ្រង់ចែកព្រះនគរប្រមាណ ១ ម៉ឺនយោជន៍ និងទេពអប្សរ ២ កោដិកន្លះ និងវេជយន្តប្បសាទ ព្រះរាជទានឲ្យពាក់កណ្តាល កាលវេលាកន្លងទៅ ៧០០ ឆ្នាំ ដោយរាប់ឆ្នាំមនុស្ស ព្រះរាជាប្រថាប់នៅក្នុងទេវលោក ដោយអត្តភាពនោះ ។ កាលអស់បុណ្យទ្រង់ក៏នឿយណាយ ព្រោះហេតុនោះ កាលព្រះរាជាត្រាស់សន្ទនាជាមួយសក្កៈ ទើបត្រាស់ព្រះគាថាដូច្នេះថា

កាលពីដើម ខ្ញុំមកនៅក្នុងឋានសួគ៌រីករាយដោយរបាំចម្រៀង
និងប្រគំទាំងឡាយ ឥឡូវនេះ ក្នុងថ្ងៃនេះ ខ្ញុំមិនត្រេកអរក្នុង
ឋានសួគ៌ទេ បពិត្រព្រះជនិន្ទដ៏ប្រសើរ អាយុ ( របស់ខ្ញុំ )
នឹងអស់ឬ ឬសេចក្តីស្លាប់ ( ឋិតនៅ ) ក្នុងទីជិត ឬក៏ខ្ញុំជា
បុគ្គលវង្វេង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាយុន្នុ ខីណំ** សេចក្តីថា ព្រះបាទសាធិនរាជទូលសួរថា ជីវិតិន្ទ្រិយ ក្នុងសរីរៈរបស់ខ្ញុំអស់ហើយ ឬដូចម្តេច ឬជីវិតិន្ទ្រិយជារបស់ជិតចំពោះមរណៈដោយអំណាចកម្មចូលមកកាត់ផ្តាច់ ។ បទថា **ជនិន្ទសេដ្ឋ** បានដល់ បពិត្រព្រះអង្គប្រសើរជាងនរជន និងទេវតាទាំង

ឡាយ ។

លំដាប់នោះ សក្កទេវរាជត្រាស់ថា

បពិត្រព្រះអង្គដ៏ប្រសើរ មានព្យាយាមជាងជន អាយុរបស់ព្រះអង្គមិនទាន់អស់ទេ ទាំងសេចក្ដីស្លាប់របស់ព្រះអង្គ ( ក៏ឋិតនៅ ) ក្នុងទីឆ្ងាយ មួយវិញទៀត ព្រះអង្គមិនមែនជាមនុស្សវង្វេងទេ តែជាព្រះអង្គសោយនូវផលនៃបុណ្យណា ក្នុងទេវលោកនេះ បុណ្យរបស់ព្រះអង្គនោះតិច បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គគង់នៅដោយទេវានុភាពចុះ សូមព្រះអង្គសោយនូវកាមទាំងឡាយ មិនមែនជារបស់មនុស្ស ក្នុងទេវលោកជាន់តាវត្តិង្សចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរិត្តកានិ** នេះ សក្កទេវរាជត្រាស់សំដៅដល់បុណ្យដែលឲ្យវិបាកក្នុងទេវលោកដោយអត្តភាពនោះ តែបុណ្យរបស់ព្រះបាទសាធិនរាជក្រៅអំពីនេះ ប្រមាណមិនបាន ដូចធូលីក្នុងផែនដី ដូច្នោះ ។ បទថា **វស ទេវានុភាវេន** សេចក្ដីថា ខ្ញុំសូមចែកបុណ្យទាំងឡាយរបស់ខ្លួនថ្វាយដល់ទ្រង់ សូមទ្រង់ប្រថាប់នៅដោយអានុភាពរបស់ខ្ញុំចុះ ។

ព្រះមហាសត្វកាលទ្រង់ឃាត់សក្កទេវរាជ ទើបត្រាស់ព្រះគាថា ដូច្នេះថា

យានដែលខ្ចីគេ និងទ្រព្យដែលខ្ចីគេ មានឧបមាយ៉ាងណាមិញ ទ្រព្យណាដែលគេបាន ព្រោះបុគ្គលដទៃឲ្យជាបច្ច័យ ទ្រព្យនុ៎ះឯងក៏មានឧបមេយ្យយ៉ាងនោះដែរ ទ្រព្យណាដែលគេបាន

ព្រោះបុគ្គលដទៃឲ្យជាបច្ច័យ ខ្ញុំមិនចង់បានទ្រព្យនុ៎ះឡើយ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង បុណ្យនោះ ទុកជាទ្រព្យរបស់ខ្ញុំជាប់តាមខ្លួន ខ្ញុំនោះនឹងទៅធ្វើកុសលឲ្យច្រើនក្នុងពួកមនុស្ស ដោយឲ្យទានផង កិរិយា ប្រព្រឹត្តិធម៌ស្មើផង កិរិយាសង្រួមដោយសីលផង កិរិយាទូន្មាននូវឥន្រ្ទិយផង ព្រោះថា បុគ្គលធ្វើកុសលហើយ រមែងដល់នូវសេចក្តីសុខទាំងមិនក្តៅក្រហាយរឿយៗក្នុងកាលជាខាងក្រោយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ បរតោ ទានបច្ចយា** សេចក្តីថា វត្ថុណាដែលបានព្រោះអ្នកដទៃឲ្យ វត្ថុនោះ ដូចគ្នានឹងរបស់ដែលខ្ចីគេនោះឯង ព្រោះថា បុគ្គលរមែងឲ្យខ្ចីគ្នាបានក្នុងកាលដែលល្អនឹងគ្នា ក្នុងពេលដែលក្រោធ ក៏តឹងទារយកមកវិញ ។ បទថា **សមចរិយាយ** គឺដោយ ការមិនធ្វើបាបដោយកាយជាដើម ។ បទថា **សំយមេន** គឺដោយការសង្រួមក្នុងសីល ។ បទថា **ទមេន** គឺដោយការទូន្មានឥន្រ្ទិយ ។ បទថា **យំ កត្វា** សេចក្តីថា ខ្ញុំនឹងធ្វើវត្ថុដែលបុគ្គលធ្វើហើយ បានទទួលសេចក្តីសុខនឹងមិនតាមក្តៅក្រហាយក្នុងកាលជាក្រោយ ។

កាលសក្កទេវរាជ ទ្រង់ស្តាប់ព្រះតម្រាស់របស់ព្រះបាទសាធិនរាជនោះហើយ ទ្រង់បញ្ជាមាតលិទេវបុត្តថា ចូរអ្នកនាំព្រះបាទសាធិនរាជទៅកាន់មិថិលា ឲ្យទ្រង់ចុះក្នុងព្រះរាជឧទ្យាន ។ មាតលិទេវបុត្តនោះ បានធ្វើតាមទេវបញ្ជា ។ ព្រះរាជាទ្រង់ចង្រ្កមក្នុងព្រះរាជឧទ្យាននោះឯង ។ កាលនោះ ឧទ្យាន

បាលឃើញព្រះរាជាហើយ ក៏ចូលទៅគាល់ ថ្វាយបង្គំហើយទូលសួរ ចាំព្រះរាជាបាន ក៏ទៅក្រាបទូលព្រះរាជានារទៈ ចំណែកព្រះបាទនារទៈនោះ ទ្រង់ស្ដាប់ការយាងមករបស់ព្រះរាជាហើយ ត្រាស់ថា នែឧទ្យានបាល ចូរអ្នកទៅមុន រៀបចំឧទ្យាន តាំងអាសនៈពីរ សម្រាប់ព្រះរាជា ១ សម្រាប់យើង ១ ហើយទ្រង់បញ្ជូននាយឧទ្យានបាលនោះទៅ ។ ឧទ្យានបាល បានធ្វើតាមព្រះរាជបញ្ជា ពេលនោះ ទើបព្រះរាជាត្រាស់សួរថា អ្នកតាំងអាសនៈ ២ ដើម្បីអ្នកណា ឧទ្យានបាលក៏ក្រាបទូលថា ដើម្បីទ្រង់មួយ ដើម្បីព្រះរាជារបស់ពួកទូលព្រះបង្គំមួយ ។ កាលនោះ ព្រះរាជាត្រាស់ថា សត្វដទៃណាអង្គុយលើអាសនៈក្នុងសម្នាក់របស់យើង ហើយប្រថាប់គង់លើអាសនៈ ១ ដាក់ព្រះបាទទាំងគូលើអាសនៈ ១ ។ ព្រះរាជានារទៈ យាងមកថ្វាយបង្គំព្រះយុគលបាទរបស់ព្រះរាជាហើយ ប្រថាប់គង់ក្នុងចំណែកម្ខាង បានឮថា ព្រះបាទនារទៈជាចៅរបស់ព្រះបាទសាធិនរាជ អង្គទី ៧ នោះឯង ។ បានឮថា កាលណោះ ព្រះបាទនារទៈទ្រង់មានព្រះជន្ម ១០០ វស្សាហើយ តែព្រះ មហាសត្វទ្រង់មាន ព្រះជន្មយឺនយូរអស់កាលមានប្រមាណប៉ុណ្ណោះ ដោយកម្លាំងបុណ្យរបស់ព្រះអង្គ ។ ទ្រង់ចាប់ព្រះហស្តរបស់ព្រះបាទនារទៈ ត្រាច់ទៅក្នុងព្រះរាជឧទ្យាន បានត្រាស់គាថា ៣ ថា

ស្រែទាំងឡាយនេះផង ទទឹកប្រកបដោយកុណ្ឌលដ៏ល្អនេះផង
ផែនដីដ៏ដេរដាសដោយស្មៅពណ៌ខៀវនេះផង ស្ទឹងទាំងឡាយ
ដែលកំពុងហូរនេះផង ស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ

មានសត្វចាកក្រពាក់យំហើយ ដ៏ដេរដាសដោយ ចន្ទុលណី ដោយផ្កាឈូក និងផ្កាឧប្បលនេះផង ពួកជនណា រាប់អាន នូវទីទាំងឡាយនេះថាជារបស់អញ ជនទាំងនោះ ទៅកាន់ទិស ណាហ្ន៎ ។

ម្នាលនារទៈ ស្រែទាំងឡាយ នៅជាស្រែទាំងនោះដដែល ភូមិភាគ នៅជាភូមិភាគនោះដដែល ឧបចារៈនៃសួនច្បារទាំង ឡាយ ក៏នៅជាឧបចារៈនោះដដែល តែថា កាលយើងមិន ឃើញនូវជនទាំងនោះ ទិសប្រាកដដល់យើងហាក់ដូចជាសូន្យ ឈឹង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខេត្តានិ** នេះ ព្រះមហាសត្វត្រាស់សំដៅដល់ ភូមិភាគទាំងឡាយ ។ បទថា **នមំ និក្ខំ** បានដល់ ទីនេះជាផ្លូវបង្ហូរទឹក គង់ជា យ៉ាងនោះ ដូចដើម ។ បទថា **សុក្កុណ្ឌលំ** គឺដែលមានគន្លងបង្ហូរទឹកចូលដល់ រោងសូបៈ ( រោងដាំស្ល ) ដ៏ស្អាត ។ បទថា **ហរិតានុចា** សេចក្តីថា ត្រង់ ប្រាំងទាំងពីរនៃផ្លូវបង្ហូរទឹក មានផែនដីជាទីលានដែលដេរដាសដោយ ស្បូវ ភ្លាំងខៀវស្រងាត់ ។ បទថា **យស្មិមានិ មមាយឹសុ** សេចក្តីថា នែបានារទៈ បណ្តាអ្នកបម្រើនិងស្នំរបស់យើង ដែលនាំគ្នាត្រាច់លេងជាមួយយើង ដោយ យសដ៏ធំក្នុងឧទ្យាននេះ នាំគ្នាត្រេកអរក្នុងទីទាំងនេះ ។ បទថា **កឹ នុ តេ ទិសតំគតា** សេចក្តីថា បានបញ្ជូនមនុស្សទាំងនោះទៅក្នុងទីណាហ្ន៎ ។ បទ ថា **តានីធ ខេត្តានិ** បានដល់ ទីដែលសម្រាប់ព្រោះពូជដែលដុះដាលល្អក្នុង

ឧទ្យាននេះ ។ បទថា **តោយេវ អារាមវត្ថុបចារា** បានដល់ ពូជដែលជាទីតាំងនៃលំនៅទាំងនេះ ជាឧបចារៈនៃអារាមនិងព្រៃនៅក្នុងទីនេះឯង ។

គ្រានោះព្រះបាទនារទៈក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព កាលទ្រង់យាងទៅទេវលោកកំណត់ ៧០០ ឆ្នាំហើយ ទូលព្រះបង្គំជាចៅជំនាន់ទី ៧ របស់ព្រះអង្គ ឧបដ្ឋាករបស់ព្រះអង្គបាត់បង់ជីវិតអស់ហើយ សូមទ្រង់សោយរាជសម្បត្តិដែលជាចំណែករបស់ទ្រង់ចុះ ។

ព្រះរាជាត្រាស់ថា នែបានារទៈ យើងមកនេះមិនមែនត្រូវការរាជសម្បត្តិមកដើម្បីធ្វើបុណ្យ យើងនិងធ្វើនូវបុណ្យប៉ុណ្ណោះ ទើបត្រាស់គាថាដូច្នេះថា

វិមានទាំងឡាយ ញុំាងទិសទាំង ៤ ឲ្យភ្លឺចិញ្ចែងចំពោះមុខទេវរាជផង ចំពោះមុខពួកទេវតាជាន់ត្រៃត្រិង្សផង យើងបានឃើញហើយ ។ ភពជាទិព្វ យើងបាននៅរួចហើយ កាមទាំងឡាយ មិនមែនជារបស់មនុស្ស យើងបានបរិភោគរួចហើយក្នុងពួកទេវតាជាន់តាវត្តិង្ស អាចសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន ។ យើងនោះ បានលះបង់សម្បត្តិទិព្វប្រាកដដូច្នោះហើយ មកក្នុងទីនេះដើម្បីធ្វើបុណ្យ យើងនឹងប្រព្រឹត្តធម៌តែម្យ៉ាង យើងមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិទេ ។ ព្រះពុទ្ធទាំងឡាយដែល មានវត្តល្អ ស្តេចយាងទៅតាមផ្លូវណា យើងនឹងដើរ ទៅតាមផ្លូវនោះ ដែលព្រះសម្មាសម្ពុទ្ធសំដែងហើយ ជាផ្លូវដែលបុគ្គលមិនមានអាថ្វាគប្បីត្រាច់ទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វុត្តំ មេ ភវធំ ធិញ្ញំ** នេះ ព្រះបាទសាធិនរាជ ត្រាស់សំដៅដល់វេជយន្តប្បសាទ ។ បទថា **សោហំ ឯតាធិសំ** សេចក្ដីថា នែបានារទៈ ខ្ញុំនោះត្រូវបោះបង់នូវសម្បត្តិនៃកាមគុណ ដែលព្រះពុទ្ធញាណ មិនគប្បីកំណត់បែបនេះ មកក្នុងទីនេះដើម្បីត្រូវការបុណ្យ ។ បទថា **អនណ្ហាវ-ចរំ** សេចក្ដីថា ផ្លូវមានអង្គ ៨ មានសម្មាទិដ្ឋិជាខាងដើម ដែលពួកលោកអ្នក មិនមានអាជ្ញា ដាក់ចុះនូវដំបងនិងសស្ត្រាហើយគប្បីដើរ ។ បទថា **សុព្វតា** សេចក្ដីថា លោកអ្នកមានវត្តល្អ បានដល់ ព្រះសព្វញ្ញុពុទ្ធទាំងឡាយ ទ្រង់ ដើរដោយផ្លូវណា សូម្បីខ្ញុំក៏នឹងសូមអង្គុយលើទឹកដីនៃពោធិ ដើម្បីទៅដល់ ទិសដែលមិនធ្លាប់ទៅ នឹងដើរទៅកាន់ផ្លូវនោះដូចគ្នា ។

ព្រះពោធិសត្វ ត្រាស់គាថាទាំងនេះ ទុកក្នុងព្រះសព្វញ្ញុតញ្ញាណដោយ ប្រការដូច្នេះ កាលនោះព្រះរាជានារទៈ ក្រាបទូលបញ្ជាក់ព្រះរាជាទៀតថា សូមទ្រង់គ្រងរាជសម្បត្តិបន្តទៀតចុះ ព្រះរាជាត្រាស់ថា នែបា ខ្ញុំមិនត្រូវការ រាជសម្បត្តិ សូមឲ្យទានដែលកន្លងទៅ ៧ ឆ្នាំ ត្រឹម ៧ ថ្ងៃប៉ុណ្ណោះឯង ។ ព្រះរាជានារទៈ ទ្រង់ទទួលព្រះតម្រាស់ របស់ព្រះរាជាថា យាងចុះព្រះអង្គ ហើយទ្រង់រៀបចំមហាទាន ព្រះរាជាទ្រង់បានឲ្យមហាទានអស់ ៧ ថ្ងៃ ក្នុង ថ្ងៃទី ៧ ក៏អស់ព្រះជន្ម ទ្រង់កើតក្នុងតាវត្តិង្សពិភពនោះឯង ។

ព្រះសាស្ដាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបត្រាស់ ថា ម្នាលឧបាសកទាំងឡាយ ឧបោសថកម្មគប្បីបំពេញដោយប្រការដូច្នេះ ហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ( កាលចប់សច្ចៈបណ្ដាឧបាសកអ្នករក្សា

ឧបោសថទាំងនោះ ពួកខ្លះតាំងនៅក្នុងសោតាបត្តិផល ពួកខ្លះតាំងនៅក្នុងសកទាគាមិផល ពួកខ្លះតាំងនៅក្នុងអនាគាមិផល ពួកខ្លះតាំងនៅក្នុងអរហត្តផល ) ហើយទ្រង់ប្រជុំជាតកថា ព្រះរាជានារទៈក្នុងកាលនោះ បានមកជាសារីបុត្តក្នុងកាលឥឡូវនេះ មាតលីទេវបុត្តក្នុងកាលនោះ បានមកជាអានន្ទ សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ បរិស័ទដ៏សេស ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកព្រះបាទសាធិនរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សាធិនជាតក ចប់

# ទសព្រាហ្មណជាតក

[ ១៣០ ] ( ព្រះសាស្ដាទ្រង់ត្រាស់ថា ) ព្រះរាជាជាយុធិដ្ឋិលគោត្ត ព្រះអង្គប្រាថ្នានូវធម៌ បានត្រាស់នឹងអាមាត្យឈ្មោះវិធូរៈថា ម្នាលវិធូរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន ម្នាលសម្លាញ់ យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៣១ ] ( អាមាត្យឈ្មោះវិធូរៈក្រាបទូលថា ) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគនូវភោជនរបស់ព្រះអង្គ គេរកបានដោយក្រ ។ បពិត្រមហារាជ ពូជជាតិព្រាហ្មណ៍ទាំងឡាយណាមាន ១០ យ៉ាង សូមព្រះអង្គ ទ្រង់ព្រះសណ្ដាប់នូវការចែករំលែក និងការពិនិត្យពិច័យនូវព្រាហ្មណ៍ទាំងនោះ តាមប្រាជ្ញារបស់ទូលព្រះបង្គំជាខ្ញុំ ដោយពិស្ដារចុះ ។ ព្រាហ្មណ៍ទាំងឡាយ កាន់ការុងទាំងឡាយ ដែលពេញដោយឫសឈើ ចងមាត់ជិត ហើយតែងក្បួនថ្នាំទាំងឡាយផង ផ្ងូតទឹកឲ្យគេផង សែកនូវ ( ភូតវិជ្ជា ) ផង ។ បពិត្រព្រះរាជា ឯព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយពេទ្យគេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ទូលព្រះបង្គំជាខ្ញុំ បានក្រាបទូលចំពោះព្រះអង្គរួចហើយ យើងនឹងចូលទៅរកពួក ព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

[ ១៣២ ] ( ព្រះរាជាគោរព្យ... ) ពួកព្រាហ្មណ៍ទាំងនោះ ប្រាសចាក

ភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៣៣ ] ( វិធុរៈ... ) ព្រាហ្មណ៍ទាំងឡាយនោះ កាន់ឃ្នោះទាំងឡាយ ហើយឃោសនាឮដ៏ខាងមុខ ( នៃស្តេចនិងអាមាត្យ ) ក៏មាន ទៅកាន់ទីសម្រាប់បម្រើគេក៏មាន សិក្សាខាងសិល្បរថក៏មាន ។ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយជនអ្នកបម្រើ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

[ ១៣៤ ] ( ព្រះរាជាកោរព្យៈ... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៣៥ ] ( វិធុរៈ... ) ព្រាហ្មណ៍ទាំងឡាយកាន់ឃ្លោកដាក់ទឹកផង ដំបងកុកផង ចូលទៅអែបអបនឹងស្តេចទាំងឡាយក្នុងស្រុក ឬនិគម ( ដោយគិត

គ្នាថា ) កាលបើគេមិនឲ្យ ( វត្ថុអ្វីមួយ ) ក្នុងស្រុកឬនិគម យើងនឹងមិនក្រោកឡើយ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នករឹបជាន់ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបបង្គំទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

[ ១៣៦ ] ( ព្រះរាជាគោរព្យ:... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីលជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៣៧ ] ( វិធុរៈ... ) ព្រាហ្មណ៍ទាំងឡាយនោះ មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល រោយរាយដោយធូលីនិងលម្អងដី ត្រាច់ទៅសូម ( ទ្រព្យផ្សេងៗ ) បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកជកនូវជង្គត់ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ។

[ ១៣៨ ] ( ព្រះរាជាគោរព្យ:... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍

ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៣៩ ] ( វិធុរៈ... ) បពិត្រព្រះជនាធិបតី ( ព្រាហ្មណ៍ទាំងឡាយ ) ជួញសម៉ផង កន្ទួតព្រៃផង ស្វាយផង ព្រីងផង សម៉ពិភេកផង ខ្នុរសម្លផង ឈើស្ទន់ផង ល្ពៅផង ពុទ្រាផង ឈើកែសផង ទឹកអំពៅនិងស្ករអំពៅផង ខ្សៀផង ទឹកឃ្មុំនិងថ្នាំបន្តក់ភ្នែកផង ជួញកណ្ឌៈមានតម្លៃតិចឬមានតម្លៃច្រើនផង បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រកដស្មើដោយពាណិជហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍ បែបដូច្នោះឬ ។

[ ១៤០ ] ( ព្រះរាជាកោរព្យៈ... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៤១ ] ( វិធុរៈ... ) ( ព្រាហ្មណ៍ទាំងឡាយ ) នាំគ្នាធ្វើនូវកសិកម្ម

និងពាណិជ្ជកម្មផង ចិញ្ចឹមពពែនិងចៀមផង ទំនុកបម្រុងពួកកុមារីផង រៀប ចំអាពាហ៍ពិពាហ៍ផង ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយកុដុម្ពិកៈនិង គហបតី គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍ បែបដូច្នោះឬ ។

[ ១៤២ ] ( ព្រះរាជាកោរព្យៈ... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាស ចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញដែលជាអ្នកមាន សីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៤៣ ] ( វិធុរៈ... ) មានព្រាហ្មណ៍ពួកខ្លះ ជាបុរោហិត ( បរិភោគ នូវភិក្ខាដែលគេទុកបម្រុងឲ្យខ្លួន ) ពួកជនច្រើនគ្នាតែងសាកសួរព្រាហ្មណ៍ នោះ ព្រាហ្មណ៍ទាំងនោះជាអ្នកក្រៀវពង ( គោជាដើម ) ផង ជាគ្រូសាក់ផង សម្លាប់សត្វចិញ្ចឹម គឺក្របីជ្រូក និងពពែផង ក្នុងផ្ទះនោះ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នកសម្លាប់គោ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបាន ក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ។

[ ១៤៤ ] ( ព្រះរាជាកោរព្យៈ... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាស

ចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៨៥ ] ( វិធុរៈ... ) ព្រាហ្មណ៍ទាំងឡាយកាន់ដាវនិងខែល កាន់ព្រះខាន់ឈរអែបនៅក្បែរផ្លូវ ជាទីទៅនៃពួកឈ្មួញ នាំពួកឈ្មួញឲ្យផុត ( អំពីពួកចោរ ) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពួកជនអ្នកឃ្វាលគោនិងពួកអ្នកនេសាទ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

[ ១៨៦ ] ( ព្រះរាជាកោរព្យ:... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៨៧ ] ( វិធុរៈ... ) ព្រាហ្មណ៍ទាំងឡាយនោះ ( ធ្វើខ្ទមក្នុងព្រៃ ) ធ្វើអន្ទាក់វែងទាំងឡាយ បៀតបៀននូវទន្សាយនិងឆ្មាត្រីផង នូវទន្សង ត្រី

និងអណ្ដើកផង បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះប្រាកដស្មើដោយព្រានព្រៃ ព្រាហ្មណ៍ទាំងនោះ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងនោះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅស្វែងរកព្រាហ្មណ៍បែបដូច្នោះឬ ។

[ ១៤៨ ] ( ព្រះរាជាកោរព្យ:... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៤៩ ] ( វិធូរៈ... ) ព្រាហ្មណ៍ទាំងឡាយដទៃទៀត ចង់បានទ្រព្យក៏ដេកនៅខាងក្រោមគ្រែ កាលសោមយាគប្រាកដហើយ ស្ដេចទាំងឡាយក៏ស្រង់ទឹកព្ធដ៏ខាងលើនៃគ្រែ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកដុសក្អែល គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

[ ១៥០ ] ( ព្រះរាជាកោរព្យ:... ) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមាន

សីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្មាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផល ច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

[ ១៥១ ] ( វិធុរៈ... ) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែល ជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគភោជនរបស់ ព្រះអង្គមានដែរ ។ ព្រាហ្មណ៍ទាំងនោះ បរិភោគនូវកត្តតែមួង ទាំងមិនផឹកនូវទឹក ស្រវឹង បពិត្រមហារាជ ( ពួកព្រាហ្មណ៍នេះ ) ខ្ញុំព្រះអង្គបានក្រាបទូលព្រះ អង្គហើយ យើងនឹងចូលទៅអញ្ជើញពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

[ ១៥២ ] ( ព្រះរាជា... ) ម្នាលវិធុរៈ បើពួកព្រាហ្មណ៍ទាំងឯង ជា អ្នកមានសីល ជាពហុស្សូតពិតមែន ម្នាលវិធុរៈ អ្នកចូរស្វែងរកពួកព្រា- ហ្មណ៍ទាំងចុះ ចូរអញ្ជើញព្រាហ្មណ៍ទាំងនោះមកឆាប់ៗ ។

## ចប់ ទសព្រាហ្មណជាតកទី ១២

# អដ្ឋកថា

# ឧសព្រាហ្មណជាតក

[ ១៣០-១៥២ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ អសទិសទាន ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **រាជា អហោច វិធូរំ** ដូច្នេះជាដើម ។

រឿងអសទិសទាននោះ មានសេចក្តីពិស្តារប្រាកដហើយ ក្នុងវិធុរជាតក អដ្ឋកនិបាត ។

បានឮថា កាលណោះ ព្រះរាជាទ្រង់ថ្វាយទាន ទ្រង់ជ្រើសរើសភិក្ខុ ប្រមាណ ៥០០ រូប ធ្វើព្រះសាស្តាឲ្យជាប្រធាន ទ្រង់បានថ្វាយទានដល់ ព្រះមហាខីណាស្រពទាំងនោះ ។ កាលនោះ កាលពួកភិក្ខុពោលគុណកថា របស់ព្រះរាជា លើករឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះរាជាកាលទ្រង់ថ្វាយអសទិសទាន ទ្រង់បានជ្រើសរើស ក្នុងភិក្ខុដែលជា ទីប្រតិស្ឋាននៃមគ្គផល ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុ ទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុ ទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនគួរអស្ចារ្យទេ ដែលព្រះបាទ កោសលជាឧបដ្ឋាករបស់ព្រះពុទ្ធដូចតថាគត ទ្រង់ជ្រើសរើសថ្វាយទានសូម្បី ពួកបណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើង ក៏ធ្លាប់បានជ្រើស រើសថ្វាយទានហើយដូចគ្នា ភិក្ខុទាំងនោះនាំគ្នាក្រាបទូលអារាធនា ទ្រង់នាំ

អតីតនិទានមកសាធក:ដូចតទៅនេះថា

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល កាលព្រះបាទកោរព្យយុធិដ្ឋិលគោត្ត សោយរាជសម្បត្តិក្នុងនគរឥន្ទបត្ត ដែនកុរុ អាមាត្យរបស់ព្រះរាជាព្រះនាមថា វិធុរៈ ចាំថ្វាយអត្ថនិងធម៌ ។ ព្រះរាជាទ្រង់ញុំាំងជម្ពូទ្វីបគ្រប់កន្លែង ឲ្យខ្វូរខ្វារទៅ ទ្រង់ថ្វាយមហាទាន ។ បណ្ដាបុគ្គលដែលទទួលទាននោះបរិភោគ មិនមានបុគ្គលណាមួយរក្សាសីល ៥ ឡើយ ជាអ្នកទ្រុស្តសីលទាំងអស់ ។ ទានមិនបានធ្វើឲ្យព្រះរាជាទ្រង់ត្រេកអរ ព្រះរាជាត្រាស់ថា ការជ្រើសរើសឲ្យទានមានផលច្រើន ទ្រង់មានបំណងនឹងឲ្យទានដល់អ្នកមានសីល ទ្រង់ព្រះតម្រិះថា ត្រូវប្រឹក្សាជាមួយវិធុរបណ្ឌិត ព្រះរាជាទ្រង់ត្រាស់ឲ្យវិធុរបណ្ឌិតអង្គុយលើអាសនៈ ហើយត្រាស់សួរបញ្ហា ។

ព្រះសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់កន្លះគាថាថា

ព្រះរាជាជាយុធិដ្ឋិលគោត្ត ព្រះអង្គប្រាថ្នានូវធម៌ បានត្រាស់
នឹងអាមាត្យឈ្មោះវិធុរៈ ដូច្នេះ ។

តទៅជាព្រះតម្រាស់របស់ព្រះរាជានិងពាក្យឆ្លើយរបស់វិធុរបណ្ឌិត

ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយ ដែលជា
អ្នកមានសីល ជាពហុស្សុត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគ
នូវភោជន របស់យើង ទក្ខិណាទានដែលគេឲ្យហើយចំពោះ
បុគ្គលណា ជាទានមានផលច្រើន ម្នាលសម្លាញ់ យើងនឹង
ឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈក្រាបទូលថា

បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគនូវភោជនរបស់ព្រះអង្គ គេរកបានដោយក្រ ។ បពិត្រមហារាជ ឮថា ជាតិព្រាហ្មណ៍ទាំងឡាយណាមាន ១០ យ៉ាង សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់ នូវការចែករំលែក និងការពិនិត្យពិច័យ នូវព្រាហ្មណ៍ទាំងនោះ តាមប្រាជ្ញារបស់ទូលព្រះបង្គំជាខ្ញុំ ដោយពិស្តារចុះ ។ ព្រាហ្មណ៍ទាំងឡាយ កាន់ការុងទាំងឡាយ ដែលពេញដោយឫសឈើ ចងមាត់ជិត ហើយតែងក្បួនថ្នាំទាំងឡាយផង ផ្សូតទឹកឲ្យគេផង សែកនូវ ( ភូតវិជ្ជា ) ផង ។ បពិត្រព្រះរាជា ឯព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយពេទ្យ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ទូលព្រះបង្គំជាខ្ញុំ បានក្រាបទូលចំពោះព្រះអង្គរួចហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

ព្រះរាជាកោរព្យត្រាស់ថា

ពួកព្រាហ្មណ៍ទាំងនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីលជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់

យើង ម្នាលសម្លាញ់ ទក្ខិណាទាន ដែលគេឲ្យហើយចំពោះ បុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈក្រាបទូលថា

ព្រាហ្មណ៍ទាំងឡាយនោះ កាន់ឈ្មោះទាំងឡាយ ហើយឃោ-សនាឮដ៏ខាងមុខ ( នៃស្ដេចនិងអាមាត្យ ) ក៏មាន ទៅកាន់ ទីសម្រាប់បម្រើគេក៏មាន សិក្សាខាងសិល្បវេជក៏មាន ។ បពិត្រ ព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយជនអ្នកបម្រើ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ(ព្រាហ្មណ៍ទាំងឡាយ នេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹង ចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រា-ហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នក មានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគ នូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យ ចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិ ណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈ ក្រាបទូលថា

ព្រាហ្មណ៍ទាំងឡាយ កាន់ឃ្លោកដាក់ទឹកផង ដំបងក្ងកផង ចូលទៅអែបអបនឹងស្តេចទាំងឡាយ ក្នុងស្រុកឬនិគម ( ដោយគិតគ្នាថា ) កាលបើគេមិនឲ្យ ( វត្ថុអ្វីមួយ ) ក្នុងស្រុកឬនិគម យើងនឹងមិនក្រោកឡើយ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នករឹបជាន់ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបបង្គំទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈក្រាបទូលថា

ព្រាហ្មណ៍ទាំងឡាយនោះ មានរោមក្លៀក និងក្រចកដុះវែង

មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល រោយរាយដោយធូលីនិងលម្អងដី ត្រាច់ទៅសូម ( ទ្រព្យផ្សេងៗ ) បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជន អ្នកជីកនូវដង្គត់ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីលជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទាន ដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈក្រាបទូលថា

បពិត្រព្រះជនាធិបតី ( ព្រាហ្មណ៍ទាំងឡាយ ) ជួញសម៉ផង កន្ទួតព្រៃផង ស្វាយផង ព្រីងផង សម៉ពិភេកផង ខ្នុរសម្លផង ឈើស្នូនផង ល្ពៅផង ពុទ្រាផង ឈើកែសផង ទឹកអំពៅនិង

ស្លាអំពៅផង ខ្សៀផង ទឹកឃ្មុំនិងថ្នាំបន្តក់ភ្នែកផង ជួញភណ្ឌៈ មានតម្លៃតិច ឬមានតម្លៃច្រើនផង បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពាណិជ ហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីលជាពហុស្សូត វៀរចាកមេថុនធម្មឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈ ក្រាបទូលថា

( ព្រាហ្មណ៍ទាំងឡាយ ) នាំគ្នាធ្វើនូវកសិកម្មនិងពាណិជ្ជកម្មផង ចិញ្ចឹមពពែនិងចៀមផង ទំនុកបម្រុងពួកកុមារីផង រៀបចំអាពាហ៍ពិពាហ៍ផង ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយកុដុម្ពិកៈនិងគហបតី គេហៅថាព្រាហ្មណ៍ដែរ បពិត្រ

មហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីលជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈក្រាបទូលថា

មានព្រាហ្មណ៍ពួកខ្លះ ជាបុរោហិត ( បរិភោគនូវកិច្ចដែលគេទុកបម្រុងឲ្យខ្លួន ) ពួកជនច្រើនគ្នាតែងសាកសួរព្រាហ្មណ៍នោះ ព្រាហ្មណ៍ទាំងនោះជាអ្នកក្រៀវពង ( គោជាដើម ) ផង ជាគ្រូសាក់ផង សម្លាប់សត្វចិញ្ចឹមគឺក្របីជ្រូកនិងពពែផង ក្នុងផ្ទះនោះ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នកសម្លាប់គោ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គបានក្រាប

ទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែប ដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវ ភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈ ក្រាបទូលថា

ព្រាហ្មណ៍ទាំងឡាយកាន់ដាវនិងខែល កាន់ព្រះខាន់ឈរអែបនៅក្បែរផ្លូវ ជាទីទៅនៃពួកឈ្មួញ នាំពួកឈ្មួញឲ្យផុត ( អំពីពួកចោរ ) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពួកជនអ្នកឃ្វាលគោនិងពួកអ្នកនេសាទ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីលជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈក្រាបទូលថា

ព្រាហ្មណ៍ទាំងឡាយនោះ ( ធ្វើខ្លួមក្នុងព្រៃ ) ធ្វើអន្ទាក់វែងទាំងឡាយ បៀតបៀននូវទន្សាយនិងខ្លាត្រីផង នូវទន្សង ត្រីនិងអណ្តើកផង បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រកដស្មើដោយព្រានព្រៃ ព្រាហ្មណ៍ទាំងនោះ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងនោះ ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅស្វែងរកព្រាហ្មណ៍បែបដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែល

ជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន ( ចំពោះបុគ្គលនោះ ) ។

អាមាត្យឈ្មោះវិធុរៈក្រាបទូលថា

ព្រាហ្មណ៍ទាំងឡាយដទៃទៀត ចង់បានទ្រព្យ ក៏ដេកនៅខាងក្រោមគ្រែ កាលសោមយាគប្រាកដហើយ ស្តេចទាំងឡាយក៏ស្រង់ទឹកឲ្យដ៏ខាងលើនៃគ្រែ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកដុសក្អែល គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ ( ព្រាហ្មណ៍ទាំងឡាយនេះ ) ខ្ញុំព្រះអង្គ បានក្រាបទូលចំពោះព្រះអង្គហើយ យើងចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

ព្រះរាជាកោរព្យៈត្រាស់ថា

ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីលជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសម្លាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិ-

ណាទាន ( ចំពោះបុគ្គលនោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលវន្តេ** បានដល់ ជាអ្នកមានសីលដែលមកជាមួយអ្នក ។ បទថា **ពហុស្សុតេ** បានដល់ លោកជាពហុស្សូត ដោយបដិវេទ ។ បទថា **ទក្ខិណំ** បានដល់ ទាន ។ បទថា **យេ** បានដល់ ពួកសមណៈនិងព្រាហ្មណ៍ដែលទ្រទ្រង់នូវធម៌ពួកណា គួរបរិភោគទាននោះសមណព្រាហ្មណ៍ទាំងនោះ រកបានលំបាក ។ បទថា **ព្រាហ្មណជាតិយោ** បានដល់ត្រកូលរបស់ព្រាហ្មណ៍ ។ បទថា **តេសំ វិភង្គំ វិចយំ** សេចក្តីថា សូមទ្រង់ស្តាប់នូវការចែកព្រាហ្មណ៍ទាំងនោះ ដែលជាការវិចិត្រនៃបញ្ញារបស់ទូលព្រះបង្គំដោយពិស្តារ ។ បទថា **សំវុតេ** បានដល់ ចងមាត់ ( ការុង ) ទុក ។ បទថា **ឱសធិកាយេ គន្ថេន្តិ** សេចក្តីថា ចងនូវស្លាក ប្រាប់គុណភាព ថ្នាំយ៉ាងនេះថា ថ្នាំមុខនេះសម្រាប់រោគនេះ ថ្នាំមុខនេះសម្រាប់រោគនេះ ហើយឲ្យដល់ពពួកមនុស្ស ។ បទថា **ន្ហាបយន្តិ** បានដល់ ធ្វើទឹកដែលហៅថាទឹកស្រង់ គឺទឹកមន្ត ។ បទថា **ជបន្តិ ច** សេចក្តីថា រាយនូវវិជ្ជាកូត ។ បទថា **តិកិច្ឆកសមា** បានដល់ ដូចគ្រូពេទ្យ ។ បទថា **តេបិ វុច្ចន្តិ** សេចក្តីថា ជនទាំងនោះក៏មិនបានដឹងថាពួកយើងជាព្រាហ្មណ៍ ឬមិនមែនព្រាហ្មណ៍ ជាអ្នកចិញ្ចឹមជីវិតដោយវេជ្ជកម្មរឿយៗទៅ ពួកជននាំគ្នាហៅថាព្រាហ្មណ៍តាមវោហារ ។ បទថា **អក្ខាតា តេ** សេចក្តីថា ទូលព្រះបង្គំក្រាបទូលដល់ពួកព្រាហ្មណ៍ដែលឈ្មោះថា ព្រាហ្មណ៍ជាគ្រូពេទ្យទាំងនោះហើយ ។ បទថា **និបតាមសេ** សេចក្តីថា វិធូរបណ្ឌិតក្រាបទូលសួរថា បពិត្រព្រះអង្គទ្រង់ប្រកប

ដោយប្រាជ្ញា ពួកយើងនឹងចូលទៅរកឬនិមន្តពួកព្រាហ្មណ៍បែបនោះឬ គឺទ្រង់នៅមានសេចក្តីត្រូវការពួកព្រាហ្មណ៍ទាំងនោះឬ ។

បទថា **ព្រាហ្មញ្ញា** បានដល់ ព្រាហ្មណធម៌ ។ បទថា **ន តេ វុច្ចន្តិ** សេចក្តីថា ពួកជនទាំងនោះហៅថាព្រាហ្មណ៍តាមសម្គាល់ថា ជាអ្នកមានបាបបន្សាត់ហើយក៏មិនមែន ។ បទថា **កិន្តិណភិយោ** សេចក្តីថា បពិត្រមហារាជនៅមានព្រាហ្មណ៍មួយពួក លះនូវព្រាហ្មណធម៌របស់ខ្លួន កាន់យកឈ្មោះប្រគំទៅខាងមុខព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ដើម្បីត្រូវការគ្រឿងចិញ្ចឹមជីវិត ។ បទថា **បេសនានិបិ** សេចក្តីថា ជួនកាលក៏ទទួលបម្រើដូចជាទាសៈនិងកម្មករ ។ បទថា **រថចរិយាសុ** សេចក្តីថា រមែងសិក្សាក្នុងរថសិប្បៈ ។ បទថា **បរិចារិកសមា** បានដល់ ដូចគ្នានឹងទាសៈ និងកម្មករ ។ បទថា **វត្ថធណ្ឌំ** បានដល់ ឈើស្ទួន់ ។ បទថា **បច្ចុបេស្សន្តិ រាជានោ** សេចក្តីថា ពួកព្រាហ្មណ៍មួយពួកទៀត ចូលទៅគប់រកជិតស្និទ្ធព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ។ បទថា **គាមេសុ និគមេសុ ច** សេចក្តីថា អង្គុយនៅក្បែរនិវេសន៍របស់លោកទាំងនោះ ។ បទថា **និគ្គាហកសមា** សេចក្តីថា ដូចរាជបុរសដែលទារកាសីអាករ សេចក្តីថា ជនទាំងនោះពោលថា បើមិនបាននឹងមិនព្រមទៅ ធ្វើនូវការតឹងទាររហូតបាននោះឯងយ៉ាងណា ក៏គិតថា នឹងទៅក្នុងស្រុកឬក្នុងព្រៃក្តី កាលមិនទាន់បានហើយ ពួកយើងនឹងស្លាប់ក៏មិនព្រមក្រោកឡើង ហើយនៅប្រចាំក្នុងទីនោះ ។ បទថា **តេបិ** បានដល់ សូម្បីជនទាំងនោះ ដូចគ្នានឹងក្អាក់ងារទារពន្ធដារមានបាបធម៌ ។

បទថា **វជវេណ្ណាហិ** សេចក្តីថា ព្រាហ្មណ៍មួយពួកទៀត ប្រឡាក់ដោយល្អងធូលី ។ បទថា **យាចកា** បានដល់ អ្នកសូមទ្រព្យ ។ បទថា **ខាណុ-ឃាតសមា** សេចក្តីថា ដូចស្ទូម គឺជាបុគ្គលស្មើដូចជន្ទត់ឈើក្នុងស្រែដែលគេដុតហើយ បានដល់ ពួកជនដែលនាំគ្នាជីកដី ហើយដកគល់ឈើ ដែលភ្លើងឆេះ ព្រោះមានរាងកាយស្មោកគ្រោក និងព្រោះឈរដោយការមិនញាប់ញ័រ ដោយតាំងចិត្តថា បើមិនបានអញមិនទៅ ទើបដូចជាជន្ទត់ឈើ ដែលគេជីកលើកឡើងតម្កល់ទុកដូច្នោះ ។ បទថា **តេបិ** សេចក្តីថា ជនទាំងនោះក៏រក្សាទ្រព្យដែលបានដោយវិធីនោះទុក រហូតក្លាយជាអ្នកមាន ហើយគង់ត្រាច់ទៅយ៉ាងនោះទៀត ជាព្រាហ្មណ៍ទ្រុស្តសីល ។ បទថា **ឧច្ចុម្ពជំ** បានដល់ អំពៅនិងស្ករអំពៅ ។ បទថា **មធុអញ្ជនំ** បានដល់ ទឹកឃ្មុំនិងថ្នាំបន្តក់ភ្នែក ។ បទថា **ឧច្ចាវចានិ** បានដល់ មានតម្លៃតិច និងតម្លៃច្រើន ។ បទថា **បណិ-យានិ** បានដល់ ទ្រព្យទាំងឡាយ ។ បទថា **វិបណេន្តិ** បានដល់រមែងទិញនិងលក់ ។ បទថា **តេបិ** សេចក្តីថា ជនទាំងនោះ លក់របស់ទាំងនេះត្រឹមប៉ុណ្ណោះ ចិញ្ចឹមជីវិតហើយក៏ជាព្រាហ្មណ៍ឈ្មួញ ។ បទថា **ចោសយន្តិ** បានដល់ ឲ្យចិញ្ចឹម ដើម្បីចិញ្ចឹមជីវិត ដោយការលក់ដូរ ។ បទថា **បវេច្ឆន្តិ** សេចក្តីថា ទទួលប្រាក់មាស ឲ្យធីតារបស់ខ្លួនដល់អ្នកដទៃ ជនទាំងនោះឲ្យដល់អ្នកដទៃយ៉ាងនេះ ហៅថា **វិវាហា** ទទួលធីតារបស់អ្នកដទៃដើម្បីកូនប្រុសរបស់ខ្លួន ហៅថា **អាវាហា** ។ បទថា **អម្ពដ្ឋវេសេហិ** សេចក្តីថា ជនទាំងនោះដូចគ្នានឹងពួកកុដុម្ពិកៈនិងគហបតី សូម្បីជនទាំងនោះក៏ហៅថា ព្រាហ្មណ៍

ដោយអំណាចនៃបញ្ញត្តិ ។ បទថា **និក្ខិត្តភិក្ខំ** បានដល់ ព្រាហ្មណ៍មួយពួកទៀតនោះសោត ជាពួកបុរោហិតប្រចាំស្រុក បរិភោគកិក្ខាដែលគេអញ្ជើញដើម្បីប្រយោជន៍ដល់ខ្លួន ។ បទថា **ពហូ ជេ** សេចក្តីថា ជនជាច្រើននាំគ្នាសួរយាមនិងការមង្គល ជាមួយពួកបុរោហិតប្រចាំស្រុកទាំងនោះ ។ បទថា **អណ្ឌច្ឆេទានិ លញ្ឆកា** សេចក្តីថា ជនទាំងនោះស៊ីឈ្នួលក្រៀវគោជាដើម ទទួលយកថ្លៃឈ្នួល ត្រឹមតែអវយវៈ ជារូបត្រីសូលជាដើម គឺធ្វើគ្រឿងសម្គាល់ ។ បទថា **តត្ថ** បានដល់ ក្នុងផ្ទះរបស់ពួកបុរោហិតប្រចាំស្រុកទាំងនោះ ហ្វូងសត្វចិញ្ចឹមជាដើមទាំងនេះ រមែងត្រូវសម្លាប់ដើម្បីលក់សាច់ ។ បទថា **តេបិ** សេចក្តីថា ជនទាំងនោះ ដូចជាអ្នកសម្លាប់គោ គង់គេហៅថាព្រាហ្មណ៍ ។ បទថា **អសិចម្មំ** បានដល់ ដាវនិងគ្រឿងការពារព្រួញ ដែលធ្វើដោយស្បែក ។ បទថា **វេស្សបថេសុ** បានដល់ ក្នុងផ្លូវដើររបស់ពួកឈ្មួញ ។ បទថា **សត្ថំ អព្ពាហយន្តិ** សេចក្តីថា ជួនកាលក៏ទទួលយកកហាបណៈ ១ រយខ្លះ ១ ពាន់ខ្លះ អំពីដៃរបស់ឈ្មួញរទេះដែលជាធំ នាំឆ្លងព្រៃដែលមានចោរ ។ បទថា **គោបនិសាទេហិ** សេចក្តីថា ជនទាំងនោះ ដូចគ្នានឹងពួកនាយគោបាល និងពួកនាយព្រាន គឺពួកចោរដែលប្លន់ស្រុក ។ បទថា **តេបិ** សេចក្តីថា ជនទាំងនោះ គឺជនបែបនោះក៏ហៅថាព្រាហ្មណ៍ ។ បទថា **កូដានិ ការយន្តិ តេ** បានដល់ ដាក់នូវអន្ទាក់និងជង់ជាដើម ។ បទថា **សសវិឡារេ** បានដល់ ទន្សាយផង ឆ្មា[១]ផង លោកសម្តែងដល់ម្រឹគ ដែលត្រាច់ទៅលើ

---

១-បិដកខ្មែរជាខ្លាត្រី ។

គោកដោយពាក្យថា **សសរិឡារេ** នោះ ។ បទថា **អាគោធា មច្ឆកច្ឆបំ** សេចក្ដីថា បៀតបៀន គឺសម្លាប់នូវបណ្ដាសត្វដែលកើតលើគោក ដែលមានជីវិត ធំនិងតូច រហូតដល់ទន្សងជាទីបំផុត បណ្ដាសត្វដែលកើតក្នុងទឹក គឺហ្វូងត្រីនិងអណ្ដើក ( ជាដើម ) ។ បទថា **តេបិ** គឺជនទាំងនោះ ដូចជាព្រាហ្មណ៍ កាឡកិណ្ណី ក៏គង់គេហៅថាព្រាហ្មណ៍ ។ បទថា **អញ្ញេ ធនស្ស កាមាហិ** សេចក្ដីថា មានព្រាហ្មណ៍មួយពួកទៀត ប្រាថ្នាតែនឹងបានទ្រព្យ ។ បទថា **ហេដ្ឋា មញ្ចេ បសក្កិតា** សេចក្ដីថា ជនទាំងនោះគិតថា ពួកយើងនឹងបានធ្វើកម្ម គឺការដេញចង្រៃ ទើបឲ្យសាងគ្រែដែលសម្រេចដោយរតនៈ ចូលទៅដេកក្រោមគ្រែរតនៈនោះ កាលដល់វិធីសោមយាគរបស់ជនទាំងនោះ ព្រះរាជាទាំងឡាយ ក៏ទ្រង់ស្រង់អំពីខាងលើ បានឮថា ជនទាំងនោះកាលពីធីសោមយាគនោះចប់ហើយ ក៏នាំគ្នាមក អង្គុយលើគ្រែនោះ លំដាប់នោះព្រាហ្មណ៍ពួកដទៃត្រិះរិះថា ពួកយើងនឹងបោសកំរោល ក៏ឲ្យជនទាំងនោះងូតទឹក ។ គ្រែរតនៈនិងព្រះរាជអលង្ការគ្រប់យ៉ាងរបស់ព្រះរាជា ក៏ជារបស់អ្នកដេកក្រោមគ្រែទាំងអស់ ។ បទថា **តេបិ** សេចក្ដីថា ជនទាំងនោះ ដូចគ្នានឹងបុគ្គលដុសនូវក្អែល គឺបុគ្គលដែលទទួលយកចង្រៃពីគេ ក៏ហៅថាព្រាហ្មណ៍ ។

ព្រះពោធិសត្វ ក្រាបទូលដល់ពួកព្រាហ្មណ៍ ដោយត្រឹមតែបញ្ញត្តិហៅទាំងនេះដោយប្រការដូច្នេះហើយ ពេលនេះ កាលនឹងទូលថ្វៃងដល់ព្រាហ្មណ៍ដែលមានប្រយោជន៍ដ៏កំពូល បានក្រាបទូលគាថា ២ ថា

បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជា

ពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគភោជនរបស់ព្រះ
អង្គមានដែរ ។ ព្រាហ្មណ៍ទាំងនោះ បរិភោគនូវកត្តតែម្តងទាំង
មិនផឹកនូវទឹកស្រវឹង បពិត្រមហារាជ ( ពួកព្រាហ្មណ៍នេះ )
ខ្ញុំព្រះអង្គបានក្រាបទូលព្រះអង្គហើយ យើងនឹងចូលទៅអញ្ជើញ
ពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលវន្តោ** បានដល់ ជាអ្នកប្រកបដោយអរិយសីល ។ បទថា **ពហុស្សុតា** បានដល់ ប្រកបដោយភាពជាពហុស្សូតព្រោះបដិវេធ ។ បទថា **តាធិសេ** សេចក្តីថា ពួកយើងនឹងចូលទៅជិតដើម្បីអញ្ជើញព្រាហ្មណ៍ គឺព្រះបច្ចេកពុទ្ធ ដែលមានបាបបន្សាត់ហើយបែបនោះ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់វិធូរបណ្ឌិតហើយត្រាស់សួរថា នែសម្លាញ់វិធូរៈ អ្នកមានព្រាហ្មណ៍ដែលជាទក្ខិណេយ្យបុគ្គលបែបនេះនៅឯណា ។ វិធូរៈក្រាបទូលថា បពិត្រមហារាជ លោកនៅឯញកក្ខំនន្ទមូលកៈ ក្នុងហិមវន្តប្បទេសទិសខាងជើង ។ ព្រះរាជាត្រាស់ថា នែបណ្ឌិត បើដូច្នោះ ចូរអ្នកជួយស្វែងរកព្រាហ្មណ៍ទាំងនោះ ដល់យើងដោយកម្លាំងរបស់ខ្លួនចុះ ទ្រង់មានព្រះហឫទ័យសោមនស្ស ត្រាស់ព្រះគាថានេះថា

ម្នាលវិធូរៈ បើពួកព្រាហ្មណ៍ទុំះឯង ជាអ្នកមានសីល ជា
ពហុស្សូតពិតមែន ម្នាលវិធូរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍
ទុំះចុះ ចូរអញ្ជើញព្រាហ្មណ៍ទាំងនោះមកឆាប់ៗ ដូច្នេះ ។

ព្រះមហាសត្វ ទទួលព្រះតម្រាស់របស់ព្រះរាជាដោយពាក្យថា សាធុ

ហើយក្រាបទូលថា បពិត្រព្រះអង្គ បើដូច្នោះ សូមទ្រង់ឲ្យរាជបុរសនាំស្គរចេញទៅ ដើរវាយប្រកាសថា អ្នកនគរគ្រប់គ្នាចូរតាក់តែងព្រះនគរ នាំគ្នាឲ្យទាន អធិដ្ឋានឧបោសថនិងរក្សាសីលឲ្យបានគ្រប់គ្នាចុះ សូម្បីព្រះអង្គ ក៏សូមទ្រង់សមាទានឧបោសថជាមួយជន ដែលជាបរិស័ទចុះ ។ វិធូរបណ្ឌិតបរិភោគអំពីព្រឹកហើយ សមាទានឧបោសថ លុះពេលល្ងាច ឲ្យមនុស្សនាំប្រអប់ដែលពេញដោយផ្កាតាមធម្មជាតិ មួយអន្លើដោយព្រះរាជា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន រឭកដល់គុណទាំងឡាយនៃព្រះបច្ចេកពុទ្ធ ថ្វាយបង្គំហើយនិមន្តដោយពាក្យថា សូមព្រះបច្ចេកពុទ្ធប្រមាណ ៥០០ ដែលស្ថិតនៅត្រង់ញកភ្នំ នន្ទមូលកៈ ក្នុងហិមវន្តប្បទេសទិសខាងជើង ទទួលភិក្ខារបស់យើងខ្ញុំទាំងឡាយ ក្នុងថ្ងៃស្អែកនេះ ហើយបាចផ្កា ៨ ក្តាប់ទៅក្នុងអាកាស ។ កាលនោះព្រះបច្ចេកពុទ្ធ ៥០០ នៅក្នុងទីនោះ ។ ផ្កាទាំងឡាយអណ្តែតទៅធ្លាក់ខាងលើទីស្នាក់នៅនៃព្រះបច្ចេកពុទ្ធទាំងនោះ ។ ព្រះបច្ចេកពុទ្ធដែលជាប្រធានដឹងហេតុនោះក៏ពោលថា អ្នកនិរទុក្ខទាំងឡាយ ពួកយើងត្រូវវិធូរបណ្ឌិតនិមន្តហើយ បុរសនេះមិនមែនជាសត្វធម្មតា ជាសព្វញ្ញូនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បនេះឯង ពួកយើងត្រូវការធ្វើការសង្គ្រោះដល់គេ នាំគ្នាទទួលនិមន្តន៍ហើយ ។ ព្រះមហាសត្វ ដឹងការដែលព្រះបច្ចេកពុទ្ធ ទទួលនិមន្តន៍ដោយសញ្ញាផ្កាទាំងឡាយ មិនហើរត្រឡប់មកវិញ ក៏ក្រាបទូលថា បពិត្រមហារាជ ព្រះបច្ចេកពុទ្ធទាំងឡាយ នឹងនាំគ្នានិមន្តមកក្នុងថ្ងៃស្អែកនេះ សូមទ្រង់ធ្វើសក្ការៈនិងការគោរពរាប់អានចុះ ។ ស្អែកឡើង ព្រះរាជាទ្រង់ធ្វើសក្ការៈធំ ឲ្យតាក់

តែងអាសនៈដែលមានតម្លៃច្រើនត្រង់លានព្រះរាជវាំង ។ ចំណែកព្រះបច្ចេកពុទ្ធ នាំគ្នាប្រតិបត្តិសរីរៈក្នុងអនោតត្តស្រះ ស្រេចហើយ កំណត់កត្តកាល នាំគ្នាមកតាមអាកាស ចុះត្រង់លានព្រះរាជវាំង ព្រះរាជានិងព្រះពោធិសត្វ មានចិត្តជ្រះថ្លា ទទួលបាត្រអំពីព្រះហស្តរបស់ព្រះបច្ចេកពុទ្ធទាំងនោះ និមន្តឲ្យឡើងប្រាសាទ និមន្តឲ្យគង់ហើយថ្វាយនូវទក្ខិណោទក អង្គាសដោយខាទនីយៈនិងភោជនីយៈដ៏ប្រណីត ក្នុងទីបំផុតនៃភត្តកិច្ចរបស់ព្រះបច្ចេកពុទ្ធទាំងនោះ ក៏និមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែកជាប់បន្តគ្នាទៅ រួមជា ៧ ថ្ងៃ ដោយវិធីនេះ ថ្វាយមហាទានក្នុងថ្ងៃជាគម្រប់ ៧ បានថ្វាយបរិក្ខារទាំងពួង ។ ព្រះបច្ចេកពុទ្ធទាំងនោះ ធ្វើអនុមោទនាហើយ នាំគ្នាទៅកាន់ញកភ្នំនន្ទមូលកៈនោះតាមអាកាស ។ បរិក្ខារទាំងឡាយសោត ក៏ហោះទៅតាមក្រោយព្រះបច្ចេកពុទ្ធទាំងនោះឯង ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយត្រាស់បញ្ជាក់ថា ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះបាទកោសល ឧបដ្ឋាករបស់តថាគត ថ្វាយវិចេយ្យទាន គឺជ្រើសរើសដើម្បីឲ្យ មិនគួរអស្ចារ្យឡើយ បណ្ឌិតក្នុងកាលមុន ទោះបីព្រះពុទ្ធមិនកើតឡើង ក៏បានថ្វាយទានហើយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ព្រះបច្ចេកពុទ្ធទាំងឡាយបរិនិព្វានហើយ ចំណែកវិធុរបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទសព្រាហ្មណជាតក ចប់

# ភិក្ខាបរម្បរជាតក

[ ១៥៣ ] ( កុដុម្ពិកៈទូលថា ) ខ្ញុំព្រះអង្គបានឃើញព្រះអង្គ មានព្រះរូបទន់ភ្លន់ ចេញចាកដែនមកកាន់ព្រៃស្ងាត់ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈដ៏ថ្លៃថ្លា ដែលគេក្រាលបម្រុងទុក ទើបថ្វាយក្រយាស្ងោយដ៏ឧត្តម ជាកត្តនៃស្រូវសាលីដ៏វិចិត្រ លាយដោយសាច់ដ៏ស្អាត ចំពោះព្រះអង្គនោះ ដោយសេចក្ដីស្រឡាញ់ ព្រះអង្គទទួលក្រយាស្ងោយនោះហើយ តែមិនសោយ ដោយព្រះអង្គឯងត្រឡប់ជាប្រទានដល់ព្រាហ្មណ៍វិញ សូមក្រាបថ្វាយបង្គំចំពោះព្រះអង្គ តើការណ៍នេះជាសភាពដូចម្ដេច ។

[ ១៥៤ ] ( ព្រះរាជាត្រាស់ថា ) ព្រាហ្មណ៍ ( នេះ ) ជាអាចារ្យរបស់យើង ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចតូចនិងកិច្ចធំផង ជាបុគ្គលគួរគោរពផង គួរឲ្យយើងហៅរកផង ( ព្រោះហេតុនោះ ) យើងគួរឲ្យភោជន ។

[ ១៥៥ ] ( កុដុម្ពិកៈ... ) ឥឡូវនេះ ខ្ញុំសូមសួរព្រាហ្មណ៍ជា គោតមគោត្តដែលស្ដេចតែងបូជា ព្រះរាជាបានប្រទានកត្តដែលលាយដោយសាច់ដ៏ស្អាតដល់អ្នក អ្នកបានទទួលកត្តនោះហើយ ក៏បានប្រគេននូវភោជនដល់ឥសីវិញ អ្នកប្រហែលជាដឹងថា ខ្លួនមិនមែនជាខេត្តនៃទាន ខ្ញុំសូមថ្វាយបង្គំចំពោះអ្នក តើការណ៍នេះ ជាសភាពដូចម្ដេច ។

[ ១៥៦ ] ( ព្រាហ្មណ៍តបថា ) ខ្ញុំតែងចិញ្ចឹមកូននិងប្រពន្ធផង ចំពាក់ចិត្តក្នុងផ្ទះទាំងឡាយផង ប្រៀនប្រដៅព្រះរាជាថា សូមព្រះអង្គសោយនូវកាមទាំងឡាយ ជារបស់នៃមនុស្សផង ហេតុនោះបានជាខ្ញុំគួរប្រគេនភោជនដល់ឥសីវិញ ដែលនៅក្នុងព្រៃមានតបៈអស់កាលវែង ចម្រើនដោយគុណ មានចិត្ត

ចម្រើនហើយ ។

[ ១៥៧ ] ( កុដុម្ពិកៈ... ) ឥឡូវនេះ ខ្ញុំសូមសួរឥសីដែលស្គមរីមរវាម ដោយសរសៃ មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល លោកនៅក្នុងព្រៃម្នាក់ឯង មិនស្តាយជីវិត លោកបាន ប្រគេនភោជនដល់ភិក្ខុណា ភិក្ខុនោះ ប្រសើរជាងលោកដោយគុណដូចម្តេច ។

[ ១៥៨ ] ( តាបសតបថា ) អាត្មាជីកជំឡូងឈ្មោះអាលុកលម្ពៈនិង តាលកន្ទៈទាំងឡាយផង ជំឡូងឈ្មោះពិលាលិនិងតក្កលៈទាំងឡាយផង ប្រូត ស្រងែនិងស្ពៅ ( យកមក ) បែនបុក ( បរិភោគ ) ផង នាំយកគ្រឿងអន្ទក់ និងក្រអៅឈូក ទឹកឃ្មុំ សាច់ ពុទ្រា និងកន្ទួតព្រៃ មកបរិភោគផង នោះជា កំណាន់របស់អាត្មា អាត្មាជាបុគ្គលជាំស្វ មានសេចក្តីខ្វល់ខ្វាយ មានសេចក្តី ប្រកាន់នៅឡើយ គួរប្រគេនភោជនដល់ភិក្ខុដែលជាអ្នកមិនជាំស្វ មិនមាន តណ្ហា មិនមានសេចក្តីប្រកាន់ ។

[ ១៥៩ ] ( កុដុម្ពិកៈ... ) ឥឡូវនេះ ខ្ញុំសូមសួរភិក្ខុដែលអង្គុយស្ងៀម មានវត្តល្អដូចតទៅនេះ ( ឥសី ) បានប្រគេនភត្តដែលលាយដោយសាច់ដ៏ស្អាត ដល់លោក លោកទទួលភត្តនោះហើយ ក៏បរិភោគស្ងៀមៗម្នាក់ឯង មិនបាន អញ្ជើញបុគ្គលដទៃណាមួយ ( ឲ្យបរិភោគផង ) ឡើយ ខ្ញុំសូមថ្វាយបង្គំ ចំពោះលោកតើការណ៍នេះជាសភាពដូចម្តេច ។

[ ១៦០ ] ( ព្រះបច្ចេកពុទ្ធ... ) អាត្មាមិនជាំស្វខ្លួនឯង មិនប្រើឲ្យគេ ជាំស្វ មិនកាត់ខ្លួនឯង មិនប្រើគេឲ្យកាត់ ហេតុនោះបានជាឥសីដឹងថា អាត្មា

ជាអ្នកមិនមានសេចក្តីកង្វល់ ជាអ្នកប្រាសចាកបាបគ្រប់ចំពូក ទើបកាន់ចង្អាន់ដោយដៃធ្វេង កាន់សម្បកឃ្មោកដោយដៃស្តាំ ហើយប្រគេនកត្តដែលលាយដោយសាច់ដ៏ស្អាត នោះដល់អាត្មា ។ តាមពិត ជនទាំងឡាយ ( មានស្តេចជាដើម ) នុ៎ះ ជាអ្នកប្រកាន់ថារបស់អញ មានសេចក្តីហួងហែង គួរតែឲ្យទាន ( ដល់បុគ្គលប្រាកដស្មើដោយអាត្មា ) បុគ្គលណាអញ្ជើញ នូវអ្នកឲ្យទាន ( មកបរិភោគ ) អាត្មាសំគាល់ ( នូវបុគ្គលនោះ ) ថាជាអ្នកប្រតិបត្តិខុសទំនង ។

[ ១៦១ ] ( កុដុម្ពិកៈ... ) ក្នុងថ្ងៃនេះ ព្រះរាជាព្រះអង្គប្រសើរលើរថបានយាងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំមែនហើយដ្បិតខ្ញុំបានដឹងច្បាស់ក្នុងថ្ងៃនេះថា ទានដែលគេឲ្យហើយ ចំពោះបុគ្គលណា ជាទានមានផលច្រើន ។ ស្តេចទាំងឡាយជាប់ចំពាក់ ក្នុងដែនដី ពួកព្រាហ្មណ៍ ជាប់ចំពាក់ក្នុងកិច្ចតូចនិងកិច្ចធំ ពួកឥសី ជាប់ចំពាក់ក្នុងមើមឈើនិងផ្លែឈើ ឯពួកភិក្ខុ ទើបរួចស្រឡះចាកកិលេស ។

**ចប់ ភិក្ខាបរម្បរជាតកទី ១៣**

**ឧទ្ទាននៃបកិណ្ណកនិបាតនោះគឺ**

និយាយអំពីសេក ១ កិន្នរ ១ គប់ភ្លើង ១ ជដិលជណ្តប់ស្បែក ខ្លាឃ្មុំទាំងក្របក ១ ក្រអៅឈូក ១ អគ្គមហេសី ១ ព្រាប ដ៏ប្រសើរ ១ ក្អែក ១ ជ្រូកឈ្មោះតុណ្ឌិលៈ ១ ពាណិជ ១ ១ សាធិនរាជ ១ ព្រាហ្មណ៍ ១ ចង្ហាន់ឲ្យតៗគ្នា ១ ។

**ចប់ បកិណ្ណកនិបាត**

# អដ្ឋកថា
# ភិក្ខាបរម្បរជាតក

[ ១៥៣-១៦១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សុខុមាលរូបំ ទិស្វា** ដូច្នេះជាដើម ។

រឿងមានដូច្នេះថា កុដុម្ពិកៈនោះមានសទ្ធាជ្រះថ្លា ធ្វើមហាសក្ការៈដល់ព្រះតថាគត និងដល់សង្ឃរឿយៗ ។ សម័យថ្ងៃមួយកុដុម្ពិកៈបានគិតថា អញថ្វាយភោជនដ៏ប្រណីត និងសំពតសាច់ម៉ដ្ឋដល់ព្រះពុទ្ធរតនៈ និងព្រះសង្ឃធ្វើមហាសក្ការៈរឿយ ៗ ពេលនេះត្រូវធ្វើមហាសក្ការៈ ដល់ព្រះធម្មរតនៈខ្លះ កាលធ្វើសក្ការៈដល់ព្រះធម្មរតនៈនោះ ត្រូវធ្វើដូចម្តេចហ្ន៎ ។ គាត់កាន់យកនូវគ្រឿងក្រអូប និងកម្រងផ្កាជាច្រើនទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តាក្រាបទូលសួរថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គប្រាថ្នានឹងធ្វើសក្ការៈ ដល់ព្រះធម្មរតនៈគួរធ្វើដូចម្តេចហ្ន៎ ។ កាលណោះព្រះសាស្តាត្រាស់ថា អ្នកប្រាថ្នានឹងធ្វើសក្ការៈដល់ព្រះធម្មរតនៈសោត ក៏ចូរធ្វើសក្ការៈដល់អានន្ទដែលជាឃ្លាំងធម៌ចុះ ។ កុដុម្ពិកៈក្រាបទូលថា សាធុ និមន្តព្រះថេរៈក្នុងថ្ងៃស្អែក នាំទៅកាន់ផ្ទះរបស់ខ្លួនដោយសក្ការៈធំ ឲ្យលោកអង្គុយលើអាសនៈ ដែលមានតម្លៃច្រើនបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ថ្វាយភោជនមានរសដ៏ប្រសើរផ្សេងៗ ហើយបានថ្វាយសំពត់មានតម្លៃថ្លៃ គួរដល់ត្រៃចីវរ ។ ព្រះថេរៈក៏ត្រិះរិះថា សក្ការៈនេះកុដុម្ពិកៈធ្វើដល់ព្រះធម្មរតនៈ មិនសមគួរដល់អញឡើយ

សមគួរដល់ព្រះធម្មសេនាបតី ទើបនាំបិណ្ឌបាតនិងសំពត់ទៅកាន់វិហារប្រគេន ដល់ព្រះសារីបុត្តត្ថេរជាដើម ព្រះសារីបុត្តនោះក៏ត្រិះរិះថា សក្ការៈនេះ គេធ្វើដល់ព្រះធម្មរតនៈ គួរដល់ព្រះសម្មាសម្ពុទ្ធដែលជាម្ចាស់របស់ធម៌ មួយអន្លើដោយពិត ហើយទើបថ្វាយដល់ព្រះទសពល ព្រះសាស្តាទ្រង់មិនឃើញបុគ្គលក្រៃលែងជាងព្រះអង្គ ទើបទ្រង់សោយបិណ្ឌបាត ទទួលសំពត់ចីវរ ។

ពួកភិក្ខុលើករឿងនោះឡើងសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ កុដុម្ពិកៈឈ្មោះនោះ គិតថានឹងធ្វើសក្ការៈដល់ព្រះធម្មរតនៈ បានប្រគេនដល់ព្រះអានន្ទត្ថេរ ដែលជាភណ្ឌាគារិកៈ ព្រះថេរៈត្រិះរិះថា របស់នេះមិនសមគួរដល់ខ្លួន បានប្រគេនដល់ព្រះធម្មសេនាបតី ព្រះធម្មសេនាបតីក៏ត្រិះរិះថារបស់នេះមិនសមគួរដល់ខ្លួន ក៏ថ្វាយដល់ព្រះតថាគត ពេលនោះព្រះតថាគត ទ្រង់មិនបានឃើញអ្នកដទៃក្រៃលែងជាងព្រះអង្គ ទ្រង់ព្រះតម្រិះថា សក្ការៈនោះសមគួរដល់តថាគតប៉ុណ្ណោះ ហើយទ្រង់សោយបិណ្ឌបាតនោះ និងទទួលសំពត់ចីវរ ព្រោះព្រះអង្គជាម្ចាស់នៃធម៌ បិណ្ឌបាតនោះដល់បាទមូលរបស់ព្រះធម្មសាមីនោះឯង ព្រោះទ្រង់ជាបុគ្គលសមគួរដោយអាការៈយ៉ាងនេះ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលបិណ្ឌបាតមកតៗគ្នា រហូតដល់បុគ្គលដែលសមគួរបាន សូម្បីក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើង

ក៏បានដល់ហើយដូចគ្នា ពួកភិក្ខុនាំគ្នាក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តទ្រង់លះនូវការលុះនូវអគតិ មិនឲ្យរាជធម៌ទាំង ១០ ប្រការវិនាសសាបសូន្យ សោយរាជសម្បត្តិដោយធម៌ ក្នុងនគរពារាណសី កាលបើដូច្នេះ ការវិនិច្ឆ័យរបស់ព្រះអង្គមិនចាំបាច់មាន ហាក់ដូចជាទទេ ព្រះរាជាក៏ទ្រង់ស្វែងរកទោសរបស់ព្រះអង្គ ទ្រង់កំណត់មើលទាំងខាងក្នុងព្រះរាជនិវេសន៍ជាដើម មិនឃើញដល់អ្នកពោលទោសរបស់ព្រះអង្គ ខាងក្នុងព្រះរាជវាំង ខាងក្នុងព្រះនគរ និងក្នុងស្រុកជិតទ្វារព្រះនគរ ទ្រង់ត្រិះរិះថា នឹងត្រូវស្វែងរកក្នុងជនបទ ទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ពួកអាមាត្យ ទ្រង់ក្លែងខ្លួនចារិកទៅក្នុងកាសិករដ្ឋជាមួយបុរោហិត ទ្រង់មិនជួបបុគ្គលពោលទោសរបស់ទ្រង់សូម្បីត្រឹមតែម្នាក់ ៗ លុះយាងដល់និគមមួយក្នុងជាយដែន ប្រថាប់គង់ត្រង់សាលាក្រៅទ្វារ ខណៈនោះ កុដុម្ពិក:មានសម្បត្តិ ៨០ កោដិ ជាអ្នកនិគមនោះ បានទៅកាន់កំពង់ទឹកជាមួយបរិវារច្រើន ឃើញព្រះរាជាមានសរីរៈល្អិតល្អន់ មានពណ៌សម្បុរដូចមាស ប្រថាប់គង់ត្រង់សាលា កើតនូវសេចក្តីស្រឡាញ់រាប់អាន ចូលទៅកាន់សាលាធ្វើបដិសណ្ឋារៈ ហើយអញ្ជើញថា សូមលោកនៅត្រង់នេះប៉ុណ្ណោះ ទៅកាន់ផ្ទះ រៀបចំភោជនមានរសប្រសើរផ្សេងៗ ឲ្យបរិវារច្រើននាក់ កាន់ភាជនៈដាក់កត្តទៅ ខណៈនោះ តាបសអ្នកនៅក្នុងហិមវន្តប្បទេស បានអភិញ្ញា ៥ មកអង្គុយក្នុងសាលានោះដូចគ្នាហើយ មានព្រះបច្ចេកពុទ្ធចេញអំពីញកភ្នំនន្ទមូលកៈ មកតាមអាកាស អង្គុយក្នុង

សាលានោះមួយអន្លើដែរ កុដុម្ពិកៈ ថ្វាយទឹកជម្រះព្រះហស្ត ដល់ព្រះរាជា ត្រៀមថាសដាក់ភត្ត មួយអន្លើដោយសម្លដែលមានរសប្រសើរផ្សេងៗបង្អោន ចូលទៅថ្វាយ ។ ព្រះរាជាទ្រង់ទទួលភត្តនោះហើយ ព្រះរាជទានដល់បុរោហិត ព្រាហ្មណ៍ទទួលភត្តនោះហើយ ប្រគេនដល់តាបស តាបសទទួលភត្តនោះហើយ ទៅកាន់សម្នាក់របស់ព្រះបច្ចេកពុទ្ធ កាន់ថាសភត្តដោយដៃខាងឆ្វេង កាន់ឃ្លោកទឹកដោយដៃខាងស្តាំ ថ្វាយទក្ខិណោទក ហើយដាក់ភត្តក្នុងបាត្រ ព្រះបច្ចេកពុទ្ធមិនបានអញ្ជើញ មិនបានសាកសួរអ្នកណា ឆាន់ហើយ ក្នុងពេលដែលលោកស្រេចភត្តកិច្ច កុដុម្ពិកៈត្រិះរិះថា អញថ្វាយភត្តដល់ព្រះរាជា ព្រះរាជាព្រះរាជទានភត្តដល់បុរោហិត បុរោហិតប្រគេនដល់តាបស តាបសប្រគេនដល់ព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធមិនបានសាកសួរអ្នកណាឡើយ ហើយឆាន់ អ្វីហ្ន៎ជាហេតុនៃការឲ្យរបស់ជនមានប្រមាណប៉ុណ្ណេះ អ្វីជាហេតុមិនសាកសួរ បុគ្គលណាមួយហើយឆាន់របស់ព្រះបច្ចេកពុទ្ធអង្គនេះ អញនឹងត្រូវសួរលោកទាំងនោះតាមលំដាប់ ។ គាត់ចូលទៅរកម្តងមួយអង្គ ថ្វាយបង្គំហើយសួរ សូម្បីលោកទាំងនោះ ក៏ប្រាប់ដូចតទៅនេះថា

ខ្ញុំព្រះអង្គបានឃើញព្រះអង្គមានព្រះរូបទន់ភ្លន់ ចេញចាកដែនមកកាន់ព្រៃស្ងាត់ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈដ៏ថ្លៃថ្លា ដែលគេក្រាលបម្រុងទុកទើបថ្វាយក្រយាស្ងោយដ៏ឧត្តម ជាភត្តនៃស្រូវសាលីដ៏វិចិត្រ លាយដោយសាច់ដ៏ស្អាតចំពោះព្រះអង្គនោះ ដោយសេចក្តីស្រឡាញ់ ព្រះអង្គទទួល

ក្រយាស្ងោយនោះហើយ តែមិនសោយដោយព្រះអង្គឯងត្រឡប់ជាប្រទានដល់ព្រាហ្មណ៍វិញ សូមក្រាបថ្វាយបង្គំចំពោះព្រះអង្គ តើការណ៍នេះ ជាសភាពដូចម្តេច ។

ព្រះរាជាត្រាស់ថា

ព្រាហ្មណ៍ ( នេះ ) ជាអាចារ្យរបស់យើង ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចតូចនិងកិច្ចធំផង ជាបុគ្គលគួរគោរពផង គួរឲ្យយើងបោរកផង ( ព្រោះហេតុនោះ ) យើងគួរឲ្យភោជន ។

កុដុម្ពិកៈពោលថា

ឥឡូវនេះ ខ្ញុំសូមសួរព្រាហ្មណ៍ ជាគោតមគោត្តដែលស្តេចតែងបូជា ព្រះរាជាបានប្រទានភត្ត ដែលលាយដោយសាច់ដ៏ស្អាតដល់អ្នក អ្នកបានទទួលភត្តនោះហើយ ក៏បានប្រគេននូវភោជនដល់ឥសីវិញ អ្នកប្រហែលជាដឹងថា ខ្លួនមិនមែនជាខេត្តនៃទាន ខ្ញុំសូមថ្វាយបង្គំចំពោះអ្នក តើការណ៍នេះ ជាសភាពដូចម្តេច ។

ព្រាហ្មណ៍តបថា

ខ្ញុំតែងចិញ្ចឹមកូននិងប្រពន្ធផង ចំពាក់ចិត្តក្នុងផ្ទះទាំងឡាយផង ប្រៀនប្រដៅព្រះរាជាថា សូមព្រះអង្គសោយនូវកាមទាំងឡាយជារបស់នៃមនុស្សផង ហេតុនោះបានជាខ្ញុំគួរប្រគេនភោជនដល់ឥសីវិញ ដែលនៅក្នុងព្រៃមាន តបៈអស់កាលវែង ចម្រើន

ដោយគុណ មានចិត្តចម្រើនហើយ ។

កុដុម្ពិកៈពោលថា

ឥឡូវនេះ ខ្ញុំសូមសួរឥសីដែលស្គម រីមរវាមដោយសរសៃ មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល លោកនៅក្នុងព្រៃម្នាក់ឯង មិនស្តាយជីវិត លោកបានប្រគេនភោជនដល់ភិក្ខុណា ភិក្ខុនោះ ប្រសើរជាង លោក ដោយគុណដូចម្តេច ។

តាបសតបថា

អាត្មាជីកជំឡូងឈ្មោះអាលុកលម្ពៈ និងតាលកន្ទះទាំងឡាយ ផង ជំឡូងឈ្មោះពិលាលិ និងតក្កលៈទាំងឡាយផង ប្រូត ស្រងែនិងស្តៅ ( យកមក ) បៃនបុក ( បរិភោគ ) ផង នាំយក គ្រឿងអន្ទក់និងក្រអៅឈូក ទឹកឃ្មុំ សាច់ ពុទ្រា និង កន្ទួតព្រៃ មកបរិភោគផង នោះជាកំណាន់របស់អាត្មា អាត្មា ជាបុគ្គលជាំស្វ មានសេចក្តីខ្វល់ខ្វាយ មានសេចក្តីប្រកាន់នៅ ឡើយ គួរប្រគេនភោជនដល់ភិក្ខុ ដែលជាអ្នកមិនជាំស្វ មិន មានតណ្ហា មិនមានសេចក្តីប្រកាន់ ។

កុដុម្ពិកៈពោលថា

ឥឡូវនេះ ខ្ញុំសូមសួរភិក្ខុដែលអង្គុយស្ងៀមមានវត្តល្អដូចតទៅ នេះ ( ឥសី ) បានប្រគេនភត្តដែលលាយដោយសាច់ដ៏ស្អាត

ដល់លោក លោកទទួលភត្តនោះហើយ ក៏បរិភោគស្ងៀមៗ ម្នាក់ឯង មិនបានអញ្ជើញបុគ្គលដទៃណាមួយ ( ឲ្យបរិភោគ ផង ) ឡើយ ខ្ញុំសូមថ្វាយបង្គំចំពោះលោក តើការណ៍នេះជា សភាពដូចម្ដេច ។

ព្រះបច្ចេកពុទ្ធពោលថា

អាត្មាមិនដាំស្លខ្លួនឯង មិនប្រើឲ្យគេដាំស្ល មិនកាត់ខ្លួនឯង មិន ប្រើគេឲ្យកាត់ ហេតុនោះ បានជាឥសីដឹងថា អាត្មាជាអ្នកមិន មានសេចក្ដីកង្វល់ ជាអ្នកប្រាសចាកបាបគ្រប់ចំពូក ទើបកាន់ ចង្ហាន់ដោយដៃឆ្វេង កាន់សម្បកឃ្លោកដោយដៃស្ដាំ ហើយ ប្រគេនភត្តដែលលាយដោយសាច់ដ៏ស្អាត នោះដល់អាត្មា ។ តាមពិត ជនទាំងឡាយ ( មានស្ដេចជាដើម ) នុ៎ះ ជាអ្នក ប្រកាន់ថា របស់អញ មានសេចក្ដីហួងហែង គួរតែឲ្យទាន ( ដល់ បុគ្គលប្រាកដស្មើដោយអាត្មា ) បុគ្គលណាអញ្ជើញនូវអ្នកឲ្យ ទាន ( មកបរិភោគ ) អាត្មាសំគាល់ ( នូវបុគ្គលនោះ ) ថា ជាអ្នកប្រតិបត្តិខុសទំនង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឝិរំ** សេចក្ដីថា ទ្រង់ធ្លាប់មកកាន់ជាយដែន នេះ ដែលដូចជាព្រៃមិនមានទឹក ។ បទថា **កូដាគារវរូបេតំ** សេចក្ដីថាធ្លាប់ យាងទៅកាន់ព្រះដំណាក់ដ៏ប្រសើរ គឺធ្លាប់ប្រថាប់នៅក្នុងដំណាក់ដ៏ប្រសើរ មួយ កន្លែង ។ បទថា **មហាសយនមុបាសិតំ** បានដល់ ធ្លាប់ចូលកាន់ព្រះទែន

សិរីសេយ្យាសនៈដែលតាក់តែងទុកយ៉ាងល្អ ក្នុងព្រះរាជដំណាក់នោះឯង ។ បទថា **តស្ស តេ** សេចក្តីថា ទូលបង្គំឃើញទ្រង់បែបនេះ ។ បទថា **បេមកេន** សេចក្តីថា ដោយការស្រឡាញ់ ដែលមានចំពោះទ្រង់នោះ ។ បទថា **វណ្ណ-មោទនំ** បានដល់ បាយដែលល្អ ។ បទថា **វិចិត្តំ** សេចក្តីថា ចម្អិនដោយអង្ករដ៏ល្អ ប្រាសចាកគ្រាប់អង្ករដែលបាក់ និងគ្រាប់អង្ករដែលមានពណ៌ខ្មៅ ។ បទថា **អធាបយិ** បានដល់ បានថ្វាយហើយ ។ បទថា **អត្តានំ** កែជា **អត្តនា** ប្រែថា ដោយព្រះអង្គ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **អនសិត្វាន** បានដល់ មិនបានសោយហើយ ។ បទថា **កោយំ ធម្មោ** សេចក្តីថា បពិត្រមហារាជ សេចក្តីនេះជាសភាវធម៌អ្វីរបស់ទ្រង់ ។ បទថា **ឆមត្តុ តេ** សេចក្តីថា ទូលព្រះបង្គំសូមថ្វាយបង្គំដល់ព្រះអង្គ ដែលមិនបានសោយដោយព្រះអង្គឯង ហើយព្រះរាជទានដល់អ្នកដទៃ ។ បទថា **អាចារិយោ** សេចក្តីថា ម្នាលកុដុម្ពិកៈ ព្រាហ្មណ៍នេះជាអាចារ្យ ទូន្មានអាចារៈរបស់ខ្ញុំ ។ បទថា **ព្យាវដោ** បានដល់ ជាអ្នកខ្វល់ខ្វាយ ។ បទថា **អាមន្តនីយោ** សេចក្តីថា គួរខ្ញុំគប្បីអញ្ជើញ គឺសមនឹងកាន់យកវត្ថុដែលខ្ញុំឲ្យ ។ បទថា **ធាតុ-មរហាមិ** សេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំគួរឲ្យភោជនដល់អាចារ្យបែបនេះ ទាំងនេះព្រះរាជាទ្រង់ពណ៌នាគុណរបស់ព្រាហ្មណ៍ ។ បទថា **អខេត្តញ្ញាសិ** សេចក្តីថា ប្រហែលជាលោកជ្រាបថា ខ្លួនមិនមែនខេត្តនៃទានយ៉ាងនេះថា ខ្ញុំមិនមែនខេត្តនៃទាន វត្ថុដែលឲ្យក្នុងខ្ញុំ មិនមានផលច្រើនឡើយ ។ បទថា **អនុសាសាមិ** សេចក្តីថា ខ្ញុំលះបង់ប្រយោជន៍ខ្លួនហើយ ថ្វាយអនុសាសន៍

អត្ថនិងធម៌ដល់ព្រះរាជា ។

បុរោហិត កាលពោលដល់ទោសរបស់ខ្លួនយ៉ាងនេះហើយ ពោលដល់គុណរបស់ឥសីថា **អារញ្ញិកស្ស** ដូច្នេះ ។ បទថា **ឥសិនោ** បានដល់ជាអ្នកស្វែងរកគុណ មានសីលជាដើម ។ បទថា **តបស្សិនោ** បានដល់ ជាអ្នកបំពេញតបៈ ។ បទថា **វុឌ្ឍស្ស** បានដល់ បុគ្គលជាបណ្ឌិត ចម្រើនដោយគុណធម៌ ។ បទថា **ឆាវកន្ទុសិ** សេចក្ដីថា ទាំងខ្លួនឯង ក៏រកភោជនបានលំបាក គង់ឲ្យភោជននេះដល់អ្នកដទៃ មិនអាឡោះអាល័យក្នុងជីវិត របស់ខ្លួនទេឬ ។ បទថា **ភិក្ខុ ភោន** បានដល់ ភិក្ខុនេះប្រសើរជាងលោកម្ចាស់ដោយគុណអ្វីហ្ន៎ ។ បទថា **ខណាមាលុកលម្ពានិ** សេចក្ដីថា អាត្មានៅជីកដំឡូង ។ បទថា **ពិលាលិតក្កលានិ ច** បានដល់ ដំឡូងដៃខ្លា និងដំឡូងពងលលក ។ បទថា **ធុនំ សាមាកនិវារំ** សេចក្ដីថា ឥសីពោលថា ខ្ញុំប្រុតស្តៅនិងស្កួយ[១] ។ បទថា **សំឃារិយំ បសារិយំ** សេចក្ដីថា ឥសីពោលថា ខ្ញុំប្រុតស្តៅនិងស្កួយទាំងនោះបាន បោកហើយហាលថ្ងៃឲ្យស្ងួត អុំដោយចង្អេរ បុកឲ្យជាអង្ករ នាំមកចម្អិនបរិភោគ ។ បទថា **សាកំ** បានដល់ ស្លឹកឈើគ្រប់ប្រភេទ ដែលធ្វើម្ហូបបាន ។ បទថា **មំសំ** បានដល់ សាច់មានសាច់ដែលជារំពារាជសីហ៍និងខ្លាធំជាដើម ។ បទថា **តានិ អាហរិត្វា** សេចក្ដីថា នាំបន្លែជាដើមទាំងនេះមក ។ បទថា **អមមស្ស** បានដល់ ជាអ្នកអស់នូវការជាប់ចំពាក់ថាអញដោយអំណាចតណ្ហានិងទិដ្ឋិ ។ បទថា **សកិញ្ចនោ** បានដល់ នៅមានការជាប់

---

១-បិដកខ្មែរជាស្រងែ ។

ចំពាក់ ។ បទថា **អឆាឆានស្ស** បានដល់ ជាអ្នកមិនប្រកាន់ ។ បទថា **ឆា-តុមរហាមិ** សេចក្តីថា រមែងគួរបានភោជនដែលខ្ញុំបានហើយដល់ព្រះបច្ចេកពុទ្ធបែបនេះ ។ បទថា **តុណ្ហីមាសីនំ** បានដល់ អង្គុយមិនពោលនឹងបុគ្គលណា ។ បទថា **អាកិញ្ចនំ** បានដល់ វៀរចាកការជាប់ចំពាក់ដោយអំណាចរាគៈជាដើម ។ បទថា **អារតំ** បានដល់ វៀរផ្តាច់ហើយ គឺលះបាបទាំងពួងតាំងនៅ ។ បទថា **កមណ្ឌលុំ** បានដល់ ល័ក្កចាន់ ( ឃ្លោកទឹក ) ។ បទថា **ឃតេ ហិ** សេចក្តីថា ព្រះបច្ចេកពុទ្ធលោកលាព្រះហស្តចង្អុលទៅកាន់ជនទាំងនោះថា ជនទាំង ៣ មានព្រះរាជាជាដើមនេះ ហើយពោលទុកយ៉ាងនេះ ។ បទថា **ឆាតុមរហាន្តិ** សេចក្តីថា រមែងគួរដែលនឹងឲ្យដល់បុគ្គលដូចអាត្មា ។ បទថា **បច្ចនីកំ** សេចក្តីថា ជាបដិបទាដែលខុស ។ សេចក្តីពិត ការអញ្ជើញអ្នកឲ្យរមែងឈ្មោះថា ជាមិច្ឆាជីវៈបដិបត្តិ ពោលគឺជាការចិញ្ចឹមជីវិតដោយការស្វែងរកជុំបាយ ដើម្បីដូរជុំបាយឯណានីមួយក្នុងបណ្តា អនេសនា ២១ យ៉ាង ។

កុដុម្ពិកៈស្តាប់ពាក្យនោះ របស់លោកហើយត្រេកអរ ពោលគាថា ចុងក្រោយ ២ គាថាដូច្នេះថា

> ក្នុងថ្ងៃនេះ ព្រះរាជាព្រះអង្គប្រសើរលើរថ បានយាងមកក្នុង
> ទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំមែនហើយ ដ្បិតខ្ញុំបានដឹងច្បាស់
> ក្នុងថ្ងៃនេះថា ទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទាន
> មានផលច្រើន ។ ស្តេចទាំងឡាយ ជាប់ចំពាក់ក្នុងដែនដី ពួក

ព្រាហ្មណ៍ជាប់ចំពាក់ក្នុងកិច្ចតូចនិងកិច្ចធំ ពួកឥសីជាប់ចំពាក់ក្នុងមើមឈើនិងផ្លែឈើ ឯពួកភិក្ខុ ទើបរួចស្រឡះចាកកិលេស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រជេសភោ** សេចក្ដីថា កុដុម្ពិកៈពោលសំដៅដល់ព្រះរាជា ។ បទថា **កិច្ចាកិច្ចេសុ** បានដល់ ក្នុងកិច្ចរបស់ព្រះរាជា ដែលខ្លួនគប្បីធ្វើ ។ បទថា **ភិក្ខវោ** បានដល់ តែភិក្ខុដែលជាព្រះបច្ចេកពុទ្ធទាំងឡាយ បានផុតហើយចាកភពទាំងពួង ។

ព្រះបច្ចេកពុទ្ធសម្ដែងធម៌ដល់កុដុម្ពិកៈហើយ ត្រឡប់ទៅកាន់លំនៅរបស់ខ្លួននោះឯង តាបសក៏ដូចគ្នា ចំណែកព្រះរាជា ទ្រង់ស្នាក់នៅក្នុងសម្នាក់របស់កុដុម្ពិកៈ ២-៣ ថ្ងៃ ហើយទៅកាន់នគរពារាណសីវិញ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលបិណ្ឌបាតមកដល់បុគ្គលដែលសមគួរបាន សូម្បីក្នុងកាលមុន ក៏បានដល់ហើយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា កុដុម្ពិកៈអ្នកបូជាធម៌ក្នុងកាលនោះ បានមកជាកុដុម្ពិកៈដែលធ្វើសក្ការៈដល់ព្រះធម្មរតនៈក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ បុរោហិតក្នុងកាលនោះ បានមកជាសារីបុត្ត ព្រះបច្ចេកពុទ្ធបានបរិនិព្វានហើយ ចំណែកតាបសដែលចេញអំពីព្រៃហិមពាន្ត ក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា ភិក្ខាបរម្បរជាតក ចប់

បកិណ្ណកនិបាតជាតក ចប់

# វីសតិនិបាតជាតក

## មាតង្គជាតក

[ ១៦២ ] ( មណ្ឌព្យកុមារសួរថា ) អ្នកមកអំពីទីណា បានជាមានប្រដាប់ស្លៀកពាក់អាក្រក់លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ដែលគេចោលលើគំនរសំរាមឰដ៏ក ខ្លួនអ្នកជាបុគ្គលផ្តេសផ្តាស មិនមែនជាទក្ខិណេយ្យបុគ្គលទេ ។

[ ១៦៣ ] ( មាតង្គមហាសត្វឆ្លើយថា ) គ្រឿងបរិភោគនេះបរិបូណ៌ដោយបរិវារ អ្នកបានតាក់តែងហើយ ពួកជនតែងទំពាស៊ី បរិភោគផឹកនូវគ្រឿងបរិភោគនោះ អ្នកស្គាល់ហើយនូវយើងថាជាអ្នកចិញ្ចឹមជីវិតដោយសារអ្នកដទៃឲ្យ សូមឲ្យមនុស្ស ចណ្ឌាលបាននូវដុំបាយដែលបុគ្គលគប្បីទៅឈរជិត ។

[ ១៦៤ ] ( មណ្ឌព្យកុមារ... ) គ្រឿងភោជននោះ ខ្ញុំបានតាក់តែងបម្រុងពួកព្រាហ្មណ៍ នេះជាភោជនរបស់ខ្ញុំដែលជឿចំពោះសេចក្តីចម្រើនរបស់ខ្លួន អ្នកចូរចៀសចេញអំពីទីនេះ អ្នកមកឋិតនៅក្នុងទីនេះធ្វើអ្វី នៃបុគ្គលថោកទាប បុគ្គលទាំងឡាយប្រហែលយើង មិនឲ្យភោជនដល់អ្នកទេ ។

[ ១៦៥ ] ( ព្រះមហាសត្វ... ) ពួកអ្នកប្រាថ្នាផលស្រូវមែនព្រោះពូជក្នុងទីទួលឬទីទំនាប និងទីដែលមិនមែនជាស្រែ អ្នកចូរឲ្យទានដោយសទ្ធាបែបនេះចុះ សូមអ្នកញុំាងទក្ខិណេយ្យបុគ្គលឲ្យត្រេកអរផង ។

[ ១៦៦ ] ( មណ្ឌព្យកុមារ... ) យើងព្រោះពូជទាំងឡាយក្នុងស្រែណា

ស្រែទាំងនោះក្នុងលោក យើងស្គាល់ច្បាស់ ពួកព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយជាតិនិងមន្ត្រ ពួកព្រាហ្មណ៍ទាំងនោះ មានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

[ ១៦៧ ] ( មហាសត្វ... ) សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មាននៅក្នុងពួកបុគ្គលណា បុគ្គលពួកនោះ មិនមែនជាអ្នកមានសីល ជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះឡើយ ។ សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មិនមានក្នុងពួកបុគ្គលណា បុគ្គលពួកនោះ ទើបឈ្មោះថា មានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

[ ១៦៨ ] ( មណ្ឌព្យកុមារ... ) ( ធ្មាំទ្វារ ៣ នាក់ ) ឈ្មោះ ឧបជោតិយៈ ១ ឈ្មោះឧបជ្ឈាយៈ ១ ឈ្មោះភណ្ឌកុច្ឆិ ១ ទៅក្នុងទីណា អ្នកទាំងឡាយចូរវាយសម្លាប់នូវមនុស្សលាមកនេះ ហើយចាប់ត្រង់ក អូសទាញចេញទៅ ។

[ ១៦៩ ] ( មហាសត្វ... ) អ្នកណាជេរប្រទេចនូវឥសី អ្នកនោះឈ្មោះថាជីកភ្នំដោយក្រចក ឈ្មោះថាខាំទំពាដែកដោយធ្មេញ ឈ្មោះថាព្យាយាមលេបភ្លើង ។

[ ១៧០ ] ( អភិសម្ពុទ្ធគាថា ) ឥសីឈ្មោះមាតង្គៈ ជាអ្នកមាន

សេចក្តីព្យាយាមទៀងទាត់ លុះពោលពាក្យនេះហើយ ក៏ចេញទៅឰដ៏អាកាស ចំពោះមុខពួកព្រាហ្មណ៍កំពុងក្រឡេកមើល ។

[ ១៧១ ] ( នាងទិដ្ឋមង្គលិកាពោលថា ) ក្បាល ( របស់កូនអញ ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅមិនគួរដល់ការងារ ភ្នែកទាំងឡាយដូចជាបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនអញនេះ ឲ្យទៅជាយ៉ាងនេះ ។

[ ១៧២ ] ( ពួកមាណពពោលថា ) មានសមណៈ ( មួយរូប ) មកក្នុងទីនេះ មានប្រដាប់ស្លៀកពាក់អាក្រក់ លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ដែលគេចោល លើគំនរសំរាមឰដ៏ក សមណៈនោះបានធ្វើនូវកូនរបស់នាងនេះ ឲ្យយ៉ាងនេះ ។

[ ១៧៣ ] ( នាងទិដ្ឋមង្គលិកា... ) សមណៈមានប្រាជ្ញាក្រាស់ ដូចផែនដីនោះ ទៅក្នុងទិសដូចម្តេច ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរប្រាប់នូវសេចក្តីនុ៎ះដល់ខ្ញុំ យើងនឹងទៅសូមខមាទោសចំពោះសមណៈនោះ ធ្វើម្តេចហ្ន៎ យើងនឹងបានកូននោះ មានជីវិតរស់នៅ ។

[ ១៧៤ ] ( ពួកមាណព... ) សមណៈមានប្រាជ្ញាក្រាស់ដូចផែនដី បានទៅក្នុងអាកាស ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ដើរទៅតាមផ្លូវនៃអាកាស មួយទៀត សមណៈនោះជាឥសី មានការប្តេជ្ញាដ៏ទៀងទាត់ មានសភាពដ៏ល្អ បានទៅកាន់ទិសខាងកើតហើយ ។

[ ១៧៥ ] ( នាងទិដ្ឋមង្គលិកា... ) ក្បាល ( របស់កូនខ្ញុំ ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅ មិនគួរដល់ការងារ ភ្នែកទាំងឡាយ

សដូចក្អែកបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនខ្ញុំនេះ ឲ្យទៅជាយ៉ាងនេះ ។

[ ១៧៦ ] ( ព្រះមហាសត្វ... ) ពួកយក្សមានអានុភាពច្រើន ( មកដោយគិតថា ) ពួកឥសីមានសភាពដ៏ល្អ មកហើយ ( ក្នុងទីនេះ ) ពួកយក្ខដឹងថា ( កូនរបស់នាង ) មានចិត្តប្រទូស្ត ក្រោធខឹង ហើយបានធ្វើនូវកូននាងឲ្យយ៉ាងនេះ ។

[ ១៧៧ ] ( នាងទិដ្ឋមង្គលិកា... ) បើពួកយក្ខបានធ្វើកូនរបស់ខ្ញុំឲ្យយ៉ាងនេះហើយ សូមលោកជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កុំខឹងចំពោះខ្ញុំ នាងខ្ញុំជាស្រីសូមដល់នូវបាទារបស់លោកជាទីពឹង បពិត្រភិក្ខុ ខ្ញុំមកដោយសេចក្ដីសោកចំពោះកូន ។

[ ១៧៨ ] ( ព្រះមហាសត្វ... ) កាលនោះក៏ដោយ ឥឡូវនេះក៏ដោយ យើងមិនមានការប្រទូស្តក្នុងចិត្តតិចតួចទេ តែកូនរបស់នាងជាអ្នកស្រវឹងដោយសេចក្ដីស្រវឹងក្នុងវេទ រៀនវេទហើយមិនស្គាល់សេចក្ដីចម្រើន ។

[ ១៧៩ ] ( នាងទិដ្ឋមង្គលិកា... ) បពិត្រភិក្ខុ សញ្ញារបស់បុរសរមែងភ្លេចភ្លាំងដោយមួយរំពេចជាប្រាកដ បពិត្រលោកមានប្រាជ្ញាក្រាស់ដូចផែនដី សូមលោកអត់នូវទោសកំហុសម្ដងចុះ អ្នកប្រាជ្ញទាំងឡាយ រមែងមិនមានក្រោធជាកម្លាំង ។

[ ១៨០ ] ( ព្រះមហាសត្វ... ) ចូរឲ្យមណ្ឌព្យកុមារដែលជាបុគ្គលមានប្រាជ្ញាតិច ជាបុត្ររបស់នាងបរិភោគនូវដុំបាយ ដែលយើងឈរហើយបានមកនេះ ចំណែកខាងពួកយក្ខ នឹងលែងបៀតបៀននូវកូនរបស់នាង ទាំងកូន

របស់នាងនោះ នឹងទៅជាបុគ្គលមិនមានរោគ ។

[ ១៨១ ] ( នាឌទិដ្ឋមង្គលិកា... ) ម្នាលមណ្ឌព្យៈ អ្នកជាបុគ្គលពាល មានប្រាជ្ញាស្តួចស្តើង អ្នកជាបុគ្គលមិនស្គាល់នូវបុញ្ញក្ខេត្តទាំងឡាយ អ្នកឲ្យទានចំពោះតែពួកជនដែលមានទឹកចត់គឺកិលេសដ៏ច្រើន មានអំពើដ៏សៅហ្មង ជាអ្នកមិនសង្រួម ។ ( ពួកជនខ្លះ ) បួងសក់ ស្លៀកនូវស្បែកខ្លាឃ្មុំ មានមុខទ្រុបទ្រុល ( ដោយពុកមាត់ពុកចង្កា ) ដូចរណ្តៅទឹកដ៏ចាស់ អ្នកទាំងឡាយចូរមើលពួកសត្វដែលមានសភាពអាក្រក់នេះចុះ ជ្បិតផ្នួងសក់ និងស្បែកខ្លាឃ្មុំ ការពារនូវបុគ្គលដែលមានប្រាជ្ញាតិចមិនបានទេ ។ ពួកបុគ្គលណា លះបង់រាគៈ ទោសៈ និងអវិជ្ជា ពួកបុគ្គលនោះ ឈ្មោះថា ជាអរហន្តខីណាស្រព ទានដែលបុគ្គលឲ្យចំពោះពួកបុគ្គលទាំងនោះ ទើបជាទានមានផលច្រើន ។

[ ១៨២ ] ( អភិសម្ពុទ្ធគាថា ) ស្តេចក្នុងដែនមេជ្ឈៈ បៀតបៀននូវចិត្តរបស់មាតង្គតាបស ជាអ្នកមានយស ស្តេចក្នុងដែនមេជ្ឈៈ ព្រមទាំងបរិស័ទក៏ដាច់សូន្យ ដែនឈ្មោះមេជ្ឈៈ ក៏ទៅជាព្រៃ ក្នុងកាលនោះ ។

## ចប់ មាតង្គជាតកទី ១

# វីសតិនិបាតជាតក

## អដ្ឋកថា មាតង្គជាតក

[ ១៦២-១៨២ ] ព្រះសាស្តា កាលគង់នៅក្នុងជេតពនមហាវិហារ ទ្រង់ប្រារព្ធឧទេនរាជវង្ស ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កុតោ នុ អាគច្ឆសិ ទុម្មវាសី** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងកាលនោះ ព្រះបិណ្ឌោលភារទ្វាជៈ ហោះមកអំពីជេតវនមហាវិហារតាមអាកាស ទៅកាន់ព្រះរាជឧទ្យានរបស់ព្រះបាទឧទេន ក្នុងក្រុងកោសម្ពី ដើម្បីសម្រាកក្នុងពេលថ្ងៃ ។ បានឮថា ក្នុងភពមុនៗ ព្រះថេរៈធ្លាប់សោយរាជ្យ គ្រប់គ្រងរាជសម្បត្តិ មានបរិវារច្រើន ក្នុងរាជឧទ្យាននោះអស់កាលយូរ ។ ដោយបុព្វចរិយា ដែលធ្លាប់បានសន្សំមក ទើបព្រះថេរៈច្រើនទៅដោយការអង្គុយសម្រាកពេលថ្ងៃ ក្នុងព្រះរាជឧទ្យាននោះរឿយៗ មកឲ្យកាលវេលាកន្លងទៅដោយសុខដែលកើតអំពីផលសមាបត្តិ ដោយច្រើន ។ ថ្ងៃមួយ កាលព្រះថេរៈទៅសម្រាកត្រង់គល់រាំង ដែលមានផ្ការយោនរយាន ក្នុងព្រះរាជឧទ្យាននោះ ព្រះបាទឧទេនទ្រង់ព្រះតម្រិះថា អញនឹងផឹកមហាបានៈ ( ទឹកចណ្ឌ ) ហើយលេងឧទ្យានកីឡា ៧ ថ្ងៃ ដូច្នេះហើយ ទើបយាងទៅកាន់ព្រះរាជឧទ្យាន មួយអន្លើដោយបរិវារជាច្រើន ទ្រង់កើយភ្លៅស្រីស្នំម្នាក់លើទែនមង្គលសិលាអាសនៈ ហើយទ្រង់និទ្រា លង់លក់ទៅ ព្រោះស្រវឹងក្នុងការសោយទឹកចណ្ឌ ។ ពួកស្នំដែលអង្គុយបំពេ ដាក់គ្រឿងតូរ្យតន្ត្រីទុកហើយចូលទៅកាន់ព្រះរាជឧទ្យាន ដើរបេះផ្កានិងផ្លែឈើជាដើម ឃើញព្រះ

ថេរៈហើយ នាំគ្នាទៅថ្វាយបង្គំ ហើយអង្គុយ ។ ព្រះថេរៈក៏អង្គុយសម្តែងធម្មកថាដល់ស្រីទាំងនោះ ។ ឯស្នំដែលអង្គុយឲ្យព្រះបាទឧទេនកើយភ្លៅ ក៏អង្រួនភ្លៅឲ្យកម្រើក ដាស់ព្រះរាជាឲ្យក្រាក់ពីបន្ទំ កាលព្រះរាជាត្រាស់សួរថា ស្រីឋោកទាបទាំងនោះទៅណាអស់ ទើបក្រាបទូលថា ស្រីទាំងនោះទៅអង្គុយចោមរោមសមណៈមួយរូប ។ ព្រះរាជាស្តាប់ដូច្នោះ ទ្រង់ព្រះពិរោធ យាងទៅជេរបរិភាសព្រះថេរៈ ហើយត្រាស់ថា ណ្ហើយចុះ យើងនឹងឲ្យអង្រ្កងចោមរោមសមណៈនេះ ហើយត្រាស់ឲ្យយកសម្បុកអង្រ្កង មកក្លែងធ្វើឲ្យខ្ចាយលើកាយព្រះថេរៈ ដោយអំណាចនៃសេចក្តីក្រោធ ។ ព្រះថេរៈហោះឡើងទៅឈរលើអាកាស ឲ្យឱវាទព្រះរាជា ហើយហោះទៅចុះត្រង់ទ្វារព្រះគន្ធកុដិត្រង់វត្តជេតពននោះឯង កាលព្រះតថាគតត្រាស់សួរថា អ្នកមកអំពីណា ក៏ក្រាបទូលសេចក្តីនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់ថា ម្នាលភារទ្វាជៈ ឧទេនរាជ បៀតបៀនបព្វជិតទាំងឡាយតែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បៀតបៀនមកហើយដូចគ្នា ។ កាលព្រះបិណ្ឌោលភារទ្វាជ ទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះមហាសត្វ កើតក្នុងកំណើតចណ្ឌាល ខាងក្រៅព្រះនគរ មាតាបិតាឲ្យឈ្មោះថា មាតង្គមាណព ។ ក្នុងកាលតមកមាតង្គមាណពចម្រើនវ័យហើយ មាននាមប្រាកដថា មាតង្គបណ្ឌិត ។ ក្នុងកាលនោះ សេដ្ឋីធីតាក្នុងក្រុងពារាណសី ឈ្មោះទិដ្ឋមង្គលិកា កាលដល់វារៈមួយខែឬពីរខែ មួយអន្លើដោយ

បរិវារជាច្រើន ទៅកាន់ឧទ្យានដើម្បីលេង ។ ថ្ងៃមួយ មហាសត្វ មាតង្គបណ្ឌិតដើរទៅកាន់ព្រះនគរ ដោយធុរៈឯណានីមួយ បានឃើញនាងទិដ្ឋមង្គលិកាក្នុងរវាងទ្វារ ទើបលបគេចទៅឈរពួនក្នុងទីមួយ ។ នាងទិដ្ឋមង្គលិកាសម្លឹងមើលតាមប្រឡោះវាំងនន ឃើញព្រះពោធិសត្វទើបសួរថា នុ៎ះជានរណា កាលបរិវារឆ្លើយថា បពិត្រអ្នកនាង នុ៎ះជាមនុស្សចណ្ឌាល ទើបគិតថា អញឃើញមនុស្សដែលមិនគួរឃើញហ្ន៎ ដូច្នេះហើយ ក៏លាងភ្នែកដោយទឹកក្រអូប ត្រឡប់ទៅវិញ ។ ឯមហាជនដែលចេញទៅជាមួយសេដ្ឋីធីតា ជេរបរិភាសថា វ៉ុយអាមនុស្សចណ្ឌាលអាក្រក់ ព្រោះអាស្រ័យអា ថ្ងៃនេះពួកយើង មិនបានភក្សស្រានិងស៊ីសាច់ ដែលមិនចាំបាច់ទិញ ត្រូវសេចក្ដីក្រោធគ្របសង្កត់ហើយ ចោមរោមវាយមាតង្គបណ្ឌិតដោយដៃនិងជើង រហូតសន្លប់ហើយចៀសចេញទៅ ។ មាតង្គបណ្ឌិតសន្លប់មួយស្របក់ ដឹងខ្លួនឡើង គិតថា បរិវាររបស់នាងទិដ្ឋមង្គលិកាវាយអញដែលមិនមានកំហុស មិនមានហេតុ អញបាននាងទិដ្ឋមង្គលិកាជាភរិយានោះឯងទើបក្រោកឡើង បើមិនបាន មិនព្រមក្រោកឡើងឡើយ កាលតាំងចិត្តហើយ ក៏ដើរទៅដេកត្រង់ទ្វារផ្ទះរបស់បិតានាងទិដ្ឋមង្គលិកានោះ ។ កាលសេដ្ឋីបិតារបស់នាងទិដ្ឋមង្គលិកាមកសួរថា ព្រោះហេតុអ្វី ទើបឯងមកដេកទីនេះ មាតង្គបណ្ឌិតក៏ឆ្លើយថា ហេតុដទៃមិនមាន តែខ្ញុំត្រូវការនាងទិដ្ឋមង្គលិកាជាភរិយា ។ កន្លងមកបានមួយថ្ងៃសេដ្ឋីនោះ ក៏មកសួរទៀត ព្រះពោធិសត្វក៏ឆ្លើយបញ្ជាក់យ៉ាងនោះ រហូតកន្លងមកដល់ថ្ងៃទី ២ ៣ ៤ ៥ និងទី ៦ ព្រះពោធិសត្វក៏នៅតែដេក និងឆ្លើយ

បញ្ឈាក់យ៉ាងនោះ ។ ធម្មតាការអធិដ្ឋានរបស់ព្រះពោធិសត្វទាំងឡាយ រមែង សម្រេច ព្រោះហេតុនោះ កាលគ្រប់ ៧ ថ្ងៃ ទើបមនុស្សទាំងឡាយ មាន លោកសេដ្ឋីជាដើម នាំនាងទិដ្ឋមង្គលិកាមកប្រគល់ឲ្យមាតង្គបណ្ឌិត ។ សម័យ នោះ នាងទិដ្ឋមង្គលិកាពោលនឹងមាតង្គបណ្ឌិតថា នែអ្នក អញ្ជើញអ្នកក្រោក ឡើង ខ្ញុំនឹងទៅផ្ទះរបស់អ្នក ។ មាតង្គបណ្ឌិតក៏ពោលថា នែនាង ខ្ញុំត្រូវបរិ វាររបស់នាងវាយតប់ ទ្រុឌទ្រោមពន់ពេក រហូតទុព្វលភាព ចូរនាងលើកខ្ញុំ ឡើងដាក់លើខ្នង ហើយនាំទៅចុះ ។ នាងក៏ធ្វើតាមនោះ កាលអ្នកនគរកំពុង សម្លឹងមើលនោះឯង ក៏នាំមាតង្គបណ្ឌិតចេញអំពីព្រះនគរ ទៅកាន់ចណ្ឌាល គ្រាម ។

លំដាប់នោះ ព្រះមហាសត្វមិនបានកន្លងល្មើសបវេណីនៃវណ្ណៈ ឲ្យនាង សម្រាកក្នុងផ្ទះ ២-៣ ថ្ងៃហើយ គិតថា អញនឹងធ្វើឲ្យនាងដល់នូវភាពជាអ្នក ប្រសើរដោយលាភយស ចាំបាច់ត្រូវបួសជាមុនសិន ទើបអាចធ្វើបាន ក្រៅ អំពីនេះហើយ មិនមានផ្លូវឡើយ ។ គ្រានោះ ព្រះមហាសត្វក៏ហៅនាងមក ពោលថា នែនាង កាលខ្ញុំមិនបាននាំអ្វីចេញមកអំពីព្រៃ ការតម្កល់ជីវិតរបស់ យើងទាំង ២ រមែងប្រព្រឹត្តទៅមិនបាន នាងកុំអផ្សុក ទម្រាំខ្ញុំត្រឡប់មក ខ្ញុំ នឹងចូលទៅកាន់ព្រៃ ដូច្នេះហើយ ពោលដាស់តឿនបរិវារថា សូម្បីពួកនាង ដែលនៅចាំផ្ទះ ក៏កុំលះបង់នាងឡើយ ជួយមើលកិរិយារបស់យើងផង ដូច្នេះ ហើយ ក៏ចូលទៅកាន់ព្រៃ បួសជាសមណៈ ជាអ្នកមិនប្រមាទ ញុំាងសមាបត្តិ ៨ អភិញ្ញា ៥ ឲ្យកើតឡើង ក្នុងថ្ងៃទី ៧ គិតថា ឥឡូវនេះ អញអាចជាទី

ពីងដល់នាងទិដ្ឋមង្គលិកាបានហើយ ទើបហោះមកដោយឫទ្ធិ ទៅចុះត្រង់ទ្វារ
បណ្ឌាលគ្រាម ហើយដើរទៅកាន់ផ្ទះនាងទិដ្ឋមង្គលិកា ។ នាងបានដំណឹងការ
មករបស់មាតង្គបណ្ឌិតហើយ ចេញមកអំពីផ្ទះ យំរៀបរាប់ថា បពិត្រអ្នកជា
ស្វាមី ហេតុអ្វី ទើបទៅបួស ចោលខ្ញុំឲ្យឥតទីពឹង ។ លំដាប់នោះ ទើបមា
តង្គតាបសលួងលោមនាងថា នែនាងដ៏ចម្រើននាងកុំទោមនស្សឡើយ ពេល
នេះ យើងនឹងធ្វើឲ្យនាងមានយសធំក្រៃលែង ជាងយសដែលនាងមានពីមុន
ទៅទៀត តែនាង អាចប្រកាសត្រឹមតែប៉ុណ្ណោះក្នុងកណ្ដាលបរិស័ទបានទេថា
មាតង្គបណ្ឌិត មិនមែនប្ដីរបស់យើង មហាព្រហ្មជាប្ដីរបស់យើង ដូច្នេះ ។
នាងទទួលពាក្យថា បពិត្រលោកម្ចាស់ ខ្ញុំអាចប្រកាសបាន មាតង្គៈក៏ពោល
ថា ពេលនេះបើមានអ្នកសួរថា ប្ដីរបស់នាងទៅណា ក៏ចូរឆ្លើយថា ទៅព្រហ្ម-
លោក កាលគេសួរថា កាលណានឹងមក ចូរប្រាប់គេថា ចាប់ពីថ្ងៃនេះទៅ ៧
ថ្ងៃទៀត ស្ដេចមហាព្រហ្មជាប្ដីរបស់ខ្ញុំនឹងហែកព្រះចន្ទចេញមក ក្នុងថ្ងៃពេញ
បូណ៌មី ។ កាលមហាសត្វពោលយ៉ាងនេះហើយ ក៏ហោះត្រឡប់ទៅកាន់ហិម
វន្តប្បទេសមួយរំពេច ។ ឯនាងទិដ្ឋមង្គលិកា ត្រាច់ទៅឈរប្រកាសសេចក្ដី
តាមដែលព្រះពោធិសត្វប្រាប់ ក្នុងទីគ្រប់កន្លែង កណ្ដាលមហាជន ក្នុងនគរ
ពារាណសី ។ មហាជនអ្នកពារាណសីនាំគ្នាជឿថា ស្ដេចមហាព្រហ្មរបស់
យើងមានពិត ក៏មិនបានពោលអ្វីជាមួយនាងទិដ្ឋមង្គលិកា សេចក្ដីនោះនឹងពិត
យ៉ាងនេះ ។ ឯព្រះពោធិសត្វ លុះដល់ថ្ងៃ ១៥ កើតពេញបូណ៌មី ក្នុងកាល
ព្រះចន្ទតាំងនៅត្រង់កណ្ដាលមេឃ ក៏និម្មិតអត្តភាពជាមហាព្រហ្ម បណ្ដាល

កាសិករដ្ឋទាំងមូលដែលមានអាណាខេត្តទំហំ ១២ យោជន៍ ឲ្យរុងរឿងភ្លឺស្វាង តែមួយ ហើយហែកមណ្ឌលព្រះចន្ទហោះចុះមក ប្រទក្សិណព្រះនគរ ៣ ជុំ កាលមហាជនបូជា ដោយគ្រឿងសក្ការៈ មានគ្រឿងក្រអូបនិងកម្រងផ្កាជាដើម បានបែរមុខទៅកាន់ចណ្ឌាលគ្រាម ។ បណ្ដាមហាជនដែលរាប់អានព្រហ្ម ក៏ប្រជុំគ្នា នាំគ្នាទៅកាន់ចណ្ឌាលគ្រាម នាំគ្នាយកសំពត់សបរិសុទ្ធបិទបាំង ប្រក់ផ្ទះរបស់នាងទិដ្ឋមង្គលិកា ហើយលាបជញ្ជាំងផ្ទះដោយគន្ធជាតិ ៤ ប្រការ បាចនូវផ្កា ចាត់ចែងឲ្យចងពិតានខាងលើ រៀបចំមហាសយនា ហើយដុតប្រទីបដោយប្រេងក្រអូប នាំគ្នាជញ្ជូនខ្សាច់ពណ៌សដូចបន្ទះប្រាក់ មករោយត្រង់ទ្វារផ្ទះ ហើយព្យួរកម្រងផ្កា ចងទង់បក់រវិចយ៉ាងស្អាត ។ កាលមហាជនតាក់តែងផ្ទះស្រេចយ៉ាងនេះហើយ ទើបព្រះមហាសត្វចុះអំពីអាកាសចូលទៅខាងក្នុង ហើយអង្គុយត្រង់ដំណេកបន្តិច ។ កាលនោះ នាងទិដ្ឋមង្គលិកា កំពុងមានរដូវ ។ កាលនោះ ព្រះពោធិសត្វយកមេដៃខាងស្ដាំ អង្អែលផ្ចិតរបស់នាង ។ នាងក៏តាំងគភ៌ ។ តមកមហាសត្វ ក៏ហៅនាងមកប្រាប់ថា នែនាង នាងមានទម្ងន់ហើយ នាងនឹងប្រសូតបុត្ត តែនាងនិងបុត្ត ជាអ្នកសម្បូរដោយលាភនិងយសដ៏លើស ទឹកសម្រាប់លាងជើងរបស់នាង នឹងបានជាទឹកសម្រាប់អភិសេករបស់ព្រះរាជាក្នុងជម្ពូទ្វីបទាំងមូល ទឹកងូតរបស់នាងនឹងជាអម្រឹតឱសថ ជនណាបានទឹកងូតរបស់នាងទៅស្រោចក្បាល ជនទាំងនោះនឹងជាសះស្បើយរោគគ្រប់យ៉ាង នឹងប្រាសចាកឧបទ្រពចង្រៃ កាឡកណ្ណី ។ម្យ៉ាងទៀត បុគ្គលដែលដាក់ក្បាលលើខ្នងជើងរបស់នាង ថ្វាយបង្គំ នឹងឲ្យ

ទ្រព្យ ១០០០ បុគ្គលដែលឈរថ្វាយបង្គំក្នុងរវាងផ្លូវ ដែលស្តាប់ឮសំឡេង នឹងឲ្យទ្រព្យ ១០០ បុគ្គលដែលឈរថ្វាយបង្គំ ចម្ងាយត្រឹមមើលឃើញ នឹងឲ្យទ្រព្យ ១ កហាបណៈ ចូរនាងកុំប្រមាទ កាលឲ្យឱវាទហើយ ក៏ចេញអំពីផ្ទះ កាលមហាជនកំពុងមើលនោះឯង ក៏ហោះចូលក្នុងមណ្ឌលព្រះចន្ទ ។

មហាជន ជាអ្នកកាប់អានព្រះព្រហ្ម បានឈរប្រជុំគ្នា រហូតរាត្រីកាលកន្លងទៅ លុះព្រឹកឡើង ក៏អញ្ជើញនាងទិដ្ឋមង្គលិកា ដាក់លើវិមាស ហើយលើកឡើងដោយសិរសោគីត្បូង នាំទៅកាន់ព្រះនគរ ។ មហាជននាំគ្នាចូលទៅរកនាងឈូធរ ដោយសម្គាល់ថា ជាអគ្គមហេសីរបស់ស្តេចមហាព្រហ្ម ហើយបូជាដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ។ មនុស្សទាំងឡាយដែលដាក់ក្បាលលើខ្នងជើងថ្វាយបង្គំ បានឲ្យថង់កហាបណៈ ១០០០ អ្នកដែលឈរថ្វាយបង្គំល្មមស្តាប់សំឡេងឮ ឲ្យកហាបណៈ ១០០ បុគ្គលដែលឈរថ្វាយបង្គំក្នុងទីល្មមមើលឃើញ ឲ្យទ្រព្យ ១ កហាបណៈ ។ មហាជននាំនាងទិដ្ឋមង្គលិកា ត្រាច់ទៅក្នុងនគរពារាណសី ដែលមានអាណាចក្រ ១២ យោជន៍ បាននូវទ្រព្យ ១៨ កោដិ ដោយអាការយ៉ាងនេះ ។ សម័យនោះមហាជនទាំងឡាយ កាលនាំនាងទិដ្ឋមង្គលិកាត្រាច់ទៅជុំវិញព្រះនគរហើយ ទើបនាំទ្រព្យនោះមកសាងមហាមណ្ឌប ត្រង់កណ្តាលព្រះនគរ បាំងវាំងននក្រាលមហាសយនៈ ហើយអញ្ជើញនាងទិដ្ឋមង្គលិកា ឲ្យនៅអាស្រ័យក្នុងមណ្ឌបនោះដោយសិរីដ៏ធំក្រៃលែង ហើយរៀបចំសាងប្រាសាទ ៧ ជាន់ មានខ្លោងទ្វារ ៧ កន្លែង ទុកក្បែរមហាមណ្ឌបនោះ ការសាងដ៏ឱឡារ មានហើយ

ក្នុងកាលនោះ ។ នាងទិដ្ឋមង្គលិកា ក៏ប្រសូតបុត្តក្នុងមណ្ឌបនោះឯង ។ លុះដល់ថ្ងៃតាំងឈ្មោះកុមារ ព្រាហ្មណ៍ទាំងឡាយក៏មកប្រជុំគ្នាដាក់នាមកុមារថា មណ្ឌព្យកុមារ ព្រោះប្រសូតក្នុងមណ្ឌប ។ ប្រាសាទនោះធ្វើហើយស្រេចក្នុងរយៈកាល ១០ ខែ ។ ចាប់ពីនោះមក នាងក៏នៅក្នុងប្រាសាទនោះ ដោយយសបរិវារដ៏ច្រើន ។ សូម្បីមណ្ឌព្យកុមារ ក៏ចម្រើនវ័យដោយពួកបរិវារជាច្រើន ។ ក្នុងកាលដែលមណ្ឌព្យកុមារមានអាយុ ៧-៨ ឆ្នាំ អាចារ្យដែលសម្បូរដោយវិទ្យាការទាំងឡាយ ក្នុងផ្ទៃជម្ពូទ្វីប មកប្រជុំគ្នា ឲ្យកុមាររៀនត្រៃវេទ ។ មណ្ឌព្យមាណពនោះ លុះមានអាយុគ្រប់ ១៦ ឆ្នាំបរិបូណ៌ ក៏ផ្តើមតាំងនិច្ចភត្តសម្រាប់ពួកព្រាហ្មណ៍ទាំងឡាយ ។ ព្រាហ្មណ៍ ១៦០០០ នាក់ក៏បានបរិភោគអាហារក្នុងសម្នាក់របស់មណ្ឌព្យមាណពជាប្រចាំ ។ មណ្ឌព្យឲ្យទានដល់ព្រាហ្មណ៍ទាំងឡាយត្រង់ខ្លោងទ្វារទី ៤ ។ តមក ក្នុងថ្ងៃប្រជុំធំមួយ មណ្ឌព្យមាណពឲ្យរៀបចំបាយាសក្នុងផ្ទះជាច្រើន ។ ព្រាហ្មណ៍ទាំង ១៦០០០ ក៏អង្គុយត្រង់ខ្លោងទ្វារទី ៤ បរិភោគបាយាសដែលចម្អិនល្អហើយដោយនវនីត សប្បិ ទឹកឃ្មុំ និងស្ករក្រាម ដែលគេរៀបចំប្រគេនដោយថាសមាស សូម្បីមណ្ឌព្យមាណព ក៏ប្រដាប់តាក់តែងដោយគ្រឿងអលង្ការទាំងពួង ពាក់ស្បែកជើងមាស កាន់ឈើច្រត់មាស ដើរមើលការអង្គាស ប្រាប់បរិវាររបស់ខ្លួនថា អ្នកទាំងឡាយ ចូរឲ្យនវនីតក្នុងទីនេះ ចូរឲ្យទឹកឃ្មុំក្នុងទីនេះ ដូច្នេះ ។

ខណៈនោះ មាតង្គបណ្ឌិតអង្គុយក្នុងអាស្រមបទនាហិមវន្តប្បទេសពិចារណាមើលថា ការប្រព្រឹត្តនៃបុត្តរបស់នាងទិដ្ឋមង្គលិកាដូចម្តេចហ្ន៎ ឃើញ

ការប្រព្រឹត្តរបស់មណ្ឌព្យ ឈមទៅក្នុងលទ្ធិដែលមិនសមគួរ ហើយគិតថា ថ្ងៃនេះឯង អញនឹងទៅទូន្មានមាណព ឲ្យបរិច្ចាគទានក្នុងស្រែដែលបុគ្គលឲ្យហើយ មានផលច្រើន ហើយសឹមត្រឡប់មក ដូច្នេះហើយ ហោះទៅកាន់អនោតត្តស្រះតាមអាកាស ធ្វើកិច្ចវត្ត មានការលុបមុខជាដើម ហើយឈរត្រង់ផ្ទៃមនោសិលា គ្រងចីវរ ២ ជាន់ ចងវត្តពន្ធចង្កេះ ដណ្តប់សង្ឃាដីដែលជាសំពត់បង្សុកូល ស្រេចហើយ កាន់យកបាត្រដី ហោះមកតាមអាកាសចុះត្រង់រោងទានខាងទ្វារទី ៤ ហើយឈរក្នុងចំណែកម្ខាង ។ មណ្ឌព្យមាណពកំពុងមើលខាងនោះខាងនេះ ឃើញតាបសនោះអំពីចម្ងាយគិតថា បព្វជិតនេះមានរូបដូចយក្ខដូចបិសាចប្រឡាក់ធូលីបែបនេះ មកកាន់ទីនេះ គេមកអំពីណាហ្ន៎ ដូច្នេះហើយ កាលនឹងសន្ទនាជាមួយមាតង្គតាបសនោះ ទើបពោលគាថាដំបូង ដោយសេចក្តីថា

> អ្នកមកអំពីទីណា បានជាមានប្រដាប់ស្លៀកពាក់អាក្រក់ លាមក
> ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ដែលគេចោល
> លើគំនរសំរាមព្វដ៏ក ខ្លួនអ្នកជាបុគ្គលផ្តេសផ្តាស មិនមែនជា
> ទក្ខិណេយ្យបុគ្គលទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱម្មាសិ** សេចក្តីថា លោកស្លៀកដណ្តប់សំពត់ចាស់ដែលមានស្នាមតមិនបានបោកជម្រះឡើយ ។ បទថា **ឱតល្លកោ** សេចក្តីថា ជាអ្នកស្មោកគ្រោកលាមក គ្រងសំពត់ឃើញសរសៃអំបោះដោយច្រើន គឃារធ្លាក់ចុះ ។ បទថា **បំសុបិសាចកោវ** សេចក្តីថា ដូចបិសាច

ដែលឈរត្រង់គំនរសំរាម ។ បទថា **សង្ការកោដ្ឋេ** បានដល់ សំពត់ចាស់ ដែលរើសបានក្នុងគំនរសំរាម ។ បទថា **បដិមុញ្ច** បានដល់ ស្លៀកដណ្តប់ ។ បទថា **អទក្ខិណេយ្យោ** សេចក្តីថា លោកជាបុគ្គលមិនសមគួរដល់ទក្ខិណាទាន មកកាន់ទីអង្គុយរបស់ទក្ខិណេយ្យបុគ្គលដ៏កំពូលទាំងនេះ អំពីទីណា ។

ព្រះមហាសត្វបានស្តាប់ដូច្នោះ កាលនឹងសន្ទនាជាមួយមណ្ឌព្យមាណពដោយចិត្តត្រជាក់ទន់ភ្លន់ ទើបពោលគាថាទី ២ ថា

> គ្រឿងបរិភោគនេះបរិបូណ៌ដោយបរិវារ អ្នកបានតាក់តែងហើយ
> ពួកជនតែងទំពាស៊ី បរិភោគ ផឹកនូវគ្រឿងបរិភោគនោះ អ្នក
> ស្គាល់ហើយនូវយើងថា ជាអ្នកចិញ្ចឹមជីវិតដោយសារអ្នកដទៃ
> ឲ្យ សូមឲ្យមនុស្សចណ្ឌាល បាននូវដុំបាយដែលបុគ្គលគប្បី
> ទៅឈរជិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បកតំ** បានដល់ រៀបចំទុក ។ បទថា **យសស្សិនំ** បានដល់ បរិបូណ៌ដោយបរិវារ ។ បទថា **តំ ខជ្ជរេ** សេចក្តីថា ព្រាហ្មណ៍ទាំងឡាយទំពាបរិភោគ និងផឹករបស់នោះឯង ព្រោះហេតុអ្វី ទើបអ្នកក្រោធនឹងខ្ញុំ ។

បទថា **ឧត្តិដ្ឋបិណ្ឌំ** បានដល់ ដុំបាយដែលចាំបាច់ឈរសូមទើបបាន ឬសុំបាយដែលមនុស្សទាំងឡាយក្រោកឈរឡើងឲ្យគប្បីបាន ព្រោះឈរខាងក្រោយ ។

បទថា **លភតំ សបាកោ** សេចក្តីថា ទោះជាសបាកចណ្ឌាលក៏សូមទាល់

តែបាន ព្រោះថា ព្រាហ្មណ៍ដែលសម្បូរដោយជាតិរមែងបានភោជនគ្រប់យ៉ាង តែសម្រាប់សបាកចណ្ឌាល អ្នកណានឹងឲ្យ ខ្ញុំរកបិណ្ឌបាតបានយ៉ាងលំបាក ព្រោះហេតុនោះ នែកុមារ ចូរអ្នកប្រាប់ឲ្យគេឲ្យភោជនដល់ខ្ញុំ ដើម្បីជាគ្រឿងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅចុះ ។

លំដាប់នោះ មណ្ឌព្យកុមារក៏ពោលគាថាដោយសេចក្ដីថា

គ្រឿងភោជននោះ ខ្ញុំបានតាក់តែងបម្រុងពួកព្រាហ្មណ៍ នេះជាភោជនរបស់ខ្ញុំដែលជឿចំពោះសេចក្ដីចម្រើនរបស់ខ្លួន អ្នកចូរចៀសចេញអំពីទីនេះ អ្នកមកឋិតនៅក្នុងទីនេះធ្វើអ្វី នែបុគ្គលថោកទាប បុគ្គលទាំងឡាយ ប្រហែលយើង មិនឲ្យភោជនដល់អ្នកទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អត្តត្ថាយ** សេចក្ដីថា ដើម្បីជាប្រយោជន៍ដល់សេចក្ដីចម្រើនរបស់ខ្លួន ។ បទថា **អបេហិ ឯត្តោ** សេចក្ដីថា អ្នកចូរចៀសទៅអំពីទីនេះ ។ បទថា **ន មាទិសា** សេចក្ដីថា នែអ្នកមានជាតិថោកទាប មនុស្សដូចយើង រមែងថ្វាយទានដល់ព្រាហ្មណ៍ឧទិច្ចគោត្តទាំងឡាយ ដែលសម្បូរដោយជាតិ រមែងមិនឲ្យទានដល់មនុស្សចណ្ឌាល ចូរអ្នកទៅចុះ ។ លំដាប់នោះ ព្រះមហាសត្វពោលគាថាដោយសេចក្ដីថា

ពួកអ្នកប្រាថ្នាផលស្រូវ រមែងព្រោះពូជក្នុងទីទួលឬទីទំនាប និងទីដែលមិនមែនជាស្រែ អ្នកចូរឲ្យទាន ដោយសទ្ធាបែបនេះចុះ សូមអ្នកញ៉ាំងទក្ខិណេយ្យបុគ្គលឲ្យត្រេកអរផង ដូច្នេះ ។

គាថានោះមានអធិប្បាយដូច្នេះថា នែកុមារ អ្នកស្រែទាំងឡាយ កាលប្រាថ្នាផលស្រូវ រមែងព្រោះពូជត្រង់ស្រែទាំង ៣ យ៉ាង ក្នុងកាលដែលភ្លៀងធ្លាក់ច្រើនពេក ស្រូវក្នុងស្រែទួលរមែងសម្រេចផល ស្រូវក្នុងស្រែទំនាបរមែងវិនាស ឯស្រូវដែលអាស្រ័យស្ទឹងនិងបឹងក្នុងទីស្មើ មិនទាប មិនទួល ត្រូវទឹកជំនន់ផាត់ទៅក្នុងកាលភ្លៀងធ្លាក់តិចតួច ស្រូវក្នុងស្រែទួលរមែងវិនាសមិនបានផល ស្រូវក្នុងស្រែទំនាបរមែងបានផលតិចតួច ឯស្រូវក្នុងស្រែកណ្ដាលគង់បានផលនោះឯង ក្នុងកាលដែលភ្លៀងធ្លាក់ស្មើ មិនច្រើនមិនតិច ស្រូវក្នុងស្រែទួលបានផលតិចតួច តែស្រូវក្នុងស្រែក្រៅពីនេះ រមែងបានផលល្អ ព្រោះហេតុនោះ អ្នកស្រែទាំងឡាយ កាលសង្ឃឹមផល តែងព្រោះក្នុងស្រែទាំង ៣ យ៉ាងណា អ្នកក៏ចូរបរិច្ចាគទានដល់បដិគ្គាហកៈទាំងឡាយដែលមកហើយដោយសទ្ធាគឺផលនេះ យ៉ាងនោះដូចគ្នា កាលបើអ្នកបរិច្ចាគទានយ៉ាងនេះ អ្នកណានឹងគប្បីឲ្យត្រេកអរ គឺបានទក្ខិណេយ្យបុគ្គលដែលល្អ ដូច្នេះ ។

គ្រានោះ មណ្ឌព្យមាណពក៏ពោលគាថាបន្ទថា

យើងព្រោះពូជទាំងឡាយក្នុងស្រែណា ស្រែទាំងនោះក្នុងលោក
យើងស្គាល់ច្បាស់ ពួកព្រាហ្មណ៍ណា ជាអ្នកប្រកបដោយជាតិ
និងមន្ត្ត ពួកព្រាហ្មណ៍ទាំងនោះ មានសីលជាទីស្រឡាញ់ដ៏ក្រៃ
លែង ដូចជាស្រែក្នុងលោកនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេសាហំ** កាត់បទជា **យេសុ អហំ** ។ បទថា **ជាតិមន្តូបបន្នា** សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយណា ជាអ្នកដល់ព្រម

ដោយជាតិនិងមន្តទាំងឡាយ ។

លំដាប់នោះ ព្រះមហាសត្វបានពោល ២ គាថា ដូច្នេះថា

សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ មោហៈ ១ ទោស ទាំងអស់នេះ មាននៅក្នុងពួកបុគ្គលណា បុគ្គលពួកនោះ មិន មែនជាអ្នកមានសីល ជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែ ក្នុងលោកនេះឡើយ ។ សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជា បុគ្គលមើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្តី ស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មិនមានក្នុងពួក បុគ្គលណា បុគ្គលពួកនោះ ទើបឈ្មោះថា មានសីលជាទី ស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មទោ** បានដល់ សេចក្តីស្រវឹងព្រោះជាតិ ដែលកើតឡើងយ៉ាងនេះថា អញជាអ្នកបរិបូណ៌ដោយជាតិ ។

បទថា **អតិមានិតា** បានដល់ ការប្រព្រឹត្តមើលងាយថា អ្នកដទៃដែល ស្មើជាមួយយើងដោយជាតិជាដើមមិនមាន ។ កិលេសទាំងឡាយ មានលោភៈ ជាដើម ត្រឹមតែជាការចង់បាន ការគិតប្រទូស្ត ការស្រវឹង និងការវង្វេង ប៉ុណ្ណោះ ។

បទថា **អបេសលានិ** សេចក្តីថា បុគ្គលទាំងឡាយបែបនេះ ជាបុគ្គល មិនមែនមានសីលជាទីស្រឡាញ់ ដូចដំបូកដែលពេញដោយអាសិរពិសដូច្នោះ

ទានដែលបុគ្គលឲ្យហើយដល់បុគ្គលបែបនេះ រមែងមិនមានផលច្រើន ព្រោះហេតុនោះ អ្នកកុំសម្គាល់ភាពដែលជនទាំងឡាយ ដែលមិនមានសីលជាទីស្រឡាញ់ទាំងនេះថាជាស្រែល្អ ព្រោះព្រាហ្មណ៍ជាអ្នកមានជាតិនិងមន្ត្រ មិនមែនទៅស្ថានសួគ៌បានឡើយ ឯជនណា ជាអរិយជន វៀរចាកការប្រកាន់ជាតិនិងមានះជាដើមបាន អរិយជនទាំងនោះ ជាស្រែល្អដែលមានសីលជាទីស្រឡាញ់ ទានដែលបុគ្គលឲ្យហើយក្នុងអរិយជនទាំងនោះ មានផលច្រើនផង អរិយជនទាំងនោះរមែងជាអ្នកទៅស្ថានសួគ៌បានផង ដូច្នេះ ។

កាលព្រះមហាសត្វពោលរឿយៗ ដូច្នេះ មណ្ឌព្យមាណពនោះខឹងអាក់អន់ ទើបពោលថា តាបសនេះពោលផ្តេសផ្តាសច្រើនពេក អ្នករក្សាទ្វារទាំងនេះទៅណាអស់ ចូរមកនាំយកមនុស្សចណ្ឌាលនេះចេញទៅ ហើយពោលគាថាថា

> ( ឆ្មាំទ្វារ ៣ នាក់ ) ឈ្មោះឧបជោតិយៈ ១ ឈ្មោះឧបជ្ឈាយៈ ១ ឈ្មោះភណ្ឌកុច្ឆិ ១ ទៅក្នុងទីណា អ្នកទាំងឡាយ ចូរវាយសម្លាប់នូវមនុស្សលាមកនេះ ហើយចាប់ត្រង់កអូសទាញចេញទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ក្វេត្ថ គតា** មានអធិប្បាយថា ទោវារិកបុរសទាំង ៣ គឺឧបជោតិយៈ ១ ឧបជ្ឈាយៈ ១ និងភណ្ឌកុច្ឆិ ១ ដែលឈរយាមទ្វារទាំង ៣ នេះ ទៅណាអស់ហើយ ។

ចំណែកអ្នកយាមទ្វារទាំងនោះ បានឮពាក្យមណ្ឌព្យមាណពហើយ ក៏រួត

រះមកសំពះហើយពោលថា បពិត្រលោកម្ចាស់ ឲ្យពួកខ្ញុំធ្វើអ្វី មណ្ឌព្យមាណព ក៏ប្រាប់ថា អ្នកទាំងឡាយឃើញមនុស្សចណ្ឌាល ជាតិលាមកនេះដែរឬទេ ពួកទ្វារបាលពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំមិនឃើញឡើយ ទើបមិនដឹងថា គាត់មកអំពីណា មណ្ឌព្យមាណពត្រិះរិះថា ប្រហែលឥសីនេះ ជាអ្នកលេងកល ឬចោរវិទ្យាធរណាមួយដោយពិត ដូច្នេះ ពោលសម្ដុតពួកទ្វារបាលថា ឥឡូវនេះ ពួកអ្នកនៅឈរធ្វើអ្វី ទ្វារបាលទាំង ៣ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ឲ្យពួកខ្ញុំធ្វើអ្វី មណ្ឌព្យមាណព ពោលថា ពួកឯងចូរវាយទះតប់មាត់មនុស្សចណ្ឌាលថោកទាបនេះ ហើយយកមែកឫស្សីសម្រាប់ដាក់អាជ្ញា វាយបកស្បែកវា ហើយសម្លាប់វាចោល ហើយចាប់អូសកមនុស្សលាមកនេះទៅឲ្យផុតអំពីទីនេះ កាលទ្វារបាលទាំង ៣ មិនទាន់មកជិត ព្រះមហាសត្វ ក៏ហោះទៅលើអាកាស ឈរពោលគាថាដោយសេចក្ដីថា

អ្នកណាជេរប្រទេចនូវឥសី អ្នកនោះឈ្មោះថា ជីកភ្នំដោយ
ក្រចក ឈ្មោះថា ខាំទំពាដែកដោយធ្មេញ ឈ្មោះថា ព្យាយាម
លេបភ្លើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជាតិវេទំ បធហសិ** សេចក្ដីថា រមែងព្យាយាមលេបនូវភ្លើង ។ កាលព្រះមហាសត្វពោលដូច្នេះហើយ មាណពនិងព្រាហ្មណ៍ទាំងឡាយ កំពុងមើលនោះឯង បានអណ្ដែតទៅក្នុងអាកាស ។ កាលនឹងប្រកាសសេចក្ដីនេះទើបព្រះសាស្ដាត្រាស់ថា

ឥសីឈ្មោះមាតង្គៈ ជាអ្នកមានសេចក្ដីព្យាយាមទៀងទាត់ លុះ

ពោលពាក្យនេះហើយ ក៏ចេញទៅឰដ៏អាកាស ចំពោះមុខពួក
ព្រាហ្មណ៍កំពុងក្រឡេកមើល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សច្ចុបរក្ខមោ** សេចក្ដីថា មានសេចក្ដីព្យាយាមឈានទៅខាងមុខជាសភាវៈ ។

មាតង្គតាបសនោះបែរមុខទៅកាន់ទិសខាងកើត ចុះក្នុងផ្លូវមួយខ្សែ រួចអធិដ្ឋានថា ស្នាមជើងរបស់អាត្មាអញចូរប្រាកដ ហើយបិណ្ឌបាតក្បែរទ្វារទិសខាងកើត ប្រមូលអាហារដែលលាយគ្នា ហើយទៅអង្គុយឆាន់ ក្នុងសាលាមួយ ។ ទេវតារក្សានគរទាំងឡាយ ពោលថា មណ្ឌព្យកុមារនេះពោលបៀតបៀនលោកម្ចាស់របស់យើងទាំងឡាយ អត់ធន់មិនបានទើបមកប្រជុំគ្នាលំដាប់នោះ យក្ខ ( ទេវតា ) ដែលជាប្រធាន នាំគ្នាចាប់ករបស់មណ្ឌព្យកុមារបង្វិលទៅក្រោយ ។ ទេវតាដ៏សេសក៏នាំគ្នាចាប់កព្រាហ្មណ៍ដ៏សេសទាំងឡាយមួលកយ៉ាងនោះដូចគ្នា តែព្រោះទេវតាទាំងនោះមានចិត្តទន់ក្នុងព្រះពោធិសត្វ ទើបមិនសម្លាប់មណ្ឌព្យមាណព ដោយគិតថា ជាបុត្តរបស់ព្រះពោធិសត្វ គ្រាន់តែធ្វើទារុណកម្មឲ្យលំបាកប៉ុណ្ណោះ ។ ក្បាលរបស់មណ្ឌព្យមាណព ក៏វិលទៅ មានមុខនៅខាងក្រោយខ្នង ដៃនិងជើង លាតត្រង់ ភ្នែកទាំងឡាយហាក់ដូចជាភ្នែករបស់មនុស្សដែលស្លាប់ហើយ មានរាងកាយរឹងដេកសន្ធឹងសន្ធៃ ។ ព្រាហ្មណ៍ទាំងឡាយ ក៏ហៀរទឹកមាត់ចេញអំពីមាត់បម្រះនទៀលទៅមក ។ មនុស្សទាំងឡាយប្រញាប់ទៅប្រាប់រឿងនោះដល់នាងទិដ្ឋមង្គលិកាថា បពិត្រអ្នកនាង បុត្តរបស់នាងកើតអ្វីក៏មិនដឹង ។ នាងទិដ្ឋមង្គលិកាប្រញាប់មកដោយ

រហ័ស ឃើញបុត្តហើយ ពោលថា មានរឿងអ្វីហ្ន៎ ទើបពោលគាថាថា

ក្បាល ( របស់កូនអញ ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅមិនគួរដល់ការងារ ភ្នែកទាំងឡាយដូចជាបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនអញនេះឲ្យទៅជាយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាវេលិតំ** បានដល់ វិលត្រឡប់ទៅក្រោយ ។ លំដាប់នោះ បុគ្គលដែលឈរក្នុងទីនោះ កាលនឹងប្រាប់ឲ្យនាងដឹងទើបពោលគាថានេះថា

មានសមណៈ ( មួយរូប ) មកក្នុងទីនេះ មានប្រដាប់ស្លៀកពាក់អាក្រក់ ឈាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ ដែលគេចោលលើគំនរសំរាមព្វង់ក សមណៈនោះបានធ្វើនូវកូនរបស់នាងនេះ ឲ្យយ៉ាងនេះ ដូច្នេះ ។

នាងទិដ្ឋមង្គលិកាបានស្តាប់ដូច្នោះហើយគិតថា នេះមិនមែនកម្លាំងនៃអ្នកដទៃ គង់ជាកម្លាំងមាតង្គបណ្ឌិតស្វាមីរបស់អញដោយឥតសង្ស័យ តែមាតង្គបណ្ឌិតនោះជាអ្នកប្រាជ្ញ សម្បូរដោយមេត្តាភាវនា គង់នឹងទូន្មានជនទាំងនេះឲ្យលំបាក ហើយទៅ លោកទៅទិសណាហ្ន៎ ។ បន្ទាប់អំពីនោះ កាលនាងសួរដល់មាតង្គបណ្ឌិត ទើបពោលគាថានេះថា

សមណៈមានប្រាជ្ញាក្រាស់ដូចផែនដីនោះ ទៅក្នុងទិសដូចម្តេច ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរប្រាប់នូវសេចក្តីនុ៎ះដល់ខ្ញុំ យើងនឹងទៅសូមខមាទោសចំពោះសមណៈនោះ ធ្វើ

ម្តេចហ្ន៎ យើងនឹងបានកូននោះមានជីវិតរស់នៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គន្ត្វាន** សេចក្តីថា ទៅកាន់សម្នាក់របស់តាបសនោះ ។ បទថា **តំ បដិករេមុ អច្ចយំ** សេចក្តីថា ខ្ញុំនឹងធ្វើជំនួស គឺសម្តែងទោសនោះ បានដល់ សូមឲ្យលោកអត់ទោសនោះឲ្យ ។ បទថា **បុត្តំ លភេមុ** សេចក្តីថា ធ្វើដូចម្តេចហ្ន៎ យើងគប្បីបានជីវិតបុត្តត្រឡប់មក ។

សម័យនោះ មាណពទាំងឡាយឈរក្នុងទីនោះ កាលប្រាប់សេចក្តីនោះដល់នាង បានពោលគាថានេះថា

សមណៈមានប្រាជ្ញាក្រាស់ដូចផែនដី បានទៅក្នុងអាកាស ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ដើរទៅតាមផ្លូវនៃអាកាស មួយទៀតសមណៈនោះជាឥសី មានការប្រព្រឹត្តដ៏ទៀងទាត់ មានសភាពដ៏ល្អ បានទៅកាន់ទិសខាងកើតហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បថទ្ធុនោ** សេចក្តីថា ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត តាំងនៅកណ្តាលអាកាស ពោលគឺផ្លូវសញ្ចរក្នុងអាកាស ។ បទថា **អបិ ចាបិ សោ** សេចក្តីថា ប្រការមួយទៀត ឥសីនោះ ទៅកាន់ទិសបូព៌ា ។

នាងទិដ្ឋមង្គលិកា ស្តាប់ពាក្យរបស់មាណពទាំងនោះហើយ ទើបគិតថា អញនឹងទៅរកប្តីរបស់អញ ទើបឲ្យទាសីកាន់កុណ្ឌីមាសនិងផ្តិលមាស ចោមរោមដោយពួកទាសី ដើរទៅរហូតដល់ទីដែលព្រះពោធិសត្វអធិដ្ឋានស្នាមជើងទុក ទើបដើរតាមស្នាមជើងនោះទៅ កាលព្រះពោធិសត្វកំពុងឆាន់កត្តាហារលើតាំង ត្រង់សាលានោះ នាងបានដើរចូលទៅកាន់ទីជិតព្រះមហាសត្វ ធ្វើ

សេចក្តីគោរពហើយឈរ ។ ព្រះមហាសត្វឃើញនាងហើយ ទើបបន្សល់បាយក្នុងបាត្របន្តិច ។ នាងទិដ្ឋមង្គលិកាក៏ប្រគេនទឹកដល់ព្រះពោធិសត្វដោយកុណ្ឌីមាស ។ ព្រះពោធិសត្វលាងដៃ ខ្ពុរមាត់ ខ្ជាក់ក្នុងបាត្រនោះឯង ។ លំដាប់នោះ កាលនាងទិដ្ឋមង្គលិកាសួរព្រះពោធិសត្វថា អ្នកណាធ្វើបុត្តរបស់ខ្ញុំឲ្យដល់នូវអាការខុសប្រក្រតីនោះ ទើបពោលគាថាថា

ក្បាល ( របស់កូនខ្ញុំ ) រមួលទៅខាងក្រោយ ដើមដៃលាត
ចេញទៅមិនគួរដល់ការងារ ភ្នែកទាំងឡាយសដូចភ្នែកបុគ្គល
ស្លាប់ អ្នកណាហ្ន៎ ធ្វើកូនខ្ញុំនេះ ឲ្យទៅជាយ៉ាងនេះ ដូច្នេះ ។

គាថាតទៅនេះជាពាក្យសួរនិងពាក្យឆ្លើយនៃជនទាំង ២ មានដូច្នេះ ព្រះពោធិសត្វស្តាប់ហើយ ទើបឆ្លើយនឹងនាងទិដ្ឋមង្គលិកាដោយគាថាថា

ពួកយក្សមានអានុភាពច្រើន ( មកដោយគិតថា ) ពួកឥសី
មានសភាពដ៏ល្អ មកហើយ ( ក្នុងទីនេះ ) ពួកយក្ខដឹងថា ( កូន
របស់នាង ) មានចិត្តប្រទូស្ត ក្រោធខឹង ហើយបានធ្វើនូវកូននាង
ឲ្យយ៉ាងនេះ ។

នាងទិដ្ឋមង្គលិកាពោលថា

បើពួកយក្ខបានធ្វើកូនរបស់ខ្ញុំ ឲ្យយ៉ាងនេះហើយ សូមលោកជា
អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កុំខឹងចំពោះខ្ញុំ នាងខ្ញុំជាស្រី សូមដល់
នូវបាទារបស់លោកជាទីពឹង បពិត្រភិក្ខុ ខ្ញុំមកដោយសេចក្តី
សោកចំពោះកូន ។

ព្រះមហាសត្វពោលថា

កាលនោះក៏ដោយ ឥឡូវនេះក៏ដោយ យើងមិនមានការប្រទូស្ត ក្នុងចិត្តតិចតួចទេ តែកូនរបស់នាងជាអ្នកស្រវឹង ដោយសេចក្តីស្រវឹងក្នុងវេទ រៀនវេទហើយមិនស្គាល់សេចក្តីចម្រើន ។

នាងទិដ្ឋមង្គលិកាពោលថា

បពិត្រភិក្ខុ សញ្ញារបស់បុរសរមែងភ្លេចភ្លាំងដោយមួយរំពេចជាប្រាកដ បពិត្រលោកមានប្រាជ្ញាក្រាស់ដូចផែនដី សូមលោកអត់នូវទោសកំហុសម្តងចុះ អ្នកប្រាជ្ញទាំងឡាយ រមែងមិនមានក្រោធជាកម្លាំង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យក្ខា** បានដល់ យក្ខទាំងឡាយ ដែលរក្សាព្រះនគរ ។ បទថា **អញ្ញាតតា** សេចក្តីថា យក្ខទាំងឡាយមកហើយ ដឹងយ៉ាងនេះថា ឥសីទាំងឡាយ មានគុណធម៌ល្អ ដល់ព្រមដោយគុណសម្បត្តិ ។ បទថា **តេ** សេចក្តីថា យក្ខទាំងនោះ កាលដឹងគុណរបស់ឥសីហើយ ក៏ដឹងច្បាស់នូវបុត្តរបស់នាងដែលកម្រើកចិត្ត គិតប្រទូស្ត ។

បទថា **ត្វញ្ញេវ មេ** សេចក្តីថា បើយក្ខទាំងឡាយក្រោធអាក់អន់ហើយបានធ្វើយ៉ាងនេះ ក៏ចូរធ្វើចុះ ឈ្មោះថា ទេវតាទាំងឡាយ បុគ្គលណាម្នាក់ អាចធ្វើឲ្យស្ងប់រម្ងាប់ គឺបាត់នូវសេចក្តីក្រោធបានដោយល្អ ដោយវិធីត្រឹមតែយកទឹកមួយពែងឲ្យផឹក ព្រោះហេតុនោះ ទើបខ្ញុំមិនខ្លាចទេវតាទាំងនោះ សូមលោកម្ចាស់តែម្យ៉ាងប៉ុណ្ណោះដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយៈ កុំក្រោធអាក់អន់

នឹងបុត្តរបស់ខ្ញុំឡើយ ។ បទថា **អន្វាគតា** សេចក្តីថា ខ្ញុំជាអ្នកជាប់តាមមក ។ នាងទិដ្ឋមង្គលិកាហៅព្រះមហាសត្វថា ភិក្ខុ យំអង្វរឲ្យទុកជីវិតដល់កូន ។

បទថា **តវេវ** សេចក្តីថា នៃនាងទិដ្ឋមង្គលិកា កាលកូនរបស់នាងជេរយើងក្នុងគ្រានោះក្តី កាលនាងមកអង្វរសូមទោសក្នុងគ្រានេះក្តី ទោសចិត្តគិតប្រទូស្តមិនមានដល់យើងឡើយ ។ បទថា **វេទមទេន** សេចក្តីថា ព្រោះការស្រវឹងថាអញរៀនចប់ត្រៃវេទហើយ ។ បទថា **អកិច្ច** សេចក្តីថា សូម្បីរៀនចប់ត្រៃវេទហើយ ក៏មិនស្គាល់វត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍ ។

បទថា **មុហុត្តកេន** សេចក្តីថា រៀនវិជ្ជាឯណាមួយហើយ រមែងភ្លេចបានដោយមួយរំពេចប៉ុណ្ណោះ ។

ព្រះមហាសត្វ កាលនាងទិដ្ឋមង្គលិកាអង្វរសូមទោស ( ជំនួស ) កូនប្រុសយ៉ាងនេះ ទើបពោលថា បើដូច្នោះ យើងនឹងឲ្យអមតឱសថ ដើម្បីបណ្តេញយក្ខទាំងឡាយនោះឲ្យគេចទៅ ហើយពោលគាថាដូច្នេះថា

ចូរឲ្យមណ្ឌព្យកុមារ ដែលជាបុគ្គលមានប្រាជ្ញាតិច ជាបុត្តរបស់
នាងបរិភោគនូវដុំបាយដែលយើងឈរហើយបានមកនេះចំណែក
ខាងពួកយក្ខនឹងលែងបៀតបៀននូវកូនរបស់នាង ទាំងកូនរបស់
នាងនោះ នឹងទៅជាបុគ្គលមិនមានរោគ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្តិដ្ឋបិណ្ឌំ** បានដល់ ដុំបាយដែលសល់

អំពីបរិភោគ ។ បាឋៈថា **ឧច្ចិដ្ឋបិណ្ឌំ** ដូច្នេះក៏មាន ។

នាងទិដ្ឋមង្គលិកាស្តាប់ពាក្យរបស់ព្រះមហាសត្វហើយ ទើបបង្អោនផ្តិលមាសចូលទៅ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យនូវអមតឱសថចុះ ទើបព្រះមហាសត្វចាក់បាយដែលឆាន់សល់ និងទឹកលាងដៃ ក្នុងផ្តិលមាសនោះ ហើយប្រាប់ថា ចូរនាងបន្តក់ទឹកអំពីចំណែកនេះដាក់ក្នុងមាត់កូនរបស់នាងនោះឯង ចំណែកដ៏សេស ចូរយកទឹកបន្ថែមដាក់ក្នុងពាងហើយបន្តក់ក្នុងមាត់ព្រាហ្មណ៍ដ៏សេសទាំងឡាយ ជនទាំងនោះ ក៏នឹងជាសះស្បើយជំងឺតម្កាត់មួយរំពេច កាលពោលដូច្នេះហើយ ក៏ហោះត្រឡប់ទៅកាន់ហិមវន្តប្បទេសមួយរំពេច ។ ឯនាងទិដ្ឋមង្គលិកាយកក្បាលទូលផ្តិលមាសនោះពោលថា យើងបានអមតឱសថហើយ ប្រញាប់ទៅកាន់និវេសន៍របស់ខ្លួនបន្តក់ទឹកបាយដែលលាងដៃដាក់ក្នុងមាត់កូនប្រុសរបស់ខ្លួនមុន ។ យក្ខដែលជាអ្នករក្សាព្រះនគរក៏ចៀសចេញទៅ ។ មណ្ឌព្យមាណពក្រោកឡើង បោសធូលីដែលជាប់នឹងកាយ ហើយសួរថា បពិត្រអ្នកម៉ែ នេះជាអ្វី ទើបនាងពោលនឹងកូនប្រុសថា ឯងនោះឯងនឹងដឹងវត្ថុដែលខ្លួនធ្វើ មកចុះបា ចូរឯងទៅមើលការវិបត្តិនៃទក្ខិណេយ្យបុគ្គលរបស់ឯងផង ។ មណ្ឌព្យមាណពឃើញព្រាហ្មណ៍ទាំងនោះ បម្រះនទៀលសន្ធប់ ក៏បានជាអ្នកមានវិប្បសារៈ ។ លំដាប់នោះ នាងទិដ្ឋមង្គលិកាដែលជាមាតាពោលនឹងមណ្ឌព្យមាណពថា នែមណ្ឌព្យកុមារ ឯងជាមនុស្សល្ងង់ខ្លៅ មិនដឹងទីដែលឲ្យទានមានផលច្រើន ឈ្មោះថាទក្ខិណេយ្យបុគ្គលទាំងឡាយ មិនមែនមានសភាពបែបនេះទេ ត្រូវដូចគ្នានឹង

មាតង្គបណ្ឌិតប៉ុណ្ណោះ តាំងអំពីនេះទៅ បាកុំឲ្យទានដល់បុគ្គលទ្រុស្តសីលពួកនេះឡើយ ចូរឲ្យទានដល់អ្នកមានសីលទាំងឡាយចុះ ដូច្នេះហើយ ពោលគាថាថា

ម្នាលមណ្ឌព្យៈ អ្នកជាបុគ្គលពាល មានប្រាជ្ញាស្តួចស្តើង អ្នកជាបុគ្គលមិនស្គាល់នូវបុញ្ញក្ខេត្តទាំងឡាយ អ្នកឲ្យទានចំពោះតែពួកជនដែលមានទឹកចត់គឺកិលេសដ៏ច្រើន មានអំពើដ៏សៅហ្មង ជាអ្នកមិនសង្រួម ។ ( ពួកជនខ្លះ ) បួងសក់ ស្លៀកនូវស្បែកខ្លាឃ្មុំ មានមុខទ្រុបទ្រុល ( ដោយពុកមាត់ពុកចង្កា ) ដូចរណ្តៅទឹកដ៏ចាស់ អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសភាពអាក្រក់នេះចុះ ដ្បិតក្នុងសក់និងស្បែកខ្លាឃ្មុំ ការពារនូវបុគ្គលដែលមានប្រាជ្ញាតិចមិនបានទេ ។ ពួកបុគ្គលណាលះបង់រាគៈ ទោសៈ និងអវិជ្ជា ពួកបុគ្គលនោះ ឈ្មោះថា ជាអរហន្តខីណាស្រព ទានដែលបុគ្គលឲ្យចំពោះពួកបុគ្គល ទាំងនោះ ទើបជាទានមានផលច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហាក្កសាវេសុ** សេចក្តីថា ក្នុងបណ្តាពួកជនដែលប្រកបដោយកិលេស ដូចទឹកម្ចត់ជំទាំងឡាយ បានឲ្យទានក្នុងបុគ្គលដែលប្រកបដោយកិលេសដូចទឹកម្ចត់ មានរាគៈជាដើមធំ ។

បទថា **ជដា ច កេសា** សេចក្តីថា នៃមណ្ឌព្យៈ ក្នុងទក្ខិណេយ្យបុគ្គលទាំងឡាយរបស់អ្នក ពួកខ្លះក៏បួងសក់ ។ បទថា **អជិនា និវត្ថា** សេចក្តីថា

ស្បៀកសំពត់ស្បែកខ្លាទាំងក្រចក ។ បទថា **ជរូទបានំវ** សេចក្ដីថា មានមាត់ទ្រុបទ្រុល ព្រោះមានពុកចង្កាវែង ដូចមាត់អណ្ដូងទឹកដែលគេបោះបង់ ស៊ុមទ្រុមទ្រុបទ្រុលដោយគុម្ពស្មៅដូច្នោះ ។ បទថា **បជំ ឥមំ** សេចក្ដីថា ចូរអ្នកពិចារណាមើលពួកជនដែលមានរូបរាងគួរខ្ពើម ត្រេកអរ ប្រដាប់នូវកេទខ្លួនដោយគ្រឿងដ៏សៅហ្មងនេះ គឺបែបនេះ ។

បទថា **ជដាជិនំ** សេចក្ដីថា ការដែលចងសក់ធ្វើជាជដាបែបនេះ មិនអាចជាទីពឹងដល់បុគ្គលដែលមានបញ្ញាតិចបាន កុសលកម្ម គឺសីល ញាណ និងតបៈប៉ុណ្ណោះ ទើបជាទីពឹងនៃពួកសត្វទាំងនោះបាន ។ បទថា **យេសំ** សេចក្ដីថា កិលេសទាំងឡាយ មានរាគៈជាដើម ដែលមានការមិនត្រេកអរ និងការវង្វេងជាសភាវៈ និងអវិជ្ជាមានវត្ថុទាំង ៨ ប្រការទាំងនេះ នៃទក្ខិណេយ្យបុគ្គលទាំងឡាយណា ទៅប្រាសហើយ ឬទក្ខិណេយ្យបុគ្គលទាំងឡាយណាបានឈ្មោះថា ជាព្រះអរហន្តអស់អាសវៈ ព្រោះកិលេសទាំងនេះ ទៅប្រាសហើយ ទានដែលបុគ្គលឲ្យហើយក្នុងទក្ខិណេយ្យបុគ្គលទាំងនោះ មានផលច្រើន ។

នាងទិដ្ឋមង្គលិកាពោលបន្តថា នៃកូនជាទីស្រឡាញ់ ព្រោះហេតុនោះ ចាប់អំពីថ្ងៃនេះទៅ អ្នកកុំឲ្យទានដល់បុគ្គលទ្រុស្តសីលបែបនេះ ចូរឲ្យទានដល់សមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ ជាអ្នកបានអភិញ្ញា ៥ និងសមាបត្តិ ៨ និងដល់ព្រះបច្ចេកពុទ្ធទាំងឡាយដែលមានក្នុងលោកទាំងនេះ មកកូនជាទីស្រឡាញ់ យើងនឹងឲ្យពួកព្រាហ្មណ៍ទាំងឡាយដែលជាទីពេញចិត្ត ជាទី

ស្មិទ្ធស្នាលរបស់កូន ផឹកនូវអមតឱសថ ហើយធ្វើឲ្យជាសះស្បើយរោគ ដូច្នេះ ហើយ ទើបយកទឹកបាយដែលជាសំណល់ចាក់ក្នុងពាងទឹក ហើយឲ្យបន្តក់ក្នុងមាត់របស់ព្រាហ្មណ៍ទាំង ១៦០០០ ។ ព្រាហ្មណ៍ម្នាក់ៗ បានសតិ ក្រោកឡើង ប្រោសធូលីដែលជាប់នឹងកាយរបស់ខ្លួន ។ លំដាប់នោះ ព្រាហ្មណ៍ទាំងឡាយដទៃនាំគ្នាតិះដៀលថា ព្រាហ្មណ៍ទាំងនេះ នាំគ្នាផឹកទឹកសំណល់នៃមនុស្សចណ្ឌាល ហើយលើកទោស ធ្វើមិនឲ្យជាព្រាហ្មណ៍តទៅ ។ ព្រាហ្មណ៍ទាំងនោះដល់នូវការខ្មាស ទើបចេញអំពីនគរពារាណសី ទៅកាន់ដែនមេជ្ឈ ហើយស្នាក់នៅ ក្នុងសម្នាក់របស់ព្រះបាទ មេជ្ឈរាជ ។ ឯមណ្ឌព្យមាណព នៅក្នុងនគរពារាណសីយ៉ាងនោះជាប្រក្រតី ។

ក្នុងសម័យនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះជាតិមន្ត បួសជាតាបសនៅត្រង់ឆ្នេរស្ទឹងវេត្តវតីនទី អាស្រ័យវេត្តវតីនគរជាទីគោចរ អាស្រ័យជាតិជាហេតុញ៉ាំងមានះធំឲ្យកើតឡើង ។ ព្រះមហាសត្វមាតង្គបណ្ឌិតគិតថា អញនឹងទម្លាយ មានះរបស់ព្រាហ្មណ៍នេះ ទើបទៅកាន់ទីនោះ នៅខាងលើខ្សែទឹកជិតសម្នាក់ជាតិមន្តតាបស ។ ថ្ងៃមួយ ព្រះពោធិសត្វទំពាឈើស្ទន់ ហើយអធិដ្ឋានថា ឈើស្ទន់នេះ ចូរអណ្តែតទៅជាប់ត្រង់ផ្នួងសក់របស់តាបសជាតិមន្ត ដូច្នេះហើយ បោះឈើជម្រះធ្មេញនោះចូលទៅក្នុងស្ទឹង ។ ឈើស្ទន់ក៏អណ្តែតទៅ ជាប់ត្រង់ជដារបស់ជាតិមន្តតាបសដែលកំពុងងូតទឹកជម្រះកាយ ។ ជាតិមន្តតាបសឃើញដូច្នោះ ជេរបរិភាសថា អន្តរធាន មនុស្សអាក្រក់ ហើយគិតថា មនុស្សកាឡកណ្ណីនេះមកអំពីណា អញត្រូវទៅមើល ទើបដើរទៅតាម

ឆ្នេរស្ទឹង ឃើញមហាសត្វហើយ សួរថា លោកជាតិអ្វី មហាសត្វឆ្លើយថា យើងជាចណ្ឌាលជាតិ ជាតិមន្តតាបសសួរថា លោកបោលឈើស្ទន់ទៅក្នុងទឹកមែនឬ ព្រះមហាសត្វឆ្លើយថា មែន ខ្ញុំជាអ្នកបោលទៅ ។ ជាតិមន្តតាបសក៏បរិភាសថា មនុស្សអន្តរជាន មនុស្សអាក្រក់ មនុស្សចណ្ឌាល មនុស្សកាឡកណ្ណី លោកកុំនៅក្នុងទីនេះឡើយ ចូរទៅនៅខាងក្រោមខ្សែទឹក ខាងនោះ ។ កាលព្រះមហាសត្វទៅនៅខាងក្រោមខ្សែទឹក បោលឈើស្ទន់ទៅក្នុងស្ទឹង ឈើស្ទន់នោះក៏អណ្តែតច្រាសទឹក ទៅជាប់ជដារបស់តាបសនោះទៀត ជាតិមន្តតាបសក្រោធហើយពោលថា វ៉ឺយ មនុស្សអន្តរជាន មនុស្សថោកទាបបើលោកនៅទីនេះ ក្បាលរបស់លោកចូរបែកជា ៧ ភាគ ខាងក្នុងថ្ងៃទី ៧ ព្រះមហាសត្វត្រិះរិះថា បើអញខឹងក្រោធតាបសនេះ សីលរបស់អញនឹងដាច់ មិនជាការរក្សា អញនឹងទម្លាយមានះរបស់តាបសដោយឧបាយ លុះដល់ថ្ងៃទី ៧ ទើបបណ្តាលឫទ្ធិ មិនឲ្យព្រះអាទិត្យរះឡើង ។ មនុស្សទាំងឡាយនាំគ្នាវឹកវរ ចូលទៅរកជាតិមន្តតាបសសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនឲ្យព្រះអាទិត្យរះឡើងឬ តាបសឆ្លើយថា កម្មនោះមិនមែនរបស់ខ្ញុំ តែមានតាបសចណ្ឌាលម្នាក់ នៅអាស្រ័យត្រង់មាត់ស្ទឹងដែរ ប្រហែលជាកម្មរបស់ចណ្ឌាលតាបសនោះ ។ មនុស្សទាំងឡាយនាំគ្នាចូលទៅរកព្រះមហាសត្វសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនឲ្យព្រះអាទិត្យរះឡើងឬ ព្រះមហាសត្វទទួលថា អើ យើងមិនឲ្យរះឡើង ។ ទើបពួកមនុស្សសួរថា ព្រោះហេតុអ្វី ព្រះមហាសត្វក៏ពោលថា តាបសដែលជាអ្នកស្និទ្ធស្នាលក្នុងត្រកូលរបស់អ្នក

ទាំងឡាយ បានផ្ដាសាយើងដែលគ្មានកំហុស កាលតាបសនោះមកក្រាបទៀប បាទជើងរបស់យើង ដើម្បីសូមខមាទោស ទើបយើងលែងព្រះអាទិត្យឲ្យរះឡើង ។ មនុស្សទាំងនោះ ទៅអូសជាតិមន្តតាបសនាំមក បង្គាប់ឲ្យក្រាបទៀបជើងរបស់ព្រះមហាសត្វ ឲ្យសូមខមាទោស ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ លែងព្រះអាទិត្យឲ្យរះឡើងចុះ ព្រះមហាសត្វពោលថា យើងមិនទាន់លែងបានទេ បើយើងលែងព្រះអាទិត្យរះឡើងសោត ក្បាលរបស់តាបសនេះនឹងបែកជា ៧ ភាគ ។ លំដាប់នោះ ទើបមនុស្សទាំងឡាយសួរថា បពិត្រលោកម្ចាស់ កាលបើដូច្នោះ ពួកយើងទាំងឡាយនឹងធ្វើដូចម្ដេច ព្រះមហាសត្វពោលថា ចូរអ្នកទាំងឡាយនាំយកដីស្អិតមក កាលឲ្យនាំមកហើយ ប្រាប់ថា ចូរយកដីស្អិតនេះពាសលើក្បាលតាបសនោះ ហើយបង្គាប់ឲ្យចុះទៅឈរក្នុងទឹក កាលឲ្យឈរក្នុងទឹកហើយ ទើបលែងព្រះអាទិត្យឲ្យរះឡើង ។ កាលព្រះអាទិត្យរះឡើងប៉ះប៉ុណ្ណោះ ដីស្អិតក៏បែកជា ៧ ភាគ តាបស ក៏មុជទៅក្នុងទឹក ។ កាលព្រះមហាសត្វទូន្មានតាបសនោះហើយទើបពិចារណាថា ព្រាហ្មណ៍ ១៦០០០ នោះ ទៅនៅក្នុងទីណាហ្ន៎ បានជ្រាបថា ទៅនៅក្នុងសម្នាក់របស់ព្រះបាទមេជ្ឈរាជ គិតថា អញនឹងទៅទូន្មានព្រាហ្មណ៍ទាំងនោះ ក៏ហោះទៅដោយឫទ្ធិ ចុះក្បែរព្រះនគរ កាន់បាត្រ សញ្ចរទៅដើម្បីបិណ្ឌបាត ក្នុងវេត្តវតីនគរ ។

ព្រាហ្មណ៍ទាំងឡាយឃើញព្រះមហាសត្វហើយ គិតថា កាលតាបសនេះនៅក្នុងទីនេះត្រឹមតែ ១ ឬ ២ ថ្ងៃ នឹងធ្វើឲ្យយើងមិនមានទីពឹង ទើបនាំគ្នាទៅ

កាន់រាជសម្នាក់ជាប្រញាប់ ក្រាបទូលព្រះរាជាថា បពិត្រមហារាជ មានវិទ្យាធរអ្នកលេងកលម្នាក់ជាចោរ មកអាស្រ័យនៅក្នុងព្រះនគរនេះ សូមទ្រង់ត្រាស់ឲ្យចាប់វាចុះ ។ ព្រះរាជាក៏ទទួលថា សាធុ យើងនឹងចាត់ការ ។ ព្រះមហាសត្វបានមិស្សកភត្ត គឺភត្តដែលលាយគ្នាហើយ ទើបនាំមកអង្គុយលើតាំងផ្អែកជញ្ជាំងមួយកន្លែងឆាន់ ។ លំដាប់នោះ រាជបុរសដែលព្រះរាជាបញ្ជូនមក ដើរតាមមក យកដាវកាត់កព្រះមហាសត្វដែលកំពុងឆាន់អាហារ មិនបានប្រយ័ត្នខ្លួន ឲ្យដល់នូវការអស់ជីវិត ។ ព្រះមហាសត្វ ធ្វើកាលកិរិយាហើយ ទៅកើតក្នុងព្រហ្មលោក ។ បានឮថា ក្នុងជាតកនេះ ព្រះពោធិសត្វបានទូន្មានកោណ្ឌព្រាហ្មណ៍ហើយ ក៏ដល់នូវការអស់ជីវិត ព្រោះជាអ្នកខ្វល់ខ្វាយទូន្មានអ្នកដទៃប៉ុណ្ណោះ ។ ទេវតាទាំងឡាយនាំគ្នាក្រោធខឹង ទើបបណ្តាលឲ្យភ្លៀងផេះ ភ្លៀងរងើកភ្លើងធ្លាក់ក្នុងមេជ្ឈរដ្ឋទាំងមូល ធ្វើឲ្យដែនវិនាសទាំងអស់ ។ សមដូចគាថាព័ន្ធដែលទ្រង់ត្រាស់ទុកថា

ស្តេចក្នុងដែនមេជ្ឈៈ បៀតបៀននូវចិត្តរបស់មាតង្គតាបស ជាអ្នកមានយស ស្តេចក្នុងដែនមេជ្ឈៈព្រមទាំងបរិស័ទក៏ដាច់សូន្យដែនឈ្មោះមេជ្ឈៈ ក៏ទៅជាព្រៃក្នុងកាលនោះ ដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់

ត្រាស់ថា មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ព្រះបាទឧទេនរាជ ទ្រង់បៀតបៀនបព្វជិតដូចគ្នា ហើយទ្រង់ប្រជុំជាតកថា មណ្ឌព្យកុមារក្នុងកាលនោះ បានមកជាព្រះបាទឧទេន ក្នុងកាលឥឡូវនេះ ឯមាតង្គបណ្ឌិតក្នុងកាលនោះ គឺតថាគតដែលជាសម្មាសម្ពុទ្ធនេះឯង ។

## អដ្ឋកថា មាតង្គជាតក ចប់

# ចិត្តសម្ភូតជាតក

[ ១៨៣ ] ( ព្រះរាជាត្រាស់ថា ) សេចក្ដីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ខ្ញុំឃើញសម្ភូតបណ្ឌិតមានអានុភាពច្រើនជាអ្នកបរិបូណ៌ដោយផលនៃបុណ្យដោយការងាររបស់ខ្លួន ។ សេចក្ដីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ចិត្តរបស់បណ្ឌិតឈ្មោះចិត្តៈនោះ សម្រេចដូចចិត្តអាត្មាអញដែរឬហ្ន៎ ។

[ ១៨៤ ] ( ទារកច្រៀងទូលថា ) សេចក្ដីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ជ្រាបនូវបណ្ឌិតឈ្មោះចិត្តៈនោះ មានចិត្តសម្រេចដូចព្រះរាជហឫទ័យព្រះអង្គដែរ ។

[ ១៨៥ ] ( ព្រះរាជា... ) ( សំដីនេះ ) អ្នកបានឮមក ( អំពីសំណាក់ ) បណ្ឌិតឈ្មោះចិត្តៈដ៏ចម្រើនឬ ឬជនណាមួយ ប្រាប់សេចក្ដីនុ៎ះដល់អ្នក គាថា ( នេះ ) អ្នកច្រៀងពីរោះហើយ ខ្ញុំមិនមានសេចក្ដីសង្ស័យទេ ខ្ញុំឲ្យស្រុកសួយមួយរយដល់អ្នក ។

[ ១៨៦ ] ( ទារក... ) ខ្ញុំព្រះអង្គ មិនបានឮ ( អំពីសម្នាក់ ) បណ្ឌិតឈ្មោះចិត្តៈទេ តែឥសី ( មួយរូប ) បានប្រាប់នូវសេចក្ដីនេះ ដល់ខ្ញុំព្រះអង្គថា អ្នកចូរទៅច្រៀងគាថាតនឹងព្រះរាជា ក្រែងលោស្ដេចសព្វព្រះរាជហឫទ័យ

នឹងប្រោសប្រទាននូវរបស់ដ៏ប្រសើរដល់អ្នក ។

[ ១៨៧ ] ( ព្រះរាជា... ) អ្នកទាំងឡាយចូរទឹមនូវរាជរថទាំងឡាយ ដែលធ្វើយ៉ាងល្អ គ្រឿងប្រដាប់ដ៏ពិចិត្ត ចូរចងនូវខ្សែជង្គន់ ពាក់នូវគ្រឿងប្រដាប់កនៃដំរីទាំងឡាយ ។ អ្នកទាំងឡាយ ចូរវាយស្គរនិងសំភោរ ផ្លុំនូវស័ង្ខ ផងចូរទឹមនូវយានទាំងឡាយដ៏លឿនៗផង ថ្ងៃនេះឯង អញនឹងទៅមើលឥសីដែលគង់ក្នុងអាស្រមណា អញនឹងទៅកាន់អាស្រមនោះ ។

[ ១៨៨ ] ឱហ្ន៎ អាត្មាអញមានលាភល្អណាស់តើ គាថាដែលអាត្មាអញច្រៀងពីរោះហើយក្នុងកណ្តាលបរិស័ទ អាត្មាអញបានឃើញនូវឥសីដ៏បរិបូណ៌ដោយសីលនិងវត្ត ហើយក៏ត្រេកអររីករាយ ។

[ ១៨៩ ] សូមលោកដ៏ចម្រើន ទទួលនូវអាសនៈ ទឹកនិងប្រេងលាបជើង របស់យើងចុះ បពិត្រម្ចាស់ថ្លៃ ខ្ញុំសួរលោកដ៏ចម្រើនក្នុងវត្ថុមានតម្លៃ សូមលោកដ៏ចម្រើន ទទួលនូវវត្ថុមានតម្លៃរបស់យើងខ្ញុំ ។

[ ១៩០ ] ពួកជនចូរធ្វើនូវលំនៅ ឲ្យជាទីរីករាយដល់លោកផង សូមលោកឲ្យពួកនារីបម្រើផង សូមលោកធ្វើនូវឱកាសដើម្បីអនុគ្រោះ យើងនឹងធ្វើជាធំនេះទាំងពីរនាក់ ។

[ ១៩១ ] ( ចិត្តបណ្ឌិតពោលថា ) បពិត្រព្រះរាជា អាត្មាភាពបានឃើញនូវផលនៃទុច្ចរិត និងផលដ៏ប្រសើរ របស់ធម៌ដែលបានសន្សំដោយប្រពៃ អាត្មាភាពនឹងសង្រួមនូវខ្លួនតែម្យ៉ាង អាត្មាភាពមិនប្រាថ្នានូវកូនឬសត្វចិញ្ចឹមឬទ្រព្យទេ ។

១០ ឆ្នាំ ១០ ដងនេះ ជាជីវិតរបស់ពួកសត្វក្នុងលោកនេះ ជីវិតនោះ មិនដល់កំណត់នោះនៅឡើយ ក៏ស្វិតស្រពោនទៅ ដូចជាដើមបបុស ដែលគេកាត់ហើយ ។ កាលបើជីវិតនោះ ( ស្រពោនទៅយ៉ាងនេះ ) តើរីករាយដូចម្ដេចកើត លេងសើច ដូចម្ដេចកើត ត្រេកអរដូចម្ដេចកើត ស្វែងរកទ្រព្យដូចម្ដេចកើត បពិត្រព្រះរាជា អាត្មាភាពមានប្រយោជន៍ដោយកូននិងប្រពន្ធ ដូចម្ដេចកើត អាត្មាភាពជាបុគ្គលផុតចាកចំណងហើយ ។ អាត្មាភាពនោះ ដឹងច្បាស់យ៉ាងនេះ មច្ចុរាជមិនមើលងាយ ចំពោះអាត្មាភាពទេ កាលបើអាត្មាភាពត្រូវមច្ចុរាជគ្របសង្កត់ ( យ៉ាងនេះ ) តើត្រេកអរដូចម្ដេចកើត ស្វែងរកទ្រព្យដូចម្ដេចកើត ។ បពិត្រព្រះអង្គជាធំជាងជន ជាតិរបស់ពួកសត្វ ជាធម្មជាតិដ៏ថោកទាប កំណើតមនុស្សចណ្ឌាលលាមកជាងពួកសត្វក្នុងពួកសត្វជើងពីរ យើងបាននៅក្នុងគភ៌មនុស្សចណ្ឌាល ក្នុងកាលមុន ព្រោះតែអំពើជារបស់ខ្លួនដ៏លាមកក្រៃលែង ។

យើងបានកើតជាមនុស្សចណ្ឌាល ក្នុងដែនអវន្តី ហើយបែរមកកើតជាម្រឹគប្របញ្ចេរស្ទឹងនេរញ្ជរា រួចកើតជាសត្វអកខ្មៅ[១] ទៀបច្រាំងស្ទឹងនម្មទា ក្នុងថ្ងៃនោះយើងជាព្រាហ្មណ៍និងក្សត្រិយ៍ ។

[ ១៩២ ] ជីវិតគឺអាយុ មានប្រមាណតិច ត្រូវជរានាំចូលទៅ ( កាន់

---

១-អាចារ្យខ្លះថា សត្វអង្កត់ខ្មៅ ។

សេចក្តីស្លាប់ ) កាលបើសត្វត្រូវជរានាំចូលទៅ ( កាន់សេចក្តីស្លាប់ហើយ ) ទីពឹងពុំមានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយដែលមានកម្រៃជាទុក្ខឡើយ ។ ជីវិតគឺអាយុ មានប្រមាណតិច ត្រូវជរានាំទៅ ( កាន់សេចក្តីស្លាប់ ) កាលបើសត្វត្រូវជរានាំទៅ ( កាន់សេចក្តីស្លាប់ហើយ ) ទីពឹងពុំមានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយ ដែលមានផលជាទុក្ខឡើយ ។ ជីវិតគឺអាយុមានប្រមាណតិច ត្រូវជរានាំទៅ ( កាន់សេចក្តីស្លាប់ ) កាលបើសត្វត្រូវជរានាំទៅ ( កាន់សេចក្តីស្លាប់ហើយ ) ទីពឹងពំនាក់ពុំមានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយដែលជាប្រធាននៃធូលីគឺកិលេសឡើយ ។ ជីវិតគឺអាយុ មានប្រមាណតិច ត្រូវជរានាំទៅ ( កាន់សេចក្តីស្លាប់ ) ជរាតែងកម្ចាត់បង់នូវសម្បុរ របស់សត្វដែលកំពុងគ្រាំគ្រា បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើដើម្បីកើតក្នុងនរកឡើយ ។

[ ១៩៣ ] ( ព្រះរាជា... ) ពាក្យ ( របស់លោក ) នោះ ពេញជាពិតមែនហើយ បពិត្រឥសី លោកពោលយ៉ាងណា សេចក្តីនុ៎ះយ៉ាងនោះ បពិត្រភិក្ខុ តែកាមទាំងឡាយរបស់ខ្ញុំ មានសភាពមិនតិចទេ កាមទាំងនោះ បុគ្គលប្រហែលខ្ញុំលះបង់បានដោយក្រ ។ ដំរីជាប់នៅក្នុងកណ្តាលភក់ មិនអាចរើខ្លួនទៅកាន់ទីគោកដោយខ្លួនឯងយ៉ាងណា ខ្ញុំក៏ជាបុគ្គលជាប់នៅក្នុងភក់ គឺកាមមិនអាចបួសតាមផ្លូវ ( ឱវាទ ) របស់លោកជាភិក្ខុយ៉ាងនោះដែរ ។ មាតាបិតា

ប្រៀនប្រដៅបុត្ត ( ដោយឧបាយថា ) ធ្វើម្ដេចបុត្តនឹងបានសេចក្ដីសុខ យ៉ាងណា បពិត្រលោកដ៏ចម្រើន សូមលោកប្រៀនប្រដៅខ្ញុំតាមសមគួរ ល្មមឲ្យខ្ញុំលះលោកនេះទៅហើយ បានសេចក្ដីសុខជាអង្វែង ក៏យ៉ាងនោះដែរ ។

[ ១៩៤ ] ( ចិត្តបណ្ឌិត... ) បពិត្រព្រះអង្គជាធំជាងជន បើព្រះអង្គមិនអាចនឹងលះបង់នូវកាមទាំងឡាយ ជារបស់មនុស្សនេះបានទេ បពិត្រព្រះរាជា សូមព្រះអង្គតាំងទុកនូវពលីប្រកបដោយធម៌ ឯការងារដែលមិនប្រកបដោយធម៌ ក៏សូមកុំឲ្យមាន ក្នុងដែនរបស់ព្រះអង្គឡើយ ។ សូមឲ្យទូតទាំងឡាយ ( របស់ព្រះអង្គ ) ជាអ្នកនិមន្តនូវពួកព្រាហ្មណ៍ចេញទៅកាន់ទិសទាំង ៤ ( និមន្តមិនរើសមុខ ) សូមឲ្យព្រះអង្គទំនុកបម្រុងនូវសមណព្រាហ្មណ៍ទាំងនោះ ដោយបាយ ទឹក សំពត់និងសេនាសនប្បច្ច័យ ។ សូមព្រះអង្គ មានព្រះទ័យជ្រះថ្លាហើយ ញុំាំងសមណព្រាហ្មណ៍ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក លុះព្រះអង្គឲ្យទាននិងប្រើប្រាស់ ( ទ្រព្យ ) តាមសមគួរដល់រាជានុភាពហើយ ឥតមានអ្នកផងតិះដៀល ហើយសូមឲ្យទៅកើតក្នុងឋានសួគ៌ ។ បពិត្រព្រះរាជា បើសេចក្ដីស្រើងគ្របសង្កត់ព្រះអង្គ ដែលមានពួកនារីចោមរោមបម្រើ សូមព្រះអង្គធ្វើទុកក្នុងព្រះទ័យចំពោះគាថានេះចុះ មួយទៀត សូមព្រះអង្គ ( ឧស្សាហ៍ ) ប្រើគេឲ្យពោលនូវគាថានេះ ក្នុងកណ្ដាលបរិស័ទថា

> សត្វណា ដេកក្នុងទីវាល បៅដោះមាតាកំពុងដើរ ជាសត្វប្របូកប្របល់ដោយពួកសុនខ សត្វនោះគេហៅថាព្រះរាជាក្នុងថ្ងៃនេះ ។

**ចប់ចិត្តសម្ភូតជាតកទី ២ ។**

## អដ្ឋកថា

## ចិត្តសម្ភូតជាតក

[ ១៨៣-១៩៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ២ រូប ដែលនៅរួមគ្នាដោយការស្រឡាញ់ ជាសទ្ធិវិហារិករបស់ព្រះមហាកស្សបៈ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វំ នរានំ សផលំ សុចិណ្ណំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុ ២ រូបនោះ ប្រើប្រាស់សមណបរិក្ខាររួមគ្នា ដែលមានការស្និទ្ធស្នាលគ្នាយ៉ាងក្រៃលែង កាលត្រាច់បិណ្ឌបាតក៏ទៅរួមគ្នា មិនអាចបែកគ្នាបាន ភិក្ខុទាំងឡាយអង្គុយសរសើរការស្និទ្ធស្នាលរបស់ភិក្ខុ ២ រូបនោះឯងក្នុងធម្មសភា ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយនោះទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលភិក្ខុ ២ រូបនេះជាអ្នកស្និទ្ធស្នាលគ្នាក្នុងអត្តភាពនេះ មិនគួរអស្ចារ្យឡើយ បុរាណកបណ្ឌិតទាំងឡាយសូម្បីអន្ទោលទៅរវាង ៣-៤ ភព ក៏មិនលះបង់សេចក្តីស្និទ្ធស្នាលក្នុងឋានៈជាមិត្តឡើយ ដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទអវន្តីមហារាជ សោយរាជសម្បត្តិនៅក្នុងក្រុងឧជ្ជេនីដែនអវន្តី ។ កាលនោះ ខាងក្រៅក្រុងឧជ្ជេនី មានភូមិចណ្ឌាលមួយ ។ ព្រះមហាសត្វកើតក្នុងភូមិចណ្ឌាលនោះ ។ ក្រោយមក សត្វដទៃទៀត ក៏មក

កើតជាកូនក្នុងផ្ទៃរបស់ម្តាយមីងរបស់ព្រះពោធិសត្វនោះដូចគ្នា ។ កុមារទាំង ២ នាក់ ម្នាក់ជាព្រះពោធិសត្វ ឈ្មោះចិត្តកុមារ ម្នាក់ជាកូនរបស់ម្តាយមីង ឈ្មោះសម្ភូតកុមារ ។ កុមារទាំង ២ នោះ កាលចម្រើនវ័យហើយ រៀនសិល្បសាស្ត្រឈ្មោះចណ្ឌាលវង្សធោវន ។ ថ្ងៃមួយ បបួលគ្នាថា យើងទាំង ២ នឹងសម្តែងសិល្បសាស្ត្រក្បែរទ្វារនគរឧជ្ជេនី ម្នាក់សម្តែងសិល្បសាស្ត្រត្រង់ទ្វារទិសខាងជើង ម្នាក់ទៀតសម្តែងសិល្បសាស្ត្រត្រង់ទ្វារទិសខាងកើត ។ ក្នុងព្រះនគរនោះ មានស្ត្រីឈ្មោះទិដ្ឋមង្គលិកា ២ នាក់ ម្នាក់ជាកូនស្រីរបស់សេដ្ឋី ម្នាក់ទៀតជាកូនស្រីរបស់បុរោហិត ។ ស្រីទាំង ២ បានឲ្យបរិវាររបស់ខ្លួនកាន់គ្រឿងទំពា និងគ្រឿងបរិភោគ មួយអន្លើដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើមជាច្រើនទៅដោយគិតថា នឹងលេងក្នុងឧទ្យាន នារីម្នាក់ចេញតាមទ្វារទិសខាងជើង ម្នាក់ទៀតចេញតាមទ្វារទិសខាងកើត ។ ទិដ្ឋមង្គលិកាកុមារីទាំង ២ នោះ ឃើញកូនរបស់ចណ្ឌាល ២ នាក់បងប្អូនសម្តែងសិប្បៈ ទើបសួរថា ជនទាំងនេះជានរណា បានឮថា ជាកូនរបស់ចណ្ឌាល ទើបគិតថា យើងទាំងឡាយបានឃើញបុគ្គលដែលមិនគួរឃើញហើយហ្ន៎ ហើយយកទឹកក្រអូបលាងភ្នែក នាំគ្នាត្រឡប់ ។ មហាជនដែលទៅជាមួយគ្នាក្រោធពោលថា រ៉ឺយ អាចណ្ឌាលជាតិអាក្រក់ ព្រោះអាស្រ័យអាទាំង ២ ទើបពួកយើងខានផឹកស្រានិងបរិភោគសម្ភោគដែលមិនចាំបាច់ទិញ ហើយនាំគ្នាវាយបងប្អូនទាំង ២ នោះ ឲ្យដល់នូវការទ្រុឌទ្រោមគ្រាំគ្រា ។ បងប្អូនទាំង ២ ដឹងខ្លួនឡើង ក្រោកដើរទៅកាន់សម្នាក់នៃគ្នានឹងគ្នា មកព្រមគ្នាក្នុងទីមួយ រួចប្រាប់

សេចក្ដីទុក្ខដែលកើតឡើងឲ្យគ្នានឹងគ្នាស្ដាប់ ស្រែកយំកន្ទក់កន្ទេញប្រឹក្សាគ្នាថា យើងទាំង ២ ធ្វើយ៉ាងណាល្អ ហើយពោលថា ព្រោះអាស្រ័យជាតិកំណើត ទើបសេចក្ដីទុក្ខនេះកើតឡើងដល់យើងទាំង ២ ពួកយើងមិនអាចធ្វើការងារ របស់មនុស្សចណ្ឌាលបានទេ ទើបស្រុះស្រួលគ្នាថា យើងទាំង ២ បិទបាំង ជាតិកំណើតហើយ ក្លែងខ្លួនជាព្រាហ្មណមាណព ទៅកាន់ក្រុងតក្កសិលារៀន សិប្បវិជ្ជាចុះ ដូច្នេះហើយ ធ្វើដំណើរទៅនគរតក្កសិលា ជាធម្មន្តេវាសិក ផ្ដើម រៀនសិល្បសាស្ត្រ ក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ បានល្បីពេញជម្ពូ ទ្វីបថា បានឮថា ចណ្ឌាល ២ នាក់បងប្អូនបិទបាំងជាតិកំណើតគេចទៅរៀន សិល្បសាស្ត្រ ។

បងប្អូនទាំង ២ នាក់នោះ ចិត្តបណ្ឌិតរៀនសិល្បសាស្ត្រសម្រេច តែ សម្ភូតកុមាររៀនមិនទាន់សម្រេច ។ ថ្ងៃមួយ ព្រាហ្មណ៍អ្នកស្រុកម្នាក់មក អញ្ជើញអាចារ្យទិសាបាមោក្ខថា ខ្ញុំនឹងធ្វើការសូធ្យមន្ត ( ក្នុងវិធីមង្គល ) យប់ នោះឯង ភ្លៀងធ្លាក់ខ្លាំង ផ្លូវទាំងឡាយជោកជាំដោយទឹក ។ អាចារ្យក៏ហៅ ចិត្តបណ្ឌិតមកអំពីព្រលឹមបញ្ជូនទៅជំនួសខ្លួន ដោយប្រាប់ថា នែបា យើង មិនអាចទៅបានទេ ចូរអ្នកទៅសូធ្យមង្គលកថា មួយអន្លើដោយមាណពទាំង ឡាយ បរិភោគអាហារចំណែកដែលពួកអ្នកបានទទួល ហើយនាំយកអាហារ ចំណែកយើងមកផង ចិត្តបណ្ឌិត ទទួលពាក្យអាចារ្យថា សាធុ ហើយនាំ មាណពទាំងឡាយមក ។ មនុស្សទាំងឡាយដួសបាយាសតម្កល់ទុក បានឮ ថា មាណពទាំងឡាយនឹងតទឹកលុបមុខស្រេចនឹងត្រជាក់ល្មម ។ កាលបាយាស

មិនទាន់ត្រជាក់ មាណពទាំងឡាយនាំគ្នាអង្គុយក្នុងផ្ទះហើយ ។ មនុស្សទាំងឡាយឲ្យទឹកទក្ខិណោទក លើកកត្តមកតម្កល់ទុកខាងមុខមាណពទាំងនោះ ។ សម្ភូតមាណពមាននិស្ស័យល្មោភក្នុងអាហារ ប្រញាប់ជួសដុំបាយាសដាក់ក្នុងមាត់ ដោយសម្គាល់ថា ត្រជាក់ល្អហើយ ដុំបាយាសដែលក្តៅគគុកដូចរងើកភ្លើង ក៏រលាកមាត់ ។ គាត់គ្រវីក្បាល រង្គើទាំងសរីរៈ តម្កល់សតិមិនបានសម្លឹងមើលចិត្តបណ្ឌិតក្លេចខ្លួន ពោលភាសាចណ្ឌាលយ៉ាងនេះថា ខលុ ខលុ ។ ឯចិត្តបណ្ឌិត តម្កល់សតិមិនបានដូចគ្នា បញ្ចូនភាសាចណ្ឌាលតបទៅយ៉ាងនេះថា និគ្គលៈ និគ្គលៈ ។ មាណពទាំងឡាយមើលមុខគ្នាពោលថា នេះជាភាសាអ្វី ។ ចិត្តបណ្ឌិតពោលមង្គលកថាអនុមោទនាហើយ ។ មាណពទាំងឡាយចេញមកខាងក្រៅ ហើយអង្គុយពិចារណាភាសាក្នុងទីនោះៗ ជាពួកៗ លុះដឹងថា ជាភាសាចណ្ឌាល ទើបជេរថា វ៉ៃយ អាចណ្ឌាលជាតិអាក្រក់ ពួកអាបោកបញ្ឆោតថាជាព្រាហ្មណ៍ អស់កាលមានប្រមាណប៉ុណ្ណេះ នាំគ្នាវាយមាណពទាំង ២ ។

សម័យនោះ សប្បុរសម្នាក់ក៏ឃាត់ថា អ្នកទាំងឡាយចូរចៀសទៅចុះ ហើយនាំមាណពមក បញ្ជូនទៅដោយពោលថា នេះជាទោសនៃជាតិកំណើតនៃអ្នកទាំង ២ ចូរនាំគ្នាទៅបួសចិញ្ចឹមជីវិតក្នុងបទេសឯណាមួយចុះ ។ ពួកមាណពទាំងឡាយត្រឡប់មកប្រាប់រឿងដែលមាណពទាំង ២ ជាចណ្ឌាលឲ្យអាចារ្យជ្រាបគ្រប់ប្រការ ។ មាណពទាំង ២ ក៏ចូលព្រៃ បួសជាឥសី មិនយូរប៉ុន្មានក៏ច្យុតិចាកអត្តភាពនោះ ទៅកើតក្នុងផ្ទៃនៃមេម្រឹគ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ។

តាំងពីកើតអំពីផ្ទៃមេម្រឹគហើយ មិគបោតកៈទាំង ២ ក៏ត្រាច់ទៅជាមួយគ្នា មិនអាចព្រាត់ប្រាសគ្នាបាន ។ ថ្ងៃមួយ ព្រានព្រៃម្នាក់មកឃើញមិគបោតកៈទាំង ២ ពាំស្មៅត្រឡប់មក ហើយឈរយកក្បាលទល់គ្នា យកស្នែងទល់ស្នែង យកមាត់ទល់មាត់ជិតគ្នា ឈរលាក់ខ្លួនត្រង់គល់ឈើមួយកន្លែង ក៏ពួយលំពែងទៅសំដៅសត្វទាំង ២ ឲ្យអស់ជីវិត ដោយការប្រហារតែមួយលំពែងប៉ុណ្ណោះ ។ កាលបោតកម្រឹគទាំងគូចុតិចាកអត្តភាពនោះហើយ ក៏ទៅកើតក្នុងកំណើតអកខ្មៅ ត្រង់ឆ្នេរស្ទឹងនម្មទានទី ។ ក្នុងអត្តភាពនោះ មានព្រានដាក់អន្ទាក់ម្នាក់ មកឃើញកូនអកខ្មៅទាំង ២ នោះ ចម្រើនវ័យហើយ ចេញទៅរកចំណី ហើយមកឈរយកក្បាលទល់ក្បាល យកចំពុះទល់ចំពុះ ស្និទ្ធស្នាលនឹងគ្នាទើបយកសំណាញ់បង់ សម្លាប់ឲ្យស្លាប់ដោយការប្រហារតែម្តងប៉ុណ្ណោះ ។ កាលចុតិចាកអត្តភាពនោះហើយ ចិត្តបណ្ឌិតកើតជាបុត្តរបស់បុរោហិត ក្នុងកោសម្ពីនគរ សម្ភូតបណ្ឌិតកើតជាឱរសរបស់ព្រះបាទឧត្តរបញ្ចាលរាជ តាំងអំពីថ្ងៃថ្វាយព្រះនាម កុមារទាំងនោះក៏រឭកជាតិបានរៀងៗខ្លួន ។ សម្ភូតបណ្ឌិតរាជកុមារ មិនអាចរឭកក្នុងចន្លោះបាន រឭកបានតែក្នុងជាតិទី ៤ គ្រាកើតជាចណ្ឌាលប៉ុណ្ណោះ ។ ឯចិត្តបណ្ឌិតកុមាររឭកបានទាំង ៤ ជាតិដោយលំដាប់ ។ លុះមានអាយុ ១៦ ឆ្នាំ ចិត្តបណ្ឌិត ចេញអំពីផ្ទះទៅកាន់ហិមវន្តប្បទេស បួសជាឥសី ញុំាងឈាននិងអភិញ្ញាឲ្យកើតហើយ នៅដោយសេចក្តីសុខដែលកើតអំពីឈាន ។ ឯសម្ភូតរាជកុមារ កាលព្រះជនកសោយទិវង្គតហើយ លើកស្វេតច្ឆត្រឡើងសោយរាជ្យជំនួស បានត្រាស់ ២ គាថា ដោយការ

ត្រេកអរក្នុងព្រះរាជហឫទ័យ ធ្វើឲ្យជាបទចម្រៀង ច្រៀងក្នុងថ្ងៃធ្វើមង្គល កណ្តាលមហាជន ក្នុងថ្ងៃធ្វើឆត្តមង្គលនោះឯង ។ ស្រីស្នំក្តី អ្នករបាំទាំងឡាយក្តី បានស្តាប់គាថានោះហើយ គិតថា បានឮថា នេះជាចម្រៀងទាក់ទងក្នុងថ្ងៃធ្វើមង្គលរបស់ព្រះរាជានៃយើងទាំងឡាយ ទើបនាំគ្នាច្រៀងនូវបទព្រះរាជនិពន្ធនោះគ្រប់គ្នា មហាជនអ្នកនគរទាំងអស់ជ្រាបថា បទចម្រៀងនេះជាទីប្រោសប្រាណ ពេញព្រះរាជហឫទ័យនៃព្រះរាជា ក៏នាំគ្នាច្រៀងបទព្រះរាជនិពន្ធនោះឯងតៗគ្នាទៅដោយលំដាប់ ។ ឯចិត្តបណ្ឌិតតាបស នៅក្នុងហិមវន្តប្បទេសនោះឯង ពិចារណាថា សម្ភូតបណ្ឌិតប្អូនប្រុសរបស់អញ បានគ្រប់គ្រងស្វេតច្ឆត្រឬមិនទាន់បានគ្រប់គ្រង ដឹងថាបានគ្រប់គ្រងហើយ ទើបគិតថា ឥឡូវនេះ អញមិនអាចទៅទូន្មានព្រះរាជាដែលបានរាជសម្បត្តិថ្មីៗឲ្យទ្រង់ដឹងច្បាស់នូវធម្មវិសេសបានទេ អញនឹងចូលទៅរកទ្រង់ ក្នុងកាលដែលទ្រង់ព្រះជរាភាព ពោលធម្មកថា ហើយនឹងនាំឲ្យទ្រង់បព្វជ្ជា ដូច្នេះហើយ ក៏មិននិមន្តទៅអស់កាល ៥០ ឆ្នាំ ។ ក្នុងកាលដែលព្រះរាជា ទ្រង់ចម្រើនដោយព្រះឱរសនិងព្រះធីតាហើយ ទើបហោះមកតាមអាកាស ដោយឫទ្ធានុភាព ចុះត្រង់ព្រះរាជឧទ្យាន អង្គុយសម្រាកនៅលើមង្គលសិលាអាសនៈដូចបដិមាមាស ។ ខណៈនោះ មានទារកម្នាក់ច្រៀងបទព្រះរាជនិពន្ធរកឧស ។ ចិត្តបណ្ឌិតតាបសហៅកុមារនោះមក កុមារក៏មក ថ្វាយបង្គំតាបសហើយឈរ ។ ពេលនោះ ចិត្តបណ្ឌិតតាបសក៏ពោលនឹងកុមារនោះថា តាំងពីព្រឹកមក ឯងច្រៀងដដែលៗ មិនចេះបទដទៃខ្លះទេឬ កុមារឆ្លើយថា បពិត្រលោកម្ចាស់ បទ

ដទៃក៏ខ្ញុំចេះច្រើន តែចម្រៀង ២ វគ្គនេះ ជាបទដែលព្រះរាជាទ្រង់ប្រោស ប្រាណសព្វព្រះរាជហឫទ័យ ព្រោះហេតុនោះ ទើបខ្ញុំច្រៀងចំពោះបទនេះ ប៉ុណ្ណោះ តាបសសួរថា តើមាននរណា ច្រៀងតបបទព្រះរាជនិពន្ធបានដែរ ឬទេ កុមារឆ្លើយថា មិនមានទេលោកម្ចាស់ ។ តាបសពោលថា អើ ចុះឯង អាចច្រៀងឆ្លើយបានដែរឬ កុមារឆ្លើយថា បើខ្ញុំដឹងក៏នឹងអាច ។ តាបស ពោលថា បើដូច្នោះ កាលព្រះរាជាទ្រង់ច្រៀងបទព្រះរាជនិពន្ធទាំង ២ ហើយ ចូរឯងយកបទចម្រៀងទាំង ៣ នេះ ទៅច្រៀងតបចុះ ហើយបង្រៀនបទនោះ ដល់កុមារបញ្ជូនទៅមួយអន្លើដោយពាក្យថា ចូរឯងច្រៀងក្នុងសម្នាក់ព្រះរាជា ព្រះរាជាទ្រង់ជ្រះថ្លា នឹងព្រះរាជទានយសដ៏ធំក្រៃលែងដល់ឯង ។ ទារកនោះ ប្រញាប់រត់ទៅកាន់សម្នាក់មាតា ឲ្យជួយប្រដាប់តាក់តែងខ្លួន ហើយទៅកាន់ ទ្វារព្រះរាជនិវេសន៍ ប្រាប់រាជបុរសឲ្យក្រាបទូលព្រះរាជាថា បានឮថា មាន កុមារម្នាក់ ចង់មកច្រៀងឆ្លើយឆ្លងជាមួយទ្រង់ កាលបានទទួលព្រះបរមរាជា នុញ្ញាតហើយ ទើបចូលទៅថ្វាយបង្គំ កាលព្រះរាជាត្រាស់សួរថា នៃកុមារ តូច បានឮថា ឯងមកច្រៀងឆ្លើយឆ្លងនឹងយើងឬ ក៏ទូលថា បពិត្រព្រះអង្គ ពិតហើយ ហើយទូលឲ្យព្រះរាជាត្រាស់ឲ្យរាជបរិស័ទទាំងឡាយមកប្រជុំគ្នា កាលរាជបរិស័ទប្រជុំគ្នាហើយ ទើបក្រាបទូលព្រះរាជាថា សូមទ្រង់ច្រៀង បទដែលទ្រង់និពន្ធមុនចុះ ទូលព្រះបង្គំនឹងច្រៀងថ្វាយឯក្រោយ ។ ព្រះរាជា បានច្រៀង ២ គាថាជាសំណួរថា

សេចក្តីខ្វល់ខ្វាយដោយការផ្សារទាំងអស់ ដែលនរជនទាំងឡាយ

សន្សំហើយដោយប្រពៃ រមែងប្រកបដោយផលមិនមែនឥតអំពើទេ ខ្ញុំឃើញសម្ភូតបណ្ឌិតមានអានុភាពច្រើន ជាអ្នកបរិបូណ៌ ដោយផលនៃបុណ្យដោយការងាររបស់ខ្លួន ។ សេចក្ដីខ្វល់ខ្វាយដោយការងារទាំងអស់ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ចិត្តរបស់បណ្ឌិតឈ្មោះចិត្តៈនោះ សម្រេចដូចចិត្តអាត្មាអញ ដែរឬហ្ន៎ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន កម្មុនា កិញ្ចន មោឃមត្ថិ** នេះ ព្រះរាជាត្រាស់ដល់អបរាបរវេទនីយកម្មថា ក្នុងកម្មដែលបុគ្គលធ្វើហើយ ទាំងល្អទាំងអាក្រក់ កម្មតិចតួចត្រឹមតែម្យ៉ាង ដែលឈ្មោះថាជាមោឃៈមិនមាន គឺមិនឥតផលឡើយ ត្រូវឲ្យផលជានិច្ច ទើបផុតទៅបាន ។ បទថា **សម្ភូតំ** សេចក្ដីថា ព្រះបាទសម្ភូតបណ្ឌិត ត្រាស់ហៅព្រះអង្គឯងថា ខ្ញុំឃើញខ្លួនឯងដែលមានឈ្មោះថា សម្ភូត ។ បទថា **សកម្មុនា បុញ្ញផលូបបន្នំ** សេចក្ដីថា ខ្ញុំឃើញខ្លួនខ្ញុំដែលកើតឡើងដោយផលនៃបុណ្យ ព្រោះកម្មរបស់ខ្លួន គឺកើតឡើងដោយផលនៃបុណ្យ ព្រោះអាស្រ័យកម្មរបស់ខ្លួនជាហេតុជាបច្ច័យ ។ បទថា **កច្ចិន្នុ ចិត្តស្សបិ** សេចក្ដីថា ពិតហើយ យើងទាំង ២ បានរក្សាសីលរួមគ្នាមក មិនយូរប៉ុន្មានខ្ញុំក៏ដល់នូវយសធំ ដោយផលនៃសីលនោះឯង យ៉ាងណា មនោរថនៃចិត្តបណ្ឌិតបងប្រុសរបស់យើង នឹងសម្រេចសមប្រាថ្នាដូច្នោះដូចគ្នា ដូចមនោរថរបស់យើងដែរឬហ្ន៎ ។

កាលព្រះបាទសម្ភូតច្រៀងចប់ ២ គាថា កុមារកាលច្រៀងតប ទើបច្រៀងគាថាទី ៣ ថា

សេចក្ដីខ្វល់ខ្វាយ ដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ បពិត្រព្រះសម្ភូតិទេព សូមព្រះអង្គទ្រង់ជ្រាបនូវបណ្ឌិតឈ្មោះចិត្តៈនោះ មានចិត្តសម្រេចដូចព្រះរាជហឫទ័យព្រះអង្គដែរ ដូច្នេះ ។

ព្រះរាជាស្ដាប់ព្រះតម្រាស់នោះហើយ បានត្រាស់គាថាទី ៤ ថា

( សំដីនេះ ) អ្នកបានឮមក ( អំពីសំណាក់ ) បណ្ឌិតឈ្មោះចិត្តៈដ៏ចម្រើនឬ ឬជនណាមួយប្រាប់សេចក្ដីនុ៎ះដល់អ្នក គាថា ( នេះ ) អ្នកច្រៀងពីរោះហើយ ខ្ញុំមិនមានសេចក្ដីសង្ស័យទេ ខ្ញុំឲ្យស្រុកសួយមួយរយដល់អ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុតមញ្ញតោ តេ** សេចក្ដីថា ពាក្យថា ខ្ញុំឈ្មោះជាចិត្តបណ្ឌិត ជាបងរបស់ព្រះបាទសម្ភូតនេះ អ្នកបានឮមកអំពីសម្នាក់របស់ចិត្តបណ្ឌិតនោះដែលពោលឬ ។ បទថា **កោចិ ឆំ** សេចក្ដីថា ឬអ្នកណាប្រាប់សេចក្ដីនេះដល់អ្នក ចិត្តបណ្ឌិតបងរបស់ព្រះបាទសម្ភូត យើងឃើញហើយ ។ បទថា **សុគីតា** សេចក្ដីថា គាថានេះ អ្នកច្រៀងបានល្អហើយដោយប្រការទាំងពួង ខ្ញុំមិនមានសន្និះសង្ស័យក្នុងបទចម្រៀងនេះឡើយ ។ បទថា **គាមវរំ សតញ្ច** សេចក្ដីថា ព្រះបាទសម្ភូតរាជត្រាស់ថា យើងនឹងឲ្យស្រុក

សួយ ១០០ ជារង្វាន់ដល់អ្នក ។ សម័យនោះ កុមារក៏ពោលគាថាទី ៥ ដោយសេចក្តីថា

ខ្ញុំព្រះអង្គ មិនបានឮ ( អំពីសម្នាក់ ) បណ្ឌិតឈ្មោះចិត្តៈទេ តែឥសី ( មួយរូប ) បានប្រាប់នូវសេចក្តីនេះ ដល់ខ្ញុំព្រះអង្គថា អ្នកចូរទៅច្រៀងគាថានឹងព្រះរាជា ក្រែងលោស្តេចសព្វព្រះរាជហឫទ័យនឹងប្រោសប្រទាននូវរបស់ដ៏ប្រសើរ ដល់អ្នកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតមត្ថំ** សេចក្តីថា ឥសីមួយរូបអង្គុយក្នុងព្រះរាជឧទ្យានរបស់ទ្រង់ប្រាប់សេចក្តីនេះដល់ខ្ញុំ ។

ព្រះបាទសម្ភូតរាជស្តាប់ពាក្យនោះហើយ ទ្រង់ព្រះតម្រិះថា តាបសនោះប្រហែលជាចិត្តបណ្ឌិត បងប្រុសរបស់អញ អញនឹងទៅជួបបងប្រុសរបស់អញនោះក្នុងកាលឥឡូវនេះឯង កាលនឹងត្រាស់ឲ្យរាជបុរសរៀបក្បួន ទើបត្រាស់ ២ គាថានេះថា

អ្នកទាំងឡាយ ចូរទឹមនូវរាជរថទាំងឡាយ ដែលធ្វើយ៉ាងល្អ គ្រឿងប្រដាប់ដ៏ពិចិត្ត ចូរចងនូវខ្សែដង្កន់ ពាក់នូវគ្រឿងប្រដាប់កនៃដំរីទាំងឡាយ ។ អ្នកទាំងឡាយចូរវាយស្គរនិងសំភោរ ផ្លុំនូវស័ង្ខផង ចូរទឹមនូវយានទាំងឡាយដ៏លឿនៗផង ថ្ងៃនេះឯង អញនឹងទៅមើលឥសីដែលគង់ក្នុងអាស្រមណា អញនឹងទៅកាន់អាស្រមនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាហាញ្ញន្តុ** សេចក្ដីថា ចូរនាំមកត្រៀមទុក ។ បទថា **អស្សមន្តំ** កាត់បទជា **អស្សមំ តំ** ប្រែថា ទៅកាន់អាស្រមបទនោះ ។

ព្រះបាទសម្ភូតរាជ កាលត្រាស់យ៉ាងនេះហើយ ទ្រង់ឡើងរថព្រះទីន័ងយានទៅដោយរួសរាន់ បញ្ឈប់រាជរថទុកត្រង់ទ្វារព្រះរាជឧទ្យាន ហើយយាងទៅរកតាបសចិត្តបណ្ឌិត នមស្ការហើយ គង់ប្រថាប់ក្នុងទីសមគួរនាចំណែកម្ខាង មានព្រះរាជហឫទ័យសោមនស្ស ត្រាស់គាថាទី ៨ ថា

ឱហ្ន៎ អាត្មាអញមានលាភល្អណាស់តើ គាថាដែលអាត្មាអញច្រៀងពីរោះហើយ ក្នុងកណ្ដាលបរិស័ទ អាត្មាអញបានឃើញនូវឥសីដ៏បរិបូណ៌ដោយសីលនិងវត្ត ហើយក៏ត្រេកអររីករាយដូច្នេះ ។

ព្រះគាថានេះ មានអធិប្បាយថា គាថាដែលខ្ញុំច្រៀងក្នុងកណ្ដាលបរិស័ទក្នុងថ្ងៃធ្វើឧត្តមមង្គលរបស់ខ្ញុំនោះ ជាការច្រៀងល្អហើយហ្ន៎ ជាហេតុឲ្យខ្ញុំបានជួបឥសីដែលដល់ព្រមដោយសីលនិងវត្តក្នុងថ្ងៃនេះ ហើយដល់នូវបីតិសោមនស្ស មិនមានអ្វីប្រៀប រាប់ថាខ្ញុំបានលាភដែលល្អក្រៃលែងហើយ ។

ចាប់តាំងពីជួបចិត្តបណ្ឌិតហើយ ព្រះបាទសម្ភូតរាជទ្រង់សោមនស្សក្រៃលែង កាលនឹងមានព្រះតម្រាស់ដល់រាជកិច្ចមានជាដើមថា អ្នកទាំងឡាយចូរក្រាលបល្ល័ង្ក ដើម្បីព្រះជេដ្ឋារបស់យើង ទើបត្រាស់គាថាទី ៩ ថា

សូមលោកដ៏ចម្រើន ទទួលនូវអាសនៈ ទឹកនិងប្រេងលាបជើងរបស់យើងចុះ បពិត្រម្ចាស់ថ្លៃ ខ្ញុំសួរលោកដ៏ចម្រើនក្នុងវត្ថុ

មានតម្លៃ សូមលោកដ៏ចម្រើនទទួលនូវវត្ថុមានតម្លៃរបស់យើង

ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អគ្ឃេ** សេចក្តីថា ខ្ញុំទទួលលោកម្ចាស់ក្នុងវត្ថុដែលមានតម្លៃដើម្បីទទួលភ្ញៀវ ។ បទថា **កុរុតុ ភោ** សេចក្តីថា សូមលោកម្ចាស់ទទួលវត្ថុដែលមានតម្លៃនេះរបស់យើងខ្ញុំចុះ ។

កាលព្រះបាទសម្ភូតបណ្ឌិតទ្រង់ធ្វើបដិសណ្ឋារៈ ដោយព្រះតម្រាស់ផ្អែមល្ហែមយ៉ាងនេះហើយ កាលទ្រង់បែងចែកទ្រព្យសម្បត្តិពាក់កណ្តាល ទើបត្រាស់គាថាក្រៅអំពីនេះថា

ពួកជនចូរធ្វើនូវលំនៅ ឲ្យជាទីរីករាយដល់លោកផង សូម
លោកឲ្យពួកនារីបម្រើផង សូមលោកធ្វើនូវឱកាសដើម្បីអនុ-
គ្រោះ យើងនឹងធ្វើជាធំនេះទាំងពីរនាក់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧភោ ឥស្សរិយំ** សេចក្តីថា យើងនឹងជាក្សត្រទាំង ២ អង្គ បែករាជសម្បត្តិគ្នាម្នាក់ពាក់កណ្តាល ហើយសោយរាជ្យគ្រប់គ្រងក្នុងឧត្តរបញ្ចាលនគរដែនកបិលរដ្ឋ ។

ចិត្តបណ្ឌិតតាបសស្តាប់ព្រះតម្រាស់របស់ព្រះបាទសម្ភូតរាជហើយ កាលនឹងសម្តែងព្រះធម្មទេសនាថ្វាយ ទើបពោលគាថា ៦ ថា

បពិត្រព្រះរាជា អាត្មាភាពបានឃើញនូវផលនៃទុច្ចរិត និង
ផលដ៏ប្រសើររបស់ធម៌ដែលបានសន្សំដោយប្រពៃ អាត្មាភាព
នឹងសង្រួមនូវខ្លួនតែម្យ៉ាង អាត្មាភាពមិនប្រាថ្នានូវកូន ឬសត្វ

ចិញ្ចឹម ឬទ្រព្យទេ ។

១០ ឆ្នាំ ១០ ដងនេះ ជាជីវិតរបស់ពួកសត្វក្នុងលោកនេះ ជីវិត នោះមិនដល់កំណត់នោះនៅឡើយ ក៏ស្វិតស្រពោនទៅ ដូចជាដើមបបុសដែលគេកាត់ហើយ ។ កាលបើជីវិតនោះ ( ស្រពោនទៅយ៉ាងនេះ ) តើរីករាយដូចម្តេចកើត លេងសើចដូចម្តេចកើត ត្រេកអរដូចម្តេចកើត ស្វែងរកទ្រព្យដូចម្តេចកើត បពិត្រ ព្រះរាជា អាត្មាភាពមានប្រយោជន៍ដោយកូននិងប្រពន្ធ ដូចម្តេចកើត អាត្មាភាព ជាបុគ្គលផុតចាកចំណងហើយ ។

អាត្មាភាពនោះ ដឹងច្បាស់យ៉ាងនេះ មច្ចុរាជមិនមើលងាយ ចំពោះអាត្មាភាពទេ កាលបើអាត្មាភាពត្រូវមច្ចុរាជគ្របសង្កត់ ( យ៉ាងនេះ ) តើត្រេកអរដូចម្តេចកើត ស្វែងរកទ្រព្យដូចម្តេចកើត ។

បពិត្រព្រះអង្គជាធំជាងជន ជាតិរបស់ពួកសត្វ ជាធម្មជាតិដ៏ថោកទាប កំណើតមនុស្សចណ្ឌាលលាមក ជាងពួកសត្វក្នុងពួកសត្វជើងពីរ យើងបាននៅក្នុងគភ៌មនុស្សចណ្ឌាលក្នុងកាលមុន ព្រោះតែអំពើជារបស់ខ្លួនដ៏លាមកក្រៃលែង ។

យើងបានកើតជាមនុស្សចណ្ឌាល ក្នុងដែនអវន្តី ហើយបែរមកកើតជាម្រឹគប្របផ្នែរស្ទឹងនេរញ្ជរា រួចកើតជាសត្វអកខ្មៅ ទៀបផ្នែរស្ទឹងរម្មទា ក្នុងថ្ងៃនោះយើងជាព្រាហ្មណ៍ និង

ក្សត្រិយ៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុច្ចរិតស្ស** សេចក្ដីថា បពិត្រមហារាជ ទ្រង់ឃើញតែផលនៃសុចរិតតែម្យ៉ាង ចំណែកអាត្មាឃើញផលនៃទុច្ចរិតផង សុចរិតផង ព្រោះថា យើងទាំង ២ បានកើតក្នុងកំណើតចណ្ឌាល ក្នុងអត្តភាពទី ៤ អំពីអត្តភាពនេះដោយផលនៃទុច្ចរិត នាំគ្នារក្សាសីលក្នុងអត្តភាពនោះមិនយូរ ដោយផលនៃសីលសុចរិតនោះ ទ្រង់កើតក្នុងត្រកូលក្សត្រ អាត្មាកើតក្នុងត្រកូលព្រាហ្មណ៍ ព្រោះអាត្មាឃើញផលនៃទុច្ចរិត និងសុចរិតដែលធ្លាប់សន្សំល្អហើយ ថាជាវិបាកធំយ៉ាងនេះ ទើបសង្រួមខ្លួនប៉ុណ្ណោះ ដោយការសង្រួមគឺសីល តើនឹងប្រាថ្នាបុត្ត បសុសត្វ ឬធនសារសម្បត្តិ ដូចម្ដេចកើត ។ បទថា **ទសេវិមា វស្សទសា** សេចក្ដីថា បពិត្រមហារាជ ព្រោះជីវិតរបស់សត្វទាំងឡាយក្នុងលោកនេះ មានកំណត់ ១០ ឆ្នាំ ១០ ដង គឺ ១០០ ឆ្នាំប៉ុណ្ណោះ ដោយអំណាចនៃទសកៈទាំងនេះ គឺមន្ទទសកៈ ១០ឆ្នាំជាវ័យទន់ខ្ចី ១ ខិឌ្ឌាទសកៈ ១០ឆ្នាំនៃការលេង ១ វណ្ណទសកៈ ១០ឆ្នាំនៃលម្អ ១ ពលទសកៈ ១០ឆ្នាំនៃការសម្បូរកម្លាំង ១ បញ្ញាទសកៈ ១០ឆ្នាំនៃបញ្ញា ១ ហានិទសកៈ ១០ឆ្នាំនៃការសាបសូន្យ ១ បព្ភារទសកៈ ១០ឆ្នាំនៃការមានកាយកោងទៅខាងមុខ ១ វង្កទសកៈ ១០ឆ្នាំនៃការមានកាយកោងខ្លាំង ១ មោមូហទសកៈ ១០ឆ្នាំនៃការវង្វេង ១ សយនទសកៈ ១០ឆ្នាំនៃការដេកនៅទីដេកខ្ទេង ១ ។ ជីវិតនេះរមែងមិនដល់លំដាប់គ្រប់ទសកៈទាំងអស់ តាមដែលកំណត់ទុកឡើយ ។ ដោយពិត មិនដល់កំណត់នោះ

ឡើយ ក៏ស្ពាំងស្គមរីងរៃទៅ ដូចដើមបបុស ដែលត្រូវកាត់ផ្តាច់គល់មានតែស្ងិតស្រពោនទៅដូច្នោះ ទោះបីសត្វពួកណាមានអាយុបាន ១០០ ឆ្នាំបរិបូណ៌ រូបធម៌និងអរូបធម៌នៃសត្វទាំងនោះ ដែលប្រព្រឹត្តទៅក្នុងមនុទសកៈ ត្រូវកាត់ហើយ រមែងប្រែប្រួលអន្តរធានទៅ ក្នុងវយៈមន្ទទសកៈនោះឯង ដូចដើមបបុសដែលគេកាត់ហើយហាលថ្ងៃដូច្នោះ ។ នឹងកន្ទងកំណាត់នោះ រហូតដល់ខិឌ្ឍាទសកៈក៏មិនបាន វណ្ណទសកៈជាដើម ដែលប្រព្រឹត្តទៅហើយក្នុងខិឌ្ឍា-ទសកៈជាដើមក៏ដូចគ្នា ។ បទថា **តត្ថ** សេចក្តីថា កាលជីវិតនោះ ត្រូវស្ងិតស្រពោនទៅ ដោយអាការដូច្នេះ ការត្រេកអរព្រោះអាស្រ័យបញ្ចកាមគុណមានប្រយោជន៍អ្វី ការលេងត្បាំត្អូង ដោយអំណាចនៃការលេងផ្សំកាយជាដើមមានប្រយោជន៍អ្វី សេចក្តីត្រេកអរដោយអំណាចនៃសោមនស្ស នឹងមានប្រយោជន៍អ្វី ការស្វែងរកធនសារសម្បត្តិមានប្រយោជន៍អ្វី ប្រយោជន៍អ្វីដោយកូនប្រពន្ធរបស់អាត្មា អាត្មារួចផុតហើយចាកចំណង គឺបុត្តនិងភរិយានោះ ។

បទថា **អន្តកោធាធិបន្នស្ស** សេចក្តីថា មច្ចុដែលធ្វើទីបំផុតនៃជីវិត គ្របសង្កត់ហើយ ។ បទថា **ទ្វិបទកនិដ្ឋា** សេចក្តីថា កំណើតជាមនុស្សចណ្ឌាល ចាត់ជាកំណើតថោកទាប ក្នុងរវាងពួកមនុស្សដែលមានជើង ២ ផងគ្នា ។ បទថា **អវសិម្ហា** សេចក្តីថា យើងទាំង ២ នាក់ធ្លាប់នៅរួមគ្នាមក ។ បទថា **ចណ្ឌាលាហុម្ហា** សេចក្តីថា បពិត្រមហារាជ កាលមុន រាប់ថយអំពីនេះទៅ ៤ ជាតិ យើងទាំង ២ កើតជាចណ្ឌាលក្នុងនគរឧជ្ជេនីអវន្តិរដ្ឋ ឃ្លាតចាក

អត្តភាពនោះហើយ យើងទាំងពីរបានកើតជាមិគបោតកៈ នៅត្រង់ឆ្នេរស្ទឹងនេរញ្ជរា មានព្រានព្រៃម្នាក់ដែលឈរផ្អែកគល់ឈើមួយដើម ត្រង់ឆ្នេរស្ទឹងនេរញ្ជរានោះ សម្លាប់យើងទាំង ២ ឲ្យអស់ជីវិតដោយការប្រហារដោយលំពែងតែម្តងប៉ុណ្ណោះ ចុតិចាកអត្តភាពនោះហើយ មកកើតជាអកខ្មៅ នៅរួមគ្នាត្រង់ឆ្នេរទន្លេនម្មទានទី មានព្រាននេសាទម្នាក់ ដាក់អន្ទាក់សម្លាប់យើងឲ្យស្លាប់ដោយការប្រហារត្រឹមតែម្តងប៉ុណ្ណោះ កាលឃ្លាតចាកអត្តភាពនោះ មកក្នុងជាតិនេះ យើងទាំង ២ កើតជាព្រាហ្មណ៍និងក្សត្រ គឺអាត្មាកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរកោសម្ពី ទ្រង់កើតជាក្សត្រក្នុងនគរនេះ ។ កាលព្រះពោធិសត្វប្រកាសជាតិកំណើតដ៏លាមកថោកទាប ដែលកន្លងមកហើយ ដល់ព្រះបាទសម្ភូតរាជនោះ ដោយប្រការដូចពោលមកនេះ សម្តែងថា អាយុសង្ខារក្នុងជាតិនេះ មានកាលតិចតួច ឲ្យព្រះបាទសម្ភូតរាជទ្រង់កើតឧស្សាហៈក្នុងបុណ្យកុសលទាំងឡាយ បានពោលគាថា ៤ ជាប់គ្នាថា

> ជីវិតគឺអាយុ មានប្រមាណតិច ត្រូវជរានាំចូលទៅ ( កាន់សេចក្តីស្លាប់ ) កាលបើសត្វត្រូវជរានាំចូលទៅ ( កាន់សេចក្តីស្លាប់ហើយ ) ទីពឹងពុំមានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយ ដែលមានកម្រៃជាទុក្ខឡើយ ។ ជីវិតគឺអាយុ មានប្រមាណតិច ត្រូវជរានាំទៅ ( កាន់សេចក្តីស្លាប់ ) កាលបើសត្វត្រូវជរានាំទៅ ( កាន់សេចក្តីស្លាប់ហើយ ) ទីពឹងពុំមានទេ បពិត្រព្រះបាទ

បញ្ចាល: សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយ ដែលមានផលជាទុក្ខឡើយ ។ ជីវិតគឺអាយុមានប្រមាណតិច ត្រូវជរានាំទៅ ( កាន់សេចក្ដីស្លាប់ ) កាលបើសត្វត្រូវជរានាំទៅ ( កាន់សេចក្ដីស្លាប់ហើយ ) ទីពឹងពំនាក់ពុំមានទេ បពិត្រព្រះបាទបញ្ចាល: សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយដែលជាប្រធាននៃធូលី គឺកិលេសឡើយ ។ ជីវិតគឺអាយុ មានប្រមាណតិច ត្រូវជរានាំទៅ ( កាន់សេចក្ដីស្លាប់ ) ជរាតែងកម្ចាត់បង់នូវសម្បុរបស់សត្វដែលកំពុងគ្រាំគ្រា បពិត្រព្រះបាទបញ្ចាល: សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើ ដើម្បីកើតក្នុងនរកឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧបនីយតិ** សេចក្ដីថា បពិត្រមហារាជ ជីវិតនេះរមែងចូលទៅជិតសេចក្ដីស្លាប់ ព្រោះអាយុរបស់សត្វទាំងឡាយនោះមានតិច ឈ្មោះថា **អប្បមាយុំ** ព្រោះស្ទុះទៅបានតិចខ្លះ ព្រោះតាំងនៅបានតិចខ្លះ ដូចគ្នានឹងតំណក់ទឹកសន្សើម ដែលជាប់ត្រង់ចុងស្មៅដែលរីងស្ងួតដោយពន្លឺនៃព្រះអាទិត្យដែលរះឡើង ដូច្នោះ ។

បទថា **ន សន្តិ តាណា** សេចក្ដីថា ព្រោះថា កាលនរជនដែលជរានាំចូលទៅជិតសេចក្ដីស្លាប់ហើយ បិយជនទាំងឡាយ មានកូនជាដើម នឹងជាទីជ្រកកោនបាន មិនមាន ។ បទថា **មមេវ វាក្យំ** សេចក្ដីថា នូវពាក្យរបស់

អាត្មានេះ ។ បទថា **មាកាសិ** សេចក្តីថា កុំដល់នូវសេចក្តីប្រមាទ ព្រោះហេតុនៃកាមគុណ មានរូបជាដើម ហើយធ្វើនូវកម្ម មានទុក្ខជាផល ដែលជាគ្រឿងឲ្យចម្រើននូវទុក្ខក្នុងអបាយ មាននរកជាដើម ។ បទថា **ទុក្ខុទ្រាបលានិ** បានដល់ កម្មដែលមានទុក្ខជាផល ។ បទថា **រជស្សិរានិ** បានដល់ កម្មដែលជាហេតុឲ្យក្បាលប្រឡាក់ដោយធូលីគឺកិលេស ។ បទថា **វណ្ណំ** សេចក្តីថា ជរាមែងកម្ចាត់វណ្ណៈនៃសរីរៈរបស់នរជនដែលវិនាសនូវវ័យ គឺមានវ័យទ្រុឌទ្រោម ។ បទថា **និរយូបបត្តិយា** សេចក្តីថា កុំសាងកម្មដើម្បីទៅកើតក្នុងនរកដែលមិនមានសេចក្តីត្រេកអរឡើយ ។

កាលព្រះមហាសត្វពោលយ៉ាងនេះ ព្រះបាទសម្ភូតរាជ ទ្រង់ភ្ញាក់ខ្លួនហើយត្រាស់ ៣ គាថាថា

ពាក្យ ( របស់លោក ) នោះ ពេញជាពិតមែនហើយ បពិត្រឥសី លោកពោលយ៉ាងណា សេចក្តីនុ៎ះយ៉ាងនោះ បពិត្រភិក្ខុ តែកាមទាំងឡាយរបស់ខ្ញុំ មានសភាពមិនតិចទេ កាមទាំងនោះ បុគ្គលប្រហែលខ្ញុំលះបង់បានដោយក្រ ។ ដំរីជាប់នៅក្នុងកណ្តាលភក់មិនអាចរើខ្លួនទៅកាន់ទីគោកដោយខ្លួនឯងយ៉ាងណា ខ្ញុំក៏ជាបុគ្គលជាប់នៅក្នុងភក់គឺកាម មិនអាចបួសតាមផ្លូវ ( ឱវាទ ) របស់លោកជាភិក្ខុយ៉ាងនោះដែរ ។ មាតាបិតា ប្រៀនប្រដៅបុត្ត ( ដោយឧបាយថា ) ធ្វើម្តេចបុត្តនឹងបានសេចក្តីសុខយ៉ាងណា បពិត្រលោកដ៏ចម្រើន សូមលោកប្រៀនប្រដៅខ្ញុំ

តាមសមគួរ ល្មមឲ្យខ្ញុំលះលោកនេះទៅហើយ បានសេចក្ដីសុខជាអង្វែង ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនប្បកា** សេចក្ដីថា កាមកិលេសទាំងឡាយរបស់ខ្ញុំនៅមានជាតិមិនមែនតិច គឺច្រើនមិនមានប្រមាណ ។ បទថា **តេ ទុច្ចជា មាធិសកេន** សេចក្ដីថា បពិត្រភិក្ខុជាច្បង លោកលះកិលេសទាំងឡាយតម្កល់ខ្លួនបានហើយ ឯខ្ញុំនៅលិចក្នុងភក់ គឺកាមកិលេស ព្រោះហេតុនោះបុគ្គលដូចខ្ញុំលះកាមកិលេសទាំងនោះបានលំបាកក្រៃលែង ។

បទថា **នាគោ យថា** សេចក្ដីថា ព្រះបាទសម្ភូតរាជ ទ្រង់សម្ដែងដល់កាលដែលទ្រង់លិចចុះក្នុងភក់ គឺកាមកិលេសដោយពាក្យនេះ ។ បណ្ដាបទទាំងនោះ បទថា **ព្យសន្នោ** សេចក្ដីថា ខ្ញុំលិចចុះហើយ គឺលិចលង់ហើយបានដល់ ជ្រមុជទៅហើយ ។ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **មគ្គំ** បានដល់ ផ្លូវនៃឱវាទានុសាសនីរបស់លោក ។ បទថា **នានុព្ពជាមិ** សេចក្ដីថា ខ្ញុំមិនអាចបព្វជ្ជាបានទេ សូមលោកមេត្តាឲ្យឱវាទដល់ខ្ញុំដែលតាំងនៅក្នុងឃរាវាសវិស័យនេះប៉ុណ្ណោះចុះ ។ បទថា **អនុសាសេ** បានដល់ រមែងប្រៀនប្រដៅ ។

លំដាប់នោះ ព្រះមហាសត្វពោលនឹងព្រះបាទសម្ភូតរាជនោះថា

បពិត្រព្រះអង្គជាធំជាងជន បើព្រះអង្គមិនអាចនឹងលះបង់នូវកាមទាំងឡាយជារបស់មនុស្សនេះបានទេ បពិត្រព្រះរាជា សូមព្រះអង្គតាំងទុកនូវពលី ប្រកបដោយធម៌ ឯការងារដែលមិន

ប្រកបដោយធម៌ ក៏សូមកុំឲ្យមានក្នុងដែនរបស់ព្រះអង្គឡើយ ។ សូមឲ្យទូតទាំងឡាយ ( របស់ព្រះអង្គ ) ជាអ្នកនិមន្តនូវពួកព្រាហ្មណ៍ចេញទៅកាន់ទិសទាំង ៤ ( និមន្តមិនរើសមុខ ) សូមឲ្យព្រះអង្គទំនុកបម្រុង នូវសមណព្រាហ្មណ៍ទាំងនោះដោយបាយទឹក សំពត់និងសេនាសនបច្ច័យ ។ សូមព្រះអង្គ មានព្រះទ័យជ្រះថ្លា ហើយញុំាងសមណព្រាហ្មណ៍ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក លុះព្រះអង្គឲ្យទាន និងប្រើប្រាស់ ( ទ្រព្យ ) តាមសមគួរដល់រាជានុភាពហើយ ឥតមានអ្នកផងតិះដៀល ហើយសូមឲ្យទៅកើតក្នុងឋានសួគ៌ ។ បពិត្រព្រះរាជា បើសេចក្តីស្រវឹងគ្របសង្កត់ព្រះអង្គ ដែលមានពួកនារីចោមរោមបម្រើ សូមព្រះអង្គធ្វើទុកក្នុងព្រះទ័យចំពោះគាថានេះចុះ មួយទៀត សូមព្រះអង្គ ( ឧស្សាហ៍ ) ប្រើគេឲ្យពោលនូវគាថានេះក្នុងកណ្តាលបរិស័ទថា សត្វណា ដេកក្នុងទីវាលទៅដោះមាតា កំពុងដើរ ជាសត្វប្រឡូកប្រឡល់ដោយពួកសុនខ សត្វនោះ គេហៅថាព្រះរាជា ក្នុងថ្ងៃនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ឧស្សហាសេ** សេចក្តីថា បើទ្រង់មិនអាច ។ បទថា **ធម្មំ ពលឹ** សេចក្តីថា សូមកាន់យកធម្មិកពលី កុំខ្វះខាតដោយធម៌ស្មើឡើយ ។ បទថា **អធម្មការោ ច** សេចក្តីថា កុំទម្លាយនូវវិនិច្ឆ័យធម៌ដែលបុរាណកក្សត្រទាំងឡាយតាំងទុក ប្រព្រឹត្តធម្មចរិយា ។

បទថា **ឆិមន្តកា** សេចក្តីថា សូមទ្រង់អារាធនាសមណព្រាហ្មណ៍ដែល តាំងនៅក្នុងធម៌មក ។ បទថា **យថានុភាវំ** សេចក្តីថា តាមកម្លាំងសតិនៃខ្លួន ។ បទថា **ឥមមេវ គាថំ** សេចក្តីថា ព្រះពោធិសត្វពោលសំដៅដល់គាថាដែល នឹងពោលតទៅក្នុងឥឡូវនេះ ។

ក្នុងគាថានោះ មានអធិប្បាយដូច្នេះថា បពិត្រមហារាជ បើការស្រើរឹង គប្បីគ្របសង្កត់ទ្រង់ គឺបើមានះប្រារព្ធកាមគុណ មានរូបជាដើម ឬប្រារព្ធ សេចក្តីសុខដែលកើតអំពីរាជសម្បត្តិ គប្បីកើតឡើងដល់ទ្រង់ដែលចោមរោម ដោយពួកស្នំទាំងឡាយសោត រំពេចនោះ ទ្រង់គប្បីចិន្តនាការថា ក្នុងជាតិមុន យើងកើតក្នុងកំណើតចណ្ឌាល បានដេកលក់ក្នុងទីវាល ព្រោះមិនមានត្រឹម តែខ្ទមដែលប្រក់ដោយស្មៅបិទជិត កាលនោះ ចណ្ឌាលីដែលជាម្តាយរបស់ យើង កាលទៅកាន់ព្រៃដើម្បីរកឧសនិងបន្លែជាដើម ឲ្យយើងដេកកណ្តាល វាល កណ្តាលហ្វូងសុនខ ឲ្យយើងបៅដោះរបស់ខ្លួនហើយទៅ យើងចោម រោមដោយកូនឆ្កែ បៅដោះនៃមេឆ្កែជាមួយកូនឆ្កែទាំងនោះ ទើបចម្រើនវ័យធំ ធាត់ យើងមានជាតិថោកទាបយ៉ាងនេះ តែថ្ងៃនេះ កើតជាបុគ្គលដែលមហា- ជនហៅថាក្សត្រ បពិត្រមហារាជ ព្រោះហេតុនេះឯង កាលទ្រង់ទូន្មានខ្លួន ឯងដោយអត្ថនេះ គប្បីត្រាស់គាថាថា ក្នុងជាតិមុន យើងជាសត្វ ដេកក្នុង អព្ភោកាស គឺទីវាល កាលចណ្ឌាលីជាមាតាទៅព្រៃ ត្រាច់ទៅខាងនោះ ខាង នេះខ្លះ ជាជនដែលមេឆ្កែអាណិតឲ្យបៅដោះ ជាមួយកូនឆ្កែទាំងឡាយ ទើប ចម្រើនធំធាត់មក តែថ្ងៃនេះ យើងដែលជនដទៃហៅថាក្សត្រ ដូច្នេះ ។

ព្រះមហាសត្វកាលឲ្យឱវាទព្រះបាទសម្ភូតរាជយ៉ាងនេះហើយ ទើបពោលថា អាត្មាឲ្យឱវាទដល់ទ្រង់ហើយ ឥឡូវនេះ សូមទ្រង់បួសចុះ កុំសោយវិបាកនៃកម្មរបស់ខ្លួនដោយខ្លួនឡើយ ហើយហោះឡើងទៅលើអាកាស ជជុះធូលីដែលជាប់នឹងជើងឲ្យធ្លាក់លើសិរសារបស់ព្រះរាជា ហើយហោះទៅកាន់ហិមវន្តប្បទេសមួយរំពេច ។ ឯព្រះរាជាទតមើលតាបសនោះទៅហើយ កើតនូវការសង្វេគ លើករាជសម្បត្តិឲ្យដល់ព្រះរាជឱរសច្បង ត្រាស់ឲ្យពលនិកាយត្រឡប់ទៅហើយ បែរមុខទៅកាន់ហិមវន្តប្បទេសមួយអង្គឯង ព្រះមហាសត្វ ជ្រាបការយាងមករបស់ព្រះរាជាហើយ ចោមរោមដោយពួកឥសីជាបរិវារ មកទទួលព្រះរាជាឲ្យទ្រង់ព្រះផ្នួស ហើយបង្រៀនកសិណបរិកម្ម ។ សម្ភូតតាបសបំពេញឈាននិងអភិញ្ញាឲ្យកើតហើយ ។ តាបសទាំង ២ នោះជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ដោយប្រការដូច្នេះ ។

ព្រះសាស្តា កាលនាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរាណកបណ្ឌិតអន្ទោលទៅ ៣-៤ ភព ក៏គង់មានការស្និទ្ធស្នាលមាំទាំយ៉ាងនេះដោយពិត ហើយទ្រង់ប្រជុំជាតកថា សម្ភូតបណ្ឌិតតាបសក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯចិត្តបណ្ឌិតតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ចិត្តសម្ភូតជាតក ចប់**

# សិវិរាជជាតក

[ ១៩៥ ] ( ព្រះឥន្ទជំលែងខ្លួនជាមនុស្សចាស់ពោលថា ) ខ្ញុំព្រះអង្គជាបុគ្គលចាស់ជរា មើលមិនឃើញឆ្ងាយ មកដើម្បីសុំនូវព្រះនេត្រ ខ្ញុំព្រះអង្គជាអ្នកមានភ្នែកម្ខាង កាលបើខ្ញុំសុំហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រដល់ខ្ញុំព្រះអង្គ ។

[ ១៩៦ ] ( ព្រះបាទសិវិរាជពោធិសត្វត្រាស់សួរថា ) នែស្មូម អ្នកណាប្រាប់អ្នក ទើបអ្នកមកក្នុងទីនេះ បម្រុងសុំនូវភ្នែកទាំងឡាយ ជនទាំងឡាយពោលនូវភ្នែកណា ថាជារបស់ដែលបុរសលះបានដោយក្រ អ្នកសុំនូវភ្នែកជាអវយវៈដ៏ខ្ពង់ខ្ពស់នោះ ដែលគេលះបានដោយក្រក្រៃលែង ។

[ ១៩៧ ] ( ព្រះឥន្ទ... ) ពួកទេវតាបានពោលនូវទេវតាវិសេសណាថា សុជម្បតិក្នុងទេវលោក ពួកជនបានពោលនូវទេវតាវិសេសនោះថាមឃវៈក្នុងមនុស្សលោក ខ្លួនខ្ញុំជាស្មូមដែលទេវតាវិសេសនោះប្រាប់ ទើបមកក្នុងទីនេះ បម្រុងសុំព្រះនេត្រទាំងឡាយ ។ ខ្លួនខ្ញុំជាស្មូម ការសូមជាកិច្ចឧត្តមរបស់ខ្ញុំកាលបើខ្ញុំសូមព្រះនេត្រទាំងឡាយ សូមព្រះអង្គប្រទាន ពួកជនបានពោលនូវភ្នែកណាថាជារបស់ដែលបុរសលះបានដោយក្រ សូមព្រះអង្គប្រទាននូវព្រះនេត្រដ៏ប្រសើរនោះ ដល់ខ្ញុំព្រះអង្គ ។

( ព្រះបាទសិវិរាជ... ) ខ្លួនអ្នកមកដោយប្រយោជន៍ណា ប្រាថ្នានូវប្រយោជន៍ណា សេចក្តីត្រិះរិះនូវប្រយោជន៍នោះ សូមឲ្យសម្រេចដល់អ្នកចុះ ម្នាលព្រាហ្មណ៍ អ្នកចូរបាននូវភ្នែកទាំងឡាយ ។ កាលបើអ្នកសូមភ្នែកមួយ យើងនឹងឲ្យភ្នែកទាំងពីរ កាលជនកំពុងមើល សូមអ្នកនោះ ជាបុគ្គល

មានក្អែកទៅចុះ អ្នកប្រាថ្នានូវរបស់ណា របស់នោះចូរសម្រេចដល់អ្នក ។

[ ១៩៨ ] ( ពួកជនពោលថា ) បពិត្រព្រះសម្មតិទេព សូមទ្រង់កុំប្រទាននូវព្រះនេត្រ សូមទ្រង់កុំលះបង់នូវពួកយើងទាំងអស់គ្នាឡើយបពិត្រមហារាជ សូមទ្រង់ប្រទាននូវព្រះរាជទ្រព្យ គឺកែវមុក្តា និងកែវពិទូរ្យដ៏ច្រើនវិញចុះ ។ បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រទាននូវរថដែលទឹមដោយសេះអាជានីយដែលប្រដាប់ហើយ បពិត្រមហារាជ សូមព្រះអង្គប្រទាននូវដំរីទាំងឡាយ ប្រកបដោយគ្រឿងប្រដាប់ក្បាល គឺបណ្តាញមាសវិញចុះ ។ វទាំងពួង ព្រមទាំងខ្សែ ព្រមទាំងរាជរថ ចោមរោមព្រះអង្គដោយជុំវិញគ្រប់កាលដោយប្រការណា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គប្រទានដោយប្រការនោះចុះ ។

[ ១៩៩ ] ( ព្រះរាជា... ) បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះឈ្មោះថា យកអន្ទាក់ដែលធ្លាក់លើផែនដីមកពាក់ពួដ៏ក ។ បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះឈ្មោះថា ជាបុគ្គលលាមកក្រៃលែង ជាងបុគ្គលលាមក ហើយដល់នូវឋាននរកជាទីសម្រេចរបស់ព្រះយមរាជ ។ ស្មូមសូមនូវរបស់ណា បុគ្គលគួរតែឲ្យនូវរបស់នោះ មិនសូមនូវរបស់ណា មិនត្រូវឲ្យរបស់នោះទេ ព្រាហ្មណ៍សូមនូវរបស់ណានឹងអាត្មាអញ អាត្មាអញនោះ នឹងឲ្យនូវរបស់នោះឯង ។

[ ២០០ ] ( ពួករាជអាមាត្យ... ) បពិត្រព្រះអង្គជាធំជាងជន ព្រះ

អង្គប្រាថ្នានូវរបស់អ្វី គឺអាយុ ឬពណ៌សម្បុរ ឬសេចក្ដីសុខ ឬក៏កម្លាំង ទើបព្រះអង្គប្រទាន ( ព្រះនេត្រ ) ព្រះរាជាទ្រង់ប្រសើរជាងជនអ្នកនៅក្នុងដែនសីវិទាំងឡាយ មិនសមបើប្រទានព្រះនេត្រទាំងឡាយព្រោះហេតុនៃប្រយោជន៍ក្នុងបរលោក ។

[ ២០១ ] ( ព្រះរាជា... ) អញមិនមែនឲ្យចក្ខុនេះ ព្រោះយសទេ មិនមែនប្រាថ្នាកូន មិនមែនប្រាថ្នាទ្រព្យ មិនមែនប្រាថ្នានូវដែនទេ ធម៌គឺប្រវេណីនៃការឲ្យទានជាផ្លូវបុរាណដែលពួកសប្បុរសធ្លាប់ប្រព្រឹត្តមកហើយ ចិត្តរបស់អញតែងរីករាយក្នុងការឲ្យ ដោយប្រការដូច្នេះឯង ។

[ ២០២ ] ( អភិសម្ពុទ្ធគាថា ) ភ្នែកទាំងពីរ មិនជាទីស្អប់របស់តថាគតទេ តថាគតមិនមែនស្អប់ខ្លួនរបស់តថាគតទេ សព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យនូវភ្នែក ។

[ ២០៣ ] ( ព្រះរាជា... ) ម្នាលពេទ្យឈ្មោះសីវិកៈ ខ្លួនអ្នកជាសម្លាញ់ជាមិត្តរបស់យើង អ្នកមានវិជ្ជាពេទ្យសិក្សាល្អហើយ ចូរធ្វើតាមសំដីរបស់យើងដោយប្រពៃចុះ កាលយើងកំពុងប្រាថ្នា អ្នកចូរឆ្កៀលនូវភ្នែកទាំងឡាយ ( របស់យើង ) ហើយដាក់លើដៃរបស់ស្មូមចុះ ។

[ ២០៤ ] ( អភិសម្ពុទ្ធគាថា ) ពេទ្យឈ្មោះសីវិកៈ លុះព្រះរាជាទ្រង់ព្រះនាមសីវិតឿន ( យ៉ាងនេះហើយ ) ក៏ធ្វើតាមព្រះបន្ទូល ហើយឆ្កៀលនូវព្រះនេត្រទាំងពីររបស់ព្រះរាជា បង្អោនទៅឲ្យព្រាហ្មណ៍ ចំណែកព្រាហ្មណ៍ក៏ទៅជាបុគ្គលមានភ្នែក ព្រះរាជាទៅជាបុគ្គលខ្វាក់ ។

[ ២០៥ ] ( អភិសម្ពុទ្ធគាថា ) តអំពីនោះមក ប្រមាណពីរបីថ្ងៃ លុះដល់ព្រះនេត្រទាំងពីរដុះឡើង ព្រះរាជា ជាអ្នកញ៉ាំងដែនឲ្យចម្រើនដល់ពួកជនអ្នកសីវិ ទ្រង់ត្រាស់បង្គាប់នាយសារថីថា នែនាយសារថី អ្នកចូរទឹមយាន លុះទឹមហើយចូរប្រាប់យើង យើងនឹងទៅកាន់ទីឧទ្យាន ដែលមានស្រះបោក្ខរណីនិងព្រៃព្រឹក្សា ។ ព្រះបាទសីវិនោះ ទ្រង់បានចូលទៅគង់លើពែនព្រះក្អួនប្របច្នេះស្រះបោក្ខរណី ទេវរាជឈ្មោះសក្កៈជាសុជម្បតិ ក៏មកដល់ចំពោះព្រះអង្គ ។

[ ២០៦ ] ( ព្រះឥន្ទ្រ... ) ខ្ញុំជាទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតា មកក្នុងសំណាក់ព្រះអង្គ បពិត្រស្តេចឥសី ព្រះអង្គប្រាថ្នាក្នុងព្រះទ័យចំពោះពរណាមួយ សូមត្រេកអរនឹងពរនោះចុះ ។

[ ២០៧ ] ( ព្រះបាទសីវិ... ) បពិត្រសក្កៈ ទ្រព្យនិងពលរបស់ខ្ញុំមានច្រើនហើយ ទាំងឃ្លាំងរបស់ខ្ញុំ មិនមែនមានតិចទេ កាលបើខ្ញុំនៅតែខ្វាក់ ក្នុងកាលឥឡូវនេះ ខ្ញុំពេញចិត្តចំពោះសេចក្តីស្លាប់តែម្យ៉ាង ។

[ ២០៨ ] ( ព្រះឥន្ទ្រ... ) បពិត្រក្សត្រិយ៍ ជាធំជាងជនមានជើងពីរ សូមព្រះអង្គពោលនូវពាក្យទាំងឡាយដែលជាសច្ចៈចុះ កាលបើព្រះអង្គពោលនូវពាក្យសច្ចៈ ព្រះនេត្រនឹងមានឡើងវិញ ។

[ ២០៩ ] ( ព្រះបាទសីវិ... ) ពួកស្មូមណាមានគោត្តផ្សេងៗគ្នា មកដើម្បីសូមចំពោះយើង បណ្តាស្មូមទាំងនោះ ស្មូមណាសូមយើង ស្មូមនោះជាទីស្រឡាញ់នៃចិត្តរបស់យើង សូមឲ្យភ្នែកកើតមានដល់យើង ដោយការ

ពោលនូវពាក្យសច្ចៈនេះ ។

[ ២១០ ] ព្រាហ្មណ៍នោះមកដើម្បីសូមនូវភ្នែកណានឹងយើងថា សូមព្រះអង្គប្រទាននូវភ្នែក យើងក៏បានឲ្យនូវភ្នែកទាំងឡាយនោះ ដល់ព្រាហ្មណ៍ដែលសូមនោះហើយ ។ បីតិនិងសោមនស្សដ៏ច្រើនក៏កើតឡើងដល់យើងដោយក្រៃលែង សូមឲ្យភ្នែកជាគម្រប់ពីរកើតមានដល់យើងដោយពោលពាក្យសច្ចៈនេះ ។

[ ២១១ ] ( ព្រះឥន្ទ... ) បពិត្រក្សត្រិយ៍ អ្នកញុំាងដែនរបស់អ្នកដែនសីវិឲ្យចម្រើន គាថាដែលព្រះអង្គពោលតាមធម៌ សូមឲ្យព្រះនេត្រទាំងពីររបស់ព្រះអង្គនេះ ប្រាកដដូចជាទិព្វ ។ ព្រះនេត្រទាំងពីររបស់ព្រះអង្គនោះ សូមឲ្យបាននូវការឃើញធ្លុះធ្លាយទៅ ខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ។

[ ២១២ ] ( ព្រះបាទសីវី... ) អ្នកណាមួយក្នុងលោកនេះ ដែលគេសូមហើយមិនឲ្យនូវទ្រព្យដ៏ពេញចិត្តឬទ្រព្យដ៏ថ្លៃថ្លា ជាទីស្រឡាញ់ ដ៏ក្រៃលែងរបស់ខ្លួន នៃអ្នកដែនសីវីទាំងអស់ដែលមកប្រជុំគ្នា ចូរអ្នកទាំងឡាយមើលនូវភ្នែកទាំងពីររបស់អញ ដែលជាទិព្វក្នុងថ្ងៃនេះចុះ ។ ចក្ខុទាំងពីររបស់យើងរមែងបាននូវការឃើញធ្លុះធ្លាយ ទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ។ ( វត្ថុណាមួយ ) ក្នុងជីវិតរបស់សត្វទាំងឡាយនេះ រមែងមិនប្រសើរជាងចាគៈទេ ( ខ្លួនយើង ) បានឲ្យនូវចក្ខុជារបស់មនុស្ស ហើយបាននូវចក្ខុទិព្វដែលមិនមែនជារបស់មនុស្ស ។ ម្នាលអ្នក

ដែនសីវិទាំងឡាយ អ្នកទាំងឡាយ បានឃើញហេតុនេះហើយ ចូរឲ្យទាន ចូរបរិភោគ លុះឲ្យហើយ បរិភោគហើយ តាមសមគួរដល់អានុភាព សូមឲ្យជាអ្នកមិនមានអ្នកណាតិះដៀលបាន ហើយចូរទៅកាន់ឋានសួគ៌ចុះ ។

## ចប់ សីវិរាជជាតកទី ៣

## អដ្ឋកថា

## សិវិរាជជាតក

[ ១៩៥-២១២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ អសទិសទាន ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទូរេ អបស្សំ ថេរោវ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ននិទាននោះ បានពោលទុកពិស្តារហើយ ក្នុងសិវិរាជជាតក ក្នុងអដ្ឋកនិបាតនោះឯង ។

ក្នុងកាលនោះ ព្រះបាទបសេនទិកោសលទ្រង់ថ្វាយបរិក្ខារគ្រប់យ៉ាងក្នុងថ្ងៃទី ៧ ហើយទូលសូមអនុមោទនា ។ ព្រះសាស្តាមិនត្រាស់អ្វីឡើយ ទ្រង់ចៀសចេញទៅហើយ ។ ព្រះរាជាសោយព្រះក្រយាហារព្រឹកហើយ យាងទៅកាន់វិហារ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបទ្រង់មិនធ្វើអនុមោទនា ព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រោះបរិស័ទមិនបរិសុទ្ធ ហើយទ្រង់សម្តែងព្រះធម្មទេសនាដោយព្រះគាថាថា **ន វេ កទរិយា ទេវលោកំ វជន្តិ** ជាដើម ប្រែថា បុគ្គលកំណាញ់ទាំងឡាយ រមែងទៅកាន់ទេវលោកមិនបានឡើយ ដូច្នេះ ។ ព្រះរាជាទ្រង់ជ្រះថ្លា ទ្រង់បូជាព្រះតថាគតដោយសំពត់ឧត្តរាសង្គសិវេយ្យកពស្ត្រ មានតម្លៃមួយសែន ហើយយាងត្រឡប់ទៅព្រះនគរ ។ ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះបាទកោសលរាជទ្រង់ថ្វាយអសទិសទាន ហើយមិនឆ្អែតដោយការថ្វាយទានបែបនោះ ។ កាលព្រះទសពលទ្រង់

សម្តែងធម៌ហើយ បានថ្វាយសំពត់សិវេយ្យកពស្ត្រដែលមានតម្លៃមួយសែនទៀត អាវុសោទាំងឡាយ អស់កាលដែលទ្រង់ថ្វាយទាន ក៏នៅមិនឆ្អែតព្រះហឫទ័យឡើយ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ពាហិរភណ្ឌ បុគ្គលឲ្យបានដោយងាយក៏មិនមែន បុរាណកបណ្ឌិតទាំងឡាយ ធ្វើជម្ពូទ្វីបទាំងមូលឲ្យមានទន្ទ្រលើកឡើងហើយ ឲ្យទាន បរិច្ចាគទ្រព្យមួយថ្ងៃ ៦ សែនរាល់ៗថ្ងៃ គង់មិនឆ្អែតដោយពាហិរកទានឡើយ បុគ្គលឲ្យរបស់ជាទីស្រឡាញ់ រមែងបានរបស់ជាទីស្រឡាញ់ដូច្នោះ បណ្ឌិតទាំងឡាយបានខ្វេះភ្នែកទាំងគូ ឲ្យទានដល់យាចកដែលមកដល់ចំពោះមុខ ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទសិវិមហារាជ សោយរាជសម្បត្តិនៅក្នុងអរិដ្ឋបុរនគរដែនសិវិរដ្ឋ ព្រះមហាសត្វកើតជាព្រះឱរសរបស់ព្រះរាជាអង្គនោះ ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមកុមារនោះថា សិវិរាជកុមារ ។ រាជកុមារចម្រើនវ័យហើយ ទៅកាន់នគរតក្កសិលា សិក្សាសិប្បសាស្ត្រចប់ហើយ បានត្រឡប់មកសម្តែងសិល្បសាស្ត្រថ្វាយព្រះជនកទត រហូតបានទទួលយសជាមហាឧបរាជ ។ ក្នុងកាលតមក កាលព្រះបិតាសោយទិវង្គតហើយ ក៏បានជាព្រះរាជា លះនូវការលុះអំណាចអគតិ មិនញុំាងទសពិធរាជធម៌ឲ្យកម្រើកសោយរាជ្យដោយធម៌ បានសាងសាលាទាន ៦ កន្លែង គឺត្រង់ទ្វារនគរ ៤

កណ្ដាលព្រះនគរ ១ ត្រង់ទ្វារព្រះរាជនិវេសន៍ ១ ហើយញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដោយទ្រង់បរិច្ចាគទ្រព្យមួយថ្ងៃ ៦ សែន រាល់ៗថ្ងៃ ក្នុងថ្ងៃអដ្ឋមី ចាតុទ្ទសី និងបណ្ណរសី គឺថ្ងៃ ៨ ថ្ងៃ ១៤ និង ១៥ ព្រះរាជាទ្រង់ចូលកាន់រោងទាន ពិនិត្យមើលការឲ្យទានជារាជករណីយកិច្ចប្រចាំ ។

ថ្ងៃមួយជាថ្ងៃបុណ្ណមីតិថី ១៥ កើត ពេលព្រឹកព្រះបាទសិវិរាជទ្រង់ប្រថាប់លើរាជបល្ល័ង្ក ខាងក្រោមសមុស្សិតស្វេតច្ឆត្រ ( ឆត្រសដែលបានទទួលអភិសេក ) ទ្រង់រំឭកដល់ទានដែលទ្រង់បរិច្ចាគ មិនបានទតឃើញពាហិរវត្ថុឯណាមួយដែលឈ្មោះថាទ្រង់មិនធ្លាប់បរិច្ចាគ ទើបទ្រង់ព្រះតម្រិះថា ពាហិរវត្ថុដែលឈ្មោះថា អញមិនធ្លាប់បរិច្ចាគមិនមានឡើយ ពាហិរកទានមិនញុំាងអញឲ្យត្រេកអរឡើយ អញបំណងឲ្យអជ្ឈត្តិកទាន ឱហ្ន៎ ពេលដែលអញទៅកាន់រោងទានថ្ងៃនេះ យាចកណាមួយកុំបីសូមពាហិរវត្ថុឡើយ គប្បីហាមាត់សូមតែអជ្ឈត្តិកទានចុះ បើបុគ្គលណាមួយ ហាមាត់សូមហទយៈអញសោតអញនឹងយកលំពែងពុះឧរុប្បទេស នាំហទយៈ ដែលមានតំណក់ឈាមកំពុងហូរចេញមកឲ្យ ដូចដកបទុមជាតិទាំងឫសអំពីទឹកថ្លា ដូច្នោះ បើនរណាហាមាត់សូម សាច់ក្នុងសរីរកាយរបស់អញ អញនឹងចៀរសាច់ក្នុងសរីរៈឲ្យ ដូចគេធូតចន្ទន៍ក្រហមដោយសស្ត្រា សម្រាប់ធូតដូច្នោះ បើនរណាហាមាត់សូមឈាម អញនឹងស្ទុះចូលទៅក្នុងគ្រឿងយន្ត ឲ្យមនុស្សនាំភាជន៍ចូលទៅត្រងរហូតពេញ នឹងឲ្យឈាម បើអ្នកឯណាហើយពោលនឹងអាត្មាអញថា ការងារក្នុងផ្ទះរបស់ខ្ញុំ មិនរៀបរយ សូមលោកជាទាសៈធ្វើការក្នុងផ្ទះរបស់ខ្ញុំ ដូច្នេះ

អញនឹងលះភេទជាក្សត្រ ធ្វើខ្លួនឲ្យធ្លាក់ក្នុងតំណែង ហើយប្រកាសខ្លួនធ្វើការងាររបស់ទាសៈ បើនរណាហាមាត់សុំភ្នែករបស់អញ អញនឹងខ្វេះភ្នែកទាំងគូឲ្យ ដូចជាខ្វេះកំពីងត្នោត ដូច្នោះហើយ ទ្រង់ត្រិះរិះ ( ក្នុងចរិយាបិដក ) ថា

ទានណាមួយជារបស់មនុស្ស ទាននោះ គឺអញមិនដែលឲ្យ
ហើយ មិនមានឡើយ បើមានយាចកណាមកសូមភ្នែកអញ
អញនឹងមិនញាប់ញ័រ ត្រូវតែឲ្យ ( ដល់យាចកនោះ ) ដូច្នេះ ។

ដូច្នេះហើយ ទ្រង់ស្រង់ដោយទឹកក្រអូប ១៦ ក្អម ប្រដាប់តាក់តែងអង្គដោយគ្រឿងសព្វាលង្ការ សោយព្រះក្រយាហារដែលមានរសប្រសើរផ្សេងៗ រួចប្រថាប់លើកមង្គលហត្ថីដែលប្រដាប់តាក់តែងហើយ បានទៅកាន់រោងទាន ។ សក្កទេវរាជទ្រង់ដឹងអធ្យាស្រ័យរបស់ព្រះរាជា ទើបទ្រង់ព្រះតម្រិះថា ថ្ងៃនេះព្រះបាទសិវិរាជ ទ្រង់ព្រះតម្រិះថា នឹងខ្វេះភ្នែកព្រះរាជទានដល់យាចកដែលមកដល់ ទ្រង់ព្រះរាជទានមែនឬមិនមែនហ្ន៎ កាលនឹងសាកល្បងព្រះបាទសិវិរាជ ទ្រង់កាឡាខ្លួនជាព្រាហ្មណ៍ចាស់ជរាភ្នែកខ្វាក់ ក្នុងកាលដែលព្រះរាជាយាងទៅកាន់រោងទាន បានឈរត្រង់ទួលមួយ លាដៃចេញថ្វាយនូវជ័យមង្គល ។ ព្រះរាជាទ្រង់ឲ្យព្រះទីន័ងបែរមុខទៅកាន់ព្រាហ្មណ៍ ហើយត្រាស់សួរថា នែព្រាហ្មណ៍ អ្នកនិយាយអ្វី លំដាប់នោះ សក្កទេវរាជត្រាស់នឹងព្រះរាជាថា បពិត្រមហារាជ លោកសន្និវាសទាំងមូល អឺងកងដោយសំឡេងសាធុការអាស្រ័យព្រះអធ្យាស្រ័យ ដែលបង្អោនទៅក្នុងទានរបស់ទ្រង់ ខ្ញុំខ្វាយជានិច្ចឯទូលព្រះបង្គំជាមនុស្សភ្នែកខ្វាក់ ទ្រង់មានព្រះនេត្រទាំង ២ ដូច្នេះហើយ

កាលនឹងទូលសូមព្រះនេត្រ ទើបត្រាស់គាថាទី ១ ថា

ខ្ញុំព្រះអង្គជាបុគ្គលចាស់ជរា មើលមិនឃើញឆ្ងាយ មកដើម្បី
សុំនូវព្រះនេត្រ ខ្ញុំព្រះអង្គជាអ្នកមានភ្នែកម្ខាង កាលបើខ្ញុំសុំ
ហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រដល់ខ្ញុំព្រះអង្គ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទូរេ** សេចក្ដីថា នៅឆ្ងាយអំពីទីនេះ ។ បទថា **ជរោ** សេចក្ដីថា ដូចបុគ្គលចាស់ជរា ចូលដល់នូវការគ្រាំគ្រាព្រោះជរា ។ បទថា **ឯកនេត្តា** សេចក្ដីថា សូមទ្រង់ព្រះរាជទានព្រះនេត្រម្ខាងដល់ទូលព្រះបង្គំផងចុះ ទូលព្រះបង្គំមានភ្នែកម្ខាងនឹងមានទាំង ២ បានដោយវិធីនេះ ។

ព្រះមហាសត្វទ្រង់ស្ដាប់ពាក្យនោះហើយ ទ្រង់ព្រះតម្រិះថា អញអង្គុយគិតក្នុងប្រាសាទអម្បាញ់មិញនេះឯង ជាលាភធំរបស់អញ មនោរថរបស់អញដល់ទីបំផុតក្នុងថ្ងៃនេះឯង អញនឹងបរិច្ចាគទានដែលមិនធ្លាប់បរិច្ចាគ ហើយទ្រង់មានព្រះហឫទ័យសោមនស្ស ត្រាស់គាថាទី ២ ថា

នែស្មូមអ្នកណាប្រាប់អ្នក ទើបអ្នកមកក្នុងទីនេះ បម្រុងសុំនូវ
ភ្នែកទាំងឡាយ ជនទាំងឡាយពោលនូវភ្នែកណាថាជារបស់
ដែលបុរសលះបានដោយក្រ អ្នកសុំនូវភ្នែកជាអវយវៈដ៏ខ្ពង់-
ខ្ពស់នោះ ដែលគេលះបានដោយក្រក្រៃលែង ដូច្នេះ ។

ក្នុងព្រះគាថានោះ ព្រះបាទសីវិរាជទ្រង់ហៅសក្កទេវរាជថា វនិព្វក គឺស្មូម ។ បទថា **ចក្ខុបថានិ** នេះ ជាឈ្មោះរបស់ចក្ខុទាំងសងខាង ។ បទថា **យមាហុ** សេចក្ដីថា បណ្ឌិតទាំងឡាយពោលនូវភ្នែកណា ដែលបុរស

លះបានដោយលំបាក ។ ខាងមុខអំពីនេះទៅ គប្បីជ្រាបសម្ពន្ធគាថាផងយ។ ដោយន័យដូចពោលមកហើយក្នុងបាលីដូចតទៅនេះ ព្រាហ្មណ៍ទូលតបថា

ពួកទេវតា បានពោលនូវទេវតាវិសេសណា ថាសុជម្បតិក្នុងទេវលោក ពួកជនបានពោលនូវទេវតាវិសេសនោះ ថាមឃវៈក្នុងមនុស្សលោក ខ្ញុំជាស្មូមដែលទេវតាវិសេសនោះប្រាប់ទើបមកក្នុងទីនេះ បម្រុងសុំព្រះនេត្រទាំងឡាយ ។ ខ្ញុំជាស្មូម ការសូមជាកិច្ចឧត្តមរបស់ខ្ញុំ កាលបើខ្ញុំសូមព្រះនេត្រទាំងឡាយ សូមព្រះអង្គប្រទាន ពួកជនបានពោលនូវភ្នែកណា ថាជារបស់ដែលបុរសលះបានដោយក្រ សូមព្រះអង្គប្រទាននូវព្រះនេត្រដ៏ប្រសើរនោះ ដល់ខ្ញុំព្រះអង្គ ។

ព្រះបាទសីវិរាជត្រាស់ថា

ខ្ញុំអ្នក មកដោយប្រយោជន៍ណា ប្រាថ្នានូវប្រយោជន៍ណា សេចក្តីត្រិះរិះនូវប្រយោជន៍នោះ សូមឲ្យសម្រេច ដល់អ្នកចុះ ម្នាលព្រាហ្មណ៍ អ្នកចូរបាន នូវភ្នែកទាំងឡាយ ។ កាលបើអ្នកសូមភ្នែកមួយ យើងនឹងឲ្យភ្នែកទាំងពីរ កាលជនកំពុងមើល សូមអ្នកនោះជាបុគ្គលមានភ្នែកទៅចុះ អ្នកប្រាថ្នានូវរបស់ណា របស់នោះ ចូរសម្រេចដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វណិព្វកោ** បានដល់ យាចក ។ បទថា **យាចកោ** សេចក្តីថា ដល់ខ្ញុំអ្នកមកសូម ។ បទថា **វណឹ** ប្រែថា ការសូម ។

បទថា **តេ តេ** សេចក្ដីថា បំណងគឺការត្រិះរិះ ដើម្បីត្រូវការវត្ថុនោះ របស់អ្នកទាំងនោះ ចូរសម្រេច ។

បទថា **សចក្ខុមា** សេចក្ដីថា ចូរអ្នកជាបុគ្គលមានចក្ខុដោយចក្ខុរបស់ខ្ញុំទៅចុះ ។ បទថា **យទិច្ឆសេ ត្វំ តទតេ សមិជ្ឈតុ** សេចក្ដីថា អ្នកគន់ប្រាថ្នាវត្ថុណាអំពីសម្នាក់របស់យើង វត្ថុនោះចូរសម្រេចដល់អ្នកចុះ ។

ព្រះរាជាត្រាស់ត្រឹមប៉ុណ្ណោះ ទ្រង់ព្រះតម្រិះថា ការដែលអញខ្វេះភ្នែកឲ្យដល់ព្រាហ្មណ៍ក្នុងទីនេះ មិនសមគួរ ទើបនាំព្រាហ្មណ៍ចូលទៅខាងក្នុងព្រះរាជដ្ឋាន ហើយប្រថាប់លើអាសនៈ ហៅពេទ្យឈ្មោះសីវិកៈមក ត្រាស់ថា ចូរអ្នកជម្រះភ្នែករបស់យើងឲ្យស្អាត ក៏មានសំឡេងអឺងកងកោលាហល តែមួយដូចគ្នាទាំងព្រះនគរថា បានឮថា ព្រះរាជានៃពួកយើងមានព្រះរាជបំណងនឹងខ្វេះព្រះនេត្រទាំង ២ ព្រះរាជទានដល់ព្រាហ្មណ៍ ។ លំដាប់នោះ ខ្ញុំរាជការ មានសេនាបតី រាជវល្លភៈ អ្នកនគរ និងស្រីស្នំទាំងឡាយជាដើម មកប្រជុំព្រមគ្នា កាលនឹងក្រាបទូលជំទាស់ព្រះរាជា បានពោលគាថា ៣ ថា

> បពិត្រព្រះសម្មតិទេព សូមទ្រង់កុំប្រទានទូវព្រះនេត្រ សូមទ្រង់កុំលះបង់នូវពួកយើងទាំងអស់គ្នាឡើយ បពិត្រមហារាជ សូមទ្រង់ប្រទានទូវព្រះរាជទ្រព្យ គឺកែវមុក្តា និងកែវពិទូរ្យដ៏ច្រើនវិញចុះ ។ បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រទានទូវរថដែលទឹមដោយសេះអាជានីយ ដែលប្រដាប់ហើយ បពិត្រមហារាជ សូមព្រះអង្គប្រទានទូវដំរីទាំងឡាយ ប្រកបដោយ

គ្រឿងប្រដាប់ក្បាល គឺបណ្តាញមាសវិញចុះ ។ រីទាំងពួង ព្រមទាំងខ្សែ ព្រមទាំងរាជរថ ចោមរោមព្រះអង្គដោយជុំវិញ គ្រប់កាល ដោយប្រការៈណា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គប្រទានដោយប្រការៈនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរក្កាិ** បានដល់ លះបង់ អធិប្បាយថា អ្នកសីវិទាំងឡាយនាំគ្នាក្រាបទូលដោយបំណាំងតែមួយថា កាលទ្រង់ព្រះរាជទានកែវភ្នែកហើយ ទ្រង់នឹងគ្រប់គ្រងរាជសម្បត្តិមិនបាន អ្នកដទៃនឹងជាព្រះរាជាជំនួស កាលបើដូច្នេះ ទូលព្រះបង្គំទាំងឡាយ ឈ្មោះថា ត្រូវទ្រង់លះបង់ហើយ ។ បទថា **បរិករេយ្យុំ** បានដល់ គប្បីចោមរោម ។ បទថា **ឃរំ នេហិ** សេចក្តីថា អ្នកសីវិទាំងឡាយគប្បីបានគាល់ទ្រង់ដែលមានព្រះនេត្រមិនខ្វះ ខាតអស់កាលយូរ ដោយវិធីណា សូមទ្រង់ព្រះរាជទានដោយវិធីនោះចុះ គឺទ្រង់ព្រះរាជទានត្រឹមតែទ្រព្យដល់ព្រាហ្មណ៍ប៉ុណ្ណោះ ទ្រង់កុំព្រះរាជទាន គូនៃព្រះនេត្រឡើយ ព្រោះកាលទ្រង់ព្រះរាជទានគូនៃព្រះនេត្រទៅហើយ អ្នកសីវិទាំងឡាយ នឹងមិនបានគាល់ទ្រង់តទៅ ។

សម័យនោះ ព្រះរាជាបានត្រាស់គាថា ៣ ដោយសេចក្តីថា

បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះឈ្មោះថា យកអន្ទាក់ដែលធ្លាក់លើផែនដី មកពាក់ពួដ៏ក ។ បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះឈ្មោះថា ជា

បុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ហើយដល់នូវឋាន
នរកជាទីសម្រេចរបស់ព្រះយមរាជ ។ ស្មូមសូមនូវរបស់ណា
បុគ្គលគួរតែឲ្យនូវរបស់នោះ មិនសូមនូវរបស់ណា មិនត្រូវឲ្យ
របស់នោះទេ ព្រាហ្មណ៍សូមនូវរបស់ណានឹងអាត្មាអញ អាត្មា
អញ នោះនឹងឲ្យនូវរបស់នោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បដិមុញ្ចតិ** បានដល់ ពាក់ ។ បទថា **ចាចា ចាបតរោ** សេចក្ដីថា រមែងឈ្មោះថា ជាបុគ្គលអាក្រក់ក្រៃលែងជាងបុគ្គលដែលអាក្រក់ ។ បទថា **សម្បត្តោ យមសាធនំ** សេចក្ដីថា រមែងជាបុគ្គលដែលឈ្មោះថា ចូលដល់ឧស្សទនរក ដែលជាទីដាក់អាជ្ញានៃស្ដេចយម ដោយពិត ។ បទថា **យញ្ហិ យាចេ** សេចក្ដីថា ព្រះបាទសីវិរាជត្រាស់ថា យាចកណាសូមនូវវត្ថុណា ទាយកក៏ត្រូវឲ្យវត្ថុនោះឯង មិនត្រូវឲ្យដល់អ្នកមិនសូម ឯព្រាហ្មណ៍នេះ មកសូមចក្ខុនឹងយើង មិនមែនសូមទ្រព្យដូចកែវមុក្ដាជាដើមឡើយ យើងនោះនឹងឲ្យចក្ខុដល់បុរសនេះប៉ុណ្ណោះ ។

លំដាប់នោះ កាលអាមាត្យទាំងឡាយទូលសួរព្រះរាជាថា ទ្រង់ព្រះរាជទានចក្ខុ ព្រោះទ្រង់ប្រាថ្នាអ្វី ទើបពោលគាថាដូច្នេះថា

បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គប្រាថ្នានូវរបស់អ្វី គឺអាយុ
ឬពណ៌សម្បុរ ឬសេចក្ដីសុខ ឬក៏កម្លាំង ទើបព្រះអង្គប្រទាន
( ព្រះនេត្រ ) ព្រះរាជាទ្រង់ប្រសើរជាងជនអ្នកនៅក្នុងដែន
សីវិទាំងឡាយ មិនសមបើប្រទានព្រះនេត្រទាំងឡាយ ព្រោះ

ហេតុនៃប្រយោជន៍ក្នុងបរលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរលោកហេតុ** សេចក្ដីថា បពិត្រមហារាជ បុរសជាបណ្ឌិតដូចទ្រង់ចាំបាច់លះឥស្សរិយយសចំណែកបច្ចុប្បន្នហើយ ព្រះរាជទានកែវភ្នែក ព្រោះហេតុនៃបរលោក ឬដូចម្ដេច ។

លំដាប់នោះ ព្រះរាជាកាលនឹងត្រាស់តបអាមាត្យទាំងនោះ ទើបត្រាស់គាថានេះថា

អញមិនមែនឲ្យចក្ខុនេះ ព្រោះយសទេ មិនមែនប្រាថ្នាកូន មិនមែនប្រាថ្នាទ្រព្យ មិនមែនប្រាថ្នានូវដែនទេ ធម៌គឺប្រវេណីនៃការឲ្យទាន ជាផ្លូវបុរាណ ដែលពួកសប្បុរសធ្លាប់ប្រព្រឹត្តមកហើយ ចិត្តរបស់អញតែងរីករាយក្នុងការឲ្យដោយប្រការដូច្នេះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នវាហំ** កាត់បទជា **ន វេ អហំ** ។ បទថា **យសសា** សេចក្ដីថា ព្រោះហេតុនៃយសដែលជាទិព្វ ឬជារបស់មនុស្សក៏មិនមែន ។ បទថា **ន បុត្តមិច្ឆេ** សេចក្ដីថា មិនមែនយើងចង់បានកូន ទ្រព្យសម្បត្តិ ដែន ព្រោះផលនៃការឲ្យចក្ខុជាទាននេះឡើយ តែសេចក្ដីនេះ ឈ្មោះថាជាផ្លូវដែលមានមកហើយអំពីបុរាណ គឺជាការបំពេញបារមីដែលសប្បុរសគឺបណ្ឌិត បានដល់ព្រះពោធិសត្វបណ្ឌិតអ្នកស្វែងរកសព្វញ្ញុ សន្សំមកល្អហើយ ដ្បិតថា ព្រះពោធិសត្វមិនបំពេញបារមីឲ្យពេញហើយ អាចសម្រេចសព្វញ្ញុតញ្ញាណបានក្នុងពោធិបល្ល័ង្កនោះឡើយ ម្យ៉ាងទៀត យើងបំពេញបារមីទុក

ក៏ប្រាថ្នាជាព្រះពុទ្ធ ។ បទថា **តស្មា ទានេ រមតោ មនោ** សេចក្តីថា ព្រោះហេតុនេះ ទើបចិត្តរបស់យើង ត្រេកអរចំពោះទាន បរិច្ចាគ ។

សម្តេចព្រះសម្មាសម្ពុទ្ធ កាលទ្រង់សម្តែងចរិយាបិដក ដល់ព្រះធម្មសេនាបតីសារីបុត្ត ដើម្បីទ្រង់សម្តែងថា ព្រះសព្វញ្ញុតញ្ញាណប៉ុណ្ណោះជាទីស្រឡាញ់ជាងកែវភ្នែករបស់យើង ទើបត្រាស់ថា

ភ្នែកទាំងពីរ មិនជាទីស្អប់របស់តថាគតទេ តថាគតមិនមែន
ស្អប់ខ្លួនរបស់តថាគតទេ សព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់
តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យនូវភ្នែក ដូច្នេះ ។

កាលអាមាត្យទាំងឡាយ បានស្តាប់ព្រះតម្រាស់របស់ព្រះមហាសត្វហើយ មិនអាចទូលទាស់ ក៏នៅស្ងៀម ព្រះមហាសត្វក៏បានត្រាស់បញ្ជាក់នឹងសីវិកពេទ្យដោយគាថានេះថា

ម្នាលពេទ្យឈ្មោះសីវិកៈ ខ្លួនអ្នកជាសម្លាញ់ ជាមិត្តរបស់យើង
អ្នកមានវិជ្ជាពេទ្យសិក្សាល្អហើយ ចូរធ្វើតាមសំដីរបស់យើង
ដោយប្រពៃចុះ កាលយើងកំពុងប្រាថ្នា អ្នកចូរឆ្កៀលនូវភ្នែក
ទាំងឡាយ ( របស់យើង ) ហើយដាក់លើដៃរបស់ស្មូមចុះ
ដូច្នេះ ។

ព្រះគាថានោះ មានអធិប្បាយថា ម្នាលសីវិកៈសម្លាញ់ អ្នកជាសម្លាញ់និងជាមិត្តរបស់យើង បានសិក្សាវិជ្ជាពេទ្យមកល្អហើយដោយពិត ចូរអ្នកធ្វើតាមពាក្យរបស់យើងឲ្យសម្រេចប្រយោជន៍ កាលយើងប្រាថ្នាពិចារណាមើល

នោះឯង ចូរអ្នកខ្វេះភ្នែកទាំងគូរបស់យើង ដូចខ្វេះនូវកំពីងត្នោត ហើយដាក់ក្នុងដៃយាចកនេះចុះ ដូច្នេះ ។

លំដាប់នោះ សិវិកពេទ្យទូលដាស់តឿនព្រះរាជាថា ការឲ្យនូវចក្ខុជាទានជាកម្មធ្ងន់ សូមព្រះសម្មតិទេពពិចារណាឲ្យល្អ ។ ព្រះរាជាត្រាស់ថា នែ សិវិកៈ យើងពិចារណាល្អហើយ អ្នកកុំបណ្តោះបណ្តៃឡើយ កុំនិយាយច្រើនឡើយ ។ សិវិកពេទ្យគិតថា ពេទ្យដែលសិក្សាល្អមកដូចអញ នឹងយកសស្ត្រាឆ្កៀលភ្នែកព្រះរាជា មិនសមគួរឡើយ អញនឹងផ្សំឱសថច្រើនមុខ អញនឹងយកផ្ទៃថ្នាំអប់ផ្កាឧប្បលខៀវ ហើយថ្វាយឲ្យទ្រង់ជូតព្រះនេត្រខាងស្តាំ ព្រះនេត្រនឹងស្រវាំង ទុក្ខវេទនាដ៏ខ្លាំងក្លានឹងកើតឡើង ហើយអញនឹងទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់កំណត់ព្រះទ័យមើលចុះ ការធ្វើព្រះនេត្រឲ្យជាប្រក្រតីជាភារៈរបស់ទូលព្រះបង្គំ ។ ព្រះរាជាត្រាស់ថា នែពេទ្យ ចូរអ្នកចៀសចេញទៅកុំបណ្តោះបណ្តៃឡើយ ទើបពេទ្យផ្សំឱសថចូលទៅឲ្យ ទ្រង់ជុតព្រះនេត្រដដែលទៀត ព្រះនេត្រក៏លៀនចេញអំពីប្រឡង់ភ្នែក ទុក្ខវេទនាកើតឡើងដ៏ខ្លាំងក្លាពន់ពេក ។ គ្រូពេទ្យទូលថា បពិត្រមហារាជ សូមទ្រង់កំណត់ព្រះទ័យមើលចុះ ការធ្វើព្រះនេត្រឲ្យជាប្រក្រតី ជាភារៈរបស់ទូលបង្គំ ។ ព្រះរាជាត្រាស់ថា ចៀសចេញទៅចុះ កុំធ្វើនូវការយឺតយូរឡើយ ។ ក្នុងវារៈទី ៣ គ្រូពេទ្យផ្សំឱសថឲ្យខ្លាំងក្លាជាងមុន បង្អោនទៅថ្វាយ ។ ដោយកម្លាំងឱសថ ព្រះនេត្រក៏រមៀលចេញអំពីប្រឡង់ភ្នែក ធ្លាក់មកសំយុងដោយសរសៃ ទើបគ្រូពេទ្យទូលដដែលទៀតថា បពិត្រព្រះអង្គ ប្រសើរជាងនរៈ សូមទ្រង់

កំណត់ព្រះទ័យមើលចុះ ការធ្វើព្រះនេត្រឲ្យជាប្រក្រតី ជាភារៈរបស់ទូលបង្គំ ។ ព្រះរាជាត្រាស់ថា ចូរអ្នកកុំធ្វើការបណ្តោះបណ្តៃឡើយ ។ ទុក្ខវេទនាកើតឡើងពន់ប្រមាណ ព្រះលោហិតក៏ហូរចេញ ព្រះភូសាជោកដោយព្រះលោហិត ។ ស្នំនិងអាមាត្យទាំងឡាយក្រាបទៀបបាទមូលរបស់ព្រះរាជា នាំគ្នាបរិទេវនាថា បពិត្រព្រះអង្គ សូមទ្រង់កុំព្រះរាជទានព្រះនេត្រឡើយ ព្រះរាជាទ្រង់អត់សង្កត់នូវទុក្ខវេទនា ត្រាស់ថា នែបា អ្នកកុំធ្វើនូវការយឺតយូរឡើយ ។ គ្រូពេទ្យទទួលព្រះរាជឱង្ការហើយ ផ្គងព្រះនេត្រដោយដៃឆ្វេង ចាប់សស្ត្រាកាត់សរសៃដោយដៃស្តាំ ហើយទទួលព្រះនេត្រដាក់ក្នុងដៃរបស់ព្រះមហាសត្វ ។ ព្រះរាជាទតព្រះនេត្រខាងស្តាំ ដោយព្រះនេត្រខាងឆ្វេង ទ្រង់អត់សង្កត់នូវទុក្ខវេទនា ត្រាស់ហៅព្រាហ្មណ៍ថា មកចុះព្រាហ្មណ៍ ហើយត្រាស់បន្តថា សព្វញ្ញុតញ្ញាណប៉ុណ្ណោះជាទីស្រឡាញ់ជាងកែវភ្នែករបស់យើងនេះ រាប់រយរាប់ពាន់រាប់សែនដង ផលដែលយើងបរិច្ចាគភ្នែកនេះ ចូរជាបច្ច័យដល់សព្វញ្ញុតញ្ញាណចុះ ហើយបានព្រះរាជទានព្រះនេត្រនោះដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ទទួលព្រះនេត្រប្រតិស្ឋានទុកក្នុងប្រឡង់ភ្នែករបស់ខ្លួន ដោយអានុភាពរបស់ព្រះបាទសីវិរាជនោះ ព្រះនេត្រក៏ប្រតិស្ឋានដូចផ្កាឧប្បលខៀវដែលរីក ។ ព្រះមហាសត្វទតភ្នែករបស់ព្រាហ្មណ៍នោះដោយព្រះនេត្រខាងឆ្វេង ហើយទ្រង់ព្រះតម្រិះថា ឱ ! អក្ខិទាន អញបានឲ្យល្អហើយ ទ្រង់សោយបីតិដែលជ្រួតជ្រាបទៅក្នុងព្រះរាជហឫទ័យមិនមានចន្លោះ ទើបព្រះរាជទានព្រះនេត្រខាងឆ្វេងក្រៅអំពីនេះទៀត ។ សក្កទេវរាជ ទ្រង់ប្រតិស្ឋានព្រះនេត្រខាងឆ្វេងនោះ ក្នុងប្រឡង់

ភ្នែករបស់ទ្រង់ ហើយចេញអំពីព្រះរាជនិវេសន៍ កាលមហាជនកំពុងមើល នោះឯង បានចេញអំពីនគរទៅកាន់ទេវលោកមួយរំពេច ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនេះ ទើបត្រាស់ព្រះគាថា ១ គាថាកន្លះថា

ពេទ្យឈ្មោះ សីវិកៈ លុះព្រះរាជា ទ្រង់ព្រះនាមសីវិតឿន ( យ៉ាងនេះហើយ ) ក៏ធ្វើតាមព្រះបន្ទូល ហើយធ្លៀលនូវព្រះនេត្រទាំងពីររបស់ព្រះរាជា បង្អោនទៅឲ្យព្រាហ្មណ៍ ចំណែកព្រាហ្មណ៍ ក៏ទៅជាបុគ្គលមានភ្នែក ព្រះរាជាទៅជាបុគ្គលខ្វាក់ ដូច្នេះ ។

មិនយូរប៉ុន្មាន សាច់ព្រះនេត្រទាំងគូរបស់ព្រះរាជាក៏ដុះឡើង កាលដុះឡើង ក៏មិនផត បានពេញបរិបូណ៌ដោយដុំសាច់ប៉ោងឡើង ដូចពកនៃសំពត់កម្ពល រណ្តៅនៃព្រះនេត្រទាំង ២ ដូចភ្នែកដែលជាងចិត្រកម្មធ្វើ ។ ទុក្ខវេទនា ក៏វិនាសបាត់អស់ទៅ កាលនោះ ព្រះមហាសត្វប្រថាប់លើប្រាសាទ ២-៣ ថ្ងៃ ទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដោយរាជសម្បត្តិដល់មនុស្សភ្នែកខ្វាក់ ព្រោះហេតុនោះ អញនឹងប្រគល់រាជសម្បត្តិ ដល់អាមាត្យទាំងឡាយ ទៅកាន់ព្រះរាជឧទ្យាន បួសបំពេញសមណធម៌ ដូច្នេះហើយ ត្រាស់ឲ្យអាមាត្យទាំងឡាយមកគាល់ ប្រាប់សេចក្តីនោះ ដល់អាមាត្យទាំងនោះហើយ ត្រាស់ថា កប្បិយការកៈម្នាក់ សម្រាប់ឲ្យរបស់ មានទឹកខ្ពុរមាត់ជាដើម នឹងនៅក្នុងសម្នាក់របស់យើង អ្នកទាំងឡាយចូរចងខ្សែទុកក្នុងទីធ្វើសរីរកិច្ចរបស់

យើងចុះ ហើយហៅនាយសារថីមកត្រាស់ថា ចូរអ្នកទឹមរថ ។ ឯអាមាត្យទាំងឡាយមិនឲ្យទ្រង់យានទៅដោយរថ នាំទ្រង់យានទៅដោយសុវណ្ណសិវិកា ហើយឲ្យប្រថាប់ត្រង់មាត់ស្រះបោក្ខរណី ចាត់ចែងកម្លាំងរក្សា ហើយចៀសចេញទៅ ព្រះរាជាប្រថាប់គង់លើបល្ល័ង្ក ទ្រង់រំពឹងដល់ទានរបស់ទ្រង់ ។ ខណៈនោះ ក៏ក្តៅដល់អាសនៈសក្កទេវរាជ សក្កទេវរាជពិចារណាមើល ឃើញហេតុការណ៍នោះហើយ ទ្រង់ព្រះតម្រិះថា អញនឹងឲ្យពរដល់ព្រះបាទសីវិមហារាជ ហើយធ្វើព្រះនេត្រឲ្យជាប្រក្រតី ដូច្នេះហើយ ទើបយាងមកត្រង់ប្រាំងស្រះបោក្ខរណីនោះ ដើរទៅដើរមក មិនឆ្ងាយអំពីព្រះមហាសត្វ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

តអំពីនោះមក ប្រមាណពីរបីថ្ងៃ លុះដល់ព្រះនេត្រ ទាំងពីរដុះឡើង ព្រះរាជា ជាអ្នកញុំាងដែនឲ្យចម្រើនដល់ពួកជនអ្នកសីវិ ទ្រង់ត្រាស់បង្គាប់នាយសារថីថា នែនាយសារថី អ្នកចូរទឹមយាន លុះទឹមហើយចូរប្រាប់យើង យើងនឹងទៅកាន់ទីឧទ្យានដែលមានស្រះបោក្ខរណី និងព្រៃព្រឹក្សា ។ ព្រះបាទសីវិនោះទ្រង់បានចូលទៅគង់ពែនព្រះក្អែន ប្របច្នេរស្រះបោក្ខរណី ទេវរាជឈ្មោះសក្កៈ ជាសុជម្បតិ ក៏មកដល់ចំពោះព្រះអង្គ ដូច្នេះ ។

ឯសក្កទេវរាជ ដែលព្រះមហាសត្វទ្រង់ស្តាប់សំឡេងជើងហើយ សួរថា ទុំះនរណា ទើបត្រាស់គាថាថា

ខ្ញុំជាទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតា មកក្នុងសំណាក់

ព្រះអង្គ បពិត្រស្តេចឥសី ព្រះអង្គប្រាថ្នាក្នុងព្រះទ័យ ចំពោះ
ពរណាមួយ សូមត្រេកអរនឹងពរនោះចុះ ដូច្នេះ ។

កាលសក្កទេវរាជត្រាស់យ៉ាងនេះហើយ ព្រះរាជាត្រាស់ថា

បពិត្រសក្កៈ ទ្រព្យនិងពលរបស់ខ្ញុំមានច្រើនហើយ ទាំងឃ្លាំង
របស់ខ្ញុំ មិនមែនមានតិចទេ កាលបើខ្ញុំនៅតែខ្វាក់ក្នុងកាល
ឥឡូវនេះ ខ្ញុំពេញចិត្តចំពោះសេចក្តីស្លាប់តែម្យ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មរណញ្ញេវ រុច្ចតិ** សេចក្តីថា បពិត្រទេវរាជ ឥឡូវនេះ ការស្លាប់តែម្យ៉ាងប៉ុណ្ណោះ ដែលខ្ញុំពេញចិត្ត ព្រោះភាពជាបុគ្គលភ្នែកខ្វាក់ សូមទ្រង់ឲ្យនូវការស្លាប់នោះដល់ខ្ញុំចុះ ។

គ្រានោះ សក្កទេវរាជក៏ត្រាស់នឹងព្រះរាជាថា បពិត្រព្រះបាទសីវិ ទ្រង់បំណងនឹងផ្តាច់ព្រះជន្ម ទើបចង់អស់ព្រះជន្ម ឬទ្រង់ចង់អស់ព្រះជន្ម ព្រោះជាបុគ្គលខ្វាក់ ។ ព្រះបាទសីវិរាជទូលតបថា ខ្ញុំចង់អស់ព្រះជន្ម ព្រោះជាបុគ្គលខ្វាក់ ។ សក្កទេវរាជត្រាស់សន្ទនាបន្តថា បពិត្រមហារាជ ឈ្មោះថា ទានឲ្យផលក្នុងសម្បរាយភពតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន រមែងជាបច្ច័យដើម្បីជាប្រយោជន៍ក្នុងបច្ចុប្បន្ន ទ្រង់កាលយាចកទូលសូមព្រះនេត្រម្ខាង បានព្រះរាជទានទាំងសងខាង ហេតុនោះ សូមទ្រង់ធ្វើសច្ចកិរិយាចុះ ហើយត្រាស់ថា

បពិត្រក្សត្រិយ៍ ជាធំជាងជនមានជើងពីរ សូមព្រះអង្គពោល
នូវពាក្យទាំងឡាយដែលជាសច្ចៈចុះ កាលបើព្រះអង្គពោល
នូវពាក្យសច្ចៈ ព្រះនេត្រនឹងមានឡើងវិញ ដូច្នេះ ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះហើយ ត្រាស់ថា បពិត្រសក្កទេវរាជ បើទ្រង់បំណងព្រះរាជទានចក្ខុដល់ខ្ញុំ ទ្រង់កុំបាច់ធ្វើឧបាយដទៃឡើយ ភ្នែកចូរកើតឡើងដោយផលនៃទានរបស់ខ្ញុំចុះ កាលសក្កៈត្រាស់ថា ខ្ញុំជាសក្កទេវរាជ មិនអាចឲ្យភ្នែកដល់អ្នកដទៃបាន ចក្ខុនឹងកើតឡើងដោយកម្លាំងនៃទានដែលទ្រង់បរិច្ចាគតែម្យ៉ាង ទើបត្រាស់ថា បើដូច្នោះ ទានដែលខ្ញុំបរិច្ចាគល្អហើយ ដូច្នេះ កាលទ្រង់ធ្វើសច្ចកិរិយា ទើបត្រាស់គាថាដូច្នេះថា

ពួកស្មូមណាមានគោត្តផ្សេង ៗ គ្នា មកដើម្បីសូមចំពោះយើង
បណ្តាស្មូមទាំងនោះ ស្មូមណាសូមយើង ស្មូមនោះជាទីស្រ-
ឡាញ់នៃចិត្តរបស់យើង សូមឲ្យភ្នែកកើតមានដល់យើងដោយ
ការពោលនូវពាក្យសច្ចៈនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោបិ មេ** សេចក្តីថា ស្មូមពួកណាមកសូមយើង ស្មូមទាំងនោះ ជាទីស្រឡាញ់របស់យើង កាលពួកគេនាំគ្នាមកសូម បុគ្គលណាសូមចក្ខុយើង បុគ្គលនោះក៏ជាទីស្រឡាញ់ដោយចិត្តរបស់យើង ។ បទថា **ឯតេន** នេះ ព្រះមហាសត្វពោលថា បើយាចកទាំងឡាយសុទ្ធតែជាទីស្រឡាញ់របស់យើង នេះជាសច្ចវាចាដែលយើងពោលហើយ ដោយការពោលសច្ចវាចានេះ ចក្ខុម្ខាងរបស់យើង ចូរកើតឡើងចុះ ។

លំដាប់នោះ ចក្ខុដែលជាបឋម កើតឡើងក្នុងរវាងនៃព្រះតម្រាស់របស់ព្រះរាជានោះឯង បន្ទាប់អំពីនោះ កាលឲ្យចក្ខុទី ២ កើតឡើង ទើបត្រាស់គាថា ២ ថា

ព្រាហ្មណ៍នោះ មកដើម្បីសូម នូវភ្នែកណានឹងយើងថា សូម
ព្រះអង្គប្រទាននូវភ្នែក យើងក៏បានឲ្យនូវភ្នែកទាំងឡាយនោះ
ដល់ព្រាហ្មណ៍ដែលសូមនោះហើយ ។ បីតិនិងសោមនស្សដ៏
ច្រើន ក៏កើតឡើងដល់យើងដោយក្រៃលែង សូមឲ្យភ្នែកជា
គម្រប់ពីរ កើតមានដល់យើង ដោយពោលពាក្យសច្ចៈនេះ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យំ មំ** សេចក្ដីថា ព្រាហ្មណ៍ណាមកសូម
យើង ។ បទថា **សោ** សេចក្ដីថា ព្រាហ្មណ៍នោះមានចក្ខុពិការមកសូមយើង
ថា សូមទ្រង់ប្រោសព្រះរាជទានព្រះនេត្រដល់ទូលព្រះបង្គំចុះ ។ បទថា **វណិព្ព-
កោ** សេចក្ដីថា ដល់ព្រាហ្មណ៍ដែលមកសូម ។ បទថា **ភិយ្យោ មំ អាវិសិ**
សេចក្ដីថា កាលឲ្យចក្ខុទាំង ២ ដល់ព្រាហ្មណ៍ហើយ រាប់តាំងអំពីនោះមក
ក៏ជាបុគ្គលភ្នែកខ្វាក់ តែក្នុងកាលភ្នែកខ្វាក់នោះ មិនបានគិតដល់ទុក្ខវេទនា
បែបនោះទេ បីតិដែលកើតផ្សាយទៅ គឺចូលកាន់ដួងហទយៈរបស់យើងដែល
ពិចារណាឃើញថា ឱ ! អញបានឲ្យទានដោយល្អហើយ ទាំងសោមនស្ស
ក៏កើតឡើង ដល់អញមិនមានប្រមាណ ។ បទថា **ឯតេន** នេះ ព្រះមហា
សត្វពោលថា បើបីតិសោមនស្ស មិនមែនតិចកើតឡើងដល់យើងក្នុងកាល
នោះសោត
នេះជាសច្ចវាចាដែលយើងពោលហើយដោយការពោលសច្ចវាចានេះ ចក្ខុទី ២
ចូរកើតឡើងដល់យើងចុះ ។

វេលាបនោះឯង ព្រះនេត្រទី ២ ក៏កើតឡើង ។ តែព្រះនេត្ររបស់ស្តេចសីវិរាជនោះជាព្រះនេត្រប្រក្រតីក៏មិនមែន ជាព្រះនេត្រទិព្វក៏មិនមែន ព្រោះព្រះនេត្ររបស់ព្រះអង្គ ទ្រង់ព្រះរាជទានដល់សក្កព្រាហ្មណ៍ហើយ ទាំងសក្កព្រាហ្មណ៍ ក៏មិនអាចធ្វើព្រះនេត្រឲ្យជាប្រក្រតីដូចរបស់ដើមបាន ។ មួ៉ាងទៀត ធម្មតាព្រះនេត្រទិព្វនឹងកើតឡើងដល់ចក្ខុដែលមានទីតាំង ដែលទម្លាយហើយមិនមាន ហេតុនោះ ព្រះនេត្រទាំងនោះរបស់ព្រះបាទសីវិរាជ ហៅថាសច្ចបារមិតាចក្ខុ គឺចក្ខុដែលកើតឡើងព្រោះសច្ចបារមីរបស់ទ្រង់ ក្នុងកាលដែលព្រះនេត្រទាំងនោះ កើតឡើងព្រមនោះឯង រាជបរិស័ទទាំងពួងក៏មកប្រជុំព្រមគ្នា ដោយអានុភាពរបស់សក្កទេវរាជ ។ លំដាប់នោះ កាលសក្កទេវរាជទ្រង់ធ្វើការសរសើរ ព្រះបាទសីវិរាជកណ្តាលមហាជននោះឯង ទើបត្រាស់គាថាថា

> បពិត្រក្សត្រិយ៍ អ្នកញុំាំងដែនរបស់អ្នកដែនសីវិឲ្យចម្រើនគាថាដែលព្រះអង្គពោលតាមធម៌ សូមឲ្យព្រះនេត្រទាំងពីររបស់ព្រះអង្គនេះ ប្រាកដដូចជាទិព្វ ។ ព្រះនេត្រទាំងពីររបស់ព្រះអង្គនោះសូមឲ្យបាននូវការឃើញធ្លុះធ្លាយទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មេន ភាសិតា** សេចក្តីថា បពិត្រមហារាជ គាថានេះទ្រង់ត្រាស់ហើយតាមធម៌ គឺតាមសភាវៈ ។ បទថា **ទិព្យានិ** សេចក្តីថា ប្រកបដោយអានុភាពដែលជាទិព្វ ។ បទថា **បដិទិស្សរេ** ប្រែថា នឹង

ប្រាកដ ។ បទថា **តិរោកុឌ្ឌំ** សេចក្តីថា បពិត្រមហារាជ ព្រះនេត្ររបស់ទ្រង់ទាំងនេះ ចូរមើលឃើញ គឺក្លំស្វាង ទតឃើញរូបបានខាងក្រៅជញ្ជាំង ក្រៅកំពែងនិងភ្នំណាមួយ ហាក់បីដូចចក្ខុនៃពួកទេវតា អស់ទី ១០០ យោជន៍ ក្នុងទិសទាំង ១០ ដោយជុំវិញ ។

សក្កទេវរាជ ទ្រង់ប្រថាប់ឈរលើអាកាស ត្រាស់ព្រះគាថាទាំងនេះក្នុងកណ្តាលមហាជនហើយ ទ្រង់ព្រះរាជទានឱវាទដល់ព្រះមហាសត្វថា សូមទ្រង់កុំប្រមាទ ហើយយាងទៅកាន់ទេវលោកនោះឯង ។

ឯព្រះមហាសត្វចោមរោមដោយមហាជន យាងចូលកាន់ព្រះនគរដោយសក្ការៈធំ ហើយទ្រង់ឡើងប្រថាប់ក្នុងសុចន្ទកប្រាសាទ ។ ភាពដែលព្រះរាជាបាននូវព្រះនេត្រទាំងគូត្រឡប់មកវិញ ប្រាកដផ្សាយទៅពេញសីវិរដ្ឋសីមាមណ្ឌល ។ សម័យនោះ មហាជនអ្នកដែនសីវិរដ្ឋទាំងមូល នាំគ្នាកាន់គ្រឿងបណ្ណាការមកថ្វាយជាច្រើន ដើម្បីត្រូវការចូលគាល់ សរសើរព្រះបារមីរបស់ព្រះបាទសីវិរាជ ព្រះមហាសត្វទ្រង់ត្រិះរិះថា កាលមហាជននេះប្រជុំគ្នាហើយ អញនឹងពណ៌នាទានរបស់អញ ទើបឲ្យគេសាងមណ្ឌបធំ ត្រង់ទ្វារព្រះរាជនិវេសន៍ ប្រថាប់គង់លើរាជបល្ល័ង្កខាងក្រោមសមុស្សិតស្វេតច្ឆត្រ ។ ទ្រង់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ត្រាស់ឲ្យសេនារាជការទាំងអស់ ប្រជុំគ្នា ហើយត្រាស់ថា នែអ្នកដែនសីវិរដ្ឋដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយឃើញព្រះនេត្រទិព្វយើងនេះហើយ តាំងអំពីនេះទៅ បើមិនទាន់ឲ្យទានជាមុន កុំគប្បីបរិភោគ កាលទ្រង់សម្តែងធម៌ បានត្រាស់គាថា ៤ ថា

អ្នកណាមួយក្នុងលោកនេះ ដែលគេសូមហើយមិនឲ្យនូវទ្រព្យដ៏ពេញចិត្ត ឬទ្រព្យដ៏ថ្លៃថ្លា ជាទីស្រឡាញ់ដ៏ក្រៃលែងរបស់ខ្លួន នៃអ្នកដែនសីវិទាំងអស់ដែលមកប្រជុំគ្នា ចូរអ្នកទាំងឡាយមើលនូវភ្នែកទាំងពីររបស់អញ ដែលជាទិព្វក្នុងថ្ងៃនេះចុះ ។ ចក្ខុទាំងពីររបស់យើង រមែងបាននូវការឃើញផ្ទះធ្លាយ ទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ។ ( វត្ថុណាមួយ ) ក្នុងជីវិតរបស់សត្វទាំងឡាយនេះ រមែងមិនប្រសើរជាងចាគៈទេ ( ខ្លួនយើង ) បានឲ្យនូវចក្ខុជារបស់មនុស្សហើយបាននូវចក្ខុទិព្វដែលមិន មែនជារបស់មនុស្ស ។ ម្នាលអ្នកដែនសីវិទាំងឡាយ អ្នកទាំងឡាយបានឃើញហេតុនេះហើយ ចូរឲ្យទាន ចូរបរិភោគ លុះឲ្យហើយបរិភោគហើយ តាមសមគួរដល់អានុភាព សូមឲ្យជាអ្នកមិនមានអ្នកណាតិះដៀលបាន ហើយចូរទៅកាន់ឋានសួគ៌ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោធីធ** កាត់បទជា **កោ ឆុ ឥធ** ប្រែថា អ្នកណាហ្ន៎ក្នុងលោកនេះ ។ បទថា **អបិ វិសិដ្ឋំ** សេចក្តីថា ជារបស់ឧត្តម ។ បទថា **ចាគមត្តា** សេចក្តីថា ឈ្មោះថា ចក្ខុដទៃកំពូលជាងប្រមាណនៃការបរិច្ចាគមិនមាន ។ បទថា **ឥធ ជីវិតេ** សេចក្តីថា ក្នុងជីវលោកនេះ ។ បាឋៈថា **ឥធ ជីវិតំ** ដូច្នេះក៏មាន ។ សេចក្តីថា ជាអ្នកនៅក្នុងជីវលោកនេះ ។ បទថា **អមានុសំ** សេចក្តីថា ចក្ខុទិព្វរបស់យើង បានហើយដោយហេតុនេះ

ទើបគួរជ្រាបសេចក្តីនេះថា ឈ្មោះថា វត្ថុដែលឧត្តមជាងការបរិច្ចាគមិនមាន ។ បទថា **ឃតំបិ ធិស្វា** សេចក្តីថា អ្នកទាំងឡាយឃើញហើយនូវចក្ខុដែលជាទិព្វដែលយើងបានហើយនេះ ចូរឲ្យទានជាមុន សឹមបរិភោគ ។

កាលព្រះបាទសីវិរាជ ទ្រង់សម្តែងធម៌ដោយគាថា ៤ ដោយប្រការដូច្នេះហើយ តាំងអំពីនោះមក រៀងរាល់កន្លះខែនិងថ្ងៃបណ្ណរសីឧបោសថ ក៏ត្រាស់ឲ្យមហាជនប្រជុំគ្នា ទ្រង់សម្តែងធម៌ ដោយគាថាទាំងនេះជាប្រចាំ មហាជនស្តាប់ធម៌នោះហើយ នាំគ្នាធ្វើបុណ្យទាំងឡាយ មានទានជាដើម បានទៅកាន់ទេវលោកពេញបរិបូណ៌ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយក្នុងកាលមុន មិនត្រេកអរដោយទានខាងក្រៅឡើយ បានខ្វេះភ្នែកទាំងគូរបស់ខ្លួន បរិច្ចាគដល់យាចកដែលមកដល់ចំពោះមុខដោយប្រការដូច្នេះ ហើយទ្រង់ប្រកាសចតុរារិយសច្ចប្រជុំជាតកថា សីវិកពេទ្យក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ រាជបរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកព្រះបាទសីវិរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សីវិរាជជាតក ចប់**

# សិរីមន្ទជាតក

[ ២១៣ ] ( ព្រះរាជាវិទេហៈត្រាស់សួរថា ) នែសេនកៈ យើងសួរនូវសេចក្តីនុ៎ះ គឺបុគ្គលប្រកបដោយប្រាជ្ញា ប្រាសចាកសិរីសម្បត្តិ ១ បុគ្គលមានយស ប្រាសចាកប្រាជ្ញា ១ អ្នកប្រាជ្ញទាំងឡាយពោលថា បណ្តាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង ។

[ ២១៤ ] ( អាចារ្យសេនកៈ... ) បពិត្រព្រះអង្គជាធំជាងជន ពួកអ្នកប្រាជ្ញ ពួកជនពាល ពួកជនអ្នកបរិបូណ៌ដោយសិល្បៈនិងពួកជនមិនមានសិល្បៈ សូម្បីជាអ្នកមានជាតិខ្ពស់ រមែងជាអ្នកធ្វើនូវការបម្រើជនអ្នកមានយស ដែលមិនមានជាតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[ ២១៥ ] ( ព្រះរាជា... ) ម្នាលមហោសធ អ្នកមានប្រាជ្ញាមិនថោកថយ ជាអ្នកឃើញនូវហេតុដោយសព្វគ្រប់ យើងសូមសួរអ្នកអំពីបុគ្គលពាល មានយស បណ្ឌិតគ្មានភោគៈ តើអ្នកប្រាជ្ញទាំងឡាយពោលថា បណ្តាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង ។

[ ២១៦ ] ( មហោសធបណ្ឌិត... ) ពួកជនពាល តែងធ្វើនូវអំពើអាក្រក់ទាំងឡាយ ហើយសំគាល់ថា អំពើនេះឯងជាអំពើប្រសើរ ជាអ្នកឃើញត្រឹមតែលោកនេះ មិនឃើញនូវលោកខាងមុខទេ បុគ្គលពាលតែងកាន់យកនូវទោសក្នុងលោកទាំងពីរ ខ្ញុំព្រះអង្គបានឃើញហេតុនេះ សូមទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាល មានយសមិនប្រសើរទេ ។

[ ២១៧ ] ( អាចារ្យសេនកៈ... ) សិល្បៈនេះរមែងមិនដល់នូវភោគ

សម្បត្តិទេ បុគ្គលមានផៅពង្សក៏មិនដល់នូវបុគ្គលមានភោគសម្បត្តិដែរ ទាំងបុគ្គលអ្នកមានឱកាសនៃសរីរៈ ( មានរូបឆោមល្អ ) ក៏មិនដល់នូវបុគ្គលមានភោគសម្បត្តិដែរ សូមទ្រង់ទតចុះ អ្នកផងតែងគប់រកនូវគោរិន្ទសេដ្ឋី ជាមនុស្សហៀរទឹកមាត់ ដល់នូវសេចក្ដីសុខ ជាអ្នកសាបសូន្យចាកសិរី ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[ ២១៨ ] ( មហោសធ... ) បុគ្គលអប្បប្រាជ្ញា បានសេចក្ដីសុខហើយ រមែងស្រវឹង លុះត្រូវសេចក្ដីទុក្ខប៉ះពាល់វិញ ក៏ដល់នូវសេចក្ដីវង្វេង បុគ្គលអប្បប្រាជ្ញា ត្រូវសេចក្ដីសុខនិងទុក្ខមកថ្មីប៉ះពាល់ហើយ ក៏រមែងញាប់ញ័រដូចជាវារិចរ ( សត្វត្រាច់ទៅក្នុងទឹក ) ដែលញាប់ញ័រក្នុងកាលក្ដៅ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។

[ ២១៩ ] ( អាចារ្យសេនកៈ... ) ពួកសត្វបក្សីតែងហើរសំដៅទៅចោមរោមដើមឈើដែលមានផ្លែដ៏ឆ្ងាញ់ក្នុងព្រៃ យ៉ាងណា ជនជាច្រើនតែងគប់រកនូវបុគ្គលស្ដុកស្ដម្ភ បរិបូណ៌ដោយទ្រព្យនិងភោគៈ ព្រោះហេតុតែប្រយោជន៍ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[ ២២០ ] ( មហោសធ... ) បុគ្គលពាលមានកម្លាំង រមែងបាននូវទ្រព្យ ( ព្រោះតែធ្វើ ) នូវកម្មដ៏ក្ងៀវក្លា មិនល្អទេ ពួកនិរយបាលតែងទាញ

កន្ត្រាក់នូវបុគ្គលពាល ឥតប្រាជ្ញា ដែលកន្ទក់កន្ទេញនោះ យកទៅកាន់នរក ដ៏ក្តៅក្លា ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលអ្នកមាន ប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។

[ ២២១ ] ( អាចារ្យសេនកៈ... ) ទឹកស្ទឹងទាំងឡាយណាមួយ រមែង ហូរចាក់ទៅក្នុងទន្លេគង្គា ទឹកស្ទឹងទាំងអស់នោះ រមែងលះបង់នូវនាម និងគោត្ត ទឹកទន្លេគង្គា កាលបើហូរដល់សមុទ្ទ ( រមែងបានឈ្មោះថាមហាសមុទ្ទយ៉ាង ណា ) បុគ្គលដែលមានប្រាជ្ញាជាគ្រឿងសម្រេច ក៏មិនប្រាកដក្នុងលោកយ៉ាង នោះដែរ ខ្ញុំព្រះអង្គ បានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[ ២២២ ] ( មហោសធ... ) លោកសេនកៈបានពោលនូវមហាសមុទ្ទ ណាថាជាសមុទ្ទធំ ទឹកស្ទឹងទាំងឡាយតែងហូរទៅក្នុងសមុទ្ទនោះ រាប់មិនបាន អស់កាលទាំងពួង សមុទ្ទនោះ មានសន្ទុះដ៏លើសលុបជានិច្ចក៏មែន តែថា ទឹកមហាសមុទ្ទ ក៏មិនកន្លងនូវច្រាំងបានទេ ការប្រឹក្សារបស់មនុស្សពាល ក៏ យ៉ាងនោះដែរ តាំងពីកាលណាមក បុគ្គលអ្នកមានសិរីរមែងមិនកន្លងនូវបុគ្គល មានប្រាជ្ញាបានឡើយ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គល មានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។

[ ២២៣ ] ( អាចារ្យសេនកៈ... ) បុគ្គលមានយសឋិតនៅក្នុងទីវិនិច្ឆ័យ បើទុកជាមិនព្រៀងទុក ក៏អាចប្រាប់នូវសេចក្តីចំពោះពួកជនដទៃបាន សំដី របស់បុគ្គលមានយសនោះឯង រមែងលូតលាស់ក្នុងកណ្តាលនៃពួកញាតិអ្នក

ផងមិនអាចញុំាងបុគ្គលដែលមានប្រាជ្ញា តែសាបសូន្យចាកសិរីឲ្យធ្វើការ ( អ្វី ) បានទេ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[ ២២៤ ] ( មហោសធ... ) បុគ្គលពាលអប្បប្រាជ្ញា រមែងនិយាយកុហក ព្រោះហេតុនៃអ្នកដទៃឬខ្លួនឯង បុគ្គលពាលនោះ ត្រូវគេតិះដៀលក្នុងកណ្ដាលទីប្រជុំ ក្នុងកាលខាងក្រោយ បុគ្គលពាលនោះ រមែងទៅកាន់ទុគ្គតិ ខ្ញុំព្រះអង្គ បានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលដែលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។

[ ២២៥ ] ( អាចារ្យសេនកៈ... ) បុគ្គលមានប្រាជ្ញាក្រាស់ដូចផែនដី មិនមានទីលំនៅ មិនមានទ្រព្យធន ជាបុគ្គលក្រីក្រ បើទុកជាពោលនូវសេចក្ដី ( ណាមួយ ) ពាក្យសំដីរបស់បុគ្គលដែលមានប្រាជ្ញានោះ ក៏មិនលូតលាស់ក្នុងកណ្ដាលនៃពួកញាតិ ទាំងសិរីរបស់បុគ្គលមានប្រាជ្ញាក៏មិនមាន ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[ ២២៦ ] ( មហោសធ... ) បុគ្គលអ្នកមានប្រាជ្ញាក្រាស់ដូចផែនដី រមែងមិននិយាយពាក្យឡេះឡោះ ព្រោះហេតុនៃបុគ្គលដទៃឬខ្លួនឯងទេ បុគ្គលអ្នកមានប្រាជ្ញានោះ មានគេបូជាក្នុងកណ្ដាលទីប្រជុំ លុះកាលខាងក្រោយអ្នកមានប្រាជ្ញានោះ រមែងទៅកាន់សុគតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិន

ប្រសើរទេ ។

[ ២២៧ ] ( អាចារ្យសេនកៈ... ) ដំរី គោ សេះ កែវមណី កុណ្ឌល និងនារី តែងកើតមានក្នុងត្រកូលដ៏ស្តុកស្តម្ភ ដំរី គោ សេះ ជាដើម ទាំងអស់នោះ ជារបស់មិនមានឫទ្ធិ ទើបជាគ្រឿងឧបភោគ ( ប្រើប្រាស់ ) របស់បុរសជាឥស្សរៈ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[ ២២៨ ] ( មហោសធ... ) សិរីគឺឥស្សរិយយស រមែងលះបង់នូវបុគ្គលពាល ដែលមិនចេះចាត់ចែងនូវការងារ ជាអ្នកមានគំនិតអាក្រក់ ឥតប្រាជ្ញា ដូចពស់ដែលលះចោលនូវសំណកចាស់ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។

[ ២២៩ ] ( អាចារ្យសេនកៈ... ) បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំង ៥ នាក់ សុទ្ធសឹងជាបណ្ឌិត ប្រណម្យដៃបម្រើព្រះអង្គទាំងអស់គ្នា ព្រះអង្គជាធំលើសលុបពួកខ្ញុំព្រះអង្គ ដូចជាទេវរាជឈ្មោះសក្កៈជាម្ចាស់នៃទេវតា ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាជាបុគ្គលថោកទាប ឯបុគ្គលមានសិរីជាបុគ្គលប្រសើរ ។

[ ២៣០ ] ( មហោសធ... ) បុគ្គលពាលដែលមានយស ទុកដូចជាទាសៈរបស់បុគ្គលអ្នកមានប្រាជ្ញា នាកាលហេតុទាំងឡាយប្រាកដដូច្នោះកើតហើយ អ្នកប្រាជ្ញតាក់តែងនូវប្រស្នាដ៏ល្អិតណា បុគ្គលពាល រមែងដល់នូវការ

វង្វេងក្នុងប្រស្នាដ៏ល្អិតនោះ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។

[ ២៣១ ] តាមពិត ពួកសប្បុរស តែងសរសើរប្រាជ្ញាតែម្យ៉ាង ពួកមនុស្សតែងត្រេកអរចំពោះភោគៈ សិរីគ្រាន់តែជាទីត្រេកអររបស់ ( ពួកមនុស្សពាល ) មួយទៀត ញាណនៃអ្នកប្រាជ្ញទាំងឡាយ មិនមានអ្វីប្រៀបផ្ទឹមបានទេ តាំងពីកាលណាមក បុគ្គលអ្នកមានសិរី រមែងមិនកន្លងនូវបុគ្គលមានប្រាជ្ញាបានឡើយ ។

[ ២៣២ ] ( ព្រះបាទវិទេហរាជ... ) ម្នាលមហោសធៈ ជាអ្នកឃើញធម៌សព្វគ្រប់ យើងបានសួរនូវប្រស្នាណា អ្នកបានថ្លែងដោះស្រាយនូវប្រស្នានោះដល់យើង យើងត្រេកអរដោយការដោះស្រាយនូវប្រស្នា ( របស់អ្នក ) យើងសូមឲ្យទ្រព្យទាំងនេះ គឺគោមួយពាន់ មានគោឧសភ ( ជាដើម ) ផងដំរីផង រថដែលទឹមដោយសេះអាជានីយ ១០ ផង ស្រុកសួយ ១៦ ផង ដល់អ្នក ។

**ចប់ សិរីមន្ទជាតក ទី ៤ ។**

# អដ្ឋកថា

# សិរីមន្ទជាតក

[ ២១៣-២៣២ ] *សិរីមន្ទប្បញ្ហានេះ មានពាក្យផ្ដើមថា* **បញ្ញាយុបេតំ សិរិយា វិហីនំ** *ដូច្នេះ ។ ផ្ទៃរឿងមានពិស្ដារក្នុង មហាឧម្មង្គជាតក នោះឯង ។*

*អដ្ឋកថា សិរីមន្ទជាតក ចប់*

## រោហណមិគជាតក

[ ២៣៣ ] ( រោហនៈម្រឹគពោធិសត្វពោលថា ) ម្នាលចិត្តកៈ ហ្វូងម្រឹគទាំងនេះ ខ្លាចសេចក្ដីស្លាប់ ទើបរត់ចេញទៅ សូមអ្នករត់ទៅចុះ កុំសង្ស័យឡើយ ហ្វូងម្រឹគទាំងឡាយនឹងរស់នៅជាមួយនឹងអ្នក ។

[ ២៣៤ ] ( ចិត្តៈម្រឹគជាប្អូនពោលថា ) បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំត្រូវសេចក្ដីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ ។

( រោហនៈ... ) មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំទេ នឹងស្លាប់មិនខាន អ្នកចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនឹងអ្នក ។

( ចិត្តកៈ... ) បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំ ត្រូវសេចក្ដីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបង ដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ ។

[ ២៣៥ ] ( រោហនៈម្រឹគពោលថា ) ម្នាលនាងជាអ្នកកិតភ័យ នាងចូរទៅចុះ រត់ទៅចុះ ខ្លួនយើងជាប់ក្នុងអន្ទាក់កោងគន្លឹះដែក ចូរនាងទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនាង ។

[ ២៣៦ ] ( សុតនាម្រឹគីពោលថា ) បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំ ត្រូវសេចក្ដីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់ ចោលអ្នកបងទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះឯង ។

( រោហនៈ... ) មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំ មុខ

ជានឹងស្លាប់មិនខាន នាងចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនឹងនាង ។

( សុតនាម្រឹគី... ) បពិត្រពោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំ ត្រូវសេចក្ដីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះឯង ។

[ ២៣៧ ] ( រោហនៈម្រឹគ... ) ព្រានណានឹងសម្លាប់យើងក្នុងថ្ងៃនេះដោយព្រួញ ឬដោយលំពែង ព្រាននោះមានរូបដ៏អាក្រក់ មានទាំងអាវុធជាប់ជាមួយ កំពុងដើរមក ។

[ ២៣៨ ] ( អភិសម្ពុទ្ធគាថា ) សុតនាម្រឹគីនោះជាសត្វកិតភ័យ លុះត្រូវភ័យគ្របសង្កត់គំរាមហើយ ក៏រត់ទៅអស់កាលមួយស្របក់ ត្រឡប់មកដើម្បីសេចក្ដីស្លាប់វិញ ឈ្មោះថា បានធ្វើនូវអំពើដ៏កម្រក្រៃពេក ។

[ ២៣៩ ] ( ព្រានសួរថា ) ម្រឹគទាំងនេះ ត្រូវជាអ្វីនឹងអ្នក រួចចាកអន្ទាក់ហើយ ចូលមករកអន្ទាក់វិញ ម្រឹគទាំងនោះ សូម្បីមានហេតុដល់ជីវិតក៏មិនប្រាថ្នាលះបង់អ្នក ។

[ ២៤០ ] ( រោហនៈម្រឹគ... ) ម្នាលព្រាន ម្រឹគទាំងនេះ ជាបងប្អូនរបស់ខ្ញុំ កើតក្នុងផ្ទៃជាមួយគ្នា មានមាតាតែមួយ សូម្បីមានហេតុដល់ជីវិតក៏មិនប្រាថ្នាលះបង់ចោលខ្ញុំ ។

[ ២៤១ ] ( ចិត្តៈម្រឹគ... ) ម្នាលព្រាន មាតាបិតាទាំងនោះ ជាសត្វខ្វាក់មិនមានអ្នកដឹកនាំ នឹងស្លាប់មិនខាន សូមអ្នកឲ្យនូវជីវិតដល់ម្រឹគទាំង ៥ សូម

អ្នកលែងរោហនៈម្រឹគ ជាបង់ឲ្យទាន ។

[ ២៤២ ] ( ព្រាន... ) ខ្ញុំនឹងលែងនូវម្រឹគដែលជាអ្នកចិញ្ចឹមនូវមាតាបិតា ឲ្យដល់អ្នកទាំងឡាយ មាតាបិតាចូររីករាយ ព្រោះឃើញនូវម្រឹគដ៏ប្រសើរដែលរួចហើយចុះ ។

[ ២៤៣ ] ( ចិត្តៈម្រឹគ... ) ម្នាលព្រាន ថ្ងៃនេះខ្លួនខ្ញុំត្រេកអរ ព្រោះបានឃើញនូវម្រឹគដ៏ប្រសើរដែលរួចហើយ យ៉ាងណា សូមអ្នកត្រេកអរ ជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះដែរ ។

[ ២៤៤ ] ( ម្រឹគជាមាតាសួរថា ) កាលបើជីវិតចូលទៅជិត ( កាន់សេចក្តីស្លាប់ ) ហើយ តើអ្នកបានរួចដោយហេតុអ្វី នែកូន ព្រានបានដោះអ្នកចេញចាកអន្ទាក់កោង តើដោយហេតុដូចម្តេច ។

[ ២៤៥ ] ( រោហនៈម្រឹគ... ) ចិត្តៈម្រឹគនិយាយពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ អាស្រ័យនូវហឫទ័យ បានដោះខ្ញុំ ( ចាកអន្ទាក់ ) ដោយពាក្យជាសុភាសិត ។ សុតនាម្រឹគីនិយាយពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ អាស្រ័យនូវហឫទ័យ បានដោះខ្ញុំ ( ចាកអន្ទាក់ ) ដោយពាក្យជាសុភាសិត ។ លុះព្រានបានស្តាប់ពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ អាស្រ័យនូវហឫទ័យហើយ ក៏បានដោះខ្ញុំ (ចាកអន្ទាក់) ព្រោះស្តាប់ពាក្យជាសុភាសិត ។

[ ២៤៦ ] ( ម្រឹគជាមាតាបិតាពោលថា ) ថ្ងៃនេះ យើងត្រេកអរ ព្រោះបានឃើញរោហនៈម្រឹគដែលមកដល់ យ៉ាងណា សូមឲ្យព្រានត្រេក

អរដោយកូនទិងប្រពន្ធទាំងឡាយ យ៉ាងនោះដែរ ។

[ ២៤៧ ] ( ព្រះរាជាត្រាស់សួរថា ) ម្នាលព្រាន អ្នកបាននិយាយថា ខ្ញុំព្រះអង្គនឹងនាំម្រឹគឬស្បែកម្រឹគមក មិនមែនឬ ចុះហេតុដូចម្តេច ទើបអ្នកមិននាំយកម្រឹគ ឬស្បែកម្រឹគមក ។

[ ២៤៨ ] ( ព្រាន... ) ម្រឹគនោះបានមកដល់កណ្តាប់ដៃ ជាប់នៅក្នុងអន្ទាក់កោងហើយ តែម្រឹគដទៃដែលផុត ( ចាកអន្ទាក់ ) ក៏ចូលមករកស្តេចម្រឹគនោះ ។ សេចក្តីតក់ស្លុត ការព្រួចព្រឺរោមដែលមិនធ្លាប់កើត ក៏កើតមានដល់ខ្ញុំព្រះអង្គនោះ ថាបើខ្ញុំព្រះអង្គនឹងសម្លាប់ម្រឹគនេះទៅ ខ្ញុំព្រះអង្គនឹងលះបង់នូវជីវិតក្នុងថ្ងៃនេះឯង ។

[ ២៤៩ ] ( ព្រះរាជា... ) ម្នាលព្រាន ពួកម្រឹគទាំងនោះមានអាការដូចម្តេច ពួកម្រឹគមានធម៌ដូចម្តេច មានវណ្ណៈដូចម្តេច មានសីលដូចម្តេច ទើបអ្នកសរសើរប្រាប់យើងខ្លាំងម្ល៉េះ ។

[ ២៥០ ] ( ព្រាន... ) ពួកម្រឹគទាំងនោះ មានស្នែងស មានរោមកន្ទុយស្អាត មានស្បែកឧបមាដូចមាស មានជើងក្រហម មានភ្នែកដ៏ថ្លាបីដូចជាគេបន្តក់ គួរជាទីរីករាយនៃចិត្ត ។

[ ២៥១ ] បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះ មានអាការដូច្នេះ ពួកម្រឹគមានធម៌ដូច្នេះ បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះជាសត្វចិញ្ចឹមមាតាបិតា ខ្ញុំព្រះអង្គមិនហ៊ាននាំយកម្រឹគទាំងនោះមកទេ ។

[ ២៥២ ] ( ព្រះរាជា... ) នែព្រាន យើងនឹងឲ្យនូវគ្រឿងក្រវិលនៃមាស

ជាច្រើនផង នូវកែវមណីនិងកុណ្ឌលដ៏ក្រាស់ក្រែលផង នូវបល្ល័ង្កប្អូនជ្រុងដ៏រុងរឿង ដូចជាផ្កាត្រកៀតផង ( ដល់អ្នក ) ។ ម្នាលព្រាន អ្នកមានឧបការៈច្រើនដល់យើង យើង ( នឹងឲ្យ ) នូវកិរិយាពីរនាក់ ដែលមានរូបនិងភោគសម្បត្តិប្រហែលគ្នាផង នូវគោមួយរយមានទាំងគោឧសភផង យើងនឹងសោយរាជ្យតាមធម៌ ។ ម្នាលព្រាន អ្នកចូរចិញ្ចឹមកូននិងប្រពន្ធដោយហេតុនេះគឺ កសិកម្ម ពាណិជ្ជកម្ម ឥណទានកម្ម ( ការបុល ) និងការស្វែងរកវរ ( ជាសម្មាអាជីវៈចុះ ) អ្នកកុំធ្វើនូវបាបទៀតឡើយ ។

## ចប់ រោហនមិគជាតកទី ៥

# អដ្ឋកថា

# រោហណមិគជាតក

[ ២៣៣-២៥២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលះបង់ជីវិតរបស់ព្រះអានន្ទ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯតេ យូថា បដិយន្តិ** ដូច្នេះជាដើម ។

ការលះបង់ជីវិតរបស់ព្រះអានន្ទនោះ ប្រាកដច្បាស់ក្នុងរឿងទូន្មានដំរីឈ្មោះធនបាល ក្នុងចុល្លហង្សជាតក អសីតិនិបាត កាលព្រះអានន្ទលះបង់ជីវិតដើម្បីការពារព្រះសាស្តាយ៉ាងនេះហើយ ភិក្ខុទាំងឡាយក៏សន្ទនាគ្នា ក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះអានន្ទជាសេក្ខបុគ្គល សម្រេចបដិសម្ភិទា រមែងលះបង់ជីវិត ដើម្បីជាប្រយោជន៍ដល់ព្រះទសពល ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទក៏ធ្លាប់លះបង់ជីវិត ដើម្បីប្រយោជន៍ដល់តថាគតដូចគ្នា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ទ្រង់មានអគ្គមហេសីព្រះនាមថាខេមា ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតម្រឹគ មានពណ៌ដូចមាស នៅក្នុងហិមវន្តប្បទេស សូម្បីប្អូនប្រុសរបស់ព្រះពោធិសត្វឈ្មោះចិត្តមិគ ក៏ជាសត្វដល់នូវភាពស្អាត មានពណ៌ដូច

មាសដូចគ្នា ម្រឹគញីប្អូនព្រះពោធិសត្វឈ្មោះថាសុតនា ក៏ជាសត្វមានពណ៌សម្បុរដូចមាសដូចគ្នា ។ ឯព្រះមហាសត្វជាស្តេចម្រឹគ ឈ្មោះរោហនមិគរាជ ស្តេចម្រឹគនោះមានម្រឹគ ៨ ម៉ឺនជាបរិវារ សម្រេចការនៅអាស្រ័យស្រះឈ្មោះរោហនៈ ក្នុងរវាងភ្នំជាន់ទី ៣ រំលងភ្នំ ២ ក្នុងហិមវន្តប្បទេស ។ ស្តេចម្រឹគរោហនៈចិញ្ចឹមមាតាបិតាដែលចាស់ជរាភ្នែកខ្វាក់ ។

កាលនោះ មានកូនព្រានព្រៃម្នាក់ ក្នុងនេសាទគាម មិនឆ្ងាយអំពីនគរពារាណសីនោះ ចូលទៅកាន់ហិមវន្តប្បទេស ជួបមហាសត្វ ហើយត្រឡប់មកផ្ទះរបស់ខ្លួន ក្រោយមក កាលធ្វើកាលកិរិយា ទើបប្រាប់ដល់កូនប្រុសរបស់ខ្លួនថា នែបា ក្នុងទីឈ្មោះនោះ ជាទីកដីសម្រាប់រកស៊ីរបស់ពួកយើង មានម្រឹគពណ៌មាសអាស្រ័យនៅ បើព្រះរាជាត្រាស់សួរ គប្បីក្រាបទូលឲ្យទ្រង់ជ្រាប ។

ថ្ងៃមួយ ព្រះនាងខេមាបរមរាជទេវី សុបិនក្នុងពេលទៀបភ្លឺ ប្រាកដឡើងថា មានស្តេចម្រឹគពណ៌ដូចមាស ឈរលើព្រះទែនមាសសម្តែង ធម៌ដល់ព្រះនាង ដោយសំឡេងដ៏ពីរោះ ដូចបុគ្គលគោះកណ្តឹងមាស ព្រះនាងប្រទានសាធុការ ហើយស្តាប់ព្រះធម្មទេសនា កាលធម្មកថាមិនទាន់ចប់ ម្រឹគមាសនោះក៏ដើរចេញទៅ ។ ឯព្រះទេវីក៏មានព្រះសវនីយ៍ត្រាស់ថា អ្នកទាំងឡាយចូរនាំគ្នាចាប់ម្រឹគ អ្នកទាំងឡាយចូរនាំគ្នាចាប់ម្រឹគ រហូតដល់ភ្ញាក់អំពីបន្ទំ ។ ពួកស្រីស្នំបានឮសំឡេងព្រះនាង នាំគ្នាសួរថា ទ្វារបង្អួចទីបន្ទំបិទអស់ហើយ សូម្បីមនុស្សក៏មិនមានឱកាសចូលទៅបាន ព្រះនាងត្រាស់ឲ្យចាប់

ម្រឹគក្នុងពេលនេះទៅកើត ។ គ្រានោះ ព្រះនាងក៏ដឹងខ្លួនថា នេះជាការយល់សប្តិ ទើបព្រះនាងព្រះតម្រិះថា បើអញក្រាបទូលព្រះរាជាថា អញយល់សប្តិឃើញបែបនេះ ទ្រង់នឹងមិនយកចិត្តទុកដាក់ តែបើអញក្រាបទូលថា ចាញ់ព្រះគភ៌ ទ្រង់នឹងជួយស្វែងរកមកឲ្យដោយការយកចិត្តទុកដាក់ អញនឹងបានស្តាប់ធម៌របស់ស្តេចម្រឹគមាស ទើបនាងផ្តុំ ឲ្យសញ្ញាដល់ពួកស្រីស្នំថា យើងប្រឈួន ។ ព្រះរាជាយាងមកត្រាស់សួរថា នែព្រះនាងមានភក្ត្រដ៏ចម្រើននាងមិនសប្បាយ នាងមានរឿងអ្វីឬ ព្រះទេវីក្រាបទូលថា បពិត្រព្រះអង្គ អ្នកទ្រទ្រង់នូវគុណដ៏ប្រសើរ រោគដទៃមិនមានទេ តែខ្ញុំម្ចាស់ចាញ់ព្រះគភ៌ ។ ព្រះរាជាត្រាស់សួរថា នាងចង់បានអ្វី ព្រះនាងក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ប្រាថ្នានឹងស្តាប់ធម៌របស់ស្តេចម្រឹគដែលមានពណ៌ដូចមាស ។ ព្រះរាជាត្រាស់ថា នែនាងមានភក្ត្រដ៏ចម្រើន វត្ថុណាមិនមាន នាងកើតចាញ់ផ្ទៃ ត្រូវការវត្ថុនោះឬ ឈ្មោះថាម្រឹគមានពណ៌ដូចមាស មិនមានទេ ព្រះនាងក្រាបទូលថា បើខ្ញុំម្ចាស់មិនបាន នឹងដេកស្លាប់ក្នុងទីនេះឯង ហើយបែរខ្នងឲ្យព្រះរាជា ហើយផ្ទុំធ្វើព្រងើយ ។ ព្រះរាជាទ្រង់លួងលោមថា បើម្រឹគពណ៌មាសមាន នាងនឹងបាន ហើយគង់ប្រថាប់កណ្តាលបរិស័ទ ត្រាស់សួរពួកអាមាត្យនិងពួក ព្រាហ្មណ៍តាមន័យដែលពោលហើយ ក្នុងមោរជាតកនោះឯង ទ្រង់បានឮថា ម្រឹគមានពណ៌ដូចមាសមាន ទើបត្រាស់ឲ្យពួកនាយព្រានប្រជុំគ្នាសួរថា ម្រឹគមានពណ៌ដូចមាសបែបនេះ អ្នកណាធ្លាប់ឃើញ ធ្លាប់បានឮមកខ្លះ កាលកូននាយនេសាទក្រាបទូលដោយទំនងដែលខ្លួនបានឮមកអំពីសម្នាក់

ឪពុកហើយ ទើបត្រាស់ថា នែសម្លាញ់ បើឯងនាំម្រឹគនោះមកបាន យើងនឹងធ្វើសក្ការៈធំដល់ឯង ចូរឯងទៅចុះ នាំម្រឹគនោះមក ទ្រង់ព្រះរាជទានស្បៀងហើយ ក៏បញ្ជូនបុរសនោះទៅ ។ ឯកូននាយនេសាទក្រាបទូលថា បពិត្រព្រះអង្គ អ្នកទ្រទ្រង់គុណដ៏ប្រសើរ បើទូលព្រះបង្គំមិនអាចនាំម្រឹគមាសនោះមកថ្វាយបាន ទូលព្រះបង្គំនឹងនាំស្បែកមកថ្វាយ បើមិនអាចនាំស្បែកមកថ្វាយបាន ក៏នឹងនាំរោមមកថ្វាយ សូមទ្រង់កុំព្រះវិតក្កឡើយ ហើយទៅកាន់ផ្ទះ ប្រគល់ស្បៀងអាហារដល់កូនប្រពន្ធ ហើយទៅកាន់ហិមវន្តប្បទេស ឃើញស្តេចម្រឹគនោះហើយគិតថា អញនឹងដាក់អន្ទាក់ក្នុងទីណាហ្ន៎ ទើបអាចចាប់ម្រឹគនេះបាន កាលពិចារណា ឃើញឱកាសត្រង់កំពង់ទឹក ទើបគេវេញខ្សែស្បែក ធ្វើជាអន្ទាក់យ៉ាងមាំ ហើយបោះបង្គោលដាក់អន្ទាក់ក្នុងទីដែលព្រះពោធិសត្វចុះផឹកទឹក ។

ស្អែកឡើង ព្រះពោធិសត្វនិងបរិវារ ៨ ម៉ឺន ត្រាច់ទៅស្វែងរកអាហារ គិតថា អញនឹងផឹកទឹកត្រង់កំពង់មុននោះឯង ទើបទៅត្រង់កំពង់នោះ គ្រាន់តែឈានជើងចុះប៉ុណ្ណោះ អន្ទាក់ក៏ជាប់ ព្រះមហាសត្វត្រិះរិះថា បើអញស្រែកថា ជាប់អន្ទាក់ ក្នុងឥឡូវនេះ ពួកញាតិរបស់អញនឹងមិនផឹកទឹក នាំគ្នាភ័យខ្លាចរត់គេចទៅ ទើបផ្អាកមកជិតបង្គោលបិទបាំងទុកដោយខ្លួន ធ្វើដូចកំពុងផឹកទឹក កាលម្រឹគទាំង ៨ ម៉ឺន ផឹកទឹកឡើងទៅហើយ គិតថា អញនឹងកាត់អន្ទាក់ឲ្យដាច់ ទើបស្ទុះ ៣ ដង លើកទី ១ អន្ទាក់មុតស្បែក លើកទី ២ មុតសាច់ លើកទី ៣ ក៏មុតសរសៃ អន្ទាក់ក៏លុះដល់ឆ្អឹង ។ ព្រះមហាសត្វ

មិនអាចកាត់អន្ទាក់ឲ្យដាច់បាន ទើបស្រែកឡើងថា យើងជាប់អន្ទាក់ហើយ ពួកម្រឹគទាំងឡាយតក់ស្លុត នាំគ្នាគេចទៅជា ៣ ក្រុម ចិត្តម្រឹគមិនឃើញព្រះមហាសត្វក្នុងហ្វូងម្រឹគទាំង ៣ ទើបគិតថា កាលភ័យនេះកើត គង់នឹងកើតដល់បងប្រុសរបស់អញ ទើបមកកាន់សម្នាក់របស់ស្តេចម្រឹគនោះ ក៏ឃើញព្រះមហាសត្វជាប់អន្ទាក់ ។

លំដាប់នោះ ព្រះមហាសត្វឃើញចិត្តម្រឹគ ទើបពោលថា នែប្អូនប្រុសឯងកុំមកឈរក្នុងទីនេះ ទីនេះគួររង្កៀស កាលបញ្ជូនប្រឡប់ទៅ ទើបពោលគាថាដំបូងថា

ម្នាលចិត្តកៈ ហ្វូងម្រឹគទាំងនេះ ខ្លាចសេចក្តីស្លាប់ទើបរត់ចេញទៅ សូមអ្នករត់ទៅចុះ កុំសង្ស័យឡើយ ហ្វូងម្រឹគទាំងឡាយនឹងរស់នៅជាមួយនឹងអ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតេ** ស្តេចម្រឹគពោលដល់ហ្វូងម្រឹគដែលគេចផុតអំពីគន្លងចក្ខុរបស់ខ្លួនទៅឆ្ងាយ ។ បទថា **បជិយន្តិ** បានដល់ ត្រឡប់ទៅ អធិប្បាយថា បែកខ្ញែកគ្នារត់ទៅ ។ ព្រះពោធិសត្វហៅប្អូនប្រុសថា ចិត្តកៈ ។ បទថា **តយា សហ** សេចក្តីថា ព្រះពោធិសត្វពោលថា នែចិត្តកៈ ចូរឯងជាស្តេចនៃម្រឹគទាំងនេះ ចូរតាំងនៅក្នុងតំណែងជំនួសអញ ម្រឹគទាំងនេះ នឹងនៅជាមួយឯងតទៅ ។ បន្ទាប់អំពីនោះ ជាគាថាដែលម្រឹគទាំង ២ សន្ទនាគ្នាជាលំដាប់ដោយគាថា ៣ ថា

បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំត្រូវសេចក្តីសោក

ទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ ។

រោហនៈម្រឹគពោលថា

មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំទេ នឹងស្លាប់មិនខាន អ្នកចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនឹងអ្នក ។

ចិត្តម្រឹកពោលថា

បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំ ត្រូវសេចក្តីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបង ដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រោហន** សេចក្តីថា ចិត្តកៈម្រឹគហៅ ព្រះមហាសត្វដោយឈ្មោះថា រោហនៈ ។ បទថា **អវកស្សតិ** សេចក្តីថា បុគ្គលណាម្នាក់ ទោះមកអូសទាញ គឺមកទាញយកបេះដូងទៅ ឬបេះដូងត្រូវសេចក្តីសោកអូសទាញទៅ ។ បទថា **តេ ហិ នូន** សេចក្តីថា មាតាបិតារបស់យើងទាំងនោះ កាលយើងទាំងពីរស្លាប់រួមគ្នាក្នុងទីនេះ នឹងមិនមានអ្នកជួយសង្គ្រោះនាំផ្លូវ កាលមិនមានអ្នកណាបដិបត្តិ និងស្គមស្គាំងស្លាប់ទៅ ព្រោះហេតុនោះនែចិត្តកៈ ចូរឯងទៅចុះ ម្រឹគទាំងនោះនឹងមានជីវិតនៅជាមួយឯង ។ បទថា **ឥធ ហេស្សាមិ** សេចក្តីថា ខ្ញុំនឹងលះបង់ជីវិតក្នុងទីនេះឯង ។

កាលចិត្តម្រឹគពោលដូច្នេះហើយ ក៏ដើរទៅផ្អែកខាងស្តាំព្រះពោធិសត្វ

លួងលោមឲ្យតម្កល់កាយសប្បាយចិត្ត ឯម្រឹគញីឈ្មោះសុតនា គេចទៅមិនឃើញបងប្រុសទាំងទ្វេក្នុងរវាងហ្វូងម្រឹគគិតថា ភ័យនេះនឹងកើតដល់បងប្រុសទាំង ២ របស់អញ ទើបវិលត្រឡប់មកកាន់សម្នាក់របស់ម្រឹគទាំង ២ នោះ មហាសត្វឃើញសុតនាម្រឹគកំពុងដើរមក ទើបពោលគាថាទី ៥ ថា

ម្នាលនាងជាអ្នកកិតភ័យ នាងចូរទៅចុះ រត់ទៅចុះ ខ្ញុំនយើង
ជាប់ក្នុងអន្ទាក់កោងគន្ទឹះដែក ចូរនាងទៅចុះ កុំសង្ស័យឡើយ
មាតាបិតានឹងរស់នៅជាមួយនាង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភីរុ** សេចក្ដីថា ឈ្មោះថា មាតុគ្រាមតែងភ័យខ្លាចដោយហេតុត្រឹមតែបន្តិចបន្តួច ដោយហេតុនោះ ទើបព្រះពោធិសត្វហៅប្អូនស្រីយ៉ាងនេះ ។ បទថា **ក្សាជេ** បានដល់ អន្ទាក់ដែលបិទបាំងទុក ។ បទថា **អាយសេ** សេចក្ដីថា អន្ទាក់នោះ គេដាក់ខ្សែដែកទុកក្នុងទឹក ហើយចងនឹងបង្គោលខ្លឹមដែលបោះទុកក្នុងទឹកនោះ ព្រោះហេតុនោះ ទើបព្រះមហាសត្វពោលយ៉ាងនេះ ។ បទថា **តយា សហា** សេចក្ដីថា ម្រឹគទាំង ៨ ម៉ឺននោះនឹងមានជីវិតនៅជាមួយនាង ។

ខាងមុខអំពីនោះ មាន ៣ គាថា ដែលម្រឹគបងប្អូនឆ្លើយឆ្លងគ្នាដោយន័យមុននោះឯងថា

បពិត្រពេហន: ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំ ត្រូវសេចក្ដី
សោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់ចោលអ្នកបងទេ ខ្ញុំនឹងសុំ
លះបង់ជីវិតក្នុងទីនេះឯង ។

រោហនៈម្រឹគពោលថា

មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំ មុខជានឹង
ស្លាប់មិនខាន នាងចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹង
រស់នៅជាមួយនឹងនាង ។

សុតនាម្រឹគីពោលថា

បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំត្រូវសេចក្ដីសោក
ទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូ
លះបង់ជីវិតក្នុងទីនេះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេ ហិ ឆ្វន** នេះ ព្រះពោធិសត្វពោលដល់
មាតាបិតាប៉ុណ្ណោះ ។ សូម្បីនាងសុតនាម្រឹគីនោះ កាលបដិសេធយ៉ាងនោះ
ហើយ ទើបចូលទៅឈរផ្អែកខាងឆ្វេងព្រះមហាសត្វ ដើម្បីលួងចិត្តបងប្រុស
ឯព្រានឃើញម្រឹគទាំងនោះគេចទៅ និងបានឮសំឡេងស្រែករបស់ម្រឹគដែល
ជាប់អន្ទាក់ គិតថា ស្ដេចម្រឹគគង់នឹងជាប់អន្ទាក់ ហើយស្លៀកសំពត់យ៉ាងជាប់
កាន់លំពែង សម្រាប់សម្លាប់ម្រឹគរត់មកដោយរហ័ស ព្រះមហាសត្វឃើញ
ព្រានកំពុងរត់មក ទើបពោលគាថាទី ៩ ថា

ព្រានណានឹងសម្លាប់យើងក្នុងថ្ងៃនេះ ដោយព្រួញ ឬដោយ
លំពែង ព្រាននោះមានរូបដ៏អាក្រក់ មានទាំងអាវុធជាប់ជា
មួយ កំពុងដើរមក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លុទ្ធរោ** បានដល់ ជាបុគ្គលកាចឃោរ

យៅ ។ បទថា **សត្តិយាមបិ** សេចក្ដីថា ព្រានណានឹងប្រហារ គឺសម្លាប់យើងដោយព្រួញក្ដី ដោយលំពែងក្ដី ព្រាននោះមានរូបអាក្រក់ កាចគួរស្ញើមកាន់អាវុធមក ព្រោះហេតុនោះ ឯងទាំង ២ ចូរនាំគ្នាគេចទៅ ទាន់ព្រានមិនទាន់មកដល់ ។

ចិត្តម្រឹគឃើញព្រាននោះហើយ ក៏មិនបានគេចទៅ ឯនាងសុតនាម្រឹគីមិនអាចតាំងនៅដោយសភាវៈរបស់ខ្លួនបាន មានសេចក្ដីតក់ស្លុតចំពោះមរណភ័យ រត់ទៅបន្តិច ហើយត្រឡប់មក គិតថា អញបោលបងប្រុសទាំង ២ ទៅណា ទើបព្រមលះបង់ជីវិតរបស់ខ្លួន អត់ធ្មត់ចំពោះសេចក្ដីស្លាប់ ត្រឡប់មកជាថ្មី ឈរផ្អែកខាងឆ្វេងបងប្រុសរបស់ខ្លួន ។

កាលប្រកាសសេចក្ដីនោះ ទើបព្រះសាស្ដាត្រាស់គាថាទី ១០ ថា

សុតនាម្រឹគីនោះជាសត្វកិតភ័យ លុះត្រូវភ័យគ្របសង្កត់គំរាម
ហើយក៏រត់ទៅអស់កាលមួយស្របក់ ត្រឡប់មកដើម្បីសេចក្ដី
ស្លាប់វិញ ឈ្មោះថា បានធ្វើនូវអំពើដ៏កម្រក្រៃពេក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មរណាយូបនិវត្តថ** សេចក្ដីថា វិលត្រឡប់មកដើម្បីសេចក្ដីស្លាប់ ។

ឯព្រានមកហើយឃើញសត្វទាំង ៣ ឈរប្រឈមមុខគ្នា ក៏កើតមេត្តាចិត្ត មានសេចក្ដីសម្គាល់ថា ហាក់ដូចបងប្អូនដែលកើតក្នុងផ្ទៃតែមួយ ទើបគិតថា ស្ដេចម្រឹគជាប់អន្ទាក់អញមុន តែម្រឹគទាំង ២ នេះ ជាប់ដោយហិរិ-ឱត្តប្បៈ សត្វទាំង ២ នេះ ត្រូវជាអ្វីនឹងស្ដេចម្រឹគនេះហ្ន៎ កាលសួរហេតុ

នោះ ទើបពោលគាថានេះថា

ម្រឹគទាំងនេះត្រូវជាអ្វីនឹងអ្នក រួចចាកអន្ទាក់ហើយ ចូលមក
រកអន្ទាក់វិញ ម្រឹគទាំងនោះ សូម្បីមានហេតុដល់ជីវិត ក៏មិន
ប្រាថ្នាលះបង់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្នុ តេមេ** កាត់បទជា **កឹ នុ តេ ឥមេ** ប្រែថា ម្រឹគទាំង ២ នេះ ជាអ្វីនឹងអ្នកហ្ន៎ ។ បទថា **ឧបាសរេ** បានដល់ នៅតែចូលទៅជិត ។

លំដាប់នោះ ទើបព្រះពោធិសត្វប្រាប់ដល់នាយព្រានថា

ម្នាលព្រាន ម្រឹគទាំងនេះ ជាបងប្អូនរបស់ខ្ញុំ កើតក្នុងផ្ទៃជា
មួយគ្នា មានមាតាតែមួយ សូម្បីមានហេតុដល់ជីវិត ក៏មិន
ប្រាថ្នាលះបង់ចោលខ្ញុំ ដូច្នេះ ។

នាយព្រានស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ ជាអ្នកមានចិត្តទោរទន់ជាខ្លាំង ។ ចិត្តមិគរាជដឹងថានាយព្រានមានចិត្តទន់ហើយ ទើបពោលថា នែព្រានសម្លាញ់ អ្នកកុំសម្គាល់ស្តេចម្រឹគនេះថា ត្រឹមតែជាម្រឹគសាមញ្ញប៉ុណ្ណោះពិតហើយ ស្តេចម្រឹគនេះ ជាស្តេចនៃម្រឹគ ៨ ម៉ឺន ដល់ព្រមដោយសីលនិងមារយាទ មានចិត្តទន់ភ្លន់ក្នុងសព្វសត្វ មានបញ្ញាច្រើន ចិញ្ចឹមមាតាបិតាដែលខ្វាក់ ហើយចាស់ជរា បើអ្នកសម្លាប់ម្រឹគដែលតាំងនៅក្នុងធម៌បែបនេះឲ្យស្លាប់ ឈ្មោះថា សម្លាប់ពួកយើងឲ្យអស់ជីវិតទាំង ៥ គឺមាតាបិតារបស់ខ្ញុំ ខ្លួនខ្ញុំ និងប្អូនស្រីខ្ញុំនោះឯង តែបើអ្នកឲ្យជីវិតដល់បងប្រុសរបស់ខ្ញុំឈ្មោះ

ថា ឲ្យជីវិតដល់ពួកយើងទាំង ៥ ហើយពោលគាថានេះថា

> ម្នាលព្រាន មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំ នឹងស្លាប់មិនខាន សូមអ្នកឲ្យនូវជីវិតដល់ម្រឹគទាំង ៥ សូមអ្នកលែងរោហនៈម្រឹគជាបងឲ្យទាន ដូច្នេះ ។

នាយព្រានបានស្តាប់ធម្មកថារបស់ចិត្តកម្រឹគហើយ មានចិត្តជ្រះថ្លា បានពោលថា ចូរអ្នកកុំខ្លាចឡើយ ហើយពោលគាថាជាលំដាប់ទៅថា

> ខ្ញុំនឹងលែងនូវម្រឹគដែលជាអ្នកចិញ្ចឹមនូវមាតាបិតា ឲ្យដល់អ្នកទាំងឡាយ មាតាបិតាចូររីករាយ ព្រោះឃើញនូវម្រឹគដ៏ប្រសើរដែលរួចហើយចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេ** ត្រឹមតែជានិបាត ។ បទថា **ទិស្វា** សេចក្តីថា ឃើញស្តេចម្រឹគរួចហើយចាកអន្ទាក់ ។

នាយព្រាន កាលពោលយ៉ាងនេះហើយ គិតថា យសដែលព្រះរាជា ព្រះរាជទានហើយ នឹងជួយអ្វីអញបាន បើអញសម្លាប់ម្រឹគនេះចោល ផែនដីនេះនឹងរហែកឲ្យឱកាសដល់អញ បើមិនដូច្នោះ អសនីបាតនឹងធ្លាក់លើអំបែងក្បាលរបស់អញ អញនឹងលែងស្តេចម្រឹគនោះ ។ ទើបព្រានចូលទៅរកមហាសត្វ ហើយពោលថា យើងនឹងធ្វើដងអន្ទាក់ឲ្យដួល ហើយកាត់នូវខ្សែស្បែកដូច្នេះហើយ លើកស្តេចម្រឹគដែលកំពុងទន់ខ្សោយសន្សឹមៗ ស្រាយអន្ទាក់ដោយមុទិតាចិត្ត ធ្វើសរសៃឲ្យជាប់នឹងសរសៃ សាច់ជាប់នឹងសាច់ ស្បែកជាប់នឹងស្បែក យកទឹកលាងឈាម បបោសអង្អែលទៅមកដោយមេត្តាចិត្ត ។

ដោយអានុភាពនៃមេត្តាចិត្តរបស់ព្រាន និងដោយអានុភាពនៃបារមីដែលព្រះមហាសត្វបានបំពេញមក សរសៃ ស្បែក និងសាច់ទាំងអស់ ក៏សះដូចដើម ជើងក៏មានស្បែកនិងរោមបិទបាំងជិតល្អ ក្នុងអវយវៈដែលមានដំបៅអំពីមុន មិនមានប្រាកដស្លាកស្នាមឡើយ ។ ព្រះមហាសត្វ ដល់នូវសេចក្តីសុខ ផុតភ័យ ក្រោកឡើងឈរហើយ ។ ចិត្តម្រឹគឃើញហេតុនោះហើយ កើតនូវសោមនស្ស កាលនឹងធ្វើអនុមោទនាចំពោះព្រាន បានពោលគាថានេះថា

ម្នាលព្រាន ថ្ងៃនេះខ្លួនខ្ញុំត្រេកអរ ព្រោះបានឃើញនូវម្រឹគដ៏
ប្រសើរដែលរួចហើយ យ៉ាងណា សូមអ្នកត្រេកអរ ជាមួយ
នឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វគិតថា ព្រាននេះ កាលនឹងចាប់អញ ចាប់ដោយការចិញ្ចឹមជីវិតរបស់ខ្លួន ឬចាប់ដោយបញ្ជារបស់អ្នកដទៃ ទើបសួរហេតុដែលចាប់ ។ កូននាយព្រានឆ្លើយថា បពិត្រស្តេចម្រឹគ ខ្ញុំមានកិច្ចកម្ម ដែលទាក់ទងនឹងអ្នកក៏មិនមែន តែអគ្គមហេសីរបស់ព្រះរាជាព្រះនាមថា ខេមា រាជទេវី មានបំណងនឹងស្តាប់ធម្មកថារបស់អ្នក ទើបអ្នកត្រូវខ្ញុំចាប់ដោយ ព្រះរាជឱង្ការ ដើម្បីជាប្រយោជន៍ដល់ព្រះទេវីនោះ ។ ព្រះមហាសត្វពោលថា នែសម្លាញ់ បើដូច្នោះ អ្នកដោះលែងខ្ញុំ ឈ្មោះថា ធ្វើវត្ថុដែលគេធ្វើបានកម្រក្រៃលែង មកសូមនាំខ្ញុំទៅសម្តែងធម៌ដល់ព្រះបរមក្សត្រចុះ ខ្ញុំនឹងសម្តែងធម៌ថ្វាយព្រះទេវី ។ នាយព្រានពោលថា ធម្មតាព្រះរាជាទាំងឡាយ មានចិត្តរឹងរូសក្រៃលែង អ្នកណានឹងដឹងថា មានអ្វីកើតឡើង ខ្ញុំមិនត្រេកអរនឹង

យសសក្តិដែលព្រះរាជាប្រទានទេ ចូរអ្នកទៅតាមសប្បាយរបស់អ្នកចុះ ព្រះមហាសត្វគិតថា ព្រាននេះ កាលលែងអញទៅ ឈ្មោះថា ធ្វើកិច្ចដែលធ្វើបានដោយក្រក្រៃលែង អញនឹងធ្វើឧបាយឲ្យព្រាននោះ បានទទួលយសសក្តិ ហើយទើបពោលថា នែសម្លាញ់ សូមលោកយកដៃស្ទាបខ្នងរបស់ខ្ញុំសិនចុះ ។ ទើបនាយព្រានយកដៃស្ទាបខ្នងស្តេចម្រឹគ ដៃរបស់ព្រាន ពេញទៅដោយរោមដែលមានពណ៌ដូចមាស ទើបសួរថា នែស្តេចម្រឹគ ខ្ញុំនឹងធ្វើដូចម្តេចជាមួយរោមទាំងនេះ ស្តេចម្រឹគក៏ប្រាប់ថា នែសម្លាញ់ សូមអ្នកយករោមទាំងនេះទៅ ថ្វាយព្រះរាជានិងព្រះរាជទេវី ទូលថា នេះជារោមរបស់សុវណ្ណម្រឹគនោះ ដូច្នេះ តាំងនៅក្នុងឋានៈជំនួសខ្ញុំ សម្តែងធម្មកថាថ្វាយព្រះបរមរាជទេវីដោយគាថាទាំងនេះ ការចាញ់ព្រះគភ៌របស់ព្រះនាងក៏នឹងស្ងប់ ព្រោះស្តាប់ធម្មកថានោះឯង ដូច្នេះហើយ ឲ្យព្រានរៀនរាជធម្មគាថា ១០ មានជាដើមថា **ធម្មញ្ចរ មហារាជ** ដែលប្រែថា បពិត្រមហារាជ ព្រះរាជាគប្បីប្រព្រឹត្តធម៌ដូច្នេះហើយ ឲ្យនូវបញ្ចសីល ពោលទូន្មានដោយអប្បមាទធម៌ ហើយបញ្ជូនទៅ ។

កូនរបស់នាយព្រានសរសើរព្រះមហាសត្វ ទុកក្នុងតំណែងអាចារ្យ ធ្វើប្រទក្សិណ ៣ ដង ហើយថ្វាយបង្គំក្នុងឋានៈ ៤ យកស្លឹកឈើខ្ចប់រោមមាសទាំងឡាយ ហើយចៀសចេញទៅ ។ ម្រឹគទាំង ៣ ជូនដំណើរព្រានព្រៃបន្តិចហើយ យកមាត់ពាំអាហារនិងទឹក នាំគ្នាត្រឡប់ទៅកាន់សម្នាក់របស់មេបា ។ មេបាទាំង ២ កាលនឹងសួរថា នែពោហនៈកូនសម្លាញ់ បានឮថា

អ្នកជាប់អន្ទាក់ ហើយរួចមកបានដូចម្តេច ទើបពោលគាថានេះថា

កាលបើជីវិតចូលទៅជិត ( កាន់សេចក្តីស្លាប់ ) ហើយ តើ
អ្នកបានរួចដោយហេតុអ្វី នែកូន ព្រានបានដោះអ្នកចេញចាក
អន្ទាក់កោង តើដោយហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបនីតស្មិ** សេចក្តីថា មានជីវិតស្ថិតនៅចំពោះមច្ចុ ឯងរួចអំពីស្លាប់មកបានដូចម្តេច ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ បានពោលគាថា ៣ ដូច្នេះថា

ចិត្តៈម្រឹគនិយាយពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅ
កាន់ហឫទ័យ អាស្រ័យនូវហឫទ័យ បានដោះខ្ញុំ ( ចាកអន្ទាក់ )
ដោយពាក្យជាសុភាសិត ។ សុតនាម្រឹគីនិយាយពាក្យជាសុខ
ដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ អាស្រ័យនូវហឫ
ទ័យ បានដោះខ្ញុំ ( ចាកអន្ទាក់ ) ដោយពាក្យជាសុភាសិត ។
លុះព្រានបានស្តាប់ពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅ
កាន់ហឫទ័យ អាស្រ័យនូវហឫទ័យហើយ ក៏បានដោះខ្ញុំ ( ចាក
អន្ទាក់ ) ព្រោះស្តាប់ពាក្យជាសុភាសិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភណំ** បានដល់ ពោល ។ បទថា **ហទយង្គមំ** បានដល់ ចូលទៅក្នុងហឫទ័យ ។ បទថា **ភណំ** ក្នុងគាថាទី ២ ស្មើគ្នានឹង **ភណមានា** ប្រែថា កាលនាងសុតនាកំពុងពោល ។ បទថា **សុត្វា** សេចក្តីថា ព្រាននោះស្តាប់វាចារបស់ម្រឹគទាំង ២ នេះហើយ ។

គ្រានោះ កាលមាតាបិតាព្រះពោធិសត្វ នឹងអនុមោទនា ក៏ពោលថា

ថ្ងៃនេះ យើងត្រេកអរ ព្រោះបានឃើញពោហនៈម្រឹគដែលមក

ដល់ យ៉ាងណា សូមឲ្យព្រានត្រេកអរដោយកូននិងប្រពន្ធ

ទាំងឡាយ យ៉ាងនោះដែរ ដូច្នេះ ។

ឯព្រានចេញអំពីព្រៃហើយ ទៅកាន់រាជត្រកូល ថ្វាយបង្គំព្រះរាជា ឈរក្នុងទីសមគួរ នាចំណែកម្ខាង ព្រះរាជាឃើញហើយ ត្រាស់សួរថា

ម្នាលព្រាន អ្នកបាននិយាយថា ខ្ញុំព្រះអង្គនឹងនាំម្រឹគ ឬស្បែក

ម្រឹគមក មិនមែនឬ ចុះហេតុដូចម្ដេច ទើបអ្នកមិននាំយកម្រឹគ

ឬស្បែកម្រឹគមក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មិគចម្មានិ** បានដល់ ម្រឹគ ឬស្បែក ។ បទថា **អាហរឹ** បានដល់ នឹងនាំមក លោកពោលអធិប្បាយទុកថា នែព្រានដ៏ចម្រើន អ្នកបានពោលទុកយ៉ាងនេះមិនមែនឬថា បើមិនអាចនាំម្រឹគមក ក៏នឹងនាំស្បែកមក កាលមិនអាចនាំស្បែកមក ក៏នឹងនាំរោមមក ព្រោះហេតុអ្វី ទើបមិនបាននាំម្រឹគ ឬស្បែករបស់ម្រឹគមក ។ ព្រានបានស្ដាប់ ព្រះតម្រាស់ហើយ ក្រាបទូលថា

ម្រឹគនោះបានមកដល់កណ្ដាប់ដៃ ជាប់នៅក្នុងអន្ទាក់កោងហើយ

តែម្រឹគដទៃដែលផុត ( ចាកអន្ទាក់ ) ក៏ចូលមករកស្ដេចម្រឹគ

នោះ ។ សេចក្ដីតក់ស្លុត ការព្រួចព្រឺរោម ដែលមិនធ្លាប់កើត

ក៏កើតមានដល់ខ្ញុំព្រះអង្គនោះ ថាបើខ្ញុំព្រះអង្គ នឹងសម្លាប់ម្រឹគ

នេះទៅ ខ្ញុំព្រះអង្គនឹងលះបង់នូវជីវិតក្នុងថ្ងៃនេះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាគមំ** សេចក្តីថា បពិត្រមហារាជ ម្រឹគនោះមកកាន់កណ្តាប់ដៃ ទាំងមកកាន់អន្ទាក់ដែលទូលព្រះបង្គំដាក់ បានជាប់អន្ទាក់នោះ ។ បទថា **តញ្ច មុត្តា ឧបាសរេ** សេចក្តីថា តែម្រឹគទាំង ២ ដែលមិនជាប់អន្ទាក់ មិនបានចូលក្នុងអន្ទាក់ បានមកឈរជិតម្រឹគនោះ ជួយលួងលោម ។ បទថា **អព្ភុតោ** បានដល់ មិនធ្លាប់កើតមកអំពីមុន ។ បទថា **ឥមញ្ចាហំ** កាត់បទជា **ឥមំ ច អហំ** ប្រែថា ខ្ញុំព្រះអង្គនោះ អធិប្បាយថា កាលបើដូច្នោះ ខ្ញុំជាអ្នកមានសេចក្តីសង្វេគ មានបរិវិតក្កនេះថា បើអញសម្លាប់ម្រឹគនេះ អញនឹងលះបង់ជីវិតក្នុងទីនេះឯង និងក្នុងថ្ងៃនេះឯង ។ ព្រះរាជាស្តាប់ដូច្នោះហើយត្រាស់ថា

ម្នាលព្រាន ពួកម្រឹគទាំងនោះមានអាការដូចម្តេច ពួកម្រឹគមាន
ធម៌ដូចម្តេច មានវណ្ណៈដូចម្តេច មានសីលដូចម្តេច ទើបអ្នក
សរសើរប្រាប់យើងខ្លាំងម្ល៉េះ ដូច្នេះ ។

ព្រះរាជាត្រាស់សួរយ៉ាងនេះរឿយៗ ដោយទ្រង់ចម្លែកក្នុងព្រះហឫទ័យ ។ នាយព្រានស្តាប់ព្រះតម្រាស់នោះហើយពោលថា

ពួកម្រឹគទាំងនោះ មានស្នែងស មានរោមកន្ទុយស្អាត មាន
ស្បែកឧបមាដូចមាស មានជើងក្រហម មានភ្នែកដ៏ថ្លា បីដូច
ជាគេបន្តក់ គួរជាទីរីករាយនៃចិត្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱទាតសិង្គា** សេចក្តីថា ម្រឹគទាំងនោះ មាន

ស្មែនដូចគ្នានឹងកម្រងប្រាក់ ។ បទថា **សុចិវ៉ាលា** សេចក្ដីថា ប្រកបដោយរោមទន់ ស្អាតដូចគ្នានឹងរោមចាមរី ។ បទថា **លោហិតកា** សេចក្ដីថា មានក្រចកក្រហមដូចគ្នានឹងកែវប្រពាល ។ បទថា **ទាឡា** បានដល់ ចុងក្រចក ។ បទថា **អញ្ជិតក្ខា** សេចក្ដីថា ប្រកបដោយភ្នែកមានបសាទទាំង ៥ បរិសុទ្ធដូចគេលាប ។ កាលនាយព្រានក្រាបទូលយ៉ាងនេះ បានដាក់លោមជាតិទាំងឡាយរបស់ព្រះពោធិសត្វ ដែលមានពណ៌ដូចមាសក្នុង ព្រះហស្តរបស់ព្រះរាជា កាលប្រកាសពណ៌កាយនៃម្រឹគទាំងនោះ បានពោលគាថាដូច្នេះថា

បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះ មានអាការដូច្នេះ ពួកម្រឹគ មានធម៌ដូច្នេះ បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះជាសត្វចិញ្ចឹមមាតាបិតា ខ្ញុំព្រះអង្គមិនហ៊ាននាំយកម្រឹគទាំងនោះមកទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មាតាបេត្តិភរា** សេចក្ដីថា ម្រឹគទាំងនោះនាំគ្នាចិញ្ចឹមមាតាបិតាដែលចាស់ជរា មានភ្នែកខ្វាក់ងងឹត ទើបឈ្មោះថា តាំងនៅក្នុងធម៌ ដូច្នេះ ។ បទថា **ន តេ សោ អភិហារតុំ** សេចក្ដីថា ស្ដេចម្រឹគនោះ បុគ្គលណាមួយមិនអាចនាំមកដើម្បីជាគ្រឿងបណ្ណាការដល់ព្រះអង្គបានឡើយ បាឋៈថា **អភិហារយឹ** ដូច្នេះក៏មាន ។ ឯសេចក្ដីមានដូច្នេះថា ទូលព្រះបង្គំមិនបាននាំស្ដេចម្រឹគនោះមកថ្វាយ ដើម្បីជាបណ្ណាការដល់ទ្រង់ឡើយ គឺមិនបាននាំមកឡើយ ។

នាយព្រានពោលពណ៌នាគុណរបស់ព្រះពោធិសត្វ ចិត្តម្រឹគ និងម្រឹគី

បោតិកា ឈ្មោះសុតនា ដោយប្រការដូច្នេះហើយ ក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំ កាលស្តេចត្រឹមឲ្យនូវពោមរបស់ខ្លួនមកហើយ ឲ្យសិក្សាបទធម៌និងពាក្យផ្តាំផ្ញើថា អ្នកគប្បីតាំងនៅក្នុងឋានៈជំនួសខ្ញុំ សម្តែងធម៌ថ្វាយព្រះទេវី ដោយរាជធម្មចរិយា ១០ ប្រការចុះ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ ត្រាស់ឲ្យនាយព្រានអង្គុយលើរាជបល្ល័ង្កដែលវិចិត្រដោយរតនៈ ៧ ប្រការ ទ្រង់និងព្រះបរមរាជទេវី ប្រថាប់គង់លើព្រះរាជអាសនៈទាប ក្នុងទីសមគួរនាចំណែកម្ខាង ទ្រង់ផ្គងអញ្ជលី អារាធនាកាលព្រានសម្តែងធម៌ថ្វាយ ទើបទូល ( គាថាក្នុងតេសកុណជាតក ) ថា

បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបម្រើមាតាបិតាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការសង្គ្រោះចំពោះបុត្តភរិយាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមិត្ត និងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះពាហនៈនិងពលទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រ

មហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះជនអ្នកស្រុកនិងអ្នកនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជសូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះអ្នកដែន និងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គ ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះពួកសមណៈនិងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺឲ្យអភ័យចំពោះពួកម្រឹគនិងសត្វបក្សីទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ( ព្រោះថា ) ធម៌ដែលព្រះអង្គប្រព្រឹត្តហើយ រមែងនាំមកនូវសេចក្ដីសុខ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ព្រោះពួកព្រះឥន្ទ្រ ទេវតាព្រមទាំងព្រហ្ម បានដល់នូវទិព្វសម្បត្តិ ដោយធម៌ដែលខ្លួនប្រព្រឹត្តល្អ បពិត្រព្រះរាជា សូមព្រះអង្គកុំប្រហែសចំពោះធម៌ ។ នោះជាវត្ថុបទក្នុងបញ្ហានោះឯង នុ៎ះឯងជាអនុសាសនី សូមព្រះអង្គសេពគប់នូវបុគ្គលមានបញ្ញាសូម

មានគុណធម៌ដ៏ល្អ ជ្រាបច្បាស់នូវធម៌នោះ ដ៏បរិបូណ៌ដោយព្រះអង្គឯង ( ប្រតិបត្តិតាមពាក្យប្រៀនប្រដៅចុះ ) ដូច្នេះ ។

កូនព្រានសម្ដែងធម៌ដោយពុទ្ធលីលា ដោយនិយាម ដែលព្រះមហាសត្វសម្ដែងហើយនោះឯង ដូចទេវតាវិសេស ញុំាងអាកាសគង្គាឲ្យធ្លាក់ចុះមកដូច្នោះ ។ មហាជនញុំាងសាធុការឲ្យប្រព្រឹត្តទៅរាប់ពាន់ ការចាញ់ព្រះគភ៌នៃព្រះបរមរាជទេវី ក៏ស្ងប់រម្ងាប់ទៅ ព្រោះព្រះនាងស្ដាប់ធម្មកថានោះឯង ។ ព្រះរាជាទ្រង់ត្រេកអរ កាលបូជាធម៌ ទ្រង់អង្គាសកូនព្រាន ឲ្យនូវយសធំ បានត្រាស់ព្រះគាថា ៣ ថា

នែព្រាន យើងនឹងឲ្យនូវគ្រឿងនៃមាសជាច្រើនផងនូវកែវមណី និងកុណ្ឌលដ៏ក្រាស់ក្រែលផង នូវបល្ល័ង្កបួនជ្រុងដ៏រុងរឿងដូចជាផ្កាត្រកៀតផង ( ដល់អ្នក ) ។ ម្នាលព្រាន អ្នកមានឧបការៈច្រើនដល់យើង យើង ( នឹងឲ្យ ) នូវភរិយាពីរនាក់ដែលមានរូបនិងភោគសម្បត្តិប្រហែលគ្នាផង នូវគោមួយរយមានទាំងគោឧសភផង យើងនឹងសោយរាជ្យតាមធម៌ ។ ម្នាលព្រាន អ្នកចូរចិញ្ចឹមកូន និងប្រពន្ធដោយហេតុនេះគឺ កសិកម្ម ពាណិជ្ជកម្ម ឥណទានកម្ម ( ការបុល ) និងការស្វែងរករបរ ( ជាសម្មាអាជីវៈចុះ ) អ្នកកុំធ្វើនូវបាបទៀតឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជួលំ** សេចក្ដីថា យើងនឹងឲ្យគ្រឿងប្រដាប់គឺកែវមណី និងកែវកុណ្ឌល ដែលមានតម្លៃច្រើនដល់អ្នក ។ បទថា **ចតុ-**

**រស្សំ** បានដល់ បល្ល័ង្កខ្ពស់ ៤ ជ្រុង អធិប្បាយថា បល្ល័ង្កខ្ពស់ ៤ ជ្រុង ។ បទថា **ឧម្មារបុប្ផសិរិន្និភំ** បានដល់ បល្ល័ង្កដែលសម្រេចដោយឈើខ្លឹមពណ៌ខ្មៅ ប្រកបដោយឱកាស មានរស្មីដូចគ្នានឹងផ្កាត្រកៀត ព្រោះដូចគ្នានឹងកម្រាលពណ៌ខៀវ ។ បទថា **សាធិសិយោ** សេចក្តីថា ប្រៀបធៀបគ្នាដោយរូបសម្បត្តិ និងភោគសម្បត្តិ ។ បទថា **ឧសភញ្ច គវំសតំ** សេចក្តីថា យើងនឹងឲ្យគោ ១០០ ដែលមានគោឧសភជាប្រធានដល់អ្នក ។

បទថា **កាារេស្សំ** សេចក្តីថា យើងនឹងមិនញុំាងទសពិធរាជធម៌ឲ្យកម្រើកនឹងសោយរាជ្យដោយធម៌ប៉ុណ្ណោះ ។ បទថា **ពហុការោ មេសិ** សេចក្តីថា អ្នកឈ្មោះថាមានឧបការៈច្រើនដល់យើង ព្រោះតាំងនៅក្នុងឋានៈជំនួសស្តេចម្រឹគដែលមានពណ៌ដូចមាស ហើយអ្នកសម្តែងធម៌ដល់យើង យើងជាបុគ្គលដែលអ្នកឲ្យប្រតិស្ឋានឲ្យតាំងនៅក្នុងបញ្ចសីល ដោយនិយាម ដូចស្តេចម្រឹគពោលហើយនោះឯង ។

បទថា **កសិវណិជ្ជា** សេចក្តីថា នែនាយព្រានសម្លាញ់ យើងមិនបានឃើញស្តេចម្រឹគ ស្តាប់តែពាក្យរបស់ស្តេចម្រឹគប៉ុណ្ណោះ តាំងនៅក្នុងបញ្ចសីលបាន សូម្បីអ្នកក៏ចូរជាអ្នកមានសីល តាំងអំពីនេះទៅ ចូរធ្វើកសិកម្ម ពាណិជ្ជកម្ម និងឥណទានកម្មឯណានីមួយ ។ បទថា **ឧញ្ឆាចរិយា** សេចក្តីថា ដែលជាគោលរបស់ការគ្រប់គ្រងជីវិត អធិប្បាយថា ចូរអ្នកចិញ្ចឹមបុត្តភរិយារបស់អ្នកដោយកសិកម្មនិងពាណិជ្ជកម្មជាដើម ដូច្នេះ ដែលជាសម្មាអាជីវៈចុះ កុំធ្វើបាបកម្មទៀតឡើយ ។

នាយព្រាន ស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក្រាបទូលថា ទូលព្រះបង្គំមិនមានបំណងនឹងនៅគ្រប់គ្រងផ្ទះ សូមទ្រង់អនុញ្ញាតការបួស ដល់ទូលព្រះបង្គំផងចុះ កាលបានបរមរាជានុញ្ញាតហើយ ក៏ប្រគល់ទ្រព្យសម្បត្តិដែលព្រះរាជាប្រទានដល់ខ្លួន ឲ្យដល់បុត្តភរិយា ហើយចូលទៅកាន់ហិមវន្តប្បទេស បួសជាឥសី ញ៉ាំងសមាបត្តិ ៨ ឲ្យកើត ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ឯព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វហើយ ទ្រង់បំពេញផ្លូវទៅស្ថានសួគ៌ឲ្យបរិបូណ៌ ។ ឱវាទរបស់ព្រះពោធិសត្វនោះ តាំងនៅជាប់គ្នាអស់កាល ១០០០ ឆ្នាំ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសំដែងហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងជាតិមុន អានន្ទក៏បានលះបង់ជីវិត ដើម្បីជាប្រយោជន៍ដល់តថាគត ដោយប្រការយ៉ាងនេះដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រានព្រៃក្នុងកាលនោះ បានមកជាឆន្នភិក្ខុក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាសារីបុត្ត ព្រះទេវីក្នុងកាលនោះ បានមកជាខេមាភិក្ខុនី មេបាម្រឹគក្នុងកាលនោះ បានមកជាត្រកូលមហារាជ សុតនាម្រឹគីក្នុងកាលនោះ បានមកជាឧប្បលវណ្ណាថេរី ចិត្តកម្រឹគក្នុងកាលនោះ បានមកជាអានន្ទ ម្រឹគ ៨ ម៉ឺន ក្នុងកាលនោះ បានមកជាសាកិយរាជ ឯស្តេចម្រឹគឈ្មោះរោហនៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា រោហនមិគជាតក ចប់**

# ហំសជាតក

[ ២៥៣ ] ( ស្តេចហង្សពោធិសត្វពោលថា ) ពួកហង្សមានកក្អក ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ ម្នាលសុមុខៈ មានសម្បុរដូចមាស អ្នកចូរគៀសខ្លួនទៅចុះ ។ ពួកបក្សីជាញាតិលះបង់នូវយើងម្នាក់ឯង ដែលលុះអំណាចអន្ទាក់ឥតមានអាឡោះអាល័យហើរទៅហើយ ខ្លួនអ្នកតែម្នាក់ឯង សម្ងំនៅដូចម្តេចបាន ។ ការដែលហើរចេញទៅ របស់ពួកសត្វស្លាបជាការប្រសើរ ការប្រព្រឹត្តិនៅជាមួយអ្នកដែលជាប់ចំណង ជាការប្រសើរ មិនមែនទេ អ្នកកុំធ្វើសេចក្តីព្យាយាមឲ្យសាបសូន្យ ដោយសេចក្តីទុក្ខឡើយ ម្នាលសុមុខៈ អ្នកចូរគៀសខ្លួនចេញទៅតាមប្រាថ្នាចុះ ។

[ ២៥៤ ] ( សុមុខៈហង្សពោលថា ) បពិត្រស្តេចហង្សឈ្មោះធតរដ្ឋ ព្រះអង្គត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ខ្ញុំព្រះអង្គមិនលះបង់ចោលព្រះអង្គទេ ការរស់ឬការស្លាប់របស់ខ្ញុំព្រះអង្គ នឹងមាននៅជាមួយព្រះអង្គ ។

[ ២៥៥ ] ( ស្តេចហង្ស... ) ម្នាលសុមុខៈ អ្នកពោលនូវពាក្យណា ពាក្យនុ៎ះជាពាក្យល្អរបស់អរិយជន ចំណែកខាងខ្ញុំ ល្បងមើលអ្នកក្នុងការហើរចេញទៅ ទើបពោលពាក្យ ( យ៉ាងនេះ ) នឹងអ្នក ។

[ ២៥៦ ] ( កូនព្រានព្រៃពោលថា ) សត្វបក្សីជាសត្វត្រាច់ទៅក្នុងអាកាស រមែងទៅកាន់ផ្លូវតាមអាកាសដែលមិនមែនជាផ្លូវ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សីហង្ស ( ម្តេចក៏ ) អ្នកមិនដឹងនូវអន្ទាក់អំពីចម្ងាយ ។

[ ២៥៧ ] ( ស្តេចហង្ស... ) សេចក្តីវិនាសមានមកក្នុងកាលណា សត្វ

កាលបើជីវិតត្រូវអស់ហើយ ទោះបីប្រទះនូវសំណាញ់ឬអន្ទាក់ រមែងមិនដឹងក្នុងកាលនោះ ។

[ ២៥៨ ] ( ព្រានពោលនឹងសុមុខៈហង្សថា ) ពួកបក្សីហង្សមានកក្អក់ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ ម្នាលអ្នកមានស្បែកដ៏ខៀវ មានវណ្ណៈដូចមាស អ្នកម្នាក់ឯងសម្ងំនៅ ។ ពួកបក្សីទាំងនេះ ជាសត្វទៅតាមអាកាស ឥតមានអាល័យ ជាសត្វមានកក្អក់ លុះស៊ីហើយ ផឹកហើយ ក៏ហើរចេញទៅ អ្នកតែម្នាក់ឯងចូលមកវិញ ។ បក្សីនេះត្រូវជាអ្វីនឹងអ្នកទើបអ្នកដែលផុត ( ចាកអន្ទាក់ ) ចូលមករកបក្សីដែលជាប់វិញ ពួកបក្សីនាំគ្នាហើរចោលអស់ទៅហើយ ហេតុដូចម្តេច អ្នកសម្ងំនៅតែម្នាក់ឯង ។

[ ២៥៩ ] ( សុមុខៈហង្ស... ) បក្សីនេះជាស្តេចរបស់យើងផង ជាមិត្តរបស់យើងផង ជាសម្លាញ់ស្មើដោយជីវិតរបស់យើងផង ខ្ញុំនយើងនឹងមិនលះបង់នូវបក្សីនោះ ដរាបអស់កាលនៃជីវិត ។

[ ២៦០ ] ( ព្រាន... ) អ្នកណា ប្រាថ្នាលះបង់ជីវិត ព្រោះហេតុសម្លាញ់យើងនឹងលែងនូវសម្លាញ់របស់អ្នកនោះ ក្នុងកាលឥឡូវនេះ សូមឲ្យស្តេចរបស់អ្នកទៅជាមួយនឹងអ្នកចុះ ។

[ ២៦១ ] ( សុមុខៈហង្ស... ) ម្នាលព្រាន ក្នុងថ្ងៃនេះ យើងត្រេកអរព្រោះបានឃើញនូវស្តេចបក្សីរួចចាកចំណង យ៉ាងណា អ្នកក៏ចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ ។

[ ២៦២ ] ( ស្តេចហង្ស... ) ព្រះអង្គមានសេចក្តីសុខស្រួលទេឬ ព្រះ

អន្តមិនមានជំងឺតម្កាត់ទេឬ ព្រះអន្តតែងប្រៀនប្រដៅនូវអ្នកដែនដ៏ធំទូលាយនេះ តាមធម៌ទេឬ ។

[ ២៦៣ ] ( ព្រះរាជាតបថា ) ម្នាលហង្ស យើងមានសេចក្តីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជំងឺតម្កាត់ទេ ខ្ញុំនយើងក៏បានប្រៀនប្រដៅនូវអ្នកដែនដ៏ធំទូលាយនេះតាមធម៌ ។

[ ២៦៤ ] ( ស្តេចហង្ស... ) ពួកអាមាត្យរបស់ព្រះអន្ត មិនមានកំហុសណាមួយទេឬ ពួកសត្រូវនៃព្រះអន្តក្នុងទីឆ្ងាយ ដូចជាស្រមោល ( ដែលមិនមាន ) ក្នុងទិសខាងត្បូងទេឬ ។

[ ២៦៥ ] ( ព្រះរាជា... ) ពួកអាមាត្យរបស់យើង មិនមានកំហុសណាមួយទេ ទាំងសត្រូវរបស់យើងក្នុងទីឆ្ងាយ ក៏ដូចស្រមោល ( ដែលមិនមាន ) ក្នុងទិសខាងត្បូង ដូច្នោះ ។

[ ២៦៦ ] ( ស្តេចហង្ស... ) កិរិយារបស់ព្រះអន្តមានចិត្តស្មើគ្នា ជាស្រីស្តាប់បង្គាប់ព្រះអន្ត ស្រដីនូវពាក្យជាទីស្រឡាញ់ បរិបូណ៌ដោយបុត្តនិងរូបនិងយសបរិវារ លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអន្តដែរឬ ។

[ ២៦៧ ] ( ព្រះរាជា... ) កិរិយារបស់យើងមានចិត្តស្មើគ្នា ជាស្រីស្តាប់បង្គាប់យើង ស្រដីពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្តនិងរូបនិងយសបរិវារ លុះអំណាចសេចក្តីប្រាថ្នារបស់យើងទេ ។

[ ២៦៨ ] ( ស្តេចហង្ស... ) បពិត្រព្រះអន្តអ្នកញុំាងដែនឲ្យចម្រើន ព្រះអន្តមានព្រះរាជបុត្តច្រើនកើតឡើងដោយល្អ បរិបូណ៌ដោយសន្ទុះនៃប្រាជ្ញា

ស្រុះស្រួលរកគ្នាក្នុងហេតុនោះៗដែរឬ ។

[ ២៦៩ ] ( ព្រះរាជា... ) ម្នាលស្តេចហង្សឈ្មោះធតរដ្ឋ យើងមានកូនមួយរយមួយនាក់ ដែលអ្នកផងឮសុសសាយថា យើងជាអ្នក ( មានកូនច្រើន ) កូនទាំងនោះ រមែងមិនទីងទីងសម្តីរបស់អ្នកទេ សូមអ្នកប្រាប់នូវអំពើដែលត្រូវធ្វើដល់កូនទាំងនោះចុះ ។

[ ២៧០ ] ( ស្តេចហង្ស... ) បុគ្គលបើទុកជាបរិបូណ៌ដោយជាតិនិងច្បាប់ តែបើក្នុងកាលជាខាងក្រោយ គឺកាលដែលខ្លួនចាស់ ធ្វើនូវសេចក្តីព្យាយាមក្នុងកិច្ចការ រមែងលិចចុះក្នុងសេចក្តីអន្តរាយ ។ កាលបុគ្គលចាស់នោះ មានប្រាជ្ញារវើរវាយ ទោសក៏កើតឡើងជាច្រើនយ៉ាង បុគ្គលចាស់នោះរមែងឃើញបានតែត្រឹមរូបធំៗ ដូចបុគ្គលងងឹតក្នុងវេលាយប់ ។ បុគ្គលចាស់ដឹងនូវសេចក្តីព្យាយាមក្នុងលទ្ធិមិនមានខ្លឹមថា លទ្ធិមានខ្លឹម រមែងមិនបាននូវប្រាជ្ញា តែងលិចចុះក្នុងសេចក្តីអន្តរាយមិនខាន ដូចជាសត្វសរភៈលិចចុះក្នុងជ្រោះនៃភ្នំ ។ ជនបើទុកជាមានជាតិថោកថយ តែជាអ្នកមានការប្រឹងប្រែងមានប្រាជ្ញា បរិបូណ៌ដោយអាចារសីល រមែងរុងរឿងដូចជាភ្លើងក្នុងរាត្រី ។ សូមព្រះអង្គ ធ្វើសេចក្តីនេះឯង ឲ្យជាគ្រឿងប្រៀបធៀប ហើយញ៉ាំងពួកព្រះរាជបុត្ត ឲ្យប្រតិស្ឋានក្នុងវិជ្ជាទាំងឡាយ ដ្បិតអ្នកប្រាជ្ញតែងលូតលាស់ល្អដូចពូជដែលលូតលាស់ក្នុងស្រែ ក្នុងកាលដែលមានភ្លៀង ។

**ចប់ ហង្សជាតកទី ៦**

# អដ្ឋកថា
# ចូឡហំសជាតក

[ ២៥៣-២៧០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការលះបង់ជីវិតរបស់ព្រះអានន្ទត្ថេរនោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯតេ ហំសា បក្កមន្តិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារមានដូច្នេះថា ក្នុងកាលនោះ ភិក្ខុទាំងឡាយពោលសរសើរគុណរបស់ព្រះអានន្ទត្ថេរក្នុងធម្មសភា ព្រះបរមសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទក៏ធ្លាប់លះបង់ជីវិតដើម្បីតថាគតដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាទ្រង់ព្រះនាមថាពហុបុត្តកៈ សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះទេវីព្រះនាមថាខេមា បានជាព្រះអគ្គមហេសីរបស់ទ្រង់ ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតស្តេចសុវណ្ណហង្ស មានហង្ស ៩ ម៉ឺនជាបរិវារ នៅអាស្រ័យនាចិត្តកូដបពិត ។ ក្នុងកាលនោះ ព្រះបរមរាជទេវីសុបិននិមិត្តដោយន័យដែលពោលមកហើយនោះឯង ទើបក្រាបទូលការដែលព្រះនាងស្តាប់ធម្មទេសនារបស់ស្តេចហង្សមាស និងការចាញ់ព្រះគភ៌ដល់ព្រះរាជា ។ ព្រះរាជាក៏ត្រាស់សួរសេវកាមាត្យថា ឈ្មោះថាហង្ស

មាសមាននៅឯណា កាលទ្រង់ឮថា នៅត្រង់ចិត្តកូដបព៌ត ទើបមានព្រះបរម-រាជឱង្ការឲ្យជីកស្រះឡើង ដាក់ឈ្មោះថា ខេមាបោក្ខរណី ហើយដាំធញ្ញជាតិសម្រាប់ជាអាហារនៃសុវណ្ណហង្សមានប្រការផ្សេងៗ ឲ្យប្រកាសឃោសនា ព្រះរាជទានអភ័យដល់ហ្វូងហង្សទាំងឡាយរាល់ៗថ្ងៃ ក្នុងជ្រុងស្រះទាំង ៤ ហើយតែងតាំងបុត្តនាយព្រានម្នាក់ទុកឲ្យឃ្លាំចាំចាប់ហង្សទាំងឡាយ ។ អាការដែលព្រះបាទពហុបុត្តកៈ ទ្រង់តែងតាំងនាយព្រានទុកក្នុងការដាក់ អន្ទាក់ចាប់ហង្សក្តី សភាវៈដែលនាយព្រានឃ្លាំកៀងហង្សឲ្យចុះក្នុងស្រះនោះក្តី អាការដែលកំណត់ដាក់អន្ទាក់ទុកក្នុងពេលដែលស្តេចហង្សមាសមក ហើយក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាបក្តី អាការដែលកំណត់ព្រះមហាសត្វជាប់អន្ទាក់ក្តី កិរិយាដែលសុមុខហង្សសេនាបតី មិនឃើញព្រះមហាសត្វមកក្នុងហ្វូងហង្សទាំង ៣ នោះហើយត្រឡប់មកមើលក្តី សេចក្តីទាំងពួងនេះ នឹងមានច្បាស់ក្នុងមហាហង្សជាតក ។ ក្នុងជាតកនេះ ព្រះមហាសត្វកាលជាប់អន្ទាក់ហើយ ក៏ដាក់ខ្លួនចុះលើបង្គោលអន្ទាក់នោះឯង អើតកមើលផ្លូវដែលពួកហង្សហើរទៅ បានឃើញសុមុខហង្សសេនាបតីហើរត្រឡប់មក ទើបត្រិះរិះថា ក្នុងកាលដែលសុមុខហង្សមកដល់ហើយ អញនឹងសាកល្បងមើល កាលសុមុខហង្សសេនាបតីមកដល់ហើយ ទើបពោលគាថា ៣ ថា

ពួកហង្ស មានកក្កក់ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ
ក៏ហើរអស់ទៅ ម្នាលសុមុខៈ មានសម្បុរដូចមាស អ្នកចូរគៀស
ខ្លួនទៅចុះ ។ ពួកបក្សីជាញាតិលះបង់នូវយើងម្នាក់ឯង ដែល

លុះអំណាចអន្ទាក់ ឥតមានអាឡោះអាល័យ ហើរទៅហើយ ខ្វនអ្នកតែម្នាក់ឯងសម្ងំនៅដូចម្ដេចបាន ។ ការដែលហើរចេញទៅរបស់ពួកសត្វស្លាបជាការប្រសើរ ការប្រព្រឹត្តិនៅជាមួយអ្នកដែលជាប់ចំណងជាការប្រសើរមិនមែនទេ អ្នកកុំធ្វើសេចក្ដីព្យាយាមឲ្យសាបសូន្យដោយសេចក្ដីទុក្ខឡើយ ម្នាលសុមុខៈ អ្នកចូរកៀសខ្វនចេញទៅតាមប្រាថ្នាចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភយមេរិតា** សេចក្ដីថា ដែលភ័យមកដល់ គឺត្រូវភ័យគំរាមនិងញាប់ញ័រព្រោះភ័យ ។

ព្រះមហាសត្វហៅហង្សនោះឯងដោយពាក្យទាំង ២ ថា **ហរិត្តច ហេមវណ្ណ** ដូច្នេះ ។ ដោយបទថា **កាមំ** នេះ ព្រះមហាសត្វពោលសំដៅសេចក្ដីថា ម្នាលសុន្ទរមុខសេនាបតីដែលមានពណ៌ល្អដូចមាស ចូរអ្នកចៀសចេញឲ្យតែរួចខ្វនទៅចុះ ប្រយោជន៍អ្វីដោយការត្រឡប់មកក្នុងទីនេះ ។ បទថា **ឱហាយ** សេចក្ដីថា លះបង់យើងទុកតែឯង មិនក្រឡេកមើល ហើរគេចទៅ ។ បទថា **អនបេក្ខមានា** សេចក្ដីថា ពួកញាតិរបស់យើងទាំងនោះ មិនដាក់ចិត្តសម្លឹងមើលយើងឡើយ ហើរគេចទៅ ។ បទថា **បតេវ** បានដល់ ហើរគេចទៅនោះឯង ។ បទថា **មា អនីឃាយ** សេចក្ដីថា អ្នកទៅអំពីទីនេះហើយ កុំលះបង់នូវការព្យាយាមព្រោះហេតុដែលអ្នកបានជាបុគ្គលនិរាសប្រាសចាកទុក្ខដែលគប្បីដល់នេះឡើយ ។

លំដាប់នោះ ហង្សសុមុខសេនាបតីទំលើកកក់ពោលគាថានេះថា

បពិត្រស្តេចហង្សឈ្មោះ ធតរដ្ឋ ព្រះអង្គត្រូវសេចក្តីទុក្ខគ្រប
សង្កត់ហើយ ខ្ញុំព្រះអង្គមិនលះបង់ចោលព្រះអង្គទេ ការរស់ឬ
ការស្លាប់របស់ខ្ញុំព្រះអង្គ នឹងមានទៅជាមួយព្រះអង្គ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុក្ខូបរេតោ** សេចក្តីថា បពិត្រមហារាជ ទោះ បីទ្រង់មានមរណទុក្ខគំរាមចំពោះមុខ ទូលព្រះបង្គំមិនលះបង់ទ្រង់ទៅដោយ ហេតុមានប្រមាណប៉ុណ្ណេះឡើយ ។ កាលហង្សសុមុខសេនាបតីបន្លឺសីហនាទ យ៉ាងនេះហើយ ស្តេចធតរដ្ឋមហារាជពោលគាថាដូច្នេះថា

ម្នាលសុមុខៈ អ្នកពោលនូវពាក្យណា ពាក្យនុ៎ះជាពាក្យល្អ
របស់អរិយជន ចំណែកខាងខ្ញុំ ល្បងមើលអ្នក ក្នុងការហើរ
ចេញទៅ ទើបពោលពាក្យ ( យ៉ាងនេះ ) នឹងអ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតទរិយស្ស** សេចក្តីថា អ្នកពោលនូវ ពាក្យណាថា មិនលះបង់យើងទៅ ពាក្យនោះជាពាក្យល្អ ឧត្តម សមជាពាក្យ របស់ព្រះអរិយៈ ដែលដល់ព្រមដោយអាចារៈ ។ បទថា **បតេតេ តំ** សេច ក្តីថា ម្យ៉ាងទៀត យើងបានពោលយ៉ាងនេះ មិនមែនមានបំណងនឹងលះបង់ អ្នកនោះទេ ដោយពិត ត្រូវការសាកល្បងនូវចិត្តអ្នក ទើបធ្វើជាពោលថាទៅ ចុះ អធិប្បាយថា បានពោលពាក្យថា ចូរអ្នកហើរទៅចុះ ។

កាលហង្សទាំង ២ នោះ កំពុងសន្ទនាគ្នានោះឯង នេសាទបុត្ត កាន់ ដំបងរត់មកដោយរហ័ស ។ សុមុខសេនាបតី ក៏ពោលលួងលោមព្រះបាទ ធតរដ្ឋមហារាជបណ្តើរ បែរមុខទៅរកនាយព្រានបណ្តើរ ហើរទៅសម្តែងការ

គោរព ហើយពោលសរសើរគុណរបស់ស្តេចហង្ស ។ រំពេចនោះឯង កូននាយព្រានក៏មានចិត្តទោរទន់ សុមុខសេនាបតីដឹងថា កូនព្រានមានចិត្តទន់ហើយ ទើបហើរទៅលួងលោមស្តេចហង្ស ។ ឯកូននាយព្រានចូលទៅរកស្តេចហង្ស ហើយពោលគាថាទី ៦ ថា

សត្វបក្សី ជាសត្វត្រាច់ទៅក្នុងអាកាស រមែងទៅកាន់ផ្លូវតាម
អាកាស ដែលមិនមែនជាផ្លូវ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សី
ហង្ស (ម្តេចក៏) អ្នកមិនដឹងនូវអន្ទាក់អំពីចម្ងាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបថេន បថំ** សេចក្តីថា នៃមហារាជជាទិជជាតិសញ្ចរទៅក្នុងអាកាសដូចជាអ្នក រមែងធ្វើផ្លូវក្នុងអាកាសដែលមិនមែនជាផ្លូវហើរទៅបាន ។ បទថា **ន ពុជ្ឈិ តុំ** សេចក្តីថា កូនព្រានសួរថា អ្នកមានសភាពបែបនេះ ហេតុអ្វីទើបមិនឈ្លាស គឺមិនដឹងថា មានអន្ទាក់នេះពីចម្ងាយ ។ ព្រះមហាសត្វឆ្លើយថា

សេចក្តីវិនាស មានមកក្នុងកាលណា សត្វកាលបើជីវិតត្រូវ
អស់ហើយ ទោះបីប្រទះនូវសំណាញ់ឬអន្ទាក់ រមែងមិនដឹង
ក្នុងកាលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទា បរាភវោ** សេចក្តីថា នៃព្រានសម្លាញ់ការវិនាស គឺការមិនចម្រើន បានដល់ សេចក្តីវិនាសនឹងមានក្នុងកាលណា កាលនោះ កាលដល់នូវការអស់ជីវិត សត្វទោះជាប់សំណាញ់ ជាប់អន្ទាក់ក៏ដឹងមិនបាន ។

ព្រានសរសើរពាក្យរបស់ស្តេចហង្ស កាលនឹងសន្ទនាជាមួយហង្សសុមុខសេនាបតី ទើបពោលគាថា ៣ ថា

ពួកបក្សីហង្សមានកក្ងក់ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ ម្នាលអ្នកមានស្បែកដ៏ខៀវ មានវណ្ណៈដូចមាស អ្នកម្នាក់ឯង សម្ងំនៅ ។ ពួកបក្សីទាំងនេះ ជាសត្វទៅតាមអាកាស ឥតមានអាល័យ ជាសត្វមានកក្ងក់ លុះស៊ីហើយផឹកហើយ ក៏ហើរចេញទៅ អ្នកតែម្នាក់ឯង ចូលមកវិញ ។ បក្សីនេះត្រូវជាអ្វីនឹងអ្នក ទើបអ្នកដែលផុត ( ចាកអន្ទាក់ ) ចូលមករកបក្សីដែលជាប់វិញ ពួកបក្សីនាំគ្នាហើរចោលអស់ទៅហើយ ហេតុដូចម្តេច អ្នកសម្ងំនៅតែម្នាក់ឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ត្វញ្ចេវ** សេចក្តីថា ព្រានសួរថា ហេតុអ្វីទើបអ្នកមកជាប់ជំពាក់ជាមួយស្តេចហង្ស ។ បទថា **ឧបាសសិ** បានដល់នៅតែចូលមកជិត ។ សុមុខហង្សសេនាបតីពោលថា

បក្សីនេះជាស្តេចរបស់យើងផង ជាមិត្តរបស់យើងផង ជាសម្លាញ់ស្មើដោយជីវិតរបស់យើងផង ខ្ញុំនឹងមិនលះបង់នូវបក្សីនោះដរាបអស់កាលនៃជីវិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាវ កាលស្ស បរិយាយំ** សេចក្តីថា នែលុទ្ទបុត្ត ខ្ញុំមិនបោះបង់ស្តេចហង្សនេះឡើយ ដរាបណាខ្ញុំនៅមានជីវិត ។

ព្រានបានស្តាប់ដូច្នោះ មានចិត្តជ្រះថ្លា គិតថា បើអញប្រព្រឹត្តខុសក្នុង

ហង្សមាស ដែលសម្បូរដោយសីលយ៉ាងនេះ សូម្បីផែនដីក៏គប្បីបើកឱកាសឲ្យដល់អញ ប្រយោជន៍អ្វីដោយយសសក្តិទ្រព្យសម្បត្តិដែលអញបានពីព្រះរាជា អញនឹងដោះលែងស្តេចហង្សនេះទៅ ដូច្នេះហើយពោលនូវគាថានេះថា

អ្នកណា ប្រាថ្នាលះបង់ជីវិត ព្រោះហេតុសម្លាញ់ យើងនឹងលែងនូវសម្លាញ់របស់អ្នកនោះ ក្នុងកាលឥឡូវនេះ សូមឲ្យស្តេចរបស់អ្នកទៅជាមួយនឹងអ្នកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ ច ត្វំ** ស្មើគ្នានឹង **យោ ឆាម ត្វំ** ប្រែថា ឈ្មោះថា បុគ្គលណា ។ បទថា **សោ** យោគជា **សោ អហំ** ប្រែថា ខ្ញុំនោះ ។ បទថា **តវានុគោ** អធិប្បាយថា ស្តេចហង្សនេះនឹងប្រព្រឹត្តទៅតាមអំណាចបំណងរបស់អ្នក គឺនៅក្នុងទីតែមួយជាមួយអ្នកចុះ ។

នាយព្រានកាលពោលយ៉ាងនេះហើយ ក៏ដោះស្តេចហង្សធតរដ្ឋចេញពីបង្គោលអន្ទាក់ នាំទៅកាន់មាត់ស្រះ ស្រាយអន្ទាក់ចេញហើយ លាងឈាមដោយចិត្តទោរទន់ទៅដោយភាពករុណា ហើយចាត់ចែងតាក់តែងសរសៃជាដើមឲ្យរៀបរយដោយល្អ ដោយអំណាចចិត្តទោរទន់របស់ព្រាននិងដោយអានុភាពនៃបារមីដែលព្រះមហាសត្វបំពេញមក ជើងដែលមានរបួសក៏មានស្បែកនិងរោមដុះឡើងក្នុងខណៈនោះ ។ សូម្បីស្នាមដែលអន្ទាក់រឹតក៏មិនប្រាកដ ។ ហង្សសុមុខសេនាបតីសម្លឹងមើលព្រះពោធិសត្វហើយ មានចិត្តត្រេកអរកាលធ្វើនូវអនុមោទនា បានពោលគាថានេះថា

ម្នាលព្រាន ក្នុងថ្ងៃនេះ យើងត្រេកអរព្រោះបានឃើញនូវស្តេច

បក្សីរួចចាកចំណង យ៉ាងណា អ្នកក៏ចូរត្រេកអរជាមួយនឹង
ពួកញាតិទាំងអស់ យ៉ាងនោះដែរ ដូច្នេះ ។

នាយព្រានបានស្តាប់ដូច្នោះហើយ ពោលថា សូមអ្នកទាំង ២ អញ្ជើញទៅចុះ ។ លំដាប់នោះ ទើបព្រះមហាសត្វសួរព្រាននោះថា នែសម្លាញ់ អ្នកមកដាក់អន្ទាក់យកយើង ដើម្បីជាប្រយោជន៍របស់ខ្លួន ឬដាក់ដោយអំណាចរបស់អ្នកដទៃ ។ កាលព្រានប្រាប់ហេតុនោះហើយ ទើបពិចារណាមើលថា យើងទៅអំពីទីនេះ ទៅកាន់ចិត្តកូដបព៌តល្អ ឬទៅកាន់ព្រះនគរល្អហ្ន៎ ដូច្នេះហើយ បានសម្រេចចិត្តថា បើអញទៅកាន់ព្រះនគរ សូម្បីកូនព្រានក៏នឹងបានទ្រព្យសម្បត្តិ ការចាញ់គភ៌របស់ព្រះទេវីក៏នឹងរម្ងាប់ មិត្តធម៌របស់សុមុខសេនាបតីក៏នឹងប្រាកដ កម្លាំងញាណរបស់អាត្មាអញ ក៏នឹងប្រាកដដូចគ្នា ទាំងអាត្មាអញ ក៏នឹងបានស្រះខេមាបោក្ខរណី ដែលជាទីឲ្យអភ័យដល់បក្សីទាំងឡាយ ការដែលអញទៅកាន់ព្រះនគររបស់ព្រះបាទពារាណសីនោះប្រសើរពិត ដូច្នេះហើយ ទើបពោលនឹងព្រានថា នែព្រាន សូមលោកយកយើងទាំងពីរដាក់អង្រែកនាំទៅកាន់សម្នាក់របស់ព្រះរាជាចុះបើព្រះរាជាទ្រង់មេត្តាប្រោស លែងនូវពួកយើងសោត ទ្រង់ក៏នឹងលែងពួកយើងទៅឯង ។ ព្រានពោលថា នែអ្នក ឈ្មោះថាព្រះរាជាទាំងឡាយ រឹងរូសពន់ពេក អ្នកទាំង ២ ទៅចុះ ។ ស្តេចហង្សពោលថា សូម្បីព្រានដែលមានសភាពដូចអ្នក គង់ពួកយើងធ្វើចិត្តឲ្យទន់បាន ការដែលឲ្យព្រះរាជាទ្រង់ប្រោសប្រាណ ជាភារៈរបស់ខ្ញុំ សូមសម្លាញ់នាំពួកយើងទៅគាល់ចុះ ។ នាយព្រានក៏បានធ្វើតាមនោះគ្រប់ប្រការ ។

ព្រះរាជាទតឃើញហង្សទាំងពីរប៉ុណ្ណោះ ក៏កើតនូវបីតិសោមនស្ស ឲ្យហង្ស ទាំង ២ ទំលើតាំងមាស ព្រះរាជទានលាជលាយទឹកឃ្មុំ ឲ្យផឹកទឹកដែលលាយដោយទឹកឃ្មុំ ហើយទ្រង់ផ្គងអញ្ជលីឲ្យសម្តែងធម្មកថា ស្តេចហង្សដឹងច្បាស់ថាស្តេចពារាណសីទ្រង់ត្រេកអរ ប្រាថ្នានឹងទ្រទ្រង់ធម៌ ទើបមានសេចក្តីត្រេកអរ បានធ្វើបដិសណ្ឋារៈជាមុន ។ គាថាសន្ទនាឆ្លើយឆ្លងរវាងស្តេចហង្ស និងព្រះរាជា មានជាលំដាប់លំដោយដូចតទៅនេះថា

ព្រះអង្គមានសេចក្តីសុខស្រួលទេឬ ព្រះអង្គមិនមានជំងឺតម្កាត់ទេឬ ព្រះអង្គតែងប្រៀនប្រដៅនូវអ្នកដែនដ៏ធំទូលាយនេះតាមធម៌ទេឬ ។

ព្រះរាជាតបថា

ម្នាលហង្ស យើងមានសេចក្តីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជំងឺតម្កាត់ទេ ខ្ញុំយើង ក៏បានប្រៀនប្រដៅនូវអ្នកដែនដ៏ធំទូលាយនេះតាមធម៌ ។

ស្តេចហង្សទូល

ពួកអាមាត្យរបស់ព្រះអង្គ មិនមានកំហុសណាមួយទេឬ ពួកសត្រូវនៃព្រះអង្គក្នុងទីឆ្ងាយ ដូចជាស្រមោល ( ដែលមិនមាន ) ក្នុងទិសខាងត្បូងទេឬ ។

ព្រះរាជាតបថា

ពួកអាមាត្យរបស់យើងមិនមានកំហុសណាមួយទេទាំង

សត្រូវរបស់យើងក្នុងទីឆ្ងាយ ក៏ដូចស្រមោល ( ដែលមិន មាន ) ក្នុងទិសខាងត្បូងដូច្នោះ ។

ស្តេចហង្សទូលថា

កិរិយារបស់ព្រះអង្គមានចិត្តស្មើគ្នា ជាស្រីស្តាប់បង្គាប់ព្រះអង្គ ស្រដីនូវពាក្យជាទីស្រឡាញ់ បរិបូណ៌ដោយបុត្ត និងរូប និង យសបរិវារ លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គដែរឬ ។

ព្រះរាជាតបថា

កិរិយារបស់យើងមានចិត្តស្មើគ្នាជាស្រីស្តាប់បង្គាប់យើង ស្រដី ពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត និងរូប និងយសបរិវារ លុះអំណាចសេចក្តីប្រាថ្នារបស់យើងទេ ។

ស្តេចហង្សទូលថា

បពិត្រព្រះអង្គអ្នកញ៉ាំងដែនឲ្យចម្រើន ព្រះអង្គ មានព្រះរាជ បុត្តច្រើនកើតឡើងដោយល្អ បរិបូណ៌ដោយសន្ទុះនៃប្រាជ្ញា ស្រុះ ស្រួលរកគ្នាក្នុងហេតុនោះៗ ដែរឬ ។

ព្រះរាជាតបថា

ម្នាលស្តេចហង្សឈ្មោះ ធតរដ្ឋ យើងមានកូនមួយរយមួយនាក់ ដែលអ្នកផងឮសុសសាយថា យើងជាអ្នក ( មានកូនច្រើន ) កូនទាំងនោះ រមែងមិនវិងនឹងសម្តីរបស់អ្នកទេ សូមអ្នកប្រាប់ នូវអំពើដែលត្រូវធ្វើដល់កូនទាំងនោះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុសលំ** បានដល់ ភាពជាអ្នកមិនមានរោគ ។ បទថា **អនាមយំ** នេះ ជាវេវចនៈនៃបទថា **កុសលំ** នោះឯង ។ បទថា **ជីតំ** សេចក្ដីថា ស្ដេចហង្សទូលសួរថា ដែនរបស់ទ្រង់នេះ ធំទូលាយ មានកិក្ខារកបានងាយ ទ្រង់ទូន្មានអ្នកដែនដោយធម៌ដែរឬ ។ បទថា **ធោសោ** បានដល់កំហុស ។

បទថា **ឆាយា ទក្ខិណតោរិវ** សេចក្ដីថា ស្រមោលមានមុខទៅកាន់ទិសទក្សិណរមែងមិនចម្រើន យ៉ាងណា ពួកសត្រូវរបស់ទ្រង់រមែងមិនចម្រើន យ៉ាងនោះ ដោយប្រការណាមួយដែរឬ ។ បទថា **សាទិសី** សេចក្ដីថា ព្រះមហេសីរបស់ទ្រង់ដល់ព្រមដោយជាតិសម្បត្តិ ភោគសម្បត្តិ និងគោត្តត្រកូលបទេសបែបនេះ មិនបានប្រព្រឹត្តក្រៅចិត្តទ្រង់ទេឬ ។ បទថា **អស្សវា** បានដល់ ជឿនូវពាក្យ ។ បទថា **បុត្តរូបយសូបេតា** សេចក្ដីថា ដល់ព្រមដោយបុត្តសម្បត្តិ រូបសម្បត្តិ និងយសសម្បត្តិ ។

បទថា **បញ្ញាជវេន** សេចក្ដីថា ស្ដេចហង្សទូលសួរថា ព្រះរាជឱរសរបស់ទ្រង់ញុំាងបញ្ញាឲ្យស្ទុះទៅដោយកម្លាំងបញ្ញា ហើយអាចវិនិច្ឆ័យកិច្ចការនោះបាន ។ បទថា **សម្មោទន្តិ តតោ តតោ** សេចក្ដីថា ព្រះរាជឱរសទាំងនោះ នាំគ្នាត្រេកអរក្នុងទីប្រកបកិច្ចការនោះៗដែរឬទេ ។ បទថា **មយា សុតា** សេចក្ដីថា ព្រះរាជាត្រាស់តបថា ឱរសទាំងឡាយប្រាកដហើយព្រោះយើងទាំងលោកក៏ហៅថា ព្រះបាទពហុបុត្តករាជ គឺពោលថា ឱរសទាំងនោះ ជាអ្នកមានកិត្តិសព្ទល្បីរន្ទឺទៅ ព្រោះយើងថា អាស្រ័យយើងកើតប្រាកដដោយ

ប្រការដូច្នេះ ។ បទថា **តេសំ តុំ កិច្ចមក្ខាហិ** សេចក្តីថា ចូរអ្នកបង្ហាញកិច្ចដែលគួរធ្វើដល់ឱរសទាំងនោះរបស់យើងផងថា រាជឱរសទាំងឡាយ ចូរធ្វើវត្តនេះៗ ។ បទថា **ឆាវុជ្ឈន្តិ** នេះ ព្រះរាជាត្រាស់ដោយព្រះរាជបំណងថា ចូរឲ្យឱវាទដល់ឱរសរបស់យើងទាំងនោះឯង ។

ព្រះមហាសត្វ ស្តាប់ព្រះតម្រាស់នោះហើយ កាលថ្វាយឱវាទដល់ព្រះរាជឱរសទាំងនោះ បានពោលគាថា ៥ ថា

បុគ្គលបើទុកជាបរិបូណ៌ដោយជាតិនិងច្បាប់ តែបើក្នុងកាលជាខាងក្រោយ គឺកាលដែលខ្លួនចាស់ ធ្វើនូវសេចក្តីព្យាយាមក្នុងកិច្ចការ រមែងលិចចុះក្នុងសេចក្តីអន្តរាយ ។ កាលបុគ្គលចាស់នោះ មានប្រាជ្ញារវើរវាយ ទោសក៏កើតឡើងជាច្រើនយ៉ាង បុគ្គលចាស់នោះ រមែងឃើញបានតែត្រឹមរូបធំ ៗ ដូចបុគ្គលងងឹតក្នុងវេលាយប់ ។ បុគ្គលចាស់ដឹងនូវសេចក្តីព្យាយាមក្នុងលទ្ធិមិនមានខ្លឹមថាលទ្ធិមានខ្លឹម រមែងមិនបាននូវប្រាជ្ញា តែងលិចចុះក្នុងសេចក្តីអន្តរាយមិនខាន ដូចជាសត្វសរកៈ លិចចុះក្នុងជ្រោះនៃភ្នំ ។ ជនបើទុកជាមានជាតិថោកថយ តែជាអ្នកមានការប្រឹងប្រែង មានប្រាជ្ញា បរិបូណ៌ដោយអាចារសីល រមែងរុងរឿងដូចជាភ្លើងក្នុងរាត្រី ។ សូមព្រះអង្គធ្វើសេចក្តីនេះឯងឲ្យជាគ្រឿងប្រៀបធៀប ហើយញុំាងពួកព្រះរាជបុត្ត ឲ្យប្រតិស្ឋានក្នុងវិជ្ជាទាំងឡាយ ដ្បិតអ្នកប្រាជ្ញតែងលូតលាស់ល្អ

ដូចពូជ ដែលលូតលាស់ក្នុងស្រែ ក្នុងកាលដែលមានភ្លៀង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិឍយេឌ វា** បានដល់ ដោយអាចារ មារយាទ ។ បទថា **បច្ឆា ក្សរតេ យោគំ** សេចក្តីថា បើកុលបុត្តណាមិនធ្វើការប្រកប គឺសេចក្តីព្យាយាមក្នុងការសិក្សាសិប្បវិជ្ជា ដែលគួរសិក្សាក្នុងពេលដែលនៅជាកុមារ ធ្វើនូវការសិក្សាក្នុងកាលខាងក្រោយ គឺក្នុងវេលាដែលចាស់ កុលបុត្តបែបនេះ រមែងលិចចុះក្នុងទុក្ខឬអន្តរាយបែបនោះក្នុងកាលជាក្រោយ ឬមិនអាចជួយស្រោចស្រង់ខ្លួនឯងបាន ។ បទថា **តស្ស សំហីរបញ្ញស្ស** សេចក្តីថា ព្រោះកុលបុត្តនោះ មិនបានទទួលការសិក្សា បន្ទាប់អំពីនោះ ការវិនាសភោគសម្បត្តិក៏កើតឡើងដល់បុគ្គលដែលមានបញ្ញាមិនពិតប្រាកដ មានវិជ្ជាមិនមាំទាំ ។ បទថា **វិវរោ** បានដល់ ឱកាស គឺការវិនាសនៃភោគសម្បត្តិជាដើម ។ បទថា **រត្តិមន្ធោ** បានដល់ ការងងឹតក្នុងរាត្រី ។ លោកពោលអធិប្បាយទុកដូច្នេះថា ការងងឹតក្នុងរាត្រី គឺការងងឹតក្នុងរាត្រីរមែងឃើញបានតែរូប គ្រោតគ្រាតតែម្យ៉ាង ដោយពន្លឺព្រះចន្ទក្នុងពេលរាត្រី មិនអាចឃើញរូបល្អិតបាន យ៉ាងណា កុលបុត្តដែលមិនបានទទួលការសិក្សា មានបញ្ញាទន់ខ្សោយ ក៏យ៉ាងនោះ កាលភ័យឯណាមួយកើតឡើងហើយ រមែងមិនអាចឃើញកិច្ចដែលល្អិតសុខុមបាន ឃើញបានចំពោះកិច្ចការដែលគ្រោតគ្រាតប៉ុណ្ណោះ ព្រោះហេតុនោះ គួរប្រោសឲ្យព្រះរាជឱរសទាំងឡាយរបស់ទ្រង់សិក្សារៀនសូត្រក្នុងកាលដែលនៅក្មេងនោះឯង ។

បទថា **អសារេ** បានដល់ ក្នុងលទ្ធិលោកាយតវេទដែលឥតសារៈ ។ បទថា **សារយោគញ្ញូ** សេចក្តីថា សម្គាល់ថា លទ្ធិសម័យនេះ ប្រកបដោយសារៈ ។ បទថា **មតី ឆត្តេវ វិន្ទតិ** សេចក្តីថា សិក្សាច្រើន រមែងមិនបានបញ្ញា គឺចំណេះដឹងឡើយ ។ បទថា **គិរិទុគ្គស្មឹ** សេចក្តីថា ប្រៀបដូចសរភៈ ( ប្រើស ) ដើរមកលំនៅស្ថានរបស់ខ្លួន សម្គាល់ទីដែលមិនរាបស្មើថា រាបស្មើ លោតទៅក្នុងជ្រោះដោយរហ័ស រមែងធ្លាក់លិចចុះក្នុងចន្លោះ មិនដល់លំនៅ យ៉ាងណា កុលបុត្តបែបនេះ ក៏យ៉ាងនោះដូចគ្នា រៀនទូវលទ្ធិ លោកាយតវេទ ដែលឥតអសារៈ ដោយសម្គាល់ថាជាសារៈ រមែងដល់នូវសេចក្តីវិនាសធំ ព្រោះហេតុនោះ សូមទ្រង់ឲ្យព្រះរាជឱរសទាំងឡាយរបស់ទ្រង់សិក្សាប្រកបក្នុងកិច្ចទាំងឡាយ ដែលទាក់ទងដោយប្រយោជន៍ នាំសេចក្តីចម្រើនមកឲ្យ ។

បទថា **ឆិសេ អគ្គីវ** សេចក្តីថា បពិត្រមហារាជ មនុស្សយើង ទោះកើតក្នុងកំណើតថោកថយ តែជាអ្នកសម្បូរដោយគុណសម្បត្តិ មានសេចក្តីព្យាយាមប្រឹងប្រែងជាដើម រមែងភ្លឺស្វាង ដូចគំនរភ្លើងក្នុងរាត្រី ដូច្នោះ ។ បទថា **ឯតំ ឞេ** សេចក្តីថា ទ្រង់ធ្វើនូវការប្រៀបធៀបក្នុងរាត្រីទៅនឹងគំនរភ្លើង ដែលទូលព្រះបង្គំក្រាបទូលមកហើយ ឲ្យឱរសទាំងឡាយរបស់ទ្រង់ តាំងនៅក្នុងវិជ្ជា គឺឲ្យប្រកបក្នុងសិក្ខាទាំងឡាយដែលគួរដល់ការសិក្សាចុះ ព្រោះកុលបុត្តដែលប្រកបដោយវិជ្ជាយ៉ាងនេះហើយ ជាអ្នកមានបញ្ញាទ្រទ្រង់ចាំ តែងល្អប្រសើរ គឺចម្រើនដោយកិត្តិយស និងភោគសម្បត្តិ ដូចពូជរមែងដុះឡើង

ក្នុងស្រែល្អទាំងឡាយ ព្រោះទឹកភ្លៀង ដូច្នោះ ។

ព្រះមហាសត្វ សម្ដែងធម៌ថ្វាយព្រះរាជាយ៉ាងនេះមួយយប់ទាល់ភ្លឺ ការចាញ់គតិរបស់ព្រះទេវីក៏ស្ងប់រម្ងាប់ ។ លុះអរុណរះឡើង ព្រះមហាសត្វ ឲ្យព្រះរាជាតាំងនៅក្នុងសីល ថ្វាយឱវាទដោយអប្បមាទកថា ហើយទូលលាទៅកាន់ចិត្តកូដបព៌តនោះឯង តាមសីហបញ្ជរទិសឧត្តរ មួយអន្លើដោយសុមុខហង្សសេនាបតី ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន អានន្ទនេះ ក៏បានលះបង់ជីវិតដើម្បីជាប្រយោជន៍ដល់តថាគតដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រានទេសាទក្នុងកាលនោះ បានមកជាឆន្នក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាសារីបុត្ត ព្រះទេវីក្នុងកាលនោះ បានមកជាខេមាភិក្ខុនី ពួកហង្សក្នុងកាលនោះ បានមកជាពួកសក្យរាជ សុមុខសេនាបតីក្នុងកាលនោះ បានមកជាអានន្ទ ឯស្ដេចហង្សក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ហំសជាតក ចប់

# សត្តិគុម្ពជាតក

[ ២៧១ ] ( ព្រះមានព្រះភាគត្រាស់ថា ) មហារាជដូចជាព្រានម្រឹគ ជាបុគ្គលប្រសើរលើរថ របស់អ្នកដែនបញ្ចាល បានយាងទៅជាមួយនឹងសេនា សាបសូន្យចាកពួក ស្តេចចូលមកកាន់ព្រៃ ។ បានឃើញស្រុករបស់ពួកចោរ នៅក្នុងព្រៃនោះ សត្វសេកហើរចេញអំពីស្រុកនោះហើយ និយាយនូវសម្តីដ៏អាក្រក់ថា ព្រះរាជា ជាបុរសកំលោះ បរិបូណ៌ដោយពាហនៈ មានកុណ្ឌលដ៏រលើង មានព្រះឧណ្ហីសៈ ( ក្បាំង ) ដ៏ក្រហមប្រាល ល្អរុងរឿងដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ ។ ឥឡូវនេះ ព្រះរាជាព្រមទាំងនាយសារថីដេកលក់ក្នុងវេលាថ្ងៃត្រង់ បើដូច្នោះ យើងនឹងយកគ្រឿងប្រដាប់ទាំងពួង របស់ព្រះរាជានោះដោយរហ័ស ។ ឥឡូវនេះ ស្តេចព្រមទាំងនាយសារថីដេកលក់ ក្នុងទីស្ងាត់ដូចនៅកណ្តាលអធ្រាត្រ យើងនឹងយកសំពត់កែវមណីនិងកុណ្ឌល ហើយសម្លាប់រួចគ្របដោយមែកឈើ ។

[ ២៧២ ] ( បតិកោលុម្ពចោរពោលថា ) ម្នាលសត្តិគុម្ពៈ ឯងនិយាយដូចជាឆ្កួតទេឬ ព្រោះថា ព្រះរាជាទាំងឡាយ យាងមកអំពីចម្ងាយ ទ្រង់រុងរឿងដូចជាភ្លើងកំពុងឆេះ ។

[ ២៧៣ ] ( សត្តិគុម្ពៈពោលថា ) ម្នាលបតិកោលុម្ពៈ អ្នកឯងដូចជាបុគ្គលស្រវឹង ទើបកំញើញយើងយ៉ាងខ្លាំង អ្នកស្អប់ខ្ពើម ( ចោរកម្ម ) ព្រោះមាតារបស់ខ្ញុំអាក្រាតឬអ្វី ។

[ ២៧៤ ] ( ព្រះរាជាត្រាស់ថា ) នែនាយសារថីសម្លាញ់ ចូរអ្នក

រលះរលាំងក្រោកឡើង ចូរទឹមរថទៅ យើងមិនពេញចិត្តនឹងបក្សីទេយើងនឹងទៅកាន់អាស្រមដទៃវិញ ។

[ ២៧៥ ] ( នាយសារថីទូលថា ) បពិត្រមហារាជ ទូលព្រះបង្គំបានទឹមរថទឹមពាហនៈដ៏មានកម្លាំងហើយ បពិត្រមហារាជ សូមព្រះអង្គឡើងគង់ចុះ យើងនឹងទៅកាន់អាស្រមដទៃ ។

[ ២៧៦ ] ( សត្តិគុម្ពៈ... ) ពួកចោរក្នុងអាស្រម ទៅក្នុងទីណាអស់ទៅអេះ ស្តេចក្នុងដែនបញ្ចាលទុំះទៅផុតអំពីការមិនឃើញរបស់ពួកចោរទាំងនោះហើយ ។ អ្នកទាំងឡាយចូរចាប់ធ្នូ ដាវនិងលំពែង ស្តេចក្នុងដែនបញ្ចាលទុំះ កំពុងតែទៅ អ្នកទាំងឡាយកុំលែងជីវិតឡើយ ។

[ ២៧៧ ] ( អភិសម្ពុទ្ធគាថា ) ក្នុងកាលនោះ សត្វសេកដទៃទៀតមានចំពុះដ៏ក្រហម បានទទួលរាក់ទាក់ថា បពិត្រមហារាជ ព្រះអង្គស្តេចមកស្រួលហើយ មួយទៀត ដំណើរមករបស់ព្រះអង្គ មិនទាស់ទេ ព្រះអង្គជាធំយាងមកដល់ហើយ សូមទ្រង់មានព្រះបន្ទូលប្រាប់នូវព្រះរាជបំណង ដែលមានក្នុងដំណើរយាងមកនេះចុះ ។ បពិត្រព្រះរាជា សូមព្រះអង្គសោយនូវផ្លែទន្លាប់ជាទីគាប់ចិត្តព្រះហឫទ័យ ផ្លែស្រគំ និងផ្លែដង្កៀបក្ដាមតូចៗ ដ៏ប្រសើរប្រសើរចុះ ។ បពិត្រមហារាជ ទឹកនេះសោតក៏ត្រជាក់ ដែលពួកឥសីនាំមកអំពីជ្រោះភ្នំ សូមព្រះអង្គសោយ ( នូវទឹក ) អំពីជ្រោះនោះចុះ បើព្រះអង្គប្រាថ្នា ។ ពួកឥសីអ្នកនៅក្នុងអាស្រមនេះ ទៅកាន់ព្រៃដើម្បីស្វែងរក ( អាហារ ) ហើយ សូមព្រះអង្គក្រោកឡើង យកដោយព្រះអង្គឯងចុះ ខ្ញុំព្រះអង្គ មិន

មានដៃថ្វាយទេ ។

[ ២៧៨ ] ( ព្រះរាជា... ) សត្វបក្សីទ្វិជាតិនេះល្អ ប្រកបដោយធម៌ណាស់តើ ចំណែកតែបក្សីសេកក្រៅពីនេះនុ៎ះ និយាយពាក្យអាក្រក់ថាអ្នកទាំងឡាយចូរសម្លាប់ ចូរចងនូវស្តេចនេះ អ្នកទាំងឡាយកុំលែងជីវិតឡើយ កាលសេកនោះកំពុងនិយាយយ៉ាងនេះ យើងក៏បានចេញមកដល់ទីអាស្រមនេះដោយសួស្តី ។

[ ២៧៩ ] ( សេកបុប្ផកៈ... ) បពិត្រមហារាជ យើងខ្ញុំទាំងពីរជាបងប្អូនរួមផ្ទៃ មានមាតាជាមួយគ្នា ធំឡើងនៅលើដើមឈើតែមួយ តែឃ្លាតទៅក្នុងខេត្តផ្សេងគ្នា ។ សត្តិគុម្ពៈទៅក្នុងសម្នាក់នៃពួកចោរ ឯខ្ញុំព្រះអង្គ មកនៅក្នុងសម្នាក់នៃពួកឥសីក្នុងទីនេះ សត្តិគុម្ពៈ ( ចូលទៅកាន់សម្នាក់ ) នៃពួកអសប្បុរស ខ្ញុំព្រះអង្គ ( ចូលមកកាន់សម្នាក់ ) នៃពួកសប្បុរស ( ហេតុនោះ ) សត្តិគុម្ពៈនិងខ្ញុំមិនវៀរចាកធម៌[១]នោះទេ ។

[ ២៨០ ] ការសម្លាប់ក្តី ចងក្តី ការបន្លំក្តី បញ្ឆោតក្តី ការប្លន់ក្តី ការកំហែងក្តី មាននៅក្នុងសម្នាក់ចោរណា សត្តិគុម្ពៈរមែងសិក្សាអំពើទាំងនោះក្នុងសម្នាក់ចោរនោះ ។ សេចក្តីពិតក្តី សុចរិតក្តី ការមិនបៀតបៀនក្តី ការសង្រួមសីលក្តី ការទូន្មានឥន្ទ្រិយក្តី មាននៅក្នុងទីនេះ បពិត្រព្រះភារតៈ ខ្ញុំព្រះអង្គធំឡើងនៅលើចង្កេះនៃពួកឥសីអ្នកឲ្យអាសនៈនិងទឹក ។

[ ២៨១ ] បពិត្រព្រះរាជា ពិតណាស់ បុគ្គលគប់រកនូវបុគ្គលណា

---

១-ចោរធម៌ និងឥសិធម៌ ។

ទោះជាសប្បុរសឬអសប្បុរស មានសីលឬឥតសីល រមែងលុះអំណាចបុគ្គល នោះឯង ។ បុគ្គលធ្វើនូវបុគ្គលបែបណា ឲ្យជាមិត្ត ចូលទៅគប់រកនូវបុគ្គល បែបណា បុគ្គលនោះក៏មានអាការបែបនោះ ឯការនៅរួមក៏ប្រាកដដូច្នោះ ។ កូនសិស្សគប់រកនូវអាចារ្យផ្តេសផ្តាស អាចារ្យនោះដែលកូនសិស្សគប់រកហើយ រមែងប្រឡាក់កូនសិស្សដែលមិនប្រឡាក់ ( ដោយបាបធម៌ ) ដូចសរដែល ជ្រលក់ដោយថ្នាំពិសតែងប្រឡាក់បំពង់សរ ។ ព្រោះភ័យអំពីការប្រឡាក់អ្នក ប្រាជ្ញទើបមិនយកបុគ្គលលាមកជាសម្លាញ់ ជនណាខ្ចប់នូវត្រីស្អុយដោយចុង ស្បូវក្លាំង សូម្បីស្បូវក្លាំងក៏មានក្លិនស្អុយផ្សាយចេញ ការគប់រកនូវបុគ្គលពាល ( របស់ជននោះ ) ក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ សូម្បីស្លឹកឈើ ក៏មានក្លិនក្រអូបផ្សាយចេញ ការគប់រកអ្នកប្រាជ្ញ ( របស់ ជននោះ ) ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលជាអ្នកប្រាជ្ញ ដឹងច្បាស់នូវ បញ្ញាចាស់ទុំ របស់ខ្លួន ដូចជាកញ្ចប់ស្លឹកឈើ មិនគួរគប់រកពួកអសប្បុរស គួរគប់រកតែពួកសប្បុរស ( ដ្បិត ) ពួកអសប្បុរស តែងនាំទៅនរក ពួក សប្បុរសតែងផ្តល់នូវសុគតិ ។

## ចប់ សត្តិគុម្ពជាតកទី ៧

# អដ្ឋកថា

# សត្តិគុម្ពជាតក

[ ២៧១-២៨១ ] ព្រះសាស្តា កាលគង់នៅក្នុងមិគទាយវនវិហារ ក្បែរគុហាមទ្ទកុច្ឆិ ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **មិគលុទ្ទោ មហារាជ** ដូច្នេះជាដើម ។

មានសេចក្ដីសង្ខេបថា កាលទេវទត្តប្រមៀលថ្ម កម្ទេចថ្មក៏បែក ប៉ះព្រះបាទារបស់ព្រះសាស្តាហើយ ទ្រង់ក៏មានទុក្ខវេទនាជាទម្ងន់ ។ ភិក្ខុទាំងឡាយមកប្រជុំគ្នាដើម្បីសួរសុខទុក្ខព្រះសាស្តា ។ លំដាប់នោះ ព្រះមានព្រះភាគទតឃើញពុទ្ធបរិស័ទមកប្រជុំគ្នាហើយ មានព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេនាសនៈនេះចង្អៀតពេក នឹងមានការប្រជុំធំ ពួកអ្នកចូរនាំតថាគតទៅដោយគ្រែស្នែង ទៅកាន់គុហាមទ្ទកុច្ឆិចុះ ភិក្ខុទាំងឡាយ នាំគ្នាធ្វើតាមព្រះពុទ្ធតម្រាស់ ពេទ្យជីវកកោមារភច្ច បានធ្វើការព្យាបាលព្រះបាទារបស់ព្រះតថាគត ឲ្យជាផាសុក ។ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងសម្នាក់ព្រះសាស្តាថា អាវុសោទាំងឡាយ ទេវទត្តខ្លួនឯងក៏លាមក បរិស័ទក៏លាមក ទេវទត្តនោះជាបុគ្គលលាមក មានបរិវារលាមកយ៉ាងនេះ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ជាបុគ្គលលាមក មានបរិវារលាមកដូចគ្នា ហើយទ្រង់នាំអតីត

និទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមបញ្ចាល សោយរាជសម្បត្តិក្នុង ឧត្តរ-បញ្ចាលនគរ កាលនោះ ព្រះមហាសត្វកើតជាកូនស្តេចសេក ២ នាក់បងប្អូន ក្នុងព្រៃកាក្បែរសានុបព៌ត នាដងព្រៃមួយ ។ នៅទិសខាងជើងនៃភ្នំនោះ មានស្រុកចោរ ជាទីនៅអាស្រ័យរបស់ចោរ ៥០០ នៅឯទិសខាងត្បូងជាអាស្រម នៃឥសី ៥០០ រូប ។ ក្នុងកាលដែលសុវបោតកៈ ២ នាក់បងប្អូនកំពុងរៀន ហើរ ព្យុះកំបុតត្បូងក៏បានតាំងឡើង សុវបោតកៈ ១ ត្រូវខ្យល់បក់ធ្លាក់ទៅ ក្បែរគំនរអាវុធរបស់ពួកចោរក្នុងចោរគ្រាម ព្រោះធ្លាក់ក្នុងចន្លោះគំនរអាវុធ ពួកចោរក៏ចាប់បាន ទើបដាក់ឈ្មោះថា សត្តិគុម្ព ឯសុវបោតកៈ ១ ទៀត ត្រូវខ្យល់កួចទៅធ្លាក់ត្រង់គំនរផ្កា ក្បែរផ្នូកខ្សាច់ ជិតអាស្រមឥសី ព្រោះ សុវបោតកៈនោះធ្លាក់ក្នុងចន្លោះគំនរផ្កា ទើបឥសីឲ្យឈ្មោះថា បុប្ផកៈ ។

សត្តិគុម្ពសុវបោតកៈ ធំចម្រើនលូតលាស់ក្នុងកណ្តាលពួកចោរ ឯបុប្ផក សុវបោតកៈចម្រើនធំធាត់ក្នុងកណ្តាលឥសីទាំងឡាយ ថ្ងៃមួយព្រះបាទបញ្ចាល រាជ តាក់តែងព្រះកាយ ដោយគ្រឿងលង្ការសព្វយ៉ាង ទ្រង់យានដោយរថ ព្រះទីន័ងដ៏ប្រសើរ ទ្រង់ប្រពាសដងព្រៃដែលជារមណីយដ្ឋាន មានផ្ការីក ស្គុសស្គាយ និងផ្លែឈើដ៏ត្រកាល មិនឆ្ងាយអំពីព្រះនគរ ។ ដោយទ្រង់មាន បំណងចង់ប្រមាញ់ម្រឹគ មួយអន្លើដោយបរិវារជាច្រើន ហើយទ្រង់ប្រកាស ថា ម្រឹគរូបត្រង់មុខអ្នកណា អាជ្ញាទឹងមានដល់អ្នកនោះ ហើយទ្រង់ចុះអំពី រថ កាន់ធ្នូប្រថាប់ឈរលាក់ខ្លួនក្នុងគុម្ពឈើ ដែលរាជបុរសរៀបចំថ្វាយ ។

កាលពួករាជបុរសនាំគ្នាគោះគុម្ពឈើ ដើម្បីឲ្យម្រឹគទាំងឡាយក្រោក ទ្រាយមួយក្រោកឡើង សម្លឹងមើលផ្លូវដែលគួរទៅ ឃើញទីដែលព្រះរាជាប្រថាប់ឈរស្ងប់ស្ងាត់ ទើបបែរមុខទៅកាន់ទិសនោះ ហើយគេចទៅ ។ អាមាត្យទាំងឡាយ ស្រែកសួរគ្នាថា ម្រឹគគេចទៅតាមមុខរបស់អ្នកណាវ៉ុយ ក៏ដឹងថាត្រង់មុខរបស់ព្រះរាជា ក៏នាំគ្នាសើចចំអកព្រះរាជា ។ ព្រះបាទបញ្ចាលរាជទ្រង់អត់ធ្មត់នឹងការចំអករបស់អាមាត្យមិនបាន ដោយអស្មិមានះ ទ្រង់ឡើងកាន់ព្រះទីន័ង ត្រាស់ថា យើងនឹងចាប់ម្រឹគនោះឲ្យបានក្នុងឥឡូវនេះឯង ហើយត្រាស់ដល់នាយសារថីថា ចូរបររថទៅដោយរហ័ស ហើយយាងទៅតាមផ្លូវដែលម្រឹគគេចទៅនោះឯង ។ រាជបរិស័ទ មិនអាចដេញតាមរថព្រះទីន័ងដែលមានសម្ទុះដ៏រហ័សបាន ។ ព្រះរាជា និងនាយសារថីយាងទៅរហូតដល់ថ្ងៃត្រង់មិនជួបម្រឹគ ទើបត្រឡប់មក ទតឃើញជ្រោះដែលជារមណីយដ្ឋាន ក្បែរចោរគ្រាមនោះហើយ ទ្រង់ចុះអំពីរាជរថ ស្រពស្រង់និងសោយហើយ ទ្រង់យាងឡើងមកវិញ ។ លំដាប់នោះ នាយសារថីដោះគ្រឿងរថ រៀបចំទីបន្ទំខាងក្រោមម្លប់ឈើ ព្រះរាជាទ្រង់ផ្ទំក្នុងទីនោះ ឯនាយសារថី ក៏អង្គុយធ្វើនូវការគក់ប្របាច់នូវព្រះយុគលបាទរបស់ព្រះរាជា ។ ព្រះរាជាទ្រង់ផ្ទំលក់ភ្ញាក់ៗក្នុងរយៈជាប់គ្នា ។ ឯពួកចោរចូលទៅព្រៃដើម្បីរក្សាព្រះរាជា ( យាមការពារតំបន់របស់ខ្លួន ) ទាំងអស់ ។ នៅឯចោរគ្រាម សល់តែសេកសត្តិគុម្ពៈ និងចុងភៅឈ្មោះបតិកោលម្ពៈ[១] ២ នាក់ ប៉ុណ្ណោះ ។ ខណៈនោះ សត្តិគុម្ព

---

១-ក្នុងទី២ះជាបតិកោលុម្ពៈ ។

សុវបោតិកៈហើរចេញពីស្រុកទៅ ឃើញព្រះរាជា ទើបគិតថា អញនឹងសម្លាប់ព្រះរាជាដែលកំពុងដេកលក់នេះ យកគ្រឿងអលង្ការទៅ ហើយហើរត្រឡប់ទៅកាន់សម្នាក់របស់នាយបតិកោលម្ពៈ ប្រាប់ហេតុនោះឲ្យដឹង ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះ បានត្រាស់គាថា ៥ ថា

មហារាជដូចជាព្រានម្រឹគ ជាបុគ្គលប្រសើរលើរថ របស់អ្នកដែនបញ្ចាល បានយាងទៅជាមួយនឹងសេនា សាបសូន្យចាកពួក ស្តេចចូលមកកាន់ព្រៃ ។ បានឃើញស្រុករបស់ពួកចោរនៅក្នុងព្រៃនោះ សត្វសេក ហើរចេញអំពីស្រុកនោះហើយនិយាយនូវសម្តីដ៏អាក្រក់ថា ព្រះរាជាជាបុរសកំលោះ បរិបូណ៌ដោយពាហនៈ មានកុណ្ឌលដ៏រលីង មានព្រះឧណ្ហីសៈ ( ក្បាំង ) ដ៏ក្រហមប្រាល ល្អរុងរឿងដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ ។ ឥឡូវនេះ ព្រះរាជាព្រមទាំងនាយសារថីដេកលក់ក្នុងវេលាថ្ងៃត្រង់ បើដូច្នោះ យើងនឹងយកគ្រឿងប្រដាប់ទាំងពួងរបស់ព្រះរាជានោះដោយរហ័ស ។ ឥឡូវនេះស្តេចព្រមទាំងនាយសារថី ដេកលក់ក្នុងទីស្ងាត់ ដូចនៅកណ្តាលអធ្រាត្រ យើងនឹងយកសំពត់ កែវមណី និងកុណ្ឌល ហើយសម្លាប់រួចគ្របដោយមែកឈើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិគលុទ្ទោ** សេចក្តីថា ព្រះបាទបញ្ចាលរាជ មានព្រះអាការដូចព្រានម្រឹគ ព្រោះទ្រង់ស្វែងរកម្រឹគដូចនាយព្រាន ។ បទថា

**ឱគណោ** សេចក្តីថា ទ្រង់លះពួកគណៈ គឺទៅឆ្ងាយអំពីពួកសេនា ។ បទថា **តក្ករានំ កុដឹកតំ** សេចក្តីថា ព្រះរាជានោះបានទតឃើញស្រុកដែលគេធ្វើទុកជាទីនៅអាស្រ័យរបស់ពួកចោរក្នុងព្រៃនោះ ។ បទថា **តស្ស** សេចក្តីថា ចេញអំពីខ្ទមរបស់ចោរនោះ ។ បទថា **លុទ្ទានិ ភាសតិ** សេចក្តីថា សុវ-បោតកៈពោលពាក្យគ្រោតគ្រាតជាមួយចុងភៅ ឈ្មោះកោលម្ពៈនោះ ។

បទថា **សម្បន្នវាហនោ** បានដល់ មានសេះជាពាហនៈដល់ព្រម ។ បទថា **លោហិតុណ្ហីសោ** សេចក្តីថា ដល់ព្រមដោយដោយក្បាំងមុខពណ៌ក្រហម ស្រស់ស្អាត ។ បទថា **សម្បតិកេ** បានដល់ អម្បាញ់មិញនេះ គឺឥឡូវនេះ បានដល់ ក្នុងកាលដែលព្រះអាទិត្យតាំងនៅចំកណ្តាលបែបនេះ ។ បទថា **សហសា** សេចក្តីថា សុវបោតកៈពោលថា ពួកយើងមកជួយធ្វើអាការសម្មតដណ្តើមយកដោយរួសរាន់ចុះ ។

បទថា **និស្សិវេបិ រហោទានិ** សេចក្តីថា ឥឡូវនេះ ជាទីស្ងាត់ ដូចពេលយប់ សុវបោតកៈពោលពាក្យនេះថា ក្នុងវេលាយប់ គឺក្នុងសម័យដែលជារត្តិកាល ពួកមនុស្សទាំងឡាយ រមែងនាំគ្នាដេក ឈ្មោះថា ជាទីស្ងាត់ យ៉ាងណា ឥឡូវនេះ ក្នុងពេលដែលព្រះអាទិត្យកំពុងតាំងនៅត្រង់កណ្តាលបែបនេះ ក៏យ៉ាងនោះដូចគ្នា ។ បទថា **ហន្ត្វាន** សេចក្តីថា កាលពួកយើងផ្តាច់ព្រះជន្មព្រះរាជា កាន់យកសំពត់អាភរណៈហើយ បន្ទាប់អំពីនោះ សឹមទាញជើងព្រះរាជាមក យកមែកឈើគ្របក្នុងចំណែកម្ខាង ។ សត្តិគុម្ពសុវបោតកៈនោះ កាលហើរចេញទៅដោយរហ័សហើយ ទើបហើរត្រឡប់ទៅកាន់សម្នាក់

របស់បតិកោលម្ពៈម្តងទៀត ដោយប្រការដូច្នេះ ។ នាយបតិកោលម្ពៈបាន ស្តាប់ពាក្យរបស់សត្តិគុម្ពៈនោះ ទើបចេញទៅមើលដឹងថា ព្រះរាជាហើយ ក៏ភ័យខ្លាចពោលគាថានេះថា

ម្នាលសត្តិគុម្ពៈ ឯងនិយាយដូចជាឆ្កួតទេឬ ព្រោះថា ព្រះរាជាទាំងឡាយ យាងមកអំពីចម្ងាយ ទ្រង់រុងរឿងដូចជាភ្លើងកំពុងឆេះ ដូច្នេះ ។

លំដាប់នោះ សុវបោតកៈបានពោលឆ្លើយនឹងបតិកោលម្ពៈដោយវចនៈជាគាថានេះថា

ម្នាលបតិកោលុម្ពៈ អ្នកឯងដូចជាបុគ្គលស្រវឹង ទើបកំញើញយើងយ៉ាងខ្លាំង អ្នកស្អប់ខ្ពើម ( ចោរកម្ម ) ព្រោះមាតារបស់ខ្ញុំអាក្រាតឬអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ តំ** សេចក្តីស្មើគ្នានឹង **ឧទុ តំ** ។ បទថា **មត្តោ** សេចក្តីថា កាលមុន អ្នកបានផឹកស្រាដែលសល់អំពីចោរ ស្រវឹងហើយ រមែងភ្លេងភ្លាំងកាច មិនមែនឬ ។ បទថា **មាតរិ** សត្តិគុម្ពសុវបោតកៈ ពោលសំដៅយកកិរិយារបស់មេចោរ បានឮថា ក្នុងកាលនោះ កិរិយារបស់មេចោរនោះស្លៀកសំពត់ក្រងដោយមែកឈើត្រាច់ទៅ ។ បទថា **វិជិគុច្ឆសេ** សេចក្តីថា កាលម្តាយរបស់យើង កំពុងអាក្រាតកាយ ឥឡូវនេះ ហេតុអ្វី ទើបស្អប់ខ្ពើមចោរកម្ម គឺមិនចង់ធ្វើចោរកម្ម ។

ព្រះបាទបញ្ចាលរាជ តើនពីព្រះបន្ទំ បានស្តាប់ពាក្យរបស់សុវបោតកៈ

ពោលនឹងចុងភៅ ដោយកាសាមនុស្ស ទ្រង់ព្រះតម្រិះថា ទីនេះមានភ័យចំពោះមុខ កាលទ្រង់ដាស់នាយសារថីឲ្យក្រោកឡើង ទើបត្រាស់នឹងនាយសារថីថា

នែនាយសារថីសម្លាញ់ ចូរអ្នករលះរលាំងក្រោកឡើង ចូរទឹមរថទៅ យើងមិនពេញចិត្តនឹងបក្សីទេ យើងនឹងទៅកាន់អាស្រមដទៃវិញ ដូច្នេះ ។

ឯនាយសារថីក៏ក្រោកឡើងដោយរួសរាន់ ទឹមរថហើយពោលគាថាក្រាបទូលថា

បពិត្រមហារាជ ទូលព្រះបង្គំ បានទឹមរថទឹមពាហនៈដ៏មានកម្លាំងហើយ បពិត្រមហារាជ សូមព្រះអង្គឡើងគង់ចុះ យើងនឹងទៅកាន់អាស្រមដទៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពលវាហនោ** បានដល់ ពាហនៈដែលមានកម្លាំង គឺសេះដែលសម្បូរដោយកម្លាំងច្រើន ។ បទថា **អភិរុហ** សេចក្តីថា សូមទ្រង់យាងឡើង ។

កាលព្រះបាទបញ្ចាលរាជ ឡើងប្រថាប់រាជរថប៉ុណ្ណោះ សេះសិន្ធពទាំងគូក៏រត់ទៅដោយរហ័សដូចខ្យល់បក់ សត្តិគុម្ពសុវបោតកៈឃើញព្រះរាជាគេចទៅ ក៏អាក់អន់ចិត្ត បានពោលគាថា ២ ថា

ពួកចោរក្នុងអាស្រមទៅក្នុងទីណាអស់ ទៅអេះ ស្តេចក្នុងដែនបញ្ចាលនុ៎ះ ទៅផុតអំពីការមិនឃើញរបស់ពួកចោរទាំងនោះ

ហើយ ។ អ្នកទាំងឡាយ ចូរចាប់ធ្នូជាវនិងលំពែង ស្ដេចក្នុង
ដែនបញ្ចាលទុំះកំពុងតែទៅ អ្នកទាំងឡាយកុំលែងជីវិតឡើយ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោនុមេ** ស្មើគ្នានឹង **កុហឹ នុ ឥមេ** ប្រែថា ចោរក្នុងអាស្រមនេះទៅណាអស់ហើយហ្ន៎ ។ បទថា **អស្មឹ** សេចក្ដីថា ក្នុងអាស្រមនេះ ។ បទថា **បរិចារកា** បានដល់ ចោរទាំងឡាយ ។ បទថា **អបស្សន្តា** សេចក្ដីថា ព្រះបាទបញ្ចាលរាជគេចផុតទៅបាន ព្រោះពួកចោរទាំងនោះមិនបានឃើញ ។ បទថា **ឯស គច្ឆតិ** សេចក្ដីថា ព្រះបាទបញ្ចាលរាជ គេចពីកណ្ដាប់ដៃពួកចោរទាំងនេះយាងទៅបាន ព្រោះមិនឃើញ ។ បទថា **កោណ្ឌកានិ** បានដល់ ធ្នូ ។ បទថា **ជីវិតំ** សេចក្ដីថា កាលពួកលោកនៅមានជីវិត កុំឲ្យរួចទៅឡើយ ចោរទាំងអស់ ចូរចាប់អាវុធដេញទៅ ចាប់ព្រះរាជាឲ្យបាន ។

កាលសត្តិគុម្ពសុវបោតកៈនោះ ស្រែកបណ្ដើរ ហើរដេញតាមព្រះរាជាបណ្ដើរទៅយ៉ាងនេះ ព្រះរាជាក៏យាងដល់អាស្រមរបស់ឥសីទាំងឡាយ ខណៈនោះពួកឥសីចេញទៅស្វែងរកផ្លែឈើតូចធំ បុប្ផកសុវបោតកៈតែឯងប៉ុណ្ណោះនៅចាំអាស្រម សេកឃើញព្រះរាជាហើយ ហើរមកទទួល ធ្វើបដិសណ្ឋារៈ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ បានត្រាស់ ៤ គាថា ដោយសេចក្ដីថា

ក្នុងកាលនោះ សត្វសេកដទៃទៀត មានចំពុះដ៏ក្រហម បាន

ទទួលរាក់ទាក់ថា បពិត្រមហារាជ ព្រះអង្គស្ដេចមកស្រួល ហើយ មួយទៀត ដំណើរមករបស់ព្រះអង្គមិនទាស់ទេ ព្រះអង្គជាធំយាងមកដល់ហើយ សូមទ្រង់មានព្រះបន្ទូលប្រាប់នូវព្រះរាជបំណងដែលមានក្នុងដំណើរយាងមកនេះចុះ ។ បពិត្រព្រះរាជា សូមព្រះអង្គសោយនូវផ្លែទន្លាប់ ជាទីគាប់ចិត្តព្រះហឫទ័យ ផ្លែស្រគំនិងផ្លែដង្កៀបក្ដាមតូចៗ ដ៏ប្រសើរប្រសើរចុះ ។ បពិត្រមហារាជ ទឹកនេះសោតក៏ត្រជាក់ ដែលពួកឥសីនាំមកអំពីជ្រោះភ្នំ សូមព្រះអង្គសោយ ( នូវទឹក ) អំពីជ្រោះនោះចុះ បើព្រះអង្គប្រាថ្នា ។ ពួកឥសីអ្នកនៅក្នុងអាស្រមនេះ ទៅកាន់ព្រៃដើម្បីស្វែងរក ( អាហារ ) ហើយ សូមព្រះអង្គក្រោកឡើង យកដោយព្រះអង្គឯងចុះ ខ្ញុំព្រះអង្គមិនមានដៃថ្វាយទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បដិនន្ទិត្វា** សេចក្ដីថា លុះឃើញព្រះរាជាហើយ ក៏ត្រេកអរ ។ បទថា **លោហិតតុណ្ឌកោ** ប្រែថា មានចំពុះក្រហម គឺដល់នូវចំណែកនៃលម្អ ។ បទថា **មធុកេ** បានដល់ ផលាផលដែលមានរសផ្អែម ។ បទថា **កាសុមារិយោ** សេចក្ដីថា សូមទ្រង់សោយផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែស្រគំនិងផ្លែដង្កៀមក្ដាមដែលមានឈ្មោះយ៉ាងនេះៗ ។ បទថា **តតោ បិវ** សេចក្ដីថា សូមទ្រង់សោយទឹកអំពីរោងទឹកនោះចុះ ។

បទថា **យេ អស្មឹ បរិចារកា** សេចក្ដីថា បពិត្រមហារាជ ឥសីពួកណា

ត្រាច់ទៅក្នុងអាស្រមនេះ ឥសីទាំងនោះ ទៅកាន់ព្រៃ ដើម្បីស្វែងរកផលាផល ។ បទថា **គណ្ហាថ** សេចក្តីថា សូមទ្រង់ចាប់យកផ្លែឈើតូចធំ ។ បទថា **ធាតវេ** បានដល់ ដើម្បីរៀបចំថ្វាយ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងបដិសណ្ឋារៈរបស់បុប្ផកសុវបោតកៈ កាលទ្រង់ធ្វើនូវការសរសើរ ទើបត្រាស់ ២ គាថាដោយសេចក្តីថា

សត្វបក្សីទ្វិជាតិនេះ ល្អ ប្រកបដោយធម៌ណាស់តើ ចម្លែកតែបក្សីសេកក្រៅពីនេះនុ៎ះ និយាយពាក្យអាក្រក់ថា អ្នកទាំងឡាយ ចូរសម្លាប់ ចូរចងនូវស្តេចនេះ អ្នកទាំងឡាយកុំលែងជីវិតឡើយ កាលសេកនោះ កំពុងនិយាយ យ៉ាងនេះ យើងក៏បាន ចេញមកដល់ទីអាស្រមនេះដោយសួស្តី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតរោ** បានដល់ សត្វសេកក្នុងផ្ទះចោរ ។ បទថា **ឥច្ចេវំ** សេចក្តីថា ចំណែកយើង កាលសេកនោះពោលយ៉ាងនេះ មកដល់អាស្រមនេះដោយសួស្តី ។

បុប្ផកសុវបោតកៈស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ បានពោលគាថា ២ ថា

បពិត្រមហារាជ យើងខ្ញុំទាំងពីរជាបងប្អូនរួមផ្ទៃ មានមាតាជាមួយគ្នា ធំឡើងនៅលើដើមឈើតែមួយ តែឃ្លាតទៅក្នុងខេត្តផ្សេងគ្នា ។ សត្តិគុម្ពៈទៅក្នុងសម្នាក់នៃពួកចោរ ឯខ្ញុំព្រះអង្គមកនៅក្នុងសម្នាក់នៃពួកឥសីក្នុងទីនេះ សត្តិគុម្ពៈ ( ចូលទៅ

កាន់សម្នាក់ ) នៃពួកអសប្បុរស ខ្ញុំព្រះអង្គ ( ចូលមកកាន់សម្នាក់ ) នៃពួកសប្បុរស ( ហេតុនោះ ) សត្តិគុម្ពៈនិងខ្ញុំមិនវៀរចាកធម៌នោះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភាតរោស្ម** សេចក្តីថា បពិត្រមហារាជ សត្តិគុម្ពៈនោះនិងខ្ញុំទាំងពីរជាបងប្អូននឹងគ្នា ។ បទថា **ចោរាណំ** សេចក្តីថា សត្តិគុម្ពៈនោះធំធាត់ក្នុងសម្នាក់ពួកចោរ ឯខ្ញុំធំធាត់ក្នុងសម្នាក់ពួកឥសី ។ បទថា **អសតំ សោ សតំ អហំ** សេចក្តីថា សត្តិគុម្ពៈចូលទៅនៅក្នុងសម្នាក់អសប្បុរសទ្រុស្តសីល ឯខ្ញុំនៅក្នុងសម្នាក់សប្បុរសអ្នកមានសីល ។ បទថា **តេន ធម្មេន នោ វិនា** សេចក្តីថា បពិត្រមហារាជ ចោរទាំងឡាយទូន្មានសត្តិគុម្ពៈនោះ ដោយធម៌របស់ចោរនិងកិរិយាចោរ ឥសីទាំងឡាយទូន្មានខ្ញុំ ដោយធម៌របស់ឥសីនិងអាចារមារយាទរបស់ឥសី ព្រោះហេតុនោះ ទើបសត្តិគុម្ពៈនោះផ្សេងអំពីខ្ញុំ ដោយចោរធម៌នោះ ឯខ្ញុំផ្សេងអំពីវាដោយឥសីធម៌ ។

ឥឡូវនេះ បុប្ផកសុវបោតិកៈកាលចែកធម៌នោះ ទើបពោលគាថា ២ ថា

> ការសម្លាប់ក្តី ចងក្តី ការបន្លំក្តី បញ្ឆោតក្តី ការប្លន់ក្តី ការកំហែងក្តី មាននៅក្នុងសម្នាក់ចោរណា សត្តិគុម្ពៈរមែងសិក្សាអំពើទាំងនោះក្នុងសម្នាក់ចោរនោះ ។ សេចក្តីពិតក្តី សុចរិតក្តី ការមិនបៀតបៀនក្តី ការសង្រួមសីលក្តី ការទូន្មានឥន្ទ្រិយក្តី មាននៅក្នុងទីនេះ បពិត្រព្រះភារតៈ ខ្ញុំព្រះអង្គធំឡើងនៅលើចង្កេះនៃពួកឥសីអ្នកឲ្យអាសនៈនិងទឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និក្កតិ** បានដល់ ការបោកបញ្ឆោតដោយរបស់ក្លែងក្លាយ ។ បទថា **វញ្ចនានិ** បានដល់ ការបោកបញ្ឆោតដោយត្រង់ៗ គឺបោកបញ្ឆោតចំពោះមុខ ។ បទថា **អាលោបា** បានដល់ ការប្លន់សម្លាប់អ្នកស្រុកក្នុងពេលថ្ងៃ ។ បទថា **សហសាការា** បានដល់ ចូលទៅកាន់ផ្ទះ ហើយចាប់ម្ចាស់ទ្រព្យធ្វើទារុណកម្ម ដោយគំរាមសម្លាប់ ។ បទថា **សច្ចំ** បានដល់ សភាវធម៌ ។ បទថា **ធម្មោ** បានដល់ សុចរិតធម៌ ។ បទថា **អហឹសា** បានដល់ ការមិនបៀតបៀន មានមេត្តាធម៌ជាបុព្វភាគ ។ បទថា **សំយមោ** បានដល់ សង្រួមក្នុងសីល ។ បទថា **ទមោ** បានដល់ ការទូន្មានឥន្ទ្រិយ ។ បទថា **អាសន្ទុទកទាយិនំ** សេចក្តីថា នៃឥសីទាំងឡាយដែលមានប្រក្រតីឲ្យអាសនៈ និងឧទកវារីដល់ជនទាំងឡាយ ដែលមកដល់ចំពោះមុខ ។ បុប្ផកសុវបោតកៈហៅព្រះរាជាថាភារតៈ ។

ឥឡូវនេះ កាលបុប្ផកសុវបោតកៈសម្តែងធម៌ដល់ព្រះរាជាបន្តទៅ បានពោលគាថាទាំងនេះថា

បពិត្រព្រះរាជា ពិតណាស់ បុគ្គលគប់រកនូវបុគ្គលណា ទោះជាសប្បុរសឬអសប្បុរស មានសីលឬឥតសីល រមែងលុះអំណាចបុគ្គលនោះឯង ។ បុគ្គលធ្វើនូវបុគ្គលបែបណា ឲ្យជាមិត្រ ចូលទៅគប់រកនូវបុគ្គលបែបណា បុគ្គលនោះក៏មានអាការបែបនោះ ឯការនៅរួមក៏ប្រាកដដូច្នោះ ។ កូនសិស្សគប់រកនូវអាចារ្យផ្តេសផ្តាស អាចារ្យនោះ ដែលកូនសិស្សគប់រក

ហើយ រមែងប្រឡាក់កូនសិស្សដែលមិនប្រឡាក់ ( ដោយបាបធម៌ ) ដូចសរដែលជ្រលក់ដោយថ្នាំពិស តែងប្រឡាក់បំពង់សរ ។ ព្រោះភ័យអំពីការប្រឡាក់ អ្នកប្រាជ្ញទើបមិនយកបុគ្គលពាលមកជាសម្លាញ់ ជនណាខ្ចប់នូវត្រីស្អុយដោយចុងស្បូវក្លាំង សូម្បីស្បូវក្លាំងក៏មានក្លិនស្អុយផ្សាយចេញ ការគប់រកនូវបុគ្គលពាល ( របស់ជននោះ ) ក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ សូម្បីស្លឹកឈើក៏មានក្លិនក្រអូបផ្សាយចេញ ការគប់រកអ្នកប្រាជ្ញ ( របស់ជននោះ ) ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលជាអ្នកប្រាជ្ញ ដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ខ្លួន ដូចជាកញ្ចប់ស្លឹកឈើ មិនគួរគប់រកពួកអសប្បុរស គួរគប់រកតែពួកសប្បុរស ( ដ្បិត ) ពួកអសប្បុរសតែងនាំទៅនរក ពួកសប្បុរសតែងផ្តល់នូវសុគតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តំ វា យទិ វា អសំ** សេចក្តីថា សប្បុរសក្តី អសប្បុរសក្តី ។ បទថា **សេវមានោ សេវមានំ** សេចក្តីថា កាលអាចារ្យគប់រកអន្តេវាសិក រមែងធ្វើអន្តេវាសិកដែលខ្លួនគប់រក ។ បទថា **សម្ផុដ្ឋោ** សេចក្តីថា អាចារ្យត្រូវអន្តេវាសិកនាំប្រឡាក់ហើយ ។ បទថា **សម្ផុសំ បរំ** សេចក្តីថា អន្តេវាសិកដែលពាល់ត្រូវអាចារ្យដទៃ ។ បទថា **អលិត្តំ** សេចក្តីថា អាចារ្យនោះរមែងធ្វើអន្តេវាសិកនោះដែលមិនប្រឡាក់ដោយបាបធម៌ ឲ្យប្រឡាក់បាន ដូចព្រួញដែលលាបដោយថ្នាំពិសហើយ តែងធ្វើនូវបំពង់ព្រួញ

ឲ្យប្រឡាក់ដូច្នោះ ។ បទថា **ឯវំ ពាលូបសេវនា** សេចក្ដីថា ពិតហើយ បុគ្គលគាប់ចិត្តគប់រកបុគ្គលពាល ទោះមិនបានធ្វើអាក្រក់ ក៏រមែងបានទទួលពាក្យតំណិះដំនៀល និងការវិនាសចាកកិត្តិសព្ទ ដូចខ្ចប់ត្រីស្អុយដោយស្បូវភ្លាំង ដូច្នោះ ។

បទថា **ធីរូបសេវនា** សេចក្ដីថា បុគ្គលដែលគប់រកធីរជន ក៏រមែងដូចស្លឹកឈើដែលខ្ចប់គន្ធជាតិ មានក្រស្នាជាដើមដូច្នោះ ទោះបីមិនអាចជាបណ្ឌិតបាន ក៏គង់បានទទួលកិត្តិគុណថា គប់រកកល្យាណមិត្ត ។ បទថា **បត្តបុ-ដស្សេវ** សេចក្ដីថា ដូចស្លឹកឈើដែលខ្ចប់របស់មានក្លិនស្អុយ និងក្លិនក្រអូបដូច្នោះ ។ បទថា **សម្បាកមត្តនោ** សេចក្ដីថា បណ្ឌិតដឹងភាពដែលញាណរបស់ខ្លួនចាស់ក្លា គឺឆ្អិនហើយដោយអំណាចការសេពគប់នឹងកល្យាណមិត្ត ។ បទថា **ចាបេន្តិ សុគ្គតឹ** សេចក្ដីថា បុប្ផកសុវបោតិកៈនោះញ៉ាំងទេសនាឲ្យដល់អនុសន្ធិតាមលំដាប់ថា សប្បុរស គឺសម្មាទិដ្ឋិបុគ្គលទាំងឡាយ រមែងញ៉ាំងពួកសត្វដែលអាស្រ័យខ្លួន ឲ្យដល់នូវស្ថានសួគ៌តែម្យ៉ាង ដោយប្រការដូច្នេះ ។ ព្រះបាទបញ្ចាលរាជទ្រង់ជ្រះថ្លាក្នុងធម្មកថារបស់បុប្ផកសុវបោតកៈនោះ ឯពួកឥសីត្រឡប់មកអំពីព្រៃ ព្រះរាជានមស្ការឥសីទាំងឡាយហើយត្រាស់ថា បពិត្រលោកម្ចាស់ កាលលោកម្ចាស់ទាំងឡាយអនុគ្រោះខ្ញុំ សូមនិមន្តទៅកាន់លំនៅរបស់ខ្ញុំចុះ ទ្រង់ទទួលបដិញ្ញារបស់ឥសីទាំងឡាយនោះហើយយាងទៅព្រះនគរ បានព្រះរាជទានអភ័យដល់សុវបោតកៈទាំងឡាយ ចំណែកឥសីក៏បាននាំគ្នាទៅក្នុងនគរនោះ ព្រះរាជាទ្រង់និមន្តពួកឥសីឲ្យនៅក្នុងព្រះរាជ

ឧទ្យាន ទ្រង់ឧបដ្ឋាកបម្រើដរាបដល់អស់ព្រះជន្មាយុ ហើយយាងទៅកាន់ សួគ៌ាល័យ ។ ឯព្រះរាជឱរសរបស់ព្រះរាជា លើកស្វេតច្ឆត្រសោយរាជសម្បត្តិបន្តមក ទ្រង់បដិបត្តិពួកឥសីដូចព្រះបិតាក្នុងរាជត្រកូលជាបន្តមក បានឲ្យទានជាដើម ដល់ពួកឥសី រហូតអស់តំណព្រះរាជា ៧ អង្គ ព្រះមហាសត្វ នៅក្នុងអារញ្ញប្បទេស តាមសមគួរ ហើយទៅតាមយថាកម្មរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន ទេវទត្តក៏លាមក មានបរិវារក៏លាមកដូចគ្នាយ៉ាងនេះ ហើយទ្រង់ប្រជុំជាតកថា សត្តិគុម្ពសុវបោតកៈក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចោរទាំងឡាយក្នុងកាលនោះ បានមកជាបរិស័ទបរិវាររបស់ទេវទត្ត ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឥសីទាំងឡាយក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯបុប្ផកសុវបោតកៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សត្តិគុម្ពជាតក ចប់

# ភល្លាតិយជាតក

[ ២៨២ ] ( ព្រះមានព្រះភាគត្រាស់ថា ) ព្រះរាជាព្រះនាមភល្លាតិយៈ បានលះបង់នូវដែន ហើយត្រាច់ចេញទៅកាន់ទីសម្លាប់ម្រឹគ ព្រះអង្គបានយាង ទៅដល់ភ្នំដ៏ប្រសើរឈ្មោះគន្ធមាទន៍ មានឈើផ្ការីកស្គុសស្គាយ ដ៏ដេរដាស ដោយពួកកិន្នរ ។ ព្រះអង្គប្រាថ្នាដើម្បីពោលពាក្យ ( នឹងពួកកិន្នរ ) ទើបហាម ឃាត់ហ្វូងឆ្កែ ហើយដាក់ចុះនូវធ្នូនិងបំពង់ព្រួញ រួចចូលទៅត្រង់កន្លែងដែល ពួកកិន្នរឋិតនៅ ។ ( ព្រះរាជាសួរថា ) កាលកន្លងហេមន្តរដូវទៅហើយ ម្តេចឡើយ អ្នកទាំងឡាយឋិតនៅក្នុងទីនេះ ប្រឹក្សាគ្នារឿយៗ ប្របន្ទោរស៊ឹង ហេមវតី យើងសូមសួរពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចជាមនុស្ស គេស្គាល់អ្នកទាំងឡាយបានក្នុងមនុស្សលោកដោយប្រការដូចម្តេច ។

[ ២៨៣ ] ( កិន្នរីឆ្លើយថា ) ម្នាលព្រាន ពួកយើងតែងត្រាច់ទៅកាន់ ភ្នំឈ្មោះមាលាគិរិ ភ្នំឈ្មោះបណ្ឌរកៈ ភ្នំត្រៃកូដ និងស្ទឹងមានទឹកដ៏ត្រជាក់ ពួក យើងជាម្រឹគមានភេទប្រាកដដូចជាពួកមនុស្សគេស្គាល់ពួកយើងថាជាកិន្នរ ។

[ ២៨៤ ] ( ព្រះរាជា... ) អ្នកទាំងពីរ មានសភាពជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរឹតហើយ យើង សូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចមនុស្ស អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្តេច ទើបទួញយំក្នុងព្រៃនេះ អ្នកទាំងពីរមានសភាពដូចជា ទុក្ខក្រៃលែងទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱប រឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចជាមនុស្ស

អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្តេច ទើបយំរៀបរាប់ ក្នុងព្រៃនេះ ។ អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចមនុស្សអ្នកអាក់អន់ចិត្តដូចម្តេច ទើបសោកស្តាយក្នុងព្រៃនេះ ។

[ ២៨៥ ] ( កិន្នរី... ) ម្នាលព្រាន យើងទាំងឡាយ ជាអ្នកព្រាត់ប្រាសគ្នាអស់មួយរាត្រី រឭកគ្នាទៅវិញទៅមក មិនដាច់អាល័យ ក្តៅក្រហាយនឹងរាត្រីមួយនោះ ទើបយំសោក រាត្រីនោះនឹងមិនមានទៀត ។

[ ២៨៦ ] ( ព្រះរាជា... ) អ្នកទាំងឡាយ ក្តៅក្រហាយនឹងរាត្រីមួយណា ដូចបុគ្គលក្តៅក្រហាយនឹងទ្រព្យដែលបាត់ និងមាតាបិតា ដែលទៅកាន់បរលោក យើងសូមសួរនូវពួកអ្នកដែលមានរាងកាយ និងសម្បុរដូចមនុស្សចំពោះរាត្រី ( នោះ ) តើអ្នកទាំងឡាយ សម្រេចនូវទីនៅផ្សេងគ្នាដូចម្តេច ។

[ ២៨៧ ] ( កិន្នរី... ) អ្នកឃើញនូវស្ទឹងណា ដែលមានខ្សែទឹកដ៏រហ័សជាស្ទឹងបិទបាំងដោយដើមឈើផ្សេងៗ មានមាត់ច្រាំងដ៏ហើយដោយថ្ម កិន្នរ ( ជាប្តី ) ជាទីស្រឡាញ់របស់ខ្ញុំ បានហែលឆ្លងស្ទឹងនោះ ក្នុងកាលរដូវភ្លៀងដោយគិតថា កិន្នរីមកតាមក្រោយអាត្មាអញដែរ ។ ចំណែកខាងខ្ញុំ កំពុងតែបេះផ្កាព្រូស ផ្កាទន្លា ផ្កាម្ទិះរួត និងផ្កាយុថ្កា ដោយបំណងថា កិន្នរ ( ជាប្តី ) ជាទីស្រឡាញ់របស់អាត្មាអញនឹងបានប្រដាប់កម្រងផ្កា ទាំងអាត្មាអញជាអ្នកប្រដាប់កម្រងផ្កា នឹងបានចូលទៅរកកិន្នរ ( ជាប្តី ) នោះ ( ក្នុងជំណោក ) ។ មួយទៀត ខ្ញុំបេះផ្កាកុរវកៈ ទាំងផ្ការាជព្រឹក្ស និងផ្កាប្រនៀងក៏ខ្ញុំបេះដោយ

បំណងថា កិន្នរ ( ជាប្ដី ) ជាទីស្រឡាញ់របស់អាត្មាអញ នឹងជាអ្នកប្រដាប់កម្រងផ្កា ទាំងអាត្មាអញក៏ជាអ្នកប្រដាប់កម្រងផ្កា នឹងចូលទៅរកកិន្នរជាប្ដីនោះ ( ក្នុងដំណេក ) ។ មួយទៀត ខ្ញុំបានបេះនូវផ្កាសាលព្រឹក្ស ដែលរីកស្កុសស្កាយ ធ្វើជាគ្រឿងប្រដាប់ដោយបំណងថា ថ្ងៃនេះ យើងនឹងនៅក្នុងទីណា អស់រាត្រីមួយ គ្រឿងប្រដាប់នេះនឹងបានជាកម្រាលរបស់យើងក្នុងទីនោះ ។ មួយទៀត ខ្ញុំមានសភាពជាអ្នកធ្វេសប្រហែស ក្ដិនខ្ទឹមក្រស្នានិងខ្ទឹមចន្ទន៍លើថ្ម[១]ដោយបំណងថា កិន្នរជាប្ដីជាទីស្រឡាញ់របស់អាត្មាអញ នឹងបានលាបខ្លួនប្រាណ ទាំងខ្លួនអញ ក៏បានលាបស្រឡាប ហើយនឹងចូលទៅរកកិន្នរជាប្ដីនោះក្នុងដំណេក ។ លំដាប់នោះ ទឹកស្ទឹង មានខ្សែដ៏រហ័ស ហូរក្ដួចយកផ្កាសាលព្រឹក្ស ផ្កាស្រល់និងផ្កាកណ្ណិការ ( ដែលខ្ញុំបេះទុកក្នុងទីទៀបមាត់ច្រាំង ) មានទឹកដ៏ពេញដោយមួយរំពេច ទាំងស្ទឹងនោះ ខ្ញុំក៏ឆ្លងបានដោយកម្រក្រៃលែង ។ គ្រានោះយើងទាំងពីរនាក់ក៏ឈរប្រេបច្នេរស្ទឹង ម្ខាងម្នាក់មើលឃើញគ្នាទៅវិញទៅមក មួងយំមួងសើច រាត្រីនោះរបស់យើងក៏កន្លងទៅដោយក្រ ។ ម្នាលព្រាន កាលបើព្រះអាទិត្យរះឡើងក្នុងវេលាព្រឹក យើងទាំងពីរនាក់ ក៏ឆ្លងស្ទឹងទទេ ( ស្ទឹងមិនមានទឹក ) ហើយឱបរឹតគ្នាទៅវិញទៅមក មួងយំមួងសើច ។ ម្នាលព្រាន កាលមុន យើងបានព្រាត់ប្រាសគ្នាអស់មួយរាត្រី កន្លងមកចំនួន ៧០០ ខ្វះ ៣ ឆ្នាំ ( ៦៩៧ ឆ្នាំ ) ម្នាលភូមិបាល ជីវិត ( របស់អ្នក ) នេះ ត្រឹមតែមួយរយឆ្នាំ អ្នកណាហ្ន៎ ក្នុងលោកនេះ នៅផ្សេង

១-បុកខ្ទឹមក្រស្នានិងខ្ទឹមចន្ទន៍ដោយថ្ម ។

គ្នាអំពីកិរិយាជាទីត្រេកអរបាន ។

[ ២៨៨ ] ( ព្រះរាជា... ) នែសម្លាញ់ ចុះអាយុរបស់អ្នកទាំងឡាយ ចំនួនប៉ុន្មាន បើអ្នកដឹង ចូរអ្នកប្រាប់អាយុ ( ដល់យើង ) ទោះបីអ្នកបានឮ ( អំពីអ្នកណាមួយ ) ក្តី ចាំតមកអំពីពួកជនចាស់ទុំក្តី សូមអ្នកកុំញញើតប្រាប់សេចក្តីនោះដល់យើង ។

[ ២៨៩ ] ( កិន្នរី... ) ម្នាលព្រាន អាយុរបស់យើងមួយពាន់ឆ្នាំ បើមិនមានរោគដ៏អាក្រក់ក្នុងចន្លោះអាយុទេ ឯសេចក្តីទុក្ខមានប្រមាណតិច សេចក្តីសុខហ្នឹងឯង មានច្រើនក្រៃលែង ពួកយើងមិនប្រាសចាកសេចក្តីត្រេកអរ ( ស្រឡាញ់គ្នា ) ទាល់តែលះជីវិតទៅ ។

[ ២៩០ ] ( អភិសម្ពុទ្ធគាថា ) ព្រះរាជាព្រះនាមកល្លាតិយៈ លុះទ្រង់ព្រះសណ្តាប់ពាក្យរបស់ពួកកិន្នរនេះហើយ ក៏វិលត្រឡប់មក ( ព្រះរាជនិវេសន៍ ) ដោយរំពឹងឃើញថា ជីវិតនេះ មានប្រមាណតិចណាស់ រួចឈប់ត្រាច់ទៅកាន់ទីជាទីសម្លាប់ម្រឹគទៀត ទ្រង់បានបរិច្ចាគទាន ទ្រង់បានប្រើប្រាស់នូវភោគសម្បត្តិ ( តាមធម្មតា ) ។

[ ២៩១ ] ( ព្រះសាស្តាទ្រង់ឲ្យឱវាទថា ) សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវជម្លោះឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកម្តៅនូវព្រះអង្គ ដូចជារាត្រីមួយរបស់ពួកកិន្នរដុតកម្តៅនូវកិន្នរទាំងនោះ សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យ របស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវការវិវាទឡើយ កំហុសនៃអំពើរបស់ខ្លួន

កុំដុតកម្តៅនូវព្រះអង្គ ដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកម្តៅនូវកិន្នរទាំងនោះ ។

[ ២៩២ ] ( ព្រះនាងមល្លិកាទេវីទូលថា ) ខ្ញុំម្ចាស់មានចិត្តត្រេកអរស្តាប់ធម្មទេសនាមានហេតុផ្សេងៗ គន្ធងនៃព្រះបន្ទូលរបស់ព្រះអង្គ ប្រកបដោយប្រយោជន៍ ព្រះអង្គបញ្ចេញវាចា បន្ទោបង់សេចក្តីក្រវល់ក្រវាយរបស់ខ្ញុំម្ចាស់ បពិត្រសមណៈ ព្រះអង្គអ្នកនាំសេចក្តីសុខមកឲ្យ សូមព្រះអង្គគង់ព្រះជន្មនៅអស់កាលយូរ ។

## ចប់ភល្លាតិយជាតកទី ៨ ។

# អដ្ឋកថា

# ភល្លាតិយជាតក

[ ២៨២-២៩២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកាទេវី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ភល្លាតិយោ នាម អហោសិ រាជា** ដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយ អាស្រ័យហេតុដែលព្រះនាងមល្លិកាទេវីផ្ទំរួមជាមួយព្រះបាទកោសលរាជ ក៏កើតវិវាទដល់គ្នានឹងគ្នា ។ ព្រះរាជាទ្រង់ព្រះពិរោធមិនសម្លឹងមើលព្រះនាងមល្លិកាអគ្គមហេសី ទើបព្រះនាងព្រះតម្រិះថា ព្រះតថាគតប្រហែលជាទ្រង់មិនជ្រាបរឿងដែលព្រះរាជាពិរោធអញទេឬហ្ន៎ ព្រះសាស្តាទ្រង់ជ្រាបហេតុនោះ ស្អែកឡើង ចោមរោមដោយពួកភិក្ខុសង្ឃ ចូលទៅបិណ្ឌបាតក្នុងនគរសាវត្ថី ដល់ទ្វារព្រះរាជវាំង ។ ព្រះរាជាទទួលព្រះ-សាស្តា ទ្រង់ទទួលបាត្រ យាងព្រះសាស្តាឡើងកាន់ប្រាសាទ អារាធនាភិក្ខុសង្ឃ ឲ្យអង្គុយដោយលំដាប់ហើយ ថ្វាយទឹកទក្ខិណោទក ទ្រង់អង្គាសដោយព្រះក្រយាហារដ៏ប្រណីត កាលស្រេចភត្តកិច្ចហើយ គង់ប្រថាប់ក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្តាត្រាស់សួរថា បពិត្រមហារាជ ហេតុអ្វីព្រះនាងមល្លិកាទេវីមិនប្រាកដ ព្រះរាជាទូលថា ព្រោះនាងស្រវឹងក្នុងសេចក្ដីសុខរបស់ខ្លួន ទើបត្រាស់ថា បពិត្រមហារាជ ក្នុងជាតិមុន ទ្រង់កើតក្នុងកំណើតកិន្នរ បែកអំពីកិន្នរីត្រឹមមួយរាត្រី ត្រូវត្រាច់បរិទេវនាការអស់ ៧០០ ឆ្នាំ មិនមែនឬ ព្រះរាជាទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទកល្ងាតិយរាជ សោយរាជសម្បត្តិក្នុងនគរពារាណសី ទ្រង់ព្រះតម្រិះថា អញនឹងបរិភោគម្រឹគ ដែលអាំងលើរងើកភ្លើង ទើបទ្រង់ប្រគល់រាជសម្បត្តិដល់ពួកអាមាត្យ ហើយប្រដាប់បញ្ចាវុធ ចោមរោមដោយពួកកោលិយសុនខ ដែលបង្វឹកល្អហើយ យាងចេញអំពីព្រះនគរ ទៅកាន់ហិមវន្តប្បទេស យាងដល់ស្ទឹងតូចមួយ មិនអាចឆ្លងស្ទឹងទៅបាន ទតឃើញព្រៃកមួយទើបយាងសសៀរទៅតាមក្រសែទឹកនោះ ។ ទ្រង់សម្លាប់ម្រឹគ មានជ្រូកជាដើមហើយអាំងដោយរងើកភ្លើង ទ្រង់ឡើងទៅកាន់ទីទួល ។ ក្នុងទីទួលនិងទីទាបនោះ មានស្ទឹងតូចៗដែលគួរជាទីរីករាយ ក្នុងកាលដែលទឹកពេញបរិបូណ៌ ស្ទឹងនោះមានទឹកជម្រៅប្រមាណត្រឹមដោះ ហូរមកជានិច្ចក្នុងវេលាដទៃទឹកស្រកចុះប្រមាណត្រឹមជង្គង់ឬត្រឹមក្លៅ មានត្រី និងអណ្តើកហែលធ្មៀលធ្មាត់ទៅមក ត្រង់ឆ្នេរខ្សាច់មានខ្សាច់ពណ៌សស្អាត ដូចលម្អិតប្រាក់ សងខាងមាត់ច្រាំង មានដើមឈើត្រសាយត្រសុំ មានផ្កានិងផ្លែច្រើនប្រភេទ ពួកបក្សីនិងកមរជាច្រើន ត្រេកអរក្នុងផ្កា ផ្លែនិងរស នាំគ្នាមកក្រេបជញ្ជក់ ទាំងពួកម្រឹគនានា ក៏ចូលសេពអាស្រ័យក្នុងម្លប់ដើមឈើដែលត្រជាក់ ។ ត្រង់ច្រាំងហេមវតីនទីដែលគួរត្រេកអរយ៉ាងនេះ មានកិន្នរញីឈ្មោលមួយគូឱបរឹតនូវគ្នានឹងគ្នា ហើយយំសោករៀបរាប់គួរករុណា ។ កាលព្រះរាជាយាងឡើងភ្នំគន្ធមាទន៍តាមច្រាំងនទីនោះ ទតឃើញកិន្នរទាំងនោះហើយ ទ្រង់ព្រះតម្រិះថា ព្រោះហេតុអ្វីហ្ន៎ ទើបកិន្នរមួយគូនេះមកយំយ៉ាងនេះ អញនឹងសាកសួរមើល ទើបផ្ទាត់ព្រះហស្ត សម្លឹងមើលថ្កោទាំងឡាយ កោលិយសុនខដែល

ហ្វឹកហាត់ល្អហើយ នាំគ្នារត់ពួនចូលកាន់គុម្ពឈើ ក្រោបនឹងផែនដីតាមសញ្ញានោះ ។ ព្រះរាជាជ្រាបថា ផ្កាទាំងនោះលាក់ខ្លួនល្អហើយ ទ្រង់ពាក់ធ្នូ និងអាវុធ ទុកត្រង់ដើមឈើ មិនធ្វើសំឡេងព្រះបាទឲ្យខ្លាំង យាងសន្សឹមៗទៅកាន់សម្នាក់កិន្នរទាំងនោះ ហើយត្រាស់សួរកិន្នរទាំង ២ ថា ព្រោះហេតុអ្វី ទើបឯងទាំង ២ នាំគ្នាយំ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់គាថា ៣ ថា

ព្រះរាជាព្រះនាមភល្លាតិយៈ បានលះបង់នូវដែន ហើយត្រាច់ចេញទៅកាន់ទីសម្លាប់ម្រឹគ ព្រះអង្គបានយាងទៅដល់ភ្នំដ៏ប្រសើរឈ្មោះគន្ធមាទន៍ មានឈើផ្ការីកស្គុសស្គាយ ដ៏ដេរដាសដោយពួកកិន្នរ ។ ព្រះអង្គប្រាថ្នាដើម្បីពោលពាក្យ ( នឹងពួកកិន្នរ ) ទើបហាមឃាត់ហ្វូងឆ្កែ ហើយដាក់ចុះនូវធ្នូនិងបំពង់ព្រួញ រួចចូលទៅត្រង់កន្លែងដែលពួកកិន្នរឋិតនៅ ។ ( ព្រះរាជាសួរថា ) កាលកន្លងហេមន្តរដូវទៅហើយ ម្តេចឡើយអ្នកទាំងឡាយឋិតនៅក្នុងទីនេះ ប្រឹក្សាគ្នារឿយៗ ប្របរន្ទោស្មឹងហោមវតីយើងសូមសួរពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចជាមនុស្ស គេស្គាល់អ្នកទាំងឡាយបានក្នុងមនុស្សលោក ដោយប្រការដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាលូរសង្ឃំ** បានដល់ ក្រុមនៃឆ្កែ ។ បទថា **ហិមច្ចយេ** សេចក្តីថា កន្លងខែនៃហិមន្តរដូវ ៤ ខែទៅហើយ ។ បទថា

**ហេមវតាយ** សេចក្តីថា ត្រង់ប្រាំងនៃស្ទឹងហេមវតីនេះ ។ កិន្នរបានស្តាប់ព្រះតម្រាស់ព្រះរាជាដែលសួរហើយ ក៏នៅស្ងៀម ឯកិន្នរីក៏ក្រាបទូលព្រះរាជាថា

ម្នាលព្រាន ពួកយើង តែងត្រាច់ទៅកាន់ភ្នំឈ្មោះមាលាគិរិ ភ្នំឈ្មោះបណ្ឌរកៈ ភ្នំត្រៃកូដ និងស្ទឹងមានទឹកដ៏ត្រជាក់ ពួកយើងជាម្រឹគមានភេទប្រាកដដូចជាពួកមនុស្ស គេស្គាល់ពួកយើងថាជាកិន្នរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មល្លំគិរឹ** សេចក្តីថា នែព្រានសម្លាញ់យើងទាំងឡាយត្រាច់នៅតាមភ្នំទាំងនេះ គឺមល្លគិរី បណ្ឌរក តិកូដ ។ បាឋៈថា **មាលាគិរឹ** ដូច្នេះក៏មាន ។ បទថា **ឆិភាសវណ្ណា** សេចក្តីថា មានភេទនិងពណ៌សម្បុរ គឺមានសរីរៈប្រាកដដូចមនុស្ស ។

លំដាប់នោះ ព្រះរាជាបានត្រាស់ ៣ គាថា ដោយសេចក្តីថា

អ្នកទាំងពីរ មានសភាពជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចមនុស្ស អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្តេច ទើបទួញយំក្នុងព្រៃនេះ អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយ និងសម្បុរដូចជាមនុស្ស អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្តេច ទើបយំរៀបរាប់ក្នុងព្រៃ

*នេះ ។ អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ទួញយំ*
*អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរឹតហើយ*
*យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយ និងសម្បុរដូច*
*មនុស្ស អ្នកអាក់អន់ចិត្តដូចម្ដេច ទើបសោកស្ដាយក្នុងព្រៃនេះ*
*ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **សុកិច្ឆរូបំ** *សេចក្ដីថា មានអាការដូចមាន ទុក្ខក្ដៅក្រហាយពន់ប្រមាណ ។ បទថា* **អាលិង្គិតោ ចាសិ បិយោ បិយាយ** *សេចក្ដីថា ការដែលអ្នកស្រឡាញ់គ្នា បានឱបរឹតគ្នា សមគួរដល់សេចក្ដីស្រឡាញ់ហើយ ។ បាឋៈថា* **អាលិង្គិយោ ចាសិ** *ដូច្នេះក៏មាន ឯសេចក្ដីក៏ដូចគ្នា ។ បទថា* **កិមិធ វនេ** *សេចក្ដីថា ព្រោះហេតុអ្វី ទើបអ្នកទាំង ២ ឱបរឹតបើបនូវគ្នានឹងគ្នា ពោលវាចាជាទីស្រឡាញ់ចំពោះគ្នា ក្នុងរវាងចន្លោះ ហើយនាំគ្នាយំក្នុងព្រៃនេះ មិនស្រោកស្រាន្ត ។*

*បន្ទាប់អំពីនេះទៅ ជាគាថាសម្ដែងការប្រាស្រ័យឆ្លើយឆ្លងរវាងព្រះរាជា និងកិន្នរីដូចតទៅនេះ*

*ម្នាលព្រាន យើងទាំងឡាយ ជាអ្នកព្រាត់ប្រាសគ្នាអស់មួយ*
*រាត្រី រឭកគ្នាទៅវិញទៅមក មិនដាច់អាល័យ ក្ដៅក្រហាយ*
*នឹងរាត្រីមួយនោះទើបយំសោក រាត្រីនោះនឹងមិនមានទៀត ។*

*ព្រះរាជាត្រាស់ថា*

*អ្នកទាំងឡាយ ក្ដៅក្រហាយនឹងរាត្រីមួយណា ដូចបុគ្គលក្ដៅ*

ក្រហាយនឹងទ្រព្យដែលបាត់ និងមាតាបិតាដែលទៅកាន់បរ-លោក យើងសូមសួរនូវពួកអ្នកដែលមានរាងកាយនិងសម្បុរដូចមនុស្ស ចំពោះរាត្រី ( នោះ ) តើអ្នកទាំងឡាយសម្រេចនូវទីនៅផ្សេងគ្នាដូចម្តេច ។

កិន្នរីទូលថា

អ្នកឃើញនូវស្ទឹងណា ដែលមានខ្សែទឹកដ៏រហ័ស ជាស្ទឹងបិទបាំងដោយដើមឈើផ្សេង ៗ មានមាត់ច្រាំងដ៏ហើយដោយថ្មកិន្នរ ( ជាប្តី ) ជាទីស្រឡាញ់របស់ខ្ញុំ បានហែលឆ្លងស្ទឹងនោះក្នុងកាលរដូវភ្លៀង ដោយគិតថា កិន្នរីមកតាមក្រោយអាត្មាអញដែរ ។ ចំណែកខាងខ្ញុំ កំពុងតែបេះផ្កាព្រូស ផ្កាទន្ទា ផ្កាម្ទះរួត និងផ្កាយុថ្កា ដោយបំណងថា កិន្នរ ( ជាប្តី ) ជាទីស្រឡាញ់របស់អាត្មាអញ នឹងបានប្រដាប់កម្រងផ្កា ទាំងអាត្មាអញ ជាអ្នកប្រដាប់កម្រងផ្កា នឹងបានចូលទៅរកកិន្នរ ( ជាប្តី ) នោះ ( ក្នុងជំណោក ) ។ មួយទៀត ខ្ញុំបេះផ្កាកុរវកៈទាំងផ្កាពជ-ព្រឹក្សនិងផ្កាប្រនៀងក៏ខ្ញុំបេះ ដោយបំណងថា កិន្នរ ( ជាប្តី ) ជាទីស្រឡាញ់របស់អាត្មាអញនឹងជាអ្នកប្រដាប់កម្រងផ្កា ទាំងអាត្មាអញ ក៏ជាអ្នកប្រដាប់កម្រងផ្កា នឹងចូលទៅរកកិន្នរជាប្តីនោះ ( ក្នុងជំណោក ) ។ មួយទៀត ខ្ញុំបានបេះនូវផ្កាសាល-ព្រឹក្សដែលរីកស្គុសស្គាយ ធ្វើជាគ្រឿងប្រដាប់ ដោយបំណង

ថា ថ្ងៃនេះយើងនឹងនៅក្នុងទីណាអស់រាត្រីមួយ គ្រឿងប្រដាប់នេះ នឹងបានជា កម្រាលរបស់យើងក្នុងទីនោះ ។ មួយទៀត ខ្ញុំមានសភាពជាអ្នកធ្វេសប្រហែស ក្ដិនខ្ចីមក្រស្នានិងខ្ចីមចន្ទន៍លើថ្ម ដោយបំណងថា កិន្នរជាប្ដីជាទីស្រឡាញ់របស់អាត្មាអញនឹងបានលាបខ្លួនប្រាណ ទាំងខ្លួនអញក៏បានលាបស្រឡាប ហើយនឹងចូលទៅរកកិន្នរជាប្ដីនោះ ក្នុងដំណេក ។ លំដាប់នោះ ទឹកស្ទឹងមានខ្សែដ៏រហ័ស ហូរក្ដួចយកផ្កាសាលព្រឹក្ស ផ្កាស្រល់ និងផ្កាកណ្ណិការ ( ដែលខ្ញុំបេះទុកក្នុងទីទៀបមាត់ច្រាំង ) មានទឹកដ៏ពេញដោយមួយរំពេច ទាំងស្ទឹងនោះ ខ្ញុំក៏ឆ្លងបានដោយកម្រក្រៃលែង ។ គ្រានោះ យើងទាំងពីរនាក់ក៏ឈរប្របច្រាំងស្ទឹងម្ខាងម្នាក់ មើលឃើញគ្នាទៅវិញទៅមក ម្ដងយំ ម្ដងសើច រាត្រីនោះរបស់យើងក៏កន្លងទៅដោយក្រ ។ ម្នាលព្រាន កាលបើព្រះអាទិត្យរះឡើងក្នុងវេលាព្រឹក យើងទាំងពីរនាក់ ក៏ឆ្លងស្ទឹងទទេ ( ស្ទឹងមិនមានទឹក ) ហើយឱបរឹតគ្នាទៅវិញទៅមកម្ដងយំម្ដងសើច ។ ម្នាលព្រាន កាលមុន យើងបានព្រាត់ប្រាសគ្នាអស់មួយរាត្រី កន្លងមកចំនួន ៧០០ ខ្វះ ៣ ឆ្នាំ ( ៦៩៧ ឆ្នាំ ) ម្នាលភូមិបាល ជីវិត ( របស់អ្នក ) នេះ ត្រឹមតែមួយរយឆ្នាំ អ្នកណាហ្ន៎ក្នុងលោកនេះ នៅផ្សេងគ្នាអំពីកិរិយាជាទីត្រេកអរបាន ។

ព្រះរាជាត្រាស់ថា

នែសម្លាញ់ ចុះអាយុរបស់អ្នកទាំងឡាយចំនួនប៉ុន្មាន បើអ្នកដឹង ចូរអ្នកប្រាប់អាយុ ( ដល់យើង ) ទោះបីអ្នកបានឮ ( អំពីអ្នកណាមួយ ) ក្តី ចាំតមកអំពីពួកជនចាស់ទុំក្តី សូមអ្នកកុំញញើតប្រាប់សេចក្តីនោះដល់យើង ។

កិន្នរីទូលថា

ម្នាលព្រាន អាយុរបស់យើងមួយពាន់ឆ្នាំ បើមិនមានរោគដ៏អាក្រក់ក្នុងចន្លោះអាយុទេ ឯសេចក្តីទុក្ខមានប្រមាណតិច សេចក្តីសុខហ្នឹងឯង មានច្រើនក្រៃលែង ពួកយើងមិនប្រាសចាកសេចក្តីត្រេកអរ ( ស្រឡាញ់គ្នា ) ទាល់តែលះជីវិតទៅដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥយេករត្តំ** កាត់បទជា **ឥយំ ឯករត្តំ** សេចក្តីថា យើងទាំង ២ ត្រូវព្រាត់ប្រាសគ្នាអស់មួយរាត្រី ។ បទថា **វិប្ប-វសិម្ហ** សេចក្តីថា យើងត្រូវព្រាត់ប្រាសគ្នា ។ បទថា **អនុតប្បមានា** សេចក្តីថា ទាំងដែលយើងទាំង ២ មិនប្រាថ្នានឹងព្រាត់ប្រាសគ្នា មួយរាត្រីក៏បានកន្លងផុតទៅ យើងទាំង ២ ក៏គិតដល់រាត្រីមួយនោះ ។ បទថា **បុន ន ហេស្សតិ** សេចក្តីថា រាត្រីនោះនឹងមិនមាន គឺនឹងមិនមកទៀត ។

បទថា **ធនំវ ឆដ្ឌំ បិតរញ្ច បេតំ** សេចក្តីថា អ្នកទាំង ២ គិតដល់ទ្រព្យដែលបាត់ទៅហើយ ឬគិតដល់ឪពុកម្តាយដែលលះលោកនេះទៅហើយ

ដោយហេតុអ្វី ទើបបែកគ្នាមួយរាត្រីនោះ ចូរប្រាប់ហេតុនោះដល់យើងចុះ ។ បទថា **យមិមំ** កាត់បទជា **យំ ឥមំ** ប្រែថា នេះ ។ បទថា **សេលក្ខលំ** សេចក្តីថា ហូរមកក្នុងរវាងប្រាំងទាំង ២ ។ បទថា **វស្សកាលេ** សេចក្តីថា កិន្នរីពោលថា ក្នុងពេលដែលពពកមួយដុំតាំងឡើង ភ្លៀងធ្លាក់ យើងទាំង ២ ក្នុងរាត្រីនោះ ដើរទៅក្នុងដងព្រៃនេះ ពពកមួយដុំតាំងឡើង សម័យនោះ កិន្នរជាប្តីសម្លាញ់របស់ខ្ញុំ សម្គាល់ថា ខ្ញុំមកតាមឯក្រោយ ទើបឆ្លងទៅ ។ បទថា **អហាញ្ច** សេចក្តីថា ខ្ញុំមិនបានដឹងថា ប្តីរបស់ខ្ញុំឆ្លងទៅត្រើយនាយហើយនោះទេ រវល់តែបេះផ្កាទាំងឡាយ មានផ្កាព្រូសជាដើម ដែលរីកស្គុសស្គាយហើយ ។

បណ្តាបទទាំងនោះ បទថា **សត្តលិយោធិកញ្ច** សេចក្តីថា កាលខ្ញុំកំពុងបេះផ្ការំដួល និងផ្កាម្លិះរួត ដោយហេតុថា ប្តីសម្លាញ់របស់ខ្ញុំនឹងបានទ្រទ្រង់នូវកម្រងផ្កា ឯខ្ញុំក៏នឹងទ្រទ្រង់នូវកម្រងផ្កា ដេកជិតស្វាមីនោះ ។ បទថា **ឧទ្ទាលកា ចាតលិ សិន្ទុវារិតា** សេចក្តីថា សូម្បីផ្កាទាំងនេះ ខ្ញុំក៏បេះហើយនោះឯង ។ បទថា **ឱចេយ្យ** បានដល់ ជ្រើសរើសហើយ ។ បទថា **អគលុំ ចន្ទនញ្ច** បានដល់ ក្រស្នាខ្មៅនិងចន្ទន៍ក្រហម ។ បទថា **ពោសិតង្គោ** សេចក្តីថា មានសីរៈលាបហើយ ។ បទថា **ពោសិតា** បានដល់ ប្រោះព្រំសរីរៈហើយ ។ បទថា **អជ្ឈុបេស្សំ** សេចក្តីថា នឹងចូលទៅនេបជិតលើដំណេក ។ បទថា **ឧទំ សាលេ សលលេ កណ្ណិការេ** សេចក្តីថា កួចយកផ្កាទាំងនេះដែលខ្ញុំបេះហើយ ទៅទុកត្រង់ប្រាំងរហូតអស់ ។

បទថា **សុចុត្តរា** សេចក្តីថា ក្នុងកាលដែលកិន្នរីនោះឈរត្រង់ច្រាំងនោះឯង ទឹកស្ទឹងក៏ជន់ឡើងមកផង ខណៈនោះ ព្រះអាទិត្យអស្តង្គតទៅផង ផ្គរបន្ទោរផ្ទៀលផ្ទាត់ ធម្មតាកិន្នរទាំងឡាយជាសត្វខ្លាចទឹក ព្រោះហេតុនោះ ទើបកិន្នរីនោះ មិនអាចឆ្លងទៅកាន់ត្រើយនាយបាន ដោយហេតុនោះ ទើបកិន្នរីពោលថា ខ្ញុំក៏ឆ្លងបានដោយកម្រក្រៃលែង ។ បទថា **សម្បស្សន្តា** សេចក្តីថា ឃើញគ្នាក្នុងពេលមានផ្គរបន្ទោរ ។ បទថា **រោទាម** សេចក្តីថា ក្នុងគ្រាងងឹត មិនឃើញគ្នាក៏យំ ក្នុងពេលផ្គរបន្ទោរឃើញគ្នាក៏សើច ។ បទថា **សម្ពរី** បានដល់ រាត្រី ។ បទថា **ចតុក្កំ** បានដល់ ទទេ ឬស្រែក ។ បទថា **ឧត្តរិយាន** បានដល់ ឆ្លងទៅ ។ បទថា **តីហូនកំ** សេចក្តីថា ជាពេល ៦៩៧ ឆ្នាំ ។

បទថា **យមិធ មយំ** សេចក្តីថា កិន្នរីពោលថា យើងទាំង ២ ត្រូវព្រាត់ប្រាសចាកគ្នាក្នុងទីនេះ អស់កាលដែលកន្លងមកនេះ ជាកាលយូរហូតដល់ ៧០០ ខ្វះ ៣ ឆ្នាំ ។ បទថា **វស្សេក្កិមំ** កាត់បទជា **វស្សំ ឯកំ ឥមំ** សេចក្តីថា កិន្នរីពោលថា ជីវិតរស់នៅរបស់អ្នកនេះ មានកំណត់ត្រឹម ១០០ ឆ្នាំប៉ុណ្ណោះ ។ បទថា **កោឈិធ** សេចក្តីថា កិន្នរីពោលថា កាលជីវិតរស់នៅតិចតួចយ៉ាងនេះ អ្នកណានឹងព្រាត់ប្រាសកិរិយាជាទីស្រឡាញ់បាន ឬមិនគួរព្រាត់ប្រាសកិរិយាជាទីស្រឡាញ់ឡើយ ។ បទថា **កីវតកោ ណុ** សេចក្តីថា ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់កិន្នរីហើយ ទ្រង់ព្រះតម្រិះថា អញនឹងសួរនូវប្រមាណអាយុនៃកិន្នរទាំងនោះនឹងកិន្នរីសាកមើល ទើបត្រាស់សួរថា នៃ

សម្លាញ់ អាយុរបស់អ្នកទាំងឡាយចំនួនប៉ុន្មាន ។ បទថា **អនុស្សវា** សេចក្តីថា បើមានអ្នកណាម្នាក់ប្រាប់ដល់ពួកអ្នកឬដឹងតាមតម្រាមានក្នុងសម្នាក់ ក្នុងមាតាបិតា ឬបុគ្គលចាស់ទុំសោត កាលបើដូច្នោះ អ្នកកុំបិទបាំងឡើយ ចូរប្រាប់ប្រមាណនៃអាយុអំពីទីដែលអ្នកបានឮមកឬអំពីតម្រា ។

បទថា **ឆ ចន្តរា** សេចក្តីថា អាយុនៃយើងទាំងឡាយប្រមាណ ១០០០ ឆ្នាំ ក្នុងរវាងនោះ រោគភ័យធ្វើអន្តរាយដល់ជីវិត មិនមានដល់ពួកយើងទេ ។ បទថា **អវីតរាគា** សេចក្តីថា យើងទាំងឡាយមិនមែនជាអ្នកប្រាសចាកសេចក្តីស្រឡាញ់គ្នានឹងគ្នាឡើយ ។

ព្រះបាទភល្លាតិយរាជទ្រង់ស្តាប់ពាក្យកិន្នរីហើយ ទ្រង់ព្រះតម្រិះថា គួរអស្ចារ្យ កិន្នរទាំងនេះ ជាសត្វតិរច្ឆាន ព្រាត់ប្រាសចាកគ្នានឹងគ្នាត្រឹមមួយរាត្រី ក៏គង់យំសោកអស់ ៧០០ ឆ្នាំ ចំណែកអញលះមហាសម្បត្តិក្នុងភាពជាស្តេច មានអាជ្ញាផ្សាយទៅ ៣០០ យោជន៍ មកនៅក្នុងព្រៃ កណ្តាចកណ្តែង អញបានធ្វើកិច្ចដែលមិនគួរធ្វើ ដូច្នេះហើយ ទ្រង់យាងនិវត្តអំពីអរញ្ញប្បទេសមកកាន់ព្រះនគរពារាណសី កាលពួកអាមាត្យមុខមន្ត្រីទូលសួរថា បពិត្រព្រះអង្គ ទ្រង់ទតឃើញហេតុដូចម្តេច ដែលជាវត្ថុអស្ចារ្យក្នុងហិមវន្តប្បទេស ទើបទ្រង់ប្រាប់ហេតុទាំងពួងដែលទ្រង់ជួបប្រទះ ហើយទ្រង់បំពេញកុសល មានទានជាដើម សោយរាជសម្បត្តិតាំងអំពីនោះជាដើមមក ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះរាជាព្រះនាមភល្លាតិយៈ លុះទ្រង់ព្រះសណ្តាប់ពាក្យរបស់

ពួកកិន្នរនេះហើយ ក៏វិលត្រឡប់មក ( ព្រះរាជនិវេសន៍ ) ដោយរំពឹងឃើញថា ជីវិតនេះ មានប្រមាណតិចណាស់ រួចឈប់ត្រាច់ទៅកាន់ទីជាទីសម្លាប់ម្រឹគទៀត ទ្រង់បានបរិច្ចាគទាន ទ្រង់បានប្រើប្រាស់នូវភោគសម្បត្តិ ( តាមធម្មតា ) ដូច្នេះ ។

ព្រះបរមសាស្តា លុះទ្រង់ត្រាស់ព្រះគាថានេះហើយ កាលនឹងទូន្មានព្រះរាជបានពោលបន្ថែម ២ គាថាទៀតថា

សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវជម្លោះឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកម្តៅនូវព្រះអង្គ ដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកម្តៅនូវកិន្នរទាំងនោះ សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវការវិវាទឡើយ កំ-ហុសនៃអំពើរបស់ខ្លួន កុំដុតកម្តៅនូវព្រះអង្គ ដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកម្តៅនូវកិន្នរទាំងនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អមានុសានំ** បានដល់ កិន្នរទាំងឡាយ ។ បទថា **អត្តកម្មាបរាធោ** បានដល់ កម្មនិងទោសរបស់ខ្លួន ។ បទថា **កឹបុរិសេករត្តំ** សេចក្តីថា កម្មនិងទោសរបស់ខ្លួន ដែលធ្វើឲ្យព្រាត់គ្នាមួយរាត្រី ធ្វើកិន្នរទាំងនោះឲ្យក្តៅក្រហាយ យ៉ាងណា កម្មនិងទោសរបស់ខ្លួនកុំធ្វើឲ្យមហាបពិត្រទាំង ២ ក្តៅក្រហាយយ៉ាងនោះឡើយ ។

ព្រះនាងមល្លិកាទេវីស្តាប់ព្រះធម្មទេសនារបស់ព្រះតថាគតហើយ ក្រោកអំពីអាសនៈ ផ្គងអញ្ជលី កាលសរសើរព្រះទសពល ទើបពោលអវសានគាថាថា

ខ្ញុំម្ចាស់មានចិត្តត្រេកអរ ស្តាប់ធម្មទេសនា មានហេតុផ្សេងៗ
គន្លងនៃព្រះបន្ទូលរបស់ព្រះអង្គ ប្រកបដោយប្រយោជន៍ ព្រះ
អង្គបញ្ចេញវាចា បន្ទោបង់សេចក្តីក្រវល់ក្រវាយរបស់ខ្ញុំម្ចាស់
បពិត្រសមណៈ ព្រះអង្គអ្នកនាំសេចក្តីសុខមកឲ្យ សូមព្រះ
អង្គគង់ព្រះជន្មនៅអស់កាលយូរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិវិធ អធិមនា សុណោមហំ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ត្រេកអរ មានចិត្តជ្រះថ្លា ស្តាប់ព្រះធម្មទេសនាដែលទ្រង់សម្តែង ប្រដាប់ទៅដោយហេតុផ្សេងៗ ។ បទថា **វចនបថំ** សេចក្តីថា គន្លងព្រះពុទ្ធវចនៈ ប្រកបទៅដោយប្រយោជន៍ដែលទ្រង់ត្រាស់ហើយនោះ ។ បទថា **មុញ្ចំ គិរំ នុទសេវ មេ ទរំ** សេចក្តីថា កាលទ្រង់បន្លឺមធុរវចនៈ ដែលពីរោះត្រចៀក ឈ្មោះថា បន្ទោបង់ហើយ គឺនាំទៅហើយនោះឯងនូវសេចក្តីក្រវល់ក្រវាយ គឺសេចក្តីសោកក្នុងហទយៈរបស់ខ្ញុំ ។ បទថា **សមណា សុខាវហា ជីវ មេ ចិរំ** សេចក្តីថា បពិត្រព្រះមហាសមណៈដ៏ចម្រើន ទ្រង់នាំទិព្វសម្បត្តិ មនុស្សសម្បត្តិ និងលោកុត្តរសម្បត្តិ មកឲ្យដល់ខ្ញុំម្ចាស់ ទ្រង់ជាធម្មរាជា សូមទ្រង់គង់ព្រះជន្មយឺនយូរចុះ ។

តាំងអំពីនោះមក ព្រះបាទកោសល ទ្រង់នៅរួមស្នេហ៍ត្រេស្នេហាជាមួយព្រះ

នាងមល្លិកាទេវី ។

ព្រះសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា កិន្នរក្នុងកាលនោះ បានមកជាព្រះបាទកោសលរាជ ក្នុងកាលឥឡូវនេះ កិន្នរីក្នុងកាលនោះ បានមកជាព្រះនាងមល្លិកាទេវី ឯស្តេចភល្លាតិយរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ភល្លាតិយជាតក ចប់

# សោមនស្សជាតក

[ ២៩៣ ] ( ព្រះបាទរេណុត្រាស់សួរថា ) នរណាប្រហារលោក ជេរលោក ម្ដេចក៏លោកអាក់អន់ចិត្ត មិនត្រេកអរ សោកសង្រេងម្ល៉េះ ថ្ងៃនេះ ចង់មាតាបិតារបស់នរណាទួញយំ ថ្ងៃនេះ ចង់នរណាត្រូវគេបៀតបៀនដេកលើផែនដី ( ក៏លោកមិនត្រូវជាអ្នកជាទុក្ខទេ ) ។

[ ២៩៤ ] ( កុហកតាបសឆ្លើយថា ) បពិត្រព្រះសម្មតិទេព អាត្មាភាពត្រេកអរ ដោយការបានឃើញនូវព្រះអង្គ បពិត្រព្រះភូមិបាល អាត្មាភាពឃើញព្រះអង្គយូរហើយ បពិត្រព្រះសម្មតិទេព ព្រះនាមរេណុ អាត្មាភាពមិនមែនជាអ្នកបៀតបៀនទេ ប៉ុន្តែអាត្មាភាពត្រូវព្រះរាជបុត្តរបស់ព្រះអង្គចូលមកបៀតបៀនហើយ ។

[ ២៩៥ ] ( ព្រះរាជា... ) ពួកអ្នកចាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាតចូរមក ចូរទៅខាងក្នុងបុរី ចូរសម្លាប់ សោមនស្សកុមារនោះ កាត់ក្បាលដ៏ប្រសើរ នាំមកឲ្យអញ ។

ពួករាជទូត ដែលព្រះរាជា ទ្រង់បញ្ជូនទៅហើយ បាននិយាយនឹងព្រះរាជកុមារយ៉ាងនេះថា បពិត្រក្សត្រ ព្រះអង្គទ្រង់ឆ្ងងផុត ចាកឥស្សរភាពហើយ ព្រះអង្គដល់នូវសេចក្ដីស្លាប់ហើយ ។

ព្រះរាជបុត្តនោះ ក៏ទ្រង់បរិទេវនាការ ផ្គងក្រពុំម្រាមព្រះហស្តទាំង ១០ ថា បពិត្រព្រះអង្គជាធំជាងជន ចំណែកទូលព្រះបង្គំជាខ្ញុំ ចង់ឃើញព្រះអង្គ អ្នកទាំងឡាយ ចូរនាំយើងទាំងរស់ទៅក្រាបបង្គំថ្វាយ ( ដល់ព្រះមហាក្សត្រ )

ចុះ ។

ពួករាជទូតបានស្ដាប់វាចា របស់ព្រះរាជបុត្តនោះហើយ ក៏នាំព្រះរាជបុត្តទៅថ្វាយព្រះរាជា ចំណែកខាងព្រះរាជបុត្ត លុះបានឃើញព្រះរាជបិតាហើយ ក៏ក្រាបបង្គំទូលអំពីចម្លាយថា

បពិត្រព្រះជនិន្ទ ពួកអ្នកចាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈ-ឃាតមកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ ថ្ងៃនេះទូលព្រះបង្គំជាខ្ញុំ មានកំហុសដូចម្ដេចក្នុងរឿងនេះ ទូលព្រះបង្គំសួរហើយ សូមទ្រង់ប្រាប់សេចក្ដីនុ៎ះ ។

[ ២៩៦ ] ( ព្រះរាជា... ) ទិព្វចក្ខុតាបស ជាអ្នកមិនធ្វេសប្រហែស ធ្វើការស្រោចទឹក បូជាភ្លើង រាល់ពេលល្ងាចព្រឹក ព្រោះហេតុអ្វី បានជាឯងហៅទិព្វចក្ខុតាបសនោះ ដែលជាអ្នកមានសេចក្ដីសង្រួម ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ មានសភាពដូច្នោះ ថាជាគហបតី ។

[ ២៩៧ ] ( សោមទត្តកុមារ... ) បពិត្រព្រះសម្មតិទេព វត្ថុទាំងឡាយនៃកុលុបកៈនោះ មានច្រើនយ៉ាងណាស់ គឺផ្លែត្នោតផង ត្រាវនិងជំឡូងផង ផ្លែឈើវល្លិទាំងឡាយផង កុលុបកតាបសរបស់ព្រះអង្គនោះ ជាអ្នកមិនមានសេចក្ដីធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវវត្ថុទាំងនោះ ព្រោះហេតុនោះ បានជាទូលព្រះបង្គំជាខ្ញុំ ហៅតាបសនោះថា គហបតី ។

[ ២៩៨ ] ( ព្រះរាជា... ) ម្នាលកុមារ អ្នកនិយាយពាក្យនេះ ពិតមែនរបស់ទាំងឡាយនៃកុលុបកតាបសនោះ មានច្រើនយ៉ាង កុលុបកតាបសនោះជាអ្នកមិនធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវរបស់ទាំងនោះ ព្រោះហេតុនោះ

ព្រាហ្មណ៍ក្លាយជាគហបតី ។

[ ២៩៩ ] ( សោមនស្សកុមារ... ) បរិស័ទព្រមទាំងអ្នកនិគមអ្នកជនបទដែលបានមកចួបជុំទាំងអស់គ្នា ចូរស្តាប់ពាក្យរបស់ខ្ញុំ ព្រះរាជានោះជាបុគ្គលពាល ស្តាប់តែពាក្យតាបសពាល ប្រើគេឲ្យសម្លាប់ខ្ញុំ ដោយការមិនសមហេតុ ។

[ ៣០០ ] នាកាលឫសគល់ចម្រើនមាំធំឡើង ឫស្សីដែលបែកមែកហើយ បុគ្គលមិនងាយនឹងគាស់ចេញទេ បពិត្រព្រះជនិន្ទ ទូលព្រះបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះបាទាព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់អនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំសូមចេញបួស ។

[ ៣០១ ] ( ព្រះរាជា... ) ម្នាលកុមារ អ្នកចូរបរិភោគនូវភោគៈទាំងឡាយដ៏ច្រើនចុះ បិតានឹងប្រគល់ឥស្សរិយយសទាំងអស់ដល់អ្នក អ្នកចូរសោយរាជ្យជាស្តេច របស់អ្នកកុរុក្នុងថ្ងៃនេះឯង អ្នកកុំបួសឡើយ ដ្បិតថាបព្វជ្ជាជាកិច្ចលំបាកណាស់ ។

[ ៣០២ ] ( សោមនស្សកុមារ... ) បពិត្រព្រះសម្មតិទេព ភោគសម្ប័ទរបស់ព្រះអង្គ រាប់ថាមានដូចម្តេចកើត ក្នុងមនុស្សលោកនេះ ក្នុងកាលមុន ទូលព្រះបង្គំជាខ្ញុំ ធ្លាប់បានត្រេកអរដោយរូប សំឡេង រស ក្លិន ផ្សព្វ ជាទីសម្រើបចិត្ត ក្នុងទេវលោកមកហើយ ។ បពិត្រព្រះសម្មតិទេព ឯភោគសម្ប័ទទាំងឡាយ ទូលព្រះបង្គំជាខ្ញុំធ្លាប់បរិភោគហើយ ក្នុងទេវលោកឈ្មោះតាវត្តិង្ស ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលធ្លាប់មានពួកស្រីអប្សរចោមរោម

ហើយ ឯទូលព្រះបង្គំជាខ្ញុំ ស្គាល់ព្រះអង្គថាជាមនុស្សពាល ដែលត្រូវតែគេដឹកនាំបាន ( ទូន្មាន ) ទូលព្រះបង្គំជាខ្ញុំ មិនត្រូវនៅក្នុងរាជត្រកូល បែបព្រះអង្គទេ ។

[ ៣០៣ ] ( ព្រះរាជា... ) នែកូន បើបិតាជាមនុស្សពាល ដែលត្រូវតែគេដឹកនាំ ក៏សូមអ្នកអត់ទោសកំហុសម្តងដល់យើងចុះ ម្នាលសោមនស្ស បើទោសយ៉ាងនេះនឹងមានម្តងទៀត ចូរអ្នកធ្វើតាមមតិចុះ ។

[ ៣០៤ ] ( សោមនស្សកុមារ... ) ការងារដែលបុគ្គលមិនបានពិចារណាហើយធ្វើ គំនិតដែលបុគ្គលមិនកំណត់ហើយគិត រមែងមានផលអាក្រក់ ដូចជាការផ្សំថ្នាំខុសដូច្នោះ ។ ឯការងារដែលបុគ្គលពិចារណាហើយទើបធ្វើ គំនិតដែលបុគ្គលកំណត់ត្រឹមត្រូវហើយទើបគិត រមែងមានផលដ៏ចម្រើន ដូចជាការផ្សំថ្នាំត្រូវដូច្នោះឯង ។

គ្រហស្ថអ្នកបរិភោគកាមខ្ជិលមិនល្អ អ្នកបួសមិនសង្រួមមិនល្អ ព្រះរាជាអ្នកមិនពិចារណាហើយធ្វើមិនល្អ បណ្ឌិតដែលមានសេចក្តីក្រោធ ការក្រោធនោះ ក៏មិនល្អឡើយ ។

បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រត្រូវពិចារណាហើយសឹមធ្វើ មិនត្រូវធ្វើទាំងមិនពិចារណាទេ បពិត្រព្រះរាជា ដ្បិតថា យសនិងសេចក្តីសរសើររមែងចម្រើនដល់បុគ្គលអ្នកពិចារណាហើយទើបធ្វើ ។

បពិត្រព្រះភូមិបាល បុគ្គលជាធំ ត្រូវតែពិចារណាហើយសឹមដាក់អាជ្ញា ការដែលបុគ្គលធ្វើដោយរួសរាន់ រមែងក្តៅក្រហាយ ម្យ៉ាងទៀត ប្រយោជន៍

ទាំងឡាយ ដែលនរជនផ្គងឡើងត្រឹមត្រូវនោះ រមែងជាប្រយោជន៍ មិនក្តៅក្រហាយខាងក្រោយ ។ ជនទាំងឡាយ បែងចែកហើយ ទើបធ្វើការងារទាំងឡាយ ដែលមិនមានសេចក្តីក្តៅក្រហាយក្នុងលោក ការងារទាំងនោះ ជាអំពើដែលអ្នកប្រាជ្ញសរសើរហើយថា មានសេចក្តីសុខជាកម្រៃ ជាអំពើដែលអ្នកប្រាជ្ញចុះអនុមតិហើយ ។ បពិត្រព្រះអង្គជាធំជាងជន ពួកឆ្មាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាតមកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ អង្គុយលើព្រះឧរូនៃមាតា ត្រូវពួកទូតទាំងនោះ ទង់ទាញមកដោយរហ័ស ទូលព្រះបង្គំជាខ្ញុំ បានដល់នូវមរណភ័យដ៏ក្តៅក្រហាយ យ៉ាងចង្អៀត លំបាកក្រៃពេក បពិត្រព្រះរាជា ជីវិតដែលជាទីស្រឡាញ់ដូចមធុរស ទូលព្រះបង្គំជាខ្ញុំបានហើយ ថ្ងៃនេះទូលព្រះបង្គំជាខ្ញុំ បានរួចចាកការសម្លាប់ ដោយលំបាក ទូលព្រះបង្គំជាខ្ញុំ មានចិត្តឱនឆ្ពោះទៅក្នុងបព្វជ្ជាតែម្យ៉ាង ។

[ ៣០៥ ] ( ព្រះរាជា... ) ម្នាលសុធម្មាទេវី សោមនស្សកុមារ ជាបុត្តរបស់នាងនេះ នៅក្មេង ជាអ្នកអនុគ្រោះ ថ្ងៃនេះ ខ្ញុំអង្វរកុមារនោះពុំបានសោះ ក្រែងតែនាងទើបអង្វរកនូវកុមារនោះបាន ។

[ ៣០៦ ] ( សុធម្មាទេវី... ) ហៃបា ចូរអ្នកត្រេកអរក្នុងភិក្ខាចរិយវត្តចុះ ចូរអ្នកពិចារណាធម៌ទាំងឡាយ ហើយបួសចុះ អ្នកចូរទម្លាក់ចោលនូវអាជ្ញា ក្នុងពួកសត្វទាំងអស់ចេញ មិនមានអ្នកណានិន្ទាបាន ហើយចូលទៅកាន់ឋានព្រហ្មលោកចុះ ។

( ព្រះរាជា... ) ម្នាលនាងសុធម្មា នាងនិយាយពាក្យណា ( ពាក្យនោះ ) ជាអស្ចារ្យក្រៃពេក នាងឈ្មោះថា ញុំាងខ្ញុំដែល ដល់នូវសេចក្ដីទុក្ខ ឲ្យរឹតតែបានទុក្ខឡើង កាលខ្ញុំនិយាយថា ចូរនាងអង្វរករបុត្ត នាងបែរជាញុំាងកុមារឲ្យប្រឹងប្រែងវិញ ។

[ ៣០៧ ] ( សុធម្មាទេវី... ) ព្រះអរិយៈទាំងឡាយណា រួចស្រឡះហើយ ( ចាករាគាទិក្កិលេស ) ជាអ្នកបរិភោគនូវភោជនមិនមានទោសវិលត់ហើយ តែងត្រាច់ទៅកាន់លោកនេះ ខ្ញុំម្ចាស់មិនអាចហាមឃាត់ព្រះរាជកុមារដែលកំពុងដើរទៅកាន់ផ្លូវរបស់ព្រះអរិយៈនោះបានទេ ។

[ ៣០៨ ] ( ព្រះរាជា... ) ជនទាំងឡាយណា ប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ នាងសុធម្មាទេវីនេះ ជាស្ត្រីមានសេចក្ដីខ្វល់ខ្វាយតិច ប្រាសចាកសេចក្ដីសោក ព្រោះបានស្ដាប់ពាក្យសុភាសិតទាំងឡាយនៃពួកជនណា ជនទាំងនោះ គួរអ្នកផងគប់រកដោយពិត ។

## ចប់ សោមនស្សជាតក ទី ៩

# អដ្ឋកថា

# សោមនស្សជាតក

[ ២៩៣-៣០៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកាពដែលទេវទត្តព្យាយាមដើម្បីផ្តាច់ព្រះជន្មព្រះអង្គ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោ តំ ហឹសតិ ហេឋេតិ** ដូច្នេះជាដើម ។

ក្នុងកាលនោះ ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តនេះ ក៏ព្យាយាមដើម្បីសម្លាប់តថាគតដូចគ្នា ហើយទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមថារេណុរាជ សោយរាជសម្បត្តិក្នុងឧត្តរបញ្ចាលនគរ ដែនកុរុ ។ កាលនោះ តាបសឈ្មោះ មហារក្ខិតៈ មានតាបស ៥០០ ជាបរិវារ នៅក្នុងហិមវន្តប្បទេស ត្រាច់ចារិកទៅ ដើម្បីសេពរសជូរប្រៃ រហូតដល់ឧត្តរបញ្ចាលនគរ សម្រាកក្នុងព្រះរាជឧទ្យាន ។ ស្អែកឡើង មួយអន្លើដោយបរិវារ ត្រាច់ទៅបិណ្ឌបាតរហូតដល់ទ្វារព្រះនគរ ព្រះបាទរេណុរាជទ្រង់ឃើញគណៈឥសី មានចិត្តជ្រះថ្លាក្នុងឥរិយាបថ ទើបនិមន្តឲ្យមកគង់ក្នុងល្វែងប្រាសាទដែលប្រដាប់តាក់តែងហើយ ទ្រង់អង្គាសដោយអាហារដ៏ប្រណីត ហើយត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយនៅចាំវស្សាត្រង់ព្រះរាជឧទ្យានរបស់ខ្ញុំ អស់រដូវភ្លៀងនេះចុះ ហើយយាងទៅកាន់ព្រះរាជឧទ្យានជាមួយតាបសទាំងនោះត្រាស់ឲ្យសាងលំនៅ ព្រះ

រាជទានបញ្ជិតបរិក្ខារ ទ្រង់នមស្ការហើយ យាងត្រឡប់មកកាន់រាជវាំង ។ តាំងអំពីនោះមក តាបសទាំងអស់ ក៏ទទួលព្រះរាជទាន ឆាន់ក្នុងព្រះរាជនិវេសន៍ជាប្រចាំ ។ ព្រះរាជាមិនមានព្រះរាជឱរស ទើបទ្រង់ប្រាថ្នាចង់បានព្រះរាជឱរស ។ ព្រះរាជឱរសក៏មិនបានកើតឡើងសមព្រះរាជបំណងឡើយ ។ រដូវភ្លៀងបានកន្លងផុតទៅ ៣ ខែហើយ មហារក្ខិតតាបស ក៏ចូលទៅថ្វាយព្រះពរលាព្រះរាជាថា ឥឡូវនេះ នៅឯព្រៃហិមពាន្ត ជារមណីយដ្ឋាន ពួកអាត្មានឹងទៅឯហិមពាន្តនោះវិញ កាលព្រះរាជាទ្រង់ធ្វើសក្ការបូជាហើយ ទើបចេញពីព្រះរាជឧទ្យានទៅ លុះដល់ថ្ងៃត្រង់ ក៏ចៀងចុះអំពីផ្លូវ នាំបរិស័ទអង្គុយត្រង់ទួលមួយ ដែលមានស្បូវក្លាំងដុះខ្ចីៗ ខាងក្រោមដើមឈើ ដែលមានម្លប់ត្រជាក់មួយដើម ។

តាបសទាំងនោះ អង្គុយប្រជុំសន្ទនាគ្នាថា ក្នុងព្រះរាជវាំងមិន មានព្រះរាជឱរសដែលបន្តវង្សឡើយ បើព្រះរាជាគប្បីបានព្រះរាជឱរស ជាការល្អនោះឯង ព្រោះបានបន្តវង្សត្រកូលតទៅ ។ ព្រះមហារក្ខិតតាបសបានឮពាក្យរបស់តាបសទាំងនោះហើយ បានពិចារណាមើលថា ព្រះរាជានឹងមានព្រះរាជឱរសឬហ្ន៎ បានដឹងថា នឹងមាន ទើបពោលឡើងថា អាវុសោទាំងឡាយ ពួកលោកកុំគិតថ្វីឡើយ ថ្ងៃនេះ ក្នុងវេលាទៀបភ្លឺទេវបុត្តមួយអង្គចុតិមកបដិសន្ធិក្នុងព្រះឧទរនៃអគ្គមហេសីរបស់ព្រះរាជា ។ សម័យនោះ ជដិលខិលខូចម្នាក់បានឮដូច្នោះ គិតថា អញនឹងបានជារាជកុលុបកៈ ចាប់ពីពេលនេះទៅ ទើបក្នុងកាលដែលពួកតាបសចេញដំណើរទៅ ក៏ក្លែងធ្វើជាឈឺ ហើយដេក

ត្រូវពួកតាបសដទៃៗដាស់តឿនថា ក្រោកឡើង ពួកយើងនឹងទៅទាំងអស់គ្នា ក៏ឆ្លើយថា ខ្ញុំមិនអាចទៅបានទេ ។ មហារក្ខិតតាបសដឹងហេតុ ដែលតាបសនោះក្លែងធ្វើជាដេក ទើបពោលថា បើលោកអាចទៅបានក្នុងកាលណា ចូរមកក្នុងកាលនោះចុះ ដូច្នេះហើយ នាំពួកឥសីធ្វើដំណើរទៅកាន់ហិមវន្តប្បទេស ។ ឯតាបសកោង ប្រញាប់ត្រឡប់ទៅដោយរហ័ស ឈរត្រង់រាជទ្វារ ប្រើឲ្យរាជបុរសទៅទូលព្រះរាជាថា តាបសឧបដ្ឋាកព្រះមហារក្ខិតតាបសមកគាល់ កាលព្រះរាជា ត្រាស់បញ្ជាឲ្យនិមន្តចូលទៅគាល់ ទើបឡើងទៅកាន់ប្រាសាទ អង្គុយលើអាសនៈដែលគេក្រាលទុកហើយ ។ ព្រះរាជាទ្រង់ថ្វាយបង្គំតាបស ហើយប្រថាប់គង់ក្នុងចំណែកម្ខាង ត្រាស់សួរដល់សុខភាព និងអនាម័យនៃឥសីទាំងឡាយ ហើយត្រាស់ថា លោកម្ចាស់រួសរាន់ត្រឡប់មកដូច្នេះ ដោយហេតុអ្វី្ន តាបសកោងថ្វាយព្រះពរថា ថ្វាយព្រះពរ ពិតហើយ ឥសីទាំងនោះអង្គុយសម្រាកតាមសប្បាយ នាំគ្នាសន្ទនាគ្នាថា បើទ្រង់មានព្រះរាជឱរសបន្តរាជវង្ស កើតឡើងសោត សេចក្តីនោះជាការល្អ ដូច្នេះហើយ អាត្មាបានស្តាប់ពាក្យសន្ទនានោះហើយ ប្រមើលមើលដោយទិព្វចក្ខុថា មហាបពិត្រនឹងមានព្រះរាជឱរសដែរឬហ្ន៎ ក៏បានឃើញថា ទេវបុត្តអ្នកមានឫទ្ធិច្យុតិមកកើតក្នុងព្រះឧទរនៃព្រះនាងសុធម្មាអគ្គមហេសី ទើបគិតថា បុគ្គលដែលមិនដឹង គប្បីទម្លាយព្រះគភ៌ឲ្យវិនាស ទើបអាត្មាចាំបាច់ទូលដល់មហាបពិត្រទាំង ២ ទើបប្រញាប់មក ដើម្បីថ្វាយព្រះពរឲ្យទ្រង់ជ្រាប ឥឡូវនេះ អាត្មាក៏បានថ្វាយព្រះពរឲ្យទ្រង់ជ្រាបហើយ នឹងថ្វាយព្រះពរ លាទៅ ។ ព្រះបាទ

វេណុរាជទ្រង់មានព្រះទ័យសោមនស្ស មានព្រះទ័យជ្រះថ្លា ត្រាស់ថាបពិត្រលោកម្ចាស់ លោកម្ចាស់កុំទាន់ទៅអី ដូច្នេះហើយ នាំតាបសកោងទៅកាន់ព្រះរាជឧទ្យាន រៀបចំទីលំនៅក្នុងព្រះរាជឧទ្យាន ។ តាំងអំពីនោះមក តាបសកោងនោះ ក៏ពំនាក់អាស្រ័យ ទំពាធាន់ក្នុងរាជត្រកូល រហូតមានឈ្មោះថា ទិព្វចក្ខុតាបសនោះឯង ។

កាលនោះ ព្រះពោធិសត្វចុតិអំពីតាវត្តិង្សពិភព មកបដិសន្ធិក្នុងព្រះឧទរនៃព្រះនាងសុធម្មាទេវីនោះ ក្នុងនគរនោះ ។ ក្នុងថ្ងៃថ្វាយព្រះនាម ព្រះរាជកុមារនោះ ទើបព្រះរាជមាតាបិតាថ្វាយព្រះនាមថា សោមនស្សកុមារ ។ ព្រះរាជឱរសទ្រង់ចម្រើនព្រះជន្មវស្សាដោយកុមារបរិហារតាមលំដាប់ ។ ឯតាបសកោងចាត់ចែងដាំបន្លែដែលឧបការៈដល់សូបៈ និងវល្លិផល គឺដើមឈើដែលមានវល្លិ មានប្រការផ្សេងៗ ត្រង់ជាយព្រះរាជឧទ្យានមួយកន្លែង ហើយលក់ដូរក្នុងទីផ្សារ ប្រមូលទ្រព្យទុក ។ ក្នុងកាលព្រះពោធិសត្វមាន ព្រះវស្សាបាន ៧ ឆ្នាំ ជាយដែនរាជអាណាខេត្តកើតបះបោរចលាចល ។ ព្រះបាទវេណុរាជត្រាស់ផ្តាំផ្ញើថា ចូរបាកុំប្រមាទក្នុងទិព្វចក្ខុតាបស ទ្រង់ឲ្យព្រះរាជកុមារទទួលពាក្យហើយយាងទៅ ដោយបំណងថា យើងនឹងរៀបចំឲ្យបច្ចន្តជនបទស្ងប់រម្ងាប់ ។ ថ្ងៃមួយ ព្រះរាជកុមារគិតថា អញនឹងទៅសួរសុខទុក្ខតាបស ទើបយាងទៅកាន់ព្រះរាជឧទ្យាន ឃើញជដិលកោងស្លៀកកាសាវពស្ត្រមួយផ្ទាំង ដណ្តប់មួយផ្ទាំង ដៃទាំង ២ យួរទឹកម្ខាងមួយក្អម កំពុងស្រោចបន្លែក្នុងចម្ការបន្លែ ក៏ទ្រង់ជ្រាបថា ជដិលនេះជាជដិលកោង មិន

បំពេញសមណធម៌របស់ខ្លួន រលំដាំបន្លែ ធ្វើចម្ការ ទើបទ្រង់សាកសួរ ឲ្យជដិលកោងនោះបាននូវសេចក្តីខ្មាសថា បពិត្រគហបតីជាឈ្មួញបន្លែ លោកកំពុងធ្វើអ្វី ។ ហើយមិនបានថ្វាយបង្គំ យាងត្រឡប់ទៅកាន់ព្រះនគរ ។ ជដិលកោងគិតថា ឥឡូវនេះ ព្រះរាជកុមារនេះ ជាសត្រូវរបស់អញហើយ អ្នកណានឹងដឹងនូវការវិនាសណាមួយនឹងមាន អញគួរកម្ចាត់ព្រះរាជកុមារតាំងពីឥឡូវនេះទៅនោះឯង ។ ក្នុងកាលព្រះរាជាជិតយាងមក ទើបបោះដុំថ្មគរទុកក្នុងចំណែកម្ខាង វាយបំបែកក្អមទឹក បាចស្មៅបោះលើបណ្ណសាលា យកប្រេងលាបខ្លួន ចូលទៅកាន់បណ្ណសាលា ដេកទទូរលើគ្រែ ធ្វើហាក់ដូចជាដល់នូវសេចក្តីទុក្ខធំ ។ ព្រះរាជាកាលយាងមក ទ្រង់ធ្វើប្រទក្សិណ ព្រះនគរមិនទាន់ចូលព្រះរាជនិវេសន៍ ទ្រង់គិតថា អញនឹងសួរសុខទុក្ខទិព្វចក្ខុតាបស លោកម្ចាស់អញជាមុនសិន ហើយយាងទៅដល់ទ្វារបណ្ណសាលា ទតឃើញអាការដែលវិបរិតបែបនោះ ទ្រង់ព្រះតម្រិះថា នេះរឿងអ្វីហ្ន៎ ទើបចូលទៅទតឃើញជដិលកោងនោះដេក ស្ទាបជើងទាំង ២ របស់ជដិលកោង ត្រាស់គាថាដំបូងថា

> នរណាប្រហារលោក ជេរលោក ម្តេចក៏លោកអាក់អន់ចិត្ត មិនត្រេកអរ សោកសង្រេងម្ល៉េះ ថ្ងៃនេះ ចង់មាតាបិតារបស់នរណាទួញយំ ថ្ងៃនេះ ចង់នរណាត្រូវគេបៀតបៀនដេកលើផែនដី ( ក៏លោកមិនត្រូវជាអុកជាទុក្ខទេ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហឹសតិ** បានដល់ វាយ ។ បទថា **ហេ–**

**ឃេតិ** បានដល់ ដេរ ។ បទថា **ក្វជ្ជ សេតុ** សេចក្ដីថា ថ្ងៃនេះ អ្នកណាមកបៀតបៀន អុកឡុកឲ្យលោកម្ចាស់ដេកលើផែនដី ។ ជដិលកោងបានឮព្រះតម្រាស់នោះ ទើបដកដង្ហើមធំ ក្រោកឡើង ពោលគាថាទី ២ ដូច្នេះថា

បពិត្រព្រះសម្មតិទេព អាត្មាភាពត្រេកអរដោយការបានឃើញ
នូវព្រះអង្គ បពិត្រព្រះភូមិបាល អាត្មាភាពឃើញព្រះអង្គយូរ
ហើយ បពិត្រព្រះសម្មតិទេព ព្រះនាមវេណុ អាត្មាភាពមិន
មែនជាអ្នកបៀតបៀនទេ ប៉ុន្តែអាត្មាភាព ត្រូវព្រះរាជបុត្តរបស់
ព្រះអង្គចូលមកបៀតបៀនហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហឹសកោ** សេចក្ដីថា អាត្មាមិនបៀតបៀនបុគ្គលណាមួយ ជាអ្នកដល់ព្រមដោយសីលនិងអាចារ ។ បទថា **វេណុ-មនុបវិស្ស** សេចក្ដីថា សូមថ្វាយព្រះពរវេណុមហារាជ អាត្មាចូលមកនៅអាស្រ័យ ។ បទថា **ហេឋយិតោស្មិ** សេចក្ដីថា អាត្មាត្រូវឱរសរបស់ទ្រង់នាំពួកបរិវារជាច្រើនមក មើលងាយ ប្រមាថថា វ៉ុយតាបសកោង ព្រោះហេតុអ្វី ទើបឯងមកនៅទីនេះ ដូច្នេះហើយ ចាប់ជុំថ្មបោះចោល វាយបំបែកក្អមទឹក លើសពីនេះទៅទៀត វាយទះតប់បៀតបៀនអាត្មាទៀតផង ។ តាបសនោះ ពោលកុហក ធ្វើហាក់ដូចជាពិត ទូលឲ្យព្រះរាជាទ្រង់ជឿ ដោយប្រការ ដូច្នេះ ។

ខាងមុខអំពីនេះទៅគប្បីជ្រាបគាថាព័ន្ធ ដែលគន្ថរចនាចារ្យចងទុកងាយៗតាមវារៈព្រះបាលីថា

ពួកអ្នកចាំទ្វារមានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាត ចូរមក ចូរទៅខាងក្នុងបុរី ចូរសម្លាប់សោមនស្សកុមារនោះ កាត់ក្បាល ដ៏ប្រសើរ នាំមកឲ្យអញ ។

ពួករាជទូត ដែលព្រះរាជា ទ្រង់បញ្ជូនទៅហើយ បាន និយាយនឹងព្រះរាជកុមារយ៉ាងនេះថា បពិត្រក្សត្រ ព្រះអង្គ ទ្រង់ធ្វេសផុតចាកឥស្សរភាពហើយ ព្រះអង្គដល់នូវសេចក្តីស្លាប់ ហើយ ។

ព្រះរាជបុត្តនោះ ក៏ទ្រង់បរិទេវនាការ ផ្គងក្រពុំម្រាមព្រះ ហស្តទាំង ១០ ថា បពិត្រព្រះអង្គជាធំជាងជន ចំណែកទូល ព្រះបង្គំជាខ្ញុំ ចង់ឃើញព្រះអង្គ អ្នកទាំងឡាយ ចូរនាំយើង ទាំងរស់ទៅក្រាបបង្គំថ្វាយ ( ដល់ព្រះមហាក្សត្រ ) ចុះ ។

ពួករាជទូតបានស្តាប់វាចា របស់ព្រះរាជបុត្តនោះហើយ ក៏ នាំព្រះរាជបុត្តទៅថ្វាយព្រះរាជា ចំណែកខាងព្រះរាជបុត្ត លុះ បានឃើញព្រះរាជបិតាហើយ ក៏ក្រាបបង្គំទូលអំពីចម្ងាយថា

បពិត្រព្រះជនិន្ទ ពួកអ្នកចាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាតមកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ ថ្ងៃនេះ ទូល ព្រះបង្គំជាខ្ញុំ មានកំហុសដូចម្តេចក្នុងរឿងនេះ ទូលព្រះបង្គំសួរ ហើយ សូមទ្រង់ប្រាប់សេចក្តីនុ៎ះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាយន្តុ** សេចក្តីថា ព្រះបាទរេណុរាជ ទ្រង់

ព្រះពិរោធរាជកុមារថា តាំងអំពីកាលដែលបានបដិបត្តិខុស ក្នុងលោកម្ចាស់របស់យើងហើយ សោមនស្សក្រុមារនោះ នឹងមិនខ្មាសក្នុងខ្លួនអញ កាលត្រាស់បង្គាប់ឲ្យសម្រេចទោសព្រះរាជកុមារ ទើបត្រាស់យ៉ាងនេះ ។ បទថា **កាសាវិយា** សេចក្តីថា ព្រះបាទរេណុរាជត្រាស់ថា នែពួកពេជ្ឈឃាតទាំងអស់ ដែលមានពូថៅក្នុងដៃ ចូរមកដោយទំនៀមរបស់ខ្លួន ។ បទថា **វរំ** សេចក្តីថា ចូរកាត់នូវក្បាលដ៏ប្រសើរ គឺអវយវៈខាងលើនាំមកឲ្យអញ ។ បទថា **រាជិនោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ទូតទាំងឡាយដែលព្រះរាជាទ្រង់បញ្ជូនទៅអំពីព្រះរាជសម្នាក់ នាំគ្នាប្រញាប់ទៅ ចោមរោមចាប់ព្រះរាជកុមារ ដែលព្រះរាជមាតាទ្រង់ប្រដាប់តាក់តែងហើយ ឲ្យប្រថាប់គង់លើភ្លៅរបស់ព្រះនាង ហើយនាំគ្នាទូលនូវសេចក្តីនោះ ។ បទថា **ឥស្សរេន** សំដៅដល់ព្រះរាជា ។ បទថា **វិតិណ្ណាសិ** សេចក្តីថា ព្រះអង្គត្រូវព្រះរាជាកាត់ផ្តាច់ហើយ ។

បទថា **ស រាជបុត្តោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជឱរសទ្រង់ស្តាប់ពាក្យរបស់ទូតទាំងនោះហើយ តក់ស្លុតក្នុងព្រះហឫទ័យ ខ្លាចចំពោះមរណភ័យ ក្រោកឡើងអំពីភ្លៅរបស់ព្រះរាជមាតា ។ បទថា **បដិ-ឧស្សយេថ** សេចក្តីថា អ្នកទាំងឡាយ ចូរនាំយើងទៅគាល់ ។ បទថា **តស្ស** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ទូតទាំងនោះ ស្តាប់ព្រះតម្រាស់របស់ព្រះរាជកុមារហើយ ទើបផ្អាកការប្រហារជីវិតសិន ហើយយកខ្សែចងព្រះរាជកុមារដឹកទៅគាល់ព្រះរាជា ដូចមនុស្សដឹកគោទៅដូច្នោះ កាលពួកពេជ្ឈឃាត

កំពុងដឹកព្រះរាជកុមារទៅ ព្រះនាងសុធម្មារាជទេវី មួយអន្លើដោយស្រីស្នំ ចោមរោមដោយពួកទាសី ព្រមទាំងអ្នកនគរទាំងឡាយ នាំគ្នាពោលថា ពួកយើងមិនព្រមឲ្យព្រះរាជាសម្រេចទោសព្រះរាជកុមារ ដែលមិនមានកំហុស ហើយនាំគ្នាតាមទៅជាមួយព្រះរាជកុមារនោះ ។ បទថា **អាគច្ឆុំ** សេចក្ដីថា ពួកពេជ្ឈឃាតមកកាន់សម្នាក់ព្រះរាជា ដើម្បីដាក់ព្រះរាជអាជ្ញា ។ បទថា **ហន្តុំ មមំ** សេចក្ដីថា ដើម្បីសម្លាប់ទូលព្រះបង្គំ ។ បទថា **កោធឹង** សេចក្ដីថា ព្រះរាជកុមារទូលសួរថា ព្រះរាជបិតាត្រាស់ឲ្យប្រហារជីវិតខ្ញុំ ដោយប្រការណា អ្វីហ្ន៎ជាកំហុសនៃខ្ញុំក្នុងរឿងនេះ ។

ព្រះបាទរេណុរាជសម្ដេចថា ភវគ្គព្រហ្មនៅទាបពេក ទោសរបស់ឯងខ្ពស់ជាងនេះ កាលទ្រង់ប្រាប់ទោសកំហុសរបស់រាជកុមារ ទើបត្រាស់គាថានេះថា

ទិព្វចក្ខុតាបស ជាអ្នកមិនធ្វេសប្រហែស ធ្វើការស្រោចទឹក
បូជាភ្លើងរាល់ពេលល្ងាចព្រឹក ព្រោះហេតុអ្វី បានជាឯងហៅ
ទិព្វចក្ខុតាបសនោះ ដែលជាអ្នកមានសេចក្ដីសង្រួម ជាអ្នក
ប្រព្រឹត្តនូវធម៌ដ៏ប្រសើរមានសភាពដូច្នោះថាជាគហបតី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទកំ សជាតិ** សេចក្ដីថា ធ្វើនូវការចុះក្នុងទឹក ។ បទថា **តំ តាធិសំ** សេចក្ដីថា ព្រះបាទរេណុរាជត្រាស់ថា ព្រោះហេតុអ្វី ទើបហៅទិព្វចក្ខុតាបសលោកម្ចាស់របស់យើងបែបនោះ ដោយពាក្យថា គហបតី ។

លំដាប់នោះ ព្រះរាជកុមារទូលថា បពិត្រព្រះអង្គ ទូលព្រះបង្គំហៅគហបតីដោយពាក្យថាគហបតី ដូច្នេះ តើនឹងមានទោសដែរឬ ដូច្នេះ ហើយបានត្រាស់គាថានេះថា

បពិត្រព្រះសម្មតិទេព វត្ថុទាំងឡាយនៃកុលុបកៈនោះ មានច្រើនយ៉ាងណាស់ គឺផ្លែត្នោតផង ត្រាវនិងជំឡូងផង ផ្លែឈើវល្លិទាំងឡាយផង កុលុបកតាបសរបស់ព្រះអង្គនោះ ជាអ្នកមិនមានសេចក្ដីធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវវត្ថុទាំងនោះ ព្រោះហេតុនោះ បានជាទូលព្រះបង្គំជាខ្ញុំ ហៅតាបសនោះថា គហបតី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មូលា** បានដល់ ពូជទាំងឡាយ មានពូជដែលកើតអំពីឫសជាដើម ។ បទថា **ផលា** បានដល់ ផ្លែវល្លិផលាផលច្រើនប្រភេទ ។ បទថា **តេ រក្ខតិ គោបយតប្បមត្តោ** សេចក្ដីថា កុលុបកតាបសរបស់ព្រះបិតានេះ ធ្វើនូវការដាំបន្លែ អង្គុយយាម មិនប្រមាទ ធ្វើរបងព័ទ្ធជុំវិញ គ្រប់គ្រងរក្សា ដោយហេតុនោះឯង ទើបកុលុបកតាបសនោះ ឈ្មោះថាជាព្រាហ្មណគហបតីរបស់ព្រះរាជបិតា ។ ព្រោះហេតុនោះ ទើបទូលព្រះបង្គំហៅតាបសនោះថា គហបតី ការដែលទូលព្រះបង្គំក្រាបទូលមក បើព្រះបិតាទ្រង់មិនជឿ សូមត្រាស់ឲ្យសួរអ្នកលក់បន្លែ ត្រង់ទ្វារទាំង ៤ ចុះ ។

ព្រះរាជាក៏ត្រាស់ឲ្យរាជបុរសទៅហៅអ្នកលក់បន្លែមកសាកសួរ អ្នកលក់បន្លែទាំងឡាយក៏នាំគ្នាក្រាបទូលថា បពិត្រព្រះអង្គ ជាការពិត ពួកទូលព្រះ

បន្តិចវិញបន្ទែបន្ការនិងផ្លែឈើអំពីដៃរបស់តាបសរូបនេះពិត ។ សោមទត្ត រាជកុមារត្រាស់ឲ្យក្អាក់ងារពិសោធមើល ធ្វើឲ្យឃើញប្រចក្ស រាជបុរស របស់កុមារចូលទៅកាន់បណ្ណសាលារបស់តាបសនោះ ហើយឆែកឆេរមើល នាំយកកញ្ចប់កហាបណមាសក ដែលបានអំពីការលក់បន្លែមកថ្វាយ ដើម្បី បញ្ជាក់ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ជ្រាបថា ព្រះមហាសត្វមិនមានកំហុស ទើបត្រាស់ព្រះគាថាដោយសេចក្ដីថា

ម្នាលកុមារ អ្នកនិយាយពាក្យនេះ ពិតមែន របស់ទាំងឡាយ
នៃកុលុបកតាបសនោះ មានច្រើនយ៉ាង កុលុបកតាបសនោះ
ជាអ្នកមិនធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវរបស់ទាំងនោះ
ព្រោះហេតុនោះ ព្រាហ្មណ៍ក្លាយជាគហបតី ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា កាលដែលអញចូលព្រៃ ហិមពាន្ត ហើយបួស ល្អជាងនៅក្នុងសម្នាក់របស់ព្រះរាជាល្ងង់ខ្លៅបែបនេះ ហើយពោលទោសរបស់ព្រះរាជាឲ្យជាក់ច្បាស់ ក្នុងកណ្ដាលបរិស័ទនោះឯង ហើយក្រាបទូលថា ខ្ញុំនឹងទូលលាទៅបព្វជ្ជាក្នុងថ្ងៃនេះឯង ។ ព្រះពោធិសត្វ ធ្វើសក្ការៈដល់បរិស័ទហើយ ត្រាស់ព្រះគាថាដោយសេចក្ដីថា

បរិស័ទព្រមទាំងអ្នកនិគម អ្នកជនបទ ដែលបានមកចួបជុំ
ទាំងអស់គ្នា ចូរស្ដាប់ពាក្យរបស់ខ្ញុំ ព្រះរាជានោះជាបុគ្គលពាល
ស្ដាប់តែពាក្យតាបសពាល ប្រើគេឲ្យសម្លាប់ខ្ញុំ ដោយការមិន
សមហេតុ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពាលាយំ ពាលស្ស** សេចក្ដីថា ព្រះរាជានេះជាពាលដោយព្រះអង្គឯង ស្ដាប់នូវពាក្យរបស់ជដិលកោងដែលជាពាល ហើយត្រាស់ឲ្យគេសម្លាប់យើង ដោយមិនមានហេតុផល ។

ព្រះពោធិសត្វត្រាស់ដូច្នេះហើយ ថ្វាយបង្គំព្រះបិតា ឲ្យទ្រង់អនុញ្ញាតបព្វជ្ជា ហើយត្រាស់គាថាក្រៅអំពីនេះថា

នាកាលឫសគល់ចម្រើនមាំធំឡើង ឫស្សីដែលបែកមែកហើយ
បុគ្គលមិនងាយនឹងគាស់ចេញទេ បពិត្រព្រះជនិន្ទ ទូលព្រះ
បង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះបាទាព្រះអង្គ បពិត្រព្រះសម្មតិទេព
សូមព្រះអង្គទ្រង់អនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ
សូមចេញបួស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិសាខេ** សេចក្ដីថា ( ឫស្សី ) ដែលបែកគុម្ពធំ ។ បទថា **ទុន្និក្ខយោ** សេចក្ដីថា លំបាកនឹងដកឲ្យអស់ណាស់ ។

បន្ទាប់អំពីនេះទៅ ជាប្រព័ន្ធគាថាឆ្លើយឆ្លងរវាងព្រះរាជានិងព្រះរាជឱរស

ម្នាលកុមារ អ្នកចូរបរិភោគនូវភោគៈទាំងឡាយដ៏ច្រើនចុះ បិតានឹងប្រគល់ឥស្សរិយយសទាំងអស់ដល់អ្នក អ្នកចូរសោយរាជ្យជាស្ដេចរបស់អ្នកកុរុក្នុងថ្ងៃនេះឯង អ្នកកុំបួសឡើយ ដ្បិតថា បព្វជ្ជាជាកិច្ចលំបាកណាស់ ។

សោមនស្សកុមារក្រាបទូលថា

បពិត្រព្រះសម្មតិទេព ភោគសម្បទរបស់ព្រះអង្គ រាប់ថាមាន

ដូចម្តេចកើតក្នុងមនុស្សលោកនេះ ក្នុងកាលមុន ទូលព្រះបង្គំជាខ្ញុំ ធ្លាប់បានត្រេកអរដោយ រូប សំឡេង រស ក្លិន ផ្សព្វ ជាទីសម្រើបចិត្ត ក្នុងទេវលោកមកហើយ ។ បពិត្រព្រះសម្មតិទេព ឯភោគសម្ប័ទទាំងឡាយ ទូលព្រះបង្គំជាខ្ញុំ ធ្លាប់បរិភោគហើយក្នុងទេវលោកឈ្មោះតាវត្តិង្ស ទូលព្រះបង្គំជាខ្ញុំជាបុគ្គលធ្លាប់មានពួកស្រីអប្សរ ចោមរោមហើយ ឯទូលព្រះបង្គំជាខ្ញុំស្គាល់ព្រះអង្គថា ជាមនុស្សពាល ដែលត្រូវតែគេដឹកនាំបាន ( ទូន្មាន ) ទូលព្រះបង្គំជាខ្ញុំ មិនត្រូវនៅក្នុងរាជត្រកូលបែបព្រះអង្គទេ ។

ព្រះរាជាត្រាស់ថា

នែកូន បើបិតាជាមនុស្សពាល ដែលត្រូវតែគេដឹកនាំ ក៏សូមអ្នកអត់ទោសកំហុសម្តងដល់យើងចុះ ម្នាលសោមទត្ត បើទោសយ៉ាងនេះនឹងមានម្តងទៀតចូរអ្នកធ្វើតាមមតិចុះ ដូច្នេះ ។

បទថា **ឧក្កា** សេចក្តីថា ព្រះរាជាត្រាស់អង្វរព្រះរាជឱរសថា កូនសម្លាញ់ ឈ្មោះថា ការបួសជាទុក្ខ ព្រោះត្រូវមានជីវិតទាក់ទងដោយអ្នកដទៃ ឯងកុំបួសឡើយ ចូរធ្វើជាព្រះរាជាចុះ ។

បទថា **កិន្នុធ ទេវ** សេចក្តីថា បពិត្រព្រះអង្គ ទ្រង់គុណដ៏ប្រសើរភោគសម្បត្តិរបស់ព្រះរាជបិតាណា មានក្នុងរាជធានីនេះ ភោគសម្បត្តិទាំងនោះរបស់ឯណាសមគួរ ដែលខ្ញុំគប្បីបរិភោគប្រើប្រាស់បាន មានឬ ។

បទថា **បរិវារិតោ** សេចក្ដីថា ទូលព្រះបង្គំដែលទេពអប្សរធ្លាប់បម្រើមកហើយ ។ ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។

បានឮថា ព្រះញាណរឭកជាតិ បានកើតឡើងដល់ព្រះពោធិសត្វ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់យ៉ាងនេះ ។

បទថា **បរនេយ្យំ** សេចក្ដីថា ទ្រង់ជាពាល ត្រូវអាស្រ័យអ្នកដទៃនាំទៅដោយឈើច្រត់ ដូចមនុស្សភ្នែកខ្វាក់ ។

បទថា **តាធិសេ** សេចក្ដីថា ព្រះពោធិសត្វត្រាស់យ៉ាងនេះ ដើម្បីឲ្យព្រះរាជបិតាទ្រង់ជ្រាបថា បណ្ឌិតមិនគប្បីនៅក្នុងសម្នាក់របស់ព្រះរាជាបែបនោះ ទូលព្រះបង្គំរួចជីវិតបានក្នុងថ្ងៃនេះ ដោយកម្លាំងប្រាជ្ញារបស់ខ្លួន ទូលព្រះបង្គំនឹងនៅក្នុងសម្នាក់របស់ព្រះបិតាបានដូចម្ដេច ។

បទថា **យថាមតី** សេចក្ដីថា ព្រះបាទវរណរាជ ទ្រង់សូមឲ្យព្រះរាជឱរសអត់ទោសឲ្យថា បើទោសកំហុសបែបនេះរបស់បិតាគប្បីមានទៀតសោតកាលនោះ ចូរបាធ្វើតាមអធ្យាស្រ័យចុះ ។

ព្រះមហាសត្វកាលនឹងថ្វាយឱវាទដល់ព្រះបិតាទើបត្រាស់គាថា ៨ ថា

> ការងារ ដែលបុគ្គលមិនបានពិចារណាហើយធ្វើ គំនិតដែលបុគ្គលមិនកំណត់ហើយគិត រមែងមានផលអាក្រក់ ដូចជាការផ្សំថ្នាំខុសដូច្នោះ ។ ឯការងារដែល បុគ្គលពិចារណាហើយទើបធ្វើ គំនិតដែលបុគ្គលកំណត់ត្រឹមត្រូវហើយទើបគិតរមែងមានផលដ៏ចម្រើន ដូចជាការផ្សំថ្នាំត្រូវដូច្នោះឯង ។

គ្រហស្ថអ្នកបរិភោគកាមខ្ជិល មិនល្អ អ្នកបួសមិនសង្រួម មិនល្អ ព្រះរាជាអ្នកមិនពិចារណាហើយធ្វើ មិនល្អ បណ្ឌិតដែលមានសេចក្តីក្រោធការក្រោធនោះ ក៏មិនល្អឡើយ ។

បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រត្រូវពិចារណាហើយសឹមធ្វើ មិនត្រូវធ្វើទាំងមិនពិចារណាទេ បពិត្រព្រះរាជា ដ្បិតថា យសនិងសេចក្តីសរសើរ រមែងចម្រើនដល់បុគ្គលអ្នកពិចារ-ណាហើយ ទើបធ្វើ ។

បពិត្រព្រះភូមិបាល បុគ្គលជាធំ ត្រូវតែពិចារណាហើយ សឹមដាក់អាជ្ញា ការដែលបុគ្គលធ្វើដោយរួសរាន់ រមែងក្តៅក្រហាយ ម្យ៉ាងទៀត ប្រយោជន៍ទាំងឡាយដែលនរជនផ្តងឡើងត្រឹមត្រូវនោះ រមែងជាប្រយោជន៍ មិនក្តៅក្រហាយខាងក្រោយ ។ ជនទាំងឡាយ បែងចែកហើយ ទើបធ្វើការងារទាំងឡាយ ដែលមិនមានសេចក្តីក្តៅក្រហាយក្នុងលោក ការងារទាំងនោះ ជាអំពើដែលអ្នកប្រាជ្ញសរសើរហើយថា មានសេចក្តីសុខជាកម្រៃ ជាអំពើដែលអ្នកប្រាជ្ញចុះអនុមតិហើយ ។ បពិត្រព្រះអង្គ ជាធំជាងជន ពួកឆ្មាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាត មកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ អង្គុយលើព្រះឧរូនៃមាតា ត្រូវពួកទូតទាំងនោះ ទង់ទាញមកដោយរហ័ស ទូល

ព្រះបង្គំជាខ្ញុំ បានដល់នូវមរណភ័យ ដ៏ក្តៅក្រហាយ យ៉ាង ចង្អៀត លំបាកក្រៃពេក បពិត្រព្រះរាជា ជីវិតដែលជាទី ស្រឡាញ់ដូចមធុរស ទូលព្រះបង្គំជាខ្ញុំបានហើយ ថ្ងៃនេះទូល ព្រះបង្គំជាខ្ញុំ បានរួចចាកការសម្លាប់ដោយលំបាក ទូលព្រះ បង្គំជាខ្ញុំ មានចិត្តឱនឆ្ពោះទៅក្នុងបព្វជ្ជាតែម្យ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនិសម្ម** សេចក្តីថា មិនត្រួតត្រាពិចារណា មុនធ្វើ ។ បទថា **អនវត្ថាយ ចិន្តិតំ** សេចក្តីថា មិនកំណត់ គឺមិនពិចារ ណា ត្រិះរិះដោយជុំវិញ ។ បទថា **វិបាកោ ហោតិ បាបកោ** សេចក្តីថា ពិតហើយ ការមិនមានប្រយោជន៍ គឺការវិនាសគុណភាពនៃថ្នាំកែរោគយ៉ាង ណា ផលលាមករមែងមានដល់បុគ្គលនោះ យ៉ាងនោះ ។

បទថា **អសញ្ញតោ** សេចក្តីថា បព្វជិតមិនសង្រួមដោយទ្វារជាដើម ជា អ្នកទ្រុស្តសីល ។ បទថា **តំ ន សាធុ** សេចក្តីថា សេចក្តីក្រោធរបស់ បណ្ឌិតនោះ មិនល្អ ។ បទថា **នានិសម្ម** សេចក្តីថា មិនបានពិចារណាមុន ហើយ មិនគួរធ្វើកិច្ចការណាមួយ ។ បទថា **បណយេយ្យ** សេចក្តីថា គប្បី ផ្តើម គឺគប្បីដាក់អាជ្ញាឲ្យប្រព្រឹត្តទៅ ។ បទថា **វេគា** សេចក្តីថា ដោយរហ័ស គឺដោយឆាប់រួសរាន់ ។

បទថា **សម្មាបណិធី ច** សេចក្តីថា ការតាំងខ្លួនទុកដោយប្រពៃ និង ប្រយោជន៍របស់នរជន ដែលធ្វើដោយចិត្ត តាំងទុកដោយឧបាយ រមែងជា របស់មិនក្តៅក្រហាយក្នុងកាលជាក្រោយ ។ បទថា **វិភជ្ជ** សេចក្តីថា ជន

ទាំងឡាយណា ចាត់ចែងដោយបញ្ញាយ៉ាងនេះថា កិច្ចការទាំងនេះគួរធ្វើ ទាំងនេះមិនគួរធ្វើ ។ បទថា **កម្មាយតនានិ** បានដល់ ការងារទាំងឡាយ ។ បទថា **ពុទ្ធានុមតានិ** សេចក្តីថា ការងារដែលបណ្ឌិតអនុមតិហើយ រមែងជារបស់មិនមានទោស ។ បទថា **កដុកំ** សេចក្តីថា បពិត្រព្រះបិតា ខ្ញុំដល់នូវការតក់ស្លុតចំពោះមរណភ័យក៏ក្តៅក្រហាយ ចង្អៀតចង្អល់ពន់ពេក ។ បទថា **លទ្ធា** សេចក្តីថា បាននូវជីវិតមកវិញដោយកម្លាំងនៃបញ្ញារបស់ខ្លួន ។ បទថា **បព្វជ្ជមេវាភិមនោហមស្មិ** សេចក្តីថា ខ្ញុំជាអ្នកមានចិត្តបង្អោនចំពោះបព្វជ្ជាតែម្យ៉ាង ។

កាលព្រះមហាសត្វសម្តែងធម៌យ៉ាងនេះហើយ ព្រះបាទរេណុរាជ ត្រាស់ឲ្យហៅព្រះទេវីមកគាល់ ហើយពោលគាថាដូច្នេះថា

ម្នាលសុធម្មាទេវី សោមនស្សកុមារ ជាបុត្តរបស់នាងនេះនៅក្មេង ជាអ្នកអនុគ្រោះ ថ្ងៃនេះខ្ញុំ អង្វរករកុមារនោះពុំបានសោះ ក្រែងតែនាងទើបអង្វរករនូវកុមារនោះបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាចិតវេ** សេចក្តីថា ដើម្បីជួយអង្វរ ។ ព្រះនាងសុធម្មាទេវី បែរជាជម្រុញឱរសដើម្បីបព្វជ្ជាតែម្យ៉ាង ត្រាស់គាថានេះថា

ហៃបា ចូរអ្នកត្រេកអរក្នុងកិច្ចាចរិយវត្តចុះ ចូរអ្នកពិចារណាធម៌ទាំងឡាយហើយបួសចុះ អ្នកចូរទម្លាក់ចោលនូវអាជ្ញា ក្នុងពួកសត្វទាំងអស់ចេញ មិនមានអ្នកណានិន្ទាបាន ហើយចូល

ទៅកាន់ឋានព្រហ្មលោកចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និសម្ម** សេចក្ដីថា កាលអ្នកបួស ចូរពិចា-ណាមើល ហើយលះនូវបព្វជ្ជាមិច្ឆាទិដ្ឋិកជនចេញ ចូរបព្វជ្ជាជាលទ្ធិដែលជាធម៌ នាំសត្វចេញចាកទុក្ខ ប្រកបដោយសម្មាទិដ្ឋិចុះ ។

លំដាប់នោះ ព្រះបាទវេណុរាជត្រាស់ព្រះគាថាដូច្នេះថា

ម្នាលនាងសុធម្មា នាងនិយាយពាក្យណា ( ពាក្យនោះ ) ជាអស្ចារ្យក្រៃពេក នាងឈ្មោះថា ញុំាងខ្ញុំដែល ដល់នូវសេចក្ដីទុក្ខ ឲ្យរឹតតែបានទុក្ខឡើង កាលខ្ញុំនិយាយថា ចូរនាងអង្វរករបុត្ត នាងបែរជាញុំាងកុមារឲ្យប្រឹងប្រែងវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យានិសញ្ច** សេចក្ដីថា នាងពោលពាក្យនេះ យ៉ាងណា ពាក្យនោះ គួរចម្លែកពិតហ្ន៎ ។ បទថា **ឧក្កិតំ** សេចក្ដីថា នាងបន្ថែមនូវទុក្ខឲ្យដល់ខ្ញុំដែលមានទុក្ខស្រាប់ហើយដោយប្រក្រតី ឲ្យជាទុក្ខក្រៃលែងឡើង ព្រះទេវីក៏ពោលគាថាបន្តទៀតថា

ព្រះអរិយៈទាំងឡាយណា រួចស្រឡះហើយ ( ចាកកាគា-ទិក្កិលេស ) ជាអ្នកបរិភោគនូវភោជនមិនមានទោស រំលត់ហើយ តែងត្រាច់ទៅកាន់លោកនេះ ខ្ញុំម្ចាស់មិនអាចហាមឃាត់ព្រះរាជកុមារ ដែលកំពុងដើរទៅកាន់ផ្លូវរបស់ព្រះអរិយៈ នោះបានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិប្បមុត្តា** សេចក្ដីថា រួចផុតហើយចាក

កិលេសទាំងឡាយ មានរាគៈជាដើម ។ បទថា **បរិនិព្វុតា** សេចក្តីថា ជាអ្នករលត់ហើយដោយកិលេសបរិព្វានធាតុ ។ បទថា **តមរិយមគ្គំ** សេចក្តីថា បពិត្រព្រះអង្គ ទ្រទ្រង់នូវគុណដ៏ប្រសើរ ខ្ញុំម្ចាស់មិនអាចឃាត់ព្រះរាជឱរសខ្ញុំ ដែលចម្រើនដោយមាគ៌ារបស់ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមនោះបានទេ ។

ព្រះរាជា ទ្រង់ស្តាប់ព្រះសវនីយ៍របស់ព្រះទេវីនោះហើយ ត្រាស់អវសានគាថាថា

ជនទាំងឡាយណា ប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ នាងសុធម្មាទេវីនេះ ជាស្ត្រីមានសេចក្តីខ្វល់ខ្វាយតិច ប្រាសចាកសេចក្តីសោក ព្រោះបានស្តាប់ពាក្យសុភាសិតទាំងឡាយនៃពួកជនណា ជនទាំងនោះ គួរអ្នកផងគប់រកដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុឋានចិន្តិនោ** សេចក្តីថា ជាអ្នកគិតហេតុការណ៍ផ្សេងៗជាច្រើន ។ បទថា **យេសាយំ** កាត់បទជា **យេសំ អយំ** ពិតហើយ ព្រះនាងសុធម្មាទេវី លុះបានស្តាប់ពាក្យជាសុភាសិតរបស់សោមនស្សកុមារនោះឯង ទើបព្រះនាងកើតការខ្វល់ខ្វាយតិច សូម្បីព្រះរាជា ក៏ត្រាស់សំដៅដល់ព្រះរាជឱរសនោះដូចគ្នា ។

ព្រះមហាសត្វ ថ្វាយបង្គំព្រះរាជមាតាបិតា ក្រាបទូលថា បើទោសកំហុសរបស់ខ្ញុំមានសោត សូមព្រះជនកជននីមេត្តាអត់ទោសផងចុះ ហើយ

ផ្គងអញ្ជលីចំពោះមហាជន បែរមុខឆ្ពោះហិមវន្តប្បទេស យាងទៅ កាល មហាជនអ្នកជូនដំណើរត្រឡប់ហើយ ទេវតាទាំងឡាយ មកដោយភេទជា មនុស្ស នាំធ្វងក្ខុំទាំង ៧ ទៅកាន់ហិមវន្តប្បទេស ទ្រង់បព្វជ្ជាដោយភេទ តាបស នៅក្នុងបណ្ណសាលាដែលវិស្សកម្មទេវបុត្តនិម្មិតទុក ។ ទេវតាទាំង ឡាយអភិបាលបម្រើព្រះមហាសត្វ ដោយភេទមនុស្ស ដែលអភិបាលបម្រើ ក្នុងរាជត្រកូល រហូតដល់ព្រះមហាសត្វមានព្រះជន្មាយុ ១៦ ឆ្នាំ ។ ឯមហា ជននាំគ្នាវាយជដិលកោងរហូតដល់អស់ជីវិត ។ ព្រះមហាសត្វ ញុំាងឈាន និងអភិញ្ញាឲ្យកើតហើយ ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន ទេវទត្តនេះក៏ព្យាយាមសម្លាប់តថា គត យ៉ាងនេះដូចគ្នា ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ជដិលកោងក្នុងកាល នោះ បានជាទេវទត្តក្នុងកាលឥឡូវនេះ ព្រះមាតាក្នុងកាលនោះ បានមកជា ព្រះនាងសិរិមហាមាយា ព្រះមហារក្ខិតតាបស ក្នុងកាលនោះ បានមកជា សារីបុត្ត ឯសោមនស្សកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សោមនស្សជាតក ចប់

# ចម្បេយ្យជាតក

[ ៣០៩ ] ( ព្រះបាទពារាណសីត្រាស់សួរថា ) នាងជាអ្វី មានពន្លឺដូចជាផ្លេកបន្ទោរ ឬដូចជាផ្កាយព្រឹក នាងជាស្រ្តីទេវតាឬជាស្រ្តីគន្ធព្វ យើងមិនសំគាល់នាងថាជាស្រ្តីមនុស្សទេ ។

[ ៣១០ ] ( នាងនាគីក្រាបបង្គំទូលថា ) បពិត្រមហារាជ ខ្ញុំម្ចាស់មិនមែនជាស្រ្តីទេវតា មិនមែនជាស្រ្តីគន្ធព្វ មិនមែនជាស្រ្តីមនុស្ស បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ជានាគកញ្ញា មកក្នុងទីនេះដោយសេចក្តីត្រូវការ ។

[ ៣១១ ] ( ព្រះរាជា... ) នាងមានចិត្តតក់ស្លុត មានឥន្រ្ទិយញ័ររន្ធត់ តំណក់ទឹកភ្នែកទាំងឡាយហូរសស្រាក់ចាកភ្នែកទាំងឡាយរបស់នាង ចុះវត្ថុអ្វីរបស់នាងបាត់ ម្នាលនារី នាងចង់បានរបស់អ្វី បានជាមកក្នុងទីនេះ ចូរនាងប្រាប់ហេតុនោះមកចុះ ។

[ ៣១២ ] ( នាងនាគី... ) បពិត្រព្រះអង្គជាធំជាងជន ពួកជនបានហៅសត្វណាថាឧរគៈ មានតេជៈដ៏ខ្លាំងខ្លស់ តែងហៅសត្វនោះថានាគ បុរសអ្នកត្រូវការចិញ្ចឹមជីវិត បានចាប់នាគនោះមកហើយ សូមព្រះអង្គលែងនាគនោះពីចំណងទៅ នាគនោះជាប្តីរបស់ខ្ញុំម្ចាស់ ។

[ ៣១៣ ] ( ព្រះរាជា... ) នាគរាជនេះ បរិបូណ៌ដោយកម្លាំងនិងព្យាយាម ហេតុដូចម្តេច ក៏ស្តេចមកលុះក្នុងកណ្តាប់ដៃ នៃមនុស្សកម្សត់ទៅវិញម្នាលនាគកញ្ញា ចូរនាងប្រាប់ហេតុនោះ ដល់យើង ធ្វើម្តេចទើបយើងស្គាល់នាគដែលគេចាប់មក ( នោះ ) បាន ។

[ ៣១៤ ] ( នាងនាគ... ) ពិតដូច្នោះមែន នាគរាជនោះបរិបូណ៌ដោយកម្លាំងនិងព្យាយាម អាចធ្វើសូម្បីនូវនគរឲ្យជាផេះបាន ប៉ុន្តែនាគរាជនោះ គោរពធម៌ ព្រោះហេតុនោះ ទើបខំតែធ្វើតបធម៌ ។

[ ៣១៥ ] បពិត្រព្រះរាជា នាគរាជជាអ្នករក្សាចាតុទ្ទសីឧបោសថនិងបណ្ណរសីឧបោសថ នៅជិតផ្លូវត្រឡែងកែង បុរសអ្នកត្រូវការចិញ្ចឹមជីវិត បានចាប់នាគរាជនោះមកហើយ សូមព្រះអង្គលែងនាគរាជនោះពីចំណង នាគរាជនុ៎ះ ជាប្តីរបស់ខ្ញុំម្ចាស់ ។

[ ៣១៦ ] នាងនាគជាស្រីស្នំរបស់នាគរាជ ជប់ប្រាំមួយពាន់ ពាក់កុណ្ឌលជាវិការៈនៃកែវមណី មានផ្ទះជាទីដេកក្នុងទឹក នាងនាគទាំងនោះឯងក៏ដល់នូវនាគរាជនោះជាទីពឹង ។ សូមព្រះអង្គលែង ( នាគរាជនោះ ) ដោយនូវគន្ធធម៌ ដោយអំពើមិនអាក្រក់ គឺដោយស្រុកសួយ ដោយមាសផ្កាដោយគោ ១ រយ ចូរឲ្យនាគមានកាយរួចស្រឡះហើយ ត្រាច់ទៅចុះ (នាគ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ។

[ ៣១៧ ] ( ព្រះរាជា... ) យើងដោះលែង ( នាគរាជ ) ដោយនូវគន្ធធម៌ ដោយអំពើមិនអាក្រក់ គឺដោយស្រុកសួយ ដោយមាសផ្កា ដោយគោ ១ រយ ចូរឲ្យនាគមានកាយរួចស្រឡះ ហើយត្រាច់ទៅចុះ ( នាគ ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ។ ម្នាលព្រាន យើងឲ្យមាសផ្កា ១ រយផង កុណ្ឌលជាវិការៈនៃកែវមណីដ៏ច្រើនផង បល្ល័ង្កមានជ្រុង ៤ មានពណ៌ដូចផ្កាត្រកៀតផង ភរិយាស្មើគ្នា ( ដោយវ័យជាដើម ) នេះ

ពីរនាក់ផង គោឧសភ ១ រយផង នាគមានកាយរូបស្រឡះហើយ ចូរត្រាច់ទៅចុះ ( នាគ ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ។

[ ៣១៨ ] ( អាលម្ពាយ... ) បពិត្រព្រះអង្គជាធំជាងជន ព្រះរាជឱង្ការរបស់ព្រះអង្គ វៀរចាកព្រះរាជអំណោយក៏បាន ទូលព្រះបង្គំសូមលែងនាគនោះអំពីចំណង នាគមានកាយរូបស្រឡះហើយ ចូរត្រាច់ទៅចុះ ( នាគ ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ។

[ ៣១៩ ] ( អភិសម្ពុទ្ធគាថា... ) ចម្បេយ្យនាគ បានរួចហើយ ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជាក្នុងដែនកាសី សូមថ្វាយបង្គំព្រះអង្គបពិត្រព្រះអង្គអ្នកញុំាងដែនកាសីឲ្យចម្រើន សូមថ្វាយបង្គំព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមផ្គងក្រពុំម្រាមដៃចំពោះព្រះអង្គ ទូលព្រះបង្គំជាខ្ញុំ ចង់បង្ហាញនូវលំនៅរបស់ទូលព្រះបង្គំជាខ្ញុំ ( ដល់ព្រះអង្គ ) ។

[ ៣២០ ] ( ព្រះរាជា... ) មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្សដោយហេតុណា អ្នកប្រាជ្ញទាំងឡាយ ពោលនូវហេតុនុ៎ះថា ជាសេចក្តីស្និទ្ធស្នាលអាក្រក់ដោយពិត ប៉ុន្តែបើអ្នកអង្វររៀងនុ៎ះនឹងយើង ម្នាលនាគ យើងនឹងទៅមើលលំនៅរបស់អ្នក ។

[ ៣២១ ] ( នាគរាជ... ) បើទុកជាខ្យល់គួចយកភ្នំទៅបាន ព្រះចន្ទនិងព្រះអាទិត្យជ្រុះចុះមកលើផែនដីទោះស្ទឹងទាំងពួងហូរច្រាសបាន បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំក៏មិនពោលពាក្យកុហកទេ ។ ផ្ទៃអាកាសបែកធ្លាយក្តី សមុទ្ររីងស្ងួតក្តី ផែនដីជាទីទ្រសត្វ ទ្រទ្រព្យ គប្បីខ្ទូរ ទាំងភ្នំមេរុ

សណ្ដកឡើង ព្រមទាំងឫសក្ដី បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំ មិនពោលពាក្យកុហកទេ ។

[ ៣២២ ] ( ព្រះរាជា... ) មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្សដោយហេតុណា អ្នកប្រាជ្ញទាំងឡាយពោលនូវហេតុនុ៎ះថា ជាសេចក្ដីស្និទ្ធស្នាលអាក្រក់ដោយពិត ប៉ុន្តែបើអ្នកអង្វររឿងនុ៎ះនឹងយើង ម្នាលនាគ យើងនឹងទៅមើលលំនៅរបស់អ្នកដែរ ។

[ ៣២៣ ] ពួកអ្នកសោត ក៏ជាសត្វមានពិសខ្លាំងក្លាពន្លឹកណាស់ មានតេជះច្រើន ឆាប់ខឹង អ្នករួចអំពីចំណងបាន ព្រោះហេតុនៃយើង អ្នកគួរដឹងនូវឧបការគុណដែលយើងបានធ្វើហើយ ។

[ ៣២៤ ] ( នាគរាជ... ) បុគ្គលណា មិនស្គាល់នូវបុគ្គលមានកុសលកម្មធ្វើហើយ ( ធ្វើគុណ ) ប្រាកដដូចព្រះអង្គ បុគ្គលនោះចូរឆេះក្នុងនរក មានសភាពគួរស្បើម កុំឲ្យបានសេចក្ដីសុខប្រព្រឹត្តទៅ ក្នុងកាយបន្តិចបន្តួចសោះ ចូរជាប់នៅក្នុងទ្រុងដល់នូវសេចក្ដីស្លាប់ចុះ ។

[ ៣២៥ ] ( ព្រះរាជា... ) ពាក្យប្ដេជ្ញារបស់អ្នកនុ៎ះ ជាពាក្យសត្យ អ្នកចូរកុំមានសេចក្ដីក្រោធ អ្នកចូរកុំចងសេចក្ដីក្រោធទុក ពួកគ្រុឌ ក៏ចូរវៀរលែងត្រកូលនាគទាំងអស់របស់អ្នក ដូចពួកមនុស្សវៀរចាកគំនរភ្លើង ក្នុងគិម្ហសម័យ ដូច្នោះចុះ ។

[ ៣២៦ ] ( នាគរាជ... ) បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គអនុគ្រោះ នូវត្រកូលនាគ ដូចជាមាតាអនុគ្រោះកូនប្រុសតែម្នាក់ ដែលជាទី

ស្រឡាញ់ស្មោះ ចំណែកខាងទូលព្រះបង្គំជាខ្ញុំ ព្រមទាំងត្រកូលនាគនឹងធ្វើនូវការខ្វល់ខ្វាយបម្រើចំពោះព្រះអង្គដ៏លើសលុប ។

[ ៣២៧ ] ( ព្រះរាជា... ) នែវ៉ីយពួកក្មាក់ងារគ្រប់តំណែង ចូរទឹមរាជរថដ៏វិចិត្រដោយប្រពៃ ចូរទឹមអស្សតរដែលកើតក្នុងដែនកម្ពុជៈជាពាហនៈទូន្មានបានបទល្អហើយ ចូររៀបដំរីប្រដាប់ដោយគ្រឿងមាស យើងនឹងទៅមើលលំនៅរបស់នាគ ។

[ ៣២៨ ] ( អភិសម្ពុទ្ធគាថា ) ពួកស្គរធំ ស្គរតូច ត្រែ ស័ង្ខ របស់ព្រះរាជាព្រះនាមឧគ្គសេន ក៏លាន់ឮឡើង ព្រះរាជាទ្រង់ព្រះលំអច្រើនប្រការទ្រង់ស្តេចយាងទៅក្នុងកណ្តាលនៃពួកនារីដែលចោមរោមជុំវិញ ។

[ ៣២៩ ] ព្រះរាជាអ្នកញុំាងដែនកាសីឲ្យចម្រើន បានទតផែនដី ដ៏វិចិត្រដោយមាស និងប្រាសាទទាំងឡាយជាវិការៈនៃមាស ដែលក្រាលដោយបន្ទះកែវពៃទូរ្យ ។ ព្រះរាជាអង្គនោះ ទ្រង់ចូលទៅកាន់នាគពិភពដ៏សម្បើមជាទីនៅនៃចម្បេយ្យនាគរាជ ដ៏ភ្លឺស្វាង ដូចជាពណ៌នៃព្រះអាទិត្យ មានរស្មីផ្លេកៗ ដូចផ្លេកបន្ទោរពណ៌មាស ។ ព្រះបាទកាសីនោះ ទ្រង់ទតនិវេសនដ្ឋានរបស់ចម្បេយ្យនាគរាជដ៏ដេរដាសដោយឈើទាំងឡាយផ្សេងៗ ដ៏ផ្សព្វផ្សាយដោយក្លិនក្រអូបផ្សេងៗ ។ កាលដែលព្រះបាទកាសីទ្រង់ចូលទៅហើយ តូរ្យ-តន្ត្រីទាំងឡាយជាទិព្វ ក៏លាន់ឮឡើង នាគកញ្ញា ទាំងឡាយក៏រាំថ្វាយ ក្នុងរាជនិវេសន៍នៃចម្បេយ្យនាគរាជ ។

ព្រះរាជនិវេសន៍នោះ ដេរដាសដោយពួកនៃនាគកញ្ញា ព្រះរាជាកាសី

ទ្រង់ជ្រះថ្លា ឡើងគង់លើបល្ល័ង្ក ជាវិការៈនៃមាស មានបង្អែកដ៏លាបលទ ដោយខ្លឹមចន្ទន៍ ។

[ ៣៣០ ] ព្រះបាទកាសីនោះ ទ្រង់សោយ ទ្រង់រីករាយក្នុងនាគពិភព នោះហើយ មានព្រះរាជឱង្ការចំពោះចម្បេយ្យនាគរាជថា វិមានដ៏ប្រសើរទាំងឡាយរបស់អ្នកនេះ មានពណ៌ដូចព្រះអាទិត្យដ៏ភ្លឺផ្លេកៗ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ពួកនាងនាគកញ្ញានោះ ពាក់នូវគ្រឿងប្រដាប់មាស មានសម្លៀកបំពាក់ដ៏ល្អ មានម្រាមដៃមូល ប្រកបដោយផ្ទៃ ( ដៃនិងជើង ) ដ៏ក្រហម មានសម្បុរមិនអន់អាប់ លើក ( នូវទិព្វបានៈ ) ទៅថ្វាយដើម្បីសោយ ធម្មជាតប្រាកដដូច្នោះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ ដើម្បីអ្វី ។ ស្ទឹងទាំងឡាយមានទឹកត្រជាក់ មានត្រីមានស្រកាក្រាស់ មានអាទាសបក្សីយំពីរោះ មានកំពង់ល្អ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ហ្វូងក្រៀល ក្ងោក ហង្ស តាវ៉ៅ ដ៏ជាទិព្វ ស្រែកនូវសម្រែកដ៏ពីរោះ ហើរទំពីព្រឹក្សាមួយ ទៅរកព្រឹក្សាមួយ ធម្មជាតដែលប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ដើមស្វាយ ដើមសាលព្រឹក្ស ដើមមៀន ដើមព្រីង ដើមរាជព្រឹក្ស ដើមប្រទៀងទាំងឡាយ មានផ្ការីកស្គុះស្គាយ រុក្ខជាតដែលប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ក្លិនដ៏ជាទិព្វទាំងឡាយ រមែងបក់ផ្សាយទៅជុំវិញស្រះបោក្ខរណីទាំងនេះ ជា

និច្ច គន្ធជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។

[ ៣៣១ ] ( នាគរាជ... ) បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំជាខ្ញុំធ្វើតបធម៌ មិនមែនព្រោះហេតុចង់បានកូន មិនមែនចង់បានទ្រព្យ ឬជាមិនមែនព្រោះហេតុចង់បានអាយុទេ ទូលព្រះបង្គំជាខ្ញុំចង់បានកំណើតជាមនុស្សព្រោះហេតុនោះ ទើបខ្ញុំប្រឹងធ្វើតបធម៌ ។

[ ៣៣២ ] ( ព្រះរាជា... ) អ្នកមានភ្នែកក្រហម មានស្មាក្តីប្រាលផ្តៅ មានខ្លួនប្រដាប់ហើយ មានសក់និងពុកមាត់កោរកាត់ហើយ ប្រោះព្រំយ៉ាងល្អដោយចន្ទន៍ក្រហម ភ្លឺផ្សាយទៅសព្វទិស ដូចជាគន្ធព្វរាជ ។ អ្នកមានឫទ្ធិដូចជាទេវតា មានអានុភាពច្រើនបរិបូណ៌ ដោយកាមទាំងឡាយគ្រប់យ៉ាង ។ ម្នាលនាគរាជ មនុស្សលោកប្រសើរដោយវិសេសជាងនាគពិភពនេះ ដោយហេតុអ្វី យើងសូមសួរអ្នកចំពោះហេតុនុ៎ះឯង ។

[ ៣៣៣ ] ( នាគរាជ... ) បពិត្រព្រះអង្គ ជាធំជាងជន សេចក្តីបរិសុទ្ធក្តី ការសង្រួមក្តី បើវៀរចាកមនុស្សលោកចេញហើយ ឥតមានទេ បើទូលព្រះបង្គំជាខ្ញុំ បានកំណើតជាមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិ និងមរណៈ ។

[ ៣៣៤ ] ( ព្រះរាជា... ) ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ គេត្រូវគប់រកដោយពិត ម្នាលនាគរាជ ចំណែកខាងយើង បានឃើញនូវពួកនាងនារីផង នូវអ្នកផង នឹង

ធ្វើបុណ្យទាំងឡាយយ៉ាងច្រើន ។

[ ៣៣៥ ] ( នាគរាជ... ) ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ គេត្រូវគប់រកដោយពិត បពិត្រព្រះរាជា ព្រះអង្គទ្រង់ទតឃើញនូវពួកនាងនារីផង នូវទូលព្រះបង្គំជាខ្ញុំផង សូមព្រះអង្គធ្វើនូវបុណ្យទាំងឡាយយ៉ាងច្រើនចុះ ។

[ ៣៣៦ ] ប្រាក់របស់ទូលព្រះបង្គំជាខ្ញុំនេះច្រើនណាស់ ទាំងគំនរមាសក៏ប្រហែលកម្ពស់ដើមត្នោត សូមព្រះអង្គ ឲ្យរាជបម្រើ នាំអំពីនាគពិភពនេះទៅកសាងព្រះរាជដំណាក់ ជាវិការៈនៃមាស ពួកជាងចូរធ្វើកំពែង ជាវិការៈនៃប្រាក់ចុះ ។ គំនរកែវមុក្តា មានប្រាំពាន់វាហៈ ( រទេះ ) គំនរកែវពៃទូរ្យ ( ប្រាំពាន់វាហៈ ) នេះ សូមពួកជននាំទៅអំពីនាគពិភពនេះ ហើយក្រាលលើផែនដីខាងក្នុងបុរី ឲ្យជាទីមិនមានភក់ មិនមានធូលី ។ បពិត្រព្រះរាជាដ៏ប្រសើរ សូមព្រះអង្គគ្រប់គ្រងក្រុងពារាណសីឲ្យជាវិមានប្រសើរ មានលំអច្រើនអន្លើ ជានគរស្តុកស្តម្ភ ទូលំទូលាយមានសភាពដូច្នេះចុះ បពិត្រព្រះអង្គមានប្រាជ្ញាមិនថោកថយ សូមព្រះអង្គសោយរាជ្យចុះ ។

## ចប់ ចម្បេយ្យជាតក ទី ១០

# អដ្ឋកថា

# ចម្បេយ្យជាតក

[ ៣០៩-៣៣៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបោសថកម្ម ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កា នុ វិជ្ជុ-រិវាភាសិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងកាលនោះ ព្រះបរមសាស្តាត្រាស់ថា ម្នាលឧបាសកឧបាសិកាទាំងឡាយ ការដែលអ្នកទាំងឡាយរក្សាឧបោសថកម្ម ជាការល្អហើយ បុរាណកបណ្ឌិតទាំងឡាយ លះនាគសម្បត្តិ ហើយរក្សាឧបោសថកម្មដូចគ្នា កាលឧបាសក ឧបាសិកាទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទអង្គតិរាជគ្រប់គ្រងរាជសម្បត្តិនៅក្នុងអង្គរដ្ឋរាជ-ធានី ។ ក្នុងរវាងដែនអង្គៈនិងមគធៈតគ្នា មានស្ទឹងឈ្មោះចម្បានទី មាននាគពិភពនៅក្រោមស្ទឹងចម្បានទីនោះ ។ ស្តេចនាគឈ្មោះ ចម្បេយ្យ គ្រងរាជសម្បត្តិក្នុងនាគពិភពនោះ ។ ជាប្រក្រតី ស្តេចទាំង ២ អង្គ តែងច្បាំងគ្នារឿយៗ ជួនកាលព្រះបាទមគធរាជដណ្តើមយកដែនអង្គៈបាន ជួនកាលព្រះបាទអង្គរាជដណ្តើមយកដែនមគធៈបាន ។

ថ្ងៃមួយ ព្រះបាទមគធរាជធ្វើយុទ្ធនាការជាមួយព្រះបាទអង្គរាជ ទ្រង់បរាជ័យ ក្នុងយុទ្ធសង្គ្រាម ឡើងព្រះទីន័ងគេចទៅ លុះមកដល់ចម្បានទីទាហានរបស់ព្រះបាទអង្គរាជតាមមកទាន់ ព្រះរាជាទង់ព្រះតម្រិះថា អញ

លោតទឹកឲ្យស្លាប់ប្រសើរជាងស្លាប់ក្នុងកណ្តាប់ដៃសត្រូវ ដូច្នេះហើយ ទើបញាក់សេះព្រះទីន័ង ឲ្យលោតចូលទៅក្នុងស្ទឹង ។ គ្រានោះ ចម្បេយ្យនាគរាជនិម្មិតរតនមណ្ឌប ក្នុងអន្លង់ទឹក ចោមរោមដោយបរិវារជាច្រើន ផឹកមហាបាន: ។ សេះព្រះទីន័ងមួយអន្លើដោយព្រះបាទមគធ: ក៏លិចទឹកធ្លាក់ចុះទៅចំពោះព្រះភក្ត្រនៃស្តេចនាគ ។ នាគរាជ ឃើញព្រះរាជាទ្រទ្រង់នូវគ្រឿងប្រដាប់ កើតនូវការរាប់អាន ទើបក្រោកអំពីអាសនៈទូលថា បពិត្រមហារាជសូមទ្រង់កុំភ័យខ្លាចឡើយ ហើយយាងឲ្យព្រះរាជាប្រថាប់គង់លើបល្ល័ង្ករបស់ខ្លួន ទូលសួរដល់ហេតុ ដែលទ្រង់លិចចុះមក ព្រះបាទមគធ:ទូលរឿងតាមសេចក្តីពិត ។

លំដាប់នោះ ចម្បេយ្យនាគរាជលួងលោមព្រះបាទមគធ: ឲ្យធូរស្បើយព្រះរាជហឫទ័យថា បពិត្រមហារាជ ទ្រង់កុំភ័យខ្លាចឡើយ ខ្ញុំនឹងជួយធ្វើឲ្យទ្រង់បានជាស្តេចក្នុងរដ្ឋទាំង ២ ដូច្នេះហើយ សោយយសដ៏ធំក្រៃលែងអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ទើបចេញអំពីនាគពិភព មួយអន្លើដោយព្រះបាទមគធ: ព្រះបាទមគធ:ចាប់ព្រះបាទអង្គរាជបាន ដោយអានុភាពរបស់ស្តេចនាគ ហើយត្រាស់ឲ្យសម្រេចទោស សោយរាជសម្បត្តិក្នុងរដ្ឋសីមាមណ្ឌលទាំង ២ ។ តាំងអំពីនោះមក ការស្និទ្ធស្នាលរវាងព្រះបាទមគធ: និងស្តេចនាគ ក៏រឹងរឹតតែមាំមួនឡើង ព្រះបាទមគធរាជបានសាងរតនមណ្ឌបត្រង់ឆ្នេរស្ទឹងចម្បានទីហើយទ្រង់ធ្វើពលីកម្មដល់ស្តេចនាគ ដោយមហាបរិច្ចាគរៀងរាល់ឆ្នាំ ។ ស្តេចនាគក៏ចេញអំពីនាគពិភព មកទទួលពលីកម្មដោយមហាបរិវារ ។ មហាជន

នាំគ្នាមកគាល់មើលសម្បត្តិរបស់ស្តេចនាគ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វ កើតក្នុងត្រកូលក្រីក្រ បានទៅកាន់ឆ្នេរស្ទឹងជាមួយពួករាជបរិស័ទ ឃើញសម្បត្តិរបស់ស្តេចនាគនោះហើយ ក៏កើតលោភចេតនាប្រាថ្នានឹងបានសម្បត្តិនោះ ទើបធ្វើបុណ្យឲ្យទាន រក្សាសីល លុះចម្បេយ្យនាគរាជធ្វើកាលកិរិយាបាន ៧ ថ្ងៃ ក៏ចុតិទៅកើតលើសិរីសេយ្យាសនៈក្នុងបន្ទប់ដ៏មានសិរី ត្រង់ប្រាសាទរបស់ចម្បេយ្យនាគរាជនោះ ។ សរីរកាយរបស់ព្រះពោធិសត្វបានប្រាកដជាធំមួយរំពេច មានពណ៌សដូច កម្រងផ្កាម្លិះ ព្រះពោធិសត្វក្រឡេកមើលខ្លួន ក៏កើតវិប្បដិសារៈ គិតថា ឥស្សរិយយសក្នុងឆកាមាវចរសួគ៌ ដូចស្រូវដែលគេរក្សាទុកក្នុងជង្រុក មានដល់អញដោយផលនៃកុសលដែលអញធ្វើ ឯអញបែរជាមកបដិសន្ធិក្នុងកំណើតសត្វតិរច្ឆាននេះ ប្រយោជន៍អ្វីដែលអញនឹងមានជីវិតរស់នៅបែបនេះ ហើយគិតប្រាថ្នានឹងស្លាប់ ។ លំដាប់នោះ នាគមាណវិកាឈ្មោះសុមនា ឃើញព្រះមហាសត្វនោះហើយ គិតថា ប្រហែលជាសត្វមានអានុភាពច្រើនមកកើតពិតដូច្នេះហើយ ទើបឲ្យសញ្ញាដល់នាគមាណវិកាទាំងឡាយ ។ នាគមាណវិកាទាំងនោះ ក៏កាន់យកគ្រឿងតូរ្យតន្ត្រីច្រើន ប្រភេទមកធ្វើការប្រគំថ្វាយព្រះមហាសត្វ នាគពិភពដែលព្រះពោធិសត្វកើតនោះ ប្រាកដដូចពិភពនៃសក្កទេវរាជ ការគិតនឹងស្លាប់របស់ព្រះមហាសត្វក៏រលត់រលាយទៅ ។ ព្រះមហាសត្វលះនូវសរីរៈពស់ ប្រដាប់នូវសព្វាលង្ការ ប្រថាប់លើព្រះទែនបន្ទំ ។ តាំងពីនោះមក ព្រះឥស្សរិយយស ក៏ប្រាកដដល់ព្រះមហាសត្វជាច្រើន ។

កាលព្រះមហាសត្វសោយនាគសម្បត្តិ ក្នុងនាគពិភពនោះ ក្នុងកាលតមកក៏កើតវិប្បដិសារៈ គិតថា ប្រយោជន៍អ្វី ដល់អញដោយកំណើតសត្វតិរច្ឆាននេះ អញនឹងរក្សាឧបោសថកម្ម នឹងផុតពីអត្តភាពនេះ ទៅកាន់ដែនដីមនុស្សនឹង បានចាក់ធ្លុះសច្ចធម៌ នឹងធ្វើទីបំផុតទុក្ខ ដូច្នេះ ។ តាំងពីនោះមក ទ្រង់ក៏រក្សាឧបោសថកម្មក្នុងប្រាសាទនោះឯង ។ ពួកនាគមាណវិកាតាក់តែងកាយដ៏ស្រស់ស្អាត នាំគ្នាទៅកាន់សម្នាក់របស់ព្រះមហាសត្វនោះ សីលរបស់ព្រះមហាសត្វ ក៏វិបត្តិបែកធ្លាយរឿយៗ ។ ចាប់តាំងអំពីនោះ ព្រះមហាសត្វ ក៏ចេញអំពីប្រាសាទ ទៅកាន់ព្រះរាជឧទ្យាន នាគមាណវិកាទាំងនោះ ក៏ទៅក្នុងព្រះឧទ្យាន ឧបោសថសីលរបស់ព្រះមហាសត្វក៏ដាច់រឿយៗ ។ សម័យនោះព្រះមហាសត្វក៏ទ្រង់ចិន្តនាការថា អញគួរចេញអំពីនាគពិភពនេះ ទៅកាន់មនុស្សលោក ដើម្បីរក្សាឧបោសថ ។ តាំងពីនោះមក លុះដល់ថ្ងៃឧបោសថទ្រង់ចេញអំពីនាគពិភពមកកាន់មនុស្សលោក ទ្រង់លះរាងកាយក្នុងទានមុខថា នរណាត្រូវការអវយវៈរបស់អញ មានស្បែកជាដើម ចូរកាន់យកចុះអ្នកណាត្រូវការឲ្យអញលេងនូវកីឡាពស់ ក៏ចូរធ្វើចុះ ហើយពត់ក្ងន ធ្លាយរង្វេល ដេករក្សាឧបោសថលើកំពូលដំបូកក្បែរផ្លូវ ទៀបបច្ចន្តជនបទមួយ ។ ជនទាំងឡាយដើរច្នេងទៅមកក្នុងផ្លូវធំ ឃើញព្រះពោធិសត្វ នាំគ្នាបូជាដោយគ្រឿងសក្ការៈ មានគ្រឿងប្រអប់ជាដើម រួចចៀសចេញទៅ ។ អ្នកបច្ចន្តជនបទ ទៅចួបហើយ គិតថា ប្រហែលជានាគរាជមានឥទ្ធានុភាពច្រើន ទើបធ្វើមណ្ឌបអំពីខាងលើ នាំគ្នាពោយខ្សាច់ក្នុងបរិវេណ ហើយបូជាដោយសក្ការៈ

មានគ្រឿងប្រអប់ជាដើម ។ តាំងពីនោះមក មនុស្សទាំងឡាយ ក៏ជ្រះថ្លាក្នុងព្រះមហាសត្វ ធ្វើនូវការបូជាប្រាថ្នាកូនប្រុសខ្លះ កូនស្រីខ្លះ ។

ព្រះមហាសត្វរក្សាឧបោសថកម្ម ដល់ថ្ងៃចាតុទ្ទសី និងបណ្ណរសី ក៏មកដេកលើដំបូក តមក ក្នុងថ្ងៃបាដិបទ ១ កើត ឬ ១ រោច ក៏ត្រឡប់ទៅកាន់នាគពិភព ។ កាលព្រះមហាសត្វរក្សាឧបោសថយ៉ាងនេះ អស់កាលកន្លងទៅដ៏យូរអង្វែង ។ ថ្ងៃមួយ នាងសុមនាអគ្គមហេសីទូលសួរព្រះមហាសត្វថា បពិត្រព្រះអង្គទ្រទ្រង់គុណដ៏ប្រសើរ ទ្រង់យាងទៅកាន់មនុស្សលោក រក្សាឧបោសថសីលនោះ តាមពិត មនុស្សលោក គួររង្កៀស មានភ័យនៅជុំវិញ បើភ័យកើតឡើងដល់ព្រះអង្គ ពួកខ្ញុំដឹងបានដូចម្តេច សូមទ្រង់ប្រាប់ នូវនិមិត្តណាមួយដល់ពួកខ្ញុំចុះ ។ លំដាប់នោះ ព្រះមហាសត្វក៏នាំនាងសុមនាទេវីទៅកាន់មាត់ស្រះមង្គលបោក្ខរណី ហើយត្រាស់ថា នែនាងដ៏ចម្រើន បើបុគ្គលណាមួយ ប្រហារធ្វើឲ្យយើងលំបាក ទឹកក្នុងស្រះបោក្ខរណីនេះនឹងល្អក់ បើស្តេចគ្រុឌចាប់យកទៅ ពពុះទឹកនិងចំហាយក្តៅ ផុរាយឡើងមក បើអាលម្ពាយចាប់យកទៅ ទឹកនឹងមានពណ៌ក្រហមដូចឈាម ព្រះពោធិសត្វត្រាស់ប្រាប់និមិត្ត ៣ ប្រការដល់នាងសុមនាទេវីយ៉ាងនេះហើយ ទ្រង់អធិដ្ឋានចាតុទ្ទសីឧបោសថ យាងចេញអំពីនាគពិភព ទៅកាន់មនុស្សលោក ដេកលើដំបូក ញាំងដំបូកឲ្យស្អាតដោយរស្មីនៃសរីរកាយ សូម្បីសរីរកាយរបស់ព្រះមហាសត្វនោះ ក៏ប្រាកដសស្អាតដូចកម្រងផ្កាម្លិះ ។ កំណាត់សិរសាខាងលើដូចស្រោបដោយសំពត់កម្ពលក្រហម ។ម្យ៉ាងទៀត ក្នុងជាតកនេះ សរីរ-

កាយរបស់ព្រះពោធិសត្វមានទំហំប៉ុនយាមទង្គ័ល ក្នុងកាលជាកូរិទត្ត មានទំហំប៉ុនក្អៅ កាលនៅជាសង្ខបាល មានទំហំប៉ុនទូកកម្រោល ។

ក្នុងកាលនោះ មានមាណពអ្នកក្រុងពារាណសីម្នាក់ ទៅនគរតក្កសិលា រៀនយកអាលម្ពាយមន្តក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ធ្វើដំណើរវិលត្រឡប់ទៅផ្ទះរបស់ខ្លួន កាត់តាមផ្លូវនោះ ឃើញព្រះមហាសត្វហើយ គិតថា អញនឹងចាប់ពស់នេះ បង្រៀនឲ្យលេងកីឡាក្នុងគាមនិគមរាជធានីទាំងឡាយ ញុំាំងទ្រព្យឲ្យកើតឡើង ដូច្នេះហើយ ទើបច្បិចយកទិព្វឱសថ រាយទិព្វមន្ត ទៅកាន់សម្នាក់របស់ព្រះមហាសត្វ តាំងអំពីព្រះមហាសត្វស្ដាប់ទិព្វមន្តហើយ ក៏កើតអាការក្ដៅរោលរាលចូលទៅក្នុងរន្ធត្រចៀកទាំង ២ ខាងលើព្រះសីសៈហាក់ដូចត្រូវលំពែងដោត ។ ព្រះមហាសត្វទ្រង់ពិចារណាថា នេះអ្វីហ្ន៎ ទើបទ្រង់អើតក្បាលពីក្នុងរង្វេល សម្លឹងមើលទៅ បានឃើញគ្រូពស់ ហើយគិតថា ពិសរបស់អញពន្លឹកពេកណាស់ បើអញក្រោធហើយ បង្ហើរខ្យល់ច្រមុះចេញទៅ សរីរៈនៃអាលម្ពាយនេះ នឹងឆេះទៅជាផេះ តែបើធ្វើដូច្នោះ សីលរបស់អញ ក៏នឹងពព្រុសពពាល អញនឹងមិនសម្លឹងមើល អាលម្ពាយនេះឡើយ ទើបទ្រង់បិទភ្នែកទាំង ២ ដាក់ព្រះសិរសាខាងក្នុងរង្វេល ។ អាលម្ពាយទំពាឱសថ រាយមន្ត ព្រួសទឹកមាត់លើសរីរកាយ របស់ព្រះមហាសត្វ ។ ដោយតេជានុភាពនៃឱសថ និងមន្ត សរីរៈនៃព្រះមហាសត្វដែលត្រូវទឹកមាត់ហើយ ប្រាកដហាក់ដូចហើមឡើង ។ កាលនោះ អាលម្ពាយក៏ទាញកន្ទុយព្រះមហាសត្វ អូសមក ឲ្យដេកត្រង់ស្តូក សង្កត់ដោយឈើ

ចំពាមដូចដើងពពែ ធ្វើឲ្យខ្សោយកម្លាំង ចាប់ត្រង់ក្បាលយ៉ាងតឹង រហូតដល់ព្រះពោធិសត្វហាមាត់ ។ គ្រានោះ ព្រាហ្មណ៍អាលម្ពាយក៏ព្រួសទឹកមាត់ចូលទៅក្នុងមាត់របស់ព្រះមហាសត្វ ហើយធ្វើកិច្ចដោយឱសថនិងមន្ត កាច់ព្រះទន្តព្រះពោធិសត្វឲ្យបាក់អស់ មាត់របស់ព្រះពោធិសត្វ ពេញទៅដោយឈាម ។ ព្រះមហាសត្វអត់ធន់ក្នុងទុក្ខវេទនាបែបនេះ ព្រោះខ្លាចសីលរបស់ខ្លួនបែកធ្លាយ ទ្រង់ធ្វើកែវភ្នែកឲ្យនៅស្ងៀម មិនធ្វើការសម្លឹងមើល ។ អាលម្ពាយនោះគិតថា អញនឹងធ្វើនាគរាជឲ្យទុព្វលភាព ដូច្នេះ ទើបឡើងទន្ទ្រាំលើរាងកាយរបស់ព្រះមហាសត្វ តាំងពីកន្ទុយរហូតដល់ក្បាល ឆ្អឹងរបស់ព្រះពោធិសត្វហាក់ដូចជាបាក់ទៅ ហើយមូរព្រះពោធិសត្វដូចមូរសំពត់ ធ្វើឆ្អឹងឲ្យខ្ទាត់ខ្ទាយទៅ ដូចសរសៃអំបោះ ចាប់កន្ទុយបោកដូចបោកសំពត់ សកលកាយរបស់ព្រះពោធិសត្វប្រឡាក់ទៅដោយឈាម ។ ព្រះមហាសត្វអត់សង្កត់នូវមហាទុក្ខវេទនានេះ ។ កាលអាលម្ពាយដឹងថា ព្រះមហាសត្វខ្សោយកម្លាំងហើយ ទើបយកវល្លិមកចាក់ធ្វើជាកំប្រោង ដាក់ព្រះមហាសត្វក្នុងកំប្រោងនោះហើយ នាំទៅកាន់បច្ចន្តគ្រាម ឲ្យលេងកីឡាកណ្តាលមហាជន ។ គ្រូពស់ប្រាថ្នាឲ្យសម្តែងដោយអាការយ៉ាងណាៗ មានធ្វើខ្លួនជាពណ៌ខៀវជាដើម ឬឲ្យធ្វើសណ្ឋានជារាងមូល ៤ ជ្រុង តូច ធំ ជាដើម ព្រះមហាសត្វក៏ធ្វើតាមនោះគ្រប់យ៉ាង ឲ្យរាំ ឲ្យបើកពពារ បានរាប់រយរាប់ពាន់យ៉ាង ។ មហាជនមើលហើយ គាប់ចិត្ត បានឲ្យទ្រព្យដល់ព្រាហ្មណ៍ជាច្រើន ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ បានទ្រព្យមួយពាន់ និងគ្រឿងបរិក្ខាររាប់ពាន់ ។ កាលពីដំបូង គ្រូ

ពស់គិតថា អញបានទ្រព្យ ១០០០ នឹងលែងទៅ តែកាលបានទ្រព្យប៉ុណ្ណោះហើយ គិតទៀតថា ក្នុងបច្ចន្តគ្រាមមួយ អញបានទ្រព្យដល់ម៉្លេះ ក្នុងសម្នាក់ព្រះរាជា និងមហាមាត្យគង់នឹងបានទ្រព្យច្រើន ទើបទិញរទេះមួយ និងយានសម្រាប់អង្គុយសប្បាយមួយ ដាក់របស់របរក្នុងរទេះ ហើយអង្គុយលើយានតូច ហែហមដោយបរិវារជាច្រើន ឲ្យព្រះមហាសត្វលេងក្នុងស្រុក និងនិគមជាដើមដោយលំដាប់តទៅ ហើយគិតថា អញនឹងឲ្យនាគរាជ លេងថ្វាយក្នុងសម្នាក់របស់ព្រះបាទឧគ្គសេនក្នុងនគរពារាណសី ហើយសឹមលែង ដូច្នេះហើយ ក៏ធ្វើដំណើរតទៅ ។ អាលម្ពាយសម្លាប់កង្កែបមកឲ្យនាគរាជបរិភោគជាអាហារ នាគរាជពិចារណាថា ព្រាហ្មណ៍អាលម្ពាយនេះ សម្លាប់កង្កែបរឿយៗ ព្រោះអាស្រ័យអញជាហេតុ អញនឹងមិនបរិភោគកង្កែបនោះ ហើយមិនព្រមបរិភោគ ។ កាលអាលម្ពាយដឹងដូច្នោះ បានឲ្យលាជលាយដោយទឹកឃ្មុំដល់ព្រះមហាសត្វ ព្រះមហាសត្វគិតថា បើអញបរិភោគអាហារនេះសោត អញគង់ស្លាប់ក្នុងកំប្រោងដោយពិតប្រាកដ ទើបមិនបរិភោគអាហារទាំងនោះ ។ អាលម្ពាយទៅដល់នគរពារាណសីហើយ ឲ្យព្រះមហាសត្វលេងបែកជូនមនុស្សមើលក្បែរទ្វារនគរ បានទ្រព្យជាច្រើន ។ ព្រះរាជា ក៏ត្រាស់ឲ្យព្រាហ្មណអាលម្ពាយចូលគាល់ ហើយត្រាស់ថា ចូរឲ្យពស់លេងឲ្យយើងមើលខ្លះ ។ បុរសនោះទូលស្នងព្រះរាជឱង្ការថា សាធុ ទូលព្រះបង្គំនឹងឲ្យលេងថ្វាយ ក្នុងថ្ងៃបណ្ណរសីស្អែកនេះ ព្រះរាជាត្រាស់ឲ្យភ្នាក់ងារវាយស្គរប្រកាសថា ស្អែកនេះ នាគរាជនឹងរាំត្រង់លានព្រះរាជវាំង មហាជនចូរមក

ប្រជុំគ្នាមើលចុះ លុះថ្ងៃស្អែកឡើង ទ្រង់ត្រាស់ឲ្យប្រដាប់តាក់តែងលានព្រះរាជវាំង និងត្រាស់ឲ្យព្រាហ្មណ៍អាលម្ពាយមកគាល់ ។ ព្រាហ្មណ៍អាលម្ពាយនាំព្រះពោធិសត្វមកដោយកំប្រោងរតនៈ ដាក់កំប្រោងទុកត្រង់ផ្ទៃកម្រាល ដ៏វិចិត្រ ហើយអង្គុយរង់ចាំ ។ ឯព្រះរាជាចុះអំពីប្រាសាទ ចោមរោមដោយពួកមហាជន ប្រថាប់គង់លើព្រះរាជអាសនៈ ។ អាលម្ពាយ នាំព្រះមហាសត្វចេញមកហើយ ឲ្យរាំថ្វាយ ។ មហាជននាំគ្នាត្រេកអរ មិនអាចតម្កល់ខ្លួនដោយប្រក្រតីបាន នាំគ្នាទះដៃ គ្រវីទង់គ្រវីសំពត់ សម្តែងការត្រេកអររាប់ម៉ឺនរាប់សែន ។ ភ្លៀងរតនៈ ៧ ប្រការ ក៏ធ្លាក់ចុះមកខាងលើព្រះពោធិសត្វ ។ កាលព្រះមហាសត្វត្រូវចាប់មកនោះ អស់កាលមួយខែគត់មកទល់នឹងពេលនេះ ព្រះមហាសត្វអត់ធន់ មិនបានបរិភោគអាហារឡើយ ។

ឯនាងសុមនាទេវីពិចារណាថា ប្តីជាទីស្រឡាញ់របស់អញយាងទៅយូរពន់ពេកបែបនេះ មិនទាន់យាងមកទីនេះឡើយ គ្រប់មួយខែល្មម តើមានហេតុភេទអ្វីកើតឡើងហ្ន៎ ដូច្នេះហើយ ទើបទៅពិនិត្យមើលស្រះបោក្ខរណីឃើញទឹកពណ៌ក្រហមដូចឈាម ក៏ដឹងថា ប្តីរបស់អញត្រូវអាលម្ពាយចាប់យកទៅ ទើបចេញពីនាគពិភព ទៅមើលត្រង់ដំបូក ឃើញស្លាកស្នាមដែលព្រះមហាសត្វត្រូវអាលម្ពាយចាប់និងធ្វើឲ្យលំបាក ហើយព្រះនាងព្រះកន្សែងរៀបរាប់ ធ្វើដំណើរទៅកាន់បច្ចន្តគ្រាម សាកសួរមើល បានដំណឹងការប្រព្រឹត្តទៅនោះហើយ ក៏តាមទៅរហូតដល់ក្រុងពារាណសី ឈរយំកណ្តាលអាកាស កណ្តាលបរិស័ទ ត្រង់ទ្វារព្រះរាជវាំង ។ ព្រះមហាសត្វ កំពុងរាំ

ថ្វាយព្រះរាជានោះឯង ក្រឡេកមើលអាកាស ឃើញសុមនាទេវីហើយ មានចិត្តខ្លាស ក៏លូនចូលទៅឆ្ពាយរន្ធ្វេលក្នុងកំប្រោង ។ ក្នុងកាលព្រះមហាសត្វលូនចូលទៅក្នុងកំប្រោង ព្រះរាជាទ្រង់ព្រះតម្រិះថា តើមានហេតុអ្វីហ្ន៎ ទើបទតមើលខាងនោះខាងនេះ ឃើញនាងសុមនាទេវី ឈរលើអាកាស ទើបត្រាស់គាថាដំបូងថា

នាងជាអ្វី មានពន្លឺដូចជាផ្ទេកបន្ទោរ ឬដូចជាផ្កាយព្រឹក នាងជាស្ត្រីទេវតាឬជាស្ត្រីគន្ធព្វ យើងមិនសំគាល់នាងថា ជាស្ត្រីមនុស្សទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន តំ មញ្ញាមិ មានុសឹ** សេចក្តីថា ខ្ញុំមិនបានសម្គាល់ថា នាងជាស្រីមនុស្ស នាងគួរជាទេពធីតា ឬស្រីគន្ធព្វ ។ នេះជាគាថាឆ្លើយឆ្លងរវាងនាងសុមនាទេវីនិងព្រះរាជាដូច្នេះថា

នាងនាគីក្រាបបង្គំទូលថា

បពិត្រមហារាជ ខ្ញុំម្ចាស់មិនមែនជាស្ត្រីទេវតា មិនមែនជាស្ត្រីគន្ធព្វ មិនមែនជាស្ត្រីមនុស្ស បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ជានាគកញ្ញា មកក្នុងទីនេះដោយសេចក្តីត្រូវការ ។

ព្រះរាជាត្រាស់ថា

នាងមានចិត្តតក់ស្លុត មានឥន្ទ្រិយញ័ររន្ធត់ តំណក់ទឹកភ្នែកទាំងឡាយ ហូរស្រោកចាកភ្នែកទាំងឡាយរបស់នាង ចុះវត្ថុអ្វីរបស់នាងបាត់ ម្នាលនារី នាងចង់បានរបស់អ្វី បានជាមក

ក្នុងទីនេះ ចូរនាងប្រាប់ហេតុនោះមកចុះ ។

នាងនាគីក្រាបបង្គំទូលថា

បពិត្រព្រះអង្គជាធំជាងជន ពួកជនបានហៅសត្វណាថាឧរគៈ មានតេជះដ៏ខ្ពង់ខ្ពស់ តែងហៅសត្វនោះថានាគ បុរសអ្នកត្រូវការចិញ្ចឹមជីវិត បានចាប់នាគនោះមកហើយ សូមព្រះអង្គលែងនាគនោះពីចំណងទៅ នាគនោះ ជាប្តីរបស់ខ្ញុំម្ចាស់ ។

ព្រះរាជាត្រាស់ថា

នាគរាជនេះ បរិបូណ៌ដោយកម្លាំងនិងព្យាយាម ហេតុដូចម្តេច ក៏ស្តេចមកលុះក្នុងកណ្តាប់ដៃ នៃមនុស្សក្រមុត់ទៅវិញ ម្នាលនាគកញ្ញា ចូរនាងប្រាប់ហេតុនោះដល់យើង ធ្វើម្តេចទើបយើងស្គាល់នាគដែលគេចាប់មក ( នោះ ) បាន ។

នាងនាគីក្រាបបង្គំទូលថា

ពិតដូច្នោះមែន នាគរាជនោះបរិបូណ៌ដោយកម្លាំង និងព្យាយាម អាចធ្វើសូម្បីនូវនគរឲ្យជាផេះបាន ប៉ុន្តែនាគរាជនោះគោរពធម៌ ព្រោះហេតុនោះ ទើបខំតែធ្វើតបធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថេនម្ហិ** សេចក្តីថា ខ្ញុំអាស្រ័យហេតុណាមួយ ទើបមកក្នុងនគរនេះ ។ បទថា **កុបិតិន្ទ្រិយា** បានដល់ ជាអ្នកមានឥន្ទ្រិយសៅហ្មង ។ បទថា **វារិគណា** បានដល់ តំណក់ទឹកភ្នែក ។ បទថា **ឧរគោតិ ចាហុ** សេចក្តីថា មហាជនហៅសត្វណាថា ឧរគជាតិ ។ បទថា

**តមគ្គហី បុរិសោ** សេចក្តីថា បុរសនេះចាប់ស្តេចនាគនោះមកដើម្បីចិញ្ចឹមជីវិត ។ បទថា **វណិព្វកស្ស** សេចក្តីថា ព្រះរាជាត្រាស់សួរថា នាគរាជនេះជាសត្វមានអានុភាពច្រើន ហេតុអ្វីទើបធ្លាក់ក្នុងកណ្តាប់ដៃរបស់ស្មូមនេះបាន ។

បទថា **ធម្មញ្ញ** សេចក្តីថា នាងសុមនាទេវីទូលថា នាគរាជកស្តាររបស់ខ្ញុំនេះ ធ្វើនូវការគោរពក្នុងធម៌ គឺបញ្ចសីលនិងធម៌គឺការរក្សាឧបោសថ ព្រោះហេតុនោះ ត្រូវបុរសនេះចាប់មក ទោះបីស្តេចនាគគិតថា បើអញបញ្ចេញខ្យល់ច្រមុះលើបុរសនេះសោត គេនឹងក្លាយជាគំនរផេះ កាលបើដូច្នោះ សីលរបស់អញនឹងបែកធ្លាយ ព្រោះខ្លាចសីលបែកធ្លាយ ទើបជាអ្នកព្យាយាមប្រឹងប្រែងអត់ធ្មត់នូវសេចក្តីទុក្ខនោះ តាំងចិត្តធ្វើតបៈ គឺធ្វើនូវសេចក្តីព្យាយាមរឿយៗ ។

ព្រះរាជាត្រាស់សួរបន្តទៀតថា ហេតុអ្វី ទើបនាគរាជព្រមឲ្យបុរសនេះចាប់មកបាន លំដាប់នោះ នាងសុមនាទេវី កាលនឹងក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ទើបពោលគាថាដោយសេចក្តីថា

> បពិត្រព្រះរាជា នាគរាជ ជាអ្នករក្សាចាតុទ្ទសីឧបោសថនិង
> បណ្ណរសីឧបោសថ នៅជិតផ្លូវត្រៀងកែង បុរសអ្នកត្រូវការ
> ចិញ្ចឹមជីវិត បានចាប់នាគរាជនោះមកហើយ សូមព្រះអង្គ
> លែងនាគរាជនោះពីចំណង នាគរាជនុ៎ះ ជាប្តីរបស់ខ្ញុំម្ចាស់
> ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុប្បថេ** សេចក្តីថា នាគរាជនេះ តាំងចិត្ត

ប្រាថ្នាអធិដ្ឋានធម៌ដែលប្រកបដោយអង្គ ៤ ត្រង់ជំពូកមួយ ទៀបផ្លូវបែកជា ៤ ។ បទថា **តំ ពន្ធនា** សេចក្តីថា សូមទ្រង់ព្រះរាជទានទ្រព្យដល់អាលម្ពាយនេះ ហើយដោះលែងនាគរាជដែលតាំងនៅក្នុងធម៌ មានគុណយ៉ាងនេះ អំពីចំណង គឺកំប្រោងចុះ ។

កាលនាគកញ្ញាសុមនាទេវីពោលយ៉ាងនេះហើយ កាលនឹងទូលអង្វរព្រះរាជាទៀត បានពោល ២ គាថាដោយសេចក្តីថា

នាងនាគជាស្រីស្នំរបស់នាគរាជដប់ប្រាំមួយពាន់ ពាក់កុណ្ឌល
ជាវិការៈនៃកែវមណី មានផ្ទះជាទីដេកក្នុងទឹក នាងនាគទាំង
នោះឯង ក៏ដល់នូវនាគរាជនោះជាទីពឹង ។ សូមព្រះអង្គលែង
( នាគរាជនោះ ) ដោយនូវគន្លងធម៌ ដោយអំពើមិនអាក្រក់
គឺដោយស្រុកសួយ ដោយមាសគ្គោរ ដោយគោ ១ រយ ចូរ
ឲ្យនាគមានកាយរួចស្រឡះហើយ ត្រាច់ទៅចុះ ( នាគ )
អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោឡសិត្ថីសហស្សានិ** សេចក្តីថា នាងសុមនាទេវីសម្តែងសេចក្តីថា សូមទ្រង់កុំសម្គាល់ថា នាគនេះជាបុគ្គលក្រីក្រ ព្រោះស្នំទាំងឡាយរបស់នាគរាជនេះ សុទ្ធតែប្រដាប់តាក់តែងដោយសព្វាលង្ការមានប្រមាណប៉ុណ្ណេះ សម្បត្តិដ៏សេស លំបាកនឹងគណនាបាន ។ បទថា **វារិគេហាសយា** សេចក្តីថា ទ្រង់បណ្តាលអន្លង់ទឹកឲ្យជាបន្ទប់សេយ្យាសនៈ ហើយផ្ទំក្នុងអន្លង់ទឹកនោះ ។ បទថា **ឱស្សដ្ឋកាយោ** សេចក្តីថា ចូរ

ជាអ្នកមានកាយជាឥស្សរៈ ។ បទថា **ចរាតុ** បានដល់ ចូរត្រាច់ទៅ ។

លំដាប់នោះ ព្រះរាជាបានត្រាស់ ៣ គាថា ដោយសេចក្ដីថា

យើងដោះលែង ( នាគរាជ ) ដោយនូវគន្ធនធម៌ ដោយអំពើ
មិនអាក្រក់ គឺដោយស្រុកស្អួយ ដោយមាសគ្គោរ ដោយគោ
១ រយ ចូរឲ្យនាគមានកាយរួចស្រឡះ ហើយត្រាច់ទៅចុះ
( នាគ ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ។
ម្នាលព្រាន យើងឲ្យមាសគ្គោរ ១ រយផង កុណ្ឌលជាវិការៈ
នៃកែវមណីដ៏ច្រើនផង បល្ល័ង្កមានជ្រុង ៤ មានពណ៌ដូចផ្កា
ត្រកៀតផង ភរិយាស្មើគ្នា ( ដោយវ័យជាដើម ) នេះពីរ
នាក់ផង គោឧសភ ១ រយផង នាគមានកាយរួចស្រឡះ
ហើយ ចូរត្រាច់ទៅចុះ ( នាគ ) អ្នកត្រូវការដោយបុណ្យ ចូរ
រួចពីចំណងចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លុទ្ទ** សេចក្ដីថា ដើម្បីដោះលែងនាគរាជទើប ព្រះរាជាត្រាស់ហៅព្រាហ្មណ៍អាលម្ពាយមក កាលសម្ដែងទេយ្យធម៌ ដែលគប្បីព្រះរាជទាន ដល់បុរសនោះ ទើបពោលយ៉ាងនេះ ឯព្រះគាថាមានអធិប្បាយ ដូចពោលហើយខាងដើមនោះឯង ។

លំដាប់នោះ លុទ្ទកព្រាហ្មណ៍ក្រាបទូលព្រះរាជាថា

បពិត្រព្រះអង្គជាធំជាងជន ព្រះរាជឱង្ការរបស់ព្រះអង្គ វៀរ
ចាកព្រះរាជអំណោយក៏បាន ទូលព្រះបង្គំ សូមលែងនាគនោះ

អំពីចំណង នាគមានកាយរួចស្រឡះហើយ ចូរគ្រាច់ទៅចុះ
(នាគ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តវ វចនំ** សេចក្តីថា បពិត្រព្រះអង្គ ទោះបីទ្រង់មិនបានព្រះរាជទានរបស់អ្វីមួយ គ្រាន់តែទ្រង់ត្រាស់ឲ្យលែងប៉ុណ្ណោះ ទូលព្រះបង្គំ នឹងគោរពដាក់លើសិរសា ។ បទថា **មុញ្ចេមុ ធំ** សេចក្តីថា ព្រាហ្មណ៍ អាលម្ពាយក្រាបទូលថា ទូលព្រះបង្គំនឹងលែងស្តេចនាគនេះមួយរំពេច ។

កាលលុទ្ទកព្រាហ្មណ៍ក្រាបទូលយ៉ាងនេះហើយ ក៏នាំព្រះមហាសត្វចេញអំពីកំប្រោង ។ ស្តេចនាគចេញមកហើយ លូនចូលទៅក្នុងចន្លោះគុម្ពផ្កា លះអត្តភាពនោះហើយ ក្លាយជាកុមារតូច តាក់តែងរាងកាយដោយគ្រឿងប្រដាប់ដ៏ស្អាត ដូចគ្នានឹងជ្រែកផែនដីចេញមកឈរ ដូច្នោះ ។ នាងសុមនាទេវី ចុះអំពីអាកាស មកឈរក្បែរកស្តាររបស់ខ្លួន ។ នាគរាជបានឈរផ្គងអញ្ជលីថ្វាយបង្គំព្រះរាជា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់គាថា ២ ថា

ចម្បេយ្យនាគ បានរួចហើយ ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជាក្នុងដែនកាសី សូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គអ្នកញ៉ាំងដែនកាសីឲ្យចម្រើន សូមថ្វាយបង្គំព្រះអង្គ ទូលព្រះបង្គំជាខ្ញុំ សូមផ្គងក្រពុំម្រាមដៃចំពោះព្រះអង្គ ទូលព្រះបង្គំជាខ្ញុំ ចង់បង្ហាញនូវលំនៅរបស់ទូលព្រះបង្គំជាខ្ញុំ ( ដល់ព្រះ

អង្គ ) ដូច្នេះ ។

ព្រះរាជាស្តាប់ដូច្នោះហើយត្រាស់ថា

មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្ស ដោយហេតុណា អ្នកប្រាជ្ញ ទាំងឡាយ ពោលនូវហេតុនុ៎ះថា ជាសេចក្តីស្និទ្ធស្នាលអាក្រក់ ដោយពិត ប៉ុន្តែបើអ្នកអង្វររឿងនុ៎ះនឹងយើង ម្នាលនាគ យើងនឹង ទៅមើលលំនៅរបស់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បស្សេយ្យាំ មេ និវេសនំ** សេចក្តីថា ចម្បេយ្យ នាគរាជទូលថា បពិត្រព្រះអង្គជាធំជាងនរៈ ចម្បេយ្យនាគរាជពិកព ជានិ-វេសន៍របស់ទូលព្រះបង្គំ ជារមណីយដ្ឋាន គួរមើល គួរឃើញ ទូលព្រះបង្គំ បំណងនឹងសម្តែងកពនោះដល់ទ្រង់ដើម្បីទ្រង់ទត សូមទ្រង់ មួយអន្ទើដោយ ពលពាហនៈយាងទៅទតចុះ ។

បទថា **ទុព្ពិស្សាសំ** សេចក្តីថា ជារបស់ស្និទ្ធស្នាលបានដោយក្រ ។ បទថា **សចេ ច** សេចក្តីថា ព្រះរាជាត្រាស់តបថា បើអ្នកយាងយើង យើង ចង់ឃើញនិវេសន៍របស់អ្នក តែយើងមិនទាន់ដាក់ចិត្តជឿអ្នកបានទេ ។

លំដាប់នោះ ព្រះមហាសត្វ កាលស្បថដើម្បីឲ្យព្រះរាជាទ្រង់ជឿ បាន ត្រាស់ ២ គាថា ដោយសេចក្តីថា

បើទុកជាខ្យល់កួចយកភ្នំទៅបាន ព្រះចន្ទនិងព្រះអាទិត្យជ្រុះចុះ មកលើផែនដី ទោះស្ទឹងទាំងពួងហូរប្រាសបាន បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំ ក៏មិនពោលពាក្យកុហកទេ ។ ផ្ទៃអាកាស

បែកធ្លាយក្តី សមុទ្ររីងស្ងួតក្តី ផែនដីជាទីទ្រសត្វ ទ្រទ្រព្យ
គប្បីរន្ធត់ ទាំងភ្នំមេរុសណ្ឋកឡើងព្រមទាំងឫសក្តី បពិត្រព្រះរាជា
ទូលព្រះបង្គំជាខ្ញុំ មិនពោលពាក្យកុហកទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សំវត្តេយ្យ ភូតធរា ពសុន្ធរា** សេចក្តីថា មហាប្រឹថពីដល់នូវការរាប់ថា ភូតធរាក្តី ពសុន្ធរាក្តី គប្បីមូរបានដូចកន្ទេល ផែង ។ បទថា **សមូលមុព្វហេ** សេចក្តីថា មហាសិនេរុបព៌តគប្បីសណ្តក ទាំងឫសទៅក្នុងអាកាសបាន ដូចស្លឹកឈើស្ងួតយ៉ាងនេះ ។

កាលព្រះមហាសត្វក្រាបទូលយ៉ាងនេះហើយ ព្រះរាជាក៏មិនជឿ ទើបត្រាស់គាថានោះឯងដដែលទៀតថា

មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្ស ដោយហេតុណា អ្នក
ប្រាជ្ញទាំងឡាយ ពោលនូវហេតុនុ៎ះថា ជាសេចក្តីស្និទ្ធស្នាល
អាក្រក់ដោយពិត ប៉ុន្តែបើអ្នកអង្វររឿងនុ៎ះនឹងយើង ម្នាលនាគ
យើងនឹងទៅមើលលំនៅរបស់អ្នកដែរ ដូច្នេះ ។

កាលប្រកាសយ៉ាងមាំទាំថា អ្នកគួរដឹងគុណដែលខ្ញុំធ្វើហើយដល់អ្នក ឯខ្លួនខ្ញុំរមែងដឹងវត្ថុដែលគួរជឿឬមិនគួរជឿបាន ដូច្នេះ ទើបត្រាស់ព្រះគាថាក្រៅអំពីនេះដោយសេចក្តីថា

ពួកអ្នកសោត ក៏ជាសត្វមានពិសខ្លាំងក្លាពន្លឹកណាស់ មាន
តេជះច្រើន ឆាប់ខឹង អ្នករួចអំពីចំណងបាន ព្រោះហេតុនៃ
យើង អ្នកគួរដឹងនូវឧបការគុណ ដែលយើងបានធ្វើហើយ

ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧឡារា** បានដល់ កាចក្រៃលែង ។ បទថា **ជាតិគវេ** បានដល់ គួរដឹង ។

ព្រះមហាសត្វកាលធ្វើនូវសម្បថ ដើម្បីឲ្យព្រះរាជាទ្រង់ជឿតទៅ ទើបពោលគាថាដោយសេចក្តីថា

បុគ្គលណាមិនស្គាល់នូវបុគ្គលមានកុសលកម្មធ្វើហើយ ( ធ្វើគុណ ) ប្រាកដដូចព្រះអង្គ បុគ្គលនោះចូរធ្លេះក្នុងនរក មានសភាពគួរស្បើម កុំឲ្យបានសេចក្តីសុខ ប្រព្រឹត្តទៅក្នុងកាយ បន្តិចបន្តួចសោះ ចូរជាប់នៅក្នុងទ្រុង ដល់នូវសេចក្តីស្លាប់ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បច្ចតំ** បានដល់ ចូរធ្លេះ ។ បទថា **កម្មកតំ** សេចក្តីថា នាគរាជក្រាបទូលថា បើទូលព្រះបង្គំមិនដឹងឧបការគុណដែលបុគ្គលដូចទ្រង់ធ្វើហើយ សូមទូលព្រះបង្គំមានសភាពបែបនេះចុះ ។

គ្រានោះ ព្រះរាជាទ្រង់ជឿពាក្យរបស់ព្រះមហាសត្វ កាលទ្រង់សរសើរបានត្រាស់គាថាដោយសេចក្តីថា

ពាក្យប្តេជ្ញារបស់អ្នកនុ៎ះ ជាពាក្យសត្យ អ្នកចូរកុំមានសេចក្តីក្រោធ អ្នកចូរកុំចងសេចក្តីក្រោធទុក ពួកគ្រុឌក៏ចូរវៀរលែងត្រកូលនាគទាំងអស់របស់អ្នក ដូចពួកមនុស្ស វៀរចាកគំនរភ្លើងក្នុងគិម្ហសម័យ ដូច្នោះចុះ ។

បណ្ដាបទទាំងនោះ បទថា **តវមេស ហោតុ** សេចក្ដីថា សច្ចប្បដិញ្ញានៃអ្នកនោះ ចូរជាវាចាសច្ចៈចុះ ។ បទថា **អគ្គឹវ គិម្ហាសុ វិវជ្ជយន្តុ** សេចក្ដីថា មនុស្សទាំងឡាយ កាលមិនប្រាថ្នាការក្ដៅក្នុងគិម្ហរដូវ រមែងវៀរចេញអំពីគំនរភ្លើង ដែលឆេះសន្ធោសន្ធៅ យ៉ាងណា សូមគ្រុឌទាំងឡាយ ចៀសឆ្ងាយទៅ ដូច្នោះ ។

ព្រះមហាសត្វ កាលទ្រង់សរសើរព្រះរាជា ទើបពោលគាថាក្រៅពីនេះដោយសេចក្ដីថា

បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គអនុគ្រោះនូវត្រកូលនាគ
ដូចជាមាតា អនុគ្រោះកូនប្រុសតែ ម្នាក់ដែលជាទីស្រឡាញ់
ស្មោះ ចំណែកខាងទូលព្រះបង្គំជាខ្ញុំ ព្រមទាំងត្រកូលនាគ នឹង
ធ្វើនូវការខ្វល់ខ្វាយបម្រើចំពោះព្រះអង្គដ៏លើសលុប ដូច្នេះ ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់នាគរាជហើយ មានព្រះបំណងនឹងយាងទៅកាន់នាគពិភព កាលនឹងត្រាស់ឲ្យធ្វើការត្រៀមពលសេនា យាងទៅ បានត្រាស់គាថានេះថា

នែវ៉ុយ ពួកក្មាក់ងារគ្រប់តំណែង ចូរទឹមរាជរថដ៏វិចិត្រដោយ
ប្រពៃ ចូរទឹមអស្សតរដែលកើតក្នុងដែនកម្ពុជៈ ជាពាហនៈ
ទូន្មាន បានបទល្អហើយ ចូររៀបដំរី ប្រដាប់ដោយគ្រឿង
មាស យើងនឹងទៅមើលលំនៅរបស់នាគ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កម្ពោជកេ អស្សតរេ សុទន្តេ** សេចក្ដីថា

ចូរត្រៀមអស្សពាជីដែលកើតក្នុងដែនកម្ពោជរដ្ឋ ដែលបានទទួលការបង្ហាត់យ៉ាងល្អ ។

គាថាក្រៅអំពីនេះ ជាព្រះគាថាដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងគ្រាដែលទ្រង់ត្រាស់ដឹងហើយថា

ពួកស្គរធំ ស្គរតូច ត្រែ ស័ង្ខ របស់ព្រះរាជាព្រះនាមឧគ្គសេន
ក៏លាន់ឮឡើង ព្រះរាជាទ្រង់ព្រះលំអច្រើនប្រការ ទ្រង់ស្តេច
យាងទៅក្នុងកណ្តាលនៃពួកនារី ដែលចោមរោមជុំវិញដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុ សោភមានោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទពារាណសីចោមរោមដោយពួកស្នំ ១៦០០០ ជាបរិវារ យាងទៅកាន់នាគពិភព អំពីនគរពារាណសីកណ្តាលពួកស្នំនោះ យាងទៅរុងរឿងក្រៃពេក ។

ក្នុងកាលព្រះបាទពារាណសីយាងចេញអំពីព្រះនគរទៅ ព្រះមហាសត្វទ្រង់បណ្តាលឲ្យនាគពិភពប្រាកដ មានកំពែងរតនៈ ៧ ប្រការ ទ្វារ ប៉ម គូទឹក ហើយនិម្មិតផ្លូវសម្រាប់ទៅកាន់នាគពិភព ឲ្យប្រដាប់តាក់តែងដោយគ្រឿងប្រដាប់ដ៏ស្អាត ដោយអានុភាពរបស់ខ្លួន ។ ព្រះរាជាមួយអន្លើដោយរាជបរិវារ យាងទៅកាន់នាគពិភពដោយផ្លូវនោះ ទតឃើញភូមិភាគនិងប្រាសាទ រាជវាំងគួរជាទីត្រេកអរ ។

ព្រះបរមសាស្តា កាលប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះរាជាអ្នកញុំាងដែនកាសីឲ្យចម្រើន បានទតផែនដីដ៏វិចិត្រ

ដោយមាស និងប្រាសាទទាំងឡាយ ជាវិការៈនៃមាស ដែល
ក្រាលដោយបន្ទះកែវពៃទូរ្យ ។ ព្រះរាជាអង្គនោះ ទ្រង់ចូល
ទៅកាន់នាគពិភពដ៏សម្បើម ជាទីនៅនៃចម្បេយ្យនាគរាជ ដ៏
ភ្លឺស្វាង ដូចជាពណ៌នៃព្រះអាទិត្យ មានរស្មីផ្លេកៗ ដូចផ្លេក
បន្ទោរពណ៌មាស ។ ព្រះបាទកាសីនោះ ទ្រង់ទតនិវេសនដ្ឋាន
របស់ចម្បេយ្យនាគរាជដ៏ដេរដាសដោយឈើទាំងឡាយផ្សេងៗ
ដ៏ផ្សព្វផ្សាយដោយក្លិនក្រអូបផ្សេងៗ ។ កាលដែលព្រះបាទ
កាសីទ្រង់ចូលទៅហើយ តូរ្យតន្ត្រីទាំងឡាយជាទិព្វ ក៏លាន់
ឮឡើង នាគកញ្ញាទាំងឡាយ ក៏រាំថ្វាយ ក្នុងរាជនិវេសន៍នៃ
ចម្បេយ្យនាគរាជ ។

ព្រះរាជនិវេសន៍នោះ ដេរដាសដោយពួកនៃនាគកញ្ញា ព្រះរាជា
កាសីទ្រង់ជ្រះថ្លា ឡើងគង់លើបល្ល័ង្ក ជាវិការៈនៃមាស មាន
បង្អែកដ៏លាបលនដោយខ្លឹមចន្ទន៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុវណ្ណចិត្តកំ** សេចក្ដីថា ក្រាលហើយដោយ
ខ្សាច់មាស ។ បទថា **ព្យម្ហំ** សេចក្ដីថា ទៅកាន់នាគពិភពដែលតាក់តែង
ហើយ ។ បទថា **ចម្បេយ្យស្ស** សេចក្ដីថា យាងទៅកាន់នាគពិភពដែល
ប្រដាប់ហើយ ទ្រង់ព្រះរាជដំណើរទៅកាន់និវេសន៍របស់ចម្បេយ្យនាគរាជ ។
បទថា **កំសាវិជ្ជុបភស្សរំ** សេចក្ដីថា រុងរឿងដោយរស្មី ដូចផ្លេកបន្ទោរក្នុង
លម្ហ ។ បទថា **នានាគន្ធសមីរិតំ** សេចក្ដីថា រមែងផ្សាយខ្ទរខ្ទាយទៅដោយ

ទិព្វសុគន្ធផ្សេងៗ ។ បទថា **ចរិតំ គណេន** សេចក្តីថា ទៅកាន់និវេសន៍នោះ ដែលនាគកញ្ញាតាមទៅជាមួយ ។ បទថា **ចន្ទនសារលិត្តោ** សេចក្តីថា លាប ហើយដោយខ្លឹមចន្ទន៍ដែលជាទិព្វ ។

កាលព្រះបាទ កាសិករាជ ទ្រង់ប្រថាប់លើបល្ល័ង្កហើយ ភ្នាក់ងារអ្នក ពិសេសក៏នាំគ្រឿងទិព្វដែលសម្បូរដោយឱជា ច្រើនប្រការ បង្អោនចូលទៅថ្វាយ និងយាងទៅអង្គាស ពួកស្នំទាំង ១៦០០០ ព្រមទាំងរាជបរិស័ទ ។ ព្រះបាទ ពារាណសី ព្រមទាំងរាជបរិស័ទ ទ្រង់សោយព្រះក្រយា និងទឹកដែលជាទិព្វ ត្រេកអររីករាយដោយទិព្វកាមគុណ និងប្រថាប់ក្នុងសុខសេយ្យាសនៈប្រមាណ ៧ ថ្ងៃ ទ្រង់សរសើរឥស្សរិយយសរបស់ព្រះមហាសត្វ ហើយត្រាស់សួរថា បពិត្រនាគរាជ ព្រោះហេតុអ្វី ទើបអ្នកបានសម្បត្តិបែបនេះ បែរជាទៅដេក រក្សាឧបោសថសីលលើដំបូក ក្នុងមនុស្សលោក ។ ឯព្រះមហាសត្វក៏ក្រាប ទូលឲ្យទ្រង់ជ្រាប ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះបាទកាសីនោះ ទ្រង់សោយ ទ្រង់រីករាយក្នុងនាគពិភព នោះហើយ មានព្រះរាជឱង្ការចំពោះចម្បេយ្យនាគរាជថា វិមាន ដ៏ប្រសើរទាំងឡាយ របស់អ្នកនេះ មានពណ៌ដូចព្រះអាទិត្យ ដ៏ភ្លឺផ្លេកៗ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ ដើម្បីអ្វី ។ ពួកនាងនាគកញ្ញានោះ ពាក់នូវគ្រឿងប្រដាប់មាស មានសម្លៀកបំពាក់ដ៏ល្អ មានម្រាម

ដៃមូល ប្រកបដោយផ្ទៃ ( ដៃនិងជើង ) ដ៏ក្រហម មានសម្បុរមិនអន់អាប់ លើក ( នូវទិព្វបានៈ ) ទៅថ្វាយដើម្បីសោយ ធម្មជាតប្រាកដដូច្នោះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ស្ទឹងទាំងឡាយមានទឹកត្រជាក់ មានត្រីមានស្រកាក្រាស់ មានអាទាសបក្សីយំពីរោះ មានកំពង់ល្អ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ហ្វូងក្រៀល ក្ងោក ហង្ស តាវៅ ដ៏ជាទិព្វ ស្រែកនូវសម្រែកដ៏ពីរោះ ហើរទំពីព្រឹក្សាមួយទៅរកព្រឹក្សាមួយ ធម្មជាតដែលប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ដើមស្វាយ ដើមសាលព្រឹក្ស ដើមមៀន ដើមព្រីង ដើមរាជព្រឹក្ស ដើមប្រទៀងទាំងឡាយ មានផ្ការីកស្គុះស្គាយ រុក្ខជាតដែលប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។ ក្លិនដ៏ជាទិព្វទាំងឡាយរមែងបក់ផ្សាយទៅជុំវិញស្រះបោក្ខរណី ទាំងនេះជានិច្ច គន្ធជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី ។

ចម្បេយ្យនាគរាជទូលថា

បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំជាខ្ញុំធ្វើតបធម៌ មិន

មែនព្រោះហេតុចង់បានកូន មិនមែនចង់បានទ្រព្យ ឬថា មិនមែន ព្រោះហេតុចង់បានអាយុទេ ទូលព្រះបង្គំជាខ្ញុំ ចង់បានកំណើតជាមនុស្ស ព្រោះហេតុនោះ ទើបខ្ញុំប្រឹងធ្វើតបធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តា** ព្រះរាជាត្រាស់សំដៅដល់នាគកញ្ញា ១ ម៉ឺន ៦ ពាន់នាក់នោះ ។ បទថា **កម្ពុកាយូរធរា** បានដល់ ពាក់នូវអាភរណៈដែលសម្រេចដោយមាស ។ បទថា **វដ្ដង្គុលី** បានដល់ មានម្រាមដៃមូលដូចគ្នានឹងពន្លកកែវប្រពាល ។ បទថា **តម្ពតលូបបន្នា** សេចក្តីថា ប្រកប ទៅដោយបាតដៃ និងបាតជើងក្រហមល្អពន់ពេក ។ បទថា **ចាយេន្តិ** សេចក្តីថា នាំគ្នាលើកទិព្វបានៈ ផ្គងចូលទៅថ្វាយ ឲ្យទ្រង់សោយ ។ បទថា **បុថុលោមមច្ឆា** សេចក្តីថា ប្រកបទៅដោយត្រីច្រើនប្រភេទជាត្រីមានស្រកាក្រាស់ ។ បទថា **អាតាសកុណ្ឌាភិរុទា** សេចក្តីថា មានសត្វកេងកងយំលេ្វងលើ្វយ ។ បទថា **សុតិត្ថា** សេចក្តីថា មានកំពង់ឡើងចុះរាបស្មើល្អ ។ បទថា **ទិរិយា ច ហំសា** បានដល់ ហ្វូងហង្សទឹក ។ បទថា **សម្បតន្តិ** សេចក្តីថា យំដោយសំឡេងពីរោះជាប់ចិត្ត ហើរឡើងអំពីដើមឈើនោះ មកដើមឈើនេះ ។

បទថា **ទិព្វា គន្ធា** សេចក្តីថា ម្យ៉ាងទៀត ទិព្វសុគន្ធទាំងឡាយ តែងផ្សាយឈ្ងុយឈ្ងប់មិនដាច់ក្នុងស្រះបោក្ខរណីទាំងឡាយនោះ ។ បទថា **អភិបត្ថយានោ** សេចក្តីថា ប្រាថ្នានូវកំណើតមនុស្សត្រាច់ទៅ ។ បទថា **តស្មា** សេចក្តីថា ដោយហេតុនោះ ទើបខ្ញុំប្រឹងប្រែង គឺផ្គងព្យាយាមធ្វើនូវតបៈ គឺ

បំពេញឧបោសថសីល បានដល់ រក្សាឧបោសថ ។

កាលមហាសត្វក្រាបទូលយ៉ាងនេះហើយ ព្រះរាជាកាលធ្វើការសរសើរ ទើបត្រាស់ព្រះគាថាដោយសេចក្តីថា

អ្នកមានភ្នែកក្រហម មានស្មើក៏ប្រាលផ្កា មានខ្លួនប្រដាប់ហើយ មានសក់និងពុកមាត់កោរកាត់ហើយ ប្រោះព្រំយ៉ាងល្អដោយចន្ទន៍ក្រហម ភ្លឺផ្សាយទៅសព្វទិស ដូចជាគន្ធព្វរាជ ។ អ្នកមានឫទ្ធិដូចជាទេវតា មានអានុភាពច្រើន បរិបូណ៌ដោយកាមទាំងឡាយគ្រប់យ៉ាង ។ ម្នាលនាគរាជ មនុស្សលោកប្រសើរដោយវិសេសជាងនាគពិភពនេះ ដោយហេតុអ្វី យើងសូមសួរអ្នកចំពោះហេតុនុ៎ះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា សុរោសិតោ បានដល់ ប្រោះព្រំ ។

លំដាប់នោះ ស្តេចនាគកាលក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ទើបទូលថា

បពិត្រព្រះអង្គ ជាធំជាងជន សេចក្តីបរិសុទ្ធក្តី ការសង្រួមក្តី បើវៀរចាកមនុស្សលោកចេញហើយ ឥតមានទេ បើទូលព្រះបង្គំជាខ្ញុំបានកំណើតជាមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិនិងមរណៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុទ្ធី វា** សេចក្តីថា បពិត្រមហារាជ វៀរមនុស្សលោកហើយ សេចក្តីបរិសុទ្ធ ពោលគឺអមតនិព្វានក្តី ការសង្រួមក្នុង

សីលក្តី មិនមានឡើយ ។ បទថា **អន្តំ** សេចក្តីថា ខ្ញុំធ្វើតបៈដោយគិតថា អញបានកំណើតមនុស្សហើយ នឹងធ្វើទីបំផុតនៃជាតិ និងមរណៈបាន ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ព្រះគាថាដោយសេចក្តីថា

ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវ
ហេតុច្រើនប្រការ គេត្រូវគប់រកដោយពិត ម្នាលនាគរាជ
ចំណែកខាងយើង បានឃើញនូវពួកនាងនារីផង នូវអ្នកផង នឹង
ធ្វើបុណ្យទាំងឡាយយ៉ាងច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នារិយោ ច** សេចក្តីថា ព្រះរាជាត្រាស់ថា យើងឃើញនាគកញ្ញាទាំងឡាយរបស់អ្នក និងខ្លួនរបស់អ្នកហើយ នឹងធ្វើបុណ្យឲ្យច្រើន ។ លំដាប់នោះ ស្តេចនាគទូលព្រះរាជាថា

ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវ
ហេតុច្រើនប្រការ គេត្រូវគប់រកដោយពិត បពិត្រព្រះរាជា ព្រះ
អង្គទ្រង់ទតឃើញនូវពួកនាងនារីផង នូវទូលព្រះបង្គំជាខ្ញុំផង
សូមព្រះអង្គធ្វើនូវបុណ្យទាំងឡាយយ៉ាងច្រើនចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ករោហិ** សេចក្តីថា បពិត្រមហារាជ ទ្រង់គប្បីធ្វើកុសលឲ្យច្រើនចុះ ។

កាលព្រះមហាសត្វក្រាបទូលយ៉ាងនេះហើយ ព្រះបាទឧគ្គសេន ទ្រង់មានបំណងត្រឡប់មកកាន់មនុស្សលោក ទើបត្រាស់ពាក្យលាថា បពិត្រនាគរាជ ខ្ញុំមកក៏យូរហើយ ចាំបាច់នឹងត្រឡប់ទៅកាន់មនុស្សលោក ។

លំដាប់នោះ ព្រះមហាសត្វ ក៏ទូលព្រះរាជាថា បពិត្រមហារាជ បើដូច្នោះ សូមទ្រង់កាន់យកទ្រព្យសម្បត្តិទៅតាមព្រះរាជបំណងចុះ កាលនាគរាជបង្ហាញទ្រព្យសម្បត្តិ ទើបទូលថា

ប្រាក់របស់ទូលព្រះបង្គំជាខ្ញុំនេះច្រើនណាស់ ទាំងគំនរមាសក៏ប្រហែលកម្ពស់ដើមត្នោត សូមព្រះអង្គឲ្យរាជបម្រើ នាំអំពីនាគពិភពនេះ ទៅកសាងព្រះរាជដំណាក់ ជាវិការៈនៃមាស ពួកជាងចូរធ្វើកំពែងជាវិការៈនៃប្រាក់ចុះ ។ គំនរកែវមុក្តា មានប្រាំពាន់វាហៈ ( រទេះ ) គំនរកែវពៃទូរ្យ ( ប្រាំពាន់វាហៈ ) នេះ សូមពួកជននាំទៅអំពីនាគពិភពនេះ ហើយក្រាលលើផែនដីខាងក្នុងបុរី ឲ្យជាទីមិនមានភក់ មិនមានធូលី ។ បពិត្រព្រះរាជាដ៏ប្រសើរ សូមព្រះអង្គគ្រប់គ្រងក្រុងពារាណសី ឲ្យជាវិមានប្រសើរ មានលំអច្រើនអន្លើ ជានគរស្តុកស្តម្ភ ទូលំទូលាយ មានសភាពដូច្នេះចុះ បពិត្រព្រះអង្គមានប្រាជ្ញាមិនថោកថយ សូមព្រះអង្គសោយរាជ្យចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រាសិ** សេចក្តីថា គំនរប្រាក់ គំនរមាសប្រមាណមួយជួរដើមត្នោតមានក្នុងទីនោះៗ ។ បទថា **សោវណ្ណាយកានិ** បានដល់ ព្រះរាជវាំងមាស ។ បទថា **និក្កទ្ទមា** សេចក្តីថា បើដូច្នោះ ភូមិភាគក្នុងព្រះរាជដ្ឋានក៏នឹងស្អាត ប្រាសចាកភក់និងល្អងធូលី ។ បទថា **ឯតាទិសំ** សេចក្តីថា គ្រប់គ្រងនគរពារាណសីដែលមានកំពែងព័ទ្ធដោយមាស និងប្រាក់

មានផ្ទៃដីក្រាលហើយដោយកែវមុក្តានិងកែវពៃទូរ្យយ៉ាងនេះ ។ បទថា **ជីតំ** សេចក្តីថា សូមទ្រង់នៅគ្រប់គ្រងព្រះនគរពារាណសីដែលមាំទាំ ទូលំទូលាយដូច្នេះ ។ បទថា **អនោមបញ្ញា** សេចក្តីថា មានព្រះបញ្ញាមិនថោកថយ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ព្រះមហាសត្វហើយ ក៏ទ្រង់ទទួលយក ។ ព្រះមហាសត្វ ក៏ឲ្យក្តាក់ងាវខាងវាយស្គរ វាយស្គរប្រកាសក្នុងនាគពិភពថា រាជបុរសទាំងពួង ចូរនាំគ្នាជញ្ជូនយកទ្រព្យសម្បត្តិ មានមាស ប្រាក់ជាដើមទៅតាមប្រាប្នាចុះ រូបយករទេះច្រើនរយដាក់ទ្រព្យសម្បត្តិ បញ្ជូនទៅថ្វាយព្រះរាជា ។ ព្រះរាជាយាងចេញពីនាគពិភព ទៅកាន់នគរពារាណសីដោយយសបរិវារច្រើន ។ បានឮថា តាំងពីនោះមក ផ្ទៃជម្ពូទ្វីប កើតមានមាសនិងប្រាក់ឡើង ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបត្រាស់ថា បុរាណកបណ្ឌិតទាំងឡាយ លះនាគសម្បត្តិហើយ រក្សាឧបោសថសីលដោយអាការយ៉ាងនេះ ហើយទ្រង់ប្រជុំជាតកថា គ្រូពស់ក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ នាគកញ្ញាសុមនាទេវី ក្នុងកាលនោះ បានមកជារាហុលមាតា ព្រះបាទឧគ្គសេនក្នុងកាលនោះ បានមកជាសារីបុត្ត ឯចម្បេយ្យនាគរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ចម្បេយ្យជាតក ចប់**

# មហាបលោភនជាតក

[ ៣៣៧ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងជាតកនេះថា ) ទេវបុត្រមានឫទ្ធិច្រើន ច្យុតចាកព្រហ្មលោកបានកើតជាបុត្តនៃព្រះរាជា ទ្រង់ឋិតនៅក្នុងសម្បត្តិជាគ្រឿងញ៉ាំងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេច ។ កាមទាំងឡាយក្តី កាមសញ្ញាក្តី មិនមានក្នុងព្រហ្មលោកទេ ព្រះរាជបុត្តនោះ នឿយណាយចាកកាមទាំងឡាយ ព្រោះឈានសញ្ញា ( ដែលកើតក្នុងព្រហ្មលោក ) នោះឯង ។ ក៏ក្នុងព្រះរាជវាំងនៃព្រះរាជានោះ មានព្រះរាជដំណាក់សម្រាប់ចម្រើនឈាន ដែលគេកសាងហើយដោយល្អ ព្រះរាជបុត្តនោះ ទ្រង់សម្ងំតែមួយព្រះអង្គឯង ចម្រើនឈានក្នុងទីកំបាំង ក្នុងព្រះរាជដំណាក់នោះ ។ ព្រះបាទកាសីនោះ ទ្រង់បរិទេវនាការ ចង្អៀត ចង្អល់ ដោយសេចក្តីសោក ព្រោះព្រះរាជបុត្តថា ព្រះរាជបុត្តតែមួយរបស់យើងនេះ មិនបរិភោគកាម ។ ឧបាយក្នុងរឿងនេះដូចម្តេចហ្ន៎ ឬថា នរណាហ្ន៎ ចេះខ្វល់ខ្វាយក្នុងរឿងនេះ អ្នកណាអាចប្រលោមកូនអញ ឲ្យប្រាថ្នាកាមទាំងឡាយបាន ។

[ ៣៣៨ ] ក្នុងព្រះរាជវាំងនោះឯង មានកុមារីម្នាក់ ជាស្ត្រីមានសម្បុរនិងរូបល្អ ជាស្ត្រីឈ្លាសវាងវៃក្នុងការរាំច្រៀង ទាំងបានសិក្សា ល្អក្នុងការប្រគំ កុមារីនោះ ចូលទៅគាល់ក្នុងទីនោះហើយ ក្រាបបង្គំទូល ( ព្រះរាជា ) ថា បើព្រះរាជឱរសនឹងបានជាព្រះភស្តានៃខ្ញុំម្ចាស់ ខ្ញុំម្ចាស់អាចនឹងប្រលោមព្រះរាជឱរសនោះឲ្យខាងតែបាន ។

[ ៣៣៩ ] ព្រះរាជាទ្រង់មានព្រះរាជឱង្ការដូច្នេះនឹងកុមារីដែលនិយាយ

ដូច្នោះនោះថា ចូរនាងប្រលោមព្រះរាជឱរសនោះចុះ ព្រះរាជឱរសនោះ នឹងជាកស្តាររបស់នាង ។

[ ៣៤០ ] កុមារីនោះ ក៏ទៅខាងក្នុងព្រះរាជវាំងហើយ ( ច្រៀង ) នូវចម្រៀងដែលប្រកបដោយកាមច្រើនប្រការ ពោលគាថាដ៏វិចិត្រ ជាទីស្រឡាញ់ ជ្រួតជ្រាបក្នុងហឫទ័យ ។

[ ៣៤១ ] ចំណង់ក្នុងកាមកើតឡើងដល់ព្រះរាជបុត្តនោះ ព្រោះបានស្តាប់សំឡេងរបស់នារីច្រៀងថ្វាយនោះឯង ព្រះរាជឱរស នោះទ្រង់សាកសួរជនថា យីអើ នុ៎ះជាសំឡេងនរណា ឬថា នរណានោះ ពោលពាក្យខ្ពស់ទាបច្រើនដ៏ជ្រួតជ្រាបក្នុងហឫទ័យជាទីស្រឡាញ់ជាសុខត្រចៀករបស់អញ ។

[ ៣៤២ ] បពិត្រព្រះសម្មតិទេព នុ៎ះឯងជាស្រ្តី ស្រ្តីនុ៎ះចេះល្បែងច្រើនប្រការ បើព្រះអង្គទ្រង់សោយនូវកាមទាំងឡាយណា កាមទាំងឡាយនោះនឹងញុំាងព្រះអង្គឲ្យរីងរឹតតែគាប់ព្រះទ័យ ។

[ ៣៤៣ ] អើបើដូច្នោះ ចូរកុមារីមកអាយចុះ ចូរច្រៀងក្នុងទីជិតចុះ ចូរច្រៀងក្នុងទីជិតអាស្រមក្នុងសំណាក់នៃយើងចុះ ។

[ ៣៤៤ ] កុមារីនោះ ច្រៀងក្នុងទីខាងក្រៅជញ្ជាំង ហើយចូលទៅក្នុងព្រះរាជដំណាក់សម្រាប់ចម្រើនឈាន ដើម្បីចងព្រះរាជកុមារនោះ តាមលំដាប់ ដូចជាហ្មដំរីចងដំរីក្នុងព្រៃ ។

[ ៣៤៥ ] ធម៌ប្រណែន បានកើតព្រោះដឹងនូវកាមរស នៃកុមារីនោះ យើងត្រូវតែបរិភោគកាមទាំងឡាយ តែម្នាក់ឯងប៉ុណ្ណោះ កុំឲ្យមានបុរសដទៃ

ឡើយ ។ តពីនោះទៅ ព្រះរាជកុមារទ្រង់កាន់ដាវ ព្យាយាម ដើម្បីសម្លាប់បុរសទាំងឡាយ ដោយគិតថា អញត្រូវបរិភោគកាមតែម្នាក់ឯងប៉ុណ្ណោះ កុំគប្បីមានបុរសដទៃ ។

[ ៣៤៦ ] ក្នុងកាលនោះ អ្នកជនបទទាំងអស់ មកប្រជុំគ្នា កន្ទក់កន្ទេញថា បពិត្រមហារាជ ព្រះរាជបុត្ររបស់ព្រះអង្គនេះ បៀតបៀននូវជនដែលមិនប្រទូស្ត ។

[ ៣៤៧ ] ព្រះរាជាជាក្សត្រ ទ្រង់បំបរបង់ព្រះរាជបុត្តចេញចាកដែននោះថា ទីដែនរបស់អញមានត្រឹមណា ឯងមិនត្រូវនៅត្រឹមនោះទេ ។

[ ៣៤៨ ] លំដាប់នោះ ព្រះរាជកុមារនោះ ទ្រង់នាំកិរិយាចូលទៅជិតសមុទ្ទ ធ្វើនូវបណ្ណសាលា ហើយចូលទៅកាន់ព្រៃដើម្បីស្វែងរកផលាផល ។

[ ៣៤៩ ] លំដាប់នោះ ឥសីមកខាងលើៗសមុទ្ទដល់ក្នុងទីនុ៎ះ ឥសីនោះបានឃើញផ្ទះរបស់ព្រះរាជកុមារនោះក្នុងភត្តកាលដល់ហើយ ។

[ ៣៥០ ] ឯកិរិយាក៏ប្រលោមតាបសនោះ ( ម្នាលភិក្ខុ ) អ្នកចូរមើលអំពើអាក្រក់គួរស្បើម ( នោះ ) ចុះ តាបសនោះឃ្លាត ចាកព្រហ្មចរិយធម៌ហើយ ក៏សាបសូន្យចាកឫទ្ធិ ។

[ ៣៥១ ] ចំណែកខាងព្រះរាជបុត្ត ដល់វេលាល្ងាចក៏នាំយកមើមឈើនិងផ្លែឈើជាច្រើនមកអំពីទីស្វែងរកផលាផល ដោយអម្រែក ហើយចូលទៅកាន់អាស្រម ។

[ ៣៥២ ] ឯឥសីបានឃើញស្តេចហើយ ក៏ចូលទៅជិតសមុទ្ទដោយគិតថា អញនឹងទៅកាន់អាកាស តែឥសីនោះលិចចុះក្នុងសមុទ្ទ ។

[ ៣៥៣ ] មហាក្សត្រ បានឃើញឥសីកំពុងលិចក្នុងសមុទ្រ ហើយពោលគាថាទាំងនេះ ដោយសេចក្តីអនុគ្រោះដល់តាបសនោះថា

[ ៣៥៤ ] តាបសមកលើទឹកមិនបែក ដោយឫទ្ធិខ្លួនឯង ហើយលិចក្នុងសមុទ្រ ព្រោះដល់នូវសេចក្តីច្រឡូកច្រឡំដោយស្ត្រី ។ ធម្មតាពួកស្រី ជាអ្នកនាំឲ្យវិលវល់ណាស់ មានមាយាច្រើន ជាអ្នកញុំាងព្រហ្មចរិយធម៌ ឲ្យកម្រើក តែងនាំពន្លិច បុគ្គលដឹងច្បាស់នូវហេតុនោះហើយ គប្បីវៀរអំពីចម្ងាយ ។ ពួកស្រីមានសម្ផស្សឥតទោស មានសម្ផស្សទន់ភ្លន់ ស្មើដោយស្ពឹង ព្រោះគេបំពេញបានដោយកម្រ តែងនាំពន្លិច បុគ្គលអ្នកដឹងច្បាស់នូវហេតុនោះហើយ គប្បីវៀរចេញអំពីចម្ងាយ ។ ស្រីទាំងនុ៎ះ ចូលទៅគប់រកបុរសណា ព្រោះសេចក្តីពេញចិត្តក្តី ព្រោះទ្រព្យក្តី រមែងដុតបំផ្លាញបុរសនោះយ៉ាងឆាប់ ដូចភ្លើងព្រៃដុតនូវឋានទីរបស់ខ្លួន ។

[ ៣៥៥ ] សេចក្តីនឿយណាយ ក៏កើតមានឡើងដល់ឥសី ព្រោះបានស្តាប់ព្រះរាជបន្ទូលរបស់មហាក្សត្រ ហើយត្រឡប់បាននូវផ្លូវចាស់ ( ឈានវិសេស ) ក៏ទៅតាមអាកាសវិញ ។

[ ៣៥៦ ] ព្រះមហាក្សត្រជាអ្នកប្រាជ្ញ លុះបានឃើញឥសីទៅតាមអាកាសហើយ ក៏បាននូវសេចក្តីតក់ស្លុត ទ្រង់គាប់ព្រះហឫទ័យសីប់ចំពោះបព្វជ្ជា ។ លំដាប់នោះ ព្រះមហាក្សត្រនោះ ទ្រង់បព្វជ្ជាហើយ ក៏នឿយណាយចាកកាមរាគ លុះនឿយណាយចាកកាមរាគហើយ បានចូលទៅកើតក្នុងព្រហ្មលោក ។

**ចប់ មហាបលោភនជាតក ទី ១១ ។**

# អដ្ឋកថា

# មហាបលោភនជាតក

[ ៣៣៧-៣៥៦ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាតុគ្រាម ធ្វើសត្វដែលបរិសុទ្ធឲ្យសៅហ្មង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ព្រហ្មលោកា ចវិត្វាន** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន ខ្ញុំពោលទុកពិស្ដារហើយខាងដើមនោះឯង ។ ក្នុងជាតកនេះ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា មាតុគ្រាមរមែងធ្វើសត្វដែលបរិសុទ្ធ ឲ្យសៅហ្មងបាន ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

រឿងក្នុងអតីត បណ្ឌិតគប្បីឲ្យពិស្ដារតាមន័យដែលពោលហើយ ក្នុងចុល្លបលោភនជាតក ( តិកនិបាត ) ថា **អតីតេ ពារាណសិយំ** ដូច្នេះជាដើម ។ ក្នុងកាលនោះ ព្រះមហាសត្វចុតិអំពីព្រហ្មលោក មកកើតជាព្រះរាជឱរសរបស់ព្រះបាទកាសិករាជ ព្រះនាមថាអនិត្ថិគន្ធកុមារ ។ កុមារមិនព្រមនៅក្នុងដៃរបស់ស្ត្រីឡើយ ។ ស្ត្រីដែលឲ្យកុមារបៅដោះ ត្រូវតែសង្វនជាបុរស ព្រះរាជកុមារចូលចិត្តប្រថាប់ក្នុងឈានាគារ ( អគារសម្រាប់ចម្រើនឈាន ) មិនចង់ជួប មិនចង់ឃើញស្ត្រីឡើយ ។

ព្រះបរមសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ បានត្រាស់គាថា ៤ ដោយសេចក្ដីថា

ទេវបុត្តមានឫទ្ធិច្រើន ច្យុតចាកព្រហ្មលោកបានកើតជាបុត្តនៃ

ព្រះរាជា ទ្រង់ឋិតនៅក្នុងសម្បត្តិ ជាគ្រឿងញ៉ាំងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេច ។ កាមទាំងឡាយក្តី កាមសញ្ញាក្តី មិនមានក្នុងព្រហ្មលោកទេ ព្រះរាជបុត្តនោះ នឿយណាយចាកកាមទាំងឡាយ ព្រោះឈានសញ្ញា ( ដែលកើតក្នុងព្រហ្មលោក ) នោះឯង ។ ក៏ក្នុងព្រះរាជវាំងនៃព្រះរាជានោះ មានព្រះរាជដំណាក់សម្រាប់ចម្រើនឈាន ដែលគេកសាងហើយដោយល្អ ព្រះរាជបុត្តនោះ ទ្រង់សម្ងំតែមួយព្រះអង្គឯងចម្រើនឈានក្នុងទីកំបាំងក្នុងព្រះរាជដំណាក់នោះ ។ ព្រះបាទកាសីនោះ ទ្រង់បរិទេវនាការចង្អៀតចង្អល់ដោយសេចក្តីសោកព្រោះព្រះរាជបុត្តថា ព្រះរាជបុត្តតែមួយរបស់យើងនេះ មិនបរិភោគកាម ។ ឧបាយក្នុងរឿងនេះ ដូចម្តេចហ្ន៎ ឬថា នរណាហ្ន៎ ចេះខ្វល់ខ្វាយក្នុងរឿងនេះ អ្នកណាអាចប្រលោមកូនអញឲ្យប្រាថ្នាកាមទាំងឡាយបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វកាមសមិទ្ធិសុ** សេចក្តីថា ទេវបុត្តមួយអង្គកើតជាព្រះរាជឱរសរបស់ព្រះរាជា តាំងនៅក្នុងរាជសម្បត្តិដ៏មាំទាំ បរិបូណ៌ដោយសព្វកាមារម្មណ៍ ។ បទថា **ស្វាស្ស** បានដល់ ព្រះរាជកុមារអង្គនោះ ។ បទថា **តាយេវ** សេចក្តីថា ដោយឈានសញ្ញាដែលកើតហើយក្នុងព្រហ្មលោកនោះឯង ។ បទថា **សុមាបិតំ** សេចក្តីថា ព្រះរាជបិតាទ្រង់សាងឈានាគារទុក គួរជាទីត្រេកអរ ។ បទថា **រហោសិ ឈាយថ** សេចក្តីថា

ព្រះរាជកុមារមិនបានដាក់ព្រះហឫទ័យសម្លឹងមើលមាតុគ្រាមឡើយ ។ បទថា **បរិធេវសិ** សេចក្តីថា ទ្រង់កន្ទក់កន្ទេញ ។

បទថា **កោ នុ ខ្វត្ថ ឧបាយោ សោ** សេចក្តីថា ក្នុងរឿងនេះ មានឧបាយឲ្យឱរសរបស់យើងសោយកាមសម្បត្តិ បានដូចម្តេចហ្ន៎ ។ បាឋៈថា **កោ នុខោ ឥធូបាយោ សោ** ប្រែថា ឧបាយក្នុងរឿងនេះមានដូចម្តេចហ្ន៎ ដូច្នេះក៏មាន ។ តែក្នុងអដ្ឋកថាលោកពោលទុកថា **កោ នុខោ តំ ឧបវសិត្វា ឧបលាបនការណំ ជានាតិ** សេចក្តីថា អ្នកណាហ្ន៎ដែលចូលទៅដឹងហេតុដែលធ្វើឲ្យកូនរបស់យើងចូលទៅជាប់ជំពាក់ក្នុងកាមបាន ។ បទថា **កោ វា ជានាតិ កិញ្ចនំ** សេចក្តីថា ឬថា បុគ្គលណាដឹងហេតុក្នុងឱរសរបស់យើងនេះឈ្លក់វង្វេងក្នុងកាមបាន ។

ខាងមុខអំពីនេះទៅ ជាអភិសម្ពុទ្ធគាថាដែលព្រះសាស្តាត្រាស់ទុក មួយគាថាកន្លះថា

> ក្នុងព្រះរាជវាំងនោះឯង មានកុមារីម្នាក់ ជាស្ត្រីមានសម្បុរនិង
> រូបល្អ ជាស្ត្រីឈ្លាសវាងវៃក្នុងការរាំច្រៀង ទាំងបានសិក្សាល្អ
> ក្នុងការប្រគំ កុមារីនោះ ចូលទៅគាល់ក្នុងទីនោះហើយ ក្រាប
> បង្គំទូល ( ព្រះរាជា ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហុ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ខាងក្នុងព្រះរាជដ្ឋាននោះឯង មានតរុណកុមារីម្នាក់ ក្នុងចំនួនចូឡនាដនារីទាំងឡាយ ។ បទថា **បធក្ខិណា** សេចក្តីថា បានទទួលការហាត់រៀនជំនាញ

ហើយ ។

កុមារិកាពោលកន្ទះគាថាទូលព្រះរាជាថា

បើព្រះរាជឱរសនឹងបានជាព្រះកស្តានៃខ្ញុំម្ចាស់ ខ្ញុំម្ចាស់អាចនឹងប្រលោមព្រះរាជឱរសនោះឲ្យខាងតែបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សចេ ភត្តា** សេចក្តីថា បើព្រះរាជកុមារនោះ នឹងបានជាកស្តារបស់ខ្ញុំ ។

ព្រះរាជា ទ្រង់មានព្រះរាជឱង្ការដូច្នេះ នឹងកុមារីដែលនិយាយដូច្នោះនោះថា ចូរនាងប្រលោមព្រះរាជឱរសនោះចុះ ព្រះរាជឱរសនោះ នឹងជាកស្តារបស់នាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តវ ភត្តា** សេចក្តីថា កូនរបស់អញនេះនឹងជាប្តីរបស់នាង នាងនឹងបានជាអគ្គមហេសីនៃកូនរបស់អញនោះឯង ចូរនាងប្រលោមកូនអញ ឲ្យដឹងនូវកាមរសចុះ ។

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ ទ្រង់បញ្ជូនកុមារិកានោះទៅ ប្រគល់ដល់ក្នាក់ងារ ដែលអភិបាលទំនុកបម្រុងព្រះរាជកុមារដោយព្រះឱង្ការថា នៃក្នាក់ងារអភិបាលទាំងឡាយ ចូរបើកឱកាសដល់កុមារិកានេះចុះ ។ ក្នុងវេលាទៀបភ្លឺ កុមារិកាកាន់ពិណាទៅឈរខាងក្រៅ ក្បែរបន្ទប់ផ្ទំរបស់ព្រះរាជកុមាររួចយកចុងក្រចកផ្ទាត់ពិណា ច្រៀងដោយសំឡេងដ៏ពីរោះ លួងលោមព្រះរាជកុមារនោះ ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថា

ទាំងឡាយថា

កុមារីនោះ ក៏ទៅខាងក្នុងព្រះរាជវាំងហើយ ( ច្រៀង ) នូវចម្រៀងដែលប្រកបដោយកាមច្រើនប្រការ ពោលគាថា ដ៏វិចិត្រ ជាទីស្រឡាញ់ ជ្រួតជ្រាបក្នុងហឫទ័យ ។

ចំណង់ក្នុងកាមកើតឡើង ដល់ព្រះរាជបុត្តនោះ ព្រោះបានស្ដាប់សំឡេងរបស់នារីច្រៀងថ្វាយនោះឯង ព្រះរាជឱរសនោះទ្រង់សាកសួរជនថា យីអើ នុ៎ះជាសំឡេងនរណា ឬថា នរណានោះពោលពាក្យខ្ពស់ទាបច្រើន ដ៏ជ្រួតជ្រាបក្នុងហឫទ័យ ជាទីស្រឡាញ់ ជាសុខត្រចៀករបស់អញ ។

បពិត្រព្រះសម្មតិទេព នុ៎ះឯងជាស្ត្រី ស្ត្រីនុ៎ះចេះល្បែងច្រើនប្រការ បើព្រះអង្គទ្រង់សោយនូវកាមទាំងឡាយណា កាមទាំងឡាយនោះ នឹងញុំាងព្រះអង្គឲ្យរីងរឹតតែគាប់ព្រះទ័យ ។

អើបើដូច្នោះ ចូរកុមារីមកអាយចុះ ចូរច្រៀងក្នុងទីជិតចុះ ចូរច្រៀងក្នុងទីជិតអាស្រម ក្នុងសំណាក់នៃយើងចុះ ។

កុមារីនោះ ច្រៀងក្នុងទីខាងក្រៅជញ្ជាំង ហើយចូលទៅក្នុងព្រះរាជដំណាក់សម្រាប់ចម្រើនឈាន ដើម្បីចងព្រះរាជកុមារនោះតាមលំដាប់ ដូចជាហ្មដំរីចងដំរីក្នុងព្រៃ ។

ធម៌ប្រណែន បានកើត ព្រោះដឹងនូវកាមរសនៃកុមារីនោះ យើងត្រូវតែបរិភោគកាមទាំងឡាយតែម្នាក់ឯងប៉ុណ្ណោះ កុំឲ្យ

មានបុរសដទៃឡើយ ។ តពីនោះទៅ ព្រះរាជកុមារទ្រង់កាន់ដាវ ព្យាយាម ដើម្បីសម្លាប់បុរសទាំងឡាយ ដោយគិតថា អញត្រូវបរិភោគកាម តែម្នាក់ឯងប៉ុណ្ណោះ កុំគប្បីមានបុរសដទៃ ។

ក្នុងកាលនោះ អ្នកជនបទទាំងអស់ មកប្រជុំគ្នា កន្ទក់កន្ទេញថា បពិត្រមហារាជ ព្រះរាជបុត្តរបស់ព្រះអង្គនេះ បៀតបៀននូវជនដែលមិនប្រទូស្ត ។

ព្រះរាជាជាក្សត្រ ទ្រង់បំបរបង់ព្រះរាជបុត្តចេញចាកដែននោះថា ទីដែនរបស់អញមានត្រឹមណា ឯងមិនត្រូវនៅត្រឹមនោះទេ ។

លំដាប់នោះ ព្រះរាជកុមារនោះ ទ្រង់នាំភរិយាចូលទៅជិតសមុទ្ទ ធ្វើនូវបណ្ណសាលា ហើយចូលទៅកាន់ព្រៃដើម្បីស្វែងរកផលាផល ។

លំដាប់នោះ ឥសីមកខាងលើៗសមុទ្ទ ដល់ក្នុងទីនុ៎ះ ឥសីនោះបានឃើញផ្ទះរបស់ព្រះរាជកុមារនោះក្នុងកត្តកាលដល់ហើយ ។

ឯភរិយាក៏ប្រលោមតាបសនោះ ( ម្នាលភិក្ខុ ) អ្នកចូរមើលអំពើអាក្រក់គួរសៀម ( នោះ ) ចុះ តាបសនោះឃ្លាតចាកព្រហ្មចរិយធម៌ហើយ ក៏សាបសូន្យចាកឫទ្ធិ ។

ចំណែកខាងព្រះរាជបុត្ត ដល់វេលាល្ងាច ក៏នាំយកមើម

ឈើនិងផ្លែឈើជាច្រើន មកអំពីទីស្វែងរកផលាផល ដោយអម្រែក ហើយចូលទៅកាន់អាស្រម ។

ឯឥសី បានឃើញស្តេចហើយ ក៏ចូលទៅជិតសមុទ្ទដោយគិតថា អញនឹងទៅកាន់អាកាស តែឥសីនោះលិចចុះក្នុងសមុទ្ទ ។

មហាក្សត្រ បានឃើញឥសីកំពុងលិចក្នុងសមុទ្រ ហើយពោលគាថាទាំងនេះ ដោយសេចក្តីអនុគ្រោះដល់តាបសនោះថា

តាបសមកលើទឹកមិនបែក ដោយឫទ្ធិខ្លួនឯង ហើយលិចក្នុងសមុទ្ទ ព្រោះដល់នូវសេចក្តីច្រឡូកច្រឡំដោយស្ត្រី ។ ធម្មតាពួកស្រី ជាអ្នកនាំឲ្យវិលវល់ណាស់ មានមាយាច្រើន ជាអ្នកញ៉ាំងព្រហ្មចរិយធម៌ឲ្យកម្រើក តែងនាំពន្លិច បុគ្គលដឹងច្បាស់នូវហេតុនោះហើយ គប្បីវៀរអំពីចម្ងាយ ។ ពួកស្រីមានសម្តីឥតទោស មានសម្តីទន់ភ្លន់ ស្មើដោយស្ទឹង ព្រោះគេបំពេញបានដោយកម្រ តែងនាំពន្លិច បុគ្គលអ្នកដឹងច្បាស់នូវហេតុនោះហើយ គប្បីវៀរចេញអំពីចម្ងាយ ។ ស្រីទាំងនុ៎ះ ចូលទៅគប់រកបុរសណា ព្រោះសេចក្តីពេញចិត្តក្តី ព្រោះទ្រព្យក្តី រមែងដុតបំផ្លាញបុរសនោះយ៉ាងឆាប់ដូចភ្លើងព្រៃដុតនូវឋានទីរបស់ខ្លួន ។

សេចក្តីនឿយណាយ ក៏កើតមានឡើងដល់ឥសី ព្រោះ

បានស្តាប់ព្រះរាជបន្ទូលរបស់មហាក្សត្រ ហើយត្រឡប់បាន
នូវផ្លូវចាស់ ( ឈានវិសេស ) ក៏ទៅតាមអាកាសវិញ ។
ព្រះមហាក្សត្រជាអ្នកប្រាជ្ញ លុះបានឃើញឥសីទៅតាមអាកាស
ហើយ ក៏បាននូវសេចក្តីតក់ស្លុត ទ្រង់គាប់ព្រះហឫទ័យស៊ប់
ចំពោះបព្វជ្ជា ។ លំដាប់នោះ ព្រះមហាក្សត្រនោះទ្រង់បព្វជ្ជា
ហើយ ក៏នឿយណាយចាកកាមរាគ លុះនឿយណាយចាក
កាមរាគហើយ បានចូលទៅកើតក្នុងព្រហ្មលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អន្តេបុរំ** បានដល់ ព្រះរាជដ្ឋានដែលជាលំនៅរបស់ព្រះរាជកុមារ ។ បទថា **ពហុំ** សេចក្តីថា ប្លែកៗ គឺច្រើនយ៉ាង ។ បទថា **កាមូបសញ្ហិតំ** សេចក្តីថា ប្រែប្រួលខុសលំនាំ គឺមានចិត្តជ្រួតជ្រាបក្នុងកាមារម្មណ៍ ។ បទថា **កាមច្ឆន្ទស្ស** សេចក្តីថា កាមច្ឆន្ទៈ កើតឡើងដល់អនិត្ថិគន្ធកុមារនោះ ។ បទថា **ជនំ** បានដល់ បរិចារិកជនដែលនៅក្បែរព្រះអង្គ ។ បទថា **ឧច្ចាវចំ** បានដល់ សំឡេងច្រៀងដែលមានសំឡេងខ្ពស់និងទាប ។ បទថា **ភុញ្ជេយ្យ** សេចក្តីថា បើទ្រង់គប្បីបរិភោគកាម-គុណសោត ។ បទថា **ជិន្ទេយ្យុំ តំ** សេចក្តីថា ឈ្មោះថា កាមទាំងឡាយនេះ គប្បីជាទីប្រោសប្រាណ ពេញព្រះហឫទ័យរបស់ទ្រង់ក្រៃលែង ។

ព្រះរាជកុមារទ្រង់ស្តាប់ថា **បមទា** ដូច្នេះហើយ ទ្រង់ក៏នៅស្ងៀម ។ ក្នុងថ្ងៃស្អែកឡើង កុមារិកាក៏នៅតែច្រៀងយ៉ាងនេះ កាលបើដូច្នោះ ព្រះរាជកុមារ ក៏កើតមានចិត្តស្រឡាញ់ កាលប្រាថ្នាឲ្យកុមារិកានោះមកគាល់ ទើប

ត្រាស់ហៅរាជបរិវារទាំងឡាយមក ហើយត្រាស់គាថា មានពាក្យថា **ឥធស្ស** ដូច្នេះ ជាដើម ។ បទថា **តិរោកុឌ្ឌម្ហិ** សេចក្តីថា ខាងក្រៅជញ្ជាំងបន្ទប់សម្រាប់ផ្ទំ ។ បទថា **មា អញ្ញោ** សេចក្តីថា ឈ្មោះថា បុរសដែលបរិភោគកាមដទៃ មិនគួរមានឡើយ ។ បទថា **ហន្ត្វាំ ឧបក្កមិ** សេចក្តីថា ព្រះរាជកុមារចុះទៅឈរកណ្តាលផ្លូវ ហើយប្រារព្ធសម្លាប់ពួកបុរសចោល ។ បទថា **វិក្កន្តេសុ** សេចក្តីថា កាលបុរស ២-៣ នាក់ ត្រូវព្រះរាជកុមារប្រហារហើយ បុគ្គលទាំងឡាយដទៃ ក៏នាំគ្នារត់គេចពួនក្នុងផ្ទះដទៃ ។ ព្រះរាជកុមារមិនជួបបុរសទាំងឡាយ ក៏ស្ងប់ទៅមួយរយៈ ។ ខណៈនោះ អ្នកនគរ ក៏នាំគ្នាមកប្រជុំត្រង់លានព្រះរាជវាំង ក្រាបទូលរឿងនោះដល់ព្រះរាជា ។ បទថា **ជនំ ហេឋេត្យទូសកំ** សេចក្តីថា អ្នកនគរក្រាបទូលពោលទោសថា ព្រះរាជឱរសរបស់ទ្រង់ប្រហារបុគ្គលដែលគ្មានកំហុស សូមទ្រង់ឲ្យចាប់ព្រះរាជឱរសនោះ ។ ព្រះរាជាត្រាស់ឲ្យចាប់ព្រះរាជកុមារដោយឧបាយ ហើយត្រាស់សួរអ្នកនគរថា គួរដាក់ទោសកុមារនេះដូចម្តេច កាលអ្នកនគរទូលថា បពិត្រព្រះអង្គទ្រទ្រង់គុណដ៏ប្រសើរ មិនមានផ្លូវដទៃ តែគួរទ្រង់និរទេសកុមារនេះមួយអន្លើដោយកុមារិកានោះចេញអំពីដែន ទើបទ្រង់ធ្វើតាមនោះ ។

កាលព្រះបរមសាស្តាទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថាជាដើមថា **តតោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វិវាសេសិ** បានដល់ ទ្រង់និទ្ទេសហើយ ។ បទថា **ឧ តេ វត្តោ តាវតេ** សេចក្តីថា អាណាខេត្តរបស់យើងមានត្រឹមណា ឯងកុំនៅក្នុងអាណាខេត្តរបស់យើងត្រឹមនោះជាដាច់

ខាត ។ បទថា **ឧញ្ឆាយ** សេចក្តីថា ដើម្បីសោយផលាផល ។ កាលព្រះរាជកុមារនោះយាងទៅព្រៃ កុមារិកាដែលជាព្រះជាយានៅចាំអាស្រម រៀបចំរបស់ដែលគួរដុត និងគួរស្ងោរ ដែលមានក្នុងអាស្រមនោះ ត្រង់ទ្វារបណ្ណសាលារង់ចាំមើលផ្លូវព្រះភស្តាត្រឡប់មក ពេលវេលាកន្លងទៅ ដោយប្រការយ៉ាងនេះ ។ ថ្ងៃមួយ តាបសអ្នកមានឫទ្ធិមួយរូប នៅអាស្រ័យត្រង់កោះកណ្តាលសមុទ្ទ ចេញអំពីអាស្រមដ្ឋាន ដើរលើទឹកបាន ដូចដើរលើដុំកែវមណី ហើយហោះឡើងទៅលើអាកាស ត្រាច់ទៅភិក្ខាចាររហូតដល់ ខាងលើបណ្ណសាលានោះ ឃើញផ្សែងភ្លើង គិតថា ទីនេះប្រហែលជាមានមនុស្សនៅអាស្រ័យ ទើបបន្ទាបខ្លួនចុះមកត្រង់លានបណ្ណសាលា ។ ឯកុមារិកា ព្រះជាយារបស់ព្រះរាជកុមារ កាលឃើញតាបសហើយ ក៏និមន្តឲ្យអង្គុយ កើតមានចិត្តប្រតិព័ទ្ធ បានសម្តែងមាយានៃស្ត្រីឲ្យឃើញ រហូតបានប្រព្រឹត្ត អនាចារជាមួយតាបសនោះ ។ កាលព្រះសាស្តាទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថាមានពាក្យជាដើមថា **អជេន្ត** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥសិ មាគញ្ឆិ** សេចក្តីថា ឥសីបានហោះមកហើយ ។ បទថា **សមុទ្ទុមុបរូបរិ** សេចក្តីថា ដោយផ្លូវខាងលើសមុទ្ទ ។ បទថា **បស្ស យាវ សុទារុណំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កម្មដ៏ស្មើមដល់ម្ល៉េះដែលកុមារិកានោះធ្វើហើយ ។ បទថា **សាយំ** បានដល់ ក្នុងសាយណ្ហសម័យ ។

បទថា **ឥស្សា** សេចក្តីថា តាបសអ្នកមានឫទ្ធិនោះ កាលមិនអាចលះ

នាងកុមារិកានោះទៅបាន ក៏នៅត្រង់បណ្ណសាលានោះពេញមួយថ្ងៃ ឃើញព្រះរាជកុមារយាងមកក្នុងវេលាល្ងាចគិតថា អញនឹងទៅតាមអាកាស ទើបលោតឡើងទៅក្នុងអាកាស ក៏ធ្លាក់ចូលក្នុងសមុទ្ទ ។ បទថា **ឥសឹ ធិស្វា** សេចក្តីថា ព្រះរាជកុមារនោះ ដេញតាមទៅឃើញឥសីនោះ ។ បទថា **អនុកម្បាយ** សេចក្តីថា ព្រះរាជកុមារកើតចិត្តករុណាថា តាបសនេះ បើមកដោយផែនដី ក៏គួរតែចូលព្រៃ ប្រហែលជាមកតាមអាកាស ព្រោះហេតុនោះ ទោះបីធ្លាក់ក្នុងសមុទ្ទក៏នៅធ្វើអាកប្បកិរិយាដូចជាហោះទៅ ហើយបានត្រាស់ ព្រះគាថាដោយសេចក្តីករុណាចំពោះតាបសនោះឯង អត្ថនៃគាថានោះ ខ្ញុំបានពោលទុកហើយក្នុងតិកនិបាតនោះឯង ។ បទថា **ឆិត្វានោ អហុ** សេចក្តីថា ការនឿយណាយក្នុងកាមទាំងឡាយកើតហើយ ។ បទថា **ចោរាណកំ មគ្គំ** បានដល់ ឈានវិសេសដែលខ្លួនសម្រេចហើយក្នុងកាលមុន ។ បទថា **បព្វជិត្វាន** សេចក្តីថា ព្រះរាជកុមារទ្រង់នាំកុមារីទៅកាន់ទឹកដីមនុស្ស ហើយយាងត្រឡប់មកបព្វជ្ជាជាឥសី នៅក្នុងដងព្រៃ ទ្រង់ខ្ជាក់កាមរាគៈបាន កាលប្រាសចាកកាមរាគៈហើយ ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ដោយប្រការដូច្នេះ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីសត្វបរិសុទ្ធល្អហើយ រមែងសៅហ្មងព្រោះអាស្រ័យមាតុគ្រាមជាហេតុយ៉ាងនេះ ហើយទ្រង់ប្រកាសអរិយសច្ចធម៌ ក្នុងកាលចប់អរិយសច្ចទេសសនា ភិក្ខុអផ្សុកក៏បានសម្រេចអរហត្តផល ហើយទ្រង់ប្រជុំជាតកថា អនិត្ថិគន្ធកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មហាបលោភនជាតក ចប់

# បញ្ចបណ្ឌិតជាតក

[ ៣៥៧ ] ( ព្រះបាទវិទេហៈត្រាស់ថា ) អ្នកប្រាជ្ញទាំង ៥ នាក់ មកជួបជុំគ្នាហើយ ប្រស្នាក្តីច្បាស់ដល់យើង អ្នកទាំងឡាយ ចូរស្តាប់ប្រស្នានោះ អ្នកផងគួរសំដែង ( ប្រាប់ ) នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់នរណា ។

[ ៣៥៨ ] ( អាចារ្យសេនកៈទូលថា ) បពិត្រព្រះភូមិបាល សូមព្រះអង្គធ្វើឲ្យជាក់ច្បាស់ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ព្រះអង្គជាអ្នកចិញ្ចឹម ជាអ្នកអត់ធន់នូវរាជកិច្ចដ៏ធ្ងន់ សូមព្រះអង្គទ្រង់ពោលប្រស្នានុ៎ះមុន បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំង ៥ នាក់ ពិចារណានូវរបស់ជាទីស្រឡាញ់ និងជាទីគាប់ព្រះទ័យរបស់ព្រះអង្គ ហើយនឹងក្រាបទូលក្នុងកាលជាខាងក្រោយ ។

[ ៣៥៩ ] ( ព្រះរាជា... ) ភរិយាណា មានសីលពិត ដែលបុរសដទៃលួច ( សម្ផស្ស ) មិនបាន ជាស្រីប្រព្រឹត្តតាម អំណាចនៃសេចក្តីប្រាថ្នារបស់ភស្តា ជាទីស្រឡាញ់ ជាទីពេញចិត្តនៃភស្តា បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទាឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់ភរិយា ( នោះ ) ឬ ។

[ ៣៦០ ] ( អាចារ្យសេនកៈ... ) សម្លាញ់ណាជាទីរឭក ជាគតិ ជាទីពឹងរបស់អ្នកដែលដល់នូវសេចក្តីលំបាក អ្នកដែលក្តៅក្រហាយ បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់សម្លាញ់ ( នោះ ) ។

[ ៣៦១ ] ( អាចារ្យបុក្កុសៈ... ) បងប្អូនណា ទោះបីជាបងបង្អស់ក្តី កណ្តាលក្តី ជាប្អូនពៅក្តី បើបងប្អូននោះតម្កល់នៅស៊ប់ក្នុងសីល មានចិត្តនឹង

នួន បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់បងប្អូន ( នោះ ) ។

[ ៣៦២ ] ( អាចារ្យកាមិន្ទ... ) កូនប្រុស អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហឫទ័យរបស់បិតា ជាអ្នកធ្វើតាមពាក្យ ជាអនុជាតបុត្ត មានប្រាជ្ញាមិនឱនថយជាងបិតា បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរដែលជាអាថ៌កំបាំងដល់កូនប្រុស ( នោះ ) ។

[ ៣៦៣ ] ( អាចារ្យទេវិន្ទ... ) បពិត្រព្រះអង្គជាធំជាងជន ដ៏ប្រសើរជាងមនុស្ស មាតាណាចិញ្ចឹមកូននោះ ដោយសេចក្តីស្រឡាញ់ពេញចិត្តបុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់មាតា ( នោះ ) ។

[ ៣៦៤ ] ( មហោសធបណ្ឌិត... ) សេចក្តីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំង គេមិនសរសើរទេ អ្នកប្រាជ្ញកាលបើសេចក្តីប្រាថ្នាមិនទាន់សម្រេចនៅឡើយ ត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយតាមសប្បាយចុះ ។

[ ៣៦៥ ] ( នាងឧទុម្ពរាទេវី... ) បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គទ្រង់មានព្រះទ័យប្រែប្រួលឬ បពិត្រព្រះអង្គជាធំជាងមនុស្ស ខ្ញុំម្ចាស់ស្តាប់ព្រះតម្រាស់របស់ព្រះអង្គនោះហើយ តើព្រះអង្គទ្រង់ព្រះចិន្តាដូចម្តេច បានជាទ្រង់តូចព្រះទ័យ បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មិនមានកំហុសទេឬ ។

[ ៣៦៦ ] ( ព្រះរាជា... ) មហោសធ ត្រូវគេសម្លាប់ព្រោះតែប្រស្នា

មហោសធជាអ្នកមានប្រាជ្ញាដូចផែនដី ខ្ញុំបង្គាប់គេឲ្យសម្លាប់ហើយ ខ្ញុំគិតរឿងនោះ បានជាតូចចិត្ត ម្នាលនាងទេវី កំហុសរបស់នាងមិនមានទេឬ ។

[ ៣៦៧ ] ( ព្រះរាជា... ) អ្នកឯងទើបតែទៅផ្ទះ ក្នុងពេលព្រលប់សោះ ឥឡូវនេះ ស្រាប់តែមកវិញភ្លាម អ្នកឯងឮដំណឹងដូចម្តេច ចិត្តរបស់អ្នកឯង រន្ធៀសដូចម្តេច ម្នាលអ្នកមានប្រាជ្ញាដូចផែនដី នរណាបានប្រាប់ដំណឹងដូចម្តេច ដល់អ្នក យើងចង់ស្តាប់ពាក្យនោះ អ្នកចូរប្រាប់ពាក្យនោះ ដល់យើង ។

[ ៣៦៨ ] ( មហោសធ... ) បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គស្តេចទៅក្នុងទីស្ងាត់ បានប្រាប់នូវអាថ៌កំបាំងដែលព្រះ អង្គប្រឹក្សាហើយ ក្នុងពេលព្រលប់ដល់ព្រះអគ្គមហេសីថា មហោសធត្រូវគេសម្លាប់ ព្រោះតែប្រស្នា ក្នុងកាលណា សេចក្តីកំបាំង ឈ្មោះថាព្រះអង្គធ្វើឲ្យប្រាកដហើយ ក្នុងកាលនោះ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

[ ៣៦៩ ] អាចារ្យសេនកៈបានធ្វើអំពើអាក្រក់ ជាអំពើមានសភាពមិនល្អក្នុងឱទ្យាន ដ៏ដេរដាសដោយដើមសាលព្រឹក្ស បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់សម្លាញ់ សេចក្តីកំបាំងណាដែលអាចារ្យសេនកៈធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

[ ៣៧០ ] បពិត្រព្រះអង្គជាធំជាងជន រោគ ( ឃ្លង់ ) កើតឡើងដល់បុក្កុសបុរសរបស់ព្រះអង្គ រោគនោះមិនសមគួរដល់ព្រះរាជាទេ គាត់បានទៅក្នុងទីស្ងាត់ហើយប្រាប់ដល់បងប្អូនប្រុស សេចក្តីកំបាំងណា ដែលអាចារ្យ

បុក្កុសៈធ្វើឲ្យប្រាកដហើយ សេចក្ដីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

[ ៣៧១ ] អាចារ្យកាមិន្ទនេះ មានអាពាធដ៏អាក្រក់ គឺត្រូវនរទេវ-យក្ខចូល បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់កូនប្រុស សេចក្ដីកំបាំងណាដែលអាចារ្យកាមិន្ទធ្វើឲ្យប្រាកដហើយ សេចក្ដីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

[ ៣៧២ ] ព្រះឥន្ទ្របានថ្វាយមណិរតន៍មានជ្រុង ៨ ដ៏ថ្លៃថ្លា ( ដល់ព្រះបាទកុសរាជ ) ជាព្រះអយ្យកោរបស់ព្រះអង្គ ថ្ងៃនេះ មណិរតន៍នោះទៅនៅក្នុងកណ្ដាប់ដៃនៃអាចារ្យទេវិន្ទហើយ អាចារ្យទេវិន្ទទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់មាតា សេចក្ដីកំបាំងណាដែលអាចារ្យទេវិន្ទធ្វើឲ្យប្រាកដហើយសេចក្ដីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

[ ៣៧៣ ] សេចក្ដីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំងគេមិនសរសើរទេ អ្នកប្រាជ្ញកាលបើសេចក្ដីប្រាថ្នាមិនទាន់សម្រេចត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយតាមសប្បាយចុះ ។

បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំង គប្បីរក្សានូវអាថ៌កំបាំងនោះ ដូចជារក្សានូវកំណប់ ដ្បិតថា អាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់មិនធ្វើឲ្យប្រាកដជាការប្រពៃ ។ អ្នកប្រាជ្ញមិនគប្បីនិយាយប្រាប់នូវអាថ៌កំបាំងដល់ស្រី ដល់ជនជាសត្រូវ ដល់ជនឡើបឡប់ដោយអាមិសដល់ជនលួចគំនិតគ្នា ជនណាតែងញុំាងអាថ៌កំបាំង ដែលមិនទាន់មានគេដឹង ឲ្យគេដឹង អ្នកប្រាជ្ញតែងអត់

សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចជាមនុស្សខ្ញុំគេ ។ ជនទាំងឡាយប៉ុន្មាននាក់ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្តីតក់ស្លុតប៉ុណ្ណោះ តែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីផ្សាយនូវអាថ៌កំបាំង ។

ក្នុងវេលាថ្ងៃ អ្នកប្រាជ្ញគប្បីនិយាយអាថ៌កំបាំង ក្នុងទីស្ងាត់ មិនគប្បីបញ្ចេញសំឡេងក្នុងវេលាយប់ឲ្យហួសកម្រិត ព្រោះថា ពួកអ្នកឈ្លបស្តាប់រមែងឮនូវអាថ៌កំបាំងដែលប្រឹក្សាគ្នា ព្រោះហេតុនោះ គំនិតនឹងដល់នូវការបែកធ្លាយយ៉ាងឆាប់ ។

## ចប់ បញ្ចបណ្ឌិតជាតក ទី ១២ ។

# អដ្ឋកថា

# បញ្ចបណ្ឌិតជាតក

[ ៣៥៧-៣៧៣ ] បញ្ចបណ្ឌិតជាតកនឹងមានពិស្តារក្នុងមហាឧម្មង្គជាតក ( មហានិបាត ) នោះឯង ។

អដ្ឋកថា បញ្ចបណ្ឌិតជាតក ចប់

# ហត្ថិបាលជាតក

[ ៣៧៤ ] ( ហត្ថិបាលកុមារពោលថា ) យូរណាស់ហើយយើងទើបនឹងឃើញព្រាហ្មណ៍មានភេទដូចទេវតា មានផ្នួងសក់ធំ មានធូលីលើព្រះសិរ ។ យូរណាស់ហើយ យើងទើបនឹងឃើញឥសីអ្នកត្រេកអរក្នុងធម្មគុណ ស្លៀកដណ្តប់សំពត់កាសាយៈ មានសំបកឈើ ជាគ្រឿងបិទបាំង ។ សូមលោកដ៏ចម្រើន ទទួលនូវអាសនៈ ទឹក និងប្រេងសម្រាប់លាបជើង របស់យើងខ្ញុំចុះ យើងខ្ញុំសូមសួរនូវរបស់មានតម្លៃ ចំពោះលោកដ៏ចម្រើន សូមលោកដ៏ចម្រើនប្រាប់នូវរបស់មានតម្លៃដល់យើងខ្ញុំ ។

[ ៣៧៥ ] ( បុរោហិតជាឥសី... ) ហៃបា អ្នកចូររៀននូវវេទទាំងឡាយហើយស្វែងរកទ្រព្យតម្កល់ទុកនូវកូនទាំងឡាយក្នុងផ្ទះ សោយនូវក្លិននិងរសទាំងឡាយផង នូវវត្ថុកាមគ្រប់បែបផង ព្រៃប្រពៃដល់អ្នកបួសឯចាស់ បុគ្គលនោះជាអ្នកប្រាជ្ញដែលព្រះអរិយៈទាំងឡាយសរសើរហើយ ។

[ ៣៧៦ ] ( ហត្ថិបាលកុមារ... ) វេទទាំងឡាយជាសភាវៈមិនទៀង ការបាននូវទ្រព្យក៏មិនទៀងដែរ ជនទាំងឡាយឃាត់ជរាដោយការបាននូវកូនមិនបានទេ សប្បុរសទាំងឡាយ សរសើរនូវការរួចចាកក្លិននិងរស កិរិយាសម្រេចផលរមែងមានតាមកម្មរបស់ខ្លួន ។

[ ៣៧៧ ] ( ព្រះបាទឯសុការីជាឥសី... ) ពាក្យរបស់អ្នកនុ៎ះ ជាពាក្យពិត ដ្បិតថា កិរិយាសម្រេចផលរមែងមានតាមកម្មរបស់ខ្លួន ប៉ុន្តែមាតានិងបិតារបស់អ្នកនេះ ចាស់ហើយ លោកតែងចង់ឃើញនូវអ្នក ជាបុគ្គលមិនមានរោគ អស់រយៈឆ្នាំ ។

[ ៣៧៨ ] ( ហត្ថិបាលកុមារ... ) បពិត្រព្រះរាជា អ្នកទ្រទ្រង់នូវសេចក្ដីព្យាយាមវិសេសជាងជន ភាពជាសម្លាញ់ដោយមរណៈ សេចក្ដីមេត្រីដោយជរា គប្បីមានដល់ជនណា ម្យ៉ាងទៀត ជនណាគប្បីដឹងថាអញនឹងមិនស្លាប់ក្នុងកាលណាមួយទេ មាតាបិតាគួរឃើញនូវជននោះ ជាបុគ្គលមិនមានរោគអស់រយនៃឆ្នាំ ។ បុរសចែវទូកក្នុងទឹក នាំទូកទុំះទៅកាន់ត្រើយ ( ខាងនាយ ) យ៉ាងណា សេចក្ដីឈឺចាប់ និងសេចក្ដីគ្រាំគ្រា រមែងនាំសត្វចូលទៅកាន់អំណាចនៃសេចក្ដីស្លាប់ អ្នកធ្វើនូវទីបំផុតជារឿយៗ យ៉ាងនោះដែរ ។

[ ៣៧៩ ] ( អស្សបាលកុមារ... ) កាមទាំងឡាយជាភក់ផង កាមទាំងឡាយជាល្បាប់ផង ជាគ្រឿងនាំមកនូវសេចក្ដីពេញចិត្ត ជាគ្រឿងឆ្លងបានដោយកម្រ ជាលំនៅនៃមច្ចុ ពួកសត្វដែលលិចចុះក្នុងភក់ក្នុងល្បាប់នេះ ជាសត្វមានចិត្តថោកទាប ជាសភាវៈឆ្លងទៅកាន់ត្រើយ ( ព្រះនិព្វាន ) ពុំបានឡើយ ។ អត្តភាពរបស់ទូលព្រះបង្គំជាខ្ញុំនេះ បានធ្វើនូវអំពើអាក្រក់ក្នុងកាលមុន ផលនៃកម្មនោះ ទូលព្រះបង្គំជាខ្ញុំបានកាន់យកហើយ ការរួចចាកផលអកុសលនោះ មិនមានដល់ទូលព្រះបង្គំជាខ្ញុំឡើយ ។ ទូលព្រះបង្គំនឹងបិទរក្សានូវអត្តភាពនោះ កុំឲ្យអត្តភាពនេះ ធ្វើអំពើអាក្រក់ទៀតឡើយ ។

[ ៣៨០ ] ( គោបាលកុមារ... ) បពិត្រព្រះរាជា ដូចបុរស កាលមិនឃើញគោស្វែងរកគោដែលបាត់ក្នុងព្រៃ យ៉ាងណា បពិត្រព្រះរាជា ទ្រង់ព្រះនាមឯសុការី ប្រយោជន៍ ( បព្វជ្ជា ) របស់ទូលព្រះបង្គំជាខ្ញុំវិនាសបាត់

ទៅក៏យ៉ាងនោះដែរ បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំមិនគប្បីស្វែងរកដូចម្ដេចបាន ។

[ ៣៨១ ] បុរសបន្ទន់ ( នូវការងារដែលត្រូវធ្វើ ) ថា ចាំថ្ងៃស្អែកៗ ដូច្នេះ រមែងសាបសូន្យ អ្នកប្រាជ្ញដឹងថា អនាគតនេះមិនមានដូច្នេះហើយ អ្នកប្រាជ្ញណា នឹងបន្ទោបង់នូវសេចក្ដីប៉ុនប៉ងដែលកើតឡើងហើយបាន ។

[ ៣៨២ ] ( អជបាលកុមារ... ) ទូលព្រះបង្គំជាខ្ញុំ បានឃើញកុមារីនៅក្មេង ( ឡេះឡោះ ) ដូចជាមនុស្សឆ្កួត មានក្អែកដូចត្របកនៃផ្កាកាកែសបិតនៅក្នុងបឋមវ័យ មិនទាន់បរិភោគនូវភោគៈទាំងឡាយ ស្រាប់តែមច្ចុនាំយកកុមារី ( នោះទៅ ) ។ ប្រុសកំលោះមានកំណើតល្អ មានមុខស្រស់បស់ គួរជាទីរមិលមើល មានសម្បុរលឿងដូចមាស មានពុកមាត់ជេរជាសដូចកេសរនៃផ្កាជកគាំ ( មច្ចុបាននាំយកនូវប្រុសកំលោះនោះទៅ ) ខ្ញុំព្រះអង្គនឹងលះបង់នូវកាមទាំងឡាយ ហើយគេចចេញចាកផ្ទះ ( ទៅបួស ) បពិត្រព្រះសម្មតិទេព សូមព្រះអង្គអនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំនឹងបួស ។

[ ៣៨៣ ] ( បុរោហិត... ) អនុបាទិន្នកសង្ខារ បានឈ្មោះថាដើមឈើ ព្រោះតែមែកទាំងឡាយ មួយទៀត ជនទាំងឡាយហៅនូវដើមឈើដែលមានមែកលះបង់អស់ហើយថាជន្ទត់ ម្នាលនាងវាសេដ្ឋីដ៏ចម្រើន ថ្ងៃនេះជាកាលគួរដើម្បីត្រាច់ទៅស្វែងរកភិក្ខារបស់ខ្ញុំ ដែលមានកូនលះបង់ហើយ ។

[ ៣៨៤ ] ( ព្រាហ្មណីបន្លឺឧទានថា ) ពួកក្រៀល ហើរទៅឰដ៏អា-

កាស ក្នុងរដូវអស់ទឹកភ្លៀង ហង្សទាំងឡាយទម្លាយនូវមងដែលពីងពាងធ្វើហើយ យ៉ាងណា កូនទាំងឡាយផង ប្តីផងរបស់អញ ( ទម្លាយមងគឺកាមហើយ ) ក៏ទៅយ៉ាងនោះដែរ អញនោះ កាលបើដឹងច្បាស់ហើយ មិនទៅតាមដូចម្តេចកើត ។

[ ៣៨៥ ] ( ព្រះរាជទេវី... ) បក្សី ( ត្មាត ) ទាំងឡាយនេះបរិភោគ ( នូវសាច់ ) ហើយក្អួតចេញ ទើបហើរចៀសចេញទៅរួច ចំណែកខាងត្មាតទាំងឡាយណា បរិភោគហើយមិនក្អួតចេញទេ ត្មាតទាំងនោះមកលុះក្នុងកណ្តាប់ដៃរបស់ខ្ញុំម្ចាស់ហើយ ។ ព្រាហ្មណ៍បានខ្ជាក់ចោលនូវកាមទាំងឡាយចេញហើយ ព្រះអង្គនោះត្រឡប់ជាលេបវិញ បពិត្រព្រះរាជា បុរសណាស៊ីនូវកញ្ជាក់ បុរសនោះមិនគួរគេសរសើរទេ ។

[ ៣៨៦ ] ( ព្រះរាជា... ) បុរសអ្នកមានកម្លាំងអាចស្រង់នូវបុរសមានកម្លាំងខ្សោយ ដែលលិចក្នុងភក់ល្បាប់បាន យ៉ាងណា ម្នាលរាជធីតារបស់ព្រះបាទបញ្ចាលដ៏ចម្រើន នាងឯងក៏ញុំាងយើងឲ្យឆ្លងឡើង ( ចាកកាម ) ដោយគាថាទាំងឡាយជាសុភាសិតយ៉ាងនោះដែរ ។

[ ៣៨៧ ] មហារាជទ្រង់ព្រះនាមឯសុការី ជាម្ចាស់ក្នុងទិស ទ្រង់ត្រាស់គាថានេះហើយ ទ្រង់លះបង់នូវដែនចេញទៅ ទ្រង់ព្រះផ្នួស ដូចជាដំរីដ៏ប្រសើរ ផ្តាច់នូវចំណងដូច្នោះ ។

[ ៣៨៨ ] ( មហាជន... ) ព្រះរាជាមានព្យាយាមវិសេសជាងជនទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជាលះបង់នូវដែន ចំណែកខាងព្រះនាង សូម

ដូចជាព្រះរាជារបស់យើងចុះ ព្រះនាងដែលពួកយើងគ្រប់គ្រងហើយ ចូរសោយរាជសម្បត្តិចុះ ។

[ ៣៨៩ ] ( ព្រះរាជទេពី... ) ព្រះរាជាមានព្យាយាមវិសេសជាងជនទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជា ទ្រង់លះបង់នូវដែន ចំណែកខាងខ្ញុំនឹងលះបង់នូវកាមទាំងឡាយ ដែលញុំាងចិត្តឲ្យត្រេកអរចេញហើយ ជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ ព្រះរាជាមានព្យាយាមវិសេសជាងជន ទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជា ទ្រង់លះបង់នូវដែន ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ តាមចំណែកហើយ ជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយ តែងកន្លងហួសទៅ រាត្រីទាំងឡាយតែងញុំាង ( អាយុសង្ខារ ) ឲ្យធ្លងទៅ គំនរនៃវ័យទាំងឡាយ រមែងរលត់ទៅតាមលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ ជាទីញុំាងចិត្តឲ្យត្រេកអរហើយ ជាស្ត្រីម្នាក់ឯងត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយរមែងញុំាង ( អាយុសង្ខារ ) ឲ្យធ្លងទៅ គំនរនៃវ័យទាំងឡាយរមែងលះបង់ទៅជាលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយតាមចំណែកហើយ ជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយរមែងញុំាង ( អាយុសង្ខារ ) ឲ្យធ្លងទៅ គំនរនៃវ័យទាំងឡាយរមែងលះបង់ទៅជាលំដាប់ ចំណែកខាងខ្ញុំ នឹងកន្លងបង់នូវគ្រឿងជាប់ទាំងអស់ ហើយជាស្ត្រីត្រជាក់ ម្នាក់ឯងត្រាច់ទៅក្នុងលោក ។

**ចប់ ហត្ថិបាលជាតក ទី ១៣ ។**

## អដ្ឋកថា

## ហត្ថិបាលជាតក

[ ៣៧៤-៣៨៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការចេញមហាភិនេស្រ្កមណ៍ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ចិរស្សំ វត បស្សាម** ដូច្នេះជាដើម ។

ពិតហើយ ក្នុងកាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏បានចេញមហាភិនេស្រ្កមណ៍មកហើយដូចគ្នា ហើយទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាល មានព្រះរាជាព្រះនាមថាឯសុការី បានសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រាហ្មណ៍បុរោហិតម្នាក់ ជាបិយសម្លាញ់របស់ព្រះរាជាតាំងពីនៅកុមារមកម៉្លេះ ។ ជនទាំង ២ នោះ មិនមានឱរសនិងបុត្តដែលបន្តវង្សត្រកូល ។ ថ្ងៃមួយ ក្នុងពេលដែលមានសេចក្តីសុខ ទើបព្រះរាជានិងព្រាហ្មណ៍បុរោហិត ប្រឹក្សាគ្នាថា ឥស្សរិយយសរបស់យើងទាំង ២ មានច្រើន ឱរសឬធីតាមិនមានឡើយ យើងទាំង ២ គួរធ្វើដូចម្តេច ។ លំដាប់នោះ ព្រះបាទឯសុការីត្រាស់នឹងបុរោហិតថា សម្លាញ់បើក្នុងផ្ទះរបស់ឯងមានកូនប្រុសកើតឡើងសោត កូនរបស់ឯង នឹងជាម្ចាស់រាជសម្បត្តិរបស់យើង បើយើងមានបុត្ត បុត្តរបស់យើងនឹងជាម្ចាស់លើភោគសម្បត្តិក្នុងផ្ទះរបស់ឯងផងដែរ ជនទាំង ២ បានធ្វើកតិកាដល់គ្នានឹងគ្នាដោយអាការៈយ៉ាងនេះ ។ ថ្ងៃមួយ ព្រាហ្មណ៍បុរោហិតទៅកាន់ស្រុកសួយរបស់ខ្លួន ក្នុងពេលត្រឡប់

ក៏ចូលទៅកាន់នគរតាមទ្វារទិសទក្សិណ ជួបស្រីទុគ៌តម្នាក់ ឈ្មោះពហុបុត្តកៈ ខាងក្រៅព្រះនគរ នាងមានកូន ៧ នាក់ មិនមានរោគភ័យជំងឺតម្កាត់ កូនប្រុសម្នាក់កាន់អំបែងដែលជាភាជនៈសម្រាប់ដាំបាយ ម្នាក់ទៀតកាន់កន្ទេលដេក ម្នាក់ទៀតដើរខាងមុខ ម្នាក់ទៀតដើរខាងក្រោយ ម្នាក់ទៀតដើរតោងដៃម្តាយទៅ ម្នាក់ទៀតកណ្តៀតត្រង់ចង្កេះ ម្នាក់ទៀតនៅលើស្មា ។ លំដាប់នោះ បុរោហិតសួរស្រីជាម្តាយថា នែនាង ឪពុករបស់ក្មេងទាំងនេះនៅឯណា ស្រីទុគ៌តឆ្លើយថា ឪពុករបស់ក្មេងទាំងនេះ មិនមាននៅប្រចាំឡើយ បុរោ-ហិតក៏សួរបន្តថា ចុះហេតុអ្វី ទើបនាងបានកូនប្រុសរហូតដល់ ៧ នាក់ដូច្នេះ នាងមិនឃើញវត្ថុដទៃជាគ្រឿងអះអាង ឃើញដើមជ្រៃមួយដុះក្បែរនគរក៏ឆ្លើយទៅថា នែលោក ខ្ញុំបួងសួងប្រាថ្នាក្នុងសម្នាក់នៃទេវតាដែលស្ថិតនៅត្រង់ដើមជ្រៃ ទើបបានកូនដល់ទៅ ៧ នាក់ ទេវតាដែលអាស្រ័យនៅទីនេះឲ្យកូនទាំងឡាយដល់ខ្ញុំ ។

បុរោហិតពោលថា បើដូច្នោះ ចូរនាងទៅចុះ ហើយចុះអំពីរថតម្រង់ទៅកាន់ដើមជ្រៃ ចាប់មែកជ្រៃអង្រួនបណ្តើរ សម្តុរក្ខទេវតាបណ្តើរថា ទេវតាដ៏ចម្រើន លោកមិនព្រមឲ្យឱរសដល់ព្រះរាជាសោះ អ្វីខ្លះដែលលោកមិនបានអំពីសម្នាក់ព្រះរាជា រាល់ៗឆ្នាំ ព្រះរាជាទ្រង់លះព្រះរាជទ្រព្យដល់ទៅ ១០០០ កហាបណៈ ត្រាស់ឲ្យធ្វើពលីកម្មដល់លោក លោកនៅតែមិនឲ្យឱរសដល់ទ្រង់ ស្រីទុគ៌តនេះធ្វើឧបការគុណអ្វីដល់លោក ហេតុអ្វី ទើបឲ្យកូនដល់នាងរហូត ៧ នាក់ បើលោកមិនឲ្យឱរសដល់ព្រះរាជារបស់យើង ៧ ថ្ងៃទៀត

រាប់ពីថ្ងៃនេះទៅ យើងនឹងឲ្យមនុស្សកាប់ដើមជ្រៃ គាស់ទាំងឫស ចិញ្ច្រាំជាកំណាត់ៗ ដូច្នេះហើយ ក៏ចៀសចេញទៅ ។ រៀងរាល់ព្រឹក បុរោហិតក្រោកទៅកាន់ដើមជ្រៃនោះ ហើយសម្លុតដោយទំនងនេះអស់រារៈ ៦ ថ្ងៃ ។ ក្នុងថ្ងៃទី ៦ ចាប់មែកជ្រៃពោលថា នែរុក្ខទេវតាសល់ត្រឹមតែ ១ យប់ប៉ុណ្ណោះ បើលោកមិនឲ្យឱរសដ៏ប្រសើរដល់ព្រះរាជាយើងសោត ស្អែកនេះ យើងនឹងសម្រេចទោសលោក រុក្ខទេវតា ពិចារណាមើលហេតុផលនោះពិតប្រាកដ ហើយគិតថា បើព្រាហ្មណ៍នេះមិនបានបុត្ត គង់បំផ្លាញវិមានរបស់អញវិនាសអស់ អញគួរឲ្យកូនដល់ព្រាហ្មណ៍បុរោហិតនេះ ដោយឧបាយដូចម្ដេចហ្ន៎ ដូច្នេះហើយ ទើបទៅកាន់សម្នាក់របស់ស្ដេចចតុមហារាជ ប្រាប់សេចក្ដីនោះឲ្យទ្រង់ជ្រាប ស្ដេចចតុមហារាជបដិសេធថា ពួកយើង គ្មានសមត្ថភាពឲ្យកូនដល់បុរោហិតនោះបានទេ ទើបរុក្ខទេវតាទៅកាន់ សម្នាក់របស់សេនាបតីយក្ខទាំង ២៨ រូប ប្រាប់រឿងនោះឲ្យជ្រាប ។ សេនាបតីយក្ខទាំងនោះក៏ពោលយ៉ាងនោះដូចគ្នា ទើបរុក្ខទេវតាទៅកាន់សម្នាក់សក្កទេវរាជ ទូលឲ្យទ្រង់ជ្រាប ឯសក្កទេវរាជទ្រង់ពិចារណាថា ព្រះរាជានឹងបានព្រះរាជឱរសសមគួរឬទេហ្ន៎ ទតឃើញទេវបុត្ត ៤ អង្គ ជាអ្នកមានបុណ្យ គួរកើតក្នុងរាជត្រកូល ។

បានឮថា ក្នុងភពមុន ទេវបុត្តទាំង ៤ កើតជាជាងតម្បាញ ក្នុងនគរពារាណសី ចែកទ្រព្យដែលរកបានអំពីការងារនោះជា ៥ ចំណែក បរិភោគ ៤ ចំណែក កាន់យកចំណែកទី ៥ ធ្វើបុណ្យឲ្យទាន ជាងតម្បាញទាំង ៤

នាក់នោះ ឃ្លាតចាកភពនោះហើយ កើតក្នុងតាវត្តិង្សភព បន្ទាប់អំពីនោះ ក៏ចុតិទៅកើតក្នុងយាមាភព កាលសោយទិព្វសម្បត្តិក្នុងទេវលោក ៦ ជាន់ វិលទៅមកដោយប្រការដូច្នេះ គ្រានោះ ដល់វារៈដែលទេវបុត្តទាំងនោះចុតិអំពីតាវត្តិង្ស ទៅកាន់យាមា សក្កទេវរាជក៏យាងទៅកាន់សម្នាក់របស់ទេវបុត្តទាំងនោះ ហៅមកហើយ មានទេវបញ្ជាថា នែអ្នកនិទ៌ុក្ខទាំងឡាយ ពួកអ្នកគួរទៅកើតក្នុងមនុស្សលោក ពួកអ្នកចូរទៅកើតក្នុងផ្ទៃអគ្គមហេសី របស់ព្រះបាទឯសុការីរាជចុះ ។ ទេវបុត្តទាំងនោះ បានស្តាប់ព្រះតម្រាស់នៃសក្កទេវរាជហើយ នាំគ្នាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំនឹងទៅតាមព្រះទេវរាជ្ញារ តែពួកខ្ញុំមិនត្រូវការរាជត្រកូល នឹងនាំគ្នាទៅកើតក្នុងផ្ទះរបស់បុរោហិត ហើយនឹងលះកាមសម្បត្តិចេញបួស ក្នុងកាលដែលនៅជាកំលោះនោះឯង ។ សក្កទេវរាជ ទ្រង់ទទួលប្តេជ្ញារបស់ទេវបុត្តទាំងនោះថា សាធុ ទើបយាងមកប្រាប់សេចក្តីនោះដល់រុក្ខទេវតា រុក្ខទេវតាត្រេកអរ ថ្វាយបង្គំសក្កទេវរាជហើយទៅកាន់វិមាននៃខ្លួនមួយរំពេច ។

ស្អែកឡើង បុរោហិតមានបញ្ជាឲ្យបុរសដែលមានខ្លួនខ្លាំង មានកម្លាំងមកប្រជុំ ហើយឲ្យកាន់កាំបិតនិងពូថៅជាដើម ទៅកាន់គល់ឈើនោះ ចាប់មែកជ្រៃហើយពោលថា នែទេវតា យើងព្យាយាមសូមកូនជាមួយអ្នក គ្រប់ ៧ ថ្ងៃទាំងថ្ងៃនេះ ឥឡូវនេះ ជាពេលដែលសម្រេចទោសលោកហើយ ។ គ្រានោះ ទើបរុក្ខទេវតាចេញអំពីដើមជ្រៃ ដោយអានុភាពធំ អញ្ជើញបុរោហិតមកដោយសំឡេងដ៏ពីរោះ ហើយពោលថា នែព្រាហ្មណ៍ ចាំបាច់និយាយថ្វី

កូនមួយ យើងនឹងឲ្យកូនដល់លោក ៤ នាក់ ព្រាហ្មណ៍បុរោហិតឆ្លើយថា ខ្ញុំមិនត្រូវការកូន សូមលោកឲ្យដល់ព្រះរាជាខ្ញុំចុះ ។ រុក្ខទេវតាពោលថា យើងឲ្យដល់លោកប៉ុណ្ណោះ ព្រាហ្មណ៍បុរោហិតសំណូមពរថា បើដូច្នោះ សូមឲ្យខ្ញុំ ២ នាក់ ឲ្យព្រះរាជា ២ នាក់ចុះ រុក្ខទេវតាឆ្លើយថា យើងមិនឲ្យព្រះរាជា ឲ្យលោកតែម្នាក់ប៉ុណ្ណោះទាំង ៤ នាក់ តែកូន ៤ នាក់នោះ លោកគ្រាន់តែបានប៉ុណ្ណោះ ព្រោះក្មេងទាំងនោះ មិននៅគ្រប់គ្រងផ្ទះ នឹងនាំគ្នាបួសតាំងពីនៅកំលោះនោះឯង ។ ព្រាហ្មណ៍បុរោហិតអង្វរថា សូមឲ្យកូនដល់ព្រះរាជាទាំង ៤ នាក់ចុះ ឯហេតុដែលមិនឲ្យក្មេងទាំង ៤ ចេញបួស ជាភារៈរបស់ខ្ញុំ ។ រុក្ខទេវតាប្រទានបុត្តដ៏ប្រសើរដល់ព្រាហ្មណបុរោហិតនោះ ហើយចូលទៅកាន់ពិភពរបស់ខ្លួន តាំងអំពីនោះមក លាភសក្ការៈ ក៏កើតដល់ទេវតាយ៉ាងទៀងទាត់ ។

ជេដ្ឋកទេវបុត្ត ចុតិមកកើតក្នុងផ្ទៃរបស់ព្រាហ្មណី កិរិយារបស់បុរោហិតក្នុងថ្ងៃដាក់នាមកុមារនោះ មាតាបិតាព្រមព្រៀងគ្នា ឲ្យឈ្មោះថា ហត្ថិបាលកុមារ ហើយប្រគល់ឲ្យហ្មដំរីចិញ្ចឹម ដើម្បីការពារកុំឲ្យកុមារនោះបួស ។ ហត្ថិបាលកុមារនោះចម្រើនក្នុងសម្នាក់របស់ហ្មដំរី ក្នុងកាលដែលហត្ថិបាលកុមារដើរទៅមកបាន ទេវបុត្តទី ២ ក៏ចុតិមកកើតក្នុងផ្ទៃរបស់ព្រាហ្មណីទៀត ។ កាលកុមារនោះកើតហើយ មាតាបិតាក៏ដាក់ឈ្មោះថា អស្សបាលកុមារ ។ អស្សបាលកុមារក៏ចម្រើនធំធាត់ក្នុងសម្នាក់របស់អ្នកចិញ្ចឹមសេះ ។ ក្នុងកាលដែលកូនទី ៣ កើតឡើង មាតាបិតាដាក់ឈ្មោះថា គោបាលកុមារ ប្រគល់ឲ្យនាយ

គោបាលចិញ្ចឹម ។ ក្នុងកាលដែលបុត្តទី ៤ កើតហើយ មាតាបិតាដាក់ឈ្មោះថា អជបាលកុមារ ប្រគល់ឲ្យអ្នកឃ្វាលពពែចិញ្ចឹម ។ អជបាលកុមារចម្រើនធំធាត់ជាមួយពួកអជបាល ។ កាលកុមារទាំងនោះ ចម្រើនវ័យធំធាត់ហើយ ជាអ្នកមានរូបល្អល្អះពន់ពេក ។

តមក មាតាបិតាទាំង ២ អញ្ជើញបព្វជិតទាំងឡាយឲ្យចេញ អំពីរាជអាណាខេត្ត ព្រោះខ្លាចកុមារទាំងនោះបួស ។ ក្នុងដែនកាសិករដ្ឋទាំងមូលមិនមានបព្វជិតសូម្បីត្រឹមតែមួយអង្គ ។ កុមារទាំង ៤ នោះ ជាបុគ្គលគ្រោតគ្រាតក្រៃលែង ទៅកាន់ទិសណាៗ ក៏នាំគ្នាដណ្តើមយកទ្រព្យរបស់គេក្នុងទិសនោះ ៗ ។ កាលហត្ថិបាលកុមារអាយុ ១៦ ឆ្នាំ ព្រះរាជា និងព្រាហ្មណ៍បុរោហិត បានឃើញសិរីសម្បត្តិ ទើបប្រឹក្សាគ្នាថា កុមារទាំង ៤ ធំហើយ ជាសម័យដែលលើកស្វេតច្ឆត្រឲ្យគ្រប់គ្រងរាជសម្បត្តិ យើងគួរចាត់ការនឹងកុមារទាំងនោះដូចម្តេច ទើបគិតថា កុមារទាំងនេះ តាំងអំពីបានអភិសេកហើយ មុខជាគ្រោតគ្រាតក្រៃលែងឡើង បើបព្វជិតទាំងឡាយមកអំពីទីផ្សេងៗ ក្នុងកាលឥឡូវនេះ កុមារទាំងនេះឃើញ ក៏នឹងនាំគ្នាបួស កាលកុមារទាំងនេះបួសហើយ អ្នកជនបទក៏នឹងបះបោរ យើងទាំង ២ ត្រូវពិសោធមើលសិនសឹមអភិសេកកុមារទាំងនោះក្នុងកាលជាក្រោយ ទាំង ២ នាក់ក៏តែងខ្លួនជាឥសី ត្រាច់ភិក្ខាចារ ទៅដល់ទ្វារនិវេសន៍របស់ហត្ថិបាលកុមារ ។ ហត្ថិបាលកុមារឃើញបព្វជិតក្លែងក្លាយទាំងនោះហើយ ត្រេកអរ មានចិត្តជ្រះថ្លា ចូលទៅជិត ថ្វាយបង្គំហើយ ពោល ៣ គាថាដោយសេចក្តីថា

យូរណាស់ហើយយើងទើបនឹងឃើញព្រាហ្មណ៍ មានភេទដូចទេវតា មានផ្នួងសក់ធំ មានធូលីលើព្រះសិរ ។ យូរណាស់ហើយ យើងទើបនឹងឃើញឥសី អ្នកត្រេកអរក្នុងធម្មគុណ ស្លៀកដណ្តប់សំពត់កាសាយៈ មានសំបកឈើ ជាគ្រឿងបិទបាំង ។ សូមលោកដ៏ចម្រើន ទទួលនូវអាសនៈ ទឹកនិងប្រេងសម្រាប់លាបជើងរបស់យើងខ្ញុំចុះ យើងខ្ញុំសូមសួរនូវរបស់មានតម្លៃ ចំពោះលោកដ៏ចម្រើន សូមលោកដ៏ចម្រើន ប្រាប់នូវរបស់មានតម្លៃដល់យើងខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្រាហ្មណំ** បានដល់ ព្រាហ្មណ៍ដែលបន្សាត់បាបហើយ ។ បទថា **ទេវវណ្ណិនំ** សេចក្តីថា មានពណ៌សម្បុរដ៏ប្រសើរ មានតបៈក្លៀវក្លា មានឥន្ទ្រិយផូរផង់ គួររាប់អាន មានអត្តភាពនៃបព្វជិត មានតបធម៌ដ៏ខ្ពង់ខ្ពស់ ។ បទថា **ខារិធរំ** សេចក្តីថា ជាបុគ្គលទ្រទ្រង់ទុកនូវខារិ-ការភណ្ឌ ( អម្រែក ) ។ បទថា **ឥសឹ** សេចក្តីថា ជាអ្នកស្វែងរកគុណមានសីលរាសិជាដើមតាំងនៅហើយ ។ បទថា **ធម្មគុណេ រតំ** សេចក្តីថា ជាអ្នកត្រេកអរក្រៃលែងហើយក្នុងចំណែកនៃសុចរិតធម៌ ។

បទថា **អាសនំ** សេចក្តីថា ហត្ថិបាលកុមាររៀបចំអាសនៈទុក ដើម្បីឥសីទាំងនោះគង់ ហើយបង្អោនទឹកលាយដោយគ្រឿងក្រអូប សំពត់ជូតជើងនិងប្រេងសម្រាប់លាបប្រគេន ហើយនិមន្ត ។ បទថា **អគ្ឃេ** សេចក្តីថា ខ្ញុំប្រគេនអាសនៈជាដើម ដែលមានតម្លៃច្រើនទាំងអស់នេះ ជាមួយលោកដ៏

បម្រើន ។ បទថា **ក្ការុតុ ភោ** សេចក្តីថា សូមលោកម្ចាស់ទទួលអាសនៈដែលមានតម្លៃច្រើនទាំងនេះរបស់ខ្ញុំផងចុះ ។

ហត្ថិបាលកុមារអញ្ជើញបណ្តាឥសីទាំង ២ នោះ ម្តងមួយរូប ផ្សេងពីគ្នាយ៉ាងនេះ ។ សម័យនោះ បុរោហិតឥសីធ្វើជាសួរថា នែបាហត្ថិបាលឯងសម្គាល់យើងទាំង ២ ថា ជានរណា ទើបពោលយ៉ាងនេះ ហត្ថិបាលកុមារឆ្លើយថា ខ្ញុំសម្គាល់ថា ជាពួកឥសីក្នុងហិមវន្តប្បទេស បុរោហិតឥសីប្រាប់ថា នែបា ពួកយើងមិនមែនឥសីទេ នេះគឺព្រះរាជាឯសុការី ឯយើង គឺបុរោហិតដែលជាឪពុករបស់ឯង ។ ហត្ថិបាលកុមារសួរថា បើដូច្នោះ ហេតុអ្វី ទើបបិតានិងព្រះរាជាក្លែងភេទជាឥសី ។ បុរោហិតឆ្លើយថា ដើម្បីសាកល្បងឯងមើល ហត្ថិបាលកុមារសួរថា សាកល្បងខ្ញុំធ្វើអ្វី ទើបព្រាហ្មណ៍បុរោហិតពោលថា សាកល្បងមើលថា បើឯងឃើញពួកយើងជាឥសីហើយមិនបានបួសសោត កាលបើដូច្នោះ ទើបពួកយើងមកដើម្បីអភិសេកឯងឲ្យសោយរាជសម្បត្តិ ។ ហត្ថិបាលកុមារពោលថា បពិត្រលោកឪពុក ខ្ញុំមិនត្រូវការដោយរាជសម្បត្តិឡើយ ខ្ញុំនឹងបួស ។ លំដាប់នោះ ទើបបុរោហិតដែលជាបិតាចង្អុលបង្ហាញហត្ថិបាលកុមារថា នែហត្ថិបាលកូនសម្លាញ់ ពេលនេះ មិនមែនជាពេលដែលឯងត្រូវបួសទេ កាលទូន្មានតាមអធ្យាស្រ័យ បានពោលគាថាទី ៤ ថា

> ហែបា អ្នកចូររៀននូវវេទទាំងឡាយ ហើយស្វែងរកទ្រព្យ
>
> តម្កល់ទុកនូវកូនទាំងឡាយក្នុងផ្ទះ សោយនូវក្លិន និងរសទាំង

ឡាយផង នូវវត្ថុកាមគ្រប់បែបផង ព្រៃប្រពៃដល់អ្នកបួស
ឯចាស់ បុគ្គលនោះ ជាអ្នកប្រាជ្ញដែលព្រះអរិយៈទាំងឡាយ
សរសើរហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អធិច្ច** បានដល់ សិក្សារៀនសូត្រ ។ បទថា **បុត្តេ** សេចក្ដីថា ចូរលើកស្វេតច្ឆត្រហើយឲ្យស្រីរបាំចូលឧបដ្ឋាក បម្រើដោយវារៈ រហូតចម្រើនដោយបុត្តធីតា ហើយឲ្យបុត្តធីតាំងនោះ គ្រប់គ្រងស្រុកទេសជំនួសខ្លួន ។ បទថា **សត្វំ** ចូរសោយក្លិននិងរសទាំងនេះ ទាំងវត្ថុកាមដ៏សេសទាំងអស់សិន ។ បទថា **អរញ្ញំ សាធុ មុនិ សោ បសត្ថោ** សេចក្ដីថា បុរោហិតពោលថា ការនៅព្រៃរបស់អ្នកបួសឯចាស់ រមែងបានដល់នូវប្រយោជន៍សម្រេចល្អ បុគ្គលណា បួសក្នុងកាលដូចពោលមកនេះ បុគ្គលនោះ ជាអ្នកមានការគិត ដែលអរិយជនទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ។ គ្រានោះ ហត្ថិបាលកុមារពោលគាថានេះថា

វេទទាំងឡាយជាសភាវៈមិនទៀង ការបាននូវទ្រព្យ ក៏មិនទៀងដែរ ជនទាំងឡាយ ឃាត់ជរាដោយការបាននូវកូនមិនបានទេ
សប្បុរសទាំងឡាយសរសើរនូវការរួចចាកក្លិននិងរស កិរិយា
សម្រេចផលរមែងមានតាមកម្មរបស់ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន សច្ចា** សេចក្ដីថា ជនទាំងឡាយពោលវិជ្ជាការឯណាថាជាសួគ៌ និងជាមគ្គ តែមិនមែនប្រើវិជ្ជាការនោះឲ្យសម្រេចប្រយោជន៍បានឡើយ វិជ្ជាទាំងឡាយជារបស់គ្មានប្រយោជន៍ ឥតសារៈ មិន

មានផលឡើយ ។ បទថា **ន ច វិត្តលាភោ** សេចក្ដីថា សូម្បីលាភ គឺទ្រព្យសម្បត្តិ ជារបស់មានសភាពតែមួយគ្រប់យ៉ាង ក៏មិនមែន ព្រោះជារបស់បញ្ចសាធារណៈ ( សាធារណៈដល់របស់ ៥ មានភ្លើងជាដើម ) ។ បទថា **ជរំ** សេចក្ដីថា បពិត្របិតា បុគ្គលណាម្នាក់ ឈ្មោះថា អាចហាមនូវជរា ឬព្យាធិមរណៈបាន ដោយលាភ គឺបុត្តក៏មិនមាន ព្រោះលាភ គឺបុត្តនេះមានទុក្ខជាមូល ជាទីតាំងនៃឧបក្កិលេស ។ បទថា **គន្ធេ រសេ** សេចក្ដីថា បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម រមែងពោលទូន្មានចំពោះការលែងចោលនូវគន្ធារម្មណ៍ រសារម្មណ៍ និងអារម្មណ៍ដ៏សេសទាំងឡាយប៉ុណ្ណោះ ។ បទថា **សកម្មុនា** សេចក្ដីថា ការកើតឡើងនៃផល គឺការឲ្យផលរមែងកើតដល់សត្វទាំងឡាយ ព្រោះកម្មដែលខ្លួនធ្វើទុកប៉ុណ្ណោះ បពិត្របិតា ព្រោះសត្វទាំងឡាយមានកម្មជារបស់ខ្លួន ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់កុមារហើយ ត្រាស់ព្រះគាថាដោយសេចក្ដីថា

ពាក្យរបស់អ្នកនុ៎ះ ជាពាក្យពិត ដ្បិតថា កិរិយាសម្រេចផល
រមែងមានតាមកម្មរបស់ខ្លួន ប៉ុន្ដែមាតា និងបិតារបស់អ្នកនេះ
ចាស់ហើយ លោកតែងចង់ឃើញនូវអ្នក ជាបុគ្គលមិនមាន
រោគ អស់រយនៃឆ្នាំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វស្សសតំ អរោគ្យំ** សេចក្ដីថា ព្រះរាជាត្រាស់ថា មាតាបិតារបស់អ្នកបំណងនឹងឃើញអ្នកមានអាយុ ១០០ ឆ្នាំ មិន

មានរោគភ័យបៀតបៀន កាលអ្នកមានជីវិតរស់នៅដល់ ១០០ ឆ្នាំ នឹងបាន ចិញ្ចឹមមាតាបិតាខ្លះ ។

ហត្ថិបាលកុមារស្តាប់រាជតម្រាស់ហើយ ទូលថា បពិត្រព្រះអង្គទ្រទ្រង់ នូវគុណដ៏ប្រសើរ ហេតុអ្វី ទើបទ្រង់ត្រាស់ដូច្នេះ ហើយពោលគាថា ២ ថា

*បពិត្រព្រះរាជា អ្នកទ្រទ្រង់នូវសេចក្តីព្យាយាមវិសេសជាងជន ភាពជាសម្លាញ់ដោយមរណៈ សេចក្តីមេត្រីដោយជរា គប្បីមាន ដល់ជនណា ម្យ៉ាងទៀត ជនណាគប្បីដឹងថា អញនឹងមិនស្លាប់ ក្នុងកាលណាមួយទេ មាតាបិតាគួរឃើញនូវជននោះ ជាបុគ្គល មិនមានរោគ អស់រយៈនៃឆ្នាំ ។ បុរសចែវទូកក្នុងទឹក នាំទូកទុំះ ទៅកាន់ត្រើយ ( ខាងនាយ ) យ៉ាងណា សេចក្តីឈឺចាប់ និងសេចក្តីគ្រាំគ្រារមែងនាំសត្វចូលទៅកាន់អំណាច នៃសេច ក្តីស្លាប់ អ្នកធ្វើនូវទីបំផុតជារឿយៗ យ៉ាងនោះដែរ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **សក្ខី** បានដល់ មិត្តធម៌ ។ បទថា **មរ-ណេន** សេចក្តីថា ជាមិត្តនឹងសេចក្តីស្លាប់ ដោយសន្មតថា នាយទត្តៈ នាយ មិត្តៈស្លាប់ទៅហើយ ។ បទថា **ជរាយ** សេចក្តីថា មិត្តមេត្រីនិងជរាដែល ប្រាកដ គប្បីមានដល់បុគ្គលណា អធិប្បាយថា មរណៈនេះ និងជរា មិន ធ្លាប់ជាមិត្ត ជាមួយបុគ្គលណាឡើយ ។ បទថា **ឃរតិ ចេធំ** សេចក្តីថា បពិត្រមហារាជ បុរសចតទូកត្រង់កំពង់ ហើយឲ្យមនុស្សដែលឆ្លងទៅត្រើយ នាយចុះកាន់ទូក បើបុគ្គលនោះយកថ្នោលដោលឬអុំទៅ ដោយចិត្តស្រឡាញ់

រមែងឲ្យទូកកម្រើកជាប់តគ្នាទៅ ពេលនោះ ក៏នាំបុគ្គលនោះ ចូលទៅកាន់ទូរ ត្រើយនាយបាន យ៉ាងណា ជរាព្យាធិរមែងនាំសត្វទាំងឡាយ ចូលទៅកាន់ អំណាចនៃមច្ចុដែលជាទីបំផុតជានិច្ច យ៉ាងនោះ ។

កាលហត្ថិបាលកុមារ សម្តែងជីវិតសង្ខារនៃសត្វទាំងនេះថាជារបស់តិច តួចយ៉ាងនេះហើយ ទើបថ្វាយឱវាទដល់ព្រះរាជាថា បពិត្រមហារាជ សូម ទ្រង់តាំងនៅជាសុខចុះ ជរាព្យាធិនិងមរណៈ រមែងរុករាន ចូលជិតទូលព្រះ បង្គំដែលកំពុងក្រាបទូលសន្ទនាជាមួយទ្រង់នោះឯង សូមទ្រង់កុំប្រមាទ និង កុំស្រវឹងឡើយ ហើយថ្វាយបង្គំព្រះរាជា ថ្វាយបង្គំឪពុក នាំបរិវាររបស់ខ្លួន លះរាជសម្បត្តិក្នុងនគរពារាណសី ចេញទៅដោយតាំងចិត្តថា អញនឹងបព្វជ្ជា មហាជនចេញទៅជាមួយហត្ថិបាលកុមារ ដោយគិតថា ឈ្មោះថា បព្វជ្ជានេះ គង់ប្រពៃពិត មានបរិស័ទជាប់តាមទៅប្រមាណមួយយោជន៍ ។ ហត្ថិបាល កុមារទៅដល់ឆ្នេរស្ទឹងគង្គា មួយអន្លើដោយបរិស័ទនោះ សម្លឹងមើលទឹកក្នុង ស្ទឹងគង្គា ចម្រើនកសិណបរិកម្ម ញុំាងឈានឲ្យកើតហើយ គិតថា សមាគម នេះនឹងធំក្រៃលែង ប្អូនប្រុសរបស់អញទាំង ៣ នាក់ មាតាបិតារបស់អញ ព្រះរាជានិងព្រះរាជទេវី ជនទាំងអស់នេះ មួយអន្លើដោយបរិវារ ក៏នឹងបួស ក្រុងពារាណសីនឹងទទេ អញនឹងនៅក្នុងទីនេះឯង ទម្រាំជនទាំងនោះតាម មក ។ ហត្ថិបាលកុមារអង្គុយឲ្យឱវាទដល់មហាជន ត្រង់ឆ្នេរស្ទឹងគង្គានោះ ឯង ។

ស្អែកឡើង ព្រះបាទឯសុការី និងព្រាហ្មណ៍បុរោហិត គិតគ្នាថា ហត្ថិ

បាលកុមារលះរាជសម្បត្តិ នាំមហាជនទៅមុន ដោយគិតថានឹងបួស ដូច្នេះហើយ អន្ទុយសម្រាកត្រង់ឆ្នេរស្ទឹងគង្គាហើយ យើងទាំង ២ ត្រូវសាកល្បងអស្សបាលកុមារនឹងបានអភិសេកឲ្យគ្រងរាជសម្បត្តិ ជនទាំង ២ ក៏បានទៅកាន់ទ្វារផ្ទះរបស់អស្សបាលកុមារ ដោយការក្លែងភេទជាឥសីដូចគ្នា ។ ឯអស្សបាលកុមារ កាលឃើញហើយ មានចិត្តជ្រះថ្លា ចូលទៅក្បែរហើយ ពោលពាក្យជាដើមថា យូរហើយ ខ្ញុំទើបតែបានឃើញ ហើយបដិបត្តិតាមន័យដែលបានពោលមកហើយនោះឯង ។ ឥសីក្លែងភេទនោះក៏ប្រាប់អស្សបាលកុមារដូចដែលពោលមកហើយដូចគ្នា និងបានប្រាប់ហេតុដែលខ្លួនមកឲ្យបានដឹង ។ អស្សបាលកុមារសួរថា កាលហត្ថិបាលកុមារបងប្រុសរបស់ខ្ញុំមាន ហេតុអ្វីទើបស្វេតច្ឆត្របានមកខ្ញុំទៅវិញ កាលបិតាឆ្លើយថា កូនជាទីស្រឡាញ់ បងប្រុសរបស់ឯងពោលថា មិនត្រូវការរាជសម្បត្តិ នឹងបួស ចេញទៅបួសហើយ ទើបសួរតទៅថា ឥឡូវនេះ បងប្រុសរបស់ខ្ញុំនៅឯណា កាលបិតាឆ្លើយថា ស្នាក់នៅត្រង់មាត់ស្ទឹងគង្គា ទើបពោលថា បពិត្របិតា ខ្ញុំមិនប្រាថ្នារាជសម្បត្តិទេ ឧបមាដូចដុំទឹកមាត់ដែលបងប្រុសស្តោះចោលហើយ ។ ពិតហើយ សត្វទាំងឡាយដែលល្ងង់ខ្លៅ អាប់ឥតប្រាជ្ញា រមែងមិនអាចលះកិលេសនោះបានឡើយ តែខ្ញុំនឹងលះ កាលសម្តែងធម៌ដល់ព្រះរាជានិងបិតារបស់ខ្លួន បានពោលគាថា ២ ថា

កាមទាំងឡាយជាភក់ផង កាមទាំងឡាយជាល្បាប់ផង ជាគ្រឿងនាំមកនូវសេចក្តីពេញចិត្ត ជាគ្រឿងឆ្លងបានដោយកម្រជាលំនៅ

នៃមច្ចុ ពួកសត្វដែលលិចចុះក្នុងភក់ក្នុងល្បាប់នេះ ជាសត្វមានចិត្តថោកទាប ជាសភាវៈឆ្លងទៅកាន់ត្រើយ ( ព្រះនិព្វាន ) ពុំបានឡើយ ។ អត្តភាពរបស់ទូលព្រះបង្គំជាខ្ញុំនេះ បានធ្វើនូវអំពើអាក្រក់ក្នុងកាលមុន ផលនៃកម្មនោះ ទូលព្រះបង្គំជាខ្ញុំបានកាន់យកហើយ ការរួចចាកផលអកុសលនោះ មិនមានដល់ទូលព្រះបង្គំជាខ្ញុំឡើយ ។ ទូលព្រះបង្គំនឹងបិទរក្សានូវអត្តភាពនោះ កុំឲ្យអត្តភាពនេះ ធ្វើអំពើអាក្រក់ទៀតឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បង្កោ** បានដល់ ភក់ឯណាមួយ ។ បទថា **បលិបោ** បានដល់ ភក់ល្បាប់ដែលលាយដោយខ្សាច់ល្អិត ។ ក្នុង ២ យ៉ាងនោះ លោកពោលថា កាមឈ្មោះ បង្កៈ ដោយអត្ថថា ញុំាងសត្វឲ្យជាប់ចំពាក់ ឈ្មោះថា បលិបៈ ដោយអំណាចញុំាងសត្វឲ្យលិចចុះ ។ បទថា **ទុត្តរា** បានដល់ ឈានកន្លងបានដោយលំបាក ។ បទថា **មច្ចុធេយ្យា** បានដល់ជាទីតាំងនៃមច្ចុ ព្រោះថា សត្វទាំងឡាយជាប់ជំពាក់ផង ចូលទៅជិតកាមទាំងនេះផង មិនអាចឆ្លងបាន រមែងដល់នូវសេចក្ដីទុក្ខនិងសេចក្ដីស្លាប់ មានប្រការដូចពោលទុកក្នុងទុក្ខក្ខន្ធបរិយាយសូត្រ ដោយហេតុនោះ ទើបអស្សបាលកុមារពោលថា ពួកសត្វដែលលិចចុះក្នុងភក់ ក្នុងល្បាប់នេះ ជាសត្វមានចិត្តថោកទាប ជាសភាវៈឆ្លងទៅកាន់ត្រើយ ( ព្រះនិព្វាន ) ពុំបានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្យសន្នា** សេចក្ដីថា បុគ្គលស្មុះទៅ ។ បាបៈ

ថា **វិសន្នា** ដូច្នេះក៏មាន សេចក្តីក៏តែមួយដូចគ្នា ។ បទថា **ហីនត្ថរូបា** បាន ដល់ ជាអ្នកមានសភាពនៃចិត្តថោកថយ ។ បទថា **ន តរន្តិ ចារំ** សេចក្តី ថា រមែងមិនអាចចូលដល់ត្រើយនៃព្រះនិព្វានបាន ។ បទថា **អយំ** សេចក្តី ថា បពិត្រមហារាជ អត្តភាពរបស់ទូលព្រះបង្គំនេះ ចម្រើនធំធាត់មក ជា មួយអ្នកចិញ្ចឹមសេះ បានធ្វើបាបកម្មដ៏គួរស្ញើមជាច្រើន ដោយអំណាចនៃ ការប្ចូន់ ដណ្តើម បៀតបៀនមហាជនជាដើម ។ បទថា **ស្វាយំ គហីតោ** សេចក្តីថា វិបាកនៃកម្មនេះ ទូលព្រះបង្គំប្រកាន់ទុកមាំហើយ ។ បទថា **ន ហិ មោក្ខិតោ មេ** សេចក្តីថា កាលការប្រព្រឹត្តទៅនៃសង្សារវដ្តមាន ការ ផុតទៅនៃផលអកុសលកម្មនេះរបស់ទូលព្រះបង្គំមិនមាន ។ បទថា **ឱរុន្ធិយា នំ បរិរក្ខិស្សាមិ** សេចក្តីថា ឥឡូវនេះ ខ្ញុំនឹងបិទទ្វារកាយទ្វារ វចីទ្វារនិង មនោទ្វារ រក្សាអត្តភាពនោះទុក ដោយជុំវិញ ព្រោះហេតុអ្វី ។ បទថា **មាយំ បុន លុទ្ទមកាសិ កម្មំ** សេចក្តីថា ព្រោះចាប់អំពីនេះទៅ ទូលព្រះបង្គំ មិនធ្វើសេចក្តីអាក្រក់ នឹងធ្វើតែអំពើល្អតែម្យ៉ាង ប៉ុណ្ណោះ ។

អស្សបាលកុមារឲ្យឱវាទបន្តថា សូមព្រះអង្គ និងលោកឪពុកតាំងនៅ ជាសុខចុះ ជរា ព្យាធិនិងមរណៈ រមែងរុករានខ្ញុំ ដែលកំពុងពោលសន្ទនា ជាមួយលោកទាំង ២ នោះឯង ហើយនាំបរិស័ទ កំណាត់មួយយោជន៍ចេញ ទៅកាន់សម្នាក់ហត្ថិបាលកុមារ ។ ហត្ថិបាលកុមារអង្គុយលើអាកាសសម្តែង ធម៌ដល់អស្សបាលហើយពោលថា ប្អូនជាទីស្រឡាញ់ សមាគមនេះ ធំក្រៃ លែង ពួកយើងនឹងនៅក្នុងទីនេះមុន ។ ចំណែកអស្សបាលកុមារ ក៏ទទួលថា

សាធុ រួចក៏នៅក្នុងទីនោះ ។ ស្អែកឡើង ព្រះរាជានិងរាជបុរោហិតនាំគ្នាទៅកាន់និវេសន៍របស់គោបាលកុមារ ដោយឧបាយយ៉ាងនោះដូចគ្នា កាលគោ-បាលកុមារត្រេកអរទទួលដូចដែលពោលមកហើយ ទើបសម្តែងហេតុនៃការមករបស់ខ្លួនឲ្យដឹង ។ គោបាលកុមារ ក៏បដិសេធដូចអស្សបាលកុមារ ពោលថា ខ្ញុំប្រាថ្នានឹងបួសមកយូរហើយ ពិចារណារកតែផ្លូវចេញបព្វជ្ជា ដូចមនុស្សដើររកគោដែលបាត់ទៅ ខ្ញុំឃើញផ្លូវដែលបងប្រុសរបស់ខ្ញុំទាំង ២ ទៅហើយ ដូចមនុស្សជួបគន្លងគោដែលបាត់ទៅ ហេតុនោះ ខ្ញុំក៏នឹងទៅតាមផ្លូវនោះដូចគ្នា ដូច្នេះហើយ ពោលគាថានេះថា

បពិត្រព្រះរាជា ដូចបុរស កាលមិនឃើញគោ ស្វែងរកគោ
ដែលបាត់ក្នុងព្រៃ យ៉ាងណា បពិត្រព្រះរាជា ទ្រង់ព្រះនាម
ឯសុការី ប្រយោជន៍ ( បព្វជ្ជា ) របស់ទូលព្រះបង្គំជាខ្ញុំ
វិនាសបាត់ទៅ ក៏យ៉ាងនោះដែរ បពិត្រព្រះរាជា ទូលព្រះបង្គំ
ជាខ្ញុំ មិនគប្បីស្វែងរកដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ គោបាលកុមារហៅព្រះរាជាថា ឯសុការី ។ បទថា **មមត្ថោ** សេចក្តីថា ប្រយោជន៍ ពោលគឺបព្វជ្ជារបស់ខ្ញុំបាត់ទៅ ដូចគោដែលបាត់ទៅក្នុងព្រៃ ។ បទថា **សោហំ** សេចក្តីថា ថ្ងៃនេះ ខ្ញុំឃើញគន្លងនៃបព្វជិតទាំងឡាយហើយ ព្រោះអ្វីដែលថាមិនស្វែងរកបព្វជ្ជា បពិត្រអរិន្ទមរាជ ខ្ញុំនឹងទៅកាន់ផ្លូវដែលបងប្រុសទាំង ២ របស់ខ្ញុំទៅហើយដូចគ្នា ។

លំដាប់នោះ ព្រះរាជានិងបុរោហិតនាំគ្នាអង្វរគោបាលកុមារថា នែបា

គោបាល ចូរបាបន្អង់ ១ ថ្ងៃ ២ ថ្ងៃសិនចុះ ល្មមឲ្យយើងទាំង ២ ជូរស្រាលចិត្ត ហើយសឹមបួស ។ គោបាលកុមារទូលថា បពិត្រមហារាជ កម្មដែលគួរធ្វើក្នុងថ្ងៃនេះ មិនគួរពោលបណ្ដោះបណ្ដោថានឹងធ្វើក្នុងថ្ងៃស្អែក ឈ្មោះថា កម្មល្អ ដែលគួរធ្វើក្នុងថ្ងៃនេះ គួរធ្វើក្នុងថ្ងៃនេះប៉ុណ្ណោះ ហើយពោលគាថាដូច្នេះថា

> បុរសបង្អង់ ( នូវការងារដែលត្រូវធ្វើ ) ថា ចាំថ្ងៃស្អែក ៗ
> ដូច្នេះ រមែងសាបសូន្យ អ្នកប្រាជ្ញដឹងថា អនាគតនេះមិនមាន
> ដូច្នេះហើយ អ្នកប្រាជ្ញណានឹងបន្ទោបង់នូវសេចក្ដីប៉ុនប៉ងដែល
> កើតឡើងហើយបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហិយ្យោ** បានដល់ ក្នុងថ្ងៃស្អែកនេះ ។ បទថា **បរេ** បានដល់ ក្នុងថ្ងៃខានស្អែក ។ មានពាក្យអធិប្បាយថា បពិត្រមហារាជ បុរសណាបណ្ដោះបណ្ដោការងារដែលគួរធ្វើក្នុងថ្ងៃនេះ ថាគួរធ្វើក្នុងថ្ងៃស្អែក ការងារដែលគួរធ្វើក្នុងថ្ងៃស្អែក ថាគួរធ្វើក្នុងថ្ងៃខានស្អែក ហើយមិនធ្វើការងារ បុរសនោះរមែងសាបសូន្យចាកការងារនោះ គឺមិនអាចធ្វើការងារនោះឲ្យសម្រេចបាន ។ គោបាលកុមារសម្ដែងដល់ការងារឈ្មោះភត្តេករត្ត គឺមានរាត្រីមួយដ៏ចម្រើនដោយអាការដូច្នេះ ។ អធិប្បាយសេចក្ដីនេះ គួរពោលភត្តេករត្តសូត្រ ។ បទថា **អនាគតំ នេតមត្ថិ** សេចក្ដីថា ជនជាបណ្ឌិតណាដឹងថា វត្ថុណាជាអនាគត វត្ថុនោះមិនទាន់មាន គប្បីបន្ទោបង់ គឺនាំកុសលឆន្ទៈដែលកើតឡើងហើយទៅ ។

គោបាលកុមារសំដែងធម៌ដោយ ២ គាថាយ៉ាងនេះហើយ ពោលថា សូមលោកទាំង ២ តាំងនៅជាសុខចុះ ជរា ព្យាធិ មរណៈជាដើម រមែងគំរាមខ្ញុំ ដែលកំពុងសន្ទនាជាមួយលោកទាំង ២ នេះឯង ហើយនាំបរិវារមានប្រមាណមួយយោជន៍ជាកំណត់ ចេញទៅកាន់សម្នាក់បងប្រុសទាំង ២ ។ ហត្ថិបាលកុមារ ក៏សំដែងធម៌ដល់គោបាលកុមារ ស្អែកឡើង ព្រះរាជានិងរាជបុរោហិត ទៅកាន់និវេសន៍របស់អជបាលកុមារ ដោយឧបាយយ៉ាងនោះដូចគ្នា សូម្បីអជបាលកុមារនោះ ត្រេកអរទទួលដូចពោលមកហើយ អ្នកទាំង ២ ប្រាប់នូវហេតុដែលខ្លួនមក ហើយពោលថា យើងទាំង ២ នឹងលើកស្វេតច្ឆត្រប្រគល់ឲ្យអ្នក អជបាលកុមារសួរថា បងប្រុសទាំង ៣ របស់ខ្ញុំទៅឯណា ព្រះរាជានិងបុរោហិតតបថា បងប្រុសទាំង ៣ របស់ឯងនោះពោលថា មិនត្រូវការដោយរាជសម្បត្តិ លះបង់ស្វេតច្ឆត្រ ហើយនាំបរិវារមានប្រមាណ ៣ យោជន៍ជាកំណត់ ចេញទៅបួស ស្នាក់នៅត្រង់ឆ្នេរស្ទឹងគង្គា ។ អជបាលកុមារពោលថា ខ្ញុំនឹងយកក្បាលទូលរាជសម្បត្តិដែលប្រៀបដូចដុំទឹកមាត់ដែលបងប្រុសរបស់ខ្ញុំទាំង ៣ ស្តោះចោល ហើយត្រាច់ទៅដូចម្តេចបាន ឯខ្ញុំក៏នឹងបួស ។ ព្រះរាជានិងបុរោហិតពោលអង្វរថា នែបាអជបាល បានៅកំលោះ ជាការៈដែលយើងទាំង ២ ត្រូវលើកស្ទួយ បាគួរបួសក្នុងវេលាដែលដល់វ័យសមគួរ ។ គ្រានោះ អជបាលកុមារពោលថា លោកទាំង ២ និយាយអ្វី ធម្មតាសត្វទាំងឡាយនេះ រមែងស្លាប់នៅជាកុមារក៏មាន ក្នុងពេលចាស់ក៏មាន មិនមែនឬ មិនមាននិមិត្ត គ្រឿងចំណាំ ត្រង់

ដែឬត្រង់ជើងរបស់បុគ្គលណាឡើយថា បុគ្គលនេះនឹងស្លាប់ក្នុងកាលជាកុមារ នឹងស្លាប់ក្នុងកាលចាស់ជរា ខ្ញុំក៏មិនដឹងពេលស្លាប់របស់ខ្ញុំ ព្រោះហេតុនោះ ខ្ញុំនឹងបួសឥឡូវនេះ បានពោលគាថា ២ ថា

ទូលព្រះបង្គំជាខ្ញុំ បានឃើញ កុមារីនៅក្មេង ( ឡេះឡោះ ) ដូចជាមនុស្សឆ្កួត មានភ្នែកដូចត្របកនៃផ្កាកាកែស ឋិតនៅក្នុងបឋមវ័យ មិនទាន់បរិភោគនូវភោគៈទាំងឡាយ ស្រាប់តែមច្ចុនាំយកកុមារី ( នោះទៅ ) ។ ប្រុសកំលោះមានកំណើតល្អ មានមុខស្រស់បស់ គួរជាទីរមិលមើល មានសម្បុរលឿងដូចមាស មានពុកមាត់ដេរដាសដូចកេសរនៃផ្កាដកគាំ ( មច្ចុបាននាំយកនូវប្រុសកំលោះនោះទៅ ) ខ្ញុំព្រះអង្គនឹងលះបង់នូវកាមទាំងឡាយ ហើយគេចចេញចាកផ្ទះ ( ទៅបួស ) បពិត្រព្រះសម្មតិទេព សូមព្រះអង្គអនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ នឹងបួស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វេា** ជានិបាត សេចក្ដីថា ទូលព្រះបង្គំឃើញនោះឯង ។ បទថា **មត្តូបមំ** សេចក្ដីថា សើច ចរចាពីរោះ កែក្រាយ ល្មមប្រមាណ ត្រាច់ទៅ ។ បទថា **កេតកបុប្ផនេត្តំ** សេចក្ដីថា មានភ្នែកទូលាយដូចត្របកផ្កាកាកែស ។ បទថា **អភុត្វា ភោគេ** សេចក្ដីថា មិនទាន់បានបរិភោគសម្បត្តិនៅឡើយ ។ បទថា **វជតេ** សេចក្ដីថា មច្ចុមកទាញយកកុមារីដែលមានរូបស្អាត កំពុងនៅក្នុងបឋមវ័យ មិនទាន់បានបរិភោគសម្បត្តិ

នោះឯង ទៅយ៉ាងនេះ ញុំាងសេចក្តីសោក ឲ្យធ្លាក់លើមាតាបិតា ជាក្រៃលែង ។ បទថា **សុជាតោ** បានដល់ មានសណ្ឋាន ទ្រង់ទ្រាយល្អ ។ បទថា **សុមុខោ** សេចក្តីថា មានកក្រូដូវផង់ដូចកញ្ចក់មាស និងព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។

បទថា **សុទស្សនោ** សេចក្តីថា សម្បូរដោយរូបដ៏ឧត្តម គួរទស្សនា ។ បទថា **សាមោ** សេចក្តីថា មានពណ៌កាយស្មើដោយមាសធម្មជាតិ ។ បទថា **កុសុម្ភបរិកិណ្ណមស្សុ** សេចក្តីថា មានពុកមាត់ពុកចង្កាល្អិតស្អាត ដូចកេសរផ្កាដកគាំ ហើយរៀបរយល្អផង ទន់ផង ។ ដោយបទនេះ អជបាលកុមារសម្តែងថា យុវកុមារបែបនេះ គង់ទៅកាន់អំណាចនៃមច្ចុរាជបាន ព្រោះមច្ចុរាជមិនមានសេចក្តីករុណា ទាញយកជីវិត សូម្បីយុវកុមារបែបនេះទៅ ដូចគ្នានឹងបុគ្គលចាប់ដកនូវកំសិនេរុរាជ ដូច្នោះ ។ បទថា **ហិត្វាន កាមេ បដិគច្ច គេហំ អនុជាន មំ បព្វជិស្សាមិ ទេវ** សេចក្តីថា បពិត្រព្រះអង្គទ្រង់ទ្រង់នូវគុណដ៏ប្រសើរ កាលចំណង គឺបុត្ត និងភរិយាកើតហើយ ចំណងនោះ ជារបស់កាត់ផ្តាច់បានដោយលំបាក ដោយហេតុនោះ ខ្ញុំនឹងលះកាម និងមេផ្ទះនោះឯង ហើយចេញបួសក្នុងកាលឥឡូវនេះ សូមទ្រង់អនុញ្ញាតឲ្យទូលព្រះបង្គំបួសចុះ ។

កាលអជបាលកុមារពោលយ៉ាងនេះហើយ ពោលតទៅថា សូមលោកទាំង ២ តាំងនៅជាសុខចុះ ជរា ព្យាធិនិងមរណៈ កំពុងរុករានខ្ញុំដែលកំពុងពោលសន្ទនាជាមួយលោកទាំង ២ នោះឯង ដូច្នេះហើយ ថ្វាយបង្គំលា

លោកទាំង ២ នាំបរិវារមានប្រមាណមួយយោជន៍ជាកំណត់ ចេញទៅកាន់ស្ទឹងគង្គានោះឯង ។ ហត្ថិបាលកុមារអង្គុយក្នុងអាកាសសម្តែងធម៌ដល់ អជបាលកុមារនោះហើយពោលថា សមាគមនឹងជាំក្រៃលែង ហើយអង្គុយក្នុងទីនោះតទៅ ស្អែកឡើង ព្រាហ្មណបុរោហិតអង្គុយកណ្តាលបល្ល័ង្ក គិតថា កូនទាំង ៤ របស់អញបួសហើយ ឥឡូវនេះ សល់តែអញម្នាក់ឯង ដូចជន្ទត់ឈើ អញក៏នឹងបួស ទើបប្រឹក្សាជាមួយព្រាហ្មណីថា

> អនុបាទិន្នកសង្ខារ បានឈ្មោះថាដើមឈើ ព្រោះតែមែកទាំងឡាយ មួយទៀត ជនទាំងឡាយ ហៅនូវដើមឈើដែលមានមែកលះបង់អស់ហើយថា ជន្ទត់ ម្នាលនាងវាសេដ្ឋីដ៏ចម្រើន ថ្ងៃនេះ ជាកាលគួរដើម្បីត្រាច់ទៅស្វែងរកភិក្ខារបស់ខ្ញុំ ដែលមានកូនលះបង់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លភតេ សមញ្ញំ** សេចក្តីថា អនុបាទិន្នកសង្ខារ បានឈ្មោះថា ដើមឈើ ។ ព្រាហ្មណ៍បុរោហិត ហៅព្រាហ្មណីថា វាសេដ្ឋី ។ បទថា **ភិក្ខាចរិយាយ** សេចក្តីថា ព្រាហ្មណ៍បុរោហិតពោលថា យើងក៏ដល់កាលដែលគួរបួស នឹងបានទៅកាន់សម្នាក់របស់បុត្តទាំង ៤ នោះឯង ។

កាលព្រាហ្មណបុរោហិតពោលយ៉ាងនេះហើយ ទើបហៅព្រាហ្មណ៍ ១ ម៉ឺន ៦ ពាន់នាក់មកប្រជុំគ្នា ។ លំដាប់នោះ ទើបព្រាហ្មណ៍បុរោហិតពោលនឹងព្រាហ្មណ៍ទាំងនោះថា ពួកលោកនឹងធ្វើដូចម្តេច ព្រាហ្មណ៍ទាំងនោះសួរ

វិញថា លោកអាចារ្យនឹងធ្វើដូចម្ដេច ព្រាហ្មណ៍បុរោហិតតបថា យើងនឹងបួស ក្នុងសម្នាក់នៃបុត្តរបស់យើង ទើបព្រាហ្មណ៍ទាំងនោះពោលថា នរកជារបស់ ក្ដៅសម្រាប់លោកតែម្នាក់ក៏មិនមែន ឯយើងទាំងឡាយក៏នឹងបួស ។ ព្រាហ្មណ៍បុរោហិតប្រគល់សម្បត្តិ ៨០ កោដិដល់ព្រាហ្មណីជាភរិយាហើយ នាំព្រាហ្មណបរិស័ទ មួយយោជន៍ជាកំណត់ទៅកាន់សម្នាក់កូនទាំង ៤ មួយរំពេច ។ ហត្ថិបាលកុមារឈរក្នុងអាកាសសម្ដែងធម៌ដល់បរិស័ទទាំងនោះ ។ ក្នុងថ្ងៃស្អែកឡើង នាងព្រាហ្មណីគិតថា កូនទាំង ៤ របស់ខ្ញុំ លះបង់ស្វេតច្ឆត្រទៅ ដោយគិតថានឹងបួស ឯព្រាហ្មណ៍ជាស្វាមី ក៏បោលសម្បត្តិ ៨០ កោដិ មួយអន្ទើដោយតំណែងបុរោហិត ទៅកាន់សម្នាក់កូនទាំង ៤ ដូចគ្នា អញម្នាក់ឯងប៉ុណ្ណោះនឹងធ្វើអ្វីបាន អញនឹងទៅតាមផ្លូវដែលកូនរបស់អញទៅហើយដូចគ្នា ព្រាហ្មណីកាលនាំយករឿងដែលកន្លងមកហើយជាឧទាហរណ៍ ទើបពោលគាថានេះថា

ពួកក្រៀលហើរទៅព្ធដ៏អាកាស ក្នុងរដូវអស់ទឹកភ្លៀង ហង្ស
ទាំងឡាយទម្លាយនូវមងដែលពីងពាងធ្វើហើយ យ៉ាងណា កូន
ទាំងឡាយផង ប្ដីផងរបស់អញ ( ទម្លាយមងគឺកាមហើយ )
ក៏ទៅ យ៉ាងនោះដែរ អញនោះ កាលបើដឹងច្បាស់ហើយ មិន
ទៅតាម ដូចម្ដេចកើត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អយស្មិ កោញ្ចាវ យថា** សេចក្ដីថា សត្វក្រៀលទាំងឡាយ ហើរទៅបាន មិនជាប់ស្អិតក្នុងអាកាស យ៉ាងណា ។ បទ

ថា **ហិមច្ចយេ** សេចក្ដីថា កាលរដូវភ្លៀងកន្លងទៅហើយ ។ បទថា **កតានិ ជាលានិ បទាលេយ្យុ ហំសា** សេចក្ដីថា បានឮថា ក្នុងអតីតកាល ហង្ស ៩៦០០០ នាំគ្នារក្សាស្រូវសាលីទុកក្នុងកញ្ចនគុហា ល្មមទុកស៊ីក្នុងរដូវភ្លៀង មិនចេញទៅខាងក្រៅ ព្រោះខ្លាចភ្លៀង នៅក្នុងគុហាមាសនោះអស់ ៤ ខែ ក្នុងរដូវភ្លៀងនោះ ក្នុងកាលនោះ ពីងពាងក៏វាយសំណាញ់ ត្រង់មាត់គុហារបស់ហង្សទាំងនោះ ។ ក្នុងហង្សទាំងនោះ ហង្សជំទង់ ២ កាត់អន្ទាក់ពីងពាងដាច់ ២ ប្រឡោះ ។ តរុណហង្សទាំងនោះ កាត់សរសៃពីងពាងដាច់ ព្រោះជាសត្វសម្បូរដោយកម្លាំង ហើយហើរទៅមុននោះឯង ហង្សដ៏សេសក៏ហើរទៅតាមតរុណហង្សហើយ ។ ព្រាហ្មណី កាលប្រកាសសេចក្ដីនោះទើបពោលគាថាយ៉ាងនេះ ។ លោកពោលអធិប្បាយទុកដូច្នេះថា សត្វក្រៀលហើរទៅក្នុងអាកាសបាន មិនទើសទាក់ យ៉ាងណា បក្សីហង្សទាំងឡាយក៏យ៉ាងនោះ លុះកន្លងរដូវភ្លៀងហើយ តរុណហង្ស ២ ទម្លាយសំណាញ់ដែលពីងពាងធ្វើទុក ហើយហើរទៅ កាលនោះ ហង្សដទៃៗក៏ហើរទៅតាមផ្លូវដែលតរុណហង្សនោះទៅ ឥឡូវនេះ កូនរបស់អញ កាត់សំណាញ់ គឺកាមទៅហើយ ដូចតរុណហង្សកាត់សំណាញ់ពីងពាងទៅ ដូច្នោះ ឯអញក៏គួរទៅតាមផ្លូវដែលកូនទាំងនោះរបស់អញទៅហើយ ព្រោះហេតុនោះ ព្រាហ្មណី កាលទៅតាមការតាំងចិត្តនេះ ទើបពោលថា កូនទាំងឡាយផង ប្ដីផងរបស់អញ ( ទម្លាយមងគឺកាមហើយ ) ក៏ទៅ យ៉ាងនោះដែរ អញនោះ កាលបើដឹងច្បាស់ហើយ មិនទៅតាមដូចម្ដេចកើត ដូច្នេះ ។

ព្រាហ្មណីសម្រេចចិត្តថា កាលអញដឹងច្បាស់យ៉ាងនេះ អញមិនចេញបួសដូចម្តេចបាន អញនឹងបួសពិតប្រាកដ ដូច្នេះហើយ ទើបហៅព្រាហ្មណីទាំងឡាយមកប្រាប់ ហើយពោលថា នាងទាំងឡាយនឹងធ្វើដូចម្តេច ព្រាហ្មណីទាំងនោះពោលថា បពិត្រអ្នកនាង ចុះអ្នកនាងធ្វើដូចម្តេច ព្រាហ្មណីឆ្លើយថា យើងនឹងបួស ។ ព្រាហ្មណីនាំគ្នាពោលថា ពួកខ្ញុំក៏នឹងបួសដែរ ព្រាហ្មណីក៏លះភោគសម្បត្តិនោះ នាំបរិស័ទមានប្រមាណមួយយោជន៍ជាកំណត់ ទៅកាន់សម្នាក់នៃបុត្តរបស់ខ្លួននោះឯង ។ ហត្ថិបាលកុមារ អង្គុយលើអាកាសសម្តែងធម៌ដល់បរិស័ទទាំងនោះ ។ ស្អែកឡើង ព្រះរាជាត្រាស់សួររាជបុរសថា បុរោហិតទៅណា រាជបុរសក្រាបទូលថា បពិត្រព្រះអង្គ បុរោហិតនិងព្រាហ្មណីលះសម្បត្តិទាំងអស់ នាំបរិវាររបស់ខ្លួនមានប្រមាណ ២ យោជន៍ជាកំណត់ទៅកាន់សម្នាក់កូនប្រុសទាំង ៤ ហើយ ព្រះរាជាទ្រង់ព្រះតម្រិះថា ទ្រព្យសម្បត្តិដែលមិនមានម្ចាស់គ្រប់គ្រង រមែងធ្លាក់ជារបស់យើង ហើយត្រាស់ឲ្យរាជបុរសជញ្ជូនយកទ្រព្យសម្បត្តិអំពីផ្ទះបុរោហិតទាំងអស់ ។ ព្រះអគ្គមហេសីរបស់ព្រះរាជាត្រាស់សួររាជបុរសថា ព្រះរាជាទ្រង់ធ្វើអ្វី កាលរាជបុរសក្រាបទូលថា ព្រះរាជាត្រាស់ឲ្យជញ្ជូនទ្រព្យ មកអំពីផ្ទះរបស់បុរោហិត ទើបសួរថា បុរោហិតទៅណា លុះព្រះនាងបានស្តាប់ថា បុរោហិតមួយអន្លើដោយភរិយាចេញបួសហើយ ទើបព្រះនាងព្រះតម្រិះថា ព្រះស្វាមីរបស់យើងនេះវង្វេងដោយមោហាចរិត ឲ្យទៅជញ្ជូនយកទ្រព្យសម្បត្តិ ដែលដូចជាគប់ភ្លើងដែលព្រាហ្មណ៍បុរោហិតនិងព្រាហ្មណីនិងកូនទាំង ៤ របស់គេលះ

បន់ចោលដូចទឹកមាត់ដែលគេស្តោះចោលហើយ មកដាក់ក្នុងឃ្លាំង អញនឹងធ្វើឲ្យព្រះរាជាលះសម្បត្តិនោះ ដោយឧបមាប្រៀបធៀប ដូច្នេះហើយ ឲ្យមនុស្សជញ្ជូនយកសាច់ខ្លែនិងសាច់គោ មកគរទុកក្នុងលានព្រះរាជវាំង រៀបចំផ្លូវឲ្យត្រង់ហើយត្រាស់ឲ្យសន្ទឹងសំណាញ់ព័ទ្ធដោយជុំវិញ ត្មាតទាំងឡាយឃើញសាច់ពីចម្ងាយ ទើបបោះពួយមកដើម្បីស៊ីសាច់នោះ ។ ក្នុងចំនួនត្មាតទាំងនោះ ត្មាតដែលមានបញ្ញា ដឹងថា គេព័ទ្ធសំណាញ់ទុក គិតថា អញស៊ីសាច់ឆ្អែត ធ្ងន់កាយ មិនអាចហើរទៅត្រង់គឺហើរទៅលើបាន ទើបក្អួតសាច់ដែលខ្លួនស៊ីហើយចោល ហើយហើរទៅបាន មិនជាប់សំណាញ់ឡើយ ឯពួកត្មាតដែលល្ងង់ខ្លៅអាប់ឥតប្រាជ្ញា នាំគ្នាស៊ីសាច់ដែលត្មាតទាំងនោះ រើចោលហើយ រហូតដល់កាយធ្ងន់ មិនអាចហើរទៅត្រង់គឺហើរទៅលើបាន នាំគ្នាជាប់ក្នុងសំណាញ់ ។ រាជបុរសទាំងឡាយ ចាប់ត្មាតបានមួយ ហើយនាំមកថ្វាយព្រះទេវី ព្រះនាងក៏នាំត្មាតនោះទៅកាន់សម្នាក់ព្រះរាជា ទូលថា បពិត្រព្រះអង្គ សូមទ្រង់ទតកិរិយារបស់ត្មាតនេះត្រង់លានព្រះរាជវាំងចុះ ហើយបើកបង្អួចទូលថា បពិត្រមហារាជ សូមទ្រង់ទតត្មាតមួយហ្វូងនេះចុះ ហើយត្រាស់ ២ គាថា ដោយសេចក្តីថា

បក្សី ( ត្មាត ) ទាំងឡាយនេះ បរិភោគ ( នូវសាច់ ) ហើយ
ក្អួតចេញទើបហើរចៀសចេញទៅរួច ចំណែកខាងត្មាតទាំងឡាយ
ណាបរិភោគហើយមិនក្អួតចេញទេ ត្មាតទាំងនោះ មកលុះក្នុង
កណ្តាប់ដៃរបស់ខ្ញុំម្ចាស់ហើយ ។ ព្រាហ្មណ៍បានខ្ជាក់ចោលនូវ

កាមទាំងឡាយចេញហើយ ព្រះអង្គនោះត្រឡប់ជាលេបវិញ បពិត្រព្រះរាជា បុរសណា ស៊ីនូវកញ្ចក់ បុរសនោះ មិនគួរគេសរសើរទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភុត្វា វមិត្វា** ច សេចក្តីថា ស៊ីសាច់ហើយរើចេញ ។ បទថា **បច្ចាវមិស្សសិ** សេចក្តីថា បែរជាទទួលយកមកបរិភោគ ។ បទថា **វន្តាទោ** សេចក្តីថា បុគ្គលណាទំពាស៊ីនូវវត្ថុដែលអ្នកដទៃខ្ជាក់ចោលហើយ ។ បទថា **ន បសំសិយោ** សេចក្តីថា បុគ្គលនោះជា បុគ្គលល្ងង់ធ្លាក់នៅក្នុងអំណាចនៃតណ្ហា ជាបុគ្គលដែលបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម មិនគប្បីសរសើរ ។

ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់ព្រះទេវីហើយ ជាអ្នកមានវិប្បដិសារៈភពទាំង ៣ ប្រាកដដូចភ្លើងកំពុងឆេះ ទ្រង់សង្វេគក្នុងព្រះហឫទ័យ ពិចារណាថា អញគួរលះរាជសម្បត្តិ បួសក្នុងថ្ងៃនេះឯង កាលសរសើរព្រះទេវី ទើបត្រាស់ព្រះគាថានេះថា

បុរសអ្នកមានកម្លាំង អាចស្រង់នូវបុរសមានកម្លាំងខ្សោយ ដែលលិចក្នុងភក់ល្បាប់បាន យ៉ាងណា ម្នាលរាជធីតារបស់ព្រះបាទបញ្ចាលដ៏ចម្រើន នាងឯងក៏ញ៉ាំងយើងឲ្យឆ្លងឡើង ( ចាកកាម ) ដោយគាថាទាំងឡាយជាសុភាសិត យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្យសន្នំ** បានដល់ លិចចុះហើយ ។ បាឋៈថា **វិសន្នំ** ដូច្នេះក៏មាន ។ បទថា **ឧទ្ធរេយ្យ** សេចក្តីថា បុរសដែលមាន

កម្ចាំង ទាញបុរសខ្សោយកម្ចាំងត្រង់សក់ ឬត្រង់ដៃ ហើយអូសឡើងមក លើគោក ។ បទថា **ឧឌតារិ** សេចក្តីថា នាងក៏បានទាញយើងឲ្យផុតអំពី ភក់គឺកាម ។ បាឋៈថា **ឧឌតាសិ** ដូច្នេះក៏មាន ។ ឯសេចក្តី ក៏យ៉ាងនោះ ដូចគ្នា ។ បាឋៈថា **ឧទ្ធដាសិ** ក៏មានសេចក្តីថា លើកឡើងហើយ ។ បទថា **បញ្ចាលិ** បានដល់ ព្រះទេវីដែលជាព្រះរាជធីតារបស់ព្រះបាទបញ្ចាល ។

កាលព្រះបាទឯសុការីរាជ ត្រាស់យ៉ាងនេះហើយ ទ្រង់មានព្រះរាជបំណង នឹងបព្វជ្ជាមួយរំពេច ក្នុងខណៈនោះ ទើបត្រាស់ឲ្យហៅអាមាត្យទាំងឡាយ មកគាល់ ត្រាស់និទានរឿងឲ្យស្តាប់ ហើយសួរថា អ្នកទាំងឡាយនឹងធ្វើ ដូចម្តេច អាមាត្យទាំងឡាយក៏ក្រាបទូលថា បពិត្រព្រះអង្គ ចុះទ្រង់វិញ ព្រះ រាជាតបថា យើងនឹងបួសក្នុងសម្នាក់របស់ហត្ថិបាលកុមារ អាមាត្យទាំងនោះ ក៏ក្រាបទូលថា បពិត្រព្រះអង្គ ទូលព្រះបង្គំទាំងឡាយក៏នឹងបួស ព្រះបាទ ឯសុការីទ្រង់លះរាជសម្បត្តិក្នុងនគរពារាណសី ដែលមានអាណាខេត្ត ១២ យោជន៍ ទ្រង់ប្រកាសថា បុគ្គលណាមានសេចក្តីត្រូវការរាជសម្បត្តិ ចូរលើក ស្វេតច្ឆត្រឡើងគ្រងរាជ្យចុះ ហើយទ្រង់ចោមរោមដោយពួកអាមាត្យរាជបរិវារ នាំបរិស័ទមានប្រមាណ ៣ យោជន៍ជាកំណត់ យាងទៅកាន់សម្នាក់របស់ ហត្ថិបាលកុមារដូចគ្នា ហត្ថិបាលកុមារអង្គុយលើអាកាស សម្តែងធម៌ដល់ បរិស័ទនោះ ព្រះបរមសាស្តាកាលទ្រង់ប្រកាសភាពជាបព្វជិតរបស់ព្រះរាជា ទើបត្រាស់ព្រះគាថាដូច្នេះថា

មហារាជទ្រង់ព្រះនាមឯសុការី ជាម្ចាស់ក្នុងទិស ទ្រង់ត្រាស់

គាថានេះហើយ ទ្រង់លះបង់នូវដែនចេញទៅទ្រង់ព្រះផ្នួស ដូច
ជាដំរីដ៏ប្រសើរផ្តាច់នូវចំណងដូច្នោះ ។

ស្អែកឡើង មហាជនដ៏សេសក្នុងព្រះនគរប្រជុំគ្នា នាំគ្នាទៅកាន់ព្រះរាជវាំង ឲ្យក្រាបទូលដល់ព្រះរាជទេវី ហើយនាំគ្នាចូលទៅក្នុងព្រះរាជនិវេសន៍ ថ្វាយបង្គំព្រះទេវីហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ពោលគាថានេះថា

ព្រះរាជាមានព្យាយាមវិសេសជាងជន ទ្រង់សព្វព្រះរាជហ-
ឫទ័យចំពោះបព្វជ្ជា លះបង់នូវដែន ចំណែកខាងព្រះនាង សូម
ដូចជាព្រះរាជារបស់យើងចុះ ព្រះនាងដែលពួកយើងគ្រប់
គ្រងហើយ ចូរសោយរាជសម្បត្តិចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុសាស** សេចក្តីថា បពិត្រព្រះនាង ជាបុគ្គលដែលយើងខ្ញុំទាំងឡាយថ្វាយនូវការរក្សាហើយ សូមព្រះនាង សោយរាជសម្បត្តិដោយទសពិធរាជធម៌ចុះ ។

ព្រះរាជទេវី ស្តាប់ពាក្យរបស់មហាជនហើយ បានត្រាស់នូវព្រះគាថាដ៏សេសទាំងឡាយ ដូច្នេះថា

ព្រះរាជាមានព្យាយាមវិសេសជាងជន ទ្រង់សព្វព្រះរាជហឫ-
ទ័យចំពោះបព្វជ្ជា ទ្រង់លះបង់នូវដែន ចំណែកខាងខ្ញុំនឹងលះបង់
នូវកាមទាំងឡាយ ដែលញុំាងចិត្តឲ្យត្រេកអរចេញ ហើយជា
ស្រ្តីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ ព្រះរាជា មានព្យាយាម
វិសេសជាងជន ទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជា ទ្រង់លះ

បង់នូវដែន ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ តាម ចំណែកហើយ ជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ កាល ទាំងឡាយតែងកន្លងហួសទៅ រាត្រីទាំងឡាយតែងញ៉ាំង ( អាយុសង្ខារ ) ឲ្យច្រូងទៅ គំនរនៃវ័យទាំងឡាយ រមែងរលត់ទៅ តាមលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ ជា ទីញ៉ាំងចិត្តឲ្យត្រេកអរហើយជាស្ត្រីម្នាក់ឯងត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយរមែងកន្លងហួសទៅ រាត្រីទាំងឡាយរមែងញ៉ាំង ( អាយុសង្ខារ ) ឲ្យច្រូងទៅ គំនរនៃវ័យទាំងឡាយរមែងលះ បង់ទៅ ជាលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំង ឡាយតាមចំណែកហើយជាស្ត្រីម្នាក់ឯងត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយរមែង ញ៉ាំង ( អាយុសង្ខារ ) ឲ្យច្រូងទៅ គំនរនៃវ័យទាំងឡាយ រមែងលះបង់ទៅជាលំដាប់ ចំណែកខាងខ្ញុំ នឹងកន្លងបង់នូវ គ្រឿងជ្កក់ទាំងអស់ ហើយជាស្ត្រីត្រជាក់ម្នាក់ឯង ត្រាច់ទៅក្នុង លោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯកា** សេចក្តីថា យើងនឹងចៀសចេញអំពី កិលេសសម្ពាធៈ ( គ្រឿងចង្អៀតចង្អល់គឺកិលេស ) គឺបុត្តធីតា ជាបុគ្គល ម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ បទថា **កាមានិ** បានដល់ កាមគុណទាំង ឡាយ មានរូបជាដើម ។ បទថា **យថោធិកានិ** សេចក្តីថា កាមគុណទាំង

ឡាយ តាំងនៅដោយទូទៅណាៗ យើងនឹងលះបង់កាមគុណទាំងឡាយដែល តាំងនៅដោយចំណែកនោះៗ យ៉ាងនោះ គឺយើងមិនប៉ះពាល់អ្វីទៀតឡើយ ។ បទថា **អច្ចេន្តិ កាលា** សេចក្តីថា កាលទាំងឡាយ មានពេលព្រឹកជាដើម រមែងកន្លងទៅ ។ បទថា **តរយន្តិ** សេចក្តីថា រាត្រីរមែងកន្លងទៅ គឺមិនបាន កន្លងទៅទទេរមែងញ៉ាំងអាយុសង្ខារឲ្យអស់ទៅ ទំពាស៊ីនូវអាយុសង្ខារទៅ ។ បទថា **វយោគុណា** សេចក្តីថា វ័យទាំង ៣ មានបឋមវ័យជាដើមក្តី ចំណែក នៃពួក ១០ មានមន្ទទសកៈជាដើមក្តី រមែងលះលំដាប់ទៅ ។ បទថា **អនុ-ពុត្តំ ជហន្តិ** សេចក្តីថា មិនដល់កោដ្ឋាស គឺចំណែកដែលខ្ពស់ឡើងទៅៗ ឡើយ រមែងរលត់ទៅក្នុងចន្លោះនោះៗឯង ។

បទថា **សីតិភូតា** សេចក្តីថា សូម្បីខ្ញុំក៏នឹងលះកិលេសទាំងឡាយដែល ធ្វើនូវការក្តៅ គឺមានការក្តៅជាសភាវៈ ជាអ្នកត្រជាក់ ។ បទថា **សព្វមតិច្ច សង្គំ** សេចក្តីថា យើងនឹងឈានកន្លងកិលេសជាគ្រឿងជាប់ចំពាក់គ្រប់យ៉ាង មានកិលេសជាគ្រឿងជាប់ចំពាក់ គឺរាគៈជាដើម ហើយជាអ្នកត្រាច់ទៅម្នាក់ ឯង បានដល់ ទៅកាន់សម្នាក់នៃហត្ថិបាលកុមារ ហើយបួស ។

ព្រះទេវីសម្តែងធម៌ដល់មហាជន ដោយគាថាទាំងនេះ ដោយប្រការដូច្នេះ ហើយ មានព្រះរាជបញ្ជាឲ្យភរិយារបស់អាមាត្យមកគាល់ ហើយត្រាស់ថា ពួកនាងនឹងធ្វើដូចម្តេច ពួកភរិយារបស់អាមាត្យទាំងឡាយទូលសួរថា បពិត្រ ព្រះនាង ចុះព្រះនាងនឹងធ្វើដូចម្តេច ព្រះនាងត្រាស់ឆ្លើយថា យើងនឹងបួស ភរិយារបស់អាមាត្យក្រាបទូលថា សូម្បីពួកខ្ញុំម្ចាស់ក៏នឹងបួស ។ ព្រះទេវីមាន

សវនីយ៍ថា សាធុ ដូច្នេះហើយ មានព្រះតម្រាស់ឲ្យក្អាក់ងាររបើកទ្វារឃ្លាំង មាសជាដើមក្នុងព្រះរាជនិវេសន៍ ត្រាស់ឲ្យចារឹកក្រាំងមាសថា មហាកំណប់ កប់ទុកហើយក្នុងទីនោះខ្លះក្នុងទីនេះខ្លះ ហើយត្រាស់ថា អ្នកណាមានសេចក្តីត្រូវការ ក៏ចូរជញ្ជូនយកទ្រព្យដែលយើងព្រះរាជទានហើយនេះទៅចុះ ហើយឲ្យចងក្រាំងមាសព្យួរទុកត្រង់សសរធំ ឲ្យក្អាក់ងារគេវាយស្គរប្រកាសពេញព្រះនគរ ហើយព្រះនាងលះមហាសម្បត្តិ ចេញអំពីព្រះនគរ ។

សម័យនោះ អ្នកនគរក្តៅក្រហាយកោលាហលថា ព្រះរាជា និងព្រះទេវីទ្រង់លះរាជសម្បត្តិចេញបួសហើយ ពួកយើងនឹងធ្វើអ្វីក្នុងព្រះនគរនេះ ។ តាំងពីនោះមក មហាជនទាំងឡាយ ក៏លះគេហដ្ឋាន ទាំងដែលមានសម្បត្តិពេញបរិបូណ៌ ដឹកដៃកូន ដឹកដៃចៅចេញទៅ ។ ផ្ទះ រានផ្សារ មានទ្រព្យគរដេរដាស ដោយនិយាមដែលដាក់តម្រៀប មិនមានបុគ្គលណាម្នាក់ បែរមកមើលទៀតឡើយ ព្រះនគរទាំងមូលទទេចាកមនុស្សម្នា ។ ចំណែកព្រះទេវីទ្រង់នាំបរិវារប្រមាណ ៣ យោជន៍ជាកំណត់ ចេញទៅក្នុងសម្នាក់របស់ហត្ថិបាលកុមាររនោះឯង ហត្ថិបាលកុមារនោះ អង្គុយលើអាកាសសម្តែងធម៌ដល់បរិស័ទនោះហើយ នាំបរិស័ទមានប្រមាណ ១២ យោជន៍នោះ បែរមុខទៅកាន់ហិមវន្តប្បទេស ឯអ្នកនគរកាសិករដ្ឋក៏ល្បីរន្ទឺទៅថា បានឮថា ហត្ថិបាលកុមារ មួយអន្ទើដោយបរិស័ទ ១២ យោជន៍ ធ្វើនគរពារាណសីឲ្យទទេ នាំមហាជនទៅកាន់ហិមវន្តប្បទេស ដោយគិតថា នឹងបួស ពួកយើងនឹងនៅធ្វើអ្វីក្នុងនគរនេះ ក្នុងកាលតមក បរិស័ទក៏កើនឡើងប្រមាណដល់ទៅ ៣០

យោជន៍ ហត្ថិបាលកុមារ ក៏ទៅកាន់ព្រៃហិមពាន្ត មួយអន្លើដោយបរិស័ទនោះ ។ សក្កទេវរាជទ្រង់ប្រមើលមើលនូវព្រឹត្តិហេតុនោះ ហើយទ្រង់ព្រះតម្រិះថា ហត្ថិបាលកុមារចេញមហាភិនេស្រ្កមណ៍ហើយ ដោយសមាគមធំក្រៃលែង គួរបរិស័ទទាំងឡាយបានទីលំនៅ ទើបទ្រង់ត្រាស់នឹងវិស្សុកម្មទេវបុត្តថា វិស្សុកម្មទេវបុត្ត ចូរអ្នកទៅនិម្មិតអាស្រមបណ្តោយ ៣៦ យោជន៍ ទទឹង ១៥ យោជន៍ ហើយចាត់ចែងបរិក្ខាររបស់បព្វជិតទុកឲ្យបរិបូណ៌ ។ វិស្សុកម្មទេវបុត្តទទួលទេវបញ្ជាហើយ ក៏ទៅនិម្មិតអាស្រម បណ្តោយទទឹងតាមទេវបញ្ជា ទុកក្នុងភូមិភាគដែលគួរជាទីត្រេកអរ ក្បែរឆ្នេរស្ទឹងគង្គា តែងតាំងអាសនៈ មានអាសនៈដែលក្រាលដោយកំណាត់ឈើ និងស្លឹកឈើជាដើមទុក រួចនិម្មិតបព្វជិតបរិក្ខារទាំងអស់ ទុកក្នុងបណ្ណសាលា ត្រង់ទ្វារបណ្ណសាលាមួយៗ និម្មិតទីចង្ក្រមទុកមួយកន្លែងមួយៗ មានទីសម្រាកពេលយប់និងទីសម្រាកពេលថ្ងៃ ខណ្ឌចែកដោយឡែកៗ មានបន្ទះក្តារសម្រាប់ផ្អែក បូកលាបដោយបាយអស្អាតបាត ក្នុងទីគ្រប់កន្លែង មានគុម្ពផ្កាសុរភី និងផ្កាកុសមៈ ក្នុងសួនមានច្រើនពណ៌ ក្នុងទីបំផុតនៃគុម្ពផ្កានីមួយៗនិម្មិតអណ្តូងទឹកមួយៗពេញទៅដោយទឹក ក្នុងទីមិនឆ្ងាយអំពីអណ្តូងនោះ និម្មិតដើមឈើដែលមានផ្លែមួយដើមៗ ដើមឈើមួយដើមៗ មានផ្លែជ្រុះដល់គ្នា ទាំងអស់នេះបានសម្រេចឡើងដោយទេវានុភាព ។ វិស្សុកម្មទេវបុត្ត កាលនិម្មិតអាស្រមដ្ឋានរៀបចំបព្វជិតបរិក្ខារទុកក្នុងបណ្ណសាលាស្រេចហើយ ទើបយកហិង្គុលជាតិរចនាអក្សរត្រង់ជញ្ជាំងថា នរណាមានបំណងចង់បួស ចូរកាន់យកបរិក្ខារ

ទាំងនេះចុះ ហើយដេញពួកម្រឹគ បក្សី ដែលមានសំឡេងគួរខ្លាច និងពួកអមនុស្សដែលមានរូបអាក្រក់ឲ្យគេចទៅក្នុងទីឆ្ងាយ ដោយអានុភាពរបស់ខ្លួន ហើយត្រឡប់ទៅកាន់ទិព្វវិមានរបស់ខ្លួនវិញ ។

ហត្ថិបាលកុមារចូលទៅកាន់អាស្រម ដែលសក្កៈប្រទាន ដោយផ្លូវចរទៅចំពោះខ្លួនម្នាក់ឯងមុន ឃើញអក្សរដែលចារឹកទុក ហើយត្រិះរិះថា សក្កទេវរាជ ទ្រង់ប្រហែលជាជ្រាបការដែលអញចេញមហាភិនេស្រ្កមណ៍ ដូច្នេះហើយ ទើបបើកទ្វារចូលទៅកាន់បណ្ណសាលា បួសជាឥសី ហើយចេញកាន់ទីចង្រ្កម ដើរចង្រ្កមទៅមក ២-៣ វារៈហើយ ញុំាងពួកជនដ៏សេសឲ្យបព្វជ្ជា ពិនិត្យមើលអាស្រមទូទៅ ឲ្យបណ្ណសាលាដល់ស្រ្តី ដែលមានកូនខ្ចី ត្រង់កណ្តាល បន្ទាប់ពីនោះ ដល់ស្ត្រីជរា បន្ទាប់មកឲ្យដល់ស្ត្រីដែលមានវ័យកណ្តាល ខាងក្រៅបំផុត ឲ្យដល់បុរសទាំងឡាយដោយជុំវិញ ។

គ្រានោះ មានព្រះរាជាមួយអង្គជ្រាបថា ក្នុងនគរពារាណសី មិនមានព្រះរាជាប្រថាប់នៅ ទើបយាងមកពិនិត្យមើលនគរដែលប្រដាប់តាក់តែងទុកល្អហើយ ទ្រង់ឡើងកាន់ព្រះរាជនិវេសន៍ ទតគំនររតនៈក្នុងទីនោះៗ ទ្រង់ព្រះតម្រិះថា តាំងពីគ្រាដែលស្តេចក្រុងពារាណសីទ្រង់លះនគរបែបនេះ ចេញបួស ប្រហែលជាបព្វជ្ជានេះ ជារបស់មានគុណគាប់ឧឡារក្រៃលែង ហើយត្រាស់សួរផ្លូវនឹងពួកអ្នកលេងសុរា យាងទៅកាន់សម្នាក់របស់ហត្ថិបាលតាបស ហត្ថិបាលតាបសជ្រាបថា ព្រះរាជាអង្គនោះយាងមកដល់ដងព្រៃ ទើបធ្វើដំណើរបញ្ច្រាសផ្លូវមកទទួល អង្គុយក្នុងអាកាសសម្តែងធម៌ដល់បរិស័ទ

ហើយនាំទៅកាន់អាស្រមបទ ឲ្យបរិស័ទទាំងអស់បព្វជ្ជា ព្រះរាជាជទៃទ្រង់ចេញបព្វជ្ជា ដោយឧបាយនេះ អស់ ៦ អង្គ រួមព្រះរាជានិងភោគសម្បត្តិ ឥស្សរិយយសសម្បត្តិចេញបួសជា ៧ អង្គ អាស្រមមានបរិមណ្ឌល ៣៦ យោជន៍ ពេញបរិបូណ៌ មិនមានទីទំនេរ ។ តាបសណាមានវិតក្កឯណានីមួយ មានកាមវិតក្កជាដើម ហត្ថិបាលតាបសដែលជាមហាបុរស ក៏សម្តែងធម៌ដល់តាបសនោះ ប្រាប់ឲ្យចម្រើនព្រហ្មវិហារភាវនា កសិណភាវនា តាបសទាំងនោះ ញុំាងឈាននិងអភិញ្ញាឲ្យកើតហើយដោយច្រើន ក្នុង ៣ ចំណែក ទៅកើតក្នុងព្រហ្មលោក ២ ចំណែក ។ ចំណែកដែលសល់ចែកជា ៣ ប្រភេទ ១ ចំណែកកើតក្នុងព្រហ្មលោក ១ ចំណែកកើតក្នុងឆកាមាវចរសួគ៌ ១ ចំណែកធ្វើការបម្រើដល់ឥសីទាំងឡាយ កើតក្នុងកុលសម្បត្តិ ៣ គឺក្សត្រ ព្រាហ្មណ៍ គហបតីក្នុងមនុស្សលោក ។ ពាក្យប្រៀនប្រដៅរបស់ហត្ថិបាលតាបសធ្វើឲ្យមហាជនប្រាសចាកទុគ្គតិ គឺ នរក តិរច្ឆាន បិត្តិវិស័យ និងអសុរកាយ ដោយប្រការដូច្នេះ ។

សមាគមរបស់កុទ្ទាលបណ្ឌិត សមាគមរបស់មូគផក្ខមហាបុរស សមាគមរបស់ចូឡសុត្តសោមមហាបុរស សមាគមរបស់អយោឃរបណ្ឌិត និងសមាគមរបស់ហត្ថិបាលតាបស មានសភាពដូចគ្នា មួយអន្លើដោយបព្វជ្ជាខាងក្រោយគេបង្អស់ក្នុងលង្កាទ្វីបនេះ គឺ ព្រះបឋវិចាលកធម្មគុត្តត្ថេរ ព្រះផុស្សទេវត្ថេរ អ្នកនៅក្នុងកតកណ្ឌការវិហារ និងព្រះមហាសង្ឃរក្ខិតត្ថេរ និងព្រះមនយមហាទេវត្ថេរ ដែលនៅក្នុងឧបរិមណ្ឌលវិហារ ព្រះមហាសិវត្ថេរ

ដែលនៅក្នុងគាមន្តបព្ភារវិហារ ព្រះមហានាគត្ថេរ អ្នកនៅក្នុងកាឡវល្លិ-មណ្ឌបវិហារ[១] ( សមាគមទាំងអស់នេះ ក៏មានសភាពដូចគ្នា ) សមដូចព្រះសាស្តាត្រាស់ទុក ( ក្នុងធម្មបទ ) ថា

បុគ្គល គួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា ការបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ដូច្នេះ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនាមកនេះ មកសម្តែងហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏ចេញមហាភិនេស្រ្កមណ៍យ៉ាងនេះដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ស្តេចឯសុការីក្នុងកាលនោះ បានមកជាព្រះបាទសុទ្ធោទនមហារាជក្នុងកាលឥឡូវនេះ ព្រះទេវីក្នុងកាលនោះ បានមកជាព្រះនាងមហាមាយា បុរោហិតក្នុងកាលនោះ បានមកជាកស្សបៈ ព្រាហ្មណីក្នុងកាលនោះ បានមកជាភទ្ទកាបិលានី អជ-បាលកុមារក្នុងកាលនោះ បានមកជាអនុរុទ្ធ គោបាលកុមារក្នុងកាលនោះបានមកជាមោគ្គល្លាន អស្សបាលកុមារក្នុងកាលនោះ បានមកជាសារីបុត្ត បរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ចំណែកហត្ថិបាលកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ហត្ថិបាលជាតក ចប់

---

១-ឈ្មោះរបស់ព្រះថេរៈ ក្តីឈ្មោះទីកន្លែងក្តី មានសភាពខុសគ្នាក្នុងទីមកផ្សេងៗ បណ្ឌិតគប្បីកាន់ យកតាមការគួរ ។

# អយោឃរជាតក

[ ៣៩០ ] ( អយោឃរកុមារពោធិសត្វ... ) សត្វនៅក្នុងគភ៌ អស់រាត្រីណាមួយជាដំបូង សត្វនោះប្រព្រឹត្តទៅដូចជាពពកដែលតាំងឡើង សត្វនោះកាលទៅរមែងមិនត្រឡប់វិញទេ ។

[ ៣៩១ ] មិនមែនពួកនរៈកាលច្បាំង មិនមែនពួកនរៈ បរិបូណ៌ដោយកម្លាំង មិនគ្រាំគ្រា មិនស្លាប់ទេ ព្រោះថា បាណមណ្ឌលទាំងអស់នោះ គឺជាតិនិងជរា តែងចូលទៅជិតបៀតបៀន ហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩២ ] ព្រះរាជាទាំងឡាយ ជារដ្ឋាធិបតី គ្របសង្កត់នូវសេនាប្រកបដោយអង្គ ៤ ជាសេនាមានសភាពគួរខ្លាចក្រៃពេក រមែងឈ្នះបាន ប៉ុន្តែមិនអាចឈ្នះនូវសេចក្ដីស្លាប់បាន ព្រោះហេតុនោះ គំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩៣ ] ព្រះរាជាទាំងឡាយអង្គខ្លះ ដែលមានពលដំរី ពលសេះ ពលរថ ពលថ្មើរជើងចោមរោមហើយ រួច ( អំពីកណ្ដាប់ដៃពួកបច្ចាមិត្ត ) បាន ប៉ុន្តែមិនអាចរួចចាកសេចក្ដីស្លាប់បាន ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩៤ ] ព្រះរាជាទាំងឡាយក្លៀវក្លា រមែង ( ញុំាងនគរទាំងឡាយរបស់ពួកស្ដេចជាបច្ចាមិត្ត ) ឲ្យខ្ទេចខ្ទី ឲ្យខ្ចាត់ខ្ចាយ ដោយពលដំរី ពលសេះ ពលរថ ពលថ្មើរជើងបាន ប៉ុន្តែមិនអាចកម្ទេចនូវមច្ចុបានទេ ព្រោះ

ហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩៥ ] ដំរីទាំងឡាយចុះប្រេង មានប្រេងធ្លាយហូរហៀរ តែងញុំាញីនូវនគរទាំងឡាយ សម្លាប់នូវជនបាន ប៉ុន្តែមិនអាចញុំាញីនូវសេចក្តីស្លាប់បានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩៦ ] ខ្មាន់ធ្នូទាំងឡាយ ទុកជាមានដៃហាត់ហើយ ជាអ្នកក្លៀវក្លាអាចញុំាងព្រួញឲ្យធ្លាក់ក្នុងទីឆ្ងាយបាន បាញ់មិនខុស ក៏មិនអាចបាញ់នូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩៧ ] ទឹកស្រះទាំងឡាយរមែងអស់ទៅ ផែនដីព្រមទាំងភ្នំនិងជងព្រៃ រមែងអស់ទៅ វត្ថុដែលប្រព្រឹត្តទៅក្នុងអំណាចនៃសង្ខារទាំងអស់នោះក៏រមែងអស់ទៅក្នុងចន្លោះនៃកាលដ៏វែង ដ្បិតថាវត្ថុទាំងអស់នោះ គប្បីបាក់បែកក្នុងកំណត់កាលជាទីវិនាស ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩៨ ] ជីវិតរបស់នារីនិងនរៈក្នុងលោកនេះទាំងអស់ តែងប្រែប្រួលដូចជាសំពត់របស់អ្នកលេង ដូចឈើដុះក្បែរច្រាំង យ៉ាងនោះដែរ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៣៩៩ ] ផ្លែឈើទាំងឡាយ ( រមែងជ្រុះចុះ ) យ៉ាងណា មាណព

ទាំងឡាយ ទាំងក្មេង ទាំងចាស់ ទាំងស្រី ទាំងប្រុស ទាំងមជ្ឈិមបុរស ( បណ្ឌកនិងខកតោព្យញ្ជនក ) រមែងមានសរីរៈបែកធ្លាយជ្រុះចុះ ( យ៉ាងនោះ ) ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០០ ] វ័យនេះមិនដូចស្តេចផ្កាយ ( ព្រះចន្ទ ) ទេ វ័យណាកន្លងទៅហើយ ឥឡូវនេះវ័យនោះ ទៀងតែទៅមែនពិត បុគ្គលចាស់ឥតមានតម្រេក ( ក្នុងកាមគុណ ) សុខនឹង ( មាន ) មកពីណា ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០១ ] ពួកយក្ខ បិសាចឬប្រេតទាំងនោះខឹងហើយ រមែងផ្ទុំសម្លាប់នូវពួកមនុស្ស ប៉ុន្តែមិនអាចផ្ទុំសម្លាប់នូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០២ ] មនុស្សទាំងឡាយរមែងធ្វើនូវការអង្វរចំពោះពួកយក្ខ ពួកបិសាច ឬពួកប្រេត ដែលខឹងហើយនោះបាន ប៉ុន្តែមិនអាចអង្វរមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០៣ ] ព្រះរាជាទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវទោស ហើយដាក់អាជ្ញាចំពោះពួកជនអ្នកមានកំហុស អ្នកប្រទូស និងអ្នកបៀតបៀនបាន ប៉ុន្តែមិនអាចដាក់អាជ្ញាដល់មច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថាអញនឹងប្រព្រឹត្តធម៌ ។

[ ៤០៤ ] ពួកជនអ្នកមានកំហុស អ្នកប្រទូស្ត អ្នកបៀតបៀន តែងអង្វរ-ករ ព្រះរាជាទាំងឡាយនោះបាន ប៉ុន្តែធ្វើនូវកិរិយាអង្វរករមច្ចុពុំបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០៥ ] មិនថាក្សត្រ មិនថាព្រាហ្មណ៍ មិនថាអ្នកស្តុកស្តម្ភ អ្នកមានកម្លាំង អ្នកមានតេជះទេ សេចក្តីយល់មុខរបស់មច្ចុរាជ មិនមានឡើយព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០៦ ] ខ្លាធំទាំងខ្លាដំបង តែងគំរាមនូវជនដែលកំពុងញាប់ញ័រហើយទំពាស៊ីបាន ប៉ុន្តែមិនអាចទំពាស៊ីនូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០៧ ] ពួកជនអ្នកធ្វើមាយា ( អ្នកលេងកល ) កាលធ្វើ ( នូវមាយា ) ក្នុងទីពាក់កណ្តាលរង្គ រមែងធ្វើនូវភ្នែកទាំងឡាយរបស់ជនឲ្យកាន់ប្រឡំបានដោយពិត ប៉ុន្តែមិនអាចញុំាងមច្ចុឲ្យកាន់ប្រឡំបានឡើយ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០៨ ] សត្វអាសិរពិសទាំងឡាយ មានតេជះដ៏ក្លាខ្លាំង ខឹង ហើយរមែងចឹកសម្លាប់នូវមនុស្សទាំងឡាយនោះក៏បាន ប៉ុន្តែមិនអាចចឹកនូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤០៩ ] សត្វអាសិរពិសទាំងឡាយក្រោធហើយចឹកនរណា ពួកពេទ្យអ្នករក្សា រមែងកម្ចាត់នូវពិសនៃសត្វអាសិរពិសទាំងនោះបាន ប៉ុន្តែកម្ចាត់នូវពិសដែលមច្ចុចឹកហើយពុំបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤១០ ] ពេទ្យទាំងឡាយឈ្មោះធម្មន្តរី ១ វេត្តរុណា ១ ភោជៈ ១ សម្លាប់នូវពិសទាំងឡាយនៃភុជង្គ ( នាគ ) បាន ពួកពេទ្យទាំងនោះ គេឮថា ធ្វើមរណកាលទៅហើយដូចគ្នាដែរ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថាអញនឹងប្រព្រឹត្តធម៌ ។

[ ៤១១ ] ពួកវិជ្ជាធររៀននូវឃោរវិជ្ជា រមែងដល់នូវការកំបាំងខ្លួនដោយថ្នាំទាំងឡាយបាន ប៉ុន្តែមិនដល់នូវការបំបាំងមច្ចុរាជបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

[ ៤១២ ] ធម៌រមែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលប្រព្រឹត្តដោយល្អហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលប្រព្រឹត្តដោយល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

[ ៤១៣ ] សភាវៈទាំងឡាយពីរ គឺធម៌ ១ អធម៌ ១ មិនមែនមានផលស្មើគ្នាទេ អធម៌នាំសត្វទៅកាន់នរក ធម៌ញុំាងសត្វឲ្យដល់នូវសុគតិ ។

**ចប់ អយោឃរជាតក ទី ១៤ ។**

## ឧទ្ទាននៃវីសតិនិបាតនោះគឺ

មាតង្គជាតក ១ ចិត្តសម្ភូតជាតក ១ សីវិរាជជាតក ១ សិរិមន្ទ-ជាតក ១ រោហនមិគជាតក ១ ហង្សជាតក ១ សត្តិគុម្ពជាតក ១ ភល្លាតិយជាតក ១ សោមនស្សជាតក ១ ចម្ពេយ្យជាតក ១ មហាបលោភនជាតក ១ បញ្ចបណ្ឌិតជាតក ១ ហត្ថិបាល-ជាតក ១ អយោឃរជាតក ១ ។

## ចប់ វីសតិនិបាត ។

# អដ្ឋកថា

## អយោឃរជាតក

[ ៣៩០-៤១៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការចេញមហាភិនេស្រ្កមណ៍នោះឯង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យមេករត្តឹ បឋមំ** ដូច្នេះជាដើម ។

ពិតហើយ ក្នុងកាលនោះ ព្រះមានព្រះភាគក៏ត្រាស់ថា មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ធ្លាប់ចេញមហាភិនេស្រ្កមណ៍ដូចគ្នា ហើយទ្រង់នាំរឿងក្នុងអតីតមកដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះអគ្គមហេសីរបស់ទ្រង់មានគភ៌ បានទទួលការបរិហារគភ៌យ៉ាងល្អ រហូតគ្រប់ខែហើយ ប្រសូតព្រះរាជឱរសក្នុងបច្ចូសសម័យនៃរាត្រីជិតភ្លឺ ។

ក្នុងភពមុន មានស្រ្តីរួមប្តីម្នាក់ជាមួយព្រះទេវីនោះ តាំងសេចក្តីប្រាថ្នាថា សូមឲ្យយើងបានស៊ីកូនរបស់នាងដែលប្រសូតហើយ ។ បានឮថា ស្រីនោះខ្លួនឯងជាស្រីអារ ធ្វើនូវការប្រាថ្នាបែបនោះ ព្រោះក្រោធនឹងស្រ្តីដែលមានកូនហើយកើត ក្នុងកំណើតយក្ខិនី ស្រ្តីដែលមានបុត្តនោះ បានជាអគ្គមហេសីរបស់ព្រះបាទព្រហ្មទត្ត ប្រសូតព្រះរាជឱរសអង្គនេះ ។ កាលនោះ យក្ខិនីបានឱកាស ទើបកាឡាខ្លួនមក កាលព្រះទេវីកំពុងទតនោះឯង ស្ទុះចូលទៅចាប់ទារកនោះ ហើយគេចទៅ ។ ព្រះទេវី ស្រែកដោយសំឡេងខ្លាំងថា យក្ខិនីយកកូនយើងទៅហើយ ។ ឯយក្ខិនីក៏ទំពាទារកឮសំឡេង មុរ មុរ ដូចស៊ីក្រអៅឈូក សម្តែងអាកប្បកិរិយាលើកដៃចង្អុលមុខគំរាមព្រះទេវី ហើយ

គេចទៅ ។ ព្រះរាជា ទ្រង់ស្តាប់ព្រះសវនីយ៍របស់ព្រះទេវីហើយ ទ្រង់ព្រះតម្រិះថា ធ្វើម្តេចហ្ន៎ទើបការពារយក្ខិនីបាន តែទ្រង់នៅស្ងៀម ។ ក្នុងកាលព្រះទេវីប្រសូតព្រះរាជឱរសអង្គទី ២ ព្រះរាជាបានធ្វើនូវការរក្សាយ៉ាងមាំទាំ យក្ខិនីក៏មកទំពាព្រះរាជកុមារនោះ ហើយគេចចេញទៅទៀត ។ ក្នុងវារៈទី ៣ ព្រះមហាសត្វទ្រង់បដិសន្ធិក្នុងព្រះឧទររបស់ព្រះទេវី ព្រះរាជាមានព្រះរាជឱង្ការឲ្យមហាជនមកប្រជុំគ្នា ត្រាស់សួរថា យក្ខិនីមួយ មកស៊ីឱរសដែលប្រសូតអំពីព្រះទេវីរបស់យើងរាល់លើក គួរចាត់ការបែបណា ។ គ្រានោះបុរសម្នាក់ក្រាបទូលថា បពិត្រមហារាជ ធម្មតាយក្ខិនី រមែងខ្លាចស្លឹកត្នោត គួរចងស្លឹកត្នោតត្រង់ព្រះហស្តនិងត្រង់ព្រះបាទទាំង ២ របស់ព្រះទេវី បុរសម្នាក់ទៀតទូលថា បពិត្រមហារាជ ធម្មតាយក្ខិនី រមែងខ្លាចផ្ទះដែក គួរធ្វើផ្ទះដែកទុក ។ ព្រះរាជាត្រាស់ថា សាធុ ហើយត្រាស់ឲ្យជាងដែកទាំងឡាយក្នុងដែនរបស់ព្រះអង្គមកប្រជុំគ្នា ទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរធ្វើផ្ទះដែកឲ្យយើង ហើយឲ្យរាជបុរសមើលការខុសត្រូវ ។ ជាងដែកទាំងឡាយ ក៏ធ្វើព្រះដំណាក់ឡើងក្នុងភូមិភាគដែលគួរជាទីត្រេកអរក្នុងព្រះនគរនោះឯង ។ សម្ភារៈព្រះរាជដំណាក់គ្រប់យ៉ាង តាំងអំពីសសរជាដើម សម្រេចហើយដោយដែកទាំងអស់ ព្រះរាជដំណាក់មានមុខ ៤ សម្រេចហើយដោយដែក ក្នុងរយៈកាល ៩ ខែ ។ ព្រះដំណាក់នោះល្អរុងរឿង ដូចគ្នានឹងពន្លឺប្រទីបដែលឆេះជានិច្ច ។ ព្រះរាជាទ្រង់ជ្រាបថាព្រះរាជទេវីមានគភ៌ចាស់ហើយ ទើបឲ្យប្រដាប់តាក់តែងព្រះដំណាក់ដែក នាំព្រះទេវីទៅប្រថាប់ក្នុងដំណាក់នោះ ព្រះទេវី ក៏

ប្រសូតព្រះរាជឱរសសម្បូរដោយធញ្ញបុញ្ញលក្ខណៈ ក្នុងព្រះដំណាក់ដែកនោះ ។ ព្រះរាជា និងអគ្គមហេសី ទ្រង់ព្រះរាជទានព្រះនាមព្រះឱរសថា អយោឃរកុមារ ។ ព្រះរាជាទ្រង់ប្រគល់ព្រះរាជកុមារដល់កីលៀង ហើយទ្រង់ចាត់ចែងការរក្សាតឹងរ៉ឹងក្រៃលែង នាំព្រះទេវីធ្វើប្រទក្សិណប្រពាតព្រះនគរ ហើយទ្រង់ឡើងកាន់ប្រាសាទដែលប្រដាប់ហើយ ។ ឯយក្ខិនីដល់វេនដងទឹក នាំទឹកទៅថ្វាយព្រះបាទវេស្សវណ ដល់នូវការអស់ជីវិតហើយ ។

ព្រះមហាសត្វ កាលទ្រង់ចម្រើនក្នុងព្រះដំណាក់ដែកនោះឯង រហូតធំដឹងក្តី ទ្រង់សិក្សាសិប្បវិជ្ជាគ្រប់យ៉ាងក្នុងទីនោះឯង ។ ព្រះរាជាត្រាស់សួរពួកអាមាត្យថា ឱរសរបស់យើងមានវស្សាប៉ុន្មានហើយ ទ្រង់ឮថា ព្រះរាជឱរសមានវស្សា ១៦ សម្បូរដោយកម្លាំងពលំ និងអនាម័យ អាចប្រយុទ្ធជាមួយយក្ខបានសូម្បីរាប់ពាន់ ទើបមានព្រះរាជឱង្ការថា យើងនឹងប្រគល់រាជសម្បត្តិដល់ឱរសរបស់យើង អ្នកទាំងឡាយចូររៀបចំតាក់តែងព្រះនគរ ហើយហៅព្រះឱរសអំពីដំណាក់ដែកមកកាន់ព្រះរាជដ្ឋាន ។ អាមាត្យទាំងឡាយ ទទួលនូវព្រះរាជឱង្ការថា សាធុ ហើយឲ្យក្នាក់ងារតាក់តែងព្រះនគរពារាណសីដែលមានបរិមណ្ឌល ១២ យោជន៍ ស្រេចហើយ នាំមង្គលហត្ថី ដែលតាក់តែងដោយអលង្ការសព្វយ៉ាងទៅកាន់ព្រះដំណាក់ដែកនោះ ប្រដាប់តាក់តែងព្រះរាជកុមារ យាងឲ្យប្រថាប់លើមង្គលហត្ថី ហើយទូលថា បពិត្រព្រះរាជកុមារ សូមទ្រង់ធ្វើប្រក្សិណព្រះនគរដែលប្រដាប់ហើយ ដែលជាមត៌កនៃរាជត្រកូល ហើយយាងទៅថ្វាយបង្គំព្រះបាទកាសិករាជដែលជាបិតា ហើយទូលថា ទ្រង់

នឹងបានស្ងួតបួត្រក្នុងថ្ងៃនេះឯង ។ កាលព្រះមហាសត្វធ្វើនូវការប្រទក្សិណព្រះនគរ ទតឃើញព្រះរាជឧទ្យាន ដងព្រៃ ស្រះបោក្ខរណី ទឹកដីនិងប្រាសាទដ៏គួរត្រេកអរជាដើមហើយ ទ្រង់ចិន្តនាការថា ព្រះរាជបិតារបស់យើងឲ្យយើងនៅក្នុងគុកអស់កាលមានប្រមាណប៉ុណ្ណេះ មិនឲ្យយើងបានឃើញព្រះនគរដែលល្អត្រកាលបែបនេះទេ ទោសកំហុសរបស់យើង មានដូចម្តេចហ្ន៎ ដូច្នេះហើយ ទើបត្រាស់សួរពួកអាមាត្យ ។ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះរាជកុមារទ្រទ្រង់គុណដ៏ប្រសើរ ទោសកំហុសរបស់ព្រះអង្គមិនមានឡើយ តែយក្ខិនីមួយរូប មកទំពាស៊ីព្រះជេដ្ឋាធិរាជរបស់ទ្រង់ដល់ទៅ ២ អង្គ ព្រោះហេតុនោះទើបព្រះរាជបិតារបស់ទ្រង់ ឲ្យទ្រង់នៅក្នុងដំណាក់ដែក ទ្រង់រួចជីវិតមកបាន ព្រោះព្រះដំណាក់ដែកពិតៗ ។ អយោឃរាជកុមារទ្រង់ស្តាប់ពាក្យរបស់អមាត្យក្រាបទូលហើយ ទ្រង់ព្រះតម្រិះថា អញនៅក្នុងព្រះឧទររបស់ព្រះមាតា ១០ ខែ ដូចនៅក្នុងលោហកុម្ភីនរក និងគូថនរក លុះប្រសូតចាកព្រះឧទរព្រះមាតាហើយ ត្រូវមកនៅក្នុងពន្ធនាគារអស់ ១៦ ឆ្នាំ មិនបានឱកាសមើលទីបលោកខាងក្រៅឡើយ ដូចធ្លាក់ក្នុងឧស្សទនរកដូច្នោះ អញរួចអំពីក្រញាំដៃរបស់យក្ខិនីមកបាន មិនមែនមិនចាស់ មិនស្លាប់នោះទេ ប្រយោជន៍អ្វីដោយរាជសម្បត្តិដល់អញ បើអញតាំងនៅក្នុងរាជសម្បត្តិហើយ នឹងចេញបព្វជ្ជាបានលំបាក អញនឹងឲ្យព្រះរាជបិតាអនុញ្ញាតការបួសដល់អញ ហើយចូលទៅកាន់ព្រៃហិមពាន្ត បួសក្នុងថ្ងៃនេះឯង ។ កាលព្រះរាជកុមារទ្រង់ធ្វើប្រទក្សិណព្រះនគរហើយយាងចូលទៅកាន់ព្រះរាជត្រកូល ថ្វាយបង្គំ

ព្រះរាជបិតាហើយ ប្រថាប់ឈរ ព្រះបាទព្រហ្មទត្តទតសិរីសោភារបស់ព្រះរាជឱរសហើយ ទ្រង់ស្នេហាក្រៃពេក ទើបទ្រង់ធ្មៀងមើលពួកអាមាត្យ ពួកអាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ឲ្យពួកទូលបង្គំ ចាត់ចែងដូចម្តេច ។ ទើបព្រះរាជាត្រាស់ថា អ្នកទាំងឡាយចូរយាងព្រះរាជឱរសរបស់យើងឲ្យប្រថាប់លើគំនររតនៈ ហើយស្រេពស្រង់ដោយទឹកស័ង្ខ ៣ យ៉ាងហើយពាក់នូវកញ្ចនមាលា លើកស្វេតច្ឆត្រឡើង ។ ព្រះមហាសត្វ ក៏ថ្វាយបង្គំព្រះរាជបិតាទូលជំទាស់ថា ទូលព្រះបង្គំមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិទេ ទូលព្រះបង្គំនឹងបួស សូមទ្រង់អនុញ្ញាតឲ្យទូលព្រះបង្គំបួសចុះ ព្រះបាទព្រហ្មទត្តត្រាស់ថា នៃកូនសម្លាញ់ ឯងលះបង់រាជសម្បត្តិ ហើយនឹងបួស ព្រោះហេតុអ្វី ព្រះមហាសត្វទូលថា បពិត្រព្រះបិតា ទ្រទ្រង់គុណដ៏ប្រសើរ ទូលព្រះបង្គំនៅក្នុងផ្ទៃព្រះមាតា ១០ ខែ ដូចនៅក្នុងគូថនរកប្រសូត ចាកព្រះផ្ទៃហើយ នៅក្នុងពន្ធនាគារអស់ ១៦ ឆ្នាំ មិនបានឃើញលោកសន្និវាសខាងក្រៅ ព្រោះភ័យដែលកើតអំពីយក្ខិនី ដូចធ្លាក់នៅក្នុងឧស្សទនរក តែទោះជាផុតកណ្តាប់ដៃរបស់យក្ខិនីហើយ មិនមែនទូលព្រះបង្គំមិនចាស់មិនស្លាប់ឡើយ ឈ្មោះថាមច្ចុរាជនេះ បុគ្គលណាម្នាក់ មិនអាចឈ្នះមិនអាចរំលងបានទេ ទូលព្រះបង្គំខ្លាចរអាក្នុងភព ទូលព្រះបង្គំនឹងបួសប្រព្រឹត្តធម៌ ទាន់ជរា ព្យាធិនិងមរណៈមិនទាន់មកដល់ ទូលព្រះបង្គំមិនប្រាថ្នារាជសម្បត្តិ សូមព្រះរាជបិតាទ្រង់គុណដ៏ប្រសើរ មេត្តាអនុញ្ញាតឲ្យទូលព្រះបង្គំបួសចុះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ដល់ព្រះរាជបិតា ទើបត្រាស់ថា

សត្វនៅក្នុងគភ៌អស់រាត្រីណាមួយជាដំបូង សត្វនោះប្រព្រឹត្តទៅដូចជាពពកដែលតាំងឡើង សត្វនោះកាលទៅ រមែងមិនត្រឡប់វិញទេ ។

មិនមែនពួកនរៈកាលច្បាំង មិនមែនពួកនរៈ បរិបូណ៌ដោយកម្លាំង មិនគ្រាំគ្រា មិនស្លាប់ទេ ព្រោះថា បាណមណ្ឌលទាំងអស់នោះ គឺជាតិនិងជរាតែងចូលទៅជិតបៀតបៀន ហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ព្រះរាជាទាំងឡាយ ជារដ្ឋាធិបតីគ្របសង្កត់នូវសេនា ប្រកបដោយអង្គ ៤ ជាសេនាមានសភាពគួរខ្លាចក្រៃពេក រមែងឈ្នះបាន ប៉ុន្តែមិនអាចឈ្នះនូវសេចក្តីស្លាប់បាន ព្រោះហេតុនោះ គំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ព្រះរាជាទាំងឡាយអង្គខ្លះ ដែលមានពលដំរី ពលសេះ ពលរថ ពលថ្មើរជើងចោមរោមហើយ រួច ( អំពីកណ្តាប់ដៃពួកបច្ចាមិត្ត ) បាន ប៉ុន្តែមិនអាចរួចចាកសេចក្តីស្លាប់បាន ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ព្រះរាជាទាំងឡាយក្លៀវក្លា រមែង ( ញុំាងនគរទាំងឡាយ

របស់ពួកស្តេចជាបច្ចាមិត្ត ) ឲ្យខ្ទេចខ្ទី ឲ្យខ្ចាត់ខ្ចាយ ដោយពលដំរី ពលសេះ ពលរថ ពលថ្មើរជើងបាន ប៉ុន្តែមិនអាចកម្ចាត់នូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ដំរីទាំងឡាយចុះប្រេង មានប្រេងធ្លាយហូរហៀរ តែងញាំញីនូវនគរទាំងឡាយ សម្លាប់នូវជនបាន ប៉ុន្តែមិនអាចញាំញីនូវសេចក្តីស្លាប់បានទេ ព្រោះហេតុនោះបានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ខ្មាន់ធ្នូទាំងឡាយ ទុកជាមានដៃហាត់ហើយ ជាអ្នកក្លៀវក្លា អាចញាំងព្រួញឲ្យធ្លាក់ក្នុងទីឆ្ងាយបាន បាញ់មិនខុស ក៏មិនអាចបាញ់នូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ទឹកស្រះទាំងឡាយរមែងអស់ទៅ ផែនដីព្រមទាំងភ្នំនិងដងព្រៃរមែងអស់ទៅ វត្ថុដែលប្រព្រឹត្តទៅក្នុងអំណាចនៃសង្ខារទាំងអស់នោះ ក៏រមែងអស់ទៅក្នុងចន្លោះនៃកាលដ៏វែង ដ្បិតថាវត្ថុទាំងអស់នោះ គប្បីបាក់បែកក្នុងកំណត់កាលជាទីវិនាស ព្រោះហេតុនោះបានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ជីវិតរបស់នារីនិងនរៈក្នុងលោកនេះទាំងអស់ តែងប្រែប្រួល

ដូចជាសំពត់របស់អ្នកលេង ដូចឈើដុះក្បែរប្រាំង យ៉ាងនោះដែរ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ផ្លែឈើទាំងឡាយ ( រមែងជ្រុះចុះ ) យ៉ាងណា មាណពទាំងឡាយ ទាំងក្មេង ទាំងចាស់ ទាំងស្រី ទាំងប្រុស ទាំងមជ្ឈិមបុរស ( បណ្ឌកនិងខកគោព្យញ្ជនក ) រមែងមានសរីរៈបែកធ្លាយជ្រុះចុះ ( យ៉ាងនោះ ) ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

វ័យនេះ មិនដូចស្តេចផ្កាយ ( ព្រះចន្ទ ) ទេ វ័យណាកន្លងទៅហើយ ឥឡូវនេះ វ័យនោះ ទៀងតែទៅមែនពិត បុគ្គលចាស់ ឥតមានតម្រេក ( ក្នុងកាមគុណ ) សុខនឹង ( មាន ) មកពីណា ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ពួកយក្ខ បិសាចឬប្រេតទាំងនោះខឹងហើយរមែងផ្តុំសម្លាប់នូវពួកមនុស្ស ប៉ុន្តែមិនអាចផ្តុំសម្លាប់នូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

មនុស្សទាំងឡាយ រមែងធ្វើនូវការអង្វរចំពោះពួកយក្ខ ពួកបិសាច ឬពួកប្រេតដែលខឹងហើយនោះបាន ប៉ុន្តែមិនអាច

អង្វរករមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ព្រះរាជាទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវទោសហើយ ដាក់អាជ្ញាចំពោះពួកជនអ្នកមានកំហុស អ្នកប្រទូស និងអ្នកបៀតបៀនបាន ប៉ុន្តែមិនអាចដាក់អាជ្ញាដល់មច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ពួកជនអ្នកមានកំហុស អ្នកប្រទូស្ត អ្នកបៀតបៀន តែងអង្វរករព្រះរាជាទាំងឡាយនោះបាន ប៉ុន្តែធ្វើនូវកិរិយាអង្វរករមច្ចុពុំបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

មិនថាក្សត្រ មិនថាព្រាហ្មណ៍ មិនថាអ្នកស្តុកស្តម្ភ អ្នកមានកម្លាំង អ្នកមានតេជៈទេ សេចក្តីយល់មុខរបស់មច្ចុរាជមិនមានឡើយ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ខ្លាធំទាំងខ្លាដំបង តែងគំរាមនូវជន ដែលកំពុងញាប់ញ័រហើយទំពាស៊ីបាន ប៉ុន្តែមិនអាចទំពាស៊ីនូវមច្ចុបានទេ ព្រោះហេតុនោះបានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ពួកជនអ្នកធ្វើមាយា ( អ្នកលេងកល ) កាលធ្វើ ( នូវមាយា ) ក្នុងទីពាក់កណ្តាលវគ្គ រមែងធ្វើនូវភ្នែកទាំងឡាយរបស់ជនឲ្យភាន់ច្រឡំបានដោយពិត ប៉ុន្តែមិនអាចញ៉ាំងមច្ចុឲ្យភាន់ច្រឡំបានឡើយ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

សត្វអាសិរពិសទាំងឡាយ មានតេជះដ៏ក្លាខ្លាំង ខឹងហើយរមែងចឹកសម្លាប់នូវមនុស្សទាំងឡាយនោះក៏បាន ប៉ុន្តែមិនអាចចឹកនូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

សត្វអាសិរពិសទាំងឡាយក្រោធហើយ ចឹកនរណា ពួកពេទ្យអ្នករក្សារមែងកម្ចាត់នូវពិសនៃសត្វអាសិរពិសទាំងនោះបាន ប៉ុន្តែកម្ចាត់នូវពិសដែលមច្ចុចឹកហើយពុំបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ពេទ្យទាំងឡាយឈ្មោះធម្មន្តរី ១ វេត្តរណៈ ១ ភោជៈ ១ សម្លាប់នូវពិសទាំងឡាយនៃភុជង្គ ( នាគ ) បាន ពួកពេទ្យទាំងនោះ គេឮថាធ្វើមរណកាលទៅហើយដូចគ្នាដែរ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ពួកវិជ្ជាធររៀននូវឃោរវិជ្ជារមែងដល់នូវការកំបាំងខ្លួនដោយថ្នាំទាំងឡាយបាន ប៉ុន្តែមិនដល់នូវការបំបាំងមច្ចុរាជបានទេព្រោះហេតុនោះបានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

ធម៌រមែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលប្រព្រឹត្តដោយល្អហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលប្រព្រឹត្តដោយល្អហើយបុគ្គលអ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិ ។

សភាវៈទាំងឡាយពីរ គឺធម៌ ១ អធម៌ ១ មិនមែនមានផលស្មើគ្នាទេ អធម៌នាំសត្វទៅកាន់នរក ធម៌ញ៉ាំងសត្វឲ្យដល់នូវសុគតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យមេករត្តឹ** សេចក្តីថា ដោយច្រើន សត្វទាំងឡាយកាលបដិសន្ធិក្នុងផ្ទៃមាតា ដោយច្រើនបដិសន្ធិក្នុងពេលរាត្រី ព្រោះហេតុនោះ ទើបព្រះពោធិសត្វត្រាស់យ៉ាងនេះ ក្នុងសេចក្តីនេះមានអធិប្បាយថា សត្វបដិសន្ធិក្នុងពេលរាត្រីក្តី ក្នុងពេលថ្ងៃក្តី រមែងនៅក្នុងគភ៌គឺផ្ទៃមាតាមុន ។ បទថា **មាណវោ** សេចក្តីថា សត្វរមែងតាំងនៅដោយភាពជាកលលៈ ។ បទថា **អព្ភុដ្ឋិតោវ សោ យាតិ** សេចក្តីថា ពពក ពោលគឺវលាហកតាំងឡើង កើតឡើង ត្រូវកម្លាំងព្យុះបក់ទៅ យ៉ាងណា សត្វរមែងទៅកាន់ភាពជាកលលៈមុនយ៉ាងនោះដូចគ្នា ។

សេចក្ដីនេះ សមដូចព្រះតម្រាស់ដែលពោលទុក ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

កលលរូបកើតជាដំបូង តពីកលលរូបមកកើតជាអព្ពុទរូប តពីអព្ពុទរូបមក កើតជាបេសិរូប តពីបេសិរូបមក កើតជាឃន-រូប តពីឃនរូបមក កើតជាសាខារូប តមកទៀត ទើបកើតសក់ រោម ក្រចក ឯមាតារបស់សត្វនោះ បរិភោគភោជនណា ទោះបាយក្ដី ទឹកក្ដី សត្វនោះដែលឋិតនៅក្នុងផ្ទៃនៃមាតានោះក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភោជននោះ ដូច្នេះ ។

ក្នុងគាថានោះ គប្បីជ្រាបអធិប្បាយដូចតទៅនេះថា

នរៈនោះ ដល់នូវភាពជាកលលៈជាដើមក្នុងផ្ទៃមាតា ដំបូងប្រសូតចាកផ្ទៃមាតាហើយ ក៏ដល់នូវភាពជាមន្ទទសកៈជាដើម រមែងប្រព្រឹត្តទៅតគ្នាមិនដាច់ ។ បទថា **ស គច្ឆំ ន និវត្តតិ** សេចក្ដីថា កាលប្រព្រឹត្តទៅយ៉ាងនេះ នរៈនេះ មិនបានថយត្រឡប់ទៅក្រោយ ដល់ភាពជាកលលៈអំពីអព្ពុទៈ ដល់នូវភាពជាអព្ពុទៈជាដើមអំពីបេសិជាដើមឡើយ ជាមន្ទទសកៈអំពីខិឌ្ឍាទសកៈ ឬដល់នូវភាពជាខិឌ្ឍាទសកៈជាដើម អំពីវណ្ណទសកៈជាដើមឡើយ ប្រៀបដូចវលាហកដែលខ្យល់កំពុងបក់ឲ្យខ្ចាត់ខ្ចាយ រមែងមិនបានគិតថា អញតាំងឡើងក្នុងទីឈ្មោះនោះ អញនឹងត្រឡប់ទៅ ហើយតាំងនៅដោយប្រក្រតីភាព ក្នុងទីនោះទៀតនោះឯង ពេលណាវលាហកនោះទៅហើយ ទីនោះបានឈ្មោះថាទៅហើយ ដែលបានអន្តរធានទៅ ទីនោះឈ្មោះថា អន្តរធានទៅហើយយ៉ាង

ណា សូម្បីសត្វដែលបដិសន្ធិក្នុងផ្ទៃក៏យ៉ាងនោះ កាលទៅដោយភាពជាកលលៈជាដើម រមែងទៅហើយនោះឯង សង្ខារទាំងឡាយក្នុងចំណែកនោះៗ ជាបច្ច័យនៃការៈមានក្នុងកាលមុន មិនបានថយក្រោយ រមែងបែកធ្លាយក្នុងទីនោះៗឯង សង្ខារទាំងឡាយក្នុងជរាកាល រមែងមិនបានវត្ថុដែលនឹងគិតថា កាលមុននេះកំលោះ សម្បុរដោយកម្លាំង ពួកយើងធ្វើបានតាមត្រូវការ ពួកយើងនឹងឲ្យសង្ខារទាំងនោះត្រឡប់ដូចដើម ធ្វើបានដូចមុននោះទៀត ដូច្នេះ រមែងអន្តរធានទៅក្នុងទីនោះឯង ។

បទថា **ន យុជ្ឈមានា** សេចក្តីថា នរជនទាំងឡាយ តាំងបន្ទាយប្រឈមមុខពលទាំងសងខាង ធ្វើសង្គ្រាមជាមួយជរាមរណៈមិនបាន ។ បទថា **ន ពលេន វស្សិតា** សេចក្តីថា នរជនទាំងឡាយ ទោះចូលដល់ គឺប្រកបដោយកម្លាំងកាយ កម្លាំងពលយោធាក៏ដោយ ។ បណ្ឌិតគប្បីនាំយក **ន** អក្ខរៈខាងមុខ ក្នុងបទថា **ន ជីរន្តិ** មកប្រកប ហើយជ្រាបអត្ថថា នរជនទាំងឡាយបែបនេះ នឹងមិនចាស់ មិនស្លាប់មិនមាន ។ បទថា **សព្វញ្ហិ តំ** សេចក្តីថា បពិត្រមហារាជ ព្រោះមណ្ឌលនៃបាណសត្វទាំងអស់នេះ ត្រូវជាតិនិងជរាបៀតបៀនជានិច្ច ដូចអំពៅត្រូវគ្រឿងយន្តដ៏ជំគាបដូច្នោះ ។ បទថា **តំ មេ មតី ហោតិ** សេចក្តីថា ព្រោះហេតុនោះ ទើបការគិតរបស់ខ្ញុំមាន គឺកើតនូវការគិតឡើងថា នឹងបួសប្រព្រឹត្តធម៌ ។ បទថា **ចតុរង្គិនី** សេចក្តីថា ប្រកបដោយអង្គ ៤ មានសេះជាដើម ។ បទថា **សេនំ សុភីសរូបំ** បានដល់សេនាដែលមានរូបរាងគួរខ្លាច ។ បទថា **ជយន្តិ** សេចក្តីថា ជួនកាលព្រះ

រាជាពួកខ្លះឈ្នះដោយសេនារបស់ខ្លួនបាន ។ បទថា **ន មច្ចុនោ** សេចក្តីថា តែព្រះរាជាទាំងនោះ មិនអាចឈ្នះសេនានៃមច្ចុរាជ ដែលមានសេនាធំបាន គឺមិនអាចញ៉ាំញីជរា ព្យាធិនិងមរណៈបានឡើយ ។

បទថា **មុច្ចរេ ឯកច្ចយា** សេចក្តីថា ព្រះរាជាពួកខ្លះចោមរោមដោយពលដ៏វិជាដើមនេះ រមែងផុតចាកកណ្តាប់ដៃនៃបច្ចាមិត្តបាន តែមិនអាចផុតចាកសម្លាក់របស់មច្ចុរាជបានឡើយ ។ បទថា **បភញ្ជន្តិ** សេចក្តីថា ព្រះរាជាដែលជាអ្នកអង់អាច រមែងវាយដណ្តើមយកព្រះនគរ របស់រាជសត្រូវបានដោយពលដ៏វិជាដើមនេះ ។ បទថា **បធំសយន្តិ** សេចក្តីថា រមែងកម្ចាត់ញ៉ាំញី ញ៉ាំងមហាជនឲ្យដល់នូវការស្លាប់បាន ។ បទថា **ន មច្ចុនោ** សេចក្តីថា តែព្រះរាជាទាំងនោះ លុះមរណកាលមកដល់ហើយ មិនអាចកាច់បំបាក់នូវមច្ចុបានឡើយ ។ បទថា **ភិន្នគឡា បភិន្នា** សេចក្តីថា គជសារទាំងឡាយជាសត្វមានប្រេងហូរចេញក្នុងទី ៣ កន្លែង ក៏ស្រវឹង គឺមានប្រេងហូរចេញ ។ បទថា **ន មច្ចុនោ** សេចក្តីថា គជសារទាំងនោះ មិនអាចញ៉ាំញីមច្ចុរាជដែលមានមហាសេនាបានទេ ។

បទថា **ឥស្សាសិនោ** បានដល់ ខ្មាន់ធ្នូទាំងឡាយដែលមានថ្វីដៃ ។ បទថា **កតហត្ថា** សេចក្តីថា ជាអ្នកសិក្សាល្អហើយ ។ បទថា **ទូរេបាតី** សេចក្តីថា ជាអ្នកអាចបាញ់ឲ្យត្រូវបានក្នុងទីឆ្ងាយ ។ បទថា **អក្ខណវេធិនោ** សេចក្តីថា បាញ់មិនខុស ឬអាចបាញ់បានដោយពន្លឺផ្លេកបន្ទោរ ។ បទថា **សរានិ** សេចក្តីថា សូម្បីស្រះធំៗទាំងឡាយ មានអនោតត្តស្រះជាដើម រមែងវិនាសអស់

ទៅដូចគ្នា ។ បទថា **សសេលកាននា** សេចក្តីថា សូម្បីមហាប្រឹថពី ព្រមទាំងបព៌តនិងដងព្រៃក្តី រមែងវិនាសសូន្យទៅ ។ បទថា **សព្វំ ហិ តំ** សេចក្តីថា ធម្មជាតិដែលរាប់ជាសង្ខារទាំងអស់នេះ សូម្បីតាំងនៅយូរត្រឹមណា ក៏រមែងវិនាសអស់ទៅ ។ សូម្បីមហាមេរុរាជ ដល់នូវភ្លើងប្រល័យកប្បហើយ រមែងរលាយទៅដូចក្រមួនឃ្មុំដាក់ក្នុងជើងក្រាន រមែងរលាយទៅដូច្នោះ ឯសង្ខារមានប្រមាណតិចតួច មិនអាចតាំងនៅបាន ។ បទថា **កាលបរិយាយំ** សេចក្តីថា សង្ខារទាំងអស់ ដល់នូវកាលជាទីបំផុត គឺដល់វារៈកាលវិនាសហើយ រមែងបាក់ខ្ទេចខ្ទី គឺបែកធ្លាយទៅ ។ ដើម្បីប្រកាសសេចក្តីនេះ គួរនាំសត្តសុរិយសូត្រមកសម្តែង ។

បទថា **ចលាចលំ** សេចក្តីថា ជារបស់ចលាចល គឺមិនអាចតាំងនៅតាមសភាពរបស់ខ្លួនបាន ដែលមានការប្រព្រឹត្តទៅផ្សេងៗ ប្លែកៗ គ្នា ។ បទថា **ទាណភុនោន ជីវិតំ** សេចក្តីថា ជីវិតរបស់បាណសត្វទាំងឡាយនេះ ក្នុងលោកនេះក៏ដូច្នោះ ។ បទថា **បជោវ ធុត្តស្ស ទុមោវ កូលជោ** សេចក្តីថា ធម្មតាអ្នកលេងសុរា ឃើញស្រាហើយ រមែងដោះសំពត់ ដូរស្រាផឹកបាននោះឯង ដើមឈើដែលដុះក្បែរស្ទឹង កាលបាក់ចុះ ក៏រមែងរលំទៅ សំពត់របស់អ្នកលេងសុរា និងដើមឈើក្បែរច្រាំងនេះ យ៉ាងណា បពិត្រមហារាជ ជីវិតនៃសត្វទាំងឡាយ ក៏យ៉ាងនោះ ។ បទថា **ទុមប្ផលានេវ** សេចក្តីថា ផ្លែឈើទាំងឡាយដែលទុំហើយត្រូវខ្យល់ប៉ះខ្ទប់ រមែងជ្រុះចាកដើម ធ្លាក់ត្រង់ផែនដីយ៉ាងណា មាណពទាំងឡាយនេះ ត្រូវខ្យល់គឺជរាប៉ះខ្ទប់ហើយ រមែង

ជ្រុះទៅលើផែនដី គឺសេចក្ដីស្លាប់យ៉ាងនោះដូចគ្នា ។ បទថា **ឧហរា** សេចក្ដីថា មាណពទាំងឡាយនេះ គឺបុរសកំលោះ ដោយហោច តាំងនៅក្នុងភាពជាកលលៈក្ដី ។ បទថា **មជ្ឈិមបោរិសា** សេចក្ដីថា បុរស ស្រ្ដីតាំងនៅក្នុងវ័យកណ្ដាល ទាំងឧភតោព្យញ្ជនកៈ និងនបុំសកភេទ ។

បទថា **តារកាជសន្និភោ** សេចក្ដីថា ព្រះចន្ទជាស្ដេចនៃផ្កាយ អស់អំណាចក្នុងកាឡបក្ខខាងរនោច តែក៏ក្លាថាពេញវង់ក្នុងជុណ្ហបក្ខខាងខ្នើតយ៉ាងណា វ័យនៃសត្វទាំងឡាយមិនមែនយ៉ាងនោះឡើយ ព្រោះវ័យនៃសត្វទាំងឡាយ ចំណែកណាដែលកន្លងទៅហើយ ចំណែកនោះកន្លងទៅហើយ ក្នុងឥឡូវនេះឯង មិនមានផ្លូវដែលនឹងត្រឡប់មកកាន់វ័យនោះទៀតបានទេ ។ បទថា **កុតោ សុខំ** សេចក្ដីថា សូម្បីការត្រេកអរក្នុងកាមគុណទាំងឡាយនៃមនុស្សចាស់ជរា រមែងមិនមាន សេចក្ដីសុខដែលកើតឡើងព្រោះអាស្រ័យកាមគុណនោះនឹងមានមកអំពីណា ។ បទថា **យក្ខា** បានដល់ យក្ខដែលមានមហិទ្ធិឫទ្ធិ ។ បទថា **បិសាចា** បានដល់ បិសាចដែលប្រឡាក់ដោយធូលី ។ បទថា **បេតា** បានដល់ សត្វដែលចូលដល់បិត្តិវិស័យ ។ បទថា **អស្សសន្តិ** សេចក្ដីថា ចូលទៅប៉ះខ្ទប់ ឬជ្រែកចូលទៅតាមខ្យល់ដង្ហើមចេញចូល ។ បទថា **ន មច្ចុនោ** សេចក្ដីថា តែយក្ខជាដើមនោះ មិនអាចចូលទៅប៉ះខ្ទប់ ឬចូលសណ្ឋិតតាមខ្យល់ដង្ហើមរបស់មច្ចុបានឡើយ ។

បទថា **និជ្ឈបនំ ករោន្តិ** សេចក្ដីថា ឲ្យអត់ទោស គឺឲ្យត្រេកអរដោយអំណាចនៃពលីកម្មបាន ។ បទថា **អបរាធកេ** បានដល់ ដែលធ្វើនូវកំហុស

ចំពោះព្រះរាជា ។ បទថា **ទុស្សកេ** បានដល់ ដែលប្រទូស្តចំពោះរាជសម្បត្តិ ។ បទថា **ហេឋកេ** បានដល់ ដែលបៀតបៀនសត្វលោកដោយការកាត់ទីតជាដើម ។ បទថា **រាជានោ** បានដល់ ព្រះរាជាទាំងឡាយ ។ បទថា **វិទិត្វាន ទោសំ** សេចក្តីថា ព្រះរាជាទាំងឡាយទ្រង់ជ្រាបទោសកំហុសហើយ រមែងដាក់នូវអាជ្ញាតាមសមគួរដល់កំហុស ។ បទថា **ន មច្ចុនោ** សេចក្តីថា តែព្រះរាជាទាំងនោះ មិនអាចដាក់នូវអាជ្ញាដល់មច្ចុរាជបាន ។ បទថា **និជ្ឈាបេន្តិ** សេចក្តីថា រមែងបានប្រកាសនូវភាពជា អ្នកឥតកំហុសនៃខ្លួនបានដោយសាក្សី ។ បទថា **ន អឌ្ឍកា ពលវា តេជវាបិ** សេចក្តីថា ព្រះពោធិសត្វទ្រង់សម្តែងថា មច្ចុរាជមិនបានក្រែងចិត្តយ៉ាងនេះថា ជនទាំងនេះស្តុកស្តម្ភជាអ្នកមានកម្លាំង ដោយកម្លាំងកាយ កម្លាំងវិជ្ជា បុគ្គលនេះ មានតេជានុភាព គឺមិនមានការក្រែងចិត្ត ស្រឡាញ់ ស្និទ្ធស្នាលក្នុងសត្វនិកាយ សូម្បីត្រឹមតែមួយ រមែងញាំញីទាំងអស់នោះឯង ។

បទថា **បសយ្ហ** សេចក្តីថា សង្កត់សង្កិនដោយកម្លាំងពល ។ បទថា **ន មច្ចុនោ** សេចក្តីថា សូម្បីសត្វទាំងនោះក៏មិនអាចទំពាស៊ីមច្ចុរាជបាន ។

បទថា **ករោន្តា** សេចក្តីថា ធ្វើនូវកលមាយា ។ បទថា **មោហេន្តិ** សេចក្តីថា សម្តែងវត្ថុដែលមិនពិត ធ្វើឲ្យឃើញដូចពិត បំភាន់ភ្នែកមហាជន ។ បទថា **ឧគ្គតេជា** សេចក្តីថា អាសិរពិសទាំងឡាយដែលប្រកបដោយតេជះគឺពិសខ្លាំងក្លា ។ បទថា **តិកិច្ឆកា** បានដល់ គ្រូពេទ្យព្យាបាលពិស ។ លោកទាំងនេះគឺ ធម្មន្តរី ១ វេត្តរុណ ១ ភោជ ១ ជាឈ្មោះរបស់គ្រូពេទ្យ ។ បទ

ថា **ឃោរមឃីយមានា** បានដល់ បុគ្គលដែលទ្រទ្រង់នូវវិជ្ជាឈ្មោះឃោរៈ ។ បទថា **ឱសធេភិ** សេចក្ដីថា វិជ្ជាធរទាំងឡាយ កាលរាយវិជ្ជាឈ្មោះឃោរៈ ឬគន្ធៈជាដើម ហើយកាន់ឱសថទៅកាន់ទីដែលមានសត្រូវទាំងឡាយ សត្រូវទាំងឡាយមិនអាចមើលឃើញបាន ដោយឱសថ ( និងមន្ត ) ទាំងនោះ ។ បទថា **ធម្មោ** បានដល់ សុចរិតធម៌ ។ បទថា **រក្ខតិ** បានដល់ សុចរិតធម៌ដែលបុគ្គលណារក្សាហើយ សុចរិតធម៌នោះ រមែងរក្សាបុគ្គលនោះវិញ ។ បទថា **សុខំ** សេចក្ដីថា ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំសុខមក គឺឲ្យដល់នូវសេចក្ដីសុខ បានដល់ នាំចូលទៅដោយអំណាចបដិសន្ធិ ក្នុងឆកាមាវចរសួគ៌ ។

កាលព្រះមហាសត្វ សម្ដែងធម៌ថ្វាយព្រះបិតា ដោយគាថា ២៤ យ៉ាងនេះហើយ ក្រាបទូលថា បពិត្រមហារាជ រាជសម្បត្តិរបស់ព្រះរាជបិតា សូមជារបស់បិតាចុះ ទូលព្រះបង្គំមិនមានសេចក្ដីត្រូវការដោយរាជសម្បត្តិនេះ ជរាព្យាធិនិងមរណៈរមែងបៀតបៀនទូលព្រះបង្គំ ដែលកំពុងក្រាបទូលសន្ទនាជាមួយទ្រង់នេះឯង សូមទ្រង់នៅឲ្យសុខចុះ ដូច្នេះហើយ លះនូវកាមទាំងឡាយថ្វាយបង្គំលាព្រះជនកព្រះជននី យាងចេញបព្វជ្ជា ដូចដំរីចុះប្រេង កាត់នូវទន្ទឹង ហើយទៅ ឬដូចសីហពោតកៈ ( កូនសីហៈ ) ទម្លាយទ្រុងមាសហើយទៅដូច្នោះ ។

លំដាប់នោះ ព្រះបិតារបស់ព្រះពោធិសត្វ ទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដោយរាជសម្បត្តិដល់អញ ទើបលះរាជសម្បត្តិ យាងចេញជាមួយព្រះរាជ

ឱរសនោះឯង ។ កាលព្រះបាទព្រហ្មទត្តកំពុងយាងចេញទៅនោះ ព្រះទេវីក្តី ពួកអាមាត្យរាជបរិវារក្តី រហូតដល់អ្នកនគរទាំងមូល មានព្រាហ្មណ៍និងគហបតីជាដើមនាំគ្នាលះនូវគេហដ្ឋាន ចេញតាមព្រះបាទព្រហ្មទត្ត កើតជាមហាសមាគមមានបរិស័ទរាប់បានប្រមាណ ១២ យោជន៍ ព្រះមហាសត្វនាំបរិស័ទចូលទៅកាន់ហិមវន្តប្បទេស សក្កទេវរាជទ្រង់ជ្រាបថា ព្រះមហាសត្វចេញបួសហើយ ទើបបញ្ជូនវិស្សកម្មទេវបុត្តទៅនិម្មិតអាស្រមបទ ដែលមានបណ្តោយ ១២ យោជន៍ ទទឹង ៧ យោជន៍ និងឲ្យចាត់ចែងបព្វជិតបរិក្ខារទុកគ្រប់គ្រាន់ បន្ទាប់អំពីនេះទៅ បព្វជ្ជារបស់ព្រះមហាសត្វក្តី ការឲ្យឱវាទក្តី ភាពជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខក្តី ការមិនទៅកាន់អបាយនៃបរិស័ទក្តី គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមទាំងអស់នោះឯង ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏ចេញមហាភិនេស្រ្កមណ៍យ៉ាងនេះដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះរាជមាតា បិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកអយោឃរបណ្ឌិតក្នុងកាលនោះ គឺតថាគតដ៏ជាអរហន្តសម្មាសម្ពុទ្ធនេះឯង ។

**អដ្ឋកថា អយោឃរជាតក ចប់**

**វីសតិនិបាត ចប់**

# តឹសនិបាត

## កឹជន្ធជាតក

[ ៤១៤ ] ( ទេវតាពោលថា ) បពិត្រព្រាហ្មណ៍ លោកពេញចិត្តនឹងអ្វី ប៉ុនប៉ងអ្វី ប្រាថ្នាអ្វី ស្វែងរកអ្វី ទើបអង្គុយម្នាក់ឯងក្នុងរដូវក្តៅ ដោយប្រយោជន៍អ្វី ។

[ ៤១៥ ] ( តាបសពោលតបថា ) ក្អមដាក់នូវទឹកដ៏ធំ មានទ្រង់ទ្រាយស្អាតបាត មានឧបមាយ៉ាងណា ផ្លែស្វាយទុំដ៏ឧត្តមដោយពណ៌និងក្លិននិងរសក៏មានឧបមេយ្យយ៉ាងនោះ ។ ម្នាលនាងមានអវយវៈត្រង់កណ្តាល ( ចង្កេះ ) មិនមានមន្ទិល អាត្មាបានឃើញផ្លែស្វាយនោះ អណ្តែតតាមខ្សែទឹក ក៏ចាប់ផ្លែស្វាយនោះដោយដៃទាំងពីរ ហើយនាំយកទៅកាន់រោងបូជាភ្លើង ។ លំដាប់នោះ អាត្មាបានដាក់ផ្លែស្វាយលើស្លឹកចេកទាំងឡាយ ដោយខ្លួនឯង ចិតនូវផ្លែស្វាយនោះដោយកាំបិតហើយ ( ឆាន់ ) ផ្លែស្វាយនោះ នាំចេញនូវសេចក្តីស្រេកឃ្លានរបស់អាត្មាបាន ។ អាត្មានោះ ប្រាសចាកសេចក្តីក្រវល់ក្រវាយលុះផ្លែស្វាយអស់ហើយ ក៏អត់ទ្រាំបានដោយលំបាក មិនបានសេចក្តីត្រេកអរក្នុងផ្លែឈើទាំងឡាយឯទៀតណាមួយ ។ ផ្លែស្វាយនោះនឹងនាំមកនូវសេចក្តីស្លាប់ដល់អាត្មាដោយពិត ព្រោះរឹងស្គមព្រោះផ្លែស្វាយមានរសឆ្ងាញ់ មានរសផ្អែមលើសលុប ជាទីពេញចិត្ត ។ អាត្មាបានស្រង់ផ្លែស្វាយដែលកំពុងអណ្តែតក្នុងអន្លង់ដ៏ធំអំពីស្ទឹង អាត្មានៅ ( ដោយសេចក្តីស្រេកឃ្លាន ) ព្រោះហេតុណា ហេតុនោះទាំងអស់ អាត្មាបានប្រាប់ដល់នាង ។ អាត្មាអង្គុយ

អាស្រ័យនូវស្ទឹងជាទីរីករាយ ស្ទឹងនេះធំទូលាយ ប្រកបដោយត្រី នាងកុំ-អាលរត់ទៅ ចូរប្រាប់ខ្លួននោះដល់អាត្មាសិន ។ ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈត្រង់កណ្តាល ( ចង្កេះ ) ដ៏ល្អ នាងមានរូបដូចដំបារមាសដ៏រលីង ( មានដំណើរ ) ដូចជាកូនខ្លាដែលកើតក្នុងញកភ្នំ ( មកក្នុងទីនេះ ) ដើម្បីអ្វី ។ នាងនារីទាំងឡាយណា ជាអ្នកបម្រើពួកទេវតាក្នុងទេវតាទាំងឡាយផង ស្រីទាំងឡាយណា ប្រកបដោយរូប ក្នុងមនុស្សលោកផង ស្រីទាំងឡាយនោះ ប្រាកដស្មើដោយរូបនៃនាងមិនមាន ក្នុងទេវគន្ធព្វ និងមនុស្សលោកឡើយ ម្នាលនាងមានអវយវៈខាងដើម ( ភ្លៅ ) ដ៏ល្អ អាត្មាសួរហើយ ចូរប្រាប់នាមនិងគោត្តផង ផៅពង្សទាំងឡាយផង ។

[ ៤១៦ ] ( ទេវតា... ) បពិត្រព្រាហ្មណ៍ លោកគង់នៅអាស្រ័យស្ទឹងឈ្មោះកោសិកីជាទីរីករាយណា ខ្ញុំមានលំនៅត្រង់ខ្សែទឹកដ៏កាច មានអន្លង់ជាទីហូរទៅនៃទឹកដ៏ប្រសើរ អាស្រ័យនៅហើយ ( ក្នុងស្ទឹងនោះ ) ។ ជ្រោះភ្នំដ៏ច្រើន កុះករដោយឈើផ្សេងៗ រមែងមានក្នុងទីចំពោះមុខខ្ញុំ រមែងហូរទៅក្នុងវជ្ជូរភ្លៀង ។ ម្យ៉ាងទៀត ស្ទឹងដ៏ច្រើន មានទឹកហូរចេញអំពីព្រៃ ទ្រទ្រង់នូវគំនរទឹកដ៏ខៀវ ស្ទឹងដ៏ច្រើន មានរូបភាពដូចជានាគ រមែងញុំាងខ្ញុំឲ្យពេញដោយទឹក ។ ដើមស្វាយ ដើមព្រីង ដើមខ្នុរសម្ល ដើមក្ទម្ព ដើមត្នោតនិងដើមល្វា ជលជាតទាំងឡាយដ៏ច្រើន រមែងចូលទៅកាន់ស្ទឹងទាំងនោះរឿយៗ ។ ផ្លែឈើណាមួយនៅក្បែរមាត់ច្រាំងទាំងពីរ រមែងជ្រុះទៅក្នុងទឹក ផ្លែឈើនោះរសាត់ទៅតាមអំណាចនៃខ្សែទឹក ដោយឥតសង្ស័យ ។ បពិត្រលោកជាអ្នក

ប្រាជ្ញ មានប្រាជ្ញាច្រើន លោកជ្រាបហេតុនុ៎ះហើយ សូមស្តាប់ពាក្យខ្ញុំចុះ បពិត្រព្រះជនាធិបតី សូមលោកកុំពេញចិត្តឡើយ ចូរបដិសេធនូវការជាប់ចំពាក់ដោយតណ្ហា ។ បពិត្រព្រះរាជឹសីអ្នកញ៉ាំងដែនឲ្យចម្រើន លោកកំពុងចម្រើន ( ដោយសាច់និងឈាម ) ប្រាថ្នាសេចក្តីស្លាប់ ដោយហេតុណា ខ្ញុំពុំសំគាល់នូវលោកថា ជាអ្នកចម្រើនដោយប្រាជ្ញា ដោយហេតុនោះទេ ។ បិតាទាំងឡាយ ( ព្រហ្ម ) និងគន្ធព្វព្រមទាំងទេវតា រមែងដឹងនូវភាពនៃបុគ្គលនោះថា ជាអ្នកលុះក្នុងអំណាចនៃតណ្ហា ម្យ៉ាងទៀត ឥសីទាំងឡាយណា ក្នុងលោក ជាអ្នកមានចិត្តសង្រួមហើយ មានតបៈ ឥសីទាំងឡាយនោះ រមែងឥតសង្ស័យ ( សូម្បី ) ពួកអ្នកមានយសជាអ្នកបម្រើ ( ឥសីទាំងនោះក៏ដឹងការនោះតៗគ្នាទៀត ) ។

[ ៤១៧ ] ( តាបស... ) បើ ( នរជនណា ) មិនគិតសម្លាប់ បុគ្គលនោះទេ បាបក៏មិនចម្រើនដល់នរជននោះដែលដឹងច្បាស់នូវធម៌ទាំងពួងរបស់អ្នកប្រាជ្ញយ៉ាងនេះផង ដឹងនូវការបែកធ្លាយនិងច្យុតិនៃជីវិតផង ម្នាលនាងជាធំ ដែលពួកឥសីដឹងច្បាស់ហើយ ប្រយោជន៍នៃសត្វលោក នាងដឹងច្បាស់ហើយយ៉ាងនេះ នាងឈ្មោះថាស្វែងរកនូវបាបកម្ម ( ចំពោះខ្លួន ) ព្រោះប្រទេចពាក្យមិនប្រសើរ ។ ម្នាលនាងទេវធីតាមានត្រគាកសាយល្អ បើយើងនឹងស្លាប់លើត្រើយរបស់នាង កាលបើយើងស្លាប់ហើយ តំណិះដំណៀលនឹងបានមកនាងឯងឥតសង្ស័យឡើយ ។ ម្នាលនាងមានអវយវៈត្រង់កណ្តាលដ៏ល្អព្រោះហេតុនោះ នាងឯងចូររក្សានូវកម្មអាក្រក់ កាលបើយើងស្លាប់ហើយ

កុំឲ្យជនទាំងអស់ជេរប្រទេចនាងក្នុងកាលជាខាងក្រោយឡើយ ។

[ ៤១៨ ] ( ទេវតា... ) ហេតុនេះ ខ្ញុំម្ចាស់ដឹងច្បាស់ហើយ ធម្មតាស្តេចនេះ មិនងាយអត់ទ្រាំបានទេ ណ្ហើយចុះ ខ្ញុំម្ចាស់នឹងប្រគេននូវខ្លួនខ្ញុំម្ចាស់ផង ប្រគេននូវស្វាយនោះផង ដល់លោកម្ចាស់ ដ្បិតលោកម្ចាស់បានលះបង់នូវកាមគុណទាំងឡាយដែលគេលះបង់បានដោយក្រ ហើយបានអធិដ្ឋាននូវសីលជាគ្រឿងស្ងប់រម្ងាប់ផង នូវសុចរិតធម៌ផង ។

បុគ្គលណា លះបង់នូវចំណាងខាងដើម ហើយឋិតនៅក្នុងចំណាងខាងចុងផង ប្រព្រឹត្តនូវអធម៌ផង បាបតែងចម្រើនឡើងដល់បុគ្គលនោះ ។ សូមលោកម្ចាស់មកចុះ ខ្ញុំម្ចាស់នឹងនាំលោកម្ចាស់ទៅឲ្យដល់ព្រៃស្វាយនោះ សូមលោកម្ចាស់មានសេចក្តីខ្វល់ខ្វាយតិចដោយពិតចុះ ខ្ញុំម្ចាស់ នឹងនាំទៅដាក់ក្នុងព្រៃស្វាយដ៏ត្រជាក់នោះ សូមលោកម្ចាស់គង់នៅកុំមានសេចក្តីខ្វល់ខ្វាយ ។ បពិត្រអរិន្ទមៈ ព្រៃស្វាយនោះ ពួកសត្វបក្សីមានកក្កក់ ស្រវឹងដោយរសនៃផ្កាឈើស្រែកបន្ទឺឡើងហើយ ពួកក្រៀល ពួកក្ងោកជាទិព្វ ពួកសត្វស្វាបឈ្មោះកោយដ្ឋិនិងឈ្មោះមធុសាលិយៈ យំជាមួយនឹងពួកហង្ស ពួកតាវៅ ដែលនៅក្នុងព្រៃស្វាយនោះ ក៏ញ៉ាំងពួកសត្វទាំងនោះឲ្យភ្ញាក់ឡើងហើយ ។ ដើមស្វាយទាំងឡាយក្នុងព្រៃនោះ មានចុងមែកដាបចុះ ( ព្រោះទម្ងន់ផ្លែ ) ប្រាកដស្មើដោយទីលានដែលពេញដោយកណ្តាប់ស្រូវ ដើមដកគាំ ស្រល់ និងកុម្ភទាំងឡាយ មានចង្កោមផ្លែសំយុងចុះ ដូចជាយផ្លែត្នោតទុំ ។

[ ៤១៩ ] ( តាបសនិយាយទៅនឹងប្រេតថា ) អ្នកទ្រទ្រង់នូវផ្កាកម្រង

ទ្រទ្រង់នូវឈ្នួត ប្រដាប់ដោយគ្រឿងអាភរណៈ ពាក់នូវពាហុរក្សរ័ត្ន ( កង កន់ ) ប្រោះព្រំដោយខ្លឹមចន្ទន៍ ឲ្យគេបម្រើក្នុងវេលាយប់ សោយនូវទុក្ខវេទនាក្នុងវេលាថ្ងៃ ។ ស្រីទាំងឡាយ ១៦.០០០ នេះ ជាស្រីបម្រើរបស់អ្នក អ្នកជាបុគ្គលមានអានុភាពច្រើនយ៉ាងនេះ អស្ចារ្យគួរឲ្យព្រឺរោម ។ ក្នុងកាលមុន អ្នកបានធ្វើអំពើបាបនាំមកនូវទុក្ខដល់ខ្លួនដូចម្តេចដែលអ្នកធ្វើក្នុងមនុស្សលោក បានជាស៊ីនូវសាច់ខ្នង ( របស់ខ្លួន ) ។

[ ៤២០ ] ( ប្រេត... ) ខ្ញុំបានរៀននូវវេទទាំងឡាយ ហើយជាប់ចំពាក់ក្នុងកាមទាំងឡាយ បានប្រព្រឹត្តមិនជាប្រយោជន៍ដល់ជនដទៃ អស់កាលដ៏យូរអង្វែង ។ បុគ្គលណា ជាអ្នកស៊ីនូវសាច់ខ្នង ( ញុះញង់គេ ) បុគ្គលនោះ ក៏ខាស៊ីនូវសាច់ខ្នងរបស់ខ្លួន ដូចខ្ញុំស៊ីក្នុងថ្ងៃនេះដែរ ។

**ចប់ កឹឆន្ទជាតក ទី ១ ។**

# តឹសនិបាត

## អដ្ឋកថា កិំឆន្ទជាតក

[ ៤១៤-៤២០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបោសថកម្ម ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កិំឆន្ទោ កិមធិប្បាយោ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ថ្ងៃមួយ ព្រះសាស្តាត្រាស់សួរឧបាសក ឧបាសិកាជាច្រើនដែលរក្សាឧបោសថ ដែលមកអង្គុយដើម្បីស្តាប់ព្រះធម្មទេសនា ត្រង់ធម្មសភាថា ម្នាលឧបាសកឧបាសិកាទាំងឡាយពួកអ្នករក្សាឧបោសថឬ កាលជនទាំងនោះទូលឲ្យទ្រង់ជ្រាបហើយ ទើបព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយធ្វើនូវការរក្សាឧបោសថ ឈ្មោះថាបានធ្វើល្អហើយ បុរាណកបណ្ឌិតទាំងឡាយបានទទួលយសធំក្រៃលែង ក៏ព្រោះផលនៃឧបោសថកម្មពាក់កណ្តាល កាលពួកឧបាសកឧបាសិកាទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទាន មកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីដោយធម៌ ។ ទ្រង់ជាអ្នកមានបសាទសទ្ធា ជាអ្នកមិនប្រមាទក្នុងទាន សីល និងឧបោសថកម្ម ។ ព្រះរាជាត្រាស់ទីងជនដ៏សេស មានអាមាត្យជាដើម ឲ្យតាំងមាំក្នុងកុសលចរិយា មានទានជាដើម តែបុរោហិតរបស់ទ្រង់ មានប្រក្រតីស៊ីនូវសាច់ខ្នងប្រជាជន ជាអ្នកស៊ីសំណូក វិនិច្ឆ័យក្តីដោយអំពើមិនត្រង់ ។ ក្នុងថ្ងៃឧបោសថ ព្រះរាជាត្រាស់ឲ្យមហាជន មានអាមាត្យជាដើមមកគាល់

ហើយត្រាស់ថា ពួកលោកទាំងឡាយចូរមករក្សាឧបោសថ ។ បុរោហិតក៏មិនព្រមសមាទានឧបោសថ ។ គ្រានោះកាលព្រះរាជាកំពុងសាកសួរពួកអាមាត្យថា អ្នកទាំងឡាយសមាទានឧបោសថឬ ទើបត្រាស់សួរបុរោហិតនោះដែលជាអ្នកស៊ីសំណូកនិងកាត់ក្តីដោយអំពើកោងក្នុងពេលថ្ងៃ ហើយមកកាន់ទីគាល់ថា លោកអាចារ្យ លោកសមាទានឧបោសថហើយឬ បុរោហិតនោះទូលនូវពាក្យកុហកថា ទូលព្រះបង្គំសមាទានហើយ ហើយក៏ចុះអំពីប្រាសាទទៅ ។ កាលនោះ អាមាត្យម្នាក់ សួរថា លោកមិនបានសមាទានឧបោសថមិនមែនឬ បុរោហិតនោះពោលដោះខ្លួនថា ខ្ញុំបរិភោគអាហារក្នុងកាលប៉ុណ្ណោះ ខ្ញុំត្រឡប់ទៅផ្ទះហើយនឹងខ្ពុរមាត់អធិដ្ឋានឧបោសថ មិនបរិភោគអាហារក្នុងពេលល្ងាច ខ្ញុំរក្សាឧបោសថសីលក្នុងពេលយប់ ដោយប្រការដូច្នេះ ខ្ញុំនឹងមានឧបោសថកម្មពាក់កណ្តាល ។ អាមាត្យនោះពោលថា សាធុ លោកអាចារ្យ ។ គាត់ទៅផ្ទះហើយបានធ្វើយ៉ាងនោះ ។

ថ្ងៃមួយ កាលបុរោហិតនោះ អង្គុយក្នុងសាលា ស្ត្រីអ្នកមានសីលម្នាក់មកឈរប្តឹង កាលមិនបានឱកាសក៏ត្រឡប់ទៅផ្ទះ ទើបគិតថា អញនឹងមិនលះឧបោសថកម្ម លុះដល់ពេល នាងក៏ខ្ពុរមាត់ ។ ខណៈនោះ មានអ្នកនាំផ្លែស្វាយទុំមកឲ្យព្រាហ្មណ៍បុរោហិតមួយចង្កោម ។ ព្រាហ្មណ៍បុរោហិត ដឹងថា ស្រីនោះសមាទានឧបោសថ ទើបចាប់ស្វាយបញ្ជូនទៅឲ្យ ព្រមទាំងពោលថា ចូរនាងបរិភោគស្វាយទុំទាំងនេះសិន ហើយសឹមសមាទានឧបោសថចុះ ។ ស្រីនោះបានធ្វើតាមនោះ ។ កុសលកម្មរបស់ព្រាហ្មណបុរោហិតមានប្រមាណ

ប៉ុណ្ណោះ ។

ក្នុងកាលកន្លងមក ព្រាហ្មណ៍បុរោហិតនោះធ្វើកាលកិរិយាហើយ បានទៅកើតលើសិរិសេយ្យាសនៈ ដែលប្រដាប់តាក់តែងហើយ ក្នុងវិមានមាសដ៏រុងរឿង មានភូមិភាគជារមណីយដ្ឋានក្នុងសួនអម្ពវ័ន មានបរិមណ្ឌលប្រមាណ ៣ យោជន៍ ក្បែរប្រាំងស្ទឹងកោសិកិគង្គានទីក្នុងហិមវន្តប្បទេស ដូចបុគ្គលដែលដេកលក់ហើយភ្ញាក់ឡើង មានសរីរៈដែលប្រដាប់តាក់តែងល្អហើយ ទ្រទ្រង់នូវរូបឆោមដ៏ស្រស់ស្អាត ចោមរោមដោយទេពកញ្ញា ១៦០០០ ជាបរិវារ ។ គាត់បានសិរីសម្បត្តិនោះក្នុងពេលយប់ប៉ុណ្ណោះ ។ ពិតហើយ ទេវបុត្តនោះបានសោយវិបាកសមគួរដល់កម្មដែលខ្លួនធ្វើទុក ដោយភាវៈជាវេមានិកប្រេត ។ ព្រោះហេតុនោះ ក្នុងកាលថ្ងៃរះឡើង គាត់ត្រូវទៅកាន់ចម្ការស្វាយ ខណៈដែលឈានចូលទៅកាន់ចម្ការស្វាយប៉ុណ្ណោះ អត្តភាពជាទិព្វ ក៏អន្តរធានទៅ អត្តភាពប្រមាណប៉ុនដើមត្នោតកម្ពស់ ៨០ ហត្ថ ក៏កើតឡើង ភ្លើងឆេះពេញរាងកាយ ដូចផ្កាចារដែលរីកពេញទំហឹងដូច្នោះ ។ ម្រាមនីមួយៗនៃដៃទាំងសងខាង មានក្រចកប៉ុនផ្លែចបធំ គាត់យកក្រចកទាំងនោះខ្វារសាច់ខ្នងរបស់ខ្លួនមកបរិភោគ សោយទុក្ខវេទនា ស្រែករោទ៍ ។ កាលព្រះអាទិត្យលិចហើយ សរីរៈនោះក៏អន្តរធានទៅ សរីរៈជាទិព្វក៏កើតឡើងជំនួស ។ ពួកអ្នករបាំដែលជាទិព្វប្រដាប់តាក់តែងហើយដោយទិព្វាលង្ការ នាំគ្នាកាន់តូរ្យតន្ត្រី មកចោមរោមបម្រើ កាលទទឹងសោយមហាសម្បត្តិ ទើបឡើងកាន់ប្រាសាទដែលជាទិព្វក្នុងចម្ការអម្ពវ័នជារមណីយដ្ឋាន ។ វេមានិកប្រេតទាំងនោះ បានទូវចម្ការ

ស្វាយដែលមានបរិមណ្ឌល ៣ យោជន៍ ដោយផលនៃការឲ្យផ្លែស្វាយដល់ស្ត្រីដែលសមាទានឧបោសថ តែព្រោះផលនៃការស៊ីសំណូក កាត់ក្តីដោយអំពើវៀច ទើបត្រូវខ្វេះសាច់ខ្នងខ្លួនឯងមកបរិភោគនិងព្រោះផលនៃឧបោសថ-កម្មពាក់កណ្តាល ទើបបានសោយយសដែលជាទិព្វ ចោមរោមដោយស្រីរបាំ ១៦០០០ ជាបរិវារ បម្រើដោយប្រការដូច្នេះ ។

កាលនោះ ព្រះបាទពារាណសី ឃើញទោសក្នុងកាមារម្មណ៍ ទើបយាងចេញសាងព្រះផ្នួសជាតាបស ធ្វើបណ្ណសាលាត្រង់ភូមិបទេស ដែលគួរជាទីត្រេកអរ ផ្នែកខាងក្រោមនៃស្ទឹងគង្គា គង់នៅញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយឧញ្ឆាចរិយវត្ត គឺការត្រាច់បិណ្ឌបាតចិញ្ចឹមជីវិត ។ ថ្ងៃមួយ ផ្លែស្វាយទុំប្រមាណប៉ុនក្អម ធ្លាក់មកអំពីចម្ការស្វាយនោះ អណ្តែតមកតាមខ្សែស្ទឹងគង្គា មកដល់ត្រង់កំពង់ទឹក ដែលជាទីប្រើប្រាស់របស់តាបសនោះ តាបសកំពុងលាងមាត់ ឃើញផ្លែស្វាយទុំនោះអណ្តែតមក ទើបចុះហែលទឹក នាំមកអាស្រមបទ ទុកក្នុងរោងភ្លើង ពុះដោយកាំបិត ហើយឆាន់ល្មមតែញុំាងជីវិតឲ្យរស់ ចំណែកដ៏សេស យកស្លឹកចេកបិទទុក ហើយឆាន់ផ្លែស្វាយនោះរាល់ថ្ងៃរហូតអស់ ។ កាលផ្លែស្វាយទុំនោះអស់ហើយ ក៏មិនចង់ឆាន់ផ្លែឈើដទៃៗ ព្រោះជាប់នឹងរស ទើបតាំងចិត្តថានឹងឆាន់តែផ្លែស្វាយទុំប្រភេទនេះប៉ុណ្ណោះ ទើបទៅអង្គុយត្រង់មាត់ស្ទឹងគិតថា បើមិនបានផ្លែស្វាយទុំនឹងមិនព្រមក្រោកឡើង ។ តាបសនោះ មិនព្រម ទំពា ឆាន់ អង្គុយចាំមើលផ្លែស្វាយត្រង់មាត់ស្ទឹងនោះអស់ ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ៥ ថ្ងៃ រហូតដល់ ៦ ថ្ងៃ រាងកាយក៏ស្គាំង

ស្គម ព្រោះខ្យល់និងកម្ដៅថ្ងៃ ។ លុះដល់ថ្ងៃទី ៧ ទេពធីតារក្សាស៊ឹង ពិចា-រណាមើលដឹងហេតុនោះហើយគិតថា តាបសនេះធ្លាក់នៅក្នុងអំណាចនៃចំណង់ ស៊ូអត់អាហារដល់ទៅ ៧ ថ្ងៃ មកអង្គុយចាំមើលត្រង់ស៊ឹងគន្ធា ការដែលអញ មិនប្រគេនផ្លែស្វាយទុំដល់តាបសនេះ មិនសមគួរឡើយ បើតាបសនេះ មិន បានផ្លែស្វាយទុំទេ មុខជាស្លាប់ អញនឹងប្រគេនដល់លោក ទើបមកឈរលើ អាកាស ត្រង់ស៊ឹងគន្ធា កាលនឹងសន្ទនាជាមួយតាបសនោះ បានពោលគា ថាដំបូងថា

បពិត្រព្រាហ្មណ៍ លោកពេញចិត្តនឹងអ្វី ប៉ុនប៉ងអ្វី ប្រាថ្នាអ្វី ស្វែងរកអ្វី ទើបអង្គុយម្នាក់ឯងក្នុងរដូវក្ដៅ ដោយប្រយោជន៍ អ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជន្ទោ** បានដល់ អធ្យាស្រ័យ ។ បទថា **អធិប្បាយោ** បានដល់ ការគិត ។ បទថា **សម្មសិ** សេចក្ដីថា លោកប្រាថ្នា អ្វី ។ បទថា **យម្មនិ** បានដល់ ក្នុងរដូវក្ដៅ ។ បទថា **ឯសំ** បានដល់ ស្វែង រក ។

ទេពធីតា ហៅតាបសនោះថាព្រាហ្មណ៍ ព្រោះបួសហើយ ។ លោក អធិប្បាយទុកថា នៃព្រាហ្មណ៍ លោកបំណងដូចម្ដេច គិតដូចម្ដេច ប្រាថ្នាអ្វី ស្វែងរកអ្វី ព្រោះត្រូវការអ្វី ទើបមកអង្គុយមើលស៊ឹង ត្រង់ប្រាំងគន្ធានេះ ។ តាបសបានស្ដាប់ដូច្នោះ ទើបពោលគាថា ១០ ថា

ក្អមដាក់នូវទឹកដ៏ធំ មានទ្រង់ទ្រាយស្អាតបាត មានឧបមាយ៉ាង

ណា ផ្លែស្វាយទុំដ៏ឧត្តមដោយពណ៌និងក្លិននិងរស ក៏មានឧប-មេយ្យយ៉ាងនោះ ។ ម្នាលនាងមានអវយវៈត្រង់កណ្តាល ( ចង្កេះ ) មិនមានមន្ទិល អាត្មាបានឃើញផ្លែស្វាយនោះ អណ្តែតតាមខ្សែទឹក ក៏ចាប់ផ្លែស្វាយនោះ ដោយដៃទាំងពីរ ហើយនាំយកទៅកាន់រោងបូជាភ្លើង ។ លំដាប់នោះ អាត្មាបាន ដាក់ផ្លែស្វាយ លើស្លឹកចេកទាំងឡាយ ដោយខ្លួនឯង ចិតនូវ ផ្លែស្វាយនោះដោយកាំបិតហើយ ( ឆាន់ ) ផ្លែស្វាយនោះ នាំចេញ នូវសេចក្តីស្រេកឃ្លានរបស់អាត្មាបាន ។ អាត្មានោះ ប្រាសចាក សេចក្តីក្រវល់ក្រវាយ លុះផ្លែស្វាយអស់ហើយ ក៏អត់ទ្រាំបាន ដោយលំបាក មិនបានសេចក្តីត្រេកអរ ក្នុងផ្លែឈើទាំងឡាយ ឯទៀតណាមួយ ។ ផ្លែស្វាយនោះ នឹងនាំមកនូវសេចក្តីស្លាប់ ដល់អាត្មាដោយពិត ព្រោះរីងស្គម ព្រោះផ្លែស្វាយមានរស ឆ្ងាញ់ មានរសផ្អែមលើសលុប ជាទីពេញចិត្ត ។ អាត្មាបានស្រង់ ផ្លែស្វាយដែលកំពុងអណ្តែតក្នុងអន្លង់ដ៏ធំ អំពីស្ទឹង អាត្មានៅ ( ដោយសេចក្តីស្រេកឃ្លាន ) ព្រោះហេតុណា ហេតុនោះទាំង អស់អាត្មាបានប្រាប់ដល់នាង ។ អាត្មាអង្គុយអាស្រ័យនូវស្ទឹង ជាទីរីករាយ ស្ទឹងនេះធំទូលាយ ប្រកបដោយត្រី នាងកុំអាល រត់ទៅ ចូរប្រាប់ខ្លួននោះដល់អាត្មាសិន ។ ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈត្រង់កណ្តាល ( ចង្កេះ ) ដ៏ល្អ

នាងមានរូបដូចដំបារមាសដ៏រលើង ( មានដំណើរ ) ដូចជាកូនខ្លាដែលកើតក្នុងញកភ្នំ ( មកក្នុងទីនេះ ) ដើម្បីអ្វី ។ នាងនារីទាំងឡាយណាជាអ្នកបម្រើពួកទេវតា ក្នុងទេវតាទាំងឡាយផង ស្រីទាំងឡាយណា ប្រកបដោយរូបក្នុងមនុស្សលោកផង ស្រីទាំងឡាយនោះប្រាកដស្មើដោយរូបនៃនាងមិនមានក្នុងទេវគន្ធព្វនិងមនុស្សលោកឡើយ ម្នាលនាងមានអវយវៈខាងដើម ( ភ្លៅ ) ដ៏ល្អ អាត្មាសួរហើយ ចូរប្រាប់នាមនិងគោត្តផង ផៅពង្សទាំងឡាយផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វារិធរោ កុម្ភោ** បានដល់ ក្អមទឹក ។ បទថា **សុបរិណាហវា** បានដល់ មានទ្រង់ទ្រាយល្អ ។ បទថា **វណ្ណគន្ធរសុត្តមំ** សេចក្ដីថា ឧត្តមដោយពណ៌ ក្លិននិងរសទាំងឡាយ ។ បទថា **ឱស្សាន** ស្មើគ្នានឹង **ឱស្សា** ប្រែថា ឃើញហើយ ។ បទថា **អមលមជ្ឈិមេ** បានដល់ មានចង្កេះប្រាសចាកមន្ទិល ។ តាបសកាលនឹងសន្ទនាប្រាស្រ័យជាមួយទេវតា ទើបពោលយ៉ាងនេះ ។ បទថា **ទាណីភិ** បានដល់ ដៃទាំង ២ ។ បទថា **អគ្យាយតនមាហរិ** សេចក្ដីថា បាននាំមកកាន់រោងបូជាភ្លើងរបស់ខ្លួន ។ បទថា **វិករប្បេត្វា** បានដល់ ចិតហើយ ។ បាឋៈជា **វិករេត្វា** ដូច្នេះក៏មាន ។ នៅមានបាឋៈដ៏សេសមួយបទទៀត គឺបទថា **ទានិ** ។

បទថា **អហាសិ មេ** សេចក្ដីថា លុះខ្ញុំដាក់ផ្លែស្វាយដល់ចុងអណ្ដាតប៉ុណ្ណោះ រសនៃស្វាយទុំនោះ ផ្សាយសព្វសរសៃដែលសម្រាប់ទទួលរសទាំង

៧០០០ កម្ចាត់នូវការឃ្លាននិងការស្រេករបស់ខ្ញុំបាន ។ បទថា **អបេតទរ-ថោ** សេចក្តីថា មានការក្រវល់ក្រវាយផ្លូវកាយ ផ្លូវចិត្តប្រាសទៅហើយ ។ ព្រោះថា ផ្លែស្វាយទុំនោះ កម្ចាត់នូវសេចក្តីក្រវល់ក្រវាយរបស់ខ្ញុំបាន ដូចបរិភោគភោជនដែលមានរសល្អ ។ បទថា **ព្យន្តីភូតោ** សេចក្តីថា ផ្លែស្វាយនោះក៏អស់ទៅ អធិប្បាយថា ជាអ្នកមានផ្លែស្វាយទុំអស់ទៅហើយ ។

បទថា **ឧក្កុក្កុមោ** សេចក្តីថា ប្រកបទៅដោយទុក្ខដែលមិនគួរត្រេកអរ គឺដោយទុក្ខលំបាកផ្លូវកាយនិងការចង្អៀតចង្អល់ផ្លូវចិត្ត ។ តាបសសម្តែងអត្ថថា ព្រោះខ្ញុំមិនដល់នូវការត្រេកអរ សូម្បីត្រឹមតិចតួចក្នុងផ្លែចេកនិងផ្លែខ្នុរជាដើមដទៃណាមួយឡើយ ផ្លែចេកនិងផ្លែខ្នុរទាំងអស់គ្រាន់តែខ្ញុំដាក់ដល់អណ្តាតក៏សម្រេចការផ្អែតក្លាម គឺមិនចង់បរិភោគ ។ បទថា **សោសិត្វា** សេចក្តីថា ព្រោះស្គាំងស្គម ទាក់ទងដោយការអត់អាហារ ។ បទថា **តំ មមំ** សេចក្តីថា ផ្លែស្វាយនោះគង់នឹងធ្វើនូវការស្លាប់មកដល់ខ្ញុំបាន ។ បទថា **យស្ស** សេចក្តីថា ផ្លែស្វាយណាគប្បីមាន គឺផ្លែស្វាយរមែងមាន ។ លោកអធិប្បាយថា ផ្លែស្វាយឯណា បានញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់ខ្ញុំ ។ បទថា **វុយ្ហមានំ** សេចក្តីថា កំពុងអណ្តែតមកតាមអន្លង់ទឹក ពោលគឺ អន្លង់ទឹកដែលមានក្រខ្សែជ្រៅផង ធំផង អធិប្បាយថា ខ្ញុំរើសផ្លែស្វាយទុំឡើងអំពីស្ទឹងនោះ ទើបខ្ញុំយល់ថា ផ្លែស្វាយនោះ គង់នាំនូវការស្លាប់មកឲ្យខ្ញុំ ព្រោះកាលមិនបានផ្លែស្វាយនោះ ជីវិតនឹងប្រព្រឹត្តទៅមិនបាន ។ បទថា **ឧបវសាមិ** សេចក្តីថា ខ្ញុំត្រូវសេចក្តីស្រេកឃ្លានបៀតបៀនហើយ ទើបត្រូវនៅក្នុងទីនេះ ។ បទថា **រម្មំ បដិនិ-**

**សិង្គោស្មិ** សេចក្តីថា ខ្ញុំអង្គុយនៅត្រង់ស្ទឹងដែលគួរត្រេកអរ ។ បទថា **បុថុ-លោមាយុតា** **បុថុ** បានដល់ ស្ទឹងធំ ទូលំទូលាយ ដែលត្រីលោមានៅអាស្រ័យ អធិប្បាយថា ទីបែបនេះ គួរជាទីផាសុកសម្រាប់ខ្ញុំ ។ បទថា **អបលាយិនី** បានដល់ កុំគេចទៅ តាបសហៅទេវតានោះថា នាងចូរឈរចំពោះមុខនៃខ្ញុំ ។ បាឋៈថា **អបលាសិនី** ដូច្នេះក៏មាន ។ អធិប្បាយថា មានសរីរៈតិះដៀលមិនបាន ដូចមាសដែលដេញមន្ទិលចេញហើយ ។ បទថា **កិស្ស ហា** សេចក្តីថា តាបសសួរថា នាងមកទីនេះ ព្រោះហេតុអ្វី ។ បទថា **រូប-បដ្ដលូមដ្ឋីវ** សេចក្តីថា មានរូបដ៏រលើងដូចដំបារមាស ។ បទថា **ព្យគ្ឃីរ** សេចក្តីថា ដូចស្តេចខ្លាជំទង់ ដើរដោយអាកាប្បកិរិយាល្វតល្វន់ ។ បទថា **ទេវានំ** បានដល់ ទេវតាជាន់កាមាវចរទាំង ៦ ។ បទថា **យា ច មនុស្ស-លោកស្មឹ** សេចក្តីថា ស្ត្រីមានរូបក្នុងមនុស្សលោកទាំងឡាយណាក្តី ។ បទថា **រូបេនន្វាគតិត្ថិយោ** បានដល់ ស្រីដែលសម្បូរដោយរូបសម្បត្តិ ។

បទថា **ឧត្តិ** សេចក្តីថា ដោយខ្លួនបំណាំងនឹងសរសើរទេពធីតា ទើបតាបសពោលយ៉ាងនេះ ។ តាបសនោះមានបំណងថា ទេវនារីនិងស្រីទាំងឡាយនោះ មិនមានកន្លែងស្មើដូចនាងដោយរូប ។ បទថា **គន្ធព្វមានុសេ** សេចក្តីថា ក្នុងពួកគន្ធព្វនិងមនុស្សលោកដែលអាស្រ័យក្លិនក្រអូប មានក្លិនឫសជាដើមព្រោះព្រំ ។ បទថា **ចារុបុព្វង្គិ** សេចក្តីថា ប្រកបទៅដោយអវៈយវៈ ត្រគាក ភ្លៅ ល្អដូចមាស ។ បទថា **នាមញ្ច ពន្ធវេ** សេចក្តីថា តាបសពោលថា សូមនាងប្រាប់នាម គោត្ត និងពូជពង្សរបស់ខ្លួនដល់ខ្ញុំចុះ ។

លំដាប់នោះ ទេពធីតាបានពោល ៨ គាថាដោយសេចក្ដីថា

បពិត្រព្រាហ្មណ៍ លោកគង់នៅអាស្រ័យស្ទឹងឈ្មោះកោសិកី ជាទីរីករាយណា ខ្ញុំមានលំនៅត្រង់ខ្សែទឹកដ៏កាច មានអន្ទង់ជាទីហូរទៅនៃទឹកដ៏ប្រសើរ អាស្រ័យនៅហើយ ( ក្នុងស្ទឹងនោះ ) ។ ជ្រោះភ្នំដ៏ច្រើន កុះករដោយឈើផ្សេងៗរមែងមានក្នុងទីចំពោះមុខខ្ញុំ រមែងហូរទៅក្នុងរដូវភ្លៀង ។ម្យ៉ាងទៀតស្ទឹងដ៏ច្រើន មានទឹកហូរចេញអំពីព្រៃ ទ្រទ្រង់នូវគំនរទឹកដ៏ខៀវ ស្ទឹងដ៏ច្រើន មានរូបភាពដូចជានាគ រមែងញ៉ាំងខ្ញុំឲ្យពេញដោយទឹក ។ ដើមស្វាយ ដើមព្រីង ដើមខ្នុរសម្ល ដើមក្ទម្ព ដើមត្នោត និងដើមល្វា ជលជាតទាំងឡាយដ៏ច្រើន រមែងចូលទៅកាន់ស្ទឹងទាំងនោះរឿយៗ ។ ផ្លែឈើណាមួយ នៅក្បែរមាត់ច្រាំងទាំងពីររមែងជ្រុះទៅក្នុងទឹក ផ្លែឈើនោះរសាត់ទៅតាមអំណាចនៃខ្សែទឹក ដោយឥតសង្ស័យ ។ បពិត្រលោកជាអ្នកប្រាជ្ញមានប្រាជ្ញាច្រើន លោកជ្រាបហេតុនុ៎ះហើយ សូមស្ដាប់ពាក្យខ្ញុំចុះ បពិត្រព្រះជនាធិបតី សូមលោកកុំពេញចិត្តឡើយ ចូរបដិសេធនូវការជាប់ចំពាក់ដោយតណ្ហា ។ បពិត្រព្រះរាជិសី អ្នកញ៉ាំងដែនឲ្យចម្រើន លោកកំពុងចម្រើន ( ដោយសាច់និងឈាម ) ប្រាជ្ញាសេចក្ដីស្លាប់ដោយហេតុណា ខ្ញុំពុំសំគាល់នូវលោកថា ជាអ្នកចម្រើនដោយប្រាជ្ញា ដោយហេតុនោះទេ ។

បិតាទាំងឡាយ ( ព្រហ្ម ) និងគន្ធព្វព្រមទាំងទេវតា រមែង ដឹងនូវភាពនៃបុគ្គលនោះថា ជាអ្នកលុះក្នុងអំណាចនៃតណ្ហា ម្យ៉ាងទៀត ឥសីទាំងឡាយណាក្នុងលោក ជាអ្នកមានចិត្ត សង្រួមហើយ មានតបៈ ឥសីទាំងឡាយនោះរមែងឥតសង្ស័យ ( សូម្បី ) ពួកអ្នកមានយសជាអ្នកបម្រើ ( ឥសីទាំងនោះ ក៏ដឹងការនោះតៗគ្នាទៀត ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោសិកី** សេចក្តីថា នៃព្រាហ្មណតាបស លោកអង្គុយចំពោះស្ទឹងកោសិកីគង្គាដែលគួរត្រេកអរណា ។ បទថា **កូសាលយា វុត្ថា** សេចក្តីថា ខ្ញុំអាស្រ័យនៅត្រង់ស្ទឹងនោះដែលមានក្រសែខ្លួល ខ្ចាញ់ ប្រកបដោយអន្លង់ទឹកធំ អធិប្បាយថា ខ្ញុំនៅក្នុងវិមានដែលតាំងនៅក្នុង ស្ទឹងគង្គា ។ បទថា **វារាវិវហោយសា** សេចក្តីថា មានទឹកហូរខ្វួលខ្ចាញ់ ប្រកបដោយអន្លង់ទឹកធំ ។ បទថា **បមុខា** សេចក្តីថា ទេវតាសម្តែងថាជ្រោះ និងថ្នារទឹកមានប្រការដូចពោលហើយ រមែងបែរមុខមកកាន់ខ្ញុំ ខ្ញុំជាប្រធាន នៃស្ទឹងទាំងឡាយនោះ ។ បទថា **អភិសន្ទន្តិ** បានដល់ រមែងហូរទៅ អធិប្បាយថា នទីធារទាំងឡាយដែលហូរមកអំពីទីនោះៗ រមែងចូលមកកាន់ ខ្ញុំ គឺស្ទឹងកោសិកីគង្គាទាំងអស់ ។ បទថា **វនគោធា** សេចក្តីថា មិនមែន តែជ្រោះ ស្ទឹង និងភ្នំប៉ុណ្ណោះឡើយ ដោយពិតនោះ ទឹកដែលហូរមកអំពីព្រៃ នោះ ដោយច្រើន រមែងហូរទៅ ។ បទថា **នីលវារិវហិន្ធរា** សេចក្តីថា ទ្រ ទ្រង់នូវទឹក ពោលគឺខ្សែទឹកដែលប្រកបដោយទឹកពណ៌ខៀវដូចកែវមណី ។

បទថា **នាគចិត្តោនា** សេចក្តីថា ទឹកដែលប្រកបដោយទឹក ពោលគឺពណ៌ដែលនាគទាំងឡាយធ្វើឲ្យវិចិត្រក្តី ។ បទថា **វារិនា** សេចក្តីថា នាងទេពធីតាសម្តែងថា ពិតហើយ ស្ទឹងទាំងឡាយជាច្រើនបែបនេះ រមែងហូរទៅតាមក្រសែ គឺញុំាងខ្ញុំឲ្យពេញបរិបូណ៌ដោយទឹកនោះឯង ។ បទថា **តា** បានដល់ ស្ទឹងទាំងឡាយនោះ ។ បទថា **អាវហន្តិ** សេចក្តីថា ទឹកទាំងឡាយនោះ រមែងនាំយកផ្លែស្វាយជាដើមនោះមក ។ បទទាំងអស់នេះជាបឋមាវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ ម្យ៉ាងទៀត បទថា **តា** ជាទុតិយាវិភត្តិពហុវចនៈ ។

បទថា **អាវហន្តិ** សេចក្តីថា ស្ទឹងទាំងនោះ រមែងនាំយកផ្លែស្វាយ ជាដើមទាំងនេះចូលមក អធិប្បាយថា ផ្លែស្វាយជាដើមដែលត្រូវក្តួចទៅ យ៉ាងនេះ រមែងទៅកាន់ក្រខ្សែរបស់ខ្ញុំ ។ បទថា **សោតស្ស** សេចក្តីថា ផ្លែឈើប្រភេទណាជ្រុះចាកដើមឈើ ដែលកើតត្រង់ឆ្នេរស្ទឹងទាំង ២ អណ្តែតទៅក្នុងទឹក ផ្លែឈើប្រភេទទាំងអស់នោះ ឈ្មោះថា ចូលដល់អំណាចនៃខ្សែទឹករបស់ខ្ញុំនោះឯង មិនមានសេចក្តីសង្ស័យក្នុងរឿងនេះ ។ ទេពធីតានោះប្រាប់ហេតុផលដែលស្វាយនោះអណ្តែតមកតាមខ្សែទឹកយ៉ាងនេះ ។ បទទាំង ២ គឺ **មេធាវី បុថុបញ្ញា** ជាអាលបនៈទាំងអស់ ។ បទថា **មា រោចយ** សេចក្តីថា លោកកុំគាប់ចិត្ត ជាប់ជំពាក់ដោយតណ្ហាយ៉ាងនេះឡើយ ។ បទថា **បដិសេធ** បានដល់ ចូរហាមចុះ ពាក្យនេះ ទេពធីតាពោលទូន្មានព្រះរាជា ។ បទថា **វឌ្ឍវំ** បានដល់ សេចក្តីចម្រើនដោយបញ្ញា គឺភាពជាបណ្ឌិត ។ បទថា **រដ្ឋាភិវឌ្ឍន** បានដល់ រាជឥសី ញុំាងរដ្ឋមណ្ឌលឲ្យចម្រើន ។ បទថា

**អាចេយ្យមានោ** សេចក្តីថា ចូរលោកធ្វើអត្តភាព គឺចម្រើនដោយសាច់និង ឈាម ជាអ្នកនៅក្មេងចុះ ។ ទេពធីតាហៅតាបសនោះថា **រាជិសិ** ប្រែថា រាជឥសី លោកអធិប្បាយទុកថា អ្នកនៅជាកំលោះ តែស្គាំងស្គមព្រោះអត់ អាហារ សន្និមទឹងបានសេចក្តីស្លាប់ ព្រោះចំណង់ក្នុងស្វាយ ខ្ញុំមិនសម្គាល់ ភាពជាបណ្ឌិតបែបនេះរបស់អ្នកឡើយ ។ បទថា **តស្ស** សេចក្តីថា បុគ្គល ណាជាអ្នកធ្លាក់ក្នុងអំណាចនៃតណ្ហារមែងដឹងនូវភាពដែលបុគ្គលនោះ ជាអ្នក ធ្លាក់ក្នុងអំណាចនៃតណ្ហាដោយឥតសង្ស័យ ។

កាលទេពធីតាឲ្យតាបសកើតនូវសេចក្តីសង្វេគ ទើបពោលយ៉ាងនេះថា ព្រហ្មដែលដល់នូវការរាប់ថាជាបិតា គន្ធព្វ ព្រមទាំងកាមាវចរទេព និងឥសី ដែលមានចក្ខុទិព្វដូចពោលមកហើយ រមែងដឹងភាពដែលបុគ្គលនោះ ជាអ្នក ធ្លាក់ក្នុងអំណាចតណ្ហា ដោយឥតសង្ស័យ តែលោកអ្នកដែលមានឫទ្ធិទាំង នោះដឹងថា តាបសឈ្មោះនោះ ជាបុគ្គលធ្លាក់នៅក្នុងអំណាចតណ្ហា ដូច្នេះ មិន គួរអស្ចារ្យដល់បរិចារិកជនរបស់ឥសី ដែលជាអ្នកផ្តើមតាំងសេចក្តីព្យាយាម ជាអ្នកទ្រទ្រង់នូវយសទាំងនោះ ក៏នឹងដឹង ព្រោះស្តាប់ពាក្យរបស់ជនទាំងនោះ និយាយគ្នាទៀត ព្រោះឈ្មោះថា អាថ៌កំបាំងរបស់បុគ្គលដែលធ្វើអាក្រក់ រមែង មិនមាន ។

លំដាប់នោះ តាបសបានពោល ៤ គាថា ដោយសេចក្តីថា

បើ ( នរជនណា ) មិនគិតសម្លាប់ បុគ្គលនោះទេ បាបក៏មិន
ចម្រើនដល់នរជននោះ ដែលដឹងច្បាស់នូវធម៌ទាំងពួងរបស់

អ្នកប្រាជ្ញយ៉ាងនេះផង ដឹងនូវការបែកធ្លាយ និងចុតិនៃជីវិតផង ។

ម្នាលនាងជាធំ ដែលពួកឥសីដឹងច្បាស់ហើយ ប្រយោជន៍នៃសត្វលោក នាងដឹងច្បាស់ហើយយ៉ាងនេះ នាងឈ្មោះថាស្វែងរកនូវបាបកម្ម ( ចំពោះខ្លួន ) ព្រោះប្រទេចពាក្យមិនប្រសើរ ។ ម្នាលនាងទេវធីតាមានត្រគាកសាយល្អ បើយើងនឹងស្លាប់លើត្រើយរបស់នាង កាលបើយើងស្លាប់ហើយ តំណិះដំណៀលនឹងបានមកនាងឯង ឥតសង្ស័យឡើយ ។ ម្នាលនាងមានអវយវៈត្រង់កណ្តាលដ៏ល្អ ព្រោះហេតុនោះ នាងឯងចូររក្សានូវកម្មអាក្រក់ កាលបើយើងស្លាប់ហើយ កុំឲ្យជនទាំងអស់ជេរប្រទេចនាងក្នុងកាលជាខាងក្រោយឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវំ វិធិត្វា** សេចក្តីថា ខ្ញុំស្គាល់សីល និងការមិនទៀងឯណា បាបរមែងមិនកពូន គឺមិនចម្រើនដល់នរៈដែលដឹងហើយតាំងនៅ ដូច្នោះ ។ បទថា **វិទូ** បានដល់ អ្នកដឹងច្បាស់ ។ បទថា **សព្វធម្មំ** បានដល់ សុចរិតធម៌គ្រប់យ៉ាង ។ ព្រោះក្នុងគាថានេះ សុចរិតធម៌ ៣ យ៉ាងបំណងយកសព្វធម៌ ។ បទថា **វិទ្ធំសនំ** បានដល់ ការបែកធ្លាយ ។ បទថា **ចវនំ** បានដល់ ចុតិ ។ បទថា **ជីវិតស្ស** បានដល់ អាយុ ។ លោកអធិប្បាយទុកថា បាបរមែងមិនកពូន គឺមិនចម្រើនដល់បុគ្គលដែលជាបណ្ឌិតដឹងច្បាស់ហើយ តាំងនៅយ៉ាងនេះ គឺដឹងច្បាស់នូវសុចរិតធម៌ទាំងពួង និង

ការមិនទៀងនៃជីវិត ។

បទថា **សចេ ច ចេតេតិ វធាយ តស្ស** សេចក្តីថា បើនរៈនោះមិនគិត គឺមិនត្រិះរិះដើម្បីសម្លាប់បុគ្គលដទៃ ដែលដល់នូវសេចក្តីសុខ បានដល់មិនញុំាងបុគ្គលដទៃ ឬទ្រព្យមត៌កនៃបុគ្គលនោះឲ្យវិនាស ក៏ខ្ញុំមិនគិតដើម្បីសម្លាប់ បុគ្គលណាមួយ អង្គុយរង់ចាំមើលស៊ើង ធ្វើនូវសេចក្តីអាល័យក្នុងស្វាយទុំតែម្យ៉ាង នាងពិនិត្យមើល បានឃើញអកុសលកម្មណាមួយរបស់ខ្ញុំដែរឬទេ ។ បទថា **ឥសិបូគសមញ្ញាតេ** សេចក្តីថា បុគ្គលដែលជាពួកឥសីដឹងទូទៅហើយដោយល្អ គឺឥសីទាំងឡាយដឹងហើយ ។ បទថា **ឯវំ លោក្យា** សេចក្តីថា អ្នកជាបុគ្គលដែលជនបទរ្សាត់បាបដឹងទូទៅហើយយ៉ាងនេះថា ជាអ្នកឧបការៈដល់លោក ។ បទថា **សតិ** នេះ ជាអាលបនៈ ដែលហៅថា នែនាងមានរូបស្អាត ។ បទថា **អនរិយំ បរិសម្ភាសេ** សេចក្តីថា ប្រកបទៅដោយពាក្យចរចាដែលមិនស្អាតជាដើមថា រំលើកដល់មាតាបិតារបស់គេ ។ បទថា **ជិគីសសិ** សេចក្តីថា កាលបាបក្នុងខ្លួនរបស់ខ្ញុំមិនមាន នាងមកបរិកាសខ្ញុំយ៉ាងនេះ ទាំងសម្ងំនូវការស្តាប់ចំពោះខ្ញុំ ឈ្មោះថាស្វែងរកបាបកម្មធ្វើឲ្យកើតឡើងដល់ខ្លួន ។

បទថា **តីរេ តេ** សេចក្តីថា ត្រង់ច្រាំងទឹករបស់នាង ។ បទថា **បុថុ-សុស្សោណិ** សេចក្តីថា ប្រកបទៅដោយត្រគាកដ៏ល្អ គឺសាយ ។ បទថា **បេតេ** សេចក្តីថា កាលខ្ញុំស្លាប់ទៅកាន់បរលោកហើយ ព្រោះមិនបាននូវផ្លែស្វាយ ។ បទថា **បក្កុដ្ឋាយិ** សេចក្តីថា ជនទាំងពួងកុំពោលអាក្រក់ ជេរ

តិះដៀល និន្ទាឡើយ ។ បាឋៈថា **បក្កន្តាសិ** ដូច្នេះក៏មាន ។

ទេពធីតាបានស្តាប់ដូច្នោះ បានពោល ៥ គាថាដោយសេចក្តីថា

ហេតុនេះ ខ្ញុំម្ចាស់ដឹងច្បាស់ហើយ ធម្មតាស្តេចនេះ មិនងាយ អត់ទ្រាំបានទេ ណ្ហើយចុះ ខ្ញុំម្ចាស់នឹងប្រគេនទូវខ្លួនខ្ញុំម្ចាស់ផង ប្រគេនទូវស្វាយនោះផង ដល់លោកម្ចាស់ ដ្បិតលោកម្ចាស់ បានលះបង់នូវកាមគុណទាំងឡាយ ដែលគេលះបង់បានដោយ ក្រ ហើយបានអធិដ្ឋាននូវសីល ជាគ្រឿងស្ងប់រម្ងាប់ផង នូវ សុចរិតធម៌ផង ។

បុគ្គលណា លះបង់នូវចំណងខាងដើម ហើយឋិតនៅក្នុង ចំណងខាងចុងផង ប្រព្រឹត្តនូវអធម៌ផង បាបតែងចម្រើនឡើង ដល់បុគ្គលនោះ ។ សូមលោកម្ចាស់មកចុះ ខ្ញុំម្ចាស់នឹងនាំលោក ម្ចាស់ទៅឲ្យដល់ព្រៃស្វាយនោះ សូមលោកម្ចាស់មានសេចក្តី ខ្វល់ខ្វាយតិចដោយពិតចុះ ខ្ញុំម្ចាស់នឹងនាំទៅដាក់ក្នុងព្រៃស្វាយ ដ៏ត្រជាក់នោះ សូមលោកម្ចាស់គង់នៅ កុំមានសេចក្តីខ្វល់ ខ្វាយ ។ បពិត្រអរិន្ទមៈ ព្រៃស្វាយនោះ ពួកសត្វបក្សីមាន កក្ងក់ ស្រវឹងដោយរសនៃផ្កាឈើ ស្រែកបន្ទឺឡើងហើយ ពួក ក្រៀល ពួកក្ងោក ជាទិព្វ ពួកសត្វស្វាបឈ្មោះកោយដ្ឋិ និង ឈ្មោះមធុសាលិយៈ យំជាមួយនឹងពួកហង្ស ពួកតាវៅ ដែល នៅក្នុងព្រៃស្វាយនោះ ក៏ញុំាងពួកសត្វទាំងនោះ ឲ្យត្រាក់ឡើង

ហើយ ។ ដើមស្វាយទាំងឡាយក្នុងព្រៃនោះ មានចុងមែកជាប
ចុះ ( ព្រោះទម្ងន់ផ្លែ ) ប្រាកដស្មើដោយទីលានដែលពេញដោយ
កណ្តាប់ស្រូវ ដើមដកគាំ ស្រល់និងកុម្ពទាំងឡាយ មាន
ចង្កោមផ្លែសំយុងចុះ ដូចជ្វាយផ្លែត្នោតទុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អញ្ញាតមេតំ** សេចក្តីថា ហេតុដែលលោកអាងថា ការនិទ្ទានឹងមានដល់លោក ពោលទុកដើម្បីត្រូវការផ្លែស្វាយនោះ ខ្ញុំដឹងហើយ ។ បទថា **អាវិសយ្ហសាហិ** សេចក្តីថា ឈ្មោះថា ព្រះរាជាទាំងឡាយ រមែងអត់សង្កត់នូវវត្ថុដែលអត់សង្កត់បានដោយក្រ ដោយហេតុនោះទេពធីតាកាលប្រារព្ធដល់ហេតុនោះ ទើបពោលយ៉ាងនេះ ។ បទថា **អត្តានំ** សេចក្តីថា កាលខ្ញុំបីលោកនាំទៅកាន់ចម្ការស្វាយ ឈ្មោះថា រមែងឲ្យខ្លួនដល់លោក និងឲ្យស្វាយដល់លោកផង ។ បទថា **កាមគុណោ** បានដល់ វត្ថុកាមទាំងឡាយ ដែលប្រដាប់ដោយកញ្ចនមាលានិងស្វេតច្ឆត្រ ។

បទថា **សន្តិញ្ច ធម្មញ្ច** បានដល់ សីល ពោលគឺសន្តិដែលញ៉ាំងភាពទ្រុស្តសីលឲ្យស្ងប់រម្ងាប់និងសុចរិតធម៌ ។ បទថា **អធិដ្ឋិតោសិ** សេចក្តីថា លោកជាបុគ្គលចូលដល់គុណធម៌ទាំងនេះ ជាអ្នកតាំងមាំ ក្នុងគុណធម៌ទាំងនេះ ។ បទថា **បុព្វសញ្ញោគំ** បានដល់ ការជាប់ជំពាក់ដែលមានក្នុងកាលមុន ។ បទថា **បច្ឆាសញ្ញោជនេ** បានដល់ ចំណងដែលមានក្នុងកាលជាក្រោយ ។ លោកពោលទុកដូច្នេះថា តាបសដ៏ចម្រើន បុគ្គលណាលះសិរីរាជសម្បត្តិដ៏ធំ ហើយមកជាប់ក្នុងរសតណ្ហាត្រឹមតែផ្លែស្វាយទុំ មិនគិតដល់

ខ្យល់និងកម្តៅថ្ងៃ អន្ទាយសុបសៅត្រង់ធ្នេរសុឹង បុគ្គលនោះចូងមហាសមុទ្ទ មិនបាន ដូចគ្នានឹងបុគ្គលដែលលិចចុះក្នុងទីបំផុតប្រាំង បុគ្គលណាធ្លាក់នៅក្នុងអំណាចរសតណ្ហា ប្រព្រឹត្តធម៌តែម្យ៉ាង បាបដែលធ្វើដោយរសតណ្ហាតែងបន្ថែមដល់បុគ្គលនោះ ទេពធីតានោះពោលតិះដៀលតាបសយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **កាមំ អប្បោស្សុក្កោ ភវ** សេចក្តីថា លោកត្រូវជាបុគ្គលមិនមានអាល័យក្នុងចម្ការស្វាយដោយចំណែកមួយចុះ ។ បទថា **សីតស្មឹ** សេចក្តីថា ខ្ញុំនឹងជាបុគ្គលដែលនាំលោកទៅត្រង់ចម្ការស្វាយដ៏ត្រជាក់នោះ ។ បទថា **តំ** សេចក្តីថា កាលទេពធីតាពោលយ៉ាងនេះហើយ ទើបបីតាបស ដាក់ផ្អិបនឹងដើមទ្រូង ហោះទៅក្នុងអាកាស ឃើញទិព្វអម្ពវ័នដែលមានបរិមណ្ឌល ៣ យោជន៍ និងបានស្តាប់សំឡេងសកុណបក្សី ហើយទើបប្រាប់តាបសដោយពាក្យយ៉ាងនេះថា **តំ** ជាដើម ។ បទថា **បុប្ផសមត្តេហិ** សេចក្តីថា ស្រវឹងដោយរសនៃបុប្ផជាតិ ។ បទថា **វគ្គរេដ្ឋភិ** សេចក្តីថា ចម្ការអម្ពវ័ននោះ ដេរដាសទៅដោយហ្វូងបក្សីទាំងឡាយដែលមានកក្កក់ ។ ឥឡូវនេះ កាលទេពធីតានឹងប្រាប់ឈ្មោះបក្សីទាំងនោះ ទើបពោលពាក្យជាដើមថា **កោញ្ចា** ប្រែថា សត្វក្រៀលដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ធិយា** ប្រែថា ដែលជាទិព្វ ។ បទថា **កោយដ្ឋិមធុសាលិយា** សេចក្តីថា ទេពធីតាសម្តែងថា ទិព្វសកុណបក្សីទាំងនេះ គឺក្រៀល ក្ងោក លលកនិងបក្សីរោមមាស ដែលមានផ្ទួតកក្កូរសេរសើរ រមែងនៅក្នុងចម្ការស្វាយនេះ ។ បទថា **ក្វជិតា ហំស**

**ប្ជគេហិ** សេចក្តីថា មានហ្វូងហង្សទំជាគូ រងាវសំឡេងពីកោះវង់ ។ បទថា **កោកិលេត្ថ បពោធរេ** សេចក្តីថា តាវៅទាំងឡាយនៅក្នុងចម្ការអម្ពវ័ននោះ យំដាស់សត្វទាំងឡាយឲ្យក្រាក់ ។ បទថា **អម្ពេត្ថ** សេចក្តីថា មានដើមស្វាយនៅក្នុងចម្ការអម្ពវ័ននោះ ។ បទថា **វិប្បសូនគ្គា** សេចក្តីថា មែកខាងចុងជាបចុះ ព្រោះពេញទៅដោយចង្កោមផ្លែ ។ បទថា **បលាលខលសន្និភា** សេចក្តីថា មានផ្លែរយោង ដូចគ្នានឹងកណ្តាប់ស្រូវសាលី ព្រោះពោរពាសទៅដោយពន្លកនិងផ្កា ។ បទថា **បក្កតាលវិលម្ពិនោ** សេចក្តីថា ទេពធីតាពណ៌នាដល់ចម្ការអម្ពវ័នថា មានផ្លែទុំសំយុង ក្លិនរងរៀងហើយ ដើមឈើបែបនេះ មាននៅក្នុងចម្ការស្វាយនេះ ។

កាលទេពធីតាពណ៌នាហើយ នាំតាបសមកក្នុងចម្ការអម្ពវ័ន ហើយប្រាប់ថា សូមលោកទំពាធាន់ស្វាយទាំងឡាយ ញុំាងនូវចំណង់របស់ខ្លួនឲ្យពេញបរិបូណ៌ក្នុងចម្ការអម្ពវ័ននេះ ហើយក៏ចៀសចេញទៅ ។ កាលតាបសទំពាធាន់ផ្លែស្វាយឆ្អែតស្កប់ស្កល់ តាមចំណង់ហើយ សម្រាកហើយ ទើបត្រាច់ទៅក្នុងចម្ការអម្ពវ័ន ក៏បានជួបប្រេតកំពុងសោយទុក្ខនោះ តែមិនអាចចរចាគ្នាបាន ។ កាលព្រះអាទិត្យអស្តង្គតហើយ ឃើញប្រេតនោះ មានស្រីបាំបោមរោមបម្រើ សោយទិព្វសម្បត្តិ ទើបពោល ៣ គាថាដោយសេចក្តីថា

អ្នកទ្រទ្រង់នូវផ្កាកម្រង ទ្រទ្រង់នូវឈ្នួត ប្រដាប់ដោយគ្រឿង
អាភរណៈ ពាក់នូវពាហុរក្សវ័ត្ន ( កងកន់ ) ប្រោះព្រំដោយ
ខ្លឹមចន្ទន៍ ឲ្យគេបម្រើក្នុងវេលាយប់ សោយនូវទុក្ខវេទនាក្នុង

វេលាថ្ងៃ ។ ស្រីទាំងឡាយ ១៦.០០០ នេះ ជាស្រីបម្រើរបស់
អ្នក អ្នកជាបុគ្គលមានអានុភាពច្រើនយ៉ាងនេះ អស្ចារ្យគួរឲ្យ
ព្រឺរោម ។ ក្នុងកាលមុន អ្នកបានធ្វើអំពើបាប នាំមកនូវទុក្ខ
ដល់ខ្លួនដូចម្តេច ដែលអ្នកធ្វើក្នុងមនុស្សលោក បានជាស៊ីនូវ
សាច់ខ្នង ( របស់ខ្លួន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាលី** បានដល់ ដែលទ្រទ្រង់នូវកម្រងផ្កាទិព្វ ។ បទថា **តិរីដិ** បានដល់ ទ្រទ្រង់នូវសំពត់ឈ្នួតដែលជាទិព្វ ។ បទថា **កាយុរី** បានដល់ ប្រដាប់អាភរណៈសុទ្ធតែជាទិព្វ ។ បទថា **អង្គទី** សេចក្តីថា ប្រកបដោយកងដៃ និងប្រដាប់ដើមដៃដែលជាទិព្វ ។ បទថា **ចន្ទនុស្សទោ** សេចក្តីថា មានរាងកាយលាបដោយខ្លឹមចន្ទន៍ដែលជាទិព្វ ។ បទថា **បរិចារេសិ** សេចក្តីថា បម្រើឥន្ទ្រិយក្នុងទិព្វសម្បត្តិ ។ បទថា **ទិវា** សេចក្តីថា តែក្នុងពេលថ្ងៃ ត្រូវសោយមហាទុក្ខវេទនា ។ បទថា **យា តេមា** កាត់បទជា **យា តេ ឥមា** ប្រែថា ស្រីទាំងនេះ ។ បទថា **អព្ភុតោ** សេចក្តីថា មិនធ្លាប់មានក្នុងមនុស្សលោកឡើយ ។ បទថា **លោមហំសនោ** សេចក្តីថា ជនទាំងឡាយណាឃើញលោក រោមរបស់បុគ្គលនោះរមែងព្រឺ ។ បទថា **បុព្វេ** បានដល់ ក្នុងភពមុន ។ បទថា **អត្តទុក្ខាវហំ** សេចក្តីថា ជាហេតុនាំទុក្ខវេទនាមកកាន់ខ្លួន ។ បទថា **មនុស្សេសុ** សេចក្តីថា តាបសសួរថា លោកធ្វើកម្មអ្វីទុកក្នុងមនុស្សលោក ទើបមកទំពាស៊ីសាច់ខ្នងរបស់ខ្លួនក្នុងកាលឥឡូវនេះ ។

ប្រេតស្គាល់តាបស ទើបទូលថា ទ្រង់ចាំទូលព្រះបង្គំមិនបាន ទូលព្រះបង្គំ ជាបុរោហិតរបស់ទ្រង់ ទូលព្រះបង្គំសោយកាមសុខ ក្នុងពេលយប់នេះ ព្រោះផលនៃឧបោសថកន្លះថ្ងៃដែលខ្លួនបានធ្វើមក ព្រោះអាស្រ័យទ្រង់ តែការដែលសោយទុក្ខវេទនាក្នុងពេលថ្ងៃ ព្រោះផលនៃបាបកម្មដែលធ្វើទុកហើយដូចគ្នា ។ ពិតហើយ ទូលព្រះបង្គំ កាលទ្រង់តាំងទុកក្នុងតំណែងចៅក្រមបាន ជម្រះក្តីមិនយុត្តិធម៌ ស៊ីសំណូក ជញ្ជក់ឈាមប្រជាជនពីក្រោយខ្នង ព្រោះផលនៃកម្មដែលធ្វើទុកនោះ ពេលថ្ងៃ ទូលព្រះបង្គំក៏បានសោយនូវទុក្ខវេទនានេះ ហើយពោល ២ គាថាដោយសេចក្តីថា

ខ្ញុំបានរៀននូវវេទទាំងឡាយ ហើយជាប់ចំពាក់ ក្នុងកាមទាំងឡាយ បានប្រព្រឹត្តមិនជាប្រយោជន៍ដល់ជនដទៃ អស់កាលដ៏យូរអង្វែង ។ បុគ្គលណា ជាអ្នកស៊ីនូវសាច់ខ្នង ( ញុះញង់គេ ) បុគ្គលនោះ ក៏ខ្វារស៊ីនូវសាច់ខ្នងរបស់ខ្លួន ដូចខ្ញុំស៊ីក្នុងថ្ងៃនេះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈេនានិ** បានដល់ វេទទាំងឡាយ ។ បទថា **បដិគ្គយ្ហ** សេចក្តីថា ជាអ្នកទ្រទ្រង់ចាំ ។ បទថា **អចរឹ** បានដល់ បដិបត្តិហើយ ។ បទថា **អហិតាយហំ** សេចក្តីថា ទូលព្រះបង្គំបានបដិបត្តិនូវសេចក្តីវិនាស មិនមែនជាប្រយោជន៍ ។ បទថា **យោ បិដ្ឋិមំសិកោ** សេចក្តីថា បុគ្គលណា ស៊ីនូវសាច់ខ្នងរបស់អ្នកដទៃ រមែងជាអ្នកញុះញង់ ស៊កសៀត ។ បទថា **ឧក្កច្ច** បានដល់ ត្រូវខ្វេះត្រូវខ្វារ ។

កាលប្រេតក្រាបទូលយ៉ាងនេះហើយ ទើបទូលសួរតាបសថា ទ្រង់យាងមកទីនេះបានដូចម្តេច តាបសនិទានរឿងទាំងអស់ឲ្យស្តាប់ដោយពិស្តារ ។ ប្រេតទូលសួរទៀតថា ឥឡូវនេះ ទ្រង់ប្រថាប់នៅទីនេះរហូត ឬយាងទៅទីដទៃ តាបសឆ្លើយថា យើងមិននៅទីនេះឡើយ នឹងត្រឡប់ទៅកាន់អាស្រមបទវិញនោះឯង ប្រេតទូលថា សាធុ ខ្ញុំនឹងទំនុកបម្រុងលោកម្ចាស់ដោយផ្លែស្វាយទុំជាប្រចាំ រួចនាំតាបសទៅក្នុងអាស្រមបទ ដោយអានុភាពរបស់ខ្លួន ទូលសូមបដិញ្ញាថា សូមលោកម្ចាស់កុំអផ្សុក គង់នៅទីនេះចុះ ហើយទូលលាទៅ ។ តាំងពីនោះមក ប្រេតនោះ ក៏ទំនុកបម្រុងតាបសដោយផ្លែស្វាយជានិច្ច ។ តាបសកាលបានឆាន់ផ្លែស្វាយនោះ ក៏ធ្វើកសិណបរិកម្ម ញុំាងឈាននិងអភិញ្ញាឲ្យកើត បានជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងដល់ឧបាសកឧបាសិកាទាំងឡាយហើយ ទ្រង់ប្រកាសអរិយសច្ចធម៌ ក្នុងទីបំផុតនៃសច្ចទេសនា ជនពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាសកទាគាមី ពួកខ្លះបានជាអនាគាមី ហើយទ្រង់ប្រជុំជាតកថា ទេពធីតាក្នុងកាលនោះបានមកជាឧប្បលវណ្ណាក្នុងកាលឥឡូវនេះ តាបសក្នុងកាលនោះ គឺ តថាគតនេះឯង ។

## អដ្ឋកថា កឹឆន្ទជាតក ចប់

# កុម្ភជាតក

[ ៤២១ ] ( ព្រះបាទសព្វមិត្តត្រាស់សួរថា ) អ្នកជាអ្វី មកប្រាកដអំពីកពតាវត្តិង្ស ( ប្រតិស្ឋាន ) លើអាកាសនេះ រស្មីទាំងឡាយរបស់អ្នកផ្សាយចេញអំពីខ្លួន ដូចព្រះចន្ទភ្លឺស្វាងក្នុងវេលាយប់ ឬដូចផ្លេកបន្ទោរធ្លៀលធ្លាត់ ពួដ៏អាកាស ។ អ្នកឯងដើរទៅមិនមានខ្យល់ពួដ៏អាកាស អ្នកដើរក្តីឈរក្តី ពួដ៏អាកាស ឫទ្ធិរបស់ពួកទេវតា ដែលមិនបាច់ដើរទៅកាន់ផ្លូវឆ្ងាយ ( ដោយជើង ) អ្នកបានធ្វើឲ្យដូចជាទីតម្កល់ ចម្រើនល្អ ។ អ្នកឋិតនៅព្រោះអាស្រ័យនូវការទៅពួដ៏អាកាស តើអ្នកជាអ្វី ( អ្នកនិយាយ ) នូវសេចក្តីណាថា អ្នកទាំងឡាយចូរទិញថ្នាំងចុះ ដូច្នេះ តើថ្នាំងនេះសម្រាប់ធ្វើអ្វី ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ។

[ ៤២២ ] ( ព្រះឥន្ទ្រាធិរាជតបថា ) នេះមិនមែនជាក្អមសប្បិទេ មិនមែនជាក្អមប្រេងទេ មិនមែនជាក្អមស្ករអំពៅទេ មិនមែនជាក្អមទឹកឃ្មុំទេ ទោសរបស់ក្អមមានច្រើន សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់នូវទោសដ៏ច្រើន ដែលតាំងនៅក្នុងក្អមចុះ ។ បុគ្គលដើរភ្លាត់ធ្លាក់ជ្រោះ រណ្តៅ គុហា អណ្តូងជ្រាំ រណ្តៅជ្រាំ ទាំងបរិភោគនូវរបស់ដែលមិនគួរបរិភោគដ៏ច្រើន ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលមិនជាធំក្នុងចិត្ត តែងដើរចប្រប់ ដូចគោស៊ីនូវបាយសុរា ជាអ្នកមិនមានទីពឹង តែងចូលទៅច្រៀងឬរាំ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលអាក្រាត ដូចជាពួកអចេលកៈ ដើរទៅ

កាន់ចន្ទោះថ្នល់ ក្នុងស្រុក មានចិត្តវង្វេង ដេកហួសវេលា ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលក្រោកឡើងទ្រេតទ្រោត ញ័រក្បាល ញ័រដើមដៃ បុគ្គលនោះ រាំ ដូចជារូបយន្តដែលធ្វើដោយឈើ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ជនទាំងឡាយត្រូវភ្លើងឆេះរមែងដេកនៅ ឬត្រូវពួកចចកខាំស៊ី បានដល់នូវទោស ត្រូវគេចង គេសម្លាប់ ទាំងសាបសូន្យនូវភោគៈ ព្រោះតែផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលនិយាយនូវពាក្យដែលគេមិនគួរនិយាយ អង្គុយក្នុងទីប្រជុំ របូតសំពត់ស្លៀក ប្រឡាក់ប្រឡូស ដេកជ្រមុចក្នុងកម្អួត ដល់នូវសេចក្តីវិនាស ព្រោះផឹកសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលលើកកម្ពស់ មានភ្នែកក្រហម សំគាល់ថាផែនដីទាំងមូលសុទ្ធតែជារបស់អញ សូម្បីស្តេចជាធំលើផែនដី មានសមុទ្ទទាំង ៤ ជាទីបំផុត ក៏មិនស្មើនឹងអញដែរ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញក្អមនេះ ក៏ពេញដោយសុរានោះចុះ ។ សុរាណា ដែលនាំឲ្យកើតមានះនិងការមើលងាយ នាំឲ្យឈ្លោះប្រកែក នាំឲ្យញុះញង់ នាំឲ្យមានពណ៌សម្បុរអាក្រក់ នាំឲ្យអាក្រាតសំពត់ ឲ្យរត់ផ្តេសផ្តាស ជាគតិ ជាលំនៅរបស់ពួកអ្នកលេងជាន់ចាស់ សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ត្រកូលទាំងឡាយ ស្តុកស្តម្ភ សាយកាយ ( ដោយសំពត់និងទ្រព្យសម្បត្តិ ) មានទ្រព្យច្រើនពាន់ ត្រូវសុរានេះធ្វើកេរ្តិ៍មតិកឲ្យដាច់សូន្យក្នុងលោក សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះ

ចុះ ។ ជនទាំងឡាយញ៉ាំងទ្រព្យសម្បត្តិប្រាក់មាសស្រែចម្ការ និងគោក្របីឲ្យវិនាសអស់ ព្រោះតែសុរាណា ( ម្យ៉ាងទៀតសុរាណា ) ផ្តាច់បង់នូវត្រកូលអ្នកមានទ្រព្យទាំងឡាយ សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុរសមានសភាពក្អឺតក្អឹន តែងជេរនូវមាតានិងបិតា ទាំងចាប់ទោសម្តាយក្មេកឬចាប់ទោសកូនប្រសាស្រី ព្រោះផឹកសុរាណា សូមព្រះអង្គ ទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ស្រីមានសភាពក្អឺតក្អឹន តែងជេរនូវឪពុកក្មេកនិងប្តី ចាប់ទោសខ្ញុំប្រុស ចាប់ទោសអ្នកបម្រើ ព្រោះតែផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលបៀតបៀនសមណៈឬព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌តែងទៅកាន់អបាយដែលមានសេចក្តីបៀតបៀននោះជាហេតុ ព្រោះផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ជនទាំងឡាយប្រព្រឹត្តអាក្រក់ ដោយកាយ វាចានិងចិត្ត លុះប្រព្រឹត្តអាក្រក់ហើយ ទៅកាន់នរក ព្រោះផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ជនទាំងឡាយសូម្បីចំណាយប្រាក់ដ៏ច្រើន អង្វរមិនបាននូវបុរសណា ( ដែលមិនទាន់ផឹកសុរា ) ក្នុងកាលមុនថា ( អ្នកចូរពោលមុសាវាទ ) បុរសនោះ លុះផឹកនូវសុរានោះរួចហើយ ក៏ពោលនូវពាក្យមុសាវាទបាន សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ កាលបើកិច្ចប្រញាប់កើតហើយ បុគ្គលនោះ គេបញ្ជូនទៅក្នុងការបម្រើ ត្រូវគេសួរថា ( អ្នកឯងមករកអ្វី ) រមែងមិនដឹងសេចក្តី ( ដែលគេសួរ ) ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវ

ក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកជនមានចិត្តប្រកបដោយសេចក្តីអៀនខ្មាស ធ្វើនូវភាពជាអ្នកមិនអៀនខ្មាសឲ្យប្រាកដក្តី ពួកជនជាអ្នកប្រាជ្ញមានចិត្តស្ងប់រម្ងាប់ ទៅជាអ្នកប្រមាទដោយសេចក្តីស្រវឹង ហើយនិយាយពាក្យច្រើនក្តី ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកជនដេកប្រគរគ្នា ( ដូចជាកូនជ្រូក ) មិនស៊ីបាយដល់នូវការដេកជាទុក្ខលើផែនដីផង ដល់នូវភាពជាអ្នកមានសម្បុរអាក្រក់ផងដល់នូវតំណិះដំណៀលផង ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកជនដេកធ្លាក់កទន់រងៀក ដូចជាគោដែលគេសំពងនឹងញញួរ កម្លាំងនៃសុរា មិនមែននរជនគ្របសង្កត់បានដោយងាយទេ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកមនុស្សវៀរបង់នូវសុរាណា ដូចជាវៀរនូវពស់ដែលមានពិសដ៏ពន្លឹក នរជនណាគួរផឹកនូវសុរានោះ ដែលមានពិស ស្មើដោយថ្នាំពិសក្នុងលោក សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ព្រះរាជបុត្តរបស់ព្រះបាទអន្ធកវេណ្ហុ ( ជាបងប្អូនគ្នា ) បានយាងទៅក្បែរឆ្នេរសមុទ្ទ ក៏ប្រហារគ្នាទៅវិញទៅមកដោយអង្រែទាំងឡាយ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកអសុរជាអ្នកស្រវឹង ហើយច្យុតចាកតាវត្តិង្សទេវលោក ដែលទៀងទាត់ ( ដោយអាយុ ) ព្រមទាំងមាយា ( របស់អសុរ ) ព្រោះផឹកនូវសុរាណា បពិត្រមហារាជ អ្នកប្រាជ្ញកាលដឹងនូវទឹកស្រវឹងនេះថាជារបស់ឥតប្រយោជន៍ប្រាកដ

ដូច្នោះ តើគួរផឹកនូវទឹកស្រវឹងនោះ ដូចម្តេចកើត ។ ទឹកដោះជូរ ឬទឹកឃ្មុំ មិនមានក្នុងក្អមនោះទេ បពិត្រព្រះរាជាព្រះនាមសព្វមិត្ត ព្រះអង្គជ្រាបច្បាស់យ៉ាងនេះហើយសូមព្រះអង្គទិញនូវសុរាក្នុងក្អមនេះ ដែលខ្ញុំព្រះអង្គក្រាបទូលតាមសភាវៈយ៉ាងនេះចុះ ។

[ ៤២៣ ] ( ព្រះរាជា... ) លោកមិនមែនជាឪពុក ឬម្តាយរបស់ខ្ញុំទេ ជាបុគ្គលទីទៃពីគ្នា តែជាអ្នកសង្គ្រោះដោយប្រយោជន៍ លោកប្រាថ្នានូវប្រយោជន៍ដ៏ឧត្តម ខ្ញុំនោះនឹងធ្វើតាមពាក្យលោកក្នុងថ្ងៃនេះ ។ ខ្ញុំនឹងឲ្យនូវស្រុកសួយ ៥ ផង ខ្ញុំស្រី ១០០ ផង គោ ៧០០ ផង រាជរថ ១០ ទឹមដោយសេះអាជានេយ្យទាំងនេះផង ដល់លោកៗជាអាចារ្យ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ។

[ ៤២៤ ] ( ព្រះឥន្ទ្រ... ) បពិត្រព្រះរាជា ខ្ញុំស្រី ១០០ ចូរជារបស់ព្រះអង្គវិញចុះ ស្រុកសួយនិងគោទាំងឡាយ ចូរជារបស់ព្រះអង្គវិញចុះ រាជរថទាំងឡាយ ដែលទឹមដោយសេះអាជានេយ្យ ចូរជារបស់ព្រះអង្គវិញដែរ ខ្ញុំជាព្រះឥន្ទ ជាធំជាងទេវតាជាន់តាវត្តិង្ស ។ សូមព្រះអង្គសោយនូវក្រយាស្ងោយដែលលាយដោយសាច់ផង នូវបាយាសដែលលាយដោយសប្បិផង សូមព្រះអង្គសោយនូវនំសណ្តែកទាំងឡាយដ៏ផ្អែមផង បពិត្រព្រះជនិន្ទ សូមព្រះអង្គត្រេកអរក្នុងធម៌យ៉ាងនេះ អ្នកផងមិនតិះដៀលទេ ទៅកើតក្នុងឋានសួគ៌ចុះ ។

**ចប់ កុម្ភជាតក ទី ២**

# អដ្ឋកថា

# កុម្ភជាតក

[ ៤២១-៤២៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីផឹកស្រា ៥០០ ដែលជាសម្លាញ់របស់នាងវិសាខាមហាឧបាសិកា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កោ បាតុរាសិ** ដូច្នេះជាដើម ។

បានឮថា គេប្រកាសរឿងមហោស្រពសុរា ក្នុងនគរសាវត្ថី ស្រី ៥០០ នាក់នោះ រៀបចំសុរា មានរសឆ្ងាញ់ទុក ដើម្បីប្ដីដែលទៅលេងមហោស្រព ហើយប្រឹក្សាគ្នាថា យើងទាំងឡាយនឹងលេងមហោស្រព ដូច្នេះហើយ ទើបជនទាំងអស់នោះនាំគ្នាទៅកាន់សម្នាក់នាងវិសាខា ហើយបបួលថា នែសម្លាញ់ពួកយើងទៅលេងមហោស្រពជាមួយគ្នាចុះ កាលនាងវិសាខាបដិសេធថា មហោស្រពនេះ ជាមហោស្រពសុរា យើងមិនផឹកសុរាឡើយ ទើបនាំគ្នាពោលថា សូមនាងថ្វាយទានដល់ព្រះសម្មាសម្ពុទ្ធចុះ ពួកយើងនឹងលេងមហោស្រពជាមួយគ្នា ។ នាងវិសាខាទទួលពាក្យថា សាធុ ទើបបញ្ជូនមនុស្សទៅអារាធនាព្រះបរមសាស្តា ថ្វាយមហាទានហើយ កាន់យកផ្កាកម្រងនិងគ្រឿងក្រអូបជាច្រើន ចោមរោមដោយស្រីទាំងនោះ ទៅកាន់វត្តជេតពនដើម្បីស្តាប់ធម្មកថាក្នុងពេលល្ងាច ។ ស្រីទាំងនោះផឹកសុរាបណ្ដើរ ដើរបណ្ដើររួមជាមួយនឹងនាងវិសាខា ឈរផឹកស្រាត្រង់ខ្លោងទ្វារហើយ ទើបចូលទៅកាន់សម្នាក់ព្រះសាស្តាជាមួយនាងវិសាខា ។ នាងវិសាខាថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង ។ បណ្ដាស្រីទាំងនោះ ស្រីពួកខ្លះរាំ ពួកខ្លះ

ផ្តាំគ្នាទងដៃនិងជើង រហូតដល់ទាស់ទែងគ្នាក្នុងសម្នាក់ព្រះសាស្តានោះឯង ព្រះសាស្តាក៏បញ្ចេញព្រះរស្មីអំពីព្រះលោមា ដោយបំណងឲ្យស្រីទាំងនោះកើតសេចក្តីសង្វេគ ។ ងងឹតបានកើតឡើងហើយក្នុងខណៈនោះ ស្រីទាំងនោះភ័យខ្លាច ត្រូវមរណភ័យគំរាម ដោយហេតុនោះទើបស្រីទាំងនោះស្វាងស្រា ។ ព្រះសាស្តា ទ្រង់បាត់អំពីបល្ល័ង្កដែលប្រថាប់ ទ្រង់ឈរព្ធដ៏កំពូលភ្នំសិនេរុ បញ្ចេញព្រះរស្មីអំពីព្រះឧណ្ណាលោម ហាក់បីដូចមានព្រះចន្ទនិងព្រះអាទិត្យរះឡើង ១០០០ ដួង ។ ព្រះសាស្តាប្រថាប់ឈរលើកំពូលភ្នំសិនេរុនោះឯង ដោយបំណងឲ្យស្រីទាំងនោះកើតនូវសេចក្តីសង្វេគ ទើបត្រាស់គាថា ( ក្នុងធម្មបទ ) ថា

កាលបើលោកសន្និវាស ត្រូវភ្លើងមានរាគៈជាដើម ឆេះទ្រ-
លោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកទាំងឡាយ
ត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ ( ម្តេចឡើយ ) ក៏មិនស្វែងរក
ប្រទីបគឺប្រាជ្ញា ដូច្នេះ ។

ក្នុងកាលចប់គាថា ស្រីទាំង ៥០០ នោះ តាំងនៅក្នុងសោតាបត្តិផល ព្រះសាស្តាយាងមកគង់លើពុទ្ធាសនៈ ត្រង់ស្រមោលព្រះគន្ធកុដិ ។ លំដាប់នោះ នាងវិសាខាថ្វាយបង្គំព្រះសាស្តាហើយ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ទឹកផឹកដែលមានឈ្មោះថាសុរា ជាគ្រឿងទម្លាយហិរិឱត្តប្បៈ នេះកើតតាំងអំពីកាលណា កាលព្រះសាស្តាត្រាស់ប្រាប់ដល់នាងវិសាខា ក៏ទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី មានព្រានព្រៃម្នាក់ឈ្មោះ សុរៈ ជាអ្នកដែនកាសី បានទៅកាន់ព្រៃហិមពាន្ត ដើម្បីស្វែងរកទ្រព្យ ។ ក្នុងព្រៃហិមពាន្តនោះ មានដើមឈើមួយដើម មានដើមត្រង់ ត្រង់ទីកម្ពស់ប្រមាណមួយជួរបុរស មានមែកបែកចេញជា ៣ ក្នុងរវាងប្រគាប ៣ នៃដើមឈើនោះ មានប្រហោងធំប៉ុនពាង កាលភ្លៀងធ្លាក់ទឹកក៏ដក់ពេញ មានដើមសម៉ កន្ទួតព្រៃនិងម្រេច ដុះជុំវិញដើមឈើនោះ ។ ផ្លែនៃដើមឈើនោះទុំហើយ ក៏ជ្រុះចាកទង ធ្លាក់ចូលទៅក្នុងទឹកនោះ ។ ក្បែរៗដើមឈើនោះ មានស្រូវសាលីដុះឯង សេកទាំងឡាយ ពាំយកកួរស្រូវសាលីអំពីទីនោះ ហើយហើរទៅទុំលើដើមឈើនោះ កាលសេកនាំគ្នាចឹកស៊ី គ្រាប់ស្រូវក្តី គ្រាប់អង្ករក្តី ក៏ធ្លាក់ចូលក្នុងទឹកនោះ ទឹកដែលដក់ក្នុងដើមឈើនោះ ត្រូវកម្តៅថ្ងៃក៏កើតមានរស មានពណ៌ក្រហមព្រឿងៗ ដោយប្រការដូច្នេះ ។

ក្នុងរដូវប្រាំង ហ្វូងបក្សីទាំងឡាយដែលស្រេកទឹក ហើរមកផឹកទឹកនោះ ក៏ស្រវឹង ធ្លាក់ចុះត្រង់គល់ឈើ លុះស្វាងបន្តិច ក៏រងាវហើយហើរទៅ ។ សូម្បីឆ្កែព្រៃ និងស្វាជាដើមក៏មានន័យដូចគ្នានេះ ។ ព្រានព្រៃឃើញដូច្នោះចម្លែកក្នុងចិត្តគិតថា បើទឹកនេះពុល សត្វទាំងនេះគង់ស្លាប់ តែសត្វទាំងនេះគ្រាន់តែស្រេងល់បន្តិច ហើយក៏ហើរទៅតាមសប្បាយ ទឹកនេះប្រហែលជាមិនមានពិស គាត់ក៏សាកល្បងផឹកឯង ក៏កើតការស្រវឹងនិងចង់បរិភោគសាច់សត្វ ។ លំដាប់នោះ គាត់ក៏បង្កាត់ភ្លើង ហើយសម្លាប់សត្វដែលរអិលធ្លាក់មកត្រង់គល់ឈើ មានសត្វទទានិងមាន់ជាដើម អាំងលើរងើកភ្លើង ដៃមួយ

រាំ ដៃមួយកាន់សាច់បរិភោគ ។ គាត់នៅក្នុងទីនោះ ១ ថ្ងៃ ២ ថ្ងៃ ។ នៅក្បែរបរិវេណនោះ មានតាបសមួយរូបឈ្មោះវរុណ ព្រានព្រៃដើរទៅកាន់សម្នាក់តាបសនោះ ដោយធុរៈឯណានីមួយ ។ គាត់កើតគំនិតថា អញនឹងផឹកទឹកនេះរួមជាមួយតាបស ទើបដងទឹកដាក់ក្នុងបំពង់ឫស្សីមួយពេញ យួរទៅជាមួយសាច់អាំង ដល់បណ្ណសាលាហើយ បបួលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ចិបទឹកនេះមើលបន្តិចចុះ ហើយជនទាំង ២ ក៏បរិភោគសាច់ផឹកជាមួយគ្នា ។ ដោយប្រការដូច្នេះ ទឹកនោះក៏មានឈ្មោះថាសុរាខ្លះ វរុណីខ្លះ ព្រោះព្រានឈ្មោះសុរៈនិងតាបសឈ្មោះវរុណឃើញមុនគេ ។

ឯសុរៈព្រាននិងវរុណតាបសទាំង ២ នាក់ ក៏គិតថា មានឧបាយរកស៊ីបាន ទើបដួសសុរាដាក់បំពង់ឫស្សីទាល់តែពេញ ហើយនាំគ្នារែកទៅរហូតដល់បច្ចន្តនគរ បានឲ្យមនុស្សទូលដល់ព្រះរាជាថា មានមនុស្សនាំទឹកផឹកមកគាល់ ព្រះរាជាក៏ត្រាស់ឲ្យជនទាំង ២ ចូលគាល់ ទើបនាំទឹកផឹកទៅថ្វាយព្រះរាជាទ្រង់សោយបាន ២-៣ ដង ក៏ទ្រង់ស្រវឹង តែទឹកនោះ សោយបានត្រឹមតែ ២-៣ ថ្ងៃប៉ុណ្ណោះ តមកព្រះរាជាត្រាស់សួរជនទាំង ២ ថា ទឹកប្រភេទនេះ មានក្នុងទីដទៃដែរឬទេ ជនទាំង ២ ក្រាបទូលថា បពិត្រព្រះអង្គមាន ព្រះរាជាត្រាស់សួរថា មានក្នុងទីណា ជនទាំង ២ ទូលថា មាននៅឯព្រៃហិមពាន្ត ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកទាំង ២ ចូរទៅយកមក ។ ជនទាំង ២ ទៅយកមកម្តងជាពីរដង ហើយប្រឹក្សាគ្នាថា ពួកយើងមិនអាចយកមករឿយៗបានទេ ទើបកំណត់ដើមឈើដែលដុះជុំវិញនោះទុក ហើយ

យកសម្បកជាដើមនៃដើមឈើនោះ មកលាយជាមួយគ្រឿងផ្សំគ្រប់យ៉ាង ផ្សំជាសុរាឡើងក្នុងព្រះនគរ ពួកអ្នកនគរនាំគ្នាផឹកស្រារហូតដល់ស្រវឹង ប្រមាទធ្លាក់ខ្លួនក្រីក្រ ជាបន្តបន្ទាប់ ព្រះនគរហាក់ដូចជានគរគ្មានមនុស្ស ដោយហេតុនោះ អ្នកផ្សំគ្រឿងធ្វើទឹកទាំង ២ ក៏រត់គេចអំពីនគរនោះ ទៅកាន់នគរពារាណសី ឲ្យទូលព្រះរាជាថា មានមនុស្សនាំទឹកមកគាល់ ព្រះបាទពារាណសីត្រាស់ឲ្យជនទាំង ២ ចូលគាល់ ហើយប្រទានស្បៀងដល់ជនទាំង ២ គេនាំគ្នាផ្សំស្រាឡើងក្នុងនគរពារាណសីនោះ ។ សូម្បីនគរនោះក៏វិនាសទៅយ៉ាងនោះទៀត ។ ជនទាំង ២ ក៏នាំគ្នាចៀសចេញអំពីនគរនោះ ទៅកាន់នគរសាកេត កាលនគរសាកេតវិនាសហើយ ក៏ទៅកាន់ក្រុងសាវត្ថី ។ កាលនោះព្រះបាទសព្វមិត្តបានជាក្សត្រក្នុងព្រះនគរសាវត្ថី ទ្រង់ធ្វើការសង្គ្រោះដល់ជនទាំង ២ នោះ ហើយត្រាស់សួរថា ពួកអ្នកត្រូវការរបស់ណាខ្លះ កាលជនទាំង ២ ទូលថា ត្រូវការឫសឈើសម្រាប់ផ្សំជាមួយស្រូវសាលី និងពាង ៥០០ ដូច្នេះ ក៏ត្រាស់ឲ្យប្រទានគ្រប់យ៉ាង ព្រានឈ្មោះសុរៈនិងវរុណតាបសទាំង ២ បិទស្រាដាក់ពាង ៥០០ តម្កល់ទុកហើយ ។ បំណងនឹងការពារកណ្តុរ ទើបចងឆ្មាមួយត្រង់ពាងនីមួយៗ ឆ្មាទាំងនោះ ផឹកស្រាដែលហៀរចេញមកដល់បាតពាង ក្នុងកាលដែលគេចាក់ ទើបស្រវឹងដេកលក់ទៅ ពួកកណ្តុរមកកកេរត្រចៀក ប្រមុះ ពុកមាត់និងកន្ទុយឆ្មា ហើយនាំគ្នារត់ទៅ ពួកអាយុត្តកបុរស គឺអ្នកស៊ើបការ គិតថា ឆ្មាផឹកស្រាងាប់អស់ ទើបក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះបាទសព្វមិត្តទ្រង់ឃើញថាជនទាំង ២ នេះដាក់

ថ្នាំពិស ទើបត្រាស់ឲ្យកាត់ក្បាលជនទាំង ២ ចោល ជនទាំង ២ ក្រាបទូលថា ទូលព្រះបង្គំសូមផឹកស្រាដែលមានរសឆ្ងាញ់មុននឹងស្លាប់ ។ កាលព្រះរាជាត្រាស់ឲ្យប្រហារជីវិតជនទាំង ២ ហើយ មានព្រះតម្រាស់ថា ពួកអ្នកចូរបំបែកពាងចោល ឯឆ្មាទាំងឡាយ កាលឫទ្ធិសុរាស្វាងហើយ ក៏ក្រោកឡើងរត់ទៅ ពួករាជបុរសឃើញដូច្នោះ ទើបទូលឲ្យព្រះរាជាទ្រង់ជ្រាប ព្រះរាជាទ្រង់ព្រះតម្រិះថា បើទឹកនេះពុលឆ្មាគង់ស្លាប់ ប្រហែលជាមានរសឆ្ងាញ់ អញនឹងសាកមើល ហើយត្រាស់ឲ្យប្រដាប់តាក់តែងព្រះនគរ ឲ្យសាងមណ្ឌបត្រង់លានព្រះរាជវាំង ស្រេចហើយ ប្រថាប់គង់លើរាជបល្ល័ង្ក ដែលលើកស្វេតច្ឆត្រឡើងក្នុងមណ្ឌបដែលតាក់តែងហើយ ចោមរោមដោយពួកអាមាត្យនាហ្មឺនមន្ត្រី ផ្តើមសោយសុរា ។

កាលនោះ សក្កទេវរាជទ្រង់ប្រមើលសត្វលោកថា អ្នកណាខ្លះហ្ន៎ មិនប្រមាទក្នុងការទំនុកបម្រុងមាតាបិតាជាដើម បំពេញសុចរិត ៣ ឲ្យពេញបរិបូណ៌ ទតឃើញព្រះបាទសព្វមិត្តនោះ គង់ប្រថាប់ដើម្បីសោយស្រា ទើបទ្រង់ព្រះតម្រិះថា បើព្រះបាទសព្វមិត្តនេះសោយស្រាសោត សកលជម្ពូទ្វីបនឹងវិនាស អាត្មាអញត្រូវហាមឃាត់ កុំឲ្យទ្រង់សោយ ហើយទ្រង់យកស្រាទៅមួយក្អម កាន់ដោយព្រះហស្ត កាឡាខ្លួនជាព្រាហ្មណ៍ យាងមកឈរក្នុងអាកាស ត្រង់ទីចំពោះព្រះភក្ត្រព្រះបាទសព្វមិត្ត ហើយត្រាស់ថា អ្នកទាំងឡាយចូរទិញឆ្នាំងនេះ អ្នកទាំងឡាយចូរទិញឆ្នាំងនេះ ។ ព្រះបាទសព្វមិត្តរាជ ទតឃើញព្រាហ្មណ៍និមិត្ត ឈរពោលលើអាកាសយ៉ាងនោះ ទ្រង់

សន្ស័យថា ព្រាហ្មណ៍នេះមកអំពីណាហ្ន៎ កាលទ្រង់សន្ទនាជាមួយព្រាហ្មណ៍នោះ បានពោលគាថា ៣ ដោយសេចក្តីថា

អ្នកជាអ្វី មកប្រាកដអំពីកពតាវត្តិង្ស ( ប្រតិស្ឋាន ) លើអាកាសនេះ រស្មីទាំងឡាយរបស់អ្នក ផ្សាយចេញអំពីខ្លួនដូចព្រះចន្ទក្នុងស្វាងក្នុងវេលាយប់ ឬដូចផ្លេកបន្ទោរផ្ទៀលធ្លាត់ពួដ៏អាកាស ។ អ្នកឯងដើរទៅមិនមានខ្យល់ពួដ៏អាកាស អ្នកដើរក្តី ឈរក្តី ពួដ៏អាកាស ឫទ្ធិរបស់ពួកទេវតាដែលមិនបាច់ដើរទៅកាន់ផ្លូវឆ្ងាយ ( ដោយជើង ) អ្នកបានធ្វើឲ្យដូចជាទីតម្កល់ចម្រើនល្អ ។ អ្នកឋិតនៅព្រោះអាស្រ័យនូវការទៅពួដ៏អាកាស តើអ្នកជាអ្វី ( អ្នកនិយាយ ) នូវសេចក្តីណាថា អ្នកទាំងឡាយចូរទិញថ្នាំងចុះ ដូច្នេះ តើថ្នាំងនេះសម្រាប់ធ្វើអ្វី ម្នាលព្រាហ្មណ៍អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ ចាតុភាសិ** សេចក្តីថា អ្នកជានរណាមកអំពីណា ទើបមកប្រាកដ អធិប្បាយថា មកអំពីណា ។ បទថា **តិទិវា នភម្ហិ** សេចក្តីថា ព្រះបាទសព្វមិត្តត្រាស់សួរថា អ្នកមកអំពីតាវត្តិង្សពិភពឬទើបប្រាកដក្នុងនភាកាសនេះ ។ បទថា **សំវរី** បានដល់ ក្នុងរត្តិកាល ។ បទថា **សតេរតា** បានដល់ ព្រះចន្ទដែលមានឈ្មោះយ៉ាងនេះ ។ បទថា **សោ** បានដល់ លោកនោះ ។ បទថា **ជិន្នវាតំ** សេចក្តីថា វលាហកទេវតារមែងឈានដើរតាមខ្យល់ ដែលមានក្រសែត្រជាក់បក់ទៅបាន ឯខ្យល់នោះ

មិនមានដល់អ្នកសោះ ដោយហេតុនោះទើបព្រះបាទសព្វមិត្តត្រាស់យ៉ាងនេះ ។ បទថា **កមសិ** បានដល់ អណ្តែតត្រសែតទៅ ។ បទថា **អយម្ហិ** បានដល់ ក្នុងអាកាសដែលមិនមានអ្វីប៉ះពាល់ ។ បទថា **វត្តុកតា** សេចក្តីថា ឫទ្ធិរបស់លោកជាវត្ថុដែលធ្វើហើយ ដូចវត្ថុ ដូចទីតម្កល់ ដូច្នោះ ។ បទថា **អនទ្ធគូនមសិ នេវតានំ** សេចក្តីថា ព្រះបាទសព្វមិត្ត ត្រាស់សួរថា ឫទ្ធិរបស់លោកដែលអប់រំល្អហើយ ដូចឫទ្ធិរបស់ទេវតាដែលឈ្មោះថា មិនបាច់ដើរផ្លូវឆ្ងាយ ព្រោះមិនចាំបាច់ប្រើជើងដើរទៅក្នុងផ្លូវឆ្ងាយ ។ បទថា **វេហាយសំ កមមាគម្ម** សេចក្តីថា លោកជានរណា ទើបអាស្រ័យនូវជំហានចូលទៅឈរនៅលើអាកាសបាន ។ បណ្ឌិតគប្បីភ្ជាប់បាទនៃគាថានោះដោយបទថា **កោ វា តុវំ** ប្រែថា លោកជានរណា អធិប្បាយថា លោកមកឈរទីនេះដើម្បីអ្វី ។ បទថា **យមេតមត្ថំ** សេចក្តីថា លោកពោលពាក្យណា ត្រូវភ្ជាប់សេចក្តីរបស់បាទគាថានេះចូលជាមួយបទថា **ឥមស្ស កិស្ស វតាយំ** ទើបបានសេចក្តីថា លោកពោលពាក្យថា ចូរទិញផ្នាំងនេះ ដូច្នេះ អធិប្បាយថា លោកពោលថា ចូរទិញផ្នាំងនេះ ដូច្នេះ ផ្នាំងរបស់លោកមានប្រយោជន៍អ្វីឬ ។

លំដាប់នោះ សក្កទេវរាជត្រាស់ថា បើដូច្នោះ សូមទ្រង់ស្តាប់ កាលទ្រង់សម្តែងទោសរបស់សុរាទើបត្រាស់ថា

នេះមិនមែនជាក្អមសប្បិទេ មិនមែនជាក្អមប្រេងទេ មិនមែនជាក្អមស្ករអំពៅទេ មិនមែនជាក្អមទឹកឃ្មុំទេ ទោសរបស់ក្អមមាន

ច្រើន សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវទោសដ៏ច្រើន ដែលតាំង នៅក្នុងក្អមចុះ ។ បុគ្គលដើរភ្លាត់ធ្លាក់ជ្រោះ រណ្តៅ គុហា អណ្តូង-ជ្រាំ រណ្តៅជ្រាំ ទាំងបរិភោគនូវរបស់ដែលមិនគួរបរិភោគដ៏ច្រើន ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញ ដោយសុរានោះចុះ ។ បុគ្គលមិនជាធំក្នុងចិត្ត តែងដើរចប្រច់ ដូចគោស៊ីនូវបាយសុរា ជាអ្នកមិនមានទីពឹង តែងចូលទៅ ច្រៀងឬរាំព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ ពេញដោយសុរានោះចុះ ។ បុគ្គលអាក្រាត ដូចជាពួកអ-ចេលកៈ ដើរទៅកាន់ចន្លោះថ្នល់ក្នុងស្រុក មានចិត្តវង្វេង ដេក ហួសវេលា ព្រោះផឹកនូវសុរាណា សូមព្រះអង្គ ទិញនូវក្អមនេះ ដ៏ពេញដោយ សុរានោះចុះ ។ បុគ្គលក្រោកឡើងទ្រេតទ្រោត ញ័រក្បាល ញ័រដើមដៃ បុគ្គលនោះរាំ ដូចជារូបយន្តដែលធ្វើ ដោយឈើ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ ពេញដោយសុរានោះចុះ ។ ជនទាំងឡាយ ត្រូវភ្លើងឆេះ រមែង ដេកនៅ ឬត្រូវពួកចចកខាំស៊ី បានដល់នូវទោស ត្រូវគេចង គេសម្លាប់ ទាំងសាបសូន្យនូវភោគៈ ព្រោះតែផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលនិយាយនូវពាក្យដែលគេមិនគួរនិយាយ អង្គុយក្នុងទីប្រជុំ របូតសំពត់ស្លៀក ប្រឡាក់ប្រឡូស ដេកជ្រមុចក្នុងកម្អួត ដល់

នូវសេចក្តីវិនាស ព្រោះផឹកសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលលើកកម្ពស់ មានភ្នែកក្រហម សំគាល់ថាផែនដីទាំងមូលសុទ្ធតែជារបស់អញ សូម្បីស្តេចជាធំលើផែនដី មានសមុទ្ទទាំង ៤ ជាទីបំផុត ក៏មិនស្មើនឹងអញដែរ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ សុរាណា ដែលនាំឲ្យកើតមានះ និងការមើលងាយ នាំឲ្យឈ្លោះប្រកែក នាំឲ្យញុះញង់ នាំឲ្យមានពណ៌សម្បុរអាក្រក់ នាំឲ្យអាក្រាតសំពត់ ឲ្យរត់ផ្តេសផ្តាស ជាគតិ ជាលំនៅរបស់ពួកអ្នកលេងជាន់ចាស់ សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ត្រកូលទាំងឡាយស្តុកស្តម្ភ សាយកាយ ( ដោយសំពត់និងទ្រព្យសម្បត្តិ ) មានទ្រព្យច្រើនពាន់ ត្រូវសុរានេះធ្វើក្តើមតិកឲ្យដាច់សូន្យក្នុងលោក សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ជនទាំងឡាយញ៉ាំងទ្រព្យសម្បត្តិ ប្រាក់មាស ស្រែចម្ការ និងគោក្របីឲ្យវិនាសអស់ ព្រោះតែសុរាណា ( ម្យ៉ាងទៀតសុរាណា ) ផ្តាច់បង់នូវត្រកូលអ្នកមានទ្រព្យទាំងឡាយ សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុរសមានសភាពក្អើតក្អើន តែងជេរនូវមាតានិងបិតាទាំងចាប់ទោសម្តាយក្មេក ឬចាប់ទោសកូនប្រសាស្រី ព្រោះផឹកសុរាណា សូមព្រះ

អង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ស្រីមានសភាពក្អឹតក្អឹន តែងជេរនូវឪពុកក្មេកនិងប្តី ចាប់ទោសខ្ញុំប្រុស ចាប់ទោសអ្នកបម្រើ ព្រោះតែផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ បុគ្គលបៀតបៀនសមណៈឬព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ តែងទៅកាន់អបាយដែលមានសេចក្តីបៀតបៀននោះជាហេតុ ព្រោះផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ជនទាំងឡាយប្រព្រឹត្តអាក្រក់ដោយកាយ វាចានិងចិត្ត លុះប្រព្រឹត្តអាក្រក់ហើយ ទៅកាន់នរក ព្រោះផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ជនទាំងឡាយសូម្បីចំណាយប្រាក់ដ៏ច្រើន អង្វរមិនបាននូវបុរសណា ( ដែលមិនទាន់ផឹកសុរា ) ក្នុងកាលមុនថា ( អ្នកចូរពោលមុសាវាទ ) បុរសនោះ លុះផឹកនូវសុរានោះរួចហើយ ក៏ពោលនូវពាក្យមុសាវាទបាន សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ កាលបើកិច្ចប្រញាប់កើតហើយ បុគ្គលនោះ គេបញ្ជូនទៅក្នុងការបម្រើ ត្រូវគេសួរថា ( អ្នកឯងមករកអ្វី ) រមែងមិនដឹងសេចក្តី ( ដែលគេសួរ ) ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកជនមានចិត្តប្រកបដោយសេចក្តីអៀនខ្មាស ធ្វើនូវភាពជាអ្នក

មិនអៀនខ្មាសឲ្យប្រាកដក្តី ពួកជនជាអ្នកប្រាជ្ញ មានចិត្តស្ងប់រម្ងាប់ ទៅជាអ្នកប្រមាទដោយសេចក្តីស្រវឹង ហើយនិយាយពាក្យច្រើនក្តី ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកជនដេកប្រគរគ្នា ( ដូចជាកូនជ្រូក ) មិនស៊ីបាយ ដល់នូវការដេកជាទុក្ខលើផែនដីផង ដល់នូវភាពជាអ្នកមានសម្បុរអាក្រក់ផង ដល់នូវតំណិះដំណៀលផង ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកជនដេកធ្លាក់កទន់រងៀក ដូចជាគោដែលគេសំពងនឹងញញួរ កម្លាំងនៃសុរា មិនមែននរជនគ្របសង្កត់បានដោយងាយទេ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកមនុស្សវៀរបង់នូវសុរាណា ដូចជាវៀរនូវពស់ ដែលមានពិសដ៏ពន្លឹកនរជនណាគួរផឹកនូវសុរានោះ ដែលមានពិសស្មើដោយថ្នាំពិសក្នុងលោក សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ព្រះរាជបុត្តរបស់ព្រះបាទអន្ធកវេណ្ហុ: ( ជាបងប្អូនគ្នា ) បានយាងទៅក្បែរឆ្នេរសមុទ្ទ ក៏ប្រហារគ្នាទៅវិញទៅមកដោយអង្រែទាំងឡាយ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ ។ ពួកអសុរជាអ្នកស្រវឹង ហើយច្យុតចាកតាវត្តិង្សទេវលោក ដែលទៀងទាត់ ( ដោយ

អាយុ ) ព្រមទាំងមាយា ( របស់អសុរ ) ព្រោះផឹកនូវសុរាណា បពិត្រមហារាជ អ្នកប្រាជ្ញកាលដឹងនូវទឹកស្រវឹងនេះថាជារបស់ឥតប្រយោជន៍ ប្រាកដដូច្នោះ តើគួរផឹកនូវទឹកស្រវឹងនោះដូចម្តេចកើត ។ ទឹកដោះជូរឬទឹកឃ្មុំ មិនមានក្នុងក្អមនោះទេ បពិត្រព្រះរាជាព្រះនាមសព្វមិត្ត ព្រះអង្គជ្រាបច្បាស់យ៉ាងនេះហើយ សូមព្រះអង្គទិញនូវសុរាក្នុងក្អមនេះដែលខ្ញុំព្រះអង្គក្រាបទូលតាមសភាវៈយ៉ាងនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វជ្ជានិ** បានដល់ ទោសទាំងឡាយ ។ បទថា **គលេយ្យ** សេចក្តីថា ដើរទ្រេតទ្រោតគ្រប់ជំហាន ។ បទថា **យំ បិត្វា បតេ** សេចក្តីថា បុគ្គលផឹកនូវទឹកប្រភេទណាហើយ គប្បីធ្លាក់ចុះទៅ ។ បទថា **សោព្ភំ** បានដល់ អណ្តូង ។ បទថា **ចន្ទនិយោលិគល្លំ** បានដល់ រណ្តៅសំរាមនិងរណ្តៅជ្រាំ ។

បទថា **អភោជនេយ្យំ** បានដល់ របស់មិនគួរបរិភោគ ។ បទថា **អនេ-សមានោ** បានដល់ មិនជាឥស្សរៈ ។ បទថា **គោរិវ** សេចក្តីថា ឧបមាដូចគោ ។ បទថា **ភក្ខសាទី** សេចក្តីថា ដូចគោស៊ីបាយស្រោ ដើរស្វែងរករបស់ស៊ីក្នុងទីផ្សេងៗ យ៉ាងណា ( អ្នកផឹកសុរា ) មិនមានសណ្តាប់ធ្នាប់ក្នុងចិត្តត្រាច់ទៅ យ៉ាងនោះ ។ បទថា **អនាថមានោ** សេចក្តីថា ដូចបុគ្គលកម្សត់ឥតទីពឹង ។ បទថា **ឧបគាយតិ** សេចក្តីថា ឃើញអ្នកដទៃគេរាំច្រៀងក៏ចូលទៅច្រៀងខ្លះ រាំខ្លះ ។ បទថា **អចេលកោវ** សេចក្តីថា អាក្រាតកាយ

បាន ដូចពួកអចេលក៍ ។ បទថា **វិសិខន្តរានិ** សេចក្តីថា ត្រាច់ចប្រប់តាមប្រកតាមផ្លូវ ។ បទថា **អតិវេលសាយី** សេចក្តីថា ជាអ្នកមានប្រក្រតីដេកជ្រុលពេល បាឋៈថា **អតិវេលចារី** ដូច្នេះក៏មាន អធិប្បាយថា ដេកលក់អស់កាលយូរ ។ បទថា **ទារុកដល្លកោវ** បានដល់ ដូចរូបយន្ត ធ្វើដោយឈើ ។ បទថា **ភោគជានិញ្ចុបេន្តិ** សេចក្តីថា រមែងចូលដល់ ការវិនាសនៃភោគទ្រព្យ អធិប្បាយថា បុគ្គលផឹកទឹកណាហើយរមែងធ្វើទុច្ចរិតជាដើមថា បាណាតិបាត ត្រូវជាក់នូវអាជ្ញា ហើយរមែងដល់នូវការវិនាសទ្រព្យ និងដល់នូវទុក្ខដទៃៗដែលត្រូវសម្លាប់និងត្រូវចងជាដើម ។

បទថា **វន្តគតោ** សេចក្តីថា លិចចុះក្នុងកម្មតរបស់ខ្លួន ។ បទថា **ព្យសន្នោ** បានដល់ ដល់នូវការវិនាស ។ បាឋៈថា **វិសន្នោ** ដូច្នេះក៏មាន អធិប្បាយថា ដេកជ្រមុជក្នុងគំនរកម្មតនោះឯង ។ បទថា **ឧក្កដ្ឋោ** សេចក្តីថា បុគ្គលផឹកនូវទឹកប្រភេទណាហើយលើកតម្កើងខ្លួន ស្រែកឡូឡាថា យើងមានទាហានខ្លាំងច្រើន តើមាននរណាស្មើយើង ។ បទថា **អាវិលក្ខោ** បានដល់ មានភ្នែកក្រហម គឺភ្នែកធំៗ ។ បទថា **សព្យបថវី** បានដល់ ផែនដីទាំងមូល ។ បាឋៈថា **សព្វាបថវី** ដូច្នេះក៏មាន ។ បទថា **ចាតុរន្តោ** សេចក្តីថា ជាធំក្នុងផែនដី មានមហាសមុទ្ទ ៤ ជាព្រំប្រទល់ ។ បទថា **មានាតិមានា** បានដល់ កើតនូវមានះ ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

បទថា **គតី** បានដល់ បដិបទាជាគ្រឿងធ្វើឲ្យកើតផល ។ បទថា **និកេតោ** បានដល់ នៅដូចអ្នកលេង ។ បទថា **តស្សា បុណ្ណំ** សេចក្តីថា សូម

ទ្រង់ទិញក្អមនេះដែលពេញដោយសុរាបែបនោះ ។ បទថា **ឥច្ឆានិ** បានដល់ មាំទាំ ។ បទថា **ជីតានិ** សេចក្ដីថា មាំទាំបរិបូណ៌ដោយវត្ថាលង្ការ និង គ្រឿងប្រើប្រាស់ទាំងឡាយ ។ បទថា **ឧច្ឆិន្នទាយជ្ជកតានិ** សេចក្ដីថា ទឹក សុរានេះរមែងធ្វើទាយាទឲ្យដាច់សូន្យ នាំទ្រព្យសម្បត្តិឲ្យវិនាស ។ បទថា **យត្ថ វិនាសយន្តិ** សេចក្ដីថា ជនទាំងឡាយអាស្រ័យសុរាណា តាំងខ្លួនទុក ក្នុងការផឹកសុរាណា ទម្លាយនូវសម្បត្តិ មានទ្រព្យនិងស្រូវជាដើមណាមួយ ឬច្រើនយ៉ាងឲ្យវិនាសបាន រហូតក្លាយជាបុគ្គលអនាថា ។ បទថា **ធិត្តរូបោ** បានដល់ ជាអ្នករីងត្អឹងគ្រោតគ្រាត ។ បទថា **គណ្ហេយ្យ** សេចក្ដីថា ចាប់ដៃ កូនប្រសាដោយអំណាចកិលេស ដោយសម្គាល់ថា ជាភរិយាបាន ។ បទថា **ទាសម្បិ គណ្ហេ** សេចក្ដីថា ចាប់ដៃទាសៈអ្នកបម្រើរបស់ខ្លួនបាន ដោយ អំណាចកិលេស ដោយសម្គាល់ថាជាប្ដីរបស់ខ្លួន ។ បទថា **បិត្វាន** បាន ដល់ ផឹកហើយ ។

បទថា **ទុច្ចរិតំ ចរិត្វា** សេចក្ដីថា ធ្វើនូវអកុសលកម្មបថ ១០ យ៉ាង ដោយទ្វារទាំង ៣ យ៉ាងនេះ ។ បទថា **យាចមានា** សេចក្ដីថា ជនទាំង- ឡាយ ទោះបីលះបង់ប្រាក់មាសជាសំណូកលួងចិត្តជាច្រើន ពោលអង្វរបុរស ណាដែលមិនធ្លាប់ផឹកស្រាមកអំពីមុនថា ចូរអ្នកនិយាយកុហកដូច្នោះ រមែង មិនបាន ។ បទថា **បិត្វា** សេចក្ដីថា អ្នកបម្រើផឹកនូវទឹកប្រភេទណាហើយ ។ បទថា **ឧបច្ចជាតាតិ វុត្តោ** សេចក្ដីថា ត្រូវគេសាកសួរថា ឯងមកដើម្បីអ្វី បុគ្គលនោះរមែងមិនដឹងរឿងនោះ ព្រោះខ្លួនទទួលពាក្យមកមិនល្អ ។ បទថា

**ហិរីមនាបិ** សេចក្ដីថា ទោះបីមានចិត្តប្រកបដោយហិរិ ។ បទថា **ឯកច្ចទា** សេចក្ដីថា ដេកប្រគរគ្នាដូចកូនជ្រូកដេកដោយជាតិកំណើតថោកទាបដូច្នោះ ។ បទថា **អនាសកា** បានដល់ អត់អាហារ ។ បទថា **ថណ្ឌិល ទុក្ខសេយ្យំ** សេចក្ដីថា ដេកជាទុក្ខលើផែនដី ។ បទថា **អាយសក្យំ** បានដល់ ធ្វើនូវការនិន្ទា ។ បទថា **បត្តក្ខន្ធា** សេចក្ដីថា ដេកមានកធ្លាក់ ។ បទថា **ក្វូដ-ហាតារិវ** សេចក្ដីថា ដេកបត់កដូចសត្វគោ ដែលប្រឡៀជាប់ត្រង់កបៀតបៀន ។ អធិប្បាយថា ដេកសំកុកដូចគោដែលមិនស៊ីស្មៅ ផឹកទឹក ដេកស្ទុបសៅ ដូច្នោះ ។ បទថា **ឃោរវិសមិវ** បានដល់ ប្រៀបដូចពស់ មានពិសដ៏ពន្លឹក ។ បទថា **វិសសមានំ** បានដល់ ដូចគ្នានឹងថ្នាំពិស ។ បទថា **អន្ធកវេណ្ហុបុត្តា** បានដល់ ព្រះរាជាបងប្អូន ១០ អង្គ ។ បទថា **ឧបក្កមុំ** បានដល់ ប្រហារនូវគ្នាដោយអង្រែ ។ បទថា **បុព្វទេវា** បានដល់ អសុរទាំងឡាយ ។ បទថា **តិទិវា** សេចក្ដីថា មកអំពីតាវត្តិង្សទេវលោក ។ បទថា **សស្សតិយា** សេចក្ដីថា សម្គាល់ខ្លួនថាទៀង ដោយភាពជាអ្នកមានអាយុវែង អធិប្បាយថា ចាកទេវលោកដែលសន្មតគ្នាថាទៀងជានិរន្តរ៍ ។ បទថា **សមាយា** សេចក្ដីថា ប្រព្រឹត្តទៅដោយអសុរមាយា ។

បទថា **ផាណំ** សេចក្ដីថា បុរសដែលឈ្លាសដូចទ្រង់ កាលជ្រាបថា ទឹកផឹកនេះ ជាទឹកស្រវឹង មិនមានប្រយោជន៍យ៉ាងនោះ តើគប្បីផឹកដូចម្ដេច ។ បទថា **កុម្ភគតា មយា** សេចក្ដីថា វត្ថុដែលនៅក្នុងក្អម ខ្ញុំប្រាប់ហើយម្យ៉ាងទៀត បាឋៈថា **កុម្ភគតំ មយា** ដូច្នេះក៏មាន ឯសេចក្ដីក៏ដូចគ្នា ។

បទថា **អក្ខាតរូបំ** សេចក្ដីថា ដែលខ្ញុំប្រាប់ហើយតាមសេចក្ដីពិត ។

ព្រះបាទសព្វមិត្តទ្រង់ស្ដាប់ដូច្នោះ ទ្រង់ជ្រាបទោសរបស់សុរា ត្រេកអរក្នុងព្រះរាជហឫទ័យ កាលទ្រង់សរសើរសក្កទេវរាជ បានត្រាស់ ២ គាថាដោយសេចក្ដីថា

លោកមិនមែនជាឪពុកឬម្ដាយរបស់ខ្ញុំទេ ជាបុគ្គលទីទៃពីគ្នា តែជាអ្នកសង្គ្រោះដោយប្រយោជន៍ លោកប្រាថ្នានូវប្រយោជន៍ដ៏ឧត្ដម ខ្ញុំនោះនឹងធ្វើតាមពាក្យលោកក្នុងថ្ងៃនេះ ។ ខ្ញុំនឹងឲ្យនូវស្រុកសួយ ៥ ផង ខ្ញុំស្រី ១០០ ផង គោ ៧០០ ផង រាជរថ ១០ ទឹមដោយសេះអាជានេយ្យទាំងនេះផង ដល់លោកៗជាអាចារ្យ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **គាមវរានិ** សេចក្ដីថា ព្រះបាទសព្វមិត្តត្រាស់ថា បពិត្រព្រាហ្មណ៍ អាចរិយភាគ គឺចំណែករបស់អាចារ្យ ដែលឈ្មោះថា បុគ្គលជាអាចារ្យគួរប្រាថ្នា ខ្ញុំសូមឲ្យនូវស្រុកសួយ ៥ ដែលមានចំណូលមួយឆ្នាំមួយសែនកហាបណៈដល់អ្នក ។ បទថា **ទស នមេ** សេចក្ដីថា កាលព្រះបាទសព្វមិត្តទ្រង់ចង្អុលរថដ៏វិចិត្រដោយមាសដែលនៅ ចំពោះព្រះភក្ត្រ ១០ គ្រឿង ទើបត្រាស់យ៉ាងនេះ ។

សក្កទេវរាជទ្រង់ស្ដាប់ដូច្នោះ កាលទ្រង់បង្ហាញអត្តភាពនៃទេវតាឲ្យព្រះបាទសព្វមិត្តទ្រង់ស្គាល់ ទើបប្រថាប់ឈរលើអាកាស បានត្រាស់ព្រះគាថា ២ ដោយសេចក្ដីថា

បពិត្រព្រះរាជា ខ្ញុំស្រី ១០០ ចូរជារបស់ព្រះអង្គវិញចុះ ស្រុកសួយនិងគោទាំងឡាយចូរជារបស់ព្រះអង្គវិញចុះ រាជរថទាំងឡាយ ដែលទឹមដោយសេះអាជានេយ្យ ចូរជារបស់ព្រះអង្គវិញដែរ ខ្ញុំជាព្រះឥន្ទជាធំជាងទេវតា ជាន់តាវត្តិង្ស ។ សូមព្រះអង្គសោយនូវក្រយាស្ងោយ ដែលលាយដោយសាច់ផង នូវបាយាសដែលលាយដោយសប្បិផង សូមព្រះអង្គសោយនូវនំសណ្តែកទាំងឡាយដ៏ផ្អែមផង បពិត្រព្រះជនិន្ទ សូមព្រះអង្គត្រេកអរក្នុងធម៌យ៉ាងនេះ អ្នកផងមិនតិះដៀលទេ ទៅកើតក្នុងឋានសួគ៌ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវំ តុវំ ធម្មរតោ** សេចក្តីថា កាលទ្រង់សោយភោជនមានរសប្រសើរផ្សេងៗយ៉ាងនេះ នឹងវៀរចាកការផឹកសុរា លះទុច្ចរិត ៣ យ៉ាង ជាអ្នកត្រេកអរក្នុងសុចរិតធម៌ ៣ ប្រការ យ៉ាងណា មិនតិះដៀលហើយ ចូលដល់ស្ថានសួគ៌ចុះ ។

សក្កទេវរាជ កាលទ្រង់ប្រទានឱវាទដល់ព្រះបាទសព្វមិត្ត ដោយប្រការដូច្នេះហើយ ក៏យាងទៅកាន់វិមានរបស់ទ្រង់មួយរំពេច ។ ចំណែកព្រះបាទសព្វមិត្ត ទ្រង់ក៏មិនសោយសុរា ត្រាស់ឲ្យទម្លាយភាជនៈសុរាទាំងអស់ ទ្រង់

បានសមាទានសីល បរិច្ចាគទាន ជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ ។ ការផឹកសុរា កើតនូវនិយមយ៉ាងទូលំទូលាយក្នុងជម្ពូទ្វីបតមកដល់សព្វថ្ងៃនេះ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលនេះ ចំណែក សក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កុម្ភជាតក ចប់

## ជយទ្ទិសជាតក

[ ៤២៥ ] ( មនុស្សយក្សពោលថា ) យូរណាស់ហើយ អាហារដ៏ច្រើនទើបកើតឡើងដល់យើងក្នុងពេលបាយក្នុងថ្ងៃទី ៧ នាថ្ងៃនេះ អ្នកទើបនឹងមកពីណា មួយទៀត អ្នកជាអ្វី អ្នកចូរប្រាប់រឿងនោះ ( ដល់យើង ) អ្នកចូរប្រាប់ជាតិល្អមឲ្យយើងដឹងបាន ។

[ ៤២៦ ] ( ព្រះបាទជយទ្ទិសៈទ្រង់តបថា ) ខ្ញុំជាស្តេចក្នុងក្រុងបញ្ចាលឈ្មោះជយទ្ទិសៈ បើអ្នកឮហើយ ចូលមកកាន់ទីសម្លាប់ម្រឹគ ត្រាច់ទៅកាន់ទីខាងក្នុំនិងព្រៃទាំងឡាយ សូមអ្នកពិសាបសទម្រឹគនេះចុះ សូមលែងខ្ញុំក្នុងថ្ងៃនេះ ។

[ ៤២៧ ] ( យក្ស... ) អ្នកឯងបៀតបៀនលោះ ( នូវខ្លួន ) ដោយម្រឹគជារបស់យើងដដែល អ្នកពោលនូវបសទម្រឹគណា បសទម្រឹគនុ៎ះ ជាអាហាររបស់យើងស្រាប់ យើងស៊ីនូវបសទម្រឹគនោះបើចង់ស៊ី នឹងស៊ីជាខាងក្រោយ កាលនេះ មិនមែនជាកាលវិលាបទេ ។

[ ៤២៨ ] ( ព្រះរាជា... ) បើខ្ញុំមិនរួចដោយការលោះទេ ( អ្នកចូរកាន់យកពាក្យប្តេជ្ញា ) ដើម្បី ( ឲ្យខ្ញុំ ) ទៅហើយត្រឡប់មកវិញក្នុងពេលព្រឹក ខ្ញុំជាអ្នករក្សានូវពាក្យសច្ចៈ ឲ្យនូវពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ហើយ នឹងត្រឡប់មកវិញ ។

[ ៤២៩ ] ( យក្ស... ) បពិត្រព្រះរាជា កម្មដូចម្តេច ដុតកម្តៅព្រះអង្គដែលចូលមកកៀកនឹងសេចក្តីស្លាប់ហើយ សូមព្រះអង្គប្រាប់ដល់ខ្ញុំ ក្រែងយើងអាចអនុញ្ញាតឲ្យព្រះអង្គត្រឡប់មកក្នុងវេលាព្រឹកបាន ។

[ ៤៣០ ] ( ព្រះរាជា... ) គោលបំណងក្នុងទ្រព្យខ្ញុំបានធ្វើហើយចំពោះព្រាហ្មណ៍ ពាក្យប្តេជ្ញានោះក៏ជាប់នៅមិនទាន់ដោះ ខ្ញុំជាអ្នករក្សានូវសច្ចៈ ឲ្យនូវពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ហើយនឹងត្រឡប់មកវិញ ។

[ ៤៣១ ] ( យក្ស... ) គោលបំណងក្នុងទ្រព្យ ព្រះអង្គបានធ្វើហើយចំពោះព្រាហ្មណ៍ ពាក្យប្តេជ្ញានោះក៏ជាប់នៅមិនទាន់ដោះ ព្រះអង្គជាអ្នករក្សានូវសច្ចៈ ឲ្យនូវពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ហើយ ចូរត្រឡប់មកវិញ ។

[ ៤៣២ ] ( អភិសម្ពុទ្ធគាថា... ) ព្រះបាទជយទ្ទិសនោះ មានសេចក្តីប្រាថ្នាក្នុងកាម បានរួចអំពីដៃបោរិសាទៈ ( អ្នកស៊ី ) ហើយយាងទៅកាន់ព្រះរាជមន្ទីររបស់ព្រះអង្គ ប្រទានពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ ហើយក៏ត្រាស់ហៅព្រះរាជបុត្ត ព្រះនាមអលីនសត្តុមកថា ។ ( នែកូនយើងប្រគល់ ) នូវរាជសម្បត្តិ ( ដល់អ្នកឯង ) ក្នុងថ្ងៃនេះ បាឯងចូរអភិសេកចុះ បាឯងចូរ ( រក្សា ) ធម៌ក្នុងដែនទាំងឡាយផង ក្នុងពួកប្រជាជនផង ជនអ្នកមិនរក្សាធម៌កុំឲ្យមានក្នុងដែនរបស់បាឯងឡើយ យើងនឹងទៅក្នុងសំណាក់នៃបោរិសាទ ។

[ ៤៣៣ ] ( អលីនសត្តុកុមារ... ) បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ ធ្វើអំពើដូចម្តេច ទៀបព្រះបាទានៃព្រះអង្គ ឲ្យព្រះអង្គមិនសប្បាយព្រះហឫទ័យ ព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំតាំងនៅក្នុងរាជ្យក្នុងថ្ងៃនេះ ដោយអំពើដែលនាំឲ្យព្រះអង្គមិនសប្បាយណា ទូលព្រះបង្គំជាខ្ញុំ ចង់ស្តាប់នូវអំពើដែលនាំឲ្យព្រះអង្គមិនសប្បាយនោះ ទូលព្រះបង្គំជាខ្ញុំ បើវៀរចាកព្រះអង្គហើយ

មិនចង់បានទូវរាជ្យទេ ។

[ ៤៣៤ ] ( ព្រះរាជា... ) ម្នាលកូន យើងនឹកមិនឃើញកំហុសរបស់អ្នក ព្រោះអំពើនិងវាចានេះទេ តែយើងបានធ្វើ ( ពាក្យសច្ចៈ ) ជាមួយនឹងបោរិសាទ យើងជាអ្នករក្សានូវពាក្យសច្ចៈ នឹងវិលទៅវិញ ។

[ ៤៣៥ ] ( ព្រះរាជកុមារ... ) ទូលព្រះបង្គំជាខ្ញុំនឹងទៅ សូមព្រះអង្គគង់នៅក្នុងទីនេះចុះ ការរួចអំពីសំណាក់នៃបោរិសាទៈនោះមិនមានដល់បុគ្គលកាលរស់នៅទេ បពិត្រព្រះរាជា បើព្រះអង្គយាងទៅ ទូលព្រះបង្គំជាខ្ញុំក៏ទៅដែរ ព្រះអង្គនិងទូលព្រះបង្គំជាខ្ញុំទាំងពីរនាក់នឹងមិននៅទេ ។

[ ៤៣៦ ] ( ព្រះរាជា... ) ម្នាលកូន ធម៌នុ៎ះជាធម៌របស់ពួកសប្បុរសមែនហើយ ប៉ុន្តែយក្សមានជើងពពាល ដុតថ្ងើរអ្នកឯង ជិតគល់ឈើស្រួចហើយកំហែងស៊ីពេញទំហឹង ក្នុងកាលណា ការនោះទុកជាសេចក្តីស្លាប់របស់យើងក្នុងកាលនោះ ។

[ ៤៣៧ ] ( អលីនសត្តុកុមារ... ) ទូលព្រះបង្គំជាខ្ញុំ នឹងយកជីវិតទៅប្តូរជីវិតរបស់ព្រះអង្គ សូមព្រះអង្គកុំយាងទៅក្នុងសំណាក់នៃបោរិសាទៈឡើយ ទូលព្រះបង្គំជាខ្ញុំ នឹងយកជីវិតនោះទៅប្តូរជីវិតរបស់ព្រះអង្គ ហេតុនោះទូល-ព្រះបង្គំជាខ្ញុំ ប្រាថ្នានូវសេចក្តីស្លាប់ដើម្បីជីវិត ( របស់ព្រះអង្គ ) ។

[ ៤៣៨ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះឯង ព្រះរាជបុត្ត អ្នកមានប្រាជ្ញា ក៏ក្រាបថ្វាយបង្គំព្រះបាទាមាតានិងបិតា ( ហើយចេញទៅ ) ។ ព្រះមាតានៃព្រះរាជកុមារនោះមានសេចក្តីទុក្ខ ក៏ដួលក្រាបលើប្រឹថពី ឯព្រះបិតា

នៃព្រះរាជកុមារនោះ ផ្គងព្រះហស្តហើយទ្រង់ព្រះកន្សែង ។

[ ៤៣៩ ] ព្រះបិតាជ្រាបនូវព្រះរាជកុមារនោះកំពុងយាងទៅ ( ថាកូនរបស់អញ ) ទៅក្នុងទីកំបាំងមុខ ហើយទ្រង់ផ្គងអញ្ជលី ថ្វាយបង្គំទេវតាថា សូមឲ្យព្រះរាជាព្រះនាមសោមៈ ព្រះរាជាព្រះនាមវរុណៈ ព្រះរាជាព្រះនាមបជាបតិ ព្រះចន្ទនិងព្រះអាទិត្យទាំងនុ៎ះគ្រប់គ្រងអ្នក ម្នាលកូន អ្នក ( ដែលយក្ស ) អនុញ្ញាតហើយ ចូរត្រឡប់មកអំពីសំណាក់បោរិសាទដោយសុវត្ថិភាពចុះ ។

[ ៤៤០ ] ( ព្រះមាតា... ) មាតានៃបុរសឈ្មោះរាមៈដែលទៅ ( ក្នុងដែន ) នៃព្រះរាជាទណ្ឌកី ជាស្ត្រីគ្រប់គ្រងល្អ បានធ្វើនូវសួស្តីណា យើងក៏ធ្វើនូវសួស្តីនោះដល់អ្នក ទេវតាទាំងឡាយ សូមរឭកឃើញដោយពាក្យពិតនោះចុះ ម្នាលកូន បើយក្សអនុញ្ញាតឲ្យហើយ អ្នកចូរត្រឡប់មកវិញដោយសួស្តីចុះ ។

[ ៤៤១ ] ( ព្រះកនិដ្ឋកតិនី... ) ខ្ញុំមិនរឭកឃើញនូវសេចក្តីប្រទូស្តក្នុងចិត្តចំពោះអលីនសត្តកុមារក្នុងទីចំពោះមុខឬកំបាំងមុខដោយពិត សូមពួកទេវតារឭកឃើញដោយពាក្យពិតនោះចុះ បពិត្រអ្នកបង បើយក្សអនុញ្ញាតសូមអ្នកបងត្រឡប់មកដោយសួស្តីចុះ ។

[ ៤៤២ ] ( អគ្គមហេសី... ) បពិត្រស្វាមី ព្រះអង្គមិនប្រព្រឹត្តកន្ទងចិត្តខ្ញុំម្ចាស់ផង ព្រះអង្គមិនមែនមិនជាទីស្រឡាញ់ដោយចិត្ត របស់ខ្ញុំម្ចាស់ផងដោយហេតុណា ( ហេតុនោះ ) សូមទេវតាទាំងឡាយ រឭកឃើញដោយ

ពាក្យសច្ចៈនុ៎ះចុះ បពិត្រស្វាមី បើយក្សអនុញ្ញាតហើយ សូមព្រះអង្គត្រឡប់មកវិញដោយសួស្តីចុះ ។

[ ៤៤៣ ] ( យក្ស... ) អ្នកជាបុគ្គលមានមាឌធំ មានកាយត្រង់ មានមុខស្រស់ តើអ្នក ( មក ) អំពីទីណា អ្នកមិនដឹងនូវយើងដែលនៅក្នុងព្រៃទេ ( ឬ ) អ្នកណាដឹងនូវយើង ជាបុគ្គលអាក្រក់ ជាអ្នកស៊ីនូវបុរសហើយគប្បីមកក្នុងទីនេះ អ្នកទំនងជាមិនដឹងនូវសុវត្ថិភាព បានជាមកឬ ។

[ ៤៤៤ ] ( អលីនសត្តកុមារ... ) បពិត្រព្រានព្រៃ ខ្ញុំស្គាល់ថាអ្នកជាបុគ្គលស៊ីនូវបុរស ខ្ញុំមិនមែនជាមិនស្គាល់អ្នកដែលនៅក្នុងព្រៃទេ ឯខ្ញុំជាព្រះរាជបុត្តនៃព្រះបាទជយទ្ទិសៈ សូមអ្នកពិសាខ្ញុំក្នុងថ្ងៃនេះចុះឲ្យតែព្រះបិតារួច ។

[ ៤៤៥ ] ( យក្ស... ) ខ្ញុំស្គាល់ថា អ្នកជាបុត្តរបស់ព្រះបាទជយទ្ទិសៈ សម្បុរមុខរបស់អ្នកទាំងពីរក៏ដូចគ្នា អ្នកណាប្រាថ្នាស្លាប់ ព្រោះឲ្យតែបិតារួចអំពើរបស់អ្នកនោះដែលអ្នកធ្វើហើយ ជាអំពើដែលគេធ្វើបាន ដោយកម្រក្រៃពេក ។

[ ៤៤៦ ] ( ព្រះរាជកុមារ... ) ខ្ញុំមិនសំគាល់នូវអំពើបន្តិចបន្តួចថា គេធ្វើបានដោយក្រក្នុងហេតុនេះទេ បុគ្គលណាប្រាថ្នាស្លាប់ព្រោះឲ្យតែបិតារួចផង ព្រោះហេតុនៃមាតាផង បុគ្គលនោះលុះទៅកាន់បរលោកក៏ប្រកបដោយសេចក្តីសុខក្នុងឋានសួគ៌ ។

[ ៤៤៧ ] ខ្ញុំរឭកមិនបាននូវកិរិយាអាក្រក់របស់ខ្លួនក្នុងទីវាលឬទីកំបាំងដោយពិត ខ្ញុំជាអ្នកមានការកើតនិងសេចក្តីស្លាប់កំណត់ដឹងហើយ ខ្ញុំ ( មិន

ផុតពីសេចក្ដីស្លាប់ ) ក្នុងលោកនេះយ៉ាងណា ក្នុងលោកខាងមុខក៏យ៉ាងនោះដែរ ។ បពិត្រលោកមានអានុភាពច្រើន ឥឡូវនេះលោកចូរពិសាខ្ញុំក្នុងថ្ងៃនេះចុះ ចូរលោកធ្វើនូវកិច្ចទាំងឡាយ ចំពោះសរីរៈនេះចុះ មួយទៀតខ្ញុំនឹងទម្លាក់ខ្លួនអំពីចុងឈើជូនលោក កាលលោកឃ្លាន ចូរពិសាសាច់ខ្ញុំចុះ ។

[ ៤៤៨ ] ( យក្ស... ) បពិត្ររាជបុត្ត អ្នកពេញចិត្តនឹងអំពើនេះ អ្នកលះបង់នូវជីវិតព្រោះឲ្យបិតារួច ព្រោះហេតុនោះអ្នកចូរជាអ្នកមានសភាពរួសរាន់ កាប់ឧសបង្កាត់ភ្លើងចុះ ។

[ ៤៤៩ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះឯង ព្រះរាជបុត្តមានប្រាជ្ញាក៏ប្រមូលនូវឧសហើយដុតភ្លើងឲ្យឆេះធំឡើង រួចប្រាប់យក្សថា ឥឡូវនេះភ្លើងដ៏ធំនេះខ្ញុំបានបង្កាត់ឆេះហើយ ។

[ ៤៥០ ] ឥឡូវនេះលោកជាអ្នកធ្វើនូវការកំហែងខ្ញុំ ចូរពិសាខ្ញុំក្នុងថ្ងៃនេះចុះ លោកព្រឺរោមហើយសម្លឹងខ្ញុំញយៗតើព្រោះហេតុអ្វី លោកឃ្លានចង់ស៊ីខ្ញុំយ៉ាងណាៗ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកយ៉ាងនោះៗ ។

[ ៤៥១ ] ( យក្ស... ) នរណាគួរស៊ីបុគ្គលតាំងនៅក្នុងធម៌ និយាយពាក្យពិត ដឹងនូវពាក្យពេចន៍បែបអ្នក បុគ្គលណាហ៊ានស៊ីនូវបុគ្គលពោលពាក្យសច្ចៈបែបអ្នក ក្បាលរបស់បុគ្គលនោះនឹងបែកជា ៧ ភាគ ។

[ ៤៥២ ] ( ព្រះរាជកុមារ... ) អម្បាលដូចជាទន្សាយនោះ កាលសំគាល់នូវហេតុនេះ បានញុំាងឥន្ទព្រាហ្មណ៍ឲ្យនៅ ( ដើម្បីឲ្យ ) សរីរៈនៃខ្លួនម្នាលយក្ស ហេតុនោះឯងបានជាចន្ទិមទេវបុត្តបង្ហូរចេញនូវសេចក្ដីប្រាថ្នានោះ

មានរូបទន្សាយឋិតនៅសព្វថ្ងៃនេះ ។

[ ៤៥៣ ] ( យក្ស... ) ព្រះចន្ទនិងព្រះអាទិត្យរួចអំពីមាត់រាហូ ហើយរុងរឿងក្នុងថ្ងៃ ១៥ កើត យ៉ាងណាមិញ បពិត្រអ្នកមានអានុភាពច្រើន អ្នកបានរួចអំពីយើងឈ្មោះបោរិសាទហើយ ចូររុងរឿងក្នុងក្រុងកបិលពស្តុចុះ រួចចូរញុំាងបិតានិងមាតាឲ្យរីករាយ ទាំងពួកញាតិទាំងអស់របស់អ្នកក៏ចូរត្រេកអរចុះ ។

[ ៤៥៤ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះឯងព្រះរាជបុត្តមានប្រាជ្ញា ព្រះនាមអលីនសត្តុ ដែលបោរិសាទនោះបានអនុញ្ញាតហើយ ក៏ធ្វើអញ្ជលីផ្គងឡើងចំពោះបោរិសាទរួចត្រឡប់មកកាន់នគរកបិលពស្តុវិញដោយសួស្តី បានសេចក្តីសុខឥតមានរោគឡើយ ។

[ ៤៥៥ ] ពួកមនុស្សនៅក្នុងនិគមក្តី ពួកមនុស្សនៅក្នុងជនបទក្តី ពួកពលដំរីក្តី ពលរថក្តី ពលថ្មើរជើងក្តីទាំងអស់ ក៏ប្រណម្យអញ្ជលីនមស្ការចូលទៅជិតអលីនសត្តុកុមារថា យើងខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ ព្រះអង្គទ្រង់ធ្វើនូវអំពើដែលគេធ្វើបានដោយក្រ ។

**ចប់ ជយទ្ទិសជាតក ទី ៣ ។**

# អដ្ឋកថា

# ជយទ្ទិសជាតក

[ ៤២៥-៤៥៥ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតាមួយរូបទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ចិរស្សំ វត មេ** ដូច្នេះជាដើម ។

ក្នុងកាលនោះព្រះសាស្ដាត្រាស់ថា បុរាណកបណ្ឌិតទាំងឡាយ លះនូវស្វេតច្ឆត្រដែលប្រដាប់ដោយកញ្ចនមាលាហើយចិញ្ចឹមមាតាបិតាដូច្នេះ កាលភិក្ខុនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះរាជាព្រះនាមថាបញ្ចាលរាជ សោយរាជសម្បត្តិនៅក្នុងនគរឧត្តរបញ្ចាលក្នុងកបិលរដ្ឋ ព្រះអគ្គមហេសីរបស់ទ្រង់តាំងព្រះគភ៌ ហើយប្រសូតព្រះរាជឱរស ។ ក្នុងភពមុន ស្រីម្នាក់រួមប្ដីជាមួយនាង ខឹងអាក់អន់ហើយក៏ប្រាថ្នាថា សូមឲ្យអញអាចទំពាស៊ីកូនរបស់នាង ដែលកើតហើយដូច្នេះហើយបានមកកើតជាយក្ខិនី ។ គ្រានោះយក្ខិនីនោះបានឱកាសទាំងដែលព្រះទេវីកំពុងទតឃើញក៏ស្រវាយកព្រះរាជកុមារដែលមានពណ៌ដូចដុំសាច់ស្រស់ ទៅទំពាស៊ីក្រួបៗហើយចៀសចេញទៅ ក្នុងវារៈទី ២ យក្ខិនីក៏បានធ្វើយ៉ាងនោះ តែក្នុងវារៈទី ៣ ក្នុងកាលដែលព្រះទេវី យាងចូលទៅកាន់ផ្ទះប្រសូតិ ពួករាជបុរសនាំគ្នាព័ទ្ធព្រះដំណាក់ចាត់ការរក្សាយ៉ាងមាំទាំ ក្នុងថ្ងៃដែលព្រះទេវីប្រសូត យក្ខិនីក៏មកចាប់យកទារកទៅទៀត ព្រះទេវីទ្រង់ស្រែកឡើងថា យក្ខិនី យក្ខិនី រាជបុរសទាំងឡាយមានអាវុធគ្រប់ដៃនាំគ្នាដេញតាម

យក្ខិនីតាមសញ្ញាដែលនាងប្រាប់ យក្ខិនីមិនបានឱកាសដើម្បីទំពាស៊ី គេចទៅអំពីទីនោះចូលទៅកាន់ល្វឹក ឯទារកហាមាត់ចៀជោះយក្ខិនីដោយសម្គាល់ថាជាមាតា យក្ខិនីកើតសេចក្តីស្រឡាញ់ដូចកូនរបស់ខ្លួន គេចចេញអំពីល្វឹកបានហើយទៅកាន់ទីរហោស្ថាន ធ្វើការផ្គត់ផ្គង់ទារកនោះនៅក្នុងគុហាថ្ម ។ ចំណេរកាលតមក ទារកនោះចម្រើនធំធាត់ដោយលំដាប់ យក្ខិនីក៏នាំសាច់មនុស្សមកឲ្យបរិភោគជាអាហារ ជនទាំង ២ បរិភោគសាច់មនុស្សក្នុងទីនោះ ទារកមិនដឹងថាខ្លួនជាមនុស្ស សម្គាល់ថាជាកូនយក្ខិនី តែមិនអាចប្រែកាយបំបាំងខ្លួនបាន ។ ក្រោយមកយក្ខិនី ក៏ឲ្យឫសឈើម្យ៉ាងដល់ព្រះរាជកុមារ ដើម្បីបំបាំងខ្លួនបាន ដោយអានុភាពនៃឫសឈើ ព្រះរាជកុមារក៏បំបាំងខ្លួនបាន ត្រាច់ទៅស៊ីសាច់មនុស្ស ។ ចំណែកយក្ខិនីទៅប្រតិបត្តិព្រះបាទវេស្សវណមហារាជ ក៏ធ្វើកាលកិរិយាក្នុងទីនោះឯង ។ ចំណែកព្រះទេវីប្រសូតឱរសមួយអង្គទៀតក្នុងវារៈទី ៤ ទើបព្រះរាជឱរសផុតអំពីភ័យព្រោះផុតអំពីយក្ខិនី ព្រះជនកព្រះជននីនិងព្រះញាតិ បានថ្វាយនាមឲ្យឱរសនោះថា ជយទ្ទិសកុមារ ព្រោះកើតមកឈ្នះយក្ខិនីដែលជាបច្ចាមិត្ត ។ ជយទ្ទិសកុមារទ្រង់ចម្រើនវ័យហើយទ្រង់បានសិក្សាសិប្បវិជ្ជាសម្រេចហើយ លើកស្វេតច្ឆត្រគ្រងរាជសម្បត្តិបន្តសន្តតិវង្ស ។

គ្រានោះព្រះពោធិសត្វ កើតក្នុងព្រះឧទរនៃព្រះអគ្គមហេសីរបស់ព្រះបាទជយទ្ទិសនោះ ព្រះជនកព្រះជននីនិងព្រះញាតិថ្វាយព្រះនាមថា អលីនសត្តកុមារ[១] ។ លុះអលីនសត្តកុមារចម្រើនវ័យហើយទ្រង់រៀនសិល្បសាស្ត្ររហូត

---

១-បិដកខ្មែរជាអលីនសត្តកុមារ ។

សម្រេចបានធ្វើជាឧបរាជ ។ ក្នុងកាលតមក កុមារដែលជាកូនយក្ខិនីនោះធ្វើឫសឈើឲ្យបាត់ ព្រោះសេចក្ដីប្រមាទ មិនអាចបំបាំងខ្លួនបានទើបមានរូបប្រាកដ ទំពាស៊ីសាច់មនុស្សក្នុងព្រៃខ្មោច មនុស្សទាំងឡាយឃើញ ក៏នាំគ្នាភ័យតក់ស្លុតរួចបួលមកក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គទ្រង់គុណដ៏ប្រសើរ មានយក្ខមួយប្រាកដខ្លួន ទំពាស៊ីសាច់មនុស្សក្នុងព្រៃខ្មោច យក្ខនោះនឹងមកព្រះនគរដោយលំដាប់នឹងសម្លាប់មនុស្សស៊ីជាអាហារ សូមទ្រង់បញ្ជាឲ្យចាប់ ។ ព្រះរាជាជ្រាបហើយមានព្រះរាជឱង្ការបញ្ជាពលនិកាយថា អ្នកទាំងឡាយ ចូរចាប់យក្ខនោះ ។ ពលនិកាយទាំងនោះទៅឈររាយគ្នាត្រង់ស្មសានបទេស ។ កុមារជាបុត្តយក្ខិនីមានរូបអាក្រាតគួរខ្លាច តក់ស្លុតចំពោះមរណភ័យ ស្រែកឡើងដោយសំឡេងខ្លាំង រត់ជ្រែកហ្វូងមនុស្សទៅ មនុស្សទាំងឡាយតក់ស្លុតចំពោះមរណភ័យស្រែកប្រាប់គ្នាថា យក្ខ យក្ខ ដូច្នេះបែកគ្នាជា ២ ចំណែក កុមារកូនយក្ខិនីគេចអំពីទីនោះបានហើយចូលទៅកាន់ព្រៃ មិនត្រឡប់មកកាន់ដែនដីមនុស្សទៀតទេ បានទៅកាន់ព្រៃក្បែរផ្លូវធំមួយកន្លែងចាំចាប់មនុស្សដែលធ្វើដំណើរមកម្ដងម្នាក់ហើយចូលកាន់ព្រៃសម្លាប់ទំពាស៊ី ស្នាក់អាស្រ័យនៅត្រង់គល់និគ្រោធមួយដើម ។ លំដាប់នោះព្រាហ្មណ៍ឈ្មួញរទេះម្នាក់ជួលអ្នករក្សាព្រៃដោយតម្លៃ ១០០០ ដើម្បីជូនឆ្លងព្រៃមួយអន្លើដោយរទេះ ៥០០ ។ មនុស្សយក្ខឃើញហើយក៏បញ្ចេញសំឡេងខ្លាំងរត់មក មនុស្សទាំងឡាយតក់ស្លុត នាំគ្នាដេកផ្កាប់មុខទៅនឹងដី មនុស្សយក្ខចាប់ឈ្មួញបានហើយ បីរត់ទៅត្រូវជន្លត់ជង់ជើង កាលអ្នករក្សាព្រៃរត់ដេញតាមមកទើបបោះព្រាហ្មណ៍ចោល

រត់គេចទៅដេកត្រង់ដើមឈើដែលជាលំនៅរបស់ខ្លួន ។ កាលមនុស្សយក្ខនោះដេកក្នុងទីនោះ ៧ ថ្ងៃ ព្រះបាទជយទ្ទិសទ្រង់យានចេញពីព្រះនគរដើម្បីបាញ់សត្វ មានព្រាហ្មណ៍ម្នាក់ជាអ្នកចិញ្ចឹមមាតាឈ្មោះនន្ទៈ ជាអ្នកនគរតក្កសិលាបានរៀនសតារហគាថា ៤ បាទ មកគាល់ព្រះបាទជយទ្ទិសដែលកំពុងយានចេញអំពីព្រះនគរ ព្រះបាទជយទ្ទិសត្រាស់ថា ចាំយើងត្រឡប់មកវិញ យើងនឹងស្តាប់ ព្រះរាជទានផ្ទះសម្រាកដល់ព្រាហ្មណ៍នោះ ហើយយានទៅប្រមាញ់ម្រឹគ ត្រាស់ថា បើម្រឹគទៅតាមមុខអ្នកណា អ្នកនោះនឹងត្រូវទទួលទោស ។

សម័យនោះប្រើសមួយក្រោកឡើងរត់តម្រង់ចំមុខព្រះរាជាគេចទៅ អាមាត្យទាំងឡាយ នាំគ្នាសើច ព្រះរាជាកាន់ព្រះខ័ន ដេញតាមប្រើសទៅអស់ចម្ងាយផ្លូវ ៣ យោជន៍ ក៏តាមទាន់ ហើយយកព្រះខ័នកាប់ប្រើសនោះជា ២ កំណាត់ ចងរែកយានមក ដល់កន្លែងដែលមនុស្សយក្ខដេក ប្រថាប់សម្រាកបន្តិច ត្រង់វាលស្បូវភ្លាំង ហើយត្រៀមនឹងចេញដំណើរទៅ ។ លំដាប់នោះមនុស្សយក្ខក្រោកឡើងពោលថា ឈប់សិន ឯងទៅណា ឯងក្លាយជាចំណីរបស់យើងហើយ ចាប់ដៃទុក ហើយពោលគាថាដំបូងថា

យូរណាស់ហើយ អាហារដ៏ច្រើនទើបកើតឡើងដល់យើងក្នុង
ពេលបាយក្នុងថ្ងៃទី ៧ នាថ្ងៃនេះ អ្នកទើបនឹងមកពីណាមួយ
ទៀត អ្នកជាអ្វី អ្នកចូរប្រាប់រឿងនោះ ( ដល់យើង ) អ្នក
ចូរប្រាប់ជាតិ ល្មមឲ្យយើងដឹងបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភក្ខោ មហា** សេចក្តីថា អាហារជាច្រើន ។

បទថា **សត្តមិភត្តកាលេ** សេចក្តីថា តាំងអំពីថ្ងៃបាដិបទមក យើងអត់អាហារ ៧ ថ្ងៃហើយ ។ បទថា **កុតោសិ** សេចក្តីថា អ្នកមកអំពីណា ។

ព្រះរាជាទតឃើញយក្ខហើយកិតភ័យ មានឧរុបទេស គឺភ្លៅរឹងដូចសសរ ទ្រង់មិនអាចរត់ទៅបានទើបតម្កល់សតិត្រាស់គាថាទី ២ ថា

ខ្ញុំជាស្តេចក្នុងក្រុងបញ្ចាល ឈ្មោះជយទ្ទិសៈ បើអ្នកឮហើយ
ចូលមកកាន់ទីសម្លាប់ម្រឹគ ត្រាច់ទៅកាន់ទីខាងភ្នំនិងព្រៃទាំងឡាយ សូមអ្នកពិសាបសទម្រឹគនេះចុះ សូមលែងខ្ញុំក្នុងថ្ងៃនេះ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិគវំ បវិដ្ឋោ** សេចក្តីថា ចេញអំពីដែនចូលព្រៃ ដើម្បីសម្លាប់ម្រឹគ ។ បទថា **គច្ឆាមិ** សេចក្តីថា ត្រាច់មកកាត់ភ្នំនិងដងព្រៃ ។ បទថា **បសទំ** សេចក្តីថា ចូរអ្នកបរិភោគប្រើសនេះ ។ យក្ខបានឮដូច្នោះទើបពោលគាថាទី ៣ ថា

អ្នកឯងបៀតបៀនលោះ ( នូវខ្លួន ) ដោយម្រឹគ ជារបស់
យើងដដែល អ្នកពោលនូវបសទម្រឹគណា បសទម្រឹគនុ៎ះ ជា
អាហាររបស់យើងស្រាប់ យើងស៊ីនូវបសទម្រឹគនោះ បើចង់
ស៊ីនឹងស៊ីជាខាងក្រោយ កាលនេះមិនមែនជាកាលវិលាបទេ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សេនេវ** សេចក្តីថា ដែលជារបស់ខ្ញុំនោះឯង ។ បទថា **បណាសិ** សេចក្តីថា ទ្រង់ត្រាស់យករបស់ខ្ញុំ មកដោះដូរនឹង

ខ្ជួនទ្រង់ ។ បទថា **សស្សមាណោ** បានដល់ ខ្ញុំត្រូវបៀតបៀន ។ បទថា **តំ ខាទិយាន** សេចក្ដីថា ស៊ីទ្រង់មុន ។ បទថា **ជិឃញ្ញំ** សេចក្ដីថា ខ្ញុំបំណាច់ នឹងទំពាស៊ី ។ បទថា **ខាទិស្សំ** សេចក្ដីថា ខ្ញុំនឹងទំពាស៊ីសាច់ប្រើសនោះក្នុង កាលឯក្រោយ ។ បទថា **ន វិលាបកាលោ** សេចក្ដីថា យក្ខទូលថា ទ្រង់ កុំសំណូមពរឡើយ ពេលនេះមិនមែនជាពេលសំណូមពរទេ ។

ព្រះរាជាទ្រង់ស្ដាប់ដូច្នោះហើយ ទ្រង់រឭកដល់នន្ទព្រាហ្មណ៍បានទើប ត្រាស់គាថាទី ៤ ដោយសេចក្ដីថា

បើខ្ញុំមិនរួច ដោយការលោះទេ ( អ្នកចូរកាន់យកពាក្យប្ដេជ្ញា )
ដើម្បី ( ឲ្យខ្ញុំ ) ទៅហើយត្រឡប់មកវិញក្នុងពេលព្រឹក ខ្ញុំជាអ្នក
រក្សានូវពាក្យសច្ចៈ ឲ្យនូវពាក្យប្ដេជ្ញានោះដល់ព្រាហ្មណ៍ហើយនឹង
ត្រឡប់មកវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ចត្ថិ** សេចក្ដីថា បើការរួចផុតរបស់យើង មិនមានដោយការដោះដូរហើយសោត ។ បទថា **គន្ត្វាន** សេចក្ដីថា កាល បើដូច្នេះថ្ងៃនេះចូរអ្នកបរិភោគប្រើសនេះ ចូរឲ្យយើងទៅព្រះនគរសិន ។ បទ ថា **បណ្ហេ** បានដល់ មុននោះឯង អធិប្បាយថា ចូរអ្នកទទួលប្ដេជ្ញា ដើម្បី ឲ្យយើងត្រឡប់មកទាន់ពេលបរិភោគអាហារព្រឹក ក្នុងថ្ងៃស្អែកនេះចុះ ។ បទ ថា **តំ សង្គរំ** សេចក្ដីថា ព្រោះយើងបានផ្ដាំផ្ញើទុកដល់ព្រាហ្មណ៍ថា នឹងឲ្យ ទ្រព្យដល់ព្រាហ្មណ៍ កាលយើងឲ្យទ្រព្យដល់ព្រាហ្មណ៍ហើយ នឹងតាមរក្សា នូវសច្ចៈតាមដែលខ្ញុំពោលទុកនេះ ត្រឡប់មករកអ្នកវិញ ។ យក្ខបានស្ដាប់

ដូច្នោះក៏ពោលគាថាទី ៥ ថា

បពិត្រព្រះរាជា កម្មដូចម្តេច ដុតកម្តៅព្រះអង្គដែលចូលមក កៀកនឹងសេចក្តីស្លាប់ហើយ សូមព្រះអង្គប្រាប់ដល់ខ្ញុំ ក្រែង យើងអាចអនុញ្ញាតឲ្យព្រះអង្គ ត្រឡប់មកក្នុងវេលាព្រឹកបាន ដូច្នេះ ។

កម្មក្នុងគាថានោះ ក៏បានដល់កម្មនោះឯង ។ បទថា **អនុតប្បតេ តំ** សេចក្តីថា ញុំាងនូវការក្តៅចិត្ត ឲ្យដល់ករណីយកិច្ចដូចម្តេច ។ បទថា **បត្តំ** បានដល់ ចូលដល់ ។ បទថា **អបិ សក្កុណេមុ** សេចក្តីថា អើ បើខ្ញុំបាន ស្តាប់ហេតុនៃការសោយសោករបស់ទ្រង់ហើយ អាចនឹងអនុញ្ញាតឲ្យទ្រង់ ត្រឡប់មកក្នុងពេលព្រឹកបាន ។

ព្រះរាជាកាលត្រាស់ប្រាប់ហេតុនោះទើបត្រាស់គាថាទី ៦ ដោយសេចក្តី ថា

គោលបំណងក្នុងទ្រព្យ ខ្ញុំបានធ្វើហើយចំពោះព្រាហ្មណ៍ ពាក្យ ប្តេជ្ញានោះ ក៏ជាប់នៅមិនទាន់ដោះ ខ្ញុំជាអ្នករក្សានូវសច្ចៈ ឲ្យ នូវពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ ហើយនឹងត្រឡប់មកវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិមោក្ខំ ឆ មុត្តំ** សេចក្តីថា ខ្ញុំតាំងនូវការ ប្តេជ្ញាដែលជាសញ្ញាចងខ្លួនដោយប្តេជ្ញាដល់ព្រាហ្មណ៍ថា ស្តាប់សតារហគាថា ៤ បាទ ហើយនឹងឲ្យទ្រព្យដល់ព្រាហ្មណ៍ ព្រោះខ្ញុំមិនបានឲ្យទ្រព្យដល់ព្រា-

ហ្មណ៍ទើបរួចផុតទៅមិនបាន ។

យក្ខបានស្តាប់ដូច្នោះទើបពោលគាថាទី ៧ ថា

គោលបំណងក្នុងទ្រព្យ ព្រះអង្គបានធ្វើហើយចំពោះព្រាហ្មណ៍ ពាក្យប្តេជ្ញានោះ ក៏ជាប់នៅមិនទាន់ដោះ ព្រះអង្គជាអ្នករក្សានូវសច្ចៈ ឲ្យនូវពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ហើយចូរត្រឡប់មកវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុនរាវជស្សុ** សេចក្តីថា សូមយាងត្រឡប់មកវិញ ។ កាលមនុស្សយក្ខពោលយ៉ាងនេះហើយ ក៏លែងព្រះរាជាទៅ ។ ព្រះរាជាកាលយក្ខលែងហើយទើបត្រាស់ថា អ្នកកុំវិតក្កឡើយ ខ្ញុំនឹងមកអំពីព្រឹកនោះឯង ហើយទ្រង់ធ្វើសញ្ញាសម្គាល់តាមផ្លូវ យាងទៅរកពលនិកាយរបស់ទ្រង់ ចោមរោមដោយពលនិកាយ ចូលទៅកាន់ព្រះនគរ ត្រាស់ឲ្យហៅនន្ទព្រាហ្មណ៍មកគាល់ ឲ្យអង្គុយលើអាសនៈដែលមានតម្លៃច្រើន ទ្រង់ស្តាប់គាថាស្រេចហើយព្រះរាជទានទ្រព្យ ៤០០០ កហាបណៈ អញ្ជើញព្រាហ្មណ៍ឲ្យឡើងយានពាហនៈហើយត្រាស់ថា ចូរអ្នកនាំទ្រព្យនេះទៅកាន់នគរតក្កសិលាចុះ ទ្រង់ប្រគល់មនុស្សឲ្យហើយ ក៏បញ្ជូនព្រាហ្មណ៍ទៅ ទ្រង់បំណងនឹងត្រឡប់មករកយក្ខក្នុងថ្ងៃស្អែក ទើបត្រាស់ហៅព្រះឱរស មកទូន្មាន ។ ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះទើបត្រាស់ ២ គាថាដោយសេចក្តីថា

ព្រះបាទជយទ្ទិសនោះមានសេចក្តីប្រាថ្នាក្នុងកាម បានរួចអំពីដៃបោរិសាទៈ ( អ្នកស៊ី ) ហើយយាងទៅកាន់ព្រះរាជមន្ទីររបស់

ព្រះអង្គ ប្រទានពាក្យប្ដេជ្ញានោះដល់ព្រាហ្មណ៍ ហើយក៏ត្រាស់ហៅព្រះរាជបុត្ត ព្រះនាមអលីនសត្តុមកថា ។ ( នែកូនយើងប្រគល់ ) នូវរាជសម្បត្តិ ( ដល់អ្នកឯង ) ក្នុងថ្ងៃនេះ បាឯងចូរអភិសេកចុះ បាឯងចូរ ( រក្សា ) ធម៌ ក្នុងដែនទាំងឡាយផង ក្នុងពួកប្រជាជនផង ជនអ្នកមិនរក្សាធម៌កុំឲ្យមានក្នុងដែនរបស់បាឯងឡើយ យើងនឹងទៅក្នុងសំណាក់នៃបោរិសាទ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អលីនសត្តុំ** បានដល់ ព្រះរាជកុមារដែលមាននាមយ៉ាងនេះ ។ តែក្នុងព្រះបាលីលោករចនាទុកថា **អលីនសត្ត** ។ បទថា **អជ្ជេវ រជ្ជំ** សេចក្ដីថា កូនសម្លាញ់ អញនឹងប្រគល់រាជសម្បត្តិឲ្យបាចូរបាស្រេពស្រង់មុទ្ធាភិសេកក្នុងថ្ងៃនេះឯង ។ បទថា **ញត្តេ** បានដល់ ក្នុងសម្នាក់ ។ ព្រះរាជកុមារទ្រង់ស្ដាប់ដូច្នោះ ទ្រង់ត្រាស់គាថាទី ១០ ថា

បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ ធ្វើអំពើដូចម្ដេចទៀតព្រះបាទានៃព្រះអង្គ ឲ្យព្រះអង្គមិនសប្បាយព្រះហឫទ័យ ព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំ តាំងនៅក្នុងរាជ្យក្នុងថ្ងៃនេះ ដោយអំពើដែលនាំឲ្យព្រះអង្គមិនសប្បាយណា ទូលព្រះបង្គំជាខ្ញុំ ចង់ស្ដាប់នូវអំពើ ដែលនាំឲ្យព្រះអង្គមិនសប្បាយនោះ ទូលព្រះបង្គំជាខ្ញុំ បើវៀរចាកព្រះអង្គហើយ មិនចង់បាននូវរាជ្យទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កតុំ** បានដល់ ធ្វើ ។ បទថា **យមជ្ជ** សេចក្ដីថា ព្រះរាជបិតាឲ្យខ្ញុំឡើងគ្រងរាជសម្បត្តិ ក្នុងថ្ងៃនេះ ព្រោះធ្វើនូវការមិនពេញព្រះហឫទ័យឯណា ។ បទថា **ឧឧស្សយេ** សេចក្ដីថា ព្រះរាជបិតាទ្រង់លើកឡើង គឺតែងតាំងឲ្យទូលព្រះបង្គំតាំងនៅក្នុងរាជសម្បត្តិព្រោះការធ្វើដែលមិនគាប់ព្រះហឫទ័យឯណា សូមទ្រង់ប្រាប់នូវការធ្វើនោះ ព្រោះខ្ញុំឥតអំពីព្រះអង្គហើយរមែងមិនប្រាថ្នារាជសម្បត្តិ ។ ព្រះរាជាស្ដាប់ដូច្នោះទើបត្រាស់គាថាបន្ទាប់ថា

ម្នាលកូន យើងនឹកមិនឃើញកំហុសរបស់អ្នក ព្រោះអំពើនិង
វាចានេះទេតែយើងបានធ្វើ ( ពាក្យសច្ចៈ ) ជាមួយនឹងបោ-
រិសាទ យើងជាអ្នករក្សានូវពាក្យសច្ចៈនឹងវិលទៅវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អបរាធិតោ** សេចក្ដីថា យើងមិនធ្លាប់ឃើញកំហុសក្នុងទ្វារទាំង ៣ របស់ឯងឡើយ ។ បទថា **តុវិយំ** បានដល់ ជារបស់ខ្ញុំ មានពាក្យអធិប្បាយថា នៃកូន ឪពុកមិនបានគិតដល់កំហុស ដែលមិនជាទីគាប់ចិត្តរបស់ឪពុកណាមួយរបស់ឯង ទាំងតាមកាយនិងតាមវាចាឡើយ ។ បទថា **សង្គិញ្ច កត្វា** សេចក្ដីថា តែព្រោះយក្ខម្នាក់ ចាប់ឪពុកបាន កាលទៅព្រៃបាញ់សត្វ បម្រុងស៊ីជាអាហារ កាលបើដូច្នោះទើបឪពុកសន្យាជាមួយយក្ខនោះថា កាលខ្ញុំស្ដាប់ធម្មកថារបស់ព្រាហ្មណ៍ធ្វើសក្ការៈដល់បុគ្គលនោះហើយនឹងមកឲ្យទាន់ពេលអាហារព្រឹក ស្អែកនេះនឹងត្រឡប់មកវិញ ព្រោះហេតុនោះដើម្បីរក្សាសច្ចៈ ឪពុកនឹងទៅទីនោះវិញ ចូរបាសោយរាជសម្បត្តិ

ចុះ ។

អលីនសត្តុរាជកុមារស្តាប់ព្រះតម្រាស់របស់ព្រះបិតាហើយ ត្រាស់នូវគាថាដោយសេចក្តីថា

ទូលព្រះបង្គំជាខ្ញុំនឹងទៅ សូមព្រះអង្គគង់នៅក្នុងទីនេះចុះ ការរួចអំពីសំណាក់នៃបោរិសាទៈនោះ មិនមានដល់បុគ្គលកាលរស់នៅទេ បពិត្រព្រះរាជា បើព្រះអង្គយាងទៅ ទូលព្រះបង្គំជាខ្ញុំក៏ទៅដែរ ព្រះអង្គនិងទូលព្រះបង្គំជាខ្ញុំ ទាំងពីរនាក់នឹងមិននៅទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធេវ** សេចក្តីថា សូមទ្រង់ប្រថាប់នៅទីនេះចុះ ។ បទថា **ឥតោ** សេចក្តីថា ឈ្មោះថា ការរួចជីវិតអំពីសម្នាក់នៃយក្ខនោះមិនមានផ្លូវឡើយ ។ បទថា **ឧភោ** សេចក្តីថា កាលបើដូច្នេះ ក៏មិនត្រូវនៅជាមួយគ្នាទាំង ២ នាក់ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះទើបត្រាស់គាថាដោយសេចក្តីថា

ម្នាលកូន ធម៌នុ៎ះ ជាធម៌របស់ពួកសប្បុរសមែនហើយ ប៉ុន្តែយក្សមានជើងពពាល ដុតថ្ងៃរអ្នកឯងជិតគល់ឈើស្រួច ហើយកាំហែងស៊ីពេញទំហឹងក្នុងកាលណា ការនោះទុកជាសេចក្តីស្លាប់របស់យើងក្នុងកាលនោះ ដូច្នេះ ។

ព្រះគាថានោះមានអធិប្បាយថា នុ៎ះជាធម៌ គឺធាតុពិតរបស់សប្បុរស គឺបណ្ឌិតទាំងឡាយដោយពិត ឯងពោលពាក្យត្រឹមត្រូវហើយតែជាទុក្ខក្រៃលែង

ជាងការស្លាប់របស់ឪពុក សេចក្តីនោះនឹងជាការសៅហ្មងរបស់ឪពុក ។ បទថា **ភិនារុក្ខមូលេ** សេចក្តីថា កាលយក្ខសង្កត់សង្កិនដុតឯងស៊ីដោយកម្លាំងត្រង់គល់ឈើពេញទំហឹង ។ ព្រះរាជកុមារទ្រង់ស្តាប់ដូច្នោះ បានត្រាស់គាថាដោយសេចក្តីថា

ទូលព្រះបង្គំជាខ្ញុំ នឹងយកជីវិតទៅប្តូរជីវិតរបស់ព្រះអង្គ សូមព្រះអង្គកុំយាងទៅក្នុងសំណាក់នៃបោរិសាទៈឡើយ ទូលព្រះ-បង្គំជាខ្ញុំ នឹងយកជីវិតនោះទៅប្តូរជីវិតរបស់ព្រះអង្គ ហេតុនោះទូលព្រះបង្គំជាខ្ញុំ ប្រាថ្នានូវសេចក្តីស្លាប់ដើម្បីជីវិត ( របស់ព្រះអង្គ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និមិស្សំ** សេចក្តីថា ខ្ញុំនឹងដូរជីវិតរបស់ខ្លួនជាមួយព្រះជន្មរបស់ព្រះបិតា ក្នុងកាលនេះឯង ។ បទថា **តស្មា** សេចក្តីថា ព្រោះទូលព្រះបង្គំនឹងដូរព្រះជន្មរបស់ព្រះរាជបិតាដូច្នោះ ទើបជ្រើសរើសយកសេចក្តីស្លាប់ ដើម្បីឲ្យព្រះរាជបិតាមានព្រះជន្ម ទូលព្រះបង្គំនឹងសរសើរការស្លាប់តែម្យ៉ាងប៉ុណ្ណោះទើបជ្រើសរើស គឺប្រាថ្នាសេចក្តីស្លាប់ ។

ព្រះបាទជយទ្ទិសបានស្តាប់ដូច្នោះ ទ្រង់ជ្រាបកម្លាំងរបស់ព្រះឱរស ទើបត្រាស់ថា សាធុ ចូរបាទៅចុះ អលីនសត្តុរាជកុមារថ្វាយបង្គំលាព្រះរាជមាតានិងបិតាហើយក៏យាងចេញអំពីព្រះនគរ ។

កាលព្រះបរមសាស្តា ទ្រង់ប្រកាសសេចក្តីនោះទើបត្រាស់កន្លះគាថានេះថា

លំដាប់នោះឯង ព្រះរាជបុត្ត អ្នកមានប្រាជ្ញា ក៏ក្រាបថ្វាយបង្គំ
ព្រះបាទាមាតានិងបិតា ( ហើយចេញទៅ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចារេ** សេចក្ដីថា ថ្វាយបង្គំព្រះយុគលបាទ ព្រះជនកព្រះជននីយាងទៅហើយ ។

លំដាប់នោះព្រះជនកព្រះជននីក្ដី ព្រះភគិនីក្ដី ព្រះជាយាក្ដីរបស់ព្រះរាជ-កុមារនោះមួយអន្លើដោយពួកអាមាត្យនិងបរិវារជន ក៏ចេញទៅជាមួយដែរ ។ កាលព្រះរាជកុមារនោះចេញអំពីព្រះនគរហើយ ក៏ទូលសួរផ្លូវនឹងព្រះរាជបិតា កំណត់ទុកដោយល្អហើយ ថ្វាយបង្គំព្រះជនកព្រះជននី ប្រទានឱវាទដល់ជនដ៏សេសហើយមិនបានតក់ស្លុត ភ័យខ្លាច ទ្រង់យាងទៅកាន់លំនៅរបស់យក្ខហាក់បីដូចកេសរសីហរាជដូច្នោះ ព្រះមាតាទតឃើញព្រះកុមារកំពុងយាងទៅមិនអាចតាំងព្រះកាយបាន ក៏ដួលចុះលើផែនដី ។ ព្រះរាជបិតាក៏ទ្រង់ផ្គងដើមដៃយំសោកដោយសំឡេងខ្លាំង ។

ព្រះបរមសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះ ទើបទ្រង់ត្រាស់កន្ធះគាថាដោយសេចក្ដីថា

ព្រះមាតានៃព្រះរាជកុមារនោះមានសេចក្ដីទុក្ខ ក៏ដួលក្រាបលើ
ប្រឹថពី ឯព្រះបិតានៃព្រះរាជកុមារនោះផ្គងព្រះហស្ដហើយទ្រង់
ព្រះកន្សែង ដូច្នេះ ។

កាលត្រាស់កន្ធះគាថាដូច្នេះហើយ កាលទ្រង់ប្រកាសសច្ចកិរិយា ដែលព្រះរាជបិតារបស់ព្រះរាជកុមារនោះទ្រង់ប្រកបនិងដែលព្រះរាជមាតាព្រះភគិនី

និងព្រះជាយាទ្រង់ធ្វើហើយទើបបានត្រាស់គាថាជាបន្ត ៤ គាថានេះថា

ព្រះបិតាជ្រាបនូវព្រះរាជកុមារនោះ កំពុងយាងទៅ ( ជាកូនរបស់អញ ) ទៅក្នុងទីកំបាំងមុខ ហើយទ្រង់ផ្គងអញ្ជលីថ្វាយបង្គំទេវតាថា សូមឲ្យព្រះរាជាព្រះនាមសោមៈ ព្រះរាជាព្រះនាមវរុណៈ ព្រះរាជាព្រះនាមបជាបតិ ព្រះចន្ទនិងព្រះអាទិត្យទាំងនុ៎ះគ្រប់គ្រងអ្នក ម្នាលកូនអ្នក ( ដែលយក្ស ) អនុញ្ញាតហើយ ចូរត្រឡប់មកអំពីសំណាក់បោរិសាទដោយសុវត្ថិភាពចុះ ។

ព្រះមាតាពោលថា

មាតានៃបុរសឈ្មោះរាមៈដែលទៅ ( ក្នុងដែន ) នៃព្រះរាជាទណ្ឌកី ជាស្ត្រីគ្រប់គ្រងល្អ បានធ្វើនូវសួស្តីណា យើងក៏ធ្វើនូវសួស្តីនោះដល់អ្នក ទេវតាទាំងឡាយសូមរឮកឃើញដោយពាក្យពិតនោះចុះ ម្នាលកូន បើយក្សអនុញ្ញាតឲ្យហើយ អ្នកចូរត្រឡប់មកវិញដោយសួស្តីចុះ ។

ព្រះកនិដ្ឋកគិនីពោលថា

ខ្ញុំមិនរឮកឃើញនូវសេចក្តីប្រទូស្តក្នុងចិត្ត ចំពោះអលីនសត្តកុមារក្នុងទីចំពោះមុខ ឬកំបាំងមុខដោយពិត សូមពួកទេវតារឮកឃើញដោយពាក្យពិតនោះចុះ បពិត្រអ្នកបង បើយក្សអនុញ្ញាត សូមអ្នកបងត្រឡប់មកដោយសួស្តីចុះ ។

អគ្គមហេសីពោលថា

បពិត្រស្វាមី ព្រះអង្គមិនប្រព្រឹត្តកន្លងចិត្តខ្ញុំម្ចាស់ផង ព្រះអង្គមិនមែនមិនជាទីស្រឡាញ់ ដោយចិត្តរបស់ខ្ញុំម្ចាស់ផង ដោយហេតុណា ( ហេតុនោះ ) សូមទេវតាទាំងឡាយ ពេញយើញដោយពាក្យសច្ចៈនុ៎ះចុះ បពិត្រស្វាមី បើយក្សអនុញ្ញាតហើយសូមព្រះអង្គត្រឡប់មកវិញដោយសួស្តីចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរម្មុខោ** សេចក្តីថា ព្រះរាជបិតាទ្រង់ជ្រាបច្បាស់ថា ព្រះរាជឱរសរបស់យើងនេះ កំពុងបែរមុខយាងទៅ ។ បទថា **បញ្ជលីកោ** សេចក្តីថា ទ្រង់ប្រឡាក់ព្រះភក្ត្រប្រតិស្ឋានអញ្ជលីលើសិរសាក្នុងកាលនោះ ទ្រង់បានអង្វរនមស្ការនូវទេវតាទាំងឡាយ ។ បទថា **ចោរិ-សាទកម្ហា** សេចក្តីថា សូមទេវតាជួយរក្សាគ្រប់គ្រងឱរសរបស់យើង អំពីអំណាចនៃយក្ខ នៃអលីនសត្តកូនជាទីស្រឡាញ់ យក្ខនោះចូរអនុញ្ញាតឲ្យអ្នកត្រឡប់មកដោយសួស្តី ។

បទថា **រាមស្សាកាសិ** សេចក្តីថា មាតារបស់រាមបុរសបានធ្វើនូវការរក្សាបានឮថា មានបុរសម្នាក់ជាអ្នកក្រុងពារាណសីឈ្មោះរាមៈ ជាអ្នកចិញ្ចឹមមាតាបដិបត្តិមាតាបិតា ។ គ្រាមួយទៅជួញដូរឯក្រុងកុម្ភវតី ក្នុងដែនរបស់ព្រះបាទទណ្ឌកិរាជ កាលអ្នកដែនទាំងមូល ត្រូវវិនាសដោយភ្លៀង ៩ ប្រការ គាត់បានរឭកដល់គុណរបស់មាតាបិតា ។ កាលនោះដោយផលនៃមាតាបិតុប្ប-ដ្ឋានធម៌ ទេវតាទាំងឡាយ បាននាំគេមកប្រគល់ឲ្យដល់មាតាបិតាដោយសួស្តី

ព្រះជនកព្រះជននីរបស់អលីនសត្តុរាជកុមារ នាំហេតុនោះមកត្រាស់យ៉ាងនេះ ដោយការបានឮបានស្តាប់មក ។

បទថា **សោត្ថានំ** បានដល់ សួស្តី ។ ទេវតាទាំងឡាយនឹងធ្វើនូវសួស្តី បានក៏ពិតតែលោកពោលថា មាតាបានធ្វើហើយ ព្រោះកើតហើយដោយអាស្រ័យមាតាបិតុបដ្ឋានធម៌ ។ បទថា **តន្តេ អហំ** សេចក្តីថា មាតារបស់រាមបុរស ធ្វើនូវសួស្តីដល់រាមជាបុត្តយ៉ាងណា សូម្បីមាតាក៏ធ្វើនូវសួស្តីនោះដល់ឯងដូចគ្នា គឺព្រោះអាស្រ័យមាតា ចូរសួស្តីមានដល់កូនរបស់មាតាដូច្នោះដូចគ្នា ។ ម្យ៉ាងទៀត បទថា **ករោមិ** បានដល់ នឹងទៅ ។ បទថា **ឃតេន សច្ចេន** សេចក្តីថា បើរាមបុរសនោះជាបុគ្គលដែលទេវតានាំមកហើយដោយសួស្តី ជាសេចក្តីពិត សោតដោយអំណាចពាក្យសច្ចៈនោះ សូមទេវតាទាំងឡាយរឭកដល់អ្នក ដើម្បីព្រះជនកព្រះជននី គឺសូមទេវតានាំអ្នកមកបង្ហាញដល់មាតាដូចរាមបុរស ដូច្នោះ ។ បទថា **អនុញ្ញាតោ** សេចក្តីថា កូនជាទីស្រឡាញ់ កាលយក្ខអនុញ្ញាតថា ទៅបាន គឺព្រះជននីត្រាស់ថា នៃកូនជាទីស្រឡាញ់ ចូរអ្នកត្រឡប់មកដោយសួស្តីដោយទេវានុភាពចុះ ។

បទថា **ជាតុមលីនសត្តេ** សេចក្តីថា ព្រះកនិដ្ឋកគិនីរបស់ព្រះបាទអលីនសត្តុរាជកុមារនោះ បានតាំងសច្ចាធិដ្ឋានយ៉ាងនេះថា ប្អូនស្រីរឭកមិនបាននូវការគិតប្រទូស្ត ទាំងចំពោះមុខ ឬកំបាំងមុខ ក្នុងអលីនសត្តុដែលជាព្រះជេដ្ឋាដោយចំណែកមួយពិត ។ បទថា **យស្មា ច មេ អនធិមនោសិ សាមិ** សេចក្តីថា ព្រះអគ្គមហេសីរបស់អលីនសត្តុរាជកុមារនោះ បានតាំងសច្ចាធិ-

ដ្ឋានយ៉ាងនេះថា បពិត្រអលីនសត្តុដ៏ជាស្វាមី ទ្រង់មិនបានប្រព្រឹត្តកន្ទងចិត្តខ្ញុំឡើយ គឺទ្រង់មិនបានប្រព្រឹត្តកន្ទងចិត្តខ្ញុំ រហូតដល់យកចិត្តប្រាថ្នាក្នុងស្រីដទៃឡើយ ។ បទថា **ន ចាបិ មេ មនសា អប្បិយោសិ** សេចក្ដីថា ទ្រង់មិនជាទីស្រឡាញ់ដោយចិត្តពិតរបស់ខ្ញុំ ក៏មិនមែន យើងទាំង ២ នៅរួមគ្នាមកដោយការស្រឡាញ់នោះឯង ។

ព្រះរាជកុមារយាងទៅកាន់ផ្លូវដែលជាលំនៅរបស់យក្ខ តាមពាក្យណែនាំដែលព្រះរាជបិតាត្រាស់ប្រាប់ ។ ចំណែកយក្ខគិតថា ធម្មតាក្សត្រមានមាយាច្រើន អ្នកណានឹងដឹងថានឹងកើតអ្វីឡើង ទើបឡើងដើមឈើ អង្គុយមើលផ្លូវព្រះបាទជយទ្ទិសយាងមក សម្លឹងឃើញព្រះរាជកុមារកំពុងយាងមក គិតថា ប្រហែលព្រះរាជឱរសឲ្យព្រះរាជបិតាត្រឡប់ ហើយមកជំនួស ភ័យគង់មិនមានដល់អញទើបចុះអំពីដើមឈើទើបឈរបែរខ្នងឲ្យ ។ ព្រះរាជកុមារយាងមកដល់ហើយបានទៅឈរពីមុខយក្ខ ។

លំដាប់នោះយក្ខពោលគាថាដោយសេចក្ដីថា

> អ្នកជាបុគ្គលមានមាឌធំ មានកាយត្រង់ មានមុខស្រស់ តើអ្នក ( មក ) អំពីទីណា អ្នកមិនដឹងនូវយើងដែលនៅក្នុងព្រៃទេ ( ឬ ) អ្នកណាដឹងនូវយើង ជាបុគ្គលអាក្រក់ ជាអ្នកស៊ីនូវបុរស ហើយគប្បីមកក្នុងទីនេះ អ្នកទំនងជាមិនដឹងនូវសុ-វត្ថិភាពបានជាមកឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោ សោត្ថិមាជានមិធាវជេយ្យ** សេចក្ដី

ថា នែកុមារ បុរសណាដឹងសួស្តីរបស់ខ្លួននៅតែហ៊ានមកក្នុងទីនេះ ប្រហែលជាអ្នកមិនដឹងទើបមក ។ ព្រះរាជកុមារស្តាប់ដូច្នោះទើបត្រាស់គាថាដូច្នេះថា

បពិត្រព្រានព្រៃ ខ្ញុំស្គាល់ថា អ្នកជាបុគ្គលស៊ីនូវបុរស ខ្ញុំមិនមែនជាមិនស្គាល់អ្នកដែលនៅក្នុងព្រៃទេ ឯខ្ញុំជាព្រះរាជបុត្តនៃព្រះបាទជយទ្ទិសៈ សូមអ្នកពិសាខ្ញុំក្នុងថ្ងៃនេះចុះឲ្យតែព្រះបិតារួច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បមោក្ខា** សេចក្ដីថា ព្រោះហេតុដែលដោះនូវភារៈ ទើបខ្ញុំលះបង់ជីវិតជំនួសព្រះរាជបិតា មកក្នុងទីនេះ ព្រោះហេតុនោះ សូមអ្នកលែងព្រះជនកខ្ញុំ ហើយបរិភោគខ្ញុំជំនួសទ្រង់ចុះ ។ លំដាប់នោះយក្ខពោលគាថាដូច្នេះថា

ខ្ញុំស្គាល់ថាអ្នកជាបុត្តរបស់ព្រះបាទជយទ្ទិសៈ សម្បុរមុខរបស់អ្នកទាំងពីរក៏ដូចគ្នា អ្នកណាប្រាថ្នាស្លាប់ ព្រោះឲ្យតែបិតារួច អំពើរបស់អ្នកនោះដែលអ្នកធ្វើហើយ ជាអំពើដែលគេធ្វើបានដោយកម្រក្រៃពេក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តថាហិ តេ** សេចក្ដីថា ព្រះភក្ត្រនិងពណ៌សម្បុររបស់អ្នកទាំង ២ ដូចគ្នា គឺដូចគ្នាពិត ។ បទថា **កតំ តវេទំ** សេចក្ដីថា កម្មរបស់អ្នកជាកម្មដែលគេធ្វើបានកម្រពិត ។

លំដាប់នោះព្រះរាជកុមារត្រាស់គាថាដោយសេចក្ដីថា

ខ្ញុំមិនសំគាល់នូវអំពើបន្តិចបន្តួចថា គេធ្វើបានដោយក្រក្នុងហេតុ

នេះទេ បុគ្គលណាប្រាថ្នាស្លាប់ ព្រោះឲ្យតែបិតារួចផង ព្រោះ
ហេតុនៃមាតាផង បុគ្គលនោះលុះទៅកាន់បរលោក ក៏ប្រកប
ដោយសេចក្តីសុខក្នុងឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិញ្ចិមហេត្ត មញ្ញេ** សេចក្តីថា ព្រះរាជកុមារ ពោលថា នៃយក្ខក្នុងសេចក្តីនេះ យើងមិនឃើញអ្វីសំខាន់ឡើយ ។ លោក ពោលអធិប្បាយថា បុគ្គលណាប្រាថ្នានឹងស្លាប់ ដើម្បីដោះនូវបិតា ឬព្រោះ ហេតុនៃមាតា ។ បទថា **បរលោកគមា្យ** សេចក្តីថា ចូលទៅកាន់បរលោក ហើយ ។ បទថា **សុខេន សគ្គេន** សេចក្តីថា រមែងជាអ្នកប្រកបដោយសុខ ជាហេតុឲ្យកើតក្នុងស្ថានសួគ៌ ។ បទថា **មត្តុមិច្ឆេ** សេចក្តីថា ព្រោះហេតុ នោះក្នុងការលះបង់ជីវិត ដើម្បីប្រយោជន៍ដល់មាតាបិតានេះ ខ្ញុំមិនសម្គាល់ថា ជារបស់ដែលធ្វើបានក្រអ្វីឡើយ ។

យក្ខស្តាប់ដូច្នោះ ទើបសួរថា នៃកុមារ ធម្មតាសត្វបុគ្គលដែលមិនខ្លាច ស្លាប់មិនមានឡើយ ហេតុអ្វីទើបអ្នកមិនខ្លាច កាលព្រះរាជកុមារប្រាប់សេចក្តី ដល់យក្ខ បានពោលពោល ២ គាថាដោយសេចក្តីថា

ខ្ញុំរឭកមិនបាននូវកិរិយាអាក្រក់របស់ខ្លួនក្នុងទីវាល ឬទីកំបាំង
ដោយពិត ខ្ញុំជាអ្នកមានការកើតនិងសេចក្តីស្លាប់ កំណត់ដឹង
ហើយខ្ញុំ ( មិនផុតពីសេចក្តីស្លាប់ ) ក្នុងលោកនេះយ៉ាងណា
ក្នុងលោកខាងមុខក៏យ៉ាងនោះដែរ ។ បពិត្រលោកមានអានុ-
ភាពច្រើន ឥឡូវនេះលោកចូរពិសាខ្ញុំក្នុងថ្ងៃនេះចុះ ចូរលោក

ធ្វើនូវកិច្ចទាំងឡាយចំពោះសរីរៈនេះចុះ មួយទៀតខ្ញុំនឹងទម្លាក់
ខ្លួនអំពីចុងឈើជូនលោក កាលលោកឃ្លាន ចូរពិសាសាច់ខ្ញុំ
ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សរេ ច ជាតុ** សេចក្តីថា ខ្ញុំរឭកមិនបាន ឡើយត្រឹមតែចំណែកមួយ ។ បទថា **សង្ខាតជាតីមរណោហមស្មិ** សេចក្តីថា ខ្ញុំដឹងថា សត្វដែលកើតហើយ មានការកើតនិងការស្លាប់ដែលញាណកំណត់ទុកហើយដោយល្អ ដែលឈ្មោះថាមានការមិនស្លាប់ជាធម្មតាមិនមាន ។ បទថា **យថេវ មេ ឥធ** សេចក្តីថា សេចក្តីនេះញាណរបស់យើងកំណត់ទុកហើយយ៉ាងល្អថា លោកនេះរបស់អញយ៉ាងណា លោកខាងមុខក៏យ៉ាងនោះ លោកខាងមុខយ៉ាងណា លោកនេះក៏យ៉ាងនោះ ឈ្មោះថាការផុតអំពីសេចក្តីស្លាប់មិនមាន ។ បទថា **ករស្សុ កិច្ចានិ** សេចក្តីថា លោកចូរធ្វើកិច្ចដែលគួរធ្វើដោយសរីរៈនេះ សរីរៈនេះខ្ញុំលះបង់ដល់លោកហើយ ។ បទថា **ជាត មាណោ មយ្ហំ ត្វមេធេសិ មំសំ** សេចក្តីថា កាលខ្ញុំធ្លាក់អំពីដើមឈើស្លាប់ហើយ កាលលោកបរិភោគ គាប់ចិត្តប្រាថ្នាសាច់ចំណែកណាអំពីសរីរៈរបស់ខ្ញុំ ក៏គួរបរិភោគសាច់ចំណែកនោះ ។

យក្ខស្តាប់ពាក្យរបស់ព្រះរាជកុមារហើយភ័យរន្ធត់ គិតថា អញមិនអាចបរិភោគសាច់កុមារនេះបានទើបរកឧបាយដេញឲ្យគេចទៅក៏ពោលគាថានេះថា

បពិត្ររាជបុត្ត អ្នកពេញចិត្តនឹងអំពើនេះ អ្នកលះបង់នូវជីវិត
ព្រោះឲ្យបិតារួច ព្រោះហេតុនោះអ្នកចូរជាអ្នកមានសភាពរួស

រាន់កាប់ឧស បង្កាត់ភ្លើងចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជលេហិ** សេចក្ដីថា យក្ខណែនាំថា ចូរអ្នកទៅកាន់ព្រៃរកឧសមានខ្លឹមមកបង្កាត់ភ្លើង ធ្វើឲ្យជារងើកដែលប្រាសចាកផ្សែង យើងនឹងអាំងសាច់របស់អ្នកក្នុងរងើកភ្លើងនោះបរិភោគ ។

អលីនសត្តុរាជកុមារបានធ្វើតាមយក្ខប្រាប់គ្រប់ប្រការ ស្រេចហើយក៏ទៅកាន់សម្នាក់របស់យក្ខ ។ ព្រះបរមសាស្ដាកាលទ្រង់ប្រកាសហេតុនោះ ទើបត្រាស់ព្រះគាថាក្រៅអំពីនេះថា

លំដាប់នោះឯង ព្រះរាជបុត្តមានប្រាជ្ញាក៏ប្រមូលនូវឧសហើយ
ដុតភ្លើងឲ្យឆេះធំឡើង រួចប្រាប់យក្សថា ឥឡូវនេះភ្លើងដ៏ធំនេះ
ខ្ញុំបានបង្កាត់ឆេះហើយ ដូច្នេះ ។

យក្ខសម្លឹងមើលព្រះរាជកុមារ ដែលបង្កាត់ភ្លើងស្រេចហើយ ដើរមករកកើតនូវការព្រឺរោមព្រឺស្បែក ហើយគិតថា បុរសនេះដូចរាជសីហ៍ មិនខ្លាចសេចក្ដីស្លាប់សោះ អស់កាលមានប្រមាណប៉ុណ្ណេះ អញមិនធ្លាប់ឃើញអ្នកដែលមិនខ្លាចស្លាប់យ៉ាងនេះឡើយ ទើបអង្គុយសម្លឹងមើលព្រះរាជកុមាររឿយៗ ព្រះរាជកុមារឃើញកិរិយារបស់យក្ខហើយទើបត្រាស់គាថាដោយសេចក្ដីថា

ឥឡូវនេះលោកជាអ្នកធ្វើនូវការកំហែងខ្ញុំ ចូរពិសាខ្ញុំក្នុងថ្ងៃនេះចុះ
លោកព្រឺរោមហើយសម្លឹងខ្ញុំញយៗ តើព្រោះហេតុអ្វី លោក
ឃ្លានចង់ស៊ីខ្ញុំយ៉ាងណាៗ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកយ៉ាង
នោះៗ ដូច្នេះ ។

*បណ្ដាបទទាំងនោះ បទថា* **មុហុំ** *បានដល់ សម្លឹងមើលរឿយៗ ។ បទថា* **តថា តថា តុយ្ហមហំ** *សេចក្ដីថា លោកគាប់ចិត្តប្រាថ្នានឹងបរិភោគ ទំពាស៊ីខ្ញុំដោយវិធីណា ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកដោយវិធីនោះ ហើយពេលនេះនឹងឲ្យខ្ញុំធ្វើដូចម្ដេច ព្រោះដូច្នោះ អញ្ជើញបរិភោគខ្ញុំក្នុងថ្ងៃនេះចុះ យក្ខស្ដាប់ពាក្យព្រះរាជកុមារហើយពោលគាថាដោយសេចក្ដីថា*

*នរណាគួរស៊ីបុគ្គលតាំងនៅក្នុងធម៌ និយាយពាក្យពិត ដឹងនូវពាក្យពេចន៍បែបអ្នក បុគ្គលណាហ៊ានស៊ីនូវបុគ្គលពោលពាក្យសច្ចៈបែបអ្នក ក្បាលរបស់បុគ្គលនោះ នឹងបែកជា ៧ ភាគដូច្នេះ ។*

*ព្រះរាជកុមារបានស្ដាប់ដូច្នោះទើបពោលថា បើលោកមិនបំណងនឹងស៊ីខ្ញុំ ហេតុអ្វីទើបប្រាប់ឲ្យខ្ញុំបង្កាត់ភ្លើង កាលយក្ខឆ្លើយថា ដើម្បីសាកល្បងមើលថាអ្នករត់គេចទៅដែរឬទេ ។ កុមារត្រាស់ថា លោកយល់ក្នុងសេចក្ដីនេះដូចម្ដេច កាលខ្ញុំកើតក្នុងកំណើតសត្វតិរច្ឆាន គង់មិនឲ្យសក្កទេវរាជមើលងាយបានទើបពោលគាថាដូច្នេះថា*

*អម្បាលដូចជាទន្សាយនោះ កាលសំគាល់នូវហេតុនេះ បានញ៉ាំងឥន្ទព្រាហ្មណ៍ឲ្យនៅ ( ដើម្បីឲ្យ ) សរីរៈនៃខ្លួន ម្នាលយក្ស ហេតុនោះឯងបានជាចន្ទិមទេវបុត្ត បង្ករចេញនូវសេចក្ដីប្រាថ្នានោះ មានរូបទន្សាយឋិតនៅសព្វថ្ងៃនេះ ដូច្នេះ ។*

*គាថានោះមានអធិប្បាយថា សសបណ្ឌិតនោះសម្គាល់សក្កព្រាហ្មណ៍នេះ*

ថា បុគ្គលនេះជាព្រាហ្មណ៍ទើបពោលថា ថ្ងៃនេះអញ្ជើញលោកទំពាស៊ីសរីរៈរបស់ខ្ញុំក្នុងទីមួយកន្លែងចុះ ហើយឲ្យអាស្រ័យ គឺឲ្យស្នាក់នៅដើម្បីឲ្យសរីរៈរបស់ខ្លួនជាទានយ៉ាងនេះ ហើយបានឲ្យសរីរៈ ដើម្បីជាអាហារដល់សក្កព្រាហ្មណ៍នោះ ទើបសក្កទេវរាជច្របាច់យករសដែលកើតអំពីបព៌ត មកគូរជារូបទន្សាយ ទុកក្នុងមណ្ឌលព្រះចន្ទ តាំងអំពីនោះមក ព្រោះរូបទន្សាយនោះឯងចន្ទិមទេវបុត្តនោះទើបសត្វលោកស្គាល់គ្រប់គ្នាថា ទន្សាយៗដូច្នេះ ចន្ទិមទេវបុត្តមានរូបទន្សាយប្រាកដជាក់ច្បាស់យ៉ាងនេះ សមតាមបំណង គឺញ៉ាំងនូវការពេញចិត្តរបស់សត្វលោក ឲ្យចម្រើនរុងរឿងដល់សព្វថ្ងៃនេះ រឿងនេះជារឿងអស្ចារ្យតាំងនៅអស់មួយកប្ប ។

យក្ខបានស្តាប់ដូច្នោះ កាលនឹងលែងព្រះរាជកុមារទើបពោលគាថានេះថា

ព្រះចន្ទនិងព្រះអាទិត្យរួចអំពីមាត់រាហូ ហើយរុងរឿងក្នុងថ្ងៃ ១៥ កើតយ៉ាងណាមិញ បពិត្រអ្នកមានអានុភាពច្រើន អ្នកបានរួចអំពីយើងឈ្មោះបោរិសាទហើយ ចូររុងរឿងក្នុងក្រុងកបិលពស្តុចុះ រួចចូរញ៉ាំងបិតានិងមាតាឲ្យរីករាយ ទាំងពួកញាតិទាំងអស់របស់អ្នកក៏ចូរត្រេកអរចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភាណុមា** បានដល់ ព្រះអាទិត្ត លោកអធិប្បាយថា ព្រះចន្ទឬព្រះអាទិត្តផុតចាកមាត់រាហូ រមែងរុងរឿងក្នុងតិថី ១៥ កើត យ៉ាងណា នៃអ្នកមានអានុភាពច្រើន សូម្បីអ្នកផុតអំពីសម្នាក់របស់ខ្ញុំហើយ ក៏រុងរឿងក្នុងកបិលវត្ថុយ៉ាងនោះចុះ ។ បទថា **ឆន្ទុតុ** សេចក្តីថា ពួក

ញាតិទាំងឡាយចូរត្រេកអររីករាយចុះ ។

យក្ខពោលថា នែមហាវីរៈ អញ្ជើញអ្នកទៅចុះហើយបញ្ជូនព្រះមហាសត្វទៅ ឯព្រះមហាសត្វកាលធ្វើយក្ខឲ្យអស់ព្យសន៍ហើយឲ្យនូវសីល ៥ កំណត់មើលថា បុគ្គលនេះមិនមែនយក្ខទេដឹងទើបទ្រង់ព្រះតម្រិះថា ធម្មតាយក្ខរមែងមានភ្នែកក្រហម មិនប៉ប្រិចភ្នែក បុរសនេះមិនប្រាកដជាអ្នកឃោរឃៅអាចហ៊ាន បុគ្គលនេះប្រហែលជាមិនមែនយក្ខ ជាមនុស្សពិត បានឮថា ព្រះជេដ្ឋានៃព្រះរាជបិតារបស់អញត្រូវយក្ខិនីចាប់អស់ ៣ អង្គ ក្នុងចំនួននោះយក្ខិនីស៊ី ២ អង្គ តែប្រហែលជាចិញ្ចឹមដោយការស្រឡាញ់ដូចកូនមួយអង្គ ប្រហែលជាបុរសនេះពិត អញនឹងនាំទៅក្រាបទូលដល់ព្រះរាជបិតារបស់អញឲ្យបុគ្គលនេះគ្រងរាជសម្បត្តិទើបបបួលថា មកចុះ លោកមិនមែនជាយក្ខ ជាព្រះជេដ្ឋានៃព្រះបិតារបស់ខ្ញុំ អញ្ជើញលោកមកជាមួយខ្ញុំហើយលើកស្វេតច្ឆត្រសោយរាជ្យបន្តសន្តតិវង្សចុះ កាលយក្ខជំទាស់ថាយើងមិនមែនមនុស្ស ទើបត្រាស់ថា លោកមិនជឿខ្ញុំ តើមានបុគ្គលដែលលោកល្មមជឿដែរឬទេ កាលយក្ខឆ្លើយថា មាន គឺតាបសដែលមានចក្ខុទិព្វក្នុងទីឈ្មោះនោះ ទើបទ្រង់នាំយក្ខនោះទៅកាន់សម្នាក់តាបស តាបសឃើញជនទាំង ២ ហើយរាក់ទាក់ឡើងថា អ៊ំនិងក្មួយ ត្រាច់ធ្វើអ្វីក្នុងព្រៃនេះ ហើយប្រាប់ភាពដែលជនទាំងនោះជាញាតិនឹងគ្នាឲ្យជ្រាប យក្ខជឿពាក្យរបស់តាបសទើបពោលថា នែក្មួយប្រុស ចូរឯងត្រឡប់ទៅចុះ អ៊ំកើតមកមួយជាតិ តែដល់នូវភាពជាបុគ្គល ២ ចំណែក អ៊ំមិនត្រូវការរាជសម្បត្តិឡើយ អ៊ំនឹងបួស ហើយបួសជាឥសីក្នុងសម្នាក់តា-

បសនោះឯង ។ លំដាប់នោះអលីនសត្តុរាជកុមារ ថ្វាយបង្គំលាម្ចាស់អ៊ំហើយ ត្រឡប់ទៅកាន់ព្រះនគរ ។

ព្រះបរមសាស្តាកាលទ្រង់ប្រកាសសេចក្ដីនោះទើបត្រាស់គាថានេះថា

លំដាប់នោះឯង ព្រះរាជបុត្តមានប្រាជ្ញា ព្រះនាមអលីនសត្តដែល
បោរិសាទនោះ បានអនុញ្ញាតហើយ ក៏ធ្វើអញ្ជលីផ្គងឡើងចំពោះ
បោរិសាទ រួចត្រឡប់មកកាន់នគរកបិលពស្តុវិញដោយសួស្ដីបាន
សេចក្ដីសុខឥតមានរោគឡើយ ដូច្នេះ ។

ព្រះបរមសាស្តា កាលត្រាស់ព្រះគាថានេះហើយ ដើម្បីសម្ដែងករណីយកិច្ចដែលអ្នកនគរនិងអ្នកនិគមជាដើមធ្វើទើបត្រាស់អវសានគាថានេះថា

ពួកមនុស្សនៅក្នុងនិគមក្ដី ពួកមនុស្សនៅក្នុងជនបទក្ដី ពួកពល
ដំរីក្ដី ពលរថក្ដី ពលថ្មើរជើងក្ដីទាំងអស់ក៏ប្រណម្យអញ្ជលី
នមស្ការចូលទៅជិតអលីនសត្តកុមារថា យើងខ្ញុំសូមថ្វាយបង្គំ
ចំពោះព្រះអង្គ ព្រះអង្គទ្រង់ធ្វើនូវអំពើ ដែលគេធ្វើបានដោយក្រ
ដូច្នេះ ។

ព្រះបាទជយទ្ទិស ទ្រង់បានដំណឹងថា ព្រះរាជកុមារត្រឡប់មក ទ្រង់បានចាត់ការរៀបចំកោជនទទួល ។ ព្រះរាជកុមារចោមរោមដោយមហាជន ទៅថ្វាយបង្គំព្រះរាជបិតា ។ លំដាប់នោះព្រះរាជាត្រាស់សួរថា កូនសម្លាញ់ បារុតអំពីយក្ខបែបនោះបានដូចម្ដេច ព្រះរាជកុមារទូលថា បពិត្រព្រះរាជបិតា បុរសនោះមិនមែនជាយក្ខ តែជាព្រះជេដ្ឋាធិរាជរបស់ព្រះរាជបិតា បុរសនោះ

ជាព្រះបិតុលារបស់ទូលព្រះបង្គំ ហើយទូលរឿងទាំងពួងឲ្យទ្រង់ជ្រាប ក្រាបទូលថា ព្រះរាជបិតាគួរយាងទៅសួរសុខទុក្ខព្រះបិតុលាផងដែរ ។ រំពេចនោះទើបព្រះបាទជយទ្ទិសត្រាស់ឲ្យភ្នាក់ងារវាយស្គរប្រកាសឲ្យដឹងគ្រប់គ្នា ហើយយាងទៅកាន់សម្នាក់តាបសទាំងឡាយ ដោយរាជបរិវារជាច្រើន ។ ទើបតាបសតំណាលរឿងយក្ខិនីនាំទ្រង់ទៅចិញ្ចឹមមិនស៊ីកាលនៅពីតូច រឿងដែលព្រះអង្គមិនមែនយក្ខនិងរឿងដែលទ្រង់ជាព្រះញាតិរបស់រាជត្រកូលទាំងនោះ ដល់ព្រះបាទជយទ្ទិស គ្រប់ប្រការដោយពិស្តារ ព្រះបាទជយទ្ទិសទ្រង់អារាធនាថា បពិត្រព្រះជេដ្ឋាធិរាជ សូមទ្រង់យាងមកសោយរាជសម្បត្តិចុះ តាបសថ្វាយព្រះពរឃាត់ថា កុំឡើយមហារាជ ព្រះបាទជយទ្ទិសនិមន្តថា បើដូច្នោះ សូមព្រះជេដ្ឋាធិរាជនិមន្តទៅកាន់ព្រះរាជឧទ្យានចុះ ខ្ញុំនឹងបម្រើដោយបច្ច័យ ៤ តាបសថ្វាយព្រះពរថា អាត្មាមិនទាន់ទៅទេ ។ ព្រះបាទជយទ្ទិសត្រាស់ឲ្យជីកអូរមួយជំតាមបណ្តោយភ្នំមួយ មិនឆ្ងាយអំពីអាស្រមបទរបស់តាបស រួចឲ្យបង្ហូរទឹកធ្វើស្រែចម្ការ ឲ្យមហាជន ១០០០ ត្រកូលតាំងទីលំនៅជាក្រុមគ្រួសារក្លាយជាតំបន់មួយ ហើយបានតម្កល់កិក្ខាដល់តាបសទាំងឡាយ ស្រុកនោះប្រាកដឈ្មោះថា ចូឡកម្មាសទម្មនិគម ឯបទេសដែលមហាសត្វ សុតសោមបណ្ឌិតទូន្មានយក្ខបោរិសាទគប្បីជ្រាបថា ឈ្មោះមហាកម្មាសទម្មនិគម ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ព្រះថេរៈអ្នកចិញ្ចឹមមាតាតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះរាជមាតាបិតាក្នុង

កាលនោះបានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ តាបសក្នុងកាលនោះបានមកជាសារីបុត្ត យក្ខក្នុងកាលនោះបានមកជាអង្គុលិមាល ព្រះកនិដ្ឋកត្តិនីក្នុងកាលនោះបានមកជាឧប្បលវណ្ណាថេរី អគ្គមហេសីក្នុងកាលនោះ បានមកជារាហុលមាតា ឯអលីនសត្តុរាជកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ជយទ្ទិសជាតក ចប់

# ឆទ្ទន្តជាតក

[ ៤៥៦ ] ( ព្រះបាទពារាណសីត្រាស់សួរថា ) ម្នាលនាងសុភទ្ទា ជាស្រីមានអវយវៈដូចមាស មានសម្បុរលឿងខ្ចី មានសម្បុរដ៏ប្រសើរ ថ្វីក៏បានជានាងសោយសោក ម្នាលនាងមានភ្នែកពិសាលថ្វីក៏បានជានាងស្រពោនដូចផ្កាឈូកដែលគេច្របាច់ ។

[ ៤៥៧ ] ( នាងសុភទ្ទាទេវីទូលថា ) បពិត្រមហារាជ ចំណង់ប្លែកកើតឡើងដល់ខ្ញុំម្ចាស់ ដោយការយល់សប្តិ តែចំណង់ប្លែករបស់ខ្ញុំម្ចាស់នោះហាក់ដូចជាមិនងាយរកបានទេ ។

[ ៤៥៨ ] ( ព្រះរាជា... ) កាមគុណទាំងឡាយណាមួយជារបស់មនុស្សក្នុងលោកជាទីត្រេកអរនេះ កាមគុណទាំងអស់នោះមានច្រើនសុទ្ធតែជារបស់យើង យើងនឹងឲ្យនូវចំណង់ប្លែកដល់នាង ។

[ ៤៥៩ ] ( នាងសុភទ្ទាទេវី... ) បពិត្រព្រះសម្មតិទេព សូមឲ្យព្រានទាំងឡាយដែលមាននៅក្នុងដែនរបស់ព្រះអង្គមកប្រជុំគ្នា ខ្ញុំម្ចាស់នឹងប្រាប់នូវចំណង់ប្លែករបស់ខ្ញុំម្ចាស់ ដល់ព្រានទាំងឡាយនុ៎ះ ។

[ ៤៦០ ] ( ព្រះរាជា... ) ម្នាលនាងទេវី ពួកព្រានព្រៃទាំងនេះជាអ្នកមានថ្វីដៃ ជាអ្នកក្លៀវក្លា ស្គាល់ព្រៃផង ស្គាល់ម្រឹគផង សឹងតែជាអ្នកស៊ូលះបង់នូវជីវិតក្នុងប្រយោជន៍របស់យើង ។

[ ៤៦១ ] ( នាងសុភទ្ទាទេវី... ) ម្នាលលុទ្ទបុត្តទាំងឡាយ អ្នកទាំងឡាយ ទាំងប៉ុន្មាននាក់ដែលមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់ ( ពាក្យរបស់ខ្ញុំចុះ )

ខ្ញុំបានយល់សប្តិឃើញដំរីស មានភ្លុកប្រាំមួយ ខ្ញុំត្រូវការដោយភ្លុកដំរីសនោះ ជីវិត ( របស់ខ្ញុំ ) នឹងមិនមានព្រោះការមិនបានភ្លុកនោះ ។

[ ៤៦២ ] ( ពួកលុទ្ទបុត្ត... ) បិតានិងជីតារបស់ទូលព្រះបង្គំជាខ្ញុំ មិនដែលឃើញ មិនដែលឮនូវដំរីមានភ្លុកប្រាំមួយ ដែលព្រះរាជបុត្រីបានទ្រង់ព្រះសុបិនឃើញនោះទេ សូមព្រះនាងទ្រង់សវនីយ៍ប្រាប់នូវដំរីដ៏ប្រសើរ ប្រាកដដូច្នោះដល់ពួកទូលព្រះបង្គំជាខ្ញុំចុះ ។

[ ៤៦៣ ] បណ្តាទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ តើព្រះរាជបុត្រី ទ្រង់ព្រះសុបិនឃើញដំរីដ៏ប្រសើរ មានភ្លុកប្រាំមួយឋិតនៅក្នុងទិសណា ។

[ ៤៦៤ ] ( ព្រះនាងសុភទ្ទាទេវី... ) អ្នកចេញអំពីទីនេះ ដើរត្រង់ទៅទិសខាងជើង រំលងភ្នំធំទាំង ៧ ទៅ នឹងឃើញភ្នំធំលើសលុបមួយ ឈ្មោះសុវណ្ណបស្ស: ជាភ្នំមានផ្កាឈើរីកព្រោងព្រាត កុះករដោយពួកកិន្នរ ។ អ្នកចូរឡើងកាន់ភ្នំជាលំនៅរបស់ពួកកិន្នរនោះ ហើយរមិលមើលនូវទីជិតនៃជើងភ្នំ គ្រានោះអ្នកនឹងឃើញនូវស្តេចជ្រៃមួយដើម មានឫស ៨០០០ មានពណ៌ប្រាកដស្មើដោយមេឃ ។ ឯស្តេចដំរីមានភ្លុកប្រាំមួយ មានខ្លួនសសុទ្ធដែលពួកដំរីដទៃគ្របសង្កត់បានដោយក្រ តែងនៅជិតដើមជ្រៃនោះ ដំរីទាំងឡាយ ៨០០០ មានភ្លុកដូចចន្ទោលរទេះ មានប្រក្រតីទៅប្រហារដោយសន្ទុះដូចជាខ្យល់តែងរក្សានូវស្តេចដំរីនោះ ។ ពួកដំរីទាំង ៨០០០ នោះ ឈរដកដង្ហើមខ្លាំងតែងក្រោធចំពោះវត្ថុសូម្បីដែលខ្យល់បក់ត្រូវហើយ មួយទៀតបើវាឃើញ

មនុស្សក្នុងទីនោះហើយ ក៏ធ្វើឲ្យទៅជាផេះ សូម្បីតែធូលី គឺផេះរបស់មនុស្ស នោះក៏មិនឲ្យមានឡើយ ។

[ ៤៦៥ ] ( សោណុត្តរព្រានព្រៃ... ) បពិត្រព្រះនាងទេវី គ្រឿងប្រដាប់ទាំងឡាយដ៏ច្រើន ដែលគេធ្វើដោយមាសក្តី កែវមុក្តាក្តី កែវមណីក្តី គ្រឿងប្រដាប់ ជាវិការៈនៃកែវពៃទូរ្យក្តី សឹងមានក្នុងរាជត្រកូល ចុះព្រះនាងមានប្រាថ្នានឹងសម្លាប់ដំរីមានភ្លុកប្រាំមួយយកមកធ្វើគ្រឿងប្រដាប់ ជាវិការៈនៃភ្លុកឬ ឬក៏ព្រះនាងចង់សម្លាប់ពួកលុទ្ទបុត្ត ( កូនព្រាន ) ។

[ ៤៦៦ ] ( ព្រះនាងសុភទ្ទាទេវី... ) ម្នាលព្រានព្រៃ ( មិនមែនដូច្នោះទេ ) យើងជាស្រីប្រណែនផង ជាស្រីដល់នូវសេចក្តីទុក្ខផង យើងរឭកឃើញ ( នូវពៀរ ) ក្នុងខាងដើម ( ដែលដំរីនោះធ្វើហើយដល់យើង ) ផង បានជាចេះតែស្គាំងស្គម ម្នាលព្រានព្រៃ អ្នកចូរធ្វើសេចក្តីនេះដល់យើងចុះ យើងនឹងឲ្យស្រុកសួយ ៥ ដល់អ្នក ។

[ ៤៦៧ ] ( សោណុត្តរព្រានព្រៃ... ) ដំរីឆទ្ទន្តនោះ តែងនៅត្រង់ទីណា តែងចូលទៅឈរក្នុងកន្លែងណា ផ្លូវដូចម្តេចដែលដំរីឆទ្ទន្តចុះទៅងូតទឹក ស្តេចដំរីឆទ្ទន្តនោះងូតទឹកតើដូចម្តេច យើងខ្ញុំធ្វើម្តេច នឹងដឹងដំណើរនៃដំរីនោះបាន ។

[ ៤៦៨ ] ( ព្រះនាងសុភទ្ទាទេវី... ) ត្រង់ទីកន្លែងដែលដំរីនៅនោះមានស្រះបោក្ខរណីនោះនៅជិត ជាស្រះគួររីករាយផង មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង ( មានកុមុទ ឧត្បលនិងឈូក ) មានផ្ការីកស្គុសស្គាយផង

ដេរដាសដោយពួកកមរជាតិផង ស្តេចដំរីដ៏ប្រសើរនោះតែងងូតទឹក ក្នុងស្រះនុ៎ះឯង ។ ដំរីឆទ្ទន្តនោះជាដំរីសសុទ្ធ មានស្បែកនិងអវយវៈស ដូចផ្កាឈូកស លាងជម្រះនូវក្បាលរួចហើយ ក៏ទ្រទ្រង់នូវផ្កាឧប្បលជាដើម ត្រេកអររីករាយពន់ពេក ក៏ឲ្យមេដំរីជាមហេសី ឈ្មោះ នាងសព្វសុភទ្ទា ដើរពីខាងមុខ ហើយដើរសំដៅទៅកាន់ទីកន្លែងនៅរបស់ខ្លួន ។

[ ៤៦៩ ] ( អភិសម្ពុទ្ធគាថា ) ព្រានព្រៃនោះបានរៀនពាក្យ ក្នុងទីនោះ ហើយក៏ចាប់យកនូវបំពង់ព្រួញនិងធ្នូ ( ដើររំលង ) ភ្នំធំទាំង ៧ ក៏ពិចារណាមើលទៅ ( ឃើញ ) ភ្នំធំខ្ពស់មួយ ឈ្មោះសុវណ្ណបស្ស: ។ ព្រានព្រៃបានឡើងទៅកាន់ភ្នំ ជាកន្លែងនៅនៃពួកកិន្នរ ក៏រមិលមើលនូវទីជិតនៃជើងភ្នំ បានឃើញស្តេចជ្រៃធំមួយដើម មានសម្បុរប្រាកដស្មើដោយមេឃ មានឫស ៨០០០ ជិតជើងភ្នំនោះ ។ បានឃើញដំរីមានភ្លុក ៦ ជាដំរីសសុទ្ធ ដែលពួកដំរីដទៃគ្របសង្កត់បានដោយក្រ នៅក្រោមដើមជ្រៃនោះ ពួកដំរីទាំង ៨០០០ មានភ្លុកងដូចជាចន្ទោលរថ មានប្រក្រតីទៅប្រហារពួកដំរីជាបច្ចាមិត្តដោយសន្ទុះដ៏លឿនដូចជាខ្យល់ តែងរក្សានូវស្តេចដំរីនោះ ។

បានឃើញស្រះបោក្ខរណីនៅជិតដើមជ្រៃនោះ ជាទីគួររីករាយ មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង ( មានផ្កាកុមុទ ឧត្បលនិងឈូក ) រីកស្គុសស្គាយផង ដេរដាសដោយពួកកមរជាតិផង ជាទីសម្រាប់ងូតរបស់ស្តេចដំរីដ៏ប្រសើរនោះ ។ បានឃើញនូវការដើរទៅនិងការឈរនៅនៃដំរីដ៏ប្រសើរផង ឃើញផ្លូវរបស់ដំរីដ៏ប្រសើរនោះ ទៅងូតទឹកផង ព្រានព្រៃជាអនរិយជន

បានប្រកប ( កិច្ចការស្រេច ) ដោយការលុះក្នុងអំណាចនៃចិត្ត ក៏បានជីករណ្តៅ ។

[ ៤៧០ ] ( អភិសម្ពុទ្ធគាថា ) ព្រានព្រៃជាអ្នកធ្វើអំពើអាក្រក់ ជីករណ្តៅហើយគ្របដោយផែនក្តារទាំងឡាយ រួចបញ្ចូលខ្លួនទនិងធ្នូ ( ទៅក្នុងរណ្តៅនោះ ) ហើយបាញ់នូវដំរីដែលដើរមកក្បែរខាង ( រណ្តៅរបស់ខ្លួន ) ដោយព្រួញដ៏ថ្លោស ។ ដំរីដ៏ប្រសើរត្រូវព្រានព្រៃបាញ់ហើយក៏បន្លឺនូវកោញ្ចនាទដ៏ពន្លឹក ពួកដំរីទាំងអស់ក៏បន្លឺនូវសំឡេងមានសភាពដ៏ពន្លឹក ដំរីទាំងនោះក៏ធ្វើនូវស្មៅនិងមែកឈើឲ្យខ្ទេចខ្ទី ហើយស្ទុះស្ទារទៅទាំង ៨ ទិសជុំវិញ ។ ដំរីដ៏ប្រសើរក៏ចាប់ព្រាននោះ ដោយបំណងថា អញនឹងសម្លាប់ព្រានព្រៃនុ៎ះ ក៏ឃើញនូវសំពត់កាសាវៈ ដែលជាទង់ជ័យរបស់ពួកឥសី ដំរីដ៏ប្រសើរត្រូវសេចក្តីទុក្ខប៉ះពាល់ហើយ ក៏មានសញ្ញាកើតឡើងថា ធម្មតាបុគ្គលប្រើប្រាស់ទង់ជ័យព្រះអរហន្ត មានសភាពដែលសប្បុរសមិនគួរសម្លាប់ ។

[ ៤៧១ ] ( ដំរីឆទ្ទន្ត... ) បុគ្គលណា មិនទាន់អស់ទឹកចត់ គឺកិលេស ជាអ្នកប្រាសចាកការទូន្មាននូវឥន្ទ្រិយនិងវចីសច្ចៈ និងស្លៀកដណ្តប់សំពត់កាសាវៈ បុគ្គលនោះមិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈទេ ។ ចំណែកបុគ្គលណា ខ្ជាក់ចោលនូវទឹកចត់ គឺកិលេស តាំងមាំក្នុងសីលទាំងឡាយ ជាអ្នកប្រកបដោយការទូន្មាននូវឥន្ទ្រិយនិងវចីសច្ចៈ បុគ្គលនោះឯងទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈ ។

[ ៤៧២ ] ( អភិសម្ពុទ្ធគាថា ) ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយ

ដោយសរដ៏ថ្លៃស មិនមានចិត្តប្រទូស្ត បាននិយាយនឹងព្រានព្រៃថា នែសម្លាញ់ អ្នកត្រូវការអ្វី តើព្រោះហេតុអ្វីបានជាអ្នកសម្លាប់យើង ម្យ៉ាងទៀតការប្រកបនេះរបស់បុគ្គលណា ។

[ ៤៧៣ ] ( ព្រានព្រៃ... ) បពិត្រដំរីដ៏ចម្រើន ព្រះមហេសីរបស់ស្តេចក្នុងដែនកាសីនោះ ឈ្មោះនាងសុភទ្ទាដែលគេបូជាហើយក្នុងរាជត្រកូល ព្រះនាងបានឃើញអ្នកហើយប្រាប់ខ្ញុំ ព្រះនាងក៏មានព្រះសវនីយ៍នឹងខ្ញុំថា យើងត្រូវការដោយភ្លុកទាំងឡាយ ។

[ ៤៧៤ ] ( ដំរីឆទ្ទន្ត... ) ព្រះរាជបុត្រីនោះដឹងថាគូនៃភ្លុកទាំងឡាយរបស់បិតានិងជីតាទាំងឡាយ របស់យើងមានច្រើនណាស់ តែនាងជាស្រីក្រោធត្រូវការសម្លាប់ ជាស្រីល្ងង់ បានចងពៀរ ( នឹងយើង ) ។ នែព្រានព្រៃ អ្នកចូរក្រោកឡើងចាប់នូវរណារហើយអារនូវភ្លុកទាំងគូនេះចុះ ទាន់ខ្ញុំមិនទាន់ស្លាប់ អ្នកឯងគប្បីទូលព្រះរាជបុត្រីដែលមានសេចក្តីក្រោធនោះថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំបានសម្លាប់ហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ ។

[ ៤៧៥ ] ព្រានព្រៃនោះក្រោកឈរឡើងហើយចាប់រណារ អារនូវភ្លុកនៃដំរីដ៏ប្រសើរ ហើយក៏យកនូវភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី រួចដើរចៀសចេញទៅអំពីទីនោះយ៉ាងឆាប់ ។

[ ៤៧៦ ] ( អភិសម្ពុទ្ធគាថា ) ពួកដំរីត្រូវភ័យ ( អំពីសេចក្តីស្លាប់ ) បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខព្រួយ ព្រោះគេសម្លាប់នូវដំរីដ៏ប្រសើរ

បានស្ទុះទៅគ្រប់ទិសទាំង ៨ លុះមិនឃើញបុរសជាសត្រូវនឹងដីរីក៏ត្រឡប់មក កាន់ទីរបស់ស្តេចដំរីដ៏ប្រសើរវិញ ។

[ ៤៧៧ ] ដំរីដ៏ប្រសើរទាំងនោះកន្ទក់កន្ទេញ រោទ៍ក្នុងទីនោះហើយរោយ រាយនូវអាចម៍ដីលើក្បាលរបស់ខ្លួន ដំរីទាំងអស់នោះ ក៏ឲ្យមេដំរីជាមហេសី ឈ្មោះសព្វសុភទ្ទាដើរមុខ មកកាន់ទីនៅរបស់ខ្លួន ។

[ ៤៧៨ ] ព្រានព្រៃនោះ បាននាំយកភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ភ្លឺសព្វដោយរស្មីមានពណ៌ដូចជាមាស ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះក៏បង្អោននូវភ្លុកទាំងឡាយ ថ្វាយព្រះរាជកញ្ញាថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំសម្លាប់បានហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ ។

[ ៤៧៩ ] ព្រះរាជកញ្ញានោះទតឃើញភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរដែលធ្លាប់ជាប្តីជាទីស្រឡាញ់អំពីជាតិមុន ក៏បែកហឫទ័យក្នុងទីនោះឯង ហេតុនោះព្រះនាងជាស្រីល្ងង់ បានសោយព្រះទិវង្គត់ទៅ ។

[ ៤៨០ ] ( ព្រះធម្មសង្គាហកត្ថេរ... ) ព្រះពុទ្ធព្រះអង្គបានសម្រេចនូវសម្ពោធិញ្ញាណផង មានអានុភាពច្រើនផង បានធ្វើនូវការញញឹមក្នុងកណ្តាលពពួកបរិស័ទ ពួកភិក្ខុមានចិត្តរួចស្រឡះ ក៏ក្រាបបង្គំទូលសួរថា ព្រះពុទ្ធទាំងឡាយមិនដែលធ្វើនូវការញញឹមឲ្យប្រាកដដោយឥតហេតុទេ ។ អ្នកទាំងឡាយបានឃើញនាងកុមារីណានៅជំទង់ ស្លៀកសំពត់កាសាវៈ ជាអ្នកបួស នាងកុមារីនោះ ក្នុងកាលនោះគឺព្រះរាជកញ្ញា ឯស្តេចដំរីក្នុងកាលនោះ គឺតថាគត

ឯង ព្រានព្រៃណាកាន់យកនូវក្អួកទាំងឡាយនៃដំរីដ៏ប្រសើរ ជាក្អួកដ៏ល្អស្អាត មិនមានក្អួកឯទៀតប្រៀបផ្ទឹមបានលើផែនដីហើយចូលទៅកាន់កាសីបុរី ព្រាន ព្រៃនោះក្នុងកាលនោះ គឺទេវទត្ត ។ ព្រះពុទ្ធព្រះអង្គប្រាសចាកសេចក្តីក្រវល់ក្រវាយ ប្រាសចាកសេចក្តីសោក ប្រាសចាកនូវកូនសរ គឺរាគៈ បានជ្រាបច្បាស់ដោយព្រះអង្គឯង ហើយទ្រង់សំដែងនូវចរិតខ្ពស់ និងទាបអំពីដើមនេះ ដែលអន្ទោលទៅអស់កាលដ៏យូរហាក់ដូចមិនកន្លងថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះតថាគតនៅក្នុងទីនោះ កាលនោះតថាគតជាស្តេចដំរី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

## ចប់ ឆទ្ទន្តជាតក ទី ៤ ។

## អដ្ឋកថា

## ចន្ទជាតក

[ ៤៥៦-៤៨០ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពនទ្រង់ប្រារព្ធភិក្ខុនីក្រមុំមួយរូប ទើបត្រាស់ព្រះធម្មទេសនេះ មានពាក្យផ្ដើមថា **កិន្នុ សោចសិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនីនោះជាធីតានៃត្រកូលមួយ ក្នុងនគរសាវត្ថី ឃើញទោសក្នុងឃរាវាសហើយចេញបួសក្នុងព្រះសាសនា ។ ថ្ងៃមួយទៅដើម្បីស្ដាប់ធម៌មួយអន្លើដោយពួកភិក្ខុនី ឃើញព្រះរូបឆោមដែលកើតឡើងដោយបុញ្ញានុភាពមិនមានប្រមាណ ប្រកបដោយរូបសម្បត្តិដ៏ឧត្តម របស់ព្រះទសពលដែលប្រថាប់លើធម្មាសនៈដ៏ឧត្តម ទ្រង់សម្ដែងព្រះធម្មទេសនា ទើបគិតថា កាលអញអន្ទោលទៅក្នុងភព ធ្លាប់ជាបាទបរិចារិកា របស់មហាបុរសនេះដែរឬទេហ្ន៎ ក្នុងវេលានោះឯងនាងក៏រឭកជាតិបានថា អញធ្លាប់ជាបាទបរិចារិការបស់មហាបុរសនេះ ក្នុងកាលទ្រង់ជាដំរីឆទ្ទន្ត កាលនាងរឭកបានដូច្នោះ ក៏កើតបីតិបាមោជ្ជក្រៃលែងឡើង ។ ដោយកម្លាំងនៃបីតិទើបនាងសើចខ្លាំងៗហើយរឭកទៀតថា ឈ្មោះថាបាទបរិចារិកាដែលមានអធ្យាស្រ័យ ប្រាថ្នាប្រយោជន៍ចំពោះស្វាមីមានតិច មិនបានប្រាថ្នាប្រយោជន៍មានច្រើន អញមានអធ្យាស្រ័យប្រាថ្នាប្រយោជន៍ចំពោះបុរសនេះដែរឬហ្ន៎ នាងរឭកបណ្ដើរ ក៏បានឃើញពិតថា អញបានសាងកំហុសទុកក្នុងហទយៈមិនមែនតិច ជួលព្រានសោណុត្តរឲ្យយកព្រួញលាបដោយថ្នាំពិស បាញ់ស្ដេចដំរីឆទ្ទន្ត កម្ពស់ប្រមាណ ១២០ហត្ថឲ្យដល់នូវការស្លាប់ ។ វេលានោះក៏មានសេចក្ដីសោកកើតឡើង បេះដូង

ក៏ចេញចំហាយក្តៅ មិនអាចអត់សង្កត់សេចក្តីសោកបានទើបទ្រហោយំដោយសំឡេងខ្លាំង ។ ព្រះបរមសាស្តាទតឃើញដូច្នោះ ក៏ទ្រង់ញញឹម ភិក្ខុសង្ឃទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ ជាបច្ច័យនៃការធ្វើនូវការញញឹមឲ្យប្រាកដ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីក្មេងនេះ រឭកដល់កំហុសដែលធ្លាប់ធ្វើចំពោះតថាគតក្នុងជាតិមុន ក៏ទ្រហោយំ ហើយទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាល មានដំរីប្រមាណ ៨០០០ ជាដំរីមានឫទ្ធិ ហោះទៅក្នុងអាកាសបាន អាស្រ័យស្រះឆទ្ទន្តរស់នៅក្នុងព្រៃហិមពាន្ត ។ កាលនោះព្រះពោធិសត្វ កើតជាកូនដំរីមេហ្វូង មានពណ៌កាយសម្បុរស មានមាត់និងជើងពណ៌ក្រហម កាលចម្រើនវ័យឡើង កម្ពស់បាន ៨៨ ហត្ថ បណ្តោយខ្លួន ១២០ ហត្ថ ប្រកបដោយប្រមោយដូចគ្នានឹងកម្រងប្រាក់ ប្រវែង ៥៨ ហត្ថ ឯភ្លុកទាំង ២ វាស់ដោយជុំវិញ ១៥ ហត្ថ បណ្តោយប្រវែង ៣០ ហត្ថ ប្រកបដោយរស្មី ៦ ប្រការ ។ ព្រះពោធិសត្វជាមេហ្វូងនៃដំរី ៨០០០ បូជាព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ អគ្គមហេសីរបស់ព្រះពោធិសត្វមាន ២ ឈ្មោះចូឡសុភទ្ទា ១ មហាសុភទ្ទា ១ ។ ស្តេចដំរីនោះមានដំរី ៨០០០ ជាបរិវារនៅក្នុងកញ្ចនគុហា ។ ម្យ៉ាងទៀតស្រះឆទ្ទន្តនោះ បណ្តោយក្តី ទទឹងក្តី ៥០ យោជន៍[១] ត្រង់កណ្តាលមានជម្រៅ ១២ យោជន៍ មិនមានសារាយ ចក ឬកក់ឡើយ ទឹកដែលដក់នៅមានពណ៌ដូចដុំកែវមណី បន្ទាប់អំពីនោះមានគុម្ព

១-ក្នុងទីខ្លះជា ៥២ យោជន៍ ។

ចន្ទលណីដុះជុំវិញមានកម្រាស់មួយយោជន៍ បន្ទាប់អំពីគុម្ពចន្ទលណីនោះមាន ឧប្បលខៀវដុះជុំវិញកម្រាស់មួយយោជន៍ បន្ទាប់អំពីនោះ មានគុម្ពឧប្បល ក្រហម ឧប្បលស បទុមក្រហម បទុមសនិងកោមុទ សុទ្ធតែកម្រាស់មួយ យោជនៗព័ទ្ធជុំវិញ ។ ម្យ៉ាងទៀតក្នុងរវាងគុម្ពឈូកទាំង ៧ នេះ មានឈូក មួយប្រភេទ ឈ្មោះថា ចន្ទលណី ដុះឆ្វាស់គ្នាដោយជុំវិញ មានបរិមណ្ឌល ទទឹងមួយយោជន៍ដូចគ្នា ។ បន្ទាប់មក ដល់ទឹកជ្រៅត្រឹមពោះដំរី មានស្រូវ សាលីក្រហមដុះលាតសន្ធឹងទៅប្រមាណមួយយោជន៍ មានគុម្ពវល្លិទឹកដេរដាស ដោយផ្កាពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស មានក្លិនក្រអូប ផ្សាយទៅ ។ ព្រៃឈើ ១០ ប្រភេទនេះ មានកម្រាស់មួយយោជន៍ស្មើគ្នា ដោយប្រការដូច្នេះ ។ បន្តពីនោះទៅ មានព្រៃសណ្តែកពជមាសគ្រាប់តូចនិង ព្រៃសណ្តែកពជមាសគ្រាប់ធំ ។ បន្ទាប់អំពីនោះទៅមានព្រៃឪឡឹក ត្រឡាច ឃ្លោកនិងល្ពៅ ។ តពីនោះមានព្រៃអំពៅ ដើមនីមួយៗប៉ុនដើមស្លា ។ បន្ទាប់ អំពីនោះមានដើមចេក ផ្លែប៉ុនៗភ្លុកដំរី បន្ទាប់អំពីនោះមានព្រៃពាំង ព្រៃខ្នុរ ណាំង ខ្នុរមួយផ្លែៗប៉ុនៗពាង ។ បន្ទាប់ពីនោះមានព្រៃខ្នុរសម្ល ផ្លែមានរស ឆ្ងាញ់ បន្ទាប់អំពីនោះមានព្រៃខ្វិត បន្ទាប់អំពីនោះមានជងព្រៃធំ មានពូជឈើ ដែលដុះលាយឡំគ្នា ។ បន្ទាប់ពីនោះទៅមានព្រៃឫស្សី នេះជាភាពសម្បូរនៃ ស្រះធទន្ត ក្នុងសម័យនោះ ក្នុងអដ្ឋកថាសំយុត្តនិកាយ លោកក៏ពណ៌នាភាព សម្បូរដែលមានក្នុងបច្ចុប្បន្ននេះទុកដូចគ្នា ។

ម្យ៉ាងទៀត មានភ្នំព័ទ្ធជុំវិញព្រៃឫស្សី ៧ ជាន់ រាប់ពីជុំខាងក្រៅទៅ ភ្នំទី

១ ឈ្មោះចូឡកាឡបព៌ត ភ្នំទី ២ ឈ្មោះមហាកាឡបព៌ត ភ្នំទី ៣ ឈ្មោះឧទកបព៌ត ភ្នំទី ៤ ឈ្មោះចន្ទបស្សបព៌ត ភ្នំទី ៥ ឈ្មោះសុរិយបស្សបព៌ត ភ្នំទី ៦ ឈ្មោះមណិបស្សបព៌ត ភ្នំទី ៧ ឈ្មោះសុវណ្ណបស្សបព៌ត ។

សុវណ្ណបស្សបព៌តកម្ពស់ ៧ យោជន៍ ព័ទ្ធជុំវិញស្រះឆទ្ទន្ត ដូចកណ្ដាប់មាត់បាត្រ ខាងក្នុងសុវណ្ណបស្សបព៌តនោះមានពណ៌ដូចមាស ។ ព្រោះស្រមោល ដែលចេញអំពីសុវណ្ណបស្សបព៌តនោះ ស្រះឆទ្ទន្តនោះហាក់បីដូចពន្លឺព្រះអាទិត្យដ៏ស្រទន់ដែលរៀបនឹងរះ ។ ម្យ៉ាងទៀត ភ្នំដែលតាំងនៅខាងក្រៅ ( រាប់ពីក្នុងមកក្រៅ ) ភ្នំមួយកម្ពស់ ៦ យោជន៍ ភ្នំមួយកម្ពស់ ៥ យោជន៍ ភ្នំមួយកម្ពស់ ៤ យោជន៍ ភ្នំមួយកម្ពស់ ៣ យោជន៍ ភ្នំមួយកម្ពស់ ២ យោជន៍ ភ្នំមួយកម្ពស់ ១ យោជន៍ ។ ត្រង់ជ្រុងទិសឦសាននៃស្រះឆទ្ទន្ត ដែលមានភ្នំ ៧ ជាន់ ព័ទ្ធជុំវិញយ៉ាងនេះ មានដើមជ្រៃធំ តាំងនៅក្នុងឱកាសដែលទឹកនិងខ្យល់ពាល់ត្រូវបាន ដើមជ្រៃនោះវាស់ដោយជុំវិញបាន ៥ យោជន៍ កម្ពស់ ៧ យោជន៍ វិកាយមែក ៦ យោជន៍ មែកផ្សាយទៅក្នុងទិសទាំង ៤ មែកដែលត្រង់ឡើងទៅលើក៏មានប្រវែង ៦ យោជន៍ដូចគ្នា វាស់ពីគល់ដល់ចុង គឺមានប្រវែង ១៣ យោជន៍ វាស់ដោយបរិមណ្ឌលមែក ១២ យោជន៍ ប្រដាប់ដោយឫស ៨ ពាន់ស្រស់ត្រកាលដូចភ្នំកែវមណីត្រងោល ។

ម្យ៉ាងទៀតក្នុងទិសបច្ចិមនៃស្រះឆទ្ទន្ត ត្រង់សុវណ្ណបស្សបព៌តមានកញ្ចនគុហាប្រមាណ ១២ យោជន៍ ។ ដល់រដូវភ្លៀងស្ដេចដំរីឆទ្ទន្តមានដំរី ៨០០០ ជាបរិវារស្នាក់នៅក្នុងកញ្ចនគុហា ក្នុងរដូវក្ដៅ ក៏មកឈរទទួលខ្យល់និងទឹក

ត្រង់ចន្លោះព្រៃជ្រៃនាដើមជ្រៃធំនេះ ។ ថ្ងៃមួយដំរីទាំងឡាយមកប្រាប់ថា ព្រៃរាំងផ្ការីកហើយ ។ ស្តេចឆទ្ទន្តគិតថា អញនឹងលេងកីឡាផ្ការាំង មួយអន្លើដោយបរិវារទៅកាន់ព្រៃរាំងនោះ យកក្បាលជល់ដើមរាំងមួយដើមដែលមានផ្ការីកស្គុសស្គាយ ។ នាងចូឡសុភទ្ទាឈរខាងលើខ្យល់ ស្លឹករាំងចាស់ៗដែលជាប់នឹងមែកងាប់ៗ អង្ក្រងនិងស្រមោចខ្មៅ ក៏ធ្លាក់មកលើសរីរៈរបស់នាង ។ នាងមហាសុភទ្ទាឈរខាងក្រោមខ្យល់ កេសរផ្កានិងស្លឹកស្រស់ៗ ក៏រោយចុះមកត្រង់សរីរៈរបស់នាង ។ ចូឡសុភទ្ទាគិតថា ស្តេចដំរីនេះបាចកេសរនិងស្លឹកស្រស់ ឲ្យធ្លាក់លើសរីរៈភរិយា ដែលខ្លួនស្រឡាញ់ប្រោសប្រាណ ឯសរីរៈរបស់អញ ឲ្យស្លឹកឈើងាប់ជាប់និងមែកក្រៀមៗ មួយអន្លើដោយអង្ក្រងនិងស្រមោចធ្លាក់មកលើ អញនឹងដឹងវត្ថុដែលគួរធ្វើ ហើយចងពៀរក្នុងព្រះពោធិសត្វ ។

ថ្ងៃមួយស្តេចដំរីមួយអន្លើដោយបរិវារ ចុះកាន់ស្រះឆទ្ទន្តដើម្បីងូតទឹក ខណៈនោះដំរីស្ទាវ ២ យកប្រមោយកាន់នូវបាច់ឫសជ្រៃតូចៗមកឲ្យស្តេចដំរីជម្រះរាងកាយដូចគ្នានឹងបោសកំពូលភ្នំកៃលាសដូច្នោះ ។ កាលស្តេចដំរីងូតទឹកឡើងមកហើយទើបឲ្យមេដំរីទាំង ២ ចុះងូត កាលដំរីទាំង ២ ឡើងមកហើយនាំគ្នាទៅឈរអមព្រះមហាសត្វ ។ បន្ទាប់អំពីនោះ ដំរីទាំង ៨០០០ ក៏ចុះកាន់ស្រះ លេងឧទកកីឡា ហើយនាំយកផ្កាច្រើនប្រភេទ មកអំពីស្រះប្រដាប់តាក់តែងព្រះមហាសត្វដូចគ្នានឹងប្រដាប់ស្តូបប្រាក់ដូច្នោះ ស្រេចហើយទើបប្រដាប់មេដំរីជាខាងក្រោយ ។ គ្រានោះមានដំរីមួយត្រាច់ទៅក្នុងស្រះបាន

នូវផ្កាបទុមធំមានស្រទាប់ ៧ ជាន់នាំមកប្រគល់ដល់ព្រះមហាសត្វ ។ ស្តេចដំរីធំទទួលយកប្រមោយទទួលផ្កាឈូក មករោយកេសរចុះលើក្បាល ហើយឲ្យដល់នាងមហាសុភទ្ទាដែលជាជេដ្ឋកិរិយា ។ នាងចូឡសុភទ្ទាឃើញដូច្នោះអាក់អន់ចិត្ត គិតថា ស្តេចដំរីនេះឲ្យផ្កាឈូកធំដែលមានត្របក ៧ ជាន់ដល់កិរិយាជាទីស្រឡាញ់តែម្នាក់ ចំណែកអញមិនឲ្យ ទើបចងពៀរក្នុងព្រះមហាសត្វទៀត ។

ថ្ងៃមួយស្តេចដំរីពោធិសត្វរៀបចំផ្លែស្រគំនិងត្រាវ ជំឡូងដោយទឹកឃ្មុំថ្វាយព្រះបច្ចេកពុទ្ធ ៥០០ អង្គឆាន់ នាងចូឡសុភទ្ទាបានប្រគេនផ្លែឈើដែលខ្លួនបេះបានដល់ព្រះបច្ចេកពុទ្ធហើយតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់បើខ្ញុំចុតិចាកអត្តភាពនេះ ក្នុងជាតិនេះហើយ សូមឲ្យកើតក្នុងត្រកូលមទ្ទរាជនិងបានឈ្មោះថា សុភទ្ទារាជកញ្ញា កាលចម្រើនវ័យហើយ សូមឲ្យបានជាអគ្គមហេសីរបស់ព្រះបាទពារាណសី ជាទីស្រឡាញ់គាប់ព្រះហឫទ័យ របស់ទ្រង់ រហូតអាចធ្វើបានតាមចិត្តនិងអាចទូលព្រះរាជាឲ្យប្រើព្រានណាមួយមកបាញ់ដំរីនេះដោយព្រួញដែលលាបដោយថ្នាំពិសឲ្យស្លាប់និងឲ្យនាំយកភ្លុកទាំងគូដែលមានពណ៌ ៦ យកមក ។ តាំងពីថ្ងៃនោះមក ចូឡសុភទ្ទាហត្ថីមិនស៊ីស្មៅ មិនផឹកទឹក រាងកាយក៏ស្គាំងស្គមជាលំដាប់ មិនយូរប៉ុន្មានក៏អស់ជីវិតទៅកើតក្នុងព្រះឧទរនៃអគ្គមហេសីរបស់ព្រះរាជា ក្នុងមទ្ទរដ្ឋ គ្រាប្រសូតមកហើយព្រះជនកជននីបានថ្វាយព្រះនាមថា សុភទ្ទា កាលព្រះនាងចម្រើនវ័យហើយទើបនាំទៅថ្វាយដល់ព្រះបាទពារាណសី បានជាទីស្រឡាញ់ ជាទីប្រោស

ប្រាណរបស់ព្រះបាទពារាណសី រហូតបានជាធំជាងស្នំទាំង ១៦០០០ ហើយ នាងមានញាណជាគ្រឿងរឭកជាតិបាន ។ នាងសុភទ្ទានោះត្រិះរិះថា សេចក្ដីប្រាថ្នារបស់អញសម្រេចហើយ គ្រានេះអញនឹងឲ្យគេយកភ្លុកទាំងគូ របស់ស្ដេចដំរីនោះមក ។ តាំងអំពីនោះមកនាងក៏យកប្រេងលាបសរីរៈ ទ្រទ្រង់នូវសំពត់សៅហ្មងសម្ដែងអាការជាអ្នកមានជំងឺ ចូលកាន់បន្ទប់ដ៏មានសិរី ផ្ទំលើព្រះទែនតូច ព្រះបាទពារាណសីត្រាស់សួរថា ព្រះនាងសុភទ្ទាទៅណា ទ្រង់ជ្រាបថាប្រឈួនទើបយាងចូលទៅកាន់បន្ទប់ផ្ទំ ប្រថាប់គង់លើព្រះទែន ទ្រង់ស្ទាបខ្នងរបស់ព្រះនាងហើយត្រាស់ព្រះគាថាទីមួយថា

ម្នាលនាងសុភទ្ទាជាស្រីមានអវយវៈដូចមាស មានសម្បុរល្មើង
ខ្ចី មានសម្បុរដ៏ប្រសើរ ប្ដីក៏បានជានាងសោយសោក ម្នាល
នាងមានភ្នែកពិសាល ប្ដីក៏បានជានាងស្រពោនដូចផ្កាឈូក
ដែលគេប្របាច់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុច្ចង្គី** សេចក្ដីថា មានព្រះសរីរៈស្អាតដូចមាស ។ បទថា **មាលាវ បរិមទ្ទិតា** សេចក្ដីថា ដូចគ្នានឹងផ្កាឈូកដែលត្រូវប្របាច់ដោយដៃដូច្នោះ ។ ព្រះនាងសុភទ្ទាបានស្ដាប់ដូច្នោះទើបបានត្រាស់គាថាជាបន្ទាថា

បពិត្រមហារាជ ចំណង់ប្លែកកើតឡើងដល់ខ្ញុំម្ចាស់ ដោយការ
យល់សប្ដិ តែចំណង់ប្លែករបស់ខ្ញុំម្ចាស់នោះ ហាក់ដូចជាមិន
ងាយរកបានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆ សោ** សេចក្ដីថា ការចាញ់គភ៌ ដែលខ្ញុំម្ចាស់យល់សប្ដិឃើញនោះ ។ បទថា **សុបិនន្តេនុបច្ចគា** សេចក្ដីថា ព្រះទេវីទូលថា ខ្ញុំម្ចាស់យល់សប្ដិឃើញជានិមិត្តក្នុងទីបំផុតនៃការយល់សប្ដិទើបចាញ់ព្រះគភ៌ វត្ថុដែលចាញ់គភ៌ព្រោះយល់សប្ដិនោះ ជាវត្ថុដែលមិនងាយរកតែកាលខ្ញុំម្ចាស់បានវត្ថុនោះទើបមានជីវិតរស់នៅបាន ។

ព្រះរាជាទ្រង់ស្ដាប់ដូច្នោះទើបត្រាស់គាថាបន្តថា

កាមគុណទាំងឡាយណាមួយ ជារបស់មនុស្សក្នុងលោក ជាទីត្រេកអរនេះ កាមគុណទាំងអស់នោះមានច្រើនសុទ្ធតែជារបស់យើង យើងនឹងឲ្យនូវចំណង់ប្លែកដល់នាង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បច្ចុរា** សេចក្ដីថា ម្នាលនាងសុភទ្ទា កាមសម្បត្តិដែលជារបស់មនុស្សដែលពួកមនុស្សប្រាថ្នាក្នុងលោកនេះនិងរតនៈ ៧ យ៉ាងណាមួយក្នុងនទ្ទូវនៃ មានច្រើនរកបានងាយ គឺកាមគុណ ៥ ណាមួយមានក្នុងមនុស្សលោក យើងនឹងឲ្យវត្ថុកាមនិងកិលេសកាមទាំងអស់ ដល់នាង ។

ព្រះទេវីបានស្ដាប់ដូច្នោះ ក៏ទូលថា បពិត្រមហារាជ ការចាញ់គភ៌របស់ខ្ញុំម្ចាស់ស្រាយបានលំបាក ខ្ញុំម្ចាស់មិនទូលឲ្យទ្រង់ជ្រាបឥឡូវនេះឡើយ ក្នុងដែនរបស់ព្រះអង្គមានព្រានព្រៃចំនួនប៉ុនណា សូមទ្រង់ឲ្យប្រជុំគ្នាទាំងអស់ចុះ ខ្ញុំម្ចាស់នឹងទូលឲ្យទ្រង់ជ្រាបក្នុងកណ្ដាលព្រានព្រៃទាំងនោះ ហើយត្រាស់គាថាជាលំដាប់តទៅថា

បពិត្រព្រះសម្មតិទេព សូមឲ្យព្រានទាំងឡាយ ដែលមាននៅ
ក្នុងដែនរបស់ព្រះអង្គ មកប្រជុំគ្នា ខ្ញុំម្ចាស់នឹងប្រាប់នូវចំណង់
ប្លែករបស់ខ្ញុំម្ចាស់ដល់ព្រានទាំងឡាយនុ៎ះ ដូច្នេះ ។

ក្នុងគាថានោះមានអធិប្បាយថា បពិត្រមហារាជ ក្នុងដែនរបស់ទ្រង់មានព្រានព្រៃប៉ុន្មានដែលជាអ្នកសមគួរ សូមទ្រង់ឲ្យព្រានទាំងអស់ប្រជុំគ្នា គឺហៅគ្នាមក ខ្ញុំនឹងប្រាប់ គឺពោលបង្ហាញនូវការចាញ់ផ្ទៃរបស់ខ្ញុំម្ចាស់ដែលមានយ៉ាងណាដល់នាយព្រានទាំងនោះ ។

ព្រះបាទក្រុងពារាណសីត្រាស់ទទួលពាក្យ ហើយទ្រង់ចេញអំពីបន្ទប់ផ្ទំត្រាស់នឹងពួកអាមាត្យថា ព្រានព្រៃចំនួនប៉ុន្មាន មានក្នុងកាសិករដ្ឋដែលមានអាណាខេត្ត ៣០០ យោជន៍ ចូរអ្នកវាយស្គរប្រកាសឲ្យព្រានទាំងអស់ មកប្រជុំគ្នា ។ អាមាត្យទាំងនោះក៏ធ្វើតាមព្រះរាជឱង្ការ ។ មិនយូរប៉ុន្មានព្រានអ្នកកាសិករដ្ឋ ក៏កាន់យកគ្រឿងបណ្ណាការតាមកម្លាំង នាំគ្នាមកគាល់ ឲ្យទូលដល់ការដែលពួកខ្លួនមកដល់ឲ្យទ្រង់ជ្រាប ។ ព្រានព្រៃទាំងអស់ប្រមាណ ៦ ម៉ឺននាក់ ។ ព្រះរាជាទ្រង់ជ្រាបថា ពួកព្រានមកហើយ ទើបប្រថាប់ឈរត្រង់មាត់បង្អួច កាលចង្អុលប្រាប់ព្រះទេវីទើបត្រាស់ព្រះគាថានេះថា

ម្នាលនាងទេវី ពួកព្រានព្រៃទាំងនេះ ជាអ្នកមានថ្វីដៃ ជាអ្នក
ក្លៀវក្លា ស្គាល់ព្រៃផង ស្គាល់ម្រឹគផង សឹងតែជាអ្នកស៊ូលះ
បង់នូវជីវិតក្នុងប្រយោជន៍របស់យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥមេ តេ** សេចក្តីថា ម្នាលទេវី នាងឲ្យ

នាយព្រានពួកណាមកប្រជុំគ្នា នាយព្រានទាំងនោះ គឺនាយព្រានទាំងនេះ ។ បទថា **កតហត្ថា** សេចក្ដីថា សុទ្ធតែមានថ្វីដៃ គឺឈ្លាស បានទទួលការសិក្សារហូតជំនាញក្នុងក្បួនបាញ់និងការកាត់ជាដើម ។

បទថា **វិសារទា** សេចក្ដីថា ជាអ្នកផុតភ័យ ។ បទថា **វនញ្ញូ ច មិគញ្ញូ ច** សេចក្ដីថា ជាអ្នកស្គាល់ព្រៃផង ស្គាល់ប្រភេទសត្វផង ។ បទថា **មមត្ថេ** សេចក្ដីថា ម្យ៉ាងទៀត ពួកព្រានទាំងអស់នេះ រមែងលះបង់ជីវិតក្នុងប្រយោជន៍របស់យើងបាន គឺគេធ្វើតាមសេចក្ដីប្រាថ្នារបស់យើងបាន ។

ព្រះទេវីទ្រង់ស្ដាប់ដូច្នោះ ហៅពួកព្រានមកហើយត្រាស់គាថាបន្ដថា

ម្នាលលុទ្ទបុត្តទាំងឡាយ អ្នកទាំងឡាយ ទាំងប៉ុន្មាននាក់ដែលមកប្រជុំគ្នាក្នុងទីនេះ ចូរស្ដាប់ ( ពាក្យរបស់ខ្ញុំចុះ ) ខ្ញុំបានយល់សប្តិឃើញដំរីស មានភ្លុកប្រាំមួយ ខ្ញុំត្រូវការដោយភ្លុកដំរីសនោះ ជីវិត ( របស់ខ្ញុំ ) នឹងមិនមានព្រោះការមិនបានភ្លុកនោះ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះថា ព្រះទេវីត្រាស់ថា អ្នកទាំងឡាយដែលជាលុទ្ទបុត្ត បណ្ដាជនដែលមកព្រមគ្នាក្នុងទីនេះ ចូរតាំងចិត្តស្ដាប់ពាក្យរបស់យើង ។

បទថា **ឆព្វិសាណំ** បានដល់ ដំរីសមានភ្លុក ៦ ពណ៌ ។ យើងយល់សប្តិឃើញដំរីស ភ្លុកមានរស្មី ៦ ប្រការ យើងឃើញគជសារបែបនេះទើបមានសេចក្ដីត្រូវការភ្លុកទាំង ២ របស់ស្ដេចដំរីនោះ បើមិនបាន ជីវិតរបស់

យើងក៏មិនមាន ។ ពួកកូនព្រានព្រៃបានស្តាប់ព្រះសវនីយ៍ដូច្នោះនាំគ្នាទូលថា

បិតានិងជីតារបស់ទូលព្រះបង្គំជាខ្ញុំ មិនដែលឃើញ មិនដែល

ឮនូវដំរីមានភ្លុកប្រាំមួយដែលព្រះរាជបុត្រី បានទ្រង់ព្រះសុបិន

ឃើញនោះទេ សូមព្រះនាងទ្រង់សវនីយ៍ប្រាប់នូវដំរីដ៏ប្រសើរ

ប្រាកដដូច្នោះដល់ពួកទូលព្រះបង្គំជាខ្ញុំចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បិតូនំ** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិ-ភត្តិ ។ មានពាក្យអធិប្បាយថា ពួកព្រានក្រាបទូលថា បពិត្រព្រះនាង សេតកុញ្ជរភ្លុកមានពណ៌ ៦ ប្រការបែបនេះ ឪពុកឬជីតារបស់ពួកទូលព្រះបង្គំក៏មិនធ្លាប់ឃើញ មិនធ្លាប់បានស្តាប់ នឹងពោលថ្វីដល់ទូលព្រះបង្គំ ព្រោះហេតុនោះព្រះនាងនិមិត្តឃើញស្តេចដំរីមានលក្ខណៈបែបណា សូមព្រះនាងត្រាស់ប្រាប់លក្ខណៈដែលព្រះនាងនិមិត្តឃើញនោះដល់ពួកទូលព្រះបង្គំចុះ ។

ពួកកូនព្រានព្រៃពោលគាថាបន្តថា

បណ្តាទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាង

លើ ១ ទិសខាងក្រោម ១ តើព្រះរាជបុត្រី ទ្រង់ព្រះសុបិន

ឃើញដំរីដ៏ប្រសើរមានភ្លុកប្រាំមួយឋិតនៅក្នុងទិសណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិសា** បានដល់ ទិសទាំងឡាយ ។ បទថា **កតមំ** សេចក្តីថា បណ្តាទិសទាំងឡាយនេះ ស្តេចដំរីនៅទិសណា ។ កាលពួកព្រានទូលសួរយ៉ាងនេះហើយ ទើបព្រះនាងសុភទ្ទារាជទេវី ទ្រង់ពិនិត្យមើលព្រានទាំងអស់ ក្នុងចំនួននោះឃើញព្រានម្នាក់ឈ្មោះសោណុត្តរៈ ធ្លាប់

ជាអ្នកចងពៀររបស់ព្រះមហាសត្វ លិចផ្ដាជាងគេបណ្ដាព្រានទាំងឡាយ មានរូបអាក្រក់ពន់ពេក មានជើងធំ ស្មងមានពកដូចដុំកត្ត ក្បាលជន្គង់ធំ ធ្មឹងជំនីរធំ ពុកមាត់ស្រមូម ពុកចង្កាពណ៌ក្រហម ភ្នែកពណ៌លឿង ទើបព្រះនាងព្រះតម្រិះថា បុរសនេះអាចធ្វើតាមពាក្យរបស់អញបាន ហើយក្រាបទូលសូមព្រះរាជានុញ្ញាតនាំព្រានសោណុត្តរៈឡើងទៅកាន់ប្រាសាទជាន់ទី ៧ ព្រះនាងបើកសីហបញ្ជរទិសខាងជើង ហើយលាព្រះហស្ត ចង្អុលទៅកាន់ព្រៃហិមពាន្តទិសឧត្តរ បានត្រាស់ ៤ គាថានេះថា

អ្នកចេញអំពីទីនេះ ដើរត្រង់ទៅទិសខាងជើង រំលងភ្នំធំទាំង ៧ ទៅ នឹងឃើញភ្នំធំលើសលុបមួយ ឈ្មោះសុវណ្ណបស្សៈ ជាភ្នំមានផ្កាឈើរីកព្រោងព្រាត កុះករដោយពួកកិន្នរ ។ អ្នកចូរឡើងកាន់ភ្នំជាលំនៅរបស់ពួកកិន្នរនោះ ហើយរមិលមើលនូវទីជិតនៃជើងភ្នំ គ្រានោះអ្នកនឹងឃើញនូវស្ដេចជ្រៃមួយដើមមានឫស ៨០០០ មានពណ៌ប្រាកដស្មើដោយមេឃ ។ ឯស្ដេចដំរីមានភ្លុកប្រាំមួយ មានខ្លួនសសុទ្ធដែលពួកដំរីដទៃគ្របសង្កត់បានដោយក្រ តែងនៅជិតដើមជ្រៃនោះ ដំរីទាំងឡាយ ៨០០០ មានភ្លុកឯដូចចន្ទោលរទេះ មានប្រក្រតីទៅប្រហារដោយសន្ទុះដូចជាខ្យល់ តែងរក្សានូវស្ដេចដំរីនោះ ។ ពួកដំរីទាំង ៨០០០ នោះឈរដកដង្ហើមខ្លាំង តែងក្រោធចំពោះវត្ថុ សូម្បីដែលខ្យល់បក់ត្រូវហើយ មួយទៀត បើវាឃើញមនុស្សក្នុងទីនោះហើយ

ក៏ធ្វើឲ្យទៅជាផេះ សូម្បីតែធូលី គឺផេះរបស់មនុស្សនោះក៏មិន

ឲ្យមានឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥតោ** សេចក្ដីថា នែព្រានដ៏ចម្រើន អ្នកចេញអំពីទីនេះទៅហើយ ។ បទថា **ឧត្តរាយំ** សេចក្ដីថា ទៅកាន់ទិសឧត្តរ ដើរឆ្លងភ្នំខ្ពស់ទាំង ៧ កាលឆ្លងទៅហួសភ្នំ ៦ ជាដំបូងបានហើយ ដល់ភ្នំឈ្មោះសុវណ្ណបស្សគិរីដែលសម្រេចដោយមាស ។ បទថា **ឧច្ចោ** សេចក្ដីថា ខ្ពស់ជាងភ្នំ ៦ ក្រៅអំពីនោះ ។ បទថា **ឱលោកយ** សេចក្ដីថា ចូរអ្នកឱនចុះហើយក្រឡេកមើល ។ បទថា **តត្ថជាតិ** សេចក្ដីថា ក្នុងវដ្ដវង្កោសេតកុញ្ជរនោះ ឈរទទួលទឹកនិងខ្យល់ត្រង់គល់ជ្រៃនោះ ។

បទថា **ឧប្បសយ្ហោ** សេចក្ដីថា ជនដទៃ ឈ្មោះថាអាចចូលទៅញាំញីចាប់យកសេតកុញ្ជរនោះមិនមានឡើយ ដូច្នោះ ទើបឈ្មោះថាបុគ្គលដទៃញាំញីបានដោយក្រ ក្នុងវដ្ដវង្កោដំរីសនេះ ឈរទទួលទឹកនិងខ្យល់ត្រង់ដើមជ្រៃនោះក្នុងទីនោះ នែព្រានព្រៃ ដំរី ៨០០០ ដូចម្ដេច ។ បទថា **ឦសាទន្តា** បានដល់ មានភ្លុកដូចចន្ទោលរថ ។ បទថា **វាតជវប្បហារិនោ** សេចក្ដីថា ដំរីទាំងនោះ មានប្រក្រតីរត់ទៅប្រហារបច្ចាមិត្តដោយសម្ទុះដ៏រហ័ស ដូចខ្យល់ ដំរី ៨០០០ នេះ គាល់រក្សាស្ដេចដំរីនោះជានិច្ច ។

បទថា **តុមុលំ** សេចក្ដីថា ដំរីទាំងនោះឈរជេកដង្ហើមចេញចូល គួរខ្លាចមានសំឡេងជាប់តគ្នាជាលំដាប់ទៅ ។ បទថា **ឃោតស្ស** សេចក្ដីថា ដំរីទាំងនោះរមែងក្រោធសូម្បីតែខ្យល់មកប៉ះ ដេញតាមសំឡេង និងរារាំងសំឡេងឲ្យ

ញាប់ញ័រ ឃើញមនុស្សមកក្នុងទីនោះហើយកាចយ៉ាងនេះ ។ បទថា **ឆាស្ស** សេចក្តីថា កាលមនុស្សត្រូវខ្យល់ដង្ហើមនោះឯងកម្ចាត់ធ្វើឲ្យជាផង់ធូលីហើយ ក៏មិនព្រមឲ្យលម្អងធូលីធ្លាក់ត្រូវស្តេចដំរីនោះ ។

នាយព្រានសោណុត្តរៈ ស្តាប់ព្រះសវនីយ៍ហើយ បានតក់ស្លុតចំពោះមរណភ័យក្រាបទូលជាគាថាដូច្នេះថា

*បពិត្រព្រះនាងទេវី គ្រឿងប្រដាប់ទាំងឡាយដ៏ច្រើនដែលគេធ្វើដោយមាសក្តី កែវមុក្តាក្តី កែវមណីក្តី គ្រឿងប្រដាប់ជាវិការៈនៃកែវពៃទូរ្យក្តីសឹងមានក្នុងរាជត្រកូល ចុះព្រះនាងមានប្រាថ្នានឹងសម្លាប់ដំរីមានភ្លុកប្រាំមួយ យកមកធ្វើគ្រឿងប្រដាប់ ជាវិការៈនៃភ្លុកឬ ឬក៏ព្រះនាងចង់សម្លាប់ពួកលុទ្ទបុត្ត ( កូនព្រាន ) ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **បិលន្ធនា** បានដល់ គ្រឿងអាភរណៈទាំងឡាយ ។ បទថា **វេឡុរិយាមយា** បានដល់ គ្រឿងធ្វើអំពីកែវពៃទូរ្យ ។ បទថា **ឃាតេស្សតិ** សេចក្តីថា នាយព្រានសោណុត្តរៈទូលសួរថា ឬព្រះនាង មានបំណងនឹងឲ្យស្តេចដំរីសម្លាប់នូវពូជពង្សព្រានព្រៃចោលដោយយកគ្រឿងប្រដាប់ធ្វើជាលេស លំដាប់នោះព្រះទេវីត្រាស់ព្រះគាថាដូច្នេះថា

*ម្នាលព្រានព្រៃ ( មិនមែនដូច្នោះទេ ) យើងជាស្រីប្រណែនផង ជាស្រីដល់នូវសេចក្តីទុក្ខផង យើងរឭកឃើញ ( នូវពៀរ ) ក្នុងខាងដើម ( ដែលដំរីនោះធ្វើហើយដល់យើង ) ផង បាន*

ជាចេះតែស្គាំងស្គម ម្នាលព្រានព្រៃ អ្នកចូរធ្វើសេចក្តីនេះដល់
យើងចុះ យើងនឹងឲ្យស្រុកសួយ ៥ ដល់អ្នក ដូច្នេះ ។

បទថា **សា** បានដល់ ខ្ញុំនោះ ។ បទថា **អនុស្សរន្តី** សេចក្តីថា យើងរឭកដល់ពៀរដែលស្តេចដំរីនោះធ្វើជាមួយយើងក្នុងកាលមុន ក៏គ្រាំគ្រាចិត្ត ។ បទថា **ឧស្សាមិ តេ** សេចក្តីថា បើសេចក្តីត្រូវការរបស់យើងនេះ សម្រេច យើងនឹងឲ្យស្រុកសួយ ៥ ដែលមានតម្លៃមួយសែនកហាបណៈរាល់ឆ្នាំ ជារង្វាន់ដល់អ្នក ។

កាលព្រះទេវីត្រាស់យ៉ាងនេះហើយ ទើបលួងលោមថា នែព្រានសម្លាញ់ ក្នុងជាតិមុន ខ្ញុំបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធតាំងសេចក្តីប្រាថ្នាទុកថា សូមឲ្យខ្ញុំបានជាមនុស្សដែលអាចសម្លាប់ដំរីឆទ្ទន្តនេះ យកភ្លុកមកឲ្យបាន មិនមែនខ្ញុំយល់សប្តិឃើញឡើយ ម្យ៉ាងទៀត ការប្រាថ្នាដែលខ្ញុំប្រាថ្នាទុកនឹងត្រូវសម្រេច ចូរអ្នកទៅចុះ កុំខ្លាចឡើយ សោណុត្តរព្រានទទួលបដិបត្តិតាមព្រះរាជសវនីយ៍របស់ព្រះទេវីថា ករុណាថ្លៃវិសេស ហើយទូលថា បើដូច្នោះសូមព្រះនាងចង្អុលបង្ហាញទីលំនៅរបស់ស្តេចដំរីឲ្យជាក់ច្បាស់ កាលនឹងទូលសួរបន្តទើបពោលគាថាដោយសេចក្តីថា

ដំរីឆទ្ទន្តនោះ តែងនៅត្រង់ទីណា តែងចូលទៅឈរក្នុងកន្លែងណា ផ្លូវដូចម្តេចដែលដំរីឆទ្ទន្តចុះទៅងូតទឹក ស្តេចដំរីឆទ្ទន្តនោះងូតទឹកតើដូចម្តេច យើងខ្ញុំធ្វើម្តេចនឹងដឹងដំណើរនៃដំរីនោះបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កត្ថច្ចតិ** សេចក្ដីថា ស្ដេចដំរីនៅត្រង់ទីណា ។ បទថា **កត្ថមុបេតិ** សេចក្ដីថា ចូលទៅក្នុងទីណា អធិប្បាយថា ឈរក្នុងទីណា ។ បទថា **វិជិស្ស កា** សេចក្ដីថា ផ្លូវណាជាផ្លូវដែលស្ដេចដំរីទៅងូត គឺស្ដេចដំរីទៅងូតទឹកផ្លូវណា ។ បទថា **កថំ វិជានេមុ គតិ** សេចក្ដីថា ព្រះនាងមិនចង្អុលបង្ហាញ ទូលព្រះបង្គំទឹងដឹងទីទៅមកនៃស្ដេចដំរីនោះ បានដូចម្ដេច ព្រោះហេតុនោះ សូមព្រះនាងត្រាស់ប្រាប់ទូលព្រះបង្គំចុះ ។ កាលព្រះទេវីត្រាស់ប្រាប់ទី ដែលមើលឃើញដោយប្រចក្ស ដោយញាណរឭកជាតិបាន ដល់ព្រានសោណុត្តរៈ បានត្រាស់ ២ គាថាដោយសេចក្ដីថា

ត្រង់ទីកន្លែងដែលដំរីនៅនោះ មានស្រះបោក្ខរណីនោះនៅជិត
ជាស្រះគួររីករាយផង មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើន
ផង ( មានកុមុទឧត្បលនិងឈូក ) មានផ្ការីកស្គុសស្គាយ
ផង ដេរដាសដោយពួកកមរជាតិផង ស្ដេចដំរីដ៏ប្រសើរនោះ
តែងងូតទឹកក្នុងស្រះនុ៎ះឯង ។ ដំរីឆទ្ទន្តនោះជាដំរីសសុទ្ធ មាន
ស្បែកនិងអវយវៈសដូចផ្កាឈូកស លាងជម្រះនូវក្បាលរួច
ហើយក៏ទ្រទ្រង់នូវផ្កាឧត្បលជាដើម ត្រេកអររីករាយពន់ពេក
ក៏ឲ្យមេដំរីជាមហេសី ឈ្មោះនាងសព្វសុភទ្ទា ដើរពីខាងមុខ
ហើយដើរសំដៅទៅកាន់ទីកន្លែងនៅរបស់ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តត្ថេវ** សេចក្ដីថា ក្នុងលំនៅរបស់ស្ដេចដំរីនោះឯង ។ បទថា **បោក្ខរណី** នេះ ព្រះទេវីត្រាស់សំដៅដល់ស្រះឆទ្ទន្ត ។

បទថា **សំបុប្ផិតា** សេចក្តីថា មានផ្កាកុមុទ ២ ប្រភេទ ផ្កាឧប្បល ៣ ប្រ-ភេទ ផ្កាបទុម ៥ ប្រភេទ រីកនៅជុំវិញ ។ បទថា **ឯត្ថ ហិ សោ** សេចក្តីថា ស្តេចដំរីនោះចុះងូតទឹកក្នុងស្រះធំទូន្លនោះ ។ បទថា **ឧប្បលមាលធារី** សេចក្តីថា ទ្រទ្រង់នូវកម្រងផ្កាបុប្ផជាតិ ដែលកើតក្នុងទឹកនិងលើគោក មានឧប្បលជាដើម ។ បទថា **បុណ្ឌរិកតចង្គី** សេចក្តីថា ប្រកបដោយអវយវៈពណ៌ស មានស្បែកដូចផ្កាបុណ្ឌរិក ។

បទថា **អាមោទមានោ** សេចក្តីថា ត្រេកអរក្រៃលែង ។ បទថា **សន្និ-កេតំ** សេចក្តីថា ទៅកាន់លំនៅរបស់ខ្លួន ។ បទថា **បុរក្ខត្វា** សេចក្តីថា ព្រះទេវីត្រាស់ថា ស្តេចដំរីនាំមហេសីឈ្មោះ សព្វសុភទ្ទាទុកខាងមុខ ចោមរោមដោយដំរី ៨០០០ ជាបរិវារ ទៅកាន់លំនៅរបស់ខ្លួន ។

ព្រានសោណុត្តរៈស្តាប់ព្រះសវនីយ៍ទូលស្នងថា សាធុ ទូលព្រះបង្គំនឹងសម្លាប់ដំរីនោះនាំយកភ្លុកមកថ្វាយ កាលនោះព្រះទេវីទ្រង់ត្រេកអរ ប្រទានទ្រព្យ ១០០០ កហាបណៈ ត្រាស់ថា ចូរត្រឡប់ទៅផ្ទះសិនចុះ ៧ ថ្ងៃទៀតសឹមទៅទីនោះ កាលបញ្ជូនទៅហើយ ព្រះនាងត្រាស់ឲ្យជាងដែកមកគាល់ បញ្ជាថា នែបា យើងត្រូវការកាំបិត ពូថៅ ចប ពន្លាក ញញួរ កាំបិតកាត់គុម្ពឫស្សី កណ្តៀវប្រួតស្មៅ ដាវ ដុំលោហៈជ្រុង រណារ ស្នឹងដែកនិងដែកចំពាម ៣ ចូរបាប្រញាប់ធ្វើរបស់ទាំងអស់មកឲ្យយើង ហើយត្រាស់ឲ្យជាងស្បែកមកគាល់ បញ្ជាថា នែបា ចូរបាធ្វើសម្ពាយស្បែក សម្រាប់ដាក់សម្ភារៈទម្ងន់ប្រមាណមួយកុម្ភៈឲ្យយើង យើងត្រូវការខ្សែព្រ័ត្រធ្វើអំពីស្បែក

ស្រោមដៃ ស្រោមជើងនិងឆត្រស្បែក ចូរបាធ្វើរបស់ទាំងអស់នេះមកឲ្យ យើងដោយប្រញាប់រាប់តាំងពីនេះទៅ ជាងទាំង ២ ក៏រួតរះធ្វើរបស់ទាំងអស់ នាំមកថ្វាយដល់ព្រះទេវី ទើបព្រះនាងត្រៀមស្បៀងឲ្យព្រានសោណុត្តរៈនោះ តាំងអំពីឈើកួតភ្លើងជាដើមទៅ ដាក់នូវគ្រឿងឧបភោគបរិភោគ គ្រប់យ៉ាង និងស្បៀង មានសជូវជុំជាដើមដាក់ក្នុងថង់ស្បែក គ្រឿងឧបករណ៍និងស្បៀង ទាំងអស់នោះ ទម្ងន់ប្រមាណមួយកុម្ភៈ ឯព្រានសោណុត្តរៈនោះ ត្រៀមខ្លួន ស្រេចហើយ ដល់ថ្ងៃទី ៧ ក៏មកថ្វាយបង្គំព្រះរាជទេវី ។ លំដាប់នោះព្រះ នាងត្រាស់នឹងបុរសនោះថា គ្រឿងឧបករណ៍គ្រប់យ៉ាង របស់អ្នកសម្រេចហើយ ចូរអ្នកសាកល្បង លើកថង់ស្បែកនេះមើលសិន នាយព្រានសោណុត្តរៈនោះ ជាមនុស្សមានកម្លាំងច្រើន ទ្រទ្រង់នូវកម្លាំងប្រមាណប៉ុនដំរីសា ៥ ព្រោះហេតុ នោះទើបលើកថង់ស្បែកឡើង ដូចលើកហិបម្ជូហើយដាក់ស្ពាយលើស្មា ឈរ ធ្វើព្រងើយដូចឈរដៃទទេទើបព្រះនាងសុកទ្ធាប្រទានរង្វាន់ដល់ពួកកូនៗរបស់ ព្រាន រួចក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប បញ្ជូននាយព្រានសោណុត្តរៈទៅ ។

ឯព្រានសោណុត្តរៈនោះ កាលថ្វាយបង្គំលាព្រះរាជានិងព្រះរាជទេវីហើយ ក៏ចុះអំពីព្រះរាជនិវេសន៍ ឡើងរថចេញអំពីព្រះនគរដោយបរិវារជាច្រើន ឆ្លង គាមនិគមនិងជនបទមកតាមលំដាប់ ដល់ខាងចុងរាជអាណាចក្រ ហើយបាន ឲ្យអ្នកជនបទត្រឡប់ ធ្វើដំណើរចូលព្រៃជាមួយពួកអ្នកជាយដែន រហូតហួស ទីកដីមនុស្សទើបឲ្យអ្នកស្រុកទាំងអស់ត្រឡប់ ហើយដើរទៅតែម្នាក់ឯងអស់ ចម្ងាយ ៣០ យោជន៍ ដល់ព្រៃស្ពុក ១៨ កន្លែងដោយលំដាប់ គឺដំបូងជា

ព្រៃស្បូវក្ងាំង ព្រៃត្រែង ព្រៃស្មៅ ព្រៃឈើមានខ្លឹម ព្រៃឈើមិនមានខ្លឹម ព្រៃមិនមានសម្បក ព្រៃ ៦ កន្លែងសុទ្ធតែជាព្រៃបន្លា គឺព្រៃផ្តៅ ព្រៃដែលមានពណ៌ផ្សេងៗលាយគ្នា ព្រៃបបុស ព្រៃក្រាស់ ដែលសូម្បីតែពស់ក៏លូនទៅបានលំបាកដូចគ្នានឹងព្រៃអញ្ចាញ ព្រៃសាមញ្ញ ព្រៃឫស្សី ព្រៃដែលមានភក់ ហើយមានទឹកសុទ្ធ មានភ្នំសុទ្ធ កាលចូលទៅហើយក៏យកកណ្តៀវប្រូតស្បូវក្ងាំងជាដើម យកកាំបិតកាប់គុម្ពឫស្សីជាដើម កាប់ព្រៃអញ្ចាញជាដើម យកពូថៅកាប់ដើមឈើ ប្រើពន្លាកធំ បោះធ្វើជាផ្លូវដើរ ដល់ព្រៃឫស្សីក៏កាប់បង្អោងដាក់ឡើងទៅកាប់គុម្ពឫស្សីឲ្យធ្លាក់លើគុម្ពឫស្សីដទៃ ហើយដើរលើចុងឫស្សី លុះដល់វាលភក់ក៏ដាក់បន្ទះក្តារស្ងួត ដើរទៅតាមនោះ ហើយដកដាក់ក្នុងទីដទៃដើរបន្តទៅទៀត លើកកំណាត់ឈើក្រៅអំពីនេះឡើងដាក់បន្តទៅខាងមុខទៀតឆ្លងព្រៃភក់ទៅបាន លុះដល់ព្រៃដែលមានតែទឹក ក៏ចាំងឈើធ្វើទូកកម្រោល ដោលទៅកាន់ជើងភ្នំ យកខ្សែចងដែកចំពាម ៣ បោះទៅថ្ពក់ត្រង់ភ្នំ ហើយយោងខ្លួនឡើងទៅតាមខ្សែព្រ័ត្រ រហូតឈរលើភ្នំបាន ហើយទម្លាក់ខ្សែស្បែកចុះទៅ ទាញខ្សែព្រ័ត្រចុះមកចងត្រង់បង្គោលខាងក្រោម ហើយឡើងតាមខ្សែ យកដែកដែលមានចុងស្រួចមុតដូចពេជ្របោះភ្នំហើយបោះស្នឹងដែកស្រេចហើយ ឈរក្នុងទីនោះហើយរលាស់ដែកចំពាម ៣ បោះទៅខាងលើទៀត ឈរលើនោះហើយសម្រូតខ្សែស្បែកចុះទៅ ចងត្រង់បង្គោលខាងក្រោម ប្រវាឡើងតាមខ្សែ ដៃឆ្វេងកាន់ខ្សែ ដៃស្តាំកាន់ញញួរ ស្រាយខ្សែ ហើយដកស្នឹងដែកបន្តទៅទៀតដោយទំនងនេះ រហូតដល់លំពូលភ្នំ កាលនឹង

ចុះក៏បោះបង្គោលដែក ត្រង់កំពូលភ្នំទី ១ ដោយទំនងដើមនោះឯង យកខ្សែចង សម្ពាយស្បែក ពាក់ត្រង់បង្គោលហើយ ខ្លួនឯងអង្គុយក្នុងថង់ស្បែកសម្រូត ខ្សែចុះដូចគ្នានឹងពីងពាងដាក់អន្ទាក់ អាចារ្យពួកខ្លះពោលថា នាយព្រានសោ-ណុត្តរៈ ចុះអំពីភ្នំដោយប្រើចត្រស្បែក ដូចបក្សីត្រដាងស្លាបទម្លាក់ខ្លួនចុះមក ដូច្នោះ ។

ព្រះសាស្តា កាលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវប្រការដែលព្រានសោណុត្តរៈ ទទួលព្រះសវនីយ៍របស់ព្រះនាងសុភទ្ទា យ៉ាងនេះហើយ ចេញអំពីព្រះនគរ រំលងព្រៃស្តុក ១៧ កន្លែងរហូតដល់ភ្នំ ហើយឆ្លងភ្នំទាំង ៦ ក្នុងទីនោះបាន ហើយឡើងកាន់កំពូលភ្នំសុវណ្ណបស្សប្រពិតទើបត្រាស់គាថាទាំងនេះថា

ព្រានព្រៃនោះបានរៀនពាក្យក្នុងទីនោះហើយ ក៏ចាប់យកនូវ បំពង់ព្រួញនិងធ្នូ ( ដើររំលង ) ភ្នំធំទាំង ៧ ក៏ពិចារណា មើលទៅ ( ឃើញ ) ភ្នំធំខ្ពស់មួយ ឈ្មោះសុវណ្ណបស្សៈ ។ ព្រានព្រៃបានឡើងទៅកាន់ភ្នំ ជាកន្លែងនៅនៃពួកកិន្នរ ក៏រមិល មើលនូវទីជិតនៃជើងភ្នំ បានឃើញស្តេចជ្រៃធំមួយដើម មាន សម្បុរប្រាកដស្មើដោយមេឃ មានឫស ៨០០០ ជិតជើងភ្នំ នោះ ។ បានឃើញដំរីមានភ្លុក ៦ ជាដំរីសសុទ្ធ ដែលពួកដំរី ដទៃគ្របសង្កត់បានដោយក្រ នៅក្រោមដើមជ្រៃនោះ ពួកដំរី ទាំង ៨០០០ មានភ្លុកដូចជាចន្ទោលរថ មានប្រក្រតីទៅ ប្រហារពួកដំរីជាបច្ចាមិត្តដោយសន្ទុះដ៏លឿនដូចជាខ្យល់ តែង

រក្សានូវស្តេចដំរីនោះ ។

បានឃើញស្រះបោក្ខរណី នៅជិតដើមជ្រៃនោះ ជាទីគួររីករាយ មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង ( មានផ្កាកុមុទ ឧត្បលនិងឈូក ) រីកស្គុសស្គាយផង ដេរដាសដោយពួកកមរជាតិផង ជាទីសម្រាប់ងូត របស់ស្តេចដំរីដ៏ប្រសើរនោះ ។ បានឃើញនូវការដើរទៅនិងការឈរនៅនៃដំរីដ៏ប្រសើរផង ឃើញផ្លូវរបស់ដំរីដ៏ប្រសើរនោះទៅងូតទឹកផង ព្រានព្រៃជាអនរិយជន បានប្រកប ( កិច្ចការស្រេច ) ដោយការលុះក្នុងអំណាចនៃចិត្ត ក៏បានជីករណ្តៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រាននោះកាន់យកព្រះតម្រាស់ព្រះទេវី ដែលប្រថាប់ឈរក្នុងផ្ទៃប្រាសាទជាន់ទី ៧ នោះហើយ កាន់យកបំពង់ព្រួញនិងធ្នូធំទៅកាន់ព្រៃក្រាស់នៃបព៌ត គិតថា ភ្នំណាហ្ន៎ឈ្មោះសុវណ្ណបស្សបព៌ត ធ្លងមហាបព៌តទាំង ៧ ។ បទថា **វិតុរិយា** សេចក្តីថា ពិចារណា គឺពិចារណាមើលក្នុងកាលនោះ ។ កាលកំពុងពិចារណានោះគាត់ឃើញភ្នំដែលឈ្មោះថា សុវណ្ណបស្សគិរី ជាភ្នំធំខ្ពស់ទើបគិតថាប្រហែលជាភ្នំមួយនេះ ។

បទថា **ឱលោកយិ** សេចក្តីថា បុរសនោះឡើងទៅកាន់បព៌តដែលជាលំនៅរបស់ពួកកិន្នរហើយ ឈ្ងោកមើលទៅខាងក្រោម កំណត់ទីដែលព្រះនាងសុភទ្ទាប្រទានមក ។ បទថា **តត្ថ** សេចក្តីថា ឃើញដើមនិគ្រោធនោះនៅ

ក្បែរជើងភ្នំនោះឯង ។ បទថា **តត្ថ** សេចក្តីថា ឈរត្រង់គល់ជ្រៃនោះ ។ បទថា **តត្ថ** សេចក្តីថា ខាងក្នុងភ្នំមិនឆ្ងាយអំពីដើមជ្រៃនោះឯង ស្តេចដំរីផ្ងូតទឹកក្នុងស្រះធម្មជាតិណា បុរសនោះឃើញស្រះធម្មជាតិនោះ ។ បទថា **ធិស្វាន** សេចក្តីថា ក្នុងកាលដំរីទាំងឡាយទៅហើយព្រាននោះក៏ចុះអំពីសុវណ្ណបស្ស-បពិត ពាក់ស្រោមដៃនិងស្បែកជើង ហើយពិនិត្យមើលទីដែលស្តេចដំរីនោះទៅនិងទីដែលស្តេចដំរីនោះនៅជាប្រចាំ ឃើញសព្វគ្រប់ប្រការថា ផ្លូវស្តេចដំរីដើរត្រង់នេះ ផ្ងូតទឹកត្រង់នេះ ផ្ងូតហើយឡើងទៅឈរត្រង់នេះ ព្រោះជាអ្នកមិនមានហិរិ គឺមានចិត្តលាមក ត្រូវព្រះនាងសុភទ្ទាដែលធ្លាក់ក្នុងអំណាចចិត្តប្រើមក ព្រោះហេតុនោះទើបមកជីករណ្តៅ គឺដើរទៅជីករណ្តៅ ។

ក្នុងរឿងនោះ មានអនុបុព្វីកថាដូចតទៅនេះ បានឮមកថា ព្រានសោណុត្តរៈនោះ មកដល់លំនៅរបស់ព្រះមហាសត្វ កំណត់បាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ កំណត់លំនៅរបស់ព្រះមហាសត្វដោយន័យដែលពោលហើយនោះឯង កំណត់ទុកថា អញត្រូវជីករណ្តៅត្រង់នេះ ឈរពួនក្នុងរណ្តៅនេះ បាញ់ស្តេចដំរីឲ្យស្លាប់ដូច្នេះហើយ ចូលព្រៃដើម្បីកាត់ឈើធ្វើសសរជាដើម ត្រៀមទព្វសម្ភារៈទុក កាលដំរីទាំងឡាយទៅងូតទឹកហើយទើបយកចបជំជីករណ្តៅ ៤ ជ្រុង ត្រង់លំនៅរបស់ស្តេចដំរី ហើយយកទឹកស្រោច ដូចដាំពូជដែលកាយធូលីឡើង បោះសសរលើថ្មដែលមានសណ្ឋានដូចត្បាល់ដាក់ទូតក្រាលបន្ទះក្តារ ចោះប្រហោងបន្តិច ហើយរោយធូលីនិងរោយអាចម៍ដំរីខាងលើ ធ្វើជាទីចូលចេញរបស់ខ្លួន កាលរណ្តៅស្រេចហើយយ៉ាងនេះ ក្នុងកាលទៀប

ភ្ញីទើបទទូរក្បាល ស្មៀកដណ្តប់កាសាវពស្ត្រ កាន់ធ្នូព្រមទាំងព្រួញដែលលាប ដោយថ្នាំពិសចុះទៅឈរក្នុងរណ្តៅ ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះទើបត្រាស់គាថានេះថា

ព្រានព្រៃ ជាអ្នកធ្វើអំពើអាក្រក់ ជីករណ្តៅហើយគ្រប់ដោយ
ផែនក្តារទាំងឡាយរួចបញ្ចូលខ្លួនទិនធ្នូ ( ទៅក្នុងរណ្តៅនោះ )
ហើយបាញ់នូវដំរី ដែលដើរមកក្បែរខាង ( រណ្តៅរបស់ខ្លួន )
ដោយព្រួញដ៏ថ្លោស ។ ដំរីដ៏ប្រសើរត្រូវព្រានព្រៃបាញ់ហើយ
ក៏បន្លឺនូវកោញ្ចនាទដ៏ពន្លឹក ពួកដំរីទាំងអស់ក៏បន្លឺនូវសំឡេងមាន
សភាពដ៏ពន្លឹក ដំរីទាំងនោះក៏ធ្វើនូវស្មៅនិងមែកឈើ ឲ្យខ្ទេចខ្ទី
ហើយស្ទុះស្ទារទៅទាំង ៨ ទិសជុំវិញ ។ ដំរីដ៏ប្រសើរក៏ចាប់
ព្រាននោះដោយបំណងថា អញនឹងសម្លាប់ព្រានព្រៃនុ៎ះ ក៏ឃើញ
នូវសំពត់កាសាវៈដែលជាទង់ជ័យ របស់ពួកឥសី ដំរីដ៏ប្រសើរ
ត្រូវសេចក្តីទុក្ខប៉ះពាល់ហើយក៏មានសញ្ញាកើតឡើងថា ធម្មតា
បុគ្គលប្រើប្រាស់ទង់ជ័យព្រះអរហន្ត មានសភាពដែលសប្បុ-
រសមិនគួរសម្លាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱឌ្ឌាយ** សេចក្តីថា ចងនូវធ្នូទុក ។ បទថា **បស្សាគតំ** សេចក្តីថា បាញ់នូវស្តេចដំរីដែលមកឈរក្បែររណ្តៅរបស់ខ្លួន ។

បានឮថា ក្នុងថ្ងៃទី ២ ស្តេចដំរីនោះមកងូតទឹកហើយឡើងមកឈរត្រង់ទីធ្លាដែលធំទូលាយ លំដាប់នោះទឹកដែលហូរអំពីសរីរៈរបស់ស្តេចដំរីនោះហូរ

ចុះត្រង់ចុងនាភីបទេស ធ្លាក់ត្រូវខ្លួនរបស់ព្រានតាមប្រហោងនោះ ។ ដោយការសង្កេតនោះនាយព្រានក៏ដឹងថា ព្រះមហាសត្វឈរហើយទើបយកព្រួញធំបាញ់ស្តេចដំរីដែលមកឈរលើរណ្តៅរបស់ខ្លួន ។

បទថា **ឧក្កដកម្មការី** សេចក្តីថា ឈ្មោះថា បុគ្គលធ្វើនូវកម្មអាក្រក់ព្រោះញុំាងទុក្ខឲ្យកើតដល់ព្រះមហាសត្វទាំងកាយនិងចិត្ត ។ បទថា **កោញ្ចមនាទិ** សេចក្តីថា បន្លឺកោញ្ចនាទកងរំពង ។ បានឮថា ព្រួញនោះទម្លុះត្រង់នាភីបទេសរបស់ស្តេចដំរី ទម្លាយអវយវៈដូចជាតម្រងនោមជាដើម ឲ្យបែកល្អិត កាត់នូវពោះវៀនតូចជាដើមរហូតធ្លុះដល់ខ្នងរបស់ស្តេចដំរី ហើយហួសទៅក្នុងអាកាស ស្នាមរបួសដ៏ធំដូចត្រូវមុតដោយពូថៅដូច្នោះ ឈាមហូរចេញអំពីមុខរបួសដូចទឹកល័ខហូរចេញអំពីក្អមដែលបែកដល់នូវទុក្ខវេទនាជាកម្លាំង ស្តេចដំរីមិនអាចអត់ធន់នឹងទុក្ខវេទនាបាន ស្រែកកងរំពងពេញសកលបពិតបន្លឺកោញ្ចនាទអស់ ៣ ដង ។ បទថា **សព្វេ** សេចក្តីថា ដំរី ៨០០០ បានឮសំឡេងនោះ តក់ស្លុតចំពោះមរណភ័យបន្លឺសំឡេងដ៏គួរតក់ស្លុត ។ បទថា **រណំ ករោន្តា** សេចក្តីថា ដំរីទាំង ៨០០០ បន្លឺសំឡេងកងរំពងគួរតក់ស្លុតមកតាមសំឡេងនោះ ឃើញស្តេចដំរីឆទ្ទន្តទទួលទុក្ខវេទនា គិតថា ពួកយើងនឹងចាប់បច្ចាមិត្តឲ្យបាន នាំគ្នារត់រកហូតស្មៅនិងឈើបាក់បែកខ្ទេចខ្ទី ។ បទថា **វជិស្សមេតំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលដំរីទាំងឡាយចៀសចេញទៅកាន់ទិសានុទិសហើយ កាលនាងមហាសុភទ្ទាចូលទៅឈរក្បែរខាងហើយលួងលោម ស្តេចដំរីឆទ្ទន្តក៏អត់សង្កត់នូវវេទនាបាន ហើយកំណាត់ផ្លូវដែលព្រួញ

ស្ទុះមក ពិចារណាថា បើព្រួញនេះមកពីលើជាដើមហើយ ព្រួញនឹងត្រូវធ្លុះត្រង់ក្បាលជាដើមសិនហើយចេញទៅខាងកន្ទុយជាដើម តែនេះចូលតាមផ្ចិតរត់ទៅក្នុងអាកាស ព្រោះហេតុនោះ នឹងមានបុគ្គលដែលឈរនៅខាងក្រោមដីបាញ់មក បំណងនឹងពិនិត្យមើលទីដែលមានមនុស្សឈរតទៅ ទើបគិតថាអ្នកណានឹងដឹងថានឹងមានអ្វីកើតឡើង អញគួរឲ្យនាងមហាសុភទ្ទាចៀសចេញទៅហើយពោលថា នែនាង ដំរី ៨០០០ តាមរកបច្ចាមិត្តរបស់យើង នាំគ្នារត់ទៅក្នុងទិសានុទិស នាងរវល់ធ្វើអ្វីក្នុងទីនេះ កាលនាងមហាសុភទ្ទាឆ្លើយថា ខ្ញុំឈរផងចាំព្យាបាលជួយលួងលោមអ្នក សូមអ្នកអត់ទោសដល់ខ្ញុំផងចុះ ហើយធ្វើប្រទក្សិណ ៣ ជុំធ្វើសេចក្តីគោរពក្នុងឋានៈទាំង ៤ រួចហោះទៅក្នុងអាកាស ឯស្តេចដំរីក៏ឈរយកក្រចកជើងកាយដី ៗ បន្ទះក្តារក៏របើកឡើង ស្តេចដំរីមើលតាមប្រហោង ឃើញព្រានសោណុត្តរៈក៏កើតទោមនស្សចិត្តគិតថា អញនឹងសម្លាប់វា ទើបលូកប្រមោយដែលល្អដូចជាកម្រងប្រាក់ទៅស្ទាបមើល បានឃើញសំពត់កាសាវពស្ត្រ ជាទង់ជ័យរបស់ព្រះអរហន្ត មានព្រះពុទ្ធជាដើមទើបស្តេចដំរីលើកព្រាននោះឡើង មកទុកអំពីខាងមុខ ៗ លំដាប់នោះសញ្ញា គឺការរព្ញកត្រូវបានកើតឡើង ដល់ព្រះមហាសត្វដែលកំពុងទទួលទុក្ខវេទនាដ៏ខ្លាំងក្លាដូច្នេះថា ឈ្មោះថា ទង់ជ័យនៃព្រះអរហន្ត បណ្ឌិតមិនគួរទម្លាយ គួរធ្វើសក្ការគោរពដោយពិត ៗ កាលព្រះមហាសត្វសន្ទនាជាមួយព្រានទើបពោល ២ គាថាដោយសេចក្តីថា

បុគ្គលណាមិនទាន់អស់ទឹកចត់ គឺកិលេស ជាអ្នកប្រាសចាក

ការទូន្មាននូវឥន្ទ្រិយ និងវចីសច្ចៈ និងស្លៀកដណ្តប់សំពត់កា-
សាវៈ បុគ្គលនោះមិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈទេ ។
ចំណែកបុគ្គលណាខ្ជាក់ចោលនូវទឹកចត់ គឺកិលេស តាំងមាំក្នុង
សីលទាំងឡាយ ជាអ្នកប្រកបដោយការទូន្មាននូវឥន្ទ្រិយនិង
វចីសច្ចៈ បុគ្គលនោះឯងទើបគួរនឹងស្លៀកដណ្តប់សំពត់កា-
សាវៈ ដូច្នេះ ។

គាថានោះមានអធិប្បាយដូច្នេះថា នៃព្រានសម្លាញ់ អ្នកណាមិនជាបុគ្គលអស់កិលេសដូចទឹកម្ចត់ មានរាគៈជាដើម ប្រាសចាកនូវការទូន្មានឥន្ទ្រិយផងវចីសច្ចៈផង គឺមិនចូលដល់គុណទាំងនោះ ស្លៀកដណ្តប់នូវសំពត់កាសាវពស្ត្រដែលជ្រលក់ហើយដោយទឹកម្ចត់ បុគ្គលនោះ មិនគួរស្លៀកដណ្តប់នូវកាសាវពស្ត្រឡើយ គឺមិនសមគួរនឹងសំពត់នោះ ឯបុគ្គលណាជាអ្នកជម្រះកិលេសបាន ព្រោះខ្ជាក់នូវកិលេស ដូចទឹកម្ចត់ទាំងនោះចេញបាន ។ បទថា **សីលេសុ សុសមាហិតោ** សេចក្តីថា បុគ្គលណាជាអ្នកមានសីលនិងអាចារតាំងមាំដោយល្អបរិបូណ៌ បុគ្គលនោះឈ្មោះថាគួរស្លៀកដណ្តប់កាសាវពស្ត្រ ។

ព្រះមហាសត្វកាលពោលយ៉ាងនេះហើយ រម្ងាប់នូវការគិតដើម្បីសម្លាប់ព្រាននោះ សួរថា នៃសម្លាញ់ អ្នកបាញ់យើងដើម្បីអ្វី ដើម្បីប្រយោជន៍ខ្លួនឯង ឬអ្នកដទៃប្រើមក ។

ព្រះបរមសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាដោយសេចក្តីថា

ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយដោយសរដ៏ថ្លៃស មិន
មានចិត្តប្រទូស្តបាននិយាយនឹងព្រានព្រៃថា នែសម្លាញ់ អ្នក
ត្រូវការអ្វី តើព្រោះហេតុអ្វីបានជាអ្នកសម្លាប់យើង ម្យ៉ាងទៀត
ការប្រកបនេះរបស់បុគ្គលណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិមត្ថិយំ** សេចក្តីថា អ្នកប្រាថ្នាអ្វីក្នុងអនាគត ។ បទថា **កិស្ស វា** បានដល់ ព្រោះហេតុអ្វី អធិប្បាយថា ដោយហេតុអ្វី គឺអ្នកចងពៀរអ្វីជាមួយខ្ញុំ ។ បទថា **កស្ស វា** សេចក្តីថា នេះជាបំណងរបស់អ្នកដទៃ គឺអ្នកណាប្រើអ្នកមកសម្លាប់ខ្ញុំ ។

កាលព្រានសោណុត្តរៈ ប្រាប់សេចក្តីនោះដល់ស្តេចដំរី ទើបពោលគាថាដូច្នេះថា

បពិត្រដំរីដ៏ចម្រើន ព្រះមហេសីរបស់ស្តេចក្នុងដែនកាសីនោះ
ឈ្មោះនាងសុភទ្ទាដែលគេបូជាហើយក្នុងរាជត្រកូល ព្រះនាង
បានឃើញអ្នក ហើយប្រាប់ខ្ញុំ ព្រះនាងក៏មានព្រះសវនីយ៍នឹងខ្ញុំ
ថា យើងត្រូវការដោយភ្លុកទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បូជិតា** សេចក្តីថា ដែលមហាជនបូជាហើយក្នុងឋានៈជាអគ្គមហេសី ។ បទថា **អទ្ទស** សេចក្តីថា បានឮថា ព្រះនាងទ្រង់យល់សប្តិឃើញអ្នក ។ បទថា **អសំសិ** សេចក្តីថា ទាំងព្រះនាងប្រោសឲ្យធ្វើសក្ការៈដល់ខ្ញុំហើយត្រាស់ថា ក្នុងព្រៃហិមពាន្ត មានស្តេចដំរីរូបរាងយ៉ាងនេះ នៅក្នុងទីឈ្មោះនោះ ។ បទថា **ឧទ្ទេហិ** សេចក្តីថា ព្រះទេវីបានត្រាស់

ប្រាប់ខ្ញុំថា ក្អុករបស់ស្ដេចដំរីនោះមានពណ៌ ៦ រុងរឿង យើងត្រូវការក្អុកទាំងនោះបំណាងធ្វើជាគ្រឿងប្រដាប់ ចូរអ្នកនាំយកក្អុកដំរីនោះមកឲ្យយើង ។

ព្រះមហាសត្វទ្រង់ស្ដាប់ដូច្នោះក៏ដឹងថា នុ៎ះជាការធ្វើរបស់នាងចូឡសុភទ្ទា អត់សង្កត់នូវវេទនាពោលថា ព្រះនាងសុភទ្ទានោះមិនមែនត្រូវការក្អុកទាំង ២ របស់យើងឡើយ តែព្រោះបំណងនឹងឲ្យអ្នកសម្លាប់ខ្ញុំ ទើបបានបញ្ជូនមក កាលនឹងសម្ដែងសេចក្ដីតទៅទើបពោលគាថា ២ ថា

ព្រះរាជបុត្រីនោះ ដឹងថាគូនៃក្អុកទាំងឡាយរបស់បិតានិងជីតាទាំងឡាយរបស់យើង មានច្រើនណាស់ តែនាងជាស្រីក្រោធ ត្រូវការសម្លាប់ ជាស្រីល្ងង់ បានចងពៀរ ( នឹងយើង ) ។

នែព្រានព្រៃ អ្នកចូរក្រោកឡើងចាប់នូវរណារហើយអារនូវក្អុកទាំងគូនេះចុះទាន់ខ្ញុំមិនទាន់ស្លាប់ អ្នកឯងគប្បីទូលព្រះរាជបុត្រីដែលមានសេចក្ដីក្រោធនោះថា ដំរីដ៏ប្រសើរទូលព្រះបង្គំជាខ្ញុំបានសម្លាប់ហើយ សូមព្រះនាងទទួលយក នេះជាក្អុករបស់ដំរីនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥមេ** សេចក្ដីថា បានឮថា ក្អុកទាំងឡាយកាលបិតានិងជីតារបស់ស្ដេចដំរីនោះ បានលាក់ក្នុងទីកំបាំងដោយបំណងថាកុំបីវិនាសឡើយ ស្ដេចដំរីឆទ្ទន្តពោលសំដៅយកក្អុកដំរីទាំងនោះ ទើបពោលយ៉ាងនេះ ។ បទថា **ជានាតិ** សេចក្ដីថា ព្រះនាងសុភទ្ទានោះដឹងថា ក្អុកដំរីជាច្រើនលាក់ក្នុងទីនេះ ។ បទថា **វធត្ថិកា** សេចក្ដីថា តែព្រះនាងសុភទ្ទា

នោះបំណងនឹងឲ្យអ្នកសម្លាប់ខ្ញុំឲ្យស្លាប់តែម្យ៉ាង បានចង់ពៀរ ព្រោះសេចក្តីព្យាបាទត្រឹមតែតិចតួចក្នុងចិត្ត គឺព្រះនាងឲ្យយើងដល់ទីបំផុតដោយការធ្វើដ៏លាមកបែបនេះ ។ បទថា **ឲរំ** បានដល់ រណារ ។ បទថា **បុរា មរាមិ** សេចក្តីថា ទាន់ខ្ញុំមិនទាន់ស្លាប់ ។ បទថា **វជ្ជាសិ** សេចក្តីថា អ្នកគប្បីក្រាបទូល ។ បទថា **ហន្ទ ឥមស្ស ឧន្តា** សេចក្តីថា អ្នកគប្បីទូលព្រះនាងសុភទ្ទានោះថា ស្តេចដំរីនោះត្រូវអ្នកសម្លាប់ស្លាប់ហើយ មនោរថរបស់ព្រះនាងដល់ទីបំផុតហើយ អញ្ជើញព្រះនាងទទួលភ្លុកទាំងនេះរបស់ស្តេចដំរីនោះចុះ ។

សោណុត្តរៈព្រាន បានស្តាប់ពាក្យរបស់ស្តេចដំរី ហើយក្រោកឡើងអំពីអាសនៈ កាន់រណារចូលមកជិតស្តេចដំរីគិតថា អញនឹងកាត់យកភ្លុកទៅ ។ ស្តេចដំរីនោះកម្ពស់ប្រមាណ ៨០ ហត្ថ ឈរប្រាកដដូចភ្នំប្រាក់ ដោយហេតុនោះទើបព្រានសោណុត្តរៈដាក់រណារមិនដល់ ។ លំដាប់នោះ ព្រះមហាសត្វក៏បន្ទន់កាយបង្អោនក្បាលឲ្យទាប ។ ខណៈនោះនាយព្រាន ក៏ជាន់ប្រមោយដូចកម្រងប្រាក់របស់ព្រះមហាសត្វ ឡើងទៅកាន់ខាងលើក្បាល ដូចឈរលើភ្នំកៃលាសរួចយកជើងរុញសាច់ដែលសំយុងត្រង់មាត់ ញាត់ចូលទៅខាងក្នុងចុះអំពីក្បាល ហើយលូករណារចូលទៅក្នុងមាត់ ។ នាយព្រានយកដៃទាំង ២ រុញឡើងទាញចុះយ៉ាងស្វាហាប់ ។ ទុក្ខវេទនាដែលកើតឡើង ដល់ព្រះមហាសត្វជាកម្លាំង មាត់ពេញដោយឈាម ។ កាលព្រានទាញរណារទៅមកក៏មិនអាចយករណារកាត់ភ្លុកឲ្យដាច់បាន ពេលនោះទើបព្រះមហាសត្វខ្ជាក់ឈាមចេញអំពីមាត់ អត់ធន់នូវទុក្ខវេទនា សួរព្រានថា នែសម្លាញ់ អ្នកមិន

អាចកាត់ភ្លុកឲ្យដាច់បានទេឬ សោណុត្តរព្រានឆ្លើយថា ពិតហើយ ។ ព្រះមហាសត្វតម្កល់សតិមាំហើយពោលថា បើដូច្នោះចូរអ្នកលើកប្រមោយរបស់ខ្ញុំឡើង ចូរចាប់រណារខាងលើ ខ្ញុំមិនមានកម្លាំងលើកប្រមោយរបស់ខ្លួនបាន ។ ព្រានក៏បដិបត្តិតាមនោះ ។ ព្រះមហាសត្វយកប្រមោយចាប់រណារ ហើយទាញឡើងទាញចុះ ឯភ្លុកទាំង ២ ក៏ដាច់ដូចគេកាត់ដង្កត់ឈើដូច្នោះ ។ កាលនោះស្តេចដំរីបានឲ្យព្រាននាំភ្លុកនោះមកកាន់ទុក ហើយពោលថា នែសម្លាញ់ ខ្ញុំឲ្យភ្លុកនេះដល់អ្នក មិនមែនខ្ញុំមិនស្រឡាញ់ភ្លុកខ្ញុំឡើយ ខ្ញុំមិនប្រាថ្នាភាពជាសក្កទេវរាជ ជាមារនិងជាព្រហ្មឡើយ តែព្រោះភ្លុក គឺសព្វញ្ញុតញ្ញាណនោះ ខ្ញុំស្រឡាញ់ជាងភ្លុកនេះរាប់រយរាប់ពាន់ដង ដោយបុញ្ញកម្មនេះ សូមជាបច្ច័យធ្វើឲ្យជាក់ច្បាស់នូវសព្វញ្ញុតញ្ញាណដូច្នេះ ហើយក៏ប្រគល់ភ្លុកទៅហើយសួរថា សម្លាញ់ ទម្រាំអ្នកមកដល់ទីនេះ អស់កាលមានប្រមាណប៉ុនណា កាលព្រានឆ្លើយថា ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបពោលថា អញ្ជើញទៅចុះ ដោយអានុភាពគូនៃភ្លុកនេះអ្នកនឹងដល់នគរពារាណសីខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ដូច្នេះហើយធ្វើនូវការការពារដល់ព្រាននោះ បញ្ជូនទៅដោយតាំងសច្ចាធិដ្ឋានថា

ខ្ញុំជាបុគ្គលត្រូវសរមុតទម្លុះហើយ ទោះបីត្រូវវេទនាគ្របសង្កត់ក៏មិនមានចិត្តប្រទូស្តក្នុងបុគ្គលដែលដណ្តប់ដោយកាសាវពស្ត្រ បើសេចក្តីនេះជាការពិតដែលខ្ញុំជាស្តេចដំរីតម្កល់ទុក សូមពាឡម្រឹគក្នុងដងព្រៃកុំបៀតបៀនព្រាននេះឡើយ ។

កាលព្រះមហាសត្វបញ្ជូនព្រានទៅហើយ ក៏ធ្វើកាលកិរិយាក្នុងកាលពួកដំរីនិងនាងមហាសុភទ្ទាមិនទាន់មកដល់ ។

ព្រះបរមសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះទើបត្រាស់ព្រះគាថានេះថា

ព្រានព្រៃនោះ ក្រោកឈរឡើងហើយចាប់រណារ អារនូវភ្លុកនៃដំរីដ៏ប្រសើរ ហើយក៏យកនូវភ្លុកដ៏ល្អស្អាតមិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី រួចដើរចៀសចេញទៅអំពីទីនោះយ៉ាងឆាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វគ្គូ** សេចក្ដីថា ល្អលើសលន់ ។ បទថា **សុភេ** បានដល់ ស្អាតបរិសុទ្ធិ ។ បទថា **អប្បដិមេ** សេចក្ដីថា ល្អរកភ្លុកដទៃក្នុងផែនដីនេះមកប្រៀបមិនបាន ។

កាលព្រាននោះចៀសចេញទៅហើយ ដំរីទាំងឡាយក៏មកដល់ មិនបានឃើញបច្ចាមិត្ត ព្រះបរមសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះទើបត្រាស់ព្រះគាថាដោយសេចក្ដីថា

ពួកដំរីត្រូវភ័យ ( អំពីសេចក្ដីស្លាប់ ) បៀតបៀនហើយដល់នូវសេចក្ដីទុក្ខព្រួយ ព្រោះគេសម្លាប់នូវដំរីដ៏ប្រសើរ បានស្ទុះទៅគ្រប់ទិសទាំង ៨ លុះមិនឃើញបុរសជាសត្រូវនឹងដំរី ក៏ត្រឡប់មកកាន់ទីរបស់ស្ដេចដំរីដ៏ប្រសើរវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភយដ្ដិតា** សេចក្ដីថា កាលសេចក្ដីខ្លាចចំពោះមរណភ័យចូលទៅគំរាមហើយ ។ បទថា **អដ្ដា** បានដល់ ដល់នូវ

សេចក្តីទុក្ខ ។ បទថា **គជបច្ចមិត្តំ** បានដល់ បុគ្គលដែលជាសត្រូវរបស់ស្តេចដំរី ។ បទថា **យេន សោ** សេចក្តីថា ស្តេចដំរីនោះ ធ្វើកាលកិរិយាដួលចុះក្នុងទីលានដ៏ធំទូលាយ ដូចភ្នំកៃលាស ដំរីទាំងឡាយនាំគ្នាមកកាន់ទីនោះ ។

ឯនាងមហាសុភទ្ទាដែលមកព្រមជាមួយដំរីទាំងនោះក្តី ដំរី ៨០០០ ក្តី ក៏នាំគ្នាខ្សឹកខ្សួលក្នុងទីនោះឯង ហើយនាំគ្នាទៅកាន់សម្នាក់ព្រះបច្ចេកពុទ្ធដែលជាកុលុបកៈរបស់ព្រះមហាសត្វ ប្រាប់ថា បពិត្រលោកម្ចាស់ បច្ចយទាយករបស់លោកម្ចាស់ទាំងឡាយ ត្រូវបាញ់ដោយព្រួញដែលលាបថ្នាំពិសធ្វើកាលកិរិយាហើយ សូមលោកម្ចាស់ទាំងឡាយ មកមើលសាកសពរបស់បច្ចយ-ទាយកនោះក្នុងឈាបនដ្ឋានចុះ ។ ចំណែកព្រះបច្ចេកពុទ្ធ ៥០០ អង្គ និមន្តមកតាមអាកាសចុះត្រង់ទីធ្លាធំ ។ ខណៈនោះដំរីជំទង់ ២ នាំគ្នាយកភ្លុកលើកសរីរៈរបស់ស្តេចដំរីឲ្យថ្វាយបង្គំព្រះបច្ចេកពុទ្ធ ហើយលើកឡើងកាន់ជើងថ្ករធ្វើឈាបនកិច្ច ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ធ្វើនូវការស្វាធ្យាយធម៌ក្នុងឈា-បនដ្ឋានមួយយប់ទល់ភ្លឺ ។ ដំរីទាំង ៨០០០ កាលលត់ធាតុស្រេចហើយ ចុះងូតទឹកហើយ អញ្ជើញនាងមហាសុភទ្ទាជាប្រធាន ដង្ហែមកកាន់លំនៅរបស់ខ្លួន ។

ព្រះបរមសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះទើបត្រាស់ព្រះគាថានេះថា

ដំរីដ៏ប្រសើរទាំងនោះកន្ទក់កន្ទេញ រេទ៍ក្នុងទីនោះហើយរោយ
រាយនូវអាចម៍ដីលើក្បាលរបស់ខ្លួន ដំរីទាំងអស់នោះ ក៏ឲ្យមេ

ដំរីជាមហេសី ឈ្មោះសព្វសុភទ្ទា ដើរមុខមកកាន់ទីនៅរបស់ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បំសុកំ** បានដល់ ធូលីសរីរង្គានៅត្រង់ឈាបនដ្ឋាន ។ ឯសោណុត្តរៈយកភ្លុកទាំងគូមក មិនទាន់ដល់ ៧ ថ្ងៃ ក៏មកដល់នគរពារាណសី ។

ព្រះបរមសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះបានត្រាស់ព្រះគាថានេះថា

ព្រានព្រៃនោះបាននាំយកភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកល្អស្អាតមិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ភ្លឺសព្វដោយរស្មី មានពណ៌ដូចជាមាស ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះ ក៏បង្អោននូវភ្លុកទាំងឡាយថ្វាយព្រះរាជកញ្ញាថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំសម្លាប់បានហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុវណ្ណរាជីហិ** សេចក្ដីថា បញ្ចេញរស្មីដូចពណ៌មាស ។ បទថា **សមន្តមោទរេ** សេចក្ដីថា ផ្សាយរស្មីពណ៌មាសទៅជុំវិញពេញដងព្រៃ ។ បទថា **ឧបនេសិ** សេចក្ដីថា ឯព្រានសោណុត្តរៈបញ្ជូនដំណឹងទូលព្រះទេវីថា ខ្ញុំនឹងនាំភ្លុកទាំងគូដែលបញ្ចេញរស្មីមានពណ៌ ៦ ប្រការរបស់ស្ដេចដំរីឆទ្ទន្តមកថ្វាយ សូមព្រះនាងប្រោសឲ្យប្រជាប់តាក់តែងព្រះនគរ កាលព្រះទេវីក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប បានឲ្យប្រជាប់តាក់តែងព្រះនគរដូចទេវនគរ ហើយក៏ចូលទៅកាន់នគរ ឡើងទៅកាន់ប្រាសាទបង្អោន

ភ្នុកទាំងគូចូលទៅ កាលបង្អោនចូលទៅហើយក៏ក្រាបទូលថា បពិត្រព្រះនាង បានឮថា ព្រះនាងអាក់អន់ត្រឹមហេតុបន្តិចបន្តួច ក្នុងព្រះហឫទ័យចំពោះស្ដេចដំរីណា ទូលព្រះបង្គំសម្លាប់ស្ដេចដំរីនោះស្លាប់ហើយ សូមព្រះនាងជ្រាបចុះថា ស្ដេចដំរីស្លាប់ហើយ សូមព្រះនាងទត នេះជាភ្លុកទាំងគូនៃស្ដេចដំរីនោះ រួចបានថ្វាយភ្លុក ។ ព្រះនាងសុកទ្វាយករង្វេលធ្វើដោយកែវមណី ទទួលនូវគូនៃភ្លុកដ៏វិចិត្រ មានរស្មី ៦ ប្រការរបស់ព្រះមហាសត្វមកទុកត្រង់ឧរុបទេស ទតភ្លុកស្វាមីជាទីស្រឡាញ់ព្រះនាងក្នុងកពមុនបណ្ដើរ គិតបណ្ដើរថា ព្រានសោណុត្តរៈ សម្លាប់ស្ដេចដំរីដ៏ល្អត្រកាលបែបនេះឲ្យអស់ជីវិត ដោយព្រួញដែលលាបដោយថ្នាំពិស កាត់យកភ្លុកទាំងគូមក កាលព្រះនាងរឭកដល់ព្រះមហាសត្វ ក៏កើតសេចក្ដីសោកមិនអាចអត់សង្កត់បាន ក្នុងរំពេចនោះហទយៈរបស់ព្រះនាងក៏បែកធ្លាយ សោយព្រះទិវង្គតក្នុងថ្ងៃនោះឯង ។

ព្រះបរមសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះក៏ត្រាស់ព្រះគាថានេះថា

ព្រះរាជកញ្ញានោះទតឃើញភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរដែល
ធ្លាប់ជាប្ដីជាទីស្រឡាញ់អំពីជាតិមុន ក៏បែកហឫទ័យក្នុងទីនោះ
ឯង ហេតុនោះព្រះនាងជាស្រីល្ងង់ បានសោយព្រះទិវង្គត
ទៅ ដូច្នេះ ។

សម័យនោះ កាលព្រះធម្មសង្គាហកត្ថេរទាំងឡាយ សរសើរព្រះគុណនៃព្រះទសពលទើបពោលពាក្យជាគាថាយ៉ាងនេះថា

ព្រះពុទ្ធព្រះអង្គ បានសម្រេចនូវសម្ពោធិញ្ញាណផង មានអានុ-

ភាពច្រើនផង បានធ្វើនូវការញញឹម ក្នុងកណ្ដាលពពួកបរិស័ទ ពួកភិក្ខុមានចិត្តរួចស្រឡះ ក៏ក្រាបបង្គំទូលសួរថា ព្រះពុទ្ធទាំងឡាយមិនដែលធ្វើនូវការញញឹមឲ្យប្រាកដដោយឥតហេតុទេ ។ អ្នកទាំងឡាយ បានឃើញនាងកុមារីណានៅជំទង់ ស្លៀកសំពត់កាសាវៈជាអ្នកបួស នាងកុមារីនោះក្នុងកាលនោះ គឺព្រះរាជ-កញ្ញា ឯស្ដេចដំរីក្នុងកាលនោះ គឺតថាគតឯង ព្រានព្រៃណាកាន់យកនូវភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកដ៏ល្អស្អាតមិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះក្នុងកាលនោះ គឺទេវទត្ត ។ ព្រះពុទ្ធព្រះអង្គ ប្រាសចាកសេចក្ដីក្រវល់ក្រវាយ ប្រាសចាកសេចក្ដីសោក ប្រាសចាកនូវកូនសរ គឺរាគៈ បានជ្រាបច្បាស់ដោយព្រះអង្គឯង ហើយទ្រង់សំដែងនូវចរិតខ្ពស់និងទាបអំពីដើមនេះដែលអន្ទោលទៅ អស់កាលដ៏យូរ ហាក់ដូចមិនកន្លងថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះតថាគតនៅក្នុងទីនោះ កាលនោះតថាគតជាស្ដេចដំរី អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ដូច្នេះ ។

គាថាទាំងនេះព្រះធម្មសង្គាហកត្ថេរទាំងឡាយ សរសើរព្រះគុណរបស់ព្រះទសពល រចនាឲ្យប្រាកដ ។ បណ្ដាបទទាំងនោះ បទថា **សិតំ អកាសិ** សេចក្ដីថា អាវុសោទាំងឡាយ ព្រះសាស្ដាទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណ

ហើយមានអានុភាពច្រើន ថ្ងៃមួយគង់លើធម្មាសនៈដ៏ឧត្តម ត្រង់កណ្ដាលបរិស័ទក្នុងធម្មសភាដែលប្រដាប់តាក់តែងហើយទ្រង់ធ្វើនូវការញញឹម ។ បទថា **ឆាការណោ** សេចក្ដីថា ភិក្ខុទាំងឡាយ ជាមហាថេរណាស្រែពទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់មិនធ្វើការញញឹមដោយឥតហេតុឡើយ ការញញឹមទ្រង់ធ្វើហើយ អ្វីជាហេតុឲ្យទ្រង់ធ្វើនូវការញញឹម ។

បទថា **យមត្ថសាធ** សេចក្ដីថា អាវុសោទាំងឡាយ ព្រះសាស្ដាត្រូវទូលសួរយ៉ាងនេះហើយ កាលនឹងត្រាស់ប្រាប់ហេតុដែលទ្រង់ធ្វើនូវការញញឹម ទ្រង់ចង្អុលភិក្ខុនីជំទង់មួយរូបត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឃើញកុមារិកានេះជាស្រីក្រមុំ គ្រងនូវសំពត់កាសាវៈចូលដល់បព្វជ្ជា ប្រព្រឹត្តអនាគារិយវត្តក្នុងព្រះសាសនានេះ កុមារិកានោះ គឺនាងសុភទ្ទារាជកញ្ញាក្នុងកាលនោះដែលប្រើនាយព្រានសោណុត្តរៈទៅថា ចូរឯងយកព្រួញលាបដោយថ្នាំពិសទៅបាញ់សម្លាប់សត្វដំរី កាលនោះតថាគតជាស្ដេចដំរីដែលនាយព្រានសោណុត្តរៈទៅបាញ់ឲ្យអស់ជីវិត ។

បទថា **ធេវធត្តោ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ សោណុត្តរព្រានក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ។ បទថា **អធាវសូរំ** កាត់បទជា **ឆ អវសូរំ** ប្រែថា ព្រះអាទិត្យមិនទាន់អស្ដង្គត ។ បទថា **ចិររត្ត-សំសិតំ** សេចក្ដីថា រាប់តាំងអំពីកាលដ៏យូរលង់មកហើយនេះ ទ្រង់អន្ទោលទៅហើយគឺទ្រង់ស្ទុះទៅហើយ បានដល់ ទ្រង់ប្រព្រឹត្តមកហើយដោយលំដាប់ក្នុងទីបំផុតនៃកោដិកប្បមិនមែនតែមួយ ។ លោកអធិប្បាយទុកថា អាវុសោ

ទាំងឡាយ ព្រះសម្ពុទ្ធឈ្មោះថា **វីតទ្ធរោ** ព្រោះទ្រង់ប្រាសចាកកិលេស មានរាគៈជាដើម ឈ្មោះថា **វីតសោកោ** ព្រោះមិនមានសេចក្តីសោកដែលកើតអំពីញាតិនិងទ្រព្យជាដើម ឈ្មោះថា **វិសល្លោ** ព្រោះប្រាសចាកកូនសរមានរាគៈជាដើម ទ្រង់ដឹងច្បាស់ដោយព្រះអង្គឯងហើយ បានត្រាស់រឿងនេះជារបស់បុរាណ គឺព្រះអាទិត្យមិនទាន់លិច រាប់តាំងពីកាលដ៏យូរនេះ សូម្បីតែទ្រង់អន្ទោលទៅក្នុងទីបំផុតនៃកោដិកប្បមិនតែមួយ ឈ្មោះថា **ឧច្ចាវចំ** ព្រោះទ្រង់ខ្ពស់ដោយអំណាចបុព្វចរិយារបស់ព្រះអង្គនិងព្រោះទាបដោយអំណាចនៃចរិយារបស់ព្រះនាងសុភទ្ទារាជធីតានិងព្រានសោណុត្តរៈ ដូចទ្រង់រឭកដល់វត្ថុដែលធ្វើដោយការវង្វេងដោយប្រាសចាកការវង្វេង ដូចវត្ថុដែលធ្វើ ក្នុងវេលាព្រឹក បានក្នុងពេលល្ងាចថ្ងៃនោះឯង ។

បទថា **ហ៊ា** ក្នុងបទថា **អហំ ហ៊ា** នេះ ត្រឹមតែជានិបាត ។ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលនោះតថាគតបានជាស្តេចដំរីនៅត្រង់ស្រះឆទ្ទន្តនោះ ។ បទថា **នាគរាជា** សេចក្តីថា កាលនៅក្នុងគ្រានោះ ជាអ្នកដទៃក៏មិនមែនដែលពិត គឺតថាគតជាស្តេចដំរីឆទ្ទន្ត ។ បទថា **ឯវំ ធារេថ** សេចក្តីថា អ្នកទាំងឡាយចូរចាំ គឺចំណាំទុក បានដល់ រៀនជាតកនេះទុកដោយប្រការដូច្នេះ ។

កាលមនុស្សជាច្រើន ស្តាប់ធម្មទេសនានេះហើយ បានសម្រេចជាព្រះសោតាបន្នជាដើម ឯភិក្ខុនីនោះចម្រើនវិបស្សនាក្រោយមកក៏បានសម្រេចអរហត្តផល ដូច្នេះ ។

**អដ្ឋកថា ឆទ្ទន្តជាតក ចប់**

# សម្ភវជាតក

[ ៤៨១ ] ( ព្រះបាទធនញ្ជយកោរព្យៈត្រាស់សួរថា ) នែសុចីរតៈ យើងបាននូវរាជសម្បត្តិផង បាននូវភាពជាធំផង យើងប្រាថ្នាដើម្បីដល់នូវភាពជាធំ ប្រាថ្នាដើម្បីត្រួតត្រានូវផែនដីនេះ ។ ( យើងប្រកប ) ដោយធម៌ មិនប្រកបដោយអធម៌ទេ ព្រោះអធម៌ មិនពេញចិត្តដល់យើងឡើយ ម្នាលសុចីរតៈ ធម៌ជាចរិតរបស់ព្រះរាជាពួកជនត្រូវតែធ្វើ ។ តែព្រាហ្មណ៍ យើងដែលពួកជនមិននិន្ទាក្នុងលោកនេះ ដោយអត្ថនិងធម៌ណាផង មិននិន្ទាក្នុងបរលោកដោយអត្ថនិងធម៌ណាផង គប្បីដល់នូវឥស្សរិយយស ក្នុងទេវលោកនិងមនុស្សលោកដោយអត្ថនិងធម៌ណាផង ។ នែព្រាហ្មណ៍ យើងប្រាថ្នាដើម្បីធ្វើនូវអត្ថនិងធម៌នោះៗ នែព្រាហ្មណ៍ អ្នកដែលយើងសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌នោះ ។

[ ៤៨២ ] ( សុចីរតព្រាហ្មណ៍ក្រាបទូលថា ) បពិត្រព្រះខត្តិយរាជ ព្រះអង្គប្រាថ្នាដើម្បីធ្វើនូវអត្ថនិងធម៌ណា តែវៀរចាកវិធុរព្រាហ្មណ៍ហើយ បុគ្គលដទៃមិនគួរនឹងប្រាប់នូវអត្ថនិងធម៌នោះបានទេ ។

[ ៤៨៣ ] ( ព្រះរាជា... ) នែសុចីរតៈ អ្នកចូរមកនេះ អ្នកឯងត្រូវយើងប្រើទៅ អ្នកចូរទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ ចូរនាំយកនូវផ្ការរនៃមាសនេះទៅចុះ អ្នកចូរឲ្យនូវផ្ការរនៃមាសនេះ ជាគ្រឿងបូជាដល់ការប្រៀនប្រដៅនូវអត្ថនិងធម៌ ។

[ ៤៨៤ ] ( អភិសម្ពុទ្ធគាថា ) សុចីរតព្រាហ្មណ៍ជាភារទ្វាជគោត្តនោះ

បានទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ សុចីរតៈជាមហាព្រាហ្មណ៍ក៏បានឃើញវិធុរព្រាហ្មណ៍នោះកំពុងតែបរិភោគក្នុងផ្ទះរបស់ខ្លួន ។

[ ៤៨៥ ] ( សុចីរតព្រាហ្មណ៍... ) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យជាយុធិដ្ឋិលគោត្ត ទ្រង់មានព្រះរាជឱង្ការថា អ្នកចូរសួរនូវអត្ថនិងធម៌ បពិត្រវិធុរ អ្នកដែលខ្ញុំសួរហើយចូរប្រាប់នូវអត្ថនិងធម៌នោះ ។

[ ៤៨៦ ] ( វិធុរព្រាហ្មណ៍... ) ម្នាលព្រាហ្មណ៍ ខ្ញុំ ( គិតថា ) អញនឹងបិទនូវទន្លេគង្គាតែមិនអាចបិទនូវទន្លេដ៏ធំនោះបាន ព្រោះហេតុនោះឱកាសនោះនឹងមានដូចម្តេចកើត ខ្ញុំដែលអ្នកសួរហើយមិនអាចដើម្បីប្រាប់នូវអត្ថនិងធម៌បានទេ ។ តែខ្ញុំមានកូនប្រុសមួយឈ្មោះភទ្រការ ជាឱរស ជាកូនបង្កើតរបស់ខ្ញុំ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះអ្នកចូរទៅសួរអត្ថនិងធម៌ចំពោះភទ្រ-ការនោះចុះ ។

[ ៤៨៧ ] ( អភិសម្ពុទ្ធគាថា ) សុចីរតព្រាហ្មណ៍ជាភារទ្វាជគោត្តនោះបានទៅកាន់សំណាក់ភទ្រការកុមារ សុចីរតៈជាមហាព្រាហ្មណ៍ បានឃើញភទ្រការកុមារនោះកំពុងអង្គុយនៅក្នុងផ្ទះរបស់ខ្លួន ។

[ ៤៨៨ ] ( សុចីរតព្រាហ្មណ៍... ) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយសទ្រង់ប្រើមក ព្រះបាទកោរព្យៈជាយុធិដ្ឋិលគោត្ត ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលភទ្រការកុមារ ព្រោះហេតុនោះអ្នកចូរប្រាប់នូវអត្ថនិងធម៌ដល់ខ្ញុំ ។

[ ៤៨៩ ] ( កទ្រការកុមារ... ) ខ្ញុំទើបទម្លាក់ចោលនូវអម្រែកសាច់ហើយដេញតាមនូវទន្សង ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់នូវអត្ថនិងធម៌បានទេ ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះសញ្ជ័យ បពិត្រសុចីរតព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរនូវអត្ថនិងធម៌ចំពោះសញ្ជ័យនោះចុះ ។

[ ៤៩០ ] ( អភិសម្ពុទ្ធគាថា ) សុចីរតព្រាហ្មណ៍ជាភារទ្វាជគោត្តនោះ បានទៅកាន់សំណាក់សញ្ជយកុមារ សុចីរតៈជាមហាព្រាហ្មណ៍បានឃើញនូវសញ្ជយកុមារនោះអង្គុយក្នុងកណ្តាលបរិស័ទរបស់ខ្លួន ។

[ ៤៩១ ] ( សុចីរតព្រាហ្មណ៍... ) ខ្ញុំជាទូតព្រះបាទធនញ្ជយកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្ត មានព្រះឱង្ការថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលសញ្ជយកុមារ ព្រោះហេតុនោះ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌ ។

[ ៤៩២ ] ( សញ្ជយកុមារ... ) បពិត្រសុចីរតព្រាហ្មណ៍ មច្ចុតែងលេបខ្ញុំរាល់ល្ងាចរាល់ព្រឹកសព្វ ៗ កាល ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់នូវអត្ថនិងធម៌ ដល់អ្នកបានទេ ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះសម្ភវៈ បពិត្រព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរនូវអត្ថនិងធម៌ចំពោះសម្ភវៈនោះចុះ ។

[ ៤៩៣ ] ( សុចីរតព្រាហ្មណ៍... ) ម្នាលអ្នកដ៏ចម្រើន បញ្ហាធម៌ក៏អស្ចារ្យម្ល៉េះ សម្ភវកុមារនេះ យើងមិនពេញចិត្តទេ ព្រោះជន ៣ នាក់ ឪពុក

និងកូនទាំងនោះ មិនដឹងច្បាស់ដោយប្រាជ្ញាទៅហើយ ។ អ្នកទាំងឡាយដែលខ្ញុំសួរហើយមិនអាចប្រាប់នូវអត្ថនិងធម៌បាន ចំណាន់បើកូនក្មេងដែលខ្ញុំសួរអត្ថនិងធម៌ហើយ គប្បីដឹងដូចម្តេចកើត ។

[ ៤៩៤ ] ( សញ្ជយកុមារ... ) បពិត្រសុចីរតព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះ ថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារទើបដឹងនូវអត្ថនិងធម៌ ។ ព្រះចន្ទប្រាសចាកមន្ទិល កាលដើរទៅតាមអាកាសធាតុ រុងរឿងកន្លងនូវពួកផ្កាយទាំងអស់ក្នុងលោកដោយពន្លឺ យ៉ាងណាមិញ បពិត្រសុចីរតព្រាហ្មណ៍ សម្ភវកុមារពិតជានៅក្មេងមែន ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយបញ្ញានិងការព្យាយាមក៏យ៉ាងនោះដែរ លោកកុំសំគាល់នូវសម្ភវកុមារនោះ ថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ បណ្តាខែខាងគិម្ហរដូវទាំងឡាយ ខែចេត្ររុងរឿងដោយផ្កាឈើទាំងឡាយជាងខែទាំងឡាយដទៃឯទៀត យ៉ាងណាមិញ ។ សម្ភវកុមារពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយបញ្ញា និងការព្យាយាមក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថានៅក្មេងហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្នំគន្ធមាទនៈមានទឹកសន្សើម ជាលំនៅនៃពពួកទេវតា ដេរដាសដោយដើមឈើផ្សេងៗទាំងឡាយផង ដោយឱសធជាទិព្វទាំងឡាយផង រមែងញុំាងទិសទាំងឡាយឲ្យភ្លឺច្បាស់ផង ផ្សាយទៅកាន់ទិសទាំងឡាយ ( ដោយក្លិនក្រអូប ) ផង

យ៉ាងណាមិញ ។ សម្កវកុមារពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវពួក បណ្ឌិតដ៏សេស ) ដោយបញ្ញានិងការព្យាយាមក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្កវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវ សម្កវកុមារទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្លើងប្រក្រតីប្រកបដោយ អណ្តាត មានអំណាច កាលឆេះនូវគុម្ពឈើក្នុងព្រៃមិនចេះឆ្អែត រមែងញុាំង ពណ៌ខ្មៅឲ្យប្រព្រឹត្តទៅ ជាសភាវៈឆេះនូវខ្ទាញ់ មានផ្សែងជាទង់ ឆេះនូវជង ព្រៃស្ងួតមានរបស់សម្រាប់ឆេះដ៏ច្រើន រមែងរុងរឿងលើកំពូលភ្នំក្នុងវេលា យប់យ៉ាងណាមិញ ។ សម្កវកុមារពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវ ពួកបណ្ឌិតដ៏សេស ) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រ ព្រាហ្មណ៍ លោកកុំសំគាល់នូវសម្កវកុមារនោះ ថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្កវកុមារទើបដឹងនូវអត្ថនិងធម៌ ។ ជនទាំងឡាយស្គាល់សេះដ៏ ចម្រើនដោយល្បឿនផង ស្គាល់គោបម្រើក្នុងការផ្ទុកផង ស្គាល់មេគោដោយ រឹតនូវទឹកដោះផង ស្គាល់អ្នកប្រាជ្ញកាលនិយាយផងយ៉ាងណាមិញ ។ សម្កវ-កុមារ ពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយ បញ្ញានិងការព្យាយាមក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវ សម្កវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្កវកុមារទើបដឹង នូវអត្ថនិងធម៌ ។

[ ៤៩៥ ] ( អភិសម្ពុទ្ធគាថា ) សុចីរតព្រាហ្មណ៍ជាភារទ្វាជគោត្តនោះ បានទៅកាន់សំណាក់នៃសម្កវកុមារ សុចីរតៈជាមហាព្រាហ្មណ៍បានឃើញនូវ

សម្ភវកុមារនោះកំពុងលេងខាងក្រៅទីលំនៅ ។

[ ៤៩៦ ] ( សុចីរតព្រាហ្មណ៍... ) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្ត ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ នៃសម្ភវកុមារ ព្រោះហេតុនោះនាងឯងដែលខ្ញុំសួរ ហើយចូរប្រាប់នូវអត្ថនិងធម៌ ។

[ ៤៩៧ ] ( សម្ភវកុមារ... ) បើដូច្នោះ អ្នកឈ្មោះសរំ ( និយាយ ) យ៉ាងណាខ្ញុំនឹងប្រាប់អ្នកយ៉ាងនោះ ព្រះរាជានឹងទ្រង់ជ្រាបនូវប្រស្នានោះ ទោះបីព្រះអង្គធ្វើតាមក្តី មិនធ្វើតាមក្តី ។

[ ៤៩៨ ] បពិត្រសុចីរតព្រាហ្មណ៍ បុគ្គលដែលព្រះរាជាសួរថា ( យើងធ្វើកុសល ) ក្នុងថ្ងៃនេះឬ គប្បីក្រាបទូលថា ក្នុងថ្ងៃស្អែកវិញ កាលបើសេចក្តីត្រូវការកើតឡើងហើយ ព្រះបាទកោរព្យៈជាយុធិដ្ឋិលគោត្ត កុំធ្វើតាមពាក្យ ( នោះ ) ហើយនៅស្ងៀមឡើយ បុគ្គលដែលព្រះរាជាសួរហើយគប្បីក្រាបបង្គំទូលនូវខន្ធបញ្ចកៈ ជាខាងក្នុងតែម្យ៉ាង សូមព្រះរាជាកុំសេពនូវផ្លូវខុស ដូចបុគ្គលវង្វេងដោយឥតចេតនា ។ ព្រះរាជាកុំប្រព្រឹត្តកន្លងនូវអត្តភាព កុំប្រព្រឹត្តនូវអធម៌ កុំចម្លងគេក្នុងទីមិនមែនជាកំពង់ កុំប្រកបក្នុងសេចក្តីវិនាសឡើយ ។ លុះតែក្សត្រិយ៍ណាទ្រង់ជ្រាបហើយធ្វើនូវហេតុទាំងឡាយនេះ ព្រះរាជានោះទើបចម្រើនរាល់ពេល ដូចជាព្រះចន្ទក្នុងសុក្កបក្ខ ។ ព្រះរាជានោះប្រកបដោយប្រាជ្ញារមែងជាទីស្រឡាញ់នៃពួកញាតិផង រុងរឿងក្នុងពួកមិត្តផង លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងឋានសួគ៌ ។

**ចប់ សម្ភវជាតក ទី ៥ ។**

# អដ្ឋកថា

## សម្ភវជាតក

[ ៤៨១-៤៩៨ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបញ្ញាបារមីទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **រជ្ជញ្ច បដិបន្នាស្មា** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានច្បាស់ក្នុងមហាឧម្មគ្គជាតក ឯរឿងក្នុងអតីត មានដូច្នេះថា ព្រះរាជាព្រះនាមថា ធនញ្ចយកោរព្យៈ សោយរាជ្យនៅក្នុងឥន្ទបត្តនគរដែនកុរុ ។ ព្រាហ្មណបុរោហិតឈ្មោះថា សុចីរតៈ បានជាអ្នកទូន្មានអត្ថនិងធម៌របស់ព្រះរាជា ។ ព្រះរាជាទ្រង់បំពេញបុណ្យកុសលមានទានជាដើម ទ្រង់គ្រងរាជ្យដោយទសពិធរាជធម៌ ថ្ងៃមួយទ្រង់តាំងបញ្ហាឈ្មោះធម្មយាគ ទើបអញ្ជើញសុចីរតព្រាហ្មណ៍ ឲ្យអង្គុយលើអាសនៈ ទ្រង់ធ្វើនូវសក្ការៈហើយកាលនឹងត្រាស់សួរបញ្ហាបានត្រាស់ ៤ គាថាដោយសេចក្តីថា

នែសុចីរតៈ យើងបាននូវរាជសម្បត្តិផង បាននូវភាពជាធំផង យើងប្រាថ្នាដើម្បីដល់នូវភាពជាធំ ប្រាថ្នាដើម្បីគ្រួតត្រានូវផែនដីនេះ ។ ( យើងប្រកប ) ដោយធម៌ មិនប្រកបដោយអធម៌ទេ ព្រោះអធម៌មិនពេញចិត្តដល់យើងឡើយ ម្នាលសុចីរតៈ ធម៌ជាចរិតរបស់ព្រះរាជា ពួកជនត្រូវតែធ្វើ ។ នែព្រាហ្មណ៍ យើងដែលពួកជនមិននិន្ទា ក្នុងលោកនេះដោយអត្ថនិងធម៌ណាផង មិននិន្ទាក្នុងបរលោកដោយអត្ថនិងធម៌ណាផង គប្បីដល់

នូវឥស្សរិយយសក្នុងទេវលោកនិងមនុស្សលោកដោយអត្ថនិង ធម៌ណាផង ។ នែព្រាហ្មណ៍ យើងប្រាថ្នាដើម្បីធ្វើនូវអត្ថនិង ធម៌នោះៗ នែព្រាហ្មណ៍ អ្នកដែលយើងសួរហើយ ចូរប្រាប់នូវ អត្ថនិងធម៌នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រដ្ឋំ** សេចក្តីថា បពិត្រលោកអាចារ្យ យើង បាននូវរាជសម្បត្តិ ក្នុងឥន្ទបត្តនគរដែលមានបរិមណ្ឌល ៧ យោជន៍នេះនិង បានទទួលភាពជាធំ ពោលគឺឥស្សរភាពក្នុងកុរុរដ្ឋ ដែលមានបរិមណ្ឌលដល់ ទៅ ៣០០ យោជន៍ហើយ ។ បទថា **បដិសន្ធាស្មា** បានដល់ សម្រេច ហើយ ។ បទថា **មហន្តំ** សេចក្តីថា គ្រានេះគង់ប្រាថ្នាភាពជាធំក្រៃលែង ។ បទថា **បត្ថុមិច្ឆាមិ វិជេតុំ** សេចក្តីថា យើងនៅប្រាថ្នាភាពជាធំដើម្បីអភិសេក គ្រប់គ្រងផែនដីនេះដោយធម៌ ។ បទថា **កិច្ចោវ** សេចក្តីថា ការប្រព្រឹត្តធម៌ ជាកិច្ច គឺជាព្រះរាជករណីដែលសំខាន់ជាងជនដ៏សេស អធិប្បាយថា ( សត្វ ) លោកអនុលោមតាមព្រះរាជា កាលព្រះរាជាមានធម៌ សត្វលោកទាំងអស់ក៏ ជាអ្នកមានធម៌ ព្រោះហេតុនោះ ឈ្មោះថាធម៌នេះ ជាកិច្ចរបស់ព្រះរាជានោះ ឯង ។

បទថា **ឥធ ចេវានិន្ទិតា** សេចក្តីថា យើងទាំងឡាយ នឹងមិនត្រូវនិន្ទា ក្នុងលោកនេះនិងលោកខាងមុខដោយហេតុណា ។ បទថា **យេន បេច្ចាមុ** សេចក្តីថា យើងទាំងឡាយនឹងមិនកើតក្នុងនរកជាដើម គប្បីដល់នូវយស គឺ ភាពជាធំ បានដល់ ដល់នូវភាពដ៏ប្រសើរដោយការស្អាត ក្នុងទេវលោកនិង

មនុស្សលោកដោយហេតុណា ចូរលោកប្រាប់ហេតុនោះដល់យើង ។ បទថា **យោហំ** សេចក្តីថា នែព្រាហ្មណ៍ យើងប្រាថ្នាធ្វើផង សមាទានផង ហើយប្រព្រឹត្តផងនូវអត្ថ គឺផលវិបាកនិងធម៌ គឺហេតុនៃផលនោះនិងញ៉ាំងអត្ថធម៌នោះឲ្យកើតឡើងផង ។ បទថា **តំ ត្វំ** សេចក្តីថា ព្រះរាជាត្រាស់សួរធម្មយាគបញ្ហានិងព្រាហ្មណ៍បុរោហិតថា កាលយើងប្រាថ្នានឹងឡើងកាន់ផ្លូវដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វានដោយស្រួលហើយ ជាអ្នកមិនមានបដិសន្ធិ កាលអ្នកត្រូវសួរដល់អត្ថនិងធម៌នោះ ចូរប្រាប់ គឺពោលធ្វើឲ្យប្រាកដចុះ ។

បញ្ហានេះជ្រាលជ្រៅ ជាពុទ្ធវិស័យ គួរនឹងសួរចំពោះព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ កាលព្រះសព្វញ្ញុពុទ្ធមិនមាន គួរសួរព្រះពោធិសត្វដែលជាអ្នកស្វែងរកសព្វញ្ញុតញ្ញាណ ព្រោះសុចីរតបុរោហិតមិនមែនព្រះពោធិសត្វទើបមិនអាចឆ្លើយបញ្ហាថ្វាយបាន កាលមិនអាចក៏មិនធ្វើការប្រកាន់ខ្លួនថាជាបណ្ឌិត កាលនឹងក្រាបទូលភាពដែលខ្លួនមិនអាចទើបពោលគាថាដោយសេចក្តីថា

> បពិត្រព្រះខត្តិយរាជ ព្រះអង្គប្រាថ្នាដើម្បីធ្វើនូវអត្ថ និងធម៌ណា
> តែវៀរចាកវិធុរព្រាហ្មណ៍ហើយ បុគ្គលដទៃ មិនគួរនឹងប្រាប់នូវ
> អត្ថនិងធម៌នោះបានទេ ដូច្នេះ ។

គាថានោះមានអធិប្បាយដូច្នេះថា បពិត្រមហារាជ បញ្ហានេះមិនជាវិស័យរបស់បុគ្គលដូចទូលព្រះបង្គំឡើយ ទូលព្រះបង្គំមិនឃើញខាងដើម ខាងចុងនៃបញ្ហានោះឡើយ ដូចអ្នកចូលកាន់ទីងងឹត តែរាជបុរោហិតនៃព្រះបាទពារាណសីឈ្មោះវិធុរព្រាហ្មណ៍មាន បុរោហិតនោះគប្បីឆ្លើយបញ្ហានោះបាន វៀរ

គាត់ចេញហើយ អ្នកដទៃមិនអាចសម្តែងអត្ថនិងធម៌ ដែលទ្រង់ប្រាថ្នានឹងធ្វើបានឡើយ ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់សុចីរតព្រាហ្មណ៍ហើយត្រាស់ថា នែព្រាហ្មណ៍ បើដូច្នោះ អ្នកគប្បីប្រញាប់ទៅកាន់សម្នាក់របស់វិធុរព្រាហ្មណ៍ចុះ មានបំណងបញ្ជូនបណ្ណាការទៅព្រះរាជទានទើបត្រាស់ព្រះគាថានេះថា

នែសុចីរតៈ អ្នកចូរមកនេះ អ្នកឯងត្រូវយើងប្រើទៅ អ្នកចូរ
ទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ ចូរនាំយកនូវផ្កានៃមាស
នេះទៅចុះ អ្នកចូរឲ្យនូវផ្កានៃមាសនេះជាគ្រឿងបូជាដល់ការ
ប្រៀនប្រដៅនូវអត្ថនិងធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបន្តិកំ** បានដល់ កាន់សម្នាក់ ។ បទថា **និក្ខំ** សេចក្តីថា មាសទម្ងន់ ៥ ជញ្ជីងជា ១ និក្ខៈ តែព្រះបាទធនញ្ចយកោរព្យៈព្រះរាជទានមាស ១០០០ ដុំ ទើបត្រាស់យ៉ាងនេះ ។ បទថា **ឥមំ ទជ្ជ** សេចក្តីថា កាលវិធុរព្រាហ្មណ៍នោះពោលធម្មយាគបញ្ហានេះហើយ ទើបនាំទៅធ្វើការបូជាប្រគល់មាស ១០០០ ដុំនេះដល់វិធុរព្រាហ្មណ៍នោះដើម្បីទទួលពាក្យអធិប្បាយអត្ថនិងធម៌ ។

ព្រះបាទធនញ្ចយកោរព្យៈ កាលត្រាស់យ៉ាងនេះហើយទើបត្រាស់ឲ្យយកមាសដែលមានតម្លៃមួយសែន មកផែជាបន្ទះ ដើម្បីនឹងបានចារឹកពាក្យវិសជ្ជនាបញ្ហា ឲ្យរៀបចំយានពាហនៈសម្រាប់ដើរផ្លូវ រៀបចំពលនិកាយសម្រាប់ជាបរិវារនិងចាត់គ្រឿងរាជបណ្ណាការស្រេចហើយ ក៏ទ្រង់បញ្ជូនទៅក្នុងខណៈនោះឯង ឯសុចីរតព្រាហ្មណ៍ចេញអំពីព្រះនគរឥន្ទបត្តហើយ មិនបានទៅកាន់

នគរពារាណសីឡើយ ពួកបណ្ឌិតនៅក្នុងទីណាក៏ចូលទៅក្នុងទីនោះ មិនបាន ទទួលផល ពោលគឺការឆ្លើយបញ្ហាក្នុងជម្ពូទ្វីបទាំងមូលរហូតដល់ព្រះនគរពា-រាណសីដោយលំដាប់ កាន់យកទីស្នាក់មួយកន្លែង ទៅកាន់និវេសន៍របស់វិ-ធុរព្រាហ្មណ៍ មួយអន្លើដោយអ្នកបម្រើ ២-៣ នាក់ ក្នុងពេលអាហារព្រឹក ប្រាប់វិធុរៈក្នុងការដែលខ្លួនមក ឲ្យជ្រាប កាលវិធុរព្រាហ្មណ៍អញ្ជើញឲ្យចូល ទៅ ឃើញវិធុរព្រាហ្មណ៍កំពុងបរិភោគអាហារក្នុងផ្ទះរបស់ខ្លួន ។ កាលព្រះ បរមសាស្តាទ្រង់ប្រកាសអត្ថនោះឲ្យជាក់ច្បាស់ឡើងទើបត្រាស់គាថាទី ៧ ថា

សុចីរតព្រាហ្មណ៍ ជាការទ្វាជគោត្តនោះ បានទៅកាន់សំណាក់
នៃវិធុរព្រាហ្មណ៍ សុចីរតៈជាមហាព្រាហ្មណ៍ក៏បានឃើញវិធុរ-
ព្រាហ្មណ៍នោះកំពុងតែបរិភោគក្នុងផ្ទះរបស់ខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ស្វាធិប្បាគា** សេចក្តីថា សុចីរតព្រាហ្មណ៍ ការទ្វាជគោត្តនោះសំដៅទៅ គឺដល់ហើយ ។ បទថា **មហាព្រហ្មា** បានដល់ ព្រាហ្មណ៍ជាធំ ។ បទថា **អសមានំ** បានដល់ កំពុងបរិភោគ ។ សុចីរត-ព្រាហ្មណ៍នោះ កាលនៅជាកុមារជាសម្លាញ់នឹងវិធុរព្រាហ្មណ៍ រៀនសិប្បវិជ្ជា ក្នុងសម្នាក់អាចារ្យជាមួយគ្នា ព្រោះហេតុនោះទើបរួមទទួលទានអាហារជាមួយ វិធុរព្រាហ្មណ៍មួយរំពេច ក្នុងវេលាទទួលទានស្រេច អង្គុយសម្រាកសប្បាយ ហើយក៏សួរថា នែសម្លាញ់ ឯងមកមានធុរៈអ្វី កាលប្រាប់ហេតុដែលមកទើប ពោលគាថាទី ៨ ថា

ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះ

បាទធនញ្ជយកោរព្យ ជាយុធិដ្ឋិលគោត្ត ទ្រង់មានព្រះរាជឱង្ការ
ថា អ្នកចូរសួរនូវអត្ថនិងធម៌ បពិត្រវិធុរ អ្នកដែលខ្ញុំសួរហើយ
ចូរប្រាប់នូវអត្ថនិងធម៌នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រញ្ញោហំ** សេចក្តីថា ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏ទ្រង់យស ។ បទថា **បហិតោ** សេចក្តីថា ខ្ញុំត្រូវព្រះអង្គប្រើជាទូតទើបមកទីនេះ ។ បទថា **បុច្ឆេសិ** សេចក្តីថា ព្រះបាទធនញ្ជយរាជយុធិដ្ឋិលគោត្តនោះ ត្រាស់សួរបញ្ហាឈ្មោះធម្មយាគ ខ្ញុំមិនអាចនឹងឆ្លើយបាន ខ្ញុំដឹងថា សម្មាញ់អាច ទើបក្រាបទូលឲ្យទ្រង់ជ្រាប ទ្រង់ព្រះរាជទានគ្រឿងបណ្ណាការកាលទ្រង់បញ្ជូនខ្ញុំមកកាន់សម្នាក់របស់ឯងដើម្បីសួរបញ្ហា បានត្រាស់ថា ចូរអ្នកទៅកាន់សម្នាក់របស់វិធុរព្រាហ្មណ៍ សួរដល់គន្លងអត្ថនិងធម៌នៃបញ្ហានេះឥឡូវនេះយើងសួរអ្នកហើយ ចូរប្រាប់អត្ថនិងធម៌នោះ ។

ក្នុងកាលនោះវិធុរព្រាហ្មណ៍គិតថា អញនឹងកំណត់ចិត្តរបស់មហាជន ដូច្នេះ ទើបវិលនៅជាមួយការវិនិច្ឆ័យសេចក្តី ដូចគ្មានឹងរាំងនូវទឹកស្ទឹងគង្គាមិនមានឱកាសដែលឆ្លើយបញ្ហានោះបាន កាលនឹងប្រាប់សេចក្តីនោះទើបពោលគាថាទី ៩ ដោយសេចក្តីថា

ម្នាលព្រាហ្មណ៍ ខ្ញុំ ( គិតថា ) អញនឹងបិទនូវទន្លេគង្គា តែមិន
អាចបិទនូវទន្លេដ៏ធំនោះបាន ព្រោះហេតុនោះ ឱកាសនោះនឹង
មានដូចម្តេចកើត ខ្ញុំដែលអ្នកសួរហើយ មិនអាចដើម្បីប្រាប់
នូវអត្ថនិងធម៌បានទេ ដូច្នេះ ។

គាថានោះមានអធិប្បាយដូច្នេះថា នែសម្លាញ់ ខ្ញុំកើតនូវសេចក្តីកន្ទួល់ខ្វល់ខ្វាយថានឹងរាំងនូវស្នឹងគង្គា គឺគតិចិត្តផ្សេងៗគ្នានៃមហាជន ក៏មិនអាចរាំងសំឡេងខ្លាំងនោះបាន ព្រោះហេតុនោះ នឹងមានឱកាសបានដូចម្តេច កាលឱកាសមិនមាន យើងក៏វិសជ្ជនាចម្លើយបង្ហាញដល់ឯងមិនបាន កាលចិត្តមិននឹងធឹង នឹងមិនមានឱកាស ត្រូវអ្នកសួរក៏មិនអាចប្រាប់អត្ថនិងធម៌ ដល់អ្នកបាន ។ កាលវិធុរព្រាហ្មណ៍ពោលយ៉ាងនេះហើយទើបប្រាប់ថា កូនប្រុសរបស់ខ្ញុំជាអ្នកឈ្លាសវៃ មានបញ្ញាជាងខ្ញុំ គេនឹងព្យាករដល់ឯងបាន ចូរឯងទៅកាន់សម្នាក់របស់គេចុះ ដូច្នេះហើយបានពោលគាថាទី ១០ ថា

តែខ្ញុំមានកូនប្រុសមួយឈ្មោះភទ្រការ ជាឱរស ជាកូនបង្កើត
របស់ខ្ញុំ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះអ្នកចូរទៅសួរអត្ថនិង
ធម៌ចំពោះភទ្រការនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱរសោ** បានដល់ ចម្រើនហើយក្នុងទ្រូង ។ បទថា **អត្រជោ** បានដល់ កើតព្រោះខ្លួន ។

សុចីរតព្រាហ្មណ៍ស្តាប់ដូច្នោះ ទើបចេញចាកផ្ទះរបស់វិធុរព្រាហ្មណ៍ ទៅកាន់និវេសន៍របស់ភទ្រការមាណព ក្នុងពេលដែលគេទទួលទានអាហារស្រេចហើយអង្គុយក្នុងកណ្តាលបរិស័ទរបស់ខ្លួន ។

ព្រះបរមសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះទើបត្រាស់គាថាទី ១១ ថា

សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្តនោះ បានទៅកាន់សំណាក់
ភទ្រការកុមារ សុចីរតៈជាមហាព្រាហ្មណ៍បានឃើញភទ្រការ-

កុមារនោះកំពុងអង្គុយនៅក្នុងផ្ទះរបស់ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឃរេ** បានដល់ ក្នុងផ្ទះ ។ សុចីរតព្រាហ្មណ៍ទៅក្នុងទីនោះហើយដែលកទ្រការមាណាព រៀបចំទទួលនិងធ្វើសក្ការគោរព អង្គុយហើយសួរដល់ហេតុដែលមក ទើបពោលគាថាទី ១២ ដោយសេចក្ដីថា

ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្ត ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលកទ្រការកុមារ ព្រោះហេតុនោះអ្នកចូរប្រាប់នូវអត្ថនិងធម៌ដល់ខ្ញុំ ដូច្នេះ ។

លំដាប់នោះទើបកទ្រការមាណាព ពោលនឹងសុចីរតព្រាហ្មណ៍ថា បពិត្រលោកឪពុក ខ្ញុំប្រឡូកប្រឡំក្នុងបរទារិកកម្មរាល់ៗថ្ងៃ ចិត្តរបស់ខ្ញុំសៅហ្មងដោយហេតុនោះមិនអាចវិសជ្ជនាដល់លោកបានទេ តែប្អូនប្រុសរបស់ខ្ញុំឈ្មោះជាសញ្ជយកុមារ មានញាណប្រសើរជាងខ្ញុំក្រៃលែងណាស់ អញ្ជើញលោកសួរគេចុះ គេនឹងឆ្លើយបញ្ហាលោកបាន ដូច្នេះហើយកាលបញ្ជូនទៅកាន់សម្នាក់ប្អូនប្រុស បានពោល ២ គាថានេះថា

ខ្ញុំទើបទម្លាក់ចោលនូវអម្រែកសាច់ ហើយដេញតាមនូវទន្សោង ខ្ញុំដែលអ្នកសួរហើយមិនអាចនឹងប្រាប់នូវអត្ថនិងធម៌បានទេ ។

បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ ឈ្មោះសញ្ជ័យ បពិត្រសុចីរតព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរនូវអត្ថ

និងធម៌ចំពោះសញ្ជ័យនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មំសកាជំ** សេចក្តីថា បុរសរែកដុំសាច់ធ្វើដំណើរទៅជួបកូនទន្សង ក្នុងរវាងផ្លូវទើបចោលអម្រែកសាច់ ដេញតាមកូនទន្សងនោះយ៉ាងណា ខ្ញុំក៏យ៉ាងនោះដូចគ្នា បោះបង់កិរិយាដែលនៅក្នុងអំណាចក្នុងផ្ទះរបស់ខ្លួនមកជាប់ជំពាក់ក្នុងស្រីដែលអ្នកជទៃហួងហែង កាលកទ្រការ-មាណពសម្តែងដូច្នេះទើបពោលយ៉ាងនោះ ។

ក្នុងខណៈនោះឯងទើបសុចីរតព្រាហ្មណ៍ ទៅកាន់និវេសន៍របស់សញ្ជយ-កុមារ កាលសញ្ជយកុមារធ្វើសក្ការគោរពហើយ ត្រូវសួរដល់ហេតុដែលមកទើបប្រាប់ឲ្យជ្រាប ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់ព្រះគាថា ២ ដោយសេចក្តីថា

សុចីរតព្រាហ្មណ៍ជាការទ្វាជគោត្តនោះ បានទៅកាន់សំណាក់សញ្ជយកុមារ សុចីរតៈជាមហាព្រាហ្មណ៍បានឃើញនូវសញ្ជ-យកុមារនោះ អង្គុយក្នុងកណ្តាលបរិស័ទរបស់ខ្លួន ។

( ទើបពោលថា ) ខ្ញុំជាទូតព្រះបាទធនញ្ជយកោរព្យៈដ៏មានយសទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈជាយុធិដ្ឋិលគោត្តមានព្រះឱង្ការថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលសញ្ជយកុមារព្រោះហេតុនោះអ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌[១]

---

១-បិដកខ្មែរគាថានេះថា សុចីរតព្រាហ្មណ៍ជាអ្នកពោល តែក្នុងអដ្ឋកថា លោកប្រាប់ថាជាអភិសម្ពុទ្ធគាថាទាំងពីរ ទើបយើងយកមកភ្ជាប់ចូលគ្នា ។

ដូច្នេះ ។

ក្នុងកាលនោះសញ្ចយកុមារ កំពុងគប់រកកិរិយារបស់អ្នកដទៃនោះឯង លំដាប់នោះទើបប្រាប់សុចីរតព្រាហ្មណ៍ថា បពិត្រលោកឪពុក ខ្ញុំកំពុងគប់រកកិរិយាអ្នកដទៃ កាលគប់រកត្រូវជ្រងទឹកទៅកាន់ត្រើយនាយ មច្ចុ គឺសេចក្តីស្លាប់ រមែងលេបត្របាក់នូវខ្ញុំដែលកំពុងជ្រងស្ទឹង ទាំងព្រឹកទាំងល្ងាច ដោយហេតុនោះទើបចិត្តរបស់ខ្ញុំល្អក់កករ មិនអាចប្រាប់អត្ថនិងធម៌ដល់លោកបានទេ ខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះសម្ភវកុមារ កើតមកបាន ៧ ឆ្នាំ មានញាណក្រៃលែងជាងខ្ញុំរាប់រយដង រាប់ពាន់ដង រាប់សែនដង គេនឹងប្រាប់ដល់លោកបាន សូមលោកទៅសាកសួរចុះ កាលប្រកាសសេចក្តីនោះ បានពោល ២ គាថានេះ ថា

បពិត្រសុចីរតព្រាហ្មណ៍ មច្ចុតែងលេបខ្ញុំរាល់ល្ងាច រាល់ព្រឹក
សព្វៗកាល ខ្ញុំដែលអ្នកសួរហើយមិនអាចនឹងប្រាប់នូវអត្ថនិង
ធម៌ដល់អ្នកបានទេ ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុស
ម្នាក់ឈ្មោះសម្ភវៈ បពិត្រព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរ
ទៅសួរនូវអត្ថនិងធម៌ចំពោះសម្ភវៈនោះចុះ ដូច្នេះ ។

សុចីរតព្រាហ្មណ៍បានស្តាប់ដូច្នោះទើបគិតថាបញ្ហានេះនឹងជារបស់អស្ចារ្យក្នុងលោកនេះ ប្រហែលជាមិនមានអ្នកណាដែលអាចវិសជ្ជនាបញ្ហានេះបានទេ ហើយបានពោល ២ គាថានេះថា

ម្នាលអ្នកដ៏ចម្រើន បញ្ហាធម៌ក៏អស្ចារ្យម្ល៉េះ សម្ភវកុមារនេះ

យើងមិនពេញចិត្តទេ ព្រោះជន ៣ នាក់ ឪពុកនិងកូនទាំងនោះ មិនដឹងច្បាស់ដោយប្រាជ្ញាទៅហើយ ។ អ្នកទាំងឡាយដែលខ្ញុំសួរហើយ មិនអាចប្រាប់នូវអត្ថនិងធម៌បាន ចំណង់បើកូនក្មេងដែលខ្ញុំសួរអត្ថនិងធម៌ហើយ គប្បីដឹងដូចម្ដេចកើត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆាយំ** សេចក្ដីថា នេះជាបញ្ហាធម៌ ដែលគួរអស្ចារ្យ ឈ្មោះថាអ្នកដែលអាចឆ្លើយបញ្ហានេះបានមិនមានឡើយ ព្រោះហេតុនោះក្មេងដែលអ្នកពោលថានឹងឆ្លើយបាននេះមិនគាប់ចិត្តខ្ញុំឡើយ ។ **សុ** អក្ខរៈក្នុងបទថា **តេ សុ** នេះត្រឹមតែជានិបាត អធិប្បាយថា វិធុរព្រាហ្មណ៍ជាបណ្ឌិតក្ដី កទ្រការមាណពនិងសញ្ជយកុមារជាបុត្តក្ដី រួមជា ៣ នាក់ ទាំងបិតានិងបុត្ត គង់មិនដឹងច្បាស់ គឺគង់មិនជ្រាបច្បាស់នូវធម៌នេះដោយបញ្ញាបាន អ្នកដទៃណានឹងដឹង ។ បទថា **ឧ ឆំ** សេចក្ដីថា អ្នកទាំង ៣ ត្រូវសួរហើយគង់មិនអាចប្រាប់បាន ចំណង់បើកូនក្មេងអាយុ ៧ ឆ្នាំនឹងដឹងបានដូចម្ដេច គឺអាចដឹងបានដោយហេតុដូចម្ដេច ។

សញ្ជយកុមារបានស្ដាប់ដូច្នោះទើបចន្លលបង្ហាញថា លោកកុំយល់ថាសម្ភវកុមារជាកូនក្មេង បើលោកមានសេចក្ដីត្រូវការដោយការវិសជ្ជនាបញ្ហា សូមលោកទៅសាកសួរមើលចុះ កាលប្រកាសកិត្តិគុណនៃកុមារជាប្អូនប្រុសដោយលើកឧទាហរណ៍ឲ្យយល់ទើបពោលគាថា ១២ ថា

បពិត្រសុចីរតព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថា
នៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារទើបដឹងនូវ

អត្ថនិងធម៌ ។ ព្រះចន្ទប្រាសចាកមន្ទិល កាលដើរទៅតាមអាកាសធាតុ រុងរឿងកន្លងនូវពួកផ្កាយទាំងអស់ក្នុងលោកដោយពន្លឺយ៉ាងណាមិញ បពិត្រសុចីរតព្រាហ្មណ៍ សម្កវកុមារ ពិតជានៅក្មេងមែន ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយបញ្ញានិងការព្យាយាមក៏យ៉ាងនោះដែរ លោកកុំសំគាល់នូវសម្កវកុមារនោះ ថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្កវកុមារទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ បណ្តាខែខាងគិម្ហរដូវទាំងឡាយ ខែចេត្រ រុងរឿងដោយផ្កាឈើទាំងឡាយជាងខែទាំងឡាយដទៃឯទៀតយ៉ាងណាមិញ ។ សម្កវកុមារ ពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយបញ្ញានិងការព្យាយាមក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្កវកុមារនោះថានៅក្មេងហើយមិនសួរ ត្រូវតែសួរនូវសម្កវកុមារ ទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្នំគន្ធមាទនៈ មានទឹកសន្សើម ជាលំនៅនៃពពួកទេវតា ដេរដាសដោយដើមឈើផ្សេងៗទាំងឡាយផងដោយឱសថជាទិព្វ ទាំងឡាយផង រមែងញុំាងទិសទាំងឡាយឲ្យភ្លឺច្បាស់ផង ផ្សាយទៅកាន់ទិសទាំងឡាយ ( ដោយក្លិនក្រអូប ) ផងយ៉ាងណាមិញ ។ សម្កវកុមារពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយបញ្ញានិងការ

ព្យាយាមក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះ ថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្លើងប្រក្រតីប្រកបដោយអណ្ដាត មានអំណាច កាលឆេះនូវគុម្ពឈើក្នុងព្រៃមិនចេះឆ្អែត រមែងញុំាងពណ៌ខ្មៅឲ្យប្រព្រឹត្តទៅ ជាសភាវៈឆេះនូវខ្ញាញ់ មានផ្សែងជាទង់ ឆេះនូវដងព្រៃស្ដុក មានរបស់សម្រាប់ឆេះដ៏ច្រើន រមែងរុងរឿងលើកំពូលភ្នំ ក្នុងវេលាយប់ យ៉ាងណាមិញ ។ សម្ភវកុមារពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេងហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារទើបដឹងនូវអត្ថនិងធម៌ ។ ជនទាំងឡាយ ស្គាល់សេះដ៏ចម្រើនដោយល្បឿនផង ស្គាល់គោបម្រើក្នុងការផ្ទុកផង ស្គាល់មេគោដោយរីតនូវទឹកដោះផង ស្គាល់អ្នកប្រាជ្ញ កាលនិយាយផងយ៉ាងណាមិញ ។ សម្ភវកុមារ ពិតមែនតែនៅក្មេង ( តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស ) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះ ថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារទើបដឹងនូវអត្ថនិងធម៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជញ្ញា** បានដល់ នឹងបានដឹង ។ បទថា **ចន្ទោ** បានដល់ ព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។ បទថា **វិមលោ** សេចក្ដីថា ប្រាសចាកមន្ទិល មានពពកជាដើម ។ បទថា **ឯវម្បិ ទហរូបេតោ** សេចក្ដីថា សម្ពវកុមារនោះ ចូលដល់ភាពជាកុមារក៏ដូច្នោះ រមែងល្អរុងរឿងកន្លងនូវពន្លឺទាំងឡាយ កន្លងនូវបណ្ឌិតដ៏សេស ក្នុងផ្ទៃជម្ពូទ្វីបទាំងមូល ព្រោះប្រកបដោយបញ្ញា ។

បទថា **រម្មកោ** បានដល់ ខែចេត្រ ។ បទថា **អតេវញ្ញេហិ** សេចក្ដីថា ស្អាតជាងខែទាំង ១១ ដទៃៗក្រៃលែង ។ បទថា **ឯវំ** សេចក្ដីថា សូម្បីសម្ពវកុមារក៏ដូច្នោះរមែងល្អរុងរឿងព្រោះប្រកបដោយបញ្ញា ។ បទថា **ហិ-មវា** សេចក្ដីថា ភ្នំឈ្មោះថា ហិមៈ ព្រោះប្រកបដោយសន្សើម ក្នុងសម័យសន្សើមធ្លាក់ ។ម្យ៉ាងទៀត ឈ្មោះថា **ហិមវា** ព្រោះបញ្ចេញសន្សើមក្នុងគិម្ហរដូវ ភ្នំឈ្មោះថាគន្ធមាទន៍ ព្រោះញ៉ាំញីជនដែលមកជួបដោយគ្រឿងក្រអូប ។ បទថា **មហាភូតគណាលយោ** បានដល់ ជាទីលំនៅរបស់ពួកទេវតា ។ បទថា **ទិសា ភាតិ** សេចក្ដីថា ភ្នំឈ្មោះគន្ធមាទន៍នោះ រមែងធ្វើទិសទាំងពួងឲ្យភ្លឺរុងរឿងដូចគ្នា ។ បទថា **បវាតិ** សេចក្ដីថា រមែងផ្សាយទៅសព្វទិសទាំងពួងដោយគ្រឿងក្រអូប ។

បទថា **ឯវំ** សេចក្ដីថា សម្ពវកុមារនៅជាកុមារដូច្នោះ រមែងភ្លឺរុងរឿងនិងក្រអូបផ្សាយទៅគ្រប់ទិសទាំងពួង ព្រោះប្រកបដោយបញ្ញា ។ បទថា **យ-សស្សិមា** សេចក្ដីថា ភ្លើងព្រៃ ឈ្មោះថា **យសស្សិមា** ប្រែថា មានអណ្ដាត

រុងរឿង ព្រោះដល់ព្រមដោយតេជះ ។ បទថា **អច្ចិមាលី** សេចក្តីថា ភ្លើងព្រៃប្រកបទៅដោយអណ្តាត ។ បទថា **ជលមានោ វនេ គច្ឆេ** សេចក្តីថា រមែងឆេះរាលនូវព្រៃឈើក្នុងព្រៃធំ ពោលគឺគុម្ពឈើ ។ បទថា **អនលោ** បានដល់ មិនឆ្អែត ។ ឈ្មោះថា **កណ្ហវត្តនី** ព្រោះផ្លូវដែលភ្លើងឆេះទៅហើយមានពណ៌ខ្មៅ ។ ឈ្មោះថា **ឃតាសនោ** ព្រោះស៊ីនូវតក្កៈដោយអំណាចនៃគ្រឿងបូជាក្នុងយញ្ញវិធី ឈ្មោះថា **ធូមកេតុ** ព្រោះផ្សែងជាគ្រឿងសម្គាល់ដូចទង់ ។ បទថា **ឧត្តមាហេវនន្ទហោ** សេចក្តីថា ភ្លើងព្រៃ រមែងឆេះដងព្រៃខ្ពស់ៗដែលហៅថាព្រៃក្រាស់ ។ បទថា **និសីថេ** បានដល់ ក្នុងវេលាយប់ ។ បទថា **បព្វតគ្គស្មឹ** បានដល់ លើកំពូលភ្នំ ។ បទថា **ពហុតេជោ** បានដល់ មានឫទ្ធិតេជះច្រើន ។ បទថា **វិរោចតិ** សេចក្តីថា រមែងភ្លឺគ្រប់ទិសទាំងពួង ។ បទថា **ឯវំ** សេចក្តីថា សម្តេចព្រះកុមារប្អូនប្រុសរបស់ខ្ញុំ សូម្បីជាកុមារក៏ដូច្នោះ រមែងរុងរឿង កន្លងនូវបណ្ឌិតទាំងឡាយ ព្រោះប្រកបដោយបញ្ញា ។ បទថា **ភទ្រំ** សេចក្តីថា ជនទាំងឡាយស្គាល់សេះអាជានេយ្យព្រោះប្រកបទៅដោយថ្វីជើង មិនមែនព្រោះរូបរាង មុខមាត់ឡើយ ។ បទថា **វាហិយេ** សេចក្តីថា ជនទាំងឡាយស្គាល់គោបម្រើថា គោនេះប្រសើរពិតព្រោះនាំភារៈទៅបានក្នុងកាលភារៈដែលគប្បីនាំទៅ ។ បទថា **ទោហេន** សេចក្តីថា ស្គាល់មេគោទឹកដោះព្រោះដល់ព្រមដោយទឹកដោះ ។ ក្នុងបទថា **ភាសមានំ** នេះ សេចក្តីថា ស្គាល់ថាជាបណ្ឌិត ព្រោះវាចាផ្សេងៗ ។ អ្នកប្រាជ្ញគប្បីនាំពាលបណ្ឌិតសូត្រមកសម្តែងប្រកបផងចុះ ។

កាលសញ្ចយកុមារ សរសើរសម្ពវកុមារយ៉ាងនេះ សុចីរតព្រាហ្មណ៍គិតថា អញសួរបញ្ហាមើលហើយនឹងដឹងដូច្នេះ ទើបសួរថា នែកុមារ ប្អូនប្រុសរបស់ឯងនៅឯណា ។ លំដាប់នោះសញ្ចយកុមារក៏បើកបង្អួច យកដៃចង្អុលប្រាប់សុចីរតព្រាហ្មណ៍ថា នុ៎ះជាសម្ពវកុមារ បុគ្គលដែលមានពណ៌សម្បុរផូរផង់ ដូចគ្នានឹងមាសកំពុងលេងជាមួយក្មេងៗ ត្រង់ថ្នល់ក្បែរទ្វារប្រាសាទ នុ៎ះគឺប្អូនប្រុសរបស់ខ្ញុំ អញ្ជើញលោកទៅសាកសួរមើល គេនឹងប្រាប់បញ្ហាដល់លោកបានដោយពុទ្ធលីលា សុចីរតព្រាហ្មណ៍ស្តាប់ពាក្យសញ្ចយកុមារហើយចុះអំពីប្រាសាទទៅកាន់សម្នាក់របស់សម្ពវកុមារ ។ មានពាក្យសួរជៀតចូលមកថា ទៅក្នុងវេលាណា ឆ្លើយថា ក្នុងពេលដែលសម្ពវកុមារឈរដោះសំពត់ស្លៀកចេញ ពាក់ទុកត្រង់ក យកដៃទាំង ២ កើបដីលេង ។

ព្រះបរមសាស្តាកាលទ្រង់ធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ ទើបត្រាស់គាថាដោយសេចក្តីថា

> សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្តនោះ បានទៅកាន់សំណាក់
> នៃសម្ពវកុមារ សុចីរតៈជាមហាព្រាហ្មណ៍បានឃើញនូវសម្ពវ
> កុមារនោះកំពុងលេងខាងក្រៅទីលំនៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហីបុរេ** បានដល់ ខាងក្រៅផ្ទះ ។ ចំណែកព្រះមហាសត្វ ឃើញព្រាហ្មណ៍ឈរខាងមុខ ទើបសួរថា បពិត្រលោកឪពុកលោកមកដោយបំណងអ្វី កាលសុចីរតព្រាហ្មណ៍ប្រាប់ថា នែកុមារ យើងត្រាច់ទៅពេញជម្ពូទ្វីប ក៏មិនជួបបុគ្គលដែលអាចឆ្លើយបញ្ហាដែលយើងសួរបាន

ទើបមកកាន់សម្នាក់របស់ឯង ដូច្នេះហើយទើប ( សម្ភវកុមារ ) គិតថា បានឮថា បញ្ហាដែលបុគ្គលណាម្នាក់វិនិច្ឆ័យមិនបានក្នុងសកលជម្ពូទ្វីបធ្លាក់មកដល់សម្នាក់របស់អញ អញជាមនុស្សចាស់ដោយចំណេះដឹង ដូច្នេះហើយនឹកខ្មាសក្នុងចិត្ត ទើបបោះធូលីក្នុងដៃចោល ទាញសំពត់មកស្លៀក ហើយបវារណាដោយសព្វញ្ញុបវារណាថា អញ្ជើញលោកសួរមកចុះ ខ្ញុំនឹងប្រាប់ដោយពុទ្ធលីលា ។

លំដាប់នោះសុចីរតព្រាហ្មណ៍សួរបញ្ហាដោយគាថាដូច្នេះថា

ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្ត ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ នៃសម្ភវកុមារ ព្រោះហេតុនោះនាងឯងដែលខ្ញុំសួរហើយចូរប្រាប់នូវអត្ថនិងធម៌ ដូច្នេះ ។

អត្ថនៃបញ្ហានោះថា កិត្តិគុណនៃសម្ភវបណ្ឌិតបានប្រាកដដូចព្រះចន្ទ ក្នុងថ្ងៃ ១៥ កើត កណ្តាលហ្វូងតារាដូច្នោះ លំដាប់នោះសម្ភវកុមារ ក៏ពោលថា បើដូច្នោះសូមលោកចាំស្តាប់ កាលនឹងវិសជ្ជនាធម្មយាគប្បញ្ហា បានពោលគាថានេះថា

បើដូច្នោះ អ្នកឈ្លាសវៃ ( និយាយ ) យ៉ាងណា ខ្ញុំនឹងប្រាប់អ្នកយ៉ាងនោះ ព្រះរាជានឹងទ្រង់ជ្រាបនូវប្រស្នានោះទោះបីព្រះអង្គធ្វើតាមក្តី មិនធ្វើតាមក្តី ដូច្នេះ ។

កាលសម្ភវកុមារសម្តែងធម៌ក្នុងវាំងផ្លូវដោយសំឡេងដ៏ពីរោះ សំឡេងក៏

ខុរខ្មារទៅពេញនគរពារាណសីប្រមាណ ១២ យោជន៍ លំដាប់នោះព្រះរាជានិងឧបរាជជាដើម មកប្រជុំគ្នាហើយទើបព្រះមហាសត្វ ផ្តើមសម្តែងធម្មទេសនាក្នុងកណ្តាលមហាជន ។

បណ្តាបទទាំងនោះ បទថា **តគ្ឃ** ជាពាក្យអញ្ជើញឲ្យស្តាប់ការព្យាករបញ្ហាមួយចំណុច ។ បទថា **យថាបិ កុសលោ** សេចក្តីថា ព្រះមហាសត្វសម្តែងធម៌ដល់សុចីរតព្រាហ្មណ៍ថា ព្រះសព្វញ្ញូ ទ្រង់ឈ្លាសក្រៃលែងត្រាស់ប្រាប់យ៉ាងណា ខ្ញុំក៏នឹងប្រាប់ដល់លោកដោយចំណែកមួយយ៉ាងនោះ ។ បទថា **រាជា ច ខោ តំ** សេចក្តីថា សម្ភវកុមារពោលថា ខ្ញុំនឹងប្រាប់បញ្ហានោះដោយប្រការដែលព្រះរាជារបស់លោក ទ្រង់នឹងជ្រាបបានក្រៃលែងជាងនោះ ព្រះរាជាទ្រង់រមែងជ្រាបអត្ថនិងធម៌នោះបានយ៉ាងនេះ ទ្រង់ធ្វើតាមក្តី មិនធ្វើតាមក្តី បញ្ហានោះនឹងកើតមានដល់ទ្រង់ដែលជាអ្នកធ្វើតាម ឬមិនធ្វើតាមនោះឯង តែទោសកំហុសរបស់ខ្ញុំមិនមាន ។

កាលសម្ភវកុមារបេ្តជ្ញាការពោលបញ្ហាដោយគាថាយ៉ាងនេះហើយ ឥឡូវនេះកាលនឹងពោលធម្មយាគបញ្ហា ទើបពោលគាថាដោយសេចក្តីថា

> បពិត្រសុចីរតព្រាហ្មណ៍ បុគ្គលដែលព្រះរាជាសួរថា ( យើងធ្វើកុសល ) ក្នុងថ្ងៃនេះឬ គប្បីក្រាបទូលថា ក្នុងថ្ងៃស្អែកវិញ កាលបើសេចក្តីត្រូវការកើតឡើងហើយ ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្ត កុំធ្វើតាមពាក្យ ( នោះ ) ហើយនៅស្ងៀមឡើយ បុគ្គលដែលព្រះរាជាសួរហើយ គប្បីក្រាបបង្គំទូលនូវ

ខន្ធបញ្ចកៈជាខាងក្នុងតែម្យ៉ាង សូមព្រះរាជាកុំសេពនូវផ្លូវខុស ដូចបុគ្គលវង្វេងដោយឥតចេតនា ។ ព្រះរាជាកុំប្រព្រឹត្តកន្លងនូវអត្ថកាព កុំប្រព្រឹត្តនូវអធម៌ កុំចម្លងគេក្នុងទីមិនមែនជាកំពង់ កុំប្រកបក្នុងសេចក្តីវិនាសឡើយ ។ លុះតែក្សត្រិយ៍ណា ទ្រង់ជ្រាបហើយធ្វើនូវហេតុទាំងឡាយនេះ ព្រះរាជានោះទើបចម្រើនរាល់ពេល ដូចជាព្រះចន្ទក្នុងសុក្កបក្ខ ។ ព្រះរាជានោះប្រកបដោយប្រាជ្ញា រមែងជាទីស្រឡាញ់នៃពួកញាតិផង រុងរឿងក្នុងពួកមិត្តផង លុះបែកធ្លាយរាងកាយរមែងទៅកើតក្នុងឋានសួគ៌ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សំសេយ្យ** បានដល់ គប្បីក្រាបទូល ។ លោកពោលអធិប្បាយទុកដូច្នេះថា បពិត្រសុចីរតៈ បើបុគ្គលណា ត្រូវព្រះរាជារបស់ខ្លួនត្រាស់សួរថា ថ្ងៃនេះយើងនឹងឲ្យទាន រក្សាសីល ធ្វើឧបោសថដូច្នេះសោត គប្បីក្រាបទូលថា បពិត្រព្រះអង្គ ថ្ងៃនេះពួកខ្ញុំនឹងសម្លាប់សត្វនឹងបរិភោគកាម នឹងផឹកសុរាសិន ស្អែកនេះសឹមធ្វើបុណ្យ ធ្វើកុសល ព្រះរាជាដែលជាយុធិដ្ឋិលគោត្តរបស់លោក ទោះទ្រង់ធ្វើតាមពាក្យរបស់អាមាត្យធំនោះហើយ មិនគប្បីញ៉ាំងថ្ងៃនោះឲ្យកន្លងទៅដោយសេចក្តីប្រមាទក្នុងកាលប្រយោជន៍បែបនោះកើតឡើង ទ្រង់កុំធ្វើតាមពាក្យរបស់បុគ្គលនោះ រក្សានូវកុសលចិត្តដែលកើតឡើងហើយកុំឲ្យវិនាស ទ្រង់បំពេញកម្មដែលបដិសំយុត្តដោយកុសលតែម្យ៉ាង លោកគួរក្រាបទូលពាក្យនេះដល់ព្រះរាជារបស់លោក ។

ដោយគាថានេះព្រះមហាសត្វសម្តែងកត្តេករត្តិសូត្រថា **អជ្ជេវ កិច្ចមាតប្បំ កោជញ្ញា មរណំ សុវេ** ជាដើម សេចក្តីថា គួរធ្វើសេចក្តីព្យាយាមក្នុងថ្ងៃនេះ អ្នកណានឹងដឹងថា ការស្លាប់នឹងមានក្នុងថ្ងៃស្អែក និងសម្តែងឱវាទទាក់ទងដោយការមិនប្រមាទថា **អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ** ជាដើម សេចក្តីថា ការមិនប្រមាទជាផ្លូវមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ដោយប្រការដូច្នេះ ។ បទថា **អជ្ឈត្តញ្ចេវ** សេចក្តីថា បពិត្រសុចីរតៈ លោកត្រូវព្រះរាជាត្រាស់សួរថា សម្លាញ់បណ្ឌិត ត្រូវលោកសួរក្នុងធម្មយាគបញ្ហា ពោលដោះស្រាយដូចម្តេច គប្បីក្រាបទូលអជ្ឈត្តធម៌តែម្យ៉ាងដល់ព្រះរាជា គឺគប្បីក្រាបទូលដល់បញ្ចក្ខន្ធដែលជានិយកជ្ឈត្តធម៌ថា ជាវត្ថុមិនទៀង ព្រោះជារបស់មានហើយប្រែជាមិនមាន ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមហាសត្វសម្តែងអនិច្ចតាធម៌ជាក់ច្បាស់ដោយគាថា ( ក្នុងធម្មបទនិងទីឃនិកាយមហាវគ្គ ) យ៉ាងនេះថា

> កាលណាបុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង
> មិនទៀងដូច្នេះ កាលនោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ
> សង្ខារទាំងឡាយមិនទៀងហ្ន៎ មានកិរិយាកើតឡើងនិងការសូន្យ
> ទៅជាធម្មតា ដូច្នេះ ។

បទថា **កុម្មគ្គំ** សេចក្តីថា បពិត្រព្រាហ្មណ៍ បុគ្គលពាលល្ងង់ខ្លៅ តែងវង្វេង មិនមានការគិតរមែងសេពនូវផ្លូវខុស គឺទិដ្ឋិ ៦២ យ៉ាងណា ព្រះរាជារបស់លោក មិនគួរសេពផ្លូវខុសនោះ គួរសេពចំពោះកុសលកម្មបថ ១០

ដែលជានិយ្យានិកធម៌ លោកគួរក្រាបទូលទ្រង់យ៉ាងនេះ ។ បទថា **អត្តានំ** សេចក្តីថា ក្សត្រមិនគួរលះបង់នូវអត្តភាពដែលតាំងនៅក្នុងសុគតិ ជនទាំងឡាយលះនូវកុសលសម្បត្តិ ៣ ប្រការ ក្នុងកាមភព ហើយកើតក្នុងអបាយ ព្រោះកម្មណា ក្សត្រមិនគួរធ្វើកម្មនោះ ។ បទថា **អធម្មំ** សេចក្តីថា មិនគួរប្រព្រឹត្តអធម៌ ពោលគឺទុច្ចរិត ៣ យ៉ាង ។ បទថា **អតិត្ថេ** សេចក្តីថា មិនគួរចូល គឺមិនគួរឈមចុះក្នុងទីដែលមិនមែនកំពង់ ពោលគឺទិដ្ឋិ ៦២ ប្រការ បាឋៈថា **ឧ តារេយ្យ** ដូច្នេះក៏មាន ។ ឯសេចក្តី គឺមិនគួរញុំាងជនដែលដល់នូវទិដ្ឋានុគតិរបស់ខ្លួនឲ្យឈមចុះ ។ បទថា **អណត្ថេ** បានដល់ ក្នុងវត្ថុដែលមិនមែនហេតុ ។ បទថា **ឧ យុញ្ជេ** សេចក្តីថា មិនគួរខ្វល់ខ្វាយក្នុងវត្ថុឥតហេតុផល ។ ក្នុងសេចក្តីនេះមានពាក្យអធិប្បាយថា បើព្រះរាជារបស់លោកបំណងប្រព្រឹត្តក្នុងធម្មយាគប្បញ្ញា សូមទ្រង់ប្រព្រឹត្តក្នុងឱវាទនេះ លោកគួរក្រាបទូលទ្រង់ដោយប្រការដូច្នេះ ។

បទថា **សទា** បានដល់ អស់កាលប្រព្រឹត្តទៅជាប់តគ្នា លោកពោលអធិប្បាយទុកដូច្នេះថា ខត្តិយរាជអង្គណាទ្រង់ជ្រាប ដើម្បីធ្វើហេតុទាំងនេះ ខត្តិយរាជអង្គនោះទ្រង់រមែងចម្រើនសព្វកាល ដូចព្រះចន្ទខាងខ្នើតដូច្នោះ ។ បទថា **វិរោចតិ** សេចក្តីថា ទ្រង់រមែងរុងរឿងកណ្តាលមិត្តនិងអាមាត្យរបស់ទ្រង់ដោយគុណទាំងឡាយ មានសីល មារយាទ និងញាណជាដើម ។

ព្រះមហាសត្វ ពោលបញ្ហាដល់ព្រាហ្មណ៍ដោយពុទ្ធលីលា ដូចញុំាងព្រះចន្ទឲ្យប្រាកដឡើងកណ្តាលអាកាសដោយប្រការដូច្នេះ ។ មហាជនបានបន្លឺ

សំឡេងទះដៃ ធ្វើនូវសាធុការ ១០០០ ដង លើកទង់និងផ្ទាត់ម្រាមដៃឲ្យប្រព្រឹត្តទៅ ទាំងបន្សាត់ទៅនូវវត្ថុមានគ្រឿងប្រដាប់ដៃជាដើម ។ ទ្រព្យដែលមហាជនបន្សាត់ទៅហើយយ៉ាងនេះរាប់កោដិ ។ ព្រះរាជាក៏ព្រះរាជទានយសធំដល់សម្ភវកុមារនោះ ឯសុចីរតព្រាហ្មណ៍ធ្វើការបូជាដោយមាស ១០០០ ដុំ ហើយចារឹកពាក្យវិសជ្ជនាបញ្ហា ក្នុងក្រាំងមាសដោយជាតហិង្គុល ហើយធ្វើដំណើរទៅកាន់ឥន្ទបត្តនគរ ក្រាបទូលធម្មយាគប្បញ្ហាដល់ព្រះរាជា ។ ព្រះរាជាទ្រង់ប្រព្រឹត្តក្នុងធម៌នោះ ហើយញ៉ាំងស្ថានសួគ៌ឲ្យពេញបរិបូណ៌ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែង ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុន តថាគតក៏មានបញ្ញាច្រើនដូចគ្នា ដូច្នេះហើយទ្រង់ប្រជុំជាតកថា ព្រះបាទធនញ្ជយកោរព្យរាជក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ សុចីរតព្រាហ្មណ៍ក្នុងកាលនោះបានមកជាអនុរុទ្ធ វិធុរព្រាហ្មណ៍ក្នុងកាលនោះបានមកជាអរិយកស្សបៈ ភទ្រការកុមារក្នុងកាលនោះ បានមកជាមោគ្គល្លានសញ្ជយមាណពក្នុងកាលនោះ បានមកជាសារីបុត្ត ឯសម្ភវបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សម្ភវជាតក ចប់

# មហាកបិជាតក

[ ៤៩៩ ] ( ព្រះសាស្តាទ្រង់សំដែងថា ) ព្រះរាជាក្នុងក្រុងពារាណសី ព្រះអង្គញុំាងដែនរបស់ពួកជនអ្នកដែនកាសីឲ្យចម្រើន ព្រះអង្គមានពួកមិត្តនិងអាមាត្យហែហម ហើយស្តេចទៅកាន់មិគាជិនឧទ្យាន ។ បានទតឃើញព្រាហ្មណ៍ម្នាក់កើតឃ្លង់ស ឃ្លង់ពពាល កើតស្រែង មានសាច់លៀនចេញដូចជាផ្ការលួសផ្អុង ស្គម ឡើងសរសៃរវាម ក្នុងមិគាជិនឧទ្យាននោះ ។ ព្រះរាជាទ្រង់ទតឃើញជនមានសេចក្តីលំបាក ដល់នូវភាពគួរអាណិតក្រៃលែង ទ្រង់ស្ញើប ទ្រង់ត្រាស់សួរថា បណ្តាពួកយក្ស អ្នកជាយក្សអ្វី ។ ដៃនិងជើងរបស់អ្នកសផង ក្បាលរបស់អ្នកសលើសជាងដៃនិងជើងនោះផង ខ្លួនរបស់អ្នកមានសម្បុរពព្រុសផង មានស្រែងដ៏ច្រើនផង ។ ខ្នងរបស់អ្នករដិបរដុបដូចជាលួសដែលវៀចផង អវយវៈរបស់អ្នកដូចវល្លិលៃពនផង យើងមិនដែលឃើញបុគ្គលដទៃបែបនេះឡើយ ។ អ្នកមានជើងប្រឡាក់ដោយធូលី ជាអ្នកតក់ស្លុត ស្គម ឡើងសរសៃរវាម ស្រេកឃ្លាន មានសភាពជាអ្នកមិនឆ្អែត តើអ្នកមកអំពីទីណា នឹងទៅក្នុងទីណា ។ អ្នកជាបុគ្គលលំបាកមើលមិនមានទ្រង់ទ្រាយ មានសម្បុរមិនល្អ មើលទៅគួរខ្លាច សូម្បីតែមាតាបង្កើតរបស់អ្នកក៏មិនចង់ឃើញអ្នកដែរ ។ អ្នកបានធ្វើនូវអំពើដូចម្តេចក្នុងកាលមុន អ្នកបានបៀតបៀននូវសត្វដែលមិនគួរសម្លាប់ដូចម្តេច អ្នកធ្វើនូវអំពើអាក្រក់ណាក៏បាននូវសេចក្តីទុក្ខនេះ ។

[ ៥០០ ] ( ព្រាហ្មណ៍ក្រាបបង្គំទូលថា ) បើដូច្នោះ អ្នកឈ្លាសវៃ

( និយាយ ) យ៉ាងណា ទូលព្រះបង្គំជាខ្ញុំ នឹងទូលយ៉ាងនោះ ព្រោះថាក្នុងលោកនេះ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលអ្នកនិយាយពាក្យពិត ។ ទូលព្រះបង្គំជាខ្ញុំតែម្នាក់ឯង កាលដើររកគោ ក៏វង្វេងដើរចូលទៅក្នុងព្រៃសូន្យសុង ជាព្រៃជាប់ទឹក ព្រៃស្ងាត់ឈឹងដែលពួកដំរីផ្សេងៗនៅហើយ ។ ទូលព្រះបង្គំជាខ្ញុំ វង្វេងផ្លូវក្នុងព្រៃដែលពួកម្រឹគកាចដើរទៅមក ជាអ្នកមានសេចក្តីស្រេកឃ្លានអស់ ៧ ថ្ងៃ ដើរទៅក្នុងព្រៃនោះ ។ ទូលព្រះបង្គំជាខ្ញុំ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ ក៏បានឃើញដើមទន្លាប់ក្នុងព្រៃនោះ ដុះនៅក្នុងទីមិនស្មើ សំយុងទៅកាន់ជ្រោះ ជាឈើទ្រទ្រង់នូវផ្លែមានរសផ្អែម ។ ទូលព្រះបង្គំជាខ្ញុំ បានទទួលទានផ្លែឈើទាំងឡាយដែលខ្យល់បក់ធ្លាក់ចុះមក ផ្លែឈើទាំងនោះ ពេញចិត្តទូលព្រះបង្គំជាខ្ញុំយ៉ាងក្រៃលែង ទូលព្រះបង្គំជាខ្ញុំមិនឆ្អែត ក៏ឡើងលើដើម ដោយគិតថានឹងស៊ីឲ្យឆ្អែតស្កប់ស្កល់លើដើមនោះ ។ ទូលព្រះបង្គំជាខ្ញុំ ទទួលទានផ្លែទន្លាប់មួយហើយ ប្រាថ្នាផ្លែជាគម្រប់ពីរទៀត លំដាប់នោះមែកឈើនោះក៏បាក់ហាក់ដូចជាគេកាប់នឹងប៉ូវថៅ ។ ទូលព្រះបង្គំជាខ្ញុំនោះ ក៏ជាប់មកជាមួយនឹងមែកឈើ មានជើងឡើងលើ មានក្បាលចុះក្រោម ធ្លាក់ចុះទៅក្នុងជ្រោះភ្នំដែលមិនមានទីឈរ មិនមានទីតោង ។ ទឹកជ្រៅមានត្រឹមណា ទូលព្រះបង្គំជាខ្ញុំមិនធ្លាក់ដល់ត្រឹមណោះទេ មិនមានសេចក្តីត្រេកអរ មិនមានទីពឹង ដេកក្នុងជ្រោះនោះអស់ ១០ រាត្រីគត់ ។ គ្រានោះស្វាមានកន្ទុយដូចជាកន្ទុយគោ ត្រាច់ទៅតាមជ្រោះភ្នំមកដល់ទីនោះ លោតពីមែកមួយទៅកាន់មែកមួយបានស៊ីនូវផ្លែឈើ ស្វានោះបានឃើញនូវទូលព្រះ-

បន្ទំជាខ្ញុំដែលស្គមស្លេកស្លាំង ក៏ធ្វើនូវសេចក្តីករុណាចំពោះទូលព្រះបង្គំជាខ្ញុំ ។ សួរថា ម្នាលអ្នកដ៏ចម្រើន អ្នកឯងនេះជាអ្វី ត្រូវទុក្ខគ្របសង្កត់ក្នុងទីនេះយ៉ាងនេះ អ្នកជាមនុស្សឬមិនមែនមនុស្ស ចូរប្រាប់ខ្លួនដល់យើង ។ ទូលព្រះ-បង្គំជាខ្ញុំ ក៏ប្រណម្យអញ្ជលីចំពោះស្វានោះ ហើយពោលនូវពាក្យនេះថា ខ្ញុំជាមនុស្សដល់នូវអំណាចនៃ ( សេចក្តីវិនាស ) ខ្ញុំទៅអំពីទីនេះ មិនបានទេ ព្រោះហេតុនោះ ខ្ញុំជម្រាបអ្នក សូមសេចក្តីចម្រើនមានដល់អ្នក សូមអ្នកជាទីពឹងរបស់ខ្ញុំ ។ ស្វាដ៏ប្រសើរត្រាច់ទៅលើភ្នំក៏យកនូវថ្មដ៏ធ្ងន់ ចង់ខ្សែនឹងថ្មហើយពោលនូវពាក្យនេះថា អ្នកចូរមក ចូរឡើងជិះខ្នងខ្ញុំ ហើយតោងកខ្ញុំដោយដៃទាំងពីរ ខ្ញុំនឹងស្រង់អ្នកចាកជ្រោះភ្នំដោយកម្លាំង ។ ទូលព្រះបង្គំជាខ្ញុំបានឮពាក្យស្តេចស្វាដ៏មានសិរីនោះ ក៏ឡើងជិះខ្នងនៃស្វាជាអ្នកប្រាជ្ញ ហើយតោងកដោយដៃទាំងពីរ ។ ស្វានោះមានតេជះ មានកម្លាំង នឿយហត់ដោយសេចក្តីលំបាក បានស្រង់ទូលព្រះបង្គំជាខ្ញុំចាកជ្រោះភ្នំដោយរហ័ស ។ ស្វាជាសប្បុរសដ៏ប្រសើរ លុះស្រង់ទូលព្រះបង្គំជាខ្ញុំរួចហើយ ក៏ពោលនូវពាក្យនេះថា នែសម្លាញ់ អ្នកចូររក្សានូវខ្ញុំផង ខ្ញុំនឹងសម្រាកមួយរំពេច ។ បើពួកសត្វរាជសីហ៍ក្តី ពួកខ្លាធំក្តី ពួកខ្លាដំបងក្តី ពួកខ្លាឃ្មុំក្តី ពួកឆ្កែព្រៃក្តី ពួកខ្លារខិនក្តី ពួកសត្វកាចទាំងនោះ មកបៀតបៀនខ្ញុំដែលធ្វេសប្រហែសហើយ បើអ្នកឃើញនូវសត្វសាហាវទាំងនោះ ចូររារាំងផង ។ ស្វានោះត្រូវទូលព្រះបង្គំ-ជាខ្ញុំការពារយ៉ាងនេះហើយក៏ដេកលក់មួយស្របក់ទៅ គ្រានោះទូលព្រះបង្គំ-ជាខ្ញុំបានទិដ្ឋិដ៏លាមកដោយមិនត្រូវទំនងថា ស្វានេះជាអាហាររបស់ពួកមនុស្ស

ដូចពួកម្រឹគដទៃក្នុងព្រៃដែរ បើដូច្នោះអាត្មាអញឃ្លានហើយ គប្បីសម្លាប់នូវស្វានេះស៊ី ។ អញស៊ីហើយនឹងយកសាច់ជាស្បៀងដើរទៅ នឹងឆ្លងផ្លូវឆ្ងាយ ស្បៀងអញក៏មានស្រាប់ ។ លំដាប់នោះទូលព្រះបង្គំជាខ្ញុំ ចាប់យកដុំថ្មគប់ក្បាល ( ស្វានោះ ) កាលទូលព្រះបង្គំជាខ្ញុំលំបាកដោយបាយ ការប្រហារក៏មានកម្លាំងថយ ។ ឯស្វានោះក៏ស្ទុះក្រោកឡើងដោយរហ័ស ប្រឡាក់ដោយឈាម មានភ្នែកពេញដោយទឹកភ្នែក យំសម្លឹងមើលទូលព្រះបង្គំជាខ្ញុំ ។ និយាយថា បពិត្រអ្នកដ៏ចម្រើន អ្នកជាម្ចាស់ កុំធ្វើបាបខ្ញុំឡើយ អ្នកឯងធ្វើអំពើអាក្រក់បែបនេះ ម្នាលអ្នកដ៏មានអាយុវែង អ្នកឯងគួរតែហាមឃាត់នូវពួកសត្វដទៃ ។ ឃើអើហ្ន៎ នែបុរសចង្រៃ ជាមនុស្សធ្វើអំពើអាក្រក់ដល់ម៉្លេះ អញបានស្រង់ឯង ឲ្យរួចពីជ្រោះជ្រៅស្រឡូងបែបនេះ ។ អញនាំអ្នកឯងមក ( នេះ ) ដូចជានាំមកពីបរលោក អ្នកឯងសំគាល់យើងថា គួរប្រទូស្តអំពើដ៏លាមកនោះ អ្នកឯងនោះជាមនុស្សលាមក ជាមនុស្សបាបគិតហើយ ។ នែអ្នកមិនបិតនៅក្នុងធម៌ អ្នកឯងកុំប៉ះពាល់នូវទុក្ខវេទនាដ៏ខ្លោចផ្សាឡើយ អំពើដ៏លាមកនោះ កុំសម្លាប់អ្នកឯងដូចជាផ្លែឫស្សីដែលសម្លាប់ដើមឯងវិញឡើយ ។ នែអ្នកជាមនុស្សមានធម៌ដ៏លាមក មិនសង្រួម យើងលែងមានសេចក្តីទុកចិត្តចំពោះអ្នក អ្នកឯងចូរមក អ្នកឯងចូរមានសរីរៈប្រាកដក្នុងទីជិត ដើរតាមក្រោយយើងចុះ ។ អ្នកឯងរួចផុតពីកណ្តាប់ដៃនៃពួកម្រឹគកាចហើយ អ្នកឯងបានដល់ឧបចារៈជារបស់នៃមនុស្សហើយ នែអ្នកមិនបិតនៅក្នុងធម៌ នុ៎ះផ្លូវអ្នកឯង ចូរដើរទៅឲ្យសុខសប្បាយតាមផ្លូវនោះចុះ ។ ស្វាដែលត្រាច់ទៅលើភ្នំ លុះបានពោលពាក្យនេះហើយទើបលាងឈាមក្បាលរបស់ខ្លួន ហើយជូត

ទឹកក្អែកឲ្យជ្រះ លំដាប់នោះក៏លោតឡើងទៅលើភ្នំ ។ ទូលព្រះបង្គំជាខ្ញុំនោះ ជាបុគ្គលដែលស្វានោះផ្តាសាហើយ ត្រូវសេចក្តីក្តៅក្រហាយបៀតបៀន មានខ្លួនក្តៅអន្ទះអន្ទែង បានចូលទៅរកទទួលទានទឹក ។ អន្លង់ទឹកទាំងអស់ក៏ក្តៅសព្វហាក់ដូចជាភ្លើងឆេះ ជាអន្លង់ហាក់ដូចជាប្រឡាក់ឈាម ហាក់ដូចជាខ្ទុះនិងឈាមប្រាកដដល់ខ្ញុំ ។ ដំណក់ទឹកមានចំនួនប៉ុន្មាន ស្រក់លើកាយរបស់ទូលព្រះបង្គំជាខ្ញុំ បូសមានចំនួនប៉ុណ្ណោះប្រាកដស្មើដោយផ្លែព្នៅមួយចំហៀងក៏កើតឡើង ។ ទូលព្រះបង្គំជាខ្ញុំទៅក្នុងស្រុកនិងនិគមទាំងឡាយតាមផ្លូវណាៗ បូសទាំងឡាយក៏បែកធ្លាយខ្ទុះនិងឈាមដ៏ស្អុយហូរចេញ ( ពីសរីរៈ ) របស់ទូលព្រះបង្គំជាខ្ញុំ ( តាមផ្លូវនោះៗ ) ។ ពួកស្ត្រីនិងបុរស មានដំបងក្នុងដៃដែលត្រូវក្លិនស្អុយគ្របសង្កត់ហើយ ឃាត់ទូលព្រះបង្គំជាខ្ញុំថា អ្នកឯងកុំចូលមកខាងអាយឡើយ ។ សេចក្តីទុក្ខលំបាកនេះប្រាកដដូច្នេះមានដល់ទូលព្រះ-បង្គំជាខ្ញុំអស់ ៧ ឆ្នាំ ហើយដល់មកឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំនៅតែទទួលផលកម្មជារបស់ខ្លួនដែលខ្លួនធ្វើអាក្រក់ហើយក្នុងកាលមុន ។ ព្រោះហេតុនោះ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលចំពោះព្រះអង្គ សូមសេចក្តីចម្រើនមានដល់ព្រះអង្គ ពួកអ្នកដែលមកចួបជុំគ្នាក្នុងទីនេះ សូមកុំប្រទូស្តពួកមិត្តឡើយ ព្រោះថាបុគ្គលប្រទូស្តមិត្តជាមនុស្សអាក្រក់ ។

( អភិសម្ពុទ្ធគាថា ) បុគ្គលណាប្រទូស្តមិត្តទាំងឡាយ ក្នុងលោកនេះ បុគ្គលនោះ រមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

**ចប់ មហាកបិជាតក ទី ៦**

# អដ្ឋកថា
# មហាកបិជាតក

[ ៤៩៩-៥០០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការប្រមៀលថ្មរបស់ទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពារាណស្យំ អហុ រាជា** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា កាលភិក្ខុទាំងឡាយនាំគ្នាពោលនិន្ទាទេវទត្ត ព្រោះប្រើនាយខ្មាន់ធ្នូ ព្រោះប្រមៀលថ្ម ក្នុងកាលតមកទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនទេវទត្តក៏ប្រមៀលថ្មដើម្បីសម្លាប់តថាគតដូចគ្នា ហើយទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីក្នុងស្រុកកាសិកគាម ព្រាហ្មណ៍អ្នកស្រែម្នាក់ភ្ជួរស្រែស្រេចហើយ លែងគោទៅ ផ្តើមធ្វើការងារ ជីកស្នោ ជ្រួយដីដោយចប ។ ហ្វូងគោទំពាស៊ីស្លឹកឈើត្រង់គុម្ពឈើមួយកន្លែង នាំគ្នាគេចចូលព្រៃដោយលំដាប់ ។ ព្រាហ្មណ៍គិតថាដល់ពេលហើយក៏ដាក់ចប សម្លឹងមើលហ្វូងគោក៏មិនឃើញកើតនូវទោមនស្សទើបដើររកក្នុងព្រៃ ចូលដល់ព្រៃហិមពាន្ត ។ ព្រាហ្មណ៍នោះវង្វេងផ្លូវក្នុងព្រៃហិមពាន្ត អត់អាហារ ៧ ថ្ងៃ ដើរមក ជួបដើមទន្លាប់មួយដើមទើបឡើងទៅបេះផ្លែបរិភោគ រអិលធ្លាក់ពីដើមទន្លាប់ រមៀលចូលទៅក្នុងជ្រោះ ដូចរណ្តៅនរក ដែលមានជម្រៅ ៦០ ហត្ថ ។ ព្រាហ្មណ៍ធ្លាក់ក្នុងជ្រោះអស់ ១០ ថ្ងៃ

កាលនោះព្រះពោធិសត្វយោនយកកំណើតជាស្វា កំពុងទំពាស៊ីផ្លែឈើ ក្រឡេកឃើញបុរសនោះទើបចងខ្សែត្រង់ថ្មទម្លាក់ទៅជួយបុរសនោះ ឡើងមកបាន ។ កាលពានរពោធិសត្វកំពុងដេកលក់ ព្រាហ្មណ៍បានយកដុំថ្មគប់ត្រង់ក្បាល ។ ព្រះពោធិសត្វដឹងការធ្វើរបស់ព្រាហ្មណ៍នោះទើបលោតឡើងមែកឈើ ពោលថា នែសម្លាញ់ ចូរលោកដើរទៅតាមផែនដី ខ្ញុំនឹងប្រាប់ផ្លូវដល់លោកតាមចុងឈើ ហើយនាំបុរសនោះចេញអំពីព្រៃរហូតដល់ផ្លូវ ទើបទៅកាន់បព៌តវិញ ។ បុរសនោះបំពានលើព្រះពោធិសត្វហើយ ក៏កើតរោគឃ្លង់ ក្លាយជាមនុស្សប្រេតក្នុងបច្ចុប្បន្នទាន់ភ្នែកនោះឯង ។ គាត់ត្រូវសេចក្ដីទុក្ខបៀតបៀនអស់ ៧ ឆ្នាំ ត្រាច់ច្រេចូទៅដល់មិគាជិនឧទ្យាន នគរពារាណសី ក្រាលស្លឹកចេកខាងក្នុងកំពែង ដេកសោយទុក្ខវេទនា ។ គ្រានោះព្រះបាទពារាណសី ទ្រង់ប្រពាតព្រះរាជឧទ្យាន យាងទៅជួបក្នុងទីនោះ ហើយត្រាស់សួរថា ឯងជានរណា ឯងធ្វើកម្មអ្វីទុកទើបទទួលទុក្ខបែបនេះ ឯមនុស្សប្រេតនោះ បានក្រាបទូលរឿងទាំងអស់ដោយពិស្ដារ ។

ព្រះបរមសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់គាថាដោយសេចក្ដីថា

ព្រះរាជាក្នុងក្រុងពារាណសី ព្រះអង្គញ៉ាំងដែនរបស់ពួកជន
អ្នកដែនកាសីឲ្យចម្រើន ព្រះអង្គមានពួកមិត្តនិងអាមាត្យហែ-
ហម ហើយស្ដេចទៅកាន់មិគាជិនឧទ្យាន ។ បានទតឃើញ
ព្រាហ្មណ៍ម្នាក់កើតឃ្លង់ស ឃ្លង់ពពាល កើតស្រែង មានសាច់

លៀនចេញ ដូចជាផ្ការលួសផង ស្គមឡើងសរសៃវ៉ាមក្នុងមិគាជិនឧទ្យាននោះ ។ ព្រះរាជាទ្រង់ទតឃើញជនមានសេចក្តីលំបាកដល់នូវភាពគួរអាណិតក្រៃលែង ទ្រង់ស្ញើប ទ្រង់ត្រាស់សួរថា បណ្តាពួកយក្ស អ្នកជាយក្សអ្វី ។ ដៃនិងជើងរបស់អ្នកសផង ក្បាលរបស់អ្នក សលើសជាងដៃនិងជើងនោះផង ខ្លួនរបស់អ្នកមានសម្បុរពព្រុសផង មានស្រែងដ៏ច្រើនផង ។ ខ្នងរបស់អ្នករជីបរជុប ដូចជាលួសដែលវៀចផង អវយវៈរបស់អ្នកដូចវល្លិលែនពែនផង យើងមិនដែលឃើញ បុគ្គលដទៃបែបនេះឡើយ ។ អ្នកមានជើងប្រឡាក់ដោយធូលី ជាអ្នកតក់ស្លុត ស្គមឡើងសរសៃវ៉ាម ស្រេកឃ្លាន មានសភាពជាអ្នកមិនឆ្អែត តើអ្នកមកអំពីទីណា នឹងទៅក្នុងទីណា ។ អ្នកជាបុគ្គលលំបាកមើលមិនមានទ្រង់ទ្រាយ មានសម្បុរមិនល្អ មើលទៅគួរខ្លាច សូម្បីតែមាតាបង្កើតរបស់អ្នក ក៏មិនចង់ឃើញអ្នកដែរ ។ អ្នកបានធ្វើនូវអំពើដូចម្តេចក្នុងកាលមុន អ្នកបានបៀតបៀននូវសត្វដែលមិនគួរសម្លាប់ដូចម្តេច អ្នកធ្វើនូវអំពើអាក្រក់ណា ក៏បាននូវសេចក្តីទុក្ខនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពារាណស្យំ** បានដល់ ក្នុងនគរពារាណសី ។ បទថា **មិត្តាមច្ចបរិព្យូឡ្ហោ** សេចក្តីថា ទ្រង់ចោមរោមដោយមិត្តនិងអាមាត្យដែលមានភក្តីមាំទាំ ។ បទថា **មិគាជិនំ** បានដល់ ព្រះឧទ្យាន ដែលមាន

ឈ្មោះយ៉ាងនេះ ។ បទថា **សេតំ** សេចក្តីថា បានទតឃើញព្រាហ្មណ៍ដេក លើស៊ឹកចេក ។ ឈ្មោះថា យូង់ស ព្រោះរោគយូង់ពណ៌ស ឈ្មោះថា យូង់ ពពាល ព្រោះរោគយូង់ល្ពៅ ឈ្មោះថា ស្រែង ព្រោះជាស្រែងដែលបែកទឹក វេងសោយនូវទុក្ខវេទនា ។

បទថា **វិទ្ធស្តំ កោវិឡារំវ** សេចក្តីថា ដេរដាសទៅដោយសាច់ដែល របេះអំពីមុខដំបៅ ដូចគ្នានឹងផ្ការលួសផ្អុង ដែលរីកហើយ ។ បទថា **កីសំ** សេចក្តីថា ក្នុងចំណែកខ្លះមានសរីរៈសល់តែស្បែកដណ្តប់ឆ្អឹង ស្គាំងស្គមរវាម ដោយសរសៃ ។ បទថា **ព្យម្ហិតោ** សេចក្តីថា ព្រះរាជាទ្រង់ស្ញើប គឺតក់ស្លុត ក្នុងព្រះហឫទ័យ ។ បទថា **យក្ខានំ** សេចក្តីថា ព្រះរាជាត្រាស់សួរថា បណ្តា ពួកយក្ខទាំងឡាយ អ្នកជាយក្ខប្រភេទណា ។ បទថា **វដ្ដនាវលិសង្កាសា** សេចក្តីថា ខ្នងរបស់អ្នកមានពកជាដុំៗ ដូចគ្នានឹងវល្លិដែលគេវេញ ។ បទថា **អង្គា** សេចក្តីថា អវយវៈទាំងឡាយរបស់អ្នកខ្មៅ ក្រិកក្រូក់ដូចវល្លិលែនពែន ។ បទថា **នាញ្ញំ** សេចក្តីថា យើងមិនឃើញអ្នកដទៃមានលក្ខណៈបែបនេះ ។ បទថា **ឧគ្ឃដ្ដចាតោ** បានដល់ មានជើងប្រឡាក់ដោយធូលី ។

បទថា **អាតិត្ថរូចោ** បានដល់ មានរាងកាយស្គាំងស្គម ។ បទថា **ធុន្ធុសី** សេចក្តីថា សម្លឹងមើលគួរខ្ពើម ។ បទថា **អប្បកាកាសិ** សេចក្តីថា មាន រាងកាយមិនស្អាតអាក្រក់ពន់ពេក ។ បទថា **កឹ កម្មមករា** សេចក្តីថា ក្នុង ជាតិនេះ អ្នកបានធ្វើកម្មអ្វីទុក ។ បទថា **កិព្វិសំ** បានដល់ កម្មដែលគ្រោត គ្រាត ។

បន្ទាប់អំពីនោះទើបព្រាហ្មណ៍ក្រាបទូលថា

បើដូច្នោះអ្នកឈ្មោសវៃ ( និយាយ ) យ៉ាងណា ទូលព្រះបង្គំជាខ្ញុំនឹងទូលយ៉ាងនោះ ព្រោះថាក្នុងលោកនេះអ្នកប្រាជ្ញទាំងឡាយតែងសរសើរបុគ្គលអ្នកនិយាយពាក្យពិត ។ ទូលព្រះបង្គំជាខ្ញុំតែម្នាក់ឯង កាលដើររកគោ ក៏វង្វេងដើរចូលទៅក្នុងព្រៃស្ងាត់ ជាព្រៃជាច់ទឹក ព្រៃស្ងាត់ឈឹង ដែលពួកដំរីផ្សេងៗនៅហើយ ។ ទូលព្រះបង្គំជាខ្ញុំ វង្វេងផ្លូវក្នុងព្រៃដែលពួកម្រឹគកាចដើរទៅមក ជាអ្នកមានសេចក្ដីស្រេកឃ្លាន អស់ ៧ ថ្ងៃដើរទៅក្នុងព្រៃនោះ ។ ទូលព្រះបង្គំជាខ្ញុំ ត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ ក៏បានឃើញដើមទន្លាប់ក្នុងព្រៃនោះ ដុះនៅក្នុងទីមិនស្មើ សំយុងទៅកាន់ជ្រោះ ជាឈើទ្រទ្រង់នូវផ្លែមានរសផ្អែម ។ ទូលព្រះបង្គំជាខ្ញុំបានទទួលទានផ្លែឈើទាំងឡាយដែលខ្យល់បក់ធ្លាក់ចុះមក ផ្លែឈើទាំងនោះពេញចិត្តទូលព្រះបង្គំជាខ្ញុំយ៉ាងក្រៃលែង ទូលព្រះបង្គំជាខ្ញុំមិនឆ្អែត ក៏ឡើងលើដើមដោយគិតថានឹងស៊ីឲ្យឆ្អែតស្កប់ស្កល់ លើដើមនោះ ។ ទូលព្រះបង្គំជាខ្ញុំ ទទួលទានផ្លែទន្លាប់មួយហើយ ប្រាថ្នាផ្លែជាគម្រប់ពីរទៀត លំដាប់នោះមែកឈើនោះក៏បាក់ហាក់ដូចជាគេកាប់នឹងប៉ូវថៅ ។ ទូលព្រះបង្គំជាខ្ញុំនោះក៏ជាប់មកជាមួយនឹងមែកឈើ មានជើងឡើងលើ មានក្បាលចុះក្រោម ធ្លាក់ចុះ

ទៅក្នុងជ្រោះភ្នំដែលមិនមានទីឈរ មិនមានទីតោង ។ ទឹកជ្រៅមានត្រឹមណា ទូលព្រះបង្គំជាខ្ញុំមិនធ្លាក់ដល់ត្រឹមណោះទេ មិនមានសេចក្ដីត្រេកអរ មិនមានទីពឹង ដេកក្នុងជ្រោះនោះអស់ ១០ រាត្រីគត់ ។ គ្រានោះស្វាមានកន្ទុយដូចជាកន្ទុយគោ ត្រាច់ទៅតាមជ្រោះភ្នំមកដល់ទីនោះ លោតពីមែកមួយទៅកាន់មែកមួយ បានស៊ីនូវផ្លែឈើ ស្វានោះបានឃើញនូវទូលព្រះបង្គំ-ជាខ្ញុំដែលស្គមស្លេកស្លាំង ក៏ធ្វើនូវសេចក្ដីករុណាចំពោះទូល-ព្រះបង្គំជាខ្ញុំ ។ សួរថា ម្នាលអ្នកដ៏ចម្រើន អ្នកឯងនេះជាអ្វីត្រូវទុក្ខគ្របសង្កត់ក្នុងទីនេះយ៉ាងនេះ អ្នកជាមនុស្សឬមិនមែនមនុស្ស ចូរប្រាប់ខ្លួនដល់យើង ។ ទូលព្រះបង្គំជាខ្ញុំ ក៏ប្រ-ណម្យអញ្ជលីចំពោះស្វានោះ ហើយពោលនូវពាក្យនេះថា ខ្ញុំជាមនុស្សដល់នូវអំណាចនៃ ( សេចក្ដីវិនាស ) ខ្ញុំទៅអំពីទីនេះមិនបានទេ ព្រោះហេតុនោះខ្ញុំជម្រាបអ្នក សូមសេចក្ដីចម្រើនមានដល់អ្នក សូមអ្នកជាទីពឹងរបស់ខ្ញុំ ។ ស្វាដ៏ប្រសើរ ត្រាច់ទៅលើភ្នំក៏យកនូវថ្មដ៏ធ្ងន់ ចងខ្សែនឹងថ្ម ហើយពោលនូវពាក្យនេះថា អ្នកចូរមក ចូរឡើងជិះខ្នងខ្ញុំ ហើយតោងកខ្ញុំដោយដៃទាំងពីរ ខ្ញុំនឹងស្រង់អ្នកចាកជ្រោះភ្នំដោយកម្លាំង ។ ទូលព្រះ-បង្គំជាខ្ញុំបានឮពាក្យស្តេចស្វាដ៏មានសិរីនោះ ក៏ឡើងជិះខ្នងនៃស្វាជាអ្នកប្រាជ្ញ ហើយតោងកដោយដៃទាំងពីរ ។ ស្វានោះ

មានតេជះ មានកម្លាំង នឿយហត់ដោយសេចក្តីលំបាក បាន ស្រង់ទូលព្រះបង្គំជាខ្ញុំ ចាកជ្រោះភ្នំដោយរហ័ស ។ ស្វាជាសប្បុរសដ៏ប្រសើរ លុះស្រង់ទូលព្រះបង្គំជាខ្ញុំរួចហើយក៏ពោលនូវពាក្យនេះថា នែសម្លាញ់ អ្នកចូររក្សានូវខ្ញុំផង ខ្ញុំនឹងសម្រាកមួយរំពេច ។ បើពួកសត្វរាជសីហ៍ក្តី ពួកខ្លាធំក្តី ពួកខ្លាដំបងក្តី ពួកខ្លាឃ្មុំក្តី ពួកឆ្កែព្រៃក្តី ពួកខ្លារខិនក្តី ពួកសត្វកាចទាំងនោះមកបៀតបៀនខ្ញុំដែលធ្វេសប្រហែសហើយ បើអ្នកឃើញនូវសត្វសាហាវទាំងនោះ ចូររារាំងផង ។ ស្វានោះត្រូវទូល-ព្រះបង្គំជាខ្ញុំការពារយ៉ាងនេះហើយ ក៏ដេកលក់មួយស្របក់ទៅ គ្រានោះទូលព្រះបង្គំជាខ្ញុំ បានទិដ្ឋិដ៏លាមកដោយមិនត្រូវទំនងថា ស្វានេះជាអាហាររបស់ពួកមនុស្សដូចពួកម្រឹគដទៃក្នុងព្រៃដែរ បើដូច្នោះអាត្មាអញឃ្លានហើយ គប្បីសម្លាប់នូវស្វានេះស៊ី ។ អញស៊ីហើយនឹងយកសាច់ជាស្បៀងដើរទៅ នឹងឆ្លងផ្លូវឆ្ងាយ ស្បៀងអញក៏មានស្រាប់ ។ លំដាប់នោះទូលព្រះ-បង្គំជាខ្ញុំ ចាប់យកដុំថ្មគប់ក្បាល ( ស្វានោះ ) កាលទូល-ព្រះបង្គំជាខ្ញុំលំបាកដោយបាយ ការប្រហារក៏មានកម្លាំងថយ ។ ឯស្វានោះក៏ស្ទុះក្រោកឡើងដោយរហ័ស ប្រឡាក់ដោយឈាម មានភ្នែកពេញដោយទឹកភ្នែក យំសម្លឹងមើលទូលព្រះបង្គំជាខ្ញុំ ។ និយាយថា បពិត្រអ្នកដ៏ចម្រើន អ្នកជាម្ចាស់កុំធ្វើបាបខ្ញុំឡើយ

អ្នកឯងធ្វើអំពើអាក្រក់បែបនេះ ម្នាលអ្នកដ៏មានអាយុវែង អ្នកឯងគួរតែហាមឃាត់នូវពួកសត្វដទៃ ។ យីអើហ្ន៎ នៃបុរសចង្រៃជាមនុស្សធ្វើអំពើអាក្រក់ដល់ម៉្លេះ អញបានស្រង់ឯងឲ្យរួចពីជ្រោះជ្រៅស្រឡូងបែបនេះ ។ អញនាំអ្នកឯងមក ( នេះ ) ដូចជានាំមកពីបរលោក អ្នកឯងសំគាល់យើងថា គួរប្រទូស្តអំពើដ៏លាមកនោះ អ្នកឯងនោះជាមនុស្សលាមក ជាមនុស្សបាបគិតហើយ ។ នៃអ្នកមិនឋិតនៅក្នុងធម៌ អ្នកឯងកុំប៉ះពាល់នូវទុក្ខវេទនាដ៏ខ្លោចផ្សាឡើយ អំពើដ៏លាមកនោះកុំសម្លាប់អ្នកឯង ដូចជាផ្លែឫស្សីដែលសម្លាប់ដើមឯងវិញឡើយ ។ នៃអ្នកជាមនុស្សមានធម៌ដ៏លាមកមិនសង្រួម យើងលែងមានសេចក្តីទុកចិត្តចំពោះអ្នក អ្នកឯងចូរមក អ្នកឯងចូរមានសរីរៈប្រាកដក្នុងទីជិត ដើរតាមក្រោយយើងចុះ ។ អ្នកឯងរួចផុតពីកណ្តាប់ដៃនៃពួកម្រឹគកាចហើយ អ្នកឯងបានដល់ឧបចារៈ ជារបស់នៃមនុស្សហើយ នៃអ្នកមិនឋិតនៅក្នុងធម៌ នុ៎ះផ្លូវ អ្នកឯងចូរដើរទៅឲ្យសុខសប្បាយ តាមផ្លូវនោះចុះ ។ ស្វាដែលត្រាច់ទៅលើភ្នំលុះបានពោលពាក្យនេះហើយ ទើបលាងឈាមក្បាលរបស់ខ្លួនហើយជូតទឹកភ្នែកឲ្យជ្រះ លំដាប់នោះក៏លោតឡើងទៅលើភ្នំ ។ ទូលព្រះបង្គំជាខ្ញុំនោះ ជាបុគ្គលដែលស្វានោះផ្តាសាហើយ ត្រូវសេចក្តីក្តៅក្រហាយបៀតបៀន មានខ្លួនក្តៅអន្ទះអន្ទែង បានចូល

ទៅរកទទួលទានទឹក ។ អន្ទង់ទឹកទាំងអស់ក៏ក្ដៅសព្វ ហាក់ដូចជាភ្លើងឆេះ ជាអន្ទង់ហាក់ដូចជាប្រឡាក់ឈាម ហាក់ដូចជាខ្ទុះនិងឈាមប្រាកដដល់ខ្ញុំ ។ ដំណក់ទឹកមានចំនួនប៉ុន្មាន ស្រក់លើកាយរបស់ទូលព្រះបង្គំជាខ្ញុំ បូសមានចំនួនប៉ុណ្ណោះប្រាកដស្មើដោយផ្លែព្នៅមួយចំហៀងក៏កើតឡើង ។ ទូលព្រះបង្គំជាខ្ញុំទៅក្នុងស្រុកនិងនិគមទាំងឡាយតាមផ្លូវណាៗ បូសទាំងឡាយក៏បែកធ្លាយខ្ទុះនិងឈាមដ៏ស្អុយហូរចេញ ( ពីសរីរៈ ) របស់ទូលព្រះបង្គំជាខ្ញុំ ( តាមផ្លូវនោះៗ ) ។ ពួកស្ត្រីនិងបុរស មានដំបងក្នុងដៃ ដែលត្រូវក្លិនស្អុយគ្របសង្កត់ ហើយឃាត់ទូល-ព្រះបង្គំជាខ្ញុំថា អ្នកឯងកុំចូលមកខាងអាយឡើយ ។ សេចក្ដីទុក្ខលំបាកនេះប្រាកដដូច្នេះ មានដល់ទូលព្រះបង្គំជាខ្ញុំ អស់ ៧ ឆ្នាំហើយដល់មកឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំ នៅតែទទួលផលកម្មជារបស់ខ្លួនដែលខ្លួនធ្វើអាក្រក់ហើយ ក្នុងកាលមុន ។ ព្រោះហេតុនោះទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលចំពោះព្រះអង្គ សូមសេចក្ដីចម្រើនមានដល់ព្រះអង្គ ពួកអ្នកដែលមកចួបជុំគ្នាក្នុងទីនេះសូមកុំប្រទូស្តពួកមិត្តឡើយ ព្រោះថា បុគ្គលប្រទូស្តមិត្តជាមនុស្សអាក្រក់ ។

បុគ្គលណាប្រទូស្តមិត្តទាំងឡាយក្នុងលោកនេះ បុគ្គលនោះរមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ

លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុសលោ** សេចក្ដីថា បពិត្រព្រះអង្គ ទូលព្រះបង្គំក្រាបទូលដល់ទ្រង់ដូចបណ្ឌិតទាំងឡាយជាអ្នកឈ្លាសពោល ។ បទថា **គោគវេសោ** សេចក្ដីថា កាលទូលព្រះបង្គំត្រាច់រកគោដែលបាត់ទៅ ។ បទថា **អច្ចសរឹ** សេចក្ដីថា វង្វេងផ្លូវផុតពីដែនមនុស្សចូលទៅកាន់ព្រៃហិមពាន្ត ។

បទថា **អរញ្ញេ** បានដល់ ក្នុងព្រៃមិនមានព្រះរាជាគ្រប់គ្រង ។ បទថា **ឦរិណេ** សេចក្ដីថា នៃផ្លូវកន្ដារ ។ បទថា **វិវនេ** បានដល់ ស្ងាត់ ។ បទថា **វិប្បនដ្ឋោ** បានដល់ វង្វេងផ្លូវ ។ បទថា **ពុភុក្ខិតោ** សេចក្ដីថា កើតនូវការស្រេកឃ្លាន គឺត្រូវសេចក្ដីឃ្លានជុតរោលហើយ ។ បទថា **បចាតមភិលម្ពន្តំ** សេចក្ដីថា ដើមនោះទោរទៅកាន់មាត់ជ្រោះ ។ បទថា **សម្បន្នផលធារិនំ** សេចក្ដីថា រយោងទៅដោយចង្កោមផ្លែដែលមានរសផ្អែម ។ បទថា **វាតស្សិតានិ** សេចក្ដីថា ជាបឋមខ្ញុំរើសផ្លែដែលខ្យល់បក់ជ្រុះមកបរិភោគ ។ បទថា **តត្ថ ហោស្សាមិ** សេចក្ដីថា ទើបខ្ញុំឡើងទៅលើដើមទន្ទាប់នោះដោយគិតថានឹងស៊ីលើដើមឲ្យសប្បាយ ។

បទថា **តតោ សា ភញ្ជថ សាខា** សេចក្ដីថា កាលខ្ញុំលាដៃស្រវាយកផ្លែឈើដែលត្រូវការ មែកឈើដែលខ្ញុំជាន់នោះ ក៏បាក់ដូចត្រូវកាត់ដោយប៉ូវថៅដូច្នោះ ។ បទថា **អនាលម្ពេ** សេចក្ដីថា មិនមានទីដែលគប្បីតោងបានឡើយ ។ បទថា **គិរិទុគ្គស្មិ** បានដល់ ភ្នំដែលខ្ពស់ទាប ។ បទថា **សេសឹ**

សេចក្តីថា ខ្ញុំចាំបាច់ត្រូវដេក ។ បទថា **កបិ មាគញ្ឆិ** សេចក្តីថា មានស្វាមកដល់ទីនោះ ។ បទថា **គោនង្គុលោ** សេចក្តីថា មានកន្ទុយដូចកន្ទុយគោ បាឋៈថា **គោនង្គុដ្ឋោ** ដូច្នេះក៏មាន ។ អាចារ្យខ្លះក៏ពោលថា **គោនង្គុលី** ។ បទថា **អករំ មយិ** សេចក្តីថា បានធ្វើនូវការអាណិតដល់ខ្ញុំ ។ បទថា **អញ្ញោ** សេចក្តីថា បពិត្រមហារាជ ស្តេចពានរនោះបានឮសំឡេងរបស់ខ្ញុំកំពុងហែលទឹកក្នុងជ្រោះនោះ ទើបស្រែករាក់ទាក់នឹងខ្ញុំថា នែអ្នកដ៏ចម្រើន ហើយសួរថា អ្នកជានរណា ។ បទថា **ព្យសម្បត្តោ** បានដល់ ដល់ហើយនូវការវិនាស ។ បាឋៈថា **បចាតស្ស វសំ បត្តោ** ដូច្នេះក៏មាន ។

បទថា **ភទ្ទំ វោ** សេចក្តីថា ព្រោះហេតុនោះទើបខ្ញុំពោលអង្វរអ្នក សូមសេចក្តីចម្រើនមានដល់អ្នក ។ បទថា **គរុំ សិលំ** សេចក្តីថា បពិត្រមហារាជ កាលខ្ញុំពោលយ៉ាងនេះហើយ ស្តេចស្វានោះក៏លួងលោមខ្ញុំថា កុំខ្លាចឡើយ ហើយឡើងទៅលើភ្នំ ចងខ្សែត្រង់ថ្មជូនទុកជាបឋម ។ បទថា **និសភោ** សេចក្តីថា ស្តេចពានរអង់អាចចងខ្សែត្រង់ថ្មហើយឈរត្រង់ញកភ្នំបានពោលពាក្យនេះនឹងខ្ញុំ ។ បទថា **ពាហុភិ** សេចក្តីថា សូមលោកឡើងមកលើខ្នងខ្ញុំ ហើយយកដៃទាំង ២ ឱបកខ្ញុំឲ្យណែន ។ បទថា **វេគសា** សេចក្តីថា ដោយពេញកម្លាំង ។ បទថា **សិរីមតោ** បានដល់ ជាអ្នកមានបុណ្យ ។ បទថា **អគ្គហឹ** សេចក្តីថា កាលស្តេចពានរលោតចុះមកកាន់ជ្រោះជម្រៅ ៦០ ហត្ថ ដោយសម្ទុះដូចខ្យល់ ខ្ញុំលោតឡើងមកលើខ្នងដោយរហ័ស យកដើមដៃទាំង ២ ឱបក ។

បទថា **វិហាញ្ញមានោ** បានដល់ លំបាកលំបិន ។ បទថា **កិច្ឆេន** សេចក្តីថា ដោយសេចក្តីលំបាក ម្យ៉ាងទៀត ដោយសេចក្តីថា បណ្ឌិតជាសប្បុរសគ្រាស្វែងរកឱកាសជួយស្រោចស្រង់ ក៏ត្រូវក្តៅក្រហាយ ។ បទថា **រក្ខស្សុ** សេចក្តីថា ខ្ញុំជួយស្រង់លោករហូតហត់នឿយ នឹងសូមសម្រាកមួយស្របក់ សូមលោកជួយរក្សាភ័យឲ្យខ្ញុំផង ។ បទថា **យថា ចញ្ញោ វនេ មិគា** សេចក្តីថា ពានរនេះក៏ជាអាហារមនុស្សបរិភោគ ដូចគ្នានឹងពួកម្រឹគសាហាវក្នុងព្រៃនេះ ក្រៅអំពីសត្វកាចមានរាជសីហ៍ជាដើម តែក្នុងបាលីលោករបនាទុកថា **អច្ឆកោ កតរច្ឆយោ** ។

បទថា **បរិត្តាតូន** សេចក្តីថា បពិត្រមហារាជ ព្រោះស្តេចពានរធ្វើខ្ញុំជាគ្រឿងការពារយ៉ាងនេះ ដាច់នូវយោនិសោមនសិការ ទើបដេកលក់មួយស្រ-បក់ ។ បទថា **ភក្ខោ** សេចក្តីថា គួរដល់ការទំពាស៊ី ។ បទថា **អសិតោ** សេចក្តីថា ស៊ីស្កប់ស្កល់ហើយ ។ បទថា **សម្ពលំ** បានដល់ ស្បៀង ។

បទថា **មត្ថកំ សន្និតាឡយិ** សេចក្តីថា គប់នូវក្បាលរបស់ពានរនោះ ។ បាឋៈថា **សន្និតាឡយំ** ដូច្នេះក៏មាន ។ បទថា **ឧត្វាលោ អហុ** សេចក្តីថា ខ្ញុំមិនសូវមានកម្លាំង ទើបគប់មិនបានខ្លាំងសមដូចបំណង ។ បទថា **វេគេន** សេចក្តីថា ដោយកម្លាំងនៃដុំថ្ម ដែលខ្ញុំគប់ទៅហើយ ។ បទថា **ឧទប្បត្តោ** បានដល់ ស្ទុះក្រោកឡើងហើយ ។ បទថា **មាយ្យោ** សេចក្តីថា ដុំថ្មដែលបុរសអ្នកទ្រុស្តមិត្តគប់ដាច់នូវស្បែកធំ ឈាមក៏ហូរ ។ ព្រះមហាសត្វសោយទុក្ខវេទនាគិតថា ក្នុងទីនេះមិនមានអ្នកដទៃឡើយ ភ័យនេះកើតឡើងព្រោះ

អាស្រ័យបុរសនេះ ទើបខ្លាចចំពោះមរណភ័យ យកដៃចាប់ស្បែកដែលរហែក សំយុងចុះលោតឡើងលើមែកឈើ កាលចរចាជាមួយបុរសលាមកនោះទើបពោលគាថាជាដើមថា **មាយ្យោ មំ** អ្នកកុំបានធ្វើខ្ញុំឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មាយ្យោ មំ ករុណ្ណ** សេចក្ដីថា ស្ដេចស្វាឃាត់នូវព្រាហ្មណ៍នោះថា លោកដ៏ចម្រើន លោកកុំធ្វើខ្ញុំឡើយ ។ បទថា **ត្វញ្ច ឆាម** សេចក្ដីថា លោកដែលខ្ញុំជួយឲ្យឡើងមកអំពីជ្រោះយ៉ាងនេះហើយធ្វើនូវកម្មទារុណក្នុងខ្ញុំបែបនេះ គួរអាណិត លោកធ្វើកម្មនេះមិនសមគួរឡើយ ។ បទថា **អហោ វត** សេចក្ដីថា ស្ដេចពានរកាលតិះដៀលព្រាហ្មណ៍នោះទើបពោលយ៉ាងនេះ ។ បទថា **តាវ ទុក្ករការកា** សេចក្ដីថា នៃបុរសអាក្រក់ លោកធ្វើកម្មកម្រដែលបុគ្គលនឹងធ្វើបានព្រោះខុសក្នុងខ្ញុំ ។ បទថា **បរលោ-កាវ** សេចក្ដីថា លោកដូចខ្ញុំនាំមកអំពីបរលោក ។ បទថា **ទុព្ភេយ្យំ** លោកនៅហ៊ានយល់ខ្ញុំថាគួរប្រទូស្ត គឺគួរសម្លាប់ ។

បទថា **វេទនំ កដុកំ** សេចក្ដីថា កាលបើដូច្នេះលោកជាបុគ្គលមិនមានធម៌ ខ្ញុំត្រូវជួបនូវទុក្ខបែបណា វេទនាដ៏ក្ដៅផ្សាបែបនេះកុំពាល់ត្រូវលោកឡើយ បាបកម្មនោះកុំសម្លាប់លោកដូចផ្លែឫស្សីសម្លាប់នូវដើមឫស្សីឡើយ ។ បពិត្រមហារាជ ស្ដេចពានរអាណិតខ្ញុំ ដូចកូនជាទីស្រឡាញ់ ដោយប្រការដូច្នេះ ។ ពេលនោះខ្ញុំពោលនឹងស្ដេចស្វាថា អ្នកកុំធ្វើវត្ថុដែលខ្ញុំធ្វើឡើយ អ្នកកុំឲ្យខ្ញុំជាអសប្បុរសត្រូវវិនាសក្នុងព្រៃបែបនេះឡើយ ខ្ញុំវង្វេងទិសមិនស្គាល់ផ្លូវ ចូរកុំញុំាងកុសលកម្មដែលខ្លួនធ្វើហើយឲ្យវិនាស ចូរឲ្យជីវិតទានដល់ខ្ញុំ ជួយនាំខ្ញុំ

ចេញអំពីព្រៃទៅតាំងនៅក្នុងដែនដីមនុស្សចុះ ។ ខ្ញុំពោលយ៉ាងនេះហើយស្ដេចស្វានោះ កាលនឹងចរចាប្រាស្រ័យជាមួយខ្ញុំទើបពោលគាថា មានពាក្យជាដើមថា **តយិ មេ ឆត្ថិ វិស្សាសោ** សេចក្ដីថា ការស្និទ្ធស្នាលក្នុងលោក មិនមានសម្រាប់ខ្ញុំ ដូច្នេះជាដើម ។ បទថា **តយិ** សេចក្ដីថា តាំងអំពីថ្ងៃនេះទៅខ្ញុំនិងលោកមិនមានសេចក្ដីស្និទ្ធស្នាលគ្នា ។ បទថា **ឃហិ** សេចក្ដីថា នែបុរសដ៏ចម្រើន ខ្ញុំមិនធ្វើដំណើរទៅជាមួយលោក តែសូមលោកមកចុះ សូមលោកដើរល្មមមើលឃើញខ្ញុំ ខ្ញុំនឹងដើរតាមចុងឈើប៉ុណ្ណោះ ។ បទថា **មុត្តោសិ** សេចក្ដីថា បពិត្រមហារាជ លំដាប់នោះស្ដេចពានរ បាននាំខ្ញុំចេញអំពីព្រៃហើយពោលថា អ្នកឯងរួចផុតពីកណ្ដាប់ដៃនៃពួកម្រឹគកាចហើយ ដូច្នេះ ។

បទថា **បត្តោសិ មានុសឹ បទំ** សេចក្ដីថា ស្ដេចស្វាពោលថា លោកដល់ គឺមកដល់ទឹកដីដែលជាឧបចារៈរបស់មនុស្សហើយ នេះផ្លូវ សូមលោកទៅតាមផ្លូវនេះចុះ ។ បទថា **គិរិចរោ** បានដល់ ពានរមានប្រក្រតីទៅតាមញកភ្នំ ។ បទថា **បក្ខល្យ** បានដល់ លាងហើយ ។ បទថា **តេឆាភិ-សត្តោស្មិ** សេចក្ដីថា បពិត្រមហារាជ ខ្ញុំជាបុគ្គលដែលស្ដេចស្វានោះសង្គ្រោះហើយ កាលបាបកម្មនោះឆ្អិនហើយសម្គាល់ថា ស្ដេចស្វាអនុគ្រោះហើយទើបពោលយ៉ាងនេះ ។ បទថា **អដ្ដិតោ** សេចក្ដីថា ត្រូវសេចក្ដីក្រវល់ក្រវាយបៀតបៀនហើយ ។ បទថា **ឧចាគមឹ** សេចក្ដីថា ខ្ញុំទៅកាន់អន្លង់ទឹកមួយកន្លែង ។ បទថា **សមបជ្ជថ** សេចក្ដីថា វត្ថុគ្រប់យ៉ាងកើតប្រាកដដល់ខ្ញុំបែបនេះ ។ បទថា **យាវត្តោ** សេចក្ដីថា មានប្រមាណប៉ុនណា ។

បទថា **គណ្ឌុ ជាយេថ** សេចក្តីថា បូសក៏ផុសឡើង ។ បានឮថា មនុស្សប្រេតនោះ កាលមិនអាចអត់ធន់នឹងសេចក្តីស្រេកបាន ទើបលើកកម្បង់ដៃដងទឹកផឹកបន្តិច ហើយស្រោចទឹកដែលសល់លើក្បាល លំដាប់នោះឯងបូសប៉ុនៗផ្លែញ្ញៅ ក៏ផុសឡើងតាមចំនួនតំណក់ទឹក ព្រោះហេតុនោះទើបបុរសនោះពោលយ៉ាងនេះ ។ បទថា **បភិន្នា** សេចក្តីថា បូសទាំងនោះក៏បែកក្នុងថ្ងៃនោះឯង ខ្ទុះនិងឈាមក៏ហូរចេញមក មានក្លិនស្អុយដូចគម្រង់ ។ បទថា **យេន យេន** សេចក្តីថា ខ្ញុំដើរទៅតាមផ្លូវណាៗ ។ បទថា **ឱក្កិត្តា** សេចក្តីថា ផ្សាយទៅដោយក្លិនស្អុយ គឺមានក្លិនស្អុយជុំវិញខ្លួន ។ បទថា **មាស្សុ ឱរេន អាគមា** សេចក្តីថា មនុស្សទាំងឡាយកាន់ដំបងរារាំងនូវខ្ញុំថា នែសត្វស្មោកគ្រោកចេញទៅឲ្យឆ្ងាយ កុំចូលជិតអញឡើយ គឺកុំចូលមកក្បែរពួកយើង ។ បទថា **សត្តវស្សានិទានិ មេ** សេចក្តីថា ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ តាំងអំពីនោះមកដល់ឥឡូវនេះជាពេល ៧ ឆ្នាំ ខ្ញុំត្រូវសោយផលកម្មរបស់ខ្លួន អស់កាលមានប្រមាណប៉ុណ្ណេះ ។ កាលមនុស្សប្រេតនោះពណ៌នាកម្ម គឺការទ្រុស្តមិត្តរបស់ខ្លួនដោយពិស្តារហើយក្រាបទូលថា បពិត្រមហារាជ បុគ្គលណាមួយឃើញខ្ញុំជាគំរូហើយ មិនគួរធ្វើនូវកម្មបែបនេះ រួចពោលគាថាជាដើមថា **តំ វោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **តំ** ស្មើគ្នានឹង **តស្មា** ប្រែថា ព្រោះហេតុនោះ អធិប្បាយថា ព្រោះហេតុនៃកម្មបែបនេះមានទុក្ខជាវិបាកយ៉ាងនេះ ។

ព្រះបរមសាស្តាត្រាស់អភិសម្ពុទ្ធគាថានេះទុកដោយសេចក្តីថា

បុគ្គលណាប្រទូស្តមិត្តទាំងឡាយ ក្នុងលោកនេះ បុគ្គលនោះ
រមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ
លុះបែកធ្លាយរាងកាយរមែងទៅកើតក្នុងនរក[១]ដូច្នេះ ។

អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាទ្រុស្តមិត្ត បៀតបៀនមិត្ត ក្នុងលោកនេះ បុគ្គលនោះរមែងមានសភាពបែបនេះ ។

កាលបុរសនោះកំពុងក្រាបទូលព្រះរាជា ផែនដីក៏បើកឱកាសឲ្យ គេក៏ចុតិទៅកើតក្នុងអវីចិមហានរក ក្នុងខណៈនោះឯង ។ កាលបុរសនោះត្រូវផែនដីលេបត្របាក់ហើយ ព្រះរាជាយាងចេញអំពីព្រះរាជឧទ្យាន ហើយយាងទៅកាន់ព្រះនគរ ។

ព្រះសាស្តា កាលទ្រង់នាំយកអតីតនិទាននេះមកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនទេវទត្តក៏ប្រមៀលថ្មប្រទូស្តតថាគតដូចគ្នា ហើយទ្រង់ប្រជុំជាតកថា បុរសទ្រុស្តមិត្តក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ស្តេចពានរក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មហាកបិជាតក ចប់

---

១-គាថានេះមនុស្សប្រេតពោលម្តង ព្រះសាស្តាកាលទ្រង់ត្រាស់ដឹងហើយក៏ត្រាស់ម្តងទៀត ។

# ធម្មទ្ធជជាតក

[ ៥០១ ] ( នាងភេរីបរិព្វាជិកាសួរថា ) កាលពួកជនទាំង ៧ នាក់ របស់ព្រះអង្គសោត់ទៅក្នុងអន្លង់ទឹកជ្រៅ អារក្សទឹកកាលស្វែងរកគ្រឿងបូជា របស់មនុស្ស គប្បីចាប់ទូក ( ព្រះអង្គព្រះរាជទានទូវជន ) តាមលំដាប់ដូច ម្តេច ទើបរួចអំពីអារក្សទឹកបាន ។

[ ៥០២ ] ( ព្រះបាទចូឡនីត្រាស់ថា ) ខ្ញុំឲ្យមាតាជាមុន រួចឲ្យភរិយា ឲ្យប្អូន លំដាប់អំពីនោះឲ្យសម្លាញ់និងឲ្យព្រាហ្មណ៍ជាគម្រប់ ៥ ទើបឲ្យខ្លួន ជាគម្រប់ ៦ មិនឲ្យមហោសធទេ ។

[ ៥០៣ ] ( នាងភេរី... ) ព្រះមាតាជាអ្នកចិញ្ចឹមព្រះអង្គផង ជាអ្នក បង្កើតផង អនុគ្រោះព្រះអង្គអស់កាលដ៏យូរផង កាលបើធព្ពិព្រាហ្មណ៍ប្រទូស្ត ចំពោះព្រះអង្គ ព្រះមាតាជាបណ្ឌិត ជាអ្នកស្គាល់ឧបាយ ធ្វើនូវរបស់ដទៃជា គ្រឿងបន្ទំ ហើយដោះព្រះអង្គឲ្យរួចអំពីការសម្លាប់ ព្រះអង្គព្រះរាជទានដល់ អារក្សទឹកនូវព្រះមាតាដែលមានព្រះគុណប្រាកដដូច្នោះ ជាអ្នកឲ្យនូវជីវិត ជា អ្នកឲ្យព្រះអង្គកើតអំពីឱរា ជាអ្នកទ្រទ្រង់នូវគភ៌នោះ តើព្រោះទោសដូចម្តេច ។

[ ៥០៤ ] ( ព្រះរាជា... ) ព្រះមាតាខ្ញុំ ទ្រទ្រង់គ្រឿងអលង្ការដែលមិន គួរតាក់តែងដូចស្ត្រីក្មេង សើចក្អាកក្អាយហួសវេលា ( ជាមួយ ) នឹងនាយ ឆ្មាំទ្វារនិងពពួកពលសេនា មិនតែប៉ុណ្ណោះ ថែមទាំងបញ្ជូននូវទូតទាំងឡាយ ដល់ពួកបដិរាជ ( ព្រះរាជានៅក្រោមអំណាច ) ដោយខ្លួនឯង ខ្ញុំឲ្យព្រះមាតា ដល់អារក្សទឹកព្រោះទោសនោះឯង ។

[ ៥០៥ ] ( នាងភេរី... ) អគ្គមហេសីជាស្ត្រីប្រសើរជាងពួកស្ត្រី ពោលពាក្យជាទីស្រឡាញ់ដ៏ក្រៃលែងជាស្ត្រីមានសណ្ដាប់ធ្នាប់ មានសីលធម៌ ធ្លាប់ជាប់តាម ( ព្រះអង្គ ) ដូចជាស្រមោល ជាស្ត្រីមិនក្រេវក្រោធ ជាអ្នកមានបុណ្យ ជាបណ្ឌិតឃើញនូវប្រយោជន៍ ព្រះអង្គព្រះរាជទាននាងឧព្វរីដល់អា-រក្សទឹក តើព្រោះទោសដូចម្ដេច ។

[ ៥០៦ ] ( ព្រះរាជា... ) នាងនន្ទាទេវីនោះ ( បានដឹងច្បាស់ ) នូវខ្ញុំថាជាអ្នកប្រកបដោយសេចក្ដីត្រេកអរក្នុងល្បែង ទាំងជាអ្នកលុះអំណាចនៃកិលេស ដែលមិនមានប្រយោជន៍ នាងបានសូមចំពោះខ្ញុំនូវទ្រព្យនៃកូនទាំងឡាយរបស់ខ្លួនដែលជាទ្រព្យមិនគួរសូម ខ្ញុំនោះកំពុងត្រេកត្រអាល ក៏បានឲ្យទ្រព្យប្រសើរនិងថោកទាបច្រើនយ៉ាង លុះខ្ញុំលះបង់នូវទ្រព្យដែលគេលះបង់បានដោយក្រហើយ ក៏មានចិត្តអាក់អន់សោកស្ដាយ ក្នុងកាលជាខាងក្រោយខ្ញុំឲ្យនាងឧព្វរីដល់អារក្សទឹក ព្រោះទោសនោះឯង ។

[ ៥០៧ ] ( នាងភេរី... ) ពួកអ្នកជនបទចម្រើនហើយ ព្រោះព្រះក-និដ្ឋកាតាណា ទាំងព្រះអង្គដែលព្រះកនិដ្ឋកាតាណានាំមកកាន់ព្រះរាជដំណាក់វិញ ព្រះរាជទ្រព្យជាច្រើនយ៉ាងដែលព្រះកនិដ្ឋកាតាណារឹបជាន់នាំមកអំពីពួកស្ដេចដទៃ ព្រះអង្គព្រះរាជទានព្រះកនិដ្ឋកាតា ជាបុគ្គលប្រសើរជាងពួកខ្មាន់ធ្នូជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ( នោះ ) ដល់អារក្សទឹក តើព្រោះទោសដូចម្ដេច ។

[ ៥០៨ ] ( ព្រះរាជា... ) ពួកអ្នកជនបទចម្រើនហើយ ព្រោះកនិដ្ឋកា-

តាណា ទាំងខ្ញុំ ( ដែលកនិដ្ឋកាតាណា ) នាំមកកាន់ដំណាក់វិញ ព្រះរាជ-ទ្រព្យជាច្រើនយ៉ាង ( ដែលកនិដ្ឋកាតាណា ) រឹបជាន់ ហើយនាំមកអំពីពួកស្ដេចដទៃ កនិដ្ឋកាតានោះមើលងាយថា អញប្រសើរជាងពួកខ្មាន់ធ្នូ ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ឯព្រះរាជានេះដូចជាក្មេង បានសេចក្ដីសុខព្រោះតែអញ បពិត្រនាងជាម្ចាស់ មិនតែប៉ុណ្ណោះកនិដ្ឋកាតានោះ មិនមកកាន់ទីបម្រើខ្ញុំដូចក្នុងកាលពីដើមទេ ខ្ញុំឲ្យកនិដ្ឋកាតា ( នោះ ) ដល់អារក្សទឹកព្រោះទោសនោះឯង ។

[ ៥០៩ ] ( នាងភេរី... ) ជនទាំងពីរនាក់ គឺព្រះអង្គនិងធនុសេខកុមារជាសម្លាញ់មានវ័យស្មើគ្នា ធ្លាប់នៅក្នុងបញ្ចាលនគរ ជាបុគ្គលពីរនាក់កើតក្នុងបញ្ចាលនគរនេះក្នុងរាត្រីតែមួយ ធនុសេខកុមារមានទុក្ខសុខជាមួយគ្នានឹងព្រះអង្គ ជាប់តាមព្រះអង្គក្នុងការត្រាច់ទៅកាន់ ( ជនបទ ) ជាអ្នកខ្មីឃ្មាតខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ដើម្បីព្រះអង្គទាំងថ្ងៃទាំងយប់ ព្រះអង្គព្រះរាជទានសម្លាញ់នេះដល់អារក្សទឹក តើព្រោះហេតុដូចម្ដេច ។

[ ៥១០ ] ( ព្រះរាជា... ) បពិត្រនាងម្ចាស់ ធនុសេខកុមារនេះ ( ជាប់តាម ) ខ្ញុំក្នុងការត្រាច់ទៅ ( កាន់ជនបទ ) សើចក្អាកក្អាយជាមួយនឹងខ្ញុំក្នុងកាលមុន សូម្បីក្នុងថ្ងៃនេះ ក៏នៅតែសើចក្អាកក្អាយហួសវេលាតាមទំនងនោះដែរ បពិត្រនាងម្ចាស់ ខ្ញុំនៅក្នុងទីស្ងាត់ កំពុងប្រឹក្សាជាមួយនឹងនាងឧព្វរី ឯសេខកុមារខ្ញុំមិនបានហៅ មិនបានឲ្យដំណឹងខ្ញុំជាមុនទេស្រាប់តែចូលមក ជាបុគ្គលមានទ្វារបានហើយ មានឱកាសធ្វើឲ្យហើយ ខ្ញុំឲ្យនូវសម្លាញ់ជាមនុស្ស

មិនមានសេចក្តីអៀនខ្មាស មិនអើពើ ដល់អារក្សទឹក ព្រោះទោសនោះឯង ។

[ ៥១១ ] ( នាងកេរី... ) ព្រាហ្មណ៍បុរោហិត ជាអ្នកឈ្លាសវៃក្នុងនិមិត្តទាំងពួង ជាអ្នកដឹងនូវសំឡេងស្រែក ជាអ្នកឈ្លាសក្នុងឧត្បាត ជាអ្នកចេះកាត់សុបិន ជាអ្នកឈ្លាសវៃក្នុងការចេញនិងការចូលផងលើផែនដីនិងលើអាកាសផង ជាអ្នកឈ្លាសវៃក្នុងចំណែកនក្ខត្តឫក្ស ព្រះអង្គព្រះរាជទានព្រាហ្មណ៍បុរោហិតដល់អារក្សទឹក តើព្រោះទោសដូចម្តេច ។

[ ៥១២ ] ( ព្រះរាជា... ) បពិត្រនាងម្ចាស់ ព្រាហ្មណ៍បុរោហិត បើកភ្នែកសម្លក់ចំពោះខ្ញុំ ក្នុងកណ្តាលបរិស័ទ ព្រោះហេតុនោះទើបខ្ញុំឲ្យបុរោហិតអាក្រក់ មានចិញ្ចើមក្រញូវ ដល់អារក្សទឹក ។

[ ៥១៣ ] ( នាងកេរី... ) ព្រះអង្គគ្រប់គ្រងនូវផែនដីដ៏ធំ មានសមុទ្ទព័ទ្ធជុំវិញជាកុណ្ឌលរបស់សាគរ ព្រះអង្គមានអាមាត្យចោមរោម ជាឥស្សរៈលើផែនដី មានសមុទ្ទទាំង ៤ ជាទីបំផុត មានដែនដ៏ច្រើន ជាអ្នកឈ្នះសង្គ្រាមមានពលច្រើន ជាព្រះរាជាឯកលើផែនដី យសរបស់ព្រះអង្គក៏ដល់នូវភាពដ៏ធំធ្ងើង មានពួកនារីមកអំពីជនបទផ្សេងៗ ជាស្ត្រីស្នំ ១៦ ពាន់ ពាក់គ្រឿងកុណ្ឌលជាវិការៈនៃកែវមណីល្អល្អះដូចស្រីទេពកញ្ញា បពិត្រក្សត្រ អ្នកប្រាជ្ញទាំងឡាយបានពោលចំពោះជីវិតដែលវែងបរិបូណ៌ដោយអង្គទាំងពួង សម្រេចនូវសេចក្តីប្រាថ្នាទាំងពួងថា ជាទីស្រឡាញ់របស់សត្វទាំងឡាយ អ្នកដល់នូវសេចក្តីសុខយ៉ាងនេះ កាលបើដូច្នោះព្រះអង្គរក្សាទុកនូវបណ្ឌិតត្រឡប់ជាលះបង់ព្រះជន្មដែលគេលះបង់បានដោយកម្រ តើដោយដំណើរដូចម្តេចឬក៏ដោយ

ហេតុដូចម្តេច ។

[ ៥១៤ ] ( ព្រះរាជា... ) បពិត្រនាងម្ចាស់ តាំងអំពីកាលដែលមហោសធបណ្ឌិត មកតាំងនៅក្នុងកណ្តាប់ដៃនៃខ្ញុំ ខ្ញុំនខ្ញុំក៏មិនដែលឃើញនូវអំពើអាក្រក់ សូម្បីបន្តិចបន្តួចរបស់មហោសធបណ្ឌិតជាអ្នកប្រាជ្ញទេ ថាបើសេចក្តីស្លាប់គប្បីមានដល់ខ្ញុំមុនក្នុងកាលណាមួយ មហោសធបណ្ឌិត គប្បីញុំាងបុត្តទាំងឡាយនិងចៅទាំងឡាយរបស់ខ្ញុំឲ្យសុខ មហោសធបណ្ឌិតតែងពិចារណាឃើញនូវប្រយោជន៍ទាំងពួង ក្នុងអនាគតនិងបច្ចុប្បន្ន ( ព្រោះហេតុនោះ ) ខ្ញុំមិនឲ្យនូវមហោសធបណ្ឌិត ជាអ្នកមានការងារមិនដែលមានកំហុស ( ដល់អារក្សទឹកទេ ) ។

[ ៥១៥ ] ( នាងភេរី... ) ពួកអ្នកនគរបញ្ចាលទាំងឡាយ ចូរស្តាប់នូវភាសិតនេះរបស់ព្រះបាទចូឡនីចុះ ព្រះរាជាទ្រង់រក្សានូវបណ្ឌិត ស៊ូលះបង់នូវព្រះជន្មដែលគេលះបានដោយក្រ ព្រះរាជាក្នុងបញ្ចាលនគរលះបង់នូវជីវិតរបស់ជន ៦ រូបគឺ ព្រះមាតា ១ ព្រះមហេសី ១ ព្រះកនិដ្ឋភាតា ១ សម្លាញ់ ១ ព្រាហ្មណ៍ ១ ព្រះអង្គ ១ បញ្ញាជាគុណជាតិដ៏ល្អិតសម្រាប់គិតនូវប្រយោជន៍ដ៏ល្អ មានឫទ្ធិច្រើនយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ននេះផង ដើម្បីសេចក្តីសុខក្នុងបរលោកផង ។

**ចប់ ទករក្ខសជាតក ទី ៧ ។**

# អដ្ឋកថា

## ទករក្ខសជាតក

[ ៥០១-៥១៥ ] ទករក្ខសជាតក មានពាក្យផ្ដើមថា **សចេ វោ វុយ្ហ-មានានំ** ដូច្នេះជាដើម ឯរឿងមានសេចក្ដីពិស្ដារក្នុងមហាឧម្មង្គជាតក ។

*អដ្ឋកថាទករក្ខសជាតក ចប់*

# បណ្ឌរកជាតក

[ ៥១៦ ] ( បណ្ឌរកនាគរាជពោលថា ) ភ័យខ្លួនឯងរមែងជាប់តាមនូវបុគ្គលដែលមានវាចាល្ហល្ហាច មានមន្តមិនលាក់ទុក ជាអ្នកមិនសង្រួម មិនចេះពិចារណា ជាអ្នកល្ងង់នោះ ដូចជាគ្រុឌចាប់យកនាគឈ្មោះ បណ្ឌរកៈ ។ ជនណារីករាយប្រាប់មន្តដែលគួរលាក់ គួររក្សាទុក ព្រោះសេចក្តីវង្វេង ភ័យរមែងជាប់តាមនូវជនដែលមានមន្តបែកធ្លាយនោះដោយឆាប់ ដូចជាគ្រុឌចាប់យកនាគឈ្មោះ បណ្ឌរកៈ ។

មិត្តគ្រាន់តែបណ្តោយតាមគេ មិនគួរឲ្យដឹងនូវហេតុជាទម្ងន់ដែលគួរលាក់ ទាំងមិត្តល្អ ជាអ្នកមិនយល់ការឬយល់ការដែរ តែជាអ្នកមិនប្រព្រឹត្តប្រយោជន៍ ( ក៏គេមិនគួរឲ្យដឹងដែរ ) ។

អញជល់នូវសេចក្តីទុកចិត្តអចេល អចេលនេះជាសមណៈ គេរាប់អានហើយ មានចិត្តចម្រើនហើយ អញក៏ប្រាប់បើកនូវអាថ៌កំបាំងដល់អចេលនោះ បានជាអញមានប្រយោជន៍កន្លងហួស ហើយទួញយំកំព្រាម្នាក់ឯង ។ បពិត្រគ្រុឌដ៏ប្រសើរ ព្រោះខ្ញុំមិនអាចនឹងសង្រួមវាចាដ៏ប្រសើរកំបាំងនេះដល់អចេលនោះ បានជាភ័យមកដល់ខ្ញុំអំពីចំណែកនៃអចេលនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រាហើយទួញយំ ។ ជនណាសំគាល់នូវបុគ្គលថាមានចិត្តល្អ ប្រាប់នូវអាថ៌កំបាំងចំពោះជនមានត្រកូលដ៏អាក្រក់ព្រោះទោសាគតិ ភយាគតិឬត្រេកអរដោយអំណាចរាគៈ ជននោះជាមនុស្សល្ងង់ ឈ្មោះថាភ្លាត់ហើយដោយឥតសង្ស័យ ។ ជនណាមានវាចាចេញទៅខាងក្រៅ រាប់

ចូលក្នុងពួកអសប្បុរស កម្ចាយនូវពាក្យ ( កំបាំងរបស់គេ ) ក្នុងទីប្រជុំ អ្នកប្រាជ្ញទាំងឡាយហៅជននោះថា ជាអ្នកមានមាត់អាក្រក់ ដូចអាសិរពិស បុគ្គលគប្បីជៀសចាកបុគ្គលបែបនោះឲ្យឆ្ងាយ ចេញអំពីចម្ងាយ ។ យើងលះបង់នូវកាមទាំងពួង គឺបាយ ទឹក សំពត់ ក្នុងដែនកាសីនិងខ្ទឹមចន្ទន៍ ពួកស្ត្រីជាទីគាប់ចិត្ត កម្រងផ្កានិងគ្រឿងប្រោះព្រំ បពិត្រសុបណ្ណៈ យើងសូមដល់នូវលោក ( ជាទីពឹង ) ស្មើដោយជីវិត ។

[ ៥១៧ ] ( សុបណ្ណរាជសួរថា ) ម្នាលនាគរាជ បណ្ដាជនទាំង ៣ នាក់ក្នុងទីនេះ តើសត្វណាគឺសមណៈ ឬគ្រុឌ ឬអ្នកឯង គួរដល់នូវសេចក្ដីតិះដៀលបានក្នុងលោកនេះ ម្នាលបណ្ឌរកៈ ( អ្នកឯងត្រូវខ្ញុំ ) ចាប់បានព្រោះហេតុដូចម្ដេច ។

[ ៥១៨ ] ( បណ្ឌរកៈ... ) អចេលជាសមណៈ ជាបុគ្គលមានសភាពដែលខ្ញុំរាប់អានហើយ ជាទីស្រឡាញ់ដោយចិត្តរបស់ខ្ញុំ មានខ្ញុំដចម្រើនហើយ ខ្ញុំប្រាប់បើកអាថ៌កំបាំងដល់សមណៈនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រាហើយទួញយំ ។

[ ៥១៩ ] ( សុបណ្ណរាជ... ) ធម្មតាសត្វលើផែនដីឈ្មោះថាមិនស្លាប់មិនមានទេ ចំណែកនៃបញ្ញាជាធម្មជាតិដែលបុគ្គលមិនគួរតិះដៀល នរជនក្នុងលោកនេះរមែងនាំមកនូវគុណវិសេស ដែលបុគ្គលមិនគួរបានដោយវិធីសច្ចៈ ១ ដោយសុចរិតធម៌ ១ ដោយធិតិគឺបញ្ញា ១ ដោយការទូន្មាននូវឥន្ទ្រិយ ១ ។ មាតាបិតាជាបុគ្គលប្រសើរជាងផៅពង្សទាំងឡាយ សត្វជាគម្រប់ ៣

( ក្រៅអំពីមាតាបិតា ) ឈ្មោះថាជាអ្នកអនុគ្រោះដល់បុគ្គលនោះមិនមានទេ បុគ្គលកាលវង្វៀសនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់ការស្ងាត់កំបាំងក្រៃលែងដល់មាតាបិតា ។ មាតាបិតា បងប្អូនស្រី បងប្អូនប្រុសនិងសម្លាញ់ ឬញាតិទាំងពីរប៉ែក របស់បុគ្គលនោះ បុគ្គលកាលវង្វៀសនូវការបែកធ្លាយមន្ត មិនគប្បីប្រាប់នូវការស្ងាត់កំបាំងដ៏ក្រៃលែងដល់មាតាបិតាជាដើមនោះឡើយ ។

បើទុកជាភរិយា ជាស្រីក្មេង ពោលពាក្យជាទីស្រឡាញ់ មានបុត្ត មានរូបល្អ មានយសដែលពួកញាតិចោមរោម ជាស្ត្រីវៀរបុរស ( ដទៃ ) បុគ្គលកាលបើវៀរនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់នូវការស្ងាត់កំបាំងដ៏ក្រៃលែងដល់ភរិយានោះទេ ។

[ ៥២០ ] បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំងទេ គប្បីរក្សានូវអាថ៌កំបាំងឲ្យដូចជារក្សាកំណប់ ដ្បិតអាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនប្រាប់គេជាការប្រពៃ ។ អ្នកប្រាជ្ញមិនគប្បីនិយាយប្រាប់អាថ៌កំបាំងដល់ស្ត្រី ដល់ជនជាសត្រូវ ដល់ជនឡើបឡប់ដោយអាមិសៈ ដល់ជនលួចគំនិតគ្នា ។ ជនណាញុំាងគេឲ្យដឹងអាថ៌កំបាំងដែលគេមិនទាន់ដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុកដូចមនុស្សខ្ញុំគេ ។ ជនទាំងឡាយមានចំនួនប៉ុន្មាននាក់ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្តីតក់ស្លុតមានចំនួនប៉ុណ្ណោះតែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីផ្សាយនូវអាថ៌កំបាំងឡើយ ។

នៅវេលាថ្ងៃអ្នកប្រាជ្ញគប្បីនិយាយអាថ៌កំបាំងក្នុងទីដ៏ស្ងាត់ នៅវេលារាត្រី

មិនគប្បីបញ្ចេញសំឡេងឲ្យហួសកម្រិត ព្រោះថាពួកជនអ្នកឈ្លបស្តាប់រមែង ឮនូវមន្ត ព្រោះហេតុនោះ មន្តក៏រមែងដល់នូវការបែកធ្លាយដោយឆាប់ ។

[ ៥២១ ] ក្រុងប្រកបដោយកំពែងដែកដ៏ធំមិនមានទ្វារ ( ចេញចូលមិនបាន ) ធ្វើអំពើដែលប្រកបដោយសាលា គឺរានផ្សារដ៏ល្អប្រកបដោយគូដែលគេជីកដោយជុំវិញយ៉ាងណា បុរសមានមន្តដែលគួរលាក់ទុក ក្នុងលោកនេះប្រាកដដល់ខ្ញុំយ៉ាងនោះដែរ ។ ម្នាលអ្នកមានអណ្តាតពីរ ពួកជនណាជាអ្នកមានមន្តគួរលាក់ទុក មានវាចាមិនល្ហល្ហាច ជាអ្នកមាំមួនក្នុងប្រយោជន៍របស់ខ្លួន សត្រូវទាំងឡាយរមែងចៀសចេញឆ្ងាយអំពីពួកជននោះ ដូចពពួកនៃសត្វចៀសចេញអំពីអាសិរពិស ។

[ ៥២២ ] ( បណ្ឌរកៈ... ) អចេលជាអ្នកបួស លះបង់ផ្ទះ អាក្រាតត្រងោល ប្រព្រឹត្តព្រោះហេតុតែអាហារ ខ្ញុំបើកបង្ហាញនូវអាថ៌កំបាំងចំពោះអចេលនោះឯង ( ព្រោះហេតុនោះ ) បានជាយើងឃ្លាតចាកអត្ថនិងធម៌ ។ បពិត្រសុបណ្ណរាជ បុគ្គលធ្វើដូចម្តេច មានសីលធម៌ដូចម្តេច ប្រព្រឹត្តវត្តដូចម្តេចឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្តីរប់អាន ( តណ្ហា ) សមណៈនោះ ធ្វើដូចម្តេចទើបទៅកាន់ឋានសួគ៌ ។

[ ៥២៣ ] ( សុបណ្ណរាជ... ) បុគ្គលប្រកបដោយហិរិ ដោយខន្តិ គឺសេចក្តីអត់ធន់ ដោយការទូន្មាន ( នូវឥន្ទ្រិយ ) ជាអ្នកមិនខឹង លះបង់នូវពាក្យញុះញង់ទើបឈ្មោះថា សមណៈ ប្រព្រឹត្តលះបង់នូវសេចក្តីរប់អាន ឯសមណៈនោះធ្វើយ៉ាងនេះឯងទើបចូលទៅកាន់ឋានសួគ៌បាន ។

[ ៥២៤ ] ( បណ្ឌរកៈ... ) មាតាឃើញកូនខ្ចីដែលកើតអំពីខ្លួន ហើយ បរិបោសអង្គែលសព្វសរីរាង្គកាយ យ៉ាងណាមិញ បពិត្រលោកជាធំជាងបក្សី លោកជាអ្នកអនុគ្រោះប្រាកដដល់ខ្ញុំដូចជាមាតា ( អនុគ្រោះ ) នូវបុត្តយ៉ាង នោះ ។

[ ៥២៥ ] ( សុបណ្ណរាជ... ) នែអ្នកមានអណ្ដាតពីរ អ្នកចូររួចអំពី ការសម្លាប់ក្នុងថ្ងៃនេះចុះ ព្រោះថាបុត្តមាន ៣ គឺសិស្ស ១ កូនគេឲ្យ ១ កូន កើតអំពីខ្លួន ១ បុត្តក្រៅពីនេះមិនមានឡើយ អ្នកចូរត្រេកអរចុះ អ្នកទុកជាបុត្ត ណាមួយរបស់ខ្ញុំហើយ ។

[ ៥២៦ ] ( អភិសម្ពុទ្ធគាថា ) ស្ដេចគ្រុឌ មានកំណើតពីរ ( លុះ ពោលពាក្យ ) យ៉ាងនេះហើយក៏ឋិតនៅលើផែនដី លែងសត្វមានអណ្ដាតពីរ ដោយពាក្យថា អ្នករួចក្នុងថ្ងៃនេះ កន្លងនូវភ័យទាំងពួងហើយ អ្នកត្រូវតែខ្ញុំ គ្រប់គ្រងក្នុងទីគោកនិងទឹកហើយ ។

ខ្ញុំជាទីពឹងរបស់អ្នក ដូចជាពេទ្យដ៏ឈ្លាស ( ជាទីពឹង ) របស់ពួកអ្នក មានជំងឺ ឬដូចជាអន្លង់ទឹកត្រជាក់ ( ជាប្រយោជន៍ ) របស់ពួកអ្នកស្រេក ទឹកឬក៏ដូចផ្ទះ ( ជាទីត្រូវការ ) របស់ពួកបុគ្គលដែលលំបាកដោយសន្សើម ត្រជាក់ ។

[ ៥២៧ ] ( សុបណ្ណរាជ... ) ម្នាលអ្នកជាជលាពុជៈ អ្នកធ្វើសេចក្ដី ស្និទ្ធស្នាលជាមួយនឹងអណ្ឌជៈជាសត្រូវហើយ នៅបើកបង្ហាញចង្កូម ( ធ្វើអ្វី ទៀត ) ភ័យនឹងមកដល់អ្នកអំពីទីណា ។

[ ៥២៨ ] ( បណ្ឌរកៈ... ) បុគ្គលត្រូវតែវៀរស្នៀសក្នុងបុគ្គលជាសត្រូវ មិនត្រូវទុកចិត្តបុគ្គលសូម្បីជាមិត្ត ( ព្រោះ ) ភ័យរមែងកើតឡើងអំពីបុគ្គលដែលមិនគួរភ័យ រមែងកាត់សូម្បីនូវឫសគល់ ( ជីវិត ) ។ បុគ្គលធ្វើនូវជម្លោះនឹងជនណា គប្បីទុកចិត្តជននោះដូចម្តេចកើត បុគ្គលគប្បីឋិតនៅដោយប្រុងប្រយ័ត្នជានិច្ច បុគ្គលនោះរមែងមិនត្រេកអរនឹងសត្រូវ ។

បុគ្គលគប្បីធ្វើឲ្យគេទុកចិត្តប៉ុន្តែមិនត្រូវទុកចិត្តគេ បុគ្គលដែលគេមិនរង្កៀសហើយ ប៉ុន្តែគប្បីរង្កៀសនឹងគេ បុគ្គលដទៃមិនដឹងនូវភាព ( របស់ខ្លួន ) យ៉ាងណាៗ វិញ្ញូបុរសគប្បីប្រឹងប្រែងដោយប្រការយ៉ាងនោះៗ ។

[ ៥២៩ ] ( អភិសម្ពុទ្ធគាថា ) បុរិសនាគទាំងពីរនោះ មានវណ្ណៈដូចជាទេវតា មានសភាពជាសុខុមាលជាតិស្មើគ្នា មានវ័យដ៏ល្អ មានគំនរនៃបុណ្យកៀកដៃគ្នា ដូចជាសេះគេទឹម បានចូលទៅកាន់សំណាក់នៃអចេល ឯកំពង់ករម្បិយៈ ។

[ ៥៣០ ] លំដាប់នោះឯងបណ្ឌរកនាគរាជ បានចូលទៅកាន់សំណាក់នៃអចេលដោយខ្លួនឯង ហើយពោលពាក្យនេះថា ខ្ញុំរួច ( អំពីការសម្លាប់ ) កន្លងនូវភ័យទាំងពួង ក្នុងថ្ងៃនេះហើយ យើងមិនជាទីស្រឡាញ់របស់លោកដោយចិត្តពិតប្រាកដទេ ។

[ ៥៣១ ] ( អចេល... ) សុបណ្ណរាជជាទីស្រឡាញ់របស់ខ្ញុំជាងបណ្ឌរកនាគរាជមែន ឥតសង្ស័យ ( នេះ ) ជាពាក្យពិត ខ្ញុំនោះជាអ្នកត្រេកអរដោយរាគៈ ជាអ្នកដឹងច្បាស់បានធ្វើនូវអំពើអាក្រក់ទុំះ មិនមែនព្រោះមោហៈ

ទេ ។

[ ៥៣២ ] ( បណ្ឌរកៈ... ) បព្វជិតកាលឃើញច្បាស់នូវលោកនេះនិងលោកខាងមុខ រមែងមិនមានគំនិតថា វត្ថុជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់របស់អញដូច្នេះទេ អ្នកជាបុគ្គលមិនសង្រួម ប្រព្រឹត្តក្នុងលោកនេះដោយភេទរបស់បុគ្គលអ្នកសង្រួមល្អ ។ អ្នកឯងបន្ទំជាអរិយៈ តែមិនមែនជាអរិយៈទេ អ្នកមិនសង្រួមតែមានភាពហាក់ដូចជាអ្នកសង្រួម មានជាតិខ្មៅ មានសភាពមិនប្រសើរ បានប្រព្រឹត្តនូវអំពើដ៏លាមកទុច្ចរិតច្រើនយ៉ាង ។

[ ៥៣៣ ] ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្តដែលមិនបានប្រទូស្តវិញផង ជាអ្នកញុះញង់ផង ដោយពាក្យសច្ចៈនេះ សូមឲ្យក្បាលរបស់អ្នកឯងបែកជា ៧ ភាគ ។

[ ៥៣៤ ] ( អភិសម្ពុទ្ធគាថា ) ព្រោះហេតុនោះ បុគ្គលមិនត្រូវប្រទូស្តមិត្តទាំងឡាយឡើយ ព្រោះថាសភាវៈដទៃលាមកជាងការទ្រុស្តមិត្ត មិនមានទេ អចេលអ្នកសង្រួមត្រូវសត្វអាសិរពិសប្រទេចផ្តាសា ក៏ខ្ទាត់ចេញអំពីដែនដី វិនាសតាមពាក្យរបស់នាគរាជដ៏ប្រសើរ ។

**ចប់ បណ្ឌរកជាតក ទី ៨ ។**

## អដ្ឋកថា

## បណ្ឌារកជាតក

[ ៥១៦-៥៣៤ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការដែលទេវទត្តធ្វើមុសាវាទ ហើយត្រូវផែនដីស្រូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វិកិណ្ណវាចំ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា កាលពួកភិក្ខុនាំគ្នាពោលទោសទេវទត្ត ក្នុងគ្រានោះព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ធ្វើមុសាវាទ ត្រូវផែនដីស្រូបហើយដូចគ្នាដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ឈ្មួញ ៥០០ នាក់ ចេញសំពៅទៅកាន់សមុទ្រគ្រប់ ៧ ថ្ងៃ សំពៅដែលនៅក្នុងទីមិនឃើញច្រាំង បានបែកធ្លាយក្នុងសមុទ្រ ពួកមនុស្សបានជាចំណីត្រីនិងអណ្តើកទាំងអស់ សល់តែមនុស្សម្នាក់ប៉ុណ្ណោះ បុរសដែលសល់ម្នាក់នោះដោយកម្លាំងខ្យល់បក់អណ្តែតទៅដល់កំពង់ឈ្មោះករម្បិយៈ គាត់ឡើងអំពីសមុទ្របានហើយ អាក្រាតកាយ ដើរទៅសុំទានតាមកំពង់នោះ មនុស្សទាំងឡាយឃើញបុរសនោះក៏នាំគ្នាសរសើរថា បុរសនេះជាសមណៈ ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ហើយធ្វើសក្ការបូជា គាត់គិតថា អញបានឱកាសចិញ្ចឹមជីវិតហើយ កាលជនទាំងនោះឲ្យគ្រឿងស្លៀកដណ្តប់ក៏មិនបានប្រាថ្នា ជនទាំងនោះយល់ថា សមណៈដែលប្រាថ្នាតិចក្រៃលែងជាងនេះមិនមាន ដូច្នេះហើយនាំគ្នាជ្រះថ្លាក្រៃលែងឡើង នាំគ្នាសាងអាស្រមបទឲ្យអ្នកបួសអាក្រាតនោះ

ស្នាក់នៅក្នុងទីនោះ ។ គាត់មានឈ្មោះប្រាកដជាករម្បិយអចេលក កាលគាត់នៅក្នុងទីនោះ លាភសក្ការៈជាច្រើនកើតឡើងដល់គាត់ ។

ស្តេចនាគរាជមួយនិងស្តេចគ្រុឌមួយ នាំគ្នាមកកាន់ទីបម្រើរបស់អចេលក៍នោះ ។ ក្នុងសត្វទាំង ២ នោះ ស្តេចនាគឈ្មោះថា បណ្ឌរកនាគរាជ ។ ថ្ងៃមួយស្តេចគ្រុឌបានទៅកាន់សម្នាក់អចេលក៍នោះថ្វាយបង្គំហើយទំគ្រង់ចំណែកម្ខាងពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ញាតិរបស់ខ្ញុំ កាលចាប់ពួកនាគរមែងវិនាសទៅជាច្រើន ព្រោះពួកខ្ញុំមិនចេះរបៀបចាប់នាគ បានឮថា អាថ៌កំបាំងរបស់ពួកនាគទាំងនោះមាន លោកម្ចាស់អាចលួងលោម សួរហេតុនោះនឹងពួកនាគបានឬទេ ។ អចេលក៍ស្តាប់ពាក្យនោះហើយ កាលគ្រុឌថ្វាយបង្គំហើយលាត្រឡប់ទៅ ក្នុងកាលដែលស្តេចនាគមករក ទើបសួរនាគដែលថ្វាយបង្គំហើយអង្គុយថា នែស្តេចនាគ ឮថាកាលពួកគ្រុឌចាប់ពួកអ្នក ត្រូវវិនាសទៅជាច្រើន ហេតុអ្វីកាលចាប់ពួកអ្នកមិនអាចចាប់បាន ។ ស្តេចនាគតបថា បពិត្រលោកម្ចាស់ សេចក្តីនេះជាអាថ៌កំបាំងសម្រាប់ពួកខ្ញុំ បើខ្ញុំប្រាប់ហេតុនេះហើយរមែងបានឈ្មោះថា នាំសេចក្តីស្លាប់មកឲ្យដល់ពួកញាតិ ។ អចេលក៍ក៏ពោលថា អាវុសោ អ្នកយល់ថា មនុស្សបែបយើងនេះនឹងប្រាប់ដល់អ្នកដទៃយ៉ាងនេះឬ យើងមិនប្រាប់ដល់អ្នកដទៃឡើយ យើងសួរព្រោះយើងចង់ដឹង អ្នកជឿយើងហើយត្រូវផុតភ័យ ចូរប្រាប់ចុះ ស្តេចនាគឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំប្រាប់មិនបាន ហើយថ្វាយបង្គំលាចៀសចេញទៅ ។ ស្អែកឡើងអចេលក៍នោះសួរទៀត ទោះជាយ៉ាងនោះ ស្តេចនាគក៏មិនព្រមប្រាប់ដដែល

ក្នុងកាលតមកក្នុងថ្ងៃទី ៣ អ្នកបួសអាក្រាត សួរស្តេចនាគដែលមកអង្គុយថា ថ្ងៃនេះជាថ្ងៃទី ៣ កាលខ្ញុំសួរ ហេតុអ្វីទើបអ្នកមិនប្រាប់ ។ ស្តេចនាគឆ្លើយថា បពិត្រលោកម្ចាស់ ព្រោះខ្ញុំខ្លាចលោកម្ចាស់ប្រាប់ដល់អ្នកដទៃ ។ អ្នកបួសអាក្រាតបញ្ជាក់ថា យើងមិនប្រាប់ដល់អ្នកណាឡើយ អ្នកមិនមានភ័យឡើយ ចូរប្រាប់មកចុះ ។ ស្តេចនាគក៏ពោលថា បពិត្រលោកម្ចាស់ បើដូច្នោះសូមលោកម្ចាស់ កុំប្រាប់អ្នកដទៃឡើយ ទទួលបេ្តជ្ញាហើយទើបប្រាប់ថា បពិត្រលោកម្ចាស់ ពួកខ្ញុំលេបដុំថ្មធំៗចូលទៅ ធ្វើខ្លួនឲ្យធ្ងន់ហើយដេក ក្នុងកាលពួកគ្រុឌមកក៏អើតក្បាល បញ្ចេញចង្កូមចាំត្របាក់គ្រុឌ ពួកគ្រុឌមកដល់ ក៏ចាប់ក្បាលរបស់ពួកខ្ញុំ កាលវាព្យាយាមទាញពួកខ្ញុំដែលដូចជាភារៈធ្ងន់ ទឹកក៏លិចសន្កត់វា ពួកវាក៏ស្លាប់ក្នុងទឹកនោះឯង ព្រោះហេតុនេះទើបពួកគ្រុឌវិនាសជាច្រើន បើពួកវាចង់ចាប់ពួកខ្ញុំ មិនត្រូវចាប់ត្រង់ក្បាល ពួកគ្រុឌល្ងង់ៗត្រូវចាប់ត្រង់កន្ទុយ ធ្វើពួកខ្ញុំឲ្យមានក្បាលសំយុងចុះ ដុំថ្មដែលពួកខ្ញុំលេបក៏ចេញតាមមាត់ ខ្លួនខ្ញុំនឹងស្រាលហើយអាចចាប់យកទៅបាន ស្តេចនាគប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់អចេលកទ្រុស្តសីលដោយប្រការដូច្នេះ ។

កាលស្តេចនាគលាត្រឡប់ទៅហើយ តមកស្តេចគ្រុឌមកថ្វាយបង្គំករម្បិយៈអចេលក ហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់សួរអាថ៌កំបាំងរបស់ស្តេចនាគហើយឬ អ្នកបួសអាក្រាតឆ្លើយថា អើអាវុសោ ហើយប្រាប់តាមដែលស្តេចនាគប្រាប់ដល់ខ្លួននោះគ្រប់ប្រការ ។ ស្តេចគ្រុឌបានស្តាប់ដូច្នោះ ទើបគិតថា ស្តេចនាគធ្វើកម្មដែលមិនសមគួរ ធម្មតាផ្លូវដែលឲ្យពួក

ញាតិវិនាសមិនគួរប្រាប់ដល់អ្នកដទៃឡើយ ឥឡូវដឹងមកដល់អញហើយ ថ្ងៃនេះ អញគួរធ្វើខ្យល់ដែលចេញអំពីកម្ចាំងស្លាប ចាប់បណ្ឌរកនាគរាជនេះមុនគេនោះឯង ។ ស្តេចគ្រុឌក៏ធ្វើខ្យល់ដោយកម្លាំងស្លាប ចាប់បណ្ឌរកនាគរាជត្រង់កន្ទុយ ធ្វើក្បាលឲ្យចុះក្រោម ធ្វើឲ្យអាហារដែលលេបធ្លាក់ចុះទៅ ហើយហោះឡើងទៅក្នុងអាកាស ។ បណ្ឌរកនាគរាជ កាលក្បាលកំពុងសំយុងចុះក្នុងអាកាស ក៏សោកខ្សឹកខ្សួលថា អញនាំទុក្ខមកឲ្យដល់ខ្លួនឯងពិត ក៏ពោលគាថាដោយសេចក្តីថា

ភ័យខ្លួនឯង រមែងជាប់តាមនូវបុគ្គលដែលមានវាចាល្ហល្ហាច
មានមន្តមិនលាក់ទុក ជាអ្នកមិនសង្រួម មិនចេះពិចារណា ជា
អ្នកល្ងង់នោះ ដូចជាគ្រុឌចាប់យកនាគឈ្មោះបណ្ឌរកៈ ។ ជន
ណារីករាយប្រាប់មន្តដែលគួរលាក់ គួររក្សាទុក ព្រោះសេចក្តី
វង្វេង ភ័យរមែងជាប់តាមនូវជន ដែលមានមន្តបែកធ្លាយនោះ
ដោយឆាប់ ដូចជាគ្រុឌចាប់យកនាគឈ្មោះបណ្ឌរកៈ ។

មិត្តគ្រាន់តែបណ្តោយតាម គេមិនគួរឲ្យដឹងនូវហេតុជាទម្ងន់
ដែលគួរលាក់ ទាំងមិត្តល្អ ជាអ្នកមិនយល់ការឬយល់ការដែរ
តែជាអ្នកមិនប្រព្រឹត្តប្រយោជន៍ ( ក៏គេមិនគួរឲ្យដឹងដែរ ) ។
អញដល់នូវសេចក្តីទុកចិត្តអចេល អចេលនេះជាសមណៈគេ
រាប់អានហើយ មានចិត្តចម្រើនហើយ អញក៏ប្រាប់បើកនូវ
អាថ៌កំបាំងដល់អចេលនោះ បានជាអញមានប្រយោជន៍កន្លង

ហួស ហើយទួញយំ កំព្រាម្នាក់ឯង ។ បពិត្រគ្រុឌដ៏ប្រសើរ ព្រោះខ្ញុំមិនអាចនឹងសង្រួមវាចាដ៏ប្រសើរកំបាំងនេះដល់អចេល នោះ បានជាភ័យមកដល់ខ្ញុំអំពីចំណែកនៃអចេលនោះ ទើបខ្ញុំ ជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រាហើយទួញយំ ។ ជន ណាសំគាល់នូវបុគ្គលថាមានចិត្តល្អ ប្រាប់នូវអាថ៌កំបាំងចំពោះ ជនមានត្រកូលដ៏អាក្រក់ព្រោះទោសាគតិ ភយាគតិឬត្រេកអរ ដោយអំណាចរាគៈ ជននោះជាមនុស្សល្ងង់ឈ្មោះថាក្លាត់ហើយ ដោយឥតសង្ស័យ ។ ជនណាមានវាចាចេញទៅខាងក្រៅ រាប់ ចូលក្នុងពួកអសប្បុរស កម្ចាយនូវពាក្យ ( កំបាំងរបស់គេ ) ក្នុងទីប្រជុំ អ្នកប្រាជ្ញទាំងឡាយហៅជននោះថា ជាអ្នកមានមាត់ អាក្រក់ដូចអាសិរពិស បុគ្គលគប្បីថយចាកបុគ្គលបែបនោះឲ្យ ឆ្ងាយចេញអំពីចម្ងាយ ។ យើងលះបង់នូវកាមទាំងពួង គឺបាយ ទឹក សំពត់ក្នុងដែនកាសីនិងខ្លឹមចន្ទន៍ ពួកស្ត្រី ជាទីគាប់ចិត្ត កម្រងផ្កានិងគ្រឿងប្រោះព្រំ បពិត្រសុបណ្ណៈ យើងសូមដល់ នូវលោក ( ជាទីពឹង ) ស្មើដោយជីវិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិកិណ្ណវាចំ** បានដល់ មានវាចាផ្សាយទៅ ហើយ ។ បទថា **អនិគុយ្ហមន្តំ** បានដល់ បុគ្គលមានការរដឹងមិនបិទបាំង ។ បទថា **អសញ្ញតំ** បានដល់ ដែលមិនអាចរក្សាកាយទ្វារជាដើមបាន ។ បទ ថា **អបរិចក្ខិតារំ** សេចក្តីថា មិនអាចត្រួតត្រាពិចារណាមើលថា បុគ្គលនេះ

អាច ឬមិនអាចដែលនឹងរក្សាមន្ត ( ការប្រឹក្សា ) ដែលអញប្រាប់ហើយ ។ បទថា **ភយំ តមន្វេតិ** សេចក្តីថា បុគ្គលប្រកបដោយអង្គទាំង ៤ នេះ ។ បទថា **អហោជំ** សេចក្តីថា ភ័យដែលខ្លួនឯងនោះឯងធ្វើរមែងជាប់តាមបុគ្គលខ្វះបញ្ញា ដូចស្តេចគ្រុឌជាប់តាមអញដែលឈ្មោះបណ្ឌរកនាគរាជ ដូច្នោះ ។ បទថា **សំសតិ ហាសមាណោ** សេចក្តីថា បុគ្គលណាត្រេកអរប្រាប់មន្តកំបាំងដែលខ្លួនគួររក្សាដល់បុគ្គលអាក្រក់ មិនអាចរក្សាបាន ។ បទថា **ឆាន្នមិត្តោ** សេចក្តីថា ស្តេចនាគបណ្ឌរកៈបរិទេវនាការថា បុគ្គលណាជាមិត្តគ្រាន់តែចាក់បណ្តោយតាម មិនមែនជាមិត្តដោយហទយៈ បុគ្គលនោះមិនគួរប្រាប់សេចក្តីដែលជាអាថ៌កំបាំងឡើយ ។

បទថា **អសម្ពុទ្ធំ** បានដល់ ជាបុគ្គលល្ងង់ គឺមិនដឹង អធិប្បាយថា មិនមានបញ្ញា ។ បទថា **សម្ពុទ្ធំ** សេចក្តីថា ជាបុគ្គលឈ្លាស គឺដឹង អធិប្បាយថាជាអ្នកមានប្រាជ្ញា ។ មានពាក្យអធិប្បាយដូច្នេះថា បុគ្គលណាជាមិត្តមានចិត្តល្អ សូម្បីមិនមានបញ្ញាក៏ដោយ ហើយបុគ្គលណាសូម្បីមានបញ្ញា តែមានការប្រព្រឹត្តវត្តមិនជាប្រយោជន៍ គឺប្រព្រឹត្តលំអៀងទៅក្នុងអនត្ថៈ បុគ្គលនោះរមែងមិនគួរឲ្យដឹងអាថ៌កំបាំងឡើយ ។ បទថា **សមណោ អយំ** សេចក្តីថា ស្តេចនាគនោះបរិទេវនាការថា ខ្ញុំសម្គាល់ថាបុគ្គលនេះជាសមណៈ ដោយសត្វលោកតម្កើងរាប់អានផង មានខ្លួនអប់រំហើយផង ទើបដល់នូវការស្និទ្ធស្នាលក្នុងបុគ្គលនោះ ។ បទថា **អក្ខិំ** បានដល់ ប្រាប់ហើយ ។ បទថា **អតីតមត្ថោ** សេចក្តីថា ឥឡូវនេះខ្ញុំដាច់ប្រយោជន៍ហើយ គឺជាអ្នកកន្លងបង់នូវប្រ-

យោជន៍ហើយត្រូវទួញយំដូចមនុស្សកំព្រា ។ បទថា **តស្ស** សេចក្ដីថា ដល់អចេលកៈនោះ ។

ស្ដេចនាគហៅស្ដេចគ្រុឌថា **ព្រហ្មេ** ប្រែថា ស្ដេចគ្រុឌដ៏ប្រសើរ ។

បទថា **សំយមេតុំ** សេចក្ដីថា ខ្ញុំមិនអាចរក្សាវាចាកំបាំងបាន គឺអាថ៌កំបាំងនេះបាន ។ បទថា **តប្បក្ខតោ ហិ** សេចក្ដីថា ស្ដេចនាគបរិទេវនាការថា ឥឡូវនេះភ័យមកដល់យើងហើយអំពីចំណែក គឺអំពីសម្នាក់របស់អ្នកបួសអាក្រាតនោះ ខ្ញុំដាច់នូវប្រយោជន៍ហើយត្រូវទួញយំដូចមនុស្សកំព្រាយ៉ាងនេះ ។ បទថា **សុហាទំ** សេចក្ដីថា បុគ្គលណាសម្គាល់ថា បុគ្គលនេះមានបំណងល្អចំពោះអញ ។ បទថា **ទុក្កុលីនេ** បានដល់ កើតក្នុងត្រកូលអាក្រក់ គឺត្រកូលថោកទាប ។ បទថា **ទោសា** សេចក្ដីថា បុគ្គលណាប្រាប់នូវអាថ៌កំបាំងបែបនេះដោយហេតុ មានទោសាគតិជាដើមនេះ បុគ្គលនោះជាបុគ្គលល្ងង់ថោកថយ រិលទៅដល់ភាពថោកទាប ឈ្មោះថាវិនាសហើយពិតប្រាកដដោយឥតសង្ស័យ ។ បទថា **តិរោក្ខវាចោ** សេចក្ដីថា បុគ្គលណាឈ្មោះថាមានវាចាមិនបិទបាំង ព្រោះធ្វើពាក្យដែលខ្ញុំនបំណងនឹងពោលខាងក្រៅ ។ បទថា **អសតំ បរិដ្ឋោ** សេចក្ដីថា រាប់ចូលក្នុងចំនួនអសប្បុរស គឺទាក់ទងក្នុងពួកអសប្បុរស ។

បទថា **សង្គតីសុ មុធិរេតិ** សេចក្ដីថា បុគ្គលណាមានលក្ខណៈយ៉ាងនេះ គឺបានឮអាថ៌កំបាំងរបស់អ្នកដទៃ ហើយនិយាយទៅក្រៅកណ្ដាលប្រជុំជនថា វត្ថុនោះបុគ្គលនោះធ្វើ ពាក្យនេះបុគ្គលនោះនិយាយដូច្នេះ អ្នកប្រាជ្ញហៅមនុស្ស

បែបនោះថាជាអ្នកមានមាត់អាក្រក់ មានមាត់ស្អុយ ដូចអាសិរពិស គួរវាងំ ប្រយ័ត្នបុគ្គលបែបនោះអំពីចម្ងាយ គឺគួរវៀរ គួរវៀរចាកបុគ្គលនោះពីចម្ងាយនោះឯង ។ បទថា **មាលមុច្ឆានធញ្ច** សេចក្តីថា ខ្ញុំបោះបង់ចោលនូវទិព្វ-មាលា ចតុគន្ធជាតិនិងគ្រឿងលាប ។ បទថា **ឱហាយ** សេចក្តីថា ថ្ងៃនេះខ្ញុំលះបង់ គឺបោះបង់នូវកាមារម្មណ៍ទាំងអស់ មានអាហារទិព្វជាដើមទៅហើយ ។ បទថា **សុបណ្ណ ចាណភូបគតាវ ត្យម្ហា** សេចក្តីថា ស្តេចគ្រុឌដ៏ចម្រើន ខ្ញុំដល់លោកស្មើដោយជីវិត សូមលោកជាទីពឹងដល់ខ្ញុំចុះ ។ បណ្ឌរកនាគរាជមានក្បាលសំយុងចុះក្នុងអាកាស បរិទេវនាការដោយគាថាទាំង ៨ យ៉ាងនេះ ស្តេចគ្រុឌបានឮសំឡេងទួញយំរបស់ស្តេចនាគនោះ ក៏តិះដៀលស្តេចនាគនោះថា នៃនាគ លោកប្រាប់អាថិកំបាំង ដល់អ្នកបួសអាក្រាត ហេតុអ្វីទើបឥឡូវនេះបរិទេវនាការទៅវិញ ហើយពោលគាថានេះថា

> ម្នាលនាគរាជ បណ្តាជនទាំង ៣ នាក់ ក្នុងទីនេះ តើសត្វណា
> គឺសមណៈ ឬគ្រុឌ ឬអ្នកឯង គួរដល់នូវសេចក្តីតិះដៀលបាន
> ក្នុងលោកនេះ ម្នាលបណ្ឌរកៈ ( អ្នកឯងត្រូវខ្ញុំ ) ចាប់បាន
> ព្រោះហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោធីធ** សេចក្តីថា ក្នុងពួកយើងទាំង ៣ មានក្នុងទីនេះតើអ្នកណា ។ បទថា **ឥធ** ក្នុងបទថា **អស្មីធ** នេះត្រឹមតែជានិបាតឯសេចក្តីក៏គឺក្នុងលោកនេះ ។ បទថា **ចាណភូ** បានដល់ សត្វមានជីវិត ។ បទថា **អថវា ត្វមេវ** សេចក្តីថា ឬលោកម្នាក់ឯង ។

ក្នុងគាថានេះមានអធិប្បាយដូច្នេះថា ក្នុងពួកយើងទាំង ៣ កុំតិះដៀលអ្នកបួសអាក្រាត ព្រោះអ្នកបួសអាក្រាតនោះសួរអាថ៌កំបាំងដោយឧបាយ លោកកុំតិះដៀលសុបណ្ណរាជឡើយ ព្រោះយើងក៏ជាសត្រូវរបស់លោកដោយត្រង់ ។ បទថា **បណ្ឌរក គហិតោ** សេចក្ដីថា នែសម្លាញ់បណ្ឌរកៈអើយ លោកសាកគិតមើលចុះថា អញត្រូវគ្រុឌចាប់ព្រោះអ្វីហើយក៏តិះដៀលខ្លួនត្រឹមតែម្នាក់ឯង ព្រោះកាលលោកប្រាប់សេចក្ដីកំបាំង ឈ្មោះថាខ្លួនធ្វើនូវសេចក្ដីវិនាសដល់ខ្លួនឯង ។ បណ្ឌរកនាគរាជបានស្ដាប់ដូច្នោះទើបពោលគាថានេះថា

អចេលជាសមណៈ ជាបុគ្គលមានសភាពដែលខ្ញុំរាប់អានហើយ ជាទីស្រឡាញ់ដោយចិត្តរបស់ខ្ញុំ មានខ្លួនចម្រើនហើយ ខ្ញុំប្រាប់បើកអាថ៌កំបាំង ដល់សមណៈនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រាហើយទួញយំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សម្មតត្តោ** សេចក្ដីថា មានសភាពដែលខ្ញុំសរសើរថា អ្នកបួសអាក្រាតនេះជាសមណៈ ជាសប្បុរសរបស់ខ្ញុំ ។ បទថា **ភាវិតត្តោ** សេចក្ដីថា មានសភាពដែលខ្ញុំសរសើរហើយ ។

លំដាប់នោះស្ដេចគ្រុឌបានពោល ៤ គាថាដោយសេចក្ដីថា

ធម្មតាសត្វលើផែនដីឈ្មោះថាមិនស្លាប់មិនមានទេ ចំណែកនៃបញ្ញាជាធម្មជាតិដែលបុគ្គលមិនគួរតិះដៀល នរជនក្នុងលោកនេះ រមែងនាំមកនូវគុណវិសេសដែលបុគ្គលមិនគួរបានដោយវចីសច្ចៈ ១ ដោយសុចរិតធម៌ ១ ដោយធិតិ គឺបញ្ញា ១

ដោយការទូន្មាននូវឥន្ទ្រិយ ១ ។ មាតាបិតាជាបុគ្គលប្រសើរ
ជាងផៅពង្សទាំងឡាយ សត្វជាគម្រប់ ៣ ( ក្រៅអំពីមាតា
បិតា ) ឈ្មោះថា ជាអ្នកអនុគ្រោះដល់បុគ្គលនោះមិនមានទេ
បុគ្គលកាលរង្កៀសនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់ការ
ស្ងាត់កំបាំងក្រៃលែងដល់មាតាបិតា ។ មាតាបិតា បងប្អូនស្រី
បងប្អូនប្រុសនិងសម្លាញ់ ឬញាតិទាំងពីរប៉ែករបស់បុគ្គលនោះ
បុគ្គលកាលរង្កៀសនូវការបែកធ្លាយមន្ត មិនគប្បីប្រាប់នូវការ
ស្ងាត់កំបាំងដ៏ក្រៃលែងដល់មាតាបិតាជាដើមនោះឡើយ ។

បើទុកជាភរិយា ជាស្រីក្មេង ពោលពាក្យជាទីស្រឡាញ់
មានបុត្ត មានរូបល្អ មានយសដែលពួកញាតិចោមរោម ជា
ស្ត្រីវៀរបុរស ( ដទៃ ) បុគ្គលកាលបើវៀរនូវការបែកធ្លាយ
នៃមន្ត មិនគប្បីប្រាប់នូវការស្ងាត់កំបាំងដ៏ក្រៃលែងដល់ភរិយា
នោះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អមរោ** សេចក្ដីថា ឈ្មោះថា សត្វដែលមិន
ស្លាប់មិនមានឡើយ ។ **ឆ** អក្ខរៈ ក្នុងបទថា **បញ្ញាវិធា ឆត្ថិ** ធ្វើនូវការ
ភ្ជាប់បទ អធិប្បាយថា ប្រភេទរបស់បញ្ញាមាន ។ លោកពោលអធិប្បាយទុក
ដូច្នេះថា នៃនាគរាជ សត្វដែលមិនស្លាប់មិនមានក្នុងលោកឡើយ ប្រភេទនៃ
បញ្ញាមានពិត ប្រភេទនៃបញ្ញា ពោលគឺចំណែកនៃបញ្ញារបស់អ្នកដទៃនោះ មិន
គួរនិន្ទាព្រោះហេតុនៃជីវិតរបស់ខ្លួន ។ ម្យ៉ាងទៀតបទថា **បញ្ញាវិធា** សេចក្ដី

ថា ធម្មជាតដទៃដែលឈ្មោះថាមិនគួរនិន្ទាដូចគ្នានឹងបញ្ញាមិនមាន ហេតុអ្វីទើប លោកនិន្ទាប្រភេទនៃបញ្ញានោះ ។ បាឋៈថា **បញ្ញាវិធានម្បិ ច និន្ទិតព្វំ** ដូច្នេះ ក៏មាន សេចក្តីថា ម្យ៉ាងទៀត ប្រភេទនៃបញ្ញារបស់បុគ្គលណាមិនគួរនិន្ទា ប្រភេទនៃបញ្ញារបស់បុគ្គលនោះដោយត្រង់នោះឯង ។

ក្នុងបទទាំងឡាយ មានបទថា **សច្ចេន** នេះ មានអធិប្បាយថា មនុស្ស ក្នុងលោកនេះ រមែងប្រមូលមក គឺនាំមកនូវគុណវិសេស ពោលគឺសមាបត្តិ ៨ មគ្គ ផលនិងនិព្វានដែលខ្លួនមិនទាន់បាន គឺបានដោយលំបាក បានដល់ ញុំាងគុណវិសេសនោះ ឲ្យសម្រេចដោយវចីសច្ចៈ ១ សុចរិតធម៌ ១ ធិតិ ពោលគឺបញ្ញា ១ ឥន្ទ្រិយទម គឺការទូន្មានឥន្ទ្រិយ ១ ព្រោះហេតុនោះ លោក មិនគួរតិះដៀលអ្នកបួសអាក្រាតឡើយ ចូរតិះដៀលខ្លួនឯងតែម្យ៉ាងចុះ ព្រោះ អ្នកបួសអាក្រាតជាអ្នកមានបញ្ញា ឈ្លាសក្នុងឧបាយ ទើបបញ្ឆោតយកអាថ៌ កំបាំង គឺមន្តដែលកំបាំងរបស់លោកបាន ។

បទថា **បរមា** សេចក្តីថា មាតាបិតាទាំង ២ នេះ ឈ្មោះថាជាពូជពង្ស ដ៏ឧត្តមរបស់ផៅពង្ស ។ បទថា **ជាស្ស តតិយោ** សេចក្តីថា បុគ្គលទី ៣ ដទៃក្រៅអំពីមាតាបិតា ឈ្មោះថាជាអ្នកអាណិតអាសូររមែងមិនមានសម្រាប់ បុគ្គលនោះ អធិប្បាយថា បុគ្គលឈ្លាសវៃ កាលរង្កៀសថាមន្តនឹងបែកធ្លាយ មិនគួរប្រាប់សេចក្តីសំខាន់ដែលកំបាំងដល់មាតាបិតាទាំង ២ ខ្លួនលោកត្រឡប់ ជាប្រាប់អាថ៌កំបាំងដែលខ្លួនមិនបានប្រាប់ដល់មាតាបិតា ដល់អ្នកបួសអាក្រាត ទៅវិញ ។ បទថា **សហាយា វា** បានដល់ មិត្តដែលមានចិត្តល្អ ។ បទថា

**សបក្ខា** បានដល់ ញាតិចំណែកខាងមាតាបិតា អ៊ំ មា មីងជាដើម ។ បទថា **តេសម្បិ** នេះ ស្តេចគ្រុឌសម្តែងសេចក្តីថា មនុស្សឈ្លាសមិនគួរប្រាប់អាថ៌កំបាំងដល់ញាតិមិត្តទាំងនេះឡើយ ឯលោកបែរជាប្រាប់ដល់អ្នកបួសអាក្រាត ចូរលោកក្រោធជាមួយខ្លួនឯងចុះ ។ បទថា **ភរិយា ចេ** សេចក្តីថា ភរិយាក្មេង ចរចាជាទីស្រឡាញ់ ដល់ព្រមដោយបុត្តធីតា ដល់ព្រមដោយរូបសម្បត្តិនិងយសសក្តិបែបនេះ បើពោលថា សូមលោកប្រាប់អាថ៌កំបាំងរបស់លោកដល់ខ្ញុំ ដូច្នេះ អ្នកប្រាជ្ញក៏មិនគួរប្រាប់សូម្បីដល់ភរិយានោះ ។

ស្តេចគ្រុឌពោលពាក្យជាគាថាបន្តថា

បុគ្គល មិនគប្បីបើកនូវអាថ៌កំបាំងទេ គប្បីរក្សានូវអាថ៌កំបាំងឲ្យដូចជារក្សាកំណប់ ដ្បិតអាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនប្រាប់គេជាការប្រពៃ ។ អ្នកប្រាជ្ញមិនគប្បីនិយាយប្រាប់អាថ៌កំបាំងដល់ស្ត្រី ដល់ជនជាសត្រូវ ដល់ជនឡើបឡប់ដោយអាមិសៈ ដល់ជនលួចគំនិតគ្នា ។ ជនណាញុំាងគេឲ្យដឹងអាថ៌កំបាំងដែលគេមិនទាន់ដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុកដូចមនុស្សខ្ញុំគេ ។ ជនទាំងឡាយមានចំនួនប៉ុន្មាននាក់ ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្តីតក់ស្លុតមានចំនួនប៉ុណ្ណោះតែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះអ្នកប្រាជ្ញមិនគប្បីផ្សាយនូវអាថ៌កំបាំងឡើយ ។

នៅវេលាថ្ងៃ

អ្នកប្រាជ្ញគប្បីនិយាយអាថ៌កំបាំងក្នុងទីដ៏ស្ងាត់ នៅវេលារាត្រី មិនគប្បីបញ្ចេញសំឡេងឲ្យហួសកម្រិត ព្រោះ ថា ពួកជនអ្នកឈ្លបស្តាប់រមែងឮនូវមន្ត ព្រោះហេតុនោះមន្ត ក៏រមែងដល់នូវការបែកធ្លាយដោយឆាប់ ដូច្នេះ ។

គាថាទាំង ៥ នេះនឹងមានច្បាស់ក្នុងបណ្ឌិតប្បញ្ហាក្នុងឧម្មង្គជាតក ។ ស្តេចត្រុឧពោល ២ គាថាបន្តអំពីនេះទៅដោយសេចក្តីថា

ក្រុងប្រកបដោយកំពែងដែកដ៏ធំមិនមានទ្វារ ( ចេញចូលមិនបាន ) ធ្វើអំពើដែលប្រកបដោយសាលា គឺរានផ្សារដ៏ល្អប្រកបដោយគូដែលគេជីកដោយជុំវិញយ៉ាងណា បុរសមានមន្តដែលគួរលាក់ទុកក្នុងលោកនេះប្រាកដដល់ខ្ញុំយ៉ាងនោះដែរ ។ ម្នាលអ្នកមានអណ្តាតពីរ ពួកជនណា ជាអ្នកមានមន្តគួរលាក់ទុក មានវាចាមិនល្ហល្ហាច ជាអ្នកមាំមួនក្នុងប្រយោជន៍របស់ខ្លួន សត្រូវទាំងឡាយ រមែងចៀសចេញឆ្ងាយអំពីពួកជននោះ ដូចពពួកនៃសត្វចៀសចេញអំពីអាសិរពិស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភន្ទសាលំ** សេចក្តីថា ដល់ព្រមដោយសាលា មានរានផ្សារជាដើម ។ បទថា **សមន្តខាតាបរិខាឧបេតំ** សេចក្តីថា ប្រកបដោយគូ ដែលជីកទុកដោយជុំវិញ ។ បទថា **ឯវម្បិ មេ** សេចក្តីថា បុរសទាំងនោះ គឺបុរសគ្រប់ពួកនោះឯងដែលមានអាថ៌កំបាំងក្នុងទីនេះ រមែង

ប្រាកដដល់ខ្ញុំ ហេតុនោះ លោកអធិប្បាយទុកថា គ្រឿងឧបភោគនិងបរិភោគរបស់មហាជន រមែងនៅខាងក្នុងនគរដែកដែលមិនមានទ្វារចេញចូលប៉ុណ្ណោះ បុគ្គលដែលនៅខាងក្នុងក៏មិនចេញទៅខាងក្រៅ បុគ្គលដែលនៅខាងក្រៅក៏មិនចូលទៅខាងក្នុងជាប់នូវការសញ្ចរទៅមកជាប់គ្នាយ៉ាងណា បុរសទាំងឡាយដែលជាអ្នកមានអាថ៌កំបាំង ត្រូវជាបុគ្គលយ៉ាងនោះ គឺឲ្យនូវអាថ៌កំបាំងរបស់ខ្លួនកប់នៅក្នុងចិត្តរបស់ខ្លួនតែម្នាក់ មិនត្រូវប្រាប់ដល់អ្នកដទៃឡើយ ។

បទថា **ធម្មា សធត្ថេសុ** សេចក្តីថា ជាអ្នកមាំទាំក្នុងប្រយោជន៍របស់ខ្លួន ស្តេចត្រូវឧហៅបណ្ឌរកនាគរាជថា **ទុជ្ជិវ្ហា** ប្រែថា អ្នកមានអណ្តាតអាក្រក់[១] ។ បទថា **ព្យវជន្តិ** បានដល់ រមែងចៀសឆ្ងាយទៅ ។ បទថា **វា** ក្នុងបាទគាថាថា **អាសីវិសា វារិវ សត្តសង្ឃា** នេះត្រឹមតែជានិបាត អធិប្បាយថា ដូចប្រជុំជនដែលប្រាថ្នាជីវិត វៀរឆ្ងាយពួកសត្វសាហាវនិងពួកអាសិរពិសដូច្នោះ ។ លោកពោលអធិប្បាយទុកថា សត្រូវរមែងចៀសឆ្ងាយអំពីបុគ្គលដែលមានអាថ៌កំបាំងទាំងនោះ ដូចពួកមនុស្សប្រាថ្នាជីវិតរមែងវៀរឲ្យឆ្ងាយពួកសត្វកាចមានអាសិរពិសជាដើមដូច្នោះ គឺមិនបានឱកាសដែលនឹងចូលជិត ។

កាលស្តេចត្រូវឧពោលធម៌យ៉ាងនេះហើយ បណ្ឌរកនាគរាជក៏ពោលគាថាដោយសេចក្តីថា

អចេលជាអ្នកបួសលះបង់ផ្ទះ អាក្រាត ត្រងោល ប្រព្រឹត្តព្រោះ

---

១-បិដកខ្មែរថា អ្នកមានអណ្តាតពីរ ។

ហេតុតែអាហារ ខ្ញុំបើកបង្ហាញនូវអាថ៌កំបាំងចំពោះអចេលនោះ
ឯង ( ព្រោះហេតុនោះ ) បានជាយើងឃ្លាតចាកអត្ថនិងធម៌ ។
បពិត្រសុបណ្ណរាជ បុគ្គលធ្វើដូចម្តេច មានសីលធម៌ដូចម្តេច
ប្រព្រឹត្តវត្តដូចម្តេច ឈ្មោះថា សមណៈ ប្រព្រឹត្តលះបង់នូវ
សេចក្តីរាប់អាន ( តណ្ហា ) សមណៈនោះធ្វើដូចម្តេចទើបទៅ
កាន់ឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃាសហេតុ** សេចក្តីថា អ្នកបួសអាក្រាតនោះមិនមានសិរី ត្រាច់ស្វែងរករបស់ទំពាររបស់ធាន់ ដើម្បីឲ្យពេញក្រពះ ។ បទថា **អបគតម្ហា** សេចក្តីថា ខ្ញុំប្រាសចាក គឺសាបសូន្យចាកអត្ថនិងធម៌ហើយ ។ កាលស្តេចនាគ ដឹងភាពជាសមណៈរបស់អ្នកបួសអាក្រាតហើយ កាលនឹងសួរបដិបទារបស់សមណៈទើបពោលពាក្យនេះថា **កថំករោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **កឹសីលោ** សេចក្តីថា ប្រកបដោយសីលដូចម្តេច

បទថា **កេន វតេន** សេចក្តីថា សមណៈ ឈ្មោះថា មានវត្ត ព្រោះសមាទានវត្តដូចម្តេច ។ បទថា **សមណោ ចរំ** សេចក្តីថា បុគ្គលដែលបានប្រព្រឹត្តបព្វជ្ជា ត្រូវលះតណ្ហាដែលប្រកាន់ថាជារបស់អញយ៉ាងណា ទើបឈ្មោះថា សមណៈដែលជាអ្នកបន្សាត់នូវបាបហើយ ។ បទថា **សគ្គំ** សេចក្តីថា សមណៈនោះ ត្រូវធ្វើដូចម្តេចទើបចូលដល់ទេវនគរដ៏ប្រសើរ ។ ស្តេចគ្រុឌពោលឆ្លើយជាគាថាដូច្នេះថា

បុគ្គលប្រកបដោយហិរិ ដោយខន្តិ គឺសេចក្តីអត់ធន់ ដោយ

ការទូន្មាន ( នូវឥន្ទ្រិយ ) ជាអ្នកមិនខឹង លះបង់នូវពាក្យញុះញង់ទើបឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្តីរាប់អាន ឯសមណៈនោះធ្វើយ៉ាងនេះឯង ទើបចូលទៅកាន់ឋានសួគ៌បាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិរិយា** សេចក្តីថា នែនាគរាជសម្លាញ់ បុគ្គលប្រកបដោយហិរិឱត្តប្បៈដែលជាសមុដ្ឋាន ទាំងខាងក្នុងនិងខាងក្រៅ ដោយអធិវាសនខន្តី ពោលគឺការអត់ធ្មត់និងប្រកបដោយការទូន្មានឥន្ទ្រិយ មានប្រក្រតីមិនក្រោធ វៀរចាកវាចាញុះញង់និងលះវត្ថុដែលប្រកាន់ថា ជារបស់អញ ដោយអំណាចនៃតណ្ហាបានហើយប្រព្រឹត្តបព្វជ្ជា ឈ្មោះថា ជាសមណៈដែលមានបាបរម្ងាប់ហើយដូចម្តេច ។ បទថា **សគ្គំ** សេចក្តីថា ស្តេចគ្រុឌពោលថា សមណៈនោះកាលធ្វើយ៉ាងនេះឯងរមែងចូលដល់ទេវនគរដ៏ប្រសើរដោយល្អ ។

បណ្ឌរកនាគរាជបានស្តាប់ធម្មកថារបស់ស្តេចគ្រុឌហើយ កាលអង្វរសូមជីវិតទើបពោលគាថាដូច្នេះថា

មាតាឃើញកូនខ្ចីដែលកើតអំពីខ្លួន ហើយបបោសអង្អែលសព្វសព៌ាង្គកាយយ៉ាងណាមិញ បពិត្រលោកជាធំជាងបក្សី លោកជាអ្នកអនុគ្រោះ ប្រាកដដល់ខ្ញុំដូចជាមាតា ( អនុគ្រោះ ) នូវបុត្តយ៉ាងនោះ ដូច្នេះ ។

គាថានោះមានអធិប្បាយដូច្នេះថា មាតាឃើញកូនតូចដែលកើតពីខ្លួន កើត

ហើយក្នុងសរីរៈខ្លួនហើយឲ្យដេកប្របទ្រូង ឲ្យបៅដោះ ផ្សាយនូវចំណែកនៃរាងកាយដើម្បីការពារបុត្ត គឺមាតាមិនទៅអំពីបុត្ត បុត្តក៏មិនទៅអំពីមាតាយ៉ាងណា សូមលោកប្រាកដដល់ខ្ញុំយ៉ាងនេះចុះ ។ បទថា **ឆិជិន្ន** សេចក្តីថា ស្តេចនាគពោលថា បពិត្រមហារាជជាធំនៃទិជជាតិ សូម្បីលោកក៏សូមឃើញដល់ខ្ញុំ សូមឲ្យជីវិតដល់ខ្ញុំដូចមាតាអាណិតបុត្តដោយដួងហទយៈទន់ភ្លន់ដូច្នោះចុះ ។

លំដាប់នោះស្តេចគ្រុឌ កាលនឹងឲ្យជីវិតដល់ស្តេចនាគ ទើបពោលគាថាក្រៅអំពីនេះថា

> នៃអ្នកមានអណ្តាតពីរ អ្នកចូររួចអំពីការសម្លាប់ ក្នុងថ្ងៃនេះចុះ
> ព្រោះថាបុត្តមាន ៣ គឺសិស្ស ១ កូនគេឲ្យ ១ កូនកើតអំពី
> ខ្លួន ១ បុត្តក្រៅពីនេះមិនមានឡើយ អ្នកចូរត្រេកអរចុះ អ្នក
> ទុកជាបុត្តណាមួយរបស់ខ្ញុំហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មុច្ច** បានដល់ ចូររួចផុត ។ មា្យ៉ាងទៀតបាឋៈព្រះបាលីក៏យ៉ាងនេះឯង ។ បទថា **ទុជិវ្ហ** សេចក្តីថា ស្តេចគ្រុឌហៅនាគរាជនោះថា **ទុជិវ្ហ** ។ អធិប្បាយថា ឈ្មោះថាបុត្តដទៃជាគម្រប់ ៤ មិនមាន ។ បទថា **អន្តេវាសី** បានដល់ បុត្តដែលរៀនសិប្បៈឬស្តាប់បញ្ហាក្នុងសម្នាក់ ។

បទថា **ទិន្នកោ** បានដល់ បុត្តដែលអ្នកដទៃឲ្យដោយពាក្យថា ក្មេងនេះសូមជាកូនរបស់អ្នកចុះ ។ បទថា **រមស្សុ** បានដល់ ចូរត្រេកអរ ។ ដោយបទថា **អញ្ញតរោ** នេះ ស្តេចគ្រុឌសម្តែងសេចក្តីថា កូន ៣ ពួកនោះ អ្នកចូរកើតជាអន្តេវាសិណាមួយរបស់យើង ។ កាលស្តេចគ្រុឌពោលយ៉ាងនេះក៏

ចុះអំពីអាកាសធ្លាក់ទាគត្រង់ផែនដី ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់ព្រះគាថា ២ ដោយសេចក្តីថា

ស្តេចគ្រុឌមានកំណើតពីរ ( លុះពោលពាក្យ ) យ៉ាងនេះ
ហើយ ក៏ឋិតនៅលើផែនដី លែងសត្វមានអណ្តាតពីរដោយ
ពាក្យថា អ្នករួចក្នុងថ្ងៃនេះកន្លងនូវភ័យទាំងពួងហើយ អ្នកត្រូវ
តែខ្ញុំគ្រប់គ្រងក្នុងទីគោកនិងទឹកហើយ ។

ខ្ញុំជាទីពឹងរបស់អ្នកដូចជាពេទ្យដ៏ឈ្លាស ( ជាទីពឹង ) របស់
ពួកអ្នកមានជំងឺ ឬដូចជាអន្លង់ទឹកត្រជាក់ ( ជាប្រយោជន៍ )
របស់ពួកអ្នកស្រេកទឹក ឬក៏ដូចផ្ទះ ( ជាទីត្រូវការ ) របស់
ពួកបុគ្គលដែលលំបាកដោយសន្សើមត្រជាក់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥច្ចេវ វាក្យំ** សេចក្តីថា ស្តេចគ្រុឌកាលពោលពាក្យយ៉ាងនេះ ដោយប្រការដូច្នេះហើយ ក៏លែងនាគរាជនោះ ។ បទថា **ភូម្យំ** សេចក្តីថា ស្តេចគ្រុឌនោះប្រតិស្ឋានលើផែនដីដោយខ្លួនឯង លែងនូវស្តេចនាគដែលមានអណ្តាតអាក្រក់បណ្តើរ ពោលបណ្តើរថា ថ្ងៃនេះអ្នករួចផុតហើយ ចាប់អំពីថ្ងៃនេះទៅអ្នកផុតភ័យទាំងពួង ជាបុគ្គលដែលយើងគ្រប់គ្រងរក្សាទាំងផ្លូវគោកនិងផ្លូវទឹកចុះ ។ បទថា **អាតង្កិនំ** បានដល់ របស់អ្នកជំងឺ ។ បទថា **ឯវម្បិ តេ** សេចក្តីថា ខ្ញុំជាទីពឹងរបស់អ្នកដូចគ្រូពេទ្យដ៏ឈ្លាសជាទីពឹងរបស់អ្នកជំងឺជាដើមដូច្នោះ ។ ស្តេចគ្រុឌលែងនាគរាជទៅ ពោលថា

ចូរអ្នកទៅចុះ ។ នាគរាជនោះក៏ចូលទៅកាន់នាគពិភព ។ ចំណែកស្តេចគ្រុឌត្រឡប់ទៅកាន់សុបណ្ណភពហើយគិតថា បណ្ឌរកនាគរាជ អញបានធ្វើនូវការស្បថលែងទៅហើយតើមានទឹកចិត្តចំពោះអញដូចម្តេចហ្ន៎ អញនឹងសាកល្បងមើលហើយទៅកាន់នាគពិភពបានធ្វើខ្យល់នៃគ្រុឌ ។ ស្តេចនាគឃើញដូច្នោះសម្គាល់ថាស្តេចគ្រុឌមកចាប់អញទើបនិម្មិតអត្តភាពប្រមាណ ១០០០ ព្យាមលេបដុំថ្មនិងខ្សាច់ទុកក្នុងខ្លួនឲ្យធ្ងន់ធ្ងាយរង្វេលក្បែរជ្រោះ ។ ខណៈនោះសរីរៈកាយរបស់ស្តេចនាគនោះជាហេតុឲ្យព្រៃមានពន្លឺដូចគ្នាតែមួយ បានដេកបើកពពារធ្វើអាការហាក់ដូចចាំត្របាក់ស្តេចគ្រុឌ ។ ស្តេចគ្រុឌឃើញដូច្នោះ ទើបពោលគាថាក្រៅអំពីនេះថា

ម្នាលអ្នកជាជលាពុជៈ អ្នកធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹង
អណ្ឌជៈជាសត្រូវហើយនៅបើកបង្ហាញចង្កូម ( ធ្វើអ្វីទៀត )
ភ័យនឹងមកដល់អ្នកអំពីទីណា ដូច្នេះ ។

ស្តេចនាគបានស្តាប់ដូច្នោះទើបពោល ៣ គាថានេះថា

បុគ្គលត្រូវតែរង្កៀសក្នុងបុគ្គលជាសត្រូវ មិនត្រូវទុកចិត្ត
បុគ្គលសូម្បីជាមិត្ត ( ព្រោះ ) ភ័យរមែងកើតឡើង អំពីបុគ្គល
ដែលមិនគួរភ័យ រមែងកាត់សូម្បីនូវឫសគល់ ( ជីវិត ) ។
បុគ្គលធ្វើនូវជម្លោះនឹងជនណា គប្បីទុកចិត្តជននោះដូចម្តេច
កើត បុគ្គលគប្បីឋិតនៅដោយប្រុងប្រយ័ត្នជានិច្ច បុគ្គលនោះ
រមែងមិនត្រេកអរនឹងសត្រូវ ។

បុគ្គលគប្បីធ្វើឲ្យគេទុកចិត្ត ប៉ុន្តែមិនត្រូវទុកចិត្តគេ បុគ្គលដែលគេមិនរង្កៀសហើយ ប៉ុន្តែគប្បីរង្កៀសនឹងគេ បុគ្គលដទៃមិនដឹងនូវភាព ( របស់ខ្លួន ) យ៉ាងណាៗ វិញ្ញូបុរស គប្បីប្រឹងប្រែងដោយប្រការយ៉ាងនោះៗ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភយា** សេចក្តីថា ភ័យកើតឡើងអំពីមិត្តដែលជាទីតាំងនៃការផុតភ័យ រមែងកាត់នូវឫសគល់ ពោលគឺជីវិតបានពិត ។ បទថា **តស្មិំ** ស្មើគ្នានឹង **តស្មឹ** បានដល់ ក្នុងបុគ្គលនោះ ។ បទថា **យេនាសិ** បានដល់ បុគ្គលដែលធ្លាប់ធ្វើនូវជម្លោះនឹងគ្នាមកហើយ ។ បទថា **និច្ចយត្តេន** បានដល់ ដោយការប្រយ័ត្នខ្លួនជានិច្ច ។ បទថា **សោ ធិសត្តិ ន រជ្ជតិ** សេចក្តីថា បុគ្គលណាតាំងមាំដោយការរវាំងប្រយ័ត្នជានិច្ច បុគ្គលនោះរមែងមិនត្រេកអរដោយអំណាចការស្និទ្ធស្នាលជាមួយសត្រូវរបស់ខ្លួន បន្ទាប់អំពីនោះកិច្ចដែលគួរធ្វើតាមបំណងរបស់សត្រូវទាំងនោះ ក៏មិនមាន ។ បទថា **វិស្សាសយេ** សេចក្តីថា បុគ្គលគួរឲ្យអ្នកដទៃទុកចិត្តក្នុងខ្លួន តែខ្លួនឯងមិនគួរទុកចិត្តក្នុងបុគ្គលនោះ ខ្លួនដែលអ្នកដទៃមិនរង្កៀសហើយ ខ្លួនត្រូវរង្កៀសបុគ្គលដទៃ ។ បទថា **ភាវំ បរោ** សេចក្តីថា ស្តេចនាគសម្តែងថា បណ្ឌិតព្យាយាមដោយវិធីណាមួយ ក៏មិនជ្រាបភាវៈ គឺបំណងរបស់បរបក្ខដោយវិធីនោះឡើយ ព្រោះហេតុនោះ បណ្ឌិតគួរធ្វើនូវសេចក្តីព្យាយាមរឿយៗទៅ ។ ដែលពោលមកនេះជាអធិប្បាយរបស់ស្តេចនាគ ។ កាលសត្វទាំង ២ ចរចាគ្នាយ៉ាងនេះហើយក៏ត្រេកអររកគ្នានាំគ្នាទៅកាន់សម្នាក់អ្នកបួសអាក្រាត ។

ព្រះបរមសាស្តាកាលប្រកាសសេចក្តីនោះទើបត្រាស់គាថានេះថា

បុរិសនាគទាំងពីរនោះ មានវណ្ណៈដូចជាទេវតា មានសភាពជាសុខុមាលជាតិស្មើគ្នា មានវ័យដ៏ល្អ មានគំនរនៃបុណ្យ កៀកដៃគ្នាដូចជាសេះគេទឹម បានចូលទៅកាន់សំណាក់នៃអចេល ឯកំពង់ករម្បិយៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមា** សេចក្តីថា សត្វទាំង ២ ទ្រទ្រង់នូវសណ្ឋានប្រហាក់ប្រហែលគ្នា ។ បទថា **សុជយា** សេចក្តីថា មានវ័យជាសុខ គឺបរិសុទ្ធិ ។ បាឋៈនៃព្រះបាលី ក៏យ៉ាងនោះដូចគ្នា ។ បទថា **បុញ្ញក្ខន្ធា** សេចក្តីថា ដូចគំនរបុណ្យ ព្រោះមានកុសលធ្វើទុកហើយ ។ បទថា **មិស្សីភូតា** សេចក្តីថា សត្វទាំង ២ ចាប់ដៃគ្នានឹងគ្នាចូលដល់នូវការបបោសអង្អែលគ្នាដោយកាយ ។ បទថា **អស្សវាហាវ នាគា** សេចក្តីថា ជាបុរសដ៏ប្រសើរដូចគ្នានឹងអស្សតរ ២ ទឹមដោយនឹមតែមួយនាំរថទៅ ចូលទៅកាន់អាស្រមរបស់អចេលក៏នោះ ។

លុះទៅដល់ហើយស្តេចគ្រុឌគិតថា ស្តេចនាគនេះគង់មិនឲ្យជីវិតដល់អចេលក៏ អញក៏មិនថ្វាយបង្គំមនុស្សទ្រុស្តសីលនេះ ។ ស្តេចគ្រុឌក៏ឈរខាងក្រៅ ឲ្យស្តេចនាគចូលទៅកាន់សម្នាក់អ្នកបួសអាក្រាតតែម្នាក់ឯង ។

ព្រះបរមសាស្តាទ្រង់សំដៅយកហេតុនោះទើបត្រាស់គាថាក្រៅនេះថា

លំដាប់នោះឯង បណ្ឌរកនាគរាជបានចូលទៅកាន់សំណាក់នៃអចេលដោយខ្លួនឯង ហើយពោលពាក្យនេះថា ខ្ញុំរួច ( អំពី

ការសម្លាប់ ) កន្ទង់នូវភ័យទាំងពួងក្នុងថ្ងៃនេះហើយ យើងមិន

ជាទីស្រឡាញ់របស់លោកដោយចិត្តពិតប្រាកដទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បិយម្ហា** សេចក្តីថា បណ្ឌរកនាគរាជពោល បរិភាសថា នែអចេលក៍ លោកចូលចិត្តក្នុងការនិយាយកុហក ខ្ញុំប្រហែលជា មិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកទេ ។

លំដាប់នោះអ្នកបួសអាក្រាតពោលថា

សុបណ្ណរាជ ជាទីស្រឡាញ់របស់ខ្ញុំ ជាងបណ្ឌរកនាគរាជមែន

ឥតសង្ស័យ ( នេះ ) ជាពាក្យពិត ខ្ញុំនោះជាអ្នកត្រេកអរដោយ

រាគៈ ជាអ្នកដឹងច្បាស់បានធ្វើនូវអំពើអាក្រក់ទុំះ មិនមែនព្រោះ

មោហៈទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បណ្ឌរកេន** សេចក្តីថា ស្តេចគ្រុឌនោះជាទី ស្រឡាញ់ជាងបណ្ឌរកនាគរាជ សេចក្តីនេះជាការពិត ។ បទថា **សោ** សេចក្តី ថា ខ្ញុំជាអ្នកលំអៀងព្រោះស្រឡាញ់ស្តេចគ្រុឌនោះ ទើបធ្វើបាបកម្មនោះទាំង ដឹងខ្លួន មិនមែនព្រោះមោហាគតិឡើយ ។

ស្តេចនាគបានស្តាប់ដូច្នោះហើយបានពោលគាថា ២ ថា

បព្វជិតកាលឃើញច្បាស់នូវលោកនេះនិងលោកខាងមុខរមែង

មិនមានគំនិតថា វត្ថុជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់របស់

អញដូច្នេះទេ អ្នកជាបុគ្គលមិនសង្រួម ប្រព្រឹត្តក្នុងលោកនេះ

ដោយភេទរបស់បុគ្គលអ្នកសង្រួមល្អ ។ អ្នកឯងបន្ទំជាអរិយៈ

តែមិនមែនជាអរិយៈទេ អ្នកមិនសង្រួមតែមានភាពហាក់ដូចជា
អ្នកសង្រួម មានជាតិខ្មៅ មានសភាពមិនប្រសើរបានប្រព្រឹត្ត
នូវអំពើដ៏លាមកទុច្ចរិតច្រើនយ៉ាង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆ មេ** សេចក្ដីថា នៃអ្នកបួសអាក្រាតទ្រុស្ដសីល អ្នកនិយាយកុហក សេចក្ដីពិតសម្រាប់បព្វជិតដែលសម្លឹងឃើញលោកនេះនិងលោកខាងមុខ រមែងមិនប្រកាន់ថា វត្ថុនេះជាទីស្រឡាញ់របស់ខ្ញុំ វត្ថុនេះមិនជាទីស្រឡាញ់របស់ខ្ញុំឡើយ តែលោកជាបុគ្គលមិនសង្រួម ប្រព្រឹត្តបោកបញ្ឆោតនូវសត្វលោកដោយភេទបព្វជិតរបស់បុគ្គលអ្នកមានសីលសង្រួមល្អ ។ បទថា **អរិយាវកាសោសិ** សេចក្ដីថា មិនមែនជាអរិយៈក៏បន្ទំខ្លួនជាអរិយៈ ។ បទថា **អសញ្ញតោ** សេចក្ដីថា មិនមែនជាអ្នកសង្រួមដោយកាយជាដើម ។ បទថា **កណ្ហាភិជាតិកោ** សេចក្ដីថា ជាបុគ្គលមានសភាពអាក្រក់ ។ បទថា **អនរិយរូបោ** សេចក្ដីថា ដាច់នូវហិរិ គឺការខ្មាសចំពោះបាប ។ បទថា **អចារិ** បានដល់ បានធ្វើនូវបាបជាច្រើន ។ កាលបណ្ឌរកនាគរាជ តិះដៀលអចេលក៍យ៉ាងនេះហើយ កាលនឹងផ្ដាសាទើបពោលគាថានេះថា

ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្តដែលមិនបានប្រទូស្ត
វិញផង ជាអ្នកញុះញង់ផង ដោយពាក្យសច្ចៈនេះសូមឲ្យក្បាល
របស់អ្នកឯងបែកជា ៧ ភាគ ដូច្នេះ ។

គាថានោះមានអធិប្បាយថា នៃបុគ្គលថោកទាប ដោយការពោលពាក្យសច្ចៈនេះថា អ្នកជាបុគ្គលទ្រុស្តមិត្ត ដែលមិនបានប្រទូស្តផង ជាអ្នកញុះញង់

ផង ក្បាលរបស់អ្នកចូរបែកជា ៧ ភាគ ។

កាលស្ដេចនាគផ្ដាសាយ៉ាងនេះ ក្បាលរបស់អ្នកបួសអាក្រាតក៏បែកចេញជា ៧ ភាគ ។ ផែនដីត្រង់ទីដែលអចេលក៍នោះអង្គុយ ក៏បានបើកឱកាស ។ អ្នកបួសអាក្រាតនោះចូលកាន់ផែនដី កើតក្នុងអវិចិមហានរក ជនទាំង ២ គឺស្ដេចនាគនិងស្ដេចគ្រុឌ ក៏បានទៅកាន់ភពរបស់ខ្លួនវិញនោះឯង ។

ព្រះបរមសាស្ដាកាលនឹងប្រកាសភាពដែលអ្នកបួសអាក្រាតនោះត្រូវផែនដីស្រូបទើបត្រាស់អភិសានគាថាដូច្នេះថា

> ព្រោះហេតុនោះ បុគ្គលមិនត្រូវប្រទូស្តមិត្តទាំងឡាយឡើយ
> ព្រោះថាសភាវៈដទៃលាមកជាងការទ្រុស្តមិត្តមិនមានទេ អចេល
> អ្នកសង្រួម ត្រូវសត្វអាសិរពិសប្រទេចផ្ដាសា ក៏ខ្ចាត់ចេញអំពី
> ផែនដី វិនាសតាមពាក្យរបស់នាគរាជដ៏ប្រសើរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តស្មា** សេចក្ដីថា ព្រោះហេតុដែលផលនៃកម្ម គឺការទ្រុស្តមិត្តជារបស់ក្ដៅក្រហាយ ។ បទថា **អាសិត្តសត្តោ** សេចក្ដីថា អ្នកបួសត្រូវអាសិរពិសកម្ចាត់ហើយ ។ បទថា **ឥន្ទស្ស** សេចក្ដីថា ដោយពាក្យរបស់ស្ដេចនាគ ។ បទថា **សំវរោ** សេចក្ដីថា អាជីវកដែលប្រាកដដោយប្ដេជ្ញាថា យើងជាអ្នកតាំងនៅក្នុងសំវរៈក៏បានត្រូវទម្លាយ ។ ព្រះបរម-

សាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ធ្វើមុសាវាទរហូតផែនដីស្រូប ហើយទ្រង់សមោធានជាតកថា អ្នកបួសអាក្រាតក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ នាគរាជក្នុងកាលនោះបានមកជាសារីបុត្ត ឯសុបណ្ណរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បណ្ឌរកជាតក ចប់

# សម្ពុលាជាតក

[ ៥៣៥ ] ( ទានវៈសួរថា ) ម្នាលនាងមានភ្នៅមូល នាងឈ្មោះអ្វី រង្គោញរ័រលើជ្រោះនៃភ្នំ ឈរនៅតែម្នាក់ឯង ម្នាលនាងមានអវយវៈត្រង់កណ្ដាលគួរវាស់ដោយដៃ ( ចង្កេះរៀវ ) យើងសួរហើយ នាងចូរប្រាប់នូវនាមនិងផៅពង្សដល់យើង ។

ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈពាក់កណ្ដាលដ៏ល្អនាងជាធីតារបស់អ្នកណា នាងញុំាងព្រៃជាទីរីករាយដែលសីហៈនិងខ្លាធំអាស្រ័យនៅឲ្យភ្លឺរុងរឿង ម្នាលនាងដ៏ចម្រើន យើងឈ្មោះទានវៈ សូមសំពះនាងសូមគោរពចំពោះនាង ។

[ ៥៣៦ ] ( នាងសម្ពុលាឆ្លើយថា ) អ្នកណាជាបុត្ររបស់ព្រះរាជាក្នុងដែនកាសី អ្នកផងតែងស្គាល់អ្នកនោះថា ព្រះនាមសោត្ថិសេន ខ្ញុំឈ្មោះនាងសម្ពុលា ជាភរិយារបស់ព្រះរាជបុត្តព្រះនាមសោត្ថិសេននោះ បពិត្រទានវៈលោកចូរដឹងយ៉ាងនេះចុះ បពិត្រលោកដ៏ចម្រើន ខ្ញុំឈ្មោះសម្ពុលា សូមសំពះសូមគោរពចំពោះលោក ។ បពិត្រលោកដ៏ចម្រើន ព្រះរាជបុត្ររបស់ព្រះរាជាវិទេហៈ ប្រឈួនក្តៅក្រហាយគង់នៅក្នុងព្រៃ ខ្ញុំជាស្ត្រីម្នាក់ឯងបម្រើព្រះរាជបុត្តដែលមានរោគបៀតបៀនមួយអង្គឯងនោះ ។ មិនតែប៉ុណ្ណោះខ្ញុំ ( ត្រាច់ទៅ ) ដើម្បីស្វែងរកផ្លែឈើក្នុងព្រៃនាំមកនូវទឹកឃ្មុំនិងសាច់ដែលជារំពាររបស់ម្រឹគណា ( ស្វាមីរបស់ខ្ញុំ ) មានទឹកឃ្មុំនិងសាច់ ជារំពាររបស់ម្រឹគនោះជាអាហារ ( កាលបើមិនមានអាហារទេសរីរៈ ) របស់ស្វាមីខ្ញុំនោះនឹងទ្រាំទ្រ

មិនបានក្នុងថ្ងៃនេះដោយពិត ។

[ ៥៣៧ ] ( ទានវៈ... ) ម្នាលនាងសម្ពុលា នាងធ្វើ ( នូវការមូលមិត្ត ) នឹងព្រះរាជបុត្តប្រឈូនក្តៅក្រហាយដែលរោគប៉ះពាល់ នៅក្នុងព្រៃធ្វើអ្វី ខ្ញុំសូមជាកស្តារបស់នាង ។

( នាងសម្ពុលា... ) ខ្ញុំរាប់ថាមានរូបដូចម្តេចកើត ព្រោះខ្ញុំជាស្ត្រីមានសេចក្តីសោកគ្របសង្កត់ មានខ្លួនដ៏លំបាក បពិត្រលោកដ៏ចម្រើន លោកចូរស្វែងរកស្ត្រីឯទៀតដែលល្អជាងខ្ញុំចុះ ។

( ទានវៈ... ) នាងចូរមកចុះ ចូរឡើងកាន់ភ្នំនេះ ប្រពន្ធរបស់ខ្ញុំមាន ៤០០ នាក់ នាងចូរជាស្ត្រីដ៏ប្រសើរ ជាងភរិយាទាំងនោះ ចូរសម្រេចតាមសេចក្តីប្រាថ្នាគ្រប់យ៉ាង ។ ម្នាលនាងមានពន្លឺដូចផ្កាយ នាងប្រាថ្នាក្នុងចិត្តចំពោះវត្ថុណាមួយ វត្ថុទាំងអស់នោះរបស់ខ្ញុំមានគរគោក ចូរនាងត្រេកអរជាមួយនឹងយើង ក្នុងថ្ងៃនេះចុះ ។ ម្នាលនាងសម្ពុលា បើនាងមិនធ្វើនូវភាពជាមហេសីរបស់ខ្ញុំទេ នាងគួរជាអាហារក្នុងពេលព្រឹកនិងជាចំណីរបស់ខ្ញុំអំពីព្រហាម ។

ចំណែកទានវៈមានផ្នួងសក់ ៧ ជាន់ ជាជាតិអាក្រក់ មានចង្កូម ជាអ្នកស៊ីនូវបុរស បានចាប់នាងសម្ពុលានោះត្រង់ដើមដៃដែលមិនឃើញនូវទីពឹងក្នុងព្រៃ ។ នាងសម្ពុលាដែលបិសាចអាក្រក់ មានក្អែកប្រកបដោយអាមិសគ្របសង្កត់ ជាស្ត្រីលុះក្នុងអំណាចនៃសត្រូវហើយក៏សោកសៅរកតែស្វាមីថា

យក្សស៊ីនូវខ្ញុំដោយហេតុណា ហេតុនេះមិនមែនជាទុក្ខនៃខ្ញុំទេ ក្រែងតែ

ព្រះហឫទ័យនៃអយ្យបុត្តរបស់ខ្ញុំទៅជាបការៈដទៃ ( ប្រច័ណ្ឌ ) ដោយហេតុណា ហេតុនោះ ( ទើបជាទុក្ខនៃខ្ញុំ ) ។

មិនមានពួកទេវតានៅគ្រប់គ្រងដោយពិត ទាំងពួកទេវតាអ្នករក្សាលោកក្នុងលោកនេះ ក៏មិនមានដោយពិត ទេវតាទាំងឡាយ អ្នកហាមឃាត់នូវពួកជនជាអ្នកមិនសង្រួម ជាអ្នកធ្វើដោយការកំហែង ក៏មិនមានដោយពិត ។

[ ៥៣៨ ] ( សក្កៈ... ) ស្ត្រីនេះជាស្ត្រីមានយស ជាស្ត្រីប្រសើរជាងស្ត្រីទាំងឡាយ ជាស្ត្រីស្ងប់ស្ងៀម មានកិរិយាដ៏ស្មើ មានតេជៈ រុងរឿងដូចជាភ្លើង បើអ្នកឯងស៊ីនាងកញ្ញានោះក្បាលអ្នកឯងនឹងបែកជា ៧ ភាគមិនខានអ្នកឯងកុំកម្តៅ ( នូវនាងសម្ពុលា ) អ្នកឯងចូរលែងនាងទៅ ព្រោះនាងជាស្ត្រីគោរពប្តី ។

[ ៥៣៩ ] ( អភិសម្ពុទ្ធគាថា ) នាងសម្ពុលា លុះរួចអំពីបោរិសាទបានត្រឡប់មកកាន់អាស្រមវិញ ដូចជាមេបក្សីបែកខ្វែកកូន ហើយមកកាន់ទ្រនំ ឬដូចមេគោមកកាន់លំនៅ ( ដែលមានកូនទៅបាត់ហើយ ) ។ ព្រះរាជបុត្រីនោះជាស្ត្រីមានយស ព្រះនាមសម្ពុលា មានភ្នែកស្រទន់ ព្រោះរដូវកាលមិនឃើញព្រះស្វាមី ជាទីពឹងក្នុងព្រៃហើយក៏ទ្រង់ព្រះកន្សែង ក្បែរអាស្រមនោះថា ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំពួកសមណព្រាហ្មណ៍និងឥសីទាំងឡាយដែលមានការប្រព្រឹត្តបរិបូណ៌ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវពួកសីហៈ ខ្លាធំនិងពួកម្រឹគដទៃ ក្នុងព្រៃ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំស្មៅ

វល្លិ ឈើជាឱសថ ភ្នំនិងព្រៃទាំងឡាយ ខ្ញុំសូមជល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវរបៀបផ្កាយ ក្នុងរាត្រីដែលមានពណ៌ដូចជាផ្កាកជព្រឹក្ស ខ្ញុំសូមជល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវស្ទឹងឈ្មោះភគិរសី ជាទីទទួលនូវស្ទឹងទាំងឡាយដែលហូរមក ខ្ញុំសូមជល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវភ្នំហិមពាន្ត ជាស្តេចភ្នំដ៏ប្រសើរ ខ្ញុំសូមជល់នូវលោកជាទីពឹង ។

[ ៥៤០ ] ( សោត្ថិសេន... ) រាជបុត្រី ជាស្ត្រីមានយស មកក្នុងវេលាល្ងាចម៉្លេះ តើថ្ងៃនេះនាងជួបប្រទះនឹងអ្នកណាហ្ន៎ អ្នកណាជាទីស្រឡាញ់របស់នាងជាងខ្ញុំ ។

[ ៥៤១ ] ( នាងសម្ពុលា... ) ខ្ញុំម្ចាស់ដែលសត្រូវនោះចាប់បាន ក៏បានពោលពាក្យនេះថា យក្សទំពាស៊ីនូវខ្ញុំម្ចាស់ដោយហេតុណា ហេតុនោះមិនមែនជាទុក្ខនៃខ្ញុំម្ចាស់ទេ ក្រែងតែព្រះហឫទ័យព្រះអយ្យបុត្តរបស់ខ្ញុំម្ចាស់ ទៅជាបការៈដទៃដោយហេតុណា ហេតុនោះ ( ទើបជាទុក្ខនៃខ្ញុំម្ចាស់ ) ។

[ ៥៤២ ] ( សោត្ថិសេន... ) ពាក្យសច្ចៈក្នុងពួកស្រីចោរ មានមាយាច្រើន គេរកបានដោយក្រណាស់ ភាពគឺឫកមារយាទរបស់ស្ត្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។

[ ៥៤៣ ] ( នាងសម្ពុលា... ) ខ្ញុំម្ចាស់មិនធ្លាប់ស្គាល់នូវបុគ្គលដទៃ ជាទីស្រឡាញ់ជាងព្រះអង្គយ៉ាងណា បើ ( ដំណើរ ) របស់ខ្ញុំម្ចាស់ ( នោះ ) ជាសច្ចៈយ៉ាងនោះ សូមសច្ចៈរក្សាព្រះអង្គ ទាំងរក្សានូវខ្ញុំម្ចាស់ ដោយពាក្យ

សច្ចៈនេះ សូមព្យាធិរបស់ព្រះអង្គស្ងប់រម្ងាប់ ។

[ ៥៤៤ ] ( តាបស... ) ដំរីទាំងឡាយច្រើនប្រមាណ ៧០០ មានអាវុធដែលយោធាប្រកបហើយ ទាំងពួកខ្មាន់ធ្នូមួយពាន់ប្រាំមួយរយ តែងរក្សាទាំងយប់ទាំងថ្ងៃ ម្នាលនាងដ៏ចម្រើន តើនាងនៅឃើញពួកសត្រូវដូចម្តេច ។

[ ៥៤៥ ] ( នាងសម្ពុលា... ) ស្វាមីឃើញពួកស្ត្រីដែលតាក់តែងកាយមានសម្បុរស្បែកល្អ ដូចស្រទាប់ផ្កាឈូក មានចង្កេះរៀវ មានសំឡេងដូចហង្ស ទ្រង់ព្រះសណ្តាប់នូវចម្រៀងនិងប្រគំ ដែលគេគួររាប់របស់ពួកស្ត្រីទាំងនោះ បពិត្រព្រះបិតា ឥឡូវនេះព្រះស្វាមីរបស់ខ្ញុំម្ចាស់មិនប្រព្រឹត្តដូចកាលមុនយ៉ាងនោះទេ ។ បពិត្រព្រះបិតា ពួកស្ត្រីមានរូបល្អទ្រទ្រង់នូវប្រដាប់សម្រាប់រឹតដោះ ជាវិការៈនៃមាស តាក់តែងខ្លួន ជាស្ត្រីមនុស្សដូចស្ត្រីទេពអប្សរ ជាទីស្រឡាញ់នៃព្រះរាជាព្រះនាមសោត្ថិសេន ជាស្ត្រីមានរាងកាយតិះដៀលមិនបាន ជាខត្តិយកញ្ញាតែងប្រលោមព្រះរាជានោះ ។ បពិត្រព្រះបិតា ប្រសិនបើ ខ្ញុំម្ចាស់ចិញ្ចឹមព្រះស្វាមីនោះដោយការស្វែងរកនូវផ្លែឈើក្នុងព្រៃ ដូចក្នុងកាលមុនយ៉ាងនោះទៀត ព្រះស្វាមីគប្បីរាប់អានខ្ញុំម្ចាស់ ទាំងមិនមើលងាយខ្ញុំម្ចាស់ទេ បពិត្រព្រះបិតា ព្រោះហេតុនោះ ( ព្រៃ ) របស់ខ្ញុំម្ចាស់ ( នោះឯង ) ប្រសើរជាងរាជសម្បត្តិក្នុងក្រុងពារាណសីនេះ ។ នារីណា ( កើតក្នុងផ្ទះត្រកូល ) មានបាយនិងទឹកបរិបូណ៌ ដែលគេចាត់ចែងហើយ ជាស្ត្រីមានគ្រឿងប្រដាប់ដ៏ស្អាតវិសេស តាក់តែងខ្លួនប្រកបដោយអង្គគ្រប់យ៉ាងតែមិនជាទីស្រឡាញ់របស់ប្តី បានសម្លាប់ ( ខ្លួន ) ហើយសេចក្តីស្លាប់របស់

នារីនោះប្រសើរជាងការរស់នៅជាយរវាសនោះទៅទៀត ។ បើស្ត្រីណាទ័លក្រកំព្រា មិនមានបបុស គឺមានះ មានតែកន្ទេលជាគម្រប់ពីរតែស្ត្រីនោះជាទីស្រឡាញ់របស់ប្តី ស្ត្រីណាទោះកំព្រាតែជាទីស្រឡាញ់ ( របស់ប្តី ) ស្ត្រីនេះឯងប្រសើរជាងស្ត្រី ដែលប្រកបដោយអន្តគ្រប់យ៉ាងដែលមិនជាទីស្រឡាញ់ ( របស់ប្តី ) ។

[ ៥៤៦ ] ( តាបស... ) ស្ត្រីណាជាគុណរបស់បុរស ស្ត្រីនោះគេរកបានក្រក្រៃលែង កស្តាណាជាគុណរបស់ស្ត្រី កស្តានោះគេរកបានដោយក្រ ម្នាលបាជាធំជាងជន កិរិយារបស់អ្នកជាគុណ ( នៃអ្នក ) ផង ជាស្ត្រីមានសីលផង អ្នកចូរប្រព្រឹត្តធម៌ចំពោះនាងសម្ពុលា ។

[ ៥៤៧ ] ( ព្រះរាជាសោត្ថិសេន... ) ម្នាលនាងសម្ពុលា មានភោគៈបានហើយដ៏ច្រើន បើនាងឆ្លងផុតចាកសេចក្តីប្រាថ្នាដល់នូវមរណៈ អញនិងពួករាជកញ្ញាទាំងអស់របស់នាងនេះនឹងធ្វើតាមពាក្យរបស់នាង ។

## ចប់ សម្ពុលាជាតក ទី ៩ ។

## អដ្ឋកថា

## សម្ពុលាជាតក

[ ៥៣៥-៥៤៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកាពជទេវីទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កា វេធមានា** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នខ្ញុំពោលទុកហើយពិស្ដារក្នុងកុម្មាសបិណ្ឌជាតក ។ ព្រះនាងមល្លិកានោះដោយអានុភាពនៃការថ្វាយនំកុម្មាសដល់ព្រះតថាគត ៣ ដុំ បានដល់នូវភាពជាអគ្គមហេសី របស់ព្រះបាទបសេនទិកោសល ក្នុងថ្ងៃនោះឯងដល់ព្រមដោយកល្យាណធម៌ ៥ ប្រការមានក្ញាក់មុនជាដើម ដល់ព្រមដោយញាណ ជាឧបដ្ឋាយិកានៃព្រះពុទ្ធ គោរពចំពោះព្រះស្វាមីដូចទេវតា ។ ភាពដែលព្រះនាងគោរពចំពោះស្វាមីដូចទេវតានោះបានប្រាកដទូទៅក្នុងព្រះនគរ ។ ថ្ងៃមួយភិក្ខុទាំងឡាយ នាំគ្នាសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ព្រះនាងមល្លិកាទេវី ជាអ្នកសម្បូរដោយវត្ត ដល់ព្រមដោយញាណគោរពចំពោះព្រះស្វាមីដូចទេវតា ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុន នាងមល្លិកានេះក៏ដល់ព្រមដោយវត្ត គោរពព្រះស្វាមីដូចទេវតាដូចគ្នាហើយទ្រង់នាំយកអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលឱរសរបស់ព្រះបាទព្រហ្មទត្ត នៅក្នុងនគរពារាណសី ព្រះនាមសោត្ថិសេនកុមារ ព្រះរាជាទ្រង់ស្ថាបនាព្រះរាជឱរស ដែលចម្រើនវ័យហើយនោះទុកក្នុងតំណែងឧបរាជ ព្រះអគ្គមហេសីរបស់សោត្ថិសេនកុមារនោះព្រះនាមថា សម្ពុលា មានព្រះរូបឆោមល្អត្រកាល ដល់ព្រមទៅដោយសរីរៈឥន្ទ្រិយចែងចាំង ប្រាកដដូចអណ្តាតប្រទីបកំពុងឆេះ ក្នុងទីមិនមានខ្យល់ ។ ក្នុងកាលតមករោគឃ្លង់កើតឡើងក្នុងសរីរៈរបស់សោត្ថិសេនកុមារ ពួកពេទ្យមិនអាចព្យាបាលបាន កាលរោគឃ្លង់បែក ព្រះរាជកុមារក៏ជាបុគ្គលដែលមហាជនគប្បីរង្កៀស ទ្រង់ដល់នូវការក្តៅក្រហាយ ត្រិះរិះថា រាជសម្បត្តិមានប្រយោជន៍អ្វីដល់អញ អញនឹងទៅស្លាប់យ៉ាងអនាថាក្នុងព្រៃ ហើយក្រាបទូលព្រះរាជបិតា ឲ្យទ្រង់ជ្រាប លះព្រះរាជដំណាក់ខាងក្នុងចេញទៅ ហើយព្រះនាងសម្ពុលាអគ្គមហេសី សូម្បីព្រះរាជកុមារឲ្យត្រឡប់ដោយឧបាយដ៏ច្រើនក៏មិនត្រឡប់ ទូលថា ខ្ញុំម្ចាស់នឹងទៅបដិបត្តិបាទាព្រះស្វាមីក្នុងព្រៃហើយតាមព្រះរាជាទៅ ។ ព្រះរាជកុមារចូលទៅដល់ព្រៃ ហើយសាងនូវបណ្ណសាលាអាស្រ័យក្នុងបទេស ដែលសម្បូរដោយផ្លែឈើតូចធំ មានម្លប់ត្រជាក់ មានទឹករកបានងាយ ។ ព្រះរាជធីតាដែលជាព្រះរាជជាយា ព្រះនាងក៏បដិបត្តិបម្រើព្រះរាជកុមារ ។ ព្រះនាងបដិបត្តិដូចម្តេច គឺព្រះនាងភ្ញាក់អំពីព្រឹកហើយបោសសម្អាតអាស្រមបទ ដងទឹកប្រើ ទឹកផឹកចូលទៅតម្កល់ទុក ថ្វាយឈើស្ទន់និងទឹកខ្ពុរព្រះឧស្ឋ កាលខ្ពុរព្រះឱស្ឋហើយក៏បុកថ្នាំលាបដំបៅ របស់ព្រះស្វាមី ឲ្យសោយផលាផលមានរសផ្អែម កាលព្រះស្វាមីខ្ពុរព្រះឱស្ឋលាងព្រះ

ហស្ត រួចទូលថា បពិត្រព្រះស្វាមីដែលទ្រទ្រង់នូវគុណដ៏ប្រសើរ សូមទ្រង់កុំមានសេចក្ដីប្រមាទ ថ្វាយបង្គំហើយកាន់ល្អី ចបជីកនិងតម្លក់ចូលព្រៃស្វែងរកផលាផល នាំផ្លែឈើមករក្សាទុកក្នុងចំណែកម្ខាងហើយយកក្អមដងទឹកមកស្រពស្រង់សោត្ថិសេនរាជកុមារ ដែលជាព្រះរាជស្វាមីដោយគ្រឿងសម្រាប់ស្រង់ មានលម្អិតផង់និងលម្អិតជុំផ្សេងៗហើយបង្អោនផលាផលមានរសឆ្ងាញ់ចូលទៅថ្វាយ កាលសោយស្រេចហើយ ព្រះនាងក៏បង្អោនទឹកផឹកដែលអប់ទុកចូលទៅថ្វាយ ខ្លួនឯងក៏បរិភោគផលាផលហើយរៀបចំបន្ទះក្ដារជាកម្រាលត្រៀមទុក កាលព្រះស្វាមីផ្ទំលើកម្រាលនោះហើយក៏លាងព្រះបាទ ធ្វើនូវការគក់ប្របាច់ព្រះសរីរកាយ ហើយចូលទៅផ្ទំត្រង់ព្រះបន្ទំ ព្រះនាងសម្ពុលាបដិ-បត្តិស្វាមីដោយឧបាយនេះឯង ។

ថ្ងៃមួយព្រះនាងកំពុងបេះផ្លែឈើនៅក្នុងព្រៃ ឃើញជ្រោះត្រង់ជើងភ្នំមួយកន្លែងទើបដាក់ល្អីចុះអំពីក្បាល ទុកត្រង់មាត់ជ្រោះ គិតថានឹងងូតទឹក ហើយចុះទៅងូតដុសសរីរកាយដោយរមៀត រហូតព្រះកាយស្អាតល្អហើយឡើងមកឈរ ស្លៀកដណ្ដប់សំពត់ដែលត្បាញដោយសម្បកឈើ នៅត្រង់មាត់ជ្រោះខណៈនោះរស្មីនៃព្រះសរីរកាយរបស់ព្រះនាងជាហេតុឲ្យព្រៃមានពន្លឺតែមួយ ។

ខណៈនោះទានវៈ ( យក្សព្រៃ ) មួយរូបស្វែងរកអាហារ ឃើញព្រះនាងសម្ពុលា មានចិត្តប្រតិព័ទ្ធក៏ពោល ២ គាថាដោយសេចក្ដីថា

ម្នាលនាងមានភ្លៅមូល នាងឈ្មោះអ្វី រងាញ័រលើជ្រោះនៃភ្នំ
ឈរនៅតែម្នាក់ឯង ម្នាលនាងមានអវយវៈ ត្រង់កណ្ដាលគួរ

វាស់ដោយដៃ ( ចង្កេះរៀវ ) យើងសួរហើយ នាងចូរប្រាប់នូវនាមនិងផៅពង្សដល់យើង ។

ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈពាក់កណ្តាលដ៏ល្អ នាងជាធីតារបស់អ្នកណា នាងញាំងព្រៃជាទីរីករាយដែលសីហៈនិងខ្លាធំអាស្រ័យនៅ ឲ្យភ្លឺរុងរឿង ម្នាលនាងដ៏ចម្រើន យើងឈ្មោះទានវៈ សូមសំពះនាង សូមគោរពចំពោះនាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កា វេធមានា** សេចក្តីថា ព្រោះនាងផ្ចិតក្នុងជ្រោះទើបរង្គោះរញ៉េរចំប្រប់ ។ បទថា **សុភក្ខុ** បានដល់ នៃនាងមានភ្នែកល្អ ។ បទថា **ចាណិបមេយ្យមជ្ឈេ** បានដល់ នៃនាងមានសរីរៈគួរស្ទាបអង្អែលដោយដៃ ។ បទថា **កា វា ត្វំ** សេចក្តីថា នាងជានរណា ឬថាជាកូនចៅរបស់អ្នកណា ។ បទថា **អភិវាទេមិ** បានដល់ ខ្ញុំសូមសំពះនាង ។ បទថា **ទានវាហំ** សេចក្តីថា ទានវៈនោះពោលថា ខ្ញុំគឺអសុរមួយរូប សូមការគោរពនេះមានដល់នាង ខ្ញុំសូមផ្គងអញ្ជលីដល់នាង ។

ព្រះនាងសម្ពុលា បានស្តាប់ពាក្យរបស់ទានវៈនោះហើយបានពោលគាថា ៣ ថា

អ្នកណាជាបុត្ររបស់ព្រះរាជាក្នុងដែនកាសី អ្នកផងតែងស្គាល់អ្នកនោះថាព្រះនាមសោត្ថិសេន ខ្ញុំឈ្មោះនាងសម្ពុលា ជាភរិយារបស់ព្រះរាជបុត្រព្រះនាមសោត្ថិសេននោះ បពិត្រទានវៈលោក

ចូរដឹងយ៉ាងនេះចុះ បពិត្រលោកដ៏ចម្រើន ខ្ញុំឈ្មោះ សម្ពុលា សូមសំពះ សូមគោរពចំពោះលោក ។ បពិត្រលោកដ៏ចម្រើន ព្រះរាជបុត្តរបស់ព្រះរាជាវិទេហៈ ប្រឈួនក្តៅក្រហាយគង់នៅក្នុងព្រៃ ខ្ញុំជាស្ត្រីម្នាក់ឯងបម្រើព្រះរាជបុត្តដែលមានរោគបៀតបៀនមួយអន្លើឯងនោះ ។ មិនតែប៉ុណ្ណោះ ខ្ញុំ ( ត្រាច់ទៅ ) ដើម្បីស្វែងរកផ្លែឈើក្នុងព្រៃ នាំមកនូវទឹកឃ្មុំនិងសាច់ដែលជាវិពារបស់ម្រឹគណា ( ស្វាមីរបស់ខ្ញុំ ) មានទឹកឃ្មុំនិងសាច់ជាវិពារបស់ម្រឹគនោះជាអាហារ ( កាលបើមិនមានអាហារទេ សរីរៈ ) របស់ស្វាមីខ្ញុំនោះនឹងទ្រាំទ្រមិនបានក្នុងថ្ងៃនេះដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេទេហបុត្តោ** បានដល់ ព្រះរាជកុមារដែលជាវេទេហរាជបិយោរស ។ បទថា **រោគសម្មត្តំ** បានដល់ ដែលរោគបៀតបៀនហើយ ។ បទថា **ឧបដ្ឋហំ** សេចក្តីថា ខ្ញុំត្រូវព្យាបាលគឺបដិបត្តិទ្រង់ ។ បាឋៈថា **ឧបដ្ឋិតា** ដូច្នេះក៏មាន ។ បទថា **វនមុញ្ឆាយ** សេចក្តីថា ខ្ញុំស្វែងរក ( ផ្លែឈើ ) ក្នុងព្រៃ ។ បទថា **មធុមំសំ** សេចក្តីថា ខ្ញុំស្វែងរកផ្លែឈើសម្បុកឃ្មុំដែលមិនមានមេនិងសាច់ម្រឹគ ដែលសល់អំពីរាជសីហ៍និងខ្លាទំពាស៊ី ។ បទថា **តំ ភក្ខោ** សេចក្តីថា ខ្ញុំនាំអាហារណាទៅ ព្រះស្វាមីរបស់ខ្ញុំក៏បានអាហារនោះសោយ ។ បទថា **តស្ស ន្វជ្ជ** សេចក្តីថា កាលព្រះស្វាមីរបស់ខ្ញុំមិនបានអាហារក្នុងថ្ងៃនេះ ព្រះសរីរៈគង់នឹងរីងស្ងួតដូចផ្កាបទុមដែល

គេហាលទុក ដូច្នោះ ។ បទថា **ឆាតតិ** សេចក្ដីថា ស្គាំងស្គម គឺហួតហែង ទៅ ។

បន្ទាប់អំពីនោះទៅជាគាថាឆ្លើយឆ្លង រវាងទានវៈនិងព្រះនាងសម្ពុលា ដូចតទៅនេះ

ម្នាលនាងសម្ពុលា នាងធ្វើ ( នូវការមូលមិត្ត ) នឹងព្រះរាជ-
បុត្ត ប្រឈួនក្ដៅក្រហាយដែលរោគប៉ះពាល់នៅ ក្នុងព្រៃធ្វើអ្វី
ខ្ញុំសូមជាភស្ដារបស់នាង ។

នាងសម្ពុលាពោលថា

ខ្ញុំរាប់ថាមានរូបដូចម្ដេចកើត ព្រោះខ្ញុំជាស្ត្រីមានសេចក្ដីសោក
គ្របសង្កត់ មានខ្លួនដ៏លំបាក បពិត្រលោកដ៏ចម្រើន លោកចូរ
ស្វែងរកស្ត្រីឯទៀតដែលល្អជាងខ្ញុំចុះ ។

ទានវៈពោលថា

នាងចូរមកចុះ ចូរឡើងកាន់ភ្នំនេះ ប្រពន្ធរបស់ខ្ញុំមាន ៤០០
នាក់ នាងចូរជាស្ត្រីដ៏ប្រសើរជាងភរិយាទាំងនោះ ចូរសម្រេច
តាមសេចក្ដីប្រាថ្នាគ្រប់យ៉ាង ។ ម្នាលនាង មានពន្លឺដូចផ្កាយ
នាងប្រាថ្នាក្នុងចិត្តចំពោះវត្ថុណាមួយ វត្ថុទាំងអស់នោះរបស់ខ្ញុំ
មានគរគោក ចូរនាងត្រេកអរជាមួយនឹងយើងក្នុងថ្ងៃនេះចុះ ។
ម្នាលនាងសម្ពុលា បើនាងមិនធ្វើនូវភាពជាមហេសីរបស់ខ្ញុំទេ
នាងគួរជាអាហារ ក្នុងពេលព្រឹកនិងជាចំណីរបស់ខ្ញុំអំពីព្រ-

ហាម ។

ចំណែកទានវៈមានផ្ទងសក់ ៧ ជាន់ ជាជាតិអាក្រក់ មានចង្កូម ជាអ្នកស៊ីនូវបុរស បានចាប់នាងសម្ពុលានោះត្រង់ដើមដៃដែលមិនឃើញនូវទីពឹងក្នុងព្រៃ ។ នាងសម្ពុលាដែលបិសាចអាក្រក់មានភ្នែក ប្រកបដោយអាមិសគ្របសង្កត់ ជាស្ត្រីលុះក្នុងអំណាចនៃសត្រូវហើយ ក៏សោកសៅរកតែស្វាមីថា

យក្សស៊ីនូវខ្ញុំដោយហេតុណា ហេតុនេះមិនមែនជាទុក្ខនៃខ្ញុំទេ ក្រែងតែព្រះហឫទ័យនៃអយ្យបុត្ររបស់ខ្ញុំទៅជាបការៈដទៃ ( ប្រច័ណ្ឌ ) ដោយហេតុណា ហេតុនោះ ( ទើបជាទុក្ខនៃខ្ញុំ ) ។

មិនមានពួកទេវតានៅគ្រប់គ្រងដោយពិត ទាំងពួកទេវតាអ្នករក្សាលោកក្នុងលោកនេះ ក៏មិនមានដោយពិត ទេវតាទាំងឡាយ អ្នកហាមឃាត់នូវពួកជន ជាអ្នកមិនសង្រួម ជាអ្នកធ្វើដោយការកំហែងក៏មិនមានដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរិចិណ្ណោន** សេចក្តីថា នាងនឹងធ្វើអ្វីបានជាមួយរាជបុត្តដែលមានរោគនោះ ។ បទថា **សោកដ្ដាយ** បានដល់ ជាអ្នកក្តៅក្រហាយដោយសេចក្តីសោក ។ បាឋៈថា **សោកដ្ឋាយ** ដូច្នេះក៏មាន ឯសេចក្តីគឺ តាំងនៅហើយក្នុងសេចក្តីសោក ។ បទថា **ធុរត្តាយ** សេចក្តីថា ជាអត្តភាពដល់ហើយនូវការលំបាកអនាថា ។ បទថា **ឯហិមំ** សេចក្តីថា

អសុរល្បួងលោមថា នាងកុំគិតថាខ្លួនមានរូបអាក្រក់ឡើយ ចូលទៅកាន់ទិព្វ-វិមានរបស់យើងលើកំពូលភ្នំ ចូរឡើងកាន់ភ្នំនេះចុះ ។

បទថា **ចតុស្សតា** សេចក្តីថា ក្នុងវិមាននោះខ្ញុំមានកិរិយា ៤០០ នាក់ ។ បទថា **សព្វន្តំ** សេចក្តីថា អសុរនោះពោលថា នាងប្រាថ្នាគ្រឿងឧបភោគបរិភោគ សំពត់និងគ្រឿងអាភរណៈ ជាដើមណាមួយ វត្ថុទាំងអស់នោះសម្រាប់ខ្ញុំ មានច្រើនពន់ពេក រកបានងាយពិត ដូច្នោះនាងកុំទោមនស្សថា ខ្លួននាងជាស្រីកំព្រា មកចុះ មករួមអភិរមត្រេកអរជាមួយខ្ញុំ ។ បទថា **មហោ-សេយ្យំ** សេចក្តីថា នែសម្ពុលាដ៏ចម្រើន បើនាងមិនព្រមជាមហេសីរបស់ខ្ញុំសោត ចូរនាងត្រៀមខ្លួន ដើម្បីជាអាហារព្រឹករបសខ្ញុំ ដោយហេតុនោះខ្ញុំនឹងនាំនាងទៅកាន់វិមានដោយបង្ខំ បើនាងមិនធ្វើតាមខ្ញុំក្នុងសេចក្តីនោះ ព្រឹកនេះនាងនឹងជាអាហារខ្ញុំអំពីព្រលឹមនោះឯង ។ បទថា **តញ្ច** សេចក្តីថា ទានវៈនោះ ប្រកបដោយជដា ៧ ជាន់ ចង្កូមចេញអំពីមាត់ កាលពោលយ៉ាងនេះហើយក៏ចាប់ដើមដៃរបស់នាងសម្ពុលា ដែលសម្លឹងមិនឃើញអ្វីជាទីពឹងរបស់ខ្លួនបានក្នុងព្រៃនោះ ។ បទថា **អធិបន្នា** បានដល់ គ្របសង្កត់ហើយ ។ បទថា **អាមិសចក្ខុនា** បានដល់ ឡេះឡោះដោយត្រូវកិលេស គ្របសង្កត់ ។ បទថា **បតិមេវ** សេចក្តីថា មិនបានគិតដល់ខ្លួន សោយសោកដល់ស្វាមីប៉ុណ្ណោះ ។ បទថា **មនោ ហោស្សតិ** សេចក្តីថា កាលទ្រង់ជ្រាបថាខ្ញុំវល់តែយឺតយូរ ព្រះហឫទ័យរបស់អយ្យបុត្តនឹងរង្កៀសផ្សេងៗ ។ បទថា **ន សន្តិ នេវា** សេចក្តីថា នាងសម្ពុលា ត្រូវទានវៈចាប់ត្រង់ដើមដៃ កាលធ្វើការបន់

ស្រន់ទេវតាទើបពោលពាក្យនេះ ។ បទថា **លោកធាលា** សេចក្តីថា នាងសម្ពុលាពោលបរិទេវនាការថា បណ្តាទេវតាដែលមានសីលបែបនេះ ស្តេចលោកបាលប្រហែលជាមិនមានក្នុងលោកនេះដោយពិត ។

លំដាប់នោះដោយតេជះនៃសីលរបស់ព្រះនាង ពិភពរបស់សក្កៈ ក៏ញាប់ញ័រ បណ្ឌុកម្ពលសិលាអាសនៈសម្តែងអាការក្តៅ ។ ទើបសក្កទេវរាជ ទ្រង់សម្លឹងមើល ទ្រង់ជ្រាបហេតុការណ៍នោះហើយ ទ្រង់កាន់វជិរាវុធ យាងមកដោយរហ័សប្រថាប់ឈរលើក្បាលរបស់ទានវៈ ត្រាស់ព្រះគាថាក្រៅអំពីនេះថា

ស្ត្រីនេះជាស្ត្រីមានយស ជាស្ត្រីប្រសើរជាងស្ត្រីទាំងឡាយ ជាស្ត្រីស្ងប់ស្ងៀម មានកិរិយាដ៏ស្មើ មានតេជះរុងរឿងដូចជាភ្លើង បើអ្នកឯងស៊ីនាងកញ្ញានោះក្បាលអ្នកឯងនឹងបែកជា ៧ ភាគមិនខាន អ្នកឯងកុំកម្តៅ ( នូវនាងសម្ពុលា ) អ្នកឯងចូរលែងនាងទៅ ព្រោះនាងជាស្ត្រីគោរពប្តី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តា** សេចក្តីថា ស្ងប់រម្ងាប់ ម្យ៉ាងទៀតសំដៅដល់ជាបុគ្គលឈ្លាសដល់ព្រមដោយប្រាជ្ញា ។ បទថា **សមា** សេចក្តីថា ប្រាសចាកការមិនស្មើផ្លូវកាយជាដើម ។ បទថា **អាទេសិ** បានដល់ នឹងទំពាស៊ី ។ បទថា **ផលេយ្យ** សេចក្តីថា ក្បាលរបស់អ្នក ដែលយើងវាយដោយវជិរាវុធគប្បីបែកពិតប្រាកដ ។ បទថា **មា ត្វំ ឌហិ** សេចក្តីថា អ្នកកុំធ្វើឲ្យស្រីដែលបដិបត្តិប្តីត្រូវក្តៅក្រហាយឡើយ ។

ទានវៈស្តាប់ដូច្នោះទើបលែងនាងសម្ពុលា សក្កទេវរាជ ទ្រង់ព្រះតម្រិះថា ទានវៈនេះគប្បីធ្វើបែបនេះទៀតដោយពិត ទើបទ្រង់ចងទានវៈនោះដោយប្រវាក់ទិព្វហើយយកទៅលែងត្រង់ភ្នំទី ៣ ដើម្បីកុំឲ្យត្រឡប់មកទៀត រួចទ្រង់ទូន្មានព្រះរាជធីតាដោយអប្បមាទធម៌ ហើយទ្រង់ទៅកាន់ទិព្វស្ថានរបស់ទ្រង់វិញ ។ ចំណែកព្រះនាងសម្ពុលារាជធីតា កាលព្រះអាទិត្យអស្តង្គតហើយ បានត្រឡប់ដល់អាស្រមដោយពន្លឺព្រះចន្ទ ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់ព្រះគាថា ៨ ដោយសេចក្តីថា

នាងសម្ពុលាលុះរួចអំពីបោរិសាទ បានត្រឡប់មកកាន់អាស្រមវិញ ដូចជាមេបក្សីបែកខ្វែកកូនហើរមកកាន់ទ្រនំ ឬដូចមេគោមកកាន់លំនៅ ( ដែលមានកូនទៅបាត់ហើយ ) ។ ព្រះរាជបុត្រីនោះជាស្ត្រីមានយស ព្រះនាមសម្ពុលា មានភ្នែកស្រទន់ព្រោះរដូវ កាលមិនឃើញព្រះស្វាមីជាទីពឹងក្នុងព្រៃហើយ ក៏ទ្រង់ព្រះកន្សែង ក្បែរអាស្រមនោះថា ខ្ញុំមិនឃើញព្រះរាជបុត្តសូមថ្វាយបង្គំពួកសមណព្រាហ្មណ៍និងឥសីទាំងឡាយ ដែលមានការប្រព្រឹត្តបរិបូណ៌ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវពួកសីហៈ ខ្លាធំនិងពួកម្រឹគដទៃក្នុងព្រៃ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំស្មៅ វល្លិ ឈើជាឱសថ ភ្នំនិងព្រៃ

ទាំងឡាយ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវរបៀបផ្កាយក្នុងរាត្រីដែលមានពណ៌ដូចជាផ្ការាជព្រឹក្ស ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវស្ទឹងឈ្មោះកគិរសីជាទីទទួលនូវស្ទឹងទាំងឡាយដែលហូរមក ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្ត សូមថ្វាយបង្គំនូវភ្នំហិមពាន្ត ជាស្ដេចភ្នំដ៏ប្រសើរ ខ្ញុំសូមដល់នូវលោកជាទីពឹង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆិទ្ទំ ឧលីឆសកុណោវ** សេចក្ដីថា មេបក្សីដែលឈ្មោះថាសកុណី មានកូនខ្ចីព្រោះជាទីកើតនៃសកុណបោតកទាំងឡាយពាំចំណីដោយចំពុះ ហើយហើរត្រឡប់មកសម្បុក ព្រោះអន្តរាយណានីមួយយ៉ាងណា ម្យ៉ាងទៀតមេគោទឹកដោះ ដែលមានការជាប់ជំពាក់ក្នុងកូនខ្ចី គប្បីត្រឡប់មកត្រង់លំនៅរបស់កូនខ្ចីចេញទៅហើយ គឺរោងទំនេរអំពីកូនខ្ចី យ៉ាងណា ព្រះនាងសម្មុលានោះក៏មកកាន់អាស្រមដែលជាទីទំនេរក៏យ៉ាងនោះ ពិតហើយពេលនោះកាលព្រះនាងសម្មុលាយឺតយូរ សោត្ថិសេនកុមារ សង្ស័យថា ឈ្មោះថាស្រី ជាមនុស្សឡេះឡោះ គប្បីនាំបច្ចាមិត្តរបស់យើងមក ទើបទ្រង់ចុះអំពីបណ្ណសាលា ចូលទៅអង្គុយពួនក្នុងរវាងគុម្ពឈើ ។ ព្រោះហេតុនោះទើបលោកពោលសេចក្ដីទុកដូចតទៅនេះ ។

បទថា **ឧត្តមត្តក្ខា** សេចក្ដីថា មានកែវភ្នែកស្រអាប់ដោយកម្ដៅដែលកើតអំពីកម្លាំងនៃសេចក្ដីសោក ។ បទថា **អបស្សន្តី** សេចក្ដីថា ព្រះនាង

សម្មុលាកាលមិនឃើញព្រះស្វាមីដែលជាទីពឹងរបស់ខ្លួន ក៏បរិទេវនាការ រត់ទៅរត់មកក្នុងព្រៃនោះ ។

បណ្ដាបទទាំងនោះ បទថា **សមណេ ព្រាហ្មណេ** បានដល់ សមណព្រាហ្មណ៍ដែលស្ងប់បាប បន្សាត់បាបហើយ ។ បទថា **សម្បន្នចរណេ** សេចក្ដីថា នឹងក្រាបថ្វាយបង្គំឥសីដែលដល់ព្រមដោយចរណៈដោយអំណាចនៃសមាបត្តិ ៨ មួយអន្លើដោយសីល អធិប្បាយថា កាលព្រះនាងសម្មុលាពោលអង្វរយ៉ាងនេះហើយ កាលមិនជួបព្រះរាជឱរសទើបបរិទេវនាការថា ខ្ញុំសូមដល់អ្នកទាំងឡាយជាទីពឹង បើអ្នកទាំងឡាយដឹងទីកន្លែងដែលព្រះស្វាមីរបស់ខ្ញុំអន្តរាយសូមប្រាប់ផងចុះ ។ ក្នុងគាថាដ៏សេសទាំងឡាយក៏មានន័យនេះដូចគ្នា ។

បទថា **តិណលតានិ ឱសធ្យោ** សេចក្ដីថា ព្រះនាងថ្វាយបង្គំអង្វរទេវតាដែលស្ថិតនៅក្នុងគុម្ពស្មៅ ដែលមានស្រោយខាងក្នុង មានខ្លឹមខាងក្រៅ ថ្វាយបង្គំអង្វរទេវតាដែលស្ថិតនៅក្នុងលតាជាតិនិងផ្កាយក្នុងអាកាស ។ ព្រះនាងសម្មុលាពោលគាថានេះ សំដៅដល់ទេវតាទាំងឡាយដែលកើតហើយក្នុងលតាជាតិជាដើម ។ បទថា **ឥន្ទគោបកសាទិសំ** បានដល់ ទេវតាដែលមានពណ៌ដូចផ្កាជព្រឹក្ស ។ បទថា **តុម្ហម្ហិ** សេចក្ដីថា ព្រះនាងសម្មុលាពោលថា **តំបិ អម្ហិ** ខ្ញុំសូមដល់លោក ថាជាទីពឹងដូច្នេះ សំដៅដល់ផ្កាយក្នុងរាត្រីនោះ ។ បទថា **ភគិរសឹ គង្គំ** បានដល់ ស្ទឹងគង្គាដែលមានឈ្មោះដោយបរិយាយយ៉ាងនេះ ។ បទថា **សវន្តីនំ** សេចក្ដីថា ព្រះនាងសម្មុលាពោលទុក សំដៅ

ដល់ទេវតាដែលកើតក្នុងស្ទឹងគង្គា ដែលជាទីទទួលនូវស្ទឹងទាំងឡាយដទៃជាច្រើននោះឯង ។ ក្នុងទេវតាដែលស្ថិតនៅក្នុងព្រៃហិមពាន្ត ក៏មានន័យនេះដូចគ្នា ។

សោត្ថិសេនកុមារជាស្វាមីទតឃើញព្រះនាងបរិទេវនាការយ៉ាងនេះ ទើបទ្រង់ត្រិះរិះថា ស្រីនេះយំសោកក្រៃលែង តែអញមិនដឹងការប្រព្រឹត្តទៅរបស់នាង បើនាងធ្វើយ៉ាងនេះ ព្រោះស្នេហាអាល័យក្នុងអញហើយ គួរតែដួងហឫទយៈរបស់នាងបែកធ្លាយ អញនឹងពិសោធនាងមើលសិនហើយយាងទៅប្រថាប់គង់ត្រង់ទ្វារបណ្ណសាលា ។ ព្រះនាងសម្មុលាក៏ទ្រហោយំដើរទៅកាន់ទ្វារសាលា ថ្វាយបង្គំបាទានៃព្រះស្វាមីហើយទូលថា បពិត្រព្រះស្វាមីជាអ្នកទ្រទ្រង់នូវគុណដ៏ប្រសើរ ទ្រង់យាងទៅណា ។

លំដាប់នោះទើបសោត្ថិសេនកុមារ ពោលនឹងនាងថា ម្នាលនាងដ៏ចម្រើនក្នុងថ្ងៃដទៃៗនាងមិនធ្លាប់មកក្នុងពេលនេះឡើយ ថ្ងៃនេះនាងមកពេលយប់ព្រលប់ កាលសួរទើបត្រាស់ថា

> រាជបុត្រី ជាស្ត្រីមានយស មកក្នុងវេលាល្ងាចម៉្លេះ តើថ្ងៃនេះ
> នាងជួបប្រទះនឹងអ្នកណាហ្ន៎ អ្នកណាជាទីស្រឡាញ់របស់នាង
> ជាងខ្ញុំ ដូច្នេះ ។

លំដាប់នោះព្រះនាងសម្មុលាក៏ក្រាបទូលព្រះស្វាមីថា បពិត្រព្រះរាជាកាលខ្ញុំបេះផ្លែឈើស្រេចហើយ ដើរមកជួបទានវៈមួយរូប យក្ខនោះមានចិត្តប្រាថ្នាខ្ញុំម្ចាស់ ចាប់ដើមដៃហើយពោលថា បើនាងមិនព្រមធ្វើតាមពាក្យរបស់

យើងទេ យើងនឹងទំពាស៊ីនាងជាអាហារ ពេលនោះខ្ញុំសោយសោកដល់ទ្រង់តែមួយអង្គទើបយំរៀបរាប់យ៉ាងនេះ ហើយពោលគាថានេះថា

ខ្ញុំម្ចាស់ដែលសត្រូវនោះចាប់បាន ក៏បានពោលពាក្យនេះថា យក្សទំពាស៊ីនូវខ្ញុំម្ចាស់ដោយហេតុណា ហេតុនោះមិនមែនជាទុក្ខនៃខ្ញុំម្ចាស់ទេ ក្រែងតែព្រះហឫទ័យព្រះអយ្យបុត្តរបស់ខ្ញុំម្ចាស់ ទៅជាបការៈដទៃដោយហេតុណា ហេតុនោះ ( ទើបជាទុក្ខនៃខ្ញុំម្ចាស់ ) ដូច្នេះ ។

កាលព្រះនាងទូលព្រឹត្តិការណ៍ដ៏សេសតទៅ ទើបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ត្រូវទានវៈនោះចាប់ហើយ កាលមិនអាចឲ្យយក្ខនោះលែងបានទើបធ្វើនូវការបន់ស្រន់ទេវតា រំពេចនោះសក្កទេវរាជ ទ្រទ្រង់នូវវជិរាវុធ យាងមកប្រថាប់ឈរលើអាកាស សម្គុតទានវៈឲ្យយក្ខនោះលែងនូវខ្ញុំម្ចាស់ ទ្រង់ចងយក្ខនោះដោយចំណងទិព្វបោះទៅក្នុងចន្លោះភ្នំទី ៣ ហើយចៀសចេញទៅ ខ្ញុំម្ចាស់អាស្រ័យសក្កទេវរាជទើបរួចជីវិតមកបាន ដូចទូលមកយ៉ាងនេះ ។

សោត្ថិសេនរាជកុមារ ទ្រង់ស្តាប់រឿងនោះហើយទើបទ្រង់ក្លែងជាត្រាស់ថា នៃនាងដ៏ចម្រើន លេសរបស់នាងនោះលើកទុកសិនចុះ ឈ្មោះថា ចិត្តរបស់មាតុគ្រាម មិនមានសច្ចៈឡើយ ក្នុងព្រៃហិមពាន្តមានពួកព្រានព្រៃ តាបសវិជ្ជាធរជាដើមសន្ធឹកសន្ធាប់ អ្នកណានឹងដឹងនាងបានហើយត្រាស់គាថាដោយសេចក្តីថា

ពាក្យសច្ចៈក្នុងពួកស្រីចោរ មានមាយាច្រើន គេរកបានដោយ

ក្រណាស់ ភាព គឺឫកមារយាទរបស់ស្ត្រីទាំងឡាយ គេដឹង
បានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ដូច្នេះ ។

ព្រះនាងសម្ពុលា បានឮព្រះតម្រាស់របស់ព្រះស្វាមីទើបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងព្យាបាលទ្រង់ដែលទ្រង់មិនជឿដោយកម្លាំងនៃសច្ចៈរបស់ខ្ញុំនោះឯងហើយដងទឹកអំពីក្អមធ្វើសច្ចកិរិយា ស្រោចទឹកលើសីសៈព្រះស្វាមីត្រាស់ថា

ខ្ញុំម្ចាស់មិនធ្លាប់ស្គាល់នូវបុគ្គលដទៃជាទីស្រឡាញ់ជាងព្រះអង្គ
យ៉ាងណា បើ ( ដំណើរ ) របស់ខ្ញុំម្ចាស់ ( នោះ ) ជាសច្ចៈ
យ៉ាងនោះ សូមសច្ចៈរក្សាព្រះអង្គទាំងរក្សានូវខ្ញុំម្ចាស់ ដោយ
ពាក្យសច្ចៈនេះ សូមព្យាធិរបស់ព្រះអង្គស្ងប់រម្ងាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ **តថា** សត្វ បណ្ឌិតគប្បីប្រកបបចូលជាមួយបទនេះថា **ថេ មមំ** មានអធិប្បាយថា ខ្ញុំទូលយ៉ាងណា បើជាការពិតរបស់ខ្ញុំយ៉ាងនោះកាលបើដូច្នោះ សូមសច្ចៈជួយរក្សានូវខ្ញុំក្នុងឥឡូវនេះ ក្នុងកាលតទៅនិងជួយរក្សាក្នុងកាលអនាគត ឥឡូវនេះសូមទ្រង់ស្តាប់ពាក្យរបស់ខ្ញុំចុះ ។ បទថា **យថាហំ ឆាភិជាឆាមិ** សេចក្តីថា ក្នុងគម្ពីរទាំងឡាយលោករចនាទុកថា **តថា មំ សច្ចំ ចាលេម** ពាក្យនោះមិនមានក្នុងអដ្ឋកថា ។

កាលព្រះនាងសម្ពុលា ធ្វើសច្ចកិរិយាយ៉ាងនេះហើយ ស្រោចទឹកថ្វាយប៉ុណ្ណោះ រោគឃ្លង់របស់សោត្ថិសេនរាជកុមារក៏រម្ងាប់មួយរំពេចដូចមាសដែលត្រូវលាងដោយទឹកជូរដូច្នោះ ។ ជនទាំង ២ នៅក្នុងអាស្រមនោះ ២-៣ រាត្រី

ក៏ចេញអំពីព្រៃដើរទៅកាន់នគរពារាណសី ចូលទៅកាន់ព្រះរាជឧទ្យាន ។

ព្រះរាជាទ្រង់ជ្រាបថាព្រះរាជឱរសនិងព្រះរាជសុណិសាត្រឡប់មក ទើបយាងទៅកាន់ព្រះរាជឧទ្យាន ត្រាស់ឲ្យលើកស្វេតច្ឆត្រថ្វាយសោត្ថិសេនរាជ-ឱរសនិងឲ្យអភិសេកព្រះនាងសម្ពុលាក្នុងតំណែងអគ្គមហេសីក្នុងព្រះរាជឧទ្យាននោះឯងហើយយាងចូលកាន់ព្រះនគរ ឯព្រះរាជបិតាទ្រង់បួសជាឥសី នៅក្នុងព្រះរាជឧទ្យាននោះហើយនិមន្តទៅឆាន់ក្នុងព្រះរាជនិវេសន៍នោះឯងជាប្រចាំ ។ ចំណែកព្រះបាទសោត្ថិសេន បានព្រះរាជទានត្រឹមតែតំណែងអគ្គមហេសីដល់ព្រះនាងសម្ពុលាតែម្យ៉ាង មិនមានរាជសក្ការៈណាមួយទៀតឡើយ មិនបានដាក់ព្រះហឫទ័យដល់ថាព្រះនាងសម្ពុលានោះ មានរវល់តែអភិរមនឹងស្ត្រីដទៃៗប៉ុណ្ណោះ ។ ដោយចង្អៀតចង្អល់ចំពោះស្រីដែលរួមព្រះស្វាមី ព្រះនាងសម្ពុលាក៏មានព្រះកាយស្គាំងស្គមទៅជាពេកស្គមលឿង មានព្រះវរកាយរវាមដោយសរសៃ ។ ថ្ងៃមួយព្រះនាងបានទៅកាន់សម្នាក់ព្រះសស្សុរតាបស ( តាបសដែលជាបិតាក្មេក ) ដែលនិមន្តមកឆាន់ក្នុងព្រះរាជវាំង ដើម្បីបន្ទោបង់នូវសេចក្ដីសោក ថ្វាយបង្គំតាបសដែលឆាន់ស្រេចហើយគង់ក្នុងចំណែកម្ខាង ។

សស្សុរតាបសនោះ កាលទតឃើញព្រះនាង មានព្រះឥន្ទ្រិយសៅហ្មង ទើបត្រាស់ព្រះគាថានេះថា

ដំរីទាំងឡាយច្រើនប្រមាណ ៧០០ មានអាវុធ ដែលយោធា
ប្រកបហើយ ទាំងពួកខ្មាន់ធ្នូមួយពាន់ប្រាំមួយរយ តែងរក្សា
ទាំងយប់ទាំងថ្ងៃ ម្នាលនាងដ៏ចម្រើន តើនាងនៅឃើញពួក

សត្រូវដូចម្តេច ដូច្នេះ ។

ព្រះគាថានោះមានអធិប្បាយថា សស្សុរតាបស មានព្រះតម្រាស់សួរថា នែនាងសម្ពុលាដ៏ចម្រើន ដីរបស់ពួកយើងមាន ៧០០ ប្រកបទៅដោយអាវុធសព្វយ៉ាង ដោយមានទាហានឡើងជិះត្រង់កដីទាំងនោះ ទាំងទាហានធ្នូក៏មាន ១៦០០ នាក់ទៀត ក៏នាំគ្នារក្សាព្រះនគរពារាណសី ទាំងយប់ទាំងថ្ងៃ កាលព្រះនគរមានការរក្សាល្អយ៉ាងនេះ នាងឃើញសត្រូវប្រភេទណាឬ នែនាងដ៏ចម្រើន ក្នុងពេលដែលនាងមកអំពីព្រៃដែលគួរខ្លើស មានភ័យជុំទិស នាងមានសរីរៈបរិបូរណ៍ តែឥឡូវនេះនាងស្គាំងស្គមដោយរោគស្គមលឿង ឥន្ទ្រិយសៅហ្មងពន់ពេក នាងខ្វាចក្រែងវត្ថុណា ។

ព្រះនាងសម្ពុលា បានស្តាប់ព្រះតម្រាស់របស់សស្សុរតាបសហើយទូលថា បពិត្រព្រះសម្មតិទេព ព្រោះព្រះរាជឱរសរបស់ទ្រង់មិនករុណាខ្ញុំម្ចាស់ដូចពេលមុនហើយត្រាស់ ៥ គាថាដោយសេចក្តីថា

ស្វាមីឃើញពួកស្ត្រីដែលតាក់តែងកាយ មានសម្បុរស្បែកល្អ ដូចស្រទាប់ផ្កាឈូក មានចង្កេះរៀវ មានសំឡេងដូចហង្ស ទ្រង់ព្រះសណ្តាប់នូវចម្រៀងនិងប្រគំដែលគេគួររាប់ របស់ពួកស្ត្រីទាំងនោះ បពិត្រព្រះបិតា ឥឡូវនេះព្រះស្វាមីរបស់ខ្ញុំម្ចាស់មិនប្រព្រឹត្តដូចកាលមុនយ៉ាងនោះទេ ។ បពិត្រព្រះបិតា ពួកស្ត្រីមានរូបល្អ ទ្រទ្រង់នូវប្រដាប់សម្រាប់រឹតដោះជាវិការៈនៃមាស តាក់តែងខ្លួន ជាស្ត្រីមនុស្សដូចស្ត្រីទេពអប្សរ ជាទីស្រឡាញ់

នៃព្រះរាជាព្រះនាមសោត្ថិសេន ជាស្ត្រីមានរាងកាយតិះដៀល មិនបាន ជាខត្តិយកញ្ញាតែងប្រលោមព្រះរាជានោះ ។ បពិត្រព្រះបិតា ប្រសិនបើខ្ញុំម្ចាស់ ចិញ្ចឹមព្រះស្វាមីនោះ ដោយការស្វែងរកនូវផ្លែឈើ ក្នុងព្រៃដូចក្នុងកាលមុន យ៉ាងនោះទៀត ព្រះស្វាមី គប្បីរាប់អានខ្ញុំម្ចាស់ ទាំងមិនមើលងាយខ្ញុំម្ចាស់ទេ បពិត្រព្រះបិតា ព្រោះហេតុនោះ ( ព្រៃ ) របស់ខ្ញុំម្ចាស់ ( នោះឯង ) ប្រសើរជាងរាជសម្បត្តិក្នុងក្រុងពារាណសីនេះ ។ នារីណា ( កើតក្នុងផ្ទះត្រកូល ) មានបាយនិងទឹកបរិបូណ៌ ដែលគេចាត់ចែងហើយ ជាស្ត្រីមានគ្រឿងប្រដាប់ដ៏ស្អាតវិសេស តាក់តែងខ្លួនប្រកបដោយអង្គគ្រប់យ៉ាង តែមិនជាទីស្រឡាញ់របស់ប្តី បានសម្លាប់ ( ខ្លួន ) ហើយសេចក្តីស្លាប់របស់នារីនោះ ប្រសើរជាងការរស់នៅជាយរាវាសនោះទៅទៀត ។ បើស្ត្រីណាទ័លក្រកំព្រា មិនមានបបុសគឺមានះ មានតែកន្ទេលជាគម្រប់ពីរ តែស្ត្រីនោះជាទីស្រឡាញ់របស់ប្តី ស្ត្រីណាទោះកំព្រា តែជាទីស្រឡាញ់ ( របស់ប្តី ) ស្ត្រីនេះឯងប្រសើរជាងស្ត្រីដែលប្រកបដោយអង្គគ្រប់យ៉ាង ដែលមិនជាទីស្រឡាញ់ ( របស់ប្តី ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បទុមុត្តរត្តចា** សេចក្តីថា ព្រះនាងសម្ពុលាសម្តែងថា អយ្យបុត្តទតឃើញស្ត្រី មានពណ៌សម្បុរស្អាត ដូចត្របកឈូក

មានរស្មីពណ៌មាស ចេញអំពីសរីរកាយរបស់នាងគ្រប់យ៉ាង ។ បទថា **វិ-រាគិតា** បានដល់ មានរូបទន់ក្ងន់ អធិប្បាយថា មានសរីរៈល្វាសល្វន់ ។ បទថា **ហំសគគ្គរា** សេចក្តីថា ទ្រង់ឃើញពួកស្ទំដែលស្អាតបែបនេះ មានសំឡេងពីរោះទន់ផ្អែម ដូចសំឡេងហង្ស ។ បទថា **តាសំ** សេចក្តីថា ព្រះនាងសម្ពុលាទូលថា ព្រោះទ្រង់ស្តាប់សំឡេងច្រៀងជាដើម របស់ស្ទំទាំងនោះ ឥឡូវនេះឱរសរបស់ព្រះអង្គមិនប្រព្រឹត្តចំពោះខ្ញុំម្ចាស់ដូចក្នុងកាលមុនឡើយ ។ បទថា **សុវណ្ណសង្កច្ចធរា** សេចក្តីថា ទ្រទ្រង់នូវគ្រឿងប្រដាប់ដែលសម្រេចដោយមាស ។ បទថា **អលង្កតា** សេចក្តីថា ប្រដាប់ដោយគ្រឿងអលង្ការច្រើនប្រភេទ ។ បទថា **មានុសិយច្ឆរូបមា** សេចក្តីថា ស្រស់ស្រាយដូចស្រីសួគ៌ក្នុងពពួកមនុស្ស ។

បទថា **សេនោបិយា** សេចក្តីថា ជាទីប្រោសប្រាណរបស់ ព្រះបាទសោត្ថិសេន ។ បទថា **បដិលោភយន្តិ នំ** សេចក្តីថា នាំគ្នាប្រលោមព្រះឱរសនោះ ។ បទថា **សចេ អហំ** សេចក្តីថា ព្រះនាងសម្ពុលាស្គាំងស្គមព្រោះចង្អៀតចង្អល់ចិត្តព្រោះស្រើរមព្រះរាជស្វាមី ក្រាបទូលថា បពិត្រព្រះរាជបិតា បើព្រះរាជឱរស ទ្រង់រាប់អានខ្ញុំម្ចាស់ដូចក្នុងកាលមុន ដែលខ្ញុំម្ចាស់ធ្លាប់បានបដិបត្តិបម្រើព្រះស្វាមី កាលស្តេចនៅក្នុងព្រៃព្រោះរោគឃ្លង់ដោយការស្វែងរកផលាផលនិងទ្រង់មិនមើលងាយខ្ញុំសោត ព្រៃមួយកន្លែងប៉ុណ្ណោះ ប្រសើរសម្រាប់ខ្ញុំ ក្រៃលែងជាងរាជសម្បត្តិក្នុងនគរពារាណសីនេះ ។ បទថា **យ-មន្នចារេ** កាត់បទជា **យំ អន្នចារេ** ។ បទថា **ឱហិតេ** សេចក្តីថា ចាត់

បែងតាំងទុកហើយ ។ ព្រះនាងសម្ពុលាសម្ដែងដល់ផ្ទះដែលមានបាយនិងទឹកច្រើនដោយបទទាំងនេះ ។

បានឮថា ព្រះនាងសម្ពុលានោះមានបំណងដូច្នេះថា នារីណាមិនមានបុត្តសូម្បីតែមួយក្នុងផ្ទះសូម្បីមានបាយទឹកបរិបូណ៌ មានអាករណៈរលោង ប្រដាប់តាក់តែងដោយអលង្ការផ្សេងៗ ដល់ព្រមដោយអង្គគុណសព្វយ៉ាង តែមិនជាទីស្រឡាញ់របស់ប្ដី ចាំតែបៀតបៀន កាលដែលស្រីនោះយកវល្លិ ឬខ្សែចងកស្លាប់ល្អជាងការរស់នៅនោះ ។

បទថា **អឌ្ឍាឡ្ហិយា** បានដល់ មិនមានគ្រឿងប្រដាប់ ។ បទថា **កដង្គុតិយា** បានដល់ មានតែកន្ទេលផែងដែលជាទីដេក ។ បទថា **សេយ្យា** សេចក្ដីថា សូម្បីនាងជាស្រីកំព្រាតែជាទីស្រឡាញ់របស់ប្ដី ស្រីនេះឯងឈ្មោះជាប្រសើរ ។

កាលព្រះនាងសម្ពុលា ទូលហេតុដែលខ្លួនស្នាំងស្គមដល់តាបសជាបិតាក្មេកយ៉ាងនេះហើយទើបតាបសជាបិតាក្មេកត្រាស់ឲ្យយាងព្រះរាជាមក ត្រាស់ថា នែបាសោត្ថិសេន កាលអ្នកកើតរោគឃ្លង់នៅក្នុងព្រៃ នាងសម្ពុលាទៅជាមួយឯង បម្រើបដិបត្តិនិងញាំងរោគរបស់ឯងឲ្យជាសះស្បើយ ដោយកម្លាំងនៃសច្ចៈរបស់ខ្លួន បានជួយធ្វើឲ្យឯងតាំងនៅក្នុងរាជសម្បត្តិតែបាមិនបានដាក់ចិត្តដល់ទីដែលឈរ ទីដែលអង្គុយរបស់នាងឡើយ បាធ្វើមិនសមគួរ ឈ្មោះជាការទ្រុស្តមិត្តនោះជាបាប កាលព្រះរាជាប្រទានឱវាទដល់ព្រះរាជឱរសទើបត្រាស់ព្រះគាថាដោយសេចក្ដីថា

ស្ត្រីណា ជាគុណរបស់បុរស ស្ត្រីនោះគេរកបានក្រក្រៃលែង
កស្តាណា ជាគុណរបស់ស្ត្រី កស្តានោះ គេរកបានដោយក្រ
ម្នាលបាជាធំជាងជន កិរិយារបស់អ្នកជាគុណ ( នៃអ្នក )
ផង ជាស្ត្រីមានសីលផង អ្នកចូរប្រព្រឹត្តធម៌ចំពោះនាងសម្ពុលា
ដូច្នេះ ។

ព្រះគាថានោះមានអធិប្បាយថា នែកូន ស្រីដែលមានឧបការៈ មានចិត្តទន់ភ្លន់ មានការអាណិតអាសូរចំពោះបុរសជាស្វាមីក្តី បុរសជាស្វាមី មានឧបការៈ ដឹងគុណដែលស្រីជាកិរិយាធ្វើហើយក្តី ទាំង ២ ពួកនេះរកបានលំបាកពេកណាស់ នាងសម្ពុលានេះមានឧបការៈចំពោះបាផង ដល់ព្រមដោយសីលផង ព្រោះហេតុនោះ ឯងត្រូវប្រព្រឹត្តធម៌ចំពោះនាង ត្រូវនឹកដល់គុណរបស់នាងហើយចូរមានចិត្តទន់ភ្លន់ ញុំាងចិត្តរបស់នាងឲ្យរីករាយចុះ ។

រាជឥសីប្រទានឱវាទដល់ព្រះរាជឱរសយ៉ាងនេះហើយ ទ្រង់ក្រោកឡើងចៀសចេញទៅកាន់ឧទ្យាន កាលរាជឥសីដែលជាព្រះជនក ទ្រង់ចៀសចេញទៅហើយព្រះបាទសោត្ថិសេន ត្រាស់ឲ្យព្រះនាងសម្ពុលាមកគាល់ ហើយត្រាស់ថា នែនាងដ៏ចម្រើន ចូរនាងអត់ទោសដែលខ្ញុំធ្វើខុសមកអស់កាលមានប្រមាណប៉ុណ្ណេះ តាំងអំពីនេះទៅខ្ញុំនឹងប្រគល់រាជសម្បត្តិឲ្យដល់នាងទាំងអស់ហើយត្រាស់អវសានគាថាថា

ម្នាលនាងសម្ពុលា មានភោគៈបានហើយដ៏ច្រើន បើនាងធ្លង
ផុតចាកសេចក្តីប្រាថ្នាដល់នូវមរណៈ អញនិងពួករាជកញ្ញា

ទាំងអស់របស់នាងនេះនឹងធ្វើតាមពាក្យរបស់នាង ដូច្នេះ ។

ព្រះគាថានោះ មានអធិប្បាយថា នែព្រះនាងសម្ពុលា បើនាងបានភោគសម្បត្តិបរិបូណ៌ដោយមិនបានទទួលតែងតាំងជាអគ្គមហេសី ព្រោះការដែលអភិសេកស្ថាបនាទុកក្នុងគំនរតនៈហើយគង់ធ្លាក់ចុះក្នុងសេចក្តីប្រណែន ទោះដល់សេចក្តីស្លាប់សោត យើងនិងរាជកញ្ញាទាំងអស់ នឹងជាអ្នកធ្វើតាមពាក្យរបស់នាង ចូរនាងចាត់ចែងរាជសម្បត្តិនេះតាមបំណងចុះ ហើយព្រះរាជទានភាពជាធំទាំងអស់ដល់អគ្គមហេសី ។

តាំងអំពីនោះមក ជនទាំង ២ នៅដោយសាមគ្គី បំពេញបុណ្យកុសលមានទានជាដើម ហើយទៅតាមយថាកម្ម ។ ព្រះរាជតាបសធ្វើនូវឈាននិងអភិញ្ញាឲ្យកើតហើយក៏ជាអ្នកចូលដល់ព្រហ្មលោក ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនព្រះនាងមល្លិកាក៏គោរពចំពោះស្វាមីដូចទេវតាដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះនាងសម្ពុលាក្នុងកាលនោះបានមកជាព្រះនាងមល្លិកាក្នុងកាលឥឡូវនេះ ស្តេចសោត្ថិសេនក្នុងកាលនោះបានមកជាព្រះបាទកោសល តាបសដែលជារាជបិតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សម្ពុលាជាតក ចប់**

# ភណ្ឌុតិណ្ឌុកជាតក

[ ៥៤៨ ] ( ភណ្ឌុតិណ្ឌុកទេវតាពោធិសត្វពោលថា ) សេចក្តីមិនប្រហែស ជាឧបាយឲ្យបាននូវព្រះនិព្វានឈ្មោះអមតៈ សេចក្តីប្រហែសជាផ្លូវនៃសេចក្តីស្លាប់ ពួកជនអ្នកមិនប្រហែសឈ្មោះថាមិនស្លាប់ ពួកជនណាជាអ្នកប្រហែស ពួកជននោះដូចជាស្លាប់ហើយ ។ សេចក្តីប្រហែសរមែងកើតឡើងព្រោះសេចក្តីស្រវឹង ការអស់ទៅ ( នៃញាតិជាដើម ) រមែងកើតឡើងព្រោះសេចក្តីប្រ-ហែស សេចក្តីប្រទូស្តទាំងឡាយ រមែងកើតឡើងព្រោះការអស់ទៅ ( នៃញាតិជាដើម ) បពិត្រព្រះអង្គដ៏ប្រសើរ មានភារៈ ( ក្នុងដែន ) ព្រះអង្គកុំប្រហែសឡើយ ។ ពួកក្សត្រិយ៍ច្រើនអង្គមានសេចក្តីប្រហែសញុំាងសេចក្តីចម្រើននិងញុំាងដែនឲ្យវិនាស ចំណែកពួកមេស្រុក អ្នកស្រុក អ្នកបួសគ្រហស្ថក៏វិនាស ។ បពិត្រព្រះរាជា ព្រះអង្គញុំាងដែនឲ្យចម្រើន ភោគៈទាំងអស់ក្នុងដែនរបស់ក្សត្រជាអ្នកប្រហែស រមែងវិនាស សេចក្តីវិនាសនោះ ជាទុក្ខរបស់ព្រះរាជា ។ បពិត្រមហារាជ សេចក្តីប្រហែសនេះ មិនមែនជាធម៌ ( របស់ពួកព្រះរាជាបុរាណទេ ) ព្រះអង្គប្រហែសហួសប្រមាណ ពួកចោរកម្ចាត់នូវជនបទដែលសម្បូណ៌ស្តុកស្តម្ភនោះ ។ ពួកបុត្ររបស់ព្រះអង្គ មិនមានទាំងប្រាក់ក៏មិនមាន ទាំងទ្រព្យក៏មិនមាន កាលបើចោរប្លន់រាស្ត្រ ( យ៉ាងនេះ ) ព្រះអង្គនឹងសាបសូន្យចាកភោគៈគ្រប់យ៉ាង ។ ពួកញាតិមិត្តនិងសម្លាញ់ រមែងមិនទទួលដឹងនូវក្សត្រនោះ ដែលជាព្រះរាជាសាបសូន្យចាកភោគៈទាំងពួង ជាបុគ្គលដែលគួរទទួលដឹងទេ ។ ពួកពលដំរី ពួកសេនា ពលរថ ពល

ថ្មីរជើននិងពួកកម្មករ ដែលអាស្រ័យចិញ្ចឹមជីវិតនឹងព្រះរាជានោះឯង ក៏មិនទទួលដឹងនូវព្រះរាជាដែលគួរទទួលដឹងនោះ ។ សិរី គឺយសសម្បត្តិ រមែងលះបង់នូវបុគ្គលពាល អ្នកមិនចាត់ចែងនូវការងារ មានគំនិតអាក្រក់ អាប់ឥតប្រាជ្ញាដូចជាពស់លះបង់នូវសំណកចាស់ ។ ភោគៈទាំងអស់រមែងចម្រើនដល់បុគ្គល អ្នកចាត់ចែងការងារដោយល្អ ក្រោកឡើងទាន់កាល ជាអ្នកមិនខ្ជិលច្រអូស ដូចជាគោប្រព្រឹត្តទៅមួយអន្លើដោយគោឧសភ ។ បពិត្រមហារាជ សូមព្រះអង្គយាងទៅកាន់ទីជាទីចាំស្តាប់ក្នុងជនបទក្នុងដែន លុះទតឃើញនឹងទ្រង់ព្រះសណ្តាប់ក្នុងដែននោះហើយ ក៏យកការណ៍តាមរាជកិច្ចនោះ តាមដំណើរនោះ ។

[ ៥៤៩ ] ( បុរសចាស់ម្នាក់ជេរថា ) ខ្លួនអញ ត្រូវបន្លាមុតហើយវេទនាក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យព្រះបាទបញ្ចាលត្រូវសរក្នុងសង្គ្រាមហើយវេទនាយ៉ាងនោះដែរ ។

[ ៥៥០ ] ( បុរោហិតសួរថា ) អ្នកជាមនុស្សចាស់ មានភ្នែកទុព្វលមើលរូបមិនឃើញដោយស្រួលទេ បន្លាមុតអ្នកឯងដោយហេតុណា ( ទោស ) របស់ព្រះរាជាព្រហ្មទត្តចំពោះហេតុនោះ តើដូចម្តេច ។

[ ៥៥១ ] ( បុរសចាស់... ) ម្នាលព្រាហ្មណ៍ ក្នុងហេតុនេះទោសរបស់ព្រះរាជាព្រហ្មទត្តមានច្រើន ( បានជា ) ខ្ញុំនោះ ( ធ្លាក់ ) ក្នុងផ្លូវ ( មានបន្លា ) ព្រោះពួកអ្នកជនបទព្រះរាជាមិនរក្សា ទ្រង់បៀតបៀនដោយពលិកម្ម ( សួយសារអាករ ) មិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ ពួកចោរស៊ី

( ប្លន់ ) ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនរបស់ព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។ ម្នាលអ្នកកាលបើភ័យបែបនេះកើតហើយ មនុស្សទាំងឡាយដែលត្រូវភ័យគ្របសង្កត់ តែងនាំយកនូវបន្ទាក្នុងព្រៃមកធ្វើជាទីសម្រាប់ពឹងពួន ។

[ ៥៥២ ] ( ស្រីទុគ៌តម្នាក់ជេរថា ) ពួកកុមារីជាស្ត្រីគ្មានប្តីរហូតចាស់ក្នុងដែននៃព្រះរាជាព្រហ្មទត្តណា កាលណាហ្ន៎ព្រះរាជាព្រហ្មទត្តនេះនឹងស្លាប់ទៅ ។

[ ៥៥៣ ] ( បុរោហិតឃាត់ថា ) នែនាងលាមក ជាស្ត្រីមិនឈ្លាសក្នុងឧបាយនៃសេចក្តីចម្រើន ពាក្យនាងជាពាក្យអាក្រក់ ព្រះរាជានឹងស្វែងរកប្តីឲ្យពួកនាងកុមារីក្នុងទីណា ។

[ ៥៥៤ ] ( ស្ត្រីចាស់... ) នែព្រាហ្មណ៍ ពាក្យរបស់ខ្ញុំមិនអាក្រក់ទេ ខ្ញុំជាស្ត្រីឈ្លាសវៃក្នុងផ្លូវចម្រើនព្រោះពួកអ្នកជនបទស្តេចមិនរក្សា ទ្រង់បៀតបៀនដោយស្លួយសារអាករមិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ ពួកចោរស៊ី ( ប្លន់ ) ក្នុងវេលាថ្ងៃពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន កាលបើរាស្ត្ររស់នៅដោយលំបាកចិញ្ចឹមប្រពន្ធបានដោយលំបាក តើពួកនាងកុមារីបានប្តីអំពីណា ។

[ ៥៥៥ ] ( អ្នកភ្ជួរជេរថា ) គោឈ្មោះសាលិយៈនេះ ត្រូវផាលមុតហើយ ដេកស្រតឹកយ៉ាងណា សូមឲ្យព្រះរាជាក្រុងបញ្ចាល ត្រូវគេសម្លាប់ដោយលំពែងក្នុងសង្គ្រាម ដេកយ៉ាងនោះចុះ ។

[ ៥៥៦ ] ( បុរោហិត... ) នែបុរសលាមក អ្នកណាខុសខ្ជួនឯង ហើយផ្ដាសាព្រះរាជា អ្នក ( នោះ ) ឈ្មោះថា ខឹងចំពោះព្រះរាជាព្រហ្មទត្ត ដោយហេតុមិនត្រូវតាមធម៌ទេ ។

[ ៥៥៧ ] ( អ្នកក្ជួរ... ) ម្នាលព្រាហ្មណ៍ ខ្ញុំខឹងចំពោះព្រះរាជាព្រហ្ម-ទត្តដោយហេតុត្រឹមត្រូវតាមធម៌ ( ព្រោះថា ) ពួកអ្នកជនបទស្ដេចមិនរក្សា ទ្រង់បៀតបៀនដោយស្ទួយសារអាករមិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូច កាច ជនមិនប្រកបដោយធម៌មានច្រើន ។ ស្ត្រីជាអ្នកនាំបាយមកនោះប្រាកដ ជាដាំម្ដងទៀត បានជានាំបាយមកក្នុងវេលារសៀល ខ្ញុំកំពុងរកមើលនូវស្ត្រី អ្នកនាំបាយមក គោឈ្មោះសាលិយៈក៏ត្រូវផាលមុត ។

[ ៥៥៨ ] ( អ្នករូតទឹកដោះជេរថា ) ក្នុងថ្ងៃនេះខ្ជួនអញ ( ត្រូវមេ គោ ) ធាក់ ទាំងទឹកដោះរបស់អញកំពប់ទៅយ៉ាងណា សូមឲ្យព្រះរាជា បញ្ចាលនគរ ត្រូវគេសម្លាប់ដោយដាវក្នុងសង្គ្រាមវិនាសយ៉ាងនោះចុះ ។

[ ៥៥៩ ] ( បុរោហិត... ) សត្វចិញ្ចឹមនេះ ចាក់ចោលនូវទឹកដោះ សត្វចិញ្ចឹមបៀតបៀននូវផាល អ្នកដ៏ចម្រើន តិះដៀលយើងដោយហេតុណា កំហុសដូចម្ដេចរបស់ព្រះរាជាព្រហ្មទត្តក្នុងហេតុនោះ ។

[ ៥៦០ ] ( អ្នករូតទឹកដោះ... ) ម្នាលព្រាហ្មណ៍ ព្រះរាជាបញ្ចាល នគររបស់រាជត្រកូលព្រហ្មទត្ត គួរអ្នកផងតិះដៀលហើយ ព្រោះថា ពួកអ្នក ជនបទព្រះរាជាមិនរក្សា ទ្រង់បៀតបៀនដោយស្ទួយអាករ មិនប្រកបដោយ

ធម៌ ។ ក្នុងវេលាយប់ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។ មេគោកាចផង យើងមិនបានរូតនូវទឹកដោះណាក្នុងកាលមុន ក្នុងថ្ងៃនេះ ឥឡូវនេះពួកយើងក៏ត្រូវពួករាជបុរសអ្នកប្រាថ្នានូវទឹកដោះ មករឹបជាន់ ទើបរូតនូវទឹកដោះនោះ ។

[ ៥៦១ ] ( ពួកក្មេងអ្នកស្រុកជេរថា ) មេគោកំព្រា ជាសត្វព្រាត់ប្រាសនេះ ស្ទុះទ្រូឆ្ងាយយ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលនគរព្រាត់ប្រាសនិរាស វង្វេងស្ទួត កន្ទក់កន្ទេញ យ៉ាងនោះចុះ ។

[ ៥៦២ ] ( បុរោហិត... ) សត្វចិញ្ចឹមរបស់អ្នករក្សានូវសត្វចិញ្ចឹមស្ទុះទ្រូឆ្ងាក្តី ស្រែកក្តីដោយហេតុណា កំហុសដូចម្តេចរបស់ព្រះរាជាព្រហ្មទត្តក្នុងហេតុនេះ ។

[ ៥៦៣ ] ( ពួកក្មេងអ្នកស្រុក... ) បពិត្រមហាព្រាហ្មណ៍ កំហុសរបស់ព្រះរាជាព្រហ្មទត្ត ( មានពិត ) ព្រោះថា ពួកអ្នកជនបទព្រះរាជាមិនរក្សា ទ្រង់បៀតបៀនដោយស្នួយសារអាករមិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ហេតុដូចម្តេចហ្ន៎ កូនគោរបស់យើងកំពុងបៅដោះ មានប្រយោជន៍ដល់ស្រោមដាវត្រូវរាជបុរសសម្លាប់ ។

[ ៥៦៤ ] ( កង្កែបជេរថា ) អញជាសត្វកើតក្នុងព្រៃ ត្រូវពួកក្អែកក្នុងស្រុកចឹកស៊ីក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យស្តេចបញ្ចាលនគរ ព្រមទាំងបុត្ត

ត្រូវគេកាប់ក្នុងចម្បាំងជាច់ខ្ទេចខ្ទី យ៉ាងនោះចុះ ។

[ ៥៦៥ ] ( បុរោហិត... ) នែកង្អែប ព្រះរាជាទាំងឡាយក្នុងមនុស្សលោកមិនចាត់ចែងនូវការរក្សាក្នុងពួកសត្វទាំងពួងទេ ពួកក្អែកស៊ីនូវសត្វទាំងរស់ដូចជាឯងដោយហេតុណា ព្រះរាជាមិនឈ្មោះថា មិនប្រព្រឹត្តធម៌ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

[ ៥៦៦ ] ( កង្អែប... ) ឱអ្នកជាព្រហ្មចារី តែមានសភាពមិនប្រកបដោយធម៌សោះ ពោលនូវពាក្យសរសើរចំពោះក្សត្រិយ៍ កាលបើប្រជាជនជាច្រើនដែលព្រះរាជារឹបជាន់ អ្នកនៅតែបូជាចំពោះព្រះរាជា ជាអ្នកមានវាទៈដ៏ក្រៃលែង ។ នែព្រាហ្មណ៍ ប្រសិនបើដែននេះមានអ្នករាជការល្អរមែងជាដែនសុកសម្ភ មានរាស្ត្រីករាយជ្រះថ្លា ទាំងពួកក្អែកក៏ស៊ីនូវដុំបាយដ៏ប្រសើរ ជាគ្រឿងបូជា ( របស់មនុស្ស ) ពួកក្អែកមិនគប្បីស៊ីសត្វទាំងរស់ ប្រាកដដូចជាខ្ញុំទេ ។

**ចប់ កណ្ឌតិណ្ឌុកជាតក ទី ១០ ។**

## ឧទ្ទាននៃតឹសនិបាតនោះគឺ

និយាយអំពីកឹចន្ទជាតក ១ កុម្ភជាតក ១ ជយទ្ទិសជាតក ១ ឆទ្ទន្តជាតក ១ សម្ភវជាតក ១ មហាកបិជាតក ១ ទករក្ខ-សជាតក ១ នាគដ៏ប្រសើរឈ្មោះបណ្ឌរកៈ ១ សម្ពុលាជាតក ១ តិណ្ឌុកជាតក ១ ។

## ចប់ តឹសនិបាត ។

## អដ្ឋកថា
## ភណ្ឌុតិណ្ឌុកជាតក

[ ៥៤៨-៥៦៦ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភ-ជោវាទទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អប្បមាទោ** ដូច្នេះជាដើម ។

រាជោវាទមានសេចក្ដីពិស្ដារហើយខាងដើមនោះឯង ។

ក្នុងអតីតកាលព្រះរាជាព្រះនាមថាបញ្ចាលតាំងនៅក្នុងអគតិ ទ្រង់ប្រមាទសោយរាជ្យមិនប្រកបដោយធម៌ នៅក្នុងឧត្តរបញ្ចាលនគរ ដែនកបិល គ្រានោះអាមាត្យជាដើមរបស់ទ្រង់ក៏ក្លាយជាមនុស្សអធម៌ទាំងអស់ ។ ប្រជានុ-រាស្ត្រត្រូវកៀបសង្កត់ដោយកាស៊ីអាករ ត្រូវនាំកូនប្រពន្ធគេចពីបំណុល ចូលទៅក្នុងព្រៃ ដូចហ្វូងម្រឹគ ក្នុងទីដែលធ្លាប់មានផ្ទះ ក៏ក្លាយជាទីមិនមានផ្ទះ ។ ពេលថ្ងៃមហាជនមិនអាចនៅក្នុងផ្ទះបាន ព្រោះខ្លាចរាជបុរស នាំគ្នាអូសបន្លាជាដើមព័ទ្ធផ្ទះ លុះអរុណរះឡើងក៏គេចចូលព្រៃ ពេលថ្ងៃរាជបុរសរឹបជាន់ពេលយប់ពួកចោរបៀតបៀន ។

សម័យនោះព្រះពោធិសត្វកើតជារុក្ខទេវតា នៅត្រង់គន្ធតិន្ទុកព្រឹក្ស ខាងក្រៅព្រះនគរ ។ រៀងរាល់ឆ្នាំបានទទួលពលីកម្មដែលមានតម្លៃ ១០០០ អំពីរាជសម្នាក់ រុក្ខទេវតាគិតថា ព្រះរាជានេះទ្រង់ប្រមាទ សោយរាជសម្បត្តិសកលរដ្ឋនឹងវិនាស វៀរអាត្មាអញហើយ មិនមានអ្នកណាអាចដឹកនាំឲ្យព្រះរាជាតាំងនៅក្នុងផ្លូវត្រូវបានឡើយ ម្យ៉ាងទៀតទ្រង់មានឧបការៈច្រើនដល់អញ

បូជាដោយពលីកម្ម ១០០០ រាល់ឆ្នាំ អញនឹងឲ្យឱវាទដល់ទ្រង់ ។ ក្នុងកាលនោះរុក្ខទេវតាចូលទៅកាន់បន្ទប់ផ្ទំរបស់ព្រះរាជា ឈរលើអាកាសត្រង់ក្បាលដំណេក បញ្ចេញរស្មី ។ ព្រះរាជាទតឃើញទេវតារុងរឿងដូចគ្នានឹងព្រះអាទិត្យទើបនឹងរះទើបត្រាស់សួរថា លោកជានរណា មកទីនេះព្រោះហេតុអ្វី រុក្ខទេវតាបានឮព្រះរាជតម្រាស់ហើយក្រាបទូលថា បពិត្រមហារាជ ខ្ញុំឈ្មោះគន្ធតិន្ទុកទេវតា គិតថានឹងថ្វាយឱវាទដល់ទ្រង់ទើបមកគាល់ ។ ព្រះរាជាត្រាស់សួរថា លោកនឹងឲ្យឱវាទអ្វីឬ កាលព្រះរាជាត្រាស់សួរយ៉ាងនេះហើយ ទើបព្រះមហាសត្វទូលថា បពិត្រមហារាជ ទ្រង់ជាអ្នកប្រមាទសោយរាជសម្បត្តិ ព្រោះហេតុនោះដែនទាំងមូលរបស់ទ្រង់នឹងវិនាសដូចត្រូវចោរប្លន់ ធម្មតាព្រះរាជា កាលសោយរាជសម្បត្តិដោយសេចក្តីប្រមាទ មិនមែនជាម្ចាស់នៃដែនទាំងមូលឡើយ ដល់នូវសេចក្តីវិនាសក្នុងបច្ចុប្បន្ន ហើយក្នុងកពខាងមុខនឹងត្រូវកើតក្នុងមហានរកទៀត ម្យ៉ាងទៀតព្រះរាជា ដល់នូវសេចក្តីប្រមាទហើយ សូម្បីជនក្នុងរាជសម្នាក់ ក្រៅរាជសម្នាក់រមែងនាំគ្នាប្រមាទ ដោយហេតុនោះព្រះរាជាមិនគួរប្រមាទដូច្នេះហើយកាលផ្តើមធម្មទេសនា ទើបពោលគាថានេះថា

សេចក្តីមិនប្រហែស ជាឧបាយឲ្យបាននូវព្រះនិព្វានឈ្មោះអមតៈ
សេចក្តីប្រហែស ជាផ្លូវនៃសេចក្តីស្លាប់ ពួកជនអ្នកមិនប្រហែស
ឈ្មោះថាមិនស្លាប់ ពួកជនណាជាអ្នកប្រហែស ពួកជននោះ
ដូចជាស្លាប់ហើយ ។ សេចក្តីប្រហែស រមែងកើតឡើងព្រោះ

សេចក្តីស្រេវឹង ការអស់ទៅ ( នៃញាតិជាដើម ) រមែងកើតឡើងព្រោះសេចក្តីប្រហែស សេចក្តីប្រទូស្តទាំងឡាយ រមែងកើតឡើងព្រោះការអស់ទៅ ( នៃញាតិជាដើម ) បពិត្រព្រះអង្គដ៏ប្រសើរ មានការៈ ( ក្នុងដែន ) ព្រះអង្គកុំប្រហែសឡើយ ។ ពួកក្សត្រិយ៍ច្រើនអង្គមានសេចក្តីប្រហែស ញុំាងសេចក្តីចម្រើននិងញុំាងដែនឲ្យវិនាស ចំណែកពួកមេស្រុក អ្នកស្រុក អ្នកបួស គ្រហស្ថ ក៏វិនាស ។ បពិត្រព្រះរាជា ព្រះអង្គញុំាងដែនឲ្យចម្រើន ភោគៈទាំងអស់ក្នុងដែនរបស់ក្សត្រជាអ្នកប្រហែស រមែងវិនាស សេចក្តីវិនាសនោះជាទុក្ខរបស់ព្រះរាជា ។ បពិត្រមហារាជ សេចក្តីប្រហែសនេះមិនមែនជាធម៌ ( របស់ពួកព្រះរាជាបុរាណទេ ) ព្រះអង្គប្រហែសហួសប្រមាណ ពួកចោរកម្ទាត់នូវជនបទដែលសម្បូណ៌ស្តុកស្តម្ភនោះ ។ ពួកបុត្តរបស់ព្រះអង្គមិនមាន ទាំងប្រាក់ក៏មិនមាន ទាំងទ្រព្យក៏មិនមាន កាលបើចោរប្លន់រាស្ត្រ ( យ៉ាងនេះ ) ព្រះអង្គនឹងសាបសូន្យចាកភោគៈគ្រប់យ៉ាង ។ ពួកញាតិ មិត្តនិងសម្លាញ់រមែងមិនទទួលដឹងនូវក្សត្រនោះ ដែលជាព្រះរាជាសាបសូន្យចាកភោគៈទាំងពួងជាបុគ្គលដែលគួរទទួលដឹងទេ ។ ពួកពលដំរី ពួកសេនា ពលរថ ពលថ្មើរជើងនិងពួកកម្មករដែលអាស្រ័យចិញ្ចឹមជីវិតនឹងព្រះរាជានោះឯង ក៏មិនទទួលដឹងនូវព្រះ

រាជាដែលគួរទទួលដីងនោះ ។ សិរី គឺយសសម្បត្តិ រមែងលះបង់នូវបុគ្គលពាលអ្នកមិនចាត់ចែងនូវការងារ មានគំនិតអាក្រក់អាប់ឥតប្រាជ្ញាដូចជាពស់លះបង់នូវសំណាកចាស់ ។ ភោគៈទាំងអស់ រមែងចម្រើនដល់បុគ្គល អ្នកចាត់ចែងការងារដោយល្អក្រោកឡើងទាន់កាល ជាអ្នកមិនខ្ជិលច្រអូស ដូចជាគោប្រព្រឹត្តទៅមួយអន្លើដោយគោឧសភ ។ បពិត្រមហារាជ សូមព្រះអង្គយាងទៅកាន់ទីជាទីចាំស្តាប់ក្នុងជនបទក្នុងដែន លុះទតឃើញនឹងទ្រង់ព្រះសណ្តាប់ក្នុងដែននោះហើយ ក៏យកការណ៍តាមរាជកិច្ចនោះ តាមដំណើរនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អប្បមាទោ** បានដល់ ការមិនទៅប្រាសសតិ ។ បទថា **អមតំបទំ** សេចក្តីថា ជាផ្លូវ គឺជាហេតុនៃអមតនិព្វាន ។ បទថា **មច្ចុនោ បទំ** សេចក្តីថា សេចក្តីប្រមាទ ជាហេតុនៃសេចក្តីស្លាប់ ។ ព្រោះបុគ្គលប្រមាទហើយ ចម្រើនវិបស្សនា កាលមិនអាចសម្រេចអប្បដិសន្ធិកភាវៈបាន រមែងកើត រមែងស្លាប់ក្នុងសង្សាររឿយៗ ហេតុនោះទើបសេចក្តីប្រមាទ ឈ្មោះថាជាផ្លូវនៃសេចក្តីស្លាប់ ។ បទថា **ន មីយន្តិ** សេចក្តីថា បុគ្គលមិនប្រមាទ ចម្រើនវិបស្សនា សម្រេចអប្បដិសន្ធិកភាវៈហើយឈ្មោះថាមិនស្លាប់ ព្រោះមិនកើតក្នុងសង្សារទៀត ។ បទថា **យេ បមត្តា** សេចក្តីថា បពិត្រមហារាជ បុគ្គលណាប្រមាទហើយ បុគ្គលនោះគួរឃើញដូចអ្នកស្លាប់ហើយ ។ ព្រោះហេតុអ្វី ព្រោះញុំាងកិច្ចឲ្យសម្រេចមិនបាន ។ ពិត

ហើយសម្រាប់អ្នកដែលស្លាប់ហើយ រមែងមិនមានការគិត ការប្រាថ្នា ឬការខ្វល់ខ្វាយថា អញនឹងឲ្យទាន នឹងរក្សាសីល នឹងធ្វើឧបោសថកម្មនិងបំពេញគុណ ព្រោះប្រាសចាកវិញ្ញាណ ។ សម្រាប់បុគ្គលប្រមាទក៏មិនមាន ព្រោះដាច់នូវការមិនប្រមាទ ព្រោះហេតុនោះ បុគ្គលដែលស្លាប់ និងបុគ្គលដែលប្រមាទ ទាំង ២ នេះ ទើបស្មើគ្នា ជាបុគ្គលប្រភេទតែមួយ ។

បទថា **មទា** សេចក្តីថា បពិត្រមហារាជ ឈ្មោះថា ការប្រមាទ តែងកើតព្រោះសេចក្តីស្រវឹង ៣ ប្រការ គឺស្រវឹងក្នុងការមិនមានរោគ ១ ស្រវឹងក្នុងវ័យ ១ និងស្រវឹងក្នុងជីវិត ១ ។ បុគ្គលនោះ លុះស្រវឹងហើយក៏ដល់នូវសេចក្តីប្រមាទ ធ្វើនូវបាបកម្មដូចជាបាណាតិបាតជាដើមបាន ។ ក្នុងពេលនោះព្រះរាជា រមែងត្រាស់ឲ្យកាត់ជើងខ្លះ ដៃខ្លះ ឲ្យប្រហារជីវិតខ្លះ រឹបអូសយកទ្រព្យទាំងអស់ខ្លះ ព្រោះសេចក្តីប្រមាទរបស់បុគ្គលនោះ ទើបកើតនូវការអស់ញាតិ អស់ទ្រព្យ អស់ជីវិតយ៉ាងនេះ ។ បុគ្គលចូលដល់នូវការអស់ទ្រព្យ ឬអស់យសហើយ កាលមិនអាចចិញ្ចឹមជីវិតបាន ក៏ត្រូវធ្វើកាយទុច្ចរិតជាដើមដើម្បីចិញ្ចឹមជីវិតតទៅ ព្រោះការលះបង់ខ្លួនចោលនៃបុគ្គលនោះយ៉ាងនេះទើបកើតទោសកំហុសឡើង ព្រោះហេតុនោះទើបខ្ញុំដាស់តឿនទ្រង់ ។ បទថា **មា មទោ ភរតូសភ** សេចក្តីថា បពិត្រព្រះអង្គដែលមានភារៈជំក្នុងដែន ទ្រង់កុំស្រវឹង អធិប្បាយថា ទ្រង់កុំប្រមាទ ។

បទថា **អត្ថំ រដ្ឋំ** សេចក្តីថា ( បើ ) ក្សត្រជាច្រើនទ្រង់ប្រមាទ សេចក្តីចម្រើននៃអ្នកជនបទនិងដែនទាំងមូល ក៏វិនាសទ្រុឌទ្រោម ។ ដើម្បីការជាក់

ច្បាស់ក្នុងសេចក្ដីនោះ បណ្ឌិតគួរសម្ដែងឧទ្ទិវាទីជាតក មាតង្គជាតក កុរុជាតក សរភង្គជាតកនិងចេតិយជាតក ។ បទថា **គាមិនោ** សេចក្ដីថា សូម្បីអ្នកស្រុកត្រូវព្រាត់ប្រាស ទ្រុឌទ្រោម វិនាសចាកផ្ទះក៏ព្រោះទោស គឺការប្រមាទច្រើន ។ បទថា **អនាគារា អគារិនោ** សេចក្ដីថា រុក្ខទេវតាពោលថា បព្វជិតវិនាសចាកបដិបទារបស់បព្វជិតក៏ព្រោះទោស គឺសេចក្ដីប្រមាទច្រើន សូម្បីគ្រហស្ថព្រាត់ប្រាសសាបសូន្យចាកការគ្រប់គ្រងផ្ទះនិងធញ្ញាហារជាដើម ជាច្រើនក៏ព្រោះទោស គឺការប្រមាទច្រើន ។ បទថា **តំ វុច្ចតេ អឃំ** សេចក្ដីថា បពិត្រមហារាជ ឈ្មោះថាការវិនាសយសនិងភោគសម្បត្តិ លោកពោលថា ទុំះជាទុក្ខរបស់ព្រះរាជា ព្រោះមិនមានភោគសម្បត្តិ យសរបស់ព្រះរាជាដែលមិនមានទ្រព្យរមែងវិនាស ព្រះរាជាដែលវិនាសយស រមែងបានទទួលទុក្ខយ៉ាងធំ ។

បទថា **នេស ធម្មោ** សេចក្ដីថា បពិត្រមហារាជ ការប្រមាទនេះមិនមែនធម៌របស់បុរាណកក្សត្រឡើយ ។ បទថា **ឥទ្ធំ ផីតំ** សេចក្ដីថា ចោរទាំងឡាយរមែងជញ្ជីមជនបទ ដែលស្ដុកស្ដម្ភដោយបាយទឹកជាដើម បរិបូណ៌ដោយប្រាក់និងមាសជាដើម ។ បទថា **ន តេ បុត្តា** សេចក្ដីថា បពិត្រមហារាជ រាជឱរសដែលបន្តសន្តិវង្សរបស់ព្រះរាជាដែលប្រមាទនឹងមិនមាន ព្រោះអ្នកដែនទាំងឡាយ រមែងមិនថ្វាយស្វេតច្ឆត្រដោយគិតថា ព្រះរាជឱរសរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌នេះ នឹងធ្វើសេចក្ដីចម្រើនអ្វី ដល់ពួកយើងបាន ពួកយើងនឹងមិនថ្វាយស្វេតច្ឆត្រដល់ព្រះរាជឱរសនោះ ព្រះរាជឱរសអ្នកបន្តបវេ-

ណីរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ទាំងនោះ ឈ្មោះថា មិនមានដោយអាការយ៉ាងនេះ ។ បទថា **បរិជិណ្ណំ** បានដល់ សាបសូន្យជុំវិញហើយ ។ បទថា **រាជានំ វាបិ** សេចក្ដីថា ទោះបីព្រះរាជាដែលវិនាសចាកភោគសម្បត្តិនោះជាព្រះរាជា ជនទាំងឡាយរមែងមិនរាប់អានព្រះរាជាអង្គនោះ សូម្បីគង់ព្រះជន្មនៅ ។

បទថា **មន្តិយំ** សេចក្ដីថា ញាតិ មិត្ត សម្លាញ់រមែងមិនសម្គាល់អាការរាប់អាន ដោយចិត្តគោរពថា បុគ្គលនេះ គឺព្រះរាជា ។ បទថា **ឧបជីវន្តា** សេចក្ដីថា ជនទាំងឡាយមានប្រមាណប៉ុណ្ណោះដែលចូលទៅពឹងពាក់ព្រះបរមពោធិសម្ភារ ក៏រមែងមិនឲ្យនូវកាពសំខាន់ ក្នុងវត្ថុដែលខ្លួនគួរឲ្យនូវកាពសំខាន់ដោយចិត្តគោរព ។ ព្រោះហេតុអ្វី ព្រោះព្រះរាជាមិនតាំងនៅក្នុងធម៌ ។ បទថា **សិរី** បានដល់ យសនិងភោគសម្បត្តិ ។ បទថា **តចំ** សេចក្ដីថា កាលពស់រន្សៀសនូវសំណាកចាស់ តែងលះបង់ចោល មិនសម្លឹងមើលទៀតយ៉ាងណា សិរី គឺយសនិងភាគសម្បត្តិ រមែងលះបង់ព្រះរាជាបែបនោះ ។ បទថា **សុសំវិហិតកម្មន្តំ** សេចក្ដីថា ជាអ្នកមិនធ្វើបាបកម្មដោយកាយទ្វារជាដើម ។ បទថា **អភិវឌ្ឍន្តិ** សេចក្ដីថា រមែងចម្រើនមុនគេ ។ បទថា **សឧសភាមិវ** សេចក្ដីថា ដូចហ្វូងគោមានគោឧសភដែលជាមេហ្វូង ។ ពិតហើយ ភោគសម្បត្តិទាំងឡាយរមែងចម្រើនដល់ព្រះរាជាដែលមិនប្រមាទហើយ ដូចហ្វូងគោ មានគោឧសភជាប្រធាន ដូច្នោះ ។

បទថា **ឧបស្សុតឹ** សេចក្ដីថា សូមទ្រង់ចារិកទៅក្នុងសកលរដ្ឋនិងជនបទ

របស់ព្រះអង្គ ដើម្បីស្តាប់ហេតុការណ៍ក្នុងជនបទ ។ បទថា **តត្ថ** សេចក្តីថា កាលទ្រង់យាងទៅក្នុងដែននោះ នឹងបានទតរបស់ដែលគួរទត នឹងបានស្តាប់របស់ដែលគួរស្តាប់ ធ្វើនូវគុណានុគុណចំណែកទ្រង់ឲ្យប្រចក្សហើយ នឹងបានបដិបត្តិបដិបទាដែលជាប្រយោជន៍ដល់ទ្រង់ ។

ព្រះមហាសត្វ ថ្វាយឱវាទព្រះរាជាដោយគាថា ១១ ដោយប្រការដូច្នេះហើយទូលថា សូមទ្រង់យាងទៅពិសោធមើល កុំយឺតយូរឡើយ កុំឲ្យដែនរបស់ទ្រង់វិនាសឡើយ ដូច្នេះហើយត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។ ឯព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ទេវតាហើយ ទ្រង់សង្វេគ ស្អែកឡើងឲ្យអាមាត្យមើលរាជសម្បត្តិ មួយអន្លើដោយបុរោហិត យាងចេញអំពីព្រះនគរ តាមទ្វារទិសខាងកើតយាងទៅអស់ផ្លូវប្រមាណមួយយោជន៍ ក្នុងទីនោះអ្នកស្រុកម្នាក់នាំបន្លាមកអំពីព្រៃស្រះទ្វារផ្ទះទុកនាំបុត្តភរិយាចូលទៅព្រៃ ពេលល្ងាច កាលពួករាជបុរសចៀសចេញទៅហើយ ក៏នាំគ្នាត្រឡប់មកកាន់ផ្ទះរបស់ខ្លួន ត្រូវបន្លាមុតជើងត្រង់ទ្វារផ្ទះទើបអង្គុយប្រហោងដោះបន្លាបណ្តើរ ជេរព្រះរាជាបណ្តើរដោយគាថានេះថា

> ខ្លួនអញត្រូវបន្លាមុតហើយ វេទនាក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យព្រះបាទបញ្ចាលត្រូវសរក្នុងសង្គ្រាម ហើយវេទនាយ៉ាងនោះដែរ ដូច្នេះ ។

ពាក្យជេរនោះ ប្រព្រឹត្តទៅដោយអានុភាពរបស់ព្រះពោធិសត្វនោះឯង ។ គួរជ្រាបថា បុរសចាស់នោះ ត្រូវព្រះពោធិសត្វបណ្តាលចិត្តទើបជេរ ។ ក្នុង

កាលនោះព្រះរាជានិងរាជបុរោហិតក្លែងភេទ ឈរនៅក្បែរបុរសចាស់នោះឯង លុះបុរោហិតបានឮពាក្យរបស់បុរសចាស់ ទើបពោលគាថាដោយសេចក្តីថា

អ្នកជាមនុស្សចាស់មានភ្នែកទុព៌ល មើលរូបមិនឃើញដោយស្រួលទេ បន្ទាមុតអ្នកឯងដោយហេតុណា ( ទោស ) របស់ព្រះរាជាព្រហ្មទត្ត ចំពោះហេតុនោះតើដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មគ្គេយ្យ** បានដល់ មុត អធិប្បាយថា អ្នកឯងត្រូវបន្ទាមុតដោយខ្លួនឯងសោត ក្នុងសេចក្តីនេះ ហេតុអ្វីទើបធ្វើព្រះរាជារបស់យើងឲ្យជាអ្នកមានកំហុសទៅវិញ អ្នកជេរព្រះរាជា ព្រោះព្រះរាជាមានតួនាទីជួយមើលបន្ទាឲ្យអ្នកឬ បុរសចំណាស់បានស្តាប់ដូច្នោះទើបបានពោល ៣ គាថានេះថា

ម្នាលព្រាហ្មណ៍ ក្នុងហេតុនេះទោសរបស់ព្រះរាជាព្រហ្មទត្តមានច្រើន ( បានជា ) ខ្ញុំនោះ ( ធ្លាក់ ) ក្នុងផ្លូវ ( មានបន្ទា ) ព្រោះពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀនដោយពលិកម្ម ( សួយសារអាករ ) មិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ពួកចោរស៊ី ( ប្លន់ ) ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនរបស់ព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។ ម្នាលអ្នក កាលបើភ័យបែបនេះកើតហើយ មនុស្សទាំងឡាយដែលត្រូវភ័យគ្របសង្កត់ តែងនាំយកនូវបន្ទាក្នុងព្រៃមកធ្វើជាទីសម្រាប់ពឹងពួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពហោត្ត** សេចក្ដីថា នែព្រាហ្មណ៍ ខ្ញុំអង្គុយក្នុងផ្លូវដែលមានបន្លា ក្នុងរឿងនេះស្ដេចព្រហ្មទត្តមានកំហុសច្រើនណាស់ ព្រោះកំហុសរបស់ព្រះរាជា អស់កាលមានប្រមាណប៉ុណ្ណោះ អ្នកមិនដឹងទេថាខ្ញុំត្រូវដើរទៅក្នុងផ្លូវមានបន្លា ព្រោះជនបទព្រះរាជាមិនរក្សាទើបមានបន្លា ។

បណ្ដាបទទាំងនោះ បទថា **ខាទន្តិ** បានដល់ ពួកចោរចោមរោមប្លន់ ។ បទថា **តុណ្ឌិយា** សេចក្ដីថា ពេលថ្ងៃ ពួករាជបុរសបៀតបៀន ដោយការសម្លាប់ ដោយការចងជាដើម ទារនូវពន្ធដារមិនប្រកបដោយធម៌ ។ បទថា **កូដរាជស្ស** សេចក្ដីថា ក្នុងដែនរបស់ព្រះរាជាលាមក ។ បទថា **អធម្មិកោ** សេចក្ដីថា មនុស្សទាំងឡាយត្រូវមានការងារបិទបាំងច្រើន ។ បុរសចាស់ហៅបុរោហិតថាព្រាហ្មណ៍ ។ បទថា **មាណវា** បានដល់ មនុស្សទាំងឡាយ ។ បទថា **និល្លេន កានិ** បានដល់ ទីដែលលាក់ខ្លួនពួនអាត្មា ។ បទថា **វនេ អាហត្វ កណ្ដកំ** សេចក្ដីថា ព្រោះភ័យបែបនេះទើបមហាជននាំយកបន្លាមកបិទទ្វារ បោលផ្ទះសម្បែង នាំកូនប្រពន្ធចូលព្រៃ ធ្វើនូវទីពួនរៀងៗខ្លួនក្នុងព្រៃនោះ ។ម្យ៉ាងទៀតបន្លាប្រភេទណាមានក្នុងព្រៃគេក៏នាំគ្នាយកបន្លាប្រភេទនោះមកស្រះការពារផ្ទះ ព្រោះទោសព្រះរាជាយ៉ាងនេះទើបខ្ញុំត្រូវបន្លាមុត លោកកុំកាន់ជើងព្រះរាជាបែបនេះឡើយ ។

ព្រះរាជាស្ដាប់ដូច្នោះទើបត្រាស់ហៅរាជបុរោហិត មកត្រាស់ថា លោកអាចារ្យ បុរសចំណាស់នេះនិយាយត្រូវ កំហុសនេះជាកំហុសយើងពិត មកយើងត្រឡប់ទៅសោយរាជសម្បត្តិដោយធម៌ ។ ទេវតាពោធិសត្វចូលក្នុងរាង

កាយបុរោហិតទូលថា បពិត្រមហារាជ សូមទ្រង់ស៊ើបការខាងមុខបន្តិចទៀតចុះ ។ ព្រះរាជានិងបុរោហិតចេញអំពីស្រុកនោះ ទៅកាន់ស្រុកដទៃទៀតបានឮសំឡេងរបស់ស្រីជរាម្នាក់ ក្នុងរវាងផ្លូវ ។ បានឮថា ស្រីនោះជាស្រីក្រីក្រ ចិញ្ចឹមកូនស្រី ២ នាក់ ដែលចម្រើនវ័យហើយ មិនឲ្យកូនស្រីចេញទៅព្រៃ ខ្លួនឯងសុខចិត្តដើរកាប់ឧសមកអំពីព្រៃ ចិញ្ចឹមកូនស្រីទាំង ២ ។ ថ្ងៃនោះស្រីនោះឡើងដើមឈើ បេះបន្លែ ជាន់មែកឆាប់ក៏ធ្លាក់ចុះមក កាលជេរព្រះរាជាទើបពោលគាថាដោយសេចក្តីថា

ពួកកុមារីជាស្ត្រីគ្មានប្តីរហូតចាស់ ក្នុងដែននៃព្រះរាជាព្រហ្មទត្តណា កាលណាហ្ន៎ព្រះរាជាព្រហ្មទត្តនេះនឹងស្លាប់ទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អប្បតិកា** បានដល់ រកប្តីមិនបាន អធិប្បាយថា បើនាងមានប្តីគង់នឹងបានមើលថែអញ ក្នុងវេលាជរាកាលរបស់ស្តេចលាមកនេះ អញបានទទួលសេចក្តីទុក្ខ កាលណាហ្ន៎វានឹងស្លាប់ ស្រីជរាផ្តាសាព្រះរាជាយ៉ាងនេះដោយអានុភាពរបស់ព្រះពោធិសត្វ ។

កាលបុរោហិតជំទាស់នឹងស្រីជរាទើបពោលគាថាដោយសេចក្តីថា

នែនាងលាមក ជាស្ត្រីមិនឈ្លាសក្នុងឧបាយនៃសេចក្តីចម្រើន ពាក្យនាងជាពាក្យអាក្រក់ ព្រះរាជានឹងស្វែងរកប្តី ឲ្យពួកនាងកុមារីក្នុងទីណា ដូច្នេះ ។

ស្រីជរាបានឮដូច្នោះបានពោល ២ គាថាដោយសេចក្តីថា

នែព្រាហ្មណ៍ ពាក្យរបស់ខ្ញុំមិនអាក្រក់ទេ ខ្ញុំជាស្ត្រីឈ្លាសវៃក្នុង

ផ្លូវចម្រើន ព្រោះពួកអ្នកជនបទ ស្តេចមិនរក្សា ទ្រង់បៀត
បៀនដោយសួយសារអាករ មិនប្រកបដោយធម៌ ។ ក្នុងវេលា
យប់ពួកចោរស៊ី ( ប្លន់ ) ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀត
បៀនស៊ី ក្នុងដែនព្រះរាជាខូចកាចជនមិនប្រកបដោយធម៌មាន
ច្រើន កាលបើរាស្ត្ររស់នៅដោយលំបាក ចិញ្ចឹមប្រពន្ធបាន
ដោយលំបាក តើពួកនាងកុមារីបានប្តីអំពីណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គោវិន្ទុបនា** សេចក្តីថា ខ្ញុំឈ្លាសក្នុងហេតុផល លោកកុំសរសើរព្រះរាជាថោកទាបបែបនេះ ។ បទថា **ទុជ្ជីវេ** សេចក្តីថា កាលដែនមានការគ្រប់គ្រងជីវិតបានដោយលំបាក ការចិញ្ចឹមកូនប្រពន្ធក៏លំបាក មនុស្សទាំងឡាយភ័យខ្លាចនាំគ្នារត់ចូលព្រៃ ។ បទថា **កុតោ ភត្តា កុមារិយា** សេចក្តីថា ស្រីក្រមុំនឹងបានប្តីអំពីណា ។

ព្រះរាជានិងបុរោហិត ស្តាប់ពាក្យរបស់ស្រីចាស់ហើយគិតថា ស្រីនេះនិយាយត្រូវ ទើបនាំគ្នាដើរទៅខាងមុខ បានឮសំឡេងរបស់អ្នកស្រែម្នាក់ ។ បានឮថា កាលអ្នកស្រែនោះកំពុងភ្ជួរស្រែ គោឈ្មោះសាលិយៈត្រូវផាលមុតក៏ដួលចុះ កាលអ្នកស្រែផ្តាសាព្រះរាជាទើបពោលគាថាដោយសេចក្តីថា

គោឈ្មោះសាលិយៈនេះត្រូវផាលមុតហើយ ដេកស្រតឹកយ៉ាងណា សូមឲ្យព្រះរាជាក្រុងបញ្ចាលត្រូវគេសម្លាប់ដោយលំពែងក្នុងសង្គ្រាមដេកយ៉ាងនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថា** សេចក្តីថា គោឈ្មោះសាលិយៈនេះ

បានទទួលទុក្ខវេទនា ដេកស្រតឹកយ៉ាងណា ស្តេចបញ្ចាលចូរដេកជាទុក្ខយ៉ាង នោះ ។ លំដាប់នោះបុរោហិតកាលពោលជំទាស់នឹងអ្នកស្រែនោះបានពោល គាថានេះថា

នែបុរសលាមក អ្នកណាខុសខ្លួនឯងហើយផ្តាសាព្រះរាជា អ្នក
( នោះ ) ឈ្មោះថា ខឹងចំពោះព្រះរាជាព្រហ្មទត្តដោយហេតុ
មិនត្រូវតាមធម៌ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អធម្មេន** សេចក្តីថា ដោយមិនមានហេតុ ផល គឺមិនមានការពិត ។

អ្នកស្រែបានស្តាប់ដូច្នោះហើយបានពោល ៣ គាថាដោយសេចក្តីថា

ម្នាលព្រាហ្មណ៍ ខ្ញុំខឹងចំពោះព្រះរាជាព្រហ្មទត្តដោយហេតុត្រឹម
ត្រូវតាមធម៌ ( ព្រោះថា ) ពួកអ្នកជនបទ ស្តេចមិនរក្សា
ទ្រង់បៀតបៀនដោយសួយសារអាករ មិនប្រកបដោយធម៌ ។
ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀត
បៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌
មានច្រើន ។ ស្ត្រីជាអ្នកនាំបាយមកនោះប្រាកដជាជាំម្តងទៀត
បានជានាំបាយមកក្នុងវេលារសៀល ខ្ញុំកំពុងរកមើលនូវស្ត្រីអ្នក
នាំបាយមក គោឈ្មោះសាលិយៈក៏ត្រូវផាលមុត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មេន** សេចក្តីថា ខ្ញុំជេរដោយមានហេតុផល លោកកុំយល់ថា អ្នកស្រែជេរដោយមិនមានហេតុឡើយ ។ បទថា **សា ឆ្នូន**

**បុន ររ បក្កា វិកាលេ ភត្តមាហរិ** សេចក្តីថា នែព្រាហ្មណ៍ ខ្ញុំគិតថា ស្រីមេផ្ទះនាំបាយមកឲ្យខ្ញុំ ចម្អិនបាយហើយគង់នាំមកអំពីព្រលឹម តែនាងត្រូវពួកខ្ញុំរាជការស្តេចព្រហ្មទត្ត ទារកាស៊ីមិនប្រកបដោយធម៌ ក៏ផ្អាកដំណើរ ត្រូវអង្គាសពួកជនទាំងនោះ ហើយដាំបាយម្តងទៀត ព្រោះហេតុនោះទើបនាំបាយមកក្នុងពេលរសៀល ដូច្នេះហើយខ្ញុំត្រូវសេចក្តីឃ្លានគ្របសង្កត់ វល់តែសម្លឹងមើលអ្នកយកបាយមក ស្រែកដេញគោ យកជន្ទួញចាក់គោ មិនសមហេតុ កាលបើដូច្នោះគោសាលិយៈក៏លើកជើងឡើងប៉ះនឹងផាលទើបត្រូវផាលមុត ហេតុនោះលោកកុំយល់ថា ខ្ញុំប្រហារគោ សេចក្តីនេះឈ្មោះថា ព្រះរាជាថោកទាប ប្រហារហើយនោះឯង លោកកុំពោលគុណរបស់ព្រះរាជានោះឡើយ ។

ព្រះរាជានិងបុរោហិត យាងតទៅទៀត ហើយស្នាក់នៅក្នុងស្រុកមួយកន្លែង ។ ព្រឹកឡើងមេគោទឹកដោះកាចមួយក្បាល យកជើងធាក់អ្នករីតទឹកដោះដួលទៅជាមួយនឹងទឹកដោះ ទើបអ្នករីតទឹកដោះគោផ្តាសាស្តេចព្រហ្មទត្តជាគាថានេះថា

ក្នុងថ្ងៃនេះខ្លួនអញ ( ត្រូវមេគោ ) ធាក់ ទាំងទឹកដោះរបស់
អញក៏ពប់ទៅយ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលនគរ ត្រូវគេ
សម្លាប់ដោយដាវក្នុងសង្គ្រាម វិនាសយ៉ាងនោះចុះ ដូច្នេះ ។

រាជបុរោហិតស្តាប់ដូច្នោះទើបពោលថា

សត្វចិញ្ចឹមនេះចាក់ចោលនូវទឹកដោះ សត្វចិញ្ចឹមបៀតបៀននូវ

ផាល អ្នកដ៏ចម្រើន តិះដៀលយើងដោយហេតុណា កំហុស ដូចម្ដេចរបស់ព្រះរាជាព្រហ្មទត្តក្នុងហេតុនោះ ដូច្នេះ ។

ព្រាហ្មបុរោហិតពោលគាថាចប់ អ្នករឹតទឹកដោះគោបានពោល ៣ គាថា ទៀតថា

ម្នាលព្រាហ្មណ៍ ព្រះរាជាបញ្ចាលនគររបស់រាជត្រកូលព្រហ្មទត្ត គួរអ្នកផងតិះដៀលហើយ ព្រោះថាពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀនដោយស្ទួយអាករ មិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ពួកចោរស៊ី ក្នុងវេលាថ្ងៃពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។ មេគោកាច ផ្ទាំង យើងមិនបានរូតនូវទឹកដោះណាក្នុងកាលមុន ក្នុងថ្ងៃនេះ ឥឡូវនេះពួកយើងក៏ត្រូវពួករាជបុរស អ្នកប្រាថ្នានូវទឹកដោះមករឹបជាន់ ទើបរូតនូវទឹកដោះនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចណ្ឌា** បានដល់ គ្រោតគ្រាត ។ បទថា **អាកឡ្ហា** បានដល់ មានប្រក្រតីរត់គេច ( ផ្ទាំង ) ។ បទថា **ទីរកាមេហិ** សេចក្ដីថា ពួកយើងត្រូវក្នាក់ងាររបស់ព្រះរាជាអធម៌ ប្រើឲ្យរកទឹកដោះមកឲ្យច្រើន បៀតបៀន ចាំបាច់ត្រូវរឹត បើស្ដេចព្រហ្មទត្តនោះ គ្រងរាជដោយធម៌ ភ័យបែបនេះមិនមានដល់ពួកយើងឡើយ ។

ព្រះរាជានិងរាជបុរោហិតគិតថា បុរសនេះនិយាយត្រូវ ទើបចេញពីស្រុក

នេះដើរតាមផ្លូវធំតម្រង់ទៅព្រះនគរដល់ស្រុកមួយ ពួកអ្នកទារពន្ធជារសម្លាប់កូនគោមួយ ដើម្បី ( យកស្បែក ) ធ្វើស្រោមដាវ កាន់យកស្បែកកូនគោទៅ មេគោត្រូវគេសម្លាប់កូន ព្រោះសេចក្តីសោក មិនស៊ីស្មៅ មិនផឹកទឹក ស្រែករោទ៍រកកូន ក្មេងអ្នកស្រុកឃើញដូច្នោះ កាលនឹងផ្តាសាព្រះរាជា ទើបពោលគាថានេះថា

មេគោកំព្រាជាសត្វព្រាត់ប្រាសនេះ ស្ទុះច្នៃឆ្ងាយយ៉ាងណា សូម
ឲ្យព្រះរាជាបញ្ចាលនគរ ព្រាត់ប្រាសនិរាស រីងស្ងួត កន្ទក់
កន្ទេញយ៉ាងនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរិធាវតិ** សេចក្តីថា រត់យំ ។ លំដាប់នោះបុរោហិតពោលគាថាក្រៅអំពីនេះដោយសេចក្តីថា

សត្វចិញ្ចឹមរបស់អ្នករក្សានូវសត្វចិញ្ចឹម ស្ទុះច្នៃឆ្ងាក្តី ស្រែកក្តី
ដោយហេតុណា កំហុសដូចម្តេចរបស់ព្រះរាជាព្រហ្មទត្ត ក្នុង
ហេតុនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្ភមេយ្យ រវេយ្យ វា** សេចក្តីថា សត្វចិញ្ចឹមក៏រត់ទៅមកបានឬយំបាន អធិប្បាយថា នែបា ធម្មតាសត្វចិញ្ចឹមកាលម្ចាស់រក្សាវាក៏រត់បាន មិនស៊ីស្មៅបាន ក្នុងសេចក្តីនេះកំហុសអ្វីរបស់ព្រះរាជានោះ ។

លំដាប់នោះក្មេងអ្នកស្រុកបានពោល ២ គាថាដោយសេចក្តីថា

បពិត្រមហាព្រាហ្មណ៍ កំហុសរបស់ព្រះរាជាព្រហ្មទត្ត ( មាន

ពិត ) ព្រោះថា ពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀត
បៀនដោយស្ទួយសារអាករ មិនប្រកបដោយធម៌ ។ ក្នុងវេលា
យប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី
ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន
ហេតុដូចម្តេចហ្ន៎ កូនគោរបស់យើងកំពុងបៅដោះ មានប្រយោ-
ជន៍ដល់ស្រោមដាវត្រូវរាជបុរសសម្លាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហាព្រហ្មេ** បានដល់ មហាព្រាហ្មណ៍ ។ បទថា **រាជិនោ** បានដល់ របស់ព្រះរាជា ។ បទថា **កថំ នោ** សេចក្តីថា ដូចម្តេច គឺព្រោះហេតុដូចម្តេច ។ បទថា **ទិវទា ហញ្ញតេ បជា** សេចក្តីថា ក្មេងទាំងឡាយជេរព្រះរាជាថា កូនគោកំពុងតែបៅដោះ ត្រូវពួករាជបុរសទាំងនោះសម្លាប់ដោយអំណាចរបស់ព្រះរាជាថោកទាប មេគោនោះយំរកកូន ឥឡូវនេះសូមព្រះរាជានោះទ្រង់យំរៀបរាប់ដូចមេគោទឹកដោះចុះ ។

ព្រះរាជានិងរាជបុរោហិតពោលថា សាធុ ពួកឯងនិយាយបានហេតុផល ហើយចៀសចេញទៅ ។ តមកក្នុងរវាងផ្លូវ ហ្វូងក្អែកកំពុងយកចំពុះចឹកកង្កែបទាំងឡាយក្នុងស្រះមួយកន្លែង កាលព្រះរាជានិងរាជបុរោហិត មកដល់ទីនោះ ព្រះពោធិសត្វក៏បណ្តាលឲ្យកង្កែបទាំងឡាយ ផ្តាសាព្រះរាជា ដោយអានុភាពរបស់ខ្លួនថា

អញជាសត្វកើតក្នុងព្រៃ ត្រូវពួកក្អែកក្នុងស្រុកចឹកស៊ីក្នុងថ្ងៃនេះ
យ៉ាងណា សូមឲ្យស្តេចបញ្ចាលនគរព្រមទាំងបុត្តត្រូវគេកាប់

ក្នុងចម្បាំងជាច់ខ្ទេចខ្ទីយ៉ាងនោះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **គាមិកោហិ** បានដល់ ក្អែកដែលនៅក្នុងស្រុក ។ រាជបុរោហិតបានស្ដាប់ដូច្នោះ កាលនឹងសន្ទនាជាមួយពួកកង្កែបបាន ពោលគាថានេះថា

នែកង្កែប ព្រះរាជាទាំងឡាយក្នុងមនុស្សលោក មិនចាត់ចែងនូវ
ការរក្សាក្នុងពួកសត្វទាំងពួងទេ ពួកក្អែកស៊ីនូវសត្វទាំងរស់ដូច
ជាឯងដោយហេតុណា ព្រះរាជាមិនឈ្មោះថា មិនប្រព្រឹត្តធម៌
ដោយហេតុមានប្រមាណប៉ុណ្ណោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជីវំ** បានដល់ សត្វដែលនៅមានជីវិត ។ បទថា **អទេយ្យុំ** បានដល់ គប្បីទំពាស៊ី ។ បទថា **ធង្កា** បានដល់ ក្អែកទាំងឡាយ អធិប្បាយថា ក្អែកទាំងឡាយគប្បីទំពាស៊ីសត្វមានជីវិត ដោយហេតុត្រឹមណាដោយហេតុត្រឹមប៉ុណ្ណោះ ព្រះរាជាឈ្មោះថាមិនជាអ្នកប្រព្រឹត្តធម៌ក៏មិនមែន ព្រះរាជាអាចចូលទៅកាន់ព្រៃការពារឯងបានដូចម្ដេច កង្កែបបានស្ដាប់ដូច្នោះទើបពោល ២ គាថាដូច្នេះថា

ឱអ្នកជាព្រហ្មចារី តែមានសភាពមិនប្រកបដោយធម៌សោះ
ពោលនូវពាក្យសរសើរចំពោះក្សត្រិយ៍ កាលបើប្រជាជនជា
ច្រើនដែលព្រះរាជារឹបជាន់ អ្នកនៅតែបូជាចំពោះព្រះរាជា ជា
អ្នកមានវាទៈដ៏ក្រៃលែង ។ នែព្រាហ្មណ៍ ប្រសិនបើដែននេះ
មានអ្នករាជការល្អ រមែងជាដែនស្ដុកស្ដម្ភ មានរាស្ត្រីកកាយ

ជ្រះថ្លា ទាំងពួកក្អែក ក៏ស៊ីនូវដុំបាយដ៏ប្រសើរ ជាគ្រឿងបូជា ( របស់មនុស្ស ) ពួកក្អែកមិនគប្បីស៊ីសត្វទាំងរស់ ប្រាកដ ដូចជាខ្ញុំទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្រហ្មចារី** សេចក្ដីថា កាលក្អែកបតិរៀល បុរោហិតទើបពោលថា លោកជាព្រហ្មចារី តែមានជាតិជាអធម៌ហ្ន៎ ។ បទថា **ខត្តិយស្ស** បានដល់ ព្រះរាជាលាមកបែបនេះ ។ បទថា **វិលុម្បមានាយ** សេចក្ដីថា កាលប្រជាជនត្រូវព្រះរាជារឹបជាន់ ម្យ៉ាងទៀតបាឋៈព្រះបាលីក៏ដូចគ្នានេះឯង ។ បទថា **បុប្ផព្បជាយ** សេចក្ដីថា កាលប្រជាជនទូទៅត្រូវរាជការធ្វើឲ្យវិនាស ។ បទថា **ឞ្វផេសិ** បានដល់ លើកតម្កើង ។ បទថា **សុរដ្ឋកំ** សេចក្ដីថា បើដែននេះដែលព្រះរាជាមិនលុះអំណាចឆន្ទាគតិជាដើម មិនញ៉ាំងទសពិធរាជធម៌ឲ្យកម្រើក រក្សា គឺជាដែនមានព្រះរាជាល្អ ។ បទថា **ជីតំ** សេចក្ដីថា មានសន្ទូងបរិបូណ៌ក្នុងកាលភ្លៀងធ្លាក់ចុះដោយប្រពៃ ។ បទថា **មាឆិសំ** សេចក្ដីថា កាលបើដូច្នេះ ក្អែកទាំងឡាយគង់មិនស៊ីសត្វរស់ដូចខ្ញុំទេ ។ ការជេរក្នុងឋានៈទាំង ៦ យ៉ាងនេះ មានដោយអានុភាពរបស់ព្រះពោធិសត្វនោះឯង ។

ព្រះរាជានិងរាជបុរោហិត ស្ដាប់ពាក្យនោះហើយ ត្រិះរិះថា ជនទាំងពួងដោយហោចរហូតដល់ក្អែក ដែលជាសត្វតិរច្ឆាននៅក្នុងព្រៃ នាំគ្នាជេរយើងដូចគ្នា ហើយយាងអំពីនោះទៅកាន់ព្រះនគរ សោយរាជ្យដោយធម៌ តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុញ្ញកម្ម មានទានជាដើម ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែង ដល់ព្រះបាទកោសលហើយត្រាស់ថា បពិត្រមហារាជ ធម្មតាព្រះរាជាគួរលះនូវអំណាចការលុះអគតិ សោយរាជសម្បត្តិដោយធម៌ហើយទ្រង់ប្រជុំជាតកថា គន្ធតិន្ទុកទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា គណ្ឌតិណ្ឌុកជាតក ចប់**

**តឹសនិបាត ចប់**

# ក្បាលទី ៤៩

# សុត្តន្តបិដក ចាលីប្រែ -៦០

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ


សាលិកេទារជាតក .......... .......... .......... .......... .......... ......... ២

អដ្ឋកថា សាលិកេទារជាតក .......... .......... .......... .......... .......... ......... ៥

ចន្ទកិន្នរជាតក .......... .......... .......... .......... .......... ..... ១៦

អដ្ឋកថា ចន្ទកិន្នរជាតក .......... .......... .......... .......... .......... ..... ២០

មហាឧក្កុសជាតក .......... .......... .......... .......... .......... ..... ៣២

អដ្ឋកថា មហាឧក្កុសជាតក .......... .......... .......... .......... .......... ..... ៣៦

ឧទ្ទាលកជាតក .......... .......... .......... .......... .......... .... ៥១

អដ្ឋកថា ឧទ្ទាលកជាតក .......... .......... .......... .......... .......... ... ៥៥

ភិសជាតក .......... .......... .......... .......... .......... ... ៧០

អដ្ឋកថា ភិសជាតក .......... .......... .......... .......... .......... ... ៧៦

សុរុចិជាតក .......... .......... .......... .......... .......... ... ៩៦

អដ្ឋកថា សុរុចិជាតក .......... .......... .......... .......... ............ ១០០

បញ្ចុបោសថិកជាតក .......... .......... .......... .......... ............ ១២១

អដ្ឋកថា បញ្ចុបោសថិកជាតក ....... .......... .......... .......... ............ ១២៤

មហាមោរជាតក .......... .......... .......... .......... ............ ១៣៦

អដ្ឋកថា មហាមោរជាតក .......... .......... .......... .......... ............ ១៤០

តច្ចសូករជាតក .......... .......... .......... .......... ............ ១៥៧

អដ្ឋកថា តច្ចសូករជាតក .......... .......... .......... .......... ............ ១៦១

មហាកណ្ហជាតក .......... .......... .......... .......... ............ ១៧៥

អដ្ឋកថា មហាវាណិជជាតក .......... .......... .......... .......... ................ ១៧៨

សាធិនរាជជាតក .......... .......... .......... .......... ................ ១៨៨

អដ្ឋកថា សាធិនរាជជាតក .......... .......... .......... .......... ................ ១៩២

ទសព្រាហ្មណជាតក .......... .......... .......... .......... ................ ២០៤

អដ្ឋកថា ទសព្រាហ្មណជាតក .......... .......... .......... .......... ................ ២១២

ភិក្ខាបរម្បរជាតក .......... .......... .......... .......... ................ ២៣១

អដ្ឋកថា ភិក្ខាបរម្បរជាតក .......... .......... .......... .......... ................ ២៣៥

## វីសតិនិបាតជាតក

មាតង្គជាតក .......... .......... .......... .......... ................ ២៤៦

អដ្ឋកថា មាតង្គជាតក .......... .......... .......... .......... ................ ២៥១

ចិត្តសម្ភូតជាតក .......... .......... .......... .......... ................ ២៨០

អដ្ឋកថា ចិត្តសម្ភូតជាតក .......... .......... .......... .......... ................ ២៨៥

សិវិរាជជាតក .......... .......... .......... .......... ................ ៣០៧

អដ្ឋកថា សិវិរាជជាតក .......... .......... .......... .......... ................ ៣១៣

សិរីមន្ទជាតក .......... .......... .......... .......... ................ ៣៣៥

អដ្ឋកថា សិរីមន្ទជាតក .......... .......... .......... .......... ................ ៣៤១

រោហនមិគជាតក .......... .......... .......... .......... ................ ៣៤២

អដ្ឋកថា រោហនមិគជាតក .......... .......... .......... .......... ................ ៣៤៧

ហំសជាតក .......... .......... .......... .......... ................ ៣៦៩

អដ្ឋកថា ហំសជាតក .......... .......... .......... .......... ................ ៣៧៣

សត្តិគុម្ពជាតក .......... .......... .......... .......... ............. ៣៨៨

អដ្ឋកថា សត្តិគុម្ពជាតក .......... .......... .......... .......... ............. ៣៩២

ភល្លាតិយជាតក .......... .......... .......... .......... ................ ៤០៧

អដ្ឋកថា កល្យាតិយជាតក .......... .......... .......... .......... ............... ៤១២

សោមទស្សជាតក .......... .......... .......... .......... ............... ៤២៦

អដ្ឋកថា សោមទស្សជាតក .......... .......... .......... .......... ............... ៤៣២

ចម្បេយ្យជាតក .......... .......... .......... .......... ............... ៤៥២

អដ្ឋកថា ចម្បេយ្យជាតក .......... .......... .......... .......... ............... ៤៦០

មហាបលោភនជាតក .......... .......... .......... .......... ............... ៤៨៨

អដ្ឋកថា មហាបលោភនជាតក .......... .......... .......... .......... ............... ៤៩២

បញ្ចបណ្ឌិតជាតក .......... .......... .......... .......... ............... ៥០៤

អដ្ឋកថា បញ្ចបណ្ឌិតជាតក .......... .......... .......... .......... ............... ៥០៩

ហត្ថិបាលជាតក .......... .......... .......... .......... ............... ៥១០

អដ្ឋកថា ហត្ថិបាលជាតក .......... .......... .......... .......... ............... ៥១៥

អយោឃរជាតក .......... .......... .......... .......... ............... ៥៥០

អដ្ឋកថា អយោឃរជាតក .......... .......... .......... .......... ............... ៥៥៦

## តឹសនិបាតជាតក

កឹឆន្ទជាតក .......... .......... .......... .......... ............... ៥៧៥

អដ្ឋកថា កឹឆន្ទជាតក .......... .......... .......... .......... ............... ៥៨០

កុម្ភជាតក .......... .......... .......... .......... ............... ៦០២

អដ្ឋកថា កុម្ភជាតក .......... .......... .......... .......... ............... ៦០៧

ជយទ្ទិសជាតក .......... .......... .......... .......... ............... ៦២៦

អដ្ឋកថា ជយទ្ទិសជាតក .......... .......... .......... .......... ............... ៦៣៣

ឆទ្ទន្តជាតក .......... .......... .......... .......... ............... ៦៦០

អដ្ឋកថា ឆទ្ទន្តជាតក .......... .......... .......... .......... .......... ............ ៦៦៨

សម្ភវជាតក .......... .......... .......... .......... .......... ............ ៧០៥

អដ្ឋកថា សម្ភវជាតក .......... .......... .......... .......... .......... ............ ៧១១

មហាកបិជាតក .......... .......... .......... .......... .......... ............ ៧៣៣

អដ្ឋកថា មហាកបិជាតក .......... .......... .......... .......... .......... ............ ៧៣៨

ទករក្ខសជាតក .......... .......... .......... .......... .......... ............ ៧៥៤

អដ្ឋកថា ទករក្ខសជាតក .......... .......... .......... .......... .......... ............ ៧៥៩

បណ្ឌរកជាតក .......... .......... .......... .......... .......... ............ ៧៦០

អដ្ឋកថា បណ្ឌរកជាតក .......... .......... .......... .......... .......... ............ ៧៦៧

សម្ពុលាជាតក .......... .......... .......... .......... .......... ............ ៧៩២

អដ្ឋកថា សម្ពុលាជាតក .......... .......... .......... .......... .......... ............ ៧៩៨

កណ្ឌុតិណ្ឌុកជាតក .......... .......... .......... .......... .......... ............ ៨២០

អដ្ឋកថា កណ្ឌុតិណ្ឌុកជាតក ................ .......... .......... .......... ............ ៨២៧